# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៦៣

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ចរិយាបិដក

# ៦៣

## បាលីប្រែ ៧៧



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦៣
# ខុទ្ទកនិកាយ ចរិយាបិដក

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ទានបារមិតា
## អកិត្តិចរិយាទី ១

[ ១ ] *អំពើណាដែលតថាគតបានប្រព្រឹត្តហើយ ក្នុងរវាងនេះ អស់ ៤ អសង្ខេយ្យ កំរៃមួយសែនកប្ប អំពើទាំងអស់នោះ ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ តថាគតលើកទុកនូវអំពើ ដែលតថាគតបានប្រព្រឹត្ត ក្នុងភពតូច និងភពធំ ក្នុងកប្បដែល កន្លងទៅហើយ នឹងសំដែងតែអំពើដែលតថាគតបានប្រព្រឹត្តហើយ ក្នុងភទ្ទកប្បនេះ អ្នកចូរស្តាប់តថាគតចុះ ។ កាលដែលតថាគតជា តាបសឈ្មោះ អកិត្តិ ចូលទៅនៅក្នុងព្រៃធំ និងព្រៃតូច ជាព្រៃ ស្ងាត់សូន្យឈឹង ។ កាលនោះ ព្រះឥន្ទអ្នកគ្របសង្កត់ទេវលោក ទ្រង់ក្តៅដោយតេជះ គឺតបធម៌នៃតថាគត ក៏ក្លែងភេទជាព្រាហ្មណ៍ ចូលមករកតថាគតដើម្បីសូមភិក្ខា ។ តថាគតឃើញព្រាហ្មណ៍ ឈរទៀបទ្វារបណ្ណសាលារបស់តថាគត ក៏ឲ្យស្លឹកជង្គៀបក្តាមទាំង អស់ ដែលតថាគតនាំមកពីព្រៃ ជាស្លឹកមិនមានប្រេង មិនមាន*

សេប្រែ ព្រមទាំងភាជន៍ ។ លុះតថាគតឲ្យស្លឹកជន្លៀបក្តាមដល់ព្រាហ្មណ៍ហើយ ក៏ផ្កាប់ភាជន៍ លះបង់នូវការស្វែងរកទៀត ហើយចូលទៅក្នុងបណ្ណសាលា ។ ក្នុងថ្ងៃទី ២ និងថ្ងៃទី ៣ ព្រាហ្មណ៍ចូលមកក្នុងសម្នាក់តថាគតទៀត តែតថាគតមិនញាប់ញ័រ មិនជាប់ជំពាក់ បានឲ្យយ៉ាងនុ៎ះទៀត សរីរៈរបស់តថាគត មិនមានប្លែកភេទ ព្រោះហេតុទាននោះ តថាគតញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅអស់ថ្ងៃនោះ ព្រោះសេចក្តីត្រេកអរ ដោយសុខដែលកើតអំពីបីតិ ។ បើតថាគតបានទក្ខិណេយ្យបុគ្គលដ៏ប្រសើរ អស់ ១ ខែ ឬ ២ ខែទៀត តថាគតមិនញាប់ញ័រ មិនរួញរានឹងឲ្យទានដ៏ឧត្តមឡើយ ។ តថាគតកាលឲ្យទាន ដល់ឥន្ទព្រាហ្មណ៍នោះ ទាំងបានប្រព្រឹត្តនូវអំពើទាំងឡាយនោះ មិនប្រាថ្នានូវយស និងលាភទេ តថាគតប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណ តែម្យ៉ាង ។

## អកិត្តិចរិយាទី ១ ចប់

# អដ្ឋកថា
# បរមត្ថទីបនី
# ខុទ្ទកនិកាយ ចរិយាបិដក

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

## គន្ថារម្ភកថា

*ចរិយាជាប្រយោជន៍ដល់សត្វលោក របស់ព្រះមានព្រះភាគទ្រង់ស្វែងរកគុណធំ អង្គណា ខ្ញុំសូមអភិវាទព្រះមានព្រះភាគអង្គនោះ ដែលមានអានុភាពជាអាចិន្តេយ្យ ជាលោកនាយកដ៏ប្រសើរ ។*

*ចរិយាសម្បូរដោយវិជ្ជា និងចរណៈ នាំសត្វចេញចាកលោក ដោយព្រះធម៌ណា ខ្ញុំសូមនមស្ការនូវព្រះធម៌ដ៏ឧត្តមនោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បូជាហើយ ។*

*ព្រះអរិយសង្ឃណា ជាអ្នកតាំងនៅក្នុងមគ្គ និងផល សម្បូរដោយគុណ មានសីលជាដើម ខ្ញុំសូមនមស្ការព្រះអរិយសង្ឃនោះ ដែលជាស្រែបុណ្យដ៏ប្រសើរ ។*

*បុណ្យណា កើតអំពីនមស្ការព្រះរតនត្រ័យ ខ្ញុំសូមប្រាសចាកអន្តរាយក្នុងទីទាំងពួង ដោយតេជះនៃបុណ្យនោះ ។*

*បារមីណា មានទានបារមីជាដើម ដែលជាបារមីដ៏ឧក្រិដ្ឋ ដែល*

បុគ្គលធ្វើបានដោយលំបាក ដែលព្រះមានព្រះភាគទ្រង់ស្វែងរកគុណធំ គង់នៅក្នុងនិគ្រោធារាម ក្នុងដែនសក្កៈ ទ្រង់ប្រកាសអានុភាពនៃសម្ពោធិចរិយា នៃព្រះបារមីទាំងនោះ ទ្រង់សន្សំទុកក្នុងភទ្ទកប្បនេះ ។

បិដកណា ឈ្មោះថា ចរិយាបដិក ដែលព្រះលោកនាថទ្រង់សម្តែងហើយ ដល់ព្រះធម្មសេនាបតីសារីបុត្ត ដែលជាកំពូលនៃសាវកទាំងពួង ។

ព្រះធម្មសង្គាហកាចារ្យទាំងឡាយ អ្នកស្វែងរកគុណធំបានចងក្រងបិដកណា ដែលសម្តែងដល់ហេតុសម្បត្តិរបស់ព្រះសាស្តា ទុកក្នុងខុទ្ទកនិកាយ កិច្ចពណ៌នាអត្ថដែលធ្វើបានលំបាកខ្ញុំអាចធ្វើបានព្រោះអាស្រ័យន័យ ដែលចែកពោធិសម្ភារនៃបិដកនោះ ។

ព្រោះកិច្ចពណ៌នា ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា នឹងតាំងនូវការវិនិច្ឆ័យរបស់បុព្វាចារ្យ ដែលដូចជាសីហៈនឹងតាំងនៅ ហេតុនោះ ខ្ញុំនឹងរក្សា ហើយនាំមកនូវបិដកនោះ ដែលជាន័យរបស់អដ្ឋកថាបុរាណ អាស្រ័យជាតក ដោយប្រការទាំងពួង ដែលជាទីអាស្រ័យបាន មិនមែនត្រឹមតែជាគន្លងនៃវាចាបរិសុទ្ធដោយល្អ មិនសាំញ៉ាំ ជាគោលវិនិច្ឆ័យអត្ថដ៏ល្អិត របស់ព្រះថេរៈទាំងឡាយ ដែលអាស្រ័យនៅក្នុងអាហារវិហារ ហើយ

នឹងធ្វើកិច្ចពណ៌នាអត្ថនៃចរិយាបិដកនោះ សម្តែងបារមីដែលផ្សេង ដោយនីតត្ថៈ និងនេយ្យត្ថៈតទៅ ។

ដោយប្រការយ៉ាងនេះ សូមសាធុជនទាំងឡាយ កាល ប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅ អស់កាលយូរ ចូរពិចារណាអត្ថនៃ បិដកនោះ ដែលចែកទុកដូច្នេះឯង ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ចរិយាបិដក** ឈ្មោះថា ចរិយាបិដក ដោយអត្ថដូចម្តេច ដោយអត្ថថា ជាតម្រាប្រកាសដល់ចរិយានុភាពរបស់ព្រះសាស្តា ក្នុងជាតិដែលជាអតីត ។ ពិតហើយ **បិដក** សព្ទនេះ មានអត្ថថា តម្រា ដូចក្នុងបទជាដើមថា **មា បិដកសម្បាទនេន** ប្រែថា កុំជឿដោយអាងតម្រា ។ ម្យ៉ាងទៀត ព្រោះបរិយត្តិនោះ ដូចគ្នានឹងភាជនៈ ប្រកាសនូវអានុភាពនៃចរិយាទាំងឡាយ ក្នុងជាតិមុនរបស់ព្រះសាស្តានោះឯង ហេតុនោះ ទើបលោកហៅថា ចរិយាបិដក ។ ពិតហើយ **បិដក** សព្ទ លោកសម្តែងសំដៅដល់ភាជនៈក៏បាន ដូចក្នុងប្រយោគជាដើមថា **អថ បុរិសោ អាគច្ឆេយ្យ កុទាលបិដកំ អាទាយ** កាលនោះ មានបុរសកាន់ចប និងកញ្ជើដើរមក ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងបិដក ៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ចរិយាបិដកនេះ សង្គ្រោះចូលក្នុងសុត្តន្តបិដក ។ ក្នុងនិកាយ ៥ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ខុទ្ទកនិកាយ ចរិយាបិដក សង្គ្រោះចូលក្នុងខុទ្ទកនិកាយ ។ ក្នុងអង្គនៃពាក្យប្រៀនប្រដៅ ៩ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម

វេទល្ល: ចរិយាបិដកសង្គ្រោះចូលក្នុងគាថា ។ ក្នុងធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទត្ថេរជាឃ្លាំងធម៌ បានប្រកាសយ៉ាងនេះថា

សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ ( ក្នុងហឫទ័យ ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ដូច្នេះ ។

ចរិយាបិដកនេះ សង្គ្រោះចូលក្នុងធម្មក្ខន្ធបន្តិចបន្តួច ។ ពោលដោយវគ្គមាន ៣ វគ្គ គឺអកិត្តិវគ្គ ១ ហត្ថិនាគវគ្គ ១ យុធញ្ជយវគ្គ ១ ។ ដោយចរិយាសង្គ្រោះចូលក្នុងចរិយា ៣៥ គឺក្នុងអកិត្តិវគ្គ ១០ ចរិយា ក្នុងហត្ថិនាគវគ្គ ១០ ចរិយា ក្នុងយុធញ្ជយវគ្គ ១៥ ចរិយា ។ ក្នុង ៣ វគ្គ អកិត្តិវគ្គជាវគ្គទី ១ ក្នុងអកិត្តិចរិយា ជាចរិយាទី ១ ។ គាថាដើមរបស់អកិត្តិចរិយានោះ មានដូច្នេះថា

អំពើណាដែលតថាគតបានប្រព្រឹត្តហើយ ក្នុងរវាងនេះ អស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប អំពើទាំងអស់នោះ ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ដូច្នេះ ។

បន្ទាប់អំពីនេះទៅ ជាពណ៌នាអត្ថនៃចរិយាបិដកនោះតាមលំដាប់ ។

## គន្ថារម្ភកថា ចប់

# និទានកថា

[ ១ ] ព្រោះកិច្ចពណ៌នាអត្ថនេះ លោកសម្ដែងនិទានទាំង ៣ នេះ គឺទូរេនិទាន ១ អវិទូរេនិទាន ១ សន្តិកេនិទាន ១ ជាការដែលអ្នកស្ដាប់ទាំងឡាយ រមែងដឹងច្បាស់ដោយល្អតាំងអំពីផ្ដើមរឿង ដូច្នោះ គប្បីជ្រាបការចែកនិទានទាំងនោះដូចតទៅ

កថាមគ្គ តាំងអំពីព្រះមហាពោធិសត្វទ្រង់សន្សំបារមី ទៀបបាទមូលរបស់ព្រះទសពលព្រះនាមទីបង្ករ រហូតដល់ទ្រង់កើតក្នុងស្ថានសួគ៌ជាន់តុសិត ឈ្មោះថា ទូរេនិទាន ។ កថាមគ្គ ដែលប្រព្រឹត្តទៅហើយ តាំងអំពីស្ថានសួគ៌ជាន់តុសិត រហូតដល់សម្រេចសព្វញ្ញុតញ្ញាណត្រង់ពោធិមណ្ឌល ឈ្មោះថា អវិទូរេនិទាន ។ កថាមគ្គ ដែលប្រព្រឹត្តទៅហើយ តាំងអំពីមហាពោធិមណ្ឌល រហូតដល់រឿងដែលកើតឡើងក្នុងបច្ចុប្បន្ន ឈ្មោះថា សន្តិកេនិទាន ។ ក្នុងនិទាន ៣ យ៉ាងនេះ ព្រោះទូរេនិទាន និងអវិទូរេនិទាន ជាសព្វសាធារណៈ ហេតុនោះ និទានទាំងនោះ គប្បីជ្រាបដោយពិស្ដារតាមន័យដែលពោលពិស្ដារហើយ ក្នុងអដ្ឋកថាជាតកនោះឯង ។ តែក្នុងសន្តិកេនិទាន មានសេចក្ដីផ្សេងចេញទៅ ដូច្នោះ គប្បីជ្រាបកថាដោយសង្ខេបនៃនិទាន ៣ យ៉ាង តាំងអំពីខាងដើមដូចតទៅនេះ

ព្រះពុទ្ធជាទីពឹងនៃលោក ជាព្រះពោធិសត្វ បានសន្សំបារមីទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាមទីបង្ករ ទ្រង់បំពេញបារមី ៣០ តាមសមគួរដល់អភិនីហាររបស់ព្រះអង្គ ទ្រង់ញុំាងបារមី ដែលសន្សំមកដើម្បីសព្វញ្ញុតញ្ញាណឲ្យដល់ទីបំផុត ទ្រង់កើតក្នុងស្ថានសួគ៌ជាន់តុសិត រង់ចាំពេល

ដើម្បីបានជាព្រះពុទ្ធ តាំងនៅក្នុងស្ថានសួគ៌ជាន់តុសិតនោះ ដរាបដល់អាយុក្ខ័យ ចុតិអំពីនោះហើយ ទ្រង់បដិសន្ធិក្នុងត្រកូលសក្យរាជ ទ្រង់បានទទួលការចិញ្ចឹមយ៉ាងល្អ ទ្រង់ចម្រើនដោយសិរីដ៏ធំក្រៃលែង ដល់នូវភាពធំពេញវ័យដោយលំដាប់ លុះព្រះជន្មបាន ២៩ វស្សា យាងចេញមហាភិនេស្ក្រមណ៍ ទ្រង់ផ្តើមមហាបធានធំ អស់ ៦ ឆ្នាំ គង់ត្រង់គល់ពោធិ៍ ក្នុងថ្ងៃវិសាខបុណ្ណមី កាលព្រះអាទិត្យមិនទាន់លិច ទ្រង់កម្ចាត់មារ និងពលមារ ក្នុងបឋមយាម ទ្រង់បាននូវបុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់បានទិព្វចក្ខុ ក្នុងបច្ឆិមយាម ទ្រង់ញុំាងកិលេស ១៥០០ ឲ្យអស់ទៅ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ។

បន្ទាប់អំពីនោះ ទ្រង់គង់ក្បែរៗ នោះ ឲ្យ ៧ សប្តាហ៍កន្លងទៅហើយ យាងទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ញុំាងព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធានឲ្យផឹកនូវអមតធម៌ ទ្រង់ញុំាងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ ញុំាងវេនេយ្យសត្វ មានព្រះយសជាដើមឲ្យតាំងនៅក្នុងអរហត្តផល ហើយទ្រង់ប្រគល់ឲ្យព្រះអរហន្ត ៦០ រូប ទៅដើម្បីអនុគ្រោះសត្វលោក ទ្រង់ផ្ទាល់យាងទៅកាន់ឧរុវេលា ញុំាងកទ្ទវគ្គិយ ៣០ រូប ឲ្យតាំងនៅក្នុងសោតាបត្តិផលក្នុងព្រៃកប្បាសជាដើម កាលយាងដល់ឧរុវេលាហើយ ទ្រង់សម្តែងបាដិហារ្យ ៣៥០០ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម និងជដិលបរិវារ ១០០០ មានជដិលទាំងនោះចោមរោមហើយ គង់ក្នុងឧទ្យានលដ្ឋិវ័ន ក្បែរក្រុងរាជគ្រឹះ

ទ្រង់ញ៉ាំងព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ មានព្រះបាទពិម្ពិសារជាប្រធាន ឲ្យឈមចុះក្នុងសាសនា គង់នៅក្នុងវេឡុវនមហាវិហារ ដែលព្រះរាជាមគធៈ ទ្រង់សាងថ្វាយ ។

ក្នុងគ្រាតមក កាលព្រះមានព្រះភាគទ្រង់គង់នៅក្នុងវេឡុវនមហាវិហារយ៉ាងនេះ កាលទ្រង់តាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានក្នុងតំណែងអគ្គសាវក កាលមានការប្រជុំសាវកសន្និបាតយ៉ាងនេះ ។ ព្រះបាទសុទ្ធោទនមហារាជទ្រង់ស្តាប់ថា បានឮថា កូនរបស់អញបំពេញទុក្ករកិរិយាអស់ ៦ ឆ្នាំហើយ បានសម្រេចបរមាភិសម្ពោធិញ្ញាណ ទ្រង់ញ៉ាំងធម្មចក្រដ៏បវរ ឲ្យប្រព្រឹត្តទៅ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់នៅត្រង់វត្តវេឡុវ័ន ទើបទ្រង់បញ្ជូនអមាត្យ ១០ នាក់ មានបុរស ១ ម៉ឺនជាបរិវារតាមលំដាប់ មួយអន្លើដោយព្រះតម្រាស់ថា ចូរពួកអ្នកនាំឱរសរបស់យើងមកឲ្យយើងមើលក្នុងទីនេះ កាលអមាត្យទាំងនោះ ទៅកាន់នគររាជគ្រឹះហើយ បានតាំងនៅក្នុងអរហត្ត ព្រោះព្រះធម្មទេសនារបស់ព្រះសាស្តា ព្រះកាឡុទាយិត្ថេរក្រាបទូលបំណងរបស់ព្រះរាជបិតាឲ្យទ្រង់ជ្រាប ព្រះមានព្រះភាគទ្រង់ចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ចេញអំពីក្រុងរាជគ្រឹះ ដល់ក្រុងកបិលពស្តុដោយចម្ងាយផ្លូវ ៦០ យោជន៍ អស់កាល ២ ខែ ។ បណ្តាស្តេចសក្យៈទាំងឡាយ ទ្រង់ប្រជុំគ្នាដោយគិតថា នឹងគាល់ព្រះញាតិដ៏ប្រសើររបស់ពួកយើង ទើបត្រាស់ឲ្យសាងនិគ្រោធារាម ជាទីគង់របស់ព្រះមានព្រះភាគ និងជាលំនៅរបស់ភិក្ខុសង្ឃ កាន់គ្រឿងក្រអូប និងផ្កាជាដើម ទ្រង់ធ្វើការទទួល អារាធនាព្រះសាស្តាឲ្យ

យានទៅកាន់និគ្រោធារាម ។

ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលស្តេចសក្យៈក្រាលថ្វាយ ។ ស្តេចសក្យៈទាំងឡាយទ្រង់មានះខ្លាំង មិនបានធ្វើសេចក្តីគោរព ។ ព្រះមានព្រះភាគទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ស្តេចសក្យៈទាំងនោះហើយ ទ្រង់ចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញាដើម្បីទម្លាយមានះ ហើយធ្វើស្តេចសក្យៈទាំងនោះ ឲ្យដូចជាភាជន៍សម្រាប់ទទួលព្រះធម្មទេសនា ទ្រង់ចេញចាកសមាបត្តិ ហោះទៅកាន់អាកាស ដូចរោយនូវល្អងធូលីព្រះបាទដាក់លើសិរសារបស់ស្តេចសក្យៈទាំងនោះ ទ្រង់បានធ្វើយមកប្បាដិហារ្យ ដូចគ្នានឹងបាដិហារ្យ ដែលទ្រង់ធ្វើត្រង់គល់គណ្ឌម្ពព្រឹក្ស ។ ព្រះរាជាឃើញភាពអស្ចារ្យនោះ ទ្រង់ព្រះតម្រិះរិះថា ឱរសនេះ ជាបុគ្គលក្រៃលែងក្នុងលោក ដូច្នេះហើយ ទ្រង់ថ្វាយបង្គំ ។ កាលព្រះរាជាថ្វាយបង្គំហើយ ស្តេចសក្យៈទាំងឡាយ មិនអាចព្រងើយបាន ក៏នាំគ្នាថ្វាយបង្គំទាំងអស់ ។

បានឮថា ក្នុងគ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើយមកប្បាដិហារ្យ ទ្រង់បានធ្វើបាដិហារ្យបើកលោក កាលបាដិហារ្យកំពុងប្រព្រឹត្តទៅ ពួកមនុស្ស ឈរក្តី អង្គុយក្តី ក្នុងមនុស្សលោក រមែងមើលឃើញទេវតា សន្ទនាធម៌នូវគ្នានិងគ្នា តាំងអំពីឋានសួគ៌ជាន់ចាតុម្មហារាជិកា ដល់ជាន់អកនិដ្ឋភពដោយភ្នែករបស់ខ្លួន ដោយពុទ្ធានុភាព ក្នុងផែនដីខាងក្រោម រមែងឃើញសត្វទាំងឡាយសោយមហាទុក្ខក្នុងនរកនោះៗ គឺក្នុងមហានរក ៨ រណ្តៅ ក្នុងឧស្សទ-

នរក ១៦ និងក្នុងលោកន្តរិយនរក ។ ពួកទេវតាក្នុងម៉ឺនលោកធាតុ ចូលគាល់ព្រះតថាគត ដោយទេវានុភាពដ៏ធំក្រៃលែង ក៏កើតចិត្តអស្ចារ្យមិនធ្លាប់មាន ផ្គងអញ្ជលីនមស្ការ នាំគ្នាចូលទៅគាល់ បន្លឺគាថាបដិសំយុត្តដោយពុទ្ធគុណ សរសើរ ទះដៃត្រេកអរ ប្រកាសដល់បីតិ និងសោមនស្ស ដូចលោកពោល ( ក្នុងខុទ្ទកនិកាយ ពុទ្ធវង្ស ) ថា

ទេវតាទាំងឡាយណា គឺកុម្មទេវតាក្តី មហារាជិកទេវតាក្តី តាវត្តិង្សទេវតាក្តី យាមាទេវតាក្តី តុសិតទេវតាក្តី និម្មានរតីទេវតាក្តី បរនិម្មិតវសវត្តីទេវតាក្តី ព្រហ្មទាំងឡាយណាក្តី ពួកទេវតានិងព្រហ្មទាំងនោះ រីករាយហើយ បានធ្វើនូវសំឡេង ឲ្យឮកងរំពង ខ្ទរខ្ទារ ដូច្នេះ ។

ក្នុងកាលនោះ ព្រះទសពលទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងកម្លាំងព្រះពុទ្ធរបស់ខ្លួន ដែលមិនមានបុគ្គលប្រៀប ដែលព្រះមហាករុណាដាស់តឿនហើយ ទ្រង់និម្មិតទីចង្ក្រមក្នុងទីប្រជុំម៉ឺនចក្កវាឡលើអាកាស ទ្រង់ឈរក្នុងទីចង្ក្រមសម្រេចដោយកែវគ្រប់យ៉ាង ក្នុងទី ១២ យោជន៍ ទ្រង់សម្តែងបាដិហារ្យ ដែលជាទីប្រជុំនៃភាពអស្ចារ្យរបស់មនុស្ស ទេវតា នាគ និងគ្រុឌ ដើម្បីសម្តែងដល់អានុភាពនៃសមាធិ និងញាណរបស់ព្រះពុទ្ធទាំងឡាយ ដែលមិនទូទៅដល់អ្នកដទៃតាមដែលពោលហើយ ទ្រង់ចង្ក្រមក្នុងទីចង្ក្រមនោះទៀត ទ្រង់សម្តែងធម៌ដែលសមគួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វទាំងឡាយ ដោយពុទ្ធលីលាដែលមិនមានអ្វីប្រៀប ដែលមាន

អានុភាពជាអាចិន្តេយ្យ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ពុទ្ធវង្ស ) ថា

ពួកមនុស្ស ព្រមទាំងទេវតាទាំងទុះ មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនដូចម្តេច ឥទ្ធិពល និងបញ្ញាពលតើដូចម្តេច ពុទ្ធពលរបស់ព្រះសាស្តា ជាប្រយោជន៍ដល់សត្វលោកដូចម្តេច ។ ពួកមនុស្ស ព្រមទាំងទេវតាទាំងទុះ មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនបែបនេះ ឥទ្ធិពល និងបញ្ញាពលបែបនេះ ពុទ្ធពលរបស់ព្រះសាស្តា ជាប្រយោជន៍ដល់សត្វលោកបែបនេះ ។

( ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យនៃមនុស្ស និងទេវតាទាំងនោះដូច្នោះហើយ ) ទើបទ្រង់ព្រះចិន្តាថា បើដូច្នោះ តថាគតនឹងសម្តែងនូវពុទ្ធពលដ៏ប្រសើរ និម្មិតទីចង្ក្រមប្រដាប់ដោយកែវពួដ៏អាកាស ដូច្នេះ ។

កាលព្រះសាស្តាទ្រង់សម្តែងបាដិហារ្យ បង្ហាញដល់ពុទ្ធានុភាពរបស់ព្រះអង្គយ៉ាងនេះហើយ ទ្រង់សម្តែងធម៌ ព្រះធម្មសេនាបតីសារីបុត្តឈរលើភ្នំគិជ្ឈកូដ ក្នុងនគររាជគ្រឹះ ឃើញដោយទិព្វចក្ខុ កើតអស្ចារ្យដែលមិនធ្លាប់មាន ដោយការឃើញពុទ្ធានុភាពនោះ ទើបគិតថា អញនឹងធ្វើពុទ្ធានុភាពឲ្យប្រាកដដល់លោកឲ្យក្រៃលែងឡើង ទើបប្រាប់សេចក្តីនោះដល់ភិក្ខុ ៥០០ ដែលជាបរិវាររបស់ខ្លួន រំពេចនោះឯង ក៏មកតាមអាកាស មួយអន្លើដោយ

បរិវារដោយឫទ្ធិ ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំដោយបញ្ចង្គ-ប្រតិស្ឋាន ផ្គងអញ្ជលីដ៏រុងរឿងដោយប្រពុំម្រាមទាំង ១០ លើសិរសា ក្រាបទូលសួរដល់មហាភិនីហារ និងការបំពេញបារមីរបស់ព្រះតថាគត ។ ព្រះមានព្រះភាគ ទ្រង់ធ្វើព្រះសារីបុត្តនោះឲ្យជាកាយសក្ខី គឺឲ្យជាបន្ទាល់ កាលទ្រង់សម្តែងពុទ្ធានុភាពរបស់ព្រះអង្គដល់ពួកមនុស្ស ដែលប្រជុំគ្នាក្នុងទីនោះ និងទេវតា ព្រហ្ម ក្នុងម៉ឺនចក្កវាឡ ទើបទ្រង់សម្តែងពុទ្ធវង្ស សមដូចលោកពោល ( ក្នុងខុទ្ទកនិកាយ ពុទ្ធវង្ស ) ថា

ព្រះសារីបុត្ត មានប្រាជ្ញាច្រើន ឆ្លៀវឆ្លាសក្នុងសមាធិ និងឈាន ជាអ្នកដល់នូវបារមីនៃប្រាជ្ញា បានក្រាបបង្គំទូលសួរព្រះលោកនាយក ដូច្នេះថា បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់ប្រសើរជាងនរៈ អភិនីហាររបស់ព្រះអង្គ តើដូចម្តេច បពិត្រព្រះអង្គមានព្យាយាម ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ ព្រះអង្គប្រាថ្នាតាំងពីក្នុងកាលណា ។ ទាន សីល នេក្ខម្មៈ បញ្ញា និងវីរិយៈ តើដូចម្តេច ខន្តិ សច្ចៈ និងអធិដ្ឋាន មេត្តា និងឧបេក្ខា តើដូចម្តេច ។ បពិត្រព្រះអង្គមានព្យាយាមធំ ជាលោកនាយក បារមី ១០ តើដូចម្តេច ឧបបារមី ១០ ដែលបរិបូណ៌ តើដូចម្តេច បរមត្ថបារមី ១០ ដែលបរិបូណ៌ តើដូចម្តេច ។ អធិបតីធម៌ទាំងឡាយ អធិដ្ឋាននូវកតិកម្មដូចម្តេច បារមីទាំងឡាយដូចម្តេច អ្នកប្រាជ្ញទាំងឡាយក្នុងលោក តើដូចម្តេច ។ មេត្តា ករុណា មុទិតា និងឧបេក្ខា តើ

ដូចម្ដេច ព្រះពុទ្ធទ្រង់បំពេញពុទ្ធធម៌ ដ៏ពេញលេញដូចម្ដេច ។ ព្រះពុទ្ធទ្រង់មានព្រះសូរសៀងពីរោះ ដូចជាសត្វករវិក ទ្រង់ញ៉ាំងហឫទ័យ ( នៃពួកសត្វ ) ឲ្យរលត់ ញ៉ាំងមនុស្សលោក ព្រមទាំងទេវលោក ឲ្យស្រស់ស្រាយ ដែលព្រះសារីបុត្តសាកសួរហើយ ទ្រង់ដោះស្រាយដល់ព្រះសារីបុត្តនោះវិញ ដូច្នេះ ។

កាលព្រះមានព្រះភាគ ទ្រង់សម្ដែងពុទ្ធវង្សយ៉ាងនេះហើយ ព្រះធម្មសេនាបតីសារីបុត្តបញ្ជូនញាណ មានពុទ្ធគុណជាអារម្មណ៍ថា ឱ ! ការដល់ព្រមដោយហេតុ ការដល់ព្រមដោយផល ការសម្រេចនៃមហាកិនីហាររបស់ព្រះពុទ្ធទាំងឡាយ ព្រះមានព្រះភាគទ្រង់បំពេញបារមីយ៉ាងនេះ អស់កាលមានប្រមាណប៉ុណ្ណេះ ទ្រង់ធ្វើវត្តដែលសត្វលោកធ្វើបានលំបាក នេះជាផលដ៏សមគួរដល់ការសន្សំពោធិសម្ភារ ដែលជាវិធីយ៉ាងនេះ គឺជាព្រះសព្វញ្ញុភាពជាអ្នកជំនាញក្នុងកម្លាំងទាំងឡាយ ភាពជាអ្នកមានឫទ្ធិច្រើនយ៉ាងនេះ ភាពជាអ្នកមានអានុភាពច្រើនយ៉ាងនេះ ។

ព្រះធម្មសេនាបតីសារីបុត្តនោះ រឭកដល់អនុលោមតាមធម៌ដល់ព្រះពុទ្ធគុណ ដែលមានអានុភាពជាអាចិន្តេយ្យយ៉ាងនេះ គឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ ហិរិឱត្តប្បៈ សទ្ធា វិរិយៈ សតិសម្បជញ្ញៈ សីលវិសុទ្ធិ ទិដ្ឋិវិសុទ្ធិ សមថៈ វិបស្សនា កុសលមូល ៣ សុចរិត ៣ សម្មាវិតក្ក ៣ សញ្ញាដែលមិនមានទោស ៣ ធាតុ ៣ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ អរិយមគ្គ ៤ អរិយសច្ច ៤ បដិសម្ភិទា ៤

ចតុយោនិបរិច្ឆេទកញ្ញាណ ៤ អរិយវង្ស ៤ វេសារជ្ជញ្ញាណ ៤ បធានិយង្គៈ ៤ សម្មាសមាធិមានអង្គ ៤ ឥន្ទ្រិយ ៥ ពល ៥ និស្សរណិយធាតុ គឺធាតុនាំចេញ ៥ វិមុត្តាយតនញ្ញាណ គឺញាណមានអាយតនៈរួចផុត ៥ វិមុត្តិបរិបាចនីយធម៌ គឺធម៌ដែលជាការដុះដាលនៃវិមុត្តិ ៥ សារាណីយធម៌ ៦ អនុស្សតិ ៦ គារវៈ ៦ និស្សរណីយធាតុ ៦ សតតវិហារធម៌ ៦ អនុត្តរិយ ៦ និព្វេធភាគិសញ្ញា គឺសញ្ញាជាចំណែកនៃការចាក់ធ្លុះ ៦ អភិញ្ញា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧ អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និទ្ទសវត្ថុ គឺគ្រឿងចង្អុលបង្ហាញ ៧ សញ្ញា ៧ ទក្ខិណេយ្យបុគ្គលទេសនា ៧ ខីណាសវពលទេសនា ៧ បញ្ញាបដិលាភហេតុទេសនា គឺការចង្អុលបង្ហាញនូវហេតុបាននូវបញ្ញា ៨ សម្មត្តៈ ៨ ការឈានកន្លងលោកធម៌ ៨ អារព្ភវត្ថុ ៨ អក្ខណទេសនា ៨ មហាបុរិសវិតក្ក ៨ អភិភាយតនទេសនា គឺការសម្តែងអាយតនៈរបស់បុគ្គលជាអភិភូ ៨ វិមោក្ខ ៨ ធម៌ជាមូលនៃយោនិសោមនសិការ ៩ បារិសុទ្ធិបធានិយង្គៈ គឺអង្គនៃធម៌ជាទីតាំងនៃសេចក្តីព្យាយាមដ៏បរិសុទ្ធ ៩ សត្តាវាស ៩ អាឃាតប្បដិវិន័យ គឺការកម្ចាត់អាឃាត ៩ បញ្ញា ៩ នានត្តទេសនា គឺការសម្តែងសេចក្តីផ្សេងគ្នា ៩ អនុបុព្វវិហារធម៌ ៩ នាថករណធម៌ ១០ កសិណាយតនៈ ១០ កុសលកម្មបថ ១០ សម្មត្តៈ ១០ អរិយវាសៈ ១០ អសេក្ខធម៌ ១០ រតនៈ ១០ កម្លាំងរបស់ព្រះតថាគត ១០ អានិសង្សមេត្តា ១១ អាការរបស់ធម្មចក្ក ១២ ធុតង្គគុណ ១៣ ពុទ្ធញ្ញាណ ១៤ វិមុត្តិបរិបាចនីយធម៌ ១៥ អានាបា-

នសុត្តិ ១៦ អបរម្បរិយធម៌ គឺធម៌ដែលមិនជាបរម្បរា ១៦ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញ្ញាណ ១៩ ញាណវត្ថុ ៤៤ ឧទយព្វយញ្ញាណ ៥០ កុសលធម៌ជាង ៥០ ញាណវត្ថុ ៧៧ មហាវជិរញ្ញាណ ដែលជាចារិត រួមទីងសមាបត្តិ ២ លាន ៤ សែនកោដិ និងទេសនាញាណជាគ្រឿងត្រិះរិះ និងពិចារណាសមន្តបដ្ឋាន ដែលមានន័យមិនមានទីបំផុត និងញាណប្រកាសអធ្យាស្រ័យជាដើមរបស់សត្វទាំងឡាយ មិនមានទីបំផុតក្នុងលោកធាតុ ដែលមិនមានទីបំផុតរបស់ព្រះមានព្រះភាគ ដែលមិនសាធារណៈដល់អ្នកដទៃ មិនឃើញទីបំផុត មិនឃើញប្រមាណ ។ ពិតហើយ ព្រះថេរៈកាលរឭកដល់ទីបំផុតក្តីប្រមាណក្តី នៃគុណទាំងឡាយរបស់ខ្លួនឯង ក៏មិនឃើញ ។ ព្រះថេរៈនោះនឹងឃើញប្រមាណនៃព្រះគុណទាំងឡាយ របស់ព្រះមានព្រះភាគបានដូចម្តេច ។ ពិតហើយ បុគ្គលមានបញ្ញាច្រើន មានញាណមុតស្រួច រមែងជឿពុទ្ធគុណទាំងឡាយ ដោយភាពជាពុទ្ធគុណធំ ។ ដោយប្រការដូច្នេះ ព្រះថេរៈ កាលមិនឃើញប្រមាណ ឬការកំណត់នៃព្រះគុណទាំងឡាយរបស់ព្រះមានព្រះភាគ ទើបសម្រេចចិត្តថា កាលបុគ្គលដូចអញ ដែលតាំងនៅក្នុងសាវកបារមីញាណ គង់មិនអាចកំណត់ព្រះគុណទាំងឡាយដោយញាណបាន នឹងពោលថ្វីដល់មនុស្សពួកនេះ គួរអស្ចារ្យហ្ន៎ សព្វញ្ញុគុណជាអាចិន្តេយ្យមិនមានកំណត់ មានអានុភាពច្រើន ។ម្យ៉ាងទៀត ព្រះសព្វញ្ញុគុណទាំងនេះជាគោចរនៃពុទ្ធញាណតែម្យ៉ាងប៉ុណ្ណោះ ដោយប្រការទាំងពួង មិនបានជាគោចរដល់អ្នកដទៃ ។ សូម្បីព្រះសម្មាសម្ពុទ្ធទាំងឡាយ ក៏មិនអាចពោល

ដោយពិស្ដារបានឡើយ សមដូចលោកពោលថា

ព្រះពុទ្ធ ពោលគុណរបស់ព្រះពុទ្ធផងគ្នា មិនត្រាស់ដល់រឿងដទៃ សូម្បីអស់មួយកប្ប កប្បរមែងអស់ទៅក្នុងរវាងវែងឆ្ងាយ គុណរបស់ព្រះតថាគត មិនទាន់អស់ឡើយ ។

ព្រះសារីបុត្តត្ថេរមានបីតិសោមនស្សជាកម្លាំង កើតឡើងព្រោះអាស្រ័យភាពដែលព្រះពុទ្ធទាំងឡាយ មានគុណធំយ៉ាងនេះ ទើបគិតថា គួរអស្ចារ្យធម៌ធ្វើឲ្យបានជាព្រះពុទ្ធ គឺបារមី មានអានុភាពច្រើន ជាហេតុនៃព្រះពុទ្ធទាំងឡាយបែបនេះ ។ ភាពជាបារមី ទ្រង់បំពេញមកក្នុងជាតិណាហ្ន៎ ឬថា ដល់នូវការចាស់ក្លាមកដូចម្ដេច ណ្ហើយចុះ កាលអញក្រាបទូលសួរសេចក្ដីនេះនឹងធ្វើពុទ្ធានុភាពឲ្យប្រាកដច្បាស់ដល់មនុស្សលោក ព្រមទាំងទេវលោក នេះផ្ដើមអំពីការប្រជុំគ្នាដោយអាការយ៉ាងនេះ ។ ព្រះសារីបុត្តត្ថេរនោះ កាលគិតយ៉ាងនោះហើយ បានក្រាបទូលសួរបញ្ហានេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលឲ្យបានជាព្រះពុទ្ធទាំងនេះ ទ្រង់អប់រំក្នុងជាតិណាហ្ន៎ ឬថា ដល់នូវការចាស់ក្លាមកបានដូចម្ដេច ។

លំដាប់នោះ ព្រះមានព្រះភាគប្រថាប់គង់ពត់ភ្នែនដែលមានទីត ៣ អន្ទើក្នុងរតនចង្រ្កមនោះ ប្រថាប់គង់ រុងរឿងដូចព្រះអាទិត្យទើបនឹងរះ រុងរឿងត្រង់កំពូលភ្នំយុគន្ធរ ដូច្នោះ ទ្រង់សម្ដែងដល់ព្រះសារីបុត្តថា ម្នាលសារីបុត្តពុទ្ធការកធម៌របស់តថាគត បានចម្រើនដុះដាលអំពីភពមកកាន់ភព អំពីជាតិមកកាន់ជាតិ ក្នុងកប្បទាំងពួង ព្រោះធ្វើដោយសេចក្ដីគោរពជាប់តគ្នា និង

ដោយការឧបត្ថម្ភរបស់វីរិយៈ តាំងអំពីសមាទាន ។ តែក្នុងកទុកប្បនេះ ពុទ្ធ-ការកធម៌ទាំងនោះ កើតចាស់ក្លាក្នុងជាតិទាំងនេះ ដូច្នេះហើយ ត្រាស់ធម្ម-បរិយាយដែលមានឈ្មោះជាគម្រប់ពីរថា ចរិយាបិដក ជាទីតាំងនៃរឿងរ៉ាវរបស់ព្រះពុទ្ធ ដោយបទថា **កប្បេ ច សតសហស្សេ** ជាដើម ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគជាទេវតា ក្រៃលែងជាងទេវតា ទ្រង់ចង្ក្រមត្រង់រតនចង្ក្រម ដែលទេវតា និងព្រហ្មជាដើមបូជា ទ្រង់ឈមចុះត្រង់និគ្រោធារាម ហោមរោមដោយព្រះខីណាស្រព ២ ម៉ឺនរូប ប្រថាប់គង់លើបវរពុទ្ធាសនៈដែលគេក្រាល ដែលព្រះសារីបុត្តទូលសួរដូចន័យដែលពោលហើយ ទើបទ្រង់សម្តែងចរិយាបិដក ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ គប្បីជ្រាបថា លោកសម្តែងទូរេនិទាន និងអវិទូរេនិទានដោយសង្ខេប ហើយចង្អុលបង្ហាញនូវសន្តិកេនិទាននៃចរិយាបិដកដោយពិស្តារ ។ ចំណែកទូរេនិទាន នឹងមានច្បាស់ក្នុងការអធិប្បាយរឿងអសង្ខេយ្យ ។

ឥឡូវនេះ នឹងពណ៌នាអត្ថនៃបាលីចរិយាបិដកដែលមានមកដោយន័យថា **កប្បេ ច សតសហស្សេ** ដូច្នេះជាដើម **កប្ប** សព្ទក្នុងបទនោះ ដែលមានឧបសគ្គ និងមិនមានឧបសគ្គ រមែងប្រាកដក្នុងសេចក្តីជាដើមថា វិតក្ក វិធាន បដិភាគៈ បញ្ញត្តិ កាលៈ បរមាយុ សមណវោហារ សមន្តភាវៈ អភិសទ្ទហនៈ ឆេទនៈ វិនិយោគៈ វិនយកិរិយា លេស អន្តរកប្ប តណ្ហាទិដ្ឋិ អសង្ខេយ្យកប្ប និងមហាកប្ប ។

**កប្ប** សព្ទ មកក្នុងវិតក្ក ដូចក្នុងប្រយោគជាដើមថា **នេក្ខម្មសង្កប្បោ**

**អព្យាបាទសង្កប្បោ** ត្រិះរិះក្នុងការចេញចាកកាម ត្រិះរិះក្នុងការមិនព្យាបាទ ដូច្នេះ ៕

មកក្នុង វិធាន ដូចក្នុងប្រយោគជាដើមថា **ចីវរេ តិកប្បំ អាបជ្ជេយ្យ** ដល់នូវកិរិយាកំណាត់ក្នុងចីវរ ដូច្នេះ ៕ អធិប្បាយថា គួរបដិបត្តិតាមទំនៀមយ៉ាងក្រលែង ៕

មកក្នុង បដិភាគ ដូចក្នុងប្រយោគជាដើមថា **សត្ថុកប្បេន វត កិរ ភោ សាវកេន សទ្ធឹ មន្តយមានោ ន ជានិម្ហ** ពុទ្ធោអើយ យើងបានប្រឹក្សាជាមួយនឹងសាវក ដែលទុកស្មើនឹងព្រះសាស្តាផងតើ ដូច្នេះ ៕ ក្នុងបទនោះ មានអធិប្បាយថា ដូចគ្នានឹងព្រះសាស្តា ៕

មកក្នុង បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥធាយស្មា កប្បោ** កប្បមាណពដ៏មានអាយុ ... ក្នុងសាសនានេះ(១) ដូច្នេះ ៕

មកក្នុង កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហារាមិ** តថាគតនោះ□ន៍ តែងនៅអស□បជានិច្ច ដូចេ□ះ៕

មកក្នុង បរមាយុ ដូចក្នុងប្រយោគជាដើមថា **អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា** ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងស្ថិតនៅ គប្បីស្ថិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ដូច្នេះ ៕ កប្បក្នុងទីនេះ លោកបំណងយកអាយុកប្ប ៕

---

១- បិដកខ្មែរខុទ្ទកនិកាយ សុត្តនិបាតជា ឥច្ចាយស្មា កប្បោ កប្បមាណពដ៏មានអាយុទូលសួរថា ៕

មកក្នុង សមណវោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** មា□ភិក□ំងឡាយ តថាគតអនុញ្ញា□ឲ្យភិក□□ទ□□បី ដោយសមណកប្ប ៥ យ៉ា□ ដូចោះ□ ។

មកក្នុង សមន្តភាវៈ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ ជេតវនំ ឱភាសេត្វា** ញ៉ាំងវត្តជេតពនឲ្យភ្លឺស្វាងដោយជុំវិញ ដូច្នេះ ។

មកក្នុង អភិសទ្ទហនៈ គឺការជឿមាំ ដូចក្នុងប្រយោគជាដើមថា **សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ** ការជឿ ការជឿមាំ សទ្ធាដែលស៊ុះទៅ ការជ្រះថ្លាដ៏ក្រៃលែង ដូច្នេះ ។ អធិប្បាយថា ការជឿ ។

មកក្នុង ឆេទនៈ គឺការកាត់ ដូចក្នុងប្រយោគជាដើមថា **អលង្កតោ កប្បិតកេសមស្សុ** មានខ្លួនប្រដាប់ហើយ មានសក់ និងពុកមាត់ កោរកាត់ហើយ ដូច្នេះ ។

មកក្នុង វិនិយោគៈ គឺការស្ទាប់ទៅហើយ ដូចក្នុងប្រយោគជាដើមថា **ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ដូច្នេះ ។

មកក្នុង វិនយកិរិយា គឺការធ្វើក្នុងវិន័យ ដូចក្នុងប្រយោគជាដើមថា **កប្បករណេន អកប្បកតំ សំសិព្វិតំ ហោតិ** ភិក្ខុដេរចីវរដែលមិនបានធ្វើកប្បពិន្ទុភ្ជាប់ជាមួយនឹងចីវរដែលបានធ្វើកប្បពិន្ទុហើយ ដូច្នេះ ។

មកក្នុង លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមិ** បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក ដូច្នេះ ។

មកក្នុង អន្តរកប្ប ដូចក្នុងប្រយោគជាដើមថា **អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ ។បេ។ កប្បំ និរយម្ហិ បច្ចតិ** ភិក្ខុអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់មួយកប្ប ។បេ។ រមែងឆេះនៅក្នុងនរកអស់មួយកប្ប ដូច្នេះ ។

មកក្នុង តណ្ហា និងទិដ្ឋិ ដូចក្នុងប្រយោគជាដើមថា

**ន កប្បយន្តិ ន បុរេក្ខរោន្តិ ធម្មាបិ តេសំ ន បដិច្ឆិតាសេ ន ព្រាហ្មណោ សីលវតេន នេយ្យោ បារង្គតោ ន បច្ចេតិ តាទិ ។**

ព្រះខីណាស្រពទាំងឡាយមិនកំណត់ មិនធ្វើតណ្ហា និងទិដ្ឋិ ឲ្យជាប្រធានទេ ធម៌ទាំងឡាយ គឺទិដ្ឋិមិនបិទបាំង ( បញ្ញា ) របស់ព្រះខីណាស្រពទាំងអម្បាលនោះបានឡើយ ព្រះខីណាសវព្រាហ្មណ៍ មិនប្រព្រឹត្តទៅតាមសីល និងវត្ត ( ដទៃ ) ទេ បានដល់ត្រើយ គឺព្រះនិព្វាន មានសភាពជាតាទិបុគ្គល មិនត្រឡប់មកកាន់ភព ( ថ្មី ) ទៀតឡើយ ដូច្នេះ ។

សេចក្តីពិតយ៉ាងនោះ លោកពោលក្នុង ( មហា ) និទ្ទេសថា ត្រង់ពាក្យថា កំណត់ បានដល់ ការកំណត់ មាន ២ គឺការកំណត់ គឺតណ្ហា ១ ការកំណត់ គឺទិដ្ឋិ ១ ដូច្នេះ ។

មកក្នុង អសង្ខេយ្យកប្ប ដូចក្នុងប្រយោគជាដើមថា **អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ** ក៏បានរឭកបានច្រើនសំវដ្តកប្ប ច្រើន

វិវដ្ដកប្ប ដូច្នេះ ។

មកក្នុង មហាកប្ប ដូចក្នុងប្រយោគជាដើមថា **ចត្តារិមានិ ភិក្ខវេ កប្បស្ស អសង្ខ្យេយ្យានិ** ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះ មាន ៤ ដូច្នេះ ។ កប្បក្នុងទីនេះ បានដល់មហាកប្ប ។

បទសម្រេចក្នុងពាក្យថា កប្បៈ នោះ មានដូច្នេះថា ឈ្មោះថា កប្បៈ ព្រោះរមែងកំណត់ អធិប្បាយថា គប្បីកំណត់មានប្រមាណដែលគួរកំណត់ដោយការប្រៀបជាមួយគំនរគ្រាប់ស្ពៃជាដើមតែម្យ៉ាង ព្រោះមិនអាចគណនាដោយឆ្នាំបានថា ប៉ុណ្ណោះឆ្នាំ ប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណោះពាន់ឆ្នាំ ប៉ុណ្ណោះសែនឆ្នាំ សមដូចលោកពោល ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា បពិត្រព្រះអង្គដ៏ចម្រើន កប្បមានកាលវែងប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ កប្បមានកាលវែងណាស់ កប្បនោះ មិនងាយនឹងរាប់ថា ប៉ុណ្ណោះឆ្នាំ ឬថាប៉ុណ្ណោះរយឆ្នាំ ថាប៉ុណ្ណោះពាន់ឆ្នាំ ឬថាប៉ុណ្ណោះសែនឆ្នាំបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាចធ្វើបាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ ដូចនគរដែលព័ទ្ធដោយកំពែង បណ្ដោយមួយយោជន៍ ទទឹងមួយយោជន៍ កម្ពស់មួយយោជន៍ ពេញដោយគ្រាប់ស្ពៃ ជានគរបិទភ្ជាប់ដោយដុំដីស្អិតកន្ទងមួយរយឆ្នាំៗ ទៅ មានបុរសទៅរើសយកគ្រាប់ស្ពៃមួយគ្រាប់ៗ អំពីនគរនោះ ម្នាលភិក្ខុ គំនរគ្រាប់ស្ពៃដ៏ធំនោះ គប្បីដល់នូវការអស់ទៅ រលីង

ទៅ ដោយសេចក្តីព្យាយាមនេះឆាប់ជាង ឯកប្បមិនទាន់អស់ទៅឡើយ ម្នាលភិក្ខុ កប្បមានកាលវែងយ៉ាងនេះឯង ដូច្នេះ ។

មហាកប្បនោះ សង្គ្រោះដោយ ៤ អសង្ខេយ្យកប្ប ដោយអំណាចនៃសំវដ្តកប្បជាដើម សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះ មាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បសូន្យទៅ តាំងមានឡើង ១ ។ កាលកប្បតាំងនៅក្នុងចន្លោះវិនាសទៅ តាំងមានឡើង ១ ។ កាលកប្បត្រឡប់ចម្រើន តាំងមានឡើងវិញ ១ ។ កាលកប្បតាំងនៅក្នុងចន្លោះចម្រើន តាំងមានឡើង ១ ដូច្នេះ ។

ក្នុងកប្បទាំងនោះ សំវដ្តកប្ប ( កាលកប្បសូន្យទៅ តាំងមានឡើង ) មាន ៣ គឺតេជោសំវដ្តកប្ប ១ អាបោសំវដ្តកប្ប ១ វាយោសំវដ្តកប្ប ១ ។ ដែនសំវដ្តកប្បមាន ៣ គឺ អាភស្សរា ១ សុភកិណ្ហា ១ វេហប្ផលា ១ ។ ក្នុងកាលណា កប្បវិនាសទៅដោយភ្លើង ក្នុងកាលនោះ កប្បខាងក្រោមអំពីអាភស្សរៈ រមែងត្រូវភ្លើងឆេះ ។ ក្នុងកាលណា កប្បវិនាសដោយទឹក ក្នុងកាលនោះ កប្បខាងក្រោមអំពីសុភកិណ្ហា រមែងវិនាសទៅព្រោះទឹក ក្នុងកាលណា កប្បវិនាសដោយខ្យល់ ក្នុងកាលនោះ កប្បខាងក្រោមវេហប្ផលា រមែងត្រូវខ្យល់កម្ចាត់ តែដោយទទឹង ចក្កវាឡមួយសែនកោដិ រមែងវិនាស ដែលលោកពោលថា ជាអាណាខេត្តរបស់ព្រះពុទ្ធទាំងឡាយ រមែងវិនាស ។

ក្នុងសំវដ្ដកប្ប ៣ នោះ ចាប់តាំងអំពីមហាមេឃ ដែលញ៉ាំងកប្បឲ្យវិនាស ដោយអណ្ដាតភ្លើងក្ដី ទឹកក្ដី ខ្យល់ក្ដី អស់ទៅ នេះជាអសង្ខេយ្យ ១ ឈ្មោះថា សំវដ្ដកប្ប ។ ចាប់តាំងអំពីអស់អណ្ដាតភ្លើង ដែលញ៉ាំងកប្បឲ្យវិនាសជាដើម រហូតទល់គ្នានឹងមហាមេឃ ( ភ្លៀង ) តាំងឡើង ពេញចក្កវាឡមួយសែនកោដិ នេះជាអសង្ខេយ្យទី ២ ឈ្មោះថា សំវដ្ដដ្ឋាយីកប្ប ។ ចាប់តាំងអំពីមហាមេឃដល់ព្រម ( កប្បកើតឡើង ) រហូតដល់ព្រះអាទិត្យ និងព្រះចន្ទកើតឡើង នេះជាអសង្ខេយ្យទី ៣ ឈ្មោះថា វិវដ្ដកប្ប ។ ចាប់តាំងអំពីព្រះចន្ទ និងព្រះអាទិត្យកើតឡើង ទៅទល់នឹងមហាមេឃដែលញ៉ាំងកប្បឲ្យវិនាស នេះជាអសង្ខេយ្យទី ៤ ឈ្មោះថា វិវដ្ដដ្ឋាយីកប្ប ។ ក្នុងកប្បទាំងនេះ ការសង្គ្រោះអន្តរកប្ប ៦៤ ដង ឈ្មោះថា វិវដ្ដដ្ឋាយីកប្ប ដោយពាក្យនោះ គប្បីជ្រាបវិវដ្ដកប្បជាដើម កំណត់ដោយកាលស្មើគ្នា ( សំវដ្ដកប្បក្ដី សំវដ្ដដ្ឋាយីកប្បក្ដី វិវដ្ដកប្បក្ដី វិវដ្ដដ្ឋាយីកប្បក្ដី មានចំណែកស្មើៗ គ្នា ) ។ អាចារ្យពួកមួយពោលថា អន្តរកប្ប ២០ ជា ( អសង្ខេយ្យ ) កប្ប ១ ។ ដោយប្រការយ៉ាងនេះ អសង្ខេយ្យកប្ប ៤ ជា ១ មហាកប្ប ដោយហេតុនោះ ទើបខ្ញុំពោលថា ១ មហាកប្ប សង្គ្រោះដោយអសង្ខេយ្យកប្ប ៤ ដោយអំណាចសំវដ្ដកប្បជាដើម ។

ម្យ៉ាងទៀត បទថា **កប្បេ** ជាទុតិយាវិភត្តិ ពហុវចនៈ ប្រើជាអច្ចន្តសំយោគ ប្រែថា អស់កប្ប ។ បទថា **សតសហស្សេ** សម្ដែងដល់បុំលិង្គ ដោយភ្ជាប់ជាមួយសព្ទថា **កប្ប**។ ក្នុងពាក្យនេះជាពហុវចនៈ ប្រើជាអច្ចន្ត-

សំយោគដូចគ្នា ។ ទាំងពីរបទនេះ ជាអធិករណៈដូចគ្នា ។ ក្នុងបទថា **ចតុរោ ច អសង្ខិយេ** នេះ ក៏មានន័យនេះឯង ។ មួយវិញទៀត បទថា **អសង្ខិយេ** នេះ ដោយឧបករណ៍ រមែងឲ្យដឹងសេចក្ដីនេះថា អសង្ខេយ្យនៃកប្ប ព្រោះមិនពោលពាក្យដទៃ និងព្រោះពោលដល់កប្បប៉ុណ្ណោះ ។ ពិតហើយ ការវៀរបទដែលពោលហើយ កាន់យកបទណាមួយ ដែលមិនបានពោល មិនសមគួរ ។ ច សព្ទ ជាសម្បិណ្ឌនត្ថ គឺបូកខាងក្រោយចូលជាមួយខាងមុខ ។ ក្នុងសេចក្ដីនេះ មានអត្ថថា ៤ អសង្ខេយ្យនៃមហាកប្ប និងមួយសែនមហាកប្ប គប្បីជ្រាបសេចក្ដីក្នុងបទថា **អសង្ខិយេ** នេះ ឈ្មោះថា អសង្ខេយ្យ ព្រោះមិនអាចរាប់បាន អធិប្បាយថា ហួសនឹងគណនា អាចារ្យពួកខ្លះពោលថា បទថា **អសង្ខេយ្យំ** ជាការរាប់វិសេសម្យ៉ាង ។ អាចារ្យពួកនោះពោលថា ពិន្ទុមហាកម្ពាំង ១០ វៀរឋានៈ ៥៩ ដែលមានពិន្ទុមហាកម្ពាំងជាទីបំផុត តាំងអំពីរួមចូលគ្នាតែមួយ ឈ្មោះថា អសង្ខេយ្យ ក្នុងលំដាប់អដ្ឋានៈ ៦០ ។ សេចក្ដីនោះ មិនត្រឹមត្រូវ ។ ការគណនាវិសេស ឈ្មោះថា ក្នុងវាងឋានៈដែលរាប់បាន ក្នុងវាងឋានៈ ១ ឈ្មោះថា អសង្ខេយ្យ ព្រោះមិនមានការគណនាវិសេសនោះ គប្បីរាប់មិនបាន ព្រោះហេតុនោះ ទើបសេចក្ដីនោះខុស ។ ការដែលកប្បមាន ៤ យ៉ាង ក្នុងភាពជាអសង្ខេយ្យកប្ប ព្រោះជាកប្បរាប់មិនបាន មិនត្រឹមត្រូវមិនមែនឬ ឆ្លើយថា មិនត្រឹមត្រូវ ក៏មិនមែន ព្រោះអសង្ខេយ្យកប្ប លោកប្រាថ្នាហើយក្នុងឋានៈ ៤ ។ ក្នុងបទនោះ គប្បីជ្រាបការចង្អុលបង្ហាញតាំងអំពីដើមដូចតទៅ

បានឮមកថា ក្នុងកប្បមួយនាអតីតកាល ព្រះសម្មាសម្ពុទ្ធ ៤ អង្គ គឺ ព្រះតណ្ហង្ករ ១ ព្រះមេធង្ករ ១ ព្រះសរណង្ករ ១ ព្រះទីបង្ករ ១ ទ្រង់កើតឡើងក្នុងលោកតាមលំដាប់ ក្នុងព្រះសម្មាសម្ពុទ្ធទាំងនោះ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមទីបង្ករ មាននគរឈ្មោះអមរវតី ។ សុមេធព្រាហ្មណ៍អាស្រ័យនៅក្នុងនគរនោះ ជាអ្នកមានជាតិបរិសុទ្ធទាំងពីរចំណែក គឺខាងចំណែកមាតា និងបិតា អស់ ៧ ជួរត្រកូល មិនវង្វៀសដោយជាតិ មានរូបស្អាត គួរសរសើរ គួរជ្រះថ្លា ដល់ព្រមដោយពណ៌សម្បុរល្អក្រៃលែង ។ សុមេធព្រាហ្មណ៍មិនបានធ្វើការងារដទៃ រៀនសិប្បៈរបស់ព្រាហ្មណ៍តែម្យ៉ាង ។ មាតាបិតាអនិច្ចកម្មតាំងអំពីសុមេធៈនៅកំលោះ ។ កាលនោះ រាសិវឌ្ឍកៈស្មៀនរបស់សុមេធបណ្ឌិត នាំបញ្ជីទ្រព្យមកឲ្យ ហើយបើកឃ្លាំងទ្រព្យដែលពេញដោយមាស ប្រាក់ កែវមណី កែវមុក្តាជាដើម ហើយប្រាប់ទ្រព្យទាំងអស់ តាំងអំពី ៧ ជួរត្រកូលថា បពិត្រកុមារ ទ្រព្យប្រមាណប៉ុណ្ណេះ ជារបស់មាតាលោក ទ្រព្យប្រមាណប៉ុណ្ណេះ ជារបស់បិតាលោក ប្រមាណប៉ុណ្ណេះ ជារបស់ជីដូនជីតា និងទួតរបស់លោក ហើយពោលថា សូមលោកគ្រប់គ្រងទ្រព្យទាំងនេះចុះ ។ សុមេធបណ្ឌិតគិតថា ញាតិទាំងឡាយ មានមាតាបិតាជាដើមរបស់អញ ប្រមូលទ្រព្យនេះទុកជាច្រើន តែទោះជាយ៉ាងនេះ កាលទៅកាន់បរលោក មិនបានកាន់យកសូម្បី ១ កហាបណៈ អញគួរធ្វើហេតុនៃការកាន់យកទៅឲ្យបាន ដូច្នេះ ទើបទូលដល់ព្រះរាជាហើយ ឲ្យវាយស្គរប្រកាសទូទៅក្នុងនគរ បានឲ្យទានដល់មហាជនហើយ ទៅកាន់ហិមវន្ត-

ប្បទេស បួសជាតាបស កន្លងទៅបាន ៧ ថ្ងៃ ទើបញ៉ាំងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងដោយសមាបត្តិវិហារធម៌ ។

ក្នុងកាលនោះ ព្រះទសពលព្រះនាមទីបង្ករ សម្រេចបរមាភិសេកសម្ពោធិញ្ញាណ ញ៉ាំងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅ ហោមរោមដោយព្រះខីណាស្រពបួនសែនរូប ចារិកទៅដោយលំដាប់ដល់រម្មវតីនគរ ទ្រង់អាស្រ័យនៅត្រង់សុទស្សនមហាវិហារ មិនឆ្ងាយអំពីនគរនោះ ។ អ្នកនគររម្មវតីបានឮថា ព្រះសាស្តាយាងដល់នគររបស់ពួកយើងហើយ គង់នៅក្នុងសុទស្សនមហាវិហារ ទើបនាំគ្នាកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម អង្គុយត្រង់ចំណែកម្ខាង ស្តាប់ព្រះធម្មទេសនា ហើយនិមន្តដើម្បីសោយភត្តក្នុងថ្ងៃស្អែក នាំគ្នាក្រោកចាកអាសនៈត្រឡប់ទៅ ។ ស្អែកឡើង អ្នកនគរទាំងនោះ ត្រៀមមហាទាន តាក់តែងនគរ ត្រេកអរ រីករាយ ធ្វើនូវការសម្អាតផ្លូវដែលព្រះទសពលយាងមក ។

ម្យ៉ាងទៀត ក្នុងកាលនោះ សុមេធតាបសមកតាមអាកាស ឃើញពួកមនុស្សទាំងនោះត្រេកអរ ទើបសួរថា អ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកសម្អាតផ្លូវនេះដើម្បីអ្នកណា កាលពួកមនុស្សប្រាប់ថា ពួកខ្ញុំធ្វើនូវការសម្អាតផ្លូវដើម្បីព្រះសម្មាសម្ពុទ្ធយាងមក ។ ព្រោះអំណាចដែលខ្លួនសន្សំបារមីមកក្នុងព្រះពុទ្ធទាំងឡាយក្នុងអតីត គ្រាន់តែបានឮពាក្យថា **ពុទ្ធោ** ក៏កើតបីតិសោមនស្ស ចុះអំពីអាកាសក្នុងវេលានោះឯង ហើយពោលថា ចូរអ្នកទាំងឡាយ

ឲ្យឱកាសដល់ខ្ញុំខ្លះ ខ្ញុំនឹងធ្វើការសម្អាតផងដែរ កាលពួកមនុស្សឲ្យឱកាស ហើយ គិតថា សេចក្តីពិត អញល្មមធ្វើផ្លូវនេះឲ្យវិចិត្រដោយរតនៈ ៧ ដោយឫទ្ធិ ហើយតាក់តែងបាន តែថ្ងៃនេះ អញគួរធ្វើសេចក្តីខ្វល់ខ្វាយផ្លូវកាយ អញនឹងកាន់យកបុណ្យសមគួរដល់កាយ ទើបនាំស្មៅ និងសំរាមជាដើមចេញ យកធូលីមកពោយឲ្យស្មើ ធ្វើឲ្យស្អាត ។ កាលធ្វើការសម្អាតទីនោះមិនទាន់ស្រេច ព្រះមានព្រះភាគទីបង្ករ ចោមរោមដោយព្រះខីណាស្រព ដែលបានអភិញ្ញា ៦ សុទ្ធតែជាអ្នកមានមហានុភាព ៤ សែនរូប យាងមកដល់ផ្លូវនោះ ។

សុមេធបណ្ឌិតគិតថា ព្រះសម្មាសម្ពុទ្ធ និងសាវករបស់ព្រះពុទ្ធ កុំបីជាន់ភក់ ទើបរលាស់សំពត់សម្បកឈើ បន្ទះស្បែក និងផ្នួងសក់ ខ្លួនឯងដេកផ្កាប់មុខបែរក្បាលទៅរកព្រះមានព្រះភាគ ។ សុមេធបណ្ឌិតគិតយ៉ាងនេះថា បើអញប្រាថ្នាជាសាវករបស់ព្រះមានព្រះភាគអង្គនេះ នឹងទម្លាយកិលេសបានក្នុងថ្ងៃនេះឯង ប្រយោជន៍អ្វីដោយការដេកឱយៈធំ គឺសង្សាររបស់អញត្រឹមម្នាក់ឯង បើដូច្នោះ អាត្មាអញគប្បីជាព្រះសម្មាសម្ពុទ្ធបែបនេះញុំាងលោក ព្រមទាំងទេវលោកឲ្យឆ្លងនូវអន្លង់ធំ គឺសង្សារ ។ សុមេធបណ្ឌិតតាំងចិត្តដោយអភិនីហារប្រកបដោយអង្គ ៨ ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគ យាងមកប្រថាប់ឈរខាងក្បាលដំណេករបស់សុមេធបណ្ឌិតនោះ ទ្រង់ជ្រាបបំណង និងការសម្រេចនៃសេចក្តីប្រាថ្នារបស់សុមេធបណ្ឌិតនោះ ទ្រង់ព្យាករការប្រព្រឹត្តទៅទាំងអស់របស់

ព្រះមានព្រះភាគថា បន្ទាប់អំពីនេះទៅ ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប សុមេធបណ្ឌិតនេះ នឹងបានជាព្រះសម្មាសម្ពុទ្ធព្រះនាមគោតម ដូច្នេះហើយ យានទៅ ។

បន្ទាប់អំពីនោះ ព្រះសម្មាសម្ពុទ្ធដទៃទ្រង់កើតឡើងតាមលំដាប់ មានព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈជាដើម រហូតដល់ព្រះទសពលព្រះនាមកស្សបៈជាទីបំផុត ទ្រង់ព្យាករព្រះមហាសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។ កាលព្រះពោធិសត្វនៃយើងបំពេញបារមី ព្រះសម្មាសម្ពុទ្ធ ទ្រង់កើតឡើង ២៤ អង្គ ។ ក្នុងកប្បដែលព្រះទសពលព្រះនាមទីបង្ករ ទ្រង់កើតឡើង មានព្រះពុទ្ធ ៣ អង្គទៀត ។ ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងនោះ មិនមានការព្យាករព្រះពោធិសត្វ ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងនោះ មិនបានប្រារព្ធក្នុងទីនេះ តែក្នុងបុរាណអដ្ឋកថា ដើម្បីសម្តែងដល់ព្រះសម្ពុទ្ធទាំងឡាយតាំងអំពីកប្បនោះ ទើបលោកពោលគាថានេះថា

ព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ ព្រះទីបង្ករ ដែលជាសម្មាសម្ពុទ្ធ និងព្រះកោណ្ឌញ្ញៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈដ៏ជាមុនី ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សី ទ្រង់មានយសធំ ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថៈ ជាលោកនាយក ព្រះតិស្សៈ ព្រះផុស្សៈ ជាព្រះសម្មាសម្ពុទ្ធ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះ

កក្កុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈជានាយក ព្រះសម្មា-
សម្ពុទ្ធទាំងឡាយនេះ ប្រាសចាករាគៈ តាំងមាំហើយ មានរស្មី
១០០ កម្ចាត់បង់នូវងងឹតធំ រុងរឿងដូចគំនរភ្លើង ព្រះសម្មាសម្ពុទ្ធ
ទាំងនោះ មួយអន្លើដោយសាវកទាំងឡាយ បានបរិនិព្វានហើយ
ដូច្នេះ ។

ក្នុងរវាងព្រះទសពលព្រះនាមទីបង្ករ និងព្រះទសពលព្រះនាមកោណ្ឌញ្ញៈ លោកទទេចាកព្រះពុទ្ធអស់មួយអសង្ខេយ្យមហាកប្ប ។ ក្នុងរវាងព្រះមានព្រះភាគព្រះនាមកោណ្ឌញ្ញៈ និងព្រះមានព្រះភាគព្រះនាមមង្គលៈក៏ដូចគ្នា ក្នុងរវាងព្រះមានព្រះភាគព្រះនាមសោភិតៈ ព្រះនាមអនោមទស្សី ព្រះនាមនារទៈ ព្រះនាមបទុមុត្តរៈក៏ដូចគ្នា សមដូចលោកពោលក្នុងពុទ្ធវង្សថា

កប្បជាចន្លោះនៃព្រះពុទ្ធ ២ ព្រះអង្គនុ៎ះ គឺព្រះពុទ្ធទីបង្ករៈ មាន
ព្រះភាគ និងព្រះសាស្តាព្រះនាមកោណ្ឌញ្ញៈ ជាកប្បគេមិនអាច
រាប់បានឡើយ ។

ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមកោណ្ឌញ្ញៈមក មានព្រះពុទ្ធជា
នាយក ព្រះនាមមង្គលៈ ( ទ្រង់ត្រាស់ឡើង ) កប្បជាចន្លោះនៃ
ព្រះពុទ្ធទាំង ២ ព្រះអង្គនុ៎ះ បុគ្គលមិនអាចរាប់បានឡើយ ។

ខាងក្រោយនៃព្រះសម្ពុទ្ធ ព្រះនាមសោភិតៈមក មានព្រះពុទ្ធ
ព្រះនាមអនោមទស្សី ជាមហាមុនី ត្រាស់ឡើងក្នុងលោក កប្ប
ជាចន្លោះនៃព្រះពុទ្ធទាំង ២ អង្គនោះ គេមិនអាចរាប់បានឡើយ។

កប្បជាចន្លោះនៃព្រះពុទ្ធ ទាំងពីរព្រះអង្គនោះ គឺព្រះមានជោគ ព្រះនាមនារទៈ និងព្រះសាស្តា ព្រះនាមបទុមុត្តរៈ គេមិនអាចរាប់បានឡើយ ។

ដោយប្រការដូច្នេះ ទើបលោកពោលថា **ចតុរោ ច អសង្ខិយេ** ៤ អសង្ខេយ្យ ដោយការកន្លងនូវការគណនាមហាកប្ប ក្នុងឋានៈ ៤ ក្នុងភាពជាអសង្ខេយ្យកប្ប ព្រោះភាពជាកប្បដែលកន្លងនូវការគណនា ។ គប្បីជ្រាបថា លោកមិនបានពោលដោយសង្ខ្យាវិសេសនៈ គឺ ការរាប់ដែលប្លែក ។ ម្យ៉ាងទៀត ព្រោះ ៣០០០០ កប្ប ក្នុងរវាងព្រះទសពលព្រះនាមបទុមុត្តរៈ និងព្រះទសពលព្រះនាមសុមេធៈ[១] ។ ៦៩៨៨២ កប្ប ក្នុងរវាងព្រះទសពលព្រះនាមសុជាតៈ និងព្រះទសពលព្រះនាមបិយទស្សី[២] ។ ២០ កប្ប ក្នុងរវាងព្រះទសពលព្រះនាមធម្មទស្សី និងព្រះទសពលព្រះនាមសិទ្ធត្ថៈ[៣] ។ ១ កប្ប ក្នុងរវាងព្រះទសពលព្រះនាមសិទ្ធត្ថៈ និងព្រះទសពលព្រះនាមតិស្សៈ ។ ៦០ កប្ប ក្នុងរវាងព្រះមានព្រះភាគព្រះនាមវិបស្សី និងព្រះមាន

---

១- រាប់អំពីកទ្ទកប្បនេះ ទៅទល់គ្នានឹងព្រះបទុមុត្តរៈ ជា ១០០០០០ កប្ប ទល់គ្នានឹងព្រះសុមេធៈ ជា ៣០០០០ កប្ប ចន្លោះពី ៣០០០០ កប្បទៅ ១០០០០០ កប្ប គួរតែជា ៧០០០០ កប្ប ។ ២- រាប់អំពីភត្តកប្បនេះ ទៅទល់គ្នានឹងព្រះសុជាតៈ ជា ៣០០០០ កប្ប ទល់គ្នានឹងព្រះបិយទស្សី ១៨០០ កប្ប ចន្លោះពី ១៨០០ កប្បទៅ ៣០០០០ កប្ប គួរតែជា ២៨២០០ កប្ប ។ ៣- រាប់អំពីភត្តកប្បនេះ ទៅទល់គ្នានឹងព្រះធម្មទស្សី ជា ១៨០០ កប្ប ទល់គ្នានឹងព្រះសិទ្ធត្ថៈ ៩៤ កប្ប ចន្លោះពី ៩៤ កប្បទៅ ១៨០០ កប្ប គួរតែជា ១៧០៦ កប្ប តែក្នុងទីនេះ យើងរក្សាទុកតាមបាលីអដ្ឋកថា ។

ព្រះភាគព្រះនាមសិខី ។ ៣០ កប្ប ក្នុងរវាងព្រះមានព្រះភាគព្រះនាមវេស្សភូ និងព្រះមានព្រះភាគព្រះនាមកកុសន្ធៈ ។ និង ១ សែនមហាកប្បមួយអន្លើដោយកប្បដែលព្រះពុទ្ធទាំងឡាយនោះៗ ទ្រង់កើតខាងក្រោយ តាំងអំពីកប្បដែលព្រះទសពលព្រះនាមបទុមុត្តរៈទ្រង់កើតឡើង និងដោយកទូកប្បនេះ ដោយប្រការដូច្នេះ ទើបលោកពោលថា **កប្បេ ច សតសហស្សេ** អស់សែនកប្ប សំដៅដល់មហាកប្បទាំងនោះ ។ កាលពោលអត្ថនេះឲ្យពិស្តារ គួរនាំបាលីពុទ្ធវង្សទាំងអស់មកពណ៌នា ដូច្នោះ យើងនឹងរក្សាចិត្តរបស់មហាជនដែលខ្លាចសេចក្តីពិស្តារ ទើបមិនពោលឲ្យពិស្តារ ។ បុគ្គលត្រូវការសេចក្តីពិស្តារ គប្បីរៀនចាក ( គម្ពីរ ) ពុទ្ធវំសៈ ។ ម្យ៉ាងទៀតក្នុងទីនេះ កថាមគ្គណាដែលគួរពោល កថាមគ្គនោះ ក៏គប្បីជ្រាបដោយន័យដូចដែលបានពោលហើយ ក្នុងអដ្ឋកថាធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី និងអដ្ឋកថាជាតកនោះឯង ។

**អន្តរ** សព្ទ ក្នុងបទថា **ឯត្ថន្តរេ** នេះ មកក្នុង ហេតុ ដូចក្នុងប្រយោគជាដើមថា **តទីតីរេសុ សណ្ឋាណេ សភាសុ រថិយាសុ ច ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ** ជនទាំងឡាយមកប្រជុំនិយាយគ្នា ទៀបឆ្នេរស្ទឹងទាំងឡាយផង ក្នុងរោងសម្រាប់សម្រាកផង ក្នុងរោងសម្រាប់ប្រជុំគ្នានិយាយផង នាផ្លូវច្រកផង ហើយនិយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ដូច្នេះ ។

មកក្នុង ខណៈ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា មំ ភន្តេ**

**អញ្ញតរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តិ** បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជន៍បានឃើញខ្ញុំព្រះអង្គ ក្នុងពេល ( ខណៈ ) មានផ្លេកបន្ទោរ អធិប្បាយថា ក្នុងខណៈមានផ្លេកបន្ទោរ ដូច្នេះ ។

មកក្នុង ចិត្ត ដូចក្នុងប្រយោគជាដើមថា **យស្សន្តរតោ ន សន្តិ កោបា** ការកម្រើកមិនមានក្នុងចិត្តរបស់បុគ្គលណា ដូចេះ ។

មកក្នុង ចន្លោះ ដូចក្នុងប្រយោគជាដើមថា **អន្តរា ច គយំ អន្តរា ច ពោធឹ** ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង ដូច្នេះ ។

មកក្នុង កណ្តាល ដូចក្នុងប្រយោគជាដើមថា **ន ឧបជ្ឈាយស្ស ភណមានស្ស អន្តរន្តរា កថា ឱបាតេតព្វា** ឧបជ្ឈាយ៍កំពុងពោលសទ្ធិវិហារិកមិនត្រូវនិយាយស្កាត់ ( ត្រង់កណ្តាល ) ពាក្យនោះឡើយ ដូច្នេះ ។ ក្នុងទីនេះ គប្បីឃើញថា មកក្នុងអត្ថថា កណ្តាលនោះឯង ព្រោះហេតុនោះ ទើបមានសេចក្តីថា ក្នុងវាងនេះ គឺក្នុងកណ្តាល ។ ពាក្យនេះ ជាការដែលលោកពោលថា ក្នុងមហាកប្ប ព្រះមានព្រះភាគនៃយើងជាសុមេធបណ្ឌិត បានធ្វើមហាភិនីហារ ប្រកបដោយអង្គ ៨ ដែលលោកពោលថា

> ភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១ ការ
> ឃើញព្រះសាស្តា ១ បព្វជ្ជា ១ គុណសម្បត្តិ ១ អធិការ ១
> ឆន្ទៈ ១ ដូច្នេះ ។

ទៀបបាទមូលនៃព្រះមានព្រះភាគព្រះនាមទីបង្ករ ទ្រង់សន្សំសមាទាន

បារមី ៣០ ទ្រង់ប្រារព្ធដើម្បីញុំាងពុទ្ធការកធម៌ទាំងអស់ឲ្យបរិបូណ៌ ។ ម្យ៉ាងទៀត មានព្រះបារមីពេញបរិបូណ៌ដោយប្រការទាំងពួង ក្នុងភទ្ទកប្បនេះ បានសម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណ ។ កាលវិសេស មានកំណត់តាមដែលពោលហើយ ក្នុងរវាងមហាកប្បទាំងពីរនេះ ។ ក្នុងសេចក្តីនោះ ដឹងបានដូចម្តេច ។ ពិតហើយ ពាក្យថា ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប ជាពាក្យសម្តែងដល់ការរាប់មហាកប្ប ដោយកំណត់ និងមិនបានកំណត់ ។ ការរាប់នេះ ជាការកាន់យកខាងដើម និងទីបំផុតនៃការគណនាវៀរអំពីនោះមិនមាន ព្រោះហេតុនោះ ការផ្តើមពោធិសម្ភារ និងការស្វែងរករមែងដឹងបានថា ទាំងពីរយ៉ាងនោះ លោកសម្តែងដោយអត្ថ ក្នុងពាក្យនេះថា ក្នុងរវាងនេះ ដោយមានដែនកំណត់ ។ ម្យ៉ាងទៀត ដែនកំណត់នេះ គប្បីជ្រាបដោយវិធីដែលក្រៃលែង ។ មិនគប្បីជ្រាបដោយអំណាចព្រំដែន ព្រោះកប្បដំបូង និងកប្បចុងក្រោយ ឈមចុះខាងក្នុងដោយឯកទេស ។ ម្យ៉ាងទៀត វិធីដែលក្រៃលែង រមែងមិនមានក្នុងទីនេះ ព្រោះមិនបានកំណត់កប្បទាំងនោះដោយមិនមានព្រំដែន មិនមែនឬ មិនមែនយ៉ាងនោះ ព្រោះនុ៎ះ ជាការពោលដល់ក្នុងឯកទេសនៃកប្បនោះ ។ ពិតហើយ កប្បដែលជាឯកទេសរបស់កប្បនោះ លោកកំណត់ដោយមិនមានព្រំដែន ។

បទថា **ចរិតំ** ក្នុងបទនេះថា **យំ ចរិតំ សព្វំ តំ ពោធិបាចនំ** បានដល់ចរិយាដែលជាបដិបទា មានទាន និងសីលជាដើម សង្គ្រោះចូលក្នុងបារមី ៣០ ព្រោះញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា ឈមចុះខាងក្នុង

ចរិយានោះ ។ ម្យ៉ាងទៀត ចរិយានេះមាន ៨ គឺឥរិយាបថចរិយា គឺចរិយាក្នុងឥរិយាបថ ៤ របស់បុគ្គលដែលដល់ព្រមដោយការតាំងចិត្ត ១ អាយតនចរិយា គឺចរិយាក្នុងអាយតនៈខាងក្នុង របស់បុគ្គលដែលមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ១ សតិចរិយា គឺចរិយាក្នុងសតិប្បដ្ឋាន ៤ របស់បុគ្គលដែលមិនប្រមាទជាវិហារធម៌ ១ សមាធិចរិយា គឺចរិយាក្នុងឈានទាំងឡាយ ៤ របស់បុគ្គលដែលខ្វល់ខ្វាយក្នុងអធិចិត្ត ១ ញាណចរិយា គឺចរិយាក្នុងអរិយសច្ច ៤ របស់បុគ្គលដែលដល់ព្រមដោយបញ្ញា ១ មគ្គចរិយា គឺចរិយាក្នុងអរិយមគ្គ ៤ របស់បុគ្គលដែលបដិបត្តិប្រពៃ ១ បត្តិចរិយា គឺចរិយាក្នុងសាមញ្ញផល ៤ របស់បុគ្គលដែលសម្រេចផល ១ លោកត្ថចរិយា គឺចរិយាដែលជាប្រយោជន៍ដល់សព្វសត្វរបស់ព្រះពុទ្ធទាំង ៣ អង្គ ( ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវកពុទ្ធ ) ១ ។ ក្នុងចរិយាទាំងនោះ លោកត្ថចរិយារបស់ព្រះពោធិសត្វ ២ អង្គ ( មហាពោធិសត្វ និងបច្ចេកពោធិសត្វ ) និងព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធ ដោយមានព្រំដែន តែរបស់ព្រះមហាពោធិសត្វ និងព្រះសម្មាសម្ពុទ្ធទាំងឡាយមិនមានព្រំដែន ។ សមដូចលោកពោលក្នុង ( ចូឡ ) និទ្ទេសថា ពាក្យថា ចរិយា បានដល់ចរិយា ៨ គឺឥរិយាបថចរិយា ១ អាយតនចរិយា ១ ដូច្នេះ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ។ ព្រះយោគាវចរ ប្រព្រឹត្តបង្អោនទៅដោយសទ្ធា ប្រព្រឹត្តផ្គងដោយសេចក្តីព្យាយាម ប្រព្រឹត្តមាំទាំដោយសតិ ប្រព្រឹត្តមិនរាយមាយដោយសមាធិ ប្រព្រឹត្តដឹងទូទៅដោយបញ្ញា ប្រព្រឹត្តដឹងច្បាស់ដោយវិញ្ញាណ កាល

បដិបត្តិយ៉ាងនេះ កុសលធម៌ទាំងឡាយរមែងផ្សាយទៅ ដោយហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយអាយតនចរិយា ។ សូម្បីបដិបត្តិយ៉ាងនេះ ក៏រមែងសម្រេចគុណវិសេស ដោយហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយវិសេស-ចរិយា ហេតុនោះ ទើបលោកពោលដល់ចរិយា ៨ ដទៃ ។ គប្បីជ្រាបការសរុបចរិយាទាំងនោះ ក្នុងបាលីទាំងឡាយនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា ពាក្យថា **ចរិតំ** គឺចរិយាដែលជាបដិបទា មានទាន និងសីលជាដើម សង្គ្រោះចូលក្នុងបារមី ៣០ ។ តែគប្បីជ្រាបថា មិនមានការរួមមគ្គចរិយា និងបត្តិចរិយាក្នុងទីនេះ ព្រោះក្នុងទីនេះ បំណងយកហេតុចរិយាប៉ុណ្ណោះ ដោយហេតុនោះ ទើបលោកពោលថា **សព្វំ តំ ពោធិចាចនំ** អំពើទាំងអស់នោះ ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ដូច្នេះ ។

**សព្វ** សព្វ ក្នុងបទនោះ រមែងប្រាកដក្នុងអត្ថ ៤ យ៉ាង គឺ **សព្វសព្វំ ១ អាយតនសព្វំ ១ សក្កាយសព្វំ ១ បទេសសព្វំ ១** ។ ក្នុងអត្ថថា **សព្វ-សព្វំ** ដូចក្នុងបទជាដើមថា **សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណាមុខេ អាបាថមាគច្ឆំ** ធម៌ទាំងពួង រមែងមកកាន់គន្លងចំមុខព្រះញាណរបស់ព្រះពុទ្ធមានជោគ ដោយអាការទាំងពួង ដូច្នេះ ។

ក្នុងអត្ថថា **អាយតនសព្វំ** ដូចក្នុងប្រយោគជាដើមថា **សព្វំ វោ ភិក្ខវេ ទេសេស្សាមិ តំ សុណាថ ។ កិញ្ច ភិក្ខវេ សព្វំ ចក្ខុញ្ចេវ រូបា ច ។បេ។ មនោ ចេវ ធម្មា ច** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអាយតនៈទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចាំស្តាប់នូវអាយតនៈនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង តើដូចម្តេច គឺភ្នែក ១ រូប ១ ។បេ។ ចិត្ត ១ ធម្មារម្មណ៍ ១ ដូច្នេះ ។

ក្នុងអត្ថថា **សក្កាយសព្វំ** ដូចក្នុងប្រយោគជាដើមថា **សព្វំ សព្វតោ សញ្ញានាតិ** បុថុជ្ជនសម្គាល់នូវរបស់ផ្សេងគ្នា ថាជារបស់ផ្សេងគ្នាពិត ដូច្នេះ ។

ក្នុងអត្ថថា **បទេសសព្វំ** ដូចក្នុងប្រយោគជាដើមថា **សព្វេសំ វោ សារិបុត្ត សុភាសិតំ បរិយាយេន** ម្នាលសារីបុត្រ បើដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាបថា **សព្វ** សព្វ ប្រើក្នុងអត្ថថា **បទេសសព្វំ** ព្រោះលោកបំណងយកការប្រព្រឹត្ត ដែលជាការសន្សំពោធិញ្ញាណ ។

បទថា **ពោធិ** បានដល់ ដើមពោធិខ្លះ អរិយមគ្គខ្លះ និព្វានខ្លះ សព្វញ្ញុតញ្ញាណខ្លះ ។ ដើមឈើឈ្មោះថា **ពោធិ** ព្រោះដើមឈើជាទីត្រាស់ដឹងក្នុងអាគតដ្ឋានថា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ** បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស និងន័យមួយទៀតថា **អន្តរា ច គយំ អន្តរា ច ពោធឹ** ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង ដូច្នេះ ។

អរិយមគ្គ ឈ្មោះថា **ពោធិ** ព្រោះអរិយមគ្គជាហេតុត្រាស់ដឹងអរិយសច្ច ៤ ក្នុងអាគតដ្ឋានថា **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ** ញាណក្នុងមគ្គ ៤ លោកហៅថា **ពោធិ** ដូច្នេះ ។

និព្វានឈ្មោះថា **ពោធិ** ព្រោះនិព្វានជានិមិត្ត ក្នុងអាគតដ្ឋានថា **បត្វាន ពោធឹ អមតំ អសង្ខតំ** ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិ ដែលជាអមតៈ មិនមានបច្ច័យតាក់តែង ដូច្នេះ ។

ព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា **ពោធិ** ព្រោះព្រះសព្វញ្ញុតញ្ញាណជាហេតុត្រាស់ដឹងនូវធម៌ទាំងពួង ដោយអាការទាំងពួង ក្នុងអាគតដ្ឋានថា **បប្បោតិ ពោធឹ វរភូរិមេធសោ** តថាគតនោះ មានប្រាជ្ញាដ៏ប្រសើរ ប្រៀបដោយផែនដី និងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ដូច្នេះ ។ ក្នុងទីនេះ សំដៅយកសព្វញ្ញុតញ្ញាណ ។ ម្យ៉ាងទៀត សព្វញ្ញុតញ្ញាណដែលជាអរហត្តមគ្គ គប្បីជ្រាបថា **ពោធិ** ក្នុងទីនេះ ។ សព្វញ្ញុតញ្ញាណរបស់ព្រះមានព្រះភាគ ឈ្មោះថា **ពោធិ** ព្រោះបំណងយកមហាពោធិ ។ ពិតហើយ សព្វញ្ញុតញ្ញាណដែលមានអាសវក្ខយញ្ញាណជាបទដ្ឋាន និងអាសវក្ខយញ្ញាណ ដែលមានសព្វញ្ញុតញ្ញាណជាបទដ្ឋាន លោកពោលថា មហាពោធិ ។ សេចក្តីសង្ខេបក្នុងបទនេះ មានដូច្នេះថា ការប្រព្រឹត្ត ពោល គឺបដិបទា មានទាន និងសីលជាដើមរបស់ព្រះតថាគតឯណា ក្នុងការកំណត់កាលតាមដែលពោលហើយ ការប្រព្រឹត្តទាំងអស់នោះជាគ្រឿងអប់រំបន្ទុំបារមី ជាគ្រឿងឲ្យសម្រេច ធ្វើឲ្យកើតនូវមហាពោធិញ្ញាណដែលមិនមានចំណែកសេសសល់ ។ អកិត្តិតាបស សម្តែងការបំពេញពោធិសម្ភារជាប់តគ្នាដោយបទនេះ ។ ម្យ៉ាងទៀត បទថា **សព្វំ** បានដល់ការប្រព្រឹត្តឯណាក្នុងរវាងនេះ គឺក្នុងការកំណត់កាល តាមដែលពោលហើយ

ការប្រព្រឹត្តទាំងអស់នោះ ជាពោធិសម្ភារទាំងអស់ មិនមានចំណែកសល់ ។ អកិត្តិតាបស សម្តែងដល់ការបំពេញបុណ្យបារមីទាំងអស់ ដោយបទនេះ ។

ភាវនាក្នុងពោធិសម្ភារមាន ៤ យ៉ាង គឺសព្វសម្ភារភាវនា ១ និរន្តរភាវនា ១ ចិរកាលភាវនា ១ សក្កច្ចភាវនា ១ ។ ក្នុងភាវនា ៤ យ៉ាងនោះ លោកពោល **ចិរកាលភាវនា** គឺការបំពេញអស់កាលយូរ ដោយបទនេះថា **កប្បេ ច សតសហស្សេ ចតុរោ ច អសង្ខេយ្យេ** អស់ ៤ អសង្ខេយ្យ កម្រៃ ១ សែនកប្ប ដូច្នេះ ។ លោកពោល **និរន្តរភាវនា** គឺការបំពេញជាប់តគ្នាដោយការកាន់យកទាំងអស់ ក្នុងអត្តភាពជាទី ១ ដោយការប្រកបកន្លងចំណែកក្នុងរវាងនេះ ។ លោកពោល **សព្វសម្ភារភាវនា** គឺការបំពេញកុសលទាំងអស់ ដោយបទនេះថា **សព្វំ ចរិតំ**[១] អំពើទាំងអស់ ដូច្នេះ ក្នុងអត្តភាពជាទី ២ ។ លោកពោល **សក្កច្ចភាវនា** គឺការបំពេញដោយសេចក្តីគោរព ដោយបទនេះថា **ពោធិបាចនំ** ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ដូច្នេះ ។ ការប្រព្រឹត្តនោះ រមែងបន្ទុំសម្មាសម្ពោធិញ្ញាណ ព្រោះសម្តែងភាពយ៉ាងនោះ យ៉ាងណា ការប្រព្រឹត្តនោះ រមែងគួរនឹងពោលថា **ពោធិបាចនំ** ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ដូច្នោះ មិនគួរពោលដោយអាការដទៃ ។ ក្នុងបទនេះ គប្បីជ្រាបភាពដែលពោធិចរិយាជាប់តគ្នាដូចម្តេច ។ បើចិត្តនោះមិនគួរ ព្រោះចិត្តជាប់តគ្នាទៅ ជាសេចក្តីពិត ដែលមិនអាចនឹងពោលបានថា ចិត្តដទៃចាកចិត្តសន្សំពោធិសម្ភារ នឹងកើតឡើងខ្ពស់ជាងមហាភិនីហារ

---

១- បិដកខ្មែរជា ចរិតំ សព្វំ ។

របស់ព្រះមហាសត្វទាំងឡាយ ។ កាលបើយ៉ាងនោះ គប្បីពោលសំដៅដល់ការប្រព្រឹត្តទៅនៃចិត្ត សម្រេចដោយកិរិយា ។ សូម្បីយ៉ាងនេះ ក៏មិនគួរ ។ សេចក្តីពិត មិនគួរឃើញថា ចិត្តសម្រេចដោយកិរិយាទាំងអស់ របស់ព្រះមហាពោធិសត្វទាំងនោះ រមែងប្រព្រឹត្តទៅបាន ដោយអំណាចនៃការសន្សំពោធិសម្ភារប៉ុណ្ណោះ សូម្បីការធ្វើសេចក្តីព្យាយាមជាប់តគ្នាទៅ លោកក៏ហាមដោយបទនេះដូចគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាប **និរន្តរភាវនា** ព្រោះការជាប់តគ្នានៃជាតិ ។ ព្រះមហាពោធិសត្វ ញុំាងមហាបណិធានឲ្យកើតក្នុងជាតិណា ជាតិនោះ រមែងមិនចូលទៅបាន តាំងអំពីនោះ រហូតដល់អត្តភាពចុងក្រោយ ។ ជាតិណា ដែលព្រះមហាពោធិសត្វសន្សំពោធិសម្ភារសព្វគ្រប់ប្រការ ដោយហោចសំដៅយកត្រឹមទានបារមី ក៏គប្បីមានមិនបាន ។ ព្រោះជាតិនេះ ជាធម្មតារបស់ព្រះពោធិសត្វទាំងឡាយ ដែលមានការប្រាថ្នាដ៏ពិតប្រាកដ ព្រះពោធិសត្វទាំងនោះ មិនទាន់ដល់ភាពជាអ្នកជំនាញក្នុងកម្មជាដើមដរាបណា ព្រះពោធិសត្វទាំងឡាយ រមែងដល់នូវការខ្វល់ខ្វាយដែលមានព្រំដែន ក្នុងការសន្សំបុណ្យដរាបនោះ ។ ម្យ៉ាងទៀត កាលណាព្រះពោធិ-សត្វទាំងឡាយ ដល់នូវភាពជាអ្នកជំនាញក្នុងកម្មជាដើម ដោយប្រការទាំងពួង កាលនោះ ការកម្រើកញាប់ញ័រ និងការធ្វើជាប់តក្នុងពោធិសម្ភារទាំងឡាយ រមែងសម្បូរដោយមិនមានព្រំដែនតាំងអំពីនោះ ។ ការធ្វើដោយសេចក្តីគោរព រមែងមានសព្វកាលទាំងពួង ។ ការសម្រេចតាមបំណងរមែងសម្បូរក្នុងផ្លូវរបស់ព្រះពោធិសត្វទាំងឡាយ ។ គប្បីជ្រាបថា លោក

ប្រកាសភាវនា ៤ យ៉ាង គឺ **សព្វសម្ភារភាវនា** ១ **ចិរកាលភាវនា** ១ **និរន្តរភាវនា** ១ **សក្កច្ចភាវនា** ១ ក្នុងពោធិសម្ភារទាំងឡាយ ដោយគាថានេះ ។

ក្នុងបទនោះ ព្រោះការប្រព្រឹត្តរបស់ព្រះពោធិសត្វ ពោធិសម្ភារ ពោធិចរិយា អគ្គយានបារមី ដូចគ្នាតែមួយដោយអត្ថ ព្យញ្ជនៈប៉ុណ្ណោះដែលផ្សេងគ្នា ។ ម្យ៉ាងទៀត ព្រោះបទថា **ចរិតំ** នេះ ជាពាក្យមិនវិសេសចាកបារមី មានទានបារមីជាដើមដែលនឹងចែកពោលតទៅ ហេតុនោះ ក្នុងទីនេះ គួរពណ៌នាបារមីទាំងឡាយ ដើម្បីឲ្យកើតភាពជាអ្នកឈ្លាសក្នុងពោធិ-សម្ភារទាំងអស់ ។ ខ្ញុំនឹងពណ៌នាបារមីទាំងនោះ ក្នុងបកិណ្ណកកថាខាងមុខរហូតគ្រប់គ្រាន់ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងចរិយាក្នុងភូមិរបស់ព្រះពោធិសត្វរបស់ព្រះអង្គដោយមិនញែកចាកពាក្យថា ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច តាំងអំពីផ្តើមរហូតដល់អវសាន ឥឡូវនេះ ដើម្បីសម្តែងដល់ភាពដែលចរិយានោះ ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ដោយសម្បូរក្រៃលែង ដោយការដល់នូវភាពជាកំពូលក្រៃលែង កាលទ្រង់ប្រកាសបុព្វចរិយាបន្តិចបន្តួចក្នុងភទ្ទកប្បនេះ ជារឿង ទើបត្រាស់ពាក្យជាដើមថា **អតីតកប្បេ** ក្នុងកប្បដែលកន្លងទៅហើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អតីតកប្បេ** គឺក្នុងមហាកប្បមានកំណត់តាមដែលពោលហើយ កន្លងទៅហើយទាំងអស់ មុន ឬជាងអំពីកប្បនេះ អធិប្បាយ

ថា ក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប ។ បទថា **ចរិតំ** បានដល់ កិច្ចបដិបត្តិបារមី មានទានបារមីជាដើម ដែលបានសន្សំហើយ ។ បទថា **ឋបយិត្វា** បានដល់ វៀរមិនកាន់យក អធិប្បាយថា មិនពោលដល់ ។ បទថា **ភវាភវេ** បានដល់ ក្នុងភពតូច និងភពធំ ។

សេចក្តីចម្រើន និងសេចក្តីមិនចម្រើន លោកហៅថា **ភវាភវ** ដូចក្នុង ប្រយោគថា **ឥតិភវាភវកថំ** និយាយអំពីសេចក្តីចម្រើន និងមិនចម្រើន ដូច្នេះ ។ សម្បត្តិ វិបត្តិ សេចក្តីចម្រើន សេចក្តីមិនចម្រើន សស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ បុណ្យ និងបាប លោកក៏ហៅថា **ភវាភវ** ដូចក្នុងប្រយោគថា **ឥតិភវាភវតញ្ច វីតិវត្តោ** កន្លងផុតនូវសេចក្តីចម្រើន និងសេចក្តីវិនាស ដូច្នេះ ម្យ៉ាងទៀត ភេសជ្ជៈ មានសប្បិ និងនវនីតជាដើមដែលប្រណីត ប្រណីតក្រៃលែងជាង ក៏ហៅថា **ភវាភវ** ។ អាចារ្យពួកខ្លះ ប្រើពាក្យថា **ភវាភវ** ជាមួយសម្បត្តិភពថា ប្រណីតជាង ប្រណីតបំផុតក៏មាន ដូចក្នុង ប្រយោគថា **ឥតិភវាភវហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧបជ្ជមានា ឧបជ្ជតិ** ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុភេសជ្ជៈឧត្តម និងថ្លៃថ្លា ដូច្នេះៗ ។ ព្រោះហេតុនោះ ក្នុងទីនេះ

គប្បីជ្រាបសេចក្តីនោះឯង លោកអធិប្បាយថា ក្នុងភពតូច និងភពធំ ។ បទថា **ឥមម្ហិ កាប្បេ** បានដល់ ក្នុងភទ្ទកប្បនេះ ។ បទថា **បរកិ្តស្សំ** ស្មើគ្នានឹង **កថយិស្សំ** ( នឹងប្រាប់ ) ។ បទថា **សុណោហិ** ព្រះមានព្រះភាគទ្រង់ដឹកនាំព្រះធម្មសេនាបតីសារីបុត្តក្នុងការស្តាប់ ។ បទថា **មេ** បានដល់ ក្នុងសម្នាក់របស់តថាគត ឬកាលតថាគតពោល ។ល។

**និទានកថា ចប់**

# អដ្ឋកថា
# អកិត្តិវគ្គទី ១

## អកិត្តិចរិយា

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងឧស្សាហ៍ក្នុងការស្ដាប់បុព្វចរិយារបស់ព្រះអង្គ ឲ្យកើតដល់ព្រះសារីបុត្តត្ថេរ និងដល់បរិស័ទទាំងទេវតា និងមនុស្សហើយ ឥឡូវនេះ កាលទ្រង់ធ្វើបុព្វចរិយានោះ ដែលអន្តរភពបិទបាំងឲ្យប្រចក្ស ដូចផ្លែកន្ទួតព្រៃលើបាតដៃ ដូច្នោះ ទើបត្រាស់ព្រះតម្រាស់ជាដើមថា

កាលដែលតថាគតជាតាបស ឈ្មោះអកិត្តិ ចូលទៅនៅក្នុងព្រៃធំ
និងព្រៃតូច ជាព្រៃស្ងាត់សូន្យឈឹង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យទា** បានដល់ ក្នុងកាលណា ។ បទថា **ព្រហារញ្ញេ** បានដល់ ក្នុងព្រៃធំ អធិប្បាយថា ក្នុងព្រៃធំឈ្មោះថា **អរញ្ញានី** ។ បទថា **សុញ្ញេ** បានដល់ ស្ងាត់ចាកជន ។ បទថា **វិបិនកាននេ** បានដល់ ព្រៃតូចដែលស្ងាត់ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងការស្ងាត់របស់ព្រៃនោះ ដោយពីរបទ ។ បទទាំងអស់នោះ លោកពោលសំដៅដល់ **ការទីប** ( កោះដើមតង្កៀបក្ដាម ) ។ បទថា **អជ្ឈោគាហេត្វា** បានដល់ ចូលទៅអាស្រ័យ ។ បទថា **វិហរាមិ** សេចក្ដីថា តថាគតកម្ចាត់ទុក្ខនៃរាងកាយ គឺញ៉ាំងអត្តភាព

ឲ្យប្រព្រឹត្តទៅ ដោយឥរិយាបថវិហារដ៏វិសេសជាផាសុខ ដែលកើតអំពីអានេញ្ជវិហារ គឺការនៅមិនញាប់ញ័រ ដែលជារបស់ទិព្វ ជារបស់ព្រហ្ម ជារបស់អរិយៈ ។ បទថា **អកិត្តិ ឆាម តាបសោ** សេចក្តីថា ក្នុងកាលណាតថាគតជាតាបសមានឈ្មោះយ៉ាងនេះ នៅក្នុងព្រៃនោះ ក្នុងកាលនោះ ព្រះសាស្តាត្រាស់ដល់កាលដែលព្រះអង្គជាតាបសឈ្មោះអកិត្តិ ដល់ព្រះធម្មសេនាបតី ដូចមានកថាជាលំដាប់ដូចតទៅ

បានឮថា ក្នុងអតីតកាល កទ្ទកប្បនេះឯង កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល មានសម្បត្តិ ៨០ កោដិ ញាតិទាំងឡាយដាក់ឈ្មោះថា អកិត្តិ ។ កាលអកិត្តិនោះដើរបាន ប្អូនស្រីម្នាក់ក៏កើតឡើង ញាតិទាំងឡាយ បានដាក់ឈ្មោះឲ្យនាងថា យសវតី ។ កាលអកិត្តិមានអាយុ ១៦ ឆ្នាំ ក៏ទៅរៀនសិប្បៈគ្រប់យ៉ាង ក្នុងនគរតក្កសិលា សម្រេចហើយ ក៏ត្រឡប់ កាលនោះ មាតាបិតារបស់អកិត្តិក៏អនិច្ចកម្ម អកិត្តិធ្វើឈាបនកិច្ចមាតាបិតាហើយ កន្លងទៅ ២-៣ ថ្ងៃ ឲ្យអ្នកចាត់ការមតិក ពិនិត្យមើលទ្រព្យសម្បត្តិ កាលបានស្តាប់ថា ទ្រព្យប៉ុណ្ណេះជារបស់មាតា ទ្រព្យប៉ុណ្ណេះជារបស់បិតា ទ្រព្យប៉ុណ្ណេះជារបស់ជីដូនជីតា ក៏កើតសេចក្តីសង្វេគថា ទ្រព្យនេះប៉ុណ្ណេះនៅប្រាកដ តែម្ចាស់ទ្រព្យមិនប្រាកដ ជនទាំងនោះលះទ្រព្យនេះទៅ តែអញនឹងកាន់យកទ្រព្យនេះទៅ ទើបក្រាបទូលព្រះរាជាឲ្យវាយស្គរប្រកាសថា អ្នកណាត្រូវការទ្រព្យ សូមមកកាន់ផ្ទះរបស់អកិត្តិបណ្ឌិត ។

អកិត្តិបណ្ឌិតបរិច្ចាគមហាទានអស់ ៧ ថ្ងៃ កាលទ្រព្យមិនទាន់អស់ គិតថា ប្រយោជន៍អ្វីដោយសេចក្ដីសុខជាមួយទ្រព្យនេះដល់អញ អ្នកណាត្រូវការក៏ចូរយកតាមចិត្ត ទើបបើកទ្វារផ្ទះ ហើយបើកឃ្លាំងទ្រព្យសម្បត្តិ ដែលពេញដោយប្រាក់ និងមាសជាដើម ប្រកាសថា ជនទាំងឡាយ ចូរនាំយកទ្រព្យដែលខ្ញុំឲ្យហើយទៅចុះ លះផ្ទះទៅ កាលពួកញាតិកំពុងយំ បាននាំប្អូនស្រីចេញអំពីក្រុងពារាណសី ឆ្លងស្ទឹងទៅបាន ២-៣ យោជន៍ ចេញបួសសាងបណ្ណសាលាក្នុងភូមិភាគដែលគួរជាទីត្រេកអរ ទ្វារដែលអកិត្តិតាបសធ្វើដំណើរចេញទៅ ក្នុងកាលនោះ បានឈ្មោះថា អកិត្តិទ្វារ កំពង់ដែលអកិត្តិតាបសឆ្លងស្ទឹងទៅ ក៏បានឈ្មោះថា កំពង់អកិត្តិ ៗ ពួកមនុស្សអ្នកស្រុក អ្នកនិគម និងអ្នកនគរបានដំណឹងថា អកិត្តិបណ្ឌិតបួសហើយ មានចិត្តត្រូវគុណរបស់អកិត្តិតាបសនោះទាញទុក ទើបនាំគ្នាបួសតាម ៗ អកិត្តិ-តាបសមានបរិវារច្រើន លាភ និងសក្ការៈជាច្រើនកើតឡើង ដូចក្នុងពុទ្ធុ-ប្បាទកាល ៗ គ្រានោះ មហាសត្វគិតថា លាភ និងសក្ការៈនេះច្រើន សូម្បីបរិវារក៏ច្រើន ត្រឹមតែកាយវិវេក ក៏រកមិនបានក្នុងទីនេះ អញគួរនៅតែម្នាក់ឯង ព្រោះជាអ្នកប្រាថ្នាតិចក្រៃលែង និងព្រោះជាអ្នកបង្អោនទៅក្នុងវិវេក ទើបមិនឲ្យអ្នកណាមួយដឹង ចេញទៅតែម្នាក់ឯង ដល់ស្រុកទមិឡតាមលំដាប់ នៅក្នុងចំណែកក្បែរកំពង់ឈ្មោះការីរៈ ញុំាងឈាន និងអភិញ្ញាឲ្យកើត ៗ ក្នុងទីនោះ លាភ និងសក្ការៈធំក៏កើតឡើងដល់អកិត្តិតាបសនោះ ៗ អកិត្តិតាបស រង្កៀសលាភ និងសក្ការៈធំនោះ ទើបហោះទៅតាមអាកាសចុះ

ត្រង់ការទីបៈ ។ កាលនោះ ការទីបៈមានឈ្មោះអហិទីបៈ ( កោះពស់ ) ។ អកិត្តិតាបស អាស្រ័យដើមតង្កៀបក្ដាមជំក្នុងទីនោះ សាងបណ្ណសាលាស្នាក់អាស្រ័យនៅ ។ តែព្រោះភាពជាអ្នកប្រាថ្នាតិច ទើបមិនទៅក្នុងទីណា បរិភោគផ្លែឈើក្នុងកាលដែលដើមឈើនោះមានផ្លែ កាលផ្លែមិនមាន ក៏បរិភោគស្លឹកដែលស្រុសដោយទឹក ញ៉ាំងកាលវេលាឲ្យកន្លងទៅដោយឈាន និងសមាបត្តិ ។

ដោយតេជះនៃសីលរបស់អកិត្តិតាបសនោះ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កៈនោះ សម្ដែងអាការក្ដៅ សក្កទេវរាជពិចារណាថា អ្នកណាហ្ន៎ បំណងឲ្យអញឃ្លាតចាកទីនេះ ទតឃើញអកិត្តិបណ្ឌិត ទ្រង់ត្រិះរិះថា តាបសនេះប្រព្រឹត្តតបៈ ដែលធ្វើបានដោយក្រយ៉ាងនេះ ដើម្បីអ្វីហ្ន៎ ឬប្រាថ្នាភាពជាសក្កៈ ឬប្រាថ្នាដទៃ អញនឹងសាកល្បងតាបសនោះមើល ។ ពិតហើយ តាបសនេះ មានការប្រព្រឹត្តផ្លូវកាយ វាចា និងចិត្តបរិសុទ្ធស្អាត មិនអាឡោះអាល័យក្នុងជីវិត បរិភោគស្លឹកតង្កៀបក្ដាមស្រុសដោយទឹក បើប្រាថ្នាភាពជាសក្កៈ នឹងឲ្យស្លឹកតង្កៀបក្ដាមដែលស្រុសហើយដើម្បីខ្លួនដល់អញ បើមិនប្រាថ្នាក៏នឹងមិនឲ្យ ទើបកាឡាខ្លួនជាព្រាហ្មណ៍ ចូលទៅរកអកិត្តិតាបសនោះ ។ ព្រះពោធិសត្វស្រុសស្លឹកតង្កៀបក្ដាមហើយ គិតថា អញនឹងបរិភោគស្លឹកតង្កៀមក្ដាមស្រុសដែលត្រជាក់ អង្គុយត្រង់ទ្វារបណ្ណសាលា ។ លំដាប់នោះ សក្កទេវរាជកាឡាខ្លួនជាព្រាហ្មណ៍ ត្រូវការភិក្ខា បានឈរខាងមុខតាបស ។ ព្រះមហាសត្វឃើញព្រាហ្មណ៍នោះ ត្រេកអរ គិតថា ជាលាភរបស់អញហ្ន៎

អញបានល្អហើយហ្ន៎ អញ ( ខាន ) ឃើញយាចកអស់កាលយូរហើយហ្ន៎ គិតតទៅទៀតថា ថ្ងៃនេះ អញនឹងញុំាងមនោរថរបស់អញឲ្យដល់ទីបំផុត ហើយនឹងឲ្យទាន ទើបកាន់យកភាជន៍ ដែលមានអាហារឆ្អិនទៅ ហើយនឹកដល់ទានបារមី ដាក់ក្នុងភិក្ខាភាជនៈរបស់ព្រាហ្មណ៍នោះទាល់តែអស់ ។ សក្កទេវរាជទទួលភិក្ខានោះទៅបានបន្តិច ក៏អន្តរធានទៅ ។ ព្រះមហាសត្វ កាលឲ្យភិក្ខាដល់ព្រាហ្មណ៍នោះហើយ មិនស្វែងរកអាហារទៀត ញុំាងកាលវេលាឲ្យកន្លងទៅដោយបីតិ និងសុខនោះឯង ។

ក្នុងថ្ងៃទី ២ អកិត្តិតាបសអង្គុយត្រង់ទ្វារបណ្ណសាលា គិតថា កាលពីម្សិលមិញនេះ អញបានទក្ខិណេយ្យបុគ្គល ថ្ងៃនេះ អញបានអ្វីហ្ន៎ ។ សក្កទេវរាជក៏យាងមកដូចមុន ។ ព្រះមហាសត្វបានឲ្យភិក្ខា ញុំាងកាលវេលាឲ្យកន្លងទៅយ៉ាងនោះទៀត ។ ក្នុងថ្ងៃទី ៣ ក៏ឲ្យយ៉ាងនោះទៀត ហើយគិតថា គួរត្រេកអរហ្ន៎ ជាលាភរបស់អញ អញជួបបុណ្យច្រើនហ្ន៎ បើអញបានទក្ខិណេយ្យបុគ្គល អញនឹងឲ្យទានយ៉ាងនេះអស់ ១ ខែខ្លះ អស់ ២ ខែខ្លះ ។ ក្នុងថ្ងៃទី ៣ តាបសក៏តាំងចិត្តអធិដ្ឋានថា ដោយទាននេះ អញមិនបានប្រាថ្នាលាភសក្ការៈ ការសរសើរ មិនប្រាថ្នាសម្បត្តិចក្កពត្តិ មិនប្រាថ្នាសក្កសម្បត្តិ មិនប្រាថ្នាព្រហ្មសម្បត្តិ មិនប្រាថ្នាសាវកពោធិញ្ញាណ មិនប្រាថ្នាបច្ចេកពោធិញ្ញាណ ដែលពិត ទានរបស់អញនេះ សូមបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណចុះ ។ ដោយហេតុនោះ ទើបអកិត្តិតាបសពោលថា

កាលនោះ ព្រះឥន្ទអ្នកគ្រប់សង្កត់ទេវលោក ទ្រង់ក្តៅដោយតេជះ គឺតបធម៌នៃតថាគត ក៏ក្លែងភេទជាព្រាហ្មណ៍ ចូលមករកតថាគត ដើម្បីសូមភិក្ខា ។ តថាគតឃើញព្រាហ្មណ៍ ឈរទៀបទ្វារបណ្ណ-សាលារបស់តថាគត ក៏ឲ្យស្លឹកតង្កៀបក្តាមទាំងអស់ ដែលតថាគតនាំមកពីព្រៃ ជាស្លឹកមិនមានប្រេង មិនមានរសប្រៃ ព្រមទាំងកាជន៍ ។ លុះតថាគតឲ្យស្លឹកតង្កៀបក្តាម ដល់ព្រាហ្មណ៍ហើយ ក៏ផ្កាប់កាជន៍ លះបង់នូវការស្វែងរកទៀត ហើយចូលទៅក្នុងបណ្ណសាលា ។ ក្នុងថ្ងៃទី ២ និងថ្ងៃទី ៣ ព្រាហ្មណ៍ចូលមកក្នុងសម្នាក់តថាគតទៀត តែតថាគតមិនញាប់ញ័រ មិនជាប់ជំពាក់បានឲ្យយ៉ាងនុ៎ះទៀត សរីរៈរបស់តថាគតមិនមានប្លែកភេទ ព្រោះហេតុទាននោះ តថាគតញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅ អស់ថ្ងៃនោះ ព្រោះសេចក្តីត្រេកអរដោយសុខដែលកើតអំពីបីតិ ។ បើតថាគតបានទក្ខិណេយ្យបុគ្គលដ៏ប្រសើរអស់ ១ ខែ ឬ ២ ខែទៀត តថាគតមិនញាប់ញ័រ មិនរួញរានឹងឲ្យទានដ៏ឧត្តមឡើយ ។ តថាគតកាលឲ្យទានដល់ឥន្ទព្រាហ្មណ៍នោះ ទាំងបានប្រព្រឹត្តនូវអំពើទាំងឡាយនោះ មិនប្រាថ្នានូវយស និងលាភទេ តថាគតប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណតែម្យ៉ាង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តទា** សេចក្តីថា ក្នុងកាលដែលតថាគតឈ្មោះអកិត្តិនៅក្នុងកោះ គឺព្រៃតង្កៀបក្តាមនោះ ។ បទថា **មំ** កែជា **មម** ( របស់

ខ្ញុំ ) ។ បទថា **តបតេជេន** បានដល់ ដោយអានុភាពនៃសីលបារមី ។ ពិតហើយ សីល លោកហៅថា **តប** ព្រោះដុតនូវការសៅហ្មងដែលកើតអំពីទុច្ចរិត ឬដោយអានុភាពនៃនេក្ខម្មបារមី និងវីរិយបារមី ។ ពិតហើយ បារមីទាំងនោះ លោកក៏ហៅថា **តប** ព្រោះដុតនូវការសៅហ្មង គឺតណ្ហា និងដុតនូវការខ្ជិលច្រអូស ។ ម្យ៉ាងទៀត បារមីទាំងនោះ ព្រះពោធិសត្វបំពេញយ៉ាងកំពូលក្នុងអត្តភាពនេះ សេចក្ដីពិត គួរនឹងពោលថា ដោយអានុភាពនៃខន្តិបារមី ព្រោះខន្តិសំវរៈចូលដល់ភាពកំពូលយ៉ាងក្រៃលែង សមដូចព្រះដ៏មានព្រះភាគត្រាស់ ( ក្នុងធម្មបទ ) ថា **ខន្តិ បរមំ តបោ** ខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ដូច្នេះ ។ បទថា **សន្តត្តោ** សេចក្ដីថា សក្កទេវរាជទ្រង់ក្ដៅដោយអាការសម្ដែងការក្ដៅរបស់បណ្ឌុកម្ពលសិលាអាសនៈ ដែលសម្រេចតាមធម្មតា ដែលកើតដោយអានុភាពនៃគុណធម៌ ដូចពោលហើយ ។ បទថា **តិទិវាភិភូ** បានដល់ ជាអ្នកធំក្នុងទេវលោក បានដល់ សក្កៈ ។ ស្លឹកតង្កៀបក្ដាមកាន់យកក្នុងទីជិតបណ្ណសាលា លោកពោលថា ដែលតថាគតនាំមកអំពីព្រៃ ព្រោះបណ្ណសាលានៅកណ្ដាលព្រៃ ។

បទថា **អតេលញ្ច អលោណិកំ** លោកពោលដើម្បីសម្ដែងភាពរុងរឿងយ៉ាងធំនៃទានបារមី ដោយការសម្បូរនៃអជ្ឈាស្រ័យ សូម្បីទេយ្យធម៌មិនធំប៉ុន្មាន ។ បទថា **មម ទ្វារេ** បានដល់ ជិតទ្វារបណ្ណសាលារបស់តថាគត ។

ដោយបទនេះថា **សកដាហេន អាគមិ** អកិត្តិតាបស សម្ដែងដល់ភាព

ដែលខ្វះឲ្យមិនមានសល់ ។

បទថា **បុនេសនំ ជហិត្វាន** សេចក្តីថា អកិត្តិតាបសគិតថា ការស្វែងរកវបស់បរិភោគមួយថ្ងៃ ២ ដង មិនជាការជុសខាត់កិលេស ទើបមិនស្វែងរកអាហារជាថ្មីក្នុងថ្ងៃនោះ ហាក់បីដូចឆ្អែត ដោយការឆ្អែតក្នុងទាន ។

បទថា **អកម្បិតោ** បានដល់ មិនញាប់ញ័រដោយសេចក្តីកំណាញ់ ព្រោះសន្តត់បានយូរមកហើយ មិនធ្វើត្រឹមតែការញាប់ញ័រដោយអធ្យាស្រ័យក្នុងការឲ្យ ។ បទថា **អនោលគ្គោ** បានដល់ មិនអាល័យសូម្បីតិចតួចដោយសេចក្តីលោភ ។ បទថា **តតិយម្បិ** រមែងប្រមូល បទនេះថា **ទុតិយម្បិ** ដោយ **បិ** សព្ទ ។ បទថា **ឯវមេវមទាសហំ** សេចក្តីថា ក្នុងថ្ងៃទី ២ ក្នុងថ្ងៃទី ៣ ខ្ញុំក៏បានឲ្យយ៉ាងនោះ ដូចក្នុងថ្ងៃដំបូងនោះឯង ។

បទថា **ន មេ តប្បច្ចយា** អកិត្តិតាបស ធ្វើនូវអត្ថដែលពោលក្នុងគាថាឲ្យប្រាកដ ។ ក្នុងបទទាំងនោះ បទថា **តប្បច្ចយា** សេចក្តីថា ព្រោះការអត់អាហារ ៣ ថ្ងៃ ព្រោះការឲ្យជាបច្ច័យ គប្បីមានការសៅហ្មងឯណាក្នុងសរីរៈ ការសៅហ្មងនោះក្នុងសរីរៈរបស់តថាគតមិនមាន ព្រោះការឲ្យជាបច្ច័យឡើយ ព្រោះហេតុអ្វី ព្រោះថា តថាគតញ៉ាំងថ្ងៃនោះៗ ឲ្យកន្លងទៅដោយបីតិ និងសុខដែលមានទានជាអារម្មណ៍ និងដោយសេចក្តីត្រេកអរដែលមានទានជាអារម្មណ៍ ។ បទថា **វីតិនាមេមិ តំ ទិវំ** សេចក្តីថា តថាគតញ៉ាំងថ្ងៃទាំងអស់នោះ គឺថ្ងៃទាំង ៣ ឲ្យកន្លងទៅ ។ ដើម្បីសម្តែងថា មិនមែនត្រឹមតែ ៣ ថ្ងៃប៉ុណ្ណោះ ដែលពិត តថាគតពេញចិត្តនឹងឲ្យយ៉ាងនោះ

អស់កាល ១ ខែ និង ២ ខែ ទើបអកិត្តិតាបសពោលថា **យថិ មាសម្បិ** ជាដើម ។ បទថា **អនោលីនោ** បានដល់ មានចិត្តមិនរួញរា អធិប្បាយថា មានចិត្តមិនរួញរាក្នុងការឲ្យ ។

បទថា **តស្ស** បានដល់ សក្កទេវរាជមកក្នុងរូបជាព្រាហ្មណ៍ ។ បទថា **យសំ** បានដល់ កិត្តិយស ឬបរិវារសម្បត្តិ ។ បទថា **លាភញ្ច** សេចក្តីថា តថាគតមិនប្រាថ្នាលាភដែលគួរបាន ដោយភាពជាស្តេចចក្កពត្តិជាដើម ក្នុងទេវលោក និងមនុស្សលោក តថាគតប្រាថ្នាសព្វញ្ញុតញ្ញាណ គឺសម្មាសម្ពោធិញ្ញាណ ទើបប្រព្រឹត្ត គឺបានធ្វើបុញ្ញកម្មដែលសម្រេចដោយទាន ដែលកើតឡើងច្រើនដងក្នុង ៣ ថ្ងៃប៉ុណ្ណោះ ឬបុញ្ញកម្ម មានកាយសុចរិតជាដើម ដែលជាបរិវាររបស់ទាន ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសត្រឹមបុញ្ញចរិយា ដែលធ្វើបានលំបាករបស់ព្រះអង្គក្នុងអត្តភាពនោះដល់ព្រះមហាថេរៈ ក្នុងវគ្គនេះ ដោយប្រការដូច្នេះ តែក្នុងទេសនាជាតក ទ្រង់ប្រកាសដល់សក្កៈចូលទៅរកក្នុងថ្ងៃទី ៤ ហើយទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះពោធិសត្វ ការប្រទានពរ ការសម្តែងធម៌របស់ព្រះពោធិសត្វដោយមាតិកា គឺការទទួលពរ និងការប្រាថ្នាទេយ្យធម៌មួយអន្ទើដោយទក្ខិណេយ្យបុគ្គល និងការមិនមករបស់សក្កៈ សមដូចលោកពោល ( ក្នុងខុទ្ទកនិកាយ ជាតក ) ថា

អភិសម្ពុទ្ធគាថា សក្កទេវរាជជាម្ចាស់នៃសត្វ លុះឃើញអកិត្តិ-
បណ្ឌិតកំពុងគង់នៅ ទើបសួរថាបពិត្រមហាព្រហ្ម លោកប្រាថ្នា

ចង់បានអ្វី បានជាមកអង្គុយនៅក្នុងទីក្តៅម្នាក់ឯង ។

អកិត្តិតាបសឆ្លើយថា បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀត នាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ នាំមកនូវសេចក្តីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្តីទុក្ខ បពិត្រវាសវៈ ហេតុនោះ បានជាអាត្មា ( អង្គុយប្រាថ្នាព្រះនិព្វាន ) ។

សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាចង់បានពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នរជនបានកូន ប្រពន្ធ ទ្រព្យ ស្រូវ និងវត្ថុដទៃជាទីស្រឡាញ់ រមែងមិនឆ្អែតស្កប់ស្កល់ដោយលោភៈណា សូមកុំឲ្យលោភៈនោះ នៅក្នុងសន្តានរបស់អាត្មាបានឡើយ ។

សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជនរមែងញ៉ាំងស្រែចម្ការ ប្រាក់ មាស គោ សេះ និងទាសបុរសឲ្យសាបសូន្យដោយទោសៈណា

ដែលកើតហើយ សូមកុំឲ្យទោសៈនោះ នៅក្នុងសន្ដានអាត្មាបាន ឡើយ ។

សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អ ហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរ នោះដល់លោក ។

អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើ ព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹង មនុស្សពាល ។

សក្កៈពោលថា មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោក មិនប្រាថ្នាជួបមនុស្សពាល ។

អកិត្តិតាបសពោលថា បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរ ណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរក អាក្រក់ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹង ច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អ

ហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។
អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។
សក្កៈពោលថា អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។
អកិត្តិតាបសពោលថា អ្នកប្រាជ្ញរមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះរមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។
សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេតពរនោះដល់លោក ។
អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើ

ព្រះអង្គប្រទានពរដល់អាត្មា នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង សូមឲ្យទិព្វភោជនកើតប្រាកដ ទាំងពួកយាចកអ្នកមានសីល ( ក៏ឲ្យមក ) កាលបើអាត្មាឲ្យ សូមទិព្វភោជនកុំឲ្យអស់ លុះឲ្យហើយ សូមកុំឲ្យក្តៅក្រហាយក្រោយ កាលបើកំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។

សក្កៈពោលថា សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមករកអាត្មាទៀតឡើយ បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។

សក្កៈពោលថា ពួកជនប្រុសស្រី តែងចង់ឃើញ ( ខ្ញុំ ) ដោយការប្រព្រឹត្តវត្តដ៏ច្រើន ចុះភ័យ ( អ្វី ) ក្នុងការឃើញខ្ញុំ ( មានដល់លោក ) ។

អកិត្តិតាបសពោលថា អាត្មាឃើញព្រះអង្គមានភេទជាទេវតាប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងកាលឃើញព្រះអង្គនុ៎ះ មានដល់ ( អាត្មា ) ។

លំដាប់នោះ សក្កទេវរាជត្រាស់ថា សាធុ លោកម្ចាស់ ចាប់ពីពេលនេះទៅ ខ្ញុំនឹងមិនមករកលោកម្ចាស់ទៀតឡើយ ទ្រង់ថ្វាយបង្គំតាបសនោះ យាងត្រឡប់ទៅ ។ ព្រះមហាសត្វនៅត្រង់ការទីបៈនោះ ដរាបអស់ជីវិតកាលអស់អាយុ ក៏ទៅកើតក្នុងព្រហ្មលោក ។ សក្កទេវរាជក្នុងកាលនោះ បានមកជាព្រះអនុរុទ្ធត្ថេរ ក្នុងកាលឥឡូវនេះ អកិត្តិបណ្ឌិតក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

អកិត្តិបណ្ឌិតនោះ បានទទួលបារមីទាំង ១០ នេះ គឺឈ្មោះថា **នេក្ខម្ម-បារមី** ព្រោះការចេញទៅរបស់អកិត្តិបណ្ឌិតនោះ ដូចគ្នានឹងមហាភិនេ-ស្រ្កមណ៍ ។ ឈ្មោះថា **សីលបារមី** ព្រោះមានសីលាចារបរិសុទ្ធដោយល្អ ឈ្មោះថា **វីរិយបារមី** ព្រោះសង្កត់នូវកាមវិតក្កជាដើមដោយល្អ ។ ឈ្មោះថា **ខន្តិបារមី** ព្រោះខន្តិសំវរៈ ដល់នូវភាពកំពូលយ៉ាងក្រៃលែង ។ ឈ្មោះថា **សច្ចបារមី** ព្រោះបដិបត្តិតាមសមគួរដល់ប្តេជ្ញា ។ ឈ្មោះថា **អធិដ្ឋានបារមី** ព្រោះតាំងចិត្តសមាទានមិនញាប់ញ័រក្នុងទីទាំងពួង ។ ឈ្មោះថា **មេត្តាបារមី** ព្រោះមានអធ្យាស្រ័យអនុគ្រោះក្នុងសព្វសត្វទាំងឡាយ ។ ឈ្មោះថា **ឧបេក្ខា-បារមី** ព្រោះដល់នូវភាពជាកណ្តាលក្នុងការខុសប្រក្រតី ដែលសត្វ និងសង្ខារធ្វើហើយ ។ ឈ្មោះថា **បញ្ញាបារមី** បានដល់ បញ្ញាដែលជាឧបាយ-កោសល ដែលជាសហជាតបច្ច័យ និងបញ្ញា ឲ្យសម្រេចនូវការប្រព្រឹត្តក្នុងការជុសខាត់កិលេសយ៉ាងក្រៃលែង ព្រោះដឹងនូវធម៌ជាឧបការៈ និងធម៌មិនជាឧបការៈដល់បារមីទាំងនោះ លះនូវធម៌ ដែលមិនជាឧបការៈ ប្រព្រឹត្ត

ក្នុងធម៌ដែលជាឧបការៈ ។

ទេសនាប្រព្រឹត្តទៅហើយដោយទានជាប្រធាន ដែលជាការទូលំទូលាយក្រៃលែង នៃបុគ្គលមានអធ្យាស្រ័យក្នុងការឲ្យ ព្រោះហេតុនោះ ធម៌ពួកណាមានប្រភេទមិនតិចរាប់រយរាប់ពាន់ ជាពោធិសម្ភារ ជាគុណរបស់មហាពោធិសត្វ មានយ៉ាងនេះ គឺមហាករុណា ដែលឲ្យសម្រេចក្នុងទីទាំងពួងបុញ្ញសម្ភារ និងញាណសម្ភារទាំងពីរ សុចរិតរបស់ព្រះពោធិសត្វ ៣ មានកាយសុចរិតជាដើម អធិដ្ឋាន ៤ មានសច្ចាធិដ្ឋានជាដើម ពុទ្ធភូមិ ៤ មានឧស្សាហៈជាដើម ធម៌ជាគ្រឿងអប់រំបន្ទុំមហាពោធិញ្ញាណ ៥ មានសទ្ធាជាដើម អធ្យាស្រ័យរបស់ព្រះពោធិសត្វទាំងឡាយ ៦ មានអធ្យាស្រ័យមិនលោភជាដើម ធម៌ គឺប្បញ្ញា ៧ មាន តថាគតធ្ងន់ផុតហើយ នឹងឲ្យសត្វឆ្លងផុតជាដើម មហាបុរិសវិតក្ក ៨ មាន ធម៌នេះរបស់អ្នកមានការប្រាថ្នាតិច ធម៌នេះមិនមែនរបស់អ្នកមានការប្រាថ្នាធំជាដើម ធម៌ មានយោនិសោមនសិការជាមូល ៩ អធ្យាស្រ័យរបស់មហាបុរស ១០ មានអធ្យាស្រ័យក្នុងការឲ្យទានជាដើម បុញ្ញកិរិយាវត្ថុ ១០ មានទាន និងសីលជាដើម ធម៌ទាំងអស់នោះ គប្បីលើកឡើងពោលក្នុងចរិយាបិដកនេះតាមសមគួរ ។

ម្យ៉ាងទៀត ក្នុងអកិត្តិចរិយានេះ គប្បីជ្រាបគុណានុភាពរបស់ព្រះមហាសត្វមានជាដើមយ៉ាងនេះ គឺការលះនូវគំនរសម្បត្តិធំ និងវង្សញាតិធំហើយចេញចាកផ្ទះ ដូចគ្នានឹងមហាភិនេស្រ្កមណ៍ កាលចេញបួសហើយទោះបីជនជាច្រើនស្គាល់ ក៏មិនជាប់ជំពាក់ក្នុងត្រកូល ក្នុងគណៈ ព្រោះជាអ្នក

ប្រាថ្នាតិចក្រៃលែង វៀរសក្កុងលាភសក្ការៈ និងការសរសើរ ត្រេកអរក្នុងការស្វាត់ កាត់អាល័យក្នុងរាងកាយ និងជីវិត ជាអ្នកបរិច្ចាគ ទោះបីអត់អាហារ ក៏ត្រេកអរដោយបីតិ ញុំាងរាងកាយឲ្យប្រព្រឹត្តទៅបាន មិនខុសប្រក្រតីអស់ ៣ ថ្ងៃ ការមានអជ្ឈាស្រ័យទូលំទូលាយក្នុងទាន ដែលជាហេតុឲ្យសម្រេច ការប្រព្រឹត្តមិនធូរថយក្នុងការបរិច្ចាគ ដោយគិតថា កាលមានបុគ្គលសូមអស់កាល ២ ខែ ៣ ខែ អញក៏នឹងឲ្យអាហារយ៉ាងនោះឯង ហើយញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបីតិ និងសុខ ដែលកើតអំពីការឲ្យបុណ្ណោះ កាលឲ្យទានហើយ ក៏ប្រព្រឹត្តដុសខាត់កិលេសក្រៃលែង មិនជាហេតុធ្វើឲ្យស្វែងរកអាហារជាថ្មី ដោយហេតុនោះ ទើបលោកពោលថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ប្រកបដោយមហាករុណា ជាអ្នកប្រាជ្ញ ជាផៅពង្សឯករបស់លោកទាំងពួង ។

ព្រះមហាសត្វដ៏ជាពោធិសត្វ មានអានុភាពជាអចិន្តេយ្យ មានព្រះសទ្ធម្មជាគោចរសព្វកាល មានការប្រព្រឹត្តដុសខាត់កិលេសយ៉ាងបរិសុទ្ធ ។

មណ្ឌលនៃរលកដែលតាំងឡើងព្រោះព្យុះធំ ព្រះពោធិសត្វលោតឆ្លងទីនោះទៅបាន មិនមែនជារឿងធម្មតា ។

ព្រះមហាសត្វទាំងនោះ សូម្បីជាអ្នកចម្រើនដោយសញ្ញាតិក្នុងលោក ជាអ្នកអប់រំល្អហើយ ក៏មិនជាប់ដោយលោកធម៌ទាំងឡាយ

ដូចផ្កាឈូកមិនជាប់ដោយទឹកដូច្នោះ ។

សេចក្តីស្រឡាញ់ព្រោះករុណាក្នុងសត្វទាំងឡាយ រមែងចម្រើនដោយប្រការដែលព្រះមហាសត្វទាំងឡាយ លះនូវការជាប់ជំពាក់ក្នុងខ្ទបេញបាន ។

កម្មរមែងនៅក្នុងអំណាចរបស់ព្រះពោធិសត្វ ព្រះពោធិសត្វមិនទៅតាមអំណាចរបស់កម្ម ដូចចិត្តរមែងនៅក្នុងអំណាច មិនប្រព្រឹត្តទៅតាមអំណាចរបស់ចិត្ត ដូច្នោះ ។

ព្រះមហាសត្វទាំងនោះ ដែលទោសៈមិនគ្របសង្កត់ ឬមិនធ្វើទោសៈឲ្យកើតឡើង ត្រាច់ស្វែងរកពោធិញ្ញាណ ដូចបុរសទាំងឡាយ ដឹងដល់សេចក្តីវិនាស មិនត្រូវសេចក្តីវិនាសគ្របសង្កត់ ឬមិនញ៉ាំងសេចក្តីវិនាសឲ្យកើតឡើង ដូច្នោះ ។

សូម្បីចិត្តជ្រះថ្លាក្នុងព្រះពោធិសត្វទាំងនោះ ក៏គប្បីផុតចាកទុក្ខបាននឹងពោលទៅថ្វីដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។៚

**អដ្ឋកថាអកិត្តិចរិយា ចប់**

# សុត្តន្តបិដក

## សង្ខព្រាហ្មណចរិយាទី ២

[ ២ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជាព្រាហ្មណ៍ឈ្មោះសង្ខៈ មានប្រាថ្នាដើម្បីឆ្លងមហាសមុទ្រ សំដៅទៅកាន់កំពង់ ( តម្ពលិត្តិ ) ។ កាលនោះ តថាគតបានឃើញព្រះបច្ចេកពុទ្ធដែលត្រាស់ដឹងឯង ទ្រង់ឈ្មោះមារ កំពុងនិមន្តទៅកាន់ផ្លូវលំបាកលើផែនដីរឹបរដុបដ៏ក្តៅ ត្រង់ផ្លូវជួបគ្នានោះ ។ លុះតថាគតឃើញព្រះបច្ចេកពុទ្ធ ត្រង់ផ្លូវជួបគ្នានោះ ក៏គិតនូវសេចក្តីនេះថា ស្រែបុណ្យនេះ រមែងសម្រេចដល់សត្វ អ្នកប្រាថ្នានូវបុណ្យ ប្រៀបដូចបុរសអ្នកក្ជួរ ឃើញស្រែ ឬសួនច្បារធំ មិនព្រោះពូជក្នុងស្រែនោះទេ បុរសនោះ ឈ្មោះថា ជាអ្នកមិនត្រូវការដោយស្រូវ យ៉ាងណាមិញ ។ តថាគតជាអ្នកចង់បានបុណ្យ បើឃើញស្រែបុណ្យដ៏ប្រសើរថ្លៃថ្លាហើយ មិនធ្វើសក្ការៈទេ តថាគតឈ្មោះថាជាអ្នកមិនត្រូវការដោយបុណ្យ យ៉ាងនោះឯង ។ មួយវិញទៀត ប្រៀបដូចអាមាត្យមានប្រាថ្នា ជាធំក្នុងក្រសួងត្រា ( ហើយបណ្តេញ ) ពួកជនក្នុងវាំងរបស់ស្តេច មិនឲ្យទ្រព្យ និងស្រូវដល់ជនទាំងនោះ អាមាត្យនោះ រមែងសាបសូន្យចាកត្រា យ៉ាងណាមិញ តថាគតជាអ្នកប្រាថ្នាបុណ្យ បានឃើញទក្ខិណេយ្យបុគ្គលដ៏ធំទូលាយ

ហើយមិនឲ្យទានដល់ទក្ខិណេយ្យបុគ្គលនោះ តថាគតរមែងសាបសូន្យចាកបុណ្យ ក៏យ៉ាងនោះដែរ ។ តថាគតលុះគិតឃើញយ៉ាងនេះហើយ ក៏ដោះស្បែកជើង ថ្វាយបង្គំព្រះបាទានៃព្រះបច្ចេកពុទ្ធនោះ រួចប្រគេនឆត្រ និងស្បែកជើង ។ ហេតុនោះ បានជាតថាគតចម្រើនដោយសេចក្ដីសុខ ដល់នូវសេចក្ដីសុខ ដោយរយគុណម្យ៉ាងទៀត តថាគតកាលបំពេញទាន ក៏បានឲ្យទានដល់ព្រះបច្ចេកពុទ្ធ យ៉ាងនេះឯង ។

## សង្ខព្រាហ្មណចរិយាទី ២ ចប់

# អដ្ឋកថា

## សង្ខព្រាហ្មណចរិយា

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខព្រាហ្មណចរិយាទី ២ ដូចតទៅនេះ បទថា **បុនាបរំ** កាត់បទជា **បុន អបរំ** អធិប្បាយថា មិនមែនអកិត្តិចរិយានេះតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត តថាគតនឹងពោលសង្ខចរិយាដទៃទៀត ចូរអ្នកស្តាប់ ។ ក្នុងបទដទៃអំពីនេះ ក៏មានន័យនេះដូចគ្នា ។ បទថា **សង្ខ-សវ្ហយោ** បានដល់ មានឈ្មោះថាសង្ខៈ ។ បទថា **មហាសមុទ្ទំ តរិតុកាមោ** បានដល់ បំណងនឹងឆ្លងមហាសមុទ្រដោយសំពៅដើម្បីទៅកាន់សុវណ្ណភូមិ ។ បទថា **ឧបគច្ឆាមិ បដ្ដនំ** បានដល់ ទើបទៅកាន់កំពង់ ឈ្មោះ **តាមលិត្តិ**។ ព្រះបច្ចេកពុទ្ធឈ្មោះសយម្ភូ ព្រោះជាអ្នកកើតឯង ព្រោះសម្រេចបច្ចេកពោ-ធិញ្ញាណ ដោយសយម្ភូញាណ ។ ឈ្មោះថា **អបរាជិតំ** ព្រោះមារទាំងឡាយ មានកិលេសមារជាដើមណាមួយ ឈ្នះមិនបាន អធិប្បាយថា ញាំញីក្បាលនៃមារ ៣ ។ បទថា **តត្តាយ កឋិនភូមិយា** បានដល់ លើផែនដីរឹងគ្រោតគ្រាត ពេញទៅដោយក្រួស និងខ្សាច់ដ៏ក្តៅក្នុងរដូវក្តៅ ។

បទថា **តំ** បានដល់ ព្រះបច្ចេកពុទ្ធអង្គនោះ ។ បទថា **ឥមមត្ថំ** បានដល់ ប្រយោជន៍នេះ គឺដែលនឹងពោលដល់ឥឡូវនេះ មានពាក្យថា ស្រែបុណ្យនេះជាដើម ។ បទថា **វិចិន្តយឹ** ព្រះសាស្តាត្រាស់ថា គ្រានោះ តថាគតជាសង្ខព្រាហ្មណ៍គិតហើយ ។ គប្បីជ្រាបអនុបុព្វីកថាក្នុងរឿងនោះតទៅ

ក្នុងអតីតកាល នគរពារាណសីឈ្មោះថា មោឡិនីនគរ ។ កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងមោឡិនីនគរ ព្រះពោធិសត្វជាព្រាហ្មណ៍ឈ្មោះសង្ខៈ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន ឲ្យតាំងរោងទាន ៦ កន្លែងក្នុងទីទាំង ៦ គឺត្រង់ទ្វារនគរទាំង ៤ ត្រង់កណ្តាលនគរ ១ ត្រង់ទ្វារផ្ទះរបស់ខ្លួន ១ លះនូវទ្រព្យរាល់ថ្ងៃ ១ ថ្ងៃ ៦ សែន ញុំាងនូវមហាទានឲ្យប្រព្រឹត្តទៅ ដល់បណ្តាយាចក និងអ្នកដំណើរជាដើម ។ ថ្ងៃមួយ សង្ខព្រាហ្មណ៍គិតថា កាលទ្រព្យក្នុងផ្ទះអស់ អញមិនអាចឲ្យទានបាន កាលទ្រព្យមិនទាន់អស់ អញនឹងទៅកាន់សុវណ្ណភូមិ ដោយសំពៅហើយ នាំទ្រព្យមក ។ សង្ខ-ព្រាហ្មណ៍ដាក់ទំនិញពេញសំពៅ ហៅបុត្រភរិយាមក ពោលថា ពួកអ្នកកុំបីលះបង់ទានរបស់ខ្ញុំ គប្បីធ្វើកុំឲ្យដាច់ ទម្រាំខ្ញុំត្រឡប់មក ហោមរោមដោយទាសៈ និងកម្មករ ពាក់ស្បែកជើង បាំងឆត្រ បែរមុខទៅកាន់បដ្ដនគាម ។

ក្នុងខណៈនោះ ត្រង់ភ្នំគន្ធមាទន៍ព្រះបច្ចេកពុទ្ធ ១ អង្គចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ កាលចេញចាកនិរោធសមាបត្តិហើយ ប្រមើលមើលសត្វលោក ឃើញសង្ខព្រាហ្មណ៍ដែលកំពុងទៅដើម្បីនាំទ្រព្យមក ពិចារណាថា មហាបុរសនឹងទៅនាំទ្រព្យមក អន្តរាយក្នុងមហាសមុទ្ទ នឹងមានដល់គេឬហ្ន៎ ដឹងថា មានអន្តរាយ គិតថា មហាបុរសនេះ ឃើញអាត្មាអញហើយនឹងប្រគេនឆត្រ មួយអន្លើដោយស្បែកជើង ដល់អាត្មាអញ ដោយអានិសង្សនៃការឲ្យស្បែកជើង កាលសំពៅបែកធ្លាយក្នុងមហាសមុទ្រ នឹងបានទីពឹងអាត្មាអញនឹងអនុគ្រោះកុលបុត្រនេះ ទើបទៅតាមអាកាស ចុះមិនឆ្ងាយអំពី

សន្ទព្រាហ្មណ៍នោះ ពេលថ្ងៃត្រង់ ជាន់ខ្សាច់ក្តៅ ដោយខ្យល់ និងកម្តៅថ្ងៃ ដែលក្តៅ ដូចគ្នានឹងក្រាលដោយរងើកភ្លើង និមន្តមកដល់ខាងមុខសន្ទ-ព្រាហ្មណ៍នោះ ។ សន្ទព្រាហ្មណ៍ឃើញព្រះបច្ចេកពុទ្ធនោះ មានសេចក្តីត្រេកអរ គិតថា បុញ្ញក្ខេត្តមករកអញហើយ ថ្ងៃនេះ អញគួរសាបព្រោះពូជក្នុងស្រែនេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគមានព្រះតម្រាស់ថា លុះតថាគតបានឃើញព្រះបច្ចេកពុទ្ធ ត្រង់ផ្លូវជួបគ្នានោះ ក៏គិតនូវសេចក្តីនេះដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឥទំ ខេត្តំ** ជាដើម ជាពាក្យសម្តែងអាការគិត ។ បទថា **ខេត្តំ** ឈ្មោះថា ខេត្ត ព្រោះការពារនូវពូជដែលព្រោះដោយធ្វើឲ្យមានផលច្រើន គឺទីដែលដាំបុព្វណ្ណជាតិ និងអបរណ្ណជាតិ ឲ្យដុះលូតលាស់ ។ ក្នុងទីនេះ ព្រះបច្ចេកពុទ្ធ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ឈ្មោះថាជាខេត្ត ព្រោះដូចជាស្រែ ដោយហេតុនោះ ទើបលោកពោលថា រមែងសម្រេចដល់សត្វអ្នកប្រាថ្នានូវបុណ្យ ។

បទថា **មហាគមំ** បានដល់ ជាទីមកនៃផលដែលបរិបូណ៌ អធិប្បាយថា ឲ្យនូវភាពបរិបូរនៃស្រូវ ។ បទថា **ពីជំ ន រោបេតិ** បានដល់ មិនសាបព្រោះពូជ ។

បទថា **ខេត្តវរុត្តមំ** បានដល់ ឧត្តមក្នុងស្រែដ៏ប្រសើរ ។ ពិតហើយសាវកទាំងឡាយដែលឆ្ងាយចាកកិលេស ដល់ព្រមដោយគុណ មានសីលជាដើម ជាខេត្តដ៏ប្រសើរ ព្រះបច្ចេកពុទ្ធជាបុគ្គលក្រៃលែងជាងនោះ ទើប

ឈ្មោះថា ជាខេត្តដ៏ប្រសើរបំផុត ។ បទថា **ការំ** បានដល់ សក្ការៈ ។ គប្បីភ្ជាប់ជាមួយពាក្យថា **យទិ ន ករោមិ** ( បើមិនធ្វើ ) ។ ពាក្យនេះ លោកអធិប្បាយថា បើខ្ញុំបានបុញ្ញក្ខេត្តដ៏ប្រសើរហើយ មិនធ្វើការបូជា សក្ការៈក្នុងបុញ្ញក្ខេត្តនោះ ខ្ញុំក៏ឈ្មោះថា ជាអ្នកមិនត្រូវការបុណ្យ ។

គប្បីជ្រាបសេចក្ដីសង្ខេបនៃពីរគាថា មានជាដើមថា **យថា អមច្ចោ** ជាដើមដូចតទៅនេះ ដូចបុរសអមាត្យ ឬសេនាបតី ដែលព្រះរាជាទ្រង់ស្ថាបនាក្នុងតំណែងមុទ្ទាធិការ ( សេនាបតីធំ ) បានទទួលត្រាប្រចាំតំណែងហើយ មិនបដិបត្តិតាមព្រះរាជឱង្ការ ក្នុងជនខាងក្នុង និងពួកពលខាងក្រៅជាដើម មិនឲ្យទ្រព្យសម្បត្តិដល់ជននោះៗ ធ្វើឲ្យកិច្ចបដិបត្តិដែលគួរធ្វើនោះៗវិនាស បុគ្គលនោះ រមែងសាបសូន្យចាកសេចក្ដីត្រេកអរ រមែងសាបសូន្យចាកសម្បត្តិដែលបានអំពីតំណែងដែលគួរជាទីត្រេកអរ យ៉ាងណា ឯខ្ញុំក៏ដូច្នោះដូចគ្នា ត្រេកអរក្នុងការបំពេញបុណ្យ ជាអ្នកប្រាថ្នាបុណ្យ ពោល គឺផលបុណ្យដែលគួរបាន ឃើញទក្ខិណេយ្យបុគ្គលដែលបរិបូណ៌នោះ គឺបាននូវទក្ខិណេយ្យបុគ្គលដ៏ក្រៃលែងដោយទក្ខិណា ឲ្យមានផលបរិបូណ៌ បើមិនឲ្យទានដល់ទក្ខិណេយ្យបុគ្គលនោះ នឹងសាបសូន្យចាកបុណ្យ នឹងចាកផលបុណ្យតទៅ ព្រោះហេតុនោះ ទើបខ្ញុំគួរធ្វើបុណ្យក្នុងទីនេះឯង ។

មហាបុរសគិតយ៉ាងនេះហើយ ដោះស្បែកជើងអំពីចម្ងាយ ប្រញាប់ចូលទៅថ្វាយបង្គំព្រះបច្ចេកពុទ្ធ ពោលថា សូមលោកម្ចាស់និមន្តចូលកាន់គល់ឈើនេះ ដើម្បីអនុគ្រោះខ្ញុំផងចុះ កាលព្រះបច្ចេកពុទ្ធចូលទៅកាន់គល់

ឈើនោះ ទើបជញ្ជូនខ្សាច់មក ហើយក្រាលសំពត់ដណ្តប់ កាលព្រះបច្ចេកពុទ្ធគង់ក្នុងទីនោះ ថ្វាយបង្គំហើយ យកទឹកដែលត្រងទុកលាងជើងរបស់ព្រះបច្ចេកពុទ្ធ យកប្រេងក្រអូបលាប ជូតស្បែកជើងរបស់ខ្លួន ខាត់ដោយប្រេងក្រអូបហើយ ពាក់ត្រង់ជើងព្រះបច្ចេកពុទ្ធ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពាក់ស្បែកជើងនេះ ហើយបាំងឆត្រនេះចុះ ហើយបានប្រគេនឆត្រ និងស្បែកជើង ។ ព្រះបច្ចេកពុទ្ធអង្គនោះ ក៏ទទួលយកឆត្រ និងស្បែកជើងនោះ ដើម្បីអនុគ្រោះ និងឆ្លងសទ្ធារបស់សង្ខព្រាហ្មណ៍នោះ កាលសង្ខព្រាហ្មណ៍កំពុងមើលនោះឯង ក៏ហោះទៅកាន់អាកាស ទៅកាន់ភ្នំគន្ធមាទន៍ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តថាគត លុះគិតឃើញយ៉ាងនេះហើយ ក៏ដោះស្បែកជើង ថ្វាយបង្គំព្រះបាទានៃព្រះបច្ចេកពុទ្ធនោះ រួចប្រគេនឆត្រ និងស្បែកជើងដូច្នេះ ។

ព្រះពោធិសត្វឃើញដូច្នោះ មានចិត្តជ្រះថ្លាក្រៃលែង ទើបទៅកាន់បដ្ដនគាម ហើយឡើងសំពៅ ។ កាលព្រះពោធិសត្វឆ្លងមហាសមុទ្រទៅក្នុងថ្ងៃទី ៧ សំពៅក៏បែកធ្លាយ ពួកទាសៈ និងកម្មករមិនអាចនឹងបាចទឹកចេញបាន នាំគ្នាខ្លាចមរណភ័យ ទើបសំពះទេវតារៀងៗ ខ្លួន ស្រែកដោយសំឡេងទ្រហឹង ។ ព្រះពោធិសត្វនាំអ្នកបម្រើម្នាក់ទៅ ហើយយកប្រេងលាបពេញខ្លួន បរិភោគស្ករ និងសប្បិតាមត្រូវការ ឲ្យអ្នកបម្រើបរិភោគខ្លះ ហើយ

ឡើងលើសសរក្តោងជាមួយអ្នកបម្រើ កំណត់ទិសថា នគររបស់យើងនៅក្នុងទិសនេះ តាំងសច្ចាធិដ្ឋាន ដើម្បីឲ្យផុតចាកអន្តរាយ គឺត្រី និងអណ្តើក ទើបលោតទៅក្នុងទីប្រមាណ ១ ឧសភៈ[១] មួយអន្លើដោយអ្នកបម្រើ ព្យាយាមហែលឆ្លងមហាសមុទ្រ ។ ចំណែកមហាជន បានដល់នូវសេចក្តីវិនាស ក្នុងមហាសមុទ្រនោះឯង ។ កាលព្រះពោធិសត្វហែលឆ្លងសមុទ្រនោះ ៧ ថ្ងៃកន្លងទៅ ក្នុងពេលនោះ ព្រះពោធិសត្វយកទឹកប្រៃខ្ពុរមាត់ ហើយរក្សាឧបោសថ ។

គ្រានោះ ទេពធីតាឈ្មោះមណីមេខលា ដែលស្តេចចតុលោកបាលទាំង ៤ ចាត់ឲ្យមើលថែបុរសវិសេសបែបនេះ ប្រហែសធ្វេស ៧ ថ្ងៃ ដោយភាពជាធំរបស់ខ្លួន ក្នុងថ្ងៃទី ៧ បានឃើញព្រះពោធិសត្វហើយ សង្វេគថា បើបុរសនេះស្លាប់ ក្នុងមហាសមុទ្រនេះ អញនឹងបានទទួលពាក្យនិន្ទាច្រើន ទើបយកអាហារទិព្វដាក់ភាជន៍មាស ប្រញាប់មក ហើយពោលថា នែព្រាហ្មណ៍ ចូរអ្នកបរិភោគអាហារទិព្វនេះចុះ ។ ព្រះពោធិសត្វសម្លឹងមើលទេពធីតានោះ ទើបបដិសេធថា ខ្ញុំមិនបរិភោគ ខ្ញុំរក្សាឧបោសថ កាលសួរទេពធីតានោះ ទើបពោល ( ក្នុងសង្ខជាតក ) ថា

នាងបានគយគន់មើលយើងដោយសេចក្តីសុខ និយាយនឹងយើង
ថា អ្នកចូរបរិភោគនូវភត្តចុះ ម្នាលនាងនារី អ្នកមានអានុភាពធំ
យើងសូមសួរនាង តើនាងជាទេវធីតា ឬជាមនុស្ស ដូច្នេះ ។

---

១- មួយឧសភៈ គឺ ១៤០ ហត្ថ ( វចនានុក្រមសម្តេចជួនណាត ) ។

ទេពធីតាមណីមេខលា កាលឲ្យពាក្យឆ្លើយដល់ព្រះពោធិសត្វ បាន ពោលគាថាទាំងនេះថា

បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវធីតាមានអានុភាពធំ មកក្នុង កណ្តាលសាគរនេះ ព្រោះខ្ញុំមានសេចក្តីអនុគ្រោះ មិនមែនមាន ចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ចំពោះអ្នក តែម្យ៉ាង ។

បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្ទនេះ មានបាយ ទឹក ទីដេក ទី អង្គុយ និងយានផ្សេងៗ ជាច្រើន អ្នកមានចិត្តប្រាថ្នាចំពោះរបស់ ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះដល់អ្នក ដូច្នេះ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ គិតថា ទេពធីតានេះពោលថា ខ្ញុំឲ្យវត្ថុ នេះៗ ដល់អញលើផ្ទៃសមុទ្រ ទេពធីតានេះពោលពាក្យណាដល់អញ ពាក្យ នោះក៏សម្រេចដោយបុណ្យរបស់អញ ម្យ៉ាងទៀត ទេពធីតានេះស្គាល់បុណ្យ របស់អញឬ ឬមិនស្គាល់ អញនឹងសួរនាង កាលសួរទើបពោលគាថានេះថា

បពិត្រនាងទេវធីតា មានរាងខ្លួនល្អ មានភ្លៅល្អ មានវង់ចិញ្ចើម ល្អ មានអវយវៈពាក់កណ្តាលខ្លួនល្អ ការបូជាធំក្តី បូជាតូចក្តី ណាមួយរបស់ខ្ញុំ នាងជាឥស្សរៈនៃបុញ្ញកម្មរបស់យើងនោះទាំង អស់ នេះជាផលនៃកម្មរបស់ខ្ញុំដូចម្តេច ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ការបូជាធំ បានដល់ បូជាហើយដោយ ការឲ្យ ។ ពាក្យថា បូជាតូច បានដល់ ឲ្យហើយដោយការនាំទៅបូជា និង

ការទទួលរាក់ទាក់ ។ ពាក្យថា នាងជាឥស្សរៈនៃបុញ្ញកម្មរបស់យើងនោះទាំងអស់ បានដល់ នាងជាធំក្នុងបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ គឺអាចព្យាករបានថា នេះជាផលរបស់កម្មនេះ នេះជាផលរបស់កម្មនេះ ដូច្នេះ ។ ពាក្យថា មានរាងខ្លួនល្អ បានដល់ មានត្រគាកល្អ ។ ពាក្យថា មានក្លៀកល្អ មានវង់ចិញ្ចើមល្អ បានដល់ ប្រកបដោយចិញ្ចើម និងក្លៀកស្អាត ។ ពាក្យថា មានអវយវៈពាក់កណ្តាលខ្លួនល្អ បានដល់ ត្រង់កណ្តាលខ្លួន គឺចង្កេះស្អាត ។ ពាក្យថា នេះជាផលនៃកម្មរបស់ខ្ញុំដូចម្តេច សេចក្តីថានេះ ជាផលនៃកម្មអ្វី ក្នុងកម្មដែលខ្ញុំធ្វើហើយ ដែលជាហេតុឲ្យខ្ញុំបានទីពឹងក្នុងថ្ងៃនេះ ក្នុងមហាសមុទ្រដែលមិនមានទីពឹង ។

ទេពធីតាបានស្តាប់ដូច្នោះ គិតថា ព្រាហ្មណ៍នេះគង់សួរដោយយល់ថា អ្នកដទៃមិនដឹងកុសលកម្មដែលខ្លួនធ្វើ អញនឹងប្រាប់ដល់គេ កាលប្រាប់ដល់ហេតុដែលជាបុណ្យ ដែលព្រាហ្មណ៍បានប្រគេនឆត្រ និងស្បែកជើងដល់ព្រះបច្ចេកពុទ្ធ ក្នុងថ្ងៃឡើងសំពៅ ទើបពោលគាថាថា

បពិត្រសទ្ធព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើង ចំពោះភិក្ខុ ១
អង្គ ( ព្រះបច្ចេកពុទ្ធ ) ដែលមានជើងកំពុងរលាក ស្រេកឃ្លាន
លំបាក ក្នុងផ្លូវដ៏ក្តៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្តីប្រាថ្នាដល់
អ្នកក្នុងថ្ងៃនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ចំពោះភិក្ខុ ១ អង្គ ទេពធីតាពោលសំដៅដល់ព្រះបច្ចេកពុទ្ធមួយអង្គ ។ ពាក្យថា ដែលមានជើងកំពុងរលាក បាន

ដល់ ជើងដែលជាន់លើខ្សាច់ក្តៅ អធិប្បាយថា មានជើងត្រូវបៀតបៀន ។ ពាក្យថា ស្រេកឃ្លាន បានដល់ ស្រេកឃ្លាន ។ ពាក្យថា ប្រគេន បានដល់ ប្រគល់ឲ្យ គឺផ្តល់ឲ្យ ។ ពាក្យថា ឲ្យនូវសេចក្តីប្រាថ្នា បានដល់ ឲ្យនូវការប្រាថ្នាទាំងពួង ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ មានសេចក្តីត្រេកអរថា អញប្រគេនឆត្រ និងស្បែកជើង ជាផលឲ្យសម្រេចនូវការប្រាថ្នាទាំងពួងដល់អញ ក្នុងមហាសមុទ្រដែលមិនមានទីពឹងបែបនេះ គួរត្រេកអរ អញបានឲ្យល្អហើយ ទើបពោលគាថាថា

សូមឲ្យកើតសំពៅ ដែលពាសដោយផែនក្តារ ជាសំពៅមិនលិចទឹក ប្រកបដោយក្តោង និងខ្យល់ ព្រោះថា ក្នុងសមុទ្រនេះ មិនមែនជាភូមិនៃយានដទៃឡើយ សូមនាងចម្លងខ្ញុំ ឲ្យដល់នូវក្រុងមោលិនី ក្នុងថ្ងៃនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ដែលពាសដោយផែនក្តារ សេចក្តីថា ប្រកបដោយបន្ទះក្តារច្រើន ព្រោះជាសំពៅធំ ។ ឈ្មោះថា ជាសំពៅមិនលិចទឹក ព្រោះទឹកមិនហូរចូល ។ ឈ្មោះថា ប្រកបដោយក្តោង និងខ្យល់ ព្រោះខ្យល់នាំទៅរៀបរយ ។

ទេពធីតាបានស្តាប់ពាក្យរបស់ព្រះពោធិសត្វ មានសេចក្តីត្រេកអរក្រៃលែង ទើបនិម្មិតសំពៅសម្រេចដោយរតនៈគ្រប់ប្រភេទ បណ្តាយ ៨ ឧសភៈ ទទឹង ៤ ឧសភៈ ជម្រៅ ២០ ហត្ថ ហើយនិម្មិតសំពៅសម្រេច

ដោយកែវផ្ទនទីល ប្រាក់ និងមាសជាដើម ប្រកបដោយសសរក្ដោង ថែវ និងកន្ទៀរពេញដោយរតនៈ ៧ ប្រការ ហើយបីព្រាហ្មណ៍ឲ្យឡើងសំពៅ តែមិនដាក់ចិត្តនឹងអ្នកបម្រើរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍បានផ្សាយចំណែកបុណ្យអំពីសេចក្ដីល្អ ដែលខ្លួនធ្វើហើយដល់អ្នកបម្រើនោះ ។ អ្នកបម្រើក៏អនុមោទនា ។ ទេពធីតាក៏បីអ្នកបម្រើនោះឲ្យឡើងសំពៅ នាំសំពៅទៅដល់មោលិនីនគរ យកទ្រព្យទៅទុកដាក់ក្នុងផ្ទះរបស់ព្រាហ្មណ៍ ទើបត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ទេវតានោះ មានចិត្តត្រេកអរ រីករាយសប្បាយ និម្មិតសំពៅ
ដ៏វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំងបុរសឧបដ្ឋាក
ចូលទៅកាន់ក្រុងជាទីសុខសាន្ត ដូច្នេះ ។

ពិតមែន ដោយភាពសម្បូរនៃចិត្តរបស់ព្រះពោធិសត្វ និងដោយភាពដែលព្រះបច្ចេកពុទ្ធចេញចាកនិរោធ ក្នុងចេតនា ៧ យ៉ាង ចេតនាដើម ទើបជាចេតនាដែលឲ្យបានសោយផលក្នុងបច្ចុប្បន្ន និងមានផលច្រើនក្រៃលែង ។ សូម្បីផលនេះ គប្បីឃើញថា ជាផលតិចតួចនៃទាននោះ ទាននោះ មានផលប្រមាណមិនបាន ជាពោធិសម្ភារ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ហេតុនោះ បានជាតថាគត ចម្រើនដោយសេចក្ដីសុខ ដល់នូវ
សេចក្ដីសុខដោយរយគុណ ម្យ៉ាងទៀត តថាគតកាលបំពេញ
ទាន ក៏បានឲ្យទានដល់ព្រះបច្ចេកពុទ្ធយ៉ាងនេះឯង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តេន** បានដល់ ចាកព្រះបច្ចេកពុទ្ធនោះ ។ បទថា **សតគុណតោ** បានដល់ មួយរយដង ។ ក្នុងកាលនោះ តថាគត ជាសង្ខព្រាហ្មណ៍ ជាបុគ្គលសុខមាលជាតិ ព្រោះហេតុនោះ ទើបតថាគតបាន ទទួលសេចក្តីសុខ គឺចម្រើនដោយសុខ ។ម្យ៉ាងទៀត កាលបើដូច្នេះ ទើប តថាគតបំពេញទានឲ្យបរិបូណ៌ ។ ព្រះសាស្តា ទ្រង់ប្រកាសភាពដែល អធ្យាស្រ័យក្នុងទានរបស់ព្រះអង្គ ទូលំទូលាយថា តថាគតគិតយ៉ាងនេះថា សូមទានបារមីរបស់អាត្មាអញបរិបូណ៌ ទើបប្រគេនឆត្រ និងស្បែកជើងដល់ ព្រះបច្ចេកពុទ្ធអង្គនោះ មិនគិតដល់ទុក្ខក្នុងរាងកាយរបស់ខ្លួន ។

ព្រះពោធិសត្វនៅគ្រប់គ្រងផ្ទះ ដែលមានទ្រព្យរាប់មិនអស់ ដរាបដល់ អស់ជីវិត បានឲ្យទានសន្ទឹកសន្ធាប់ រក្សាសីល កាលអស់អាយុ ក៏ញុំាង ទេវនគរឲ្យពេញ មួយអន្លើដោយបរិស័ទ ។

ទេពធីតាក្នុងកាលនោះ បានជាឧប្បលវណ្ណាថេរី ក្នុងកាលឥឡូវនេះ បុរសអ្នកបម្រើក្នុងកាលនោះ បានជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ សង្ខព្រាហ្មណ៍ ក្នុងកាលនោះ បានជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

សង្ខព្រាហ្មណ៍នោះ រមែងបានទទួលបារមីទាំងនេះ គឺសីលបារមី ដោយ អំណាចនិច្ចសីល និងឧបោសថសីលដែលបរិសុទ្ធដោយល្អ ។ នេក្ខម្មបារមី ដោយអំណាចនៃកុសលធម៌ ព្រោះចេញចាកធម៌ដែលជាបដិបក្ខចំពោះទាន និងសីលជាដើម ។ វីរិយបារមី ដោយអំណាចនៃឧស្សាហៈក្រៃលែង ដើម្បី ឲ្យសម្រេចនូវទានបារមីជាដើម និងដោយអំណាចនៃសេចក្តីព្យាយាមធ្លងនូវ

មហាសមុទ្រ ។ ខន្តិបារមី ដោយអំណាចនៃការអត់ធ្មត់ដើម្បីប្រយោជន៍នោះ ។ សច្ចបារមី ដោយកិច្ចបដិបត្តិសមគួរដល់ប្តេជ្ញា អធិដ្ឋានបារមី ដោយអំណាចនៃការសមាទាន និងការតាំងចិត្តមិនញាប់ញ័រក្នុងទីទាំងពួង មេត្តាបារមី ដោយអំណាចនៃអធ្យាស្រ័យ អនុគ្រោះក្នុងសព្វសត្វទាំងឡាយ ឧបេក្ខាបារមី ដោយការដល់នូវភាពជាកណ្តាលក្នុងការខុសប្រក្រតី ដែលសត្វ និងសង្ខារធ្វើ ។ បញ្ញាបារមី គឺបញ្ញាដែលកើតឡើងឯង និងបញ្ញាដែលជាឧបាយកោសល ព្រោះដឹងធម៌ដែលជាឧបការៈ និងមិនជាឧបការៈនៃបារមីទាំងពួងហើយ លះនូវធម៌មិនជាឧបការៈ ប្រាថ្នាបដិបត្តិក្នុងធម៌ជាឧបការៈ ។

ទេសនាប្រព្រឹត្តទៅហើយ ដោយអំណាចនៃទានបារមី ដែលជាការទូលំទូលាយក្រៃលែង ដល់បុគ្គលមានអធ្យាស្រ័យក្នុងការឲ្យ ។ម្យ៉ាងទៀត ព្រោះក្នុងទីនេះ បាននូវបារមីគ្រប់ ១០ ប្រការដូច្នោះ ក្នុងឥឡូវនេះ គួរពោលចំពោះដល់គុណរបស់ព្រះពោធិសត្វ មានមហាករុណាជាដើម ខាងក្រោយតាមសមគួរ ។ ម្យ៉ាងទៀត គប្បីជ្រាបគុណរបស់ព្រះមហាសត្វយ៉ាងនេះថា ការមិនពិចារណាដល់ភោគសុខរបស់ខ្លួន គិតដោយមហាករុណាថា អញនឹងបំពេញទានបារមី ហើយត្រៀមការធ្វើដំណើរឆ្លងសមុទ្រ ដើម្បីនាំសម្ភារៈ ក្នុងការឲ្យទៅ ការចុះទៅក្នុងសមុទ្រ ក៏អធិដ្ឋានឧបោសថ ក្នុង

សមុទ្រនោះ និងការមិនបរិភោគអាហារដែលទេពធីតានាំចូលទៅជិត ព្រោះខ្លាចដាច់សីល ។ ឥឡូវនេះ កាលពោលដល់ការប្រព្រឹត្តដ៏សេស គប្បីជ្រាបដល់ការពោលចំពោះគុណដោយន័យនេះឯង ។ ខ្ញុំនឹងពោលត្រឹមតែការផ្សេងគ្នាក្នុងទីនោះៗ ប៉ុណ្ណោះ ដោយហេតុនោះ ទើបលោកពោលថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វី ដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។l៙

## អដ្ឋកថាសង្ខព្រាហ្មណចរិយា ចប់

# សុត្តន្តបិដក

## កុរុធម្មចរិយានី ៣

[ ៣ ] ចរិយាដទៃទៀត កាលតថាគតជាស្តេច ឈ្មោះធនញ្ជ័យ នៅក្នុងឥន្ទបត្តបុរីដ៏ឧត្តម ប្រកបដោយកុសលធម៌ ១០ ព្រាហ្មណ៍ទាំងឡាយ នៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឲ្យបានទ្រព្យ ដែលគេសន្មតថា ជាសត្វមង្គល ដោយពាក្យថា ជនបទ ( នៃយើងខ្ញុំព្រះអង្គ ) មិនមានភ្លៀង ទុរ្ភិក្ស អត់ឃ្លានខ្លាំងណាស់ សូមព្រះអង្គប្រទានដំរីប្រសើរ ដែលមានសម្បុរខៀវ ឈ្មោះអញ្ជន ។ បើស្មូមមកដល់ហើយ តថាគតមិនគួរប្រកែក ការសមាទានរបស់តថាគត កុំបែកធ្លាយឡើយ ដូច្នេះ តថាគតនឹងឲ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ ប្រូចទឹកកុណ្ឌី ជាវិការនៃកែវ លើដៃព្រាហ្មណ៍ហើយឲ្យដំរីដល់ព្រាហ្មណ៍ ។ កាលតថាគតបានឲ្យដំរី ដល់ពួកព្រាហ្មណ៍ហើយ មានពួកអាមាត្យក្រាបទូលពាក្យនេះថា ហេតុដូចម្តេច បានជាព្រះអង្គ ប្រទានដំរីដ៏ប្រសើររបស់ព្រះអង្គ ដែលជាដំរីនាំឲ្យបានទ្រព្យ ប្រកបដោយមង្គល ជាដំរីឧត្តមក្នុងសង្គ្រាមជ័យ ដល់ពួកស្មូម កាលបើព្រះអង្គប្រទានដំរីដ៏ប្រសើរ ដល់ពួកស្មូម

នោះហើយ ព្រះអង្គសោយរាជ្យធ្វើអ្វី ។ តថាគតតបថា តថាគត អាចនឹងឲ្យរាជ្យទាំងអស់ របស់តថាគតដល់ស្មូមក៏បាន ឬនឹងឲ្យសរីរៈរបស់ខ្លួនដល់ពួកស្មូមក៏បាន ដ្បិតសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគត ឲ្យដំរីដ៏ប្រសើរ ។

## កុរុធម្មចរិយាទី ៣ ចប់

# អដ្ឋកថា

## កុរុធម្មចរិយា

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុរុធម្មចរិយាទី ៣ ដូចតទៅ បទថា **ឥន្ទបត្តេ បុរុត្តមេ** បានដល់ ក្នុងនគរដ៏ឧត្តម នគរដ៏ប្រសើរ នៃដែនកុរុ ឈ្មោះឥន្ទបត្តៈ ។ បទថា **រាជា** ឈ្មោះថា **រាជា** ព្រោះធ្វើបរិស័ទឲ្យត្រេកអរ ដោយសង្គហវត្ថុ ៤ ដោយធម៌ ដោយស្មើ ។ បទថា **កុសលេ ទសហុបាគតោ** បានដល់ ប្រកបដោយកុសលកម្ម ១០ ប្រការ អធិប្បាយថា ប្រកបដោយបុញ្ញកិរិយាវត្ថុ ១០ មានទានមយៈជាដើម ឬប្រកបដោយកុសលកម្មបថ ១០ ។

បទថា **កាលិង្គរដ្ឋវិសយា** បានដល់ ពួកព្រាហ្មណ៍អ្នកកាលិង្គរដ្ឋ ។ បទថា **ព្រាហ្មណា ឧបគញ្ចុ មំ** បានដល់ ព្រាហ្មណ៍ ៨ នាក់ ដែលស្ដេចកាលិង្គៈបញ្ជូនមក បានមករកតថាគត កាលចូលទៅរកហើយ បានសូមស្ដេចគជសារនឹងតថាគត គឺបានសូមស្ដេចដំរីដែលជាមហានាគនឹងតថាគត ។ បទថា **ធញ្ញំ** បានដល់ ស្ដេចគជសារ សម្បូរដោយលក្ខណៈដ៏មានសិរីសមគួរជាគជសារព្រះទីន័ង ។ បទថា **មង្គលសម្មតំ** បានដល់ ដែលជនទាំងឡាយឃើញយ៉ាងក្រៃលែងថា ជាមង្គលហត្ថី ជាហេតុនៃសេចក្ដីចម្រើនក្រៃលែង ដោយលក្ខណសម្បត្តិនោះឯង ។

បទថា **អវុដ្ឋិកោ** បានដល់ ប្រាសចាកភ្លៀង ។ បទថា **ទុព្ភិក្ខោ** បានដល់ រកអាហារបានដោយក្រ ។ បទថា **ឆាតកោ មហា** បានដល់ កើតនូវ

ជំងឺតម្កាត់ ព្រោះសេចក្ដីស្រេកឃ្លានខ្លាំង ។ បទថា **ឧបាហរិ** បានដល់ សូមទ្រង់ព្រះរាជទាន ។ បទថា **ធីលំ** បានដល់ មានពណ៌ខៀវ ។ បទថា **អញ្ជនសន្នាយំ** បានដល់ គួរហៅឈ្មោះ ដោយ **អញ្ជន** សព្ទ អធិប្បាយថា មានឈ្មោះថា អញ្ជនៈ ។ លោកអធិប្បាយពាក្យនេះថា ដែនកាលិង្គៈរបស់ទូលបង្គំ ភ្លៀងមិនធ្លាក់ ដោយហេតុនោះ ទើបឥឡូវនេះ កើតមហាទុព្ភិក្ខភ័យ មហាធាតកភ័យ ក្នុងដែននោះ ដើម្បីស្ងប់ភ័យនោះ សូមទ្រង់ព្រះរាជទានមង្គលហត្ថីឈ្មោះអញ្ជនៈរបស់ព្រះអង្គ ដែលដូចគ្នានឹងអញ្ជនគិរីនេះចុះ ព្រោះថា កាលនាំស្ដេចដំរីនេះទៅក្នុងដែននោះហើយ ភ្លៀងនឹងធ្លាក់ ភ័យសព្វយ៉ាងនឹងស្ងប់ដោយគជសារនោះពិត គប្បីជ្រាបអនុបុព្វីកថាក្នុងរឿងនោះដូចតទៅ

ក្នុងអតីតកាល ក្នុងឥន្ទបត្តនគរ ដែនកុរុ ព្រះពោធិសត្វទ្រង់កាន់យកបដិសន្ធិ ក្នុងផ្ទៃរបស់អគ្គមហេសីនៃព្រះបាទកុរុរាជ ដល់នូវការចម្រើនវ័យដោយលំដាប់ ទៅកាន់នគរតក្កសិលា រៀននូវសិល្បសាស្ត្រ ដែលជាប្រយោជន៍ក្នុងការគ្រប់គ្រង និងវិជ្ជាគោល ។ កាលរៀនចប់ ត្រឡប់មកកាន់ព្រះនគរ ព្រះជនកទ្រង់តែងតាំងក្នុងតំណែងឧបរាជ ។ ក្នុងកាលតមក កាលព្រះបិតាសោយទិវង្គត បានទទួលអភិសេកជាព្រះរាជា តាំងនៅក្នុងទសពិធរាជធម៌ គ្រប់គ្រងរាជសម្បត្តិដោយធម៌ មានព្រះនាមថា ធនញ្ជ័យ ។ ព្រះបាទធនញ្ជ័យទ្រង់សាងរោងទាន ៦ កន្លែង គឺត្រង់ទ្វារនគរ ៤ កន្លែង ត្រង់កណ្ដាលនគរ ១ កន្លែង ត្រង់ទ្វារព្រះរាជនិវេសន៍ ១ កន្លែង ទ្រង់លះទ្រព្យមួយថ្ងៃ ៦ សែន ទ្រង់ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមានទន្ទ័លលើកឡើង

ហើយទ្រង់បរិច្ចាគទាន ព្រោះទ្រង់មានព្រះអធ្យាស្រ័យក្នុងការបរិច្ចាគ សេចក្តីត្រេកអរក្នុងទាន ផ្សាយទូទៅពេញជម្ពូទ្វីប ។

ក្នុងកាលនោះ ដែនកាលិង្គៈកើតនូវភ័យ ៣ យ៉ាង គឺទុព្ភិក្ខភ័យ ១ ឆាតកភ័យ ១ រោគភ័យ ១ ។ អ្នកដែនទាំងមូល នាំគ្នាទៅកាន់ទន្តបុរី ក្រាបទូលដោយសំឡេងអឺងកងត្រង់ទ្វារព្រះរាជវាំងថា បពិត្រទេវៈ សូមទ្រង់ឲ្យភ្លៀងធ្លាក់ចុះ ។ ព្រះរាជាស្តាប់ដូច្នោះហើយ ត្រាស់សួរពួកអមាត្យថា ពួកប្រជាជននាំគ្នាស្រែកអ្វី ពួកអមាត្យក្រាបទូលសេចក្តីនោះ ដល់ព្រះរាជា ។ ព្រះរាជាមានព្រះតម្រាស់សួរថា ព្រះរាជាអង្គមុន កាលភ្លៀងមិនធ្លាក់ តើទ្រង់ធ្វើដូចម្តេច ពួកអមាត្យក្រាបទូលថា ព្រះរាជាក្នុងកាលមុន ទ្រង់ឲ្យទានអធិដ្ឋានឧបោសថ ទ្រង់សមាទានសីល យាងចូលបន្ទប់ដ៏មានសិរីផ្ទំអស់ ៧ ថ្ងៃ ដោយទ្រង់អធិដ្ឋានថា សូមឲ្យភ្លៀងធ្លាក់ ។ ព្រះរាជាស្តាប់ដូច្នោះ ទ្រង់ក៏ធ្វើយ៉ាងនោះ ភ្លៀងក៏មិនធ្លាក់ ។ ព្រះរាជាត្រាស់ថា យើងបានធ្វើកិច្ចដែលគួរធ្វើហើយ ភ្លៀងក៏មិនធ្លាក់ កាលបើយ៉ាងនេះ យើងនឹងធ្វើដូចម្តេចតទៅ ពួកអមាត្យក្រាបទូលថា បពិត្រព្រះអង្គ កាលនាំស្តេចគជសារមង្គលហត្ថីរបស់ព្រះបាទធនញ្ជយកុរុរាជ ក្នុងឥន្ទបត្តនគរមក ភ្លៀងនឹងធ្លាក់ ។ ព្រះរាជាត្រាស់ថា ព្រះរាជាអង្គនោះ មានពលពាហនៈរឹងប៉ឹង ធ្វើឲ្យចាញ់បានលំបាក យើងនឹងនាំស្តេចគជសាររបស់ព្រះអង្គមកបានដូចម្តេច ពួកអមាត្យក្រាបទូលថា បពិត្រមហារាជ ទ្រង់មិនចាំបាច់ច្បាំងជាមួយព្រះរាជានោះឡើយ ព្រះរាជាអង្គនោះ មានអធ្យាស្រ័យក្នុងការបរិច្ចាគ ទ្រង់ត្រេកអរក្នុងទាន កាលមានបុគ្គល

ទូលសូមហើយ សូម្បីព្រះសិរសាដែលប្រដាប់តាក់តែងហើយ ក៏កាត់ឲ្យបាន សូម្បីព្រះនេត្រដែលមានបសាទបរិបូណ៌ ក៏ទ្រង់ខ្វេះឲ្យបាន សូម្បីរាជសម្បត្តិទាំងមូល ក៏ទ្រង់ប្រគល់ឲ្យបាន មិនចាំបាច់ពោលដល់ស្តេចដំរីឡើយ កាលទូលសូមហើយ ទ្រង់នឹងព្រះរាជទានពិត ព្រះរាជាត្រាស់សួរថា អ្នកណាអាចទូលសូមបាន ពួកអមាត្យក្រាបទូលថា បពិត្រមហារាជ គឺពួកព្រាហ្មណ៍ ព្រះរាជាត្រាស់ឲ្យហៅព្រាហ្មណ៍ ៨ នាក់ចូលគាល់ ធ្វើសក្ការៈ និងការរាប់អានហើយ ទ្រង់ឲ្យស្មៀងបញ្ជូនទៅ ដើម្បីសូមស្តេចគជសារ ។ ព្រាហ្មណ៍ទាំងនោះ ប្រញាប់ទៅស្នាក់នៅក្នុងទីគ្រប់កន្លែងត្រឹមតែមួយរាត្រី បរិភោគអាហារត្រង់រោងទាន ក្បែរទ្វារនគរ នៅអស់កាលបន្តិចបន្តួច កាលថ្ងៃតស្កប់ស្កល់ហើយ ក៏ឈរត្រង់ទ្វារទិសខាងកើត រង់ចាំព្រះរាជាមកកាន់រោងទាន ព្រះពោធិសត្វទ្រង់ស្រពស្រង់អំពីព្រលឹម ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ឡើងកាន់កដំរីដ៏ប្រសើរ ដែលតាក់តែងហើយ យាងទៅកាន់រោងទានដោយរាជានុភាពធំ ទ្រង់ព្រះរាជទានដល់ជន ៧-៨ នាក់ ដោយព្រះហស្តឯងហើយ ត្រាស់ថា ចូរពួកអ្នកឲ្យដោយទំនងនេះឯង ទ្រង់ឡើងកាន់គជសារហើយ យាងទៅកាន់ទ្វារទិសខាងត្បូង ពួកព្រាហ្មណ៍មិនបានឱកាស ព្រោះទិសខាងកើត មានការរក្សាតឹងរ៉ឹង ទើបទៅកាន់ទ្វារទិសខាងត្បូង រង់ចាំមើលព្រះរាជាយាងមក នាំគ្នាឈរលើទួលមិនឆ្ងាយអំពីទ្វារ កាលព្រះរាជាយាងមកដល់ ក៏លើកដៃថ្វាយជយមង្គល ។ ព្រះរាជាទ្រង់បញ្ជូរដំរីឲ្យត្រឡប់ដោយកង្វេរពេជ្រ យាងទៅរកព្រាហ្មណ៍ទាំងនោះ ត្រាស់សួរ

ពួកព្រាហ្មណ៍ថា ពួកអ្នកត្រូវការអ្វី ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ អ្នកដែនកាលិង្គៈ ត្រូវទុព្ភិក្ខភ័យ ឆាតកភ័យ និងរោគភ័យបៀតបៀន ការបៀតបៀននោះ នឹងស្ងប់ទៅបាន កាលនាំស្តេចមង្គលហត្ថីរបស់ទ្រង់នេះទៅ ព្រោះហេតុនោះ សូមទ្រង់ព្រះរាជទានស្តេចដំរី ដែលមានពណ៌ដូចផ្កាអញ្ចន នេះ ដល់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយ នៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើរ ។បេ។ សូមព្រះអង្គប្រទានដំរីដ៏ប្រសើរ ដែលមានសម្បុរខៀវ ឈ្មោះអញ្ចន ដូច្នេះ ។ សេចក្តីនៃពាក្យនោះ មានអធិប្បាយទុកហើយ ។

លំដាប់នោះ ព្រះពោធិសត្វទ្រង់ត្រាស់ថា ការដែលយើងទម្លាយសេចក្តីត្រូវការរបស់យាចកទាំងឡាយ និងទម្លាយកុសលសមាទានរបស់យើង មិនជាការសមគួរដល់យើង ទើបចុះអំពីកស្តេចដំរី ទ្រង់ព្រះតម្រិះថា បើមានទីដែលមិនបានតាក់តែង អញនឹងតាក់តែងហើយសឹមឲ្យ ទើបទ្រង់ពិនិត្យមើលដោយជុំវិញ មិនបានឃើញទីដែលមិនបានតាក់តែង ទើបទ្រង់ចាប់ស្តេចដំរីត្រង់ប្រមោយ ដាក់ក្នុងដៃរបស់ព្រាហ្មណ៍ ទ្រង់ប្រួចទឹក ដែលអប់ដោយផ្កា និងគ្រឿងក្រអូបដោយឃ្នោកមាស ហើយព្រះរាជទានដល់ព្រាហ្មណ៍ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

បើសូមមកដល់ហើយ តថាគតមិនគួរប្រកែក ការសមាទានរបស់តថាគត កុំបែកធ្លាយឡើយ ដូច្នេះ តថាគតនឹងឲ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ ប្រួចទឹកកុណ្ឌិជាវិការនៃកែវលើដៃព្រាហ្មណ៍ ហើយឲ្យដំរីដល់ព្រាហ្មណ៍ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យាចកមនុប្បត្តេ** បានដល់ យាចកទាំងឡាយ ដែលមកដល់ហើយ ។ បទថា **អនុច្ឆវោ** បានដល់ សមរម្យសមគួរ ។ បទថា **មា មេ ភិជ្ជិ សមាទានំ** សេចក្តីថា កុសលសមាទានឯណារបស់យើងដែលតម្កល់ទុកថា អញ កាលឲ្យវត្ថុទាំងពួងដែលមិនមានទោសដែលយាចកទាំងពួងត្រូវការ ក៏នឹងបំពេញទានបារមីឲ្យបរិបូរដើម្បីប្រយោជន៍ដល់សព្វញ្ញុតញ្ញាណបាន កុសលសមាទាននោះកុំបែកធ្លាយឡើយ ព្រោះហេតុនោះ អញនឹងឲ្យស្តេចដំរីដ៏ប្រសើរ បានដល់ អញនឹងឲ្យមង្គលហត្ថីដ៏ធំនេះ ។ បទថា **អទំ** ស្មើគ្នានឹង **អទាសិំ** ( បានឲ្យ ) ។

កាលព្រះរាជទានស្តេចដំរីហើយ ពួកអមាត្យនាំគ្នាក្រាបទូលព្រះពោធិសត្វថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបទ្រង់ព្រះរាជទានមង្គលហត្ថី គួរព្រះរាជទានដំរីដទៃមិនមែនឬ មង្គលហត្ថីទូន្មានសម្រាប់ជាដំរីជំនិះបែបនេះដែលព្រះរាជាទ្រង់បំណងភាពជាធំ និងជ័យជម្នះ មិនគួរព្រះរាជទានឡើយ ។ ព្រះមហាសត្វត្រាស់ថា យើងនឹងឲ្យវត្ថុដែលយាចកទាំងឡាយសូមជាមួយយើង បើសូមរាជសម្បត្តិ យើងក៏ឲ្យរាជសម្បត្តិដល់ពួកគេ សព្វញ្ញុតញ្ញាណប៉ុណ្ណោះ ជាទីស្រឡាញ់ក្រៃលែងជាងរាជសម្បត្តិ និងជាងជីវិតរបស់យើង

ព្រោះហេតុនោះ ទើបយើងឲ្យដំរីនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **តស្ស នាគេ បទិន្នម្ហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **តស្ស** បានដល់ កាលទ្រង់ព្រះរាជទានស្ដេចដំរីនោះហើយ ។

បទថា **មង្គលសម្បន្នំ** បានដល់ ប្រកបដោយគុណដែលជាមង្គល ។ បទថា **សង្គាមវិជយុត្តមំ** សេចក្ដីថា ដ៏ឧត្ដម ព្រោះឈ្នះក្នុងសង្គ្រាម ឬស្ដេចដំរីដ៏ឧត្ដមជាប្រធានដ៏ប្រសើរក្នុងការឈ្នះសង្គ្រាម ។ បទថា **កឹ តេ រជ្ជំ ការិស្សតិ** លោកសម្ដែងថា កាលស្ដេចដំរីទៅហើយ ព្រះអង្គនឹងសោយរាជសម្បត្តិបានដូចម្ដេច នឹងធ្វើរាជសម្បត្តិបានដូចម្ដេច រាជសម្បត្តិក៏នឹងដាច់សូន្យទៅ ។

បទថា **រជ្ជម្បិ មេ ទទេ សព្វំ** សេចក្ដីថា ស្ដេចដំរីជាសត្វតិរច្ឆាន ចូរស្ទះចុះ សូម្បីដែនកុរុទាំងអស់នេះ យើងក៏គប្បីឲ្យដល់អ្នកសូមទាំងឡាយបាន ។ បទថា **សរីរំ ទជ្ជមត្តនោ** សេចក្ដីថា នឹងពោលថ្វី ដល់រាជសម្បត្តិ សូម្បីសរីរៈរបស់ខ្លួន យើងក៏គប្បីឲ្យដល់ស្មូមទាំងឡាយបាន ។ វត្ថុគ្រប់គ្រងទាំងខាងក្នុង ទាំងខាងក្រៅ ទាំងអស់របស់យើង យើងក៏លះឲ្យ ដើម្បីប្រយោជន៍ដល់សត្វលោកបាន ។ ព្រះអង្គសម្ដែងថា ព្រោះសព្វញ្ញុតញ្ញាណ និងភាពជាព្រះសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់យើង ដែលបុគ្គលមិនបំពេញបារមីទាំងពួង មានទានបារមីជាដើម មិនអាចនឹងឲ្យបាន ហេតុនោះទើបយើងឲ្យស្ដេចដំរី ។

កាលស្ដេចដំរីមកក្នុងដែនកាលិង្គៈហើយ ភ្លៀងក៏មិនធ្លាក់នោះឯង ព្រះ

បាទកាលិង្គៈត្រាស់សួរថា ឥឡូវនេះ ភ្លៀងក៏មិនធ្លាក់ អ្វីហ្ន៎ជាហេតុ ។ ទ្រង់ជ្រាបថា ព្រះបាទកុរុទ្រង់រក្សាគុរុធម៌ ដោយហេតុនោះ ទើបក្នុងដែនរបស់ព្រះអង្គភ្លៀងធ្លាក់រៀងរាល់កន្លះខែ ឬ ១០ ថ្ងៃតាមលំដាប់ នេះជាគុណានុភាពរបស់ព្រះរាជា មិនមែនអានុភាពរបស់សត្វតិរច្ឆាននេះ ទើបទ្រង់បញ្ជូនអមាត្យទៅដោយព្រះតម្រាស់ថា យើងនឹងរក្សាគុរុធម៌ដោយខ្លួនឯង ចូរពួកអ្នកទៅចម្លងគុរុធម៌ទាំងនោះ ក្នុងរាជសម្នាក់របស់ព្រះបាទធនញ្ជយកោរព្យៈ ដាក់ក្នុងក្រាំងមាសហើយនាំមក ។ លោកហៅសីល ៥ ថា គុរុធម៌ ។ ព្រះពោធិសត្វទ្រង់រក្សាសីលទាំង ៥ នោះ ធ្វើឲ្យបរិសុទ្ធយ៉ាងល្អ ។ មួយយ៉ាងទៀត ព្រះមាតាអគ្គមហេសី ប្អូនប្រុសដែលជាឧបរាជ ព្រាហ្មណបុរោហិត អមាត្យ អ្នកវាស់វែង សារថី សេដ្ឋី អ្នកវាល់ស្រូវ ឆ្មាំទ្វារ នាងវណ្ណទាសី ដែលជានគរសោភិនី ក៏រក្សាគុរុធម៌ ដូចព្រះពោធិសត្វ ដោយហេតុនោះ ទើបលោកពោលថា

ជន ១១ នាក់ គឺព្រះរាជា ១ ព្រះជននី ១ មហេសី ១ ឧបរាជ
១ បុរោហិត ១ អ្នកវាស់វែង ១ សារថី ១ សេដ្ឋី ១ អ្នកវាល់
ស្រូវ ១ ឆ្មាំទ្វារ ១ ស្រីគណិកា ១ តាំងនៅក្នុង គុរុធម៌[១] ។

ពួកអមាត្យទាំងនោះ ចូលទៅគាល់ព្រះពោធិសត្វ ថ្វាយបង្គំហើយក្រាបទូលសេចក្តីនោះ ។ ព្រះមហាសត្វត្រាស់ថា យើងមានការសន្ទិះសង្ស័យក្នុងគុរុធម៌ តែព្រះជននីរបស់យើងរក្សាយ៉ាងល្អ ចូរពួកអ្នកទទួលក្នុងសម្នាក់

---

១- ក្នុងជាតកជាកុរុធម៌ ។

របស់ព្រះជននីយើងចុះ ។ ពួកអមាត្យទូលអង្វរថា បពិត្រមហារាជ ឈ្មោះថាការវង្វៀស រមែងមានដល់អ្នកត្រូវការអាហារ មានការប្រព្រឹត្តផុសខាត់កិលេស សូមទ្រង់ព្រះរាជទានដល់ពួកខ្ញុំព្រះអង្គចុះ ហើយត្រាស់ឲ្យរចនាចុះក្នុងក្រាំងមាសថា មិនគួរសម្លាប់សត្វ ១ មិនគួរលួចទ្រព្យ ១ មិនគួរប្រព្រឹត្តខុសក្នុងកាម ១ មិនគួរនិយាយកុហក ១ មិនគួរផឹកទឹកស្រវឹង ១ កាលពួកព្រាហ្មណ៍ចារឹកស្រេចហើយ ទើបត្រាស់ថា ចូរពួកអ្នកទៅទូលក្នុងសម្នាក់របស់ព្រះមាតាយើងចុះ ។

ពួកទូតថ្វាយបង្គំព្រះរាជាហើយ ទៅកាន់សម្នាក់របស់ព្រះមាតា ក្រាបទូលថា បពិត្រព្រះទេវី បានឮថា ព្រះនាងរក្សាគុរុធម៌ សូមព្រះនាងព្រះរាជ-ទានគុរុធម៌នោះ ដល់ទូលបង្គំទាំងឡាយចុះ ។ ព្រះមាតារបស់ព្រះពោធិសត្វក៏ត្រាស់ថា នៅមានសេចក្តីវង្វៀសដូចគ្នា តែកាលពួកព្រាហ្មណ៍អង្វរ ក៏បានព្រះរាជទានឲ្យ ។ សូម្បីព្រះមហេសីជាដើមក៏ដូចគ្នា ។ ពួកព្រាហ្មណ៍បានចម្លងគុរុធម៌ដាក់ក្នុងក្រាំងមាស ក្នុងសម្នាក់ជនទាំងអស់ ហើយវិលទៅកាន់ទន្តបុរី ថ្វាយដល់ព្រះបាទកាលិង្គៈ ហើយទូលរឿងឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់បដិបត្តិក្នុងធម៌នោះ ទ្រង់បំពេញសីល ៥ ឲ្យបរិបូណ៌ ។ បន្ទាប់អំពីនោះភ្លៀងក៏ធ្លាក់ក្នុងដែនកាលិង្គៈ ។ ភ័យ ៣ ប្រការក៏ស្ងប់ ដែនក៏បានជាដែនក្សេម ភិក្ខាក៏រកបានងាយ ព្រះពោធិសត្វទ្រង់បំពេញបុណ្យ មានទានជាដើមដរាបដល់អស់ព្រះជន្មាយុ មួយអន្លើដោយបរិស័ទ ក៏ទៅកើតក្នុងស្ថានសួគ៌ ។

ស្រីគណិកាជាដើម ក្នុងកាលនោះ បានជាឧប្បលវណ្ណាជាដើម ក្នុង

កាលឥឡូវនេះ សមដូចព្រះមានព្រះភាគត្រាស់ថា

ស្រីគណិកាក្នុងកាលនោះ បានមកជាឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ អ្នកឆ្មាំទ្វារក្នុងកាលនោះ បានមកជាបុណ្ណៈ ក្នុងកាលឥឡូវនេះ អ្នកវាស់វែងក្នុងកាលនោះ បានមកជាកច្ចានៈ ក្នុងកាលឥឡូវនេះ អ្នកវាល់ស្រូវក្នុងកាលនោះ បានមកជាកោលិតៈ ក្នុងកាលឥឡូវនេះ សេដ្ឋីក្នុងកាលនោះ បានមកជាសារីបុត្ត ក្នុងកាលឥឡូវនេះ សារថីក្នុងកាលនោះ បានមកជាអនុរុទ្ធ ក្នុងកាលឥឡូវនេះ ព្រាហ្មណ៍ ( បុរោហិត ) ក្នុងកាលនោះ បានមកជាកស្សបត្ថេរ ក្នុងកាលឥឡូវនេះ ឧបរាជក្នុងកាលនោះ បានមកជានន្ទបណ្ឌិត ក្នុងកាលឥឡូវនេះ មហេសីក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ ព្រះមាតាក្នុងកាលនោះ បានមកជាព្រះនាងមហាមាយាទេវី ក្នុងកាលឥឡូវនេះ ព្រះពោធិសត្វដែលជាព្រះរាជាក្នុងដែនកុរុ ក្នុងកាលនោះ បានមកជាតថាគត ពួកអ្នកចូរចាំទុកនូវជាតក ដោយប្រការដូច្នេះ ។

ក្នុងទីនេះ ធម៌ដ៏សេស មានទេក្ខម្មបារមីជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ៕ល៚

## អដ្ឋកថាកុរុរាជចរិយា ចប់

# សុត្តន្តបិដក

## មហាសុទស្សនចរិយាទី ៤

[ ៤ ] កាលតថាគតជាក្សត្រចក្រពត្តិ ឈ្មោះមហាសុទស្សនៈ មានពលច្រើន នៅក្នុងនគរកុសាវតី ។ ក្នុងនគរនោះ តថាគត បានឲ្យគេឃោសនាក្នុងមួយថ្ងៃ ៣ ដង ក្នុងទីនោះៗ ថា អ្នកណា ប្រាថ្នាចង់បានអ្វី ចូរឲ្យនូវទ្រព្យអ្វីដល់អ្នកណា ។ អ្នកណាឃ្លាន អ្នកណាស្រេក អ្នកណា ( ប្រាថ្នា ) នូវកម្រងផ្កា អ្នកណា ( ប្រាថ្នា ) នូវគ្រឿងលាប អ្នកណាអាក្រាត នឹងស្លៀកដណ្តប់នូវសំពត់ទាំង ឡាយ ដែលជ្រលក់ដោយពណ៌ផ្សេងៗ អ្នកណាយកឆត្រ ( ដើម្បី បាំង ) ក្នុងផ្លូវ អ្នកណាយកស្បែកជើងដ៏ទន់ល្អ ( ដើម្បីពាក់ក្នុង ផ្លូវ ) ។ តថាគតឲ្យគេឃោសនាក្នុងវេលាព្រឹក ( ថ្ងៃត្រង់ ) ល្ងាច ក្នុងទីនោះៗ ដូចបានពោលហើយ ក្នុងខាងលើ ទាននោះ តថាគត មិនមែនចាត់ចែងតែក្នុងទី ១០ កន្លែង មិនមែនចាត់ចែងតែក្នុងទី មួយរយកន្លែងទេ ។ ទ្រព្យដែលតថាគតចាត់ចែងចំពោះស្មូម ក្នុង ទីច្រើនរយកន្លែង សម្រាប់ពួកវណិព្វកៈ ដែលមកក្នុងវេលាថ្ងៃ ឬមកក្នុងវេលាយប់ ។ ពួកស្មូម លុះតែបានភោគៈគួរតាមសេចក្តី ប្រាថ្នា ពេញក្នុងដៃហើយ ទើបបានដើរចេញទៅ តថាគតបានឲ្យ

មហាទានបែបនេះ ដរាបដល់អស់ជីវិត ។ តថាគតមិនឲ្យទ្រព្យដែលមិនជាទីគាប់ចិត្តទេម្យ៉ាងទៀត តថាគតមិនមែនជាអ្នកមិនសន្សំទ្រព្យទុកទេ ដូចបុរសកើតរោគក្តៅក្រហាយ ចង់ជារោគញុំាងពេទ្យឲ្យស្កប់ស្កល់ដោយទ្រព្យ រមែងរួចចាករោគ យ៉ាងណាមិញ តថាគតកាលដឹងច្បាស់ថា ( ការឲ្យទាន ជាឧបាយ ) ដើម្បីបំពេញអធ្យាស្រ័យរបស់សត្វ ដោយមិនមានសេសសល់ តថាគតឲ្យទានចំពោះស្មូម ដើម្បីបំពេញចិត្តស្មូម ដែលខ្វះកន្ទះ តថាគតជាអ្នកមិនមានអាល័យ មិនមានសេចក្តីប៉ុនប៉ង ( ចំពោះផលនៃទាននោះទេ តថាគតឲ្យទាន ) ដើម្បីបានត្រាស់ដឹង នូវសម្ពោ-ធិញ្ញាណយ៉ាងនេះឯង ។

## មហាសុទស្សនចរិយាទី ៤ ចប់

# អដ្ឋកថា

## មហាសុទស្សនចរិយា

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាសុទស្សនចរិយាទី ៤ ដូចតទៅ បទថា **កុសាវតិម្ហិ នគរេ** បានដល់ ក្នុងនគរឈ្មោះកុសាវតី ។ ក្នុងទីនោះ ឥឡូវនេះ ជានគរកុសិនារា ។ បទថា **មហីបតិ** បានដល់ ជាស្តេចមាន ឈ្មោះថា មហាសុទស្សនៈ ។ បទថា **ចក្កវត្តិ** មានវិគ្គហៈថា បុគ្គលណា ញុំាងចក្រឲ្យវិលទៅ ឬវិលទៅដោយចក្កសម្បត្តិ ៤ ញុំាងចក្រដទៃ ក្រៅ អំពីចក្កសម្បត្តិទាំងនោះ ឲ្យប្រព្រឹត្តទៅ មានការវិលទៅនៃចក្រ គឺឥរិយាបថ ដើម្បីប្រយោជន៍ដល់អ្នកដទៃ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ចក្កវត្តិ** ។ ម្យ៉ាងទៀត ឈ្មោះថា **ចក្កវត្តិ** ព្រោះមានការវិលទៅនៃចក្រ គឺ អាណាខេត្ត ដែលអ្នកដទៃគ្របសង្កត់មិនបាន បំពានមិនបាន ព្រោះប្រកប ដោយសង្គហវត្ថុដែលជាអច្ឆរិយធម៌ ៤ ប្រការ ។ ឈ្មោះថា **មហព្វលោ** ព្រោះប្រកបដោយពួកពលច្រើន មានបរិនាយករតនៈជាប្រធាន មានហត្ថីរតនៈ ជាដើមជាប្រធាន និងដោយកម្លាំងព្រះវរកាយដែលកើតដោយបុញ្ញានុភាព ។ គប្បីភ្ជាប់សេចក្តីជាមួយពាក្យថា **យទា អាសឹ** ( ក្នុងកាលណា ) ។ ក្នុង ពាក្យនោះ គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះថា

បានឮថា ក្នុងអតីតកាល ព្រះមហាបុរសកើតក្នុងត្រកូលគហបតី ក្នុង អត្តភាពទី ៣ មុនអត្តភាពដែលជាស្តេចចក្រពត្តិមហាសុទស្សនៈ ចូលទៅ កាន់ព្រៃដោយការងាររបស់ខ្លួន ឃើញព្រះថេរៈមួយរូប ក្នុងសាសនារបស់

ព្រះពុទ្ធដែលគង់ព្រះជន្មនៅ អាស្រ័យនៅក្នុងព្រៃ អង្គុយត្រង់គល់ឈើ គិតថា អញគួរសាងបណ្ណសាលាឲ្យដល់លោកម្ចាស់ក្នុងព្រៃនេះហើយ លះនូវការងាររបស់ខ្លួន កាប់នូវគ្រឿងកសាង ធ្វើនូវបណ្ណសាលាឲ្យជាទីដែលសមគួរប្រកបដោយទ្វារ ប្រដាប់ដោយកម្រាលស្លឹកឈើ គិតថា ព្រះថេរៈប្រើប្រាស់ដែរឬហ្ន៎ ហើយអង្គុយដោយចំណែកម្ខាង ព្រះថេរៈមកអំពីខាងក្នុងស្រុក ចូលទៅកាន់បណ្ណសាលា អង្គុយត្រង់កម្រាលស្លឹកឈើ ព្រះមហាសត្វក៏ចូលទៅរកព្រះថេរៈ ហើយសួរថា បពិត្រលោកម្ចាស់ បណ្ណសាលានេះ ជាផាសុកឬ ព្រះថេរៈឆ្លើយថា នែបុរសមានមុខល្អ ជាទីផាសុក សមគួរដល់សមណៈ ។ ព្រះពោធិសត្វសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់នៅក្នុងទីនេះឬ ព្រះថេរៈឆ្លើយថា ត្រូវហើយឧបាសក ។ មហាបុរសជ្រាបថា ព្រះថេរៈនៅដោយអាការទទួលនិមន្តហើយ ទើបសូមឲ្យព្រះថេរៈទទួលប្តេជ្ញាថា សូមលោកម្ចាស់មកកាន់ទ្វារផ្ទះរបស់ខ្ញុំជានិច្ច ហើយលះបង់កត្តាហារក្នុងផ្ទះរបស់ខ្លួនជានិច្ច ។ មហាបុរសក្រាលកន្ទេលផែងក្នុងបណ្ណសាលា ហើយតម្កល់គ្រែ និងតាំង ធ្វើនូវទីសម្រាប់ផ្អែក រៀបចំតាំងឈើសម្រាប់ជូតជើង ជីកស្រះបោក្ខរណី ធ្វើទីចង្រ្កមរោយដោយខ្សាច់ ព័ទ្ធបណ្ណសាលាដោយបន្ទាដើម្បីការពារអន្តរាយស្រះបោក្ខរណី និងទីចង្រ្កមក៏ព័ទ្ធដូចគ្នា ។ ក្នុងទីបំផុតនៃរបង បានដាំដើមត្នោតជាជួរ ។ កាលឲ្យទីលំនៅសម្រេចយ៉ាងនេះហើយ ទើបបានថ្វាយសមណ-បរិក្ខារទាំងឡាយ មានចីវរជាដើមដល់ព្រះថេរៈ ។ ពិតហើយ ក្នុងកាលនោះ គ្រឿងប្រើប្រាស់របស់បព្វជិត មានត្រៃចីវរ បិណ្ឌបាត ស្មោកបាត្រ ធម្មក្រក

ភាជន៍ដាក់របស់បរិភោគ ឆត្រ ស្បែកជើង ផ្តិលទឹក ម្ជុល កន្ត្រៃ ឈើច្រត់ដៃកកណ្តារ ដែកអង្រួស កាំបិតកាត់ក្រចក ប្រទីប ឈ្មោះថា ព្រះពោធិសត្វមិនបានប្រគេនដល់ព្រះថេរៈមិនមានឡើយ ។ ព្រោះពោធិសត្វ រក្សាសីល ៥ រក្សាឧបោសថ ទំនុកបម្រុងព្រះថេរៈ ដរាបដល់អស់ជីវិត ព្រះថេរៈអាស្រ័យក្នុងទីនោះ បានសម្រេចអរហត្តហើយ បរិនិព្វាន ។

ព្រះពោធិសត្វបានធ្វើបុណ្យដរាបដល់អស់អាយុ ទៅកើតក្នុងទេវលោក ចុតិចាកទេវលោកនោះ មកកាន់មនុស្សលោក កើតក្នុងកុសាវតីរាជធានី បានជាស្តេចចក្រពត្តិ ព្រះនាមមហាសុទស្សនៈ ។ អានុភាពនៃភាពជាធំរបស់ព្រះរាជាមហាសុទស្សនៈនោះ មកហើយក្នុងសូត្រដោយន័យថា ម្នាលអានន្ទ កាលពីព្រេងនាយមក មានព្រះរាជាទ្រង់ព្រះនាមមហាសុទស្សនៈ ជាក្សត្របានមុទ្ធាភិសេកដូច្នេះជាដើម ។ បានឮថា ព្រះរាជាមហាសុទស្សនៈនោះ មាននគរបទេសរាជ ៨៤០០០ ដែលមានកុសាវតីរាជធានីជាប្រធាន ។ មានប្រាសាទ ៨៤០០០ មានធម្មប្រាសាទជាប្រធាន មានផ្ទះកំពូល ៨៤០០០ មានផ្ទះកំពូលឈ្មោះមហាព្យូហៈជាប្រធាន ។ ទាំងអស់នេះ កើតដោយអានិសង្សនៃបណ្ណសាលា ១ ខ្នង ដែលទ្រង់ធ្វើប្រគេនព្រះថេរៈនោះ ។ បល្ល័ង្ក ៨៤០០០ ដំរី ១០០០ សេះ ១០០០ រថ ១០០០ កើតដោយអានិសង្សនៃគ្រែ និងតាំង ដែលព្រះពោធិសត្វប្រគេនដល់ព្រះថេរៈនោះ ។ កែវមណី ៨៤០០០ កើតដោយអានិសង្សនៃប្រទីប ដែលព្រះពោធិសត្វប្រគេនដល់ព្រះថេរៈ ។ ស្រះបោក្ខរណី ៨៤០០០ កើតដោយអានិសង្សនៃស្រះបោក្ខរណី ១ ស្ត្រី

៨៤០០០ បុត្រ ១០០០ និងគហបតី ១០០០ កើតដោយអានិសង្សនៃការប្រគេនបរិក្ខាររបស់បព្វជិត ដែលសមគួរដល់សមណបរិភោគ មានស្មោកបាត្រជាដើម ។ មេគោទឹកដោះ ៨៤០០០ កើតដោយអានិសង្សនៃការប្រគេនបញ្ចគោរស ។ យ៉ាំងសំពត់ ៨៤០០០ កើតដោយអានិសង្សនៃការប្រគេនគ្រឿងស្លៀកដណ្តប់ ថាសអាហារ ៨៤០០០ កើតដោយអានិសង្សនៃការប្រគេនភោជន ។ ព្រះពោធិសត្វជាព្រះរាជាធិរាជប្រកបដោយរតនៈ ៧ ឫទ្ធិ ៤ ទ្រង់ឈ្មះ គ្រប់គ្រងបឋវីមណ្ឌល មានសាគរជាទីបំផុតដោយធម៌ ទ្រង់ធ្វើរោងទានច្រើនយកនៃ្វង តម្កល់មហាទាន ទ្រង់ឲ្យរាជបុរសវាយស្គរប្រកាសក្នុងព្រះនគរមួយថ្ងៃ ៣ ដងថា អ្នកណាចង់បានរបស់ណា អ្នកនុ៎ះ ចូរមកកាន់រោងទាន ទទួលយកវត្ថុនោះចុះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ក្នុងនគរនោះ តថាគតបានឲ្យគេឃោសនា ក្នុងមួយថ្ងៃ ៣ ដង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងនគរនោះ ។ បាឋៈថា **តទាហំ** ក៏មាន អធិប្បាយថា ក្នុងគ្រានោះ គឺក្នុងគ្រាដែលតថាគតជាសុទស្សនមហារាជ ។ បទថា **តហឹ តហឹ** បានដល់ ក្នុងទីនោះៗ អធិប្បាយថា ទាំងខាងក្នុង និងខាងក្រៅនៃកំពែងនោះៗ ។ បទថា **កោ កឹ ឥច្ឆតិ** សេចក្តីថា បណ្តាព្រាហ្មណ៍ជាដើម អ្នកណាប្រាថ្នាអ្វី ក្នុងបណ្តាទេយ្យធម៌ មានបាយជាដើម ។ បទថា **បត្ថេតិ** ជាវេវចនៈរបស់បទថា **ឥច្ឆតិ** នោះឯង ។ បទថា **កស្ស កឹ ទិយតុ ធនំ** លោកពោលដើម្បីសម្តែងភាពដែលការឃោសនា

ទានប្រព្រឹត្តទៅហើយ ដោយបរិយាយច្រើនជង ។ ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងសរុបដោយទានបារមី ។ ពិតហើយ ទានបារមីរបស់ព្រះពោធិសត្វទាំងឡាយ មិនមានកំណត់ដោយទេយ្យធម៌ និងបដិគ្គាហក ។ ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្តែងសរសើរបុគ្គលដែលសមគួរដល់ទេយ្យធម៌នោះ ដោយការឃោសនាទាន ទើបត្រាស់ថា **កោ ឆាតកោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឆាតកោ** បានដល់ ចង់បាន ។ បទថា **តសិតោ** បានដល់ ស្រេក ។ គប្បីនាំបទថា **ឥច្ឆតិ** ( ត្រូវការ ) មកប្រកបជាមួយបទថា **កោ មាលំ កោ វិលេបនំ** ( អ្នកណាត្រូវការកម្រងផ្កា អ្នកណាត្រូវការគ្រឿងលាប ) ។ បទថា **ឆន្នោ** បានដល់ ខ្វះនូវសំពត់ អធិប្បាយថា ត្រូវការសំពត់ ។ បទថា **បរិទហិស្សតិ** បានដល់ នាំទៅស្លៀកដណ្តប់ ។

បទថា **កោ បថេ ឆត្តមាទេតិ** អ្នកណាដើរផ្លូវណា ត្រូវការឆត្រដើម្បីបាំងភ្លៀង ខ្យល់ និងកម្តៅថ្ងៃរបស់ខ្លួនក្នុងផ្លូវទៅ អធិប្បាយថា ត្រូវការដោយឆត្រ ។ បទថា **កោ ឧបាហនា មុទូ សុភា** សេចក្តីថា ស្បែកជើងឈ្មោះថា **សុភ** ព្រោះគួរមើល ឈ្មោះថា **មុទុ** ព្រោះមានសម្ផស្សសប្បាយ ដើម្បីការពារជើង និងភ្នែករបស់ខ្លួន ។ បទថា **កោ អាទេតិ** អធិប្បាយថា អ្នកណាត្រូវការស្បែកជើងទាំងនោះ ។ គប្បីនាំបទថា **មជ្ឈន្តិកេ** ( ពេលថ្ងៃត្រង់ ) មកប្រកបដោយ ច សព្ទ ក្នុងបទនេះថា **សាយញ្ច ទាតោ** ច ទាំងពេលល្ងាច ទាំងពេលព្រឹក និងពេលថ្ងៃត្រង់ ។ លោកពោលថា

តថាគតឲ្យប្រកាសមួយថ្ងៃ ៣ ដង ។

បទថា **ន តំ ទសសុ ឋានេសុ** មានយោជនាថា ទាននោះ មិនមែនតថាគតរៀបចំក្នុងទី ១០ កន្លែង មិនមែនមួយរយកន្លែង ដែលពិតនោះតថាគតរៀបចំហើយ ក្នុងទីច្រើនរយកន្លែង ។ បទថា **យាចកេ ធនំ** សេចក្តីថា តថាគតតាក់តែងទ្រព្យ គឺត្រៀមសម្រាប់យាចកទាំងឡាយ ។ ព្រោះក្នុងនគរបណ្តោយ ១២ យោជន៍ ទទឹង ៧ យោជន៍ ព័ទ្ធដោយជួរនៃដើមត្នោត ៧ ជួរ ក្នុងរវាងកំពែង ៧ ជាន់ ។ ក្នុងជួរនៃដើមត្នោតទាំងនោះ មានស្រះបោក្ខរណី ៨៤០០០ តថាគតតម្កល់មហាទានត្រង់មាត់ស្រះបោក្ខរណីមួយស្រះមួយ មួយស្រះមួយ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងមហាសុទស្សនសូត្រ ) ថា

> ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បានតាំងទានវត្ថុនេះក្បែរឆ្នេរស្រះបោក្ខរណីទាំងនោះ គឺបាយសម្រាប់អ្នកត្រូវការបាយ ទឹកសម្រាប់អ្នកត្រូវការទឹក សំពត់សម្រាប់អ្នកត្រូវការសំពត់ យានសម្រាប់អ្នកត្រូវការយាន ទីដេកសម្រាប់អ្នកត្រូវការទីដេក ស្រីសម្រាប់អ្នកត្រូវការស្រី ប្រាក់សម្រាប់អ្នកត្រូវប្រាក់ មាសសម្រាប់អ្នកត្រូវការមាស ដូច្នេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនោះដូច្នេះថា មែនពិត មហាបុរស ប្រាថ្នាតែនឹងឲ្យទាន ទើបសាងគ្រឿងប្រដាប់ដែលសមគួរដល់ស្ត្រី និងបុរស តាំងស្ត្រីដើម្បីឲ្យបម្រើក្នុងទីនោះ តម្កល់ទានទាំងអស់នោះដើម្បីបរិច្ចាគ ទើបឲ្យគេ

វាយស្គរប្រកាសថា ព្រះរាជាមហាសុទស្សនៈ ព្រះរាជទានទេយ្យទាន ពួកអ្នកទាំងឡាយ ចូរបរិភោគទាននោះ តាមសប្បាយចុះ ។ មហាជននាំគ្នាទៅកាន់ស្រះបោក្ខរណី ងូតទឹក ស្លៀកសំពត់ជាដើមហើយ បរិភោគនូវមហាសម្បត្តិ បុគ្គលណាមានសម្បត្តិបែបនេះហើយ បុគ្គលនោះ ក៏មិនយក បុគ្គលណាមិនទាន់មាន បុគ្គលនោះ ក៏កាន់យកទៅ បុគ្គលណាអង្គុយលើយានដំរីជាដើមក្តី ត្រាច់ទៅតាមសប្បាយ ដេកលើដំណេកដ៏ប្រសើរក្តី ក៏យកសម្បត្តិទៅសោយសេចក្តីសុខជាមួយស្ត្រីខ្លះ ប្រដាប់គ្រឿងអលង្ការសម្រេចដោយកែវ ៧ ប្រការ សោយសម្បត្តិហើយ ក៏កាន់យកសម្បត្តិអំពីសម្នាក់ដែលបានយកទៅ កាលមិនត្រូវការ ក៏មិនយក ។ ព្រះរាជាមហាសុទស្សនៈ ទ្រង់ខ្នះខ្នែងក្នុងការបរិច្ចាគទានរាល់ៗ ថ្ងៃ ។ ក្នុងសម័យនោះ អ្នកជម្ពូទ្វីបមិនមានការងារដទៃឡើយ ។ បរិភោគទាន សោយសម្បត្តិ ត្រាច់ដើរលេង ទាននោះមិនមានកំណត់ ។ បុគ្គលត្រូវការនឹងមកក្នុងពេលណា ទោះពេលយប់ ឬពេលថ្ងៃ ក៏ព្រះរាជទានក្នុងកាលនោះ ដោយប្រការដូច្នេះ មហាបុរសទ្រង់ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមាននង្គ័លលើកឡើងហើយ ទ្រង់ញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដរាបដល់អស់ព្រះជន្ម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពួកវណិព្វកៈដែលមកក្នុងវេលាថ្ងៃ ឬមកក្នុងវេលាយប់ជាដើម ។

ក្នុងសេចក្តីនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងទានតាមកាលរបស់មហាបុរសនោះ ដោយបទនេះថា **ទិវា វា យទិ វា រត្តឹ យទិ ឯតិ។** ពិតហើយ ក្នុងកាលដែលអ្នកសូមចូលទៅដើម្បីប្រាថ្នាលាភ ឈ្មោះថា ជា

កាលនៃទានរបស់ព្រះពោធិសត្វទាំងឡាយ ។ បទថា **វណិព្វកោ** បានដល់អ្នកសូម ។ ដោយបទនេះថា **លទ្ធា យទិច្ឆកំ ភោគំ** លោកពោលដល់ទានតាមគាប់ចិត្ត ព្រោះថា អ្នកសូមណា ប្រាថ្នាទេយ្យធម៌ណា ព្រះពោធិ-សត្វទ្រង់ឲ្យទាននោះៗ ដល់អ្នកសូមនោះ ។ ព្រះពោធិសត្វមិនបានគិតដល់ភាពដែលទេយ្យធម៌នោះមានតម្លៃច្រើន រកបានលំបាក ដែលជាំទាស់នឹងព្រះអង្គឡើយ ។ ដោយបទនេះថា **ប្បហាន្តោវ គច្ឆតិ** សម្តែងដល់ទានដែលបានតាមសេចក្តីប្រាថ្នា ព្រោះថា អ្នកសូមទាំងឡាយប្រាថ្នាប៉ុនណា ព្រះមហាសត្វក៏ឲ្យប៉ុណ្ណោះ មិនបន្ថយ ព្រោះមានអធ្យាស្រ័យទូលាយ និងព្រោះមានអំណាចច្រើន ។

ដោយបទថា **យាវជីវិកំ** សម្តែងដល់ការមិនមានទីបំផុតកាលរបស់ទាន ព្រោះថា តាំងអំពីសមាទាន ព្រះមហាសត្វទាំងឡាយ មិនបានកំណត់កាលក្នុងកណ្តាល រហូតបរិបូណ៌ ។ ការមិនចូលទៅកាត់ផ្តាច់ដោយសេចក្តីស្លាប់ អំពីការមិនចូលដល់ទីបំផុតក្នុងចន្លោះ ព្រោះមិនមានការនឿយណាយក្នុងការសន្សំពោធិសម្ភារ ខាងមុខអំពីនោះ ព្រោះកិច្ចបដិបត្តិយ៉ាងនោះ ទើបព្រះពុទ្ធអង្គត្រាស់ដោយអំណាចនៃការប្រព្រឹត្ត របស់ព្រះរាជាមហាសុទស្សនៈថា ដរាបដល់អស់ជីវិត ដូច្នេះ ។ បទថា **ឆឌ្ឌាហំ គេហេ ធនំ ឥធម្មិ** សេចក្តីថា ឈ្មោះថា ទ្រព្យនេះ គួរខ្ពើម មិនគួរពេញចិត្ត សម្រាប់តថាគតក៏មិនមែន ព្រោះហេតុនោះ កាលតថាគតឲ្យមហាទានបែបនេះ ទើបឲ្យនាំទ្រព្យមកអំពីផ្ទះ ។ បទថា **ឆបិ ឆត្តិ ឆិចយោ មយិ** សេចក្តីថា ការសន្សំទ្រព្យ

ការរួបរួមទ្រព្យ ក្នុងទីជិត មិនមានដល់តថាគត ក៏មិនមែន អធិប្បាយថា តថាគតមិនរួបរួមទ្រព្យ ដូចសមណៈដែលប្រព្រឹត្តជុសខាត់កិលេស ក៏មិនមែន ។ មហាទានរបស់ព្រះមហាសត្វនោះ ប្រព្រឹត្តទៅដោយអជ្ឈាស្រ័យណា ដើម្បីសម្តែងដល់អជ្ឈាស្រ័យនោះ ទើបលោកពោលពាក្យនេះ ។

ឥឡូវនេះ ដើម្បីសម្តែងសេចក្តីនោះដោយឧបមា ទើបពោលថា **យថាបិ អាតុរោ នាម** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទនេះសម្តែងអត្ថ មួយអន្ទើដោយការប្រៀបធៀបដោយឧបមា ដូចបុរសត្រូវរោគគ្របសង្កត់ រសាប់រសល់ បំណងនឹងឲ្យផុតចាករោគ ត្រូវការគ្រូពេទ្យព្យាបាល ពេញចិត្ត គឺត្រេកអរដោយទ្រព្យ មានប្រាក់ និងមាសជាដើម ហើយបដិបត្តិតាមវិធី ក៏ផុតចាករោគនោះ យ៉ាងណា តថាគតក៏យ៉ាងនោះដូចគ្នា បំណងនឹងដោះសត្វលោកទាំងមូល ដែលងនឹតដោយរោគ គឺកិលេស និងអំពីរោគ គឺទុក្ខក្នុងសង្សារទាំងមូល ដឹង ដឹងច្បាស់ថា ការបរិច្ចាគសម្បត្តិទាំងពួងនេះជាទានបារមី ជាឧបាយនៃការដោះ ( សត្វ ) ចាកលោកនោះ ដើម្បីញ៉ាំងអជ្ឈាស្រ័យនៃសត្វទាំងឡាយឲ្យបរិបូណ៌ ដោយអំណាចនៃអ្នកទទួលទេយ្យធម៌ ដោយមិនមានសេសសល់ និងដោយអំណាចនៃមហាទាន ដោយមិនមានសេសសល់ ។ មា្យ៉ងទៀត ទានបារមីរបស់តថាគត មិនបរិបូណ៌ដល់ខ្លួន ព្រោះហេតុនោះ ដើម្បីញ៉ាំងចិត្តដែលខ្វះខាត ដែលប្រព្រឹត្តទៅក្នុងបទថា " **ឩមនំ** ( ចិត្តដែលខ្វះខាត ) ឲ្យពេញ គឺឲ្យប្រព្រឹត្តទៅ ទើបបានទាននោះដល់វនិព្វក គឺអ្នកសូម តថាគតឲ្យមហាទាន

បែបនេះ តថាគតមិនមានអាឡោះអាល័យ មិនត្រេកអរ មិនសង្ឃឹម មិនបំណងរបស់ណាមួយ ក្នុងការឲ្យទាននោះឯង ក្នុងផលនៃការឲ្យនោះ ឲ្យដើម្បីសម្រេចសម្ពោធិញ្ញាណ គឺដើម្បីត្រាស់ដឹងសព្វញ្ញុតញ្ញាណតែម្យ៉ាង ។

ព្រះមហាសត្វ ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅយ៉ាងនេះ ទ្រង់ឡើងកាន់ធម្មប្រាសាទ ដែលកើតដោយបុញ្ញានុភាពរបស់ព្រះអង្គ ទម្លាយកាមវិតក្កជាដើម ត្រង់ទ្វារផ្ទះកំពូលឈ្មោះមហាព្យូហៈនោះឯង គង់លើរាជបល្ល័ង្កដែលធ្វើដោយមាស ត្រង់ទ្វារផ្ទះកំពូលនោះ ញ៉ាំងឈាន និងអភិញ្ញាឲ្យកើត ចេញអំពីទីនោះ យាងទៅកាន់ផ្ទះកំពូលសម្រេចដោយមាស គង់លើបល្ល័ង្កដែលសម្រេចដោយប្រាក់ ក្នុងផ្ទះកំពូលនោះ ទ្រង់ចម្រើនព្រហ្មវិហារ ៤ ញ៉ាំងកាលវេលាឲ្យកន្លងទៅដោយឈាន និងសមាបត្តិអស់ ៨៤០០០ ឆ្នាំ ទ្រង់ឲ្យឱវាទដល់ស្រីស្នំ ៨៤០០០ នាក់ មានព្រះនាងសុភទ្ទាទេវីជាប្រធាន និងអមាត្យ មួយអន្លើដោយសមាជិកដែលប្រជុំគ្នាជាដើម ដែលចូលទៅគាល់ក្នុងមរណសម័យ ដោយគាថានេះថា

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ។**

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានការកើតឡើង និងមានការវិនាសទៅជាធម្មតា សង្ខារទាំងឡាយ កាលកើតឡើងហើយក៏រលត់ទៅ ការចូលទៅស្ងប់សង្ខារទាំងនោះ ជាសុខ ដូច្នេះ ។

កាលអស់ព្រះជន្មាយុ ក៏បានទៅកាន់ព្រហ្មលោក ។ ព្រះនាងសុភទ្ទាទេវី ក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ បរិនាយកកែវ ក្នុងកាលនោះ បានមកជារាហុល ក្នុងកាលឥឡូវនេះ បរិស័ទដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ចំណែកព្រះបាទមហាសុទស្សនៈ ក្នុងកាលនោះ បានជាព្រះលោកនាថ ។

ក្នុងចរិយានេះ ជាការបានបារមី ១០ ដោយសរុប ទានបារមីប៉ុណ្ណោះ មកក្នុងបាលី ព្រោះអធ្យាស្រ័យក្នុងការឲ្យទូលំទូលាយ ។ ធម៌ដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបដល់គុណានុភាពជាដើមយ៉ាងនេះថា សូម្បីតាំងនៅក្នុងភាពជាធំក្នុងទ្វីបទាំង ៤ ដែលរុងរឿងដោយរតនៈ ៧ ក៏មិនពេញចិត្តក្នុងភោគសុខបែបនោះ សង្កត់នូវកាមវិតក្កជាដើមអំពីចម្ងាយ ប្រព្រឹត្តក្នុងមហាទានបែបនោះ ញ៉ាំងកាលវេលាឲ្យប្រព្រឹត្តទៅដោយសមាបត្តិអស់ ៨ ម៉ឺន ៤ ពាន់ឆ្នាំ ធ្វើធម្មកថាបដិសំយុត្តដោយភាពជារបស់មិនទៀងជាដើម ក៏មិនបោះបង់សេចក្តីខ្វល់ខ្វាយក្នុងវិបស្សនា ក្នុងទីទាំងពួង ។៚

## អដ្ឋកថាមហាសុទស្សនចរិយា ចប់

# សុត្តន្តបិដក

## មហាគោវិន្ទចរិយាទី ៥

[ ៥ ] ចរិយាដទៃទៀត កាលតថាគតកើតជាមហា-គោវិន្ទព្រាហ្មណ៍ បានជាបុរោហិតនៃស្តេច ៧ អង្គ ជាបុរោហិតដែលមនុស្ស និងទេវតាបូជាហើយ ។ សួយសារអាករណា ដែលកើតដល់តថាគតក្នុងរាជ្យ នៃស្តេចទាំង ៧ អង្គ ក្នុងកាលនោះ តថាគតបានឲ្យនូវមហាទាន ជាទានមិនកម្រើក ដូចជាសាគរ ដោយសួយសារអាករនោះ ។ ទ្រព្យ និងស្រូវ មិនមែនជាទីស្អប់ខ្ពើមរបស់តថាគតទេ ទាំងការសន្សំទ្រព្យនៃតថាគត មិនមែនជាមិនមានទេ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគត ឲ្យទ្រព្យដ៏ប្រសើរ ។

មហាគោវិន្ទចរិយាទី ចប់

# អដ្ឋកថា

## មហាគោវិន្ទចរិយា

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាគោវិន្ទចរិយាទី ៥ ដូចតទៅនេះ បទថា **សត្តរាជបុរោហិតោ** បានដល់ បុរោហិតដែលថ្វាយអនុសាសន៍ក្នុងកិច្ចទាំងពួងដល់ព្រះរាជា ៧ អង្គ មានព្រះរាជាព្រះនាមសត្តភូជាដើម ។ បទថា **បូជិតោ នរទេវេហិ** សេចក្ដីថា ដែលនរជនពួកដទៃនោះឯង និងដែលស្ដេចទាំងអស់ក្នុងជម្ពូទ្វីបបូជាហើយ ដោយបច្ច័យ ៤ និងដោយសក្ការៈ និងសមានៈ ។ បទថា **មហាគោវិន្ទព្រាហ្មណោ** សេចក្ដីថា ព្រាហ្មណ៍ឈ្មោះមហាគោវិន្ទៈ ព្រោះជាអ្នកមានអានុភាពច្រើន និងព្រោះបានទទួលតែងតាំងដោយអភិសេកឲ្យជាគោវិន្ទៈ ។ ឈ្មោះនេះ បានកើតឡើងដល់ព្រះពោធិសត្វ តាំងអំពីថ្ងៃអភិសេក តែដោយឈ្មោះ មានឈ្មោះថា ជោតិបាល ។ បានឮថា ក្នុងថ្ងៃដែលជោតិបាលកើត សព្វាវុធទាំងឡាយភ្លឺរុងរឿង ព្រះរាជាក៏ទតឃើញមង្គលាវុធរបស់ព្រះអង្គភ្លឺរុងរឿងក្នុងពេលទៀបភ្លឺ ទ្រង់ភ័យខ្លាច សួរបុរោហិតរបស់ព្រះអង្គ ដែលជាបិតារបស់ព្រះពោធិសត្វ ដែលមកបដិបត្តិរាជការ បុរោហិតទូលឲ្យទ្រង់ជ្រាបថា បពិត្រមហារាជ សូមព្រះអង្គកុំតក់ស្លុតឡើយ កូនរបស់ទូលបង្គំកើតដោយអានុភាពរបស់កូននោះ មិនមែនក្នុងក្រុងរាជគ្រឹះប៉ុណ្ណោះ សូម្បីក្នុងនគរទាំងមូល អាវុធទាំងឡាយ ក៏ភ្លឺរន្ទាលប្រាលផ្លោ អន្តរាយមិនមានដល់ទ្រង់ ព្រោះអាស្រ័យបុត្ររបស់ទូលបង្គំឡើយ ម្យ៉ាងទៀត ក្នុងជម្ពូទ្វីបទាំងមូល នឹងរកបុគ្គលដែលមានបញ្ញាស្មើនឹងបុត្ររបស់ទូលបង្គំមិនមានឡើយ នុ៎ះជាបុព្វនិមិត្តរបស់កូន

ទូលបង្គំ ។ ព្រះរាជាទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យ ១ ពាន់ ត្រាស់ថា នេះជាតម្លៃទឹកដោះរបស់កុមារ ហើយត្រាស់បន្តថា កាលបុត្ររបស់អ្នកចម្រើនវ័យ ចូរនាំមកនៅជាមួយយើង ។ តមក កុមារនោះចម្រើនវ័យ ជាអ្នកឃើញប្រយោជន៍ដែលគួរ ទើបបានជាអ្នកថ្វាយអនុសាសន៍ ក្នុងកិច្ចទាំងពួងរបស់ព្រះរាជា ៧ អង្គ កាលបួសហើយ ក៏បានប្រៀនប្រដៅសត្វទាំងឡាយចាកវត្ថុមិនជាប្រយោជន៍ ហើយដឹកនាំក្នុងវត្ថុដែលជាប្រយោជន៍ ទាំងបច្ចុប្បន្ន និងសម្បរាយភព ។ ដោយហេតុនោះ ទើបបានឈ្មោះថា ជោតិបាល ព្រោះជាអ្នករុងរឿង និងព្រោះអាចក្នុងការទូន្មាន ដោយហេតុនោះ ទើបលោកពោលថា **នាមេន ជោតិបាលោ នាម** ដោយឈ្មោះ ឈ្មោះជោតិបាល ដូច្នេះ ។ គប្បីជ្រាបអត្ថក្នុងបទទាំងនោះដូចតទៅ ព្រះពោធិសត្វជាបុត្ររបស់គោវិន្ទព្រាហ្មណ៍ ជាបុរោហិតរបស់ព្រះរាជាព្រះនាមទិសម្បតិ កាលបិតាអនិច្ចកម្មទៅ ព្រះរាជាសោយទិវង្គតហើយ ញុំាងព្រះរាជា ៧ អង្គ ឲ្យតាំងនៅក្នុងរាជសម្បត្តិ ដែលព្រះរាជាទាំង ៧ អង្គ គឺព្រះបាទរេណុ ជាឱរសរបស់ព្រះបាទទិសម្បតិរាជា ១ ព្រះបាទសហាយ ១ ព្រះបាទសត្តក ១ ព្រះបាទព្រហ្មទត្ត ១ ព្រះបាទវេស្សភូ ១ ព្រះបាទភារត ១ ព្រះបាទធតរដ្ឋ ១ មិនបានវិវាទដល់គ្នានិងគ្នា ថ្វាយអនុសាសន៍ អត្ថ និងធម៌ ដល់ព្រះរាជាទាំងនោះ ព្រះរាជាទាំងអស់ ព្រាហ្មណ៍ពួកដទៃ ទេវតា នាគ និងគហបតីក្នុងផ្ទៃជម្ពូទ្វីប ធ្វើសក្ការៈរាប់អាន បូជា នមស្ការ បានដល់ ឋានៈ ជាទីគោរពយ៉ាងឧត្តម ព្រោះគោវិន្ទព្រាហ្មណ៍នោះ ជាអ្នកឈ្លាសក្នុងអត្ថ និងធម៌ ទើបទទួលសន្មត

ថា មហាគោវិន្ទៈ ដោយប្រការដូច្នេះ ដូចលោកពោល ( ក្នុងមហាគោវិន្ទសូត្រ ) ថា អើហ្ន៎ មើលចុះគោវិន្ទព្រាហ្មណ៍ អើហ្ន៎ មើលចុះមហាគោវិន្ទព្រាហ្មណ៍ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ចរិយាដទៃទៀត កាលតថាគតកើតជាមហាគោវិន្ទព្រាហ្មណ៍ បាន
ជាបុរោហិតនៃស្ដេច ៧ អង្គ ជាបុរោហិតដែលមនុស្ស និងទេវតា
បូជាហើយ ដូច្នេះ ។

លំដាប់នោះ លាភសក្ការៈជាច្រើនរាប់មិនអស់ ដែលព្រះរាជាត្រេកអរដោយអានុភាពរបស់ព្រះពោធិសត្វ ព្រះរាជាដែលរាប់អានព្រះរាជាទាំងនោះ ព្រាហ្មណ៍ គហបតី និងអ្នកនិគម អ្នកជនបទ បង្អោននាំចូលទៅបូជា ដូចជំនន់ទឹកជំលិចដោយជុំវិញ ដូចលាភសក្ការៈកើតដល់បុគ្គលដែលសន្សំបុណ្យបរិបូណ៌ ដែលបានសន្សំទុកមកក្នុងជាតិរាប់មិនអស់ ជាអ្នកមានធម៌កើតឡើងហើយសន្ទឹកសន្ទាប់ គឺសីលាចារវត្តបរិសុទ្ធ មានសីលជាទីស្រឡាញ់ សម្រេចសិល្បសាស្ត្រគ្រប់ប្រភេទ មានហទយៈទន់ភ្លន់គួរស្រឡាញ់ ផ្សាយទៅដោយមហាករុណាក្នុងសព្វសត្វទាំងឡាយ ដូចគ្នានឹងបុត្រ ។ ព្រះពោធិសត្វនោះត្រិះរិះថា ឥឡូវនេះ លាភ និងសក្ការៈកើតឡើងហើយដល់អញ បើដូច្នោះ អញនឹងឲ្យសត្វទាំងឡាយឆ្អែតដោយលាភសក្ការៈនេះ ហើយញ៉ាំងទានបារមីឲ្យបរិបូណ៌ ទើបឲ្យសាងរោងទាន ៦ កន្លែង គឺកណ្ដាលព្រះនគរ ១ ត្រង់ទ្វារនគរ ៤ ត្រង់ទ្វាររាជនិវេសន៍ ១ ហើយញ៉ាំងនូវមហាទានឲ្យប្រព្រឹត្តទៅដោយការបរិច្ចាគទ្រព្យ ប្រមាណមិនបានរាល់ៗ ថ្ងៃ របស់ដែល

គេបូជា ដែលគេនាំមកដើម្បីប្រយោជន៍ដល់ខ្លួន បញ្ជូនទៅកាន់រោងទានទាំងអស់ ។ កាលព្រះពោធិសត្វធ្វើមហាបរិច្ចាគរាល់ៗ ថ្ងៃយ៉ាងនេះ ការរំភើបនៃចិត្តក្តី ការសន្ទោសក្តី មិនមានដល់ព្រះពោធិសត្វឡើយ តើការធុញទ្រាន់នឹងមានមកអំពីណា ។ ពួកជនដែលមកកាន់រោងទាន សង្ឃឹមនឹងបានលាភរបស់ព្រះពោធិសត្វ បានទទួលទេយ្យធម៌ត្រឡប់ទៅ និងប្រកាសគុណវិសេសរបស់ព្រះមហាសត្វដោយជុំវិញ ទាំងខាងក្នុង និងខាងក្រៅព្រះនគរមានសំឡេងអ៊ូអែដូចមហាសមុទ្រមានអន្លង់ទឹកតែមួយ វិលវល់ព្រោះព្យុះធំបក់ឡើងដរាបដល់អស់កប្ប ដូច្នោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សួយសារអាករណា ដែលកើតដល់តថាគតក្នុងរាជ្យ នៃស្តេចទាំង ៧ អង្គ ក្នុងកាលនោះ តថាគតបានឲ្យនូវមហាទាន ជាទានមិនកម្រើក ដូចជាសាគរ ដោយសួយសារអាករនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តទាហំ** បានដល់ ក្នុងកាលដែលតថាគត ជាមហាគោវិន្ទព្រាហ្មណ៍ ជាបុរោហិតរបស់ព្រះរាជា ៧ អង្គ ។ បទថា **សត្ត-រជ្ជេសុ** បានដល់ ក្នុងរាជអាណាចក្ររបស់ព្រះរាជា ៧ អង្គ មានព្រះរាជាព្រះនាមរេណុជាដើម ។ បទថា **អក្ខោភំ** សេចក្តីថា ឈ្មោះថា ដែលបុគ្គលណាមួយឲ្យកម្រើកមិនបាន ព្រោះសត្រូវខាងក្នុង និងខាងក្រៅបៀតបៀនមិនបាន ។ បាឋៈថា **អច្ចុត្តំ** ដូច្នេះក៏មានអធិប្បាយថា បរិបូណ៌ក្រៃលែងដោយភាពទូលំទូលាយ និងដោយការបរិបូណ៌នៃអជ្ឈាស្រ័យ ក្នុងការឲ្យដ៏ពេញ

និងនៃទេយ្យធម៌ ។ បទថា **សាគរូបមំ** សេចក្តីថា ដូចគ្នានឹងសាគរ អធិប្បាយថា ទេយ្យធម៌ក្នុងរោងទានរបស់ព្រះពោធិសត្វ ដូចទឹកក្នុងសាគរ ដែលសត្វលោកទាំងអស់នាំយកទៅប្រើប្រាស់ ក៏មិនអាចធ្វើឲ្យអស់បាន ។

គប្បីជ្រាបសេចក្តីក្នុងគាថាចុងក្រោយដូចតទៅ បទថា **វរំ ធនំ** បានដល់ ទ្រព្យដ៏ប្រសើរ គឺទ្រព្យដែលមនុស្សត្រូវការ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

ព្រះមហាសត្វញុំាងភ្លៀង គឺមហាទានឲ្យធ្លាក់ចុះមិនឈប់ ដូចមហាមេឃធ្លាក់ក្នុងបឋមកប្បដូច្នោះ ជាអ្នកខ្វល់ខ្វាយក្នុងទាន មិនប្រមាទ ថ្វាយអនុសាសន៍អត្ថ និងធម៌ដល់ព្រះរាជា ៧ អង្គ និងញុំាងព្រាហ្មណមហាសាល ៧ ឲ្យសិក្សាសិប្បសាស្ត្រ និងប្រាប់សិប្បៈដល់ជាងកោរកាត់ ៧០០ នាក់ ក្នុងកាលតមក កិត្តិសព្ទដ៏ល្អនេះរបស់ព្រះពោធិសត្វខ្ចរខ្ចាយទៅថា មហាគោវិន្ទព្រាហ្មណ៍បានជួបព្រហ្ម មហាគោវិន្ទព្រាហ្មណ៍សន្ទនា ចរចា ប្រឹក្សាជាមួយព្រហ្មបាន ។ ព្រះមហាសត្វត្រិះរិះថា ឥឡូវនេះ កិត្តិសព្ទដែលមិនពិតរបស់អញនេះ បានខ្ចរខ្ចាយទៅថា មហាគោវិន្ទព្រាហ្មណ៍ជួបព្រហ្ម មហាគោវិន្ទព្រាហ្មណ៍ សន្ទនា ចរចា ប្រឹក្សាជាមួយព្រហ្មបាន បើដូច្នោះ អញគប្បីធ្វើរឿងនេះ ឲ្យជារឿងពិតឲ្យបាន ។ ព្រះមហាសត្វបំពេញព្រហ្មវិហារភាវនា អស់ ៤ ខែ ក្នុងរដូវវស្សា ដោយតាំងចិត្តថា អញគប្បីលាព្រះរាជា ៧ អង្គ ព្រាហ្មណមហាសាល ៧ នាក់ ជាងកោរកាត់ ៧០០ នាក់ បុត្រ និងភរិយា ចូលគាល់ព្រះព្រហ្ម ដោយការតាំងចិត្តរបស់ព្រះពោធិសត្វនោះ សនង្កុមារព្រហ្ម

បានដឹងបរិវិតក្ក ទើបប្រាកដខាងមុខ ។ មហាបុរសឃើញសនង្កុមារព្រហ្ម ទើបសួរថា

បពិត្រលោកនិទ្ទុក្ខ លោកជាអ្វីហ្ន៎ ទើបមានសម្បុរ មានយស មានសិរី ( យ៉ាងនេះ ) យើងមិនស្គាល់ បានជាសូមសួរលោក ធ្វើដូចម្ដេចហ្ន៎ យើងនឹងស្គាល់លោក ដូច្នេះ ។

ព្រហ្មកាលញ៉ាំងព្រះពោធិសត្វឲ្យស្គាល់ខ្លួនទើបពោលថា

ពួកជនតែងស្គាល់ខ្ញុំថា ជាកុមារ ក្នុងព្រហ្មលោក មកអស់កាលយូរហើយ ពួកទេវតាទាំងពួងសោត ក៏ស្គាល់ខ្ញុំដែរ ម្នាលគោវិន្ទ អ្នកចូរដឹងយ៉ាងនេះចុះ ដូច្នេះ ។

ព្រះពោធិសត្វពោលថា

អាសនៈ ទឹក ប្រេងសម្រាប់លាបជើង និងទឹកឃ្មុំ តែងមានដល់ព្រហ្ម យើងសូមទទួលលោកដ៏ចម្រើន ដោយគ្រឿងទទួលភ្ញៀវ សូមលោកដ៏ចម្រើន ទទួលគ្រឿងទទួលភ្ញៀវរបស់យើងចុះ ដូច្នេះ ។

ព្រហ្មមិនត្រូវការដោយរបស់ទទួលភ្ញៀវ ដែលព្រះពោធិសត្វនាំចូលទៅ ក៏នៅតែទទួល ដើម្បីការត្រេកអរនៃចិត្តរបស់ព្រះពោធិសត្វ និងដើម្បីធ្វើការស្និទ្ធស្នាល ទើបពោលថា ម្នាលគោវិន្ទ អ្នកពោលចំពោះគ្រឿងទទួលភ្ញៀវណា យើងព្រមទទួលគ្រឿងទទួលភ្ញៀវនោះរបស់អ្នក ដើម្បីឲ្យឱកាស ទើបពោលថា

ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងបរលោកផង អ្នកប្រាថ្នាប្រយោជន៍ណាមួយ ចូរសួរប្រយោជន៍នោះចុះ ដូច្នេះ ។

លំដាប់នោះ ទើបមហាបុរសសួរដល់ប្រយោជន៍ក្នុងភពខាងមុខតែម្យ៉ាង ខ្ញុំមានសេចក្តីសង្ស័យ សូមសួរសនង្កុមារព្រហ្ម ដែលជាអ្នកមិនមានសេចក្តីសង្ស័យ ក្នុងប្រស្នាទាំងឡាយ ដែលបុគ្គលដទៃគួរដឹងថា សត្វស្ថិតនៅក្នុងធម៌អ្វី សិក្សាក្នុងធម៌អ្វី ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ដូច្នេះ ។

ព្រហ្មកាលព្យាករដល់ព្រះពោធិសត្វ ទើបពោលដល់ផ្លូវដែលទៅកាន់ព្រហ្មលោកថា

ម្នាលព្រាហ្មណ៍ សត្វលះបង់នូវសេចក្តីប្រកាន់ ថារបស់អញ ក្នុងពួកសត្វចេញ ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង មានចិត្តឱនទៅរកករុណាឈាន ប្រាសចាកក្លិនពុល គឺកិលេស វៀរចាកមេថុនធម្ម ស្ថិតនៅក្នុងធម៌ទាំងនេះ លុះសិក្សាក្នុងធម៌ទាំងនេះហើយ ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ពួកជនតែងស្គាល់ខ្ញុំថាជាកុមារ សេចក្តីថា ទេវតាទាំងឡាយ ស្គាល់ខ្ញុំថាជាកុមារព្រហ្មដោយចំណែកមួយប៉ុណ្ណោះ ។ ពាក្យថា ក្នុងព្រហ្មលោក បានដល់ ក្នុងលោកដ៏ប្រសើរ ។ ពាក្យថា មកអស់កាលយូរហើយ បានដល់ បុរាណាយូរមកហើយ ។ ពាក្យថា ម្នាលគោវិន្ទៈ

ចូរអ្នកដឹងយ៉ាងនេះចុះ បានដល់ នែគោវិន្ទៈ ចូរអ្នកចាំខ្ញុំទុកយ៉ាងនេះ ។

ពាក្យថា អាសនៈ នេះ បានដល់ អាសនៈដែលក្រាលដើម្បីឲ្យព្រហ្ម ដ៏ចម្រើនអង្គុយ ។ ទឹកនេះសម្រាប់ប្រើដើម្បីលាងជើង ទឹកផឹកដើម្បីបន្ទោបង់នូវការស្រេក គ្រឿងជូតជើងនេះ គឺប្រេងលាបជើង ដើម្បីបន្ទាបង់នូវការហត់នឿយ ។ អន្ទក់ផ្សំដោយទឹកឃ្មុំនេះ មិនដាក់តក្កៈ មិនដាក់អំបិល មិនត្រូវផ្សេង លាងដោយទឹកស្អាត លោកពោលសំដៅដល់បន្លែ ។ ក្នុងកាលនោះ ព្រះពោធិសត្វប្រព្រឹត្តព្រហ្មចរិយៈ ៤ ខែ ជាព្រហ្មចរិយៈដ៏កំពូល ក្នុងការប្រព្រឹត្តដុសខាត់កិលេស ។ ខ្ញុំសូមយករបស់មានតម្លៃទាំងអស់នេះ ទទួលលោក សូមលោកទទួលរបស់មានតម្លៃនេះ អធិប្បាយថា សូមលោកទទួលរបស់មានតម្លៃដែលជារបស់ខ្ញុំ ។ ព្រះមហាបុរសដឹងថា ព្រហ្មមិនបរិភោគរបស់ទាំងនោះ តែតម្កល់ទុកជាពិធី ក្នុងកិច្ចបដិបត្តិ ដើម្បីសម្តែងការបូជាភ្ញៀវដែលខ្លួនធ្លាប់ប្រព្រឹត្តមក ទើបពោលយ៉ាងនោះ ។ ព្រហ្មក៏ជ្រាបបំណងរបស់ព្រះពោធិសត្វ ទើបពោលថា ម្នាលគោវិន្ទៈ អ្នកពោលចំពោះគ្រឿងទទួលភ្ញៀវណា យើងព្រមទទួលគ្រឿងទទួលភ្ញៀវនោះរបស់អ្នក ដូច្នេះ ។

អធិប្បាយក្នុងពាក្យនោះថា ខ្ញុំអង្គុយលើអាសនៈរបស់អ្នក លាងជើងដោយទឹកលាងជើង ផឹកនូវទឹកផឹក លាបដោយគ្រឿងលាប និងបរិភោគបន្លែដែលលាងដោយទឹក ។

ពាក្យថា ខ្ញុំមានសេចក្តីសង្ស័យ សូមសួរសនង្កុមារព្រហ្ម ដែលជាអ្នកមិនមានសេចក្តីសង្ស័យ ក្នុងប្រស្នាទាំងឡាយ ដែលបុគ្គលដទៃគួរដឹង សេចក្តី

ថា ខ្ញុំមិនសង្ស័យក្នុងបញ្ហាដែលប្រាកដដល់អ្នកដទៃ ព្រោះអ្នកដទៃ សាង បញ្ហាឡើងមកឯង ។

ពាក្យថា លះបង់នូវសេចក្តីប្រកាន់ថារបស់អញ សេចក្តីថា លះនូវតណ្ហាដែលជាគ្រឿងឧបការៈឲ្យប្រព្រឹត្តទៅយ៉ាងនេះថា នេះរបស់អញ នេះរបស់អញ ដូច្នេះ ។ ពាក្យថា ក្នុងពួកសត្វ បានដល់ ក្នុងសត្វទាំងឡាយ ។ ពាក្យថា ម្នាលព្រាហ្មណ៍ ព្រហ្មហៅព្រះពោធិសត្វ ។ ពាក្យថា បុគ្គលប្រព្រឹត្តតែម្នាក់ឯង មានវិគ្គហៈថា ឈ្មោះថា បុគ្គលប្រព្រឹត្តតែម្នាក់ឯង ព្រោះប្រព្រឹត្តទៅម្នាក់ឯង គឺនៅតែឯង ។ ដោយពាក្យនេះ លោកពោលសំដៅដល់កាយវិវេក ។ ម្យ៉ាងទៀត ឈ្មោះថា ម្នាក់ឯង ព្រោះជាឯកផុសឡើង បានដល់ សមាធិ ។ ឈ្មោះថា ជាឯកផុសឡើង ព្រោះដល់នូវភាពជាឯកផុសឡើងនោះ អធិប្បាយថា តាំងមាំដោយឧបចារសមាធិ និងអប្បនាសមាធិ ។ ព្រហ្មកាលសម្តែងភាព ជាឯកផុសឡើង ដោយអំណាចនៃករុណាព្រហ្មវិហារនោះ ទើបពោលថា មានចិត្តឱនទៅរកករុណាឈាន អធិប្បាយថា បង្អោនទៅក្នុងករុណាឈាន គឺញ៉ាំងឈានឲ្យកើតឡើង ។ ពាក្យថា ប្រាសចាកក្លិនពុល បានដល់ ប្រាសចាកក្លិនពុល គឺកិលេស ។ ពាក្យថា ស្ថិតនៅក្នុងធម៌ទាំងនេះ បានដល់ តាំងនៅក្នុងធម៌ទាំងឡាយនេះ ញ៉ាំងធម៌ទាំងឡាយនេះឲ្យបរិបូណ៌ ។ ពាក្យថា លុះសិក្សាក្នុងធម៌ទាំងនេះហើយ បានដល់ សិក្សាក្នុងធម៌ទាំងឡាយនេះ អធិប្បាយថា ចម្រើនព្រហ្មវិហារភាវនានេះ ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ចំណែកសេចក្តីពិស្តារ មកក្នុងបាលីនោះឯង ។

លំដាប់នោះ ព្រះមហាបុរសបានស្តាប់ពាក្យរបស់ព្រហ្មនោះ រង្កៀសក្នុងក្ងិនពុល ទើបពោលថា ខ្ញុំនឹងបួសក្នុងកាលឥឡូវនេះ ។ ព្រហ្មក៏ពោលថា សាធុ មហាបុរស ចូរអ្នកបួសចុះ កាលបើយ៉ាងនេះ ការដែលខ្ញុំមករកអ្នក ទើបជាការមកដោយល្អ អ្នកជាអគ្គបុរសទូទៅពេញជម្ពូទ្វីប នៅក្នុងបឋមវ័យ ។ ឈ្មោះថា ការលះសម្បត្តិ និងភាពជាធំដល់ម៉្លេះ ចេញបួសជាការប្រសើរក្រៃលែង ដូចហត្ថិត្រកូលគន្ធៈ ផ្តាច់នូវទន្លីងដែលធ្វើដោយដែក ហើយចូលព្រៃ ដូច្នោះ ។ នេះឈ្មោះថា ជាផៅពង្សរបស់ព្រះពុទ្ធ ។ ព្រហ្មបានធ្វើទឡ្ហីកម្មដល់ព្រះមហាសត្វ ហើយក៏ត្រឡប់ទៅកាន់ព្រហ្មលោកវិញ ឯព្រះមហាសត្វក៏ត្រិះរិះថា អញចេញចាកនគរនេះទៅបួសមិនសមគួរឡើយ អញនៅថ្វាយអនុសាសន៍ អត្ថ និងធម៌ដល់រាជត្រកូល ព្រោះហេតុនោះ អញទូលព្រះរាជាទាំងនោះ បើព្រះរាជាទាំងនោះបួសក៏ជាការល្អ បើព្រះរាជាទាំងនោះមិនបួស អញនឹងផ្ទេតំណែងបុរោហិតរបស់អញ ហើយបួស ទើបទូលដល់ព្រះរាជារេណុៗ ទ្រង់លួងលោមដោយកាមជាច្រើន ទើបទូលដល់ហេតុនៃសេចក្តីសង្វេគរបស់ខ្លួន និងបំណងដើម្បីបួសតែម្យ៉ាងដល់ព្រះរាជា កាលព្រះរាជារេណុត្រាស់ថា បើយ៉ាងនោះ យើងក៏បួសដែរ ទើបទទួលថា សាធុ ដោយន័យនេះ ទើបលាក្សត្រ ៦ អង្គ មានព្រះរាជាសត្តភូជាដើម ព្រាហ្មណមហាសាល ៧ នាក់ ជាងកោរកាត់ ៧០០ នាក់ និងភរិយារបស់ខ្លួន ហើយធ្វើតាមទំនើងចិត្តរបស់ជនទាំងនោះ អស់ ៧ ថ្ងៃ ទើបចេញបួស ដូចគ្នានឹងមហាភិនេស្រ្កមណ៍ ។

ជនទាំងអស់នោះ មានព្រះរាជា ៧ អង្គជាដើម ចេញបួសតាមព្រះពោធិសត្វ បានជាបរិស័ទធំឡើងហើយ ។ ព្រះមហាបុរសចោមរោមដោយបរិស័ទច្រើនយោជន៍ ត្រាច់ចារិកសម្តែងធម៌ក្នុងស្រុក និគម ជនបទ និងរាជធានី ញុំាងមហាជនឲ្យតាំងមាំក្នុងអំពើល្អ ក្នុងទីដែលព្រះពោធិសត្វទៅហើយ ប្រាកដដូចពុទ្ធកោលាហល ។ ពួកមនុស្សបានដំណឹងថា គោវិន្ទបណ្ឌិតមក ទើបនាំគ្នាសាងមណ្ឌបទុកមុន តាក់តែងមណ្ឌបនោះ ហើយទទួលនិមន្តឲ្យចូលកាន់មណ្ឌប អង្គាសដោយភោជនមានរសដ៏ប្រសើរផ្សេងៗ ។ លាភសក្ការៈធំកើតឡើង ដូចជំនន់ទឹកធំ ។ មហាបុរសញុំាងមហាជនឲ្យតាំងនៅក្នុងអំពើល្អ គឺក្នុងសីលសម្បទា ឥន្ទ្រិយសំវរៈ ការដឹងប្រមាណក្នុងការបរិភោគ ការប្រកបព្យាយាម បរិកម្មកសិណឈាន អភិញ្ញា សមាបត្តិ ៨ និងព្រហ្មវិហារ ។ ក្នុងកាលនោះ ដូចការកើតឡើងនៃព្រះពុទ្ធ ។

ព្រះពោធិសត្វបំពេញបារមីដរាបដល់អស់អាយុ ញុំាងកាលវេលាឲ្យកន្លងទៅដោយសុខ ដែលកើតអំពីសមាបត្តិ កាលអស់អាយុ ក៏ទៅកើតក្នុងព្រហ្មលោក ។ ការប្រព្រឹត្តព្រហ្មចរិយៈរបស់ព្រះពោធិសត្វនោះ មាំទាំ ផ្សាយទៅទូលំទូលាយ ដែលគេស្គាល់ច្រើន រហូតទេវតា និងមនុស្សទាំងឡាយប្រកាសល្អហើយ ប្រព្រឹត្តទៅអស់កាលយូរអង្វែង ។ បុគ្គលណាដឹងពាក្យប្រៀនប្រដៅរបស់ព្រះពោធិសត្វនោះដោយឥតសេសសល់ បុគ្គលនោះស្លាប់ទៅហើយ ក៏បានទៅកើតក្នុងព្រហ្មលោកដែលជាសុគតិភព ។ បុគ្គលណាដឹងមិនដល់ បុគ្គលនោះក៏ចូលដល់ភាពជាសម្លាញ់នៃពួកទេវតា ជាន់បរនិម្មិត-

វសវត្តី ។ ពួកខ្លះ ក៏ចូលដល់ភាពជាសម្លាញ់នឹងពួកទេវតាជាន់និម្មានរតី ។បេ។ តុសិត យាមា តាវត្តិង្ស ចាតុម្មហារាជិកា ។ ទាបជាងគេបង្អស់ បុគ្គលនោះក៏កើតជាពួកគន្ធព្វ ។ មហាជនដោយច្រើន បានចូលដល់ព្រហ្មលោក និងចូលដល់ស្ថានសួគ៌ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទេវលោក និងព្រហ្មលោក ទើបពេញទាំងអស់ អបាយ ៤ ហាក់ដូចជាសូន្យទៅ ។

ក្នុងមហាគោវិន្ទចរិយានេះ គប្បីជ្រាបការពោលចំពោះដល់ពោធិសម្ភារ ដូចក្នុងអកិត្តិជាតក ។

ព្រះរាជា ៧ អង្គ ក្នុងកាលនោះ បានមកជាព្រះមហាថេរៈទាំងឡាយ ក្នុងកាលឥឡូវនេះ បរិស័ទដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ មហាគោវិន្ទៈ ក្នុងកាលនោះ គឺព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីប្រកាសគុណានុភាពយ៉ាងនេះជាដើម គឺការប្រតិស្ឋានក្នុងរជ្ជកាលរៀងៗ ខ្លួនដោយមិនខុសនៃចិត្តគ្នានិងគ្នារបស់ព្រះរាជា ៧ អង្គ មានព្រះបាទរេណុជាដើម ។ ការមិនប្រមាទក្នុងការថ្វាយអនុសាសន៍ អត្ថ ធម៌ដល់ព្រះរាជាទាំងនោះក្នុង ៧ រជ្ជកាលដ៏ធំក្រៃលែង ។ ការសរសើរដែលប្រព្រឹត្តទៅហើយថា ព្រះពោធិសត្វសន្ទនាជាមួយព្រហ្ម ។ ការនៅប្រព្រឹត្តព្រហ្មចរិយៈ

ដល់កំពូលយ៉ាងក្រៃលែង ៤ ខែ ដើម្បីធ្វើការពិត ។ ការឲ្យព្រហ្មចូលមកដល់ខ្លួន ដោយការប្រព្រឹត្តព្រហ្មចរិយៈនោះ ។ ការតាំងនៅក្នុងឱវាទរបស់ព្រហ្មហើយ លះបង់នូវលាភសក្ការៈដែលព្រះរាជា ៧ អង្គ និងសត្វលោកទាំងមូលនាំចូលទៅឲ្យ ដូចដុំទឹកមាត់ ហើយកាន់យកក្នុងបព្វជ្ជា ដែលជាគ្រឿងសម្គាល់នូវការបួសតាមរបស់បរិស័ទ មានក្សត្រ និងព្រាហ្មណ៍ជាដើម រាប់មិនអស់ ។ ការភ្ជាប់ពាក្យប្រៀនប្រដៅ ដូចពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ អស់កាលយូរ ។៚

## អដ្ឋកថាមហាគោវិន្ទចរិយា ចប់

# សុត្តន្តបិដក

## នេមិរាជចរិយាទី ៦

[ ៦ ] ចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចធំ ឈ្មោះនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល នៅក្នុងក្រុងដ៏ប្រសើរ ឈ្មោះមិថិលា ។ កាលនោះ តថាគតបានឲ្យគេស្ថាបនាសាលាបួនខ្នង មានមុខ ៤ ហើយញុំាំងទានឲ្យប្រព្រឹត្តទៅដល់ពួកម្រឹគ បក្សី និងមនុស្សជាដើម ក្នុងសាលានោះ ។ តថាគតបានធ្វើនូវសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក បាយ ទឹក និងភោជន ឲ្យជារបស់ប្រព្រឹត្តទៅមិនដាច់ ហើយញុំាំងមហាទានឲ្យប្រព្រឹត្តទៅ ។ សេវកាមាត្យ ចូលទៅរកចៅហ្វាយនាយ ព្រោះហេតុចង់បានទ្រព្យ ហើយស្វែងរកហេតុដែលគួររីករាយ ដោយកាយ ឬដោយវាចា ចិត្ត ( ផ្គាប់ចិត្តចៅហ្វាយនាយ ) យ៉ាងណា ។ តថាគតនឹងស្វែងរកនូវពូជនៃពោធិញ្ញាណក្នុងភពទាំងពួង ញុំាំងសត្វឲ្យស្កប់ស្កល់ដោយទានហើយ ប្រាថ្នានូវពោធិញ្ញាណដ៏ឧត្តមយ៉ាងនេះឯង ។

**នេមិរាជចរិយាទី ៦ ចប់**

# អដ្ឋកថា
# នេមិរាជចរិយា

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនេមិរាជចរិយាទី ៦ ដូចតទៅ បទថា **មិថិលាយំ បុរុត្តមេ** បានដល់ ក្នុងនគរដែលឧត្តម នៃវិទេហរដ្ឋ ឈ្មោះថា មិថិលា ។ បទថា **និមិ នាម មហារាជា** សេចក្ដីថា និមិកុមារកើតឡើងបន្តខត្តិយវង្សដូចកង់រថ ទើបបានឈ្មោះថា និមិ ។ ឈ្មោះថា **មហារាជា** ព្រោះជាព្រះរាជាធំ ព្រោះប្រកបដោយគុណវិសេស មានទាន និងសីលច្រើន និងព្រោះប្រកបដោយរាជានុភាពធំ ។ បទថា **បណ្ឌិតោ កុសលត្ថិកោ** បានដល់ ត្រូវការបុណ្យដើម្បីខ្លួន និងដើម្បីអ្នកដទៃ ។

បានឮថា ក្នុងអតីតកាល ក្នុងមិថិលានគរដែនវិទេហៈ ព្រះពោធិសត្វនៃយើងជាព្រះរាជា ព្រះនាមមឃទេព ។ ទ្រង់សោយសុខជាកុមារអស់ ៨៤០០០ ឆ្នាំ បានទទួលតំណែងជាឧបរាជ ៨៤០០០ ឆ្នាំ គ្រងរាជសម្បត្តិ ៨៤០០០ ឆ្នាំ ទ្រង់ត្រាស់នឹងជាងកោរកាត់ថា កាលណាអ្នកឃើញសក់ស្កូវលើក្បាលរបស់យើង កាលនោះ គប្បីប្រាប់ដល់យើង ក្នុងកាលតមក ជាងកោរកាត់ឃើញព្រះកេសាស្កូវ ទើបក្រាបទូល ហើយទ្រង់ឲ្យយកសណ្ដាសមាសដកដាក់លើព្រះហស្ត ទ្រង់ទតមើលព្រះកេសាស្កូវ ទ្រង់កើតសង្វេគថា ទេវទូតប្រាកដដល់អញហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អញគួរនឹងចេញបួស ទើបព្រះរាជទានស្រុកសួយដែលរកចំណូលបាន ១ សែន ដល់ជាងកោរកាត់ ហើយត្រាស់ហៅឱរសច្បងមក ត្រាស់ ( ក្នុងមឃទេវជាតក ) ថា

សក់ទាំងឡាយនេះ នាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ

ទេវទូតកើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់អញ

ដូច្នេះ ។

ហើយប្រគល់រាជសម្បត្តិឲ្យ ទោះបីខ្លួននៅសល់អាយុ ៨៤០០០ ឆ្នាំ ក៏គង់សម្គាល់ដូចឈរនៅក្បែរមច្ចុ ទើបសង្វេគ ត្រេកអរនឹងបព្វជ្ជា ។ ដោយហេតុនោះ ទើបលោកពោលថា

ព្រះទិសម្បតីព្រះនាមថា មឃទេព ជាអ្នកប្រាជ្ញ ទតឃើញព្រះ

កេសាស្កូវ លើព្រះសិរសា បាននូវសេចក្តីសង្វេគ ពេញព្រះ

ហឫទ័យនឹងផ្នួស ដូច្នេះ ។

ព្រះរាជាទ្រង់ប្រទានឱវាទដល់បុត្រច្បងថា បុត្រគួរប្រព្រឹត្តដោយទំនងនេះ ដូចដែលឪពុកបដិបត្តិ កូនកុំជាមនុស្សចុងក្រោយឡើយ ហើយយាងចេញអំពីព្រះនគរ បួសជាភិក្ខុ ញ៉ាំងកាលវេលាឲ្យកន្លងទៅដោយឈាននិងសមាបត្តិអស់ ៨៤០០០ ឆ្នាំ កាលអស់ព្រះជន្ម ក៏ទៅកើតក្នុងព្រហ្មលោក សូម្បីឱរសរបស់ព្រះអង្គ ក៏គ្រងរាជសម្បត្តិដោយធម៌ច្រើនពាន់ឆ្នាំ បានបួសដោយឧបាយនោះដូចគ្នា ហើយទៅកើតក្នុងព្រហ្មលោក ។ ស្តេច ៨៤០០០ អង្គ មិនរាប់រួមជា ២ អង្គយ៉ាងនេះ គឺឱរសរបស់ក្សត្រអង្គនោះក៏ដូចគ្នា របស់អង្គនោះក៏ដូចគ្នា លុះទ្រង់ឃើញព្រះកេសាស្កូវលើព្រះសិរសាហើយ ក៏ទ្រង់ផ្នួស ។

លំដាប់នោះ ព្រះពោធិសត្វទ្រង់ប្រតិស្ឋានលើព្រហ្មលោក ទ្រង់ពិចារណា

ថា កល្យាណធម៌ដែលអញបានធ្វើក្នុងមនុស្សលោក នៅប្រព្រឹត្តទៅឬ ឬមិនប្រព្រឹត្តទៅ បានឃើញថា ប្រព្រឹត្តទៅអស់កាលមានប្រមាណប៉ុណ្ណោះ ឥឡូវនេះ នឹងមិនប្រព្រឹត្តតទៅ ព្រះពោធិសត្វទ្រង់ត្រិះរិះថា តែអញនឹងមិនឲ្យការបន្តវង្សរបស់អញសាបសូន្យទៅ ទើបទ្រង់បដិសន្ធិក្នុងគភ៌របស់អគ្គមហេសីរបស់ព្រះរាជា ដែលមានកំណើតក្នុងវង្សរបស់ព្រះអង្គនោះឯង ទ្រង់កើតបន្តវង្សរបស់ព្រះអង្គដូចកង់រថ ដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា និមិកុមារ ទ្រង់កើតបន្តខត្តិយវង្សដូចកង់រថ ទើបបានឈ្មោះថា និមិ ។

ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះរាជឱរសនោះ ព្រះជនកត្រាស់ហៅព្រាហ្មណ៍ដែលជំនាញក្នុងការព្យាករណ៍លក្ខណៈ កាលព្រាហ្មណ៍ពិចារណាមើលព្រះលក្ខណៈហើយ ក៏ព្យាករថា បពិត្រមហារាជ ព្រះរាជកុមារនេះនឹងផ្គងវង្សរបស់ព្រះអង្គ កុមារនេះមានអានុភាពធំ មានបុណ្យជាងព្រះជនកព្រះអយ្យកោអយ្យកា ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបទ្រង់ថ្វាយព្រះនាមព្រះរាជឱរសនោះថា និមិ ព្រោះអត្ថដូចបានពោលហើយ ។ ព្រះរាជឱរសនោះតាំងពីនៅក្មេង បានខ្វល់ខ្វាយក្នុងសីល និងឧបោសថកម្ម ។

លំដាប់នោះ ព្រះបិតារបស់ព្រះរាជកុមារទតឃើញព្រះកេសាស្កូវដោយន័យមុន ទើបព្រះរាជទានស្រុកសួយដល់ជាងកោរកាត់ ប្រគល់រាជសម្បត្តិដល់ព្រះរាជឱរសហើយ យាងចេញអំពីព្រះនគរ ទ្រង់ផ្នួស ញុំាងឈានឲ្យកើតហើយ កើតក្នុងព្រហ្មលោក ។

ចំណែកព្រះបាទនិមិរាជ ទ្រង់មានអធ្យាស្រ័យក្នុងការឲ្យ ទើបឲ្យសាង

រោងទាន ៥ កន្លែង គឺត្រង់ទ្វារនគរ ៤ កណ្តាលនគរ ១ ទ្រង់បរិច្ចាគទាន ។ ទ្រង់បរិច្ចាគមួយថ្ងៃ ៥ សែន រោងទានមួយ ១ សែនកហាបណៈ ទ្រង់រក្សាសីល ៥ ទ្រង់សមាទានឧបោសថកម្មក្នុងថ្ងៃនៃបក្ខ ។ ទ្រង់ឲ្យមហាជនកាន់យកក្នុងបុញ្ញកម្ម មានទានជាដើម ។ ទ្រង់ប្រាប់ផ្លូវស្ថានសួគ៌ ទ្រង់គំរាមឲ្យភ័យក្នុងនរក ទ្រង់ហាមចាកបាប មហាជនតាំងនៅក្នុងឱវាទរបស់ព្រះបាទនិមិរាជនោះ ទ្រង់ធ្វើបុណ្យ មានទានជាដើម ចុតិចាកមនុស្សលោកហើយទៅកើតក្នុងទេវលោក ។ ទេវលោកពេញដោយពួកទេវតា នរកប្រាកដជាហាក់ដូចទទេ ។

ក្នុងកាលនោះ ព្រះសាស្តាកាលទ្រង់ប្រកាសអធ្យាស្រ័យ ក្នុងការឲ្យរបស់ព្រះអង្គទូលំទូលាយ និងភាពដែលទានបារមីបរិបូណ៌ដ៏កំពូល ទើបត្រាស់ព្រះតម្រាស់ជាដើមថា

កាលនោះ តថាគតបានឲ្យគេស្ថាបនាសាលាបួនខ្នង មានមុខ ៤
ហើយញ៉ាំងទានឲ្យប្រព្រឹត្តទៅដល់ពួកម្រឹគ បក្សី និងមនុស្ស
ជាដើមក្នុងសាលានោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តទា** បានដល់ ក្នុងកាលជានិមិរាជនោះ ។ បទថា **មាបយិត្វាន** បានដល់ ឲ្យសាង ។ បទថា **ចតុស្សាលំ** បានដល់ រោងទានជាប់គ្នាក្នុង ៤ ទិស ។ បទថា **ចតុម្មុខំ** បានដល់ ប្រកបដោយទ្វារ ៤ ក្នុងទិស ៤ ។ ព្រោះមិនអាចធ្វើទានធម៌ ( ទេយ្យធម៌ ) ឲ្យអស់ដោយទ្វារមួយ និងឲ្យទេយ្យធម៌អស់បាន ព្រោះរោងទានធំ និងព្រោះទេយ្យធម៌

និងអ្នកសូមមានច្រើន ព្រោះហេតុនោះ ទើបឲ្យសាងទ្វារធំ ៤ ក្នុងទិសទាំង ៤ នៃរោងទាន ។ ក្នុងរោងទាននោះ ទេយ្យធម៌តាំងនៅជាគំនរធំ តាំងអំពីទ្វារដល់ចុងទ្វារ ។ តាមប្រក្រតីទាន រមែងប្រព្រឹត្តទៅតាំងអំពីថ្ងៃរះ រហូតដល់ថ្ងៃលិច ។ ក្នុងកាលក្រៅអំពីនេះ ( ពេលយប់ ) ក៏អុជប្រទីបច្រើនរយ បុគ្គលត្រូវការមកក្នុងកាលណា ក៏ឲ្យក្នុងកាលនោះ ។ ទាននោះ មិនបានឲ្យដល់អ្នកក្រីក្រ អ្នកដំណើរ វនិព្វក និងយាចកប៉ុណ្ណោះទេ ដែលពិតមនុស្សអ្នកជម្ពូទ្វីបទាំងមូល ក៏ទទួល និងបរិភោគទាននោះដូចគ្នា ព្រោះលះទេយ្យធម៌សន្និកសន្និបាត់ និងប្រណីត ដូចគ្នានឹងទានរបស់ព្រះបាទមហាសុទស្សនៈ ដោយសម្រេចដល់មនុស្សស្ទុកស្ដម្ភ ទោះបីមានសម្បត្តិច្រើន ។ ពិតហើយ មហាបុរសធ្វើជម្ពូទ្វីបទាំងមូលឲ្យមាននង្គ័លលើកឡើងហើយ ហើយបរិច្ចាគមហាទានក្នុងកាលនោះ ។ ទ្រង់បរិច្ចាគទានដើម្បីអនុគ្រោះ សូម្បីដល់សត្វតិរច្ឆានទាំងឡាយ មានម្រឹគ និងបក្សីជាដើមក្នុងចំណែកមួយក្រៅរោងទាន ដូចគ្នានឹងមនុស្សដែរ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ញុំាងទានឲ្យប្រព្រឹត្តទៅដល់ពួកម្រឹគ បក្សី និងមនុស្សជាដើម ក្នុងសាលានោះ ដូច្នេះ ។ មិនបរិច្ចាគចំពោះតែសត្វតិរច្ឆានប៉ុណ្ណោះទេ សូម្បីប្រេតទាំងឡាយ ក៏ទ្រង់ឲ្យចំណែកបុណ្យរាល់ៗ ថ្ងៃ ។ ទ្រង់បរិច្ចាគទានក្នុងរោងទាន ៥ កន្លែង ដូចគ្នាគ្រប់រោងទាន តែក្នុងបាលីពោលដូចមួយកន្លែងថា កាលនោះ តថាគតបានឲ្យគេស្ថាបនាសាលាបួនខ្នង មានមុខ ៤ ដូច្នេះ ។ បទនោះ លោកពោលសំដៅដល់រោងទាន ដែលនៅត្រង់កណ្ដាលនគរ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ទេយ្យធម៌ក្នុងវេលាទាននោះដោយឯកទេស ទើបត្រាស់ថា នូវសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក បាយ ទឹក និងភោជន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អច្ឆាទនំ** បានដល់ គ្រឿងស្លៀកដណ្តប់ច្រើនយ៉ាង មានសំពត់ធ្វើដោយសម្បកឈើ និងសំពត់សាច់ម៉ដ្ឋជាដើម ។ បទថា **សយនំ** បានដល់ ទីគួរដេកច្រើនយ៉ាង មានគ្រែ និងបល្ល័ង្កជាដើម និងព្រំដែលធ្វើដោយរោមចៀម និងកម្រាលដែលប៉ាក់ជារូបល្អៗ ជាដើម ។ ម្យ៉ាងទៀត ក្នុងពាក្យនេះ សូម្បីទីអង្គុយក៏គប្បីពោលថា លោកកាន់យកដោយ **សយន** សព្ទនោះឯង ។ បទថា **អន្នំ ចានញ្ច ភោជនំ** បានដល់ បាយ និងទឹក មានរសប្រសើរផ្សេងៗ តាមគាប់ចិត្តរបស់សត្វនោះៗ និងប្រភេទនៃអាហារផ្សេងៗ ដ៏សេស ។ បទថា **អព្ភោច្ឆិន្នំ ករិត្វាន** បានដល់ ធ្វើមិនឲ្យដាច់ គឺធ្វើមិនឲ្យដាច់ទាំងថ្ងៃ ទាំងយប់ដរាបដល់អស់អាយុ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលទាននោះប្រព្រឹត្តទៅហើយ ដោយភាពជាទានបារមី ប្រារព្ធដល់សម្មាសម្ពោធិញ្ញាណ ដើម្បីទ្រង់សម្តែងដល់អធ្យាស្រ័យរបស់ព្រះអង្គ ដែលប្រព្រឹត្តទៅហើយ ក្នុងកាលនោះ ដោយឧបមា ទើបត្រាស់ព្រះតម្រាស់ជាដើមថា **យថាបិ សេវកោ** ដូច្នេះ ។ ព្រះពុទ្ធតម្រាស់នោះ មានសេចក្តីដូចតទៅ បុរសដែលជាសេវកៈចូលទៅរកចៅហ្វាយរបស់ខ្លួនដោយការសេពគប់ តាមកាលសមគួរ ព្រោះហេតុនៃទ្រព្យដែលគួរបាន រមែងស្វែងរក គឺស្វះស្វែងរកនូវការត្រេកអរ

ដែលចៅហ្វាយគប្បីឲ្យត្រេកអរបាន ដោយអាការដែលឲ្យចៅហ្វាយត្រេកអរ ដោយកាយកម្ម វចីកម្ម និងមនោកម្ម ក្នុងទីទាំងពួង យ៉ាងណា តថាគត ដែលជាពោធិសត្វក៏យ៉ាងនោះ បំណងនឹងសេពនូវភាពជាព្រះពុទ្ធដ៏ប្រសើរ ជាធំនៃលោក ព្រមទាំងទេវលោក ដើម្បីឲ្យជាទីត្រេកអរដល់សត្វលោកនោះ និងស្វែងរកសព្វញ្ញុតញ្ញាណដែលបានឈ្មោះថា **ពោធិជ** ព្រោះកើតអំពី អរិយមគ្គញ្ញាណ ពោល គឺពោធិ ដោយឧបាយផ្សេងៗ ក្នុងទីទាំងពួង ខាង មុខក្នុងភពទាំងពួង គឺក្នុងភពដែលកើតហើយកើតទៀតទាំងពួង ទើបញ៉ាំង សព្វសត្វឲ្យស្កប់ស្កល់ដោយទាន ដោយការបំពេញទានបារមី ។ តថាគត ប្រាថ្នាពោធិញ្ញាណ គឺសម្មាសម្ពោធិញ្ញាណដ៏ឧត្តមនោះ ទើបធ្វើយ៉ាងណា មួយ មានការបរិច្ចាគជីវិតជាដើម ។

ដើម្បីសម្ដែងដល់ភាពទូលំទូលាយនៃអធ្យាស្រ័យក្នុងការឲ្យ ក្នុងទីនេះ ដោយប្រការដូច្នោះ ទើបព្រះមានព្រះភាគទ្រង់កំណត់ទេសនា ដោយទាន-បារមីប៉ុណ្ណោះ តែក្នុងទេសនាជាតក លោកចង្អុលបង្ហាញដល់ការបរិបូណ៌នៃ សីលបារមីជាដើម របស់ព្រះពោធិសត្វនោះ ។ ពិតហើយ កាលព្រះពោធិ-សត្វតាក់តែងព្រះអង្គដោយគុណ មានសីលជាដើម តាមន័យដែលពោល ហើយខាងដើមនោះឯង ហើយទ្រង់ឲ្យមហាជនតាំងនៅក្នុងសីលនោះ ទេវតា ដែលកើតឡើងព្រោះតាំងនៅក្នុងឱវាទ ប្រជុំគ្នាក្នុងទេវសភា ឈ្មោះសុធម្មា នាំគ្នាពោលសរសើរគុណរបស់ព្រះមហាបុរសថា គួរអស្ចារ្យហ្ន៎ ពួកយើង បានទទួលសម្បត្តិនេះ ព្រោះអាស្រ័យនិមិរាជរបស់ពួកយើង កាលព្រះពុទ្ធ

មិនទាន់កើតឡើង មនុស្សអស្ចារ្យបែបនេះ ក៏គង់ធ្វើពុទ្ធកិច្ចឲ្យសម្រេចដល់មហាជន កើតឡើងក្នុងលោក ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះ ( ក្នុងខុទ្ទកនិកាយ ជាតក ) ថា

**អច្ឆេរំ វត លោកស្មឹ ឧប្បជ្ជន្តិ វិចក្ខណា យទា អហុ និមិរាជា បណ្ឌិតោ កុសលត្ថិកោ ។**

ឱ ! អស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោកហើយ ក្នុងកាលដែលព្រះបាទនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល ដូច្នេះ ។

ពួកទេវតាទាំងពួង មានសក្កទេវរាជជាដើម បានស្តាប់ដូច្នោះ បំណងនឹងឃើញព្រះពោធិសត្វ ។ ថ្ងៃមួយ កាលព្រះមហាបុរសទ្រង់រក្សាឧបោសថប្រថាប់នៅលើប្រាសាទដ៏ប្រសើរ ប្រថាប់គង់ពត់ភ្នែនក្នុងបច្ឆិមយាម ទ្រង់កើតបរិវិតក្កថា ទានប្រសើរ ឬព្រហ្មចរិយៈប្រសើរហ្ន៎ ព្រះពោធិសត្វមិនអាចកាត់សេចក្តីសង្ស័យរបស់ព្រះអង្គបាន ក្នុងខណៈនោះ ភពរបស់សក្កៈក៏សម្តែងនូវអាការក្តៅ ។ សក្កទេវរាជ ទ្រង់រំពឹងដល់ហេតុនោះ កាលទ្រង់ឃើញព្រះពោធិសត្វបរិវិតក្កយ៉ាងនោះ ទើបទ្រង់ព្រះតម្រិះថា ណ្ហីយចុះ អញនឹងកាត់វិតក្ករបស់ព្រះពោធិសត្វនោះ ទើបយាងមកប្រថាប់អំពីខាងមុខ ព្រះពោធិសត្វត្រាស់សួរថា អ្នកជានរណា ទើបទ្រង់ប្រាប់ភាពដែលទ្រង់ជាទេវរាជ ហើយត្រាស់សួរព្រះពោធិសត្វថា មហារាជទ្រង់ព្រះតម្រិះដល់អ្វី ទើបព្រះពោធិសត្វត្រាស់ប្រាប់សេចក្តីនោះ ។ សក្កទេវរាជ កាលទ្រង់សម្តែងឲ្យ

ឃើញថា ព្រហ្មចរិយៈនោះឯងប្រសើរ ទើបត្រាស់ ( ក្នុងខុទ្ទកនិកាយ ជាតក ) ថា

បុគ្គលកើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈថោកទាប ដល់នូវភាពជាទេវតា ដោយព្រហ្មចរិយៈជាកណ្តាល បរិសុទ្ធស្អាត ដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។ ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយ មិនងាយបានសោះទេ ដូច្នេះ ។

ក្នុងគាថានោះ គប្បីជ្រាបសេចក្តីដូចតទៅនេះ ការប្រព្រឹត្តត្រឹមតែវៀរចាកមេថុន ក្នុងលទ្ធិសាសនាជាច្រើន ( ខាងក្រៅ ) ឈ្មោះថា ព្រហ្មចរិយៈថោកថយ ។ ដោយព្រហ្មចរិយៈថោកថយនោះ បុគ្គលរមែងកើតក្នុងត្រកូលក្សត្រ ។ ការប្រព្រឹត្តក្បែរនឹងបានឈាន ឈ្មោះថា ព្រហ្មចរិយៈជាកណ្តាល ដោយព្រហ្មចរិយៈជាកណ្តាលនោះ រមែងកើតជាទេវតា តែការញុំាងសមាបត្តិ ៨ ឲ្យកើត ឈ្មោះថា ព្រហ្មចរិយៈឧត្តម ដោយព្រហ្មចរិយៈឧត្តមនោះ រមែងកើតក្នុងព្រហ្មលោក ជនខាងក្រៅពោលព្រហ្មលោកនោះថា និព្វាន ដោយហេតុនោះ ទើបលោកពោលថា បរិសុទ្ធ ។ តែក្នុងព្រះសាសនា កាលភិក្ខុមានសីលបរិសុទ្ធ ប្រាថ្នានូវពួកទេវតាណាមួយ ឈ្មោះថា ព្រហ្មចរិយៈថោកថយ ព្រោះចេតនាក្នុងការប្រព្រឹត្តព្រហ្មចរិយៈថោកថយ ។ ដោយព្រហ្មចរិយៈថោកថយនោះ រមែងកើតក្នុងទេវលោកតាមដែលខ្លួនប្រាថ្នា ការដែលបុគ្គលមានសីលបរិសុទ្ធ ញុំាងសមាបត្តិ ៨ ឲ្យកើត ឈ្មោះថា ព្រហ្ម-

ចរិយៈជាកណ្តាល ដោយព្រហ្មចរិយៈជាកណ្តាលនោះ រមែងកើតក្នុងព្រហ្ម-លោក ចំណែកបុគ្គលមានសីលបរិសុទ្ធ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ឈ្មោះថា ព្រហ្មចរិយៈឧត្តម ។ រមែងបរិសុទ្ធដោយព្រហ្មចរិយៈឧត្តមនោះ ដោយប្រការដូច្នេះ ទើបសក្កទេវរាជពណ៌នាថា មហារាជ ការប្រព្រឹត្តព្រហ្មចរិយៈនោះឯង មានផលច្រើនជាងទានរាប់រយដង រាប់ពាន់ដង រាប់សែនដង ។ ពាក្យថា ពួកព្រហ្ម បានដល់ ពួកព្រហ្ម ។ ពាក្យថា បុគ្គលអ្នកប្រកបក្នុងការសូម បានដល់ ប្រកបដោយការអង្វរ ។ បាលីថា **យាជយោគេន** ដូច្នេះក៏មាន គឺប្រកបដោយការបូជា អធិប្បាយថា ប្រកបដោយការឲ្យ ។ ពាក្យថា ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ បានដល់ ត្រូវអាស្រ័យការបំពេញតបៈ ។ សក្កទេវរាជ ទ្រង់សម្តែងដល់ការប្រព្រឹត្តព្រហ្ម-ចរិយៈប៉ុណ្ណោះថា មានអានុភាពច្រើនដោយគាថានេះ ។ សក្កទេវរាជកាលត្រាស់យ៉ាងនេះហើយ ទើបឲ្យឱវាទព្រះពោធិសត្វថា មហារាជ សូម្បីព្រហ្ម-ចរិយៈមានផលច្រើនជាងទានក៏ពិត តែមហាបុរសគួរធ្វើទាំងពីរយ៉ាងនោះឯង ចូរជាអ្នកមិនប្រមាទក្នុងធម៌ទាំងពីរ គឺទាន និងព្រហ្មចរិយៈ ចូរឲ្យទាន និងចូររក្សាសីល ហើយយាងត្រឡប់ទៅកាន់ទេវលោក ។

កាលនោះ ពួកទេវតាទូលសួរសក្កៈថា បពិត្រទេវរាជ ទ្រង់យាងទៅណា មកណា សក្កទេវរាជត្រាស់ថា យើងទៅកាត់សេចក្តីសង្ស័យរបស់ព្រះបាទនិមិរាជ ក្នុងក្រុងមិថិលា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបពណ៌នាគុណរបស់ព្រះពោធិសត្វដោយពិស្តារ ទេវតាបានស្តាប់ដូច្នោះ ក៏ទូលថា

បពិត្រសក្កៈ ពួកទូលបង្គំទាំងឡាយបំណាំងនឹងឃើញព្រះបាទនិមិរាជ ពួកទូលបង្គំសូមឱកាស សូមទ្រង់អញ្ជើញព្រះបាទនិមិរាជមកចុះ ។ សក្កទេវរាជត្រាស់ថា សាធុ ហើយត្រាស់ហៅមាតលីទេវបុត្រមកត្រាស់ថា ចូរអ្នកទៅយាងព្រះបាទនិមិរាជ ឲ្យប្រថាប់លើវេជយន្តរថហើយនាំមក មាតលីទេវបុត្រទទួលទេវបញ្ជាថា សាធុ ហើយនាំរថទៅទទួលព្រះមហាសត្វៗ ទ្រង់សាកសួរដេញដោល ទើបទូលដល់ឋានៈរបស់អ្នកមានបាបកម្ម និងអ្នកមានបុញ្ញកម្ម នាំទៅកាន់ទេវលោកតាមលំដាប់ ។ ទេវតាទាំងឡាយ បានឮថា ព្រះបាទនិមិរាជយាងមកហើយ ទើបកាន់យកគ្រឿងក្រអូប និងផ្កាទិព្វជាដើមទៅទទួលតាំងអំពីខ្លោងទ្វារចិត្តកូដ បូជាព្រះពោធិសត្វ ដោយរបស់ទិព្វជាដើម ហើយនាំទៅកាន់សុធម្មទេវសភា ។ ព្រះរាជាយាងចុះអំពីរថហើយចូលទៅកាន់ទេវសភា ប្រថាប់គង់រួមអាសនៈជាមួយសក្កទេវរាជ សក្កទេវរាជទទួលដោយកាមជាទិព្វ ទ្រង់បដិសេធថា បពិត្រទេវរាជ សូមទ្រង់កុំទទួលដោយកាម ឧបមាដូចជារបស់ខ្ចីទាំងនេះដល់ខ្ញុំឡើយ ហើយទ្រង់សម្តែងធម៌ដោយអនេកបរិយាយ ទ្រង់ប្រថាប់នៅ ៧ ថ្ងៃ ដោយថ្ងៃរបស់មនុស្ស ហើយទូលថា ខ្ញុំនឹងត្រឡប់ទៅកាន់មនុស្សលោក ។ ខ្ញុំនឹងធ្វើបុណ្យមានទានជាដើមក្នុងមនុស្សលោកនោះ ។ សក្កទេវរាជ មានទេវបញ្ជានឹងមាតលីទេវបុត្រថា ចូរអ្នកនាំព្រះបាទនិមិរាជ ទៅកាន់នគរមិថិលាចុះ ។ មាតលីទេវបុត្រទូលព្រះពោធិសត្វ ឲ្យទ្រង់ឡើងកាន់វេជយន្តរថ ហើយនាំទៅកាន់ក្រុងមិថិលា តាមទ្វារទិសខាងកើត ។ មហាជនឃើញទិព្វរថ ទើប

បានធ្វើការទទួលព្រះរាជា ។ មាតលីទេវបុត្រ ទូលអារាធនាព្រះមហាសត្វឲ្យចុះតាមសីហបញ្ជរ ហើយលាត្រឡប់ទៅកាន់ទេវលោក ។ មហាជនក៏នាំគ្នាមកចោមរោមព្រះរាជា ទូលសួរថា បពិត្រព្រះអង្គ ទេវលោកដូចម្ដេចខ្លះ ព្រះរាជាទ្រង់ពណ៌នាដល់សម្បត្តិក្នុងទេវលោក ហើយទ្រង់សម្ដែងធម៌ថា ចូរពួកអ្នកធ្វើបុណ្យ មានទានជាដើម ពួកអ្នកនឹងកើតក្នុងទេវលោកនោះ ដោយប្រការដូច្នេះ ។ ក្នុងកាលតមក ព្រះពោធិសត្វទតឃើញសក់ស្កូវ តាមន័យដែលពោលហើយក្នុងកាលមុន ទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះរាជឱរសទ្រង់លះកាមចេញបួស ចម្រើនព្រហ្មវិហារ ៤ ហើយទៅកាន់ព្រហ្មលោក ។

សក្កទេវរាជក្នុងកាលនោះ បានមកជាព្រះអនុរុទ្ធត្ថេរ ក្នុងកាលឥឡូវនេះ មាតលីទេវបុត្រក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ព្រះរាជា ៨៤០០០ អង្គក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ព្រះបាទនិមិរាជក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងនិមិរាជចរិយានេះ គប្បីពោលចំពោះដល់ពោធិសម្ភាររបស់ព្រះបាទនិមិរាជនោះ ដោយន័យដែលពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត គប្បីពោលចំពោះដល់គុណានុភាពយ៉ាងនេះ គឺការលះសម្បត្តិក្នុងព្រហ្មលោក ហើយកើតក្នុងមនុស្សលោកដោយមហាករុណាថា អញនឹងបន្តកល្យាណវត្ត ដែលអញធ្លាប់បដិបត្តិមកហើយ ក្នុងកាលមុនជាដើម ។ អធ្យាស្រ័យក្នុងទានដ៏ទូលំទូលាយ កិច្ចបដិបត្តិក្នុងទានជាដើមដ៏សមគួរដល់អធ្យាស្រ័យនោះ ។ ការឲ្យមហាជនតាំងនៅក្នុងកិច្ចបដិបត្តិនោះតាំងអំពីពេលដែលយសរបស់ព្រះបាទនិមិរាជផ្សាយទៅ ដល់ទេវតា និងមនុស្សទាំងឡាយ រហូតដល់ការភ្ញាក់ផ្អើលក្នុងការចូលទៅរករបស់សក្កទេវរាជៗ ទ្រង់ទទួលដោយសម្បត្តិទិព្វ ក៏មិនពេញព្រះហឫទ័យក្នុងសម្បត្តិទិព្វនោះ ហើយត្រឡប់មកកាន់លំនៅរបស់មនុស្សវិញ ដើម្បីសន្សំបុញ្ញសម្ភារ ការមិនជាប់នៅក្នុងសម្បត្តិទាំងពួង មានលាភសម្បត្តិជាដើម ៕

## អដ្ឋកថានិមិរាជចរិយា ចប់

# សុត្តន្តបិដក

## ចន្ទកុមារចរិយាទី ៧

[ ៧ ] មានចរិយាដទៃទៀត កាលដែលតថាគតជាឱរស ឈ្មោះចន្ទកុមារ របស់ស្តេចព្រះនាមឯករាជ នៅក្នុងក្រុងបុប្ផវតី ។ កាលនោះ តថាគតរួចអំពីការដែលគេត្រូវសម្លាប់ ចេញផុតពីទីយញ្ញនោះហើយ ក៏កើតសេចក្តីសង្វេគ បានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ។ តថាគត បើមិនទាន់បានឲ្យទេយ្យធម៌ ចំពោះទក្ខិណេយ្យ-បុគ្គលទេ តថាគតក៏មិនផឹក មិនទំពាស៊ី មិនបរិភោគភោជន អស់ចំនួន ៥ ឬ ៦ រាត្រី ។ ពាណិជធ្វើការសន្សំទ្រព្យ ( បើដឹងថា ) ទីណាមានលាភច្រើន ក៏នាំកណ្ឌៈទៅក្នុងទីនោះ យ៉ាងណា ។ វត្ថុដែលត្រូវបរិភោគខ្លួនឯង បើឲ្យដល់បដិគ្គាហកដទៃ ជាវត្ថុមានផលច្រើន ហេតុនោះ ត្រូវតែឲ្យដល់បុគ្គលដទៃវិញ នឹងមានផល ១០០ ភាគ ក៏យ៉ាងនោះដែរ ។ តថាគតដឹងនូវអំណាចនៃហេតុនុ៎ះហើយ ទើបឲ្យទានក្នុងភពតូច និងភពធំ មិនគេចចេញចាកទាន ដើម្បីបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ ។

**ចន្ទកុមារចរិយាទី ៧ ចប់**

# អដ្ឋកថា

## ចន្ទកុមារចរិយា

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចន្ទកុមារចរិយាទី ៧ ដូចតទៅ បទថា **ឯករាជស្ស អត្រជោ** បានដល់ ជាព្រះរាជឱរសរបស់ព្រះបាទកាសី ព្រះនាមឯករាជ ។ បទថា **នគរេ បុប្ផវតិយា** បានដល់ ក្នុងនគរឈ្មោះបុប្ផវតី ។ បទថា **ចន្ទសវ្ហយោ** គឺគប្បីហៅឈ្មោះដោយសព្ទថា **ចន្ទ** អធិប្បាយថា ឈ្មោះថា **ចន្ទ** ។

បានឮថា ក្នុងអតីតកាល ក្រុងពារាណសី មានឈ្មោះថា បុប្ផវតី ក្នុងក្រុងបុប្ផវតីនោះ ឱរសរបស់ព្រះរាជាវសវត្តី ព្រះនាមឯករាជ គ្រងរាជសម្បត្តិ ។ ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃរបស់អគ្គមហេសីនៃព្រះបាទឯករាជនោះ ព្រះនាមគោតមី ។ ព្រះមាតាបិតាថ្វាយព្រះនាមថា ចន្ទកុមារ កាលព្រះចន្ទកុមារដើរបាន ក៏មានព្រះរាជឱរសមួយអង្គទៀត ពួកញាតិបានថ្វាយព្រះនាមព្រះរាជឱរសនោះថា សុរិយកុមារ កាលសុរិយកុមារដើរបាន ក៏មានព្រះរាជធីតាមួយអង្គទៀត ពួកញាតិបានថ្វាយព្រះនាមព្រះរាជធីតាអង្គនោះថា សេលា ។ ព្រះរាជឱរស និងព្រះរាជធីតាទាំងនោះ មានបងប្អូនមាតាដទៃពីរអង្គទៀត គឺភទ្ទសេនៈ ១ និងសូរៈ ១ ។ ព្រះពោធិសត្វចម្រើនវ័យដោយលំដាប់ បានសម្រេចនូវសិប្បសាស្ត្រ និងទីតាំងនៃវិជ្ជា ។ ព្រះរាជបិតាបានអភិសេកព្រះរាជធីតាចន្ទាដល់ព្រះពោធិសត្វ ហើយទ្រង់តែងតាំងឲ្យជាឧបរាជ ។ ព្រះពោធិសត្វមានព្រះរាជឱរសមួយអង្គ ព្រះនាមវាសុលៈ ។ ព្រះរាជាមានបុរោហិតម្នាក់ ឈ្មោះខណ្ឌហាល ។ ទ្រង់តែងតាំងខណ្ឌហាល

ឲ្យជាចៅក្រម ខណ្ឌហាលជាអ្នកឃើញតែសំណូក បានសំណូកហើយ កាត់ក្តីដល់បុគ្គលដែលមិនជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យ បុគ្គលជាម្ចាស់ទ្រព្យឲ្យមិនជាម្ចាស់ទ្រព្យ ។ ថ្ងៃមួយ បុរសម្នាក់ត្រូវកាត់ក្តីឲ្យចាញ់ ទើបតិះដៀលបុរោហិតក្នុងរោងវិនិច្ឆ័យ កាលដើរចេញមក ឃើញព្រះពោធិសត្វកំពុងយាងមកគាល់ព្រះរាជបិតា ក៏ក្រាបចុះទៀបបាទារបស់ព្រះពោធិសត្វ ហើយយំត្អូញត្អែរថា បពិត្រព្រះអង្គ ខណ្ឌហាលបុរោហិត ស៊ីសំណូកក្នុងសាលាវិនិច្ឆ័យ គាត់ទទួលសំណូកហើយ កាត់ក្តីឲ្យទូលបង្គំចាញ់ ។ ព្រះពោធិសត្វទ្រង់លួងលោមបុរសនោះថា កុំខ្លាចឡើយ ហើយទ្រង់នាំទៅកាន់រោងវិនិច្ឆ័យ ទ្រង់កាត់ក្តីឲ្យបុរសម្ចាស់ទ្រព្យជាម្ចាស់ទ្រព្យ ។ មហាជន ក៏នាំគ្នាបន្លឺសំឡេងឲ្យសាធុការ ។

ព្រះរាជាទ្រង់ស្តាប់ដំណឹងថា បានឮថា ព្រះពោធិសត្វវិនិច្ឆ័យក្តីយុត្តិធម៌ ទើបត្រាស់ហៅព្រះពោធិសត្វមក ហើយព្រះរាជទានការវិនិច្ឆ័យដល់ព្រះពោធិសត្វថា នែបា តាំងអំពីថ្ងៃនេះទៅ ចូរបាជាអ្នកវិនិច្ឆ័យក្តីទូទៅ ។ លាភសក្ការៈរបស់ខណ្ឌហាលក៏អស់ទៅ តាំងអំពីនោះមក ខណ្ឌហាលក៏ចងអាឃាតក្នុងព្រះពោធិសត្វ ឃ្លាំរកឱកាសចាប់កំហុសរឿយៗ មក ។ ចំណែកព្រះបាទឯករាជ ទ្រង់មានសតិបញ្ញាទន់ខ្សោយ ជាមនុស្សជឿងាយ ។ ថ្ងៃមួយ ទ្រង់ព្រះសុបិនថា បានឃើញនូវទេវលោក ទ្រង់បំណងនឹងយាងទៅក្នុងទេវលោកនោះ ទើបត្រាស់នឹងបុរោហិតថា ចូរអ្នកប្រាប់ផ្លូវទៅព្រហ្មលោក ។ បុរោហិតទូលថា សូមទ្រង់ឲ្យទានដ៏ក្រៃលែង គឺបូជាយញ្ញដោយ

របស់មានជីវិតមួយមុខៗ ៤ ព្រះរាជត្រាស់សួរថា ទានដ៏ក្រៃលែងតើដូចម្ដេច បុរោហិតទូលថា ការបរិច្ចាគសត្វជើង ២ ជើង ៤ ដើម្បីបូជាយញ្ញ ធ្វើឲ្យជារបស់មួយមុខៗ ៤ ដូច្នេះ គឺព្រះរាជឱរស ព្រះរាជធីតា អគ្គមហេសីជាទីស្រឡាញ់របស់ព្រះអង្គ សេដ្ឋី ដំរីមង្គល និងសេះមង្គលជាដើម បូជាដោយឈាមក្នុងបំពង់-ករបស់សត្វទាំងនោះ ឈ្មោះថា ជាទានដ៏ក្រៃលែង ព្រះរាជាទ្រង់យល់ព្រម ដោយប្រការដូច្នេះ ។ ខណ្ឌហាលគិតថា នឹងប្រាប់ផ្លូវស្ថានសួគ៌ តែបែរជាប្រាប់ផ្លូវទៅនរក ។

ព្រះរាជាទ្រង់សម្គាល់ថា ខណ្ឌហាលនោះជាបណ្ឌិត មានបំណងនឹងបដិបត្តិតាមខណ្ឌហាល ទ្រង់សម្គាល់ថា វិធីដែលខណ្ឌហាលប្រាប់នោះ ជាផ្លូវទៅកាន់ស្ថានសួគ៌ ទើបត្រាស់ឲ្យជីករណ្ដៅបូជាមហាយញ្ញ ហើយត្រាស់ថា ចូរពួកអ្នកនាំសត្វជើង ២ ជើង ៤ ទាំងអស់ តាមដែលខណ្ឌហាលប្រាប់ តាំងអំពីព្រះរាជកុមារ មានព្រះពោធិសត្វជាដើម ទៅក្នុងទីដែលប្រកបវិធីបូជាយញ្ញ ។ វត្ថុជាគ្រឿងប្រើប្រាស់ក្នុងការបូជាយញ្ញទាំងអស់ ត្រៀមទុកព្រមហើយ មហាជនបានស្ដាប់ដូច្នោះ ក៏ស្រែកគោឡោរីករវធំ ។ ព្រះរាជាក្ដៅក្រហាយក្នុងព្រះហឫទ័យ តែត្រូវខណ្ឌហាលជំរុញ ទ្រង់ក៏បញ្ជាយ៉ាងនេះទៀត ។

ព្រះពោធិសត្វជ្រាបថា ខណ្ឌហាលមិនបានតំណែងចៅក្រម ទើបចងអាឃាតក្នុងអាត្មាអញ ប្រាថ្នាឲ្យអាត្មាអញស្លាប់ ហើយបានធ្វើសេចក្ដីវិនាសឲ្យកើតដល់ជនដទៃទៀត សូម្បីព្យាយាមដើម្បីឲ្យព្រះរាជានឹកឃើញកំហុស

ដោយឧបាយច្រើនយ៉ាង ចាកការយល់ខុសនោះ ក៏មិនអាចធ្វើឲ្យត្រឡប់ព្រះហឫទ័យបាន មហាជនកំពុងយំទ្រហឹងអឺងអាប់ ។ ព្រះពោធិសត្វទ្រង់មានសេចក្តីករុណាច្រើន កាលមហាជនកំពុងយំនោះ ពិធីកម្មទាំងអស់ក្នុងរណ្តៅបូជាយញ្ញ ក៏សម្រេច ។ ពួករាជបុរសនាំព្រះរាជឱរសចូលទៅហើយ ឲ្យអន្ទុយឱន-ក ខណ្ឌហាលនាំថាសមាសចូលទៅ កាន់ដាវឈរដោយគិតថា នឹងកាត់ព្រះសូរងរបស់ព្រះពោធិសត្វ ។ ព្រះនាងចន្ទាទេវីមហេសីរបស់ព្រះរាជឱរសឃើញដូច្នោះ គិតថា ឥឡូវនេះ អញមិនមានទីពឹងដទៃឡើយ អញនឹងធ្វើសួស្តីដល់ស្វាមី ដោយកម្លាំងសច្ចៈរបស់ខ្លួន ទើបផ្គងអញ្ជលី យាងទៅក្នុងចន្លោះប្រជុំជន ធ្វើសច្ចាធិដ្ឋានថា ផ្លូវទៅកាន់ស្ថានសួគ៌ដែលខណ្ឌហាលប្រាប់នេះ ជាកម្មលាមកដោយចំណែកមួយ ដោយពាក្យសច្ចៈរបស់ខ្ញុំនេះ ចូរសួស្តីមានដល់ស្វាមីរបស់ខ្ញុំចុះ ។

ទេវតាទាំងឡាយដែលមានក្នុងលោកនេះ សូមមកជាទីពឹង សូមការពារខ្ញុំដែលគ្មានទីពឹង សូមឲ្យខ្ញុំបាននៅជាមួយស្វាមីដោយសួស្តីចុះ ។

សក្កទេវរាជបានស្តាប់សំឡេងយំរបស់ព្រះនាងចន្ទាទេវី ទ្រង់ជ្រាបរឿងទាំងអស់ ទើបទ្រង់ទាញយកដំបងដែក ដែលមានភ្លើងឆេះសន្ធោសន្ធៅ យាងមកធ្វើឲ្យព្រះរាជាខ្លាច មានទេវបង្គាប់ឲ្យដោះលែងជនដែលត្រូវសម្លាប់ដើម្បីបូជាយញ្ញទាំងអស់ ។ សក្កទេវរាជ ទ្រង់បានសម្តែងរូបទិព្វរបស់ព្រះអង្គ ក្នុងកាលនោះ ទ្រង់គ្រវីដំបងពេជ្រដ៏រុងរឿង ប្រថាប់ឈរលើ

អាកាសត្រាស់ថា នែព្រះរាជាលាមក ចិត្តឃោរឃៅ ជាបុគ្គលកាឡកិណី ការទៅស្ថានសួគ៌ ដោយការធ្វើបាណាតិបាត ទ្រង់ធ្លាប់ឃើញក្នុងកាលណា ចូរទ្រង់លែងចន្ទកុមារ និងជនទាំងអស់នេះអំពីចំណង បើទ្រង់មិនលែង យើងនឹងពុះសីសៈរបស់ទ្រង់ និងរបស់ព្រាហ្មណ៍អាក្រក់នេះ ក្នុងកាលឥឡូវនេះ ក្នុងទីនេះឯង ព្រះរាជា និងព្រាហ្មណ៍ ឃើញភាពអស្ចារ្យដូច្នោះ ក៏ប្រញាប់ដោះលែងសត្វទាំងអស់អំពីចំណង ។

គ្រានោះ មហាជនក៏ធ្វើកោលាហលព្រមគ្នា ប្រញាប់លុបរណ្តៅបូជាយញ្ញ ហើយកាន់ដុំដីម្នាក់មួយដុំគប់ខណ្ឌហាល រហូតដល់ស្លាប់ក្នុងទីនោះឯង ហើយត្រៀមនឹងសម្លាប់ព្រះរាជាទៀតផង ។ ព្រះពោធិសត្វទ្រង់ចូលទៅឱបព្រះបិតាមិនឲ្យសម្លាប់បាន មហាជននាំគ្នាពោលដោយសេចក្តីចង្អៀតចង្អល់ថា យើងទុកជីវិតព្រះរាជាលាមកនេះ តែមិនឲ្យស្វេតច្ឆត្រ មិនឲ្យនៅក្នុងព្រះនគរ ឲ្យនៅខាងក្រៅព្រះនគរ ហើយនាំគ្នាដោះគ្រឿងយសរបស់ព្រះរាជាចេញ ឲ្យស្លៀកសំពត់កាសាវៈ យកសំពត់ចាស់ជ្រលក់រមៀតជួតសីសៈ ធ្វើដូចមនុស្សចណ្ឌាល ហើយបញ្ជូនទៅកាន់ស្រុកចណ្ឌាល ។ ម្យ៉ាងទៀត ជនទាំងឡាយណាបូជាយញ្ញដោយការសម្លាប់សត្វឯងក្តី ឲ្យអ្នកដទៃបូជាយញ្ញក្តី ត្រេកអរតាមក្តី ជនទាំងអស់នោះ ត្រូវធ្លាក់នរក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរក យ៉ាងណា ពួកជនមិនធ្វើបាបកម្មហើយ ទៅអំពីលោកនេះទៅ គប្បីបាននូវ

សុគតិ យ៉ាងនោះឯង ដូច្នេះ ។

លំដាប់នោះ រាជបរិស័ទ អ្នកនគរ អ្នកជនបទទាំងអស់ប្រជុំគ្នាអភិសេកព្រះពោធិសត្វក្នុងរាជសម្បត្តិ ។ ព្រះពោធិសត្វទ្រង់សោយរាជសម្បត្តិដោយធម៌ ទ្រង់រឭកដល់សេចក្ដីវិនាសដែលកើតឡើងដល់ព្រះអង្គ និងដល់មហាជនដោយហេតុមិនសមគួរ ទ្រង់កើតសេចក្ដីសង្វេគ មានឧស្សាហៈ ក្នុងការបំពេញបុណ្យឲ្យក្រៃលែង ទ្រង់បរិច្ចាគមហាទាន ទ្រង់រក្សាសីល ទ្រង់សមាទានឧបោសថកម្ម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា

កាលនោះ តថាគតរួចអំពីការដែលគេត្រូវសម្លាប់ ចេញផុតពីទី
យញ្ញនោះហើយ ក៏កើតសេចក្ដីសង្វេគ បានញុំាងមហាទានឲ្យ
ប្រព្រឹត្តទៅជាដើម ។

ក្នុងបទទាំងនោះ បទថា **យជនា មុត្តោ** បានដល់ ផុតចាកការត្រូវសម្លាប់ដោយន័យដូចពោលហើយ អំពីយញ្ញពិធី ដែលខណ្ឌហាលត្រៀម ។ បទថា **និក្ខន្តោ យញ្ញវាដតោ** បានដល់ ចេញអំពីទីបូជាយញ្ញនោះ មួយអន្លើដោយមហាជន ដែលកើតនូវឧស្សាហៈដើម្បីនឹងធ្វើអភិសេក ។ បទថា **សំវេគំ ជនយិត្វាន** បានដល់ ឲ្យកើតសេចក្ដីសង្វេគយ៉ាងក្រៃលែងថា ការអាស្រ័យនៅក្នុងលោកមានអន្តរាយច្រើន ។ បទថា **មហាទានំ បវត្តយឹ** បានដល់ ឲ្យសាងរោងទាន ៦ កន្លែង ហើយបរិច្ចាគមហាទាន ដូចគ្នានឹងទានរបស់ព្រះវេស្សន្តរ ដោយការបរិច្ចាគទ្រព្យដ៏ច្រើន ។ ដោយពាក្យនេះ ព្រះមានព្រះភាគទ្រង់សម្ដែងភាពដែលមហាទាននោះ ប្រព្រឹត្តទៅហើយ តាំង

អំពីបានទទួលអភិសេក ។

បទថា **ឧក្កិណោយ្យំ អនគ្ឃាន** បានដល់ តថាគតមិនបរិច្ចាគទេយ្យធម៌ក្នុងទក្ខិណេយ្យបុគ្គលឡើយ ។ បទថា **អបិ ឆប្បញ្ច រត្តិយោ** ព្រះមានព្រះភាគទ្រង់សម្ដែងថា គ្រប់គ្រា តថាគតមិនបរិភោគរបស់ផឹករបស់ទំពា និងភោជនរបស់ខ្លួន ៦ រាត្រីខ្លះ ៥ រាត្រីខ្លះ ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វទ្រង់ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមាននង្គ័លលើកឡើងហើយ ទ្រង់បរិច្ចាគមហាទានដូចភ្លៀងធំ ។ ព្រះពោធិ-សត្វទ្រង់បរិច្ចាគទានច្រើន និងប្រណីតទាំងនោះ មានបាយ និងទឹកជាដើមក្នុងរោងទាន ដល់អ្នកសូមទាំងឡាយតាមគាប់ចិត្តរាល់ៗ ថ្ងៃ ក៏ពិត តែបើទ្រង់មិនទាន់បរិច្ចាគដល់អ្នកសូមទាំងឡាយ ក៏ទ្រង់មិនសោយអាហារ ដែលត្រៀមសម្រាប់ព្រះអង្គ សូម្បីព្រះក្រយាហារនោះសមគួរដល់ព្រះរាជា ។ ព្រះមានព្រះភាគសំដៅដល់សេចក្ដីនោះ ទើបត្រាស់ថា តថាគតក៏មិនផឹកដូច្នេះជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងដល់ហេតុក្នុងការបរិច្ចាគដល់អ្នកសូមទាំងឡាយយ៉ាងនោះ ទើបទ្រង់នាំសេចក្ដីប្រៀបធៀបដោយន័យថា **យថាបិ វាណិជោ នាម** ដូច្នេះជាដើម ។

អធិប្បាយសេចក្ដីនោះដូច្នេះថា ប្រៀបដូចឈ្មួញទៅធ្វើនូវការជួញដូរមានទំនិញតិច តែលក់បានថ្លៃ ទើបសន្សំទំនិញឲ្យច្រើន ដើម្បីដឹងកាលៈទេសៈ ក្នុងកាលៈទេសៈណាទីងបានកម្រៃច្រើន ក៏នាំទំនិញនោះទៅលក់ ក្នុង

កាលៈទេសៈនោះ ។

បទថា **សកភុត្តាបិ** បានដល់ អាហាររបស់ខ្លួនក្តី អាហារដែលខ្លួនបរិភោគក្តី ។ បាឋៈថា **សកបរិភុត្តាបិ** ដូច្នេះក៏មាន ។ បទថា **បរេ** បានដល់ បុគ្គលដែលទទួលដទៃ ។ បទថា **សតភាគោ** បានដល់ ចំណែកមួយរយ គឺចំណែកច្រើនរយ នឹងមានតទៅ លោកអធិប្បាយថា ដូចទំនិញដែលឈ្មួញទិញ និងមិនលក់ក្នុងទីនោះភ្លាម រង់ចាំលក់ក្នុងកាលៈទេសៈដែលមានចំណេញច្រើន មានផលបរិបូណ៌ យ៉ាងណា របស់ខ្លួនក៏យ៉ាងនោះខ្លួនឯងក៏មិនបរិភោគ ឲ្យបុគ្គលដទៃមុន នឹងមានផលច្រើន នឹងមានចំណែកច្រើនរយ ព្រោះហេតុនោះ ខ្លួនឯងមិនគួរបរិភោគ គួរឲ្យអ្នកដទៃមុន ដោយប្រការដូច្នេះ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ ( ក្នុងទក្ខិណាវិភង្គសូត្រ ) ថា ទក្ខិណាមានគុណមួយរយ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ដូច្នេះ ។ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ។ ព្រះមានព្រះភាគត្រាស់គាថាដទៃទៀត ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តក ) ថា ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀត មន្ទិល គឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។ ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណារបស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ ដូច្នេះជាដើម ។

បទថា **ឯតមត្ថវសំ ញត្វា** សេចក្តីថា ដឹងអំណាចប្រយោជន៍ ដឹងហេតុ ពោល គឺភាពដែលទានមានផលច្រើន និងភាពដែលទានជាបច្ច័យនៃសម្មាសម្ពោធិញ្ញាណ ។ បទថា **ន បដិក្កមាមិ ទានតោ** សេចក្តីថា មិនថយក្រោយ មិនចៀសវាងចាកទានបារមី សូម្បីតែតិចតួច ។ ដើម្បីអ្វី ដើម្បីសម្រេចសម្ពោធិញ្ញាណ ។ បទថា **សម្ពោធិមនុបត្តិយា** បានដល់ ដើម្បីសម្រេច គឺសម្រេចដល់ អធិប្បាយថា ដើម្បីសម្រេចសម្ពោធិញ្ញាណ គឺព្រះសព្វញ្ញុតញ្ញាណ ។

ក្នុងកាលនោះ កាលមហាជនបណ្តេញព្រះបិតាទៅកាន់ស្រុកចណ្ឌាល ព្រះពោធិសត្វបានប្រទានស្បៀង សំពត់ស្លៀក និងសំពត់ដណ្តប់ ដែលគួរឲ្យ ។ ព្រះបិតានោះក៏មិនបានចូលព្រះនគរ កាលព្រះពោធិសត្វយាងទៅក្រៅនគរដើម្បីក្រសាលក្នុងឧទ្យានជាដើម ព្រះបិតាមិនថ្វាយបង្គំ មិនធ្វើអញ្ជលីកម្ម ព្រោះយល់ថាជាបុត្រ តែពោលថា ចូរបុត្រមានអាយុយឺនយូរចុះ ។ ព្រះពោធិសត្វ ក្នុងថ្ងៃដែលឃើញព្រះបិតា ទ្រង់ក៏ធ្វើការរាប់អានយ៉ាងក្រៃលែង ។ ព្រះពោធិសត្វទ្រង់គ្រងរាជសម្បត្តិ ដោយធម៌យ៉ាងនេះ កាលសោយទិវង្គត ក៏ទៅកាន់ទេវលោក មួយអន្លើដោយបរិស័ទ ។

ខណ្ឌហាលក្នុងកាលនោះ បានជាទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះនាងគោតមីទេវីក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា ក្នុងកាលឥឡូវនេះ ព្រះនាងចន្ទារាជធីតាក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ រាជកុមារវាសុលៈក្នុងកាលនោះ បានមកជារាហុល ក្នុងកាលឥឡូវនេះ

ព្រះនាងសេលាក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ ព្រះរាជកុមារសូរៈក្នុងកាលនោះ បានមកជាព្រះមហាកស្សបៈ ក្នុងកាលឥឡូវនេះ ភទ្ទសេនរាជកុមារក្នុងកាលនោះ បានមកជាព្រះមហាមោគ្គល្លាន ក្នុងកាលឥឡូវនេះ សុរិយកុមារក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ក្នុងកាលឥឡូវនេះ ព្រះបាទចន្ទរាជក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងទីនេះក៏គួរពោលចំពោះដល់បារមីដ៏សេស របស់ព្រះពោធិសត្វនោះ តាមសមគួរដោយន័យដូចពោលមកហើយក្នុងកាលមុននោះឯង គប្បីពោលចំពោះដល់គុណានុភាពជាដើមថា ក្នុងកាលនោះ ព្រះពោធិសត្វសូម្បីដឹងថា ខណ្ឌហាលជាមនុស្សគ្រោតគ្រាត ក៏ទ្រង់ប្រើតុល្យវិនិច្ឆ័យក្ដីដោយធម៌ស្មើ ទោះបីទ្រង់ជ្រាបវិធីបូជាយញ្ញយ៉ាងនោះរបស់ខណ្ឌហាល ដែលបំណងនឹងផ្ដាច់ព្រះជន្មព្រះអង្គ ក៏មិនមានចិត្តក្រោធអាក់អន់នឹងខណ្ឌហាលនោះ ។ សូម្បីអាចចាប់បរិស័ទរបស់ព្រះអង្គ ដែលជាសត្រូវរបស់ព្រះបិតា កាលព្រះបិតាបំណងនឹងធ្វើព្រះអង្គឲ្យជាបុរសសត្វចិញ្ចឹម ហើយសម្លាប់ ក៏មិនបានប្រើតួនាទីក្នុងការដាក់អាជ្ញា ដោយទ្រង់ព្រះតម្រិះថា ការខឹងក្រោធ

ដោយកម្មធ្ងន់ មិនសមគួរដល់បុគ្គលដូចអាត្មាអញ ។ កាលបុរោហិតដកដាវចេញអំពីស្រោម ឈានជើងចូលទៅដើម្បីកាត់ក្បាល ទ្រង់មានចិត្តមេត្តាផ្សាយទៅក្នុងព្រះបិតារបស់ព្រះអង្គ ស្មើនឹងព្រះរាជឱរស និងសព្វសត្វទាំងឡាយ ។ កាលមហាជនបោមរោមចូលទៅ បំណាំងនឹងផ្តាច់ព្រះជន្មរបស់បិតា ខ្លួនឯងចូលឱបព្រះបិតា ឲ្យជីវិតព្រះបិតានោះ ។ កាលទ្រង់បរិច្ចាគមហាទាន ដូចគ្នានឹងទានរបស់ព្រះវេស្សន្តររាល់ៗ ថ្ងៃ ក៏មិនឆ្អែតក្នុងទាន ។ កាលឲ្យរបស់ដែលគួរឲ្យដល់ព្រះជនកដែលត្រូវមហាជនបណ្តេញទៅកាន់ស្រុកចណ្ឌាល ហើយចិញ្ចឹមរក្សា ការឲ្យមហាជនតាំងនៅក្នុងការធ្វើបុណ្យ ។ល។

## អដ្ឋកថាចន្ទកុមារចរិយា ចប់

# សុត្តន្តបិដក

## សិវិរាជចរិយាទី ៨

[ ៨ ] កាលតថាគតជាក្សត្រ ឈ្មោះសិវិ សោយរាជ្យក្នុងនគរអរិដ្ឋៈ អង្គុយក្នុងប្រាសាទដ៏ប្រសើរ តថាគតគិតយ៉ាងនេះថា ទានណាមួយជារបស់មនុស្ស ទាននោះ គឺអញមិនដែលឲ្យហើយ មិនមានឡើយ បើមានយាចកណាមកសូមភ្នែកអញ អញនឹងមិនញាប់ញ័រ ត្រូវតែឲ្យ ( ដល់យាចកនោះ ) ។ សក្កៈជាធំជាងពួកទេវតាបានដឹងនូវសេចក្ដីត្រិះរិះរបស់តថាគត អង្គុយនៅក្នុងទេវបរិស័ទក៏ពោលនូវពាក្យនេះថា ស្ដេចសិវិ មានឫទ្ធិច្រើន គង់ក្នុងប្រាសាទដ៏ប្រសើរ កំពុងពិចារណានូវទានផ្សេងៗ ( ដែលខ្លួនឲ្យហើយ ) ស្ដេចនោះ មិនឃើញនូវវត្ថុ ដែលខ្លួនមិនធ្លាប់ឲ្យសោះឡើយ ។ ការណ៍នុ៎ះពិត ឬមិនពិតអេះ បើដូច្នេះ អញនឹងល្បងស្ដេចនោះមើល អ្នកទាំងឡាយ ចូររង់ចាំមួយរំពេច ទម្រាំយើងបានដឹងនូវព្រះរាជហឫទ័យនៃស្ដេចនោះ ( ព្រះឥន្ទក៏ក្លែងខ្លួនជាព្រាហ្មណ៍ ) មានសក់ស្កូវ មានខ្លួនជ្រួញជ្រីវ ទុរន់ទុរាដោយជរា ព្រមទាំងមានសម្បុរអាក្រក់ ដើរញញាក់ញញ័រ ចូលទៅរកព្រះរាជា ។ គ្រានោះព្រាហ្មណ៍នោះផ្គងដៃឆ្វេង និងដៃស្ដាំ ហើយធ្វើអញ្ជលីលើសិរ្សៈពោលពាក្យនេះថា បពិត្រធម្មិកមហារាជ ជាអ្នកញ៉ាំងដែនឲ្យចម្រើន ខ្ញុំព្រះអង្គសូមអង្វរព្រះអង្គ កិត្តិសព្ទរបស់ព្រះអង្គ ថាត្រេកអរក្នុងទាន ល្បីទូទៅទៅក្នុងទេវលោក និងមនុស្សលោក ។

ភ្នែកទាំងពីរនៃទូលព្រះបង្គំ ត្រូវងងឹតបៀតបៀនហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រមួយ ដល់ទូលព្រះបង្គំ ចំណែកព្រះអង្គសូមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយព្រះនេត្រម្ខាងចុះ ។ តថាគតឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏រីករាយ មានចិត្តសង្វេគ ធ្វើអញ្ជលី មានសេចក្តីត្រេកអរ ហើយពោលថា ខ្ញុំទើបនឹងគិតឃើញអម្បាញ់មិញនេះ ហើយចុះអំពីប្រាសាទមកក្នុងទីនេះ អ្នកទំនងជាដឹងចិត្តខ្ញុំ ទើបមកសូមភ្នែកខ្ញុំ ឱហ្ន៎ ! សេចក្តីប្រាថ្នាក្នុងចិត្តនៃខ្ញុំសម្រេចហើយ សេចក្តីត្រិះរិះនៃខ្ញុំពេញហើយ ទានដ៏ប្រសើរដែលខ្ញុំមិនធ្លាប់ឲ្យ ខ្ញុំនឹងឲ្យដល់ស្មូមក្នុងថ្ងៃនេះ ។ ម្នាលពេទ្យឈ្មោះសិវកៈ អ្នកចូរមក ចូរក្រោកឡើង កុំបង្អង់ឲ្យយឺតយូរឡើយ កុំញាប់ញ័រ ចូរឆ្កៀលភ្នែកទាំងពីរ ( របស់អញ ) ហើយឲ្យដល់ស្មូម ។ លំដាប់នោះ ពេទ្យសិវកៈនោះដែលតថាគតដាស់តឿនហើយ ក៏ធ្វើតាមពាក្យតថាគត បានខ្វេះឆ្កៀល ( ភ្នែកតថាគត ) ហើយប្រគល់ឲ្យដល់ស្មូម ដូចជាឲ្យសាច់ត្នោត ។ ក្នុងកាលមុនឲ្យក្តី កំពុងឲ្យក្តី ឲ្យរួចហើយក្តី ចិត្តរបស់តថាគត ឥតមានការរាយមាយឡើយ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។ ភ្នែកទាំងពីរមិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនសោតទៀត ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យចក្ខុ ។

# អដ្ឋកថា

## សិវិរាជចរិយា

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិវិរាជចរិយាទី ៨ ដូចតទៅនេះ បទថា **អរិដ្ឋសវ្ហយេ នគរេ** បានដល់ ក្នុងព្រះនគរឈ្មោះអរិដ្ឋបុរី ។ បទថា **សិវិ នាមាសិ ខត្តិយោ** បានដល់ ព្រះរាជាមាននាមយ៉ាងនេះ ដោយគោត្រថា សិវិ ។

បានឮថា ក្នុងអតីតកាល ព្រះបាទសិវិរាជគ្រងរាជសម្បត្តិ ក្នុងអរិដ្ឋ-បុរនគរ ដែនសិវិ ។ ព្រះមហាសត្វកើតជាព្រះរាជឱរសរបស់ព្រះបាទសិវិរាជនោះ ។ ព្រះញាតិបានថ្វាយព្រះនាមរបស់ព្រះមហាសត្វនោះថា សិវិកុមារ កាលព្រះមហាសត្វចម្រើនវ័យ ទ្រង់យាងទៅកាន់នគរតក្កសិលា ទ្រង់រៀននូវសិប្បៈ សម្រេចហើយយាងត្រឡប់ ទ្រង់សម្តែងសិប្បៈថ្វាយព្រះបិតា បានទទួលតំណែងឧបរាជ តមក ព្រះបិតាសោយទិវង្គត បានជាព្រះរាជា ទ្រង់លះអគតិ ទ្រង់តាំងនៅក្នុងរាជធម៌ គ្រងរាជសម្បត្តិ ទ្រង់ឲ្យសាងរោងទាន ៦ គឺត្រង់ទ្វារនគរ ៤ ត្រង់កណ្តាលនគរ ១ ត្រង់ទ្វារព្រះរាជនិវេសន៍ ១ ទ្រង់បរិច្ចាគទានមួយថ្ងៃ ៦ សែនរាល់ៗ ថ្ងៃ ក្នុងថ្ងៃ ៨ ថ្ងៃ ១៤ និងថ្ងៃ ១៥ ទ្រង់ឡើងកាន់រោងទានដោយព្រះអង្គឯង ទ្រង់ត្រួតមើលរោងទាន ។ ជួនកាល ក្នុងថ្ងៃ ១៥ ពេលព្រឹក ទ្រង់ប្រថាប់គង់លើរាជបល្ល័ង្ក ខាងក្រោមស្វេតច្ឆត្រដែលលើកឡើង ទ្រង់ព្រះតម្រិះថា ទានខាងក្រៅរបស់អញមិនញុំាងចិត្តឲ្យត្រេកអរ ដូចទានខាងក្នុង ។ ធ្វើម្តេចហ្ន៎ ក្នុងពេលដែលអញទៅកាន់រោងទាន នឹងមានបុគ្គលណាមួយមិនសូមវត្ថុខាងក្រៅ សូមវត្ថុខាង

*ក្នុងតែម្យ៉ាង ។ បើបុគ្គលណាមួយគប្បីសូមសាច់ ឬឈាមក្នុងរាងកាយរបស់អញ សីសៈ បេះដូង ភ្នែក រាងកាយមួយចំហៀង ឬអត្តភាពទាំងមូលយកទៅធ្វើជាទាសៈ អញនឹងញ៉ាំងបំណងរបស់បុគ្គលនោះឲ្យបរិបូណ៌មួយរំពេចក្នុងទីដែលអាចឲ្យបាន ។ តែក្នុងបាលីពោលត្រឹមតែភ្នែកប៉ុណ្ណោះ ដូចព្រះមានព្រះភាគត្រាស់ថា*

> *កាលតថាគតជាក្សត្រ ឈ្មោះសិវិ សោយរាជ្យក្នុងនគរអរិដ្ឋៈ អង្គុយក្នុងប្រាសាទដ៏ប្រសើរ តថាគតគិតយ៉ាងនេះថា ទានណាមួយជារបស់មនុស្ស ទាននោះ គឺអញមិនដែលឲ្យហើយ មិនមានឡើយ បើមានយាចកណាមកសូមភ្នែកអញ អញនឹងមិនញាប់ញ័រ ត្រូវតែឲ្យ ( ដល់យាចកនោះ ) ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **មានុសំ ទានំ** *បានដល់ បាយ និងទឹកជាដើមដែលជាទាន ដែលមនុស្សទូទៅគប្បីឲ្យ ។ កាលអធ្យាស្រ័យក្នុងកាលឲ្យដ៏ទូលាយ កើតឡើងដល់ព្រះមហាសត្វយ៉ាងនេះ បណ្ឌុកម្ពលសិលាសនៈរបស់សក្កៈ សម្ដែងនូវអាការក្ដៅ សក្កៈនោះ ទ្រង់គប្បីដឹងដល់ហេតុនោះ ទ្រង់បានឃើញព្រះអធ្យាស្រ័យរបស់ព្រះពោធិសត្វ ទ្រង់ព្រះតម្រិះថា ព្រះបាទសិវិទ្រង់គិតថា ថ្ងៃនេះ បើមានបុគ្គលមកសូមភ្នែកអញ អញនឹងខ្វេះភ្នែកឲ្យ ទើបសក្កទេវរាជត្រាស់នឹងទេវបរិស័ទថា យើងនឹងសាកល្បងព្រះពោធិសត្វមើលថា តើអាចឲ្យភ្នែកពិតឬហ្ន៎ កាលព្រះពោធិសត្វទ្រង់ស្រង់ដោយទឹកក្រអូប ១៦ ក្អម ហើយទ្រង់ប្រដាប់ដោយអលង្ការសព្វយ៉ាង ទ្រង់*

ប្រថាប់លើ-កដីរព្រះទីន័ង ដែលតាក់តែងយ៉ាងល្អ យាងទៅកាន់រោងទាន ទើបសក្កៈកាឡាខ្លួនជាព្រាហ្មណ៍ខ្វាក់ភ្នែក ជាមនុស្សចាស់ ដើរផ្ទក់ៗ ទ្រង់លាដៃទាំងទ្វេក្នុងទីទួលមួយកន្លែង ក្នុងគន្លងចក្ខុរបស់ព្រះពោធិសត្វ ឈរថ្វាយព្រះពរ សូមឲ្យព្រះរាជាទ្រង់មានសេចក្ដីចម្រើន ព្រះពោធិសត្វទ្រង់ឲ្យដំរីទៅកាន់មុខព្រាហ្មណ៍នោះ ហើយត្រាស់សួរថា នែព្រាហ្មណ៍ អ្នកត្រូវការអ្វី ព្រាហ្មណ៍ទូលសូមភ្នែកម្ខាង ដោយត្រាស់ពាក្យជាខ្លោសថា សត្វលោកទាំងឡាយ ល្បីខ្ចរខ្ចាយមិនដាច់ ដោយការប្រកាសកិត្តិគុណដ៏ឧត្តម អាស្រ័យអជ្ឈាស្រ័យក្នុងទានរបស់ព្រះអង្គ ម្យ៉ាងទៀត ទូលបង្គំជាមនុស្សខ្វាក់ ព្រោះហេតុនោះ ទើបសូមព្រះនេត្ររបស់ព្រះអង្គ ដូចព្រះមានព្រះភាគត្រាស់ថា

សក្កៈជាធំជាងពួកទេវតា បានដឹងនូវសេចក្ដីត្រិះរិះ របស់តថាគតអង្គុយនៅក្នុងទេវបរិស័ទ ក៏ពោលនូវពាក្យនេះថា ស្ដេចសិវិមានឫទ្ធិច្រើន គង់ក្នុងប្រាសាទដ៏ប្រសើរ កំពុងពិចារណានូវទានផ្សេងៗ ( ដែលខ្លួនឲ្យហើយ ) ស្ដេចនោះ មិនឃើញនូវវត្ថុដែលខ្លួនមិនធ្លាប់ឲ្យសោះឡើយ ។ ការណ៍នុ៎ះពិត ឬមិនពិតអេះ បើដូច្នេះ អញនឹងល្បងស្ដេចនោះមើល អ្នកទាំងឡាយចូររង់ចាំមួយរំពេច ទម្រាំយើងបានដឹងនូវព្រះរាជហឫទ័យនៃស្ដេចនោះ ( ព្រះឥន្ទក៏ក្លែងខ្លួនជាព្រាហ្មណ៍ ) មានសក់ស្កូវ មានខ្លួនជ្រួញជ្រីវ ទូរន់ទូរាដោយជរា ព្រមទាំងមានសម្បុរអាក្រក់ ដើរញញាក់ញញ័រ ចូលទៅរកព្រះរាជា ។ គ្រានោះ ព្រាហ្មណ៍នោះ

ផ្គងដៃឆ្វេង និងដៃស្តាំ ហើយធ្វើអញ្ជលីលើសិរ្សៈ ពោលពាក្យនេះថា បពិត្រធម្មិកមហារាជ ជាអ្នកញុំាងដែនឲ្យចម្រើន ខ្ញុំព្រះអង្គសូមអង្វរព្រះអង្គ កិត្តិសព្ទរបស់ព្រះអង្គ ជាត្រេកអរក្នុងទាន ល្បីទូទៅទៅក្នុងទេវលោក និងមនុស្សលោក ។ ភ្នែកទាំងពីរនៃទូលព្រះបង្គំ ត្រូវងងឹតបៀតបៀនហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រមួយ ដល់ទូលព្រះបង្គំ ចំណែកព្រះអង្គ សូមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយព្រះនេត្រម្ខាងចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ចិន្តេន្តោ វិវិធំ ទានំ** សេចក្តីថា ទ្រង់ត្រិះរិះដល់ទានផ្សេងៗ ដែលទ្រង់ព្រះរាជទាន គឺទ្រង់ត្រិះរិះដល់ទាន ឬទេយ្យធម៌ខាងក្រៅច្រើនយ៉ាង ដែលទ្រង់ព្រះរាជទាន ។ បទថា **អទេយ្យំ សោ ន បស្សតិ** សេចក្តីថា ទ្រង់មិនឃើញវត្ថុដែលមិនបានឲ្យ គឺមិនបានឃើញសូម្បីវត្ថុខាងក្នុង ដែលមិនទាន់បានឲ្យ គឺមិនអាចឲ្យបាន ដូចវត្ថុខាងក្រៅ អធិប្បាយថា ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា សូម្បីភ្នែកអញក៏ខ្វះឲ្យបាន ។ បទថា **តជំ នុ វិតជំ ឆេតំ** សេចក្តីថា ការមិនឃើញវត្ថុខាងក្នុងជាវត្ថុដែលមិនបានឲ្យ ការឃើញ ការគិត ដោយភាពជាវត្ថុដែលគួរឲ្យនោះឯង សេចក្តីនោះ ពិត ឬមិនពិតហ្ន៎ ។ បទថា **សោ តទា បគ្គហេត្វាន វាមំ ទក្ខិណ-ពាហុំ ច** បានដល់ ក្នុងកាលនោះ ទ្រង់ផ្គងដើមដៃឆ្វេង និងដើមដៃស្តាំ អធិប្បាយថា ទ្រង់លើកដើមដៃទាំងទ្វេ ។ បទថា **រដ្ឋវឌ្ឍន** បានដល់ ដែលធ្វើនូវសេចក្តីចម្រើនដល់ប្រទេស ។ បទថា **តុម្ហិ ឯកេន យាបយ** លោក

សម្តែងថា ទ្រង់ឃើញទីស្មើ និងមិនស្មើដោយព្រះនេត្រម្ខាង ទ្រង់ក៏ញ៉ាំង អត្តភាពរបស់ទ្រង់ឲ្យប្រព្រឹត្តទៅបាន ឯទូលបង្គំក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ បាន ដោយភ្នែកម្ខាងដែលបានអំពីព្រះអង្គដ៏ចម្រើន ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ ទ្រង់ត្រេកអរ កើតនូវកម្លាំងចិត្តថា អញអង្គុយលើប្រាសាទ គិតយ៉ាងនេះហើយ អម្បាញ់មិញនេះឯង ព្រាហ្មណ៍ នេះសុំភ្នែកដូចដឹងចិត្តរបស់អញ ជាលាភរបស់អញពិតហ្ន៎ ថ្ងៃនេះ សេចក្តី ប្រាថ្នារបស់អញនឹងដល់ទីបំផុត ។ អញនឹងឲ្យទានដែលមិនធ្លាប់ឲ្យ ព្រះ សាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

*តថាគត ឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏រីករាយ មានចិត្ត សង្វេគ ធ្វើអញ្ជលី មានសេចក្តីត្រេកអរ ហើយពោលថា ខ្ញុំ ទើបនឹងគិតឃើញអម្បាញ់មិញនេះ ហើយចុះអំពីប្រាសាទ មក ក្នុងទីនេះ អ្នកទំនងជាដឹងចិត្តខ្ញុំ ទើបមកសូមភ្នែកខ្ញុំ ឱហ្ន៎ ! សេចក្តី ប្រាថ្នាក្នុងចិត្តនៃខ្ញុំសម្រេចហើយ សេចក្តីត្រិះរិះនៃខ្ញុំ ពេញហើយ ទានដ៏ប្រសើរ ដែលខ្ញុំមិនធ្លាប់ឲ្យ ខ្ញុំនឹងឲ្យដល់ស្មូម ក្នុងថ្ងៃនេះ ដូច្នេះ ។*

ក្នុងបទទាំងនោះ បទថា **តស្ស** បានដល់ សក្កទេវរាជ ដែលមកក្នុង រូបរបស់ព្រាហ្មណ៍ ។ បទថា **ហដ្ឋោ** បានដល់ ត្រេកអរ ។ បទថា **សំវិគ្គ-មានសោ** សេចក្តីថា ព្រាហ្មណ៍នេះសូមភ្នែកដូចដឹងចិត្តអញ ។ ឈ្មោះថា **សំវិគ្គ** ព្រោះអញមិនគិតយ៉ាងនេះ មកអស់កាលមានប្រមាណប៉ុណ្ណេះ ជា

អ្នកប្រមាទហើយហ្ន៎ ។ បទថា **វេទជាតោ** បានដល់ កើតនូវបីតិ និង បាមោជ្ជ ។ បទថា **អត្រវី** បានដល់ បានពោលហើយ ។ បទថា **មានសំ** បានដល់ ការតាំងចិត្ត គឺអធ្យាស្រ័យក្នុងការឲ្យ អធិប្បាយថា កើតអធ្យាស្រ័យក្នុងការឲ្យថា យើងនឹងឲ្យក្អែក ។ បទថា **សង្កប្បោ** បានដល់ សេចក្តីប្រាថ្នានៃចិត្ត ។ បទថា **បរិបូរិតោ** បានដល់ ពេញហើយ ។

លំដាប់នោះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះសូមក្អែកដែលបុគ្គលណាមួយលះឲ្យបានដោយក្រជាមួយនឹងអញ ដូចដឹងវារៈចិត្តរបស់អញ ។ គួរខ្ញាចថា ទេវតាមួយអង្គប្រាប់មកឬដូចម្តេច អញនឹងសួរដូច្នេះហើយ ទើបត្រាស់សួរព្រាហ្មណ៍នោះ ដូចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាជាតកថា

នៃស្មូម អ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ បម្រុងសុំនូវ
ក្អែកទាំងឡាយ ជនទាំងឡាយពោលនូវក្អែកណា ថាជារបស់
ដែលបុរសលះបានដោយក្រ អ្នកសុំនូវក្អែក ជាអវយវៈដ៏
ខ្ពង់ខ្ពស់នោះ ដែលគេលះបានដោយក្រក្រៃលែង ដូច្នេះ ។

សក្កទេវរាជដែលមកក្នុងភេទរបស់ព្រាហ្មណ៍ ស្តាប់ដូច្នោះហើយ ទើបត្រាស់ថា

ពួកទេវតា បានពោលនូវទេវតាវិសេសណាថា សុជម្បតិក្នុង
ទេវលោក ពួកជនបានពោលនូវទេវតាវិសេសនោះ ថាមឃវៈ
ក្នុងមនុស្សលោក ខ្លួនខ្ញុំជាស្មូម ដែលទេវតាវិសេសនោះប្រាប់

ទើបមកក្នុងទីនេះ បម្រុងសុំព្រះនេត្រទាំងឡាយ ។ ខ្ញុំនខ្ញុំជាស្មូម ការសូមជាកិច្ចឧត្តមរបស់ខ្ញុំ កាលបើខ្ញុំសូមព្រះនេត្រទាំងឡាយ សូមព្រះអង្គប្រទាន ពួកជនបានពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះ ដល់ខ្ញុំព្រះអង្គ ដូច្នេះ ។

ព្រះពោធិសត្វត្រាស់ថា

ខ្ញុំនអ្នកមកដោយប្រយោជន៍ណា ប្រាថ្នានូវប្រយោជន៍ណា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ សូមឲ្យសម្រេចដល់អ្នកចុះ ម្នាលព្រាហ្មណ៍ អ្នកចូរបាននូវភ្នែកទាំងឡាយ ។ កាលបើអ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនកំពុងមើល សូមអ្នកនោះ ជាបុគ្គលមានភ្នែកទៅចុះ អ្នកប្រាថ្នានូវរបស់ណា របស់នោះ ចូរសម្រេចដល់អ្នក ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ស្មូម** បានដល់ ព្រះពោធិសត្វត្រាស់ហៅព្រាហ្មណ៍នោះ ។ ពាក្យថា ភ្នែកទាំងឡាយ នេះជាឈ្មោះរបស់ភ្នែក ព្រោះជាគន្លងនៃការឃើញ ។ ពាក្យថា ជនទាំងឡាយពោលនូវភ្នែកណាថា បាលដល់ វត្ថុដែលជនទាំងឡាយ និយាយគ្នាក្នុងលោកថា លះបានដោយក្រ ។ បទថា ជាស្មូម បានដល់ ជាអ្នកសូម ។ ពាក្យថា ការសូម បានដល់ ការសូម ។ ពាក្យថា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ បានដល់ សេចក្តីប្រាថ្នាទាំងនោះ របស់អ្នកដែលមានភ្នែកខ្វាក់ ។ ពាក្យថា ជាបុគ្គលមានភ្នែក

*បានដល់ អ្នកដែលមានភ្នែក ដោយភ្នែករបស់ខ្ញុំ ។ ពាក្យថា **របស់នោះ** ចូរសម្រេចដល់អ្នក សេចក្តីថា អ្នកប្រាថ្នាវត្ថុណាអំពីសម្នាក់របស់ខ្ញុំ វត្ថុនោះ ចូរសម្រេចដល់អ្នក ។ ព្រះរាជាកាលត្រាស់ត្រឹមប៉ុណ្ណេះហើយ ទើបត្រាស់ ( បន្ត ) ថា ព្រាហ្មណ៍នេះសក្កៈប្រាប់ ទើបមករកអញក្នុងទីនេះ ទ្រង់ជ្រាប ថា ភ្នែកនឹងសម្រេចបរិបូណ៌ដល់ព្រាហ្មណ៍នេះ ដោយឧបាយនេះពិត ទើប ទ្រង់ព្រះតម្រិះថា អញមិនគួរខ្វេះភ្នែកឲ្យក្នុងទីនេះ ទើបទ្រង់នាំព្រាហ្មណ៍ ចូលទៅខាងក្នុងព្រះនគរ ប្រថាប់គង់លើរាជអាសនៈ ត្រាស់ហៅគ្រូពេទ្យ ឈ្មោះសិវកៈមក ។ លំដាប់នោះ ក៏កើតក្ញាក់ផ្អើល កោលាហលពេញ ព្រះនគរថា បានឮថា ព្រះរាជារបស់ពួកយើង មានបំណងនឹងឲ្យគ្រូពេទ្យខ្វេះ ភ្នែកឲ្យដល់ព្រាហ្មណ៍ ។ កាលនោះ ពួករាជវល្លភៈរបស់ព្រះរាជា មាន ព្រះញាតិ និងសេនាបតីជាដើម ពួកអមាត្យ បរិស័ទ អ្នកនគរ ពួកស្នំ ទាំងអស់ប្រជុំគ្នាទូលហាមព្រះរាជាដោយឧបាយផ្សេងៗ សូម្បីព្រះរាជាក៏មិន បានយល់ស្របតាមបុគ្គលទាំងនោះ ដូចព្រះមានព្រះភាគត្រាស់ថា*

> *បពិត្រព្រះសម្មតិទេព សូមទ្រង់កុំប្រទាននូវព្រះនេត្រ សូមទ្រង់កុំ លះបង់នូវពួកយើងទាំងអស់គ្នាឡើយ បពិត្រមហារាជ សូម ទ្រង់ប្រទាននូវព្រះរាជទ្រព្យ គឺកែវមុក្តា និងកែវពិទូរ្យដ៏ច្រើន វិញចុះ ។ បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទាននូវរថ ដែល ទឹមដោយសេះអាជានេយ្យ ដែលប្រដាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទាននូវដំរីទាំងឡាយ ប្រកបដោយគ្រឿងប្រដាប់*

ក្បាល គឺបណ្តាញមាសវិញចុះ ។ រទាំងពួង ព្រមទាំងខ្សែ ព្រមទាំងរាជរថ ចោមរោមព្រះអង្គដោយជុំវិញ គ្រប់កាល ដោយប្រការណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គ ប្រទានដោយប្រការនោះចុះ ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់ ៣ គាថាថា

បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថា យកអន្ទាក់ដែលធ្លាក់លើផែនដីមកពាក់ពួដ៏ក ។ បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថា ជាបុគ្គលលាមកក្រៃលែង ជាងបុគ្គលលាមក ហើយដល់នូវស្ថាននរក ជាទីសម្រេចរបស់ព្រះយមរាជ ។ ស្មូមសូមនូវរបស់ណា បុគ្គលគួរតែឲ្យនូវរបស់នោះ មិនសូមនូវរបស់ណា មិនត្រូវឲ្យរបស់នោះទេ ព្រាហ្មណ៍សូមនូវរបស់ណា នឹងអាត្មាអញ អាត្មាអញនោះនឹងឲ្យនូវរបស់នោះឯង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឆោ** ក្នុងបទថា **មា ឆោ ឆោ** ( បពិត្រព្រះសម្មតិទេព សូមទ្រង់កុំ ) ត្រឹមតែជានិបាត ។ សេចក្តីថា បពិត្រ ព្រះអង្គសូមទ្រង់កុំព្រះរាជទានព្រះនេត្រឡើយ ។ ពាក្យថា សូមទ្រង់កុំលះបង់នូវពួកយើងទាំងអស់គ្នាឡើយ សេចក្តីថា ទ្រង់កុំបោះបង់ពួកទូលបង្គំទាំងឡាយឡើយ ។

*ជនទាំងឡាយ ក្រាបទូលយ៉ាងនេះដោយបំណងថា ព្រោះកាលព្រះអង្គព្រះរាជទានព្រះនេត្រ ទ្រង់នឹងមិនអាចគ្រប់គ្រងរាជសម្បត្តិបាន កាលបើយ៉ាងនោះ ពួកទូលបង្គំ នឹងឈ្មោះថា ត្រូវព្រះអង្គបោះបង់ ។ ពាក្យថា ចោមរោមព្រះអង្គដោយជុំវិញ បានដល់ ចោមរោម ។ ពាក្យថា សូមព្រះអង្គប្រទានដោយប្រការនោះចុះ សេចក្ដីថា សូមទ្រង់ព្រះរាជទាន ដោយវិធីដែលអ្នកសិវិចោមរោមព្រះអង្គ ដែលមានព្រះនេត្រមិនពិការតទៅ អស់កាលយូរ សូមទ្រង់ព្រះរាជទានទ្រព្យដល់ព្រាហ្មណ៍នោះតែម្យ៉ាងចុះ ទ្រង់កុំព្រះរាជទានព្រះនេត្រឡើយ លោកសម្ដែងថា ព្រោះកាលព្រះរាជទានព្រះនេត្រហើយ អ្នកសិវិក៏នឹងមិននាំគ្នាចោមរោមព្រះអង្គ ។*

*ពាក្យថា* ***ពាក់*** *បានដល់ ទាក់ចូលទៅ ។ ពាក្យថា បុគ្គលនោះឈ្មោះថា ជាបុគ្គលលាមកក្រៃលែង ជាងបុគ្គលលាមក បានដល់ ឈ្មោះថាជាបុគ្គលលាមកជាងបុគ្គលលាមក ។ ពាក្យថា ហើយដល់នូវស្ថាននរក ជាទីសម្រេចរបស់ព្រះយមរាជ បានដល់ បុគ្គលនោះ ឈ្មោះថា ធ្លាក់ឧស្សទនរក ដែលស្ដេចយមដាក់អាជ្ញា ។ ពាក្យថា ស្នូមសូមនូវរបស់ណា ព្រះពោធិសត្វត្រាស់ថា ស្នូមសូមនូវវត្ថុណា បុគ្គលក៏គួរឲ្យវត្ថុនោះ មិនឲ្យវត្ថុដែលគេមិនបានសូម ។ ព្រាហ្មណ៍នេះ សូមភ្នែកនឹងអញ មិនសូមទ្រព្យមានកែវមុក្ដាជាដើម អញនឹងឲ្យវត្ថុដែលព្រាហ្មណ៍សូម ។*

*លំដាប់នោះ ជនទាំងឡាយសួរព្រះពោធិសត្វថា បពិត្រព្រះសម្មតិទេពទ្រង់ប្រាថ្នាអាយុជាដើម ទើបព្រះរាជទានព្រះនេត្រ ។ ព្រះមហាបុរសត្រាស់*

ថា យើងមិនបានឲ្យព្រោះប្រាថ្នាសម្បត្តិក្នុងបច្ចុប្បន្ន ឬក្នុងកពខាងមុខ ដែលពិត នេះជាផ្លូវបុរាណដែលព្រះពោធិសត្វទាំងឡាយប្រព្រឹត្តសន្សំមក គឺការបំពេញទានបារមី សមដូចព្រះមានព្រះភាគត្រាស់ថា

បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គប្រាថ្នានូវរបស់អ្វី គឺអាយុ ឬពណ៌សម្បុរ ឬសេចក្តីសុខ ឬក៏កម្លាំង ទើបព្រះអង្គប្រទាន ( ព្រះនេត្រ ) ព្រះរាជាទ្រង់ប្រសើរជាងជន អ្នកនៅក្នុងដែនសីវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយ ព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក ។

អញមិនមែនឲ្យចក្ខុនេះ ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌ គឺប្រវេណីនៃការឲ្យទាន ជាផ្លូវបុរាណ ដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អញតែងរីករាយក្នុងការឲ្យ ដោយប្រការដូច្នេះឯង ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក សេចក្តីថា បពិត្រមហារាជ បុរសបណ្ឌិតដូចព្រះអង្គ លះនូវភាពជាធំ ដែលទ្រង់ឃើញហើយ ដូចគ្មានឹងសម្បត្តិរបស់សក្កៈ គប្បីព្រះរាជទានព្រះនេត្រព្រោះហេតុនៃបរលោកបានដូចម្តេច ។

ពាក្យថា **ន វាហំ** ( អញមិនមែន ) កាត់បទជា **ន វេ អហំ** ។ ពាក្យថា ព្រោះយសទេ សេចក្តីថា ព្រោះហេតុនៃភាពជាធំដែលជារបស់ទិព្វ

ឬរបស់មនុស្ស ។ ម្យ៉ាងទៀត ធម៌ដែលជាពុទ្ធការកធម៌ របស់សប្បុរស ទាំងឡាយ គឺរបស់ព្រះពោធិសត្វទាំងឡាយ ជារបស់បុរាណ ដែលបណ្ឌិត ប្រព្រឹត្តក្រៃលែង សន្សំហើយ ចិត្តរបស់យើងយ៉ាងនេះ ត្រេកអរជានិច្ចក្នុង ទាននោះឯង ដោយហេតុនេះ ដោយប្រការដូច្នេះ ។

ព្រះរាជាកាលត្រាស់យ៉ាងនេះហើយ ទ្រង់ឲ្យអមាត្យទាំងឡាយយល់ ព្រមហើយ ត្រាស់នឹងពេទ្យសិវកៈថា មកសិវកៈ អ្នកចូរប្រញាប់ខ្វេះភ្នែក ទាំងពីររបស់យើង ហើយដាក់ក្នុងដៃដើម្បីប្រគល់ឲ្យដល់ព្រាហ្មណ៍នេះចុះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

> ម្នាលពេទ្យ ឈ្មោះសិវកៈ អ្នកចូរមក ចូរក្រោកឡើង កុំបង្អង់ ឲ្យយឺតយូរឡើយ កុំញាប់ញ័រ ចូរធ្លៀលភ្នែកទាំងពីរ ( របស់ អញ ) ហើយឲ្យដល់ស្មូម ។ លំដាប់នោះ ពេទ្យសិវកៈនោះ ដែលតថាគតដាស់តឿនហើយ ក៏ធ្វើតាមពាក្យតថាគត បានខ្វេះ ធ្លៀល ( ភ្នែកតថាគត ) ហើយប្រគល់ឲ្យដល់ស្មូម ដូចជាឲ្យ សាច់ត្នោត ។

ក្នុងបទទាំងនោះ បទថា **ឧដ្ឋេហិ** ព្រះមហាសត្វសម្តែងថា ចូរព្យាយាម ចូរធ្វើកិច្ចរបស់សម្លាញ់ ដោយការឲ្យភ្នែករបស់យើងនេះ ។ បទថា **មា ឧទ្ធយិ** ប្រែថា កុំប្រព្រឹត្តយឺតយូរ ព្រោះខណៈនៃទានដ៏ឧត្តមនេះ រកបានដោយក្រ ក្រៃលែង យើងប្រាថ្នាមកយូរហើយ យើងបានហើយ អធិប្បាយថា ខណៈ របស់ទាននោះ កុំភ្លាំងភ្លាត់ឡើយ ។ បទថា **មា បវេធយិ** សេចក្តីថា កុំ

ញាប់ញ័រ គឺកុំញាប់ញ័រដោយការតក់ស្លុតនៃចិត្តថា អញនឹងខ្វេះព្រះនេត្រ របស់ព្រះរាជានៃអញ កុំដល់នូវការរន្ធត់ក្នុងរាងកាយ ( ឈឺបន្ទោបង់បស្សាវៈ-ឧច្ចារៈ ) ។ បទថា **ឧភោបិ ឧយនំ** បានដល់ ភ្នែកទាំងសងខាង ។ បទថា **វធិត្វោកោ** បានដល់ ស្តូម ។ បទថា **មយ្ហំ** បានដល់ ដែលយើង ។ បទថា **ឧទ្ធរិត្វាន ទានាសិ** បានដល់ ពេទ្យនោះ ខ្វេះភ្នែកទាំងពីរ អំពីប្រឡង់ភ្នែក របស់ព្រះរាជា ហើយដាក់លើព្រះហស្ថរបស់ព្រះរាជា ។

ម្យ៉ាងទៀត ពេទ្យនោះ កាលឲ្យ មិនបានខ្វេះដោយកាំបិត កាត់ឲ្យ ព្រោះគិតថា គ្រូពេទ្យជំនាញដូចអញ មិនគួរប្រើកាំបិតកាត់ក្នុងព្រះនេត្រ របស់ព្រះរាជា ទើបបុកភេសជ្ជៈ យកលម្អិតភេសជ្ជៈ ផ្សំនឹងកេសរឈូក ហើយរោយត្រង់ព្រះនេត្រខាងស្តាំ ព្រះនេត្រក៏លៀនចេញមក កើតនូវទុក្ខ-វេទនា ពេទ្យផ្សំថ្នាំហើយរោយម្តងទៀត ព្រះនេត្រក៏ផុតអំពីប្រឡង់ភ្នែក វេទនាក៏កើតខ្លាំងក្លា លើកទី ៣ ពេទ្យផ្សំភេសជ្ជៈឲ្យខ្លាំងជាងមុន រោយចូលទៅ ព្រះនេត្រក៏រមៀលចេញអំពីប្រឡង់ភ្នែកដោយកម្លាំងភេសជ្ជៈ តែនៅជាប់ដោយសរសៃ វេទនាក៏កើតក្រៃលែងឡើង លោហិតក៏ហូរ សូម្បីព្រះ ភូសារបស់ទ្រង់ ក៏ជោកដោយព្រះលោហិត ពួកស្នំ ពួកអមាត្យ ក្រាប ចុះទៀបបាទារបស់ព្រះរាជា យំកន្ទក់កន្ទេញថា បពិត្រ ព្រះសម្មតិទេព សូមទ្រង់កុំព្រះរាជទានព្រះនេត្រទាំងទ្វេឡើយ កុំព្រះរាជទានព្រះនេត្រទាំង ទ្វេឡើយ ។

ព្រះរាជាទ្រង់អត់សង្កត់នូវវេទនាហើយត្រាស់ថា កុំយឺតយូរឡើយបា ។

គ្រូទេព្យទូលស្នងហើយ ចាប់ព្រះនេត្រដោយដៃឆ្វេង ចាប់សស្ត្រាដោយដៃស្តាំ កាត់សរសៃព្រះនេត្រហើយ ដាក់ព្រះនេត្រលើព្រះហស្តរបស់ព្រះមហាសត្វ ។ ព្រះមហាសត្វទ្រង់ទតព្រះនេត្រខាងស្តាំ ដោយព្រះនេត្រខាងឆ្វេង សោយទុក្ខវេទនា ទ្រង់សង្កត់ទុក្ខដោយបីតិក្នុងការបរិច្ចាគ ត្រាស់ហៅព្រាហ្មណ៍ថា នែព្រាហ្មណ៍ ចូរមកចុះ ហើយត្រាស់បន្តថា សមន្តចក្ខុរបស់យើង ជាទីស្រឡាញ់ជាងភ្នែកនេះរាប់រយ រាប់ពាន់ដង រាប់សែនដង ការឲ្យនូវភ្នែករបស់យើងនេះ សូមជាបច្ច័យនៃសមន្តចក្ខុនោះចុះ ហើយបានព្រះរាជទានព្រះនេត្រដល់ព្រាហ្មណ៍ ព្រាហ្មណ៍ចាប់ព្រះនេត្រនោះដាក់ត្រង់ភ្នែករបស់ខ្លួន ព្រះនេត្រនោះ ប្រាកដដូចផ្កាឧប្បលរីក ដោយអានុភាពនៃព្រាហ្មណ៍កាឡាខ្លួននោះ ។ ព្រះមហាសត្វទ្រង់ឃើញព្រះនេត្ររបស់ព្រាហ្មណ៍ដោយព្រះនេត្រខាងឆ្វេង មានព្រះវរកាយជ្រួតជ្រាបដោយបីតិ ផុសឡើងខាងក្នុង ជាលំដាប់ថា ឱអញឲ្យភ្នែកល្អហើយ បានព្រះរាជទានម្ខាងទៀត ។ សក្កទេវរាជក៏ធ្វើដូចមុន ទ្រង់ចេញអំពីព្រះរាជនិវេសន៍ កាលមហាជនកំពុងមើលនោះឯង ទ្រង់ចេញអំពីព្រះនគរ ត្រឡប់ទៅកាន់ទេវលោក ។

មិនយូរប៉ុន្មាន ព្រះនេត្ររបស់ព្រះរាជាមិនដល់នូវភាពជារណ្តៅ មានដុំព្រះមំសៈដុះឡើងពេញដូចកូនឃ្លី ស្បែកស្រោបដោយសំពត់កម្ពលដូច្នោះ ដុះឡើងពេញដូចរូបចិត្តកម្ម វេទនាទាំងឡាយក៏អស់ទៅ ។ លំដាប់នោះ ព្រះមហាសត្វប្រថាប់នៅក្នុងប្រាសាទ ២-៣ ថ្ងៃ ទ្រង់ព្រះតម្រិះថា មនុស្សខ្វាក់គប់គ្រងរាជសម្បត្តិធ្វើអ្វី អញនឹងប្រគល់រាជសម្បត្តិឲ្យដល់អមាត្យទាំង

ឡាយ ហើយនឹងទៅកាន់ព្រះរាជឧទ្យាន បួសបំពេញសមណធម៌ ហើយទ្រង់ប្រាប់សេចក្ដីនោះដល់ពួកអមាត្យ ត្រាស់ថា រាជបុរសម្នាក់ ធ្វើកិច្ចឲ្យទឹកលុបមុខជាដើម ចូរនៅជាមួយយើង ។ យើងនឹងធ្វើសរីរកិច្ចក្នុងទីនេះឯង ចូរពួកអ្នកចងខ្សែសម្រាប់យើង ហើយទ្រង់ឡើងលើគ្រែស្នែង ប្រថាប់គង់លើរាជបល្ល័ង្ក ក្បែរមាត់ស្រះបោក្ខរណី ។ ចំណែកពួកអមាត្យថ្វាយបង្គំហើយ ក៏នាំគ្នាត្រឡប់ ។ ព្រះពោធិសត្វទ្រង់រឭកដល់ទានរបស់ព្រះអង្គ ក្នុងខណៈនោះ អាសនៈរបស់សក្កៈសម្ដែងអាការក្ដៅ ។ សក្កៈទ្រង់ឃើញដូច្នោះ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យពរដល់មហារាជ ហើយធ្វើព្រះនេត្រឲ្យដូចប្រក្រតីវិញ ទើបចូលទៅរកព្រះពោធិសត្វ ទ្រង់ធ្វើនូវសូរជើង ព្រះមហាសត្វត្រាស់សួរថា នុ៎ះនរណា សក្កទេវរាជត្រាស់ថា

ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មកក្នុងសម្នាក់ព្រះអង្គ
បពិត្រស្ដេចឥសី ព្រះអង្គប្រាថ្នាក្នុងព្រះហឫទ័យ ចំពោះពរណា
មួយ សូមត្រេកអរនឹងពរនោះចុះ ដូច្នេះ ។

កាលព្រះមហាសត្វត្រាស់ថា

បពិត្រសក្កៈ ទ្រព្យ និងពលរបស់ខ្ញុំ មានច្រើនហើយ ទាំងឃ្លាំង
របស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់ ក្នុងកាលឥឡូវ
នេះ ខ្ញុំពេញចិត្តចំពោះសេចក្ដីស្លាប់តែម្យ៉ាង ដូច្នេះ ។

លំដាប់នោះ សក្កទេវរាជក៏ត្រាស់នឹងមហាសត្វថា បពិត្រព្រះបាទសិវិរាជ ទ្រង់ពេញចិត្តនឹងការស្លាប់ ព្រោះចង់ស្លាប់ ឬព្រោះភ្នែកខ្វាក់ ។

ព្រះមហាសត្វត្រាស់ថា ព្រោះភ្នែកខ្វាក់ ។ សក្កទេវរាជត្រាស់ថា បពិត្រមហារាជ ទានមិនមែនឲ្យផលដើម្បីភពខាងមុខតែម្យ៉ាងប៉ុណ្ណោះទេ គង់ជាបច្ច័យដើម្បីផលក្នុងបច្ចុប្បន្នផងដែរ ព្រោះហេតុនោះ សូមទ្រង់តាំងសច្ចាធិដ្ឋានអាស្រ័យបុណ្យនៃទានរបស់ទ្រង់ចុះ ដោយកម្លាំងនៃសច្ចាធិដ្ឋាននោះឯង ភ្នែករបស់ទ្រង់នឹងកើតឡើងដូចមុន ។ ព្រះមហាសត្វត្រាស់ថា បើដូច្នោះមហាទានខ្ញុំឲ្យល្អហើយ កាលទ្រង់ធ្វើសច្ចាធិដ្ឋាន ទើបត្រាស់ថា

ពួកស្មូមណា មានគោត្រផ្សេងៗ គ្នា មកដើម្បីសូមចំពោះយើង
បណ្ដាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះ ជាទីស្រឡាញ់
នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើង ដោយការ
ពោលនូវពាក្យសច្ចៈនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ពួកស្មូមណា ... ចំពោះយើង សេចក្ដីថា បុគ្គលណាមកដើម្បីសូមនឹងយើង បុគ្គលដែលមកទាំងនោះ បុគ្គលណាហាមាត់នឹងយើងថា សូមទ្រង់ព្រះរាជទានវត្ថុនេះចុះ បុគ្គលនោះ ក៏ជាទីស្រឡាញ់របស់ខ្ញុំ ។ ពាក្យថា ដោយការពោលនូវពាក្យសច្ចៈនេះ សេចក្ដីថា បើអ្នកសូមទាំងអស់ជាទីស្រឡាញ់របស់ខ្ញុំ ពាក្យដែលខ្ញុំពោលនោះ ជាពាក្យពិត ដោយសច្ចវាចារបស់ខ្ញុំនេះ សូមភ្នែកម្ខាងកើតឡើងដូចដើមចុះ ។

រំពេចនោះ ព្រះនេត្រម្ខាងកើតឡើងព្រមនឹងព្រះតម្រាស់របស់ព្រះមហាសត្វ ។ បន្ទាប់ពីនោះ ដើម្បីឲ្យព្រះនេត្រទីពីរកើតឡើង ព្រះមហាសត្វក៏ត្រាស់ថា

ព្រាហ្មណ៍នោះ មកដើម្បីសូមនូវភ្នែកណា នឹងយើងថា សូមព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ ដល់ព្រាហ្មណ៍ដែលសូមនោះហើយ ។ បីតិ និងសោមនស្សដ៏ច្រើន ក៏កើតឡើងដល់យើង ដោយក្រៃលែង សូមឲ្យភ្នែកជាគម្រប់ពីរកើតមានដល់យើង ដោយពោលពាក្យសច្ចៈនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **យំ មំ** ( នូវភ្នែកណានឹងយើង ) កែជា **យោ មំ**។ ពាក្យថា នោះ បានដល់ ព្រាហ្មណ៍ដែលសូមភ្នែកនោះ ។ ពាក្យថា មក បានដល់ មកហើយ ។ ពាក្យថា ដែលសូម បានដល់ អ្នកសូម ។ ពាក្យថា កើតឡើងដល់យើង បានដល់ បីតិដ៏លើសលុប បានចូលទៅដល់យើងដែលឲ្យភ្នែកដល់ព្រាហ្មណ៍ ហើយមិនបានគិតដល់វេទនាបែបនោះ ក្នុងពេលភ្នែកខ្វាក់ហើយ ពិចារណាថា ឱ ! ទាន អញឲ្យល្អហើយ ។ ពាក្យថា សោមនស្សដ៏ច្រើន បានដល់ សោមនស្សមិនមានប្រមាណកើតឡើងហើយ ។ ពាក្យថា ដោយពោលពាក្យសច្ចៈនេះ សេចក្តីថា បើក្នុងគ្រានោះ បីតិ និងសោមនស្សមិនតិច កើតឡើងដល់យើង ពាក្យដែលយើងពោលនោះ ជាការពិត ដោយសច្ចវាចានេះ សូមភ្នែកទីពីរ កើតឡើងដល់យើងចុះ ។

រំពេចនោះឯង ភ្នែកទីពីរកើតឡើង តែព្រះនេត្រទាំងពីររបស់ព្រះពោធិសត្វនោះ មិនដូចដើមឡើយ មិនមែនជារបស់ទិព្វ ។ ព្រោះមិនអាចធ្វើភ្នែក ដែលឲ្យដល់សក្កព្រាហ្មណ៍ ដូចមុនបានវិញ ។ម្យ៉ាងទៀត ទិព្វចក្ខុ រមែងមិនកើតដល់បុគ្គលដែលមានភ្នែកបែកធ្លាយហើយ ។ ភ្នែកកើតដោយ

អំណាចនៃបីតិ ជ្រួតជ្រាបអាស្រ័យបីតិ ក្នុងទានរបស់ខ្លួននៃព្រះពោធិសត្វនោះ មិនវិបរិតក្នុងខាងដើម ក្នុងកណ្តាល និងខាងចុង តាមន័យដូចពោលហើយ លោកហៅថា **សច្ចវារមិតាចក្ខុ** គឺភ្នែកអាស្រ័យសច្ចបារមី ។ សមដូចព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលមុនឲ្យក្តី កំពុងឲ្យក្តី ឲ្យរួចហើយក្តី ចិត្តរបស់តថាគត
ឥតមានការរាយមាយឡើយ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង
ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧឧមានស្ស** បានដល់ ឲ្យគ្រូពេទ្យខ្វេះដើម្បីឲ្យទានភ្នែក ។ បទថា **ធេន្តស្ស** បានដល់ ដាក់ភ្នែកដែលខ្វេះហើយ លើដៃសក្កព្រាហ្មណ៍ ។ បទថា **ទិន្នធានស្ស** បានដល់ ឲ្យភ្នែកជាទានហើយ ។ បទថា **ចិត្តស្ស អញ្ញថា** បានដល់ អធ្យាស្រ័យក្នុងការឲ្យ មិនប្រែប្រួលដទៃ ។ បទថា **ពោធិយាយេវ ការណា** បានដល់ ចក្ខុទាននោះ ជាហេតុនៃព្រះសព្វញ្ញុតញ្ញាណនោះឯង ។

តថាគតធ្វើវត្ថុដែលធ្វើបានដោយក្រយ៉ាងនេះ ព្រោះព្រះសព្វញ្ញុតញ្ញាណរកបានលំបាក កាលទ្រង់សម្តែងថា ព្រោះតថាគតមិនស្រឡាញ់ក្នុងភ្នែកក៏មិនមែន មិនស្រឡាញ់ក្នុងអត្តភាពក៏មិនមែន ទើបត្រាស់គាថាចុងក្រោយថា **ឧ មេ ធេស្សា** ជាដើម ។

ក្នុងបទទាំងនោះ **ឧ** អក្ខរៈដែលជាអក្ខរៈដំបូងក្នុងបទថា **អត្តា ឧ មេ ឧ ធេស្សិយោ** ត្រឹមតែជានិបាត អធិប្បាយថា ខ្លួនតថាគត ក៏មិនក្រោធ

មិនជាទីស្រឡាញ់ក៏មិនមែន ។ បាឋៈថា **អត្តានំ មេ ន ទេស្សិយំ** ក៏មាន ពាក្យនោះ មានសេចក្តីថា តថាគតមិនស្អប់ មិនក្រោធ មិនគួរនឹងក្រោធខ្លួន របស់តថាគត គឺខ្លួននោះ តថាគតមិនគួរស្អប់ខ្ពើម ។ អាចារ្យពួកខ្លះពោលថា **អត្តាបិ មេ ន ទេស្សិយោ** ( សេចក្តីក៏យ៉ាងនោះដូចគ្នា ) ។ បទថា **អធាសយាំ** កាត់បទជា **អធាសី អហំ** ។ បាឋៈថា **អធាសិហំ** ដូច្នេះក៏មាន ។

ក្នុងកាលនោះ កាលព្រះនេត្រកើតឡើងដោយសច្ចាធិដ្ឋានរបស់ព្រះ ពោធិសត្វហើយ ពួករាជបរិស័ទទាំងអស់ បានប្រជុំគ្នាដោយអានុភាពរបស់ សក្កៈ លំដាប់នោះ សក្កទេវរាជប្រថាប់ឈរលើអាកាស កណ្តាលមហាជន សរសើរព្រះពោធិសត្វដោយគាថាទាំងឡាយថា

បពិត្រក្សត្រិយ៍ អ្នកញុំាំងដែនរបស់អ្នកដែនសីវិឲ្យចម្រើន គាថា ដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីររបស់ ព្រះអង្គនេះ ប្រាកដដូចជាទិព្វ ។ ព្រះនេត្រទាំងពីររបស់ព្រះអង្គ នោះ សូមឲ្យបាននូវការឃើញធ្លុះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ដូច្នេះ ។ ពោលហើយ ទ្រង់ក៏យាងត្រឡប់ទៅកាន់ទេវលោក ។

ព្រះពោធិសត្វ ចោមរោមដោយមហាជន យាងចូលទៅកាន់ព្រះនគរ ដោយសក្ការៈធំ កាលត្រៀមទ្វារព្រះរាជមន្ទីរស្រេចបាច់ហើយ ប្រថាប់គង់លើ រាជបល្ល័ង្ក ខាងក្រោមស្វេតច្ឆត្រដែលគេលើកឡើងក្នុងមហាមណ្ឌប កាល ទ្រង់សម្តែងធម៌ដល់អ្នកនគរ អ្នកជនបទ និងរាជបរិស័ទដែលជាអ្នកត្រេកអរ

ដោយការបានព្រះនេត្រមកវិញ នាំគ្នាមកដើម្បីចូលគាល់ ទើបត្រាស់គាថាទាំងនេះថា

អ្នកណាមួយ ក្នុងលោកនេះ ដែលគេសូម ហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្ត ឬទ្រព្យដ៏ថ្លៃថ្លា ជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ខ្លួន នៃអ្នកដែនសីវិទាំងអស់ ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើលនូវភ្នែកទាំងពីររបស់អញដែលជាទិព្វ ក្នុងថ្ងៃនេះចុះ ។ ចក្ខុទាំងពីររបស់យើង រមែងបាននូវការឃើញធ្លុះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។ ( វត្ថុណាមួយ ) ក្នុងជីវិតរបស់សត្វទាំងឡាយនេះ រមែងមិនប្រសើរជាងចាគៈទេ ( ខ្លួនយើង ) បានឲ្យនូវចក្ខុជារបស់មនុស្ស ហើយបាននូវចក្ខុទិព្វ ដែលមិនមែនជារបស់មនុស្ស ។ ម្នាលអ្នកដែនសីវិទាំងឡាយ អ្នកទាំងឡាយ បានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយ បរិភោគហើយ តាមសមគួរដល់អានុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ស្ថានសួគ៌ចុះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ព្រះអង្គពោលតាមធម៌ បានដល់ បពិត្រមហារាជ ទ្រង់ត្រាស់គាថាទាំងនេះដោយធម៌ ដោយភាពជារបស់ពិតនោះឯង ។ ពាក្យថា ដូចជាទិព្វ បានដល់ ប្រកបដោយអានុភាពដែលជារបស់ទិព្វ ។ ពាក្យថា **បដិធិស្សរេ** ( ប្រាកដ ) កែជា **បដិធិសន្តិ** ។ ពាក្យថា

ខាងក្រោជញ្ជាំង បានដល់ ក្រោជញ្ជាំង ។ ពាក្យថា ខាងក្រោក្អំថ្ម បានដល់ ខាងក្រោថ្ម ។ ពាក្យថា **សមតិគ្គយ្ហ** ស្មើគ្នានឹង **អតិក្កមិត្វា** ( ផ្ទុះធ្លាយ ) ។ ពាក្យថា ដោយជុំវិញ បានដល់ ចូរឲ្យផល គឺសម្រេចការឃើញរូបទូទៅ ១០ ទិស ប្រមាណ ១០០ យោជន៍ ដល់ទ្រង់ចុះ ។

ពាក្យថា **កោ ឌីធ** កាត់បទជា **កោ នុ ឥធ** ( អ្នកណាមួយក្នុងលោកនេះ ) ។ ពាក្យថា ដ៏ថ្លៃថ្លា បានដល់ ជារបស់ល្អបំផុត ។ ពាក្យថា មិនប្រសើរជាងចាគៈទេ បានដល់ មិនមានរបស់ដទៃ ឈ្មោះថា ប្រសើរជាងការបរិច្ចាគ ។ ពាក្យថា **ឥធ ជីវិតេ** ( ក្នុងជីវិតរបស់សត្វទាំងឡាយនេះ ) បានដល់ ក្នុងជីវលោកនេះ ។ បាលីថា **ឥធ ជីវតំ** ដូច្នេះក៏មាន ។ សេចក្តីថា រស់នៅក្នុងលោកនេះ ។ ពាក្យថា មិនមែនជារបស់មនុស្ស បានដល់ បានទិព្វចក្ខុ ដោយហេតុនេះ ទើបគួរពោលបានថា មិនមានវត្ថុ ឈ្មោះថា ឧត្តមជាងការបរិច្ចាគ ។ ពាក្យថា បានឃើញហេតុនេះ បានដល់ ឃើញទិព្វចក្ខុដែលយើងបាននេះហើយ ។

ព្រះពោធិសត្វមិនបានសម្តែងដោយគាថាទាំង ៤ គាថានេះ ក្នុងខណៈនោះប៉ុណ្ណោះ ដែលពិត ព្រះពោធិសត្វទ្រង់ប្រជុំមហាជនក្នុងថ្ងៃឧបោសថ ទ្រង់សម្តែងធម៌រៀងរាល់កន្លះខែ ដោយប្រការដូច្នេះ ។ មហាជនបានស្តាប់ព្រះធម៌នោះហើយ ធ្វើបុណ្យមានទានជាដើម ហើយក៏បានទៅកើតក្នុងទេវលោក ។

គ្រូពេទ្យក្នុងកាលនោះ បានមកជាអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធត្ថេរ ក្នុងកាលឥឡូវនេះ បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ព្រះបាទសិវិរាជក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងសិវិរាជចរិយានេះ របស់ព្រះពោធិសត្វនោះ គប្បីពោលចំពោះដល់បារមីទាំងឡាយតាមសមគួរ ដោយន័យដូចពោលហើយនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបគុណានុភាពរបស់ព្រះមហាសត្វមានជាដើមយ៉ាងនេះ គឺ រាល់ៗ ថ្ងៃ វត្ថុដែលជាទេយ្យធម៌ខាងក្រៅ ដែលមិនធ្លាប់ព្រះរាជទាន មិនមាន យ៉ាងណា កាលព្រះពោធិសត្វទ្រង់បរិច្ចាគមហាទានដែលរាប់មិនអស់ក៏យ៉ាងនោះ ទ្រង់មិនត្រេកអរដោយមហាទាននោះ ទ្រង់ព្រះតម្រិះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញគប្បីបរិច្ចាគទាន ដែលជាវត្ថុខាងក្នុងបាន កាលណាហ្ន៎ គប្បីមានបុគ្គលណាមួយមករកអាត្មាអញ ហើយសូមទេយ្យធម៌ ដែលជាវត្ថុខាងក្នុង បើមានបុគ្គលសូមរបស់ណាមួយ គប្បីសូមសាច់ហទយៈរបស់អញ អញនឹងនាំសាច់ហទយៈនោះ ចេញមកដោយលំពែង ហើយនាំហទយៈដែលមានតំណក់ឈាមហូរ ដូចលើកផ្កាឈូក មួយអន្ទើដោយទងអំពីទឹកថ្លា ហើយឲ្យ បើសូមសាច់ក្នុងរាងកាយ យើងនឹងវះសាច់ក្នុងរាងកាយ ដូចគេគាបទឹកអំពៅ ត្ដិះគ្រាប់ត្នោតដោយការធូតចេញហើយ នឹងឲ្យ បើគប្បីសូមឈាម អញនឹងយកជាវចាក់ ឬរត់ចូលទៅក្នុងមាត់នៃគន្ទឹះយន្ត នាំយកភាជនៈចូលទៅត្រងឲ្យពេញ ហើយនឹងឲ្យឈាម ម្យ៉ាងទៀត បើបុគ្គល

*ណាមួយគប្បីពោលថា ក្នុងផ្ទះរបស់ខ្ញុំ ការងារមិនទាន់រៀបរយ សូមទ្រង់បម្រើខ្ញុំក្នុងផ្ទះនោះចុះ អញនឹងដោះគ្រឿងទ្រទ្រង់របស់ព្រះរាជាចេញ ប្រគល់ខ្លួនដល់បុរសនោះ ហើយនឹងធ្វើជាអ្នកបម្រើ ។ បើបុគ្គលណា សូមភ្នែកនឹងអញ អញនឹងខ្វេះភ្នែកឲ្យ ដូចក្តិះនូវគ្រាប់ត្នោតចេញអំពីប្រឡង់ ហើយឲ្យដល់បុគ្គលនោះ ។ ព្រះមហាសត្វទ្រង់ដល់នូវភាពជាអ្នកជំនាញ ដែលមិនទូទៅដល់អ្នកដទៃយ៉ាងនេះ ទ្រង់កើតនូវបរិវិតក្ក ទូលំទូលាយជាពិសេស ។ ការបាននូវអ្នកសូមភ្នែកហើយ ទោះបីអមាត្យ និងពួកបរិស័ទទូលទាស់ ក៏ទ្រង់មិនស្តាប់ពាក្យរបស់ជនទាំងនោះ ទ្រង់សោយបីតិក្រៃលែង ដោយកិច្ចបដិបត្តិសមគួរដល់បរិវិតក្ករបស់ព្រះអង្គ ទ្រង់តាំងសច្ចាធិដ្ឋានចំពោះព្រះភក្ត្ររបស់សក្កៈ អាស្រ័យកិច្ចបដិបត្តិនោះជាសេចក្តីពិត ព្រោះទ្រង់មានព្រះហឫទ័យផ្អែត ភាពដែលព្រះនេត្ររបស់ព្រះអង្គ ជាប្រក្រតីដោយសច្ចាធិដ្ឋាននោះ និងភាពដែលព្រះនេត្រនោះ មានអានុភាពជារបស់ទិព្វ ដោយប្រការដូច្នេះ ។*

## អដ្ឋកថាសិវិរាជចរិយា ចប់

# សុត្តន្តបិដក

## វេស្សន្តរចរិយាទី ៩

[ ៩ ] ព្រះនាងផុស្សតី ខត្តិយកញ្ញា ជាព្រះជននីរបស់តថាគត ព្រះនាងផុស្សតីនោះ ជាព្រះមហេសីនៃសក្កទេវរាជ ក្នុងអតីតជាតិទាំងឡាយ ។ ព្រះឥន្ទទ្រង់ជ្រាបនូវការអស់ទៅនៃអាយុរបស់ព្រះនាងហើយ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលនាងដ៏ចម្រើន យើងនឹងឲ្យនូវពរ ១០ ប្រការដល់នាង បើនាងប្រាថ្នានូវពរណា ចូរទទួលយកនូវពរនោះចុះ ។ ព្រះនាងទេវីនោះ កាលបើព្រះឥន្ទពោលយ៉ាងនេះហើយ ក៏ពោលពាក្យនេះ តបនឹងព្រះឥន្ទវិញថា ខ្ញុំមានទោសកំហុសដូចម្តេច ខ្ញុំជាទីស្អប់របស់ព្រះអង្គយ៉ាងណាទៅ បានជាព្រះអង្គញុំាងខ្ញុំឲ្យឃ្លាតចាករមណីយដ្ឋាន ដូចជាខ្យល់បក់បោករំលំនូវរុក្ខជាតិ ដែលដុះលើផែនដី ដូច្នោះ ។ សក្កទេវរាជនោះ លុះឮព្រះនាងផុស្សតីពោលយ៉ាងនេះហើយ ក៏ត្រាស់ពាក្យនេះតបនឹងព្រះនាងវិញថា អំពើដ៏លាមកនាងមិនបានធ្វើទេ នាងមិនមែនជាស្អប់នៃយើងទេ ។ អាយុរបស់នាងត្រឹមតែប៉ុណ្ណោះ កាលជាទីច្យុតនឹងមាន ( ដល់នាង ) ចូរនាងទទួលយកពរដ៏ប្រសើរឧត្តម ១០ ប្រការ ដែលយើងឲ្យនេះចុះ ។ ព្រះនាងផុស្សតីនោះ បានទទួលពរដែលសក្កទេវរាជឲ្យហើយ ក៏មានព្រះហឫទ័យត្រេកអររីករាយ ធ្វើតថាគតឲ្យនៅខាងក្នុង ( ពរទាំងនោះ ) ហើយទទួលយកពរទាំង ១០ ប្រការ ។ ព្រះនាងផុស្សតីនោះ លុះច្យុតចាក

ស្ថានទេវលោកនោះហើយ មកកើតក្នុងត្រកូលក្សត្រ ហើយមកកប់ប្រសព្វនឹងសញ្ជយរាជកុមារ ក្នុងជេតុត្តរនគរ ។ កាលណាតថាគតចុះមកកាន់ផ្ទៃនៃនាងផុស្សតី ជារាជមាតាដែលជាទីស្រឡាញ់ក្នុងកាលនោះ ដោយតេជានុភាពរបស់តថាគត មាតានៃតថាគតក៏ត្រេកអរក្នុងទានសព្វៗ កាល ។ ព្រះនាងផុស្សតីនោះ ទ្រង់បរិច្ចាគទាន ដល់ពួកជនអ្នកឥតទ្រព្យ ពួកជនឈឺជានិច្ច ពួកជនចាស់ជរា ពួកយាចក ពួកអ្នកដំណើរ និងពួកសមណព្រាហ្មណ៍ ដែលមានអាសវៈអស់ហើយ មិនមានកិលេសជាគ្រឿងកង្វល់ ។ កាលព្រះនាងផុស្សតីទេវីនោះ ទ្រង់គភ៌គ្រប់ ១០ ខែហើយ ព្រះបាទសញ្ជយមហារាជ ទ្រង់នាំព្រះនាងទៅធ្វើប្រទក្សិណបុរី ព្រះនាងប្រសូតតថាគតត្រង់កណ្តាលថ្នល់នៃអ្នកជំនួញ ។ ឈ្មោះរបស់តថាគត មិនមែនជាប់មកអំពីមាតា មិនមែនជាប់មកអំពីបិតាទេ គឺព្រោះតែតថាគត កើតត្រង់កណ្តាលថ្នល់អ្នកជំនួញ ហេតុនោះបានជាឈ្មោះថាវេស្សន្តរ ។ កាលណាតថាគតជាទារក មានអាយុ ៨ ឆ្នាំ អំពីកំណើត ក្នុងកាលនោះ តថាគតអង្គុយក្នុងប្រាសាទត្រិះរិះដើម្បីឲ្យនូវអជ្ឈត្តិកទានថា បើអ្នកណា មកសូមតថាគត តថាគតគប្បីឲ្យបេះដូង ឲ្យភ្នែក ឲ្យសាច់ និងឈាម ឬក៏គេញ៉ាំងតថាគតឲ្យដឹងឮថា ( អ្នកចូរធ្វើជាទាសៈរបស់ខ្ញុំ ) តថាគតនឹងព្រមប្រគល់កាយ ( ដល់អ្នកនោះ ) ។ កាលតថាគតកំពុងគិត

នូវភាពដែលមិនញាប់ញ័រ ដែលមិនរួញរា មហាប្រឹថពី មានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងទីនោះ ។ តថាគតឡើងជិះដំរីឈ្មោះបច្ច័យ ចូលទៅ ( កាន់សាលាទាន ) ដើម្បីឲ្យទានក្នុងថ្ងៃឧបោសថ ខែពេញបូណ៌មី ទី ១៥ ក្នុងកន្លះខែ ជាលំដាប់ ។ ព្រាហ្មណ៍ទាំងឡាយ ដែលនៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឲ្យបានទ្រព្យ ដែលគេសន្មតជាសត្វមង្គលថា ជនបទ ( របស់យើងខ្ញុំព្រះអង្គ ) មិនមានភ្លៀង ទុរ្ភិក្ស អត់ឃ្លានខ្លាំង សូមព្រះអង្គព្រះរាជទានដំរីប្រសើរ មានអវយវៈសសុទ្ធ ជាដំរីឧត្តម ។ ព្រាហ្មណ៍ទាំងឡាយសូមដំរីណាចំពោះតថាគត តថាគតឲ្យដំរីនោះ ឥតញាប់ញ័រឡើយ តថាគតមិនលាក់លៀម នូវទេយ្យធម៌ដែលមាន ព្រោះចិត្តរបស់តថាគត ត្រេកអរក្នុងទាន ។ កាលបើយាចកមកដល់ហើយ ការប្រកែកក៏មិនសមគួរដល់តថាគត ការសមាទានរបស់តថាគត កុំបីបែកធ្លាយឡើយ ដូច្នេះ តថាគតនឹងឲ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ រួចប្រួចទឹកក្នុងកុណ្ឌី ជាវិការនៃកែវដាក់លើដៃព្រាហ្មណ៍ ហើយឲ្យដំរីដល់ព្រាហ្មណ៍ ។ កាលតថាគតឲ្យដំរីដ៏ឧត្តម សសុទ្ធដទៃទៀត ក្នុងកាលនោះ មហាប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ក៏ញាប់ញ័រ ។ ព្រោះតែការឲ្យនូវដំរីនោះ ជាហេតុឲ្យពួកអ្នកដែនសិវិខឹងខ្លាំង ក៏មកប្រជុំគ្នា

ហើយបណ្តេញតថាគត ចាកដែនរបស់ខ្លួន ដោយពាក្យថា សូមព្រះអង្គទៅនៅវង្កតបព៌តទៅ ។ កាលពួកអ្នកដែនសិវិនោះ បណ្តេញតថាគតឲ្យចេញចាកដែន ចិត្តរបស់តថាគត មិនញាប់ញ័រ មិនតក់ស្លុតទេ តថាគតបានសូមពរមួយដ៏ប្រសើរ នឹងជនទាំងនោះ ដើម្បីញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ។ ពួកអ្នកដែនសិវិទាំងអស់ ដែលតថាគតសូមពរហើយ ក៏ឲ្យនូវពរមួយដ៏ប្រសើរ ដល់តថាគតៗញ៉ាំងគេឲ្យដឹងឮដោយស្គរមានត្រចៀក ហើយឲ្យមហាទាន ។ គ្រានោះ សំឡេងកោលាហល ដែលនាំឲ្យភ័យធំ ក៏ប្រព្រឹត្តទៅក្នុងរោងទានទុំះថា ( ពួកអ្នកដែនសិវិ ) បណ្តេញព្រះបាទវេស្សន្តរនេះ ព្រោះតែទាន ឥឡូវព្រះ បាទវេស្សន្តរនេះ នៅតែឲ្យទានទៀត ។ កាលនោះ តថាគតឲ្យដំរី សេះ រថ ខ្ញុំស្រី ខ្ញុំប្រុស មេគោ និងទ្រព្យ លុះឲ្យមហាទានហើយ ក៏ចេញអំពីនគរ ។ លុះតថាគតចេញចាកនគរហើយ ក៏ងាកមើលទៅព្រះនគរវិញ កាលនោះ មហាប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ តថាគតឲ្យនូវរថដែលទឹមដោយសេះសិន្ធព ៤ ហើយស្ថិតនៅក្នុងផ្លូវធំ ៤ ជាបុគ្គលតែម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរ និយាយនូវពាក្យនេះនឹងនាងមទ្រីទេវីថា ម្នាលនាងមទ្រី នាងចូរ-ពកណ្ហាជិនាចុះ ព្រោះកណ្ហាជិនាជាប្អូននេះ ស្រាល បងនឹង-ពជាលីកុមារ ព្រោះជាលីកុមារជាបង ធ្ងន់ ។ នាងមទ្រីទេវីពកណ្ហាជិនាដូចជាផ្កាឈូក-ស

តថាគតពាក្យត្រជាលីដូចជារូបភាព ជាវិការនៃមាស ។ ខត្តិយជន ទាំង ៤ អង្គ ធ្លាប់ចម្រើនដោយសេចក្តីសុខ មានជាតិខ្ពង់ខ្ពស់ កាលស្តេចទៅក្នុងផ្លូវមិនរាបស្មើខ្វះ រាបស្មើខ្វះ ( ដោយគិតថា ) យើងនឹងទៅកាន់វង្កតបព៌ត ។ បើមនុស្សណាមួយ ដើរមកក្នុងផ្លូវ បណ្តោយគ្នា ឬផ្លូវជួបគ្នា យើងនឹងសាកសួរផ្លូវនឹងមនុស្សទាំងនោះ ថា វង្កតបព៌ត នៅក្នុងទីណា ។ មនុស្សទាំងនោះ ឃើញយើងក្នុង ទីនោះនឹងប្រាប់ ( នូវផ្លូវដែលទៅ ) កាន់ភ្នំ ដោយសេចក្តីករុណា មនុស្សទាំងនោះ ដឹងនូវទុក្ខ ( របស់យើងនឹងប្រាប់ថា ) វង្កតបព៌ត នៅក្នុងទីឆ្ងាយអំពីទីនេះ ។ បើទារកទាំងពីរ ឃើញឈើមានផ្លែក្នុង ព្រៃធំ ព្រោះហេតុនៃផ្លែឈើទាំងនោះ ទារកទាំងពីរនឹងយំទារ ។ ដើមឈើធំខ្ពស់ទាំងឡាយ ព្រោះឃើញទារកទាំងពីរយំ ក៏ទោរទន់ ចូលមកជិតទារកដោយខ្លួនឯង ។ នាងមទ្រី មានអវយវៈទាំងអស់ ល្អ ឃើញនូវហេតុគួរអស្ចារ្យ ចម្លែក គួរព្រឺរោម ក៏ញុំាំងសាធុការ ឲ្យប្រព្រឹត្តទៅថា ឱហ្ន៎ ! ហេតុអស្ចារ្យចម្លែក គួរព្រឺរោមកើតឡើង ហើយ ក្នុងលោកនេះ ដោយតេជៈនៃព្រះវេស្សន្តរ ដើមឈើទាំង ឡាយ ក៏ទោរទន់ចុះមកដោយខ្លួនឯង ។ ពួកទេវតាបានបង្រួញផ្លូវ ដោយសេចក្តីអនុគ្រោះចំពោះទារក ញុំាំងជនទាំងនោះ ឲ្យដល់ដែន ចេតៈ ក្នុងថ្ងៃដែលខ្លួនចេញទៅ ។ កាលនោះ ស្តេចទាំងអស់ ៦០០០០ អង្គ ដែលនៅក្នុងមាតុលនគរ ក៏ប្រណម្យអញ្ជលីទួញយំ

ដើរចូលមកជិត ៗ ក្សត្រទាំង ៤ ព្រះអង្គនោះ និយាយចរចាជាមួយនឹងស្តេចចេតៈទាំងឡាយ និងពួកបុត្ររបស់ស្តេចចេតៈក្នុងទីនោះ ហើយលាចេញពីទីនោះទៅថា យើងនឹងទៅកាន់វង្កតបពិត ៗ ព្រះឥន្ទទ្រង់ហៅនូវវិស្សកម្មទេវបុត្រ ដែលមានឫទ្ធិច្រើន មកប្រាប់ថា អ្នកចូរនិម្មិតអាស្រម និងបណ្ណសាលាដ៏ល្អ ជាទីរីករាយថ្វាយព្រះបាទវេស្សន្តរ ព្រមទាំងភរិយា និងបុត្រ ៗ វិស្សកម្មទេវបុត្រដែលមានឫទ្ធិច្រើន លុះបានស្តាប់ពាក្យរបស់សក្កទេវរាជហើយ ក៏ចុះមកនិម្មិតអាស្រម និងបណ្ណសាលាដ៏ល្អ ជាទីរីករាយ ៗ ក្សត្រ ៤ ព្រះអង្គ បានចូលទៅកាន់ព្រៃធំ ដែលមិនមានសំឡេង មិនមានសេចក្តីរីករាវ ហើយ ( និយាយគ្នាថា ) យើងនឹងនៅក្នុងចន្លោះនៃភ្នំនោះ កាលនោះ តថាគត នាងមទ្រីទេវី កូនទាំងពីរ គឺជាលី និងកណ្ហាជិនា បានបន្ទោបង់សេចក្តីសោកដល់គ្នានិងគ្នា ហើយនៅក្នុងអាស្រម កាលនោះ តថាគតរក្សាទារកក្នុងអាស្រម មិនសូន្យស្ងាត់ នាងមទ្រីនោះ តែងនាំផ្លែឈើមកចិញ្ចឹមជនទាំង ៣ នាក់ ៗ កាលតថាគតនៅក្នុងព្រៃធំ មានអ្នកដំណើរម្នាក់ ចូលមករកតថាគតសូមកូនទាំងពីរនៃតថាគត គឺជាលី និងកណ្ហាជិនា ៗ កាលនោះ តថាគតកើតសេចក្តីរីករាយ ព្រោះបានឃើញយាចកដើរចូលមកបានយកកូនទាំងពីរឲ្យដល់ព្រាហ្មណ៍ កាលតថាគតបរិច្ចាគបុត្រទាំងពីររបស់ខ្លួន ដល់ជូជកព្រាហ្មណ៍ កាលនោះ ប្រឹថពីដែល មានភ្នំ

សិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ ព្រះឥន្ទបានក្លែងភេទជាព្រាហ្មណ៍ម្តងទៀត ចុះមកសូមនាងមទ្រីទេវីដែលមានសីលមានវត្តចំពោះប្តី នឹងតថាគត ។ តថាគតមានសេចក្តីត្រិះរិះក្នុងចិត្តដោយជ្រះថ្លា ចាប់នាងមទ្រីទេវីត្រង់ដើមដៃ ហើយប្រោចទឹកដាក់លើអញ្ជលីនៃព្រាហ្មណ៍ ឲ្យនាងមទ្រីដល់ព្រាហ្មណ៍ ។ កាលដែលតថាគតឲ្យនាងមទ្រី ទេវតាឮដ៏អាកាស ក៏ត្រេកអររីករាយ ប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងកាលនោះ ។ កាលតថាគតបរិច្ចាគជាលីកុមារ កណ្ហាជិនាជីតា និងនាងមទ្រីទេវី ដែលមានវត្តចំពោះប្តី ឥតគិតក្តៅក្រហាយសោះឡើយ ក៏ព្រោះហេតុនៃពោធិញ្ញាណតែម្យ៉ាង ។ បុត្រទាំងពីរ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងនាងមទ្រីទេវី ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគតបានជាតថាគតឲ្យបុត្រ និងភរិយាជាទីស្រឡាញ់ ។ កាលពួកជនមកប្រជុំគ្នាក្នុងសម្នាក់នៃមាតា និងបិតា ក្នុងព្រៃធំ ក៏ខ្សឹកខ្សួលដោយសេចក្តីករុណា ចរចា សួរសុខ និងទុក្ខគ្នា ។ កាលមហាជនចូលទៅរកជនទាំងពីរ ជាអ្នកជូនដោយហិរិ និងឱត្តប្បៈ កាលនោះ

ប្រឹថពី ដែលមានក្អំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏កម្រើកញាប់ញ័រ ៗ ម្យ៉ាងទៀត តថាគតចេញអំពីព្រៃធំជាមួយនឹងពួកញាតិ ចូលទៅកាន់បុរី គួរជាទីសប្បាយឈ្មោះជេតុត្តរ ដែលជានគរដ៏ឧត្តម ក្នុងកាលនោះ មហាមេឃ ក៏បង្អុរចុះនូវភ្លៀងជាវិការនៃកែវ ៧ ប្រការ ប្រឹថពី ដែលមានក្អំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏កម្រើក ៗ ប្រឹថពីមិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហាប្រឹថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត ៗ

## វេស្សន្តរចរិយាទី ៩ ចប់

# អដ្ឋកថា

## វេស្សន្តរចរិយា

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេស្សន្តរចរិយាទី ៩ ដូចតទៅនេះ បទថា **មេ** ក្នុងបទថា **យា មេ អហោសិ ជនិកា** ព្រះសាស្តាត្រាស់សំដៅដល់ព្រះអង្គកាលជាព្រះវេស្សន្តរ ដោយហេតុនោះ ទើបត្រាស់ថា **ផុស្សតី នាម ខត្តិយា** ដូច្នេះ ។ សេចក្តីពិត កាលនោះ ព្រះមាតារបស់ព្រះពោធិសត្វជាម្ចាស់ក្សត្រិយ៍ ព្រះនាមផុស្សតី ។ បទថា **សា អតីតាសុ ជាតីសុ** សេចក្តីថា ព្រះនាងក្នុងជាតិដែលកន្លងមកហើយ បន្ទាប់អំពីជាតិនោះ ។ ពិតហើយ បទថា **ជាតីសុ** នេះ ជាពហុវចនៈ ប្រើក្នុងភាពជាឯកវចនៈ ។ គប្បីជ្រាបការភ្ជាប់សេចក្តីថា ព្រះនាងជាមហេសី ជាទីស្រឡាញ់របស់សក្កទេវរាជ ។ម្យ៉ាងទៀត ព្រះនាងបានជាព្រះជននីរបស់តថាគត ក្នុងអត្តភាពចុងក្រោយ ។ ក្នុងជាតិដែលកន្លងហើយនោះ ព្រះនាងមានព្រះនាមថា ផុស្សតី ។ ជាក្សត្រិយានីក្នុងជាតិដែលកន្លងហើយនោះ ។ តថាគតកើតជាវេស្សន្តរ ក្នុងព្រះឧទររបស់ព្រះនាង ក្នុងជាតិណា មុនអំពីជាតិនេះ ព្រះនាងបានជាព្រះមហេសី ជាទីស្រឡាញ់របស់សក្កទេវរាជ ។ គប្បីជ្រាបអនុបុព្វីកថាដូចតទៅ

ក្នុងកប្បទី ៩១ បន្ទាប់អំពីកប្បនេះ ព្រះសាស្តាព្រះនាមវិបស្សី ទ្រង់កើតឡើងក្នុងលោក កាលព្រះសាស្តាព្រះនាមវិបស្សី អាស្រ័យពន្ធុមតីនគរ ប្រថាប់ត្រង់មិគទាយវ័នឈ្មោះខេមៈ ព្រះបាទពន្ធុមរាជ បានព្រះរាជទានខ្លឹមចន្ទន៍មានតម្លៃច្រើន ដែលព្រះរាជាមួយអង្គបញ្ជូនទៅថ្វាយ ដល់បុត្រីច្បង

របស់ព្រះអង្គ ។ ព្រះរាជធីតាបានយកខ្លឹមចន្ទន៍នោះ បុកជាលម្អិត ដាក់ពេញប្រអប់ យាងទៅវិហារ បូជាព្រះសរីរៈរបស់ព្រះសាស្តា ដែលមានពណ៌ដូចមាស ហើយរោយនូវលម្អិតដ៏សេសក្នុងព្រះគន្ធកុដិ ព្រះនាងតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់គប្បីបានជាមាតារបស់ព្រះពុទ្ធ ដូចព្រះអង្គក្នុងអនាគតចុះ ។ កាលព្រះនាងចុតិអំពីមនុស្សលោក ដោយផលនៃការបូជាលម្អិតខ្លឹមចន្ទន៍នោះ មានព្រះសរីរៈដូចអប់ដោយខ្លឹមចន្ទន៍ក្រហម អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក កើតជាអគ្គមហេសីរបស់សក្កទេវរាជក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស កាលព្រះនាងអស់ព្រះជន្ម បុព្វនិមិត្តក៏កើតឡើង សក្កទេវរាជទ្រង់ជ្រាបថា ព្រះនាងនឹងអស់អាយុ កាលអនុគ្រោះ ទើបត្រាស់ថា នៃផុស្សតី យើងនឹងឲ្យពរ ១០ ប្រការដល់នាង ចូរនាងទទួលពរចុះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

ព្រះឥន្ទទ្រង់ជ្រាបនូវការអស់ទៅនៃអាយុ របស់ព្រះនាងហើយ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលនាងដ៏ចម្រើន យើងនឹងឲ្យនូវពរ ១០ ប្រការដល់នាង បើនាងប្រាថ្នានូវពរណា ចូរទទួលយកនូវពរនោះចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វរ** បានដល់ ចូរជ្រើសរើសទទួលនូវពរ ។ បទថា **ភទ្ទេ យទិច្ឆសិ** សក្កទេវរាជត្រាស់ថា ម្នាលនាងផុស្សតីដ៏ចម្រើន នាងប្រាថ្នាពរណាៗ ដែលជាទីស្រឡាញ់របស់នាង ចូរនាងទទួលពរ ១០ ប្រការនោះ ។

បទថា **បុនិនមព្រាំ** បានដល់ ព្រះនាងមិនដឹងថា ខ្លួនត្រូវចុតិជាធម្មតា ទើបទទួលពាក្យជាដើមថា **កឹ នុ មេ អបរាធត្ថិ** ខ្ញុំមានទោសកំហុសដូចម្ដេច ។ ព្រោះនាងជាបុគ្គលប្រមាទ មិនដឹងថាខ្លួនត្រូវអស់អាយុ កាលសក្កៈត្រាស់ថា ចូរនាងទទួលពរ ទើបដឹងថា សក្កទេវរាជទ្រង់ប្រាថ្នាឲ្យអញកើតក្នុងទីណា ទើបពោលយ៉ាងនេះ ។ ក្នុងបទទាំងនោះ បទថា **អបរាធត្ថិ** កាត់បទជា **អបរាធោ អត្ថិ**។ បទថា **កឹ នុ ធេស្សា អហំ វត** សេចក្ដីថា ទ្រង់ស្អប់ខ្ញុំម្ចាស់ព្រោះហេតុអ្វី គឺទ្រង់ស្អប់អស់សេចក្ដីស្រឡាញ់ហើយឬ ។ បទថា **រម្មា ចាវេសិ មំ ឋានា** បានដល់ ទ្រង់នឹងឲ្យខ្ញុំម្ចាស់ឃ្លាតចាកស្ថានដែលគួរជាទីត្រេកអរនេះ ។ បទថា **វាតោវ ធរណីរុហំ** ព្រះនាងទូលសួរសក្កៈថា ព្រះអង្គបំណងឲ្យខ្ញុំម្ចាស់ឃ្លាតចាកលោកនេះ ដូចខ្យល់ខ្លាំងបក់ផ្ដាច់នូវដើមឈើដូច្នោះ ព្រោះហេតុអ្វីហ្ន៎ ។

បទថា **តស្សិធំ** កាត់បទជា **តស្សា ឥធំ** ។ បទថា **ន ចេវ តេ កតំ ចាបំ** បានដល់ អំពើអាក្រក់ណាមួយ នាងមិនបានធ្វើ កំហុសរបស់នាងក៏មិនមាន ។ បទថា **ន ច មេ ត្វំសិ អប្បិយា** សេចក្ដីថា នាងមិនបានជាទីស្រឡាញ់របស់យើងក៏មិនមែន អធិប្បាយថា ជាទីស្អប់ខ្ពើម មិនជាស្រឡាញ់ក៏មិនមែន ។

ឥឡូវនេះ សក្កទេវរាជកាលទ្រង់សម្ដែងដល់បំណងដែលនឹងប្រទានពរ ទើបត្រាស់ថា អាយុរបស់នាងត្រឹមតែប៉ុណ្ណោះ កាលជាទីច្យុតនឹងមាន ( ដល់នាង ) កាលទ្រង់ឲ្យនាងទទួលពរ ទើបត្រាស់ថា ចូរនាងទទួលពរដ៏ប្រសើរ

ដ៏ឧត្តម ១០ ប្រការ ដែលយើងឲ្យនេះចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វរុត្តមេ** បានដល់ ពរដ៏ប្រសើរឧត្តមជាងពរទាំងឡាយ ។ បទថា **ធិន្នវរា** បានដល់ ពរដែលសក្កៈប្រទានហើយ ដោយទ្រង់ឲ្យប្ដេជ្ញាថា អញនឹងឲ្យពរ ។ បទថា **តុដ្ឋហដ្ឋា** សេចក្ដីថា ត្រេកអរដោយការពេញចិត្តក្នុងលាភដែលនាងប្រាថ្នា និងត្រេកអរដោយការត្រេកអរព្រោះឃើញសេចក្ដីប្រាថ្នានោះដល់ទីបំផុត ។ បទថា **បមោទិតា** បានដល់ មានព្រះហឫទ័យត្រេកអរ ដោយបាមោជ្ជដែលមានកម្លាំង ។ បទថា **មមំ អព្ភន្តរំ កត្វា** បានដល់ ទ្រង់ធ្វើខ្ញុំទុកខាងក្នុង គឺក្នុងពរទាំងនោះ ។ បទថា **ទស វរេ វរិ** សេចក្ដីថា ព្រះនាងជ្រាបថា ព្រះនាងនឹងអស់អាយុ សក្កៈឲ្យឱកាសដើម្បីប្រទានពរ ទើបព្រះនាងប្រមើលមើលផ្ទៃជម្ពូទ្វីប ឃើញព្រះរាជនិវេសន៍របស់ព្រះបាទសិវិ សមគួរដល់ខ្លួន ទើបព្រះនាងទទួលពរទាំង ១០ ប្រការនេះ គឺសូមឲ្យបានជាអគ្គមហេសីរបស់ព្រះបាទក្រុងសិវិ ក្នុងដែនសិវិនោះ ១ សូមឲ្យមានព្រះនេត្រខ្មៅ ១ សូមឲ្យមានចិញ្ចើមខ្មៅ ១ សូមឲ្យមានឈ្មោះផុស្សតី ១ សូមឲ្យបានឱរសប្រកបដោយគុណវិសេស ១ សូមកុំឲ្យមានគភ៌ប៉ោងឡើង ១ សូមកុំឲ្យស្ដួនសណ្ដាយ ១ សូមកុំឲ្យសក់ស្កូវ ១ សូមឲ្យមានសម្បុរស្បែកល្អិត ១ សូមឲ្យបានដោះលែងអ្នកទោសដែលត្រូវប្រហារជីវិតបាន ១ ។

កាលព្រះនាងបានទទួលពរ ១០ ប្រការហើយ ចុតិអំពីទេវលោក មកកើតក្នុងគភ៌របស់អគ្គមហេសីរបស់ព្រះបាទមទ្ទរាជ ។ ម្យ៉ាងទៀត កាល

ព្រះនាងប្រសូត មានព្រះសរីរៈដូចអប់ដោយខ្លឹមចន្ទន៍ ដោយហេតុនោះ ក្នុងថ្ងៃថ្វាយព្រះនាម ទើបឲ្យឈ្មោះថា ផុស្សតី ។ ព្រះនាងផុស្សតីមានបរិវារច្រើន កាលព្រះជន្មបាន ១៦ វស្សា មានព្រះរូបឆោមល្អក្រៃលែង ។ កាលនោះ ព្រះបាទសិវិមហារាជក្នុងនគរជេតុត្តរ ទ្រង់នាំព្រះនាងមកដើម្បីអភិសេកជាមួយសញ្ជយកុមារដែលជាព្រះរាជឱរស ត្រាស់ឲ្យលើកស្វេតច្ឆត្រ ស្ថាបនាព្រះនាងផុស្សតីក្នុងតំណែងអគ្គមហេសី ឲ្យជាធំជាងស្ត្រី ១៦០០០ នាក់ ដូចព្រះមានព្រះភាគត្រាស់ថា

> ព្រះនាងផុស្សតីនោះ លុះច្យុតចាកស្ថានទេវលោកនោះហើយ មក
> កើតក្នុងត្រកូលក្សត្រ ហើយមកកប់ប្រសព្វនឹងសញ្ជយរាជកុមារ
> ក្នុងជេតុត្តរនគរ ដូច្នេះ ។

ព្រះនាងផុស្សតីនោះ ជាទីស្រឡាញ់ ជាទីពេញព្រះហឫទ័យរបស់ព្រះបាទសញ្ជ័យ ។ លំដាប់នោះ សក្កទេវរាជទ្រង់ពិចារណាថា ពរដែលយើងឲ្យដល់ព្រះនាងផុស្សតីសម្រេច ៩ ប្រការ ទ្រង់ព្រះតម្រិះថា ពរដែលទាក់ទងដោយព្រះឱរស មិនទាន់សម្រេច អញនឹងឲ្យពរនោះសម្រេចដល់នាង ទ្រង់ឃើញថា ព្រះពោធិសត្វអស់អាយុក្នុងទេវលោកជាន់តាវត្តិង្ស ក្នុងកាលនោះហើយ ទើបយាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ត្រាស់ថា លោកនិរទុក្ខ លោកសមគួរបដិសន្ធិក្នុងគភ៌របស់អគ្គមហេសីរបស់ព្រះបាទសញ្ជ័យដែនសិវិ ក្នុងមនុស្សលោក ទ្រង់ទទួលបដិញ្ញារបស់ព្រះពោធិសត្វ និងទេវបុត្រ ៦ ម៉ឺនពួកដទៃ ដែលបដិបត្តិតាមទេវបញ្ញាស្រេចហើយត្រឡប់ទៅកាន់វិមាន

របស់ព្រះអង្គ ។ ព្រះមហាសត្វកាលចុតិចាកជាន់តាវត្តិង្សនោះហើយ ទ្រង់កើតក្នុងដែនសិវិនោះ ។ សូម្បីទេវបុត្រដ៏សេស ក៏កើតឡើងក្នុងផ្ទះរបស់ពួកអមាត្យ ៦ ម៉ឺន កាលព្រះមហាសត្វនៅក្នុងព្រះឧទរ ព្រះនាងផុស្សតីទេវីត្រាស់ឲ្យសាងរោងទាន ៦ គឺត្រង់ទ្វារនគរ ៤ ត្រង់កណ្តាលនគរ ១ ត្រង់ទ្វារព្រះរាជនិវេសន៍ ១ ព្រះនាងលះទ្រព្យ ៦ សែនរាល់ៗ ថ្ងៃ ព្រះនាងចាញ់ព្រះគភ៌ចង់ឲ្យទាន ។ ព្រះរាជាបានដំណឹងថា ព្រះនាងចាញ់គភ៌ ទើបត្រាស់ឲ្យហៅព្រាហ្មណ៍ដែលជាហោរាមកសួរ ទ្រង់ស្តាប់ពាក្យក្រាបទូលថា បពិត្រមហារាជ សត្វមានបុណ្យច្រើន ត្រេកអរក្នុងទាន កើតក្នុងព្រះឧទររបស់ព្រះទេវី ។ សត្វនោះ មិនឆ្អែតដោយទាន ទ្រង់មានព្រះហឫទ័យត្រេកអរទ្រង់ឲ្យតម្កល់ទានដូចបានពោលហើយ ។ ទ្រង់ឲ្យសមណព្រាហ្មណ៍ មនុស្សចាស់ អ្នកជំងឺ មនុស្សក្រីក្រ អ្នកដំណើរ វនិព្វក និងយាចកទាំងឡាយឆ្អែតស្កប់ស្កល់ ។ តាំងអំពីព្រះពោធិសត្វបដិសន្ធិ សេចក្តីចម្រើនរបស់ព្រះរាជាប្រមាណមិនបាន ។ ដោយបុញ្ញានុភាពរបស់ព្រះពោធិសត្វនោះ ព្រះរាជាពេញជម្ពូទ្វីប បញ្ជូនបណ្ណាការទៅថ្វាយ ដូចព្រះមានព្រះភាគត្រាស់ថា

កាលណា តថាគតចុះមកកាន់ផ្ទៃនៃនាងផុស្សតី ជារាជមាតាដែលជាទីស្រឡាញ់ ក្នុងកាលនោះ ដោយតេជានុភាពរបស់តថាគត មាតានៃតថាគត ក៏ត្រេកអរក្នុងទានសព្វៗ កាល ។ ព្រះនាងផុស្សតីនោះ ទ្រង់បរិច្ចាគទានដល់ពួកជនអ្នកឥតទ្រព្យ ពួកជនឈឺជានិច្ច ពួកជនចាស់ជរា ពួកយាចក ពួកអ្នកដំណើរ និងពួក

សមណព្រាហ្មណ៍ ដែលមានអាសវៈអស់ហើយ មិនមាន
កិលេសជាគ្រឿងកង្វល់ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មម តេជេន** បានដល់ ដោយអានុភាពនៃអធ្យាស្រ័យក្នុងការឲ្យរបស់តថាគត ។ បទថា **ខីណោ** បានដល់ បុគ្គលដែលអស់ភោគៈជាដើម គឺដល់សេចក្ដីវិនាស ។ បទថា **អកិញ្ចនេ** បានដល់ មិនមានអ្វីប្រកាន់ឡើយ ។ គ្រប់បទ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃវិស័យ គឺជាអារម្មណ៍ ព្រោះថា បុគ្គលមិនមានទ្រព្យជាដើម ជាអារម្មណ៍នៃការបរិច្ចាគទេយ្យធម៌ ។

ព្រះទេវីទ្រង់ទទួលការបរិហារព្រះគភ៌យ៉ាងច្រើន កាលគ្រប់ ១០ ខែ មានបំណងនឹងទតព្រះនគរ ទើបក្រាបទូលព្រះរាជស្វាមី ។ ព្រះរាជាត្រាស់ឲ្យតាក់តែងព្រះនគរ ដូចទេវនគរ អញ្ជើញព្រះទេវីឡើងរថដ៏ប្រសើរ ហើយឲ្យធ្វើប្រទក្សិណព្រះនគរ ។ កាលព្រះនាងយាងដល់កណ្ដាលវិថីនៃពួកឈ្មួញខ្យល់កម្មជវាត បានបក់ឡើងហើយ ។ ពួកអមាត្យក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់ឲ្យសាងផ្ទះប្រសូតដល់ព្រះនាង ត្រង់វិថីរបស់ពួកឈ្មួញនោះឯង ហើយទ្រង់ឲ្យធ្វើការរក្សា ។ ព្រះនាងប្រសូតព្រះឱរសក្នុងទីនោះឯង ដូចព្រះមានព្រះភាគត្រាស់ថា

កាលព្រះនាងផុស្សតីទេវីនោះ ទ្រង់គភ៌គ្រប់ ១០ ខែហើយ ព្រះ
បាទសញ្ជយមហារាជ ទ្រង់នាំព្រះនាងទៅធ្វើប្រទក្សិណបុរី ព្រះ
នាងប្រសូតតថាគត ត្រង់កណ្ដាលថ្នល់នៃអ្នកជំនួញ ។ ឈ្មោះ

របស់តថាគត មិនមែនជាប់មកអំពីមាតា មិនមែនជាប់មកអំពីបិតាទេ គឺព្រោះតែតថាគត កើតត្រង់កណ្តាលថ្នល់អ្នកជំនួញ ហេតុនោះ បានជាឈ្មោះថា វេស្សន្តរ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ករោន្តេ បុរំ បទក្ខិណំ** សេចក្តីថា កាលព្រះបាទសញ្ជយមហារាជ ទ្រង់នាំព្រះទេវីធ្វើប្រទក្សិណព្រះនគរ ។ បទថា **វេស្សានំ** បានដល់ ពួកឈ្មួញ ។

បទថា **ន មត្តិកំ នាមំ** បានដល់ ឈ្មោះរបស់តថាគត មិនទាក់ទងដោយជីដូនជីតា ដែលមកខាងមាតា ។ បទថា **បេត្តិកសម្ភវំ** មានវិគ្គហៈថា ឈ្មោះថា **បេត្តិកំ** ព្រោះនេះជាចំណែកខាងបិតា ។ ឈ្មោះថា **សម្ភវោ** ព្រោះកើតអំពីខាងបិតា ។ ឈ្មោះថា **បេត្តិកសម្ភវំ** ព្រោះកើតទាក់ទងខាងចំណែកបិតា សំដៅដល់ឈ្មោះ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា មិនបានតាំងព្រះនាមដោយការពាក់ព័ន្ធខាងមាតា និងបិតា ។ បទថា **ជាតេត្ថ** កាត់បទជា **ជាតោ ឯត្ថ** បានដល់ កើតត្រង់វិថីរបស់ពួកឈ្មួញនេះ ។ បាឋៈថា **ជាតោម្ហិ** ដូច្នេះក៏មាន ប្រែថា តថាគតកើតហើយ ។ បទថា **តស្មា វេស្សន្តរោ អហុំ** សេចក្តីថា ព្រោះក្នុងកាលនោះ តថាគតកើតត្រង់ផ្លូវរបស់ពួកអ្នកជំនួញ ហេតុនោះ ទើបឈ្មោះថា វេស្សន្តរ អធិប្បាយថា ព្រះជនក និងព្រះជននី ទ្រង់ដាក់នាមថា វេស្សន្តរ ។

ព្រះមហាសត្វទ្រង់ប្រសូតចាកព្រះគភ៌ព្រះមាតា ទ្រង់ស្អាត ទ្រង់បរិសុទ្ធ ទ្រង់បើកភ្នែកប្រសូត ។ កាលទ្រង់ប្រសូតនោះឯង ទ្រង់លាព្រះហស្តទៅរក

ព្រះមាតា ត្រាស់ថា បពិត្រមាតា បុត្រនឹងឲ្យទាន មានអ្វីខ្លះទេ ។ ព្រះមាតារបស់ព្រះមហាសត្វ ដាក់កញ្ចប់ទ្រព្យ ១ ពាន់ ក្បែរព្រះហស្ត ដោយត្រាស់ថា បុត្រសម្លាញ់ ចូរបុត្រឲ្យទានតាមអធ្យាស្រ័យចុះ ។ ពិតហើយ ព្រះពោធិសត្វទ្រង់ប្រសូតភ្លាម និយាយបានភ្លាម ៣ ជាតិ គឺក្នុងឧម្មង្គជាតក ( មហោសថជាតក ) ១ ក្នុងជាតកនេះ ១ ក្នុងអត្តភាពចុងក្រោយ ១ ។ ព្រះរាជាទ្រង់ឲ្យមេដោះ ៦៤ នាក់ ដែលមានទឹកដោះផ្អែម វៀរចាកទោសមានខ្ពស់ពេកជាដើម មើលថែព្រះមហាសត្វ ។ ព្រះរាជទានមេដោះដល់ទារក ៦០០០០ ដែលកើតក្នុងថ្ងៃជាមួយព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វទ្រង់ចម្រើនដោយបរិវារច្រើន មួយអន្លើដោយទារក ៦០០០០ នាក់ ។ ព្រះរាជាត្រាស់ឲ្យជាងធ្វើគ្រឿងប្រដាប់ដល់កុមារ ដែលមានតម្លៃ ១ សែន ព្រះរាជ-ទានដល់ព្រះរាជកុមារនោះ ។ ព្រះរាជកុមារ កាលមានវស្សា ៤-៥ វស្សា ទ្រង់ដោះគ្រឿងប្រដាប់នោះ ឲ្យដល់ពួកមេដោះ ពួកមេដោះថ្វាយវិញក៏មិនយក ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ថា គ្រឿងប្រដាប់ដែលឱរសរបស់យើងឲ្យ ជាការឲ្យល្អហើយ ហើយទ្រង់ឲ្យជាងធ្វើគ្រឿងប្រដាប់ដទៃទៀត ។ ព្រះរាជកុមារក៏ឲ្យទៀត ។ ទារកនោះ បានឲ្យគ្រឿងប្រដាប់ដល់ពួកមេដោះ អស់វារៈ ៩ ដង ។

កាលព្រះជន្មបាន ៨ វស្សា ទ្រង់ផ្ទំលើតាំង ព្រះតម្រិះថា អញឲ្យទានខាងក្រៅ ទាននោះមិនជាទីគាប់ចិត្តអញ អញបំណងនឹងឲ្យអជ្ឈត្តិកទាន បើអ្នកណាសូមនូវហទយៈនឹងអញ អញនឹងនាំហទយៈចេញហើយឲ្យ បើអ្នក

ណាសូមភ្នែកនឹងអញ អញនឹងខ្វេះភ្នែកឲ្យ បើអ្នកណាសូមសាច់ និងឈាម ក្នុងរាងកាយទាំងមូលរបស់អញ អញនឹងពុះវះ ពន្ធះរាងកាយទាំងមូល យកជាវចាក់យកឈាមឲ្យ ។ បើបុគ្គលឯណាពោលថា សូមទ្រង់ជាទាសៈរបស់ខ្ញុំចុះ អញនឹងប្រកាស ហើយឲ្យខ្លួនដល់បុគ្គលនោះ កាលព្រះរាជកុមារព្រះតម្រិះតាមសេចក្ដីពិត មួយអន្លើដោយសម្បត្តិដែលសំខាន់យ៉ាងនេះ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ញាប់ញ័ររហូតដល់ទឹកជាទីបំផុត ។ ភ្នំសិនេរុទោរទន់ទៅកាន់ជេតុត្តរនគរ ដូចព្រះមានព្រះភាគត្រាស់ថា

កាលណា តថាគតជាទារក មានអាយុ ៨ ឆ្នាំអំពីកំណើត ក្នុងកាលនោះ តថាគតអង្គុយក្នុងប្រាសាទ ត្រិះរិះដើម្បីឲ្យនូវអជ្ឈត្តិកទានថា បើអ្នកណា មកសូមតថាគត តថាគតគប្បីឲ្យបេះដូងឲ្យភ្នែក ឲ្យសាច់ និងឈាម ឬក៏គេញ៉ាំងតថាគត ឲ្យដឹងឮថា ( អ្នកចូរធ្វើជាទាសៈរបស់ខ្ញុំ ) តថាគតនឹងព្រម ប្រគល់កាយ ( ដល់អ្នកនោះ ) ។ កាលតថាគតកំពុងគិត នូវភាពដែលមិនញាប់ញ័រ ដែលមិនរួញរា មហាប្រឹថពី មានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងទីនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សាវេត្វា** បានដល់ ប្រកាសភាពជាទាសៈថា តាំងអំពីថ្ងៃនេះទៅ ខ្ញុំជាទាសៈរបស់បុគ្គលនេះ ។ បទថា **យទិ កោចិ យាចយេ មមំ** បានដល់ បើបុគ្គលណា គប្បីសូមនឹងតថាគត ។ បទថា **សភាវំ**

**ចិន្តយន្តស្ស** សេចក្តីថា កាលតថាគតគិតដល់សេចក្តីពិត តាមសភាពរបស់ខ្លួនដែលមិនវិបរិត តាមអធ្យាស្រ័យដែលមិនទៀយណាយ អធិប្បាយថា កាលតថាគតគិត ។ បទថា **អកម្បិតំ** បានដល់ ប្រាសចាកការញាប់ញ័រ ។ បទថា **អសណ្ឋិតំ** បានដល់ ប្រកាសនូវការរួញរា អធិប្បាយថា ព្រោះចិត្តញាប់ញ័រ ពោល គឺចិត្តតក់ស្លុត និងចិត្តសោកសៅ ពោល គឺចិត្តរួញរា ព្រោះការឲ្យអវយវៈមានចក្ខុជាដើម សម្រាប់បុគ្គលដែលមិនមែនព្រះពោធិសត្វ ដោយសេចក្តីលោភជាដើម គប្បីកើតមានបាន ។ វៀរចាកចិត្តយ៉ាងនោះ ។ បទថា **អកម្បិ** បានដល់ បានញាប់ញ័រ ។ បទថា **សិនេរុវនវដំសកា** បានដល់ ភ្នំសិនេរុ ដែលមានឧទ្យាននន្ទវ័ន បារុសកវ័ន មិស្សកវ័ន ចិត្តលតាវ័នជាដើម ដែលតាំងនៅលើភ្នំសិនេរុជាព្រៃសម្រាប់លម្អ ។ មួយវិញទៀត ភ្នំសិនេរុ និងឧទ្យានជាទីគួរត្រេកអរ ក្នុងជម្ពូទ្វីបជាដើម ឈ្មោះថា សិនេរុវ័ន ឈ្មោះថា **សិនេរុវនវដំសកា** ព្រោះឧទ្យាននោះ មានលក្ខណៈជាគ្រឿងប្រដាប់ ។

ម្យ៉ាងទៀត ផែនដីញាប់ញ័រប្រព្រឹត្តទៅយ៉ាងនេះ មេឃគ្រហឹម ភ្លៀងពុំដូកាលក៏ធ្លាក់ចុះ ផ្ទេកបន្ទោរ រលកបក់បោកក្នុងមហាសមុទ្រ សក្កទេវរាជប្រណម្យព្រះហស្ត មហាព្រហ្មឲ្យសាធុការ ភាពខ្ទរខ្ទារ កោលាហលមានឡើង រហូតដល់ព្រហ្មលោក ។

ព្រះមហាសត្វ កាលមានព្រះជន្ម ១៦ វស្សា ទ្រង់ក៏សម្រេចសិប្បៈសព្វអន្ទើ ព្រះបិតាមានបំណងឲ្យគ្រងរាជសម្បត្តិ ទើបទ្រង់ប្រឹក្សាជាមួយព្រះ

ជននី នាំរាជកញ្ញាព្រះនាមមទ្រី ជាព្រះរាជធីតារបស់ម្ចាស់អ៊ំ អំពីត្រកូលមទ្ទរាជ ហើយតែងតាំងឲ្យជាអគ្គមហេសី ជាធំជាងស្រ្តី ១៦០០០ នាក់ ហើយអភិសេកមហាសត្វឲ្យគ្រងរាជសម្បត្តិ ។ ព្រះមហាសត្វ ទ្រង់គ្រងរាជសម្បត្តិ ទ្រង់លះរាជទ្រព្យមួយថ្ងៃ ៦ សែនរាល់ៗ ថ្ងៃ ទ្រង់បរិច្ចាគមហាទាន ទ្រង់ពិនិត្យមើលរោងទានរៀងរាល់កន្លះខែ ។ ក្នុងកាលតមក ព្រះនាងមទ្រីប្រសូតព្រះរាជឱរស ។ ពួកអមាត្យទទួលព្រះរាជកុមារដោយបណ្តាញមាស ព្រោះហេតុនោះ ទើបមាននាមថា ជាលីកុមារ ។ កាលជាលីកុមារចេះដើរ ព្រះនាងមទ្រីក៏ប្រសូតព្រះរាជធីតាមួយអង្គ ។ ពួកអមាត្យទទួលព្រះរាជធីតានោះដោយស្បែកខ្លាឃ្មុំខ្មៅ ព្រោះហេតុនោះ ទើបមាននាមថា កណ្ហាជិនា ដូចព្រះមានព្រះភាគត្រាស់ថា

> តថាគតឡើងជិះដំរី ឈ្មោះបច្ច័យ ចូលទៅ ( កាន់សាលាទាន )
> ដើម្បីឲ្យទានក្នុងថ្ងៃឧបោសថ ខែពេញបូណ៌មី ទី ១៥ ក្នុងកន្លះខែ
> ជាលំដាប់ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អន្វទ្ធមាសេ** ស្មើគ្នានឹង **អនុអទ្ធមាសេ** អធិប្បាយថា រៀងរាល់កន្លះខែ ។ បទថា **បុណ្ណមាសេ** សេចក្តីថា ក្នុងតិថីព្រះចន្ទពេញវង់ គប្បីជ្រាបការភ្ជាប់សេចក្តីថា កាលដល់ថ្ងៃ ១៥ កើត ក្នុងខែពេញបូណ៌មី ព្រះចន្ទពេញវង់ តថាគតចូលទៅកាន់រោងទាន ដើម្បីឲ្យទាន ។ ក្នុងបទនោះ មានពាក្យអធិប្បាយថា តថាគតឡើងកាន់កដំរីឈ្មោះបច្ច័យ ចូលទៅកាន់រោងទានដើម្បីឲ្យទានកន្លះខែម្តងៗ ។ម្យ៉ាងទៀត ក្នុង

កាលណា កាលតថាគតចូលទៅយ៉ាងនេះ បានចូលទៅដើម្បីឲ្យទាន ក្នុងថ្ងៃឧបោសថ ពេញបូណ៌មី ១៥ កើត ១ ។ ក្នុងកាលនោះ ព្រាហ្មណ៍អ្នកដែនកាលិង្គៈ បានចូលទៅរកតថាគត ។ បទថា **បច្ចយំ នាគំ** បានដល់មង្គលហត្ថីឈ្មោះបច្ច័យ ។ ព្រោះក្នុងថ្ងៃដែលព្រះពោធិសត្វប្រសូត ដំរីញីមួយត្រាច់ទៅក្នុងអាកាស នាំកូនដំរីសសុទ្ធ ដែលគេសន្មតថា ជាដំរីមង្គលក្រៃលែង យកមកដាក់ត្រង់ទីរបស់មង្គលហត្ថីហើយ ត្រឡប់ទៅ ។ ដំរីនោះបានមកចំពោះព្រះមហាសត្វជាបច្ច័យ ទើបដាក់ឈ្មោះថា បច្ច័យ ។ តថាគតឡើងដំរីមង្គលនោះ ដែលឈ្មោះថា បច្ច័យ ចូលទៅកាន់រោងទាន ដើម្បីឲ្យទាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយ ដែលនៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឲ្យបានទ្រព្យដែលគេសន្មតជាសត្វមង្គលថា ជនបទ ( របស់យើងខ្ញុំព្រះអង្គ ) មិនមានភ្លៀង ទុរ្ភិក្ស អត់ឃ្លានខ្លាំង សូមព្រះអង្គព្រះរាជទានដំរីប្រសើរ មានអវយវៈសសុទ្ធ ជាដំរីឧត្តម ដូច្នេះ ។

ក្នុងបទទាំងនោះ គាថាជាដើមថា **កាលិង្គរដ្ឋវិសយា** មកហើយក្នុងកុរុរាជចរិយាខាងដើម ព្រោះហេតុនោះ សេចក្តីនៃគាថាទាំងនោះ និងកថាមគ្គគប្បីជ្រាបតាមន័យដូចពោលហើយ ក្នុងកុរុរាជចរិយានោះឯង តែក្នុងទីនេះព្រះមានព្រះភាគត្រាស់ថា **សព្វសេតំ គជុត្តមំ** ព្រោះដំរីមង្គលជាដំរីសសុទ្ធ ។ ព្រះពោធិសត្វនោះ ទ្រង់ឡើងគង់លើ-កដំរីដ៏ប្រសើរ កាលទ្រង់ប្រកាស

សេចក្តីត្រេកអរយ៉ាងក្រៃលែង ក្នុងទានរបស់ព្រះអង្គ ទើបត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយសូមដំរីណា ចំពោះតថាគត តថាគតឲ្យដំរីនោះ ឥតញាប់ញ័រឡើយ តថាគតមិនលាក់លៀម នូវទេយ្យធម៌ដែលមាន ព្រោះចិត្តរបស់តថាគត ត្រេកអរក្នុងទាន ។

ទ្រង់ប្តេជ្ញាថា

កាលបើយាចកមកដល់ហើយ ការប្រកែកក៏មិនសមគួរដល់តថាគត ការសមាទានរបស់តថាគត កុំបីបែកធ្លាយឡើយ ដូច្នេះ តថាគត នឹងឲ្យដំរីប្រសើរ ដូច្នេះ ។

ហើយទ្រង់ចុះអំពីកដំរី ពិចារណាមើលទីកន្លែង ដែលមិនទាន់តាក់តែង ទ្រង់មិនឃើញទីដែលមិនបានតាក់តែង ទើបទ្រង់ចាប់ឃ្មោកមាសដែលពេញដោយទឹកក្រអូប លាយដោយផ្កា ត្រាស់ថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមកខាងណេះ ហើយទ្រង់ចាប់ប្រមោយគជសារ ដែលដូចគ្នានឹងកម្រងប្រាក់ដែលតាក់តែងហើយ ដាក់លើដៃរបស់ពួកព្រាហ្មណ៍ ទ្រង់ប្រួចទឹកហើយ ទ្រង់ព្រះរាជទានស្តេចដំរីដែលតាក់តែងយ៉ាងល្អ ដល់ពួកព្រាហ្មណ៍ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតចាប់ដំរីត្រង់ប្រមោយ រួចប្រួចទឹកក្នុងកុណ្ឌី ជាវិការនៃកែវ ដាក់លើដៃព្រាហ្មណ៍ ហើយឲ្យដំរីដល់ព្រាហ្មណ៍ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សន្តំ** បានដល់ ទេយ្យធម៌ដែលមាន ។ បទថា **ឆប្បដិគូហាមិ** បានដល់ មិនបិទបាំង ។ ព្រោះបុគ្គលណាគិតថា

របស់ខ្លួន ត្រូវតែជារបស់អញប៉ុណ្ណោះដូច្នេះ ឬគេសូមហើយបដិសេធ បុគ្គលនោះ ឈ្មោះថា បិទបាំងរបស់ចំពោះមុខអ្នកសូមទាំងឡាយ ដោយអត្ថ ។ ចំណែកព្រះមហាសត្វ មានបំណងព្រះរាជទាននូវអជ្ឈត្តិកទាន មានសីសៈរបស់ព្រះអង្គជាដើម តើទ្រង់នឹងបដិសេធទានខាងក្រៅដូចម្តេចកើត ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា តថាគតមិនលាក់លៀមនូវទេយ្យធម៌ដែលមាន ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រោះចិត្តរបស់តថាគត ត្រេកអរក្នុងទាន ដូច្នេះ ។ បទដ៏សេស មានសេចក្តីដូចពោលហើយខាងដើមនោះឯង ។

គ្រឿងប្រដាប់ត្រង់ជើងទាំង ៤ របស់គជសារនោះ មានតម្លៃ ៤ សែន គ្រឿងប្រដាប់ត្រង់ចំហៀងទាំងពីរ មានតម្លៃ ២ សែន សំពត់កម្ពលដែលដាក់ខាងក្រោមពោះ មានតម្លៃ ១ សែន បណ្តាញដែលគ្របលើខ្នង មាន ៣ បណ្តាញ គឺបណ្តាញកែវមុក្តា បណ្តាញកែវមណី បណ្តាញមាស មានតម្លៃ ៣ សែន គ្រឿងប្រដាប់ត្រចៀកទាំងពីរ មានតម្លៃ ២ សែន សំពត់កម្ពលដែលក្រាលលើខ្នង មានតម្លៃ ១ សែន គ្រឿងប្រដាប់ត្រង់ពោង មានតម្លៃ ១ សែន កម្រងមាល័យ ៣ កម្រង មានតម្លៃ ៣ សែន គ្រឿងប្រដាប់ត្រង់ចុងត្រចៀក មានតម្លៃ ១ សែន គ្រឿងប្រដាប់ត្រង់ភ្លុកទាំងសងខាង មានតម្លៃ ២ សែន គ្រឿងប្រដាប់ត្រង់ប្រមោយ មានតម្លៃ ១ សែន គ្រឿងប្រដាប់កន្ទុយ មានតម្លៃ ១ សែន ញ៉ែង មានតម្លៃ ១ សែន ភាជនៈដាក់អាហារ មានតម្លៃ ១ សែន របស់មានប្រមាណប៉ុណ្ណោះ មានតម្លៃ ២ លាន

៤ សែន មិនរាប់របស់ដែលកាត់ថ្លៃមិនបានដទៃទៀត ។ របស់ដែលកាត់ថ្លៃមិនបាន មាន ៦ យ៉ាង គឺកែវមណីត្រង់កំពូលឆត្រ ១ ចូឡាមណី ១ កែវមុក្តាហារ ១ កែវមណីត្រង់កង្វេរ ១ កែវមុក្តាហារដែលពាក់ត្រង់កដំរី ១ កែវមណីត្រង់ពោង ១ សូម្បីដំរី ក៏មានតម្លៃកាត់ថ្លៃមិនបានដូចគ្នា រួមរបស់ដែលមានតម្លៃកាត់ថ្លៃមិនបាន មាន ៧ យ៉ាង ទាំងដំរី ។ ព្រះពោធិសត្វបានព្រះរាជទានរបស់ទាំងអស់នោះ ដល់ព្រាហ្មណ៍ទាំងឡាយម្យ៉ាង បានព្រះរាជទានត្រកូលសម្រាប់បម្រើដំរី ៥០០ ត្រកូល មួយអន្លើដោយហ្ម និងអ្នកឃ្វាលដំរី ។ ម្យ៉ាងទៀត តំណាលគ្នានឹងការព្រះរាជទាន បានកើតអស្ចារ្យមានផែនដីកម្រើកជាដើម ដោយន័យដូចពោលហើយខាងដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលតថាគតឲ្យដំរីដ៏ឧត្តម សស្កុទ្ធដទៃទៀត ក្នុងកាលនោះ
មហាប្រឹថពី ដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏
ញាប់ញ័រ ដូច្នេះ ។

ក្នុងជាតក ព្រះមានព្រះភាគក៏ត្រាស់ថា

កាលដែលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ផែនដីកម្រើកញាប់ញ័រ
ការកើតហេតុគួរខ្លាច គួរព្រឺរោម ក៏មានក្នុងកាលនោះ ដូច្នេះ ។

បទថា **តស្ស នាគស្ស ទានេន** សេចក្តីថា ព្រោះបរិច្ចាគមង្គលហត្ថីនោះ មួយអន្លើដោយទ្រព្យជាគ្រឿងប្រដាប់ មានតម្លៃ ២ លាន ៤ សែន និងរបស់ដែលកាត់ថ្លៃមិនបាន ៦ យ៉ាង ។ បទថា **សិវយោ** បានដល់

សិវិរាជកុមារទាំងឡាយ និងអ្នកដែនសិវិ ។ បទថា **សិវយោ** នេះ ជាមាតិកា នៃទេសនា ។ ព្រោះពួកអមាត្យ មហាជន ព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ អ្នកនគរ អ្នកដែនទាំងអស់ វៀរសញ្ជយមហារាជ ព្រះនាងផុស្សតី និងព្រះនាងមទ្រី ឈ្មោះថា អ្នកសិវិ ក្នុងបទថា **សិវយោ** នោះ ។ បទថា **កុទ្ធា** បានដល់ ក្រោធនឹងព្រះពោធិសត្វ ព្រោះទេវតាបណ្តាលចិត្ត ។ បទថា **សមាគតា** បានដល់ ប្រជុំគ្នា ។

បានឮថា ព្រាហ្មណ៍ទាំងនោះ កាលបានគជសារហើយ ក៏ឡើងគជសារនោះចូលទៅតាមទ្វារធំ នាំគ្នាជីកថ្វាយព្រះពរត្រង់កណ្តាលព្រះនគរ ។ ម្យ៉ាងទៀត កាលមហាជនពោលថា ព្រាហ្មណ៍ដ៏ចម្រើន អ្នកជិះដំរីរបស់យើងមកអំពីណា ព្រាហ្មណ៍ទាំងឡាយប្រាប់ថា ព្រះវេស្សន្តរមហារាជព្រះរាជទានដល់ពួកយើង ពួកលោកជានរណា ហើយគ្រវីដៃបណ្តេញ នាំគ្នាធ្វើដំណើរទៅ ។

លំដាប់នោះ មហាជនមានពួកអមាត្យជាដើម នាំគ្នាមកប្រជុំត្រង់ទ្វារព្រះរាជវាំងពោលទោសថា ព្រះរាជាគួរព្រះរាជទានទ្រព្យ ស្រូវ ស្រែចម្ការ ទាសី ទាសា និងស្នំដល់ពួកព្រាហ្មណ៍ ព្រះវេស្សន្តរមហារាជ ព្រះរាជទានមង្គលហត្ថី ដែលជាដំរីព្រះទីន័ងនេះទៅបានដូចម្តេច ឥឡូវនេះ ពួកយើងនឹងមិនឲ្យរាជសម្បត្តិវិនាសទៅយ៉ាងនេះ ទើបក្រាបទូលសេចក្តីនោះ ដល់ព្រះបាទសញ្ជយមហារាជ កាលព្រះបាទសញ្ជយមហារាជ ទ្រង់ឃើញតាមពាក្យប្រាប់ ទ្រង់ទទួល និងធ្វើតាមហើយ ពួកអ្នកញុះញង់ក៏នាំគ្នាត្រឡប់ទៅ ។

តែមហាជនបានក្រាបទូលថា

សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្តនោះ ដោយដំបង ឬគ្រឿងសស្ត្រាឡើយ ព្រោះព្រះរាជបុត្តនោះ មិនគួរដល់ចំណងទេ ព្រះអង្គគ្រាន់តែបណ្តេញព្រះរាជបុត្តនោះ ចេញអំពីដែនទៅចុះ សូមឲ្យព្រះរាជបុត្តនោះ ទៅគង់នៅឯវង្កបព៌តចុះ ដូច្នេះ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ហើយបណ្តេញតថាគតចាកដែនរបស់ខ្លួន ដោយពាក្យថា សូមព្រះអង្គទៅនៅវង្កតបព៌តទៅ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បព្វាជេសុំ** បានដល់ បានធ្វើសេចក្តីព្យាយាម ដើម្បីឲ្យទៅនៅខាងក្រៅអំពីរាជសម្បត្តិ ។

ព្រះរាជាក៏ទ្រង់ព្រះតម្រិះថា នេះជាបដិបក្ខជំក្រៃពេក ណ្ហើយចុះ ឱរសរបស់អញ ចូរនៅខាងក្រៅរាជសម្បត្តិបន្តិចសិន ហើយត្រាស់ថា

ថាបើអ្នកដែនសិវិ មានចំណង់បែបនេះហើយ យើងក៏មិនអាចបន្ទាបង់ចំណង់នេះបានទេ តែសូមឲ្យកូនយើងនោះ នៅបរិភោគកាមបានមួយរាត្រីនេះសិនចុះ ។ នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង ទើបសូមឲ្យពួកអ្នកសិវិរាស្ត្រ ព្រមព្រៀងគ្នាបណ្តេញកូនរបស់យើងនោះ ចេញអំពីដែនចុះ ដូច្នេះ ។

ហើយបញ្ជូនអមាត្យទៅកាន់សម្នាក់រាជឱរស ដោយព្រះតម្រាស់ថា ចូរអ្នកប្រាប់ដំណឹងនេះ ដល់ឱរសរបស់យើង អមាត្យបានធ្វើតាមនោះ

ព្រះមហាសត្វបានស្តាប់ដូច្នោះ ទើបត្រាស់សួរដល់ហេតុផលថា ព្រោះដំណើរដូចម្តេច បានជាពួកអ្នកសិវិរាស្ត្រ ខឹងនឹងយើង ដ្បិតយើងរកមិនឃើញអំពើអាក្រក់ទេ ម្នាលអាមាត្យ អ្នកចូរប្រាប់ដំណើរនោះដល់យើង ព្រោះហេតុអ្វី បានជាគេបណ្តេញដូច្នេះ ។

កាលអមាត្យក្រាបទូលថា ព្រោះទ្រង់ព្រះរាជទានគជសារ ។ ព្រះវេស្សន្តរ ទ្រង់មានសោមនស្សក្រៃលែង ត្រាស់ថា

យើងចង់ឲ្យបេះដូង ឬភ្នែកផង ទ្រព្យជាខាងក្រៅរបស់យើង គឺប្រាក់ មាស កែវមុក្តា កែវពិទូរ្យ និងកែវមណី ជាប្រយោជន៍អ្វី បើយើងបានឃើញស្មូម មកសុំដៃស្តាំ ឬដៃឆ្វេង គួរតែឲ្យ មិនគប្បីរំកើបទេ (ព្រោះថា) ចិត្តរបស់យើងរីករាយក្នុងការឲ្យ (ទាន) ។ ពួកអ្នកសិវិរាស្ត្រទាំងអស់នោះ ចង់បណ្តេញ ឬចង់សម្លាប់យើងក៏ដោយចុះ យើងនឹងមិនវៀរចាកការឲ្យ ( ទាន ) ទេ អ្នកដែនទាំងអស់ ចង់កាត់យើងជាប្រាំពីរកំណាត់ក៏ដោយចុះ ដូច្នេះ ។

ហើយមានព្រះតម្រាស់បន្តថា អ្នកនគរទាំងឡាយ ចូរឲ្យឱកាសដល់យើង ដើម្បីឲ្យទានមួយថ្ងៃចុះ ស្អែកនេះ យើងឲ្យទានហើយ ក្នុងថ្ងៃទី ៣ នឹងទៅ ហើយទ្រង់បញ្ជូនអមាត្យទៅកាន់សម្នាក់របស់អ្នកនគរ ត្រាស់នឹងអមាត្យអ្នកមើលថែរាជកិច្ចទាំងពួងថា ស្អែកនេះ យើងនឹងឲ្យសត្តសតកមហាទាន ចូរអ្នកត្រៀមដំរី ៧០០ សេះ ៧០០ រថ ៧០០ ស្រី ៧០០

ទាសៈ ៧០០ ទាសី ៧០០ មេគោទឹកដោះ ៧០០ ។ ចូររៀបចំបាយ និងទឹក ជាដើមច្រើនយ៉ាង ដែលជារបស់គួរឲ្យទាំងអស់ ហើយទ្រង់មួយអង្គឯង ប៉ុណ្ណោះ យាងទៅកាន់ទីប្រថាប់របស់ព្រះនាងមទ្រី ហើយត្រាស់ថា នែមទ្រី កាលនឹងកប់កំណប់ទ្រព្យ ដែលជាប់តាមខ្លួន គប្បីឲ្យក្នុងបុគ្គលមានសីល ទាំងឡាយ ហើយទ្រង់ទូន្មានព្រះនាងមទ្រីក្នុងការបរិច្ចាគទាន ទ្រង់ប្រាប់ដល់ហេតុដែលទ្រង់យាងទៅ ឲ្យព្រះនាងជ្រាប ហើយត្រាស់ថា យើងនឹងទៅកាន់ព្រៃ ចូរនាងនៅក្នុងព្រះនគរនេះចុះ កុំតាមយើងទៅឡើយ ។ ព្រះនាងមទ្រី ទូលថា បពិត្រព្រះរាជស្វាមី ខ្ញុំម្ចាស់វៀរព្រះអង្គហើយ នឹងមិនសូមនៅ ( រស់នៅ ) សូម្បីមួយថ្ងៃ ។

ក្នុងថ្ងៃទី ២ ព្រះវេស្សន្តរ ទ្រង់បរិច្ចាគសត្តសតកមហាទាន កាលព្រះវេស្សន្តរ ទ្រង់បរិច្ចាគសត្តសតកមហាទាននោះឯង ក៏ដល់ពេលល្ងាច ។ ទ្រង់យាងដោយរថដែលតាក់តែងហើយ ទៅគាល់ព្រះមាតាព្រះបិតា ទូលលាព្រះមាតាព្រះបិតាថា ស្អែកនេះ បុត្រនឹងទៅ កាលព្រះមាតា ព្រះបិតា ទ្រង់មិនបំណាង ទ្រង់ព្រះកន្សែង មានទឹកព្រះនេត្រជោកព្រះភក្ត្រ ព្រះវេស្សន្តរ ថ្វាយបង្គំ ធ្វើប្រទក្សិណ យាងចេញអំពីទីនោះ ។ ក្នុងថ្ងៃនោះ ទ្រង់ប្រថាប់នៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ ស្អែកឡើង ទ្រង់ព្រះតម្រិះថា អញនឹងទៅ ទើបទ្រង់ចុះអំពីប្រាសាទ ។ ព្រះនាងមទ្រី សូម្បីមាតាក្មេក បិតាក្មេក អង្វរដោយន័យផ្សេងៗ ឲ្យត្រឡប់ ក៏ព្រះនាងមិនបានស្តាប់ព្រះតម្រាស់ របស់ព្រះមាតា និងព្រះបិតាក្មេក ថ្វាយបង្គំហើយ ធ្វើប្រទក្សិណ ព្រះនាង

លាបណ្តាស្ត្រីដ៏សេស នាំកូនទាំងពីរ គឺព្រះរាជឱរស និងព្រះរាជធីតាយាងទៅប្រថាប់ឈរលើរថ មុនព្រះវេស្សន្តរ ។

ព្រះមហាបុរសឡើងរថ ប្រថាប់ឈរលើរថ ទ្រង់លាមហាជន ទ្រង់ប្រទានឱវាទដល់មហាជនថា ចូរពួកអ្នកកុំប្រមាទ ចូរធ្វើបុណ្យ មានទានជាដើម ហើយយាងចេញអំពីព្រះនគរ ព្រះមាតាព្រះពោធិសត្វទ្រង់ត្រិះរិះថា ឱរសរបស់អញ ត្រេកអរក្នុងការឲ្យទាន ចូរឲ្យទានចុះ ទើបព្រះនាងបញ្ជូនរទេះ ដែលពេញដោយរតនៈ ៧ ប្រការ មួយអន្ទើដោយគ្រឿងអាភរណៈទៅទាំងសងខាង ។ ព្រះមហាបុរស ព្រះរាជទានគ្រឿងប្រដាប់ ដែលជាប់ទៅជាមួយព្រះវរកាយរបស់ព្រះអង្គ ដល់យាចកដែលចូលទៅសូម អស់ ១៨ ដង បានព្រះរាជទានវត្ថុដ៏សេស ដរាបដល់អស់ ។ ព្រះអង្គចេញអំពីព្រះនគរ មានបំណងនឹងទតព្រះនគរ រំពេចនោះ ដោយបុញ្ញានុភាពរបស់ព្រះអង្គ មហាប្រឹថពីក្នុងទីប៉ុនរទេះ បានវិលត្រឡប់ធ្វើរថឲ្យបែរមុខទៅកាន់ព្រះនគរ ព្រះពោធិសត្វទតព្រះនគរ ដែលជាទីប្រថាប់របស់ព្រះមាតាបិតា ។ ដោយមហាករុណានោះ មហាប្រឹថពីក៏បានញាប់ញ័រ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាលពួកអ្នកដែនសិវិនោះ បណ្តេញតថាគតដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **និច្ឆុភមានាធំ** បានដល់ អ្នកក្រុងសិវិទាំងនោះ អូសចេញទៅ គឺបណ្តេញ ។ ឬកាលក្សត្រទាំងនោះចេញទៅ ។ បទថា **មហាធានំ បវត្តេតុំ** បានដល់ ដើម្បីបរិច្ចាគសត្តសតកមហាទាន ។

បទថា **អាយាចិស្សំ** បានដល់ តថាគតបានសូមហើយ ។ បទថា **សាវយិត្វា** បានដល់ ឲ្យប្រកាស ។ បទថា **កណ្ណភេរី** បានដល់ ស្គរជំមួយគូ ។ បទថា **ឧធាមហំ** បានដល់ តថាគតឲ្យមហាទាន ។

បទថា **អថេត្ថ** បានដល់ កាលតថាគតឲ្យទានក្នុងរោងទាននេះ ។ បទថា **តុម្ហលោ** បានដល់ សំឡេងកងរំពង មាន ។ បទថា **ភេរវោ** បានដល់ គួរភ័យខ្លាច ។ ពិតហើយ សំឡេងនោះ ធ្វើឲ្យអ្នកដទៃខ្លាច វៀរលែងតែព្រះមហាសត្វ ដើម្បីទ្រង់សម្តែងអាការដែលសំឡេងនោះ នាំឲ្យកើតការភ័យខ្លាច ទើបត្រាស់ថា **ធានេធិមំ** ដូច្នេះជាដើម សេចក្តីថា អ្នកក្រុងសិវិនាំគ្នាបណ្តេញព្រះវេស្សន្តរមហារាជនេះចេញអំពីដែន ព្រោះការឲ្យទាន ។ ទោះជាដូច្នោះ ព្រះបាទវេស្សន្តរមហារាជនេះ ក៏នៅតែឲ្យទានបែបនោះទៀត ។

ឥឡូវនេះ ដើម្បីសម្តែងទាននោះ ទើបត្រាស់គាថាថា **ហត្ថឹ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **គវំ** បានដល់ មេគោទឹកដោះ ។ បទថា **ចតុវាហឹ រថំ ឧត្វា** បានដល់ សេះ ឈ្មោះថា **វាហិន** ព្រោះនាំទៅ អធិប្បាយថា ឲ្យនូវសេះសិន្ធពអាជានេយ្យ ៤ និងរថដល់ពួកព្រាហ្មណ៍ ។

ពិតហើយ ព្រះមហាសត្វកាលទ្រង់ចេញអំពីព្រះនគរយ៉ាងនោះ ទ្រង់ឲ្យអមាត្យ ៦ ម៉ឺន ដែលជាសហជាត និងឲ្យជនដ៏សេស ដែលមានមុខជោកដោយទឹកភ្នែក ដែលតាមទៅត្រឡប់ ទ្រង់បររថទៅដោយព្រះអង្គឯង ត្រាស់នឹងព្រះនាងមទ្រីថា នែនាង បើមានយាចកមកតាមក្រោយ ចូរនាងមើលផង ។ ព្រះនាងមទ្រីក៏អង្គុយចាំមើល ។ លំដាប់នោះ ព្រាហ្មណ៍ ៤

នាក់ មកមិនទាន់សត្តសតកមហាទានរបស់ព្រះអង្គ និងទានដែលទ្រង់បរិច្ចាគក្នុងខណៈទ្រង់ធ្វើដំណើរ ទើបនាំគ្នាណើរមកសួរថា ព្រះវេស្សន្តរប្រថាប់នៅឯណា កាលពួកមនុស្សឆ្លើយថា ទ្រង់ឲ្យទាន ឡើងរថយានទៅហើយ ទើបគិតថា អញនឹងសូមសេះ ក៏ដើរតាមទៅ ។ ព្រះនាងមទ្រីទ្រង់ឃើញព្រាហ្មណ៍ទាំងនោះដើរមក ទើបក្រាបទូលថា បពិត្រព្រះអង្គ យាចកមកហើយ ។ ព្រះមហាសត្វទ្រង់បញ្ឈប់រថ ។ ពួកព្រាហ្មណ៍ទាំងនោះ ក៏ក្រាបទូលសូមសេះ ។ ព្រះមហាសត្វទ្រង់ឲ្យសេះ ពួកព្រាហ្មណ៍ ទទួលសេះហើយ ក៏នាំគ្នាត្រឡប់ កាលព្រះរាជទានសេះហើយ នឹមរបស់រថ ក៏តាំងនៅលើអាកាសនោះឯង ។ លំដាប់នោះ ទេវបុត្រ ៤ អង្គ កាឡាខ្លួនជាសត្វរមាំង ទទួលនឹមរថហើយអូសទៅ ។ ព្រះមហាសត្វទ្រង់ជ្រាបថារមាំងនេះ ជាទេវបុត្រ ទើបត្រាស់នឹងនាងមទ្រីថា

នែមទ្រី នាងចូរគន់មើលចុះ ម្រឹគទាំងឡាយ មានភេទជារមាំង
នាំខ្ញុំទៅ ដូចសេះដែលគេទូន្មានល្អហើយ ប្រាកដជារូបដ៏វិចិត្រ
ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា រូបដ៏វិចិត្រ បានដល់ មានរូបគួរអស្ចារ្យ ។ ពាក្យថា ដូចសេះដែលគេទូន្មានល្អហើយ បានដល់ ដូចសេះដែលត្រូវបង្ហឹកល្អហើយ នាំយើងទៅ ។

កាលនោះ មានព្រាហ្មណ៍ម្នាក់មកទូលសូមរថ ដែលកំពុងទៅនោះឯង ។ ព្រះមហាសត្វទ្រង់ឲ្យព្រះរាជឱរស និងមហេសីចុះ ព្រះរាជទានរថ ។

កាលព្រះរាជទានរថហើយ ទេវបុត្រក៏អន្តរធានទៅ ។ តាំងអំពីនោះ ក្សត្រទាំង ៤ អង្គ ក៏ទ្រង់យាងដោយព្រះបាទ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា នែមទ្រី នាងព-កណ្ហា អញនឹងព-ជាលី ក្សត្រទាំងពីរអង្គ ក៏ព-កុមារកុមារីទាំងទ្វេទៅ ទ្រង់សន្ទនាប្រាស្រ័យពាក្យជាទីស្រឡាញ់ដល់គ្នានិងគ្នា ។ ត្រាស់សួរផ្លូវដែលទៅកាន់ភ្នំវង្កត ជាមួយមនុស្សដែលធ្វើដំណើរបញ្រាស់ផ្លូវមក ។ ដើមឈើទាំងឡាយក៏ទោរទន់មកឯង ទ្រង់បេះផ្លែឈើឲ្យព្រះរាជឱរស និងព្រះរាជធីតា ព្រោះទេវតាប្រាប់ផ្លូវទីនឹងបង្រួញផ្លូវឲ្យ ទើបដល់ចេតរដ្ឋក្នុងថ្ងៃនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចតុវាហឹ រថំ ទត្វា** តថាគតឲ្យនូវរថដែលទឹមដោយសេះសិន្ធព ៤ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឋត្វា ចាតុម្មហាបថេ** សេចក្តីថា ឈរត្រង់ផ្លូវធំដែលមានមុំ ៤ ពោល គឺផ្លូវដែលបែកជា ៤ ព្រោះផ្លូវដែលខ្លួនមក និងផ្លូវដែលព្រាហ្មណ៍នោះមកជួបគ្នា ហើយឲ្យរថដល់ព្រាហ្មណ៍នោះ ។ បទថា **ឯកាកិយោ** ឈ្មោះថា **ឯកាកិយ** ព្រោះមិនមានសម្លាញ់ មានអមាត្យនិងសេវកៈជាដើម ដោយហេតុនោះ ទើបត្រាស់ថា **អទុតិយោ** មិនមានបុគ្គលជាគម្រប់ពីរ ។ បទថា **មទ្ទិទេវឹ ឥទមព្រវិ** បានដល់ បានពោលនឹងព្រះនាងមទ្រីទេវី ដូច្នេះ ។

បទថា **បទុមំ បុណ្ឌរីកំវ** បានដល់ ដូចផ្កាឈូក និងដូចផ្កាឈូក-ស ។ បទថា **កណ្ហាជិនគ្គហា** បានដល់ ព្រះនាងមទ្រីព-នាងកណ្ហា ។ បទថា

**អភិជាតា** បានដល់ សម្បូរដោយជាតិ ។ បទថា **វិសមំ សមំ** បានដល់ ភូមិប្រទេសដែលពុំរាបស្មើ ។ បទថា **ឯន្តិ** បានដល់ ដើរមក ។ បទថា **អនុមគ្គេ បដិបន្ថេ** បានដល់ ដើរតាមមកក្តី ដើរបញ្ច្រាស់ផ្លូវក្តី ។ គប្បីឃើញថា លុប **វា** សព្ទចេញ ។ សព្ទថា **ការុញ្ញំ** សម្តែងសភាវៈជានបុំសកលិង្គ អធិប្បាយថា ភាពជាបុគ្គលប្រកបដោយករុណា ។ បទថា **ទុក្ខំ តេ បដិ-វេទេន្តិ** សេចក្តីថា ក្សត្រទាំងនេះ ជាសុខមាលជាតិ ទ្រង់យានដោយព្រះបាទយ៉ាងនេះ ក្នុំវង្កតនៅឆ្ងាយទៀត ក្សត្រទាំងនោះ ខ្លួនឯងបានទទួលសេចក្តីទុក្ខ ព្រោះករុណាក្នុងពួកយើងក្នុងកាលនោះ ឬសោយទុក្ខដែលកើតឡើងដល់ខ្លួន ក៏ព្រោះសេចក្តីករុណាក្នុងពួកយើងដូចគ្នា ។

បទថា **បវនេ** បានដល់ ក្នុងបរិវេណព្រៃធំ ។ បទថា **ផលិនេ** បានដល់ មានផ្លែ ។ បទថា **ឧព្វិទ្ធា** បានដល់ ខ្ពស់ខ្លាំង ។ បទថា **ឧបគច្ឆន្តិ ទារកេ** សេចក្តីថា ដើមឈើទាំងឡាយបង្អោនមែកចូលមករកកុមារកុមារីឯង ដែលកុមារកុមារីលូកព្រះហស្តចាប់បេះបាន ។ បទថា **អច្ឆរិយំ** បានដល់ ប្រកបដោយភាពអស្ចារ្យ គឺគួរដល់ការទះដៃ ។ ឈ្មោះថា **អព្ភុតំ** ព្រោះមិនធ្លាប់មានមកអំពីមុន ។ ឈ្មោះថា **លោមហំសនំ** ព្រោះអាចធ្វើឲ្យព្រឺរោមព្រឺស្បែក ។ បទថា **សាហុការំ** ស្មើគ្នានឹង **សាធុការ** ម្យ៉ាងទៀត បាលីយ៉ាងនេះ ( សាធុការំ ) ក៏មាន ។ ឈ្មោះថា **សព្វង្គសោភណា** ព្រោះមានអវយវៈទាំងអស់ល្អ ព្រោះជាឥត្ថីរតនៈ ។ បទថា **អច្ឆេរំ វត** បានដល់ គួរអស្ចារ្យ ។ បទថា **វេស្សន្តរស្ស តេជេន** បានដល់ ដោយបុញ្ញានុភាពរបស់

ព្រះវេស្សន្តរ ។ បទថា **សដ្ឋិបឹសុ បថំ យក្ខា** សេចក្តីថា ទេវតាដែល
បុណ្យព្រះពោធិសត្វជាស់តឿន ទើបបង្រួញផ្លូវឲ្យ គឺធ្វើឲ្យខ្លី ។ ធ្វើដូច
ករុណាក្នុងកុមារកុមារី ដូចព្រះមានព្រះភាគត្រាស់ថា **អនុកម្បាយ ទារកេ**
ដោយសេចក្តីអនុគ្រោះចំពោះទារក ដូច្នេះ ។ ព្រោះភ្នំឈ្មោះសុវណ្ណគិរិតាល
ចេញអំពីជេតុត្តរនគរ ៥ យោជន៍ ។ ស្ទឹងឈ្មោះកោន្តិមារា ចម្ងាយអំពីភ្នំ
នោះ ៥ យោជន៍ ។ ភ្នំឈ្មោះនារញ្ជនាគិរី ឆ្ងាយអំពីស្ទឹងនោះ ៥ យោជន៍ ។
ស្រុកទណ្ឌព្រាហ្មណ៍ ចម្ងាយអំពីភ្នំនោះ ៥ យោជន៍ មាតុលនគរ ទៅអំពី
ស្រុកទណ្ឌព្រាហ្មណ៍នោះ ១០ យោជន៍ អំពីជេតុត្តរនគរដល់ដែននោះ រួម
ជាផ្លូវ ៣០ យោជន៍ ។ ពួកទេវតាដែលបុញ្ញតេជះរបស់ព្រះពោធិសត្វ
ជាស់តឿន ទើបបង្រួញផ្លូវឲ្យ ។ ក្សត្រទាំង ៤ អង្គ ធ្វងផុតទីទាំងអស់នោះ
ត្រឹមមួយថ្ងៃប៉ុណ្ណោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា
**និក្ខន្តទិវសេនេវ ចេតរដ្ឋមុបាគមុំ** ញុំាងជនទាំងនោះឲ្យដល់ដែនចេតៈ
ក្នុងថ្ងៃដែលខ្លួនចេញទៅ ដូច្នេះ ។

ព្រះមហាសត្វយាងដល់មាតុលនគរ ដែនចេតរដ្ឋក្នុងពេលល្ងាច ប្រថាប់
គង់ក្នុងសាលា ក្បែរទ្វារនគរនោះ ។ លំដាប់នោះ ព្រះនាងមទ្រីជូតធូលីជាប់
ព្រះបាទារបស់ព្រះមហាសត្វ ហើយព្រះនាងគក់ប្រចាប់ ព្រះនាងព្រះតម្រិះថា
អញនឹងឲ្យជនទាំងឡាយដឹងថា ព្រះវេស្សន្តរយាងមក ទើបព្រះនាងចេញអំពី
សាលា ប្រថាប់ឈរត្រង់ទ្វារសាលា ល្មមព្រះវេស្សន្តរទតឃើញ ។ បណ្តា
ស្ត្រីដែលចេញចូលព្រះនគរឃើញនាងមទ្រី ទើបនាំគ្នាចោមរោម ។

មហាជនឃើញព្រះនាងមទ្រី ព្រះវេស្សន្តរ និងព្រះរាជឱរសយាងមក យ៉ាងនោះ ទើបទៅក្រាបទូលព្រះរាជា ។ ព្រះរាជា ៦ ម៉ឺន ទ្រង់ព្រះកន្សែង នាំគ្នាមកគាល់ព្រះវេស្សន្តរ បន្ទោបង់នូវការហត់នឿយក្នុងការធ្វើដំណើរ ហើយ ទើបទូលសួរដល់ហេតុដែលយាងមកយ៉ាងនោះ ។

ព្រះមហាសត្វ តំណាលរឿងទាំងអស់ ចាប់តាំងអំពីឲ្យដំរី ។ ព្រះរាជា បានស្តាប់ដូច្នោះហើយ ទើបប្រឹក្សាគ្នាប្រគល់រាជសម្បត្តិដល់ព្រះអង្គ ព្រះ មហាបុរសត្រាស់ថា ការដែលយើងទទួលរាជសម្បត្តិរបស់ពួកទ្រង់ ចូរស្ងេះ ចុះ ព្រះរាជាបណ្តេញយើងចេញចាកដែន ព្រោះហេតុនោះ យើងនឹងទៅ កាន់ភ្នំវង្កត សូម្បីព្រះរាជាទាំងនោះ ទូលអង្វរឲ្យប្រថាប់នៅក្នុងចេតរដ្ឋនោះ មានប្រការផ្សេងៗ ក៏មិនបានពេញព្រះហឫទ័យក្នុងការទទួល ទ្រង់សូមឲ្យ ព្រះរាជាទាំងនោះ ធ្វើការរក្សា ប្រថាប់នៅក្នុងសាលានោះអស់រាត្រី ស្អែក ឡើង ក្នុងពេលព្រឹក ទ្រង់សោយព្រះក្រយាហារ មានរសប្រសើរផ្សេងៗ ហើយចោមរោមដោយព្រះរាជាទាំងនោះ យាងទៅអស់ចម្ងាយផ្លូវ ១៥ យោជន៍ ប្រថាប់នៅត្រង់មាត់ព្រៃ ត្រាស់ឲ្យព្រះរាជាទាំងនោះត្រឡប់ បានយាងទៅតាម ផ្លូវដែលព្រះរាជាទាំងនោះទូល អស់ ១៥ យោជន៍បន្តទៀត ដោយហេតុ នោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលនោះ ស្តេចទាំងអស់ ៦០០០០ អង្គ ដែលនៅក្នុងមាតុល-
នគរ ក៏ប្រណម្យអញ្ជលីទួញយំ ដើរចូលមកជិត ។ ក្សត្រទាំង ៤
ព្រះអង្គនោះ និយាយចរចាជាមួយនឹងស្តេចចេតៈទាំងឡាយ និង

ពួកបុត្ររបស់ស្តេចចេតៈក្នុងទីនោះ ហើយលាចេញពីទីនោះទៅថា យើងនឹងទៅកាន់វង្កតបព៌ត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តត្ថ វត្តេត្វា សល្លាបំ** បានដល់ ចរចាប្រាស្រ័យដោយពាក្យដែលនាំឲ្យកើតសេចក្តីត្រេកអរ ជាមួយនឹងព្រះរាជាដែលមកប្រជុំគ្នាក្នុងទីនោះ ។ បទថា **ចេតបុត្តេហិ** បានដល់ ឱរសរបស់ស្តេចចេតរាជ ។ បទថា **តេ តតោ និក្ខមិត្វាន** បានដល់ ឲ្យព្រះរាជាទាំងនោះ ត្រឡប់ត្រង់ប្រកព្រៃនោះ ។ បទថា **វង្កំ អគមុ បព្វតំ** បានដល់ យើង ៤ នាក់ នឹងចូលទៅកាន់ភ្នំវង្កត ។

លំដាប់នោះ ព្រះមហាសត្វយាងទៅតាមផ្លូវដែលព្រះបាទចេតរាជទូលដល់ភ្នំគន្ធមាទន៍ ទ្រង់ឃើញភ្នំនោះ ប្រថាប់នៅក្នុងទីនោះ បន្ទាប់អំពីនោះ ទ្រង់បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ យាងទៅដល់ជើងភ្នំវេបុលបព៌ត ប្រថាប់គង់ត្រង់ឆ្នេរស្ទឹងកេតុមតី សោយទឹកឃ្មុំ និងសាច់ដែលព្រានព្រៃថ្វាយ ទ្រង់ព្រះរាជទានម្ជុលមាស ( ស្នៀតសក់ ) ដល់ព្រានព្រៃ ទ្រង់ស្រេពស្រង់ ទ្រង់សោយនូវទឹក រម្ងាប់សេចក្តីក្រវល់ក្រវាយ យាងចេញអំពីឆ្នេរស្ទឹង ប្រថាប់គង់សម្រាកត្រង់គល់ជ្រៃ ដែលតាំងនៅក្បែរកំពូលភ្នំសានុបព៌ត ទ្រង់ក្រោកទៅបរិហារព្រះវរកាយ ត្រង់នាលិកបព៌ត យាងទៅកាន់ស្រះមុចលិន្ទ ទ្រង់យាងដល់ចុងទិសខាងកើត ចៀងខាងជើងឆ្នេរស្រះ យាងចូលទៅកាន់ដងព្រៃ ដោយផ្លូវដែលដើរបានតែម្នាក់ប៉ុណ្ណោះ ទ្រង់ឆ្លងដងព្រៃ ដល់ស្រះបោក្ខរណី ៤ ជ្រុង ខាងមុខទឹកពុះ ជាភ្នំដែលទៅបានលំបាក ។

ខណៈនោះ សក្កទេវរាជអាវជ្ជនៈថា ព្រះមហាសត្វយាងទៅកាន់ហិម-វន្តប្បទេស គួរបានទីប្រថាប់ ទើបទ្រង់បញ្ជូនវិស្សកម្មទេវបុត្រ ដោយទេវបញ្ជាថា ចូរអ្នកទៅសាងអាស្រមបទក្នុងទីដែលគួរត្រេកអរ ក្នុងញកភ្នំវង្កត ។ វិស្សកម្មទេវបុត្រទទួលទេវបញ្ជាហើយ ទើបទៅសាងបណ្ណសាលា ២ ខ្នង ទីចង្ក្រម ២ ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ២ កន្លែង ទ្រង់ញកភ្នំ ដាំដើមផ្កាដែលមានផ្កាល្អផ្សេងៗ ឈើផ្លែ គុម្ពផ្កា និងចម្ការ ចេកជាដើមក្នុងទីនោះៗ ហើយដាក់បព្វជិតបរិក្ខារគ្រប់យ៉ាង ចារិកអក្សរថា បុគ្គលដែលបំណងនឹងបព្វជ្ជា ចូរកាន់យកចុះ ហើយមិនឲ្យមានអមនុស្ស ម្រឹគ និងបក្សីដែលមានសំឡេងគួរខ្លាចបៀតបៀន ស្រេចហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។

ព្រះមហាសត្វទតឃើញផ្លូវដែលដើរបានតែម្នាក់ ទ្រង់ព្រះតម្រិះថា គង់ជាលំនៅរបស់អ្នកបួស ទើបឲ្យព្រះនាងមទ្រី ឱរស និងធីតា ប្រថាប់នៅក្នុងទីនោះ យាងចូលកាន់អាស្រមបទ ទតឃើញអក្ខរា ទ្រង់ព្រះតម្រិះថា សក្កទេវរាជប្រទាន ទើបទ្រង់បើកទ្វារបណ្ណសាលាចូលទៅ ទ្រង់ដោះព្រះខ័ននិងធ្នូចេញ ផ្លាស់សំពត់សាដក កាន់យកភេទឥសី កាន់ឈើច្រត់ ចេញទៅរកកុមារាកុមារី ដោយសេចក្តីស្ងប់ ដូចព្រះបច្ចេកពុទ្ធ ។

ព្រះនាងមទ្រីទេវីឃើញព្រះមហាសត្វ ព្រះនាងក៏ក្រាបចុះទៀបបាទា ទ្រង់ព្រះកន្សែង យាងចូលកាន់អាស្រមជាមួយព្រះមហាសត្វ ហើយយាងទៅកាន់បណ្ណសាលារបស់ព្រះនាង ព្រះនាងកាន់យកភេទជាឥសី ខាងក្រោយ ព្រះ

នាងឲ្យព្រះកុមារកុមារី បួសជាតាបសកុមារ ។

ព្រះពោធិសត្វទ្រង់សូមពរព្រះនាងមទ្រីថា តាំងអំពីនេះទៅ យើងជាអ្នកបួសហើយ ធម្មតាស្រ្តីជាមន្ទិលដល់ព្រហ្មចរិយៈ ឥឡូវនេះ នាងកុំមករកយើងក្នុងកាលដែលមិនសមគួរឡើយ ព្រះនាងទទួលថា សាធុ ហើយសូមពរព្រះមហាសត្វថា បពិត្រព្រះអង្គ សូមទ្រង់សម្ងំមើលកូនប្រុសស្រី ក្នុងបណ្ណសាលានេះចុះ ខ្ញុំម្ចាស់នឹងស្វែងរកផ្លែឈើតូចធំមកប្រគេន ។ តាំងអំពីនោះ នាងមទ្រី ក៏នាំយកផលាផលមកអំពីព្រៃ ផ្គត់ផ្គង់ជនទាំង ៣ ។ ក្សត្រទាំង ៤ អង្គ ប្រថាប់នៅលើភ្នំវង្កតអស់ ៧ ខែ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អាមន្តយិត្វា ទេវិន្ទោ វិស្សុកម្មំ មហិទ្ធិកំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អាមន្តយិត្វា** បានដល់ ត្រាស់មក ។ បទថា **មហិទ្ធិកំ** បានដល់ ប្រកបដោយទេវឫទ្ធិច្រើន ។ បទថា **អស្សមំ សុកតំ** បានដល់ ឲ្យសាងអាស្រមបទ អធិប្បាយថា បណ្ណសាលាដែលសមគួរជាទីប្រថាប់របស់ព្រះវេស្សន្តរ គួរជាទីត្រេកអរ ។ បទថា **សុមាបយ** បានដល់ឲ្យសាងឲ្យល្អ ។ លោកឲ្យបន្ថែមពាក្យថា **អាណាបេសិ** ( ប្រើ ) ចូលមក ។ បទថា **សុមាបយិ** បានដល់ ឲ្យសាងយ៉ាងល្អ ។

បទថា **អសុញ្ញោ** បានដល់ អាស្រមនោះ មិនទទេយ៉ាងណា តថាគតជាបុគ្គលមិនទទេ ព្រោះធ្វើអាស្រ័យនោះ មិនឲ្យទទេក៏យ៉ាងនោះ ។ បាឋៈថា **អសុញ្ញោ** ដូច្នេះក៏មាន គឺតថាគតរក្សាក្មេងទាំងពីរ ក្នុងអាស្រមដែលមិនទទេ

ដោយការនៅរបស់តថាគត គឺតថាគតតាំងនៅក្នុងអាស្រមនោះ ។ ដោយអានុភាពនៃមេត្តារបស់ព្រះពោធិសត្វ សូម្បីតិរច្ឆានទាំងពួង ក៏បានទូវមេត្តាក្នុងទី ៣ យោជន៍ដោយជុំវិញ ។

កាលក្សត្រទាំង ៤ អង្គប្រថាប់នៅក្នុងក្នុំវង្កតនោះយ៉ាងនេះ ជូជកព្រាហ្មណ៍ អ្នកស្រុកកាលិង្គរដ្ឋ កាលភរិយាឈ្មោះអមិត្តតាបនាពោលថា ខ្ញុំមិនអាចបុកអង្ករ ដងទឹក ដាំបបរ និងដាំបាយដល់អ្នកបានជានិច្ចទេ ចូរអ្នកនាំទាសា ឬទាសីមកបម្រើខ្ញុំចុះ ។ ជូជកពោលថា អើនាង អញជាមនុស្សក្រីក្រ នឹងបានអ្នកបម្រើប្រុស និងអ្នកបម្រើស្រីអំពីណាមកឲ្យនាង ។ កាលនាងអមិត្តតាបនាប្រាប់ថា ព្រះរាជាវេស្សន្តរនុ៎ះ ដូចម្តេច ទ្រង់ប្រថាប់នៅត្រង់ភ្នំវង្កត ចូរអ្នកសូមព្រះរាជឱរស ព្រះរាជធីតារបស់ព្រះអង្គមកឲ្យជាអ្នកបម្រើខ្ញុំចុះ ជូជកមិនអាចបំពានពាក្យរបស់នាងបាន ព្រោះខ្លួនមានចិត្តប្រតិព័ទ្ធដោយអំណាចកិលេស ទើបឲ្យនាងរៀបចំស្បៀង ធ្វើដំណើរដល់នគរជេតុត្តរដោយលំដាប់ ហើយសួរធ្វើពើថា ព្រះវេស្សន្តរមហារាជនៅឯណា ។

មហាជនខឹងក្រោធថា ព្រះរាជារបស់ពួកយើង ព្រោះទ្រង់ឲ្យទានដល់យាចកពួកនេះ ទើបត្រូវនិរទេសចាកដែន តាព្រាហ្មណ៍កញ្ចាស់នេះ ធ្វើឲ្យព្រះរាជារបស់ពួកយើង បានទទួលសេចក្តីវិនាសហើយ នឹងមានមុខមកដល់ទីនេះទៀត នាំគ្នាកាន់ដុំដី និងដំបងជាដើម ដេរហើយដេញតាមព្រាហ្មណ៍ទៅ ។

ជូជកព្រាហ្មណ៍នោះ ទេវតាបណ្តាលចិត្តចេញអំពីជេតុត្តរនគរ ដើរតម្រង់

ទៅកាន់ភ្នំវង្កត ដល់ច្រកចូលព្រៃដោយលំដាប់ ឈមចុះកាន់ព្រៃធំ ដល់ផ្លូវដែលដើរបានតែម្នាក់ ចៃដន្យជួបនឹងចេតបុត្ត ដែលព្រះរាជាទាំងនោះតែងតាំងដើម្បីរក្សាព្រះពោធិសត្វ ចេតបុត្តសួរថា នែព្រាហ្មណ៍ តើអ្នកទៅណា ជូជកប្រាប់ថា ទៅរកព្រះវេស្សន្តរមហារាជ ។ ចេតបុត្តគិតថា តាព្រាហ្មណ៍នេះមុខជាទៅទូលសូមព្រះរាជឱរស ព្រះរាជធីតា ឬព្រះទេវីរបស់ព្រះវេស្សន្តរដោយពិត ទើបកំហែងថា នែព្រាហ្មណ៍ អ្នកកុំទៅទីនោះឡើយ បើទៅអញនឹងកាត់ក្បាលឯងក្នុងទីនេះ ហើយឲ្យឆ្កែរបស់អញស៊ី ជូជកត្រូវកំហែងខ្លាចស្លាប់ ទើបពោលកុហកថា ព្រះជនករបស់ព្រះវេស្សន្តរ បញ្ជូនយើងជាទូតមកដោយបំណងថា នឹងនាំព្រះវេស្សន្តរត្រឡប់ចូលកាន់ព្រះនគរ ។

ចេតបុត្តបានស្តាប់ដូច្នោះ ត្រេកអរ សម្តែងនូវការគោរពរាប់អានព្រាហ្មណ៍ ទើបប្រាប់ផ្លូវចូលទៅកាន់ភ្នំវង្កត ដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ធ្វើដំណើរចេញអំពីទីនោះ ក្នុងរវាងផ្លូវ បានជួបនឹងអច្ចុតតាបស ទើបសួរផ្លូវ កាលអច្ចុតតាបសបង្ហាញផ្លូវ ទើបដើរទៅតាមសញ្ញាដែលអច្ចុតតាបសប្រាប់ ដល់ទីជិតអាស្រមបទរបស់ព្រះពោធិសត្វដោយលំដាប់ ទើបចូលទៅរកព្រះពោធិសត្វ ក្នុងកាលព្រះនាងមទ្រីទៅរកផលាផល ហើយទូលសូមព្រះរាជ-កុមារកុមារីទាំងទ្វេ ដូចព្រះមានព្រះភាគត្រាស់ថា

កាលតថាគតនៅក្នុងព្រៃធំ មានអ្នកដំណើរម្នាក់ ចូលមករកតថាគត
សូមកូនទាំងពីរនៃតថាគត គឺជាលី និងនាងកណ្ហជិនា ដូច្នេះ ។

កាលព្រាហ្មណ៍ទូលសូមកុមារកុមារីយ៉ាងនេះហើយ ព្រះមហាសត្វ

ទ្រង់កើតសោមនស្សដោយបំណងថា យូរហើយ យាចកខានមករកអញ ថ្ងៃនេះ អញនឹងបំពេញទានបារមីឲ្យគ្រប់បរិបូណ៌ ទ្រង់ញុំាងចិត្តរបស់ព្រាហ្មណ៍ឲ្យត្រេកអរ ដូចដាក់ថង់ទ្រព្យ ១ ពាន់ ក្នុងដៃដែលលាចេញ ទ្រង់ញុំាងញកភ្នំទាំងមូលឲ្យខ្ទរខ្ទារ ត្រាស់ថា យើងឲ្យកូនទាំងទ្វេរបស់យើង ដល់អ្នក តែនាងមទ្រីទេវី ទៅព្រៃដើម្បីរកផលាផលអំពីព្រលឹម នឹងត្រឡប់ក្នុងពេលល្ងាច ។ ម្យ៉ាងទៀត កាលនាងមទ្រីត្រឡប់ហើយ ឲ្យនាងឃើញកូនទាំងពីរសិន ចូរអ្នកផឹក ទំពាមើមឈើ និងផ្លែឈើតូចធំ ស្នាក់នៅមួយយប់ លុះបាត់នឿយហត់ ព្រលឹមឡើងសឹមទៅ ។ ព្រាហ្មណ៍គិតថា ព្រះវេស្សន្តរនេះព្រះរាជទានព្រះកុមារកុមារី ព្រោះមានអធ្យាស្រ័យទូលាយពិត តែព្រះនាងមទ្រីជាម្តាយ មានសេចក្តីស្រឡាញ់កូន ត្រឡប់មក គប្បីធ្វើអន្តរាយដល់ទានបាន បើដូច្នោះ អញទូលទាស់ព្រះវេស្សន្តរនេះហើយ នាំកូនទាំងពីរទៅក្នុងថ្ងៃនេះ ឲ្យខាងតែបាន ទើបក្រាបទូលថា បើទ្រង់ព្រះរាជទានកូនទាំងពីរដល់ទូលបង្គំហើយ ក៏មិនមានប្រយោជន៍អ្វី ដែលបង្ហាញដល់ព្រះនាងមទ្រីឲ្យឃើញជាមុនទើបឲ្យ ទូលបង្គំនឹងនាំកូនទាំងពីរទៅក្នុងថ្ងៃនេះឯង ។ ព្រះវេស្សន្តរត្រាស់ថា អើ ព្រាហ្មណ៍ បើអ្នកមិនប្រាថ្នានឹងឃើញព្រះនាងមទ្រីរាជបុត្រី ចូរអ្នកនាំទារកទាំងពីរនេះ ទៅកាន់ជេតុត្តរនគរ ក្នុងទីនោះ ព្រះបាទសញ្ជយមហារាជ នឹងទទួលទារកទាំងពីរ ហើយព្រះរាជទានទ្រព្យជាច្រើន ដល់អ្នក អ្នកនឹងមានអ្នកបម្រើ ប្រុសស្រីដោយទ្រព្យនោះ ហើយអ្នកនឹងមានជីវិតរស់នៅយ៉ាងសប្បាយ ។ ម្យ៉ាងទៀត ទារកទាំងពីរនេះ ជា

សុខមាលជាតិ គេនឹងប្រតិបត្តិ ( បម្រើ ) អ្នកបានដូចម្តេច ។

ព្រាហ្មណ៍ទូលថា ទូលបង្គំមិនអាចធ្វើយ៉ាងនោះបាន ទូលបង្គំខ្លាចព្រះរាជអាជ្ញា ទូលបង្គំនឹងនាំទៅផ្ទះរបស់ទូលបង្គំតែម្តង ។ ទារកទាំងពីរបានស្តាប់ការសន្ទនារបស់បិតា និងព្រាហ្មណ៍ គិតថា ព្រះបិតាបំណាងនឹងឲ្យយើងទាំងពីរដល់ព្រាហ្មណ៍ ទើបគេចទៅកាន់ស្រះបោក្ខរណី ពួនត្រង់គុម្ពឈូក ។ ព្រាហ្មណ៍មិនឃើញកុមារកុមារី ទើបទូលថា ព្រះអង្គត្រាស់ថា ព្រះរាជទានទារកទាំងទ្វេហើយ ឲ្យទារកទាំងពីរគេចទៅ នុ៎ះជាឧបាយ ដែលល្អរបស់ព្រះអង្គ ។

លំដាប់នោះ ព្រះមហាសត្វប្រញាប់ក្រោកឡើង ត្រាច់តាមរកកុមារកុមារី ទ្រង់ឃើញទារកទាំងពីរពួនត្រង់គុម្ពឈូក ទើបត្រាស់ថា កូនសម្លាញ់ទាំងពីរ ចូរឡើងមកចុះ កូនទាំងពីរ កុំធ្វើអន្តរាយដល់ទានបារមីរបស់ឪពុកឡើយ ចូរឲ្យអធ្យាស្រ័យក្នុងទានរបស់ឪពុកដល់ទីបំផុតចុះ ។ម្យ៉ាងទៀត ព្រាហ្មណ៍នេះ នាំកូនទាំងពីរទៅហើយ នឹងទៅរកព្រះបាទសញ្ជយមហារាជ ដែលជាជីតារបស់កូន បាជាលីជាទីស្រឡាញ់ កូននឹងបានជាអ្នកជា គប្បីឲ្យមាស ១ ពាន់ដុំ ដល់ព្រាហ្មណ៍ ក៏នឹងបានជាអ្នកជា ។ ឯកណ្ហាជិនាកូនសម្លាញ់ កូនគួរឲ្យវត្ថុមួយមុខ ១០០ គឺខ្ញុំប្រុស ១០០ ខ្ញុំស្រី ១០០ ដំរី ១០០ សេះ ១០០ គោឧសភៈ ១០០ មាស ១០០ ដុំ កូននឹងបានជាអ្នកជា ទ្រង់កាត់ថ្លៃកូនទាំងពីរដូច្នេះហើយ នាំត្រឡប់ទៅកាន់អាស្រមបទ យកកុណ្ឌីទឹកប្រួចលើដៃរបស់ព្រាហ្មណ៍ធ្វើឲ្យជាបច្ច័យនៃសព្វញ្ញុតញ្ញាណ ទ្រង់កើតបីតិ

សោមនស្សក្រៃលែង ញុំាងមហាប្រឹថពីឲ្យកក្រើក បានព្រះរាជទានបុត្រជាទីស្រឡាញ់ជាទាន ។ ក្នុងចរិយានេះ មានផែនដីកម្រើកដោយន័យដូចពោលហើយក្នុងចរិយាមុន ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ តថាគតកើតសេចក្តីរីករាយ ព្រោះបានឃើញយាចកដើរចូលមក បានយកកូនទាំងពីរឲ្យដល់ព្រាហ្មណ៍ កាលតថាគតបរិច្ចាគបុត្រទាំងពីររបស់ខ្លួន ដល់ជូជកព្រាហ្មណ៍ កាលនោះប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។

កាលនោះ ព្រាហ្មណ៍យកវល្លិចងហត្ថា អូសទារកទាំងពីរដែលមិនចង់ទៅ ត្រង់ហត្ថាដែលចងនោះ ឈាមក៏ហូរចេញអំពីស្បែក ព្រាហ្មណ៍យកកំណាត់វល្លិវាយអូសទៅ កុមារកុមារីក្រឡេកមើលបិតា ហើយទូលថា

បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតាឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រព្រះបិតា ព្រះអង្គកុំអាលប្រទានយើងខ្ញុំឡើយ រង់ចាំព្រះមាតារបស់យើងខ្ញុំ ត្រឡប់មកសិន ។ ក្នុងពេលនោះ ព្រាហ្មណ៍នេះ ចង់លក់ ឬចង់សម្លាប់ក៏តាមប្រាថ្នាចុះ ដូច្នេះ ។

កុមារទូលតទៅទៀតថា ព្រាហ្មណ៍ចាស់ជរានេះ កាចពេកណាស់ធ្វើនូវអំពើគ្រោតគ្រាត ។

បពិត្រព្រះបិតា ( ព្រាហ្មណ៍នេះ ) ជាមនុស្ស ឬជាយក្ស ជាអ្នកស៊ីសាច់ និងឈាម ចេញអំពីស្រុកមកកាន់ព្រៃ សូមទ្រព្យ គឺ

កូន នឹងព្រះបិតាទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាច កំពុងនាំទៅ ព្រះបិតាទ្រង់ទតឃើញឬទេ ដូច្នេះ ។

កុមារកុមារីទាំងពីរ នាំគ្នាព្រះកន្សែង ។ ក្នុងពាក្យទាំងនោះ ពាក្យថា ទ្រព្យ បានដល់ ទ្រព្យ គឺបុត្ត ។

កាលកុមារកុមារីកំពុងយំយ៉ាងនោះ ជូជកក៏វាយអូសចៀសចេញទៅ ។ ព្រះមហាសត្វទ្រង់កើតសេចក្តីសោកជាកម្លាំង ដោយសេចក្តីករុណាកូនទាំងទ្វៃដែលកំពុងយំ និងដោយការគ្មានករុណារបស់ព្រាហ្មណ៍ ។ ក្នុងខណៈនោះឯង ទ្រង់រឭកដល់បវេណីរបស់ព្រះពោធិសត្វទាំងឡាយ ។ ទ្រង់តិះដៀលខ្លួនឯងថា ធម្មតាព្រះពោធិសត្វទាំងឡាយ ទ្រង់បំពេញមហាបរិច្ចាគ ៥ ហើយ នឹងបានត្រាស់ជាព្រះពុទ្ធ ឯអាត្មាអញ ក៏ជាបុរសម្នាក់ ក្នុងបណ្តាព្រះពោធិសត្វទាំងនោះ បរិច្ចាគបុត្តជាទាន និងមហាបរិច្ចាគឯណាមួយ ព្រោះហេតុនោះ ម្នាលវេស្សន្តរ ការឲ្យទានហើយក្តៅក្រហាយក្នុងកាលជាខាងក្រោយ មិនសមគួរដល់អ្នកឡើយ ហើយទ្រង់ដាស់តឿនខ្លួនឯងថា តាំងអំពីពេលដែលអាត្មាអញឲ្យទានហើយ វត្ថុនោះ មិនមែនជារបស់អញ ទ្រង់អធិដ្ឋានកុសលសមាទានឲ្យមាំទាំ ប្រថាប់គង់ត្រង់ទ្វារបណ្ណសាលា ដូចបដិមាមាស តម្កល់លើផ្ទាំងថ្ម ដូច្នោះ ។

លំដាប់នោះ ព្រះនាងមទ្រីរែកផលាផលត្រឡប់អំពីព្រៃមក ទេវតាទាំងឡាយកាឡាខ្លួនជាសត្វសាហាវរារាំងផ្លូវ ដោយគិតថា ព្រះនាងមទ្រី កុំជាអន្តរាយដល់ទានរបស់ព្រះមហាសត្វឡើយ កាលម្រឹគកាចចៀសចេញទៅ

ហើយ ព្រះនាងក៏យាងដល់អាស្រមយឺតយូរ ព្រះនាងព្រះតម្រិះថា ថ្ងៃនេះ អញយល់សប្តិមិនល្អឡើយ នឹងកើតនិមិត្តអាក្រក់ថែមទៀត តើនឹងមានរឿងអ្វីហ្ន៎ នាងចូលទៅកាន់អាស្រម មិនឃើញកុមារកុមារី ទើបចូលទៅរកព្រះពោធិសត្វទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនឃើញកូនទាំងពីររបស់ខ្ញុំ តើកូនទាំងពីរទៅឯណា ។ ព្រះពោធិសត្វទ្រង់នៅស្ងៀម ។ ព្រះនាងមទ្រីគយគន់រកមើលកូនទាំងពីរ ដើររកក្នុងទីនោះៗ មិនបានឃើញ ទើបត្រឡប់ទៅទូលសួរទៀត ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អញនឹងឲ្យមទ្រី លះសេចក្តីសោកដល់បុត្រដោយពាក្យគ្រោតគ្រាត ដូច្នេះហើយ ទើបត្រាស់ថា

ក្រែងនាងមទ្រី មានកម្ពស់ និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយសឬ នាងទៅដើម្បីស្វែងរក ( ផ្លែឈើតូចធំ ) តាំងពីពេលព្រឹក ហេតុដូចម្តេច បានជាដល់ពេលល្ងាចហើយ ទើបមកដូច្នេះ ។

កាលព្រះនាងទូលដល់ហេតុដែលធ្វើឲ្យយឺតយូរ ព្រះវេស្សន្តរ ក៏មិនបានត្រាស់ពាក្យណាមួយដល់ទារកទាំងពីរទៀតឡើយ នាងមទ្រី ដោយសេចក្តីសោកដល់បុត្រ ទើបប្រញាប់ចេញអំពីព្រៃស្វែងរកបុត្រទៀត ទីដែលព្រះនាងមទ្រីត្រាច់ស្វែងរកក្នុងរាត្រីមួយ បើគណនាហើយ ក៏បានចម្ងាយ ១៥ យោជន៍ ។ លុះភ្លឺស្វាង នាងបានចូលទៅរកព្រះពោធិសត្វ ប្រថាប់ឈរ ត្រូវសេចក្តីសោក មានកម្លាំងគ្របសង្កត់ ព្រោះមិនឃើញកូន ទើប

ដួលសន្ធប់លើផែនដី ទៀបព្រះបាទារបស់ព្រះពោធិសត្វ ដូចដើមចេកដែលគេកាប់រំលំ ដូច្នោះ ។

ព្រះពោធិសត្វទ្រង់ញាប់ញ័រ ព្រោះសម្គាល់ថា ព្រះនាងមទ្រីអស់ព្រះជន្ម ទ្រង់កើតសេចក្តីសោកជំកន្ទង ទ្រង់តម្កល់ស្មារតីត្រិះរិះថា អាត្មាអញនឹងដឹងថា នាងមទ្រីនៅមានជីវិត ឬមិនមានជីវិត ទោះបីអស់កាល ៧ ខែ មិនធ្លាប់ប៉ះពាល់រាងកាយគ្នាឡើយ តែព្រោះមិនមានចិត្តដទៃ ទើបទ្រង់លើកសិរសារបស់នាងដាក់លើព្រះឧរុ គឺភ្លៅ យកទឹកប្រោះព្រំ លាបស្រលាបព្រះឧរៈ គឺទ្រូង និងព្រះភក្ត្រ មួយអន្លើដោយព្រះហទយៈ ។ លុះកន្លងទៅអស់កាលបន្តិចបន្តួច នាងមទ្រីក៏មានសតិ កើតហិរិឱត្តប្បៈ ទូលសួរថា បពិត្រព្រះអង្គ កូនទាំងពីរទៅណា ព្រះពោធិសត្វត្រាស់ថា អើទេវី អញបានឲ្យបុត្ររបស់យើងដើម្បីជាទាសៈដល់ព្រាហ្មណ៍ម្នាក់ ដែលមកសូម កាលព្រះនាងមទ្រីទូលថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ទ្រង់ឲ្យកូនទាំងពីរដល់ព្រាហ្មណ៍ហើយ មិនប្រាប់ដល់ខ្ញុំ ឲ្យខ្ញុំទ្រហោយំ ត្រាច់ស្វែងរកអស់មួយរាត្រី ទើបត្រាស់ថា បើអញប្រាប់មុន នាងនឹងមានទុក្ខច្រើន តែឥឡូវនេះ ទុក្ខផ្លូវកាយធូរស្បើយហើយ ទើបទ្រង់លួងលោមព្រះនាងមទ្រីថា

ហៃនាងមទ្រី នាងចូរមើលមកអញ កុំមើលបុត្រទាំងពីរ កុំខ្សឹកខ្សួលខ្លាំងឡើយ កាលបើយើងរស់នៅបានសុខសប្បាយ ក៏គង់បាន ( ជួបប្រទះ ) នឹងបុត្រវិញ ដូច្នេះ ។

ហើយត្រាស់បន្តថា

សប្បុរសបានឃើញពួកស្មូមមកហើយ គប្បីឲ្យកូន សត្វចិញ្ចឹម ធញ្ញជាតិ និងទ្រព្យដទៃដែលមានក្នុងផ្ទះជាទាន ហៃនាងមទ្រី នាងចូររីករាយតាមនូវអំណោយបុត្រ ដ៏ឧត្តមរបស់អញ ដូច្នេះ ។

ហើយទ្រង់ឲ្យព្រះនាងមទ្រីអនុមោទនាបុត្តទានរបស់ព្រះអង្គ ព្រះនាងក៏ទូលអនុមោទនាថា

បពិត្រព្រះទេវៈ ខ្ញុំម្ចាស់សូមរីករាយ តាមនូវអំណោយបុត្រ ដ៏ឧត្តមរបស់ព្រះអង្គ ព្រះអង្គប្រទានហើយ សូមធ្វើព្រះហឫទ័យឲ្យជ្រះថ្លាចុះ សូមព្រះអង្គទ្រង់ឲ្យទានជាកិយ្យោភាពចុះ ដូច្នេះ ។

កាលក្សត្រទាំងពីរសន្ទនាគ្នា ជាទីសុខសាន្តព្រះហឫទ័យនៃគ្នានិងគ្នាយ៉ាងនេះហើយ សក្កទេវរាជទ្រង់ព្រះតម្រិះថា ម្សិលមិញមហាបុរសញ៉ាំងប្រឹថពីឲ្យកក្រើករំពើក បានប្រទានព្រះរាជឱរស ព្រះរាជធីតាដល់ជូជកឥឡូវនេះ នឹងមានបុរសអាក្រក់ចូលទៅរកព្រះអង្គ ហើយសូមព្រះនាងមទ្រីនាំទៅទៀត បន្ទាប់អំពីនោះ ព្រះពោធិសត្វនឹងអស់ទីពឹង ណ្ហើយចុះអញនឹងកាឡាខ្លួនជាព្រាហ្មណ៍ ចូលទៅរកព្រះអង្គ ទូលសូមព្រះនាងមទ្រី ធ្វើឲ្យព្រះពោធិសត្វកាន់យកកំពូលនៃបារមី ហើយកុំឲ្យទ្រង់ធ្វើវត្ថុដែលមិនគួរលះបង់ ឲ្យដល់បុគ្គលណាមួយ រួចហើយ នឹងថ្វាយនាងមទ្រីនោះសងដល់ព្រះពោធិសត្វវិញ ហើយត្រឡប់មក ។ សក្កទេវរាជក៏កាឡាខ្លួនជាព្រាហ្មណ៍ក្នុងកាលព្រះអាទិត្យរះឡើង បានចូលទៅរកព្រះពោធិសត្វ ព្រះមហាបុរសទតឃើញព្រាហ្មណ៍នោះ ទ្រង់កើតនូវបីតិសោមនស្សថា ភ្ញៀវរបស់អញមកហើយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងរាក់ទាក់ជាមួយព្រាហ្មណ៍នោះ ហើយត្រាស់

សួរថា នែព្រាហ្មណ៍ អ្នកមកទីនេះបំណងដូចម្ដេច ។

លំដាប់នោះ សក្កទេវរាជក៏ទូលសូមព្រះនាងមទ្រីទេវីនឹងព្រះវេស្សន្តរ ដូចព្រះមានព្រះភាគត្រាស់ថា

ព្រះឥន្ទបានក្លែងភេទជាព្រាហ្មណ៍ម្ដងទៀត ចុះមកសូមនាងមទ្រី-
ទេវី ដែលមានសីល មានវត្តចំពោះប្ដីនឹងតថាគត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុនទេវ** បានដល់ ខាងក្រោយអំពីថ្ងៃដែលតថាគតឲ្យកូនទាំងពីរនោះឯង អធិប្បាយថា ក្នុងលំដាប់នោះឯង ។ បទថា **ឱរុយ្ហ** បានដល់ ចុះអំពីទេវលោក ។ បទថា **ព្រាហ្មណសន្និភោ** បានដល់ កាឡាខ្លួនដូចព្រាហ្មណ៍ ។

លំដាប់នោះ ព្រះមហាសត្វមិនបានត្រាស់ថា ម្សិលមិញនេះ យើងបានឲ្យកូនទាំងទ្វេដល់ព្រាហ្មណ៍ យើងក៏ត្រូវនៅម្នាក់ឯងប៉ុណ្ណោះក្នុងព្រៃ យើងនឹងឲ្យនាងមទ្រីដែលជាស្រីមានសីល បដិបត្តិល្អក្នុងស្វាមី ដល់អ្នកបានដូចម្ដេច ។ មានព្រះហឫទ័យមិនរួញរាឡើយ ព្រោះមិនលះបង់ ព្រោះមិនជាប់ជំពាក់ ដូចដាក់រតនៈដែលមានតម្លៃកាត់ថ្លៃមិនបានលើដៃដែលលាចេញ ទ្រង់ត្រេកអរ ដូចញុំាងគិរីឲ្យកក្រើករំពើកថា ថ្ងៃនេះ ទានបារមីរបស់អញនឹងដល់ទីបំផុត ទើបត្រាស់ថា

ម្នាលព្រាហ្មណ៍ យើងឲ្យរបស់ដែលអ្នកសូមនឹងយើង យើងមិន
រួញរាទេ យើងមិនលាក់លៀមវត្ថុដែលមាន ចិត្តរបស់យើង
ត្រេកអរក្នុងទាន ដូច្នេះ ។

ទ្រង់ប្រញាប់យកទឹកក្នុងកុណ្ឌី ហើយប្រួចក្នុងដៃព្រាហ្មណ៍ បានព្រះរាជទានកិរិយា ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតមានសេចក្តីត្រិះរិះក្នុងចិត្ត ដោយជ្រះថ្លា ចាប់នាងមទ្រីទេវី
ត្រង់ដើមដៃ ហើយប្រួចទឹកដាក់លើអញ្ជលីនៃព្រាហ្មណ៍ ហើយឲ្យ
មទ្រីដល់ព្រាហ្មណ៍ ។

ក្នុងបទទាំងនោះ បទថា **ឧទកញ្ជលិ** កែជា **ឧទកំ អញ្ជលឹ** ប្រែថា ញ៉ាំងបាតដៃឲ្យពេញដោយទឹក ។ ម្យ៉ាងទៀត បទថា **ឧទកំ** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា ញ៉ាំងដៃ គឺបាតដៃដែលលាចេញរបស់ព្រាហ្មណ៍នោះឲ្យពេញដោយទឹក ។ បទថា **បសន្នមនសង្កប្បោ** សេចក្តីថា មានសេចក្តីត្រិះរិះនៃចិត្តជ្រះថ្លាហើយ ដោយការជ្រះថ្លាក្នុងសទ្ធាដែលកើតឡើងហើយថា អញនឹងញ៉ាំងទីបំផុតនៃទានបារមីឲ្យដល់ ដោយការបរិច្ចាគកិរិយានេះ ហើយនឹងសម្រេចសម្មាសម្ពោធិញ្ញាណពិតប្រាកដ ។

ក្នុងខណៈនោះឯង បានប្រាកដបាដិហារ្យទាំងពួង មានប្រការដូចបានពោលមកហើយខាងដើម ។ ពួកទេវតា ពួកព្រហ្ម កើតនូវបីតិសោមនស្សក្រៃលែងថា ឥឡូវនេះ ព្រះសម្មាសម្ពោធិញ្ញាណរបស់ព្រះពោធិសត្វនោះនៅមិនឆ្ងាយ ដូចព្រះមានព្រះភាគត្រាស់ថា

កាលដែលតថាគតឲ្យនាងមទ្រី ទេវតាឰដ៏អាកាស ក៏ត្រេកអរ
រីករាយ ប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏
ញាប់ញ័រ ក្នុងកាលនោះ ដូច្នេះ ។

ម្យ៉ាងទៀត កាលតថាគតឲ្យនូវព្រះនាងមទ្រី មិនមានការយំយែក ឬត្រឹមតែការចងចិញ្ចើម ។ ព្រះនាងមទ្រីទេវី មានព្រះតម្រិះតែម្យ៉ាងថា សូមទ្រង់តាមបំណងចុះ ហើយត្រាស់ថា

ខ្ញុំម្ចាស់ជាកិរិយារបស់ព្រះអង្គអំពីក្មេង ព្រះអង្គជាស្វាមី ជាឥស្សរៈរបស់ខ្ញុំម្ចាស់ស្រាប់ហើយ ចង់ឲ្យខ្ញុំម្ចាស់ដល់អ្នកណា គប្បីឲ្យដល់អ្នកនោះចុះ ចង់លក់ ឬចង់សម្លាប់ ( ក៏បាន ) ដូច្នេះ ។

មហាបុរសត្រាស់ថា ព្រាហ្មណ៍ដ៏ចម្រើន សព្វញ្ញុតញ្ញាណប៉ុណ្ណោះ យើងស្រឡាញ់ក្រៃលែងជាងនាងមទ្រីរាប់រយ រាប់ពាន់ រាប់សែនដង សូមទានរបស់យើង បានជាបច្ច័យនៃការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណចុះ ហើយទ្រង់ព្រះរាជទាន ដូចព្រះមានព្រះភាគត្រាស់ថា

កាលតថាគតបរិច្ចាគជាលីកុមារ កណ្ហាជិនាជីតា និងនាងមទ្រីទេវី ដែលមានវត្តចំពោះប្តី ឥតគិតក្តៅក្រហាយសោះឡើយ ក៏ព្រោះហេតុនៃពោធិញ្ញាណតែម្យ៉ាង ដូច្នេះ ។

បុត្រទាំងពីរមិនមែនជាទីស្អប់របស់តថាគតទេ ទាំងនាងមទ្រីទេវីក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត បានជាតថាគតឲ្យបុត្រ និងកិរិយាជាទីស្រឡាញ់ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ចជមានោ ន ចិន្តេសឹ** សេចក្តីថា កាល

តថាគតលះបង់ ក៏មិនបានគិតដល់ដោយសេចក្តីក្តៅក្រហាយ អធិប្បាយថា អញលះបង់ហើយ ក៏ជាការលះបង់ទៅ ។ ត្រង់នេះមានពាក្យសួរថា ព្រោះហេតុអ្វី ទើបមហាបុរសទ្រង់លះបង់បុត្រកិរិយារបស់ព្រះអង្គ ដែលសម្បូរដោយជាតិ ជាក្សត្រ ឲ្យជាទាសៈរបស់អ្នកដទៃ ព្រោះការធ្វើបុគ្គលដែលជាអ្នកជា មិនឲ្យជាអ្នកជា ( ខ្ញុំគេ ) មិនគួរពោលថា ជាវត្ថុដែលល្អ ឆ្លើយថា ព្រោះជាធម៌សមគួរ ។ ពិតហើយ ការបរិច្ចាគវត្ថុដែលហួងហែងថា ជារបស់អញ ដែលទាក់ទងក្នុងខ្លួនទាំងពួង ដោយមិនសេសសល់នេះឯង ជាធម្មតាក្នុងការចូលដល់ពុទ្ធការកធម៌ ព្រោះការបំពេញទានបារមី មិនមានកំណត់ដោយទេយ្យធម៌ និងបដិគ្គាហកឡើយ ការមិនលះបង់វត្ថុដែលហួងហែងថារបស់អញ ដល់យាចក មិនសមគួរដល់ព្រះពោធិសត្វ ដែលដល់នូវការខ្វល់ខ្វាយ ។ សេចក្តីនេះ ជាធម៌សមគួរផង ដែលជារបស់បុរាណផង ។ ការបរិច្ចាគរបស់គ្រប់យ៉ាងនេះ ទើបជាធម៌ដែលប្រព្រឹត្តសន្សំមកជានិច្ច ជាវង្សរបស់ត្រកូល ជាបវេណីរបស់ត្រកូលនៃព្រះពោធិសត្វទាំងឡាយ ។ តែដោយពិសេស ក្នុងសេចក្តីនោះ គឺការបរិច្ចាគវត្ថុដែលជាទីស្រឡាញ់ជាង ។ ពិតហើយ ព្រះពោធិសត្វអង្គខ្លះ បានជាព្រះពុទ្ធ ព្រោះទ្រង់បរិច្ចាគមហាបរិច្ចាគទាំង ៥ នេះ គឺបរិច្ចាគទ្រព្យ មានភាពជាឥស្សរៈក្នុងរាជសម្បត្តិជាដើម ដែលបន្តវង្សមក ១ បរិច្ចាគអវយវៈ មានក្បាល និងភ្នែកជាដើមរបស់ខ្លួន ១ បរិច្ចាគជីវិតដែលជាទីស្រឡាញ់ ១ បរិច្ចាគបុត្រដែលជាទីស្រឡាញ់ ដែលនឹងតវង្សត្រកូល ១ បរិច្ចាគភរិយាជាទីស្រឡាញ់ មានការ

ប្រព្រឹត្តជាទីពេញចិត្ត ១ ធ្លាប់មានមកហើយមិនមែនឬ ។ សេចក្តីពិតយ៉ាងនោះ ព្រះមានព្រះភាគព្រះនាមសុមង្គលៈ កាលនៅជាព្រះពោធិសត្វ ទ្រង់ស្វែងរកមហាពោធិញ្ញាណ ប្រថាប់នៅត្រង់ភ្នំ ១ មួយអន្ទើដោយបុត្រភរិយាក្នុងអត្តភាពទី ៣ បន្ទាប់ពីអត្តភាពមុន ។ សម័យនោះ មានយក្សឈ្មោះខរទាឋិកៈ បានដឹងថា ព្រះមហាបុរសមានអធ្យាស្រ័យក្នុងការឲ្យ ទើបកាឡាខ្លួនជាព្រាហ្មណ៍ ចូលទៅរកព្រះមហាសត្វ សុំទារកទាំងទ្វេ ។

ព្រះមហាសត្វត្រេកអរថា អញនឹងឲ្យបុត្រទាំងពីរដល់ព្រាហ្មណ៍ ញុំាងប្រឹថពីដែលមានទឹកជាទីបំផុតឲ្យញាប់ញ័រ បានឲ្យទារកទាំងពីរ ។ យក្សឈរផ្អែកធ្នាក់ដៃខាងចុងទីចង្រ្កម កាលព្រះពោធិសត្វកំពុងឃើញនោះឯង បានទំពាស៊ីទារកទាំងពីរ ដូចទំពាក្រអៅឈូក ។ កាលព្រះមហាបុរសសម្លឹងមើលមាត់យក្ស ដែលតំណក់ឈាមកំពុងហូរមកដូចអណ្តាតភ្លើង មិនឲ្យឱកាសដល់ចិត្តកើតឡើងថា យក្សបោកបញ្ឆោតអញ ព្រោះភាពជាអ្នកឈ្លាសក្នុងឧបាយ ដែលបានអប់រំមកល្អហើយ ព្រោះសភាវៈនៃធម៌ក្នុងអតីត មិនមានបដិសន្ធិ និងព្រោះការញុំាញីនៃសង្ខារទាំងឡាយ ដោយអំណាចនៃភាពជារបស់មិនទៀងជាដើម ទើបកើតសោមនស្សឡើងថា ទានបារមីរបស់អញពេញហើយ អញញុំាងប្រយោជន៍ធំឲ្យសម្រេច ហើយបានត្រាស់ដឹង ។ ដោយគំនរសង្ខារដែលមិនមានសារៈ ពុកផុយទៅ តាំងនៅមួយស្របក់យ៉ាងនេះ ។ ព្រះមហាសត្វជ្រាបភាពបរិសុទ្ធនៃចិត្តរបស់ខ្លួន ក្នុងខណៈនោះដែលមិនទូទៅដល់អ្នកដទៃ ទើបតាំងសេចក្តីប្រាថ្នាថា ដោយផលនេះ ក្នុង

អនាគត សូមរស្មីរបស់អញចេញអំពីរាងកាយ ដោយទំនងដូចគ្នានេះចុះ ។

រស្មីចេញអំពីសរីរៈរបស់ព្រះពោធិសត្វ ដែលជាព្រះពុទ្ធអង្គនោះ ព្រោះអាស្រ័យសេចក្តីប្រាថ្នានោះ បានផ្សាយទៅរហូតលោកធាតុ ១ ម៉ឺន តាំងនៅជានិច្ច ។ ព្រះពោធិសត្វដទៃក៏យ៉ាងនោះ លះបង់បុត្ត និងភរិយា ដែលជាទីស្រឡាញ់ក្រៃលែងរបស់ខ្លួន ក៏ដឹងច្បាស់ ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ។

ម្យ៉ាងទៀត ដូចបុរសណាមួយស៊ីឈ្នួលធ្វើការងារស្រុក ឬជនបទក្នុងសម្នាក់របស់បុគ្គលណាមួយ គប្បីធ្វើទ្រព្យឲ្យវិនាសទៅ ដោយសេចក្តីប្រមាទរបស់ខ្លួន ឬរបស់កូនសិស្ស បុគ្គលនោះ ត្រូវគេចាប់បញ្ជូនទៅកាន់ពន្ធនាគារ បុគ្គលនោះ គប្បីមានការគិតយ៉ាងនេះថា អញធ្វើការងាររបស់ព្រះរាជាអង្គនេះ រក្សាទ្រព្យបានប្រមាណប៉ុណ្ណេះ អញត្រូវព្រះរាជានោះបញ្ជូនចូលទៅក្នុងគុក បើអញនៅក្នុងគុកនេះ ខ្លួនក៏នឹងវិនាស បុត្រ ភរិយា កម្មករ និងបុរសរបស់អញ មិនមានអ្នកចិញ្ចឹម គប្បីដល់នូវសេចក្តីវិនាសលំបាក បើដូច្នោះ អញនឹងទូលព្រះរាជា ឲ្យទ្រង់ចងបុត្រ ឬបងប្រុស ប្អូនប្រុសរបស់អញក្នុងទីនេះជំនួស ហើយគប្បីចេញទៅ អញផុតចាកគុកនេះ មិនយូរមិនឆាប់ នឹងប្រមូលទ្រព្យអំពីមិត្ត អំពីសម្លាញ់ ហើយថ្វាយដល់ព្រះរាជា ហើយលោះបុត្រ បងប្រុស ប្អូនប្រុសនោះអំពីគុក អញជាបុគ្គលមិនប្រមាទ នឹងធ្វើសម្បត្តិរបស់ខ្លួនឲ្យដូចដើម បានដោយកម្លាំងសេចក្តីព្យាយាមយ៉ាងណា ព្រះមហាសត្វក៏ធ្វើយ៉ាងនោះ គប្បីឃើញឧបមេយ្យនេះយ៉ាងនេះ ។

ក្នុងសេចក្តីនោះ មានការប្រៀបធៀបដូចតទៅ ការងារ ដូចព្រះរាជា

សង្សារ ដូចគុក មហាបុរសដែលត្រាច់ទៅក្នុងសង្សារដោយអំណាចកម្ម ដូចបុរសដែលព្រះរាជាចាប់ដាក់គុក ។ កាលដែលមហាបុរសឲ្យបុត្រជាដើម របស់ខ្លួនដល់អ្នកដទៃ ហើយដោះសត្វទាំងពួងឲ្យផុតចាកទុក្ខក្នុងវដ្តៈ ដោយការបាននូវសព្វញ្ញុតញ្ញាណ ដូចការផុតចាកទុក្ខរបស់បុត្រ ឬបងប្អូនរបស់ខ្លួន ដែលត្រូវនៅក្នុងគុក ដោយការពឹងអ្នកដទៃ ។ ការដល់ព្រមដោយសម្បត្តិ គឺសព្វញ្ញុតញ្ញាណ មានទសពលញ្ញាណជាដើម ដោយភាពជាព្រះពុទ្ធនៃមហាបុរស ដែលប្រាសចាកទុក្ខក្នុងវដ្តៈ ដោយអរហត្តមគ្គ និងការដល់ព្រមដោយសម្បត្តិ មានវិជ្ជា ៣ ជាដើម របស់បុគ្គលដែលធ្វើតាមពាក្យប្រៀនប្រដៅរបស់ខ្លួន ដូចការដែលបុរសដែលផុតទុក្ខហើយ តាំងនៅក្នុងសម្បត្តិតាមបំណង ជាមួយជនទាំងនោះ ព្រោះហេតុនោះ ការបរិច្ចាគបុត្រកិរិយារបស់មហាបុរសទាំងឡាយ ទើបជាសភាវៈដែលមិនមានទោស ដោយប្រការដូច្នេះ ។ ដោយន័យនេះឯង ការទាក់ទងណាក្នុងការបរិច្ចាគអវយវៈ និងជីវិតរបស់ព្រះពោធិសត្វទាំងនោះ សូម្បីការទាក់ទងនោះ ក៏គប្បីជ្រាបថា បរិសុទ្ធល្អហើយ ។

កាលព្រះមហាសត្វ ឲ្យព្រះនាងមទ្រីទេវីយ៉ាងនេះហើយ សក្កទេវរាជទ្រង់កើតអស្ចារ្យដែលមិនធ្លាប់មាន ទ្រង់សរសើរដោយការអនុមោទនាទានរបស់ព្រះមហាបុរសដោយន័យជាដើមថា

ពួកសត្រូវទាំងអស់ ដែលឃាត់នូវទិព្វសម្បត្តិ និងមនុស្សសម្បត្តិ
ព្រះអង្គក៏បានឈ្នះហើយ ព្រះអង្គបានញុំាងផែនដីឲ្យខ្ទរខ្ទារ កិត្តិ-

សព្ទរបស់ព្រះអង្គ ផ្សាយទៅដល់ទេវលោក ។ កាលដែលពួកជនកំពុងឲ្យវត្ថុ ដែលគេឲ្យបានដោយកម្រ កំពុងធ្វើអំពើ ដែលគេធ្វើបានដោយកម្រ ពួកអសប្បុរស រមែងមិនធ្វើតាម ( អំពើនោះ ) ឡើយ ធម៌របស់ពួកសប្បុរស គឺគេដឹងបានដោយក្រ ។ ព្រោះហេតុនោះ ដំណើរទៅអំពីលោកនេះ ( ទៅកាន់បរលោក ) នៃពួកសប្បុរស និងពួកអសប្បុរស ជាដំណើរផ្សេងគ្នា ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរស មានស្ថានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បច្ចូហា** ស្មើគ្នានឹង **បច្ចត្ថិកា** ( ពួកសត្រូវ ) ។ ពាក្យថា ទិព្វសម្បត្តិ បានដល់ ដែលឃាត់នូវយសជាទិព្វ ។ ពាក្យថា មនុស្សសម្បត្តិ បានដល់ ដែលហាមនូវយសជារបស់មនុស្ស ។ សត្រូវទាំងនោះជានរណា គឺសេចក្តីកំណាញ់ ។ សក្កទេវរាជសម្តែងថា សេចក្តីកំណាញ់ទាំងអស់នោះ ដែលព្រះមហាសត្វទ្រង់ឲ្យបុត្រ និងភរិយា ទ្រង់ឈ្នះបានហើយ ។ ពាក្យថា ដែលគេឲ្យបានដោយកម្រ សេចក្តីថា កាលបុគ្គលដូចទ្រង់ឲ្យវត្ថុដែលឲ្យបានដោយក្រ មានបុត្រ និងភរិយាជាដើម ធ្វើវត្ថុដែលធ្វើបានដោយក្រនោះ សាវកក្តី ព្រះបច្ចេកពោធិសត្វទាំងឡាយ ពួកដទៃក្តី ធ្វើតាមមិនបាន នឹងពោលថ្វីដល់អសប្បុរសដែលមានសេចក្តីកំណាញ់ ព្រោះហេតុនោះ ធម៌របស់សប្បុរស ដែលជនដទៃប្រព្រឹត្តតាមបាន ដោយក្រ គឺធម៌ដែលជាបដិបទារបស់សប្បុរស គឺព្រះមហាសត្វ ដែលបុគ្គល

ដទៃធ្វើតាមបានដោយក្រ ។

សក្កទេវរាជទ្រង់សរសើរដោយការអនុមោទនា ដល់មហាបុរសយ៉ាង នេះហើយ កាលទ្រង់ប្រគល់ព្រះនាងមទ្រីទេវីមកវិញ ទើបត្រាស់ថា

ឥឡូវខ្ញុំសូមថ្វាយនាងមទ្រី ជាស្ត្រីមានសព៌ាង្គដ៏ល្អ ជាកិរិយា
របស់ព្រះអង្គវិញ ព្រះអង្គសមគួរនឹងនាងមទ្រីដោយពិត នាង
មទ្រី ក៏សមគួរនឹងព្រះអង្គ ដែលជាកស្វាដែរ ដូច្នេះ ។

ហើយទ្រង់ប្រគល់ព្រះនាងមទ្រីមកវិញ ប្រថាប់ឈរលើអាកាស រុងរឿង ដោយអត្តភាពជាទិព្វ ដូចព្រះអាទិត្យដែលទើបរះ កាលសម្តែងព្រះអង្គ ( ថាជាព្រះឥន្ទ ) ទើបត្រាស់ថា

ខ្ញុំជាទេវិន្ទឈ្មោះសក្កៈ បានមកក្នុងសម្នាក់ព្រះអង្គ បពិត្រព្រះ
រាជាជាឥសី សូមព្រះអង្គទទួលយកពរចុះ ខ្ញុំសូមថ្វាយពរ ៨
យ៉ាង ចំពោះព្រះអង្គ ដូច្នេះ ។

ហើយទ្រង់ឲ្យព្រះពោធិសត្វជ្រើសរើសពរ ។

ព្រះមហាសត្វក៏ទ្រង់ជ្រើសរើសពរទាំង ៨ ប្រការនេះ គឺសូមឲ្យព្រះ បិតាតាំងខ្ញុំឲ្យតាំងនៅក្នុងរាជសម្បត្តិ ១ សូមឲ្យខ្ញុំដោះអ្នកទោសដែលត្រូវ ប្រហារ ឲ្យផុតចាកការប្រហារ ១ សូមឲ្យខ្ញុំបានជាទីពឹងរបស់សព្វសត្វទាំង ឡាយ ១ សូមឲ្យខ្ញុំកុំបីកន្លងល្មើសក្នុងកិរិយារបស់អ្នកដទៃ កុំបីលុះអំណាច របស់ស្ត្រី ១ សូមឲ្យឱរសរបស់ខ្ញុំមានអាយុវែង ១ សូមឲ្យទេយ្យធម៌ មាន បាយ និងទឹកជាដើមមានច្រើន ១ សូមឲ្យខ្ញុំមានចិត្តថ្លាផង់ បរិច្ចាគទេយ្យធម៌

មិនចេះអស់ ១ សូមឲ្យខ្ញុំបរិច្ចាគមហាទានយ៉ាងនេះ លុះអស់ជីវិត ហើយសូមឲ្យទៅកាន់ទេវលោក ត្រឡប់អំពីទេវលោក មកកើតក្នុងមនុស្សលោកនេះ សម្រេចសព្វញ្ញុតញ្ញាណ ១ ។

សក្កទេវរាជត្រាស់ថា មិនយូរមិនឆាប់ ព្រះបាទសញ្ជយមហារាជជាបិតានឹងយាងមកក្នុងទីនេះ ទទួលព្រះអង្គឲ្យតាំងនៅក្នុងរាជសម្បត្តិ ។ ម្យ៉ាងទៀត សេចក្តីប្រាថ្នារបស់ព្រះអង្គទាំងអស់ នឹងដល់ទីបំផុត ទ្រង់កុំព្រះវិតក្កថ្វីឡើយ សូមទ្រង់កុំប្រមាទ កាលប្រទានឱវាទហើយ ក៏ត្រឡប់ទៅកាន់ទេវលោកមួយរំពេច ។ ព្រះពោធិសត្វ និងព្រះនាងមទ្រីទេវី ទ្រង់ត្រេកអរក្នុងព្រះហឫទ័យ ប្រថាប់នៅនាអាស្រមដែលសក្កៈប្រទាន ។

កាលជូជក នាំកុមារទាំងពីរទៅ ពួកទេវតាបានធ្វើការរក្សា ។ រាល់ៗថ្ងៃ ទេពធីតាមួយអង្គមកក្នុងពេលរាត្រី កាឡាខ្លួនជានាងមទ្រីមើលថែកុមារទាំងពីរ ។

ជូជកនោះ ត្រូវទេវតាបណ្តាលចិត្ត គិតថា ទៅកាន់កាលិង្គរដ្ឋ តែបែរជាទៅកាន់ជេតុត្តរនគរអស់កាលកន្លះខែ ។ ព្រះរាជាប្រថាប់គង់ត្រង់ទីវិនិច្ឆ័យ ទតឃើញកុមារទាំងពីរ និងព្រាហ្មណ៍ត្រង់លានព្រះរាជវាំង ទ្រង់ស្គាល់ ទើបត្រាស់ឲ្យហៅកុមារ និងព្រាហ្មណ៍មកគាល់ ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះ ទ្រង់ក៏ព្រះរាជទានទ្រព្យ តាមចំនួនដែលព្រះពោធិសត្វត្រង់កាត់ថ្លៃដើម្បីលោះកុមារទាំងពីរ ឲ្យកុមារទាំងពីរស្រេចស្រង់ សោយព្រះក្រយាហារ ទ្រង់តាក់តែងដោយគ្រឿងអលង្ការសព្វយ៉ាង ព្រះរាជាឲ្យជាលីប្រថាប់លើភ្លៅ

ព្រះនាងផុស្សតី ឲ្យកណ្ហាជិនា ប្រថាប់លើភ្លៅ ទ្រង់ស្តាប់ការប្រព្រឹត្តទៅរបស់ព្រះពោធិសត្វ និងព្រះនាងមទ្រីរាជបុត្រី ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់សង្វេគថា ឱ ! អញបានទម្លាយសេចក្តីល្អហើយ រំពេចនោះឯង ទ្រង់រៀបចំកងទ័ពចំនួន ១២ អក្ខោភិនី ទ្រង់បែរមុខទៅកាន់ភ្នំវង្កត មួយអន្លើដោយព្រះនាងផុស្សតីទេវី និងកុមារទាំងពីរ ទ្រង់ដល់ដោយលំដាប់ ហើយទៅរកព្រះរាជឱរស និងព្រះសុណិសា ។

ព្រះវេស្សន្តរទតឃើញព្រះបិយបុត្រ មិនអាចអត់សង្កត់សេចក្តីសោកបាន ទ្រង់ដួលសន្លប់ត្រង់សាលាស្លឹកនោះឯង ព្រះនាងមទ្រី ព្រះជនក ព្រះជននី និងអមាត្យ ៦ ម៉ឺនដែលជាសហជាត ក៏សន្លប់ទាំងអស់ បណ្តាបុគ្គលឃើញសេចក្តីករុណានោះ សូម្បីតែម្នាក់ មិនអាចតម្កល់នៅដោយភាពជារបស់ខ្លួនបាន ។ អាស្រមបទទាំងមូល ហាក់ដូចជាព្រៃរាំងភ្នំដែលត្រូវយុគន្ធរវាតបោកបក់ ដូច្នោះ ។

សក្កទេវរាជ ដើម្បីឲ្យក្សត្រ និងអមាត្យភ្ញាក់ពីសន្លប់ ទើបបណ្តាលភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ចុះមក បុគ្គលប្រាថ្នាចង់សើម ក៏សើម ដូចភ្លៀងធ្លាក់ក្នុងស្លឹកឈូក ហើយក៏ក្លាយជាទឹកហូរទៅ ។ ជនទាំងអស់ក៏ដឹងខ្លួន ។ ក្នុងកាលនោះ ភាពអស្ចារ្យ មានផែនដីកម្រើកជាដើម មានប្រការដូចពោលហើយខាងដើម ក៏បានប្រាកដ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលពួកជនមកប្រជុំគ្នា ក្នុងសម្នាក់នៃមាតា និងបិតា ក្នុងព្រៃធំ
ក៏ខ្សឹកខ្សួលដោយសេចក្តីករុណា ចរចា សួរសុខ និងទុក្ខគ្នា ។

កាលមហាជន ចូលទៅរកជនទាំងពីរ ជាអ្នកធ្ងន់ដោយហិរិ និង ឱត្តប្បៈ កាលនោះ ប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿង ប្រដាប់ ក៏កម្រើកញាប់ញ័រ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ការុញ្ញំ បរិទេវន្តេ** សេចក្តីថា កាលជនមក ព្រមគ្នាទាំងអស់ មានព្រះមាតាបិតាជាដើម ទ្រង់សោកខ្សឹកខ្សួលគួរករុណា ។ បទថា **សល្លបន្តេ សុខំ ទុក្ខំ** សេចក្តីថា ត្រាស់សួរដល់សុខ និងទុក្ខ ហើយ សន្ទនាដោយបដិសណ្ឋារៈ ។ បទថា **ហិរោត្តប្បេន គរុនា ឧភិន្នំ** សេចក្តីថា តថាគតមិនមានចិត្តក្រោធខឹងថា ជនទាំងនេះ បណ្តេញអញដែលមិនមាន កំហុស ដែលតាំងនៅក្នុងធម៌ ព្រោះស្តាប់ពាក្យអ្នកសិវិ ទើបចូលគាល់ព្រះ ជនក ព្រះជននី ដោយហិរិ និងឱត្តប្បៈ ដែលកើតឡើងដោយសេចក្តីគោរព ក្នុងធម៌ ក្នុងជនទាំងពីរ គឺព្រះជនក ព្រះជននីនេះ ដោយហេតុនោះ ទើប មហាប្រឹថពីញាប់ញ័រក្នុងកាលនោះ ដោយតេជះនៃធម៌របស់តថាគត ។

លំដាប់នោះ ព្រះបាទសញ្ជយមហារាជ ទ្រង់ឲ្យព្រះមហាសត្វអត់ទោស ឲ្យហើយ ទ្រង់ប្រគល់រាជសម្បត្តិឲ្យគ្រប់គ្រងក្នុងខណៈនោះឯង ទ្រង់ឲ្យព្រះ មហាសត្វដាក់ព្រះកេសា និងព្រះមស្សុជាដើម ឲ្យស្រេចស្រង់ ទ្រង់អភិសេក ព្រះមហាសត្វដែលតាក់តែងហើយដោយសព្វាភរណៈ ល្អដូចទេវរាជ ក្នុង រាជសម្បត្តិ មួយអន្លើដោយព្រះនាងមទ្រី រំពេចនោះ ទ្រង់ក្រោកឡើង មួយ អន្លើដោយសេនាប្រកបដោយអង្គ ៤ ដែលមានប្រមាណ ១២ អក្ខោភិនី ចោមរោមព្រះរាជឱរស ត្រាស់ឲ្យធ្វើផ្លូវ ៦០ យោជន៍ តាំងអំពីភ្នំវង្កត របួត

ដល់ជេតុត្តរនគរ យាងចូលកាន់ព្រះនគរដោយសួស្តីអស់កាល ២ ខែ ។

មហាជនបានសោយបីតិសោមនស្សជាច្រើន នាំគ្នាលើកសំពត់ជាដើមគ្រវីទៅមក គ្រាប់ប្រគំនន្ទភេរីពេញព្រះនគរ ។ សត្វទាំងពួង ដោយហោចឆ្មាដែលនៅក្នុងចំណង ក៏បានផុតចាកចំណង ក្នុងថ្ងៃយាងចូលកាន់នគរនោះឯង ក្នុងពេលទៀបភ្លឺ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ស្អែកនេះ ពេលទៀបភ្លឺយាចកទាំងឡាយបានដំណឹងថា អញត្រឡប់មកវិញ នឹងនាំគ្នាមក អញនឹងឲ្យអ្វីដល់យាចកទាំងនោះ ។

ក្នុងខណៈនោះ អាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅ សក្កទេវរាជ ទ្រង់ពិចារណាជ្រាបហេតុនោះហើយ រំពេចនោះឯង ទ្រង់បណ្តាលឲ្យភ្លៀងកែវ ៧ ប្រការ ដូចគ្នានឹងភ្លៀងព្រិល ធ្លាក់ចុះពេញបរិវេណខាងមុខនិងខាងក្រោយព្រះរាជនិវេសន៍ កម្ពស់ត្រឹមជង្គង់ ។ ក្នុងនគរទាំងមូលក៏ធ្លាក់ត្រឹមជង្គង់ដូចគ្នា ដូចព្រះមានព្រះភាគត្រាស់ថា

ម្យ៉ាងទៀត តថាគតចេញអំពីព្រៃធំជាមួយនឹងពួកញាតិ ចូលទៅកាន់បុរី គួរជាទីសប្បាយឈ្មោះជេតុត្តរ ដែលជានគរដ៏ឧត្តម ក្នុងកាលនោះ មហាមេឃ ក៏បង្អុរចុះនូវភ្លៀងជាវិការនៃកែវ ៧ ប្រការ ប្រឹថពីដែលមានភ្នំសិនេរុ និងព្រៃ ជាគ្រឿងប្រដាប់ ក៏កម្រើក ។ ប្រឹថពីមិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហាប្រឹថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត ដូច្នេះ ។

កាលភ្លៀងកែវ ៧ ប្រការធ្លាក់យ៉ាងនេះ ស្អែកឡើងព្រះមហាសត្វទ្រង់ព្រះតម្រិះថា ទ្រព្យដែលធ្លាក់លើផែនដីត្រង់មុខផ្ទះ និងក្រោយផ្ទះរបស់បុគ្គលណា ចូរជារបស់ត្រកូលនោះឯង ហើយទ្រង់ឲ្យនាំចំណែកដ៏សេសមកដាក់ក្នុងឃ្លាំង រួមជាមួយទ្រព្យដែលមានពីមុន ក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គហើយ ទ្រង់បរិច្ចាគមហាទាន ។

បទថា **អចេតនាយំ បថវី** បានដល់ ប្រឹថពីនេះធំ ប្រាសចាកចិត្តតែទេវតាប្រកបដោយចិត្ត ។ បទថា **អវិញ្ញាយ សុខំ ទុក្ខំ** បានដល់ មិនដឹងសុខ មិនដឹងទុក្ខ ព្រោះមិនមានចិត្តនោះឯង ។ កាលមានការប្រកបបច្ច័យដែលជាសុខជាទុក្ខ ប្រឹថពីនោះ ក៏មិនបានសោយបច្ច័យដែលជាសុខ ជាទុក្ខនោះ ។ បទថា **សាបិ ទានពលា មយ្ហំ** បានដល់ មហាប្រឹថពីនោះក៏យ៉ាងនោះ ព្រោះហេតុនៃបុញ្ញានុភាពនៃទានរបស់តថាគត ។ បទថា **សត្តក្ខត្តុំ បកម្បថ** សេចក្តីថា មហាប្រឹថពីញាប់ញ័រអស់ ៧ ដង ក្នុងឋានៈទាំងនេះ គឺក្នុងកាលតថាគតមានអាយុបាន ៨ ឆ្នាំ កើតអជ្ឈាស្រ័យក្នុងការឲ្យថា អញគប្បីឲ្យសូម្បីបេះដូង និងសាច់ជាដើមដល់យាចកទាំងឡាយ ១ ក្នុងកាលឲ្យមង្គលហត្ថី ១ ក្នុងការឲ្យធំ កាលត្រូវបណ្តេញ ១ ក្នុងការឲ្យបុត្រ ១ ក្នុងការឲ្យភរិយា ១ ក្នុងកាលពួកញាតិមកជួបជុំគ្នា ត្រង់ភ្នំវង្កត ១ ក្នុងកាលភ្លៀងរតនៈធ្លាក់ ក្នុងថ្ងៃចូលព្រះនគរ ១ ។ ព្រះមហាសត្វ ទ្រង់បរិច្ចាគមហាទានដរាបដល់អស់ព្រះជន្មាយុ ដែលជាហេតុប្រាកដនូវភាពអស្ចារ្យ មានមហាប្រឹថពីកម្រើកអស់ ៧ ដងជាដើម ក្នុងមួយអត្តភាពប៉ុណ្ណោះ កាលទ្រង់

សោយទិវង្គត បានទៅកើតក្នុងស្ថានសួគ៌ ជាន់តុសិត ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លំដាប់នោះ ព្រះបាទវេស្សន្តរជាក្សត្រ ប្រកបដោយប្រាជ្ញា ទ្រង់ឲ្យទាន លុះបែកធ្លាយរាងកាយនោះទៅ ក៏បានស្តេចទៅកើតក្នុងស្ថានសួគ៌ទេវលោក ដូច្នេះ ។

ជូជកក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ នាងអមិត្តតាបនា ក្នុងកាលនោះ បានមកជានាងចិញ្ចមាណវិកា ក្នុងកាលឥឡូវនេះ ចេតបុត្ត ក្នុងកាលនោះ បានមកជាឆន្ន ក្នុងកាលឥឡូវនេះ អច្ចុតតាបស ក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរ ក្នុងកាលឥឡូវនេះ សក្កទេវរាជ ក្នុងកាលនោះ បានមកជាព្រះអនុរុទ្ធ ក្នុងកាលឥឡូវនេះ ព្រះនាងមទ្រី ក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ ជាលីកុមារ ក្នុងកាលនោះ បានមកជារាហុល ក្នុងកាលឥឡូវនេះ កណ្ហាជិនា ក្នុងកាលនោះ បានមកជាឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ ព្រះមាតាបិតា ក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ បរិស័ទដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ព្រះបាទវេស្សន្តរ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងវេស្សន្តរចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសតាមសមគួរ ដោយន័យដូចពោលហើយខាងដើមនោះឯង គប្បីប្រកាសគុណានុភាពនៃព្រះមហាបុរសក្នុងចរិយានេះ ដែលជាហេតុប្រាកដនូវភាពអស្ចារ្យច្រើនយ៉ាង

មានមហាប្រឹថពីញាប់ញ័រជាដើមអស់វារៈ ៧ ដងយ៉ាងនេះ គឺកាលព្រះមហាសត្វ នៅក្នុងព្រះឧទរ ព្រះជននីចាញ់គភ៌មានបំណងនឹងលះទ្រព្យ ៦ សែនរាល់ៗ ថ្ងៃ ។ ម្យ៉ាងទៀត កាលទ្រង់ឲ្យទាន ព្រះរាជទ្រព្យក៏មិនអស់ទៅ ក្នុងខណៈប្រសូតនោះឯង ទ្រង់លាព្រះហស្តហើយបន្លឺព្រះវាចាថា ខ្ញុំនឹងឲ្យទាន តើមានទ្រព្យដែរឬទេ លុះមានព្រះជន្ម ៤-៥ ឆ្នាំ ទ្រង់មានបំណងនឹងឲ្យគ្រឿងប្រដាប់របស់ទ្រង់ ដល់មេដោះទាំងឡាយ ដែលជាហេតុនៃភាពជាអគ្គបុគ្គល លុះព្រះជន្មបាន ៨ ឆ្នាំ ទ្រង់មានបំណងនឹងឲ្យអវយវៈរបស់ព្រះអង្គ មានបេះដូង និងសាច់ជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វីដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។

## អដ្ឋកថាវេស្សន្តរចរិយា ចប់

# សុត្តន្តបិដក

## សសបណ្ឌិតចរិយាទី ១០

[ ១០ ] ចរិយាដទៃទៀត កាលតថាគតកើតជាទន្សាយ ត្រាច់ទៅក្នុងព្រៃ មានស្មៅ ស្លឹកឈើ បន្លែ និងផ្លែឈើជាអាហារ វៀរចាកការបៀតបៀនសត្វដទៃ ។ កាលនោះ ស្វា ចចក ភេ និងតថាគត ព្រមព្រៀងនៅជាមួយគ្នា ទាំងព្រឹកទាំងល្ងាច ។ តថាគតប្រៀនប្រដៅសម្លាញ់ទាំង ៣ នោះ ដែលមានកិរិយាល្អ និងកិរិយាអាក្រក់ថា អ្នកទាំងឡាយ ចូរវៀរនូវអំពើអាក្រក់ ហើយចូរតម្កល់ខ្ជាប់ក្នុងអំពើល្អ ។ តថាគតឃើញព្រះចន្ទពេញវង់ ក្នុងថ្ងៃឧបោសថក៏ប្រាប់ដល់សម្លាញ់ទាំងនុ៎ះ ក្នុងទីនោះថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ។ អ្នកទាំងឡាយ ចូរចាត់ចែងទាន ដើម្បីឲ្យដល់ទក្ខិណេយ្យបុគ្គល លុះបានឲ្យទានដល់ទក្ខិណេយ្យបុគ្គលរួចហើយ ចូររក្សាឧបោសថ ។ សត្វជាសម្លាញ់នោះ បានទទួលពាក្យតថាគតថា សាធុ ហើយចាត់ចែងទានតាមសេចក្តីអង់អាច តាមកម្លាំង ហើយស្វែងរកទក្ខិ-ណេយ្យបុគ្គល ។ ឯតថាគត ដេកគិតនូវទានដែលសមគួរដល់ទក្ខិណេយ្យបុគ្គលថា បើអញបានទក្ខិណេយ្យបុគ្គល តើអញនឹងឲ្យទានដូចម្តេច ។ ល្ង និងសណ្តែកបាយនៃអញគ្មានទេ សណ្តែករាជមាស អង្ករ និងខ្លាញ់នៃអញក៏គ្មានដែរ អញញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយស្មៅ អញមិនអាចនឹងឲ្យស្មៅបានទេ ដូច្នេះ បើមានទក្ខិណេយ្យបុគ្គលណាមួយ ដើរមកក្នុងសម្នាក់អញដើម្បី

កិច្ចា អញនឹងឲ្យខ្លួនជារបស់ខ្លួន នឹងមិនឲ្យទក្ខិណេយ្យបុគ្គលនោះ មានដៃទទេទៅវិញឡើយ ព្រះឥន្ទដឹងនូវសេចក្តីត្រិះរិះរបស់តថាគត ហើយ ក្លែងភេទជាព្រាហ្មណ៍ ចូលមកកាន់លំនៅតថាគត ដើម្បីល្បងទានរបស់តថាគត ។ តថាគតឃើញឥន្ទព្រាហ្មណ៍នោះហើយ ក៏ត្រេកអរ បានពោលពាក្យនេះថា ពេញជាល្អមែន អ្នកមកក្នុងសម្នាក់ខ្ញុំ ព្រោះហេតុតែអាហារ ។ ក្នុងថ្ងៃនេះ ខ្ញុំនឹងឲ្យនូវទានដ៏ប្រសើរដល់អ្នក ជាទានដែលខ្ញុំមិនធ្លាប់ឲ្យឡើយ អ្នកប្រកបដោយគុណ គឺសីល ការបៀតបៀនសត្វដទៃ មិនគួរដល់អ្នកឡើយ អ្នកចូរមក ចូរទៅនាំយកឧសផ្សេងៗ មកបង្កាត់ភ្លើងឲ្យឆេះឡើង ខ្ញុំនឹងដុតខ្លួន អ្នកនឹងបានបរិភោគសាច់ឆ្អិន ។ ឥន្ទព្រាហ្មណ៍នោះ មានចិត្តត្រេកអរ ទទួលថា សាធុ ហើយទៅនាំឧសផ្សេងៗ យកមកធ្វើជើងថ្ករយ៉ាងធំ ហើយធ្វើឲ្យមានផ្ទៃពេញដោយរងើកភ្លើង ។ គំនរភ្លើងធំនោះ ឆេះធាបយ៉ាងណា ឥន្ទព្រាហ្មណ៍នោះ ក៏ដុតភ្លើងឆេះសន្ធោក្នុងទីនោះ យ៉ាងនោះ តថាគតរលាស់ខ្លួនដែលប្រឡាក់ដោយធូលី ហើយអង្គុយក្នុងទីដ៏សមគួរនោះ ។ កាលណា គំនរឧសធំត្រូវភ្លើងឆេះ ឮសូរសំឡេង ធុំ ធុំ កាលនោះ តថាគតលោតទម្លាក់ខ្លួនទៅក្នុងកណ្តាលចន្លោះអណ្តាតភ្លើង ធម្មតាទឹកត្រជាក់ដែលបុគ្គលណាមួយចុះទៅហើយ រមែងញុំាងសេចក្តីក្រវល់ក្រវាយក្តៅក្រហាយ ឲ្យស្ងប់រម្ងាប់បាន ញុំាងសេចក្តីត្រេកអរ និងបីតិឲ្យ

កើតឡើង យ៉ាងណា ។ កាលតថាគតចូលទៅក្នុងភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ ក៏ញ៉ាំងសេចក្ដីក្រវល់ក្រវាយទាំងអស់ ឲ្យស្ងប់រម្ងាប់ ដូចជាទឹកត្រជាក់ដូច្នោះឯង ។ តថាគត បានឲ្យសម្បុរថ្ងៃ ស្បែក សាច់ សរសៃ ឆ្អឹង បេះដូង និងកាយទាំងមូល មិនឲ្យមានសេសសល់ដល់ព្រាហ្មណ៍ ។

**សសបណ្ឌិតចរិយាទី ១០ ចប់**

## ឧទ្ទាននៃចរិយានោះ

អកិត្តិចរិយា ១ សង្ខព្រាហ្មណចរិយា ១ ស្ដេចក្នុងដែនកុរុព្រះនាមធនញ្ជ័យ ( កុរុធម្មចរិយា ) ១ មហាសុទស្សនរាជ ( សុទស្សនចរិយា ) ១ មហាគោវិន្ទចរិយា ១ នេមិរាជចរិយា ១ ចន្ទកុមារចរិយា ១ សិវិរាជចរិយា ១ វេស្សន្តរចរិយា ១ សសបណ្ឌិតចរិយា ១ បុគ្គលណាបានឲ្យទានដ៏ប្រសើរទាំងឡាយនោះ ក្នុងកាលនោះ បុគ្គលនោះ គឺតថាគតហ្នឹងឯង ។ ការបរិច្ចាគនូវទេយ្យធម៌ទាំងឡាយនុ៎ះ ជាបរិក្ខារនៃទាន ការបរិច្ចាគនូវទានដ៏ប្រសើរទាំងឡាយនុ៎ះ ជាបារមីនៃទាន ( ហេតុនោះ ) បានជាតថាគតឲ្យនូវជីវិតដល់យាចក ហើយបំពេញនូវបារមីនេះ ។ តថាគតឃើញយាចកចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួនជារបស់ខ្លួន បុគ្គលអ្នកឲ្យទាន ស្មើដោយទានរបស់តថាគត មិនមានឡើយ នេះជាទានបារមីរបស់តថាគត ។ **ទានបារមី ចប់** ។

# អដ្ឋកថា

## សសបណ្ឌិតចរិយា

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសសបណ្ឌិតចរិយាទី ១០ ដូចតទៅនេះ បទថា **យទា ហោមិ សសកោ** សេចក្តីថា ម្នាលសារីបុត្ត តថាគត ត្រាច់ស្វែងរកពោធិញ្ញាណក្នុងកាលតថាគតជាសសបណ្ឌិត ។ ពិតហើយ ព្រះពោធិសត្វទាំងឡាយ ទោះបីដល់នូវភាពជាអ្នកជំនាញក្នុងរឿងកម្ម ក៏គង់កើតក្នុងកំណើតតិរច្ឆាន ដើម្បីអនុគ្រោះសត្វតិរច្ឆានបែបនោះ ។ បទថា **បវនចារកោ** បានដល់ ត្រាច់ទៅក្នុងព្រៃធំ ។ ឈ្មោះថា **តិណបណ្ណសាកផលភក្ខោ** ព្រោះមានស្មៅ មានស្លឹកល្វាំងជាដើម ស្លឹកឈើត្រង់គុម្ពឈើបន្លែណាមួយ និងផ្លែឈើ ដែលជ្រុះអំពីដើមឈើជាភក្ខា ។ បទថា **បរហេឋនវិវជ្ជិតោ** បានដល់ វៀរចាកការបៀតបៀនអ្នកដទៃ ។ បទថា **សុត្តពោតោ ច** ស្មើគ្នានឹង **ឧទ្ទពោតោ ច** ( កូនកេ ) ។ បទថា **អហំ តទា** សេចក្តីថា ក្នុងកាលតថាគតជាទន្សាយ តថាគតទូន្មាននូវសម្លាញ់ មានស្វាជាដើម ។

បទថា **កិរិយេ កល្យាណបាបកេ** បានដល់ ក្នុងកុសលកម្ម និងអកុសលកម្ម ។ បទថា **បាបានិ** ជាបទសម្តែងអាការប្រៀនប្រដៅ ។ ក្នុងបទទាំងនោះ បទថា **បាបានិ បរិវជ្ជេថ** សេចក្តីថា អ្នកទាំងឡាយ ចូរវៀរបាបទាំងនេះ គឺការសម្លាប់សត្វ ។បេ។ មិច្ឆាទិដ្ឋិ ។ បទថា **កល្យាណេ អភិនិវិស្សថ** បានដល់ កម្មល្អ គឺទាន សីល ។បេ។ និងទិដ្ឋុជុកម្ម ។ អ្នក

ទាំងឡាយ ចូរតម្កល់កាយវាចាចិត្តរបស់ខ្លួនក្នុងកល្យាណកម្មនេះ ឲ្យនៅចំពោះមុខ អធិប្បាយថា ចូរបដិបត្តិ កល្យាណបដិបត្តិនេះចុះ ។

ព្រះមហាសត្វ ទោះបីកើតក្នុងកំណើតតិរច្ឆានយ៉ាងនេះ ក៏នៅជាកល្យាណមិត្ត ព្រោះជាអ្នកដល់ព្រមដោយញាណ ទ្រង់សម្តែងធម៌ ដោយការឲ្យឱវាទដល់សត្វទាំង ៣ នោះ ដែលចូលទៅរកតាមកាលវេលា ។ សត្វទាំង ៣ នោះ ទទួលឱវាទរបស់ព្រះមហាសត្វហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន កាលកន្លងទៅយ៉ាងនេះ ព្រះពោធិសត្វសម្លឹងមើលអាកាស ឃើញព្រះចន្ទពេញវង់ ទើបទូន្មានថា ចូរពួកអ្នករក្សាឧបោសថ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតឃើញព្រះចន្ទពេញវង់ ក្នុងថ្ងៃឧបោសថ ក៏ប្រាប់ដល់
សម្លាញ់ទុំ ក្នុងទីនោះថា ថ្ងៃនេះជាថ្ងៃឧបោសថ ។ អ្នកទាំងឡាយ
ចូរចាត់ចែងទាន ដើម្បីឲ្យដល់ទក្ខិណេយ្យបុគ្គល លុះបានឲ្យទាន
ដល់ទក្ខិណេយ្យបុគ្គល រួចហើយ ចូររក្សាឧបោសថ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ចន្ទំ ទិស្វា ឆ បូរិតំ** សេចក្តីថា តថាគតឃើញព្រះចន្ទ ខ្វះបន្តិចបន្តួចពេញវង់ ក្នុងថ្ងៃ ១៤ កើត តែកាលរាត្រីអស់ហើយ ជាពេលថ្ងៃរះ ក្នុងថ្ងៃឧបោសថ ១៥ កើត ទើបប្រាប់ដល់សម្លាញ់ទាំងឡាយរបស់តថាគត មានស្វាជាដើមទាំងនោះថា ថ្ងៃនេះជាថ្ងៃឧបោសថ ។ ព្រោះហេតុនោះ គប្បីប្រកបបទថា **អាចិក្ខឹ** ( ទើបប្រាប់ ) វិធីបដិបត្តិក្នុងថ្ងៃឧបោសថនោះ ដោយបទជាដើមថា **ទានានិ បដិយាទេថ** ។ ក្នុងបទទាំង

នោះ បទថា **ធានាធិ** បានដល់ ទេយ្យធម៌ទាំងឡាយ ។ បទថា **បដិយា-ទេថ** បានដល់ ចូរត្រៀមតាមសតិ និងតាមកម្លាំង ។ បទថា **ធាតវេ** គឺជា **ធាតុំ** ( ដើម្បីឲ្យ ) ។ បទថា **ឧបវស្សថ** លោកសម្ដែងថា ចូរធ្វើឧបោសថកម្ម ចូររក្សាឧបោសថសីល ការតាំងនៅក្នុងសីលហើយឲ្យទាន រមែងមានផល ច្រើន ព្រោះហេតុនោះ កាលយាចកមកដល់ គប្បីឲ្យអំពីអាហារដែលពួក អ្នកគួរបរិភោគហើយ សឹមបរិភោគឯង ។

បទថា **សាធុ** នោះ សេចក្ដីថា សត្វទាំងនោះទទួលឱវាទរបស់ព្រះ ពោធិសត្វដោយសិរសា គឺត្បូង ហើយអធិដ្ឋានអង្គឧបោសថ ។ ក្នុងសត្វទាំង នោះ កូនកេទៅកាន់ឆ្នេរស្ទឹងអំពីព្រលឹមដោយគិតថា អញនឹងរកអាហារ ។ កាលនោះ ព្រានសន្ទូចម្នាក់បានត្រីឆ្ពិន ៧ យកវល្លិដោតហើយ កប់ខ្សាច់ ត្រង់មាត់ស្ទឹង ហើយចេញទៅរកត្រីបន្តទៀត ធ្លាក់ចុះទៅខាងក្រោមក្រសែ ទឹក ។ កូនកេហិតក្លិនត្រី កាយខ្សាច់ឃើញត្រី ទើបនាំចេញ ប្រកាស ៣ ដងថា ត្រីនេះមានម្ចាស់ដែរឬទេ កាលមិនឃើញម្ចាស់ ក៏ពាំត្រង់វល្លិ ដាក់ ត្រង់គុម្ពឈើដែលជាលំនៅរបស់ខ្លួន គិតថា អញនឹងបរិភោគក្នុងកាលដែល គួរ ។ ដេកពិចារណាដល់សីលរបស់ខ្លួន ។ ចចក ក៏ត្រាច់ស្វែងរកអាហារ ឃើញសាច់អាំង ២ ចង្កាក់ ទន្សង ១ ទឹកដោះជូរ ១ ដប ត្រង់ខ្ទមរបស់ អ្នកចាំស្រែមួយកន្លែង ប្រកាស ៣ ដងថា អាហារទាំងនេះ មានម្ចាស់ដែរឬ ទេ កាលមិនឃើញម្ចាស់ ក៏យកខ្សែដែលចងដប ទឹកដោះជូរពាក់ត្រង់ក ពាំ សាច់អាំង និងទន្សងមកដាក់ត្រង់គុម្ពឈើ ដែលជាលំនៅរបស់ខ្លួន គិតថា នឹង

បរិភោគក្នុងកាលដ៏សមគួរ ដេកពិចារណាដល់សីលរបស់ខ្លួន ចំណែកស្វា ចូលព្រៃ នាំយកផ្លែស្វាយមកដាក់ត្រង់គុម្ពឈើ ដែលជាលំនៅរបស់ខ្លួន គិតថា នឹងបរិភោគក្នុងពេលដែលសមគួរ ដេកពិចារណាដល់សីលរបស់ខ្លួន ។ សត្វទាំង ៣ គិតថា ឱ ! យាចក គប្បីមកក្នុងទីនេះ មានដែរឬហ្ន៎ សមដូច ព្រះមានព្រះភាគត្រាស់ថា

សត្វជាសម្លាញ់នោះ បានទទួលពាក្យតថាគតថា សាធុ ហើយ ចាត់ចែងទានតាមសេចក្តីអង់អាច តាមកម្លាំង ហើយស្វែងរក ទក្ខិណេយ្យបុគ្គល ដូច្នេះ ។

ចំណែកព្រះពោធិសត្វ ចេញពីលំនៅក្នុងកាលដ៏សមគួរ គិតថា អញ នឹងស៊ីស្មៅ មានស្បូវភ្លាំងជាដើម ដេកត្រង់គុម្ពឈើដែលជាលំនៅរបស់ខ្លួន គិតថា បើយាចកទាំងឡាយមករកអញ មិនអាចបរិភោគស្មៅបាន អញមិន មានល្ង និងអង្ករជាដើម បើយាចកមករកអញ អញចិញ្ចឹមជីវិតដោយស្មៅ អញនឹងឲ្យសាច់ក្នុងរាងកាយរបស់ខ្លួន ដូចព្រះមានព្រះភាគត្រាស់ថា

ឯតថាគត ដេកគិតនូវទានដែលសមគួរដល់ទក្ខិណេយ្យបុគ្គលថា បើអញបានទក្ខិណេយ្យបុគ្គល តើអញនឹងឲ្យទានដូចម្តេច ។ ល្ង និងសណ្តែកបាយនៃអញគ្មានទេ សណ្តែករាជមាស អង្ករ និង ខ្លាញ់នៃអញក៏គ្មានដែរ អញញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយ ស្មៅ អញមិនអាចនឹងឲ្យស្មៅបានទេ ដូច្នេះ បើមានទក្ខិណេយ្យ-បុគ្គលណាមួយ ដើរមកក្នុងសម្នាក់អញដើម្បីភិក្ខា អញនឹងឲ្យខ្លួន

ជារបស់ខ្លួន នឹងមិនឲ្យទក្ខិណេយ្យបុគ្គលនោះ មានដៃទទេទៅវិញ ឡើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទានំ ទក្ខិណានុច្ឆវំ** សេចក្ដីថា តថាគតគិតដល់ទានដែលសមគួរ ដោយជាគ្រឿងទក្ខិណា គឺទេយ្យធម៌ដែលគួរឲ្យដល់ទក្ខិណេយ្យបុគ្គល ។ បទថា **យទិហំ លភេ** សេចក្ដីថា បើថ្ងៃនេះ អញគប្បីបានទក្ខិណេយ្យបុគ្គលត្រឹមតែម្នាក់ ។ បទថា **កឹ មេ ទានំ ភវិស្សតិ** បានដល់ អាត្មាអញនឹងយកអ្វីឲ្យជាទាន ។ បទថា **ន សន្តា តិលា ទានវេ** សេចក្ដីថា បើអាត្មាអញមិនមានល្ង និងសណ្ដែកបាយជាដើម ដើម្បីឲ្យដល់ទក្ខិណេយ្យបុគ្គល អញមិនអាចឲ្យស្មៅ ដែលជាអាហាររបស់អញដល់ទក្ខិណេយ្យបុគ្គលបាន ។ បទថា **ឧដ្ឋាហំ សកមត្តានំ** សេចក្ដីថា ប្រយោជន៍អ្វីដែលអញរវល់គិតក្នុងទេយ្យធម៌ រាងកាយរបស់អញនេះឯង មិនមានទោស សមគួរជាអាហារបរិភោគរបស់អ្នកដទៃផង រកបានងាយផង ព្រោះមិនចាំបាច់ពឹងអ្នកដទៃ បើទក្ខិណេយ្យបុគ្គលម្នាក់មករកអញ អញនឹងឲ្យរាងកាយរបស់ខ្លួននេះដល់បុគ្គលនោះ ។ កាលបើដូច្នោះ បុគ្គលណា មករកអញ ក៏នឹងមិនទៅវិញទទេ គឺនឹងមិនមានដៃទទេត្រឡប់ទៅ ។

កាលព្រះមហាបុរសបរិវិតក្កដល់សភាវៈតាមសេចក្ដីពិតយ៉ាងនេះហើយ ដោយអានុភាពនៃបរិវិតក្កនោះ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កៈ ក៏សម្ដែងអាការក្ដៅ ។ សក្កទេវរាជពិចារណាឃើញហេតុនេះហើយ ទើបទ្រង់ព្រះតម្រិះថា អញនឹងសាកល្បងស្ដេចទន្សាយ ទើបកាឡាខ្លួនជាព្រាហ្មណ៍ ទៅកាន់

លំនៅរបស់គេមុន ហើយប្រថាប់ឈរ ។ គេសួរថា នែព្រាហ្មណ៍ អ្នកឈរដើម្បីអ្វី សក្កទេវរាជឆ្លើយថា បើខ្ញុំបានអាហារណាមួយ ខ្ញុំនឹងរក្សាឧបោសថបំពេញសមណធម៌ ។ គេឆ្លើយថា សាធុ ខ្ញុំនឹងឲ្យអាហារដល់អ្នក ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសសបណ្ឌិតជាតក ) ថា

ខ្ញុំមានត្រីឆ្អិន ៧ ដែលព្រានសន្ទូចស្រង់ឡើងពីទឹកដាក់លើគោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

ព្រាហ្មណ៍ពោលថា ចូរអ្នកបង្អង់សិនចុះ ខ្ញុំនឹងដឹងក្នុងកាលខាងក្រោយ ទើបចូលទៅរកចចក និងស្វាដោយទំនងយ៉ាងនោះ សត្វទាំងនោះ ក៏ទទួលដោយទេយ្យធម៌ដែលខ្លួនមាន ព្រាហ្មណ៍ពោលថា ចូរអ្នកបង្អង់សិន ខ្ញុំនឹងដឹងខាងក្រោយ ។ ដូចព្រះមានព្រះភាគត្រាស់ថា

កត្តរបស់អ្នករក្សាស្រែឯណោះ គឺសាច់ពីរជ្រនួចផង ទន្សងមួយផង ដបទធិមួយផង ខ្ញុំបាននាំមកក្នុងវេលាយប់ ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧស្សុ** ស្មើគ្នានឹង **អមុស្ស** ( ឯណោះ ) ។

ពាក្យថា **រត្តិភត្តំ អចាភតំ** ខ្ញុំបាននាំមកជាអាហារក្នុងវេលាយប់ សេចក្តីថា នាំចេញមក ព្រោះជាអាហារពេលយប់ ។ ពាក្យថា សាច់ពីរជ្រួចផង ទន្សេងមួយផង បានដល់ សាច់អាំង ២ ប្រទួច និងទន្សេងមួយ ។ ពាក្យថា **ទធិវារកំ** កែជា **ទធិវារកោ** ( ដបទឹកដោះជូរ ) ។

បន្ទាប់អំពីនោះ ព្រាហ្មណ៍ក៏ចូលទៅរកសសបណ្ឌិត កាលសសបណ្ឌិតសួរថា អ្នកមកដើម្បីអ្វី ព្រាហ្មណ៍ក៏ប្រាប់យ៉ាងនោះ ដូចព្រះមានព្រះភាគត្រាស់ថា **មម សន្តប្បមញ្ញាយ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **មម សន្តប្បមញ្ញាយ** សេចក្តីថា សក្កទេវរាជទ្រង់ជ្រាបបរិវិតក្ក មានប្រការដូចពោលហើយក្នុងកាលមុន ។ បទថា **ព្រាហ្មណវណ្ណិនា** បានដល់ កាឡាខ្លួនជាព្រាហ្មណ៍ ។ បទថា **អាសយំ** បានដល់ មកកាន់គុម្ពឈើដែលជាលំនៅ ។

បទថា **សន្តុដ្ឋោ** បានដល់ ត្រេកអរដោយចំណែកទាំងពួងយ៉ាងស្មើ ។ បទថា **ឃាសហោតុ** បានដល់ ព្រោះអាហារជាហេតុ ។ បទថា **អទិន្នបុព្វំ** បានដល់ ដែលបុគ្គលណាមួយ ដែលមិនមែនព្រះពោធិសត្វមិនធ្លាប់ឲ្យ ។ បទថា **ទានវរំ** បានដល់ ទានដ៏ឧត្តម ។ សសបណ្ឌិតពោលថា ថ្ងៃនេះ ខ្ញុំនឹងឲ្យដល់អ្នក ។ អ្នកជាបុគ្គលប្រកបដោយសីលគុណ ការបៀតបៀនអ្នកដទៃមិនសមគួរដល់អ្នក ឥឡូវនេះ ដើម្បីនឹងដោះព្រាហ្មណ៍អំពីបាណាតិបាត ហើយធ្វើខ្លួនឲ្យសមគួរដល់ការបរិភោគរបស់ព្រាហ្មណ៍នោះ ហើយឲ្យ ទើបពោលពាក្យថា **ឯហិ អគ្គឹ បទីបេហិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អហំ បជិស្សាមត្ថានំ** បានដល់ កាលអ្នកធ្វើបន្ទប់ដ៏ពេញដោយភ្លើង ហើយខ្ញុំនឹងលោតចូលដុតខ្លួនរបស់ខ្ញុំ ។ បទថា **បក្កំ តំ ភក្ខយិស្សសិ** បានដល់ អ្នកនឹងបានបរិភោគសាច់ ដែលឆ្អិនបែបនោះ ។

បទថា **ឆាតាកដ្ឋេ សមានយិ** សេចក្តីថា សក្កៈ ដែលទ្រទ្រង់នូវភេទជាព្រាហ្មណ៍នោះ ធ្វើជារកឧសផ្សេងៗ មក ។ បទថា **មហន្តំ អកាសិ ចិតកំ កត្វា អង្គារគព្ភកំ** សេចក្តីថា ព្រាហ្មណ៍នោះបានធ្វើជើងក្ករធំ ក្នុងខណៈនោះមួយរំពេច ប្រាសចាកអណ្តាតភ្លើង ប្រាសចាកផ្សែង ខាងក្នុងពេញដោយរងើកភ្លើង ឆេះសន្ធោសន្ធៅដោយជុំវិញ ល្មមរាងកាយរបស់ខ្ញុំចូលទៅបាន អធិប្បាយថា សក្កទេវរាជប្រញាប់និម្មិតឡើងដោយឫទ្ធិ ដូចព្រះមានព្រះភាគត្រាស់ថា គំនរភ្លើងធំនោះឆេះឆាប យ៉ាងណា ឥន្ទព្រាហ្មណ៍នោះ ក៏ដុតភ្លើងឆេះសន្ធោសន្ធៅក្នុងទីនោះ យ៉ាងនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សោ** សេចក្តីថា ព្រាហ្មណ៍បានបង្កាត់ ដូចគំនរភ្លើងនោះ ជាគំនរភ្លើងធំមួយរំពេច ។

បទថា **ធោជេត្វា រជគតេ គត្តេ** សេចក្តីថា រលាស់ខ្លួនរបស់តថាគតដែលមានធូលី ៣ ដង ដោយគិតថា បើមានសត្វនៅក្នុងចន្លោះរោម សត្វទាំងនោះកុំស្លាប់ឡើយ ។ បទថា **ឯកមន្តំ ឧបាវិសឹ** សេចក្តីថា តថាគតឃើញថា គំនរឧសមិនទាន់ឆេះដោយភ្លើង ទើបចៀសចេញទៅអង្គុយបន្តិច ។

បទថា **យទា មហាកដ្ឋបុញ្ជោ អាទិត្តោ ធមធមាយតិ** សេចក្តីថា ក្នុងកាលគំនរឧសមិនទាន់ឆេះទូទៅដោយជុំវិញ នៅមានផ្សែង ដោយអំណាច

នៃអណ្តាតភ្លើងដែលបន្ទាត់ឡើងដោយភាពរហ័ស ។ បទថា **តនុប្បតិត្វា បបតិ មជ្ឈេ ជាលសិខន្តរេ** សេចក្តីថា ក្នុងកាលនោះ គឺវេលានោះ តថាគតគិតថា គំនរភ្លើងនេះ អាចដុតសរីរៈរបស់អញបាន ទើបលោតចូលទៅ ឲ្យនូវរាងកាយទាំងមូលជាទាន លោតចូលក្នុងកណ្តាលគំនររងើកភ្លើងនោះ ដែលនៅក្នុងរវាងអណ្តាតភ្លើង មានចិត្តត្រេកអរ ដូចស្តេចហង្សលោតចូលក្នុងគុម្ពឈូក ដូច្នោះ ។

បទថា **បរិដ្ឋំ យស្ស កស្សចិ** សេចក្តីថា ដូចក្នុងពេលក្តៅ ទឹកត្រជាក់ដែលបុគ្គលណាជ្រមុជទៅ រមែងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ និងការក្តៅរបស់បុគ្គលនោះបាន គឺឲ្យកើតនូវការពេញចិត្ត និងបីតិយ៉ាងណា ។ បទថា **តថេវ ជលិតំ អគ្គឹ** សេចក្តីថា ក្នុងកាលតថាគតចូលទៅក្នុងគំនររងើកភ្លើងដែលឆេះសន្ធោសន្ធៅ ក៏យ៉ាងនោះ មិនមានសូម្បីតែការក្តៅដោយពិត មាននូវការរម្ងាប់សេចក្តីក្រវល់ក្រវាយ ក្តៅក្រហាយទាំងពួង ដោយការផ្តែតក្នុងទាន សរីរាវយវៈទាំងអស់ មានរោម និងស្បែកជាដើមរបស់តថាគត ចូលដល់ភាពជារបស់គួរឲ្យជាទាន ។ សេចក្តីប្រាថ្នាដែលតថាគតប្រាថ្នា បានដល់សេចក្តីសម្រេចហើយ អស់កាលយូរហ្ន៎ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតបានឲ្យសម្បុរថ្ងៃ ស្បែក សាច់ សរសៃ ឆ្អឹង បេះដូង
និងកាយទាំងមូល មិនឲ្យមានសេសសល់ដល់ព្រាហ្មណ៍ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ហទយពន្ធនំ** បានដល់ សាច់បេះដូង ។ ពិតហើយ សាច់បេះដូងនោះ លោកហៅថា ហទយពន្ធនៈ ព្រោះតាំងនៅដូចចង

នូវហទយវត្ថុ ។ មួយវិញទៀត បទថា **ហទយពន្ធនំ** បានដល់ ហទយៈ ការចង នឹងសាច់ហទយៈ អធិប្បាយថា ដូចសាច់ថ្មើមចងសាច់បេះដូង ។ បទថា **កេវលំ សកលំ កាយំ** បានដល់ សរីរៈទាំងអស់ មិនមានចំណែក សេសសល់ ។

ចំណែកព្រះពោធិសត្វ អត់ធន់ ( ក្នុងសេចក្តីសង្ស័យ ) មិនបាន ដែលគំនរភ្លើងនោះ មិនធ្វើនូវការក្តៅ សូម្បីត្រឹមតែរណ្តៅរោមក្នុងរាងកាយ របស់ខ្លួន ដូចចូលទៅក្នុងបន្ទប់សន្សើម ទើបពោលនឹងសក្កៈដែលកាឡាខ្លួន ជាព្រាហ្មណ៍យ៉ាងនេះថា នែព្រាហ្មណ៍ ភ្លើងដែលអ្នកបង្កាត់ត្រជាក់ល្អពិត ហេតុអ្វី ទើបដូច្នេះ ព្រាហ្មណ៍ពោលថា នែបណ្ឌិត ខ្ញុំមិនមែនជាព្រាហ្មណ៍ ឡើយ ខ្ញុំជាសក្កទេវរាជ មកធ្វើយ៉ាងនេះ ដើម្បីពិសោធអ្នក ។ ព្រះពោធិសត្វ បានបន្លឺសីហនាទថា បពិត្រសក្កៈ ណ្ហើយចុះ បើលោកទាំងមូលគប្បីសាក ល្បងខ្ញុំដោយទាន គេនឹងឃើញថា ការដែលខ្ញុំមិនចង់ឲ្យនោះ មិនមានឡើយ ។

លំដាប់នោះ សក្កទេវរាជត្រាស់ថា សសបណ្ឌិត គុណធម៌របស់អ្នក ចូរប្រាកដអស់កប្បចុះ ហើយទ្រង់ច្របាច់ភ្នំ នាំយករសរបស់ភ្នំ គូរលក្ខណៈ របស់ទន្សាយក្នុងមណ្ឌលព្រះចន្ទ ហើយឲ្យព្រះពោធិសត្វដេកលើតាំងស្បូវ ភ្លាំងដ៏ទន់ ក្បែរគុម្ពឈើក្នុងដងព្រៃនោះ ហើយត្រឡប់ទៅកាន់ទេវលោក ។ បណ្ឌិតទាំង ៤ នោះ ក៏រីករាយស្មោះស្ម័គ្រ បំពេញនិច្ចសីល និងឧបោសថ- សីល ធ្វើបុណ្យតាមសមគួរហើយ ក៏ទៅតាមយថាកម្ម ។

ភេក្នុងកាលនោះ បានមកជាព្រះអានន្ទ ក្នុងកាលឥឡូវនេះ ចចក ក្នុងកាលនោះ បានមកជាព្រះមហាមោគ្គល្លាន ក្នុងកាលឥឡូវនេះ ស្វា ក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ក្នុងកាលឥឡូវនេះ សសបណ្ឌិត ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងសសបណ្ឌិតចរិយានេះ គប្បីពោលចំពោះដល់សីលបារមីជាដើម របស់សសបណ្ឌិតនោះតាមសមគួរ ដោយន័យដូចពោលហើយខាងដើមនោះឯង ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពរបស់ព្រះពោធិសត្វក្នុងទីនេះយ៉ាងនេះ គឺកាលកើតក្នុងកំណើតតិរច្ឆាន ( បើមាន ) ការដឹងធម៌ដែលជាកុសលជាដើម ដោយភាពជាកុសលជាដើម តាមសេចក្ដីពិត ការឃើញទោសមានប្រមាណតិចក្នុងកុសលទាំងនោះ ដោយភាពជារបស់គួរខ្ពើម ហើយវៀរចាកអកុសលយ៉ាងដាច់ខាត ការតម្កល់ខ្លួនក្នុងកុសលធម៌ទាំងឡាយ ដោយប្រពៃប៉ុណ្ណោះ ការចង្អុលបង្ហាញនូវទោសដល់អ្នកដទៃថា ធម៌លាមកឈ្មោះនេះ ដែលអ្នកកាន់យកហើយយ៉ាងនេះ បពោសអង្អែលហើយយ៉ាងនេះ រមែងមានគតិយ៉ាងនេះ ក្នុងភពខាងមុខ យ៉ាងនេះហើយ ដឹកនាំក្នុងការវៀរចាកទោសទាំងនោះ ការចង្អុលបង្ហាញដល់អានិសង្សក្នុងការធ្វើបុណ្យ ដោយន័យជាដើមថា នេះឈ្មោះថា ទាន នេះឈ្មោះថា សីល នេះឈ្មោះថា ឧបោសថកម្ម ទេវសម្បត្តិ មនុស្សសម្បត្តិ នៅក្នុងកណ្ដាប់ដៃរបស់បុគ្គលដែលតាំងនៅក្នុងធម៌នេះ ហើយឲ្យបុគ្គលនោះ តាំងនៅការមិនគិតដល់រាង

កាយ និងជីវិតរបស់ខ្លួន ការអនុគ្រោះសត្វពួកដទៃ និងការមានអធ្យាស្រ័យក្នុងទានដ៏ទូលំទូលាយជាដើម ដូចលោកពោលថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វី ដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។៙

## អដ្ឋកថាសសបណ្ឌិតចរិយា ចប់

ឥឡូវនេះ នឹងលើកភាពវិសេសនៃចរិយា ១០ តាមដែលពោលហើយដោយន័យថា **អកិត្តិព្រាហ្មណោ**[១] ដូច្នេះជាដើមមកសរុប ។

ក្នុងបទទាំងនោះ បទថា **អហាមេវ តទា អាសឹ យោ តេ ទានវរេ អទា** សេចក្តីថា បុគ្គលណាបានឲ្យទានដ៏ប្រសើរទាំងនោះ គឺបុគ្គលណាបានឲ្យទានដ៏ឧត្តមទាំងនោះ បុគ្គលនោះ មានអកិត្តិព្រាហ្មណ៍ជាដើម ក្នុងកាលនោះ បានមកជាតថាគតនេះឯង មិនមែនអ្នកដទៃឡើយ ព្រះមានព្រះភាគទ្រង់លើកទេសនាឡើងដោយអំណាចទានបារមីប៉ុណ្ណោះ ទ្រង់សំដៅដល់ភាពទូលំទូលាយយ៉ាងក្រៃលែងនៃអធ្យាស្រ័យក្នុងទាន ក្នុងកាលនោះរបស់ព្រះអង្គក្នុងភាពជាអ្នកបំពេញសីលបារមីជាដើម មានក្នុងអត្តភាពទាំងឡាយនោះ

១- បទនេះ និងបទខាងក្រោម ជាបទពន្យល់សេចក្តីក្នុងឧទានគាថា ។

តាមសមគួរ ដោយប្រការដូច្នេះ ។ បទថា **ឯកេ ទានបរិក្ខារា ឯកេ ទានស្ស ចារមី** សេចក្ដីថា តថាគតបរិច្ចាគទេយ្យធម៌ដែលមានគុណច្រើន ក្នុងអកិត្តិ-ជាតកជាដើម តថាគតបរិច្ចាគអវយវៈ និងបុត្ររបស់តថាគតជាលើកចុង ក្រោយណា ការបរិច្ចាគទាំងនោះ ជាទានបារមីប៉ុណ្ណោះ ដោយដល់នូវភាព កំពូលក្រៃលែងរបស់ទាន ព្រោះតថាគតកាន់យកនូវភាពជាអ្នកឈ្លាសក្នុង ឧបាយ គឺករុណា ព្រោះតថាគតបរិច្ចាគដើម្បីឧទ្ទិសចំពោះសព្វញ្ញុតញ្ញាណ ប៉ុណ្ណោះដោយពិត តែទោះជាយ៉ាងនោះ ទានទាំងនេះ ក៏ជាទានបរិក្ខារ ព្រោះជួយឧបការៈទានរបស់តថាគត ឲ្យជាទានបរមត្ថបារមី ព្រោះជួយ ឧបការៈសន្តានឲ្យចម្រើនដោយជុំវិញ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែង ដល់ទានដែលជាបរិវារទាំងនោះ ទើបត្រាស់ថា **ជីវិតំ យាចកេ ទត្វា ឥមំ ចារមិ បូរយឹ** ដូច្នេះ ។ ពិតហើយ ក្នុងទីនេះ គប្បីជ្រាបទានបារមី ទាន-ឧបបារមី ក្នុង ៩ ចរិយាដ៏សេសតាមសមគួរ វៀរសសបណ្ឌិតចរិយា ។ ព្រោះក្នុងសសបណ្ឌិតចរិយា ជាទានបរមត្ថបារមី ដូចព្រះមានព្រះភាគ ត្រាស់ថា

> តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន ជា
> របស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទានរបស់តថាគត មិនមាន
> ឡើយ នេះជាទានបារមីរបស់តថាគត ដូច្នេះ ។

ពិតហើយ ការកំណត់អត្តភាព ដែលបំពេញទានបារមីរបស់ព្រះមហាបុរស ក្នុងកាលដែលសោយព្រះជាតិជាអកិត្តិព្រាហ្មណ៍ជាដើម តាមដែលពោលហើយ និងក្នុងកាលដទៃ គឺក្នុងកាលដែលសោយព្រះជាតិជាព្រះមហាជនក និងមហាសុតសោមជាដើម ធ្វើមិនបានក៏ពិត តែក៏គប្បីប្រកាសភាពជាបរមត្ថបារមី នៃទានបារមី ក្នុងកាលដែលសោយព្រះជាតិជាសសបណ្ឌិត ដោយចំណែកមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។៚

សង្គ្រោះចរិយា ១០ ដែលប្រកាសដោយទានបារមី

ដោយវិសេស ចប់

បឋមវគ្គ ចប់

# សុត្តន្តបិដក
# សីលបារមិតា

## សីលវនាគចរិយាទី ១

[ ១១ ] កាលដែលតថាគតកើតជាដំរី ជាសត្វចិញ្ចឹមមាតា នៅក្នុងព្រៃធំ កាលនោះ នឹងរកអ្នកណាលើផែនដីនេះ ឲ្យស្មើនឹងតថាគត ដោយសីលគុណ មិនមានឡើយ ។ មានព្រៃព្រៃម្នាក់ឃើញតថាគតក្នុងព្រៃ ក៏ក្រាបទូលដល់ស្តេចពារាណសីថា បពិត្រមហារាជ គជសារមួយនៅក្នុងព្រៃធំ ជាសត្វមានសភាពសមគួរដល់ព្រះអង្គ ដំរីនោះ មិនមានសេចក្តីត្រូវការដោយស្នាមភ្លោះទេ មិនមានសេចក្តីត្រូវការដោយខ្សែប្រកាំ និងវណ្តៅទេ ដំរីនោះគ្រាន់តែបុគ្គលចាប់ទាញប្រមោយ នឹងមកក្នុងទីនេះដោយខ្លួនឯង ។ ចំណែកខាងព្រះរាជា ទ្រង់បានព្រះសណ្តាប់នូវពាក្យ របស់ព្រៃព្រៃនោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរ ទើបទ្រង់ប្រើហ្មដំរីដែលជាហត្ថាចារ្យ ឈ្លាសវាងវៃ បានសិក្សាវិជ្ជាចាប់ដំរី ចេះល្អិតល្អ ។ ហ្មដំរីនោះលុះទៅដល់ ក៏ឃើញតថាគតកំពុងដកមើមឈូកក្រអៅឈូក ក្នុងបទុមស្រះ ដើម្បីចិញ្ចឹមមាតា ។ នាយហត្ថាចារ្យនោះ លុះដឹងច្បាស់សីលគុណនៃតថាគត ក៏ពិចារណាឃើញលក្ខណៈ ( នៃតថាគត ) ហើយពោលថា ម្នាលកូន អ្នកចូរមក

ហើយចាប់ដឹកតថាគតត្រង់ប្រមោយ ។ កាលនោះ កម្លាំងណា ប្រព្រឹត្តទៅក្នុងសរីរៈនៃតថាគត ដែលតាំងនៅដោយប្រក្រតី កម្លាំងនោះ ប្រាកដស្មើដោយកម្លាំងនៃដំរីច្រើនពាន់ ក្នុងថ្ងៃនេះ ។ បើតថាគតខឹងចំពោះជនទាំងឡាយនោះ ដែលចូលមកចាប់តថាគត តថាគតអាច ( នឹងញ៉ាំញីនូវជីវិត ) នៃមនុស្សនោះ រហូតដល់រាជ្យជារបស់មនុស្សក៏បាន ។ តែតថាគតរក្សាសីល ( សូម្បីឃើញ ) នូវជនកាលដាក់តថាគត ក្នុងរោង ក៏មិនធ្វើចិត្តឲ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។ ប្រសិនបើជនទាំងឡាយនោះ កាប់ចាក់តថាគត ដោយប៉ូវថៅ និងលំពែងស្នែងក្របី ក្នុងទីនោះ ក៏តថាគតមិនក្រោធខឹង ចំពោះជនទាំងនោះ ព្រោះតថាគតខ្លាចដាច់សីល ។

**សីលវនាគចរិយាទី ១ ចប់**

# អដ្ឋកថា
# ហត្ថិនាគវគ្គទី ២

## សីលវនាគចរិយា

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលវនាគចរិយាទី ១ នៃវគ្គទី ២ ដូចតទៅ បទថា **កុញ្ជរោ** បានដល់ ដំរី ។ បទថា **មាតុបោសកោ** បានដល់ បម្រើមាតាចាស់ភ្នែកខ្វាក់ ។ បទថា **មហិយា** បានដល់ ក្នុងផែនដី ។ បទថា **គុណេន** បានដល់ ដោយសីលគុណ ។ ក្នុងកាលនោះ មិនមានបុគ្គលស្មើតថាគត ។

បានឮថា ព្រះពោធិសត្វក្នុងកាលនោះ កើតក្នុងកំណើតដំរី ក្នុងហិមវន្តប្បទេស ។ ដំរីនោះជាដំរីសសុទ្ធ មានរូបស្អាត បរិបូរដោយលក្ខណៈជាមេហ្វូង មានដំរីបរិវារ ១ សែន ។ ចំណែកមាតារបស់ព្រះពោធិសត្វភ្នែកខ្វាក់ ។ ព្រះពោធិសត្វដាក់ផលាផលមានរសឆ្ងាញ់ ក្នុងប្រមោយនៃដំរីទាំងឡាយ បញ្ជូនទៅដើម្បីមាតា ។ ដំរីទាំងឡាយមិនយកទៅឲ្យមាតា ទំពាស៊ីឯង ។ ព្រះពោធិសត្វឃ្លាំសង្កេតមើលក៏ដឹងរឿង គិតថា អញនឹងលះបង់ហ្វូងចិញ្ចឹមមាតាឯង លុះកណ្តាលយប់ កាលដំរីទាំងឡាយមិនដឹង ក៏នាំមាតាទៅកាន់ជើងភ្នំចណ្ឌោរណបព៌ត ចូលទៅអាស្រ័យស្រះឈូកមួយ ឲ្យមាតានៅក្នុងគុហាភ្នំ ហើយចិញ្ចឹមរក្សា ។

ព្រានព្រៃម្នាក់វង្វេងផ្លូវ មិនអាចកំណត់ទិសបាន យំរៀបរាប់ដោយ

សំឡេងខ្លាំង ។ ព្រះពោធិសត្វបានឮសំឡេងរបស់ព្រានព្រៃនោះ ទើបគិតថា បុរសនេះឥតទីពឹង ដរាបណាអាត្មាអញរស់នៅ បុរសនេះវិនាសទៅក្នុងទីនេះ មិនជាការសមគួរឡើយ ។ ទើបចូលទៅរកព្រានព្រៃ ឃើញព្រានព្រៃរត់ព្រោះខ្លាច ទើបសួរថា នែអ្នក អ្នកកុំភ័យព្រោះអាស្រ័យយើងឡើយ កុំរត់ថ្វីឡើយ ហេតុអ្វី ទើបអ្នកត្រាច់ទួញយំ ដូច្នេះ ព្រានព្រៃឆ្លើយថា ខ្ញុំវង្វេងផ្លូវថ្ងៃនេះជាថ្ងៃទី ៧ ហើយ ។ ព្រះពោធិសត្វពោលថា កុំខ្លាចថ្វីឡើយ យើងនឹងនាំអ្នកទៅកាន់ដែនដីមនុស្ស ហើយឲ្យព្រានព្រៃអង្គុយលើខ្នងរបស់ខ្លួន នាំចេញអំពីព្រៃហើយក៏វិលត្រឡប់ ។ ព្រានព្រៃចិត្តបាប គិតថា អញនឹងទៅកាន់ព្រះនគរ ក្រាបទូលដល់ព្រះរាជា ទើបធ្វើគ្រឿងសម្គាល់ មានដើមឈើនិងភ្នំជាដើម ហើយធ្វើដំណើរទៅកាន់ក្រុងពារាណសី ។

ក្នុងកាលនោះ មង្គលហត្ថីរបស់ព្រះរាជាស្លាប់ ។ ព្រានព្រៃក៏ចូលទៅគាល់ព្រះរាជា ក្រាបទូលដល់ភាពដែលខ្លួនឃើញមហាបុរស ដូចព្រះមានព្រះភាគត្រាស់ថា

មានបុរសព្រៃម្នាក់ឃើញតថាគតក្នុងព្រៃ ក៏ក្រាបទូលដល់ស្តេចពារាណសីថា បពិត្រមហារាជ គជសារមួយនៅក្នុងព្រៃធំ ជាសត្វមានសភាពសមគួរដល់ព្រះអង្គ ដំរីនោះ មិនមានសេចក្តីត្រូវការដោយស្នាមភ្លោះទេ មិនមានសេចក្តីត្រូវការដោយខ្សែប្រកាំ និងរណ្តៅទេ ដំរីនោះ គ្រាន់តែបុគ្គលចាប់ទាញប្រមោយនឹងមកក្នុងទីនេះ ដោយខ្លួនឯង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បវនេ ទិស្វា វនចរោ** បានដល់ ព្រានព្រៃម្នាក់ត្រាច់ទៅក្នុងព្រៃធំ ឃើញតថាគតហើយ ។ បទថា **រញ្ញោ មំ បដិវេទយិ** បានដល់ បានក្រាបទូលតថាគតដល់ស្ដេចពារាណសី ។ បទថា **តវានុច្ឆវោ** បានដល់ សមគួរធ្វើជាដំរីព្រះទីន័ងរបស់ព្រះអង្គ ។ បទថា **ន តស្ស បរិក្ខា-យត្ថោ** សេចក្ដីថា ក្នុងការចាំដំរីនោះ មិនចាំបាច់ គឺមិនមានប្រយោជន៍ដើម្បីជីកប្រឡាយជុំវិញ ដើម្បីកុំឲ្យដំរីគេច ឬបោះសសរ ឲ្យមេដំរីធ្នាក់យកស្លឹកត្រចៀកបាំងខ្លួនឯង យកខ្សែអន្ទាក់ចង ឬដោយការជីករណ្ដៅបញ្ឆោត ដើម្បីកុំឲ្យដំរីដែលធ្លាក់ទៅគេចបាន ។ បទថា **សហាគហិតេ** បានដល់ ក្នុងខណៈដែលចាប់នោះឯង ។ បទថា **ឃហិត** បានដល់ នឹងមក ។

ព្រះរាជាបានឲ្យព្រានព្រៃជាអ្នកនាំផ្លូវទៅព្រៃ ទ្រង់បញ្ជូនហ្មដំរីទៅជាមួយបរិវារ ដោយព្រះតម្រាស់ថា ចូរអ្នកនាំគជសារដែលព្រានព្រៃប្រាប់មកឲ្យបាន ។ ហ្មដំរីនោះ បានទៅជាមួយព្រានព្រៃ ឃើញព្រះពោធិសត្វចូលទៅកាន់ស្រះឈូករកអាហារ ។ ដូចព្រះមានព្រះភាគត្រាស់ថា

ចំណែកខាងព្រះរាជា ទ្រង់បានព្រះសណ្ដាប់នូវពាក្យរបស់ថ្មើរព្រៃនោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរ ទើបទ្រង់ប្រើហ្មដំរីដែលជាហត្ថាចារ្យ ឈ្លាសវាងវៃ បានសិក្សាវិជ្ជាចាប់ដំរីចេះល្អិតល្អ ។ ហ្មដំរីនោះ លុះទៅដល់ ក៏ឃើញតថាគតកំពុងដកមើមឈូក ក្រអៅឈូក ក្នុងបទុមស្រះ ដើម្បីចិញ្ចឹមមាតា ។ នាយហត្ថាចារ្យនោះ លុះដឹងច្បាស់សីលគុណនៃតថាគត ក៏ពិចារណា

ឃើញលក្ខណៈ ( នៃតថាគត ) ហើយពោលថា ម្នាលកូន អ្នកចូរមក ហើយចាប់ដឹកតថាគតត្រង់ប្រមោយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឆេកាចរិយំ** បានដល់ ហ្មដំរីអ្នកឈ្លាសក្នុងវិធីចាប់ដំរីទាំងឡាយជាដើម ។ បទថា **សុសិក្ខិតំ** បានដល់ សិក្សាល្អហើយដោយសម្រេចវិជ្ជាទូន្មានដំរី ។ បទថា **វិញ្ញាយ មេ សីលគុណំ** បានដល់ ហ្មដំរីដឹងនូវសីលគុណរបស់តថាគតថា ដំរីដ៏ប្រសើរនេះ ជាដំរីអាជានេយ្យ មិនល្ងង់ មិនកាច មានប្រក្រតីមិនច្រឡូកច្រឡំ ។ សួរថា ដឹងបានដូចម្តេច ឆ្លើយថា ពិចារណាមើលលក្ខណៈហើយ រមែងដឹង ។ បទថា **លក្ខណំ ឧបធារយិ** សេចក្តីថា ហត្ថាចារ្យពិចារណាមើលលក្ខណៈរបស់តថាគតដោយសព្វគ្រប់ ព្រោះជាអ្នកមានសិប្បៈក្នុងការមើលដំរី ដែលសិក្សាមកយ៉ាងល្អ ដោយហេតុនោះ ទើបហត្ថាចារ្យពោលថា មកកូន ហើយចាប់តថាគតត្រង់ប្រមោយ ។

ព្រះពោធិសត្វ ឃើញហ្មដំរីហើយតាំងចិត្តអធិដ្ឋានថា ភ័យរបស់អាត្មាអញនេះ កើតអំពីព្រានព្រៃនេះ អញមានកម្លាំងច្រើន អាចកម្ទេចដំរីរាប់ពាន់បាន បើអញកើតសេចក្តីក្រោធ អាចញុំាងអ្នកចម្បាំង ព្រមទាំងដែនឲ្យវិនាសបាន បើអញក្រោធ សីលរបស់អញនឹងដាច់ ព្រោះហេតុនោះ ទោះបីហត្ថាចារ្យយកលំពែងចាក់អាត្មាអញ ក៏មិនគួរក្រោធ ដូច្នេះហើយ បង្អោនសីសៈ ហើយឈរស្ងៀម ដូចព្រះមានព្រះភាគពោលថា

កាលនោះ កម្លាំងណា ប្រព្រឹត្តទៅក្នុងសរីរៈនៃតថាគត ដែលតាំងនៅដោយប្រក្រតី កម្លាំងនោះ ប្រាកដស្មើដោយកម្លាំងនៃដំរីច្រើនពាន់ ក្នុងថ្ងៃនេះ ។ បើតថាគតខឹងចំពោះជនទាំងឡាយនោះ ដែលចូលមកចាប់តថាគត តថាគតអាច ( នឹងញាំញីនូវជីវិត ) នៃមនុស្សនោះ រហូតដល់រាជ្យជារបស់មនុស្សក៏បាន ។ តែតថាគតរក្សាសីល ( សូម្បីឃើញ ) នូវជនកាល ដាក់តថាគតក្នុងរោង ក៏មិនធ្វើចិត្តឲ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។ ប្រសិនបើជនទាំងឡាយនោះ កាប់ចាក់តថាគត ដោយប៉ូវថៅនិងលំពែងស្នែងក្របី ក្នុងទីនោះ ក៏តថាគតមិនក្រោធខឹងចំពោះជនទាំងនោះ ព្រោះតថាគតខ្លាចដាច់សីល ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ថាមតិកំ** បានដល់ ដូចដើម ។ បទថា **សរីរានុគតំ** បានដល់ កម្លាំងកាយ ដែលជាប់ក្នុងរាងកាយ អធិប្បាយថា មិនមែនកម្លាំងកាយដែលកើតឡើងដោយញាណ គឺភាពជាអ្នកឈ្លាសក្នុងឧបាយ ។ បទថា **អជ្ជ នាគសហស្សានំ** សេចក្ដីថា ក្នុងថ្ងៃនេះ ស្មើគ្នានឹងដំរីច្រើនពាន់ ។ បទថា **ពលេន សមសាធិសំ** បានដល់ កម្លាំងរបស់តថាគតស្មើគ្នានឹងកម្លាំងក្នុងរាងកាយរបស់ដំរីទាំងនោះ មិនមែនត្រឹមតែប្រៀបធៀបព្រោះក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលមង្គលហត្ថី ។

បទថា **យទិហំ តេសំ បកុប្បេយ្យំ** សេចក្ដីថា បើតថាគតក្រោធនឹងហត្ថាចារ្យដែលចូលមកដើម្បីចាប់តថាគតៗ គប្បីមានកម្លាំងប្រយុទ្ធ ក្នុង

ការបំផ្លាញជីវិតរបស់ហត្ថាចារ្យបាន មិនមែនមានកម្លាំងប្រយុទ្ធជាមួយនឹងហត្ថាចារ្យតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត តថាគតអាចប្រយុទ្ធរហូតដល់រាជសម្បត្តិរបស់មនុស្ស ។

បទថា **យាវ រជ្ជម្បិ មានុសំ** សេចក្តីថា តថាគតនឹងទម្លាយរាជ-សម្បត្តិទាំងអស់របស់មនុស្សទាំងនេះ ដែលមកដោយរាជការ ឲ្យជាផេះផង់ធូលីទៅ ។ បទថា **អបិ ចាហំ សីលរក្ខាយ** សេចក្តីថា តថាគតអាចធ្វើយ៉ាងនោះបាន តថាគតក៏បានទទួលនូវការរក្សា ដោយការរក្សាសីលដោយការគ្រប់គ្រងរបស់សីលដែលតាំងនៅក្នុងខ្លួន ដូចចង ។ បទថា **ន ករោមិ ចិត្តេ អញ្ញថត្តំ** សេចក្តីថា តថាគតមិនធ្វើចិត្តឲ្យថ្នាំងថ្នាក់ គឺតថាគតមិនធ្វើវិធីមានការចាប់បោកជាដើម ដល់សត្វទាំងនោះ ដែលជាការទម្លាយនូវសីលនោះ គឺចិត្តក្នុងការចាប់បោកជាដើមនោះ ក៏មិនបានកើតឡើងឡើយ ។ បទថា **បក្ខិបន្តំ មមាឡ្ហកេ** បានដល់ ចងត្រង់សសរសម្រាប់លាមដំរី ។ ឲ្យបន្ថែមពាក្យថា **ឱស្សាមិ** ចូរមក ។ បើសួរថា ព្រោះហេតុអ្វី អធិប្បាយប្រកបថា កាលតថាគតមិនទម្លាយសីល ក្នុងឋានៈបែបនេះ ដោយការបំពេញសីលបារមី ក្នុងកាលមិនយូរ សីលបារមីក៏នឹងបរិបូណ៌ ព្រោះហេតុនោះដើម្បីបំពេញសីលបារមី ទើបតថាគតមិនទម្លាយសីល សូម្បីក្នុងការគិត ។ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវការមាំទាំរបស់សីល ដោយធ្វើនូវការមាំទាំដោយការរក្សាសីល ដោយគាថាថា **យទិ តេ មំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **កោដ្ដយុំ** បានដល់ គប្បីទម្លាយ ( បោក ) ។

បទថា **សីលវណ្ណភយា មម** បានដល់ ព្រោះតថាគតខ្លាចសីលដាច់ ។

ព្រះពោធិសត្វកាលត្រិះរិះយ៉ាងនេះហើយ ទើបឈរស្ងៀមមិនកម្រើក ។ ហ្មដំរីចុះកាន់ស្រះឈូក ឃើញលក្ខណៈសម្បត្តិរបស់ព្រះពោធិសត្វ ទើបពោលថា មកកូន ហើយចាប់ត្រង់ប្រមោយ ដែលដូចគ្នានឹងកម្រងប្រាក់ នាំទៅកាន់នគរពារាណសី អស់កាល ៧ ថ្ងៃ ។ ហ្មដំរីកាលដល់រវាងផ្លូវ បានបញ្ជូនដំណឹងទៅថ្វាយព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ឲ្យតាក់តែងព្រះនគរ ។ ហ្មដំរីនាំព្រះពោធិសត្វដែលមានខ្សែបង ធ្វើដោយគ្រឿងក្រអូបប្រដាប់តាក់តែងហើយ ចូលទៅកាន់រោងដំរីដែលបាំងដោយវាំងននដ៏វិចិត្រ ក្រាបទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់កាន់យកភាជនៈ មានរសដ៏ប្រសើរផ្សេងៗ ទៅឲ្យដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វមិនបានទទួលភោជនាហារ ដោយត្រិះរិះថា អាត្មាអញបែកពីមាតាហើយ នឹងមិនទទួលអាហារ ។ ព្រះរាជាទ្រង់អង្វរ ក៏មិនទទួលដោយពោលថា

> មេដំរីនោះជាសត្វកំព្រា ខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងជន្លត់ឈើ ហើយបែរមុខ ទៅរកភ្នំចណ្ឌោរណៈ ដួលនៅដូច្នេះ ។

> ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ក៏ត្រាស់សួរថា

> ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងជន្លត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង ដូច្នេះ ។

ព្រះពោធិសត្វក្រាបទូលថា

បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទន្ទិចជើងនឹងជន្ទត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅទោះ ត្រូវជាមាតារបស់ទូលព្រះបង្គំជាខ្ញុំ ដូច្នេះ ។

កាលព្រះពោធិសត្វទូលថា ថ្ងៃនេះជាថ្ងៃទី ៧ មាតារបស់ទូលបង្គំ មិនទាន់បានអាហារឡើយ ដូច្នេះហើយ ក៏មិនទទួលអាហារ ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ថា

អ្នកទាំងឡាយ ចូរលែងនូវដំរីដ៏ប្រសើរនុ៎ះ ជាសត្វចិញ្ចឹមនូវមាតា ចូរឲ្យដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ ដូច្នេះ ។ ហើយត្រាស់ដោះលែងដំរីនោះទៅ ។

ដំរីគ្រាន់តែរួចចាកចំណង ដែលព្រះរាជាកាសីបានបញ្ជូនទៅ សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កបណិកា** បានដល់ គួរករុណា ។ បទថា **ខាណុំ ចាេនន ឃដ្ដេតិ** សេចក្ដីថា មាតាយំរៀបរាប់ ព្រោះភ្នែកខ្វាក់ និងព្រោះទុក្ខ ដែលកើតអំពីការព្រាត់ប្រាសកូន ទើបជំពប់ត្រង់គល់ឈើនោះៗដោយជើង ។ បទថា **ចណ្ឌោរណំ បតិ** បានដល់ ដួលចុះត្រង់ភ្នំចណ្ឌោរណៈ គឺបែរមុខទៅកាន់ចណ្ឌោរណបព៌ត អធិប្បាយថា ដើរចូលត្រង់ជើងភ្នំនោះ ។ បទថា **អគមា យេន បព្វតោ** សេចក្ដីថា ដំរីដ៏ប្រសើរនោះ ផុតចាកចំណងហើយ សម្រាកបន្តិច សម្ដែងទសពិធរាជធម៌ ថ្វាយព្រះរាជាថា បពិត្រ

មហារាជ សូមទ្រង់កុំប្រមាទជាដើម ។ មហាជននាំគ្នាបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ចេញអំពីនគរ ចូលទៅរកមាតាក្នុងថ្ងៃនោះឯង ហើយប្រាប់រឿងទាំងអស់ឲ្យមាតាជ្រាប ។ មេដំរីត្រេកអរ បានអនុមោទនាដល់ព្រះរាជាថា

ព្រះរាជាណា បានលែងកូនរបស់ខ្ញុំ ជាអ្នកកោតក្រែងចំពោះបុគ្គលចាស់សព្វៗ កាល សូមព្រះរាជានោះ ញុំាងដែនរបស់ពួកអ្នកកាសីឲ្យចម្រើន គង់ព្រះជន្មនៅអស់កាលយូរអង្វែងចុះ ដូច្នេះ ។

ព្រះរាជាទ្រង់ជ្រះថ្លាក្នុងគុណរបស់ព្រះពោធិសត្វ ត្រាស់ឲ្យបង្កើតស្រុកមិនឆ្ងាយអំពីស្រះឈូក ទ្រង់បដិបត្តិព្រះពោធិសត្វ និងមាតារបស់ព្រះពោធិសត្វជានិច្ច ។ ក្នុងកាលតមក មាតាព្រះពោធិសត្វក៏ស្លាប់ ព្រះពោធិសត្វកប់សពមាតាហើយ ទៅកាន់ការណ្ឌកៈអាស្រមបទ ។ ក្នុងទីនោះ មានឥសី ៥០០ ចេញអំពីហិមវន្តប្បទេស អាស្រ័យនៅ ។ ព្រះរាជាទ្រង់ប្រតិបត្តិឥសីទាំងនោះ ហើយទ្រង់ឲ្យជាងចម្លាក់ធ្លាក់ថ្មឲ្យដូចជារូបព្រះពោធិសត្វ ហើយទ្រង់ធ្វើមហាសក្ការៈ អ្នកជម្ពូទ្វីបប្រជុំគ្នារាល់ឆ្នាំដោយលំដាប់ ធ្វើនូវបុណ្យឆ្លងរូបដំរី ។

ព្រះរាជាក្នុងកាលនោះ បានជាអានន្ទ ក្នុងកាលឥឡូវនេះ មេដំរី ក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា ក្នុងកាលឥឡូវនេះ ព្រានព្រៃក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ដំរីដ៏ប្រសើរអ្នកចិញ្ចឹមមាតា ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងមាតុបោសកចរិយានេះ គប្បីពោលចំពោះដល់ទានបារមីជាដើម តាមសមគួរ តែសីលបារមី ជាបារមីកំពូល ព្រោះហេតុនោះ ទើបសីលបារមីនោះ លោកលើកឡើងកាន់ទេសនា ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពនៃព្រះមហាបុរសក្នុងចរិយានេះយ៉ាងនេះ គឺព្រះពោធិសត្វ សូម្បីកើតក្នុងកំណើតតិរច្ឆាន ក៏គង់តាំងចិត្តគោរពមាតា ដែលសមគួរដល់ភាពជាបុគ្គលដែលព្រះសព្វញ្ញុពុទ្ធ ទ្រង់សរសើរដោយភាពជាព្រហ្ម ជាបុព្វទេវា ជាបុព្វាចារ្យ ជាអាហុនេយ្យ បុគ្គលរបស់បុត្រជាដើម ហើយធ្វើទុកក្នុងចិត្តថា ឈ្មោះថា មាតា ជាអ្នកមានឧបការៈច្រើនរបស់បុត្រ ព្រោះហេតុនោះ ការបម្រើមាតា បណ្ឌិតទាំងឡាយបញ្ញត្តហើយ ។ ព្រះពោធិសត្វចិញ្ចឹមមាតាដោយគិតថា អញជាធំជាងដំរីច្រើនពាន់ មានអានុភាពច្រើន ជាមេហ្វូង ដំរីទាំងនោះមិនស្តាប់ មិនពិចារណាដល់អន្តរាយ ដល់ការនៅម្នាក់ឯង លះបង់ហ្វូង ជាដំរីម្នាក់ឯង បូជាមាតាដែលជាខេត្តនៃបុគ្គលមានឧបការៈ ។ ការឃើញបុរសវង្វេងផ្លូវហើយ ចូលទៅរកដោយសេចក្តីករុណា ជូនទៅរហូតដល់ដែនដីមនុស្ស ការអត់សង្កត់នូវអំពើខុសឆ្គងរបស់ព្រានព្រៃដែលបានធ្វើ ទោះបីអាចញាំញីបុរសដែលមកចាប់ខ្លួន មានហត្ថាចារ្យជាប្រធាន ដោយគ្រាន់តែឲ្យកើតនូវការតក់ស្លុតបាន ក៏មិនធ្វើយ៉ាងនោះ ដោយគិតថា សីលរបស់អញនឹងដាច់ ហើយចូលទៅចាប់បានដោយងាយ ដូចដំរីដែលទូន្មានល្អហើយ

ការអត់អាហារអស់ ៧ ថ្ងៃ ដោយគិតថា វៀរមាតាហើយ អញនឹងមិនបរិភោគអាហារណាមួយ ការមិនធ្វើចិត្តឲ្យកើតឡើងថា បុគ្គលនេះ ចងអញហើយផ្សាយមេត្តាដល់ព្រះរាជា ការសម្តែងធម៌ថ្វាយព្រះរាជាដោយន័យផ្សេងៗ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វី ដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។

អដ្ឋកថាមាតុបោសកចរិយា ចប់

# សុត្តន្តបិដក

## ភូរិទត្តចរិយាទី ២

[ ១២ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជានាគ ឈ្មោះភូរិទត្ត មានឫទ្ធិច្រើន កាលនោះ តថាគតបានទៅកាន់តាវត្តិង្សទេវលោក ជាមួយនឹងមហារាជ ព្រះនាមវិរូបក្ខៈ ។ តថាគតបានឃើញទេវតាទាំងឡាយ ដែលឆ្អែតស្កប់ស្កល់ដោយសេចក្តីសុខយ៉ាងក្រៃលែង ក្នុងតាវត្តិង្សទេវលោកនោះ បានជាតថាគតសមាទាននូវសីល និងវត្ត ដើម្បីទៅកាន់ស្ថានសួគ៌នោះ ។ តថាគតធ្វើនូវកិច្ចថែទាំសរីរៈ បរិភោគគ្រាន់តែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ អធិដ្ឋាននូវអង្គ ៤ ហើយដេកលើក្បាលដំបូក ។ កិច្ចដែលបុគ្គលណា គួរធ្វើដោយសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកនូវសម្បុរថ្ងៃ ស្បែក ដែលតថាគតឲ្យហើយនោះចុះ ។

អាលម្ពានព្រាហ្មណ៍ លុះនេសាទព្រាហ្មណ៍ ជាអកតញ្ញូ ប្រាប់កន្លែងហើយ ក៏ទៅចាប់យកតថាគតដាក់ក្នុងកំប្រោង ហើយប្រើតថាគតឲ្យលេងក្នុងស្រុក និគម ជនបទនោះៗ ។ កាលអាលម្ពានព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោងក្តី ញាំញីតថាគតដោយដៃក្តី

តថាគតមិនទីងទីងអាលម្ពានព្រាហ្មណ៍ ព្រោះតថាគតខ្វាចដាច់សីល ។ ការបរិច្ចាគជីវិតនៃខ្លួនរបស់តថាគត ជាធម្មជាតិស្រាលជាងបាច់ស្មៅទៅទៀត ឯការប្រព្រឹត្តកន្លងសីលនៃតថាគត ធ្ងន់ដូចជាការប្រែត្រឡប់ផែនដី ។ តថាគតលះបង់ជីវិត នៃតថាគតអស់រយជាតិ មិនមានចន្លោះ តថាគតមិនដែលទម្លាយសីល ព្រោះហេតុតែបានជាស្តេចចក្រពត្តិ ក្នុងទ្វីបទាំង ៤ ទេ ។ ចំណែកខាងតថាគតរក្សាសីល ( សូម្បីឃើញ ) នូវអាលម្ពានព្រាហ្មណ៍ដាក់តថាគតក្នុងកំប្រោង ក៏មិនធ្វើចិត្តឲ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។

## ភូរិទត្តចរិយាទី ២ ចប់

# អដ្ឋកថា

## ភូរិទត្តចរិយា

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភូរិទត្តចរិយាទី ២ ដូចតទៅនេះ ឈ្មោះថា **ភូរិទត្តោ** បានដល់ បុគ្គលមានបញ្ញាស្មើដោយផែនដី ទើបឈ្មោះថាភូរិទត្ត ឈ្មោះដែលមាតាបិតារបស់ព្រះពោធិសត្វដាក់ឲ្យ ក្នុងកាលនោះថា **ទត្ត** ។ ព្រះពោធិសត្វនោះ វិនិច្ឆ័យបានដោយល្អនូវបញ្ហា ដែលកើតឡើងក្នុងនាគពិភព ក្នុងស្ថានរបស់វិរូបក្ខមហារាជ និងក្នុងតាវត្តិង្ស ។ ថ្ងៃមួយ កាលព្រះបាទវិរូបក្ខមហារាជទៅកាន់ស្ថានត្រៃត្រិង្សជាមួយនាគបរិស័ទ រួចអង្គុយចោមរោមសក្កទេវរាជ បញ្ហាបានប្រាកដឡើងក្នុងវាំងពួកទេវតា បុគ្គលណាមួយមិនអាចឆ្លើយប្រស្នានោះបាន ។ ព្រះមហាសត្វអង្គុយលើបល្ល័ង្កដ៏ប្រសើរ ដែលសក្កៈអនុញ្ញាត ឆ្លើយនូវបញ្ហានោះបាន ។ លំដាប់នោះ សក្កទេវរាជក៏បូជាព្រះមហាសត្វដោយគ្រឿងក្រអូប និងផ្កាដែលជាទិព្វ ហើយពោលថាទត្តៈ អ្នកមានបញ្ញាដូចផែនដី តាំងពីនោះមក ព្រះពោធិសត្វក៏មានឈ្មោះថាភូរិទត្ត ។ បទថា **ភូរិ** ជាឈ្មោះរបស់ផែនដី ព្រោះហេតុនោះ ទើបព្រះមហាសត្វប្រាកដឈ្មោះថា ភូរិទត្ត ព្រោះត្រេកអរក្នុងអត្ថតាមសេចក្ដីពិត ព្រោះស្មើដោយផែនដី ព្រោះប្រកបដោយបញ្ញាធំដូចផែនដី ឈ្មោះថា **មហិទ្ធិកោ** ព្រោះប្រកបដោយឫទ្ធិរបស់នាគដ៏ធំ ដោយប្រការដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងកប្បនេះឯង ព្រះរាជឱរសរបស់ព្រះបាទពារាណសី ត្រូវបិតានិរទេសចេញអំពីដែន ក៏ចូលទៅកាន់ព្រៃ បាននៅរួមជាមួយនាគមាណវិកាម្នាក់ កាលនៅរួមគ្នាក៏បានទារក ២ អង្គ ប្រុស ១

ស្រី ១ បានតាំងឈ្មោះបុត្តថា សាគរព្រហ្មទត្ត ធីតាថា សមុទ្ទជា ។ ក្នុងកាលក្រោយមក ព្រះបិតាសោយទិវង្គត ព្រះរាជឱរសក៏ទៅកាន់ក្រុងពារាណសី ហើយគ្រងរាជសម្បត្តិ ក្នុងកាលនោះ នាគរាជឈ្មោះធតរដ្ឋគ្រងរាជសម្បត្តិក្នុងនាគពិភពប្រមាណ ៥០០ យោជន៍ ព្រះបាទធតរដ្ឋស្តាប់ពាក្យដែលអណ្តើកឈ្មោះចិត្តចូឡៈ ដែលពោលផ្តេសផ្តាសថា ព្រះបាទពារាណសីបំណងនឹងលើកព្រះរាជធីតាឲ្យដល់ទ្រង់ រាជធីតានោះ ឈ្មោះថាសមុទ្ទជា មានរូបស្អាត គួរមើល គួរជ្រះថ្លា ទើបបញ្ជូននាគមាណព ៤ នាក់ទៅហើយ សម្តួតព្រះបាទពារាណសីដែលទ្រង់មិនប្រាថ្នាលើកបុត្រីឲ្យដោយពិសនាគ កាលព្រះបាទពារាណសីត្រាស់ថា យើងព្រមលើកឲ្យ ទើបបញ្ជូនបណ្ណាការជំក្រៃលែង ទៅទទួលព្រះរាជធីតារបស់ព្រះបាទពារាណសីមកកាន់នាគពិភពដោយឫទ្ធិនាគ និងដោយបរិវារច្រើន ហើយតាំងទុកក្នុងតំណែងអគ្គមហេសី ។

ក្នុងកាលតមក ព្រះនាងអាស្រ័យព្រះបាទធតរដ្ឋ ក៏បានឱរស ៤ អង្គគឺសុទស្សនៈ ១ ទត្តៈ ១ សុភោគៈ ១ អរិដ្ឋៈ ១ ។ ក្នុងឱរសទាំងនោះឱរសឈ្មោះទត្តៈ ជាព្រះពោធិសត្វ ។ ព្រះពោធិសត្វនោះប្រាកដឈ្មោះថាភូរិទត្ត ព្រោះជាឈ្មោះដែលសក្កៈមានព្រះហឫទ័យត្រេកអរ ព្រះរាជទានឲ្យថា ភូរិទត្ត ដោយន័យដូចពោលខាងដើមហើយ ។ កាលនោះ បិតារបស់ព្រះរាជឱរសទាំងនោះ បានបែងចែករាជអាណាចក្រឲ្យគ្រប់គ្រង មួយអង្គ ១០០ យោជន៍ បានប្រាកដយសជំក្រៃលែង មាននាគកញ្ញាមួយអង្គ ១ ម៉ឺន

៦ ពាន់ចោមរោម ។ ព្រះបិតាក៏មានរាជអាណាចក្រ ១០០ យោជន៍ដូចគ្នា ។ ព្រះរាជឱរសទាំង ៣ យាងមកដើម្បីសួរសុខទុក្ខព្រះបិតាមាតា រៀងរាល់មួយខែម្តង ។ ចំណែកព្រះពោធិសត្វ យាងមកសួរសុខទុក្ខកន្លះខែម្តង ។

ថ្ងៃមួយ ព្រះពោធិសត្វយាងទៅឧបដ្ឋាកសក្កទេវរាជ ជាមួយព្រះបាទវិរូបក្ខមហារាជ ទ្រង់ឃើញសម្បត្តិរបស់សក្កទេវរាជគួរជាទីត្រេកអរក្រៃពេក មានពេជយន្តប្រាសាទ សុធម្មទេវសភា ដើមឈើសួគ៌ឈ្មោះបារិច្ឆត្តក បណ្ឌុកម្ពលសិលាអាសនៈ មានទេពអប្សរចោមរោម ទើបគិតថា សម្បត្តិប្រមាណប៉ុណ្ណេះ ក៏គង់រកបានលំបាក ក្នុងអត្តភាពរបស់នាគ តើនឹងបានសម្មាសម្ពោធិញ្ញាណមកអំពីណា ។ ទ្រង់រង្កៀសអត្តភាពរបស់នាគ ទ្រង់ត្រិះរិះថា អញនឹងទៅកាន់នាគពិភពរក្សាឧបោសថ ផ្គងនូវសីលប៉ុណ្ណោះ សីលនោះ នឹងជាគ្រឿងអប់រំបន្ទំពោធិញ្ញាណ ក្នុងទេវលោកនេះ នឹងមានហេតុការណ៍កើតឡើង ទើបទៅកាន់នាគពិភព ទូលមាតាបិតាថា បពិត្រព្រះមាតាបិតា ខ្ញុំនឹងរក្សាឧបោសថ ។ កាលព្រះមាតាបិតាត្រាស់ថា ចូរកូនរក្សាឧបោសថក្នុងនាគពិភពនេះឯង ភ័យធំនឹងមានដល់នាគ ដែលចេញទៅខាងក្រៅ ។ ព្រះពោធិសត្វធ្វើយ៉ាងនោះបានម្តង ត្រូវនាគកញ្ញាបៀតបៀនក្នុងកាលតទៅ មិនប្រាប់មាតាបិតា ត្រាស់ហៅមហេសីរបស់ខ្លួន មកប្រាប់ថា នែនាង អញនឹងទៅកាន់មនុស្សលោក ត្រង់ឆ្នេរស្ទឹងយមុនា មានដើមជ្រៃធំមួយ មិនឆ្ងាយអំពីដើមជ្រៃនោះ អញនឹងឆ្វាយវង្វេលលើដំបូក ដេកអធិដ្ឋានឧបោសថប្រកបដោយអង្គ ៤ ហើយនឹងធ្វើឧបោសថកម្ម ទើបចេញអំពីនាគ-

ពិភព ហើយធ្វើយ៉ាងនោះ ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ តថាគតបានទៅកាន់តាវត្តិង្សទេវលោក ជាមួយនឹងមហារាជ ព្រះនាមវិរូបក្ខៈ ។ តថាគតបានឃើញទេវតាទាំងឡាយដែលឆ្អែតស្កប់ស្កល់ដោយសេចក្តីសុខយ៉ាងក្រៃលែង ក្នុងតាវត្តិង្ស-ទេវលោកនោះ បានជាតថាគតសមាទាននូវសីល និងវត្ត ដើម្បីទៅកាន់ស្ថានសួគ៌នោះ ។ តថាគតធ្វើនូវកិច្ចថែទាំសរីរៈ បរិភោគគ្រាន់តែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ អធិដ្ឋាននូវអង្គ ៤ ហើយដេកលើក្បាលដំបូក ។ កិច្ចដែលបុគ្គលណា គួរធ្វើដោយសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកនូវសម្បុរថ្ងៃ ស្បែកដែលតថាគតឲ្យហើយនោះចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិរូបក្ខេន មហារញ្ញា** បានដល់ ទេវរាជដែលជាធំក្នុងពួកនាគ ឈ្មោះវិរូបក្ខៈ ។ បទថា **ទេវលោកំ** បានដល់ទេវលោកជាន់តាវត្តិង្ស ។ បទថា **អគច្ឆហំ** បានដល់ តថាគតបានទៅហើយចូលទៅជិតហើយ ។ បទថា **តត្ថ** បានដល់ ក្នុងទេវលោកនោះ ។ បទថា **បស្សឹ ត្វាហំ** បានដល់ តថាគតបានឃើញ ។ **តុ** សព្ទ ត្រឹមតែជានិបាត ។ បទថា **ឯកន្តំ សុខសមប្បិតេ** សេចក្តីថា ទេវតាដែលសម្បូរដោយសេចក្តីសុខ ដោយចំណែកមួយ គឺដល់ព្រមដោយសេចក្តីសុខ ដោយចំណែកមួយប៉ុណ្ណោះ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិ-បណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ស្ថានសួគ៌ឈ្មោះថា មានផស្សាយតនៈ

៦ មាន[១] ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនងាយនឹងធ្វើឧបមាឲ្យដល់កម្រិត ស្ថានសួគ៌ដែលមានសេចក្តីសុខបានឡើយ ដូច្នេះ ។ បទថា **តំសគ្គគមនត្ថាយ** បានដល់ ដើម្បីទៅដោយការកើតក្នុងស្ថានសួគ៌នោះ ។ បទថា **សីលព្វតំ** បានដល់ វត្ត ពោល គឺសីល ។ ម្យ៉ាងទៀត បទថា **សីលព្វតំ** បានដល់ ឧបោសថសីល និងវត្ត ដែលបានដល់ការប្រកាន់មាំក្នុងការបរិច្ចាគសរីរាវយវៈរបស់ខ្លួន ដោយបទជាដើមថា បុគ្គលណា ត្រូវការស្បែករបស់អញ ចូរកាន់យកចុះ ។ បទថា **សរីរកិច្ចំ** បានដល់ ការរក្សារាងកាយមានលុបមុខជាដើម ។ បទថា **កត្វា យាបនមត្តកំ** សេចក្តីថា បរិភោគអាហារត្រឹមតែឲ្យរាងកាយតាំងនៅបាន ដើម្បីធ្វើឥន្ទ្រិយទាំងឡាយឲ្យអស់ព្យសន៍ ។ បទថា **ចតុរោ អង្គេ** បានដល់ មានអង្គ ៤ ។ បទថា **អធិដ្ឋាយ** កែជា **អធិដ្ឋហិត្វា** ( អធិដ្ឋាន )។ បទថា **សេមិ** កែជា **សយាមិ** ( ដេក )។

បទថា **ឆវិយា** ជាដើម ជាពាក្យសម្តែងដល់អង្គទាំង ៤ នោះ ។ ក្នុងអង្គទាំង ៤ នោះ ការលះសម្បុរថ្ងៃ និងស្បែក ជាអង្គ ១ អាការដែលសល់ ជាអង្គដទៃៗ ទៀត ។ ក្នុងទីនេះ គប្បីឃើញថា លោកសង្គ្រោះយកឈាមដោយ **មំស** សព្ទនោះឯង ។ បទថា **ឯតេន** បានដល់ ដោយអវយវៈទាំងឡាយនេះ ។ បទថា **ហរាតុ សោ** ព្រះពោធិសត្វបវារណា ដោយការបវារណាមិនជាប់ជំពាក់ថា បុគ្គលណាមានកិច្ចដែលគប្បីធ្វើដោយសម្បុរថ្ងៃ និងស្បែកជាដើមនេះ បុគ្គលនោះ ចូរកាន់យកអវយវៈដែលខ្ញុំឲ្យនេះទៅចុះ

---

១- ពាក្យមានប្រមាណប៉ុណ្ណេះ មិនប្រទះក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកទេ ។

ខ្ញុំឲ្យទាំងអស់ ។

កាលព្រះមហាសត្វទ្រង់រក្សាឧបោសថរៀងរាល់កន្លះខែ ដោយទំនងនេះ កន្លងទៅអស់កាលយូរ ។ កាលកន្លងទៅយ៉ាងនេះ ថ្ងៃមួយ ព្រាហ្មណ៍នេសាទម្នាក់ មួយអន្លើដោយបុត្ររបស់ខ្លួន ឈ្មោះសោមទត្ត បានទៅដល់ទីនោះក្នុងពេលថ្ងៃរះឡើង ឃើញព្រះមហាសត្វចោមរោមដោយនាគកញ្ញា ទើបចូលទៅរកព្រះមហាសត្វ ។ ក្នុងវេលានោះឯង នាគកញ្ញាទាំងឡាយជ្រែកផែនដី គេចទៅកាន់ពិភពនាគ ។ ព្រាហ្មណ៍សួរព្រះមហាសត្វថា អ្នកនិរទុក្ខ អ្នកជានរណា ជាទេវតា យក្ស ឬនាគ ។ ព្រះពោធិសត្វត្រិះរិះថា បើព្រាហ្មណ៍នេះ ស្គាល់ខ្លួនតាមសេចក្តីពិត គប្បីទៅអំពីនេះ ប្រាប់ថា អាត្មាអញនៅក្នុងទីនេះដល់មហាជន ដោយហេតុនោះ គប្បីជាអន្តរាយដល់ការនៅរក្សាឧបោសថរបស់អញ បើដូច្នោះ អញនឹងនាំព្រាហ្មណ៍ចេញអំពីទីនេះ ទៅកាន់នាគពិភព ហើយប្រគល់សម្បត្តិដ៏ធំក្រៃលែងឲ្យ ព្រាហ្មណ៍នឹងត្រេកអរក្នុងនាគពិភពនោះដោយពិត ដោយហេតុនោះ ការរក្សាឧបោសថរបស់អញគប្បីនៅបានយូរ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់នឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ ខ្ញុំនឹងឲ្យយសធំដល់អ្នក ពិភពនាគគួរជាទីត្រេកអរ មក យើងទៅកាន់ភពនាគជាមួយគ្នាចុះ ។ ព្រាហ្មណ៍ពោលថា នែអ្នក ខ្ញុំមានបុត្រ បើគេទៅ ទើបខ្ញុំទៅ ។ ព្រះមហាសត្វត្រាស់ថា នែព្រាហ្មណ៍ ចូរអ្នកទៅនាំបុត្រមកចុះ ។ ព្រាហ្មណ៍ទៅប្រាប់សេចក្តីនោះដល់បុត្រ ហើយនាំកូនប្រុសមក ។ ព្រះមហាសត្វនាំជន

ទាំងពីរ គឺឪពុក និងកូន ទៅកាន់នាគពិភពដោយអានុភាពរបស់ខ្លួន ។ អត្ត-ភាពជាទិព្វ ប្រាកដដល់ឪពុកកូនក្នុងនាគពិភពនោះ ។ ព្រះមហាសត្វ ទ្រង់ប្រទានទិព្វសម្បត្តិឲ្យដល់ឪពុក និងកូន ហើយទ្រង់ប្រទាននាគកញ្ញាឲ្យ ម្នាក់ ៤០០ ។ ឪពុក និងកូនសោយសម្បត្តិដ៏ក្រៃលែង ។

ព្រះមហាសត្វទ្រង់ក៏មិនប្រមាទ បានរក្សាឧបោសថ ។ រៀងរាល់កន្លះខែ ទ្រង់បានយាងទៅសួរសុខទុក្ខព្រះរាជមាតាបិតា ហើយទ្រង់ពោលធម្ម-កថា បន្ទាប់ពីនោះ ក៏ទៅរកព្រាហ្មណ៍សួរដល់សុខ និងទុក្ខ ហើយត្រាស់ថា អ្នកគប្បីប្រាប់ដល់វត្ថុដែលអ្នកត្រូវការ ហើយត្រាស់បន្តថា អ្នកកុំនឿយណាយឡើយ ចូរត្រេកអរចុះ ទ្រង់ធ្វើបដិសណ្ឋារៈជាមួយសោមទត្ត ហើយយាងត្រឡប់ទៅកាន់លំនៅរបស់ព្រះអង្គ ។ ព្រាហ្មណ៍នៅក្នុងនាគពិភពបានមួយឆ្នាំ កើតនូវការធុញទ្រាន់ ព្រោះខ្លួនមានបុណ្យតិច ទើបនាំបុត្រដែលមិនប្រាថ្នានឹងទៅលាព្រះពោធិសត្វ មិនទទួលទ្រព្យជាច្រើន ដែលព្រះពោធិសត្វឲ្យ សូម្បីតែកែវមណី ដែលជាកែវឲ្យសម្រេចតាមសេចក្ដីប្រាថ្នា ក៏មិនទទួល ព្រោះខ្លួនជាបុគ្គលមិនមានវាសនា ពោលថា ខ្ញុំនឹងទៅកាន់មនុស្សលោក ហើយនឹងបួស ។ ព្រះមហាសត្វត្រាស់ឲ្យនាគមាណពនាំព្រាហ្មណ៍ មួយអន្លើដោយបុត្រទៅដល់មនុស្សលោក ។ ជនទាំងពីរ គឺឪពុក និងកូន ដោះគ្រឿងអលង្ការទិព្វ និងសំពត់ទិព្វចេញហើយ ចុះកាន់ស្រះបោក្ខរណី ដើម្បីងូតទឹក ក្នុងខណៈនោះគ្រឿងប្រដាប់ និងសំពត់ទិព្វក៏អន្តរធានទៅកាន់នាគពិភពមួយរំពេច ។ លំដាប់នោះ សំពត់ដែលជ្រលក់ដោយទឹកម្ចត់ និងសំពត់ចាស់ដែលខ្លួនស្លៀកក្នុងកាលមុន ក៏មកពាក់ត្រង់រាងកាយ ។ ជនទាំងពីរ គឺឪពុក

និងកូន កាន់ផ្គូព្រួញ និងលំពែង ចូលព្រៃបាញ់សត្វ សម្រេចជីវិតដូចមុន ។

សម័យនោះ តាបសមួយអង្គបានអាលម្ពាយមន្តអំពីស្តេចគ្រុឌ បានឲ្យមន្តនោះ មួយអន្លើដោយឱសថសម្រាប់ប្រកបជាមួយមន្តនោះ និងឧបចារៈនៃមន្ត ដល់ព្រាហ្មណ៍ម្នាក់ដែលបម្រើខ្លួន ។ ព្រាហ្មណ៍នោះគិតថា អញបានឧបាយជាគ្រឿងចិញ្ចឹមជីវិតហើយ ទើបស្នាក់នៅ ២-៣ ថ្ងៃ លាតាបសទៅដល់ឆ្នេរស្ទឹងយមុនាដោយលំដាប់ ស្វាធ្យាយនូវមន្តនោះ ដើរទៅតាមផ្លូវធំ ។ កាលនោះ នាគមាណវិកា ជាបរិចារិការបស់ព្រះពោធិសត្វ កាន់យកកែវមណីដែលជាកែវឲ្យសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដាក់កែវមណីលើផ្នូកខ្សាច់ ត្រង់ឆ្នេរស្ទឹងយមុនា សប្បាយក្នុងរាត្រីដោយពន្លឺកែវមណីនោះ លុះថ្ងៃរះឡើង បានឮសំឡេងមន្តរបស់ព្រាហ្មណ៍ ភិតភ័យជាខ្លាំង ដោយសម្គាល់ថាជាគ្រុឌ មិនកាន់យកកែវមណីទៅ ជ្រែកដីទៅកាន់ពិភពនាគ ។

ព្រាហ្មណ៍កាន់យកកែវមណីដើរទៅ ។ ខណៈនោះ ព្រាហ្មណ៍នេសាទចូលទៅកាន់ព្រៃជាមួយបុត្រដើម្បីបរបាញ់សត្វ ឃើញកែវមណីក្នុងដៃព្រាហ្មណ៍នោះ ស្គាល់ថាជាកែវមណីដែលឲ្យសម្រេចតាមប្រាថ្នារបស់ព្រះកូវិទត្ត ចង់បានកែវមណីនោះ ទើបធ្វើជាសន្ទនាប្រាស្រ័យជាមួយព្រាហ្មណ៍នោះ ដឹងនូវភាពដែលកែវមណីនោះមានមន្ត ( អានុភាព ) ទើបពោលថា បើអ្នកឲ្យកែវមណីនេះដល់ខ្ញុំ ខ្ញុំនឹងបង្ហាញនាគ ដែលមានអានុភាពច្រើនដល់អ្នក ហើយអ្នកនាំនាគនោះ ត្រាច់ទៅកាន់ស្រុក និគម រាជធានី នឹងបានទ្រព្យច្រើន ។ កាលព្រាហ្មណ៍ពោលថា បើដូច្នោះ ចូរបង្ហាញនាគមកចុះ ។ ព្រាហ្មណ៍

នេសាទ ក៏នាំព្រាហ្មណ៍នោះចូលទៅឈរ ក្នុងទីមិនឆ្ងាយ ចង្អុលឲ្យមើល ព្រះពោធិសត្វដែលដេកឆ្វាយរង្វេលលើកំពូលដំបូក ជាទីរក្សាឧបោសថ ។

ព្រះមហាសត្វឃើញព្រាហ្មណ៍នេសាទនោះ ត្រិះរិះថា អ្នកនេសាទនេះ ទោះបីអញនាំទៅកាន់ស្ថាននាគ ព្រោះខ្លាចក្រែងធ្វើអន្តរាយដល់ឧបោសថរបស់អញ ឲ្យតាំងនៅក្នុងមហាសម្បត្តិ ក៏នៅតែមិនប្រាថ្នា ចង់គេចចេញអំពីស្ថាននាគ មិនត្រូវការសូម្បីតែកែវមណីដែលអញឲ្យ តែឥឡូវនេះ បែរជានាំអាលម្ពាយមក ។ បើអញខឹងក្រោធបុរសទ្រុស្តមិត្តនេះ សីលនឹងដាច់ អញអធិដ្ឋានឧបោសថប្រកបដោយអង្គ ៤ អំពីខាងដើម ឧបោសថនោះ ចូរប្រព្រឹត្តទៅតាមដែលអាត្មាអញអធិដ្ឋានចុះ ។ ទោះបីអាលម្ពាយ ពុះ វះ ពន្ទះអញក៏ដោយ អញនឹងមិនក្រោធ ហើយបិទភ្នែកអធិដ្ឋានបារមីឲ្យជាបុរេចារិក ដាក់សីសៈត្រង់ចន្លោះរង្វេល ហើយដេកស្ងៀម ។ នេសាទព្រាហ្មណ៍ ពោលថា នែអាលម្ពាយ ចូរអ្នកចាប់នាគនេះ ចូរអ្នកឲ្យកែវមណីដល់ខ្ញុំចុះ ។ អាលម្ពាយឃើញនាគក៏ត្រេកអរ មិនពិចារណាដល់កែវមណី បោះកែវមណីក្នុងដៃ ពោលថា យកចុះព្រាហ្មណ៍ កែវមណីនោះ រអិលអំពីដៃព្រាហ្មណ៍ធ្លាក់ដល់ផែនដីប៉ុណ្ណោះ ក៏ជ្រែកផែនដីទៅកាន់នាគពិភពមួយរំពេច ។ នេសាទ-ព្រាហ្មណ៍ សាបសូន្យចាកកែវមណី និងចាកភាពជាមិត្តជាមួយព្រះភូរិទត្ត ទើបអស់ទីពឹង ចៀសចេញទៅ ។

អាលម្ពាយ ក៏យកឱសថដែលមានអានុភាពច្រើន លាបរាងកាយរបស់ខ្លួន ហើយទំពាបន្តិច ស្តោះទឹកមាត់ដាក់រាងកាយរបស់ខ្លួន រាយទិព្វមន្ត

ចូលទៅរកព្រះពោធិសត្វ ចាប់ត្រង់កន្ទុយអូសមក ហើយចាប់ក្បាលយ៉ាងណែន ប្របាច់មាត់របស់ព្រះពោធិសត្វ ទំពាឱសថ ស្ដោះឱសថ មួយអន្ទើដោយទឹកមាត់ចូលទៅក្នុងមាត់របស់ព្រះពោធិសត្វ ។ ព្រះមហាសត្វជាសត្វស្អាត មិនខឹងក្រោធ ព្រោះខ្លាចវិនាសសីល ក៏មិនបើកភ្នែក ។ នេសាទព្រាហ្មណ៍ ចាប់ព្រះពោធិសត្វត្រង់កន្ទុយដោយកម្លាំងឱសថ និងទិព្វមន្តចាប់សីសៈទុកខាងក្រោម រែងយកអាហារចេញ ឲ្យដេកសន្ធឹងលើផែនដី យកដៃប្របាច់ដូចប្របាច់ខ្នើយ ។ ឆ្អឹងទាំងឡាយ ហាក់ដូចជាបែកខ្ទេចខ្ទី ។

ព្រាហ្មណ៍នោះ ចាប់ត្រង់កន្ទុយបោកដូចបោកសំពត់ ព្រះពោធិសត្វទទួលទុក្ខដល់ម្ល៉េះ ក៏មិនមានសេចក្ដីក្រោធ រឭកដល់សីលរបស់ខ្លួនតែម្យ៉ាង ។ នេសាទព្រាហ្មណ៍ ធ្វើព្រះមហាសត្វឲ្យអស់កម្លាំង យកវល្លិចាក់ជាកំប្រោងដាក់ព្រះមហាសត្វចូលក្នុងកំប្រោងនោះ ។ រាងកាយរបស់ព្រះមហាសត្វធំព្រាហ្មណ៍នោះមិនអាចញាត់ក្នុងកំប្រោងបាន នេសាទព្រាហ្មណ៍ក៏យកកែងជើង ជាន់ព្រះមហាសត្វឲ្យចូលទៅខាងតែបាន ហើយពុនកំប្រោងទៅកាន់ភូមិមួយ ទម្លាក់ចុះត្រង់កណ្ដាលស្រុក ប្រកាសថា អ្នកណាចង់មើលនាគរាំអាចមើលបាន ពួកអ្នកស្រុកទាំងអស់ក៏នាំគ្នាមកមើល ។ ក្នុងខណៈនោះនេសាទដែលជាអាលម្ពាយក៏ពោលថា មហានាគ ចូរចេញមក ។ ព្រះមហាសត្វត្រិះរិះថា ថ្ងៃនេះអញគួរលេងឲ្យមហាជនពេញចិត្ត ដោយប្រការដូច្នេះ អាលម្ពាយបានទ្រព្យច្រើននឹងត្រេកអរ ដោះលែងអាត្មាអញ អញនឹងធ្វើវត្ថុដែលព្រាហ្មណ៍ឲ្យអញធ្វើ គ្រប់ប្រការ ។

អាលម្ពាយនេសាទពោលនឹងព្រះពោធិសត្វ ដែលចេញអំពីកំប្រោងថា ចូរធ្វើឲ្យធំ ព្រះមហាសត្វក៏ធ្វើខ្លួនឲ្យធំ កាលនាយនេសាទពោលថា ចូរធ្វើឲ្យតូច ចូរធ្វាយរង្វេល ចូរលា ចូរបើកពពារ ១ ពពារ ២ រហូតដល់ពពារ ១ ពាន់ ឲ្យខ្ពស់ ឲ្យទាប ឲ្យឃើញខ្លួន ឲ្យបាត់ខ្លួន ឲ្យឃើញពាក់កណ្តាលខ្លួន ឲ្យមានពណ៌ខៀវ ឲ្យមានពណ៌លឿង ឲ្យមានពណ៌ក្រហម ឲ្យមានពណ៌ស ឲ្យមានពណ៌ហង្សបាទ ឲ្យព្រួសផ្សែង ឲ្យព្រួសភ្លើង ឲ្យព្រួសទឹកជាដើម ។ ព្រះពោធិសត្វក៏និម្មិតអាការនោះៗ តាមដែលព្រាហ្មណ៍នោះប្រាប់ហើយសម្តែងការរាំ ។ ពួកមនុស្សឃើញដូច្នោះ កើតអស្ចារ្យក្នុងចិត្តមិនធ្លាប់មាន ទើបឲ្យប្រាក់ មាស សំពត់ និងគ្រឿងអលង្ការជាច្រើន ។ ព្រាហ្មណ៍បានទ្រព្យក្នុងស្រុកនោះប្រមាណ ១ ពាន់ ។ សេចក្តីពិត កាលព្រាហ្មណ៍ចាប់ព្រះមហាសត្វ បានសម្គាល់ថា អញបានទ្រព្យមួយពាន់នឹងដោះលែងពស់នេះ តែអាលម្ពាយនោះ កាលបានទ្រព្យនោះហើយ គិតថា ក្នុងស្រុកតូចៗ អញគង់បានទ្រព្យដល់ម៉្លេះ បើក្នុងនគរ អញនឹងបានទ្រព្យសន្ធឹកសន្ធាប់ ដោយលោភក្នុងទ្រព្យ ទើបមិនលែងព្រះពោធិសត្វ ។

អាលម្ពាយប្រមូលទ្រព្យក្នុងស្រុកនោះ ហើយឲ្យជាងធ្វើកំប្រោងរតនៈ ដាក់ព្រះមហាសត្វក្នុងកំប្រោងនោះ ខ្លួនឯងឡើងជិះយានតូចយ៉ាងសប្បាយ នាំបរិវារធំចេញអំពីស្រុក ឲ្យព្រះមហាសត្វសម្តែងតាមស្រុក និគម និងរាជធានី រហូតដល់នគរពារាណសី ។ អាលម្ពាយបានឲ្យទឹកឃ្មុំ លាជ និងសង្ហូវផង់ដល់ស្តេចនាគ ។ ព្រះមហាសត្វមិនព្រមទទួលអាហារ ព្រោះ

ខ្លាចអាលម្ពាយមិនដោះលែង សូម្បីព្រះពោធិសត្វ មិនទទួលអាហារ អាលម្ពាយក៏ញ៉ាំងមហាសត្វឲ្យសម្តែងតាមស្រុក ក្បែរទ្វារព្រះនគរទាំង ៤ ទិសជាដើមប្រមាណមួយខែ ដូចព្រះមានព្រះភាគត្រាស់ថា

អាលម្ពាយព្រាហ្មណ៍ លុះនេសាទព្រាហ្មណ៍ ជាអកតញ្ញូ ប្រាប់ កន្លែងហើយ ក៏ទៅចាប់យកតថាគតដាក់ក្នុងកំប្រោង ហើយប្រើ តថាគតឲ្យលេង ក្នុងស្រុក និគម ជនបទនោះៗ ។ កាល អាលម្ពាយព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោងក្តី ញាំញីតថាគត ដោយដៃក្តី តថាគតមិនខឹងនឹងអាលម្ពាយព្រាហ្មណ៍ ព្រោះ តថាគតខ្លាចដាច់សីល ។ ការបរិច្ចាគជីវិតនៃខ្លួន របស់តថាគត ជាធម្មជាតិស្រាលជាងបាច់ស្មៅទៅទៀត ឯការប្រព្រឹត្តកន្លង សីលនៃតថាគត ធ្ងន់ដូចជាការប្រែត្រឡប់ផែនដី ។ តថាគត លះបង់ជីវិតនៃតថាគតអស់រយជាតិ មិនមានចន្លោះ តថាគតមិន ដែលទម្លាយសីល ព្រោះហេតុតែបានជាស្តេចចក្រពត្តិក្នុងទ្វីប ទាំង ៤ ទេ ។ ចំណែកខាងតថាគតរក្សាសីល ( សូម្បីឃើញ ) នូវអាលម្ពាយព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោង ក៏មិនធ្វើចិត្ត ឲ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សំសិតោ** សេចក្តីថា អាលម្ពាយដែលបុគ្គល អកតញ្ញូចន្ទលប្រាប់លំនៅយ៉ាងនេះថា ស្តេចនាគនេះ ដេកត្រង់កំពូលដំបូក ក្បែរដើមជ្រៃនោះ ។ បទថា **អកតញ្ញុនា** អធិប្បាយថា នេសាទព្រាហ្មណ៍

ដែលទ្រុស្តមិត្ត ជាអ្នកមិនដឹងឧបការៈដែលមិត្តធ្វើហើយ ។ បទថា **អលម្ពា-យនោ** សេចក្តីថា ព្រាហ្មណ៍អ្នកចាប់ពស់ បានឈ្មោះយ៉ាងនេះថា **អលម្ពាយន** ព្រោះរាយវិជ្ជាឈ្មោះអលម្ពាយនៈ គឺវិជ្ជាសង្កត់ចិត្ត ។ បទថា **មមគ្គហិ** បានដល់ បានចាប់នូវតថាគត ។ បទថា **កីឡេតិ មំ តហឹ តហឹ** សេចក្តីថា ឲ្យតថាគតលេងក្នុងស្រុក និគម ជនបទ និងរាជធានី នោះៗ ដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន ។

បទថា **តិណតោបិ លហុកោ មម** សេចក្តីថា ការបរិច្ចាគជីវិតរបស់ខ្លួន ប្រាកដដល់តថាគតជារឿងស្រាលជាងការបរិច្ចាគស្មៅ ។ បទថា **បឋវី-ឧប្បតនំ វិយ** ព្រះមានព្រះភាគទ្រង់សម្តែងថា ចំណែកការកន្លងសីល រមែងប្រាកដដល់តថាគតថា ជាវត្ថុដែលធ្ងន់ជាងនោះ ដូចការត្រឡប់ផែនដី ដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ។ បទថា **និរន្តរំ ជាតិសតំ** សេចក្តីថា តថាគតគប្បីលះបង់ គឺអាចលះបង់ជីវិតរបស់តថាគត ព្រោះការមិនកន្លងសីលរឿយៗ អស់រយជាតិរបស់តថាគតមិនមែនតិច គឺក្នុងជាតិមួយរយ មិនមែនតិច ។ បទថា **នេវ សីលំ បភិន្ទេយ្យំ** សេចក្តីថា តថាគតមិនទម្លាយសីល សូម្បីតែមួយសិក្ខាបទ ដែលតថាគតសមាទានហើយ គឺមិនឲ្យវិនាស ។ បទថា **ចតុទ្ទីបាន ហេតុ** លោកសម្តែងថា ព្រោះហេតុចក្រពត្តិរាជសម្បត្តិដែលជាសិរី ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ប្រយោជន៍ ដែលទ្រង់លះបង់ជីវិតរបស់ព្រះអង្គ ហើយទ្រង់រក្សាសីលតែម្យ៉ាង ទាំងព្រះអង្គ

ក៏មិនបានទឹងក្រោធក្នុងព្រាហ្មណ៍នេសាទ និងក្នុងព្រាហ្មណ៍អាលម្ពាយដែលធ្វើឲ្យទ្រង់លំបាក ដើម្បីរក្សាសីលនោះ ទើបត្រាស់គាថាចុងក្រោយថា **អបិ** ច ដូច្នេះជាដើម ។ បទនោះ មានសេចក្ដីដូចបានពោលហើយនោះឯង ។

កាលព្រះពោធិសត្វធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់គ្រូពស់ ព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់សុបិនអាក្រក់ ទ្រង់មិនឃើញឱរសក្នុងទីនោះ ត្រូវសេចក្ដីសោកគ្របសង្កត់ ។ លំដាប់នោះ សុទស្សនៈដែលជាជេដ្ឋបុត្ររបស់ព្រះនាងបានដំណឹង ទើបបញ្ជូនសុភោគៈ និងព្រះអនុជទៅដោយពាក្យថា ចូរប្អូនទៅកាន់ព្រៃហិមពាន្ត ស្វែងរកភូរិទត្ត ដោយហោចក្នុងស្ទឹងធំទាំង ៥ ស្រះធំទាំង ៧ ហើយចូរត្រឡប់មក បញ្ជូនអរិដ្ឋៈ និងអនុជពៅថា បើពួកទេវតាបំណងនឹងស្ដាប់ធម៌នាំភូរិទត្តទៅទេវលោក ហើយនាំទៅក្នុងទីនោះ ចូរប្អូននាំភូរិទត្តត្រឡប់អំពីទេវលោក ចំណែកខ្លួនឯងពោលថា ខ្ញុំនឹងត្រាច់ទៅរកក្នុងមនុស្សលោក ក្លែងភេទជាតាបស ចេញអំពីនាគពិភព ។ ព្រះភគិនីមាតាដទៃរបស់ព្រះពោធិសត្វ ឈ្មោះអច្ចិមុខី មានសេចក្ដីស្រឡាញ់ក្នុងព្រះពោធិ-សត្វច្រើន ក៏សុំខ្លួនទៅដែរ ។ សុទស្សនៈក៏ឲ្យនាងអច្ចិមុខីកាឡាខ្លួនជាកូនកង្កែបដាក់ក្នុងរវាងជដា ត្រាច់ស្វែងរកគ្រប់ប្រកល្អក មានទីដែលធ្លាប់រក្សាឧបោសថរបស់ព្រះមហាសត្វជាដើម ដល់ក្រុងពារាណសីដោយលំដាប់ បានទៅកាន់ទ្វារព្រះរាជវាំង ។ ក្នុងកាលនោះ អាលម្ពាយបើកកំប្រោង ឲ្យព្រះភូរិទត្តលេងថ្វាយព្រះរាជា ក្នុងកណ្ដាលមហាជន ត្រង់លានព្រះរាជវាំង បានឲ្យសញ្ញាថា ចេញមកចុះមហានាគ ។

ព្រះមហាសត្វអើតព្រះសិសៈ ឃើញសុទស្សនៈជាបងក៏លូនចេញអំពីកំប្រោងចូលទៅរក ។ មហាជនភ័យខ្លាច ក៏ប្រញាប់ថយចេញទៅ ព្រះមហាសត្វថ្វាយបង្គំសុទស្សនៈហើយ ត្រឡប់ចូលកំប្រោង ។ អាលម្ពាយយល់ថា តាបសត្រូវនាគចឹក ទើបពោលថា កុំភ័យឡើយ កុំភ័យឡើយ ។ សុទស្សនៈពោលថា នាគនេះ នឹងធ្វើអ្វីយើងបាន ឈ្មោះថា គ្រូពស់ ប្រហែលយើងមិនមានឡើយ ហើយក៏ប្រកែកគ្នា សុទស្សនៈក៏ពោលថា អ្នកនាំនាគនេះមកសម្គុតកំហែង យើងនឹងឲ្យកូនកង្កែបកម្ចាត់អាលម្ពាយ ឲ្យដល់នូវសេចក្ដីលំបាក ទើបហៅប្អូនស្រីហើយលាដៃ ។ កូនកង្កែបដេកក្នុងផ្នួងសក់ បានឮសំឡេងរបស់សុទស្សនៈ ក៏ស្រែកជាសំឡេងកង្កែប ៣ ដង ហើយលោតចេញមកអង្គុយត្រង់ចង្កួយស្មា ខ្ជាក់ពិស ៣ តំណក់ ក្នុងដៃរបស់សុទស្សនៈ ហើយចូលទៅកាន់ផ្នួងសក់របស់សុទស្សនៈវិញ ។

សុទស្សនៈ បង្ហាញតំណក់ពិសពោលថា បើពិសនេះធ្លាក់លើផែនដីស្មៅ និងព្រៃទាំងឡាយរមែងវិនាសអស់ បើគ្រវែងទៅលើអាកាស នឹងរាំងភ្លៀង ៧ ឆ្នាំ បើចោលទៅក្នុងទឹក សត្វទឹកមានប៉ុន្មាននឹងស្លាប់អស់ ដើម្បីឲ្យព្រះរាជាទ្រង់ជឿ ទើបឲ្យជីករណ្ដៅ ៣ រណ្ដៅទី ១ ដាក់ពេញដោយភេសជ្ជៈផ្សេងៗ រណ្ដៅទី ២ ដាក់ដោយគោម័យ គឺលាមកគោ រណ្ដៅទី ៣ ដាក់ពេញដោយថ្នាំទិព្វ ហើយសម្រក់តំណក់ពិសត្រង់កណ្ដាលរណ្ដៅ ។ រំពេចនោះ ក៏ហុយផ្សែង ហើយឆេះជាអណ្ដាតភ្លើង តំណក់ពិសនោះ រាលទៅឆាបឆេះរណ្ដៅគោម័យ ហើយឆេះរាលដល់រណ្ដៅថ្នាំទិព្វ កាលឆេះថ្នាំទិព្វ

អស់ហើយក៏រលត់ ។ អាលម្ពាយឈរក្បែររណ្តៅនោះ ចំហាយផ្សែងពិស ពេលស្បែករបកទៅ ក្លាយជាពេកឃ្ញង់ល្ពៅ អាលម្ពាយភិតភ័យ ស្រែក ៣ ដងថា ខ្ញុំលែងនាគរាជ ។ ព្រះពោធិសត្វបានឮសំឡេងដូច្នោះ ចេញពីកំប្រោងរតនៈ ហើយនិម្មិតអត្តភាព ប្រដាប់ដោយអលង្ការសព្វយ៉ាង រួចឈរដោយអាកប្បកិរិយាដូចទេវរាជ សុទស្សនៈ និងអច្ចិមុខីក៏ឈរដូចគ្នា ។

លំដាប់នោះ សុទស្សនៈទូលព្រះរាជាថា ទ្រង់ជាក្មួយ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់ចូលទៅឱបថើបសីសៈ នាំចូលទៅខាងក្នុងព្រះនគរ ទ្រង់ធ្វើសក្ការៈ និងការរាប់អានដ៏ក្រៃលែង កាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រះភូរិទត្ត ទើបត្រាស់សួរថា នែបា អាលម្ពាយចាប់បា ដែលមានអានុភាពដល់ម៉្លេះបានដូចម្តេច ព្រះភូរិទត្តទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ហើយសម្តែងធម៌ដល់ម្ចាស់អ៊ំថា បពិត្រមហារាជ ធម្មតាព្រះរាជាគួរគ្រងរាជ្យដោយទំនងនេះ ។ លំដាប់នោះ សុទស្សនៈទូលថា បពិត្រម្ចាស់អ៊ំ ព្រះមាតារបស់ទូលបង្គំ កាលមិនបានឃើញភូរិទត្ត រមែងលំបាក ពួកទូលបង្គំមិនអាចបង្អែបង្អង់ក្នុងទីនេះបាន ហើយលាម្ចាស់អ៊ំទៅកាន់ភពនាគ ជាមួយព្រះភូរិទត្ត និងនាងអច្ចិមុខី ។

កាលនោះ ព្រះមហាបុរសដេកដោយមានជំងឺក្នុងនាគពិភពនោះ កាលអរិដ្ឋៈពោលសរសើរវេទ យញ្ញ និងព្រាហ្មណ៍ជាមួយនាគបរិស័ទ ដែលមកសាកសួរអាការជំងឺ ទើបព្រះពោធិសត្វទម្លាយវាទៈទាំងនោះ ហើយសម្តែងធម៌ដោយន័យផ្សេងៗ ឲ្យតាំងនៅក្នុងសីលសម្បទា និងទិដ្ឋិសម្បទា រក្សា

សីលដរាបដល់អស់ជីវិត ធ្វើឧបោសថកម្ម កាលអស់អាយុ ក៏ទៅកើតក្នុងស្ថានសួគ៌ ។

ព្រះមាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ ព្រាហ្មណ៍នេសាទ ក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ សោមទត្ត ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ នាងអច្ចិមុខី ក្នុងកាលនោះ បានមកជាឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ សុទស្សនៈ ក្នុងកាលនោះ បានមកជាសារីបុត្ត ក្នុងកាលឥឡូវនេះ សុភោគៈ ក្នុងកាលនោះ បានមកជាមោគ្គល្លាន ក្នុងកាលឥឡូវនេះ អរិដ្ឋៈ ក្នុងកាលនោះ បានមកជាសុនក្ខត្តៈ ក្នុងកាលឥឡូវនេះ ភូរិទត្ត ក្នុងកាលនោះ បានមកជាព្រះលោកនាថក្នុងកាលឥឡូវនេះ ។

ក្នុងភូរិទត្តចរិយានេះ គប្បីពោលដល់បារមីដ៏សេស របស់ព្រះភូរិទត្ត ដោយន័យដូចពោលហើយនោះឯង ។ ក្នុងចរិយានេះ គប្បីជ្រាបគុណានុភាពរបស់ព្រះពោធិសត្វយ៉ាងនេះថា ការដែលព្រះពោធិសត្វត្រូវនាងនាគកញ្ញា ១ ម៉ឺន ៦ ពាន់បម្រើ ដូចរូបវិចិត្រ ក្នុងនាគពិភពរបស់ខ្លួនដែលមានទំហំ ១០០ យោជន៍ ទោះបីតាំងនៅក្នុងភាពជាធំក្នុងស្ថាននាគ ដូចគ្មានទឹងសម្បត្តិក្នុងទេវលោក ក៏មិនបានស្រវឹងក្នុងភាពជាធំ បម្រើមាតាបិតារៀងរាល់កន្លះខែ ។ ការឱនលំទោនចំពោះបុគ្គលជាធំក្នុងត្រកូល ។ ការកាត់បញ្ហាដែលកើតឡើងដល់ពួកនាគ ពួកទេវតាជាន់ចាតុម្មហារាជិកា ពួកទេវតាជាន់តាវត្តិង្ស ដោយសស្ត្រា គឺបញ្ញារបស់ខ្លួន ក្នុងកណ្តាលបរិស័ទនោះៗ បានភ្លាមៗ ដូចកាត់

ដើមឈូកដោយដាវ ដែលសំលៀងល្អហើយ ដូច្នោះហើយ សម្តែងធម៌សមគួរដល់ចិត្តរបស់បរិស័ទទាំងនោះ លះនូវភោគសម្បត្តិ មានប្រការដូចពោលហើយ អធិដ្ឋានឧបោសថប្រកបដោយអង្គ ៤ មិនពិចារណាដល់រាងកាយ និងជីវិតរបស់ខ្លួន ។ ការព្រមធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់គ្រូពស់ព្រោះខ្លាចពោលខុសពាក្យប្តេជ្ញា ។ កាលអាលម្ពាយធ្វើទារុណកម្មមានប្រការផ្សេងៗ យ៉ាងនេះ គឺស្តោះទឹកមាត់លាយដោយថ្នាំពិសចូលក្នុងមាត់ ចាប់កន្ទុយអូសលើផែនដី ជាន់ព្រះពោធិសត្វឲ្យបានទទួលទុក្ខធំដល់ម្ល៉េះ ទោះបីអាចធ្វើអាលម្ពាយឲ្យក្លាយជាផេះត្រឹមតែក្រោធ ហើយបើកភ្នែកសម្លឹង ក៏ពិចារណាដល់សីលបារមី មិនមានចិត្តប្រទូស្តសូម្បីតែបន្តិច ព្រោះខ្លាចដាច់សីល ការធ្វើតាមចិត្តព្រាហ្មណ៍អាលម្ពាយ ដោយគិតថា នឹងឲ្យបុរសនោះបានទ្រព្យ ។ ទោះបីមិនទាន់អធិដ្ឋានសីល ក៏មិនក្រោធនឹងព្រាហ្មណ៍នេសាទដែលទ្រុស្តមិត្តជាបុគ្គលអកតញ្ញូ ដែលសុភោគៈនាំមក ។ ការទម្លាយវាទៈខុស ដែលអរិដ្ឋៈពោលហើយ សម្តែងធម៌ដោយបរិយាយផ្សេងៗ ក្នុងនាគបរិស័ទ តាំងនៅក្នុងសីល និងសម្មាទិដ្ឋិ ដូចលោកពោលថា

> គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វី ដល់ការធ្វើតាមព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។

## អដ្ឋកថាភូរិទត្តចរិយា ចប់

# សុត្តន្តបិដក

## ចម្បេយ្យចរិយាទី ៣

[ ១៣ ] ចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចនាគឈ្មោះចម្បេយ្យ មានឫទ្ធិច្រើន កាលនោះ តថាគតជាអ្នកប្រកបដោយធម៌ ជាអ្នកឆ្អែតស្កប់ស្កល់ដោយសីល និងវត្ត ។ កាលនោះ ហ្មពស់ចាប់តថាគត ដែលជាអ្នកប្រព្រឹត្តធម៌ រក្សាឧបោសថ យកទៅឲ្យលេងល្បែង ទៀបទ្វារក្រុងនៃស្តេច ។ ហ្មពស់នោះ គិតឲ្យមានពណ៌ខៀវ លឿង ក្រហម តថាគតធ្វើតាមចិត្តហ្មពស់ ឲ្យសម្រេចដូចគំនិតដែលគិត ។ តថាគតអាចនឹងធ្វើទីទួល ឲ្យជាទីទឹក ធ្វើទីទឹកឲ្យជាទីទួល បើតថាគតខឹងចំពោះហ្មពស់នោះ តថាគតធ្វើឲ្យខ្ទេចជាផេះមួយរំពេច ។ បើតថាគតបណ្តោយតាមអំណាចចិត្ត តថាគតនឹងសាបសូន្យចាកសីលប្រយោជន៍ដ៏ឧត្តម គឺភាពជាព្រះពុទ្ធ នឹងមិនសម្រេចដល់តថាគតដែលសាបសូន្យចាកសីលឡើយ ។ កាយនេះ ទោះបែកធ្លាយរោយរាយលើផែនដីនេះ ឲ្យដូចជាបុគ្គលរោយនូវសំដីស្រូវ ក៏តថាគតមិនទម្លាយសីលឡើយ ។

ចម្បេយ្យចរិយាទី ៣ ចប់

# អដ្ឋកថា

## ចម្បេយ្យនាគចរិយា

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចម្បេយ្យនាគចរិយាទី ៣ ដូចតទៅ បទថា **ចម្បេយ្យកោ** សេចក្ដីថា ស្ទឹងឈ្មោះចម្ប៉ា នៅក្នុងរវាងដែនអង្គៈ និងមគធៈ នាគពិភពដែលនៅខាងក្រោមស្ទឹងនោះ ក៏ឈ្មោះថា ចម្ប៉ាដូចគ្នា ព្រោះកើតមិនឆ្ងាយអំពីគ្នា នាគរាជកើតត្រង់នាគពិភពនោះ ទើបមានឈ្មោះថា ចម្បេយ្យកៈ ។ បទថា **តទាបិ ធម្មិកោ អាសឹ** សេចក្ដីថា ក្នុងកាលដែលតថាគតជានាគរាជ ឈ្មោះចម្បេយ្យកៈនោះ ក៏បានជាអ្នកប្រព្រឹត្តធម៌ ។

មានរឿងសង្ខេបថា ព្រះពោធិសត្វក្នុងកាលនោះ កើតក្នុងនាគពិភពឈ្មោះចម្ប៉ា ជានាគរាជឈ្មោះចម្បេយ្យកៈ មានឫទ្ធិច្រើន មានអានុភាពច្រើន នាគរាជនោះ សោយនាគរាជសម្បត្តិក្នុងនាគពិភពនោះ សោយឥស្សរិយសម្បត្តិ ដូចភោគសម្បត្តិរបស់ទេវរាជ ព្រោះមិនមានឱកាសបានបំពេញបារមី ក៏ត្រិះរិះថា ប្រយោជន៍អ្វីដោយកំណើតតិរច្ឆាននេះ អញនឹងរក្សាឧបោសថ ផុតចាកអំពីទីនេះហើយ នឹងបំពេញបារមីឲ្យល្អនោះឯង តាំងអំពីនោះមក ក៏រក្សាឧបោសថ ក្នុងប្រាសាទរបស់ខ្លួននោះឯង ។ នាងនាគមាណវិកាតែងខ្លួនហើយ មករកព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រិះរិះថា អញនៅលើប្រាសាទនេះ នឹងអន្តរាយដល់សីល ទើបចេញអំពីប្រាសាទទៅកាន់ឧទ្យាន ។ ក្នុងឧទ្យាននោះ ពួកនាគមាណវិកាក៏មករកទៀត ព្រះពោធិសត្វត្រិះរិះថា ក្នុងឧទ្យាននេះ សីលរបស់អញក៏នឹងសៅហ្មង អញនឹងចេញអំពីនាគពិភពនេះ ទៅកាន់មនុស្សលោក ហើយរក្សាឧបោសថ ។ តាំងអំពីនោះ

មក ព្រះពោធិសត្វក៏ចេញចាកអំពីនាគពិភព ក្នុងថ្ងៃឧបោសថ លះរាងកាយឲ្យជាទានដោយអធិដ្ឋានថា បុគ្គលឯណាត្រូវការស្បែកជាដើមរបស់អញ ចូរយកស្បែកចុះ ឬបំណងយកអាត្មាអញ ទៅឲ្យលេងកីឡា ក៏ចូរធ្វើចុះ ហើយដេកច្វាយរង្វេលលើកំពូលដំបូក ក្បែរផ្លូវ មិនឆ្ងាយអំពីស្រុកជាយដែនមួយកន្លែង រក្សាឧបោសថក្នុងថ្ងៃ ១៤ និងថ្ងៃ ១៥ ។ ក្នុងថ្ងៃ ១ កើត ១ រោច ទើបទៅកាន់នាគពិភព ។ កាលព្រះពោធិសត្វរក្សាឧបោសថយ៉ាងនេះ ពេលវេលាកន្លងទៅអស់កាលដ៏យូរ ។ លំដាប់នោះ ព្រះពោធិសត្វដែលអគ្គមហេសីឈ្មោះសុមនារបស់ព្រះអង្គពោលថា បពិត្រព្រះអង្គ ទ្រង់យាងទៅមនុស្ស-លោករក្សាឧបោសថ មនុស្សលោកនោះ ពេញដោយភយន្តរាយ ទើបព្រះពោធិសត្វប្រថាប់នៅត្រង់ស្រះបោក្ខរណីជាមង្គល ទ្រង់ប្រាប់និមិត្ត ៣ ប្រការដល់នាងសុមនាថា នែនាងដ៏ចម្រើន បើមានបុគ្គលណាមួយធ្វើអញឲ្យលំបាក ទឹកក្នុងស្រះបោក្ខរណីនេះ នឹងល្អក់ បើគ្រុឌចាប់ទៅ ទឹកនឹងក្តៅ បើគ្រូពស់ចាប់ ទឹកនឹងមានពណ៌ក្រហម ហើយអធិដ្ឋានឧបោសថក្នុងថ្ងៃ ១៤ ចេញអំពីនាគពិភព ទៅដេកលើក្បាលដំបូក ញុំាងដំបូកឲ្យស្អាតដោយលម្អនៃរាងកាយរបស់ព្រះពោធិសត្វ ព្រោះសរីរៈរបស់ព្រះពោធិសត្វមានពណ៌សដូចកម្រងប្រាក់ អើតសិរដូចកូនឃ្លីដែលធ្វើដោយសំពត់កម្ពលក្រហម មានសរីរៈប្រមាណប៉ុនយាមនង្គ័ល ក្នុងកាលកើតជាភូរិទត្ត ទំហំប្រមាណប៉ុនភ្លៅកាលជាសង្ខបាល ទំហំប៉ុនទូកកម្រោល ។

ក្នុងកាលនោះ មាណពអ្នកក្រុងពារាណសីម្នាក់ ទៅកាន់នគរតក្កសិលា

រៀនអាលម្ពាយមន្ត ចប់ហើយ ក៏ត្រឡប់មកកាន់មាតុភូមិរបស់ខ្លួន តាមផ្លូវ ឃើញព្រះមហាសត្វ គិតថា រឿងអ្វីដែលអញត្រូវត្រឡប់ទៅផ្ទះដោយដៃទទេ ចាប់នាគនេះទៅឲ្យលេងក្នុងស្រុក និគម រាជធានី ក៏នឹងបានប្រាក់បណ្ដើរ ទើបកាន់ឱសថទិព្វ រាយទិព្វមន្ត ចូលទៅរកនាគរាជ ។ នាគរាជ តាំងអំពីបានឮទិព្វមន្ត ហាក់ដូចដាក់ដុំដែកក្ដៅចូលទៅក្នុងត្រចៀកទាំងសងខាង ត្រង់សិររបស់ព្រះពោធិសត្វ ហាក់ដូចត្រូវប្រដាប់ ។ ព្រះមហាសត្វ អើតក្បាលចេញអំពីរង្វេល សម្លឹងមើល ពិចារណាថា អ្នកណាហ្ន៎ ឃើញគ្រូពស់ ទើបត្រិះរិះថា ពិសរបស់អញខ្លាំងក្លា បើអញក្រោធបញ្ចេញខ្យល់ច្រមុះ រាងកាយរបស់គ្រូពស់នេះ ក៏នឹងបែកខ្ចាត់ខ្ចាយដូចគំនរអង្កាម សីលរបស់អញនឹងដាច់ អញមិនគប្បីសម្លឹងមើលគ្រូពស់នេះឡើយ ។ ព្រះមហាសត្វ បិទភ្នែក ដាក់ក្បាលចូលទៅក្នុងរង្វេល ។ ព្រាហ្មណ៍ដែលគ្រូពស់ទំពាឱសថ រាយមន្ត ស្ដោះទឹកមាត់លើរាងកាយរបស់ព្រះមហាសត្វ ដោយអានុភាពនៃឱសថ និងមន្ត រាងកាយរបស់ព្រះមហាសត្វក៏ពុះពោរ ក្នុងទីដែលទឹកមាត់ពាល់ត្រូវ ។

លំដាប់នោះ ព្រាហ្មណ៍ដែលជាគ្រូពស់ ក៏ចាប់ត្រង់កន្ទុយអូសមកឲ្យដេកសន្ធឹង យកឈើដែលមានសណ្ឋានដូចជើងពពែ សង្កត់ធ្វើឲ្យអស់កម្លាំង ហើយចាប់សីសៈយ៉ាងណែន ព្រះមហាសត្វក៏ហាមាត់ គ្រូពស់ ក៏ស្ដោះទឹកមាត់ចូលទៅក្នុងមាត់របស់ព្រះមហាសត្វ កាច់ធ្មេញដោយកម្លាំងមន្ត និងឱសថ ឈាមពេញមាត់ ព្រះមហាសត្វអត់សង្កត់នូវទុក្ខវេទនាបែប

នេះ ព្រោះខ្លាចសីលរបស់ខ្លួនដាច់ ទើបបិទភ្នែក មិនធ្វើសូម្បីត្រឹមតែការសម្លឹងមើល ។ គ្រូពស់គិតថា អញនឹងធ្វើនាគរាជឲ្យអស់កម្លាំង ទើបប្រចាប់ពេញរាងកាយ ដូចធ្វើឲ្យធ្អឹងតាំងអំពីកន្ទុយមកបាក់បែក រុំដោយសំពត់ដែលធ្វើអំពីកប្បាស យកអំបោះចង ចាប់ត្រង់កន្ទុយយកសំពត់វាយ ឈាមប្រឡាក់ពេញរាងកាយព្រះមហាសត្វ ។ ព្រះមហាសត្វអត់សង្កត់នូវវេទនាដ៏ខ្លាំងក្លា ។

លំដាប់នោះ គ្រូពស់ដឹងថា ព្រះមហាសត្វអស់កម្លាំង ទើបយកវល្លិធ្វើកំប្រោង ចាប់ព្រះមហាសត្វដាក់ក្នុងកំប្រោង នាំទៅកាន់ស្រុកជាយដែន បានឲ្យពស់លេងកីឡាត្រង់កណ្ដាលផ្លូវដល់មហាជន ។ ព្រះមហាសត្វធ្វើនូវការសម្ដែងតាមព្រាហ្មណ៍ត្រូវការឲ្យធ្វើជាពណ៌ខៀវ ជារាង ៤ ជ្រុង ទំហំតូចធំជាដើម ធ្វើពពារ ១០០ ខ្លះ ១ ពាន់ខ្លះ មហាជនពេញចិត្ត បានឲ្យទ្រព្យដ៏ច្រើន ។ មួយថ្ងៃប៉ុណ្ណោះ បានកហាបណៈ ១ ពាន់ និងបរិក្ខារដែលមានតម្លៃ ១ ពាន់ ។ ព្រាហ្មណ៍គិតអំពីខាងដើមថា បានទ្រព្យ ១ ពាន់ ហើយនឹងដោះលែង ។ តែកាលបានទ្រព្យនោះហើយ គិតថា ក្នុងស្រុកជាយដែនប៉ុណ្ណោះ អញគង់បានទ្រព្យដល់ម៉្លេះ បើអញសម្ដែងដល់ព្រះរាជា និងអមាត្យធំរបស់ព្រះរាជា នឹងបានទ្រព្យច្រើនប៉ុនណាហ្ន៎ ទើបរករទេះ និងយានតូច ជាទីសប្បាយដាក់បរិក្ខារក្នុងរទេះ ខ្លួនឯងអង្គុយលើយានដែលជាទីសប្បាយ គិតថា អញឲ្យពស់នេះ សម្ដែងការលេងក្នុងស្រុក និគម និងរាជធានីដោយបរិវារធំ កាលឲ្យលេងក្នុងរាជសម្នាក់របស់ព្រះបាទឧគ្គសេន ក្នុងក្រុងពារាណសីហើយ ក៏នឹងដោះលែង ទើបធ្វើដំណើរទៅ ។ ព្រាហ្មណ៍

នោះ បានសម្លាប់កង្កែបឲ្យដល់នាគរាជៗ មិនបរិភោគដោយគិតថា បើអញបរិភោគ ព្រាហ្មណ៍នឹងសម្លាប់កង្កែបព្រោះអាស្រ័យអញរឿយៗ ។ ពេលនោះ ព្រាហ្មណ៍ក៏ឲ្យទឹកឃ្មុំ និងលាជដល់ព្រះមហាសត្វ ។ ព្រះមហាសត្វមិនបរិភោគសូម្បីទឹកឃ្មុំ និងលាជទាំងនោះ ដោយគិតថា បើអញបរិភោគអាហារ នឹងត្រូវស្លាប់ក្នុងកំប្រោងនេះឯង ។

ព្រាហ្មណ៍បានទៅដល់នគរពារាណសី ដោយអស់កាលប្រមាណ ១ ខែ ឲ្យព្រះពោធិសត្វលេងកីឡាត្រង់ទ្វារស្រុក បានទ្រព្យជាច្រើន ។ ព្រះរាជាឲ្យហៅព្រាហ្មណ៍នោះមកត្រាស់ថា ចូរធ្វើការសម្តែងឲ្យយើងមើល ព្រាហ្មណ៍ទទួលព្រះតម្រាស់ថា បពិត្រព្រះអង្គ ទូលបង្គំនឹងឲ្យពស់លេងកីឡាថ្វាយក្នុងថ្ងៃ ១៥ ស្អែកនេះ ព្រះរាជាត្រាស់ឲ្យវាយស្គរប្រកាសថា ស្អែកនេះ នាគរាជនឹងសម្តែងការលេងត្រង់លានព្រះរាជវាំង ចូមហាជនមកប្រជុំគ្នាមើលចុះ ។ ស្អែកឡើង ត្រាស់ឲ្យតាក់តែងលានព្រះរាជវាំង ហើយត្រាស់ហៅព្រាហ្មណ៍ឲ្យចូលគាល់ ។ ព្រាហ្មណ៍នាំព្រះមហាសត្វ ដែលនៅក្នុងកំប្រោងរតនៈទៅដាក់កំប្រោងលើកម្រាលដ៏វិចិត្រ ហើយអង្គុយ ។ ព្រះរាជាចុះអំពីប្រាសាទ ចោមរោមដោយមហាជន ប្រថាប់គង់លើរាជាសនៈ ។ ព្រាហ្មណ៍នាំព្រះមហាសត្វចេញមកហើយ ឲ្យសម្តែងការលេង ។ ព្រះមហាសត្វសម្តែងអាការទៅតាមព្រាហ្មណ៍គិតឲ្យសម្តែង មហាជនមិនអាចទ្រទ្រង់នូវប្រក្រតីរបស់ខ្លួនបាន លើកសំពត់គ្រវីទៅមក ហើយរោយនូវភ្លៀងរតនៈខាងលើព្រះមហាសត្វ ដូចព្រះមានព្រះភាគត្រាស់ថា **តទាបិ មំ ធម្មចារី** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **តទាបិ** សេចក្តីថា ក្នុងកាលដែលតថាគតជានាគរាជឈ្មោះចម្បេយ្យកៈ ។ បទថា **ធម្មចារី** សេចក្តីថា ប្រព្រឹត្តកុសលកម្មបថ ១០ នោះឯង ។ ឈ្មោះថា **ធម្មចារី** ព្រោះមិនប្រព្រឹត្តវត្ថុដែលជាអធម៌ សូម្បីបន្តិចបន្តួច ។ បទថា **ឧបវុដ្ឋឧបោសថំ** សេចក្តីថា រក្សាឧបោសថដោយការរក្សាអរិយុបោសថសីលប្រកបដោយអង្គ ៨ ។ បទថា **រាជទ្វារម្ហិ កីឡតិ** សេចក្តីថា ឲ្យលេងត្រង់ទ្វាររាជវាំងរបស់ព្រះបាទឧគ្គសេន ក្នុងក្រុងពារាណសី ។ បទថា **យំ យំ សោ វណ្ណំ ចិន្តយិ** សេចក្តីថា ព្រាហ្មណ៍ដែលជាគ្រូពស់នោះគិតថា ចូរធ្វើជាពណ៌ណាមួយ មានពណ៌ខៀវជាដើម ដូចព្រះមានព្រះភាគត្រាស់ថា **នីលំ វ បីតិលោហិតំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ **វា** សព្ទ ក្នុងបទថា **នីលំ វា** ប្រាប់ភាពមិនពិតប្រាជក ។ **វា** សព្ទ ធ្វើសំឡេងឲ្យខ្លីជា **វ** ដើម្បីងាយស្រួលក្នុងការចងគាថា ។ ដោយ **វា** សព្ទនោះ លោកសង្គ្រោះយកការផ្សេងគ្នារបស់ពណ៌ មានពណ៌សជាដើម ការផ្សេងគ្នានៃសណ្ឋាន មានសណ្ឋានមូលជាដើម ការផ្សេងគ្នានៃទំហំ មានតូច និងធំជាដើម ពាក្យដ៏សេស ដូចពាក្យដែលពោលហើយ ។ បទថា **តស្ស ចិត្តានុវត្តន្តោ** បានដល់ ផ្លាស់ប្តូរទៅតាមការគិតរបស់គ្រូពស់នោះ ។ បទថា **ចិន្តិតសន្និភោ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតជួយឲ្យមហាជនចាប់អារម្មណ៍ ដោយអាការដែលគ្រូពស់គិតឲ្យធ្វើ ។ អានុភាពរបស់តថាគត មិនមែនសម្តែងអាការតាមដែលគ្រូពស់គិតតែម៉្យាងប៉ុណ្ណោះទេ ដែលពិត តថាគតនិម្មិតទីគោកឲ្យជាទឹកខ្វះ និម្មិតទីទឹកឲ្យជាគោកខ្វះ ។

តថាគតអាចធ្វើផែនដីធំឲ្យក្លាយជាទឹកបាន អាចធ្វើទឹកឲ្យក្លាយជាដីបាន តថាគតមានអានុភាពធំ ដោយប្រការដូច្នេះ ។

បទថា **ថលំ ករេយ្យមុទកំ ឧទកម្បិ ថលំ ករេ** សេចក្តីថា តថាគតអាចធ្វើផែនដីធំ ដែលជាគោកឲ្យជាទឹកបាន អាចធ្វើទឹកឲ្យជាផែនដីបាន តថាគតមានអានុភាពធំ ដោយប្រការដូច្នេះ ។

បទថា **យទិហំ តស្ស កុប្បេយ្យំ** សេចក្តីថា បើតថាគតក្រោធអាក់អន់ចំពោះគ្រូពស់នោះ ។ បទថា **ខណេន ជារិកំ ករេ** សេចក្តីថា គប្បីធ្វើឲ្យក្លាយជាផេះក្នុងខណៈក្រោធនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលទ្រង់អាចកម្ចាត់សេចក្តីវិនាសដែលកើតដល់ព្រះអង្គក្នុងកាលនោះ ឥឡូវនេះ ដើម្បីសម្តែងដល់បំណងដែលទ្រង់មិនធ្វើការកម្ចាត់គ្រូពស់នោះ ទើបត្រាស់ថា **យទិ ចិត្តវសី ហិស្សំ** ដូច្នេះជាដើម ។

អត្ថនៃគាថានោះ មានសេចក្តីដូចតទៅនេះ បើតថាគតប្រព្រឹត្តទៅក្នុងអំណាចរបស់ចិត្ត ដោយហេតុត្រឹមតែក្រោធ ហើយសម្លឹងមើលដោយគិតថា គ្រូពស់នេះបៀតបៀនអញពន់ពេក ប្រហែលជាមិនស្គាល់អានុភាពរបស់អញណ្ហើយចុះ អញនឹងសម្តែងអានុភាពរបស់អញ ឲ្យគ្រូពស់ឃើញដូច្នេះ ខណៈនោះ គ្រូពស់នឹងបែកខ្ទេចខ្ទី ដូចអង្កាមដូច្នោះ ។ តថាគតក៏នឹងវិនាសចាកសីល តាមដែលតថាគតបានសមាទាន ។ កាលតថាគតវិនាសចាកសីល មានសីលដាច់ ប្រយោជន៍ណាដែលតថាគតប្រាថ្នា តាំងអំពីទៀបបាទមូល

របស់ព្រះទសពលព្រះនាមទីបង្ករ ប្រយោជន៍ដ៏ឧត្តម គឺភាពជាព្រះពុទ្ធនោះ ក៏នឹងមិនសម្រេច ។ បទថា **កាមំ ភិជ្ជតុយំ កាយោ** សេចក្តីថា កាយ មានការមិនទៀង ត្រូវជុសខាត់ ត្រូវគក់ច្របាច់ ត្រូវបែកធ្លាយ និងត្រូវកម្ចាត់ ជាធម្មតា ធំចម្រើនឡើងដោយបាយ និងនំ គឺមហាភូតរូប ៤ នេះ ចូរបែក គឺចូរវិនាសទៅ ចូរខ្ចាត់ខ្ចាយទៅដូចអង្កាម ដែលបន្សាត់ទៅក្នុងខ្យល់ខ្លាំង ក្នុងទីនេះក៏ដោយចុះ ។ បទថា **នេវ សីលំ បភិន្ទេយ្យំ វិកិរន្តេ ភុសំ វិយ** លោកសម្តែងថា តថាគតគិតថា កាលរាងកាយនេះខ្ចាត់ខ្ចាយទៅដូចអង្កាម តថាគតក៏មិនទម្លាយសីល ដែលជាហេតុនៃការសម្រេចប្រយោជន៍ដ៏ឧត្តម ។ តថាគតមិនគិតដល់រាងកាយ និងជីវិត បំពេញសីលបារមីប៉ុណ្ណោះ ហើយ អត់ធន់ក្នុងទុក្ខបែបនោះ ក្នុងកាលនោះ ។

កាលព្រះមហាសត្វធ្លាក់ក្នុងកណ្តាប់ដៃរបស់គ្រូពស់អស់ ១ ខែពេញ ព្រះមហាសត្វអត់អាហារអស់កាលមានប្រមាណប៉ុណ្ណោះ ។ នាងសុមនាសម្លឹង មើលស្រះបោក្ខរណី ដោយគិតថា ស្វាមីរបស់អញយឺតយូរពន់ពេក មាន ហេតុអ្វីហ្ន៎ កាលឃើញទឹកមានពណ៌ក្រហម ក៏ដឹងថា ស្វាមីត្រូវគ្រូពស់ចាប់ ក៏ចេញពីនាគពិភពទៅជិតដំបូក ឃើញទីដែលមហាសត្វត្រូវចាប់ និងទទួល ទារុណកម្ម យំសោកខ្សឹកខ្សួល ទៅកាន់ស្រុកជាយដែនស្តួររក កាលជ្រាប ការប្រព្រឹត្តទៅនោះហើយ ក៏ទៅកាន់ក្រុងពារាណសី ឈរយំលើអាកាស ក្បែរទ្វារព្រះរាជវាំង ព្រះមហាសត្វកំពុងសម្តែងការរាំ សម្លឹងមើលអាកាស ឃើញនាងសុមនា មានចិត្តខ្មាស ចូលក្នុងកំប្រោង ហើយដេក ។

ខណៈដែលព្រះពោធិសត្វចូលក្នុងកំប្រោង ព្រះរាជាទ្រង់ត្រិះរិះថា មានហេតុអ្វីហ្ន៎ ប្រជាប់ឈរទតក្នុងទីផ្សេងៗ ឃើញនាងសុមនាឈរលើអាកាស ត្រាស់សួរថា នាងជាអ្នកណា កាលទ្រង់ជ្រាបថា នាងជានាគកញ្ញា ទ្រង់សម្គាល់ថា នាគរាជប្រហែលជាឃើញនាគកញ្ញានេះ ទើបខ្លាសហើយចូលក្នុងកំប្រោង ដោយឥតសង្ស័យ ឫទ្ធានុភាពតាមដែលបានសម្ដែងនេះ ជារបស់នាគរាជប៉ុណ្ណោះ មិនមែនរបស់គ្រូពស់ ទើបត្រាស់សួរថា នាគរាជនេះមានអានុភាពដល់ម្ល៉េះ ធ្លាក់ក្នុងដៃព្រាហ្មណ៍នេះបានដូចម្ដេច ទ្រង់បានឮថា នាគរាជនេះមានសីល ប្រព្រឹត្តធម៌ រក្សាឧបោសថក្នុងថ្ងៃ ១៤ និងថ្ងៃ ១៥ ប្រគល់រាងកាយរបស់ខ្លួនឲ្យជាទាន ដេកលើកំពូលដំបូកក្បែរផ្លូវធំ ត្រូវគ្រូពស់ចាប់ក្នុងទីនោះ នាគរាជនេះ មាននាគកញ្ញាច្រើនពាន់ ប្រៀបដូចទេព-អប្សរ ។ សម្បត្តិក្នុងនាគពិភព ដូចគ្នានឹងសម្បត្តិក្នុងទេវលោក ។ នាគរាជនេះមានឫទ្ធិច្រើន មានអានុភាពច្រើន អាចត្រឡប់ផែនដីទាំងមូលបាន ។ នាគរាជគិតតែម្យ៉ាងថា សីលរបស់អញនឹងដាច់ ទើបព្រមទទួលទុក្ខដ៏ខ្លាំងក្លាបែបនេះ ព្រះរាជាទ្រង់កើតសេចក្ដីសង្វេគ ក្នុងវេលានោះឯង បានព្រះរាជទានទ្រព្យជាច្រើន យស និងឥស្សរៈយ៉ាងធំដល់ព្រាហ្មណ៍ ដែលជាគ្រូពស់ ហើយទ្រង់ឲ្យដោះលែងដោយព្រះតម្រាស់ថា នែព្រាហ្មណ៍ដ៏ចម្រើន ចូរអ្នកដោះលែងនាគរាជនេះចុះ ។

ព្រះមហាសត្វញ៉ាំងភេទនាគរាជឲ្យវិនាសទៅ ក្លាយជាមាណព ប្រាកដដូចទេវកុមារ ។ នាងសុមនាក៏ចុះអំពីអាកាស ឈរក្បែរព្រះពោធិសត្វនោះ ។

នាគរាជថ្វាយបង្គំព្រះរាជា ទូលថា បពិត្រមហារាជ សូមទ្រង់យាងមកទត លំនៅរបស់ខ្ញុំចុះ ដូចព្រះមានព្រះភាគត្រាស់ថា

ចម្បេយ្យកនាគ បានរួចហើយ ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជាក្នុងដែនកាសី សូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ អ្នកញុំាងដែនកាសីឲ្យចម្រើន សូមថ្វាយបង្គំព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមផ្គងក្រពុំម្រាមដៃចំពោះព្រះអង្គ ទូលព្រះបង្គំជាខ្ញុំ ចង់បង្ហាញនូវលំនៅរបស់ទូលព្រះបង្គំជាខ្ញុំ ( ដល់ព្រះអង្គ ) ដូច្នេះ ។

ព្រះរាជា ទ្រង់អនុញ្ញាតឲ្យស្តេចនាគត្រឡប់ទៅកាន់នាគពិភព ព្រះមហាសត្វនាំព្រះរាជា មួយអន្លើដោយរាជបរិវារ ទៅកាន់នាគពិភព សម្តែងឥស្សរិយសម្បត្តិរបស់ខ្លួន ឲ្យទ្រង់ស្នាក់នៅក្នុងនាគពិភពនោះ ២-៣ ថ្ងៃ ទើបឲ្យវាយស្គរប្រកាសថា ពួករាជបរិវារទាំងអស់ ចូរកាន់យកទ្រព្យ មានប្រាក់ និងមាសជាដើមតាមសេចក្តីត្រូវការ ប្រគល់ទ្រព្យថ្វាយព្រះរាជាច្រើនរយរទេះ ។ ព្រះមហាសត្វថ្វាយឱវាទ ដោយរាជធម្មកថា ១០ ប្រការជាដើមថា បពិត្រមហារាជ ធម្មតាព្រះរាជា គួរបរិច្ចាគទាន គួររក្សាសីល គួរធ្វើការរក្សាគ្រប់គ្រងក្នុងកិច្ចដោយធម៌ទាំងពួង ហើយបញ្ជូនព្រះរាជាត្រឡប់ ។ ព្រះរាជាយាងចេញអំពីនាគពិភពដោយយសធំ ដល់ក្រុងពារាណសី ។ បានឮថា តាំងអំពីនោះមក ក្នុងជម្ពូទ្វីបក៏មានប្រាក់ និងមាសជាច្រើន ។ ព្រះមហាសត្វរក្សាសីល ធ្វើឧបោសថកម្មរៀងរាល់កន្លះខែ មួយអន្លើដោយបរិស័ទ បានទៅកើតក្នុងស្ថានសួគ៌ ។

*គ្រូពស់ក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ នាងសុមនា ក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ ឧគ្គសេនរាជក្នុងកាលនោះ បានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចម្បេយ្យកនាគរាជ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។ ក្នុងចរិយានេះ គប្បីពោលដល់បារមីដ៏សេសរបស់ព្រះមហាសត្វនោះ តាមសមគួរ អានុភាពដែលគួរអស្ចារ្យរបស់ព្រះពោធិសត្វក្នុងទីនេះ មានន័យដូចពោលហើយខាងដើមនោះឯង ។*

## អដ្ឋកថាចម្បេយ្យកចរិយា ចប់

# សុត្តន្តបិដក

## ចូឡពោធិចរិយាទី ៤

[ ១៤ ] ចរិយាដទៃទៀត កាលដែលតថាគតជាបរិញ្វជក ឈ្មោះចូឡពោធិ ជាអ្នកមានសីលល្អ ឃើញនូវភពថាជារបស់គួរខ្លាចហើយ ក៏ចេញទៅសាងអភិនេស្រ្កមណ៍ ។ នាងព្រាហ្មណី មានសម្បុរដូចមាស នាងជាភរិយារបស់តថាគត នាងមិនមានអាល័យក្នុងវដ្តៈ ក៏បានចេញទៅសាងអភិនេស្រ្កមណ៍ដែរ នាងមិនមានអាល័យ លះបង់នូវផៅពង្ស មិនជាប់នឹងពួកត្រកូល តថាគតនិងព្រាហ្មណីនោះ ដើរទៅកាន់ស្រុក និងនិគម ក៏បានចូលទៅកាន់ក្រុងពារាណសី ។ យើងទាំងពីរនាក់ ជាអ្នកមានបញ្ញា នៅជិតក្រុងពារាណសីនោះ មិនទៅប្រឡូកប្រឡំក្នុងពួកត្រកូលទេ នៅក្នុងឧទ្យានស្តេច ជាទីមិនមានសំឡេង មិនមានវឹកវរ ។ ព្រះរាជាទ្រង់ស្តេចទៅទតឧទ្យាន បានឃើញព្រាហ្មណី ទ្រង់ចូលទៅសួរតថាគតថា ស្រីនេះជាភរិយារបស់លោក ឬជាភរិយារបស់អ្នកណា ។ កាលព្រះរាជាត្រាស់សួរយ៉ាងនេះហើយ តថាគតបានទូលព្រះរាជាថា ស្រីនេះមិនមែនជាភរិយារបស់អាត្មាភាពទេ គ្រាន់តែជាស្រីមានធម៌ត្រូវគ្នា មានសាសនាត្រូវគ្នាប៉ុណ្ណោះ ។ ព្រះរាជាមានព្រះហឫទ័យប្រតិព័ទ្ធ ចំពោះបរិញ្វជិកានោះ ក៏ប្រើរាជបុរសឲ្យចាប់សង្កត់សង្កិនដោយកម្លាំង យកចូលទៅខាងក្នុងព្រះរាជវាំង ។ កាលភរិយា មានជាតិជាមួយគ្នា មានសាសនាត្រូវគ្នារបស់តថាគត

ដែលរាជបុរស ទាញអូសនាំទៅនោះ សេចក្ដីក្រោធក៏កើតឡើង ដល់តថាគត ។ កាលសេចក្ដីក្រោធកើតឡើង តថាគតពិចារណា នូវសីល វត្ត ផ្ចញ់ផ្ចាល់នូវសេចក្ដីក្រោធក្នុងទីនោះ មិនឲ្យចម្រើន ឡើងបាន បើប្រសិនជាអ្នកណាមួយ ចាក់ព្រាហ្មណីនោះ ដោយ លំពែងដ៏មុត តថាគតក៏មិនទម្លាយសីល ព្រោះហេតុនៃ ពោធិញ្ញាណ ព្រាហ្មណីនោះ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងកម្លាំង តថាគតក៏មិនមែនជាមិនមានឡើយ តែសព្វញ្ញុ-តញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជា តថាគតរក្សាសីលតែម្យ៉ាង ។

## ចូឡពោធិចរិយាទី ៤ ចប់

# អដ្ឋកថា

## ចូឡពោធិចរិយា

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចូឡពោធិចរិយាទី ៤ ដូចតទៅនេះ បទថា **ចូឡពោធិ** សេចក្តីថា ឈ្មោះថា **ចូឡពោធិ** លោកលើកឡើងក្នុងចរិយានេះ សំដៅដល់អត្តភាពរបស់បរិព្វាជក ឈ្មោះមហាពោធិ ។ តែក្នុងជាតកនេះ មិនគប្បីឃើញថា ព្រះមហាសត្វជាបងជាប្អូនជាដើមរបស់មហាពោធិ ។ បទថា **សុសីលវា** បានដល់ មានសីលដោយល្អ អធិប្បាយថា ដល់ព្រមដោយសីល ។ បទថា **ភវំ ទិស្វាន ភយតោ** បានដល់ ឃើញភព មានកាមភពជាដើម ដោយភាពជារបស់គួរភ័យខ្លាច ។ ក្នុងបទថា **នេក្ខម្មំ** នេះ គប្បីឃើញថា លុប ច សព្ទ ។ ដោយហេតុនោះ គួរលើកបទថា **ទិស្វាន** ចូលមកជា **នេក្ខម្មំ ទិស្វាន** ( ឃើញនេក្ខម្មៈ ) ។ បទនេះលោកអធិប្បាយថា ឃើញភព មានកាមភពជាដើម ប្រាកដជារបស់គួរខ្លាចក្នុងសង្សារវដ្ត ដោយពិចារណាសង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ សេចក្តីទុក្ខក្នុងអបាយ អតីតវដ្តមូលទុក្ខ អនាគតវដ្តមូលទុក្ខ និងទុក្ខព្រោះការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន និងឃើញនេក្ខម្មៈទាំង ៣ គឺនិព្វាន ១ សមថវិបស្សនាដែលជាឧបាយនៃនិព្វាននោះ ១ និងបព្វជ្ជា ដែលជាឧបាយនៃសមថ-វិបស្សនានោះ ១ ដោយភាពជាបដិបក្ខចំពោះភពនោះដោយញាណចក្ខុ ដែលសម្រេចដោយការស្តាប់ជាដើម ហើយទើបចេញអំពីភាពជាគ្រហស្ថ ដែលប្របូកប្របល់ដោយទោសសន្ទឹកសន្ទាប់ ដោយការបួសជាតាបស ។

បទថា **ឧតុតិយិកា** បានដល់ កិរិយាអំពីមុន គឺកិរិយាកាលនៅជាគ្រហស្ថ ។ បទថា **កនកសន្និភា** បានដល់ មានពណ៌សម្បុរដូចមាស ។ បទថា **វគ្គេ អនបេក្ខា** បានដល់ មិនបានអាល័យក្នុងសង្ឃារវគ្គ ។ បទថា **នេក្ខម្មំ អភិនិក្ខមិ** បានដល់ ចេញអំពីផ្ទះដើម្បីនេក្ខម្មៈ បានដល់ បួស ។

តណ្ហា ឈ្មោះថា **អាលយ** ព្រោះជាហេតុឲ្យសត្វជាប់នៅ ។ ឈ្មោះថា **និរាលយ** ព្រោះមិនមានតណ្ហា ។ ឈ្មោះថា **ឆិន្នពន្ធុ** ព្រោះបន្ទាប់អំពីនោះ ក៏កាត់នូវចំណង គឺតណ្ហាក្នុងញាតិទាំងឡាយ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងដល់ការមិនមានការជាប់ជំពាក់ ក្នុងការគ្រប់គ្រងផ្ទះ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់ការមិនមានការជាប់ជំពាក់ណាមួយរបស់បព្វជិតទាំងឡាយ ទើបត្រាស់ថា **អនបេក្ខា កុលេ គណេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កុលេ** បានដល់ ក្នុងត្រកូលឧបដ្ឋាក ។ បទថា **គណេ** បានដល់ ក្នុងគណៈតាបស ។ លោកពោលជនដ៏សេស ថាជាព្រហ្មចារី ។ បទថា **ឧចាគមុំ** បានដល់ យើងទាំងពីរមកដល់ក្រុងពារាណសី ។ បទថា **តត្ថ** បានដល់ ក្នុងនគរពារាណសី ។ បទថា **និបកា** បានដល់ មានបញ្ញា ។ បទថា **និរាកុលេ** បានដល់ មិនរឹករវរដោយជនទាំងឡាយ ព្រោះប្រាសចាកជនត្រាច់ទៅមក ។ បទថា **អប្បសទ្ទេ** សេចក្តីថា ស្ងាត់ចាកសំឡេង ព្រោះប្រាសចាកសំឡេងសត្វយំ ដោយការប្រាកដនៃម្រឹគ និងបក្សីទាំងឡាយ ។ បទថា **រាជុយ្យានេ វសាមុភោ** សេចក្តីថា ក្នុងកាលនោះ យើងទាំងពីរនៅក្នុងរាជឧទ្យានរបស់ព្រះបាទពារាណសី ។

គប្បីជ្រាបរឿងជាលំដាប់ដូចតទៅនេះថា ក្នុងអតីតកាល ក្នុងកទ្ទកប្ប នេះឯង ព្រះពោធិសត្វច្យុតិចាកព្រហ្មលោក កើតជាបុត្ររបស់ព្រាហ្មណ៍ មានសម្បត្តិច្រើនក្នុងត្រកូលមួយ ក្នុងកាសិគាមមួយកន្លែង ។ ដល់ពេលដាក់ឈ្មោះ មាតាបិតាក៏ដាក់ឈ្មោះថា ពោធិកុមារ ។ កាលពោធិកុមារចម្រើនវ័យ ចូលទៅកាន់នគរតក្កសិលា រៀនសិល្បសាស្ត្រគ្រប់យ៉ាង កាលត្រឡប់មក ទាំងព្រះពោធិសត្វមិនប្រាថ្នានោះឯង មាតាបិតាបាននាំកុលធីតាម្នាក់ មានជាតិស្មើគ្នាមកឲ្យ ។ កុលធីតានោះ ក៏ច្យុតិអំពីព្រហ្មលោកដូចគ្នា ជាស្ត្រីមានរូបស្អាតដូចទេពអប្សរ ជនទាំងពីរមិនប្រាថ្នា មាតាបិតាក៏ធ្វើអាវាហមង្គល និងវិវាហមង្គលដល់គ្នានិងគ្នា ជនទាំងពីរមិនធ្លាប់មានកិលេសរួមគ្នាឡើយ ។ សូម្បីសម្លឹងមើលគ្នា ដោយអំណាចរាគៈក៏មិនមាន ចាំបាច់ពោលថ្វីដល់ការរួមសម្ពន្ធរវាងគ្នានិងគ្នា ជនទាំងពីរមានសីលបរិសុទ្ធ ដោយប្រការដូច្នេះ ។

សម័យក្រោយមក កាលមាតាបិតាអនិច្ចកម្មទៅ ព្រះពោធិសត្វធ្វើឈាបនកិច្ចមាតាបិតាហើយ ហៅភរិយាមកពោលថា នែនាងដ៏ចម្រើន ចូរនាងគ្រប់គ្រងទ្រព្យ ៨០ កោដិ ចិញ្ចឹមជីវិតតាមសប្បាយចុះ ភរិយាសួរថា ចុះអ្នកវិញ មហាសត្វឆ្លើយថា ខ្ញុំមិនត្រូវការទ្រព្យ ខ្ញុំនឹងបួស នាងសួរថា ការបួស មិនសមគួរដល់ស្ត្រីទេឬ ។ ព្រះពោធិសត្វឆ្លើយថា នាងក៏គួរ ទារិកានោះឆ្លើយថា បើដូច្នោះ ខ្ញុំមិនត្រូវការទ្រព្យ ខ្ញុំក៏បួសដែរ ។ ជនទាំងពីរលះបង់សម្បត្តិទាំងអស់ឲ្យជាមហាទាន ចេញអំពីនគរចូលព្រៃហើយបួស ចិញ្ចឹមអាត្មាដោយផ្លែឈើដែលស្វែងរកមកអស់ ១០ ឆ្នាំដោយសេចក្តីសុខ

ក្នុងនេក្ខម្មៈនោះឯង ត្រាច់ទៅតាមជនបទ ដើម្បីរសជូរប្រៃ ដល់នគរពារាណសី ដោយលំដាប់ អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ។ ដូចព្រះមានព្រះភាគត្រាស់ថា **រាជុយ្យានេ វសាមុភោ** ដូច្នេះ ។

ថ្ងៃមួយ ព្រះរាជាយាងទៅទតព្រះរាជឧទ្យាន ដល់កន្លែងតាបស និងតបស្សិនីដែលកំពុងញុំាងកាលវេលា ឲ្យបង្ហួនទៅដោយសេចក្តីសុខ ក្នុងបព្វជ្ជា នាចំណែកម្ខាងនៃព្រះរាជឧទ្យាន ទតឃើញបរិព្វាជិកាមានរូបល្អក្រៃលែង គួរជាទីជ្រះថ្លា មានព្រះហឫទ័យប្រតិព័ទ្ធដោយអំណាចកិលេស ត្រាស់សួរព្រះពោធិសត្វថា បរិព្វាជិកានេះ ជាអ្វីនឹងលោកម្ចាស់ កាលព្រះពោធិសត្វទូលថា មិនជាអ្វីនឹងគ្នាឡើយ ជាបព្វជិតរួមបព្វជ្ជាជាមួយគ្នាតែម៉្យាង តែកាលនៅជាគ្រហស្ថ ជាភរិយារបស់អាត្មា ព្រះរាជាព្រះតម្រិះថា បរិព្វាជិកានេះ មិនមែនជាអ្វីនឹងព្រះពោធិសត្វ តែកាលជាគ្រហស្ថជាភរិយា បើដូច្នោះ អញនឹងនាំបរិព្វាជិកានេះ ចូលទៅខាងក្នុងព្រះនគរ ដោយវិធីនេះឯង អញនឹងដឹងបរិព្វាជកនោះ តើធ្វើដូចម្តេច ជាមួយបរិព្វាជិកានេះ ។ ព្រះរាជាជាបុគ្គលពាលល្ងង់ខ្លៅ មិនអាចហាមឃាត់ចិត្តប្រតិព័ទ្ធរបស់ទ្រង់ ក្នុងបរិព្វាជិកានោះបាន ទើបត្រាស់នឹងរាជបុរសម្នាក់ថា ចូរនាំបរិព្វាជិកានេះចូលកាន់ព្រះរាជនិវេសន៍ ។

រាជបុរសទទួលបញ្ជារបស់ព្រះរាជាហើយ ពោលពាក្យជាដើមថា អធម៌ប្រព្រឹត្តទៅក្នុងលោក ហើយនាំបរិព្វាជិកាដែលកំពុងយំទៅ ។ ព្រះពោធិសត្វស្តាប់សំឡេងខ្សឹកខ្សួលរបស់បរិព្វាជិកានោះ សម្លឹងមើលតែម្តង ក៏មិនសម្លឹង

មើលទៀត គិតថា បើអញហាមឃាត់ អន្តរាយនឹងមានដល់សីលរបស់អញ ព្រោះចិត្តប្រទូស្តចំពោះបុគ្គលទាំងនោះ ទើបអង្គុយពិចារណាដល់សីលបារមី តែម្យ៉ាង ដូចព្រះមានព្រះភាគត្រាស់ថា **ឧយ្យានឧស្សន្ធំ គន្ត្វា រាជា អឝ្ជូស ព្រាហ្មណី** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **តុយ្ហេសា កា កស្ស ភរិយា** សេចក្តីថា ព្រាហ្មណីនេះ ជាអ្វីនឹងលោកម្ចាស់ ជាភរិយាឬ ឬជាប្អូនស្រី ឬជាភរិយារបស់អ្នកណាដទៃ ។ បទថា **ន មយ្ហំ ភរិយា ឯសា** សេចក្តីថា ព្រាហ្មណីនេះ ទោះជាភរិយាក្នុងកាលមុនរបស់អាត្មា កាលនៅជាគ្រហស្ថក៏ពិត តែតាំងអំពីបួសហើយ នាងមិនមែនជាភរិយារបស់អាត្មា ឯអាត្មាក៏មិនមែនជាស្វាមីរបស់នាង តែជាអ្នកបដិបត្តិរួមគ្នា មានសាសនារួមគ្នាប៉ុណ្ណោះ អាត្មាឯងក៏ជាអ្នកបួស ស្រីនេះក៏ជាអ្នកបួស ហេតុនោះ ទើបមានធម៌ស្មើគ្នា មានសាសនាជាមួយគ្នា ដោយពាក្យប្រៀនប្រដៅរបស់អ្នកបួស អធិប្បាយថា ជាសព្រហ្មចារីផងគ្នា ។

បទថា **តិស្សា សារត្តគធិតោ** បានដល់ ព្រះរាជាទ្រង់ត្រេកត្រអាលជាប់ជំពាក់ដោយកាមរាគ ។ បទថា **គាហាបេត្វាន ចេដកេ** សេចក្តីថា ត្រាស់ឲ្យរាជបុរសចាប់ គឺទ្រង់បញ្ជារាជបុរសរបស់ព្រះអង្គ ឲ្យចាប់បរិព្វាជិកានោះ ។ បទថា **និប្បីឡយន្តោ ពលសា** សេចក្តីថា ទ្រង់បង្ខំបរិព្វាជិកានោះ ដែលមិនប្រាថ្នា ដោយការទង់ទាញជាដើម ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ឲ្យរាជបុរសចាប់បរិព្វាជិកា ដែលមិនទៅ ដោយកម្លាំង គឺដោយកម្លាំងបាយ

ហើយឲ្យចូលទៅខាងក្នុងព្រះនគរ ។

បទថា **ឱទបត្តកិយា** បានដល់ ស្រីដែលព្រាហ្មណ៍ប្រួចទឹកហើយទទួលជាភរិយា ឈ្មោះថា **ឱទបត្តិកា ។** ពាក្យនេះ គប្បីជ្រាបថា ត្រឹមតែជាពាក្យជំនួសនឹងពាក្យថាភរិយាចាស់ ។ ម្យ៉ាងទៀត ស្រីនោះដែលមាតាបិតាលើកឲ្យដល់បុរស ដោយព្រាហ្មណវិវាហៈ ។ ម្យ៉ាងទៀត បទថា **ឱទ-បត្តកិយា** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថប្រាប់លក្ខណៈ ប្រាប់ភាវៈ ។ បទថា **សហជាតា** បានដល់ កើតរួមគ្នា ដោយកើតក្នុងបព្វជ្ជា ដូចព្រះមានព្រះភាគត្រាស់ថា **ឯកសាសនី ។** ម្យ៉ាងទៀត បទថា **ឯកសាសនី** នេះ ជាបឋមា-វិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ អធិប្បាយថា ក្នុងសាសនាតែមួយ ។ បទថា **នយន្តិយា** បានដល់ ត្រូវនាំចូលទៅ ។ បទថា **កោធោ មេ ឧបបជ្ជថ** សេចក្ដីថា ព្រាហ្មណីនេះ ជាអ្នកមានសីល ជាភរិយារបស់អ្នក កាលនៅជាគ្រហស្ថ ។ កាលបួសហើយ ជាប្អូនស្រីកើតរួមដោយភាពជាសព្រហ្មចារី ។ ព្រាហ្មណីនោះ ត្រូវរាជបុរសអូសចូលទៅដោយកម្លាំងបាយ ក្នុងចំពោះមុខអ្នក ។ សេចក្ដីក្រោធដែលដេកសម្ងំនៅអស់កាលយូរ បានផុសឡើងដោយមានះរបស់បុរសថា ម្នាលពោធិព្រាហ្មណ៍ អ្នកជាកូនប្រុសឥតប្រយោជន៍ ដូច្នេះ កើតឡើងដោយរហ័សក្នុងចិត្តរបស់តថាគត ដូចអាសិរពិសត្រូវបុរសណាមួយទាញចេញអំពីរន្ធក្នុងដំបូក បើកពពារ បញ្ចេញសំឡេងសុសុ ដូច្នេះ ។ បទថា **សហកោបេ សមុប្បន្នេ** បានដល់ ព្រមជាមួយនឹងសេចក្ដីក្រោធដែលកើតឡើង អធិប្បាយថា ក្នុងលំដាប់នៃសេចក្ដីក្រោធ ដែលកើត

ឡើងនោះឯង ។ បទថា **សីលព្វតមនុស្សរឹ** បានដល់ រឭកដល់សីលបារមីរបស់ខ្លួន ។ បទថា **តត្ថេវ កោបំ និគ្គណ្ហឹ** សេចក្តីថា តាមដែលអង្គុយលើអាសនៈនោះឯង តថាគតហាមសេចក្តីក្រោធនោះបាន ។ បទថា **នាធាសឹ វឌ្ឍិតូបរិ** សេចក្តីថា តថាគតមិនឲ្យកិលេសនោះចម្រើនក្រៃលែងឡើង ជាងដែលកើតឡើងគ្រាដំបូងនោះ ។ ពាក្យនេះ លោកអធិប្បាយថា ត្រឹមតែមានសេចក្តីក្រោធកើតឡើងនោះឯង តថាគតបរិភាសខ្លួនឯងថា ម្នាលពោធិ-បរិព្វាជក អ្នកបំពេញបារមីទាំងពួង បំណងនឹងត្រាស់ដឹងសព្វញ្ញុតញ្ញាណមិនមែនឬ ហេតុអ្វីត្រឹមតែសីលក៏អ្នកប្រមាទ បានការប្រមាទនេះ ដូចជាគោទាំងឡាយ បំណងនឹងទៅកាន់ត្រើយអាយនៃមហាសមុទ្រ លិចក្នុងទឹកក្រុតដូច្នោះ ក្នុងខណៈនោះឯង តថាគតសង្កត់សេចក្តីក្រោធដោយកម្លាំងនៃការពិចារណា មិនឲ្យសេចក្តីក្រោធនោះចម្រើន ដោយការកើតឡើងទៀត ដូចព្រះមានព្រះភាគត្រាស់ថា **យទិ នំ ព្រាហ្មណឹ** ជាដើម ។

បទនោះ មានអត្ថដូចតទៅនេះ ព្រះរាជា ឬបុគ្គលដទៃណាមួយ យកលំពែងដ៏មុត ចាក់ព្រាហ្មណីបរិព្វាជិកានោះ បើកាប់ជាកង់ៗ ទោះបីយ៉ាងនេះក៏មិនគប្បីទម្លាយនូវសីល គឺសីលបារមីរបស់ខ្លួនឡើយ ព្រោះហេតុអ្វី ព្រោះហេតុនៃពោធិញ្ញាណប៉ុណ្ណោះ គឺបុគ្គលអាចសម្រេចសម្មាសម្ពោធិញ្ញាណដោយសីលមិនដាច់ក្នុងទីទាំងពួងប៉ុណ្ណោះ មិនមែនដោយហេតុក្រៅអំពីនេះ ។

បទថា **ន មេ សា ព្រាហ្មណី ទេស្សា** សេចក្តីថា ព្រាហ្មណីនោះជាទីស្អប់ខ្ពើមរបស់តថាគត ក៏មិនមែន មិនជាទីស្រឡាញ់របស់តថាគត ក៏

មិនមែន ដោយប្រការទាំងពួង គឺដោយជាតិ គោត្រ ដោយស្រុកកំណើត របស់ត្រកូល ដោយមារយាទ និងដោយគុណសម្បត្តិ មានបព្វជ្ជាជាដើម ដែលសន្សំមកអស់កាលយូរ មិនមានអ្វីដែលធ្វើឲ្យតថាគតមិនស្រឡាញ់ព្រាហ្មណីនេះ ។ បទថា **ឆបិ មេ ពលំ ន វិជ្ជតិ** លោកសម្តែងថា កម្លាំងរបស់តថាគតមិនមាន ក៏មិនមែន គឺមានជាប្រក្រតីនោះឯង តថាគតមានកម្លាំងដូចដំរីសារ សម្បូរដោយសមុះ បើប្រាថ្នា អាចក្រោកដោយរហ័ស ហើយញាំញីបុរសដែលអូសព្រាហ្មណីនោះ ចាប់បុរសនោះទៅកាន់ទីដែលត្រូវការបាន ។ បទថា **សព្វញ្ញុតំ បិយំ មយ្ហំ** សេចក្តីថា សព្វញ្ញុតញ្ញាណប៉ុណ្ណោះ ជាទីស្រឡាញ់ក្រៃលែងជាងបរិព្វាជិកានោះរាប់រយដង រាប់ពាន់ដង រាប់សែនដង ។ បទថា **តស្មា សីលានុរក្ខិស្សំ** សេចក្តីថា ដោយហេតុនោះ ទើបតថាគតតាមរក្សាសីល ។

លំដាប់នោះ ព្រះរាជាទ្រង់មិនធ្វើឲ្យយឺតយូរក្នុងព្រះរាជឧទ្យាន ប្រញាប់យាងទៅដោយរហ័សតាមដែលធ្វើបាន ត្រាស់ឲ្យហៅបរិព្វាជិកានោះមកហើយ ទ្រង់ប្រគល់យសជាច្រើនឲ្យ ។ បរិព្វាជិកានោះពោលដល់ទោសរបស់យស គុណរបស់បព្វជ្ជា និងភាពដែលខ្ទួន និងព្រះពោធិសត្វលះគំនរភោគសម្បត្តិដ៏មហាសាល ហើយបួសដោយសេចក្តីសង្វេគ ។ ព្រះរាជាទ្រង់មិនបានទាំងសមតាមព្រះហឫទ័យ ដោយឧបាយណាមួយ ទើបទ្រង់ព្រះតម្រិះថា បរិព្វាជិកានេះមានសីល មានកល្យាណធម៌ បរិព្វាជកនោះ កាលបរិព្វាជិកានេះ ត្រូវអូសនាំមក ក៏មិនបានសម្តែងអាការខុសប្រក្រតីណាមួយឡើយ ។

មិនពិចារណាដល់អ្វីទាំងអស់ ។ ការធ្វើវត្តុខុសប្រក្រតីក្នុងបុគ្គលមានគុណបែបនេះ មិនសមគួរដល់អញឡើយ ណ្ហើយចុះ អញនឹងនាំបរិព្វាជិកានេះទៅកាន់ឧទ្យាន ហើយសូមខមាទោសបរិព្វាជិកានេះ និងបរិព្វាជកនោះ ។ កាលព្រះរាជាទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ត្រាស់នឹងរាជបុរសថា ចូរពួកអ្នកនាំបរិព្វាជិកានេះទៅកាន់ឧទ្យាន ទ្រង់យាងទៅមុន ទ្រង់ចូលទៅរកព្រះពោធិសត្វ ត្រាស់សួរថា បព្វជិតដ៏ចម្រើន កាលខ្ញុំនាំបរិព្វាជិកានោះទៅលោកម្ចាស់ខឹងដែរឬទេ ព្រះមហាសត្វទូលតបថា

សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាល
រស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័ស ឲ្យដូចជា
ភ្លៀងធំ ឃាត់នូវធូលី ដូច្នេះ ។

ព្រះរាជាកាលស្តាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា បរិព្វាជកនេះពោលសំដៅដល់សេចក្តីក្រោធតែម្យ៉ាង ឬសំដៅដល់អ្វីដទៃ មានសិប្បៈជាដើម ទើបត្រាស់សួរបន្តថា

អ្វីកើតឡើងដល់លោក ចេញមកមិនបាន លោកកាលរស់នៅ
អ្វីចេញមកបាន លោកឃាត់អ្វី ដូចភ្លៀងធំឃាត់នូវធូលី ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា កើត បានដល់ សេចក្តីក្រោធកើតឡើងម្តង មិនកើតទៀត ។ ពាក្យថា ក៏ចេញមកមិនបាន បានដល់ មិនលែងចេញដោយឲ្យកើតកាយវិការ វចីវិការ អធិប្បាយថា មិនលែងសេចក្តីក្រោធនោះចេញទៅខាងក្រៅ ។ ពាក្យថា ឲ្យដូចជាភ្លៀងធំ ឃាត់នូវធូលី សេចក្តីថា

អាត្មារម្ងាប់សេចក្តីក្រោធនោះ ហាមសេចក្តីក្រោធ ដូចតំណក់ភ្លៀងពុំជួកាល ធ្លាក់មកយ៉ាងខ្លាំង កម្ចាត់ធូលីដែលកើតឡើងក្នុងខែចុងក្រោយនៃរដូវប្រាំង ជាប្រក្រតី ដូច្នោះ ។

លំដាប់នោះ មហាបុរសកាលប្រកាសទោសរបស់សេចក្តីក្រោធដោយប្រការផ្សេងៗ ដល់ព្រះរាជានោះ ទើបសម្តែងធម៌ដោយគាថាទាំងនេះថា

កាលសភាវៈណាកើតឡើង បុគ្គលមើលមិនឃើញ កាលមិនកើតឡើង ទើបឃើញងាយ សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

បុគ្គលទាំងឡាយជាសត្រូវ អ្នកស្វែងរកនូវសេចក្តីទុក្ខ រមែងត្រេកអរដោយសភាវៈណា ដែលកើតឡើងហើយ សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

កាលសភាវៈណាកើតឡើង បុគ្គលរមែងមិនយល់នូវប្រយោជន៍របស់ខ្លួន សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មាមិនបានទេ ។

បពិត្រមហារាជ បុគ្គលត្រូវសេចក្តីក្រោធណា គ្របសង្កត់ហើយ រមែងលះបង់នូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយឲ្យសាបសូន្យផង សេចក្តីក្រោធនោះ មានសេនា គឺកិលេស

ដែលគួរខ្លាច មានកម្លាំងអាចញាំញីសត្វបាន សេចក្តីក្រោធ
ចេញពីអាត្មាមិនបានទេ ។
ជម្មតាភ្លើង រមែងកើតក្នុងឈើដែលពួតភ្លើងនោះ កើតអំពីឈើ
ណា ឆេះនូវឈើនោះវិញ ។
កាលបុគ្គលល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា មិនចេះដឹងយ៉ាងនេះ
សេចក្តីក្រោធ រមែងកើតអំពីការប្រណាំងប្រជែង បុរសនោះ
រមែងត្រូវភ្លើង គឺសេចក្តីក្រោធនោះឆាបឆេះ ។
សេចក្តីក្រោធ របស់បុគ្គលណាចម្រើនឡើង ដូចភ្លើង កាល
ចម្រើនឡើង ក្នុងគំនរស្មៅ និងឈើ យសរបស់បុគ្គលនោះ
រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ ។
សេចក្តីក្រោធ របស់បុគ្គលណាស្ងប់រម្ងាប់ ដូចភ្លើងមិនមាន
កំញ៉ម យសរបស់បុគ្គលនោះ រមែងបរិបូណ៌ ដូចព្រះចន្ទ្រក្នុង
សុក្កបក្ខ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មិនឃើញ សេចក្តីថា សូម្បីប្រយោជន៍ខ្លួនក៏មិនឃើញ ចាំបាច់ពោលថ្វីដល់ប្រយោជន៍អ្នកដទៃ ។ ពាក្យថា ទើបឃើញងាយ សេចក្តីថា រមែងឃើញប្រយោជន៍ខ្លួនផង ប្រយោជន៍អ្នកដទៃផង ប្រយោជន៍ទាំងពីរផង ដោយប្រពៃនោះឯង ។ ពាក្យថា ជាអារម្មណ៍របស់បុគ្គលល្ងង់ សេចក្តីថា ជាវិស័យរបស់បុគ្គលដែលឥតប្រាជ្ញា ឬជាគោចរដែលឥតបញ្ញា ឬមានឥន្ធនៈ ( របស់សម្រាប់ដុត ) ជាអាហារ ព្រោះ

ហេតុនោះ ទើបឈ្មោះថា ជាអារម្មណ៍របស់បុគ្គលល្ងង់ ។ ពាក្យថា អ្នកស្វែងរកនូវសេចក្តីទុក្ខ បានដល់ ប្រាថ្នាសេចក្តីទុក្ខ ។ ពាក្យថា ប្រយោជន៍របស់ខ្លួន បានដល់ សេចក្តីចម្រើនដែលជាប្រយោជន៍របស់ខ្លួន ។ ពាក្យថា ធ្វើ ... ឲ្យសាបសូន្យ បានដល់ គប្បីនាំចេញទៅ គឺធ្វើឲ្យអស់ទៅ ។ ពាក្យថា សេចក្តីក្រោធនោះ មានសេនា គឺកិលេសដែលគួរខ្លាច សេចក្តីថា សេចក្តីក្រោធនោះ ប្រកបដោយសេនា គឺកិលេសធំឲ្យកើតភ័យដែលគួរខ្លាច ។ ពាក្យថា ញាំញីសត្វ បានដល់ មានប្រក្រតីញាំញីនូវសត្វទាំងឡាយ ដោយកម្លាំង ។ ពាក្យថា សេចក្តីក្រោធចេញពីអាត្មាមិនបានទេ សេចក្តីថា សេចក្តីក្រោធនោះ មិនបាននូវការផុតទៅអំពីសម្នាក់របស់អាត្មា ។ អាត្មាទូន្មានទុកខាងក្នុងនោះឯង អធិប្បាយថា ធ្វើឲ្យអស់ព្យសន៍ ឬសេចក្តីក្រោធតាំងនៅជាមួយចិត្ត ដោយធ្វើចិត្តឲ្យខូចទៅមួយស្របក់ ដូចទឹកដោះជូរ ដូច្នោះ ។

ពាក្យថា ឈើដែលពួតភ្លើង ( មន្ថមានស្មឹ ) បានដល់ ឈើពំនួតដែលត្រូវក្លួត បាឋៈថា **មថមានស្មឹ** ដូច្នេះក៏មាន ។ ពាក្យថា អំពីឈើណា បានដល់ អំពីឈើណា ។ ពាក្យថា ភ្លើង ( **តិជិ**) បានដល់ ភ្លើង ។ ពាក្យថា បុគ្គលល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា បានដល់ បុគ្គលពាលល្ងង់ខ្លៅ ។ ពាក្យថា រមែងកើតអំពីការប្រណាំងប្រជែង សេចក្តីថា សេចក្តីក្រោធ រមែងកើតព្រោះការប្រណាំងប្រជែង ដែលមានលក្ខណៈធ្វើហួសហេតុ ដូចភ្លើងកើតព្រោះឈើពំនួត ដូច្នោះ ។ ពាក្យថា បុរសនោះ រមែងត្រូវភ្លើង គឺសេចក្តីក្រោធនោះ សេចក្តីថា បុគ្គលពាលនោះ រមែងត្រូវសេចក្តីក្រោធដុតរោល

ឈើត្រូវភ្លើងឆេះដូច្នោះ ។ ពាក្យថា ដូចភ្លើងមិនមានកំញ៉ម បានដល់ ដូចភ្លើងមិនមានកំញម ដូច្នោះ ។ ពាក្យថា របស់បុគ្គលនោះ បានដល់ យសដែលបានហើយ រមែងចម្រើនហើយចម្រើនទៀត ដល់បុគ្គលដែលប្រកបហើយដោយការអត់ធន់នោះ ដូចព្រះចន្ទ្រក្នុងសុក្កបក្ខ ដូច្នោះ ។

ព្រះរាជា កាលទ្រង់ស្តាប់ធម្មកថារបស់ព្រះមហាសត្វហើយ ទ្រង់សូមខមាទោសមហាបុរស មួយអន្លើដោយបរិព្វាជិកាដែលមកអំពីព្រះរាជវាំងដោយព្រះតម្រាស់ថា សូមលោកម្ចាស់ទាំងពីរ សោយសុខក្នុងបព្វជ្ជាក្នុងឧទ្យាននេះចុះ ខ្ញុំនឹងធ្វើការរក្សាការពារឃុំគ្រងប្រកបដោយធម៌ ដល់លោកម្ចាស់ទាំងទ្វេ នមស្ការហើយ ទ្រង់យាងត្រឡប់ ។ បរិព្វាជក និងបរិព្វាជិកាទាំងពីរអង្គ អាស្រ័យនៅក្នុងព្រះរាជឧទ្យាននោះឯង ។ តមក បរិព្វាជិកាក៏អនិច្ចកម្ម ។ ព្រះពោធិសត្វចូលទៅកាន់ព្រៃហិមពាន្ត ញុំាងឈាន និងអភិញ្ញាឲ្យកើត កាលអស់អាយុ ក៏បានទៅកាន់ព្រហ្មលោក ។

បរិព្វាជិកាក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ ព្រះរាជា ក្នុងកាលនោះ បានមកជាអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ ពោធិ-បរិព្វាជកក្នុងកាលនោះ បានមកជាព្រះលោកនាថក្នុងកាលឥឡូវនេះ ។

ក្នុងចូឡពោធិចរិយានេះ គប្បីពោលដល់បារមីដ៏សេសរបស់ព្រះពោធិសត្វតាមសមគួរ ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពនៃព្រះមហា-បុរសក្នុងទីនេះ យ៉ាងនេះ គឺការលះគំនរភោគៈធំ និងវង្សញាតិធំ ចេញអំពីផ្ទះ ដូចគ្នានឹងចេញមហាភិនេស្រ្កមណ៍ កាលចេញទៅយ៉ាងនោះហើយ តាំង

ចិត្តជាបព្វជិតដែលជនជាច្រើនលើកតម្កើង មិនជាប់ជំពាក់ក្នុងត្រកូល ក្នុងគណៈ ព្រោះជាអ្នកប្រាថ្នាតិចយ៉ាងក្រៃលែង ការត្រេកអរក្រៃលែងក្នុងសេចក្តីស្ងាត់ ព្រោះវៀរសចាកលាភ និងសក្ការៈដោយចំណែកមួយប៉ុណ្ណោះ ការប្រព្រឹត្តជុសខាត់កិលេស ដែលជាសេចក្តីល្អក្រៃលែង ការពិចារណាដល់សីលបារមី មិនសម្តែងសេចក្តីក្រោធអាក់អន់ កាលបរិព្វាជិកាដែលជាអ្នកមានកល្យាណធម៌ មានសីលបែបនោះ ត្រូវរាជបុរសចាប់ទៅដោយកម្លាំងបាយចំពោះមុខ ខ្លួនដែលមិនបានអនុញ្ញាត កាលព្រះរាជាទ្រង់ជីងខ្លួនថា ទ្រង់ធ្វើខុស ទើបចូលទៅរក តាំងចិត្តបំពេញប្រយោជន៍ និងថ្វាយពាក្យប្រៀនប្រដៅដោយប្រយោជន៍ក្នុងបច្ចុប្បន្ន និងប្រយោជន៍ក្នុងបរលោក ដូចលោកពោលថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជាអ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វីដល់ការធ្វើតាម ព្រះពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។

## អដ្ឋកថាចូឡពោធិចរិយា ចប់

# សុត្តន្តបិដក

## មហិសរាជចរិយាទី ៩

[ ១៥ ] មានចរិយាដទៃទៀត កាលតថាគតកើតជាក្របីព្រៃ ត្រាច់ទៅក្នុងព្រៃធំ មានកាយចម្រើន មានកម្លាំងច្រើន មានសរីរៈធំធាត់ បើគេឃើញហើយ គួរតែខ្លាច ។ ទីនៅនៃក្របីទាំងឡាយមានក្នុងទីនោះ គឺញកភ្នំ ផ្លូវជិតភ្នំ ដែលបុគ្គលទៅបានដោយកម្រ គល់ឈើ និងបឹង សត្វនីមួយៗ កាលត្រាច់ទៅក្នុងទីនោះៗ តែងបានឃើញទីដ៏ល្អក្នុងព្រៃធំ ឯតថាគតក៏ចូលទៅកាន់ទីនោះ ឈរផង ដេកផង ។ គ្រានោះ មានស្វាមួយ ក្នុងព្រៃធំនោះ ជាសត្វលាមក ថោកទាប ឡេះឡោះ មកកាន់ទីនោះ នោម ជុះដាក់តថាគតត្រង់ក ថ្ងាស និងចិញ្ចើម ពានរនោះប្រទូស្តនឹងតថាគតអស់មួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ បួនថ្ងៃ តថាគតត្រូវពានរនោះបៀតបៀនសព្វៗ កាល ទេវតាឃើញតថាគត ដែលត្រូវស្វានោះបៀតបៀនហើយ ក៏ពោលពាក្យនេះនឹងតថាគតថា ( ម្នាលក្របី ) អ្នកចូរញាំញីស្វាលាមក អាក្រក់នេះ ឲ្យវិនាសដោយស្នែង និងក្រចកទៅ ។ កាលទេវតាពោលយ៉ាងនេះហើយ តថាគតបាននិយាយតបទៅនឹងទេវតានោះវិញថា ( ម្នាលទេវតា ) បើទុកជាអ្នកប្រឡាក់ខ្ញុំដោយសាកសព លាមកថោកទាបដូចម្តេចក៏ដោយក៏ខ្ញុំមិនធ្វើតាមពាក្យអ្នកឡើយ ។ ព្រោះថា បើខ្ញុំខឹងនឹងស្វានេះខ្ញុំជាបុគ្គលថោកទាបជាងស្វានោះទៅទៀត សីលរបស់ខ្ញុំនឹងបែក

ធ្លាយផង វិញ្ញូជនទាំងឡាយនឹងតិះដៀលដល់ខ្ញុំផង ។ ការស្លាប់ដោយសេចក្តីបរិសុទ្ធ ប្រសើរជាងការរស់នៅ ដែលពួកអ្នកប្រាជ្ញតិះដៀល បើយ៉ាងនេះ ឲ្យខ្ញុំធ្វើនូវការបៀតបៀនអ្នកដទៃ ព្រោះហេតុតែជីវិត ( របស់ខ្លួន ) ដូចម្តេចកើត ។ បុគ្គលប្រកបដោយប្រាជ្ញា កាលអត់ទ្រាំចំពោះសេចក្តីមើលងាយ ( របស់ពួកជនដទៃ ) ក្នុងហេតុយ៉ាងមុទុ មជ្ឈិម និងឧក្រិដ្ឋ រមែងបានសម្រេចដូចសេចក្តីប្រាថ្នាក្នុងចិត្តយ៉ាងនេះឯង ។

**មហិសរាជចរិយាទី ៥ ចប់**

# អដ្ឋកថា

## មហិសរាជចរិយា

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហិសរាជចរិយាទី ៥ ដូចតទៅនេះ បទថា **មហឹសោ បវនចារកោ** គប្បីប្រកបសេចក្តីថា ក្នុងកាលតថាគតជាក្របីព្រៃ ត្រាច់ទៅក្នុងព្រៃធំ ។ បទថា **បវឌ្ឍកាយោ** សេចក្តីថា មានកាយធំធាត់ ដោយវ័យសម្បូរ និងដោយការធំរបស់អវយវៈតូចធំ ។ បទថា **ពលវា** បានដល់ មានកម្លាំងច្រើន បរិបូរដោយសម្ទុះ ។ បទថា **មហន្តោ** បានដល់ មានរាងកាយធំ បានឮថា កាយរបស់ព្រះពោធិសត្វក្នុងកាលនោះប្រមាណប៉ុនដំរីជំទន់ ។ បទថា **ភីមទស្សនោ** សេចក្តីថា គួរស្បើម ព្រោះឲ្យកើតនូវការខ្លាចដល់បុគ្គលដែលមិនស្គាល់សីល ព្រោះរាងកាយធំសម្បើម និងព្រោះជាក្របីព្រៃ ។ បទថា **បព្ភារេ** បានដល់ ត្រង់ញកភ្នំមានថ្មសំយុង ។ បទថា **ឧកាសយេ** បានដល់ ក្បែរបឹង ។ បទថា **ហោតេត្ថ ឋានំ** បានដល់ ប្រទេសក្នុងព្រៃធំ ដែលជាលំនៅរបស់ក្របីព្រៃ ។ បទថា **តហឹ តហឹ** បានដល់ ក្នុងព្រៃនោះៗ ។ បទថា **វិចរន្តោ** បានដល់ ត្រាច់ទៅដើម្បីរកផាសុកក្នុងការនៅ ។ បទថា **ឋានំ អទ្ទស្សំ ភទ្ទកំ** ទ្រង់សម្តែងថា កាលតថាគតត្រាច់ទៅយ៉ាងនេះ បានឃើញទីមួយត្រង់គល់ឈើ ដែលជាទីចម្រើនក្នុងព្រៃធំនោះ ជាផាសុករបស់តថាគត កាលឃើញហើយ ទើបចូលទៅកាន់ទីនោះឈរ និងដេក រកអាហារក្នុងពេលថ្ងៃ ហើយទៅត្រង់គល់ឈើនោះ ញុំាងកាលវេលាឲ្យកន្លងទៅដោយការឈរ និងការដេក ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតក្របីក្នុងហិម-វន្តប្បទេស កាលចម្រើនវ័យ សម្បូរដោយកម្លាំង មានរាងកាយធំប្រមាណប៉ុនដំរីជំទង់ ត្រាច់ទៅតាមជើងភ្នំ ញកភ្នំ ល្អាងភ្នំ ព្រៃ និងជ្រោះជាដើម ឃើញគល់ឈើធំគួរសប្បាយមួយដើម រកអាហារហើយ ក៏មកអាស្រ័យនៅត្រង់គល់ឈើនោះក្នុងពេលថ្ងៃ ។ កាលនោះ មានស្វាអាក្រក់មួយ ចុះអំពីដើមឈើ ឡើងលើខ្នងព្រះមហាសត្វ បន្ទោបង់ឧច្ចារៈ បស្សាវៈដាក់លើខ្នងចាប់ស្នែងយោលខ្លួនទៅមក ចាប់កន្ទុយយោលខ្លួន ព្រះពោធិសត្វមិនដាក់ចិត្តក្នុងអនាចាររបស់ស្វានោះ ព្រោះដល់ព្រមដោយខន្តី មេត្តា និងការអាណិតអាសូរ ស្វារឹងរឹតតែធ្វើយ៉ាងនោះរឿយៗ ដូចព្រះមានព្រះភាគត្រាស់ថា គ្រានោះ មានស្វាមួយក្នុងព្រៃធំនោះ ដូច្នេះ ។ បទថា **កបិមាគន្ធា** ក្នុងគាថានោះ កាត់បទជា **កបិ មាគន្ធា** ។ **ម** អក្ខរៈ ជាបទសន្ធិ ។ បទថា **ធាតោ** បានដល់ លាមក ។ បទថា **អនរិយោ** សេចក្តីថា ស្វានោះ ឡេះឡោះដោយការប្រព្រឹត្តក្នុងសេចក្តីវិនាស និងដោយមិនប្រព្រឹត្តក្នុងសេចក្តីចម្រើនអធិប្បាយថា មានមារយាទអាក្រក់ ។ បទថា **លហុ** បានដល់ ឡេះឡោះ ។ បទថា **ខន្ធេ** បានដល់ ត្រង់ជង់-ក ។ បទថា **មុត្តេតិ** បានដល់ បន្ទោបង់បស្សាវៈ ។ បទថា **ឱហានេតិ** បានដល់ បន្ទោបង់ឧច្ចារៈ ។ បទថា **តំ** គឺ **មំ** បានដល់ តថាគតជាក្របីក្នុងកាលនោះ ។ បទថា **សកិម្បិ ទិវសំ** សេចក្តីថា បៀតបៀនតថាគតមួយថ្ងៃខ្លះ អស់កាលទាំងពួងខ្លះ ដូចព្រះមានព្រះភាគត្រាស់ថា តថាគតត្រូវពានរនោះបៀតបៀនសព្វៗ កាល ដូច្នេះ គឺមិនបៀត

បៀនតថាគតត្រឹមតែ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ដែលពិត បៀតបៀនតថាគត ដោយបន្ទោបង់បស្សាវៈជាដើម អស់កាលទាំងពួង ។ លោកសម្តែងថា ស្វានោះ ចង់បន្ទោបង់បស្សាវៈជាដើមក្នុងកាលណា ក៏បន្ទោបង់លើខ្នង តថាគតនោះឯងក្នុងកាលនោះ ។ បទថា **ឧបទ្ទវេតោ** បានដល់ ត្រូវបៀតបៀន អធិប្បាយថា តថាគតត្រូវស្វានោះបៀតបៀន ដោយយោលខ្លួនជាដើម ត្រង់ស្នែង និងដោយការយករបស់ស្មោកគ្រោក មានបស្សាវៈជាដើមមក លាប និងដោយស្រោចទឹកលាយកក់ និងធូលី តថាគតលាងច្រើនដង ត្រង់ ចុងស្នែង និងចុងកន្ទុយ ដើម្បីជម្រះគ្រឿងស្មោកគ្រោក ។ បទថា **យក្ខោ** បានដល់ ទេវតាដែលស្ថិតនៅលើដើមឈើនោះ ។ បទថា **មំ ឥទមព្រវិ** សេចក្តីថា ទេវតាដែលស្ថិតនៅលើដើមឈើ កាលប្រកាសសេចក្តីនេះថា នៃមហិសរាជ ព្រោះហេតុអ្វី ទើបអ្នកអត់ធន់ក្នុងការប្រមាថមើលងាយ របស់ស្វាអាក្រក់នេះ ទើបពោលពាក្យនេះនឹងតថាគតថា ចូរអ្នកញាំងស្វា លាមកអាក្រក់នេះឲ្យវិនាសដោយស្នែង និងក្រចកទៅ ដូច្នេះ ។

បទថា **ឯវំ វុត្តេ តទា យក្ខេ** បានដល់ កាលទេវតាពោលយ៉ាងនេះ ក្នុងកាលនោះហើយ ។ បទថា **អហំ តំ ឥទមព្រវិ** សេចក្តីថា តថាគត បានពោលឆ្លើយនឹងទេវតានោះ ដែលកំពុងពោលក្នុងឥឡូវនេះ ។ បទថា **កុណបេន** សេចក្តីថា ដោយសាកសព ព្រោះជាវត្ថុដែលគួរខ្ពើមក្រៃលែង របស់បុគ្គលដែលមានជាតិស្អាត ដោយការហូរចេញនៃអសុចិ គឺកិលេស ព្រោះដូចគ្នានឹងសាកសព ដោយមានក្លិនស្អុយផ្សាយទៅ ។ បទថា **ចាបេន**

បានដល់ លាមកដោយការសម្លាប់សត្វ ។ បទថា **អនរិយេន** ក្របីសម្តែងថា នែទេវតា ព្រោះហេតុអ្វី ទើបលោកមើលងាយខ្ញុំដោយវត្ថុដែលមិនចម្រើន ព្រោះជាធម្មតារបស់បុគ្គលអាក្រក់ មានព្រានម្រឹគជាដើមដែលមិនចម្រើន មិនមែនបុគ្គលល្អ ពាក្យសម្តីដែលអ្នកពោលដឹកនាំខ្ញុំក្នុងអំពើអាក្រក់នោះ មិនសមគួរឡើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសទោសក្នុងបាបធម៌នោះ ទើបត្រាស់ព្រះតម្រាស់ថា **យថិហំ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូចតទៅថា នែទេវតា បើខ្ញុំក្រោធនឹងស្វានោះ ខ្ញុំក៏អាក្រក់ជាងស្វា ព្រោះស្វានោះជាស្វាពាល ជាស្វាអាក្រក់ មិនប្រព្រឹត្តធម៌ បើខ្ញុំប្រព្រឹត្តធម៌អាក្រក់ ដែលមានកម្លាំងជាងស្វានោះ ខ្ញុំក៏គប្បីជាបុគ្គលបាបជាងស្វានោះ ដោយហេតុនោះ មិនមែនឬ ការដែលខ្ញុំដឹងលោកនេះ និងបរលោកយ៉ាងល្អហើយតាំងនៅ បានបដិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ ដោយចំណែកមួយប៉ុណ្ណោះ ការប្រព្រឹត្តធម៌លាមកបែបនោះ មិនមែនជាឋានៈឡើយ ។ សួរថា មានអ្វីក្រៃលែងជាងនេះទៀត ឆ្លើយថា មាន គឺសីលរបស់ខ្ញុំគប្បីដាច់ ។ បទថា **សីលញ្ច មេ បភិជ្ជេយ្យ** សេចក្តីថា ខ្ញុំគប្បីធ្វើអំពើអាក្រក់បែបនោះ សីលបារមីរបស់ខ្ញុំគប្បីដាច់ ។ បទថា **វិញ្ញូ ច គរហេយ្យុ មំ** សេចក្តីថា ទេវតា និងមនុស្សជាបណ្ឌិត គប្បីតិះដៀលតថាគតបានថា លោកឪពុក អ្នកម្តាយ បងប្អូនទាំងឡាយ ចូរមើល ព្រះពោធិសត្វត្រាច់ស្វែងរកពោធិញ្ញាណ បានធ្វើអំពើអាក្រក់បែបនេះហើយ ។

វា សព្វ ក្នុងបទថា **ហីឡិតា ជីវិតា វាបិ** ជាអវធារណៈ អធិប្បាយថា ការស្លាប់ដែលស្លាប់ដោយសេចក្តីបរិសុទ្ធិ គឺជាអ្នកមានសីលបរិសុទ្ធ គង់ប្រសើរ ឧត្តមជាងមានជីវិតរស់នៅ ត្រូវវិញ្ញូជនទាំងឡាយតិះដៀល ដោយប្រការដូច្នេះ ។ បទថា **ក្យាហំ ជីវិតហេតុបិ កាហាមិ បរហេឋនំ** សេចក្តីថា កាលខ្ញុំដឹងយ៉ាងនេះ ខ្ញុំនឹងធ្វើការបៀតបៀនសត្វដទៃ យកជីវិតរបស់ខ្ញុំជាដើមទុនបានដូចម្តេច អធិប្បាយថា មិនមានហេតុក្នុងការធ្វើការបៀតបៀននេះ ។

ក្របីពោលថា ស្វានេះ សម្គាល់សត្វដទៃថាដូចខ្ញុំ នឹងធ្វើអនាចារយ៉ាងនេះ បន្ទាប់អំពីនោះ ស្វានេះនឹងធ្វើយ៉ាងនេះដល់ក្របីកាចពួកណា ក្របីកាចពួកនោះឯង នឹងសម្លាប់ស្វានេះ ការដែលស្វានេះស្លាប់ព្រោះសត្វដទៃ ខ្ញុំក៏នឹងផុតចាកទុក្ខ និងបាណាតិបាត ដូចព្រះមានព្រះភាគត្រាស់ថា

**មមេវាយំ មញ្ញមានោ អញ្ញេបេវំ ករិស្សតិ**
**តេ នំ តត្ថ វធិស្សន្តិ សា មេ មុត្តិ ភវិស្សតិ។**

ស្វានេះ កាលមើលងាយខ្ញុំបាន គង់នឹងធ្វើ ( អនាចារៈ ) យ៉ាងនេះ នឹងក្របីដទៃទៀត ក្របីទាំងនោះ នឹងសម្លាប់វាក្នុងទីនោះ ការរួច ( ចាកសេចក្តីលំបាក ) នោះ នឹងមានដល់ខ្ញុំ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មមេវាយំ** កាត់បទជា **មំ ឯវ អយំ។** បទថា **អញ្ញេបិ** បានដល់ សូម្បីដល់សត្វពួកដទៃ ។ ពាក្យដ៏សេសមានន័យ

ដូចពោលហើយនោះឯង ។

បទថា **ហីនមជ្ឈិមឧក្កដ្ឋេ** សេចក្តីថា ព្រោះបុគ្គលអាក្រក់ បុគ្គលកណ្តាល និងបុគ្គលឧត្តមជាហេតុ ។ បទថា **សហន្តោ អវមានិតំ** សេចក្តីថា អត់សង្កត់នូវពាក្យមើលងាយ គ្រោតគ្រាត ដែលមនុស្សទាំងនោះ មិនបានបែក ប្រព្រឹត្តទៅហើយ ។ បទថា **ឯវំ លភតិ សប្បញ្ញោ** សេចក្តីថា បុគ្គលមានបញ្ញា មិនបានធ្វើការបែកក្នុងបុគ្គលថោកទាបជាដើមយ៉ាងនេះ ចូលទៅតម្កល់នូវខន្តី មេត្តា និងករុណា អត់ធ្មត់ក្នុងកំហុសនោះ ចម្រើនសីលបារមីជាដើម រមែងបាន គឺចាក់ចុះនូវសព្វញ្ញុតញ្ញាណតាមចិត្តប្រាថ្នា គឺតាមត្រូវការ ។ សេចក្តីប្រាថ្នារបស់បុគ្គលនោះ នៅមិនឆ្ងាយប៉ុន្មានឡើយ ដោយប្រការដូច្នេះ ។

ព្រះមហាសត្វកាលប្រកាសអធ្យាស្រ័យរបស់ខ្លួនយ៉ាងនេះ ទើបសម្តែងធម៌ដល់ទេវតា ។ ក្របីនោះលុះកន្លងបាន ២-៣ ថ្ងៃក៏ទៅកាន់ទីដទៃ ក្របីកាចដទៃបានទៅអាស្រ័យក្នុងទីនោះ ព្រោះជាលំនៅសប្បាយ ស្វាអាក្រក់សម្គាល់ក្របីនោះថាជាក្របីមុននោះឯង ទើបឡើងលើខ្នងក្របីកាច ហើយធ្វើអនាចារ

ក្នុងទីនោះដូចគ្នា ។ ទើបក្របីកាចទម្លាក់ស្វាឲ្យធ្លាក់លើផែនដី យកស្នែងវែងត្រង់ដើមទ្រូង យកជើងជាន់របហូតបែកខ្ទេចខ្ទី ។

មហិសរាជអ្នកមានសីល ក្នុងកាលនោះ គឺព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។ ក្នុងមហិសរាជចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះពោធិសត្វនោះ តាមសមគួរដោយន័យ ដូចពោលខាងដើមនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបគុណានុភាពរបស់ព្រះមហាសត្វក្នុងចរិយានេះ ដូចក្នុងហត្ថិនាគចរិយា ( មាតុបោសកចរិយា ) ភូរិទត្តចរិយា ចម្បេយ្យចរិយា និងនាគរាជចរិយា ។ល។

## អដ្ឋកថាមហិសរាជចរិយា ចប់

# សុត្តន្តបិដក

## រុរុមិគចរិយាទី ៦

[ ១៦ ] មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចម្រឹគឈ្មោះរុរុ សម្បុរស្បែកដូចមាស ដែលជាធំដុតល្អ ប្រកបដោយសីលដ៏ឧត្តម ។ កាលនោះ ប្រទេសដែលគួរឲ្យត្រេកអរ គួរឲ្យរីករាយ ជាប្រទេសស្ងាត់សូន្យ មិនមានមនុស្ស នៅជិតច្រាំងទន្លេគង្គា គួរជាទីរីករាយនៃចិត្ត តថាគតបានចូលទៅនៅក្នុងទីនោះ ។ កាលនោះ មានបុរសម្នាក់ ( ចំពាក់បំណុលគេ ) ត្រូវពួកម្ចាស់ទ្រព្យតឹងទារខ្លាំង ក៏លោតទម្លាក់ខ្លួនចុះ ក្នុងទីខាងលើខ្សែទឹកទន្លេគង្គា ដោយគិតថា អញរស់ក៏ដោយ ស្លាប់ក៏ដោយ ។ បុរសនោះ ត្រូវខ្សែទឹកទន្លេគង្គាកួចទៅក្នុងទឹកជំ អស់មួយយប់មួយថ្ងៃ ស្រែកនូវសម្រែកគួរអាណិត អណ្តែតទៅក្នុងកណ្តាលទន្លេ ។ តថាគតឮសំឡេងនៃបុរសនោះ កំពុងខ្សឹកខ្សួលគួរអាណិត ស្ថិតនៅទៀបច្នេរនៃស្ទឹង ក៏ស្រែកសួរថា អ្នកជាមនុស្សឬ ។ បុរសនោះ ដែលតថាគតសួរហើយ ក៏ប្រាប់ហេតុរបស់ខ្លួនក្នុងកាលនោះថា ខ្ញុំភ័យតក់ស្លុតខ្លាំងនឹងពួកម្ចាស់បំណុល ហើយស្ទុះមកក្នុងស្ទឹងធំនេះ ។ តថាគតមានសេចក្តីអាណិត ចំពោះបុរសនោះ ក៏ប្រថុយលះបង់ជីវិតរបស់ខ្លួន ចូលទៅនាំយកបុរសនោះមក ក្នុងរាត្រីដ៏ងងឹត ។ តថាគតដឹងនូវកាលនៃបុរសនោះ បាត់សេចក្តីលំបាកហើយ ក៏ពោលពាក្យនេះនឹងបុរសនោះថា ខ្ញុំសូមពរ

មួយនឹងអ្នកថា ចូរអ្នកកុំប្រាប់រូបខ្ញុំដល់អ្នកណាមួយឡើយ ។ បុរសនោះទៅកាន់នគរវិញ ស្តេចសួរហេតុតែចង់បានទ្រព្យ ក៏ក្រាបទូល ( ដល់ស្តេច ) ហើយនាំស្តេចចូលទៅកាន់សម្នាក់តថាគត ។ តថាគតប្រាប់ហេតុសព្វគ្រប់ដល់ស្តេច ស្តេចលុះបានស្តាប់ពាក្យនោះហើយ ក៏បានសម្រេចព្រះហឫទ័យថា ត្រូវសម្លាប់បុរសនេះដោយកូនសរ ( ទ្រង់ត្រាស់ថា ) អញនឹងសម្លាប់បុរសទ្រុស្តមិត្តដ៏អាក្រក់ក្នុងទីនេះ ។ តថាគតកាលរក្សានូវបុរសនោះ ក៏ស៊ុបបួរខ្លួនបុរសនោះ ដោយខ្លួនរបស់តថាគត ( ក្រាបទូលថា ) បពិត្រមហារាជ បុរសនុ៎ះ ចូររស់នៅចុះ សូមព្រះអង្គធ្វើខ្ញុំព្រះអង្គតាមប្រាថ្នាវិញ ។ តថាគត រក្សាសីលរបស់តថាគត មិនរក្សាជីវិតរបស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលហ្មត់ចត់ ព្រោះហេតុតែពោធិញ្ញាណ ។

## រុរុមិគចរិយាទី ៦ ចប់

# អដ្ឋកថា

## រុរុមិគរាជចរិយា

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរុរុមិគរាជចរិយាទី ៦ ដូចតទៅនេះ បទថា **សុតត្តកនកសន្និភោ** សេចក្តីថា ស្តេចម្រឹគឈ្មោះរុរុនេះ ប្រាសចាកពណ៌ខ្មៅ បរិសុទ្ធពេញខ្លួន យ៉ាងណា មាសដែលគេដាក់ចូលក្នុងភ្លើងហើយដុត ក៏ចែងចាំងយ៉ាងនោះ ។ បទថា **មិគរាជា រុរុ នាម** សេចក្តីថា ដោយការសម្រេចនៃជាតិ គឺដោយឈ្មោះ ជាសត្វឈ្មោះរុរុ ដោយជាតិជាស្តេចម្រឹគ អធិប្បាយថា ជាសត្វឈ្មោះរុរុ និងជាស្តេចនៃពួកម្រឹគ ។ បទថា **បរមសីលសមាហិតោ** សេចក្តីថា តាំងមាំនៅក្នុងសីលដ៏ឧត្តម គប្បីជ្រាបអត្ថក្នុងបទនេះយ៉ាងនេះថា សីលបរិសុទ្ធ និងមានចិត្តតាំងមាំ ឬមានចិត្តតាំងមាំដោយប្រពៃក្នុងសីលដ៏បរិសុទ្ធ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគ ឈ្មោះរុរុ ពណ៌នៃរាងកាយរបស់ម្រឹគនោះ ក្រហមដូចមាសដែលគេដុត ហើយខាត់យ៉ាងល្អ ជើងទាំង ៤ ដូចលាបដោយល័ក្ត កន្ទុយដូចកន្ទុយចាមរី ស្នែងមានពណ៌ដូចកម្រងប្រាក់ ភ្នែកដូចដុំកែវមណីដែលខាត់ល្អហើយ មាត់ដូចកូនឃ្លីស្បែកស្រោបដោយសំពត់កម្ពលពណ៌ក្រហម ដែលគេយកទៅដាក់តម្កល់ ។ ម្រឹគនោះលះនូវការប្រឡូកប្រឡំដោយពួកគណៈ បំណងនឹងនៅស្ងប់ស្ងាត់ ទើបលះបង់បរិវារនៅម្នាក់ឯងក្នុងព្រៃធំ ដែលដេសដាសដោយផ្ការីកស្គុសស្គាយ លាយឡំដោយដើមសាលព្រឹក្ស ដែលគួរជាទីត្រេកអរក្បែរស្ទឹងគង្គា ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ ប្រទេសដែលគួរឲ្យត្រេកអរ គួរឲ្យរីករាយ ជាប្រទេសស្ងាត់សូន្យ មិនមានមនុស្ស នៅជិតប្រាំងទន្លេគង្គា គួរជាទីរីករាយនៃចិត្ត តថាគតបានចូលទៅនៅក្នុងទីនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **រម្មេ បទេសេ** សេចក្ដីថា ក្នុងអរញ្ញប្រទេសគួរជាទីត្រេកអរ ព្រោះប្រកបដោយភូមិភាគពណ៌សដោយខ្សាច់ ដូចគ្នានឹងកម្រាលកែវមុក្តា គ្របដណ្ដប់ដោយព្រៃ និងស្មៅពណ៌ខៀវស្រស់ ដុះឡើងដ៏ត្រកាល លម្អដោយផ្កាំងថ្មដ៏វិចិត្រ ដោយពណ៌ផ្សេងៗ ហាក់ដូចក្រាលយ៉ាងល្អ និងដោយស្រះប្រកបដោយទឹកថ្លាស្អាតដូចដុំកែវមណី និងព្រោះគ្របដណ្ដប់ដោយតិណជាតិ មានសម្ផស្សទន់ដោយច្រើន មានពណ៌ក្រហមដូចពណ៌នៃមេក្អៀង ។ បទថា **រម្មណីយេ** សេចក្ដីថា ជារម្មណីយដ្ឋាន ធ្វើឲ្យកើតការត្រេកអរដល់ជនដែលចូលទៅក្នុងទីនោះ ព្រោះល្អដោយព្រៃក្រាស់មានមែកសាខាគ្របដណ្ដប់ សម្រេចហើយដោយផ្កា ផ្លែ ឈើ និងត្រួយឈើ ពួកបក្សីច្រើនប្រភេទ បញ្ចេញសំឡេងខ្ទៀវខ្ទារ រុងរឿងដោយដើមឈើលតាវល្លិ និងព្រៃច្រើនយ៉ាង មានដើមស្វាយ ដើមសាលព្រឹក្ស ដងព្រៃ សមដូចព្រះតម្រាស់ត្រាស់ក្នុងរុរុមិគរាជជាតកថា

ដើមស្វាយ និងដើមសាលព្រឹក្ស ក្នុងដងព្រៃនុ៎ះ មានផ្ការីក ( ផែនដី ) ដ៏ដេរដាសដោយស្មៅ មានសម្ផស្សស្រួល មានពណ៌ក្រហមដូចជាសម្បុរនៃសត្វមេក្អៀង ម្រឹគនុ៎ះ ស្ថិតនៅក្នុងដងព្រៃនោះ ដូច្នេះ ។

បទថា **វិវិត្តេ** បានដល់ ស្ងាត់ចាកមនុស្ស ។ បទថា **អមនុស្សកេ** បានដល់ ប្រាសចាកមនុស្ស ព្រោះមិនមានមនុស្សសញ្ចរទៅមកក្នុងទីនោះ ។ បទថា **មនោរមេ** មានវិគ្គហៈថា ឈ្មោះថា **មនោរមេ** ព្រោះជាទីត្រេកអរនៃចិត្តដោយចំពោះរបស់បុគ្គលអ្នកត្រូវការសេចក្ដីស្ងប់ ដោយគុណសម្បត្តិតាមដែលពោលហើយ ។

បទថា **អជ** ក្នុងបទថា **អជ ឧបរិគង្គាយ** នេះជានិបាត ចុះក្នុងអធិការគឺហេតុកើតឡើង លោកសម្ដែងថា ដោយហេតុនោះ កាលតថាគតនៅយ៉ាងនោះក្នុងទីនោះ កើតហេតុនេះឡើងហើយ ។ បទថា **ឧបរិគង្គាយ** បានដល់លើក្រសែស្ទឹងគង្គា ។ បទថា **ធនិកេហិ បរិបីឡិតោ** បានដល់ បុរសត្រូវម្ចាស់បំណុលតឹងទារមិនអាចសងបាន ។

មានរឿងតំណាលថា សេដ្ឋីក្រុងពារាណសីម្នាក់ មិនឲ្យកូនរបស់ខ្លួនសិក្សានូវសិប្បៈណាមួយ ដោយគិតថា កូននេះរៀនសិប្បៈនឹងលំបាក ។ បុត្រសេដ្ឋីមិនចេះអ្វីសោះក្រៅអំពីការច្រៀង លេងភ្លេង រាំ ទំពាស៊ី និងបរិភោគ ។ កាលបុត្រចម្រើនវ័យ មាតាបិតារកកិរិយាដែលសមគួរឲ្យ ប្រគល់ទ្រព្យសម្បត្តិឲ្យហើយ ក៏ធ្វើមរណកាលទៅ ។ កាលមាតាបិតាអនិច្ចកម្មទៅហើយ សេដ្ឋីបុត្រក៏ត្រូវចោមរោមដោយអ្នកលេងស្រី អ្នកលេងស្រា បំផ្លាញទ្រព្យទាំងអស់ ដោយអបាយមុខផ្សេងៗ ខ្ចីបំណុលគេ ក្នុងទីនោះៗ មិនអាចសងបាន កាលត្រូវម្ចាស់បំណុលតឹងទារ ទើបគិតថា ប្រយោជន៍អ្វីដោយជីវិតរបស់អញ មានអត្តភាពបែបនេះ ដូចអ្នកដទៃ អាត្មាអញស្លាប់វិញប្រសើរជាង

ទើបប្រាប់ម្ចាស់បំណុលទាំងឡាយថា អ្នកទាំងឡាយ ចូរយកបញ្ជីបំណុលមក ខ្ញុំមានទ្រព្យដែលជារបស់ត្រកូលកប់ត្រង់ឆ្នេរស្ទឹងគង្គា ខ្ញុំនឹងឲ្យទ្រព្យនោះដល់ពួកអ្នក ។ ម្ចាស់ទ្រព្យទាំងឡាយ ក៏ទៅជាមួយបុរសនោះ ។ សេដ្ឋីបុត្រក៏ធ្វើជាប្រាប់ទីកប់ទ្រព្យថា ទ្រព្យកប់ក្នុងទីនេះៗ គិតថា ដោយអាការយ៉ាងនេះ អញនឹងផុតបំណុល ហើយគេចទៅលោតទឹក ។ សេដ្ឋីបុត្រនោះអណ្តែតទៅតាមខ្សែទឹកដែលហូរខ្លួនខ្លាញ់ ស្រែកសូមឲ្យជួយ ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ មានបុរសម្នាក់ ( ចំពាក់បំណុលគេ ) ត្រូវពួកម្ចាស់ទ្រព្យតឹងទារខ្លាំង ក៏លោតទម្លាក់ខ្លួនចុះ ក្នុងទីខាងលើខ្សែទឹកទន្លេគង្គា ដោយគិតថា អញរស់ក៏ដោយស្លាប់ក៏ដោយ ។ បុរសនោះត្រូវខ្សែទឹកទន្លេគង្គាក្ខួចទៅក្នុងទឹកជំ អស់មួយយប់ មួយថ្ងៃ ស្រែកនូវសម្រែកគួរអាណិត អណ្តែតទៅក្នុងកណ្តាលទន្លេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ជីវាមិ វា មរាមិ វា** សេចក្តីថា បុរសនោះលោតចុះទៅក្នុងក្រសែទឹក គិតថា អញរស់ឬស្លាប់ក៏ដោយ អធិប្បាយថា អញមានជីវិត ឬស្លាប់ក្នុងស្ទឹងនេះក៏ដោយចុះ ដោយប្រការទាំងពីរយ៉ាងនឹងមិនមានការបៀតបៀនអំពីម្ចាស់បំណុលដូច្នេះ ។ បទថា **មជ្ឈេ គង្គាយ គច្ឆតិ** សេចក្តីថា បុរសនោះអណ្តែតទៅក្នុងស្ទឹងអស់ថ្ងៃ និងយប់ ព្រោះនៅស្រឡាញ់ជីវិត មិនទាន់ដល់សេចក្តីស្លាប់ ទើបខ្លាចមរណភ័យ សូមឲ្យគេជួយ អណ្តែតទៅតាមជំនន់ទឹកកណ្តាលស្ទឹង ។

កាលនោះ មហាបុរសបានឮសំឡេងរបស់បុរសនោះ ស្រែកឲ្យជួយក្នុងកណ្ដាលរាត្រី គិតថា អញបានឮសំឡេងមនុស្ស ដរាបណាអញនៅក្នុងទីនេះ បុរសនេះកុំបីស្លាប់ឡើយ អញនឹងជួយជីវិតបុរសនេះ ទើបចេញអំពីគុម្ពឈើដែលជាជំណេក ចូលទៅកាន់ឆ្នេរស្ទឹងពោលថា បុរសដ៏ចម្រើន អ្នកកុំខ្លាចឡើយ ខ្ញុំនឹងជួយជីវិតអ្នក ហើយលួងលោម ហែលជ្រែកក្រសែទឹក ឲ្យបុរសនោះជិះលើខ្នង នាំទៅដល់ត្រើយ ហើយនាំទៅកាន់លំនៅរបស់ខ្លួន បន្ទាបង់នូវការហត់នឿយ ឲ្យផ្លែឈើបរិភោគ ។ កន្លងទៅ ២-៣ ថ្ងៃ ទើបពោលនឹងបុរសនោះថា បុរសដ៏ចម្រើន ខ្ញុំនឹងនាំអ្នកទៅកាន់ផ្លូវដែលនឹងទៅកាន់ក្រុងពារាណសី សូមអ្នកកុំប្រាប់អ្នកណាថា ក្នុងទីនោះ មានប្រើសមាសអាស្រ័យនៅ ។ បុរសនោះទទួលថា សាធុ ខ្ញុំមិនប្រាប់អ្នកណាឡើយ ។ ព្រះមហាសត្វឲ្យបុរសនោះជិះលើខ្នងរបស់ខ្លួន នាំទៅកាន់ផ្លូវដែលទៅកាន់ក្រុងពារាណសី ហើយក៏វិលត្រឡប់ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតឮសំឡេងនៃបុរសនោះ កំពុងខ្សឹកខ្សួលគួរអាណិត ស្ថិតនៅទៀបឆ្នេរនៃស្ទឹង ក៏ស្រែកសួរថា អ្នកជាមនុស្សឬ ។ បុរសនោះដែលតថាគតសួរហើយ ក៏ប្រាប់ហេតុរបស់ខ្លួនក្នុងកាលនោះថា ខ្ញុំភ័យតក់ស្លុតខ្លាំងនឹងពួកម្ចាស់បំណុល ហើយស្ទុះមកក្នុងស្ទឹងធំនេះ ។ តថាគតមានសេចក្ដីអាណិត ចំពោះបុរសនោះ ក៏ប្រថុយលះបង់ជីវិតរបស់ខ្លួន ចូលទៅនាំយកបុរសនោះមក ក្នុងរាត្រីដ៏ងងឹត ។ តថាគតដឹងនូវកាលនៃបុរសនោះ បាត់សេចក្ដី

លំបាកហើយ ក៏ពោលពាក្យនេះនឹងបុរសនោះថា ខ្ញុំសូមពរមួយនឹងអ្នកថា ចូរអ្នកកុំប្រាប់រូបខ្ញុំដល់អ្នកណាមួយឡើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កោសិ ត្វំ ឥធ** សេចក្តីថា អ្នកជាអ្នកណា ជាមនុស្សឬ អធិប្បាយថា អ្នកអណ្តែតមកអំពីណា ទើបមកដល់ទីនេះ ។ បទថា **អត្តនោ ករុណំ** បានដល់ កាលធ្វើរបស់ខ្លួន ។ បទថា **ធនិកេហិ ភីតោ** បានដល់ ត្រូវម្ចាស់បំណុលធ្វើឲ្យភ័យខ្លាច ។ បទថា **តសិតោ** បានដល់ ឲ្យតក់ស្លុត ។

បទថា **តស្ស កត្វាន ការុញ្ញំ ចជិត្វា មម ជីវិតំ** សេចក្តីថា តថាគតជួយស្រង់បុរសនោះ ដោយករុណាដ៏ខ្លាំង ទើបប្រថុយលះបង់ជីវិតរបស់ខ្លួនដល់បុរសនោះ ។ បទថា **បវិសិត្វា នីហរឹ តស្ស** សេចក្តីថា ចុះស្ទឹងហែលកាត់ខ្សែទឹកទៅត្រង់ៗ ឲ្យបុរសនោះឡើងលើខ្នង ហើយនាំចេញអំពីទីនោះ ។ បទថា **តស្ស** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បាលីថា **តត្ថ** ដូច្នេះក៏មាន អធិប្បាយថា ក្នុងស្ទឹងនោះ ។ បទថា **អន្ធការម្ហិ រត្តិយា** សេចក្តីថា ក្នុងរាត្រី បានដល់ ក្នុងរាត្រីរនោច ។

បទថា **អស្សត្ថកាលមញ្ញាយ** សេកក្តីថា តថាគតដឹងកាលដែលគេបាត់ហត់នឿយ ហើយទើបឲ្យផ្លែឈើតូចធំ រហូតបុរសនោះប្រាសចាកសេចក្តីទុក្ខ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ។ បទថា **ឯកំ តំ វរំ យាចាមិ** សេចក្តីថា ខ្ញុំសូមពរនឹងអ្នកមួយ អធិប្បាយថា សូមអ្នកឲ្យពរមួយដល់ខ្ញុំ ។ បើសួរថា ពរនោះដូចម្តេច ឆ្លើយថា សូមអ្នកកុំប្រាប់ខ្ញុំដល់បុគ្គលណាមួយ

គឺកុំយករឿងរបស់ខ្ញុំប្រាប់ដល់ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាថា មានប្រើសមាសអាស្រ័យនៅក្នុងទីនោះ ដូច្នេះ ។

លំដាប់នោះ ក្នុងថ្ងៃដែលបុរសនោះ ចូលដល់ក្រុងពារាណសីនោះឯង អគ្គមហេសីបានទូលព្រះរាជាថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់បានយល់សប្តិឃើញប្រើសមាសសម្តែងធម៌ដល់ខ្ញុំម្ចាស់ៗ យល់សប្តិពិត ប្រើសមាសនឹងមានពិត ព្រោះហេតុនោះ ខ្ញុំប្រាថ្នានឹងស្តាប់ធម៌របស់ប្រើសមាស ។ បើខ្ញុំម្ចាស់បានស្តាប់ធម៌ ទើបមានជីវិត បើមិនបានស្តាប់ ក៏នឹងមិនមានជីវិត ។ ព្រះរាជាលួងលោមអគ្គមហេសី ហើយត្រាស់ថា បើប្រើសមាសមានក្នុងមនុស្ស-លោក នាងនឹងបាន ហើយត្រាស់ឲ្យហៅព្រាហ្មណ៍ សួរថា ធម្មតាប្រើសមាសមានឬ ទ្រង់បានស្តាប់ថាមាន ទើបទ្រង់យកថង់ទ្រព្យមួយពាន់ ដាក់ក្នុងប្រអប់មាស លើកដាក់លើ-កដំរី ហើយឲ្យវាយស្គរប្រកាសពេញព្រះនគរថា អ្នកណាប្រាប់ប្រើសមាស យើងនឹងឲ្យថង់ទ្រព្យនេះ មួយអន្លើដោយដំរីដល់បុគ្គលនោះ ។ ព្រះរាជាមានបំណងនឹងឲ្យច្រើនជាងនោះ ទើបត្រាស់ឲ្យចារឹកស្រុកសួយ ដាក់លើដំបារមាស ហើយប្រកាសពេញព្រះនគរថា

នរណាប្រាប់ម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយដល់
យើង យើងនឹងឲ្យស្រុកសួយ និងនាងនារីដែលស្អិតស្អាងហើយ
ដល់អ្នកនោះ ដូច្នេះ ។

លំដាប់នោះ សេដ្ឋីបុត្របានស្តាប់ដូច្នោះ ក៏ចូលទៅរករាជបុរស ហើយពោលថា ខ្ញុំនឹងប្រាប់ម្រឹគបែបនោះដល់ព្រះរាជា អ្នកទាំងឡាយចូរនាំខ្ញុំចូល

គាល់ព្រះរាជាចុះ ។ ពួករាជបុរសនាំសេដ្ឋីបុត្រនោះចូលគាល់ព្រះរាជា ហើយទូលសេចក្ដីនោះឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់សួរថា អ្នកបានឃើញពិតឬ បុរសនោះទូលថា ពិតព្រះអង្គ ពិតមែន សូមទ្រង់មកជាមួយទូលបង្គំចុះ ទូលបង្គំនឹងឲ្យទ្រង់ទតម្រឹគនោះ ។ ព្រះរាជាឲ្យបុរសនោះនាំផ្លូវទៅ ដល់ទីនោះដោយបរិវារធំ ឲ្យពួករាជបុរសកាន់អាវុធព័ទ្ធជុំវិញទីដែលបុរសទ្រស្តមិត្តនោះចង្អុលឲ្យមើលដោយជុំវិញ ហើយត្រាស់ថា ចូរពួកអ្នកធ្វើសំឡេងខ្លាំង ហើយទ្រង់ប្រថាប់ឈរក្នុងចំណែកម្ខាង ជាមួយបុរស ២-៣ នាក់ បុរសនោះក៏បានឈរក្នុងទីមិនឆ្ងាយ ។ ព្រះមហាសត្វស្ដាប់សំឡេងក៏ដឹងថា ជាសំឡេងកងពលធំ ភ័យរបស់អាត្មាអញ គង់កើតអំពីបុរសនោះដោយពិត ទើបក្រោកឡើងសម្លឹងមើលជនទាំងអស់ គិតថា អញនឹងផុតភ័យ ក្នុងទីដែលព្រះរាជាប្រថាប់ឈរ ទើបដើរសំដៅចូលទៅរកព្រះរាជា ។ ព្រះរាជាទ្រង់ទតឃើញប្រើសមាសនោះដើរមក ទ្រង់ព្រះតម្រិះថា ប្រើសមាសនេះ មានកម្លាំងដូចដំរីសារ គង់មកបៀតបៀនអញ ទើបទ្រង់ផ្ទាប់ព្រួញ តម្រង់ទៅកាន់ព្រះពោធិសត្វដោយព្រះតម្រិះថា បើម្រឹគនេះខ្លាចគេចទៅ អញនឹងបាញ់ដើម្បីបង្អន់កម្លាំង ហើយសឹមចាប់ ។ ព្រះមហាសត្វបានពោលគាថាដូច្នេះថា

បពិត្រមហារាជ សូមព្រះអង្គឈប់សិន បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំបាញ់ទូលព្រះបង្គំជាខ្ញុំឡើយ នរណាអេះ

បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគនុ៎ះ ស្ថិតនៅក្នុងដង

ព្រៃនុ៎ះ ដូច្នេះ ។

ព្រះរាជា ទ្រង់បន្តន់ដោយពាក្យដ៏ពីរោះរបស់ម្រឹគនោះ ទ្រង់ដោះសរ ប្រថាប់ឈរដោយសេចក្ដីគោរព ។ ព្រះពោធិសត្វក៏ចូលទៅរកព្រះរាជា ធ្វើបដិសណ្ឋារៈយ៉ាងទន់ភ្លន់ ។ មហាជនក៏ដាក់សព្វាវុធចោមរោមព្រះរាជា ដូចព្រះមានព្រះភាគត្រាស់ថា

បុរសនោះ ទៅកាន់នគរវិញ ស្ដេចសួរហេតុ តែចង់បានទ្រព្យ

ក៏ក្រាបទូល ( ដល់ស្ដេច ) ហើយនាំស្ដេចចូលទៅកាន់សម្នាក់

តថាគត ដូច្នេះ ។

អត្ថរបស់គាថានោះ មានដូចតទៅ បុគ្គលណាទ្រុស្តមិត្ត ជាបុរសអាក្រក់ ខ្ញុំលះបង់ជីវិតជួយឲ្យផុតអំពីចំណីសត្វ នាំទៅកាន់ក្រុងពារាណសី បែរជាប្រាប់ដល់ព្រះរាជា ព្រោះត្រូវការទ្រព្យ ។ កាលប្រាប់ហើយ បុរសអាក្រក់នោះ ជាអ្នកនាំផ្លូវដើម្បីឲ្យព្រះរាជាមកចាប់ខ្ញុំ ទើបនាំព្រះរាជាមកកាន់លំនៅរបស់ខ្ញុំ ។

ព្រះមហាសត្វទូលសួរព្រះរាជា ដោយសំឡេងដ៏ពីរោះ ដូចគេអង្រួនកណ្ដឹងមាសថា អ្នកណាហ្ន៎ ទូលរឿងនេះដល់ព្រះអង្គថា ក្នុងទីនេះ មានម្រឹគអាស្រ័យនៅ ។ ក្នុងខណៈនោះ បុរសអាក្រក់នោះ ចៀសចេញទៅបន្តិច រួចឈរក្នុងទីដែលល្មមស្ដាប់ឮ ។ ព្រះរាជាត្រាស់ថា បុរសនេះប្រាប់អ្នកដល់យើង ហើយទ្រង់ចង្អុលទៅកាន់បុរសអាក្រក់នោះ គ្រានោះ ព្រះពោធិសត្វ

ពោលគាថាថា

បានឮមកថា នរជនពួកខ្លះ ក្នុងលោកនេះ បានពោលពាក្យពិត យ៉ាងនេះថា កំណាត់ឈើដែលគេស្រង់ឡើង ប្រសើរជាង ឯនរជនពួកខ្លះ ដែលគេស្រង់ឡើងមិនប្រសើរទេ ដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់កើតសេចក្តីសង្ស័យ ត្រាស់គាថាថា

ម្នាលម្រឹគ អ្នកតិះដៀលម្រឹគទាំងឡាយ ឬបក្សីទាំងឡាយ ឬក៏មនុស្សទាំងឡាយ យើងមានភ័យច្រើន ព្រោះតែឮអ្នកនិយាយជាភាសាមនុស្ស ដូច្នេះ ។

លំដាប់នោះ មហាបុរសកាលទូលថា បពិត្រមហារាជ ខ្ញុំមិនតិះដៀលម្រឹគ មិនតិះដៀលបក្សី តែខ្ញុំតិះដៀលមនុស្ស ទើបពោលថា

ខ្ញុំបានស្រង់មនុស្សណា ដែលរសាត់ទៅក្នុងផ្លូវទឹក មានទឹកច្រើន ទឹកជ្រៅ មានខ្សែទឹកហូររហ័ស ( ឥឡូវ ) ភ័យមានមកដល់ទូលព្រះបង្គំជាខ្ញុំហើយ ព្រោះហេតុតែស្រង់មនុស្សនោះ បពិត្រមហារាជ ការរួបរួមនឹងអសប្បុរស តែងនាំមកនូវសេចក្តីទុក្ខ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ស្រង់ឡើង បានដល់ ស្រង់អំពីទឹក ។ ពាក្យថា នរជនពួកខ្លះ សេចក្តីថា បុគ្គលខ្លះទ្រុស្តមិត្ត ជាបាបបុរស ទោះបីធ្លាក់ចូលទៅក្នុងទឹក កាលមានបុរសជួយស្រង់មក មិនប្រសើរឡើយ ព្រោះកំណាត់ឈើ គង់ប្រើប្រយោជន៍បានច្រើនយ៉ាង តែបុគ្គលទ្រុស្តមិត្ត រមែង

ប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ព្រោះហេតុនោះ ទើបកំណាត់ឈើ ប្រសើរជាងបុគ្គលទ្រុស្ដមិត្តនោះ ។ ពាក្យថា ម្រឹគទាំងឡាយ សេចក្ដីថា ព្រះរាជាត្រាស់សួរថា នែរុរុមិគរាជ បណ្ដាម្រឹគ បក្សី មនុស្ស អ្នកតិះដៀលនរណា ។ ពាក្យថា យើងមានភ័យច្រើន សេចក្ដីថា យើងបាននូវភ័យធំ អធិប្បាយថា ធ្វើភ័យហាក់ដូចជារបស់ខ្លួន ។

ពាក្យថា ក្នុងផ្លូវទឹក សេចក្ដីថា ជំនន់ទឹកអាចបន្សាត់មនុស្សដែលធ្លាក់ទៅហើយបាន ។ ពាក្យថា មានទឹកច្រើន ទឹកជ្រៅ បានដល់ ក្នុងទឹកដែលមានទឹកច្រើន ។ ដោយពាក្យទាំងពីរ លោកសម្ដែងថា ជំនន់ទឹកមានទឹកច្រើន ។ ពាក្យថា ព្រោះហេតុតែស្រង់មនុស្សនោះ ស្ដេចម្រឹគទូលព្រះរាជាថា បពិត្រមហារាជ បុរសណាដែលទ្រង់ចង្អុលបង្ហាញដល់ខ្ញុំ បុរសនោះអណ្ដែតទៅក្នុងស្ទឹង យំខ្សឹកខ្សួល សូមនូវការជួយសង្គ្រោះទាំងកណ្ដាលរាត្រី ខ្ញុំជួយលើកបុរសនោះឡើងអំពីទឹក ។ ភ័យនេះមកដល់ខ្ញុំ ព្រោះបុរសនោះជាហេតុ ឈ្មោះថា ការរួបរួមជាមួយអសប្បុរស ជាទុក្ខ ។ ព្រះរាជាកាលទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់ខ្ញាល់នឹងបុរសអាក្រក់នោះ ទ្រង់ផ្ដាប់ព្រួញដោយព្រះតម្រិះថា បុរសនេះមិនដឹងគុណ បុគ្គលដែលមានឧបការៈដល់ម៉្លេះធ្វើឲ្យស្ដេចម្រឹគលំបាក អញនឹងបាញ់វាឲ្យស្លាប់បង់ ។ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតប្រាប់ហេតុ សព្វគ្រប់ដល់ស្ដេច ស្ដេចលុះបានស្ដាប់
ពាក្យនោះហើយ ក៏បានសម្រេចព្រះហឫទ័យថា ត្រូវសម្លាប់

បុរសនេះដោយកូនសរ ( ទ្រង់ត្រាស់ថា ) អញនឹងសម្លាប់
បុរសទ្រុស្តមិត្ត ដ៏អាក្រក់ក្នុងទីនេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យាវតា ករណំ** សេចក្តីថា ទូលដល់ការធ្វើឧបការៈទាំងអស់ ដែលតថាគតធ្វើដល់បុរសនោះ ។ បទថា **បកប្បយិ** បានដល់ ផ្គាប់ព្រួញ ។ បទថា **មិត្តទុព្ភី** បានដល់ ជាអ្នកមានប្រក្រតីប្រទូស្តមិត្ត ដែលមានឧបការៈដល់ខ្លួន ។

លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា បុរសពាលនេះកុំបីវិនាស ព្រោះអាស្រ័យអញឡើយ ទើបទូលថា បពិត្រមហារាជ ឈ្មោះថា ការសម្លាប់បុគ្គលពាលក្តី បណ្ឌិតក្តី វិញ្ញូជនមិនសរសើរថាល្អឡើយ ដោយពិតវិញ្ញូជនតិះដៀលយ៉ាងក្រៃលែង ព្រោះហេតុនោះ សូមទ្រង់កុំសម្លាប់បុរសពាលនេះឡើយ បណ្តោយឲ្យគេទៅតាមការពេញចិត្តចុះ សូមទ្រង់កុំឲ្យគេវិនាសឡើយ សូមទ្រង់ព្រះរាជទានវត្ថុដែលទ្រង់ប្តេជ្ញាដល់បុរសនោះថា នឹងព្រះរាជទានចុះព្រះអង្គ ហើយទូលបន្តថា ម្យ៉ាងទៀត ខ្ញុំនឹងនាំវត្ថុដែលទ្រង់ប្រាថ្នា ខ្ញុំនឹងប្រគល់ខ្លួនដល់ទ្រង់ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតកាលរក្សានូវបុរសនោះ ក៏ស៊ូប្តូរខ្លួនបុរសនោះ ដោយខ្លួន
របស់តថាគត ( ក្រាបទូលថា ) បពិត្រមហារាជ បុរសនុ៎ះ ចូរ
រស់នៅចុះ សូមព្រះអង្គធ្វើខ្ញុំព្រះអង្គតាមប្រាថ្នាវិញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឋិម្មិតឹ** សេចក្តីថា តថាគតតាមរក្សាបុរសដែលទ្រុស្តមិត្តនោះ ជាបុគ្គលថោកទាប បានប្រគល់អត្តភាពរបស់តថាគត

ថ្វាយដល់ព្រះរាជានោះ អធិប្បាយថា តថាគតបានប្រគល់ខ្លួនថ្វាយដល់ព្រះរាជា ហើយបញ្ឈប់ការស្លាប់របស់បុរសនោះ ដែលធ្លាក់ក្នុងកណ្ដាប់ដៃរបស់ព្រះរាជា ។ បទថា **តិដ្ឋតោសោ** ជាដើម ជាបទសម្ដែងអាការនៃពាក្យសម្ដីដែលអាស្រ័យចំពោះគ្នា ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងដល់ប្រយោជន៍ដែលធ្វើនូវពាក្យដែលអាស្រ័យគ្នារបស់ព្រះអង្គ ទើបត្រាស់គាថាចុងក្រោយ ។

សេចក្ដីនៃគាថាចុងក្រោយនោះ មានដូចតទៅនេះថា

ក្នុងកាលនោះ កាលព្រះរាជាមានបំណងនឹងសម្លាប់បុរសដែលទ្រុស្ដមិត្តនោះ ព្រោះអាស្រ័យតថាគត ទើបតថាគតលះបង់ខ្លួនដល់ព្រះរាជា តាមរក្សាសីលរបស់តថាគត មិនមែនតាមរក្សាជីវិតរបស់តថាគតទេ ការដែលតថាគតជាអ្នកមានសីល មិនគិតដល់ជីវិតរបស់ខ្លួន ក៏ព្រោះហេតុនៃសម្មាសម្ពោធិញ្ញាណនោះឯង ។

លំដាប់នោះ ព្រះរាជាកាលព្រះពោធិសត្វលះបង់ជីវិតរបស់ខ្លួន បញ្ឈប់នូវការស្លាប់របស់បុរសនោះ មានព្រះហឫទ័យត្រេកអរ ត្រាស់ថា ចូរអ្នកទៅចុះ អ្នកផុតអំពីសេចក្ដីស្លាប់ ដែលមានក្នុងកណ្ដាប់ដៃរបស់យើង ដោយការជួយសង្គ្រោះរបស់ស្ដេចម្រឹគ ហើយព្រះរាជទានទ្រព្យដល់បុរសនោះតាមប្រាថ្នា ។ ព្រះរាជាទ្រង់អនុញ្ញាតពរតាមការពេញចិត្តរបស់ព្រះពោធិសត្វ ហើយនាំព្រះពោធិសត្វចូលកាន់ព្រះនគរ ត្រាស់ឲ្យតាក់តែងព្រះនគរ និងឲ្យតាក់តែងព្រះពោធិសត្វ ឲ្យព្រះពោធិសត្វសម្ដែងធម៌ដល់ព្រះទេវី ព្រះពោធិសត្វ

សម្តែងធម៌ ដោយភាសាមនុស្សដ៏ពីរោះ ដល់ព្រះរាជា ព្រះទេវី និងដល់រាជបរិស័ទ ថ្វាយឱវាទព្រះរាជាដោយទសពិធរាជធម៌ ទូន្មានមហាជន ហើយចូលព្រៃ ចោមរោមដោយពួកម្រឹគ រស់នៅតាមសប្បាយ ។ ព្រះរាជាទ្រង់ក៏តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់ប្រទានអភ័យដល់សព្វសត្វ ទ្រង់បំពេញកុសល មានទានជាដើម មានស្ថានសួគ៌ជាទីទៅខាងមុខ ។

សេដ្ឋីបុត្រក្នុងកាលនោះ បានជាទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ រុរុមិគរាជ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងរុរុមិគរាជចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះពោធិសត្វនោះតាមសមគួរ ដោយន័យដូចពោលខាងដើមនោះឯង ។

ម្យ៉ាងទៀត ក្នុងចរិយានេះ គប្បីប្រកាសគុណានុភាពរបស់ព្រះមហាសត្វមានយ៉ាងនេះ គឺការលះបង់ហ្វូងរបស់ស្តេចម្រឹគ ដែលមិនប្រាថ្នាជាប់ចំពាក់នឹងជន ព្រោះត្រេកអរក្នុងការស្ងប់ស្ងាត់ហើយនៅតែឯង ការបានឮសំឡេងសោយសោករបស់បុរសដែលខ្សឹកខ្សួល សូមនូវការជួយដែលអណ្តែតក្នុងស្ទឹង ក្នុងវេលារាត្រី ទើបក្រោកចាកទីដំណេក ទៅកាន់ឆ្នេរស្ទឹង លះបង់ជីវិតរបស់ខ្លួន ចុះកាន់អន្លង់ទឹកដែលហូរទៅក្នុងស្ទឹងធំ ហែលកាត់ខ្សែទឹក ឲ្យបុរសនោះឡើងលើខ្នងរបស់ខ្លួននាំមកដល់ច្រាំង លួងលោម ឲ្យផ្លែឈើតូចធំជាដើមហើយ ឲ្យបន្ទោបង់នូវការហត់នឿយ ការឲ្យបុរសនោះឡើងលើខ្នងម្តងទៀត ហើយនាំចេញអំពីព្រៃទៅកាន់ផ្លូវ ភាពជាបុគ្គលមិនខ្វាច ហ៊ាន

ទៅប្រឈមមុខជាមួយព្រះរាជា ដែលផ្ដាប់ព្រួញប្រថាប់ឈរ ដោយបំណង ថានឹងបាញ់ ហើយទូលដោយភាសាមនុស្សមុន ធ្វើនូវបដិសណ្ឋារៈយ៉ាងទន់ភ្លន់ ការពោលធម្មកថានឹងព្រះរាជា ដែលមានបំណងនឹងសម្លាប់បុរសអាក្រក់ ទ្រុស្តមិត្ត ហើយលះបង់ជីវិតរបស់ខ្លួនម្ដងទៀត ហើយក៏ដោះបុរសអាក្រក់ នោះ ឲ្យផុតចាកសេចក្ដីស្លាប់ ការទូលឲ្យព្រះរាជា ទ្រង់ប្រទានទ្រព្យដល់ បុរសនោះតាមប្ដេជ្ញា ការដែលព្រះរាជាប្រទានពរដល់ខ្លួន ក៏សូមឲ្យព្រះ រាជាទ្រង់ឲ្យអភ័យដល់សព្វសត្វ ការសម្ដែងធម៌ដល់មហាជន ដែលមាន ព្រះរាជា និងព្រះទេវីជាប្រធាន ហើយឲ្យជនទាំងនោះ តាំងនៅក្នុងបុណ្យ ទាំងឡាយ មានទានជាដើម ការឲ្យឱវាទដល់ម្រឹគទាំងឡាយដែលបានទទួល អភ័យហើយ ហាមមិនឲ្យស៊ីសន្ទូងរបស់ពួកមនុស្ស ការប្រើស្លឹកឈើ ( កំណួច ) ជាគ្រឿងសម្គាល់ ( មិនឲ្យសត្វស៊ីដំណាំ ក្នុងស្រែចម្ការ ) មានមករហូតដល់សព្វថ្ងៃនេះ ដោយប្រការដូច្នេះ ។

## អដ្ឋកថារុរុមិគចរិយា ចប់

# សុត្តន្តបិដក

## មាតង្គចរិយាទី ៧

[ ១៧ ] មានចរិយាដទៃទៀត កាលតថាគតកើតជាជដិលតាបស ឈ្មោះមាតង្គៈ មានតបៈខ្ពង់ខ្ពស់ មានសីលបរិសុទ្ធ មានចិត្តតម្កល់មាំល្អ ។ ជនពីរនាក់ គឺតថាគត និងព្រាហ្មណ៍នៅជិតឆ្នេរទន្លេគង្គា តថាគតនៅខាងលើខ្សែទឹក ឯព្រាហ្មណ៍នៅខាងក្រោមខ្សែទឹក ។ ព្រាហ្មណ៍កាលដើរទៅតាមឆ្នេរទន្លេ បានឃើញអាស្រមតថាគតនៅខាងលើខ្សែទឹក ក៏ប្រទេច ផ្ដាសាតថាគត ក្នុងទីនោះហើយដាក់សម្បថថា ( ចូរឲ្យក្បាលអ្នកបែកជា ៧ ភាគ ក្នុងថ្ងៃទី ៧ ) ។ បើតថាគតខឹងនឹងព្រាហ្មណ៍ មានតែតថាគតមិនរក្សាសីល តថាគតនឹងក្រឡេកមើលព្រាហ្មណ៍នោះ ហើយធ្វើឲ្យឆេះទៅជាផេះក៏បាន ។ កាលនោះ ព្រាហ្មណ៍នោះ មានចិត្តប្រទូស្តខឹង ដាក់សម្បថដល់តថាគតដោយឧបាយណា សម្បថនោះ បែរជាធ្លាក់លើក្បាលព្រាហ្មណ៍នោះវិញ តថាគតដោះព្រាហ្មណ៍នោះ ឲ្យរួចចាកសម្បថ ដោយឧបាយនោះ ។ តថាគតរក្សាសីលរបស់តថាគត មិនរក្សាជីវិតរបស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលហ្មត់ចត់ ព្រោះហេតុនៃពោធិញ្ញាណ ។

**មាតង្គចរិយាទី ៧ ចប់**

# អដ្ឋកថា

## មាតង្គចរិយា

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមាតង្គចរិយាទី ៧ ដូចតទៅ បទថា **ជដិលោ** បានដល់ មានជដា អធិប្បាយថា មានសក់គួចជាជដា ។ បទថា **ឧគ្គតាបនោ** មានវិគ្គហៈថា ឈ្មោះថា **ឧគ្គតាបនោ** ព្រោះមានសេចក្តីព្យាយាម គឺតបៈដ៏ក្លៀវក្លា ព្រោះដុត គឺសង្កត់នូវឥន្ទ្រិយ ដែលជាចំណុចសំខាន់នៃរាងកាយ អធិប្បាយថា មានតបៈក្លៀវក្លា មានឥន្ទ្រិយមាំទាំក្រៃលែង ។ ន័យម្យ៉ាងទៀត ឈ្មោះថា **ឧគ្គតាបនោ** ព្រោះដុតកិលេសគ្រោតគ្រាត ព្រោះទម្លាយវត្ថុដែលមិនជាប្រយោជន៍ ដែលមានក្នុងបច្ចុប្បន្នជាដើមច្រើនយ៉ាង ព្រោះលះបោលខាងក្រៅ ឬព្រោះដុតកិលេសដែលឈ្មោះ **ឧគ្គា** ដោយអត្ថថា គួរខ្លាចក្រែង ដោយតបៈ គឺសេចក្តីព្យាយាម ។ បទថា **មាតង្គោ ណាម ណាមេន** បានដល់ មានឈ្មោះថា មាតង្គៈ ។ ឈ្មោះរបស់ជដិលនោះ មកហើយដោយជាតិ ដែលកើតក្នុងត្រកូលមាតង្គៈ ។ បទថា **សីលវា** បានដល់ ដល់ព្រមដោយសីល មានសីលបរិសុទ្ធ ។ បទថា **សុសមាហិតោ** បានដល់ មានចិត្តតាំងមាំដោយល្អដោយឧបចារសមាធិនិងអប្បនាសមាធិ អធិប្បាយថា ជាបុគ្គលបានឈានសមាបត្តិ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតចណ្ឌាល មានរូបរាងគួរខ្ពើម នៅក្នុងស្រុកចណ្ឌាលក្រៅព្រះនគរ មានឈ្មោះល្បីថា មាតង្គបណ្ឌិត ។ ថ្ងៃមួយ កាលគេប្រកាសលេងនក្ខត្តឫក្សក្នុងព្រះនគរ អ្នកនគរដោយច្រើននាំ

គ្នាទៅលេងនក្ខត្តឫក្ស កូនក្រមុំរបស់ព្រាហ្មណមហាសាលម្នាក់ មានអាយុ ១៥-១៦ ឆ្នាំ មានរូបស្អាតគួរមើល គួរជ្រះថ្លា ដូចទេពកញ្ញា គិតថា អញនឹងលេងនក្ខត្តឫក្សតាមសមគួរដល់សម្បត្តិរបស់ខ្លួន ទើបផ្ទុករបស់ទំពា របស់បរិភោគជាច្រើនក្នុងរទេះ ឡើងរថដែលទឹមដោយសេះពណ៌ស មួយអន្ទើដោយបរិវារធំទៅកាន់ឧទ្យាន ។ ទារិកានេះមានឈ្មោះថា ទិដ្ឋមង្គលិកា បានឮថា នាងមិនប្រាថ្នានឹងឃើញរូបដែលមានទ្រង់ទ្រាយអាក្រក់ ជាអពមង្គល ដោយហេតុនោះ ទើបនាងមានឈ្មោះថា ទិដ្ឋមង្គលិកា ។

ក្នុងកាលនោះ ព្រះពោធិសត្វភ្ញាក់ឡើងអំពីព្រលឹម ស្លៀកដណ្តប់នូវសំពត់ចាស់ៗ កាន់ឈើប្រត់ឫស្សីធ្វើជារូបប្រវឹក កាន់ភាជនៈចូលទៅកាន់នគរ ឃើញពួកមនុស្ស ដើម្បីឲ្យមនុស្សទាំងនោះចេញទៅឲ្យឆ្ងាយ ទើបយកឈើប្រត់នោះធ្វើសញ្ញា ។ លំដាប់នោះ នាងទិដ្ឋមង្គលិកាដែលបុរសទាំងឡាយរបស់ខ្លួននាំទៅធ្វើសំឡេងអឺអរថា ចូរពួកអ្នកចេញទៅ ចូរពួកអ្នកចេញទៅ នាងឃើញមាតង្គបណ្ឌិតត្រង់កណ្តាលទ្វារព្រះនគរ ទើបសួរថា នុ៎ះនរណា កាលបុរសទាំងនោះឆ្លើយថា មាតង្គចណ្ឌាល ទើបប្រាប់ឲ្យយានត្រឡប់ដោយគិតថា ឃើញមនុស្សកាឡកិណីបែបនេះហើយ ធ្វើដំណើរតទៅ នឹងមានសួស្តីដូចម្តេចកើត ។ ពួកមនុស្សនាំគ្នាក្រោធថា ពួកយើងទៅកាន់ឧទ្យានសង្ឃឹមថា បានរបស់ទំពា របស់បរិភោគជាដើមយ៉ាងច្រើន មាតង្គៈ ធ្វើអន្តរាយដល់ពួកយើងហើយ ទើបពោលថា ចូរពួកអ្នកចាប់មនុស្សចណ្ឌាលហើយយកដុំដីគប់រហូតមាតង្គបណ្ឌិតសន្លប់ ហើយនាំគ្នាត្រឡប់ទៅ ។

មិនយូរប៉ុន្មាន មាតង្គបណ្ឌិតមាននូវស្មារតី ក្រោកឡើងសួរពួកមនុស្ស ថា អ្នកដ៏ចម្រើនទាំងឡាយ ធម្មតាទ្វារជារបស់ទូទៅដល់មនុស្សគ្រប់គ្នា ឬថា ធ្វើឲ្យដល់ពួកព្រាហ្មណ៍ប៉ុណ្ណោះ ពួកមនុស្សពោលថា ជាសាធារណៈដល់ មនុស្សគ្រប់គ្នា ។ មាតង្គបណ្ឌិតគិតថា ពួកមនុស្សធ្វើអញដែលមិនចៀស ចេញទៅកាន់ចំណែកម្ខាង ក្នុងទ្វារដែលជាសាធារណៈដល់ជនទាំងពួង យ៉ាងនេះ ឲ្យដល់នូវសេចក្តីលំបាកព្រោះនាងទិដ្ឋមង្គលិកា ទើបប្រាប់ដល់ ពួកមនុស្សត្រង់ផ្លូវ ហើយគិតថា ណ្ហើយចុះ អញនឹងទម្លាយមានះរបស់នាង ទិដ្ឋមង្គលិកានេះ ទើបទៅកាន់ទ្វារផ្ទះរបស់នាង ហើយក៏ដេក ដោយតាំង ចិត្តថា បើអញមិនបាននាងទិដ្ឋមង្គលិកា នឹងមិនក្រោកឡើងឡើយ ។ បិតា របស់នាងទិដ្ឋមង្គលិកាបានឮថា មាតង្គៈមកដេកត្រង់ទ្វារផ្ទះ ទើបពោលថា ចូរពួកអ្នកឲ្យទ្រព្យ ១ កាកណិកដល់មាតង្គៈ ហើយប្រាប់មាតង្គៈថា ចូរយក ប្រេងលាបសរីរៈហើយទៅចុះ ។ មាតង្គបណ្ឌិតពោលតែម្យ៉ាងថា បើខ្ញុំមិន បាននាងទិដ្ឋមង្គលិកា នឹងមិនក្រោកឡើយ ។ លំដាប់នោះ ទោះបីព្រាហ្មណ៍ ពោលថា ចូរពួកអ្នកឲ្យទ្រព្យ ២ កាកណិក ១ មាសក ១ បាត ១ កហាបណៈ ២ កហាបណៈ រហូតដល់ ១០០ កហាបណៈ ១ ពាន់ កហាបណៈ មាតង្គបណ្ឌិតក៏មិនទទួល ។ កាលជនទាំងឡាយកំពុងប្រឹក្សាគ្នា យ៉ាងនោះ ព្រះអាទិត្យក៏អស់ស្តង្គត ។ លំដាប់នោះ មាតារបស់នាងទិដ្ឋ-មង្គលិកា ចុះអំពីប្រាសាទ ឲ្យយករាំងននព័ទ្ធជាកំពែងទៅរកមាតង្គបណ្ឌិត ហើយពោលថា បាមាតង្គៈ ចូរបាអត់ទោសដល់នាងទិដ្ឋមង្គលិកាផងចុះ ចូរ

បាយកទ្រព្យ ២ ពាន់ រហូតដល់ ១ សែន មាតង្គបណ្ឌិតក៏មិនទទួល ដេក ក្នុងទីនោះឯង ។ កាលមាតង្គបណ្ឌិតដេកយ៉ាងនោះ កន្លងទៅ ៦ ថ្ងៃ លុះដល់ថ្ងៃទី ៧ ពួកមនុស្សដែលនៅផ្ទះជិតខាង និងមនុស្សដែលស្និទ្ធស្នាល នាំគ្នាក្រោកឡើងអ៊ូអរពោលថា ចូរពួកអ្នកឲ្យមាតង្គៈក្រោកឡើង ឬចូរឲ្យកូនស្រីទៅមាតង្គៈចុះ កុំឲ្យពួកយើងវិនាសជាមួយឡើយ ។ បានឮថា ក្នុងកាលនោះ មានទំនៀមរបស់ទឹកដីនោះថា មនុស្សចណ្ឌាលដេកស្លាប់ត្រង់ទ្វារផ្ទះរបស់បុគ្គលណា បុគ្គលដែលនៅម្ខាង ៧ ផ្ទះនៃផ្ទះនោះ នឹងក្លាយជាចណ្ឌាលទាំងអស់ ។

លំដាប់នោះ មាតាបិតារបស់នាងទិដ្ឋមង្គលិកា ក៏ឲ្យនាងទិដ្ឋមង្គលិកាស្លៀកដណ្តប់សំពត់ចាស់ៗ ឲ្យរបស់ប្រើប្រាស់ជារបស់មនុស្សចណ្ឌាល ហើយនាំកូនស្រីដែលកំពុងយំទៅរកមាតង្គៈ ពោលថា ចូរអ្នកក្រោកឡើងទទួលទារិកាក្នុងកាលឥឡូវនេះចុះ ហើយលើកឲ្យ ។ ចំណែកនាងទិដ្ឋមង្គលិកាឈរក្បែរៗ ពោលថា ក្រោកឡើងចុះ មាតង្គបណ្ឌិតពោលថា ខ្ញុំអស់កម្លាំងពន់ពេក ចូរនាងចាប់ដៃឲ្យខ្ញុំក្រោកឡើងចុះ ។ នាងបានធ្វើយ៉ាងនោះ ។ មាតង្គបណ្ឌិតពោលថា ខ្ញុំនៅខាងក្នុងព្រះនគរមិនបាន ចូរនាងមកចុះ យើងនឹងទៅស្រុកចណ្ឌាលខាងក្រៅព្រះនគរ បានទៅកាន់ផ្ទះរបស់ខ្លួន ដើម្បីគេចអំពីពួកជន ។ អាចារ្យអ្នករចនាជាតកពោលថា ឱប-កនាងទៅ ។

កាលទៅដល់ផ្ទះហើយ មាតង្គបណ្ឌិតមិនបានប្រព្រឹត្តកន្លង ព្រោះការបែងចែកជាតិ ឲ្យនាងនៅក្នុងផ្ទះបាន ២-៣ ថ្ងៃ ប្រមូលកម្លាំង គិតថា អញ

នឹងឲ្យកូនស្រីព្រាហ្មណមហាសាលនេះ នៅក្នុងផ្ទះមនុស្សចណ្ឌាលរបស់អញ ណ្ហើយចុះ ឥឡូវនេះ អញនឹងធ្វើនាងឲ្យជាស្រីប្រសើរដោយលាភ ប្រសើរដោយយស ។ មាតង្គបណ្ឌិតក៏ចូលព្រៃ បួសញ៉ាំងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យកើតខាងក្នុង ៧ ថ្ងៃនោះឯង ហើយហោះមកចុះត្រង់ទ្វារផ្ទះរបស់មនុស្សចណ្ឌាលដោយឫទ្ធិ ឈរត្រង់ទ្វារផ្ទះ ហៅនាងទិដ្ឋមង្គលិកាដែលកំពុងខ្សឹកខ្សួលថា បពិត្រអ្នក ព្រោះហេតុអ្វី ទើបអ្នកធ្វើខ្ញុំឲ្យឥតទីពឹងហើយទៅបួស មាតង្គបណ្ឌិតពោលថា នែប្អូនស្រី នាងកុំគិតថ្វីឡើយ ឥឡូវនេះខ្ញុំនឹងឲ្យយសធំជាងយសមុនរបស់នាង តែនាងគប្បីពោលក្នុងប្រជុំជនថា ប្ដីរបស់ខ្ញុំជាមហាព្រហ្ម មិនមែនមាតង្គៈឡើយ ប្ដីរបស់ខ្ញុំទៅព្រហ្មលោករាប់ពីនេះទៅ ៧ ថ្ងៃ ក្នុងថ្ងៃ ១៥ កើត ស្វាមីរបស់ខ្ញុំ នឹងហែកមណ្ឌលព្រះចន្ទ្រត្រឡប់មក ដូច្នេះហើយ ក៏ទៅកាន់ហិមវន្តប្បទេសវិញ ។

នាងទិដ្ឋមង្គលិកា បានពោលយ៉ាងនោះក្នុងទីនោះៗ កណ្ដាលមហាជនក្នុងក្រុងពារាណសី ក្នុងថ្ងៃពេញបូណ៌មី ព្រះពោធិសត្វក្នុងវេលាដែលឈរកណ្ដាលអាកាសនៃចន្ទមណ្ឌល និម្មិតអត្តភាពជាព្រហ្ម ជ្រែកចន្ទមណ្ឌលធ្វើក្រុងពារាណសីដែលមានទំហំ ១២ យោជន៍ និងដែនកាសីទាំងមូលឲ្យភ្លឺស្វាងដូចគ្នាទាំងអស់ ហើយចុះអំពីអាកាស ប្រទក្សិណក្រុងពារាណសី ៣ ជុំ មហាជនបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម បែរមុខទៅកាន់ស្រុកចណ្ឌាល ពួកព្រហ្មភត្ត គឺអ្នករាប់អានព្រហ្ម ប្រជុំគ្នាក្នុងស្រុកចណ្ឌាលនោះ តាក់តែងផ្ទះរបស់នាងទិដ្ឋមង្គលិកាដោយសំពត់ស គ្រឿងក្រអូប និងផ្កាជាដើម

ដូចទេវវិមាន ។ ក្នុងកាលនោះ នាងទិដ្ឋមង្គលិកាមានរដូវ ព្រះមហាសត្វទៅក្នុងទីនោះ យកម្រាមមេដៃអង្អែលនាងទិដ្ឋមង្គលិកាត្រង់ផ្ចិត ហើយពោលថា នែនាង នាងតាំងគភ៌ហើយ នឹងប្រសូតបុត្រ នាងក្តី បុត្រក្តី នឹងបានជាបុគ្គលប្រសើរដោយលាភ ប្រសើរដោយយស ទឹកលាងក្បាលរបស់នាង នឹងបានជាទឹកអភិសេករបស់ព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីប ទឹកងូតរបស់នាង នឹងបានជាទឹកអម្រឹត បុគ្គលណាស្រោចទឹកត្រង់សីសៈ បុគ្គលនោះ នឹងប្រាសចាករោគទាំងឡាយ និងផុតចាកកាឡកិណី ជនទាំងឡាយដាក់សីសៈលើខ្នងជើងរបស់នាង ហើយថ្វាយបង្គំ នឹងបានទ្រព្យ ១ ពាន់ ឈរថ្វាយបង្គំក្នុងទីដែលល្មមស្តាប់ឮ នឹងបានទ្រព្យ ១០០ ឈរថ្វាយបង្គំក្នុងទីដែលល្មមមើលឃើញ នឹងបានម្នាក់ ១ កហាបណៈ ចូរនាងកុំប្រមាទ ។ ព្រះមហាសត្វឲ្យឱវាទហើយចេញអំពីផ្ទះ កាលមហាជនសម្លឹងមើល បានចូលទៅកាន់ចន្ទមណ្ឌល ពួកព្រហ្មកត្តប្រជុំគ្នា អញ្ជើញនាងទិដ្ឋមង្គលិកាចូលព្រះនគរដោយសក្ការៈធំ ឲ្យនាងនៅក្នុងព្រះនគរនោះ ដោយមង្គលសិរីដ៏វិចិត្រជាំក្រៃលែង បានសាងលំនៅរបស់នាង ដូចគ្នានឹងទេវវិមាន ហើយបាននាំលាភសក្ការៈជាច្រើនទៅឲ្យនាងក្នុងលំនៅនោះ ។ លាភទាំងពួង មានការបានបុត្រជាដើម ដូចព្រះពោធិសត្វពោលគ្រប់ប្រការ ។ ព្រាហ្មណ៍ ១ ម៉ឺន ៦ ពាន់បរិភោគរួមជាមួយបុត្ររបស់នាងទិដ្ឋមង្គលិកាជានិច្ច ព្រាហ្មណ៍ប្រមាណ ១ ពាន់ចោមរោមកុមារនោះ កុមារឲ្យទានដល់ព្រាហ្មណ៍ច្រើនពាន់នាក់ ។

លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា បុត្រនេះជ្រះថ្លាខុស ណ្ហើយចុះ អញនឹងឲ្យបុត្រស្គាល់ទក្ខិណេយ្យបុគ្គល ទើបត្រាច់បិណ្ឌបាត ដល់ផ្ទះរបស់នាងទិដ្ឋមង្គលិកានោះ សន្ទនាជាមួយបុត្រនោះហើយត្រឡប់ទៅ លំដាប់នោះ កុមារពោលគាថាដូច្នេះថា

អ្នកមកអំពីទីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់ លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោល លើគំនរសំរាមឰដ៏ក ខ្លួនអ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ ដូច្នេះ ។

ពួកទេវតាអត់សង្កត់នឹងពាក្យអនាចារដែលកុមារពោលមិនបាន ក៏មួលកកុមារនោះ និងព្រាហ្មណ៍ ១ មុឺន ៦ ពាន់នាក់នោះ ។ នាងទិដ្ឋមង្គលិកាឃើញដូច្នោះ ទើបចូលទៅរកព្រះមហាសត្វប្រាប់សេចក្តីនោះឲ្យជ្រាប ។ ព្រះពោធិសត្វពោលថា ទេវតាអត់ទ្រាំនឹងពាក្យអនាចាររបស់កុមារនោះមិនបាន ទើបធ្វើឲ្យខុសប្រក្រតី តែនាងចូរយកដុំបាយដែលយើងឆាន់សល់នេះ ទៅដាក់ក្នុងមាត់របស់ព្រាហ្មណ៍ទាំងនោះ ការខុសប្រក្រតីនោះ នឹងបាត់ទៅ ។ នាងបានធ្វើយ៉ាងនោះ ការខុសប្រក្រតីក៏វិនាសទៅ ។ នាងទិដ្ឋមង្គលិកាក៏ពោលនឹងបុត្រថា នែកូន ក្នុងលោកនេះ ឈ្មោះថា ទក្ខិណេយ្យបុគ្គលរមែងដូចគ្នានឹងមាតង្គបណ្ឌិត ព្រាហ្មណ៍ទាំងនេះ មិនមែនជាទក្ខិណេយ្យ-បុគ្គលទេ ជាអ្នករឹងត្អឹងដោយមានះ ដោយហេតុត្រឹមតែជាតិ ឬដោយហេតុត្រឹមតែស្វាធ្យាយមន្ត ចូរកូនធ្វើសេចក្តីជ្រះថ្លាឲ្យកើតដល់បុគ្គលដែលប្រកប

ដោយគុណវិសេស មានសីលជាដើម ដែលបានទូវឈានសមាបត្តិ និងព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងទីនោះចុះ ។

ក្នុងកាលនោះ ព្រាហ្មណ៍ម្នាក់ឈ្មោះជាតិមន្ត ក្នុងនគរវេត្តវតី បួសហើយ ក៏មានមានះខ្លាំងព្រោះអាស្រ័យជាតិ ។ ព្រះមហាសត្វគិតថា អញនឹងទម្លាយមានះរបស់ព្រាហ្មណ៍នោះឲ្យបាន ទើបទៅកាន់ទីនោះ អាស្រ័យនៅខាងលើខ្សែទឹក ក្បែរអាស្រមព្រាហ្មណ៍នោះ ដូចព្រះមានព្រះភាគត្រាស់ថា

ជនពីរនាក់ គឺតថាគត និងព្រាហ្មណ៍ នៅជិតឆ្នេរទន្លេគង្គា តថាគតនៅខាងលើខ្សែទឹក ឯព្រាហ្មណ៍នៅខាងក្រោមខ្សែទឹក ដូច្នេះ ។

ថ្ងៃមួយ ព្រះមហាសត្វទំពាឈើស្ទន់ ហើយចុះកាន់ស្ទឹង អធិដ្ឋានថា ចូរឈើស្ទន់នេះ ទៅជាប់ត្រង់ជដារបស់ជាតិមន្តចុះ ។ ឈើស្ទន់នោះ ជាប់ត្រង់ជដារបស់ជាតិមន្តដែលកំពុងងូតទឹក ។ ជាតិមន្តឃើញឈើស្ទន់នោះ ទើបជេរថា មនុស្សថោកទាប ចូរឯងវិនាស ហើយទៅខាងលើខ្សែទឹក ដោយគិតថា មនុស្សកាឡកិណីនេះមកអំពីណា អញនឹងទៅរកមនុស្សកាឡកិណីនោះ កាលឃើញព្រះមហាសត្វ ទើបសួរថា អ្នកមានជាតិជាអ្វី ព្រះមហាសត្វឆ្លើយថា ខ្ញុំមានជាតិជាចណ្ឌាល ជាតិមន្តសួរថា លោកទំពាឈើស្ទន់ខ្ទាក់ចោលក្នុងស្ទឹងឬ មាតង្គៈឆ្លើយថា ពិតហើយ ខ្ញុំខ្ទរនោះឯងជាតិមន្តពោលថា មនុស្សថោកទាប មនុស្សចណ្ឌាល មនុស្សកាឡកិណី ចូរអ្នកវិនាស អ្នកកុំនៅទីនេះឡើយ ចូរនៅខាងក្រោមខ្សែទឹកចុះ កាលព្រះពោធិសត្វនៅខាងក្រោមខ្សែទឹក ខ្ទរមាត់ ឈើស្ទន់ក៏ហូរប្រាសខ្សែទឹក មក

ជាប់ត្រង់ផ្នួងសក់ទៀត ទើបជាតិមន្តតាបសគិតថា មនុស្សថោកទាប ចូរវិនាស បើអ្នកនៅក្នុងទីនេះ ក្នុងថ្ងៃទី ៧ ក្បាលរបស់អ្នកនឹងបែកជា ៧ ភាគ ដូចព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ កាលដើរទៅតាមច្នេរទន្លេ បានឃើញអាស្រម តថាគតនៅខាងលើខ្សែទឹក ក៏ប្រទេចផ្តាសាតថាគតក្នុងទីនោះ ហើយដាក់សម្បថថា ( ចូរឲ្យក្បាលអ្នកបែកជា ៧ ភាគ ក្នុងថ្ងៃទី ៧ ) ។ បើតថាគតខឹងនឹងព្រាហ្មណ៍ មានតែតថាគតមិនរក្សាសីល តថាគតនឹងក្រឡេកមើលព្រាហ្មណ៍នោះ ហើយធ្វើឲ្យផេះទៅជាផេះក៏បាន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិចរន្តោ អនុក្កូលម្ហិ** សេចក្តីថា កាលឈើស្ងួនដែលប្រើហើយ ជាប់ត្រង់ជដារបស់ខ្លួន ទើបព្រាហ្មណ៍ត្រាច់ទៅតាមច្នេរស្ទឹង ដើម្បីស្វែងរកទីមករបស់ឈើស្ងួននោះ ។ បទថា **ឧទ្ទំ មេ អស្សមទ្ទស** សេចក្តីថា បានឃើញបណ្ណសាលា ដែលជាអាស្រមរបស់តថាគត នៅលើក្រសែទឹក អំពីលំនៅរបស់ខ្លួន ។ បទថា **តត្ថ មំ បរិភាសេត្វា** សេចក្តីថា ព្រាហ្មណ៍នោះ មកកាន់អាស្រមរបស់តថាគត ស្តាប់រឿងជាតិហើយ ថយទៅឈរក្នុងទីល្មមបានឮ ពោលពាក្យជាដើមថា មនុស្សថោកទាប មនុស្សចណ្ឌាល មនុស្សកាឡកិណី ចូរអ្នកវិនាស អ្នកកុំនៅក្នុងទីនេះឡើយ ហើយសម្គុតឲ្យខ្លាច ។ បទថា **អភិសបិ មុទ្ធផាលនំ** សេចក្តីថា ព្រាហ្មណ៍នោះពោលថា បើអ្នកប្រាថ្នានឹងមានជីវិត ចូរប្រញាប់ចៀសចេញ

អំពីទីនេះ ហើយផ្តាសាតថាគតថា បើអ្នកមិនចៀសចេញ រាប់ពីនេះទៅ ៧ ថ្ងៃ ក្បាលរបស់អ្នកនឹងបែកជា ៧ ភាគ ។

សួរថា ក្បាលនឹងបែកតាមពាក្យផ្តាសារបស់ព្រាហ្មណ៍ដែរឬទេ ឆ្លើយថា មិនបែក ព្រាហ្មណ៍នោះកុហក ព្រាហ្មណ៍ពោលយ៉ាងនោះដើម្បីឲ្យខ្លាច ដោយសម្គាល់ថា ព្រះមហាសត្វខ្លាចចំពោះមរណភ័យ ហើយក៏ចៀសចេញទៅឆ្ងាយ ដោយប្រការដូច្នេះ ។

បទថា **យទិហំ តស្ស បកុប្បេយ្យំ** សេចក្តីថា បើតថាគតគប្បីក្រោធចំពោះជដិលកោងដែលរឹងត្អឹងដោយមានះនោះ ។ បទថា **យទិ សីលំ ន គោបយេ** សេចក្តីថា បើតថាគតមិនរក្សាសីល អធិប្បាយថា បើតថាគតមិនគិតថា ឈ្មោះថា សីលនេះ គប្បីរក្សាដោយប្រពៃ មិនពិចារណាដល់ជីវិត ។ បទថា **ឱលោកេត្វានហំ តស្ស ករេយ្យំ ឆារិកំ វិយ** សេចក្តីថា បើក្នុងកាលនោះ តថាគតមិនពេញចិត្តចំពោះព្រាហ្មណ៍នោះ បើទេវតាដែលជ្រះថ្លាដឹងគំនិតរបស់តថាគត គប្បីកម្ចាត់ព្រាហ្មណ៍នោះ ឲ្យក្លាយជាផេះមួយរំពេច ។ ព្រះសាស្តាទ្រង់សម្តែងឲ្យឃើញថា ក្នុងកាលនោះ កាលព្រះអង្គមានការមិនពេញចិត្ត ពួកទេវតានឹងធ្វើសេចក្តីវិនាសឲ្យដល់ព្រាហ្មណ៍នោះ ក៏ដូចទ្រង់ធ្វើដោយខ្លួនឯង ទើបត្រាស់ថា **ករេយ្យំ ឆារិកំ វិយ** ដូច្នេះ ។

តែអ្នកពោលទទឹងទាស់ពោលថា ព្រះពោធិសត្វនោះឯង បើប្រាថ្នាធ្វើ ក៏អាចធ្វើជដិលនោះឲ្យក្លាយជាផេះដោយឫទ្ធិបាន កាលបើយ៉ាងនោះ សេចក្តីនៃបាលីនេះ ក៏ជាការត្រឹមត្រូវហើយ ។ បុគ្គលនោះ គប្បីឆ្លើយយ៉ាងនេះថា

អ្នកនិយាយដល់ការបៀតបៀនអ្នកដទៃដោយឫទ្ធិ ឈ្មោះថា ឫទ្ធិនេះ មាន ១០ យ៉ាង ឫទ្ធិ គឺការអធិដ្ឋាន ១ ឫទ្ធិ គឺការធ្វើឲ្យវិសេស ១ ឫទ្ធិ គឺអ្វីដែលសម្រេចដោយចិត្ត ១ ឫទ្ធិ គឺការផ្សាយចេញដោយសារញាណ ១ ឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ១ ឫទ្ធិ គឺគុណជាតប្រសើរ ១ ឫទ្ធិកើតអំពីផលកម្ម ១ ឫទ្ធិរបស់បុគ្គលមានបុណ្យ ១ ឫទ្ធិសម្រេចដោយសារវិជ្ជា ១ ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ ១ ។ ក្នុងឫទ្ធិ ១០ យ៉ាងនោះ លោកពោលដល់ឫទ្ធិដូចម្តេច ឆ្លើយថា លោកពោលដល់ឫទ្ធិដែលសម្រេចដោយភាវនា ។ សួរថា ការបៀតបៀនអ្នកដទៃ រមែងមានដោយឫទ្ធិដែលសម្រេចដោយភាវនាឬ ឆ្លើយថា មាន អាចារ្យពួកខ្លះពោលថា មានត្រឹមតែម្តង ដូចជាបុគ្គលបំណងប្រហារអ្នកដទៃ ត្រូវវែងក្អមដែលពេញដោយទឹកទៅ អ្នកដទៃក៏ត្រូវប្រហារ ក្អមក៏បែកយ៉ាងណា ការបៀតបៀនអ្នកដទៃដោយឫទ្ធិ ដែលសម្រេចដោយភាវនា រមែងមានត្រឹមតែម្តងយ៉ាងនោះដូចគ្នា បន្ទាប់អំពីនោះ ឫទ្ធិនោះក៏វិនាស ។

លំដាប់នោះ ពួកអ្នកពោលទទឹងទាស់នោះពោលថា ការបៀតបៀនអ្នកដទៃ ដោយឫទ្ធិសម្រេចដោយភាវនា មិនមែនតែម្តង មិនមែន ២ ដង គួរសួរថា ឫទ្ធិសម្រេចដោយភាវនាដូចម្តេច កាលដឹងថា ឫទ្ធិសម្រេចដោយភាវនា ជាកុសល អកុសល អព្យាកតៈ សម្បយុត្តដោយសុខវេទនា ទុក្ខ-វេទនា អទុក្ខមសុខវេទនា មានវិតក្ក វិចារ មិនមានវិតក្ក តែមានវិចារ មិនមានទាំងវិតក្ក វិចារ ជាកាមាវចរ រូបាវចរ អរូបាវចរ នឹងពោលថា ឫទ្ធិ

សម្រេចដោយភាវនា ជាកុសល អព្យាកតៈ មិនមានទុក្ខវេទនា មិនមានសុខវេទនា មិនមានវិតក្ក មិនមានវិចារ ជារូបាវចរ ។ គួរពោលនឹងអ្នកពោលទទឹងទាស់នោះថា ចេតនាសម្លាប់សត្វ រមែងបានចំណែកណា ក្នុងបណ្តាកុសលជាដើម ។ កាលដឹងនឹងពោលថា ចេតនាសម្លាប់សត្វ ជាអកុសលពិត ជាទុក្ខវេទនាពិត មានវិតក្ក វិចារពិត ជាកាមាវចរពិត ។ កាលបើយ៉ាងនោះ បញ្ហារបស់អ្នក គួរសម្តែងឲ្យដឹងដល់ការខុសក្លាំងក្លាត់ក្នុងបាលីថា មិនសមដោយកុសលត្តិកៈ វេទនាតិកៈ វិតក្កតិកៈ ភូមន្តរៈ ( ភូមិដទៃ ) ។ បើបុគ្គលនោះ គប្បីលើកកុលុម្បសូត្រ ដែលមិនបានលើកឡើងកាន់សង្គីតិថា ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត សមណៈ ឬព្រាហ្មណ៍ក្នុងលោកនេះ មានឫទ្ធិ ដល់នូវការជំនាញផ្លូវចិត្ត មានចិត្តលាមក ចូលទៅសម្លឹងដល់សត្វដែលកើតក្នុងគភ៌របស់ស្រីដទៃថា ឱ សត្វនេះ មិនគួរប្រសូតចាកផ្ទៃដោយសួស្តីឡើយ ទោះបីយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ការចូលទៅបៀតបៀនរបស់កុលុម្បសូត្រនៅមាន ដូច្នេះ ។ គួរឲ្យបុគ្គលនោះដឹងថា លោកមិនទាន់ដឹងនូវអត្ថរបស់សូត្រនោះ ។ ព្រោះក្នុងបទនេះថា បុគ្គលមានឫទ្ធិ ដល់នូវភាពជំនាញដោយចិត្ត មិនបានបំណងដល់ឫទ្ធិ ដែលសម្រេចដោយភាវនា ទ្រង់បំណងយកឫទ្ធិដែលជាអថព្វន គឺវិជ្ជាអថ័ន ដ្បិតថា ឫទ្ធិកាលនឹងបាន រមែងបានក្នុងអថព្វននេះ ព្រោះហេតុនោះ ការចូលទៅបៀតបៀនអ្នកដទៃដោយឫទ្ធិ ទើបមិនកើតឡើងដោយឫទ្ធិដែលសម្រេចដោយភាវនា បើមិនទាន់យល់ព្រម ក៏គប្បីខ្វល់ខ្វាយធ្វើល្អ ។ ព្រោះហេតុ

នោះ គប្បីជ្រាបអត្ថនៃគាថាក្នុងបទនេះ ដោយន័យដូចបានពោលហើយនោះឯង ។

ម្យ៉ាងទៀត ព្រះមហាសត្វត្រូវព្រាហ្មណ៍នោះផ្ដាសា ទើបគិតថា បើអញក្រោធព្រាហ្មណ៍នេះ សីលរបស់អញ ក៏ឈ្មោះថា មិនជាការរក្សា អញនឹងទម្លាយមានះរបស់ព្រាហ្មណ៍ដោយឧបាយ ក៏នឹងជាការរក្សាព្រាហ្មណ៍នោះផង ក្នុងថ្ងៃទី ៧ ទើបឃាត់ព្រះអាទិត្យមិនឲ្យរះ ។ ពួកមនុស្សនាំគ្នាវឹកវរព្រោះព្រះអាទិត្យមិនរះ ទើបទៅរកតាបសឈ្មោះជាតិមន្ត សួរថា បពិត្រលោកម្ចាស់ៗ មិនឲ្យព្រះអាទិត្យរះឡើងឬ ។ តាបសនោះពោលថា ទុំះមិនមែនខ្ញុំធ្វើទេ តែនៅត្រង់ឆ្នេរស្ទឹង មានតាបសចណ្ឌាលម្នាក់ ប្រហែលជាតាបសនោះធ្វើទេដឹង ។ ពួកមនុស្សក៏នាំគ្នាទៅរកព្រះមហាសត្វ សួរថា លោកម្ចាស់មិនឲ្យព្រះអាទិត្យរះឬ ព្រះពោធិសត្វឆ្លើយថា អាវុសោ ត្រូវហើយ អ្នកស្រុកសួរថា ព្រោះហេតុអ្វី ព្រះពោធិសត្វឆ្លើយថា តាបសដែលជាកុលុបកៈរបស់ពួកអ្នក បានផ្ដាសាអាត្មាដែលមិនមានកំហុស បើតាបសនោះមកក្រាបទៀបជើងរបស់អាត្មា ដើម្បីសូមខមាទោស ទើបអាត្មាលែងព្រះអាទិត្យ ។ ពួកមនុស្សនាំគ្នាទៅអូសតាបសនោះ នាំមកឲ្យក្រាបទៀបបាទារបស់ព្រះមហាសត្វឲ្យសូមខមាទោស ហើយពោលថា សូមលោកម្ចាស់លែងព្រះអាទិត្យចុះ ។ ព្រះមហាសត្វពោលថា អាត្មាមិនអាចលែងបាន បើអាត្មាលែង ក្បាលរបស់តាបសនេះនឹងបែកជា ៧ ភាគ ។ អ្នកស្រុកសួរថា កាលបើដូច្នោះ លោកម្ចាស់នឹងធ្វើដូចម្ដេច ព្រះមហាសត្វពោលថា ចូរ

ពួកអ្នកយកដុំដីស្អិតមក កាលមនុស្សនាំមកហើយ ទើបពោលថា ចូរពួកអ្នកដាក់ដីឥដ្ឋនេះ លើក្បាលរបស់តាបស ហើយឲ្យតាបសចុះទៅក្នុងទឹក ។ ចូរតាបសមុជចុះក្នុងទឹក កាលព្រះអាទិត្យប្រាកដ ដូច្នេះហើយ ទើបលែងព្រះអាទិត្យ ដុំដីស្អិត គ្រាន់តែរស្មីរបស់ព្រះអាទិត្យប៉ះប៉ុណ្ណោះ ក៏បែកជា ៧ ចម្រៀក ។ តាបសមុជចុះទៅក្នុងទឹក ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ ព្រាហ្មណ៍នោះ មានចិត្តប្រទូស្តខឹង ដាក់សម្បថ
ដល់តថាគតដោយឧបាយណា សម្បថនោះ បែរជាធ្លាក់លើ
ក្បាលព្រាហ្មណ៍នោះវិញ តថាគតដោះព្រាហ្មណ៍នោះ ឲ្យរួចចាក
សម្បថដោយឧបាយនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យំ សោ តទា មំ អភិសបិ** សេចក្តីថា ក្នុងកាលនោះ ជដិលជាតិមន្ទនោះផ្តាសាតថាគត បំណងឲ្យក្បាលរបស់តថាគតបែក ។ បទថា **តស្សេវ មត្ថកេ និបតិ** សេចក្តីថា ពាក្យផ្តាសានោះ ព្រាហ្មណ៍ប្រាថ្នាឲ្យធ្លាក់លើក្បាលតថាគត តែបែរជាត្រឡប់ធ្លាក់លើក្បាលខ្លួនឯង គឺបានតាំងនៅដោយភាពជារបស់ធ្លាក់ចុះមក សេចក្តីនេះដូចបុគ្គលប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត ដូចព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ប្រទូស្តអ្នកមិនប្រទូស្តតប ។បេ។ ដូចធូលីល្អិត
ដែលបុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់ ដូច្នេះ ។

បទថា **យោគេន តំ បមោចយឹ** សេចក្តីថា តថាគតជួយដោះព្រាហ្មណ៍នោះ ឲ្យផុតចាកក្បាលបែក តាមដែលជដិលកោងផ្តាសាដោយ

ឧបាយ ឬជួយដោះជដិលនោះឲ្យផុតចាកការបែកក្បាល អធិប្បាយថា បានធ្វើដោយឧបាយដែលមិនឲ្យក្បាលបែក ។

ពិតហើយ ពាក្យគ្រោតគ្រាតដែលជាពាក្យផ្តាសា ដែលជាអរិយូបវាទណា ដែលតាបសនោះបានផ្តាសាព្រះមហាសត្វ ដែលតាំងនៅក្នុងមហាករុណា ដែលមានសន្តានបានអប់រំមកហើយយ៉ាងល្អ ដោយសីលសម្បទា និងទិដ្ឋិ ដែលពេញប្រៀបដោយសមាបត្តិវិហារធម៌ច្រើនប្រការ សម្រេចដោយការអប់រំបារមី បើតាបសនោះ មិនឲ្យព្រះមហាសត្វអត់ទោស ពាក្យផ្តាសានោះនឹងជាផល ឲ្យបានសោយកម្មក្នុងបច្ចុប្បន្ន ព្រោះព្រះមហាសត្វជាស្រែបុណ្យដ៏វិសេស និងព្រោះតាបសនោះ ជាអ្នកមានអជ្ឈាស្រ័យគ្រោតគ្រាត ក្នុងថ្ងៃទី ៧ កម្មនោះនឹងធ្ងន់ គឺឲ្យផលដ៏ខ្លាំងក្លា តែកាលព្រះមហាសត្វអត់ទោសឲ្យ ការហាមដោយបយោគសម្បត្តិ ក៏ដល់នូវការមិនមានវិបាកជាធម្មតា ព្រោះជាអហោសិកម្ម ។ នេះជាធម្មតារបស់បាបដែលកើតអំពីអរិយូបវាទ ដែលនឹងឲ្យផលក្នុងបច្ចុប្បន្ន ។ ការដែលព្រះពោធិសត្វឃាត់ព្រះអាទិត្យក្នុងថ្ងៃទី ៧ នោះ ជាឧបាយដែលលោកបំណងក្នុងបទថា **យោគោ** នេះ ។ ដោយហេតុនោះ ទើបពួកមនុស្សរឹករវរ នាំគ្នាអូសតាបសទៅរកព្រះពោធិសត្វឲ្យអត់ទោស ។ គប្បីជ្រាបថា តាបសនោះក៏ដឹងគុណព្រះមហាសត្វ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះមហាសត្វនោះ ។ ការដែលយកដុំដីស្អិតដាក់លើក្បាលរបស់តាបសនោះ និងការដែលព្រះមហាសត្វ ធ្វើដុំដីស្អិតនោះឲ្យបែកជា ៧ ចម្រៀក ក៏ដើម្បីយកចិត្តពួកមនុស្ស ព្រោះបព្វជិតទាំង

នេះ ក៏រមែងប្រព្រឹត្តទៅក្នុងអំណាចរបស់ចិត្តដោយប្រការដទៃ តែមិនធ្វើចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ព្រោះហេតុនោះ ទើបពួកមនុស្សក្រាន់យក សូម្បីព្រះមហាសត្វធ្វើឲ្យដូចគ្នានឹងតាបសនោះ ។ ការធ្វើរបស់តាបសនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មនុស្សទាំងនោះ អស់កាលយូរ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងដល់ប្រយោជន៍ ដែលព្រះមហាសត្វ មិនធ្វើចិត្តឲ្យប្រទូស្តក្នុងតាបសនោះ ហើយរក្សាសីលឲ្យបរិសុទ្ធប៉ុណ្ណោះ ទើបត្រាស់ព្រះគាថាចុងក្រោយថា **អនុរក្ខំ មម សីលំ** ដូច្នេះជាដើម ។ បទនោះ មានសេចក្តីដូចបានពោលហើយខាងដើមនោះឯង ។

មណ្ឌព្យៈក្នុងកាលនោះ បានមកជាព្រះបាទឧទេន ក្នុងកាលឥឡូវនេះ មាតង្គបណ្ឌិត ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងមាតង្គចរិយានេះ ក៏គប្បីពោលចំពោះដល់បារមីដ៏សេសផងដែរ ។ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពរបស់ព្រះមហាសត្វយ៉ាងនេះ គឺការសង្កត់មានះរបស់នាងទិដ្ឋមង្គលិកាបានតាមបំណង របស់មាតង្គបណ្ឌិតដែល

មានជាតិ និងត្រកូលថោកទាប ការបួសហើយមានចិត្តកើតឡើងថា អញនឹង ជាទីពឹងរបស់នាងទិដ្ឋមង្គលិកា ទៅព្រៃ បួសញ៉ាំងឈាន និងអភិញ្ញាឲ្យកើត តាមបំណងខាងក្នុង ៧ ថ្ងៃនោះឯង ការត្រឡប់មកអំពីព្រៃនោះ ញ៉ាំង ឧបាយឲ្យសម្រេច ដោយការឲ្យនាងទិដ្ឋមង្គលិកាប្រសើរដោយលាភ និង ប្រសើរដោយយស ការសង្កត់នូវមានះរបស់មណ្ឌព្យកុមារ ការសង្កត់នូវ មានះរបស់ជាតិមន្តតាបស ការជួយជីវិតតាបសដែលមិនស្គាល់ ការមិន ក្រោធចំពោះតាបស ដែលមានកំហុសធំក្រៃពេក ហើយតាមរក្សាសីល របស់ខ្លួន ការធ្វើបាដិហារ្យគួរអស្ចារ្យមិនធ្លាប់មាន ។

## អដ្ឋកថាមាតង្គចរិយា ចប់

# សុត្តន្តបិដក

## ធម្មទេវបុត្តចរិយាទី ៨

[ ១៨ ] មានចរិយាដទៃទៀត កាលតថាគតកើតជាទេវបុត្រ មានអានុភាពធំ ឈ្មោះធម្មៈ មានសក្តិធំ មានឫទ្ធិច្រើន ជាអ្នកអនុគ្រោះដល់សត្វលោកទាំងពួង ។ កាលនោះ តថាគតញុំាងមហាជនឲ្យតម្កល់នៅក្នុងកុសលកម្មបថ ១០ ត្រាច់ទៅក្នុងស្រុក និងនិគមជាមួយនឹងមិត្ត ជាមួយនឹងជនជាបរិវារ ។ មានទេវបុត្រមួយអង្គ មានធម៌លាមក កំណាញ់ ស្អិតស្អាញ សម្តែងនូវធម៌លាមក ១០ ប្រការ ទេវបុត្រនោះត្រាច់ទៅលើផែនដីដ៏ធំ ក្នុងជម្ពូទ្វីបនេះ ជាមួយនឹងមិត្ត ជាមួយនឹងជនជាបរិវារ ។ យើងជាទេវបុត្រទាំងពីរនាក់ គឺទេវបុត្រអ្នកពោលនូវធម៌ និងទេវបុត្រអ្នកពោលនូវអធម៌ ទៅជាសត្រូវនឹងគ្នា យើងទាំងពីរនាក់ ត្រូវបររថប៉ះនឹម ដោយនឹមក្នុងផ្លូវជួបគ្នា ។ ជម្លោះជាហេតុញុំាងភ័យឲ្យកើត ប្រព្រឹត្តទៅដល់កល្យាណទេវបុត្រ និងបាបទេវបុត្រ មហាសង្គ្រាមក៏តាំងឡើង ដើម្បីប្រជែងផ្លូវគ្នា ។ បើតថាគតវិងនឹងអធម្មទេវបុត្រ មានតែ

តថាគតទម្លាយតបោគុណ គឺសីលដ៏ប្រសើរ តថាគតគប្បីធ្វើនូវ អធម្មទេវបុត្រនោះ ព្រមទាំងជនជាបរិស័ទ ឲ្យទៅជាធូលីក៏បាន ។ ប៉ុន្តែតថាគតរម្ងត់ចិត្ត ដើម្បីរក្សាសីល តថាគត ព្រមទាំងជនជាបរិស័ទ ក៏បរចៀសបើកផ្លូវឲ្យបាបទេវបុត្រ ។ កាលតថាគត ព្រមទាំងជនជាបរិស័ទ រម្ងត់ចិត្ត បររថចៀសអំពីផ្លូវហើយ មហាប្រឹថពី ក៏ស្រូបបាបទេវបុត្រ ក្នុងខណៈនោះ ។

ធម្មទេវបុត្តចរិយាទី ៨ ចប់

# អដ្ឋកថា

## ធម្មទេវបុត្តចរិយា

[ ១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មទេវបុត្តចរិយាទី ៨ ដូចតទៅនេះ បទថា **មហាបក្ខោ** បានដល់ មានបរិវារច្រើន ។ បទថា **មហិទ្ធិកោ** បានដល់ ប្រកបដោយទេវឫទ្ធិច្រើន ។ បទថា **ធម្មោ នាម មហាយក្ខោ** បានដល់ ទេវបុត្រដែលមានអានុភាពច្រើន ឈ្មោះធម្មៈ ។ បទថា **សព្វលោកានុកម្បកោ** សេចក្តីថា ជាអ្នកមានសេចក្តីអនុគ្រោះលោកទាំងពួង ដោយមហាករុណា ដោយមិនធ្វើការបែងចែក ។

ពិតហើយ ក្នុងកាលនោះ ព្រះមហាសត្វកើតជាទេវបុត្រ ឈ្មោះធម្មទេវបុត្ត ក្នុងកាមាវចរទេវលោក ។ ធម្មទេវបុត្ត តាក់តែងដោយគ្រឿងប្រដាប់ជាទិព្វ ឡើងទិព្វរថ ចោមរោមដោយពួកទេពអប្សរ កាលមនុស្សទាំងឡាយ បរិភោគអាហារក្នុងពេលល្ងាចហើយ អង្គុយសន្ទនាគ្នាជាសុខត្រង់ទ្វារផ្ទះរៀងៗខ្លួន ក្នុងថ្ងៃឧបោសថ ១៥ កើត ប្រតិស្ឋានទៅលើអាកាសក្នុងស្រុក និគម និងរាជធានី ដឹកនាំមនុស្សទាំងឡាយ ឲ្យតាំងនៅក្នុងកុសលកម្មបថ ១០ ថា អ្នកទាំងឡាយ ចូរវៀរចាកអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម ហើយបំពេញសុចរិតធម៌ ៣ យ៉ាង បម្រើមាតាបិតា សមណៈ ព្រាហ្មណ៍ ឱនលំទោនចំពោះត្រកូលរាមច្បង អ្នកទាំងឡាយនឹងបានទៅកាន់ស្ថានសួគ៌ដោយយសធំក្រៃលែង ដូច្នេះ ធ្វើប្រទក្សិណជម្ពូទ្វីប ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ តថាគតញុំាងមហាជន ឲ្យតម្កល់នៅក្នុងកុសលកម្មបថ ១០ ត្រាច់ទៅក្នុងស្រុក និងនិគមជាមួយនឹងមិត្ត ជាមួយនឹងជនជាបរិវារ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សមិត្តោ** បានដល់ មានសម្លាញ់ដែលតាំងនៅក្នុងធម៌ ជាអ្នកពោលធម៌ ។ សម័យនោះ មានទេវបុត្រមួយអង្គ ឈ្មោះអធម្មទេវបុត្ត កើតក្នុងលោកជាន់កាមាវចរ អធម្មទេវបុត្តនោះ ដឹកនាំសត្វទាំងឡាយឲ្យតាំងនៅក្នុងអកុសលកម្មបថ ១០ ដោយន័យជាដើមថា អ្នកទាំងឡាយចូរសម្លាប់សត្វ ចូរលួចទ្រព្យចុះ ចោមរោមដោយបរិស័ទធំ ធ្វើជម្ពូទីបឲ្យទៅខាងឆ្វេង ដូចព្រះមានព្រះភាគត្រាស់ថា

មានទេវបុត្រមួយអង្គ មានធម៌លាមក កំណាញ់ស្វិតស្វាញ
សម្តែងនូវធម៌លាមក ១០ ប្រការ ទេវបុត្រនោះត្រាច់ទៅលើ
ផែនដីដ៏ធំ ក្នុងជម្ពូទីបនេះ ជាមួយនឹងមិត្ត ជាមួយនឹងជន ជា
បរិវារ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធាធោ** បានដល់ ប្រកបដោយធម៌អាក្រក់ ។ បទថា **កទរិយោ** បានដល់ កំណាញ់ស្វិតស្វាញ ។ បទថា **យក្ខោ** បានដល់ ទេវបុត្រ ។ បទថា **ទីបេន្តោ ទស ធាបកេ** សេចក្តីថា ត្រាច់ប្រកាសដឹកនាំថា ធម៌អាក្រក់ ១០ ប្រការ មានបាណាតិបាតជាដើម គួរធ្វើដោយន័យជាដើមថា សក្ការៈ ឈ្មោះថា ជាអាហារក្នុងសព្វលោក កើតមកដើម្បីជារបស់ឧបភោគបរិភោគ ព្រោះហេតុនោះ គួរសម្លាប់សត្វ ធ្វើយ៉ាងណា

មួយឲ្យខ្ទន់ខ្អែត ធ្វើឥន្ទ្រិយឲ្យសុខស្រួល ។ បទថា **សោបេត្ត** សេចក្តីថា អធម្មទេវបុត្តនោះ ត្រាច់ទៅ ក្នុងជម្ពូទ្វីបនេះ ។ បទថា **មហិយា** បានដល់ ជិតផែនដី អធិប្បាយថា ក្នុងឧបចារៈ ដែលពួកមនុស្សឃើញ និងបានឮ ។

ក្នុងបទនោះ មានសេចក្តីដូចតទៅ សត្វពួកណាធ្វើកម្មល្អ ជាអ្នកជូន់ ក្នុងធម៌ សត្វទាំងនោះ ឃើញធម្មទេវបុត្តមកយ៉ាងនោះ ក្រោកចាកទីអង្គុយ បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម នាំគ្នាសរសើរ ឈរផ្គងអញ្ជលី បាន ស្តាប់ពាក្យរបស់ធម្មទេវបុត្តហើយ ជាអ្នកមិនប្រមាទ ធ្វើបុណ្យដោយគោរព ។ ចំណែកសត្វទាំងឡាយណា មានការប្រព្រឹត្តអាក្រក់ មានកម្មគ្រោតគ្រាត សត្វទាំងនោះ ស្តាប់ពាក្យរបស់អធម្មទេវបុត្តហើយ ក៏នាំគ្នាពេញចិត្តយ៉ាង ក្រៃលែង ប្រព្រឹត្តកម្មលាមកក្រៃលែងថែមទៀត ។ ក្នុងកាលនោះ ទេវបុត្ត ទាំងពីរក៏មានវាទៈផ្ទុយគ្នា និងមានការធ្វើផ្ទុយគ្នា ត្រាច់ទៅក្នុងលោក ដោយ ប្រការដូច្នេះ ដូចព្រះមានព្រះភាគត្រាស់ថា

យើងជាទេវបុត្រទាំងពីរនាក់ គឺទេវបុត្រអ្នកពោលនូវធម៌ និង
ទេវបុត្រអ្នកពោលនូវអធម៌ ទៅជាសត្រូវនឹងគ្នា ដូច្នេះ ។

ក្នុងកាលកន្លងទៅ ថ្ងៃមួយ រថរបស់ទេវបុត្តទាំងពីរ បានមកជួបគ្នាក្នុង អាកាស ពេលនោះបរិវាររបស់ទេវបុត្តទាំងពីរក៏សួរគ្នាថា ពួកអ្នកជានរណា ពួកអ្នកជានរណា ក៏ឆ្លើយថា ពួកយើងជាបរិវារធម្មទេវបុត្ត ពួកយើងជា បរិវាររបស់អធម្មទេវបុត្ត ហើយជនទាំងពីរចំណែក ក៏ចៀសចេញអំពីផ្លូវ ។ រថរបស់ធម្មទេវបុត្ត និងអធម្មទេវបុត្តក៏ជួបគ្នា ចន្ទោលរថ និងចន្ទោលរថ

ប៉ះគ្នា ជនទាំងពីរចំណែកប្រកែកគ្នា ឲ្យភាគីម្ខាងទៀតចៀសផ្លូវថា ចូរអ្នក ចៀសរថរបស់អ្នក ហើយឲ្យផ្លូវដល់ខ្ញុំ ទេវបុត្តម្ខាងទៀតពោលថា អ្នកទុំះ ឯង ចូរចៀសរថរបស់អ្នក ឲ្យផ្លូវដល់យើង ។ ចំណែកពួកបរិវាររបស់ ទេវបុត្តទាំងពីរចំណែក ក៏នាំយកអាវុធចេញត្រៀមធ្វើសង្គ្រាម ដូចព្រះមាន ព្រះភាគត្រាស់ថា

យើងទាំងពីរនាក់ ត្រូវបររថប៉ះនឹម ដោយនឹមក្នុងផ្លូវជួបគ្នា ។ ជម្លោះជាហេតុញុាំងភ័យឲ្យកើត ប្រព្រឹត្តទៅដល់កល្យាណ ទេវបុត្រ និងបាបទេវបុត្រ មហាសង្គ្រាមក៏តាំងឡើង ដើម្បី ប្រជែងផ្លូវគ្នា ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធុរេ ធុរំ** បានដល់ ចន្ទោលរថរបស់ ទេវបុត្រម្ខាង ដល់ចន្ទោលរថរបស់ទេវបុត្រម្ខាងទៀត ។ បទថា **សមិច្ចា** បានដល់ មកព្រមគ្នា គឺមកជួបមុខគ្នា ។ បទថា **ឧភោ** លោកពោលដើម្បី សម្តែងថា យើងទាំងពីរជាសត្រូវនៃគ្នានិងគ្នា ត្រាច់ទៅក្នុងលោក ថ្ងៃមួយ មកជួបមុខគ្នា កាលបរិវារទាំងពីរចៀសចេញអំពីផ្លូវ មួយអន្ទើដោយរថ យើងទាំងពីរក៏ជួបមុខគ្នាទៀត ។ បទថា **ភេស្មា** បានដល់ គួរខ្លាច ។ បទថា **កល្យាណបាបកស្ស** ច បានដល់ ដែលមានកល្យាណធម៌ និងដែលមាន បាបធម៌ ។ បទថា **មហាយុទ្ធោ ឧបដ្ឋិតោ** បានដល់ មហាសង្គ្រាមជិតកើត ឡើងហើយ ។

ពិតហើយ ភាពដែលបរិវារ គិតនឹងច្បាំងគ្នានិងគ្នាកើតឡើង ។ ក្នុងពីរ

ចំណែកនោះ ធម្មទេវបុត្រពោលនឹងអធម្មទេវបុត្រថា នែសម្លាញ់ អ្នកជាអធម៌ ខ្ញុំជាធម៌ ទើបផ្លូវគួរដល់ខ្ញុំ ចូរអ្នកចៀសរថរបស់អ្នក ហើយឲ្យផ្លូវដល់ខ្ញុំចុះ ។ កាគីម្ខាងទៀតក៏ពោលថា ខ្ញុំមានយានរឹងមាំ មានកម្លាំងមិនតក់ស្លុត ព្រោះហេតុនោះ ខ្ញុំមិនឲ្យផ្លូវ តែខ្ញុំនឹងច្បាំង ផ្លូវជារបស់អ្នកឈ្នះក្នុងការច្បាំងចុះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ធម្មទេវបុត្រពោលថា

ម្នាលអធម្មទេវបុត្រ ខ្ញុំឈ្មោះធម្មៈ ជាអ្នកធ្វើយស ធ្វើបុណ្យ ខ្ញុំដែលពួកសមណព្រាហ្មណ៍សរសើរជានិច្ច ដែលទេវតា និងមនុស្សបូជាហើយ គួរបានផ្លូវ អ្នកចូរឲ្យផ្លូវ ។

អធម្មទេវបុត្រពោលថា

ម្នាលធម្មៈ ខ្ញុំជិះរថ ឈ្មោះអធម្មយានដ៏មាំ ជាអ្នកមិនតក់ស្លុត មានកម្លាំង ខ្ញុំនោះ នឹងឲ្យផ្លូវដល់អ្នកដែលមិនធ្លាប់ឲ្យហើយ ក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ។

ធម្មទេវបុត្រពោលថា

ធម៌បានកើតមុន អធម៌កើតក្រោយក្នុងលោក ខ្ញុំជាច្បងផង ប្រសើរជាងផង មានតាំងពីព្រេងនាយផង ម្នាលប្អូន អ្នកចូរចៀសចេញអំពីផ្លូវរបស់បង ។

អធម្មទេវបុត្រពោលថា

ខ្ញុំមិនត្រូវឲ្យផ្លូវដល់អ្នកដោយសេចក្តីអង្វរ មិនត្រូវឲ្យដោយពាក្យសមគួរ មិនត្រូវឲ្យព្រោះខ្ញុំគួរបានផ្លូវ យើងទាំងពីរនាក់ចូរច្បាំងគ្នាក្នុងថ្ងៃនេះ អ្នកណាឈ្នះក្នុងចម្បាំង ផ្លូវជារបស់អ្នកនោះ ។

ធម្មទេវបុត្រពោលថា

ម្នាលអធម្មៈ ខ្ញុំឈ្មោះធម្មៈ ជាអ្នកល្បីល្បាញសព្វទិស មានកម្លាំងច្រើន មានយសរាប់មិនអស់ មិនមានអ្នកណាផ្ទឹមបាន មានសភាពជាអ្នកប្រកបដោយគុណ គ្រប់យ៉ាង អ្នកនឹងឈ្នះ ( ខ្ញុំ ) ដូចម្តេចបាន ។

អធម្មទេវបុត្រពោលថា

គេតែងជំមាសដោយដែក គេមិនដែលជំដែកដោយមាសទេ បើអធម្មៈជំធម្មៈ ក្នុងថ្ងៃនេះ ដូចជាដែកជំមាស បុគ្គលគួរមើលដែរ ។

ធម្មទេវបុត្រពោលថា

ម្នាលអធម្មៈ បើអ្នកមានកម្លាំង នឹងច្បាំងបុគ្គលចាស់ និងបុគ្គលជាគ្រូមិនមានដល់អ្នក ខ្ញុំនឹងឲ្យនូវផ្លូវដល់អ្នក ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ផង ខ្ញុំនឹងអត់ទ្រាំ នូវពាក្យទ្រគោះបោះបោករបស់អ្នកផង ដូច្នេះ ។

ក្នុងគាថាទាំងនេះ ជាគាថាឆ្លើយឆ្លង រវាងធម្មទេវបុត្រ និងអធម្មទេវបុត្រ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ជាអ្នកធ្វើយស សេចក្តីថា ឲ្យនូវយស ដល់ទេវតា និងមនុស្សទាំងឡាយ ដោយការដឹកនាំឲ្យប្រព្រឹត្តធម៌ ។ ក្នុងពាក្យទី ២ ( ធ្វើបុណ្យ ) ក៏ន័យនេះដូចគ្នា ។ ពាក្យថា សរសើរជានិច្ច សេចក្តីថា លើកតម្កើងសព្វកាល បានដល់ សរសើរជានិច្ច ។ ពាក្យថា ខ្ញុំនោះ នឹងឲ្យផ្លូវដល់អ្នកដែលមិនធ្លាប់ឲ្យហើយ ក្នុងថ្ងៃនេះ ព្រោះហេតុអ្វី សេចក្តីថា ខ្ញុំអធម្មទេវបុត្រឡើងកាន់អធម្មយាន មិនខ្លាច មានកម្លាំង នៃធម្មទេវបុត្រ ថ្ងៃនេះ ខ្ញុំនឹងឲ្យផ្លូវ ដែលខ្ញុំមិនធ្លាប់ឲ្យដល់អ្នកណាមួយ ដល់អ្នក ដោយហេតុដូចម្តេច ។ ពាក្យថា ធម៌បានកើតមុន បានដល់ ធម៌ គឺកុសលកម្មបថ ១០ ក្នុងលោកនេះ បានប្រាកដមកមុនតាំងពីបឋមកប្ប អធម៌បានប្រាកដក្នុងកាលឯក្រោយ ។ ពាក្យថា ខ្ញុំជាច្បងផង សេចក្តីថា ធម្មទេវ-បុត្រពោលថា ខ្ញុំ ទើបជាច្បង ជាបុគ្គលប្រសើរ ជាបុគ្គលចាស់ ព្រោះកើតមុន ចំណែកអ្នកជាប្អូន ព្រោះហេតុនោះ ប្អូនត្រូវចៀសផ្លូវឲ្យបង ។

ពាក្យថា មិនត្រូវឲ្យដោយពាក្យសមគួរ សេចក្តីថា នៃធម្មទេវបុត្រ សេចក្តីពិត ខ្ញុំគប្បីឲ្យផ្លូវដល់អ្នក មិនមែនព្រោះការអង្វរ មិនមែនព្រោះពាក្យសរសើរ មិនមែនព្រោះសមគួរដល់ផ្លូវ ។ ពាក្យថា ល្បីល្បាញ សេចក្តីថា ខ្ញុំជាបុគ្គលប្រាកដ ល្បីល្បាញដោយគុណធម៌របស់ខ្លួនសព្វទិស គឺទិសធំ ៤ ទិសតូច ៤ ។ ពាក្យថា ដែក បានដល់ ញញួរធ្វើដោយដែក ។ ពាក្យថា ជំ បានដល់ វាយ ។ ពាក្យថា ម្នាលអធម្មៈ បើអ្នកមានកម្លាំងនឹងច្បាំង បានដល់ នៃអធម្មទេវបុត្រ បើអ្នកជាអ្នកមានកម្លាំងក្នុងការច្បាំង ។

ពាក្យថា បុគ្គលចាស់ និងបុគ្គលជាគ្រូ សេចក្ដីថា បើបុគ្គលចាស់ទាំងនេះ គ្រូទាំងនេះដែលជាបណ្ឌិត មិនមានដល់អ្នក ដោយប្រការដូច្នេះ ។ ពាក្យថា ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ បានដល់ ដោយការមិនស្រឡាញ់ ដូចការស្រឡាញ់ អធិប្បាយថា កាលខ្ញុំឲ្យដោយការមិនស្រឡាញ់ ក៏រមែងឲ្យផ្លូវដល់អ្នក ដូចឲ្យដោយការស្រឡាញ់ ។

ក្នុងកាលនោះ ព្រះមហាសត្វគិតថា បើអញផ្ទាត់ម្រាមដៃ ហើយពោល នឹងបុគ្គលអាក្រក់នេះ ដែលបដិបត្តិដើម្បីភាពមិនជាប្រយោជន៍ដល់សត្វលោក ប្រកាន់នូវវត្ថុផ្សុយគ្នាជាមួយអញយ៉ាងនេះថា នែបុគ្គលឥតមារយាទ អ្នកកុំនៅទីនេះឡើយ ប្រញាប់ចៀសចេញទៅចុះ ចូរវិនាសចុះ ។ ក្នុងខណៈនោះឯង បុគ្គលនោះ គប្បីខ្ចាត់ខ្ចាយទៅដូចផេះដោយធម្មតេជះរបស់អញ ។ បន្ទាប់អំពីនោះ មិនសមគួរដល់អញឡើយ អញអនុគ្រោះសត្វលោក និងបដិបត្តិដោយបំណងថា ញ៉ាំងលោកត្ថចរិយាឲ្យដល់នូវទីបំផុត បុគ្គលលាមកនេះ នឹងមានចំណែកនៃទុក្ខធំតទៅ អញគប្បីអនុគ្រោះទេវ-បុត្រអាក្រក់នេះដោយពិសេស ព្រោះហេតុនោះ អញនឹងឲ្យផ្លូវដល់ទេវ-បុត្រនេះ ដោយអាការយ៉ាងនេះ សីលរបស់អញនឹងបរិសុទ្ធដោយល្អ និងមិនដាច់ ។ កាលព្រះពោធិសត្វត្រិះរិះយ៉ាងនេះហើយ ទើបពោលគាថាថា បើអ្នកមានកម្លាំងនឹងច្បាំងដូច្នេះជាដើម លុះចៀសចេញអំពីផ្លូវបន្តិចប៉ុណ្ណោះ អធម្មទេវបុត្រមិនអាចនៅលើរថបាន ដាំដូងចុះលើផែនដីៗ ក៏ញែកជាពីរចំណែក ទៅកើតក្នុងអវីចិមហានរក ដូចព្រះមានព្រះភាគត្រាស់ថា

បើតថាគតខឹងនឹងអធម្មទេវបុត្រ មានតែតថាគតទម្លាយតបោគុណ គឺសីលដ៏ប្រសើរ តថាគតគប្បីធ្វើនូវអធម្មទេវបុត្រនោះ ព្រមទាំងជនជាបរិស័ទ ឲ្យទៅជាធូលីក៏បាន ។ ប៉ុន្តែតថាគតរម្ងាប់ចិត្ត ដើម្បីរក្សាសីល តថាគត ព្រមទាំងជនជាបរិស័ទ ក៏បរចៀសបើកផ្លូវឲ្យបាបទេវបុត្រ ។ កាលតថាគត ព្រមទាំងជនជាបរិស័ទ រម្ងាប់ចិត្តបររថ ចៀសអំពីផ្លូវហើយ មហាប្រឹថពី ក៏ស្រូបបាបទេវបុត្រក្នុងខណៈនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យទិហំ តស្ស អកុប្បេយ្យំ** បានដល់ បើតថាគតគប្បីក្រោធអធម្មទេវបុត្រនោះ ។ បទថា **យទិ ភិន្ទេ តបោគុណំ** បានដល់ បើតថាគតគប្បីញុំាងសីលសំវរៈ ដែលជាតបគុណរបស់តថាគតឲ្យវិនាសទៅដោយសេចក្ដីក្រោធក្នុងអធម្មទេវបុត្រនោះ ។ បទថា **សហ-បរិជនំ តស្ស** បានដល់ អធម្មទេវបុត្រនោះ មួយអន្លើដោយបរិវារ ។ បទថា **រជភូតំ** បានដល់ ដូចធូលី គឺតថាគតគប្បីធ្វើឲ្យដល់នូវភាពជាធូលី ។ បទថា **អហំ** ក្នុងបទថា **អបិចាហំ** នេះ ត្រឹមតែជានិបាត ។ បទថា **សីល-រក្ខាយ** បានដល់ ដើម្បីរក្សាសីល ។ បទថា **និព្វាបេត្វាន** បានដល់ ស្ងប់ចិត្តដោយស្ងប់ការក្រវល់ក្រវាយ ដែលកើតអំពីទោសៈ ដោយមិនឲ្យសេចក្ដីក្រោធ ដែលកើតឡើងក្នុងអធម្មទេវបុត្រនោះកើតឡើងបាន ព្រោះតថាគតចូលទៅតម្កល់ខន្តី មេត្តា និងការអាណិតអាសូរអំពីខាងមុខហើយ ។ បទថា **សហ ជនេនោក្កមិត្វា** បានដល់ តថាគតបានជៀសផ្លូវ មួយអន្លើដោយជន

ជាបរិវាររបស់តថាគត ហើយឲ្យផ្លូវដល់អធម្មទេវបុត្រដ៏លាមកនោះ ។

បទថា **សហ បថតោ ឱក្កមេ** បានដល់ ដំណាលគ្នានឹងតថាគតធ្វើនូវការស្ងប់ចិត្ត តាមន័យដូចពោលហើយ និងពោលថា ខ្ញុំឲ្យផ្លូវដល់អ្នក ហើយចៀសផ្លូវឲ្យបន្តិច ។ បទថា **ចាបយក្ខស្ស** ស្មើគ្នានឹង **អធម្មទេវបុត្តស្ស** ( ដល់អធម្មទេវបុត្រ ) ។ បទថា **តាវទេ** បានដល់ ក្នុងខណៈនោះឯងមហាប្រឹថពីក៏បើកចន្លោះ ។ តែក្នុងអដ្ឋកថាជាតកពោលថា ក្នុងខណៈដែលពោលគាថាថា ខ្ញុំឲ្យផ្លូវដល់អ្នកនុ៎ះឯង ។

កាលអធម្មទេវបុត្រ ធ្លាក់ចូលទៅកាន់ផែនដីយ៉ាងនោះ មហាប្រឹថពីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ សូម្បីទ្រទ្រង់នូវវត្ថុល្អ និងមិនល្អទាំងអស់ ក៏បានបែកចេញជាពីរ ក្នុងទីដែលអធម្មទេវបុត្រឈរនោះ ហាក់ដូចពោលថា ខ្ញុំមិនអាចទ្រទ្រង់បុរសអាក្រក់នេះបាន ។ ចំណែកព្រះមហាសត្វ កាលអធម្មទេវបុត្រនោះ ធ្លាក់ទៅកើតក្នុងអវីចិមហានរក ក៏ឈរត្រង់ទូករទេះមួយអន្លើដោយបរិវារដោយទេវានុភាពធំ ហើយទៅតាមផ្លូវប្រក្រតី ចូលទៅកាន់វិមានរបស់ខ្លួន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ធម្មទេវបុត្ត មានខន្តិធម៌ជាកម្លាំង មានចិត្ត មានកម្លាំងក្រៃពេក
មានព្យាយាមដ៏ទៀងទាត់ បានផ្ចាញ់ បានសម្លាប់នូវអធម្មទេវបុត្ត
ដែលមានចម្បាំងជាកម្លាំង ទម្លាក់ទៅលើផែនដី ហើយឡើងកាន់
រថ ( របស់ខ្លួន ) បរទៅតាមផ្លូវដដែល ដូច្នេះ ។

អធម្មទេវបុត្រក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ បរិវាររបស់អធម្មទេវបុត្រ ក្នុងកាលនោះ បានមកជាបរិស័ទរបស់ទេវទត្ត ក្នុងកាលឥឡូវនេះ ធម្មទេវបុត្រក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ បរិវាររបស់ធម្មទេវបុត្រក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ។

ក្នុងធម្មទេវបុត្តចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសតាមគួរ ដោយន័យដូចពោលហើយ ខាងដើមនោះឯង ។

ម្យ៉ាងទៀត ក្នុងចរិយានេះ គប្បីប្រកាសគុណានុភាពនៃព្រះមហាសត្វ មានយ៉ាងនេះ គឺការដែលព្រះមហាសត្វដល់ព្រមដោយអាយុ ពណ៌សម្បុរ យស សុខ និងភាពជាធំដែលជាទិព្វ ដោយកាមគុណដ៏ធំក្រៃលែង ជាទិព្វ ដូចគ្នា ដែលស្រីទេពអប្សរមួយពាន់ បម្រើសព្វកាល គួរតាំងនៅក្នុងសេចក្តីប្រមាទដ៏ក្រៃលែង តែមិនប្រមាទសូម្បីតិចតួច សម្តែងធម៌ក្នុងថ្ងៃ ១៥ កើត រាល់ៗ ខែដោយបំណងថា នឹងញុំាងលោកត្ថចរិយាឲ្យដល់ទីបំផុត មួយអន្លើ ដោយបរិវារ ត្រាច់ទៅក្នុងផ្ទះរបស់មនុស្ស ញុំាងសព្វសត្វឲ្យវៀរចាកអធម៌ ហើយប្រកបក្នុងធម៌ ដោយមហាករុណា ។ ការដែលព្រះពោធិសត្វ ជួបជាមួយអធម្មទេវបុត្រ ក៏មិនបានគិតដល់ការឥតមារយាទ ដែលអធម្មទេវបុត្រ បង្ហាញចេញមក មិនធ្វើចិត្តឲ្យក្រោធក្នុងអធម្មទេវបុត្រនោះ ញុំាងខន្តី មេត្តា និងការអាណិតអាសូរប៉ុណ្ណោះឲ្យតាំងនៅ ហើយរក្សាសីលរបស់ខ្លួនមិនឲ្យដាច់ និងឲ្យបរិសុទ្ធយ៉ាងល្អ ៕៚

**អដ្ឋកថាធម្មទេវបុត្តចរិយា ចប់**

# សុត្តន្តបិដក

## ជយទិសចរិយាទី ៩

[ ១៩ ] មានស្តេចមួយអង្គ ព្រះនាមជយទិស ប្រកបដោយសីលគុណ ក្នុងក្រុងដ៏ឧត្តមឈ្មោះកប្បិលា ជាក្រុងដ៏ប្រសើរក្នុងដែនបញ្ចាល ។ តថាគតកើតជាព្រះរាជបុត្ររបស់ស្តេចនោះ ឈ្មោះអលីនសត្តកុមារ ជាអ្នកល្បីល្បាញក្នុងធម៌ មានសីលដ៏ល្អ ប្រកបដោយមហាបុរិសគុណ ជាអ្នករក្សានូវជនជាបរិវារសព្វកាល ។ បិតារបស់តថាគត បានទៅប្រពាសម្រឹគ ( ក្នុងព្រៃ ) ជ្រុលចូលទៅកាន់សម្នាក់យក្ខ ឈ្មោះបោរិសាទ យក្ខនោះចាប់ស្តេចជយទិសជាបិតានៃតថាគត ( ហើយនិយាយថា ) អ្នកត្រូវជាអាហាររបស់យើងហើយ អ្នកកុំកម្រើកឡើយ ។ បិតារបស់តថាគតនោះ លុះឮពាក្យរបស់យក្ខិនីបុត្រនោះ ហើយក៏ភ័យ តក់ស្លុត ញ័ររន្ធត់ រឹងក្ដៅទាំងពីរ បិតានៃតថាគតនោះ ឈរនៅស្ងៀម មិនអាចនឹងរត់ចេញទៅបាន ព្រោះឃើញស្តេចបោរិសាទ ។ ព្រះរាជាទ្រង់អង្វរថា សូមអ្នកយកសាច់ម្រឹគនេះចុះ សូមលែងខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យដល់ព្រាហ្មណ៍ រួចហើយ នឹងត្រឡប់មកវិញ ។ បិតាហៅតថាគតមកប្រាប់ថា ម្នាលកូន អ្នកចូរគ្រប់គ្រងរាជ្យ ចូរកុំប្រមាទបុរីនេះឡើយ ដែលអញបានត្រឡប់មកវិញនេះ ព្រោះតែអញបានប្តេជ្ញាជាមួយនឹងយក្ខបោរិសាទ ។ តថាគតថ្វាយបង្គំព្រះមាតា និងព្រះបិតា ហើយទិម្មិតខ្លួនកាន់ធ្នូ និងព្រះខ័ន ចេញអំពីនគរ ដើរចូលទៅរក

ប្រៀសាទយក្ខ ។ ( តថាគតគិតថា យក្ខនោះ បើឃើញតថាគត ) មានគ្រឿងសស្ត្រាវុធនៅក្នុងដៃ ក៏នឹងតក់ស្លុត កាលបើតថាគត ធ្វើយក្ខនោះឲ្យតក់ស្លុត សីលរបស់តថាគត នឹងបែកធ្លាយ ដោយ ការញ៉ាំងសេចក្តីតក់ស្លុត ឲ្យកើតដល់យក្ខនោះ ។ ( លុះគិតឃើញ យ៉ាងនេះ ) តថាគតមិនពោលពាក្យជាទីស្អប់ ទៅរកយក្ខនោះទេ ព្រោះការខ្លាចដាច់សីលនៃតថាគត តថាគតមានមេត្តាចិត្ត ពោល តែពាក្យមានប្រយោជន៍ ហើយបានពោលនូវពាក្យនេះថា ចូរលោក តាដុតភ្លើងឲ្យឆេះខ្លាំងឡើង ខ្ញុំនឹងលោតពីដើមឈើនេះ ទម្លាក់ទៅ ( ក្នុងភ្លើងនោះ ) បពិត្រជីតា បើលោកតាដឹងនូវកាលនៃសាច់នោះ ឆ្អិនល្អហើយ ចូរបរិភោគសាច់នោះចុះ ។ ព្រោះហេតុបិតាមាន សីល ដូចរៀបរាប់មកនេះ តថាគតមិនរក្សាជីវិតរបស់តថាគតទេ តថាគតញ៉ាំងបោរិសាទ ជាអ្នកធ្វើអំពើបាណាតិបាត ឲ្យវៀរចេញ អំពើអាក្រក់សព្វកាល ។

**ជយទិសចរិយាទី ៩ ចប់**

# អដ្ឋកថា

## ជយទិសចរិយា

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជយទិសចរិយាទី ៩ ដូចទៅ បទថា **បញ្ចាលរដ្ឋេ** បានដល់ ក្នុងជនបទមានឈ្មោះយ៉ាងនេះ ។ បទថា **នគរវរេ កបិលាយំ** បានដល់ ក្នុងឧត្តមនគរ ដែលមានឈ្មោះយ៉ាងនេះថា កប្បិលា ។ ការពោលថា **នគរវរេ** ហើយនៅតែពោលថា **បុរុត្តមេ** ទៀត ដើម្បីសម្តែងថា នគរនោះ ជានគរដ៏ប្រសើរជាងនគរទាំងអស់ ក្នុងជម្ពូទ្វីប ក្នុងកាលនោះ ។ បទថា **ជយទ្ទិសោ នាម** សេចក្តីថា ព្រះរាជាប្រសូតក្នុងកាលបិតាទ្រង់ឈ្នះសត្រូវរបស់ទ្រង់ ឬទ្រង់ឈ្នះជយទិស គឺយក្ខិនីដែលជាសត្រូវរបស់ព្រះអង្គ ព្រោះហេតុនោះ ទើបទ្រង់បានព្រះនាមយ៉ាងនេះ ។ បទថា **សីលគុណមុ-បាគតោ** បានដល់ ទ្រង់ប្រកបដោយអាចារសីល និងគុណធម៌របស់ព្រះរាជា មានការដល់ព្រមដោយព្រះឧស្សាហៈជាដើម អធិប្បាយថា ទ្រង់ដល់ព្រមដោយសីលគុណនោះ ។

បទថា **តស្ស រញ្ញោ** បានដល់ នៃព្រះបាទជយទិសរាជ ។ ឲ្យបន្ថែមពាក្យថា ខ្ញុំជាព្រះរាជឱរសរបស់ព្រះរាជាអង្គនោះ ចូលមក ។ បទថា **សុតធម្មោ** បានដល់ ឈ្មោះថា ធម៌ ដែលព្រះរាជបុត្តនោះ គប្បីស្តាប់ ។ ឈ្មោះថា **សុតធម្មោ** ព្រោះទ្រង់ស្តាប់ធម៌ទាំងពួង អធិប្បាយថា ជាពហុសូត ។ ម្យ៉ាងទៀត បទថា **សុតធម្មោ** សេចក្តីថា មានធម៌ប្រាកដហើយ ប្រាកដឈ្មោះបោះសំឡេងដោយធម្មចរិយា សមចរិយា អធិប្បាយថា

មានធម៌ជាកិត្តិយស ផ្សាយទៅក្នុងលោក ។ បទថា **អលីនសត្តោ** គឺមានឈ្មោះយ៉ាងនេះ ។ បទថា **គុណវា** បានដល់ ប្រកបដោយគុណរបស់មហាបុរស ដែលធំក្រៃលែង ។ បទថា **អនុរក្ខបរិជនោ សទា** សេចក្តីថា មើលថែបរិវារជនអស់កាលជានិច្ច ព្រោះប្រកបដោយគុណវិសេស មានសទ្ធាជាដើម និងព្រោះសង្គ្រោះដោយសង្គហវត្ថុ ៤ ដោយប្រពៃ ។

បទថា **បិតា មេ មិគវំ គន្ត្វា ពោរិសាទំ ឧបាគមិ** សេចក្តីថា ព្រះបាទជយទិស ព្រះជនករបស់តថាគត ទ្រង់យាងទៅបរបាញ់សត្វ កាលយាងដល់កណ្តាលព្រៃ ទ្រង់បានជួបស្តេចបោរិសាទ កូនយក្ខិនីស៊ីមនុស្ស ទើបចូលទៅរកស្តេចបោរិសាទនោះ ។

បានឮថា ថ្ងៃមួយ ព្រះបាទជយទិសយាងចេញអំពីកបិលនគរ មួយអន្លើដោយបរិវារធំ ដែលសមគួរដល់ព្រះអង្គ ដោយមានបំណងថា អញនឹងទៅបាញ់សត្វ ។ លុះព្រះរាជាយាងចេញទៅបានបន្តិច នន្ទព្រាហ្មណ៍អ្នកក្រុងតក្កសិលា កាន់យកគាថា ឈ្មោះសតារហា ៤ បទ ចូលទៅរកដើម្បីប្រាប់ ហើយក្រាបទូលដល់ហេតុដែលខ្លួនមកដល់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងត្រឡប់មកស្តាប់ ទើបព្រះរាជទានផ្ទះជាលំនៅ និងស្បៀងដល់ព្រាហ្មណ៍ ហើយយាងចូលព្រៃ ត្រាស់ថា ម្រឹគគេចទៅត្រង់មុខរបស់អ្នកណា អ្នកនុ៎ះត្រូវកាត់ក្បាល ហើយទ្រង់ត្រាច់បាញ់ម្រឹគ ។ កាលនោះ ម្រឹគមួយបានឮសំឡេងជើងរបស់មនុស្សជាច្រើន ទើបចេញអំពីលំនៅ គេចទៅតាមផ្លូវរបស់ព្រះរាជា ។ ពួកអមាត្យនាំគ្នាសើចចំអក ព្រោះពេញចិត្ត ។

ព្រះរាជាទ្រង់តាមម្រឹគនោះ ទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ ទ្រង់បាញ់ម្រឹគនោះដែលអស់កម្លាំងឲ្យដួលចុះ ។ ព្រះរាជាទ្រង់យកដាវកាត់ម្រឹគដែលដួលហើយនោះ ជាពីរចំណែក ទោះបីទ្រង់មិនប្រាថ្នា តែដើម្បីដោះពាក្យដែលពោលថា ព្រះរាជាមិនអាចចាប់ម្រឹគដែលរត់ទៅបាន ទើបទ្រង់ធ្វើជង់រែករែកម្រឹគត្រឡប់មក ប្រថាប់គង់លើស្បូវភ្លាំង ត្រង់គល់ជ្រៃមួយដើម ទ្រង់សម្រាកមួយស្របក់ ត្រៀមនឹងធ្វើដំណើរចេញទៅ ។

សម័យនោះ ព្រះជេដ្ឋា គឺបងប្រុសរបស់ព្រះរាជានោះ ក្នុងថ្ងៃប្រសូតត្រូវយក្ខិនីចាប់ដើម្បីបរិភោគ យក្ខិនីនោះ ត្រូវពួកមនុស្សអ្នកយាមដេញតាមទៅលូទឹក ទើបដាក់ព្រះរាជកុមារត្រង់ទ្រូង ព្រះរាជកុមារបៅដោះដោយសម្គាល់ថាជាព្រះមាតា យក្ខិនីកើតសេចក្ដីស្រឡាញ់ដូចបុត្រ ទើបចិញ្ចឹមយ៉ាងល្អ ។ ព្រះរាជកុមារសោយសាច់មនុស្ស ព្រោះយក្ខិនីប្រកបជាអាហារឲ្យសោយ ចម្រើនវ័យតាមលំដាប់ ក៏បំបាំងខ្លួនបាន ដោយអានុភាពរបស់ឫសថ្នាំដែលយក្ខិនីឲ្យដើម្បីបំបាំងខ្លួនបាន ទើបសោយសាច់មនុស្សចិញ្ចឹមជីវិត កាលយក្ខិនីស្លាប់ ឫសថ្នាំនោះក៏បាត់ទៅ ព្រោះសេចក្ដីប្រមាទរបស់ខ្លួន ទើបមានរាងកាយប្រាកដជារាងកាយអាក្រាតគួរខ្លាច ទំពាស៊ីសាច់មនុស្សឃើញរាជបុរសដែលដេញតាមរកព្រះរាជា ទើបគេចចូលព្រៃ អាស្រ័យត្រង់គល់ជ្រៃនោះ កាលឃើញព្រះរាជា ទើបពោលថា អ្នកជាអាហាររបស់យើងទើបចាប់ត្រង់ព្រះហស្ត ដូចព្រះមានព្រះភាគត្រាស់ថា

យក្ខនោះ ចាប់ស្ដេចជយទិស ជាបិតានៃតថាគត ( ហើយ

និយាយថា ) អ្នកត្រូវជាអាហាររបស់យើងហើយ អ្នកកុំកម្រើក ឡើយ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សោ មេ បិតុមគ្គហេសិ** សេចក្តីថា ស្តេចបោរិសាទនោះ បានចាប់ត្រង់ព្រះហស្តរបស់ព្រះបាទជយទិស ព្រះបិតារបស់តថាគត ដែលមកក្បែរដើមឈើដែលខ្ជុនអន្ធយ ដោយពោលថា ចូរមកជាអាហាររបស់យើង កុំកម្រើក ដោយការរលាស់ដៃជាដើម យើងនឹងបរិភោគអ្នក ទោះបីខំរើ ដូច្នេះ ។ បទថា **តស្ស** បានដល់ នៃកូនយក្ខិនីនោះ ។ បទថា **តសិតវេធិតោ** បានដល់ តក់ស្លុតដោយការតក់ស្លុតនៃចិត្ត ព្រោះមានរាងកាយញ័រចម្រប់ ។ បទថា Ï **ុរុក្ខម្ហា** បានដល់ ភ្លៅទាំងពីររឹង ។ ព្រះរាជាមិនអាចគេចទៅអំពីទីនោះបាន ។

បទថា **មិគវំ** ក្នុងបទថា **មិគវំ គហេត្វា មុញ្ចស្សុ** លោកហៅម្រឹគនោះថា **មិគវំ** ព្រោះបានមកដោយការបរបាញ់ អធិប្បាយថា ស្តេចបោរិសាទកាន់យកសាច់របស់ម្រឹគនេះហើយ ទើបដោះលែងខ្ញុំ ។ ព្រោះព្រះរាជាទ្រង់ឃើញបុត្រយក្ខិនីនោះ ទ្រង់ខ្លាច ទើបមានភ្លៅរឹង ប្រហាប់ឈរដូចគល់ឈើ ។ ស្តេចបោរិសាទស្ទុះទៅចាប់ព្រះរាជាត្រង់ព្រះហស្ត ហើយពោលថា អ្នកជាអាហាររបស់យើងហើយ ។ លំដាប់នោះ ព្រះរាជាទ្រង់តាំងស្មារតី ហើយត្រាស់នឹងស្តេចបោរិសាទថា បើអ្នកត្រូវការអាហារ យើងនឹងឲ្យម្រឹគនេះដល់អ្នក ចូរអ្នកទទួលម្រឹគនេះបរិភោគចុះ ។ ចូរអ្នកដោះលែងខ្ញុំចុះ ។ ស្តេចបោរិសាទបានស្តាប់ដូច្នោះ ទើបពោលថា អ្នកឲ្យរបស់ផងខ្ញុំ ហើយមក

ពោលល្អជាមួយខ្ញុំ ម្រឹគក្តី អ្នកក្តី ជារបស់ផងខ្ញុំ តាំងអំពីខ្ញុំចាប់ដៃអ្នក មិនមែនឬ ព្រោះហេតុនោះ ខ្ញុំនឹងស៊ីអ្នកមុនហើយ ទើបស៊ីម្រឹគឯក្រោយ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ស្តេចបោរិសាទនេះ គង់មិនដោះលែងអញ ព្រោះយកម្រឹគជាថ្នូរពិត ម្យ៉ាងទៀត កាលអញមកបរបាញ់ម្រឹគ បានធ្វើប្តេជ្ញាជាមួយព្រាហ្មណ៍នោះថា យើងត្រឡប់មកហើយ ឲ្យទ្រព្យដល់អ្នក ។ បើយក្ខនេះអនុញ្ញាត អញនឹងរក្សាពាក្យសច្ចៈ ត្រឡប់ទៅផ្ទះដោះនូវពាក្យប្តេជ្ញានោះហើយ នឹងត្រឡប់មកជាអាហាររបស់យក្ខនេះវិញ ទ្រង់ប្រាប់សេចក្តីនោះដល់យក្ខ ។ ស្តេចបោរិសាទស្តាប់ដូច្នោះហើយ ពោលថា បើអ្នករក្សាពាក្យសច្ចៈ បំណងនឹងទៅ អ្នកទៅហើយឲ្យទ្រព្យដល់ព្រាហ្មណ៍នោះ ចូររក្សាពាក្យសច្ចៈ គប្បីប្រញាប់ត្រឡប់មក ហើយដោះលែងព្រះរាជាទៅ ។ ព្រះរាជាកាលស្តេចបោរិសាទដោះលែងហើយ ទើបត្រាស់ថា អ្នកកុំវិតក្កឡើយ ខ្ញុំនឹងមកអំពីព្រឹកនោះឯង ហើយទ្រង់សង្កេតគ្រឿងសម្គាល់ផ្លូវ យាងចូលទៅដល់ពួកពលរបស់ព្រះអង្គ ដែលពួកពលចោមរោមយាងចូលកាន់ព្រះនគរ ត្រាស់ហៅនទូព្រាហ្មណ៍នោះមក ឲ្យអង្គុយលើអាសនៈដ៏សមគួរ ទ្រង់ស្តាប់គាថាទាំងនោះហើយ ព្រះរាជទានទ្រព្យ ៤ ពាន់កហាបណៈ ឲ្យព្រាហ្មណ៍ឡើងកាន់យាន មានព្រះតម្រាស់ថា ពួកអ្នកចូរនាំព្រាហ្មណ៍នេះទៅឲ្យដល់នគរតក្កសិលា ហើយទ្រង់ឲ្យពួកមនុស្សជូនដំណើរព្រាហ្មណ៍ ក្នុងថ្ងៃទី ២ មានបំណងនឹងទៅរកស្តេចបោរិសាទ កាលទ្រង់តាំងព្រះរាជឱរសក្នុងរាជសម្បត្តិ ទើបទ្រង់ឲ្យឱវាទ ហើយត្រាស់ប្រាប់

សេចក្តីនោះ ដូចព្រះមានព្រះភាគត្រាស់ថា

ព្រះរាជាទ្រង់អង្វរថា សូមអ្នកយកសាច់ម្រឹគនេះចុះ សូមលែងខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យដល់ព្រាហ្មណ៍ រួចហើយ នឹងត្រឡប់មកវិញ ។ បិតាហៅតថាគតមកប្រាប់ថា ម្នាលកូន អ្នកចូរគ្រប់គ្រងរាជ្យ ចូរកុំប្រមាទបុរីនេះឡើយ ដែលអញបានត្រឡប់មកវិញនេះ ព្រោះតែអញបានប្តេជ្ញាជាមួយនឹងយក្ខបោរិសាទ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាគមនំ បុន** សេចក្តីថា បានឲ្យប្តេជ្ញាដល់ស្តេចបោរិសាទថា នឹងត្រឡប់មកវិញ ។ បទថា **ព្រាហ្មណស្ស ធនំ ទត្វា** សេចក្តីថា ស្តាប់គាថារបស់នន្ទព្រាហ្មណ៍ដែលមកអំពីនគរតក្កសិលា ហើយឲ្យទ្រព្យប្រមាណ ៤ ពាន់កហាបណៈ ។ បទថា **បិតា អាមន្តយី មមំ** សេចក្តីថា ព្រះបាទជយទិស ព្រះបិតារបស់តថាគតហៅតថាគតទៅជួប បើសួរថា ទៅជួបរឿងអ្វី ឆ្លើយថា រឿងរាជសម្បត្តិជាដើម ។ គាថានោះ មានសេចក្តីថា ព្រះរាជាត្រាស់ថា នែកូន ចូរកូនគ្រប់គ្រងរាជសម្បត្តិដែលជារបស់ត្រកូលនេះចុះ បិតាគ្រងរាជសម្បត្តិដោយធម៌ដោយស្មើ យ៉ាងណា សូម្បីកូនដែលគេលើកស្វេតច្ឆត្រឲ្យគ្រងរាជសម្បត្តិ ក៏ចូរជាយ៉ាងនោះ កូនរក្សានគរនេះ និងគ្រងរាជសម្បត្តិ កុំដល់នូវសេចក្តីប្រមាទឡើយ បិតាបានទទួលប្តេជ្ញាជាមួយយក្ខបោរិសាទត្រង់គល់ជ្រៃក្នុងទីនោះថា បិតានឹងមករកគេវិញ បិតារក្សាពាក្យសច្ចៈ ទើបត្រឡប់មកទីនេះ ដើម្បីឲ្យទ្រព្យដល់ព្រាហ្មណ៍នោះតែម្យ៉ាង ព្រោះហេតុនោះ បិតានឹងទៅក្នុងទីនោះ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ ទើបពោលថា បពិត្រមហារាជ បិតាកុំយាងទៅក្នុងទីនោះឡើយ ទូលបង្គំនឹងទៅក្នុងទីនោះឯង បពិត្របិតា បើព្រះបិតានឹងយាងទៅឲ្យខានតែបាន ទូលបង្គំក៏នឹងទៅជាមួយបិតាផងដែរ ។ ព្រះពោធិសត្វបានទទួលអនុញ្ញាតអំពីព្រះរាជា ដែលទ្រង់ឃាត់ដោយប្រការផ្សេងៗ ថា កាលបើយ៉ាងនោះ យើងទាំងពីរក៏នឹងមិនមានសល់ ព្រោះហេតុនោះ បានេះឯងនឹងទៅក្នុងទីនោះ ហើយថ្វាយបង្គំព្រះមាតាបិតា លះបង់ជីវិតដើម្បីប្រយោជន៍ដល់បិតា កាលបិតាទ្រង់ឲ្យឱវាទ និងកាលព្រះមាតាព្រះភគិនី ព្រះជាយា ធ្វើសច្ចកិរិយាដើម្បីសួស្តី ទើបកាន់អាវុធចេញអំពីនគរលាមហាជនដែលមានមុខជោកដោយទឹកភ្នែក ដែលធ្វើដំណើរតាមទៅ ទ្រង់យាងទៅតាមផ្លូវដែលជាលំនៅរបស់យក្ខ ដោយន័យដែលព្រះបិតាបានប្រាប់ ។ បុត្តយក្ខិនីគិតថា ឈ្មោះថា ក្សត្រ មានមាយាច្រើន អ្នកណានឹងដឹងថាយ៉ាងណា ទើបឡើងដើមឈើអគ្គុយ ចាំមើលការមករបស់ព្រះរាជា ឃើញព្រះរាជកុមារយាងមក ទើបគិតថា កូនមកជំនួសបិតា ភ័យមិនមានដល់អញទើបចុះអំពីដើមឈើ អគ្គុយបែរខ្នងឲ្យព្រះពោធិសត្វ ព្រះមហាសត្វយាងមកប្រថាប់ឈរអំពីខាងមុខស្តេចបោរិសាទនោះ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតថ្វាយបង្គំព្រះមាតា និងព្រះបិតា ហើយនិម្មិតខ្លួនកាន់ធ្នូ
និងព្រះខ័ន ចេញអំពីនគរ ដើរចូលទៅរកបោរិសាទយក្ខ ។
( តថាគតគិតថា យក្ខនោះ បើឃើញតថាគត ) មានគ្រឿង
សស្ត្រាវុធនៅក្នុងដៃ ក៏នឹងតក់ស្លុតកាលបើតថាគតធ្វើយក្ខនោះឲ្យ

តក់ស្លុត សីលរបស់តថាគត នឹងបែកធ្លាយ ដោយការញ៉ាំង សេចក្តីតក់ស្លុត ឲ្យកើតដល់យក្ខនោះ ។ ( លុះគិតឃើញយ៉ាង នេះ ) តថាគតមិនពោលពាក្យជាទីស្អប់ ទៅរកយក្ខនោះទេ ព្រោះ ការខ្លាចដាច់សីលនៃតថាគត តថាគតមានមេត្តាចិត្ត ពោលតែ ពាក្យមានប្រយោជន៍ ហើយបានពោលនូវពាក្យនេះថា ដូច្នេះ ។

បទថា **សសត្ថហត្ថុបគតំ** បានដល់ ស្តេចបោរិសាទ ឃើញតថាគត មានដៃកាន់អាវុធចូលទៅរកខ្លួន ។ បទថា **កទាចិ សោ តសិស្សតិ** បានដល់ ជួនកាលយក្ខនោះ គប្បីខ្លាច ។ បទថា **តេន ភិជ្ជិស្សតិ សីលំ** សេចក្តីថា សីលរបស់តថាគតនឹងវិនាស នឹងសៅហ្មងដោយហេតុដែលធ្វើឲ្យយក្ខនេះ កើតការខ្លាច ។ បទថា **បរិតាសំ កតេ មយិ** បានដល់ កាលតថាគតធ្វើឲ្យ យក្ខនោះតក់ស្លុត ។ បទថា **សីលខណ្ឌភយា មយ្ហំ តស្ស ទេស្សំ ន ព្យាហរឹ** សេចក្តីថា តថាគតបានដាក់សស្ត្រា ព្រោះខ្លាចសីលដាច់ ចូលទៅ រកស្តេចបោរិសាទនោះ យ៉ាងណា ព្រោះតថាគតខ្លាចសីលដាច់ ទើបមិននាំ វត្ថុដែលគួរខ្លាច មិនពោលពាក្យមិនជាទីស្រឡាញ់ គឺពាក្យមិនគួរប្រាថ្នា ដល់ស្តេចបោរិសាទនោះយ៉ាងនោះ តែតថាគតពោលពាក្យជាប្រយោជន៍ ដោយចិត្តមេត្តា ទើបបានពោលពាក្យដែលគួរពោលនោះ ក្នុងឥឡូវនេះ ។

ព្រះមហាសត្វ កាលយាងទៅប្រថាប់ឈរខាងមុខយក្ខិនីបុត្ត បំណង នឹងសាកល្បងព្រះមហាសត្វនោះ ទើបសួរថា អ្នកជានរណា មកអំពីណា អ្នកមិនស្គាល់យើងថា យើងជាព្រានបរិភោគសាច់មនុស្សទេឬ ហេតុអ្វី ទើប

អ្នកមកដល់ទីនេះ ។ ព្រះរាជកុមារត្រាស់ថា យើងជាឱរសរបស់ព្រះបាទជយទិស យើងដឹងថា អ្នក គឺបោរិសាទ ស៊ីសាច់មនុស្ស យើងមកទីនេះ ដើម្បីរក្សាព្រះជន្មរបស់ព្រះបិតា ព្រោះហេតុនោះ ចូរអ្នកវៀរព្រះបិតា បរិភោគយើងជំនួសចុះ ។ យក្ខិនីបុត្តពោលដោយអាការធ្ងល់ថា យើងស្គាល់អ្នកថា ជាឱរសរបស់ព្រះរាជាជយទិសនោះ តែអ្នកមកយ៉ាងនេះ ឈ្មោះថា អ្នកធ្វើវត្ថុដែលធ្វើបានដោយក្រ ។ ព្រះរាជកុមារត្រាស់ថា មិនក្រឡើយ ការលះបង់ជីវិត ព្រោះប្រយោជន៍របស់បិតា មែនពិត បុគ្គលធ្វើបុណ្យបែបនេះ ព្រោះហេតុមាតាបិតា រមែងត្រេកអរក្នុងស្ថានសួគ៌ដោយចំណែកមួយប៉ុណ្ណោះ ម្យ៉ាងទៀត យើងដឹងថា សត្វណាមួយ ឈ្មោះថា មិនមានការស្លាប់ជាធម្មតានុ៎ះ មិនមាន យើងមិនឃើញបាបណាមួយដែលខ្លួនធ្វើ ព្រោះហេតុនោះ ទើបយើងមិនខ្លាចចំពោះសេចក្ដីស្លាប់ យើងលះបង់ជីវិតនេះឲ្យដល់អ្នក ចូរអ្នកបង្កាត់ភ្លើង ហើយបរិភោគយើងចុះ ដូចព្រះមានព្រះភាគត្រាស់ថា

ចូរលោកតាជុតភ្លើងឲ្យឆេះខ្លាំងឡើង ខ្ញុំនឹងលោតពីដើមឈើនេះ
ទម្លាក់ទៅ ( ក្នុងភ្លើងនោះ ) បពិត្រជីតា បើលោកតាដឹងនូវកាល
នៃសាច់នោះឆ្អិនល្អហើយ ចូរបរិភោគសាច់នោះចុះ ដូច្នេះ ។

យក្ខិនីបុត្តបានស្ដាប់ដូច្នោះហើយ គិតថា អញមិនអាចបរិភោគសាច់កុមារនេះបាន អញនឹងឲ្យកុមារនេះគេចទៅដោយឧបាយ ទើបពោលថា បើដូច្នោះ អ្នកគប្បីចូលទៅកាន់ព្រៃ រកឈើដែលមានខ្លឹមមកធ្វើឲ្យជាគំនររងើកភ្លើងមិនមានផ្សែង យើងនឹងអាំងសាច់អ្នកលើរងើកភ្លើងនោះ ហើយបរិភោគ ។

ព្រះមហាសត្វបានធ្វើតាមនោះហើយ ទើបប្រាប់ដល់បោរិសាទ ។ បោរិសាទសម្លឹងមើលកុមារនោះ គិតថា កុមារនេះជាបុរសសីហរាជ មិនខ្លាចសូម្បីតែសេចក្តីស្លាប់ ។ បុគ្គលមិនខ្លាចសេចក្តីស្លាប់យ៉ាងនេះ អញមិនធ្លាប់ឃើញកើតព្រឺរោមព្រឺស្បែក សម្លឹងមើលកុមារ ។ ព្រះរាជកុមារត្រាស់សួរថា អ្នកសម្លឹងមើលយើងធ្វើអ្វី អ្នកមិនធ្វើតាមវាចា ។ យក្ខិនីបុត្តពោលនឹងព្រះមហាសត្វថា បុគ្គលណាស៊ីអ្នក ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគ ។ ព្រះមហាសត្វត្រាស់ថា បើអ្នកមិនបំណងបរិភោគយើង អ្នកឲ្យបង្កាត់ភ្លើងធ្វើអ្វី យក្ខឆ្លើយថា ដើម្បីសម្គុតអ្នក ។ ព្រះរាជកុមារកាលទ្រង់សម្តែងសេចក្តីនោះថា អ្នកនឹងសង្កត់សង្កិនយើងបានដូចម្តេច ក្នុងកាលឥឡូវនេះ ។ យើងសូម្បីកើតក្នុងកំណើតតិរច្ឆាន ក៏គង់មិនឲ្យសក្កទេវរាជសង្កត់សង្កិនបាន ដូច្នេះ ទើបពោលគាថាដូច្នេះថា

អម្បាលដូចជាទន្សាយនោះ កាលសម្គាល់នូវហេតុនេះ បានញុំាងឥន្ទព្រាហ្មណ៍ឲ្យនៅ ( ដើម្បីឲ្យ ) សរីរៈនៃខ្លួន ម្នាលយក្ស ហេតុនោះឯង បានជាចន្ទិមទេវបុត្ត បង្ហូរចេញនូវសេចក្តីប្រាថ្នានោះ មានរូបទន្សាយស្ថិតនៅសព្វថ្ងៃនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា អម្បាលដូចជាទន្សាយ ... បានញុំាងឥន្ទព្រាហ្មណ៍ឲ្យនៅ ( ដើម្បីឲ្យ ) សរីរៈនៃខ្លួន សេចក្តីថា ព្រោះសរីរៈរបស់ខ្លួនជាហេតុ ទន្សាយកាលឲ្យសរីរៈរបស់ខ្លួន ក្នុងសរីរៈរបស់ខ្លួនដោយពោលយ៉ាងនេះថា ចូរអ្នកទំពាស៊ីសរីរៈហើយ ចូរនៅក្នុងទីនេះចុះ

ទើបឲ្យសក្កៈដែលមានរូបជាព្រាហ្មណ៍នោះ នៅក្នុងទីនោះ ។ ពាក្យថា មានរូបទន្សាយ បានដល់ បានទូវការសរសើរដោយសំឡេងថា **សស** យ៉ាងនេះថា **សសី** ( ទន្សាយ ) ដូច្នេះ ។ ពាក្យថា បង្ហូរចេញនូវសេចក្តីប្រាថ្នា បានដល់ ឲ្យបម្រើននូវការពេញ ។ ពាក្យថា ម្នាលយក្ស បានដល់ ទេវតា ។

ព្រះមហាសត្វប្រាប់ថា ទោះបីសក្កទេវរាជដែលធ្វើរូបទន្សាយទុកត្រង់ព្រះចន្ទជាសាក្សី គួរកាន់កាំងតាំងនៅអស់កប្បក៏មិនអាចសម្មតឲ្យខ្ទាចស្លាប់បាន ។ ស្តេចបោរិសាទ បានស្តាប់ដូច្នោះ កើតអស្ចារ្យក្នុងចិត្តមិនធ្លាប់មាន ទើបពោលគាថាថា

ព្រះចន្ទ្រ និងព្រះអាទិត្យរួចអំពីមាត់រាហុ ហើយរុងរឿងក្នុងថ្ងៃ ១៥ កើត យ៉ាងណាមិញ បពិត្រអ្នកមានអានុភាពច្រើន អ្នកបានរួចអំពីយើងឈ្មោះបោរិសាទហើយ ចូររុងរឿងក្នុងក្រុងកបិលពស្តុចុះ រួចចូរញ៉ាំងបិតា និងមាតាឲ្យរីករាយ ទាំងពួកញាតិទាំងអស់របស់អ្នក ក៏ចូរត្រេកអរចុះ ដូច្នេះ ។

ហើយក៏លែងព្រះរាជកុមារទៅដោយទូលថា បពិត្រមហាវីរបុរស សូមលោកត្រឡប់ទៅចុះ ។ ព្រះមហាសត្វ ទ្រង់ធ្វើឲ្យបោរិសាទនោះ អស់ព្យសន៍ហើយ ឲ្យនូវសីល ៥ កាលទ្រង់សាកល្បងមើលថា បោរិសាទនេះជាយក្ខ ឬមិនមែនជាយក្ខ ទើបសន្និដ្ឋានមិនខុស ដូចព្រះសព្វញ្ញុតញ្ញាណដោយការប្រៀបធៀប គឺកាន់យកតាមន័យដូច្នេះ គឺភ្នែកយក្ខមានពណ៌ក្រហម មិនប៉ប្រិច ស្រមោលមិនប្រាកដ មិនតក់ស្លុត បោរិសាទមិនមានសភាពយ៉ាងនោះ

ព្រោះហេតុនោះ ទើបមិនមែនជាយក្ខ ជាមនុស្សនោះឯង បានឮថា ព្រះបិតារបស់អញមានបងប្អូន ៣ អង្គ ត្រូវយក្ខិនីចាប់ទៅ ទាំង ៣ អង្គនោះ ត្រូវយក្ខិនីស៊ីអស់ ២ អង្គ ១ អង្គត្រូវយក្ខិនីចិញ្ចឹមដោយសេចក្តីស្រឡាញ់ដូចជាកូន បោរិសាទនេះ ប្រហែលជាព្រះរាជកុមារអង្គនោះពិត ហើយគិតថា អញនឹងទូលព្រះបិតារបស់អញ ឲ្យតាំងបោរិសាទក្នុងរាជសម្បត្តិ ហើយពោលថា អ្នកមិនមែនជាយក្ខ ជាព្រះជេដ្ឋារបស់បិតាខ្ញុំ មក សូមទ្រង់ទៅជាមួយខ្ញុំ ហើយគ្រងរាជសម្បត្តិដែលជារបស់ត្រកូល ។ ដូចព្រះរាជកុមារពោលថា លោកតា ។ កាលបោរិសាទពោលថា ខ្ញុំមិនមែនមនុស្ស ទើបព្រះរាជកុមារនាំទៅរកតាបសដែលមានភ្នែកទិព្វ ដែលបោរិសាទជឿ ។ កាលតាបសពោលដល់ភាពជាឪពុកកូនថា ឪពុកកូន មកធ្វើអ្វីនៅក្នុងព្រៃ ទើបបោរិសាទជឿ ពោលថា ទៅចុះកូន យើងមិនត្រូវការរាជសម្បត្តិ យើងនឹងបួស ហើយបួសជាឥសីក្នុងសម្នាក់របស់តាបស ដូចព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុបិតាមានសីល ដូចរៀបរាប់មកនេះ តថាគតមិនរក្សា
ជីវិតរបស់តថាគតទេ តថាគតញ៉ាំងបោរិសាទ ជាអ្នកធ្វើអំពើ
បាណាតិបាត ឲ្យវៀរចង់អំពើអាក្រក់សព្វកាល ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សីលវតំ ហេតុ** បានដល់ ព្រោះហេតុនៃរាជបិតារបស់តថាគតជាអ្នកទ្រទ្រង់សីល ។ ម្យ៉ាងទៀត បទថា **សីលវតំ ហេតុ** បានដល់ ព្រោះហេតុនៃការមានសីល ព្រោះការសមាទានសីលវត្តរបស់តថាគតជាហេតុ បានដល់ ដើម្បីមិនឲ្យសីលដាច់ ។ បទថា **តស្ស**

បានដល់ បោរិសាទនោះ ។

លំដាប់នោះ ព្រះមហាសត្វទ្រង់នមស្ការម្ចាស់អឺរបស់ខ្លួនដែលបួសហើយ ត្រឡប់ទៅដល់ព្រះនគរ ព្រះរាជា អ្នកនគរ អ្នកនិគម អ្នកជនបទ បាន ដំណឹងថា ព្រះរាជកុមារត្រឡប់មកហើយ ក៏នាំគ្នាត្រេកអរ ទៅទទួល ព្រះ រាជកុមារថ្វាយបង្គំព្រះរាជាហើយ ទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ព្រះរាជា បានស្តាប់ដូច្នោះហើយ ទើបទ្រង់ត្រាស់ឲ្យវាយស្គរប្រកាសមួយរំពេច ទ្រង់ យាងទៅរកតាបសបោរិសាទនោះដោយបរិវារធំ ហើយត្រាស់ថា បពិត្រម្ចាស់ បង សូមទ្រង់គ្រងរាជសម្បត្តិចុះ តាបសទូលថា កុំឡើយ មហាបពិត្រ ព្រះ រាជាត្រាស់ថា បើដូច្នោះ សូមនិមន្តលោកម្ចាស់នៅក្នុងព្រះរាជឧទ្យានរបស់ ខ្ញុំចុះ ។ តាបសទូលថា អាត្មាមិនទៅឡើយ ព្រះរាជាឲ្យបង្កើតស្រុកក្បែរ អាស្រមនោះហើយ រៀបចំកិច្ចា ស្រុកនោះមានឈ្មោះថា ចូឡកម្មាសទម្ម-និគម ។

ព្រះមាតាព្រះបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាល ឥឡូវនេះ តាបសក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ក្នុងកាលឥឡូវនេះ បោរិសាទក្នុងកាលនោះ បានមកជាអង្គុលីមាល ក្នុងកាលឥឡូវនេះ ព្រះ កនិដ្ឋាក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ អគ្គ-មហេសីក្នុងកាលនោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ អលីន-សត្តុកុមារ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងអលីនសត្តុចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសរបស់

ព្រះពោធិសត្វនោះតាមសមគួរ ដោយន័យដែលពោលមកហើយខាងដើមនោះឯង ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពរបស់ព្រះពោធិសត្វក្នុងចរិយានេះ គឺការដែលព្រះពោធិសត្វត្រូវព្រះបិតាទ្រង់ហាម ក៏នៅតែលះបង់ជីវិតរបស់ខ្លួនដើម្បីរក្សាជីវិតរបស់ព្រះបិតា ទើបសម្រេចព្រះហឫទ័យថា ខ្ញុំនឹងទៅរកបោរិសាទ ។ ការដែលដាក់សស្ត្រាចូលទៅរក ដើម្បីកុំឲ្យបោរិសាទនោះភ័យខ្លាច ការចរចាពាក្យគួរជាទីស្រឡាញ់ ជាមួយបោរិសាទនោះដោយបំណងថា សីលរបស់អាត្មាអញកុំដាច់ឡើយ ការមិនមានការតក់ស្លុតចំពោះសេចក្ដីស្លាប់ ទាំងដែលបោរិសាទនោះសម្លុតដោយន័យផ្សេងៗ ការត្រេកអរថា អញនឹងធ្វើរាងកាយរបស់អញឲ្យមានផលក្នុងប្រយោជន៍របស់បិតា ការដឹងការៈរបស់ខ្លួនដែលមិនគិតដល់ជីវិត ដើម្បីបរិច្ចាគក្នុងជាតិជាទន្សាយសូម្បីតែសក្កៈ ក៏មិនអាចសម្លុតបាន ការមិនមានសភាពខុសប្រក្រតីនៃចិត្តកាលជួបមុខ ឬកាលបោរិសាទនោះដោះលែង ការមិនប្រែក កាលដឹងថាបោរិសាទនោះ ជាមនុស្ស និងជាអាំ ភាពជាអ្នកប្រាថ្នាដើម្បីឲ្យបោរិសាទនោះតាំងនៅក្នុងរាជសម្បត្តិជារបស់ត្រកូល គ្រាន់តែបានស្គាល់គ្នា ការឲ្យបោរិសាទកើតសង្វេគ ក្នុងការសម្ដែងធម៌ ហើយឲ្យតាំងនៅក្នុងសីល ។

**អដ្ឋកថាជយទិសចរិយា ចប់**

# សុត្តន្តបិដក

## សង្ខបាលចរិយាទី ១០

[ ២០ ] មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចនាគឈ្មោះសង្ខបាល មានឫទ្ធិច្រើន មានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក មានអណ្តាតពីរ ជាសត្វគ្រប់សង្កត់ខរគជាតិ ។ តថាគតអធិដ្ឋានអង្គទាំង ៤ ជិតផ្លូវធំ ៤ ជាកន្លែងទៅមកនៃជនផ្សេងៗ ហើយសម្រេចនូវការនៅ ក្នុងទីនោះ ។ បុគ្គលណាមានកិច្ចគួរធ្វើដោយអវយវៈនេះ គឺសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកអវយវៈដែលអញ ឲ្យហើយចុះ ។ កូនព្រានព្រៃទាំងឡាយ ជាមនុស្សរឹងត្អឹងអាក្រក់ ឥតមានសេចក្តីអាណិតអាសូរ មានដំបង ៤ ជ្រងក្នុងដៃ បានឃើញតថាគតហើយ ដើរចូលទៅមកក្នុងទីនោះ កូនព្រានព្រៃទាំងឡាយ បានចោះតថាគតត្រង់ប្រមុះ កន្ទុយ ខ្នងនិង-ក ហើយលើកតថាគតដាក់ក្នុងសង្រែករែកយកទៅ ។ តថាគតបើប្រាថ្នានឹងធ្វើនូវមហាប្រឹថពី ដែលមានសមុទ្រជាទីបំផុត ព្រមទាំងឈើព្រៃ ព្រមទាំងភ្នំឲ្យឆេះខ្ទេចទៅជាផេះ ដោយខ្យល់តាមប្រមុះ ក្នុងទីនោះក៏បាន ។ ( ប៉ុន្តែ ) តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួចនឹងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត ។

សង្ខបាលចរិយាទី ១០ ចប់

**ឧទ្ទាននៃចរិយានោះ**

សីលវនាគចរិយា ១ ភូរិទត្តចរិយា ១ ចម្បេយ្យចរិយា ១ ចូឡពោធិចរិយា ១ មហិសរាជចរិយា ១ រុរុមិគចរិយា ១ មាតង្គចរិយា ១ ធម្មទេវបុត្តចរិយា ១ ជយទិសចរិយា ១ សង្ខបាលចរិយា ១ ។ ចរិយាទាំងអស់នោះ តថាគតសម្តែងហើយថា មានសីលជាកម្លាំង ជាបរិក្ខារ តថាគតបានគ្រប់គ្រងជីវិតរក្សាសីល ។ កាលតថាគតជាសង្ខបាលនាគរាជ បានប្រគល់ជីវិតឲ្យដល់បុគ្គលណាមួយ សព្វៗ កាល ហេតុនោះ បារមីនោះ ជាសីលបរមត្ថបារមី ( នៃតថាគត ) ។

**សីលបារមីនិទ្ទេស ចប់**

# អដ្ឋកថា

## សង្ខបាលចរិយា

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខបាលចរិយាទី ១០ ដូចតទៅ នេះថា សេចក្តីសង្ខេបក្នុងបទថា **សង្ខបាលោ** ជាដើម មានដូច្នេះ ឈ្មោះថា **មហិទ្ធិកោ** ព្រោះប្រកបដោយឫទ្ធិរបស់មហានាគ ដូចគ្នានឹងភោគសម្បត្តិរបស់ទេវតា ។ ឈ្មោះថា **ចាតុទ្ធសោ** ព្រោះមានចង្កូម ៤ ជាអាវុធ គឺខាងក្រោម ២ ខាងលើ ២ ។ ឈ្មោះថា **ឃោរវិសោ** ព្រោះគេជះនៃពិសខ្លាំង ។ ឈ្មោះថា **ទ្វិជិវ្ហោ** ព្រោះប្រកបដោយអណ្តាតបែកជាពីរ សម្រេចមកអំពីកំណើតរបស់នាគ ។ ឈ្មោះថា **ឧរគាធិភូ** ព្រោះភាពជាធំជាងនាគទាំងឡាយ សូម្បីមានអានុភាពច្រើន ក៏បានឈ្មោះថា **ឧរគ** ព្រោះទៅដោយទ្រូង ។ បទថា **ចតុប្បថេ** បានដល់ ក្នុងទីនោះ ផ្លូវពីរខ្វែងប្រសព្វគ្នា ។ បទថា **មហាមគ្គេ** បានដល់ ជាទីដែលមហាជនសញ្ចរទៅមក ជានិច្ចជាកាល ។ បទថា **នានាជនសមាកុលេ** បានដល់ ព្រោះទីនោះ មានមហាជនច្រើន ។ បទថា **ចតុរោ អង្គេ** បានដល់ ដោយអំណាចនៃអង្គ ៤ ដែលនឹងពោលក្នុងឥឡូវនេះ ។ បទថា **អធិដ្ឋាយ** បានដល់ អធិដ្ឋាន គឺការតាំងចិត្ត ។ កាលណាតថាគត ជានាគមានរូប តាមដែលពោលហើយ ឈ្មោះថា **សង្ខបាល** កាលនោះ តថាគតសម្រេចការនៅក្នុងទីដូចពោលហើយខាងដើម គឺសម្រេចការនៅ ដោយការរក្សាឧបោសថ ។

ពិតហើយ ព្រះមហាសត្វជាអ្នកខ្វល់ខ្វាយក្នុងបុណ្យ មានទាន និងសីល

ជាដើម អន្ទោលទៅក្នុងគតិរបស់ទេវតា និងមនុស្សទាំងឡាយ ដោយការស្វែងរកពោធិញ្ញាណ ជួនកាលកើតក្នុងនាគពិភព ដែលមានសម្បត្តិដូចគ្នានឹងសម្បត្តិរបស់ទេវតា ជានាគឈ្មោះសង្ខបាល មានឫទ្ធិច្រើន មានអានុភាពច្រើន ។ នាគរាជនោះ កាលកន្លងទៅ រង្កៀសសម្បត្តិនោះ ប្រាថ្នាកំណើតមនុស្ស ទើបរក្សាឧបោសថ ។ កាលនាគរាជនោះនៅក្នុងនាគពិភព ការរក្សាឧបោសថមិនបរិបូណ៌ សីលនឹងសៅហ្មង ដោយហេតុនោះ ទើបនាគរាជចេញអំពីនាគពិភព ឆ្ងាយរង្វេលលើដំបូកមួយកន្លែង ក្នុងរវាងផ្លូវធំ និងផ្លូវដើរបានតែមនុស្សម្នាក់ មិនឆ្ងាយអំពីស្ទឹងឈ្មោះកណ្ណវណ្ណា ហើយអធិដ្ឋានឧបោសថសមាទានក្នុងថ្ងៃ ១៤-១៥ ជាប្រក្រតី អធិដ្ឋានថា បុគ្គលត្រូវការស្បែកជាដើមរបស់អាត្មាអញ ចូរយកទៅចុះ លះខ្លួនឲ្យជាទាន ហើយដេក ។ ក្នុងថ្ងៃ ១ កើត ១ រោច ទើបទៅកាន់នាគពិភព ដូចព្រះមានព្រះភាគត្រាស់ថា មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចនាគឈ្មោះសង្ខបាល ដូច្នេះជាដើម ។ អត្ថនៃគាថានោះ លោកបានពោលហើយនោះឯង ។

លោកពោលបទថា **ចតុរោ អង្គេ អធិដ្ឋាយ** ដែលមានពាក្យថា សម្បូរថ្ងៃ ស្បែកជាដើមទុកក្នុងទីនេះ ជាការសម្តែងដល់អធិដ្ឋានមានអង្គ ៤ ព្រោះស្បែកជាអង្គមួយក្នុងទីនេះ ។ កាលព្រះមហាសត្វនៅរក្សាឧបោសថយ៉ាងនេះ ពេលវេលាកន្លងទៅអស់កាលយូរ ។

ថ្ងៃមួយ កាលសង្ខបាលនាគរាជសមាទានសីលយ៉ាងនោះហើយ ដេក កូនរបស់ព្រាន ១៦ នាក់គិតគ្នាថា យើងនឹងរកម្រឹគ ទើបកាន់អាវុធត្រាច់ទៅ

ក្នុងព្រៃ កាលមិនបានសត្វណាមួយក៏ត្រឡប់មក ឃើញនាគនោះដេកលើកំពូលដំបូក គិតថា ថ្ងៃនេះ យើងមិនបានសត្វអ្វីសោះ សូម្បីតែកូនទន្សោងយើងនឹងសម្លាប់នាគនេះបរិភោគ តែនាគនេះធំណាស់ បើយើងចូលទៅចាប់គង់គេចទៅ ហើយគិតគ្នាថា យើងនឹងយកស្នចាក់នាគរាជនោះ ដែលកំពុងដេកនោះឯងត្រង់រង្វេល ធ្វើឲ្យខ្សោយកម្លាំងហើយសឹមចាប់ ទើបកាន់ស្នចូលទៅរក ។ ព្រះពោធិសត្វមានរាងកាយធំប្រមាណប៉ុនទូកកម្រោល ដូចកម្រងផ្កាម្លិះ ដែលគេក្រងល្អក្រៃលែង ប្រកបដោយកែវភ្នែក ដូចគ្នានឹងផ្លែទំពាំងជូរ ក្បាលដូចគ្នានឹងផ្កាច្បា នាគរាជនោះ អើតក្បាលអំពីរង្វេល ព្រោះឮសូរជើងរបស់ជនទាំង ១៦ នាក់នោះ បើកភ្នែកពណ៌ក្រហម ឃើញមនុស្ស ១៦ នាក់កាន់ស្នដើរចូលមក គិតថា ថ្ងៃនេះ សេចក្តីប្រាថ្នារបស់អញនឹងដល់ទីបំផុត បានប្រគល់ខ្លួនឲ្យជាទានហើយ តាំងចិត្តអធិដ្ឋានយ៉ាងមាំទាំ ព្រោះខ្លាចសីលរបស់ខ្លួនដាច់ថា អញមិនសម្លឹងមើលជនទាំងនេះ ដែលយកស្នចាក់រាងកាយរបស់អញ ធ្វើឲ្យជាប្រហោងតូចធំ ទើបដាក់ក្បាលចូលទៅក្នុងរង្វេល ដេកបន្តទៀត ។

លំដាប់នោះ បុត្រព្រានទាំងនោះ ចូលទៅចាប់នាគរាជនោះត្រង់កន្ទុយទាញចុះមកធ្លាក់លើផែនដី យកស្នដែលមានមុខស្រួចចាក់ក្នុងទី ៨ កន្លែងស៊កផ្តៅទាំងបន្លា ចូលទៅត្រង់មុខរបួស យកដងរែក ៨ សែងដើរទៅកាន់ផ្លូវធំ ។ ព្រះមហាសត្វតាំងអំពីត្រូវចាក់ដោយស្ន ក៏បិទភ្នែក មិនសម្លឹងមើលកូនព្រានទាំងនោះ ក្នុងទីណាមួយឡើយ ។ នាគរាជនោះ កាលព្រានយក

ដងវែក ៨ សែងនាំទៅ ក្បាលនាគអូសនឹងផែនដី លំដាប់នោះ កូនព្រាន ទាំងឡាយឃើញក្បាលនាគសំយុងចុះ ក៏ឲ្យនាគរាជនោះដេកត្រង់ផ្លូវធំ ហើយ យកស្នូចាក់ត្រង់ច្រមុះ ដោតខ្សែចូលទៅ លើកក្បាលឡើងហើយពាក់ត្រង់ចុង ដងវែក សែងបន្តដំណើរទៅទៀត ដូចព្រះមានព្រះភាគត្រាស់ថា

កូនព្រានព្រៃទាំងឡាយ ជាមនុស្សរឹងត្អឹងអាក្រក់ ឥតមានសេចក្តី អាណិតអាសូរ មានដំបង ៤ ជ្រុងក្នុងដៃ បានឃើញតថាគត ហើយ ដើរចូលទៅមកក្នុងទីនោះ កូនព្រានព្រៃទាំងឡាយ បាន ចោះតថាគតត្រង់ច្រមុះ កន្ទុយ ខ្នង និង-ក ហើយលើកតថាគត ដាក់ក្នុងសង្រែក វែកយកទៅ ។ តថាគត បើប្រាថ្នានឹងធ្វើនូវ មហាប្រឹថពី ដែលមានសមុទ្រជាទីបំផុត ព្រមទាំងឈើព្រៃ ព្រម ទាំងភ្នំឲ្យឆេះខ្ទេចទៅជាផេះ ដោយខ្យល់តាមច្រមុះ ក្នុងទីនោះ ក៏បាន ។ ( ប៉ុន្តែ ) តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច និងចាក់ដោយលំពែងទាំងឡាយ ឡើយ នេះជាសីលបារមីរបស់តថាគត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភោជបុត្តា** បានដល់ កូនព្រាន ។ បទថា **ខរា** បានដល់ រឹងត្អឹង គឺមានកាយកម្ម និងវចីកម្មគ្រោតគ្រាត ។ បទថា ... បានដល់ អាក្រក់ គឺមានចិត្តកាច ។ បទថា **អការុណា** គឺមិនមានសេចក្តី អាណិតអាសូរ ។ បទថា **ធណ្ឌមុគ្គរបាណិនោ** បានដល់ កាន់ដំបងមាន ជ្រុង ៤ ។ បទថា **ឆាសាយ វិនិវិជ្ឈិត្វា** បានដល់ យកស្នូចាក់តថាគត

ត្រង់ប្រមុះ ដើម្បីដោតខ្សែចូលទៅ ។ បទថា **ឆន្ដុដ្ឋេ បិដ្ឋិកណ្ដកេ** គប្បី ជ្រាបការភ្ជាប់សេចក្ដីថា ចាក់ត្រង់កន្ទុយ និងទីនោះៗ ដែលជិតនឹងឆ្អឹងខ្នង ។ បទថា **កាជេ អារោបយិត្វាន** សេចក្ដីថា កូនព្រានម្នាង ២ នាក់លើកជងរែកម្នាក់ម្នាង ត្រង់ទីដែលចាក់មួយកន្លែងៗ ក្នុងបរិវេណរបស់ផ្ដៅ និងវល្លិ ៨ កន្លែង ដែលចាក់ក្នុងទីទាំង ៨ ដាក់លើស្មារៀងៗ ខ្លួន ។ បទថា **សសាគរន្តំ បថវឹ** បានដល់ មហាប្រឹថពីដែលមានសាគរជាទីបំផុត ។ បទថា **សកាននំ សបព្វតំ** បានដល់ មួយអន្លើដោយព្រៃ និងភ្នំ ។ បទថា **នាសាវាតេន ឈាបយេ** សេចក្ដីថា បើតថាគតត្រូវការ ឬប្រាថ្នាក្រោធហើយ គប្បីបញ្ចេញខ្យល់ច្រមុះ ញាំងមហាប្រឹថពីនេះ ដែលមានមហាសមុទ្រជាទីបំផុត មួយអន្លើដោយព្រៃ និងភ្នំឲ្យឆេះ គឺគប្បីធ្វើឲ្យក្លាយជាផេះ មួយអន្លើដោយការបញ្ចេញខ្យល់ច្រមុះ ក្នុងកាលនោះ អានុភាពរបស់តថាគត មានសភាពបែបនេះ កាលបើយ៉ាងនោះ ទោះបីចាក់ដោយស្នួ ឬចាក់ដោយលំពែង ។ បទថា **ភោជបុត្តេ ន កុប្បាមិ** សេចក្ដីថា តថាគតមិនក្រោធកូនព្រានដែលកាច សូម្បីចាក់ដោយឈើអណ្ដោតដ៏មុត ដែលចាំងធ្វើដោយឈើខ្លឹម ដើម្បីធ្វើឲ្យអស់កម្លាំង កាលសិកផ្ដៅ និងវល្លិចូលទៅក្នុងទី ៨ កន្លែង និងចាក់ដោយស្នួដ៏មុត ដើម្បីឲ្យអស់កម្លាំងក្នុងទីនោះៗ ។ បទថា **ឯសា មេ សីល–បារមី** សេចក្ដីថា ការដែលតថាគតមានអានុភាពច្រើនយ៉ាងនេះ អធិដ្ឋានយ៉ាងនោះ មិនក្រោធនឹងកូនព្រាន ព្រោះខ្លាចសីលដាច់ នេះជាសីលបារមីរបស់តថាគត ដែលប្រព្រឹត្តទៅហើយ ដោយការមិនគិតដល់ជីវិត ដោយ

ចំណែកមួយប៉ុណ្ណោះ អធិប្បាយថា ជាបរមត្ថបារមី ដោយអំណាចរបស់សីល ។

ម្យ៉ាងទៀត កាលព្រះពោធិសត្វត្រូវកូនព្រានទាំទៅ កុដុម្ពិកៈឈ្មោះថា អាឡារៈអ្នកមិថិលានគរនាំរទេះ ៥០០ អង្គុយលើយានដ៏សុខស្រួល ឃើញពួកកូនព្រានទាំងនោះ កំពុងនាំព្រះមហាសត្វទៅ ក៏កើតសេចក្ដីករុណា សួរព្រានទាំងនោះថា ពួកអ្នកនាំយកនាគរាជនេះទៅធ្វើអ្វី ពួកអ្នកនាំយកនាគរាជនេះទៅធ្វើអ្វី ពួកព្រានឆ្លើយថា ពួកយើងនឹងអាំងសាច់ដ៏ឆ្ងាញ់ ជាសាច់ខ្ទិរបស់នាគនេះបរិភោគ ។ កុដុម្ពិកៈនោះ ក៏ឲ្យគោឈ្មោល ១៦ មាសម្នាក់មួយទូកដៃ ដល់កូនព្រានទាំងនោះ មួយអន្ទើដោយសំពត់ដណ្ដប់ដល់កិរិយាជនទាំងនោះ និងឲ្យវត្ថុជាទីពេញចិត្តដល់កូនព្រានហើយ ពោលថា នាគនេះ ជានាគរាជមានអានុភាពច្រើនដោយប្រពៃ មិនប្រទូស្តដល់ពួកអ្នក ដោយសីលគុណរបស់ខ្លួន ពួកអ្នកធ្វើនាគរាជនេះឲ្យលំបាក នឹងមានបាបច្រើន សូមអ្នកលែងនាគនេះចុះ កូនព្រានទាំងនោះពោលថា នាគនេះ ជាអាហារឆ្ងាញ់របស់ពួកយើង ពួកយើងមិនធ្លាប់ស៊ីសាច់នាគឡើយ ណ្ហើយចុះ ពួកយើងរាប់អានវាចារបស់អ្នក ព្រោះហេតុនោះ យើងនឹងលែងនាគនេះ ហើយឲ្យព្រះមហាសត្វដេកលើផែនដី ព្រោះអំពីគ្រោតគ្រាតរបស់ខ្លួន ទើបចាប់ត្រង់ចុងផ្ដៅ និងវល្លិប្រេងដែលដោតទាំងបន្ទា ប្រុងប្រៀបនឹងកញ្ឆក់ចេញ ។

លំដាប់នោះ កុដុម្ពិកៈឃើញនាគលំបាក ទើបធ្វើមិនឲ្យលំបាកដោយការយកដាវកាត់វល្លិថ្នមៗ ទាញចេញមិនឲ្យឈឺចាប់ ដូចគ្នានឹងនាំនូវគ្រឿងចោះ

ត្រចៀករបស់ទារកទាំងឡាយចេញ ។ ក្នុងកាលនោះ កូនព្រានទាំងឡាយនាំគ្នាទាញចំណងសន្ទឹមៗ ចេញអំពីច្រមុះរបស់នាគរាជនោះ ។ មួយសម្មុះព្រះមហាសត្វក៏បែរមុខទៅកាន់ទិសខាងកើត សម្លឹងមើលអាឡារកុដុម្ពិកៈដោយភ្នែកពេញដោយទឹកភ្នែក ។ ពួកព្រានទៅបានបន្តិច ពួនប្រឹក្សាគ្នាថានាគខ្សោយកម្លាំង កាលនាគស្លាប់ ពួកយើងនឹងយកនាគនោះទៅ ។ អាឡារ-កុដុម្ពិកៈ ថ្វាយបង្គំព្រះមហាសត្វ ពោលថា ទៅចុះមហានាគ ពួកព្រានមិនចាប់អ្នកទៀតឡើយ តាមជូនដំណើរនាគរាជនោះទៅបន្តិច ហើយត្រឡប់ ។

ព្រះពោធិសត្វទៅកាន់នាគពិភព មិនធ្វើឲ្យខូចពេលវេលាក្នុងនាគពិភពនោះ ចេញទៅមួយអន្ទើដោយបរិវារធំចូលទៅរកអាឡារៈ ពណ៌នាគុណរបស់នាគពិភព ហើយនាំអាឡារៈទៅកាន់នាគពិភពនោះ ឲ្យនូវយសធំ មួយអន្ទើដោយនាគកញ្ញា ៣០០ ដល់អាឡារៈ ហើយប្រតិបត្តិដោយកាមទិព្វ ។ អាឡារៈនៅក្នុងនាគពិភពបាន ១ ឆ្នាំ បរិភោគកាមទិព្វ ទើបប្រាប់ដល់នាគថានែសម្លាញ់ ខ្ញុំប្រាថ្នានឹងបួស ទើបកាន់យកបរិក្ខាររបស់បព្វជិត ចេញអំពីនាគពិភពនោះ ទៅកាន់ហិមវន្តប្បទេស ហើយបួស អាស្រ័យនៅក្នុងហិម-វន្តប្បទេសនោះអស់កាលដ៏យូរ តមក ចារិកទៅដល់ក្រុងពារាណសី ព្រះបាទក្រុងពារាណសីទតឃើញ ទ្រង់ជ្រះថ្លានឹងអាចារសម្បត្តិ ទើបត្រាស់សួរថា លោកម្ចាស់ប្រហែលជាបួសអំពីត្រកូលដែលមានសម្បត្តិច្រើន លោកម្ចាស់បួសព្រោះហេតុអ្វី កាលទូលដល់ហេតុដែលខ្លួនបួស ទើបទូលរឿងទាំងអស់ តាំងអំពីការសូមឲ្យពួកព្រានដោះលែងព្រះពោធិសត្វ អំពីកណ្តាប់ដៃ

ដល់ព្រះរាជា ហើយសម្តែងធម៌ដោយគាថាទាំងឡាយថា

បពិត្រព្រះរាជា កាមគុណទាំងឡាយ សូម្បីជារបស់មនុស្ស អាត្មាភាពបានឃើញហើយ ថាជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា លុះអាត្មាភាពឃើញទោស ក្នុងកាមគុណទាំងឡាយ ទើបបួសដោយសទ្ធា ។ បពិត្រព្រះរាជា មនុស្សទាំងឡាយ ក្មេងក្តី ចាស់ក្តី កាលមានសរីរៈបែកធ្លាយហើយ រមែងធ្លាក់ចុះ ដូចជាផ្លែឈើទាំងឡាយ ដូច្នោះដែរ អាត្មាភាពឃើញហេតុនេះហើយ ទើបចេញបួស សាមញ្ញគុណ គឺបព្វជ្ជា ជាធម៌ប្រតិបត្តិមិនខុស ជាធម៌ដ៏ប្រសើរ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ថា

ពួកជនណា មានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រអាឡារតាបស ខ្ញុំនឹងធ្វើនូវបុណ្យដ៏ច្រើន ព្រោះបានស្តាប់ ( នូវពាក្យ ) របស់នាគរាជផង របស់លោកផង ។

លំដាប់នោះ តាបសសម្តែងធម៌ថ្វាយព្រះរាជាយ៉ាងនេះថា

ពួកជនណា មានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រព្រះរាជា ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាព និងនាគហើយ សូមព្រះអង្គធ្វើបុណ្យឲ្យច្រើន ដូច្នេះ ។

តាបសស្នាក់នៅក្នុងក្រុងពារាណសីនោះ អស់ ៤ ខែ ក្នុងរដូវភ្លៀង ហើយទៅកាន់ហិមវន្តប្បទេស ចម្រើនព្រហ្មវិហារ ៤ ដរាបដល់អស់ជីវិត ក៏បានចូលដល់ព្រហ្មលោក ព្រះពោធិសត្វក៏រក្សាឧបោសថដរាបដល់អស់ជីវិត បានទៅកាន់ស្ថានសួគ៌ ។ ព្រះរាជានោះ ក៏ទ្រង់ធ្វើបុណ្យ មានទានជាដើម ហើយ ក៏ទៅតាមយថាកម្ម ។

អាឡារៈ ក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ក្នុងកាលឥឡូវនេះ ព្រះបាទពារាណសី ក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ សង្ខបាលនាគរាជ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ការបរិច្ចាគសរីរៈរបស់នាគរាជនោះ ជាទានបារមី ការដែលនាគរាជប្រកបដោយតេជះ មានពិសបែបនោះ កាលមានការបៀតបៀនដល់ម្ល៉ោះ ក៏មិនទម្លាយសីល ឈ្មោះថា សីលបារមី ។ ការលះភោគសម្បត្តិ ដូចគ្នានឹងភោគសម្បត្តិរបស់ទេវតា ហើយចេញអំពីនាគពិភពបំពេញសមណធម៌ ឈ្មោះថា នេក្ខម្មបារមី ការត្រៀមខ្លួនថា គួរធ្វើប្រយោជន៍ មានទានជាដើម និងវត្តនេះៗ ឈ្មោះថា បញ្ញាបារមី ។ ការបន្ទោបង់កាមវិតក្ក និងសេចក្ដីព្យាយាមដោយការអត់សង្កត់ ឈ្មោះថា វិរិយបារមី ការអត់ធន់ ដោយការអត់ធ្មត់ ឈ្មោះថា ខន្តិបារមី ការសមាទានសច្ចៈ ឈ្មោះថា សច្ចបារមី ការតាំងចិត្តសមាទាន មិនញាប់ញ័រ ឈ្មោះថា អធិដ្ឋានបារមី ។ ភាពជាអ្នកមានមេត្តា និងការអាណិតអាសូរក្នុងសព្វសត្វទាំងឡាយ សំដៅដល់ពួកកូន

ព្រាន ឈ្មោះថា មេត្តាបារមី ។ ភាពជាកណ្តាលក្នុងវេទនា និងការខុស ប្រក្រតីដែលធ្វើហើយក្នុងសត្វ និងសង្ខារទាំងឡាយ ឈ្មោះថា ឧបេក្ខាបារមី ជាការបានបារមី ១០ យ៉ាងនេះ ដោយប្រការដូច្នេះ ។ តែសីលបារមីប៉ុណ្ណោះ ដែលលោកលើកឡើងកាន់ទេសនា ធ្វើឲ្យជាបារមី មានភាពកំពូលយ៉ាង ក្រៃលែង ។ ម្យ៉ាងទៀត គុណានុភាពរបស់ព្រះពោធិសត្វក្នុងចរិយានេះ គប្បី ប្រកាសដោយន័យដូចពោលហើយ ក្នុងភូរិទត្តចរិយាថា ក្នុងទីតាំង នាគពិភពប្រមាណ ១០០ យោជន៍ ដូច្នេះជាដើម ។៚

## អដ្ឋកថាសង្ខបាលចរិយា ចប់

បទថា **ឯតេ** បានដល់ ចរិយា មានហត្ថិនាគចរិយាជាដើម ដែល សម្តែងហើយក្នុងវគ្គនេះ និងចរិយា ៩ ដែលសម្តែងសរុបដោយមាតិកា ជាដើមថា **ហត្ថិ នាគោ ភូរិទត្តោ** ដោយគាថាបន្តគ្នាមក ហត្ថិនាគចរិយា ភូរិទត្តចរិយា ពួកណា ទាំងអស់នោះ ឈ្មោះថា **សីលពលា** ព្រោះមានសីល ជាកម្លាំង ដោយការប្រព្រឹត្តទៅ ដោយការបំពេញសីលបារមីជាពិសេស ។ ឈ្មោះថា **បរិក្ខារា** ព្រោះទំនុកបម្រុងសីលដែលជាបរមត្ថបារមី និងព្រោះ ទំនុកបម្រុងសន្តាន ដោយអំណាចការអប់រំ ។ ឈ្មោះថា **បទេសិកា** គឺនៅ មានការលះបង់ឲ្យ ព្រោះសីលបរមត្ថបារមី ដែលដល់នូវភាពឧក្រិដ្ឋ គង់មិន

សម្បូរ គឺមិនឲ្យក៏មិនមែន បើសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះរក្សាជីវិត ហើយនឹងតាមរក្សាសីល ។ លោកសម្តែងថា ព្រោះបណ្តាចរិយាទាំងឡាយ មានហត្ថិនាគចរិយាជាដើមនោះ តថាគតរក្សាជីវិតរបស់ខ្លួនដោយឯកទេសប៉ុណ្ណោះ ហើយតាមរក្សាសីល ។ តថាគតមិនបានលះបង់ជីវិតដោយប្រការទាំងពួងឡើយ តែកាលតថាគតជាសង្ខបាលនាគរាជ បានលះបង់ជីវិតឲ្យបុគ្គលណាមួយ ក៏បានសព្វកាលជានិច្ច តែកាលតថាគតជាសង្ខបាលនាគរាជ មានអានុភាពច្រើន មានតេជះ គឺពិសដ៏ខ្លាំងខ្លាស់ ជីវិតរបស់តថាគត ត្រូវព្រានទាំងនោះ ដែលមិនបានចែកបុគ្គលទាំងមុន ទាំងក្រោយ រួមគ្នានាំទៅដោយចំណែកមួយប៉ុណ្ណោះ តថាគតលះបង់ជីវិតដែលត្រូវគេនាំទៅយ៉ាងនោះឲ្យជាទាន ដើម្បីតាមរក្សាសីលប៉ុណ្ណោះ ព្រោះហេតុនោះ ចរិយានោះ ដល់នូវភាពជាបរមត្ថបារមី ដែលជាសីលបារមីរបស់តថាគត ដោយប្រការដូច្នេះ ។

នេះជាការបង្អួលបង្ហាញដល់សីលបារមីដោយវិសេស ដែលសង្គ្រោះចូលក្នុងចរិយា ១០ យ៉ាង ៕

**អដ្ឋកថាទុតិយវគ្គ ចប់**

# សុត្តន្តបិដក
# នេក្ខម្មាធិបារមី

## យុធញ្ជយចរិយាទី ១

[ ២១ ] កាលដែលតថាគតកើតជារាជបុត្រ ( នៃស្តេចសព្វទត្ត ) ឈ្មោះយុធញ្ជ័យ ជារាជកុមារមានបរិវារ និងយស រាប់មិនបាន ក្នុងកាលនោះ តថាគតកើតសេចក្តីសង្វេគ ព្រោះឃើញតំណក់ទឹកសន្សើម ដែលរីងហួតដោយកម្តៅព្រះអាទិត្យ ។ តថាគតយកតំណក់ទឹកសន្សើមនោះ ជាអធិបតី ចម្រើននូវសេចក្តីសង្វេគ ថ្វាយបង្គំព្រះមាតា និងព្រះបិតា ហើយសូមបព្វជ្ជា ។ ពួករាជបុរស ព្រមទាំងអ្នកនិគម អ្នកនៅក្នុងដែន ផ្គងអញ្ជលីអង្វរតថាគតថា បពិត្រព្រះរាជបុត្រ សូមព្រះអង្គម្ចាស់គ្រប់គ្រងមហាប្រឹថពី ដែលសម្រេចដោយសម្បត្តិដ៏ស្តុកស្តម្ភ ក្នុងថ្ងៃនេះចុះ ។ តថាគតមិនមានអាល័យ លះបង់រាជបុរស ព្រមទាំងស្តេច ស្រីស្នំ អ្នកនិគម និងអ្នកនៅក្នុងដែន ដែលកំពុងខ្សឹកខ្សួល គួរឲ្យអាណិត ។ តថាគតលះបង់រាជ្យលើផែនដី ញាតិ ជនជាបរិស័ទ និងយសទាំង

អស់ ឥតមានគិតដល់ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។ មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ។

## យុធញ្ជយចរិយាទី ១ ចប់

# អដ្ឋកថា

# យុធញ្ជយវគ្គ

## យុធញ្ជយចរិយា

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយុធញ្ជយចរិយាទី ១ នៃវគ្គទី ៣ ដូចតទៅនេះ បទថា **អមិតយសោ** បានដល់ មានបរិវារ និងសម្បត្តិប្រមាណមិនបាន ។ បទថា **រាជបុត្តោ យុធញ្ជយោ** បានដល់ មានឈ្មោះថា យុធញ្ជយ ជាឱរសរបស់ព្រះរាជា ព្រះនាមសព្វទត្តៈ ក្នុងរម្មនគរ ។

ក្រុងពារាណសីនេះ ក្នុងឧទយជាតក ឈ្មោះថា សុរុន្ធនគរ ក្នុងចូឡសុត្តសោមជាតក ឈ្មោះថា សុទស្សននគរ ក្នុងសោណនន្ទជាតក ឈ្មោះថា ព្រហ្មវឌ្ឍននគរ ក្នុងខណ្ឌហាលជាតក ឈ្មោះថា បុប្ផវតីនគរ តែក្នុងយុធញ្ជយជាតក ឈ្មោះថា រម្មនគរ ។ ជួនកាល ឈ្មោះរបស់នគរនេះប្រែប្រួលទៅយ៉ាងនេះ ដូចលោកពោលថា ព្រះរាជបុត្រជាឱរសរបស់ព្រះរាជាព្រះនាមសព្វទត្តៈ ក្នុងរម្មនគរ ។ ព្រះរាជាអង្គនោះ មានព្រះរាជឱរស ១ ពាន់អង្គ ព្រះពោធិសត្វជាឱរសច្បង ព្រះរាជាទ្រង់ប្រទានតំណែងឧបរាជឲ្យ ។ ព្រះរាជឱរសនោះ ទ្រង់ឲ្យទានរាល់ៗ ថ្ងៃ តាមន័យដូចពោលហើយខាងដើមនោះឯង ។

ពេលវេលាកន្លងទៅយ៉ាងនេះ ថ្ងៃមួយ ព្រះពោធិសត្វឡើងប្រថាប់លើរថដ៏ប្រសើរអំពីព្រលឹម យាងប្រពាសព្រះរាជឧទ្យាន ដោយយសសម្បត្តិ

និងសិរីដ៏ធំ ទតឃើញដំណក់ទឹកសន្សើមដែលជាប់លើត្រួយឈើ ចុងស្មៅ មែកឈើ និងត្រង់សម្បុកពីងពាំងជាដើម មានលក្ខណៈដូចបណ្ដាញកែវមុក្តា ត្រាស់សួរថា ម្នាលសារថី នុ៎ះជាអ្វី កាលទ្រង់ស្ដាប់ថា នុ៎ះគឺដំណក់ទឹកសន្សើម ដែលធ្លាក់ក្នុងពេលមានសន្សើម ។ ព្រះរាជា ទ្រង់រវល់សប្បាយរីករាយក្នុង ព្រះរាជឧទ្យានអស់មួយថ្ងៃ លុះដល់ពេលល្ងាចក៏យាងត្រឡប់ ទ្រង់មិនឃើញ ដំណក់ទឹកសន្សើមទាំងនោះ ទើបត្រាស់សួរថា នែសារថី ដំណក់ទឹកសន្សើម នោះ បាត់ទៅណាអស់ហ្ន៎ ឥឡូវនេះ យើងមិនឃើញដំណក់ទឹកសន្សើមទាំង នោះ កាលទ្រង់ស្ដាប់ថា កាលព្រះអាទិត្យរះ ដំណក់ទឹកសន្សើមទាំងអស់ ក៏រីងស្ងួតទៅ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ដំណក់ទឹកសន្សើមទាំងនេះ កើត ឡើងហើយ រីងស្ងួតទៅ យ៉ាងណា សូម្បីសង្ខារ គឺជីវិតរបស់សត្វទាំង ឡាយ ក៏យ៉ាងនោះ ដូចគ្នានឹងដំណក់ទឹកសន្សើមត្រង់ចុងស្មៅ ព្រោះហេតុ នោះ អាត្មាអញដែលមិនទាន់ព្យាធិ មិនទាន់ជរា និងមរណៈបៀតបៀន គួរ លាព្រះមាតាបិតាចេញបួស ទើបទ្រង់ធ្វើដំណក់ទឹកសន្សើមនោះ ឲ្យជាអា-រម្មណ៍ ឃើញភពទាំង ៣ ដូចត្រូវភ្លើងឆេះ យាងមកកាន់ដំណាក់របស់ ព្រះអង្គ ចូលទៅគាល់ព្រះបិតាដែលប្រថាប់នៅក្នុងរោងវិនិច្ឆ័យ ដែលប្រដាប់ តាក់តែងយ៉ាងល្អ ថ្វាយបង្គំព្រះបិតា ប្រថាប់ឈរក្នុងចំណែកម្ខាង ទូល សូមបួស ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតកើតសេចក្ដីសង្វេគ ព្រោះឃើញដំណក់ទឹកសន្សើមដែល
រីងហួតដោយកម្ដៅព្រះអាទិត្យ ។ តថាគតយកដំណក់ទឹកសន្សើម

នោះ ជាអធិបតី ចម្រើននូវសេចក្ដីសង្វេគ ថ្វាយបង្គំព្រះមាតា និងព្រះបិតា ហើយសូមបព្វជ្ជា ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សូរិយាតបេ** សេចក្ដីថា ព្រោះហេតុ គឺពន្លឺព្រះអាទិត្យ គឺព្រោះការប៉ះត្រូវនៃរស្មីព្រះអាទិត្យ ។ បាឋៈថា **សូរយាតបេន** ដូច្នេះក៏មាន ។ បទថា **បតិតំ ទិស្វាន** សេចក្ដីថា ព្រោះទ្រង់ឃើញដំណក់ទឹកសន្សើមរីងស្ងួតទៅ គឺព្រោះសម្លឹងមើលដំណក់ទឹកសន្សើមដែលដក់លើត្រួយឈើជាដើម កាលមុននៅប្រាកដនៅឡើយ លុះត្រូវរស្មីព្រះអាទិត្យក៏ហួតហែងទៅ ដោយបញ្ញាចក្ខុ ។ បទថា **សំវេជី** សេចក្ដីថា ដល់នូវសេចក្ដីសង្វេគ ដោយទ្រង់មនសិការដល់ការមិនទៀងថា ដំណក់ទឹកសន្សើមទាំងនេះ យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះ មានការបែកធ្លាយទៅយ៉ាងរហ័ស ។ បទថា **តញ្ញេវាធិបតី កត្វា សំវេគមនុព្រូហយឹ** សេចក្ដីថា ព្រះពោធិសត្វទ្រង់ធ្វើនូវការមិនទៀងនៃដំណក់ទឹកសន្សើមនោះឯង ឲ្យជាធំ ជាប្រធាន ជាប្រមុខ ជាបុរេចារិក ហើយទ្រង់មនសិការដល់ភាពដែលសង្ខារទាំងពួង មានពេលបន្តិចបន្តួច តាំងនៅមិនយូរ ទ្រង់ចម្រើននូវសេចក្ដីសង្វេគ ដែលកើតឡើងម្ដង ដោយឲ្យកើតឡើងរឿយៗ ។ បទថា **បព្វជ្ជ-មនុយាចហំ** សេចក្ដីថា តថាគតត្រិះរិះថា អាត្មាអញដែលជរា ព្យាធិ និងមរណៈ មិនទាន់គ្របសង្កត់ ក្នុងជីវិតរបស់សត្វទាំងឡាយ ដែលមិនតាំងនៅយូរ ដូចដំណក់ទឹកសន្សើមលើចុងស្មៅ គួរបួសស្វែងរកមហានិព្វាន ដែលជាអមតៈ ដែលមិនមានជរា ព្យាធិ និងមរណៈទាំងនេះ ដូច្នេះហើយ

ចូលទៅគាល់ព្រះមាតាបិតា ថ្វាយបង្គំហើយ ទូលសូមបព្វជ្ជាថា សូមព្រះមាតាបិតា ទ្រង់អនុញ្ញាតឲ្យទូលបង្គំបួសចុះ ។ កាលព្រះមហាសត្វទូលសូមអនុញ្ញាតដើម្បីបួសយ៉ាងនេះហើយ ក៏កើតកោលាហលធំពេញនគរថា បានឮថា ឧបរាជយុធញ្ជ័យ មានបំណងនឹងបួស ។

សម័យនោះ អ្នកដែនកាសីមកដើម្បីគាល់ព្រះរាជា នាំគ្នាចូលទៅក្នុងរម្មនគរ ជនទាំងអស់នោះក៏ប្រជុំគ្នា ព្រះរាជា មួយអន្លើដោយបរិវារ អ្នកនិគម អ្នកជនបទ ព្រះមាតា ព្រះទេវីរបស់ព្រះពោធិសត្វ និងស្នំទាំងពួង នាំគ្នាឃាត់ព្រះពោធិសត្វថា បពិត្រព្រះរាជកុមារ ទ្រង់កុំបួសឡើយ ។ បណ្ដាជនទាំងនោះ ព្រះរាជាត្រាស់ថា បើកាមទាំងឡាយរបស់កូននៅខ្វះខាត បិតានឹងបន្ថែមឲ្យ ថ្ងៃនេះ ចូរបុត្រគ្រងរាជសម្បត្តិចុះ ។ ព្រះមហាសត្វទូលដល់ការពេញចិត្ត ក្នុងការបួសរបស់ព្រះអង្គតែម្យ៉ាង ដល់ព្រះបិតាថា

បពិត្រព្រះបិតា ជាធំក្នុងរថ សូមព្រះអង្គ កុំឃាត់ផ្ទួសខ្ញុំព្រះអង្គនោះ កុំឲ្យខ្ញុំព្រះអង្គពោរពេញដោយកាមទាំងឡាយ ឲ្យលុះក្នុងអំណាចជរាឡើយ ដូច្នេះ ។

កាលព្រះមាតា មួយអន្លើដោយស្រីស្នំបានស្ដាប់ហើយ ទ្រង់ខ្សឹកខ្សួលដ៏គួរឲ្យអាសូរ ទើបទូលដល់ហេតុនៃការបួសរបស់ព្រះអង្គថា

ទឹកសន្សើមលើចុងស្មៅ តែងធ្លាក់ចុះ ( លើផែនដី ) ក្នុងកាលព្រះអាទិត្យរះឡើង យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយក៏យ៉ាងនោះដែរ បពិត្រព្រះមាតា សូមព្រះមាតា កុំឃាត់ខ្ញុំឡើយ

ដូច្នេះ ។

កាលព្រះមាតា ព្រះបិតា កំពុងឃាត់ដោយប្រការផ្សេងៗ ក៏មិនមានព្រះហឫទ័យរួញរា ព្រោះសេចក្តីសង្វេគចម្រើនក្រៃលែង មិនមានទូវព្រះហឫទ័យអាឡោះអាល័យក្នុងញាតិវង្សដ៏ធំ ដែលជាទីស្រឡាញ់ដ៏ក្រៃលែង និងក្នុងរាជឥស្សរិយយសដ៏ឧត្តម ទ្រង់បួសហើយ ដូចព្រះមានព្រះភាគត្រាស់ថា

ពួករាជបុរស ព្រមទាំងអ្នកនិគម អ្នកនៅក្នុងដែន ផ្គងអញ្ជលី អង្វរតថាគតថា បពិត្រព្រះរាជបុត្រ សូមព្រះអង្គម្ចាស់គ្រប់គ្រងមហាប្រឹថពី ដែលសម្រេចដោយសម្បត្តិដ៏ស្តុកស្តម្ភ ក្នុងថ្ងៃនេះចុះ ។ តថាគតមិនមានអាល័យ លះបង់រាជបុរស ព្រមទាំងស្តេច ស្រីស្នំ អ្នកនិគម និងអ្នកនៅក្នុងដែន ដែលកំពុងខ្សឹកខ្សួល គួរឲ្យអាណិត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បញ្ជលិកា** បានដល់ ផ្គងអញ្ជលី ។ បទថា **សនេគមា សរដ្ឋកា** ព្រះមហាសត្វសម្តែងថា រាជបុរសទាំងពួង មួយអន្លើដោយអ្នកនិគម និងអ្នកដែន នាំគ្នាអង្វរតថាគតថា បពិត្រព្រះអង្គ សូមទ្រង់កុំបួសឡើយ ។ ព្រះមាតាព្រះបិតាត្រាស់អង្វរថា នែកូន ចូរកូនគ្រងរាជសម្បត្តិក្នុងថ្ងៃនេះចុះ គឺចូរគ្រប់គ្រងមហាប្រឹថពីនេះ ដែលមានទំហំធំដោយសេចក្តីចម្រើនក្រៃលែងរបស់ស្រុក និគម និងរាជធានី និងដោយដល់នូវការបរិបូណ៌ដ៏វិសាល ដោយការសម្បូរដោយទ្រព្យដែលជាសារៈ និង

ដោយការស្អាតរបស់ពូជ មានសម្ពន្ធជាដើម ចូរកូនឲ្យលើកស្វេតច្ឆត្រ ហើយគ្រប់គ្រងរាជសម្បត្តិចុះ ។ កាលមហាជន មួយអន្លើដោយព្រះរាជា ស្នំ អ្នកនិគម អ្នកដែនកំពុងយំខ្សឹកខ្សួលគួរអាណិត ដោយអាការដែលមហាករុណារមែងមានដល់អ្នកស្តាប់ មិនបាច់ពោលដល់បុគ្គលដែលឃើញតថាគត មិនអាឡោះអាល័យ មិនជាប់ជំពាក់ ក្នុងបុគ្គលនោះៗ បួសហើយ ក្នុងកាលនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងថា តថាគតលះសិរីរាជ-សម្បត្តិ ដែលដូចគ្នានឹងសម្បត្តិស្តេចចក្រពត្តិ និងព្រះញាតិដែលជាទីស្រឡាញ់ មិនអាឡោះអាល័យ លះបរិវារជន មនុស្សស្និទ្ធស្នាល និងមហាយសដែលសត្វលោកសម្លឹងចង់បាន ទើបត្រាស់ព្រះ ២ គាថាថា

តថាគតលះបង់រាជ្យ លើផែនដី ញាតិ ជនជាបរិស័ទ និងយស
ទាំងអស់ ឥតមានគិតដល់ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។
មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិន
មែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់
របស់តថាគត ព្រោះហេតុនោះ បានជាតថាគត លះបង់រាជ្យ
ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សោវលំ** បានដល់ ទាំងអស់ អធិប្បាយថា តថាគតលះបង់ព្រះរាជដំណាក់របស់ស្រីស្នំទាំងអស់ និងផែនដីដែលមានមហាសមុទ្រជាទីបំផុត ដោយបំណងនឹងបួស មិនគិតដល់អ្វី ព្រោះហេតុនៃ

ពោធិញ្ញាណតែម្យ៉ាងថា តថាគតអាចសម្រេចសម្មាសម្ពោធិញ្ញាណបាន ដោយអាការយ៉ាងនេះ គឺតថាគតមិនកើតនូវការជាប់ជំពាក់ក្នុងវត្ថុនោះ សូម្បីតែបន្តិចបន្តួច ។ បទថា **តស្មា** សេចក្តីថា ព្រោះតថាគតស្អប់ខ្ពើមមាតាបិតា យសសក្តិដែលធំក្រៃលែង និងរាជសម្បត្តិក៏មិនមែន តថាគតស្រឡាញ់ទាំងអស់តែសព្វញ្ញុតញ្ញាណប៉ុណ្ណោះ ជាទីស្រឡាញ់ក្រៃលែង ជាងវត្ថុទាំងនោះរាប់រយ រាប់ពាន់ រាប់សែនដង ហេតុនោះ ទើបតថាគតលះរាជសម្បត្តិ មួយអន្លើដោយព្រះមាតាជាដើមក្នុងកាលនោះបាន ដោយប្រការដូច្នេះ ។

កាលព្រះមហាសត្វ ទ្រង់លះបង់វត្ថុគ្រប់យ៉ាងចេញបួស យុធិដ្ឋិលកុមារជាប្អូនប្រុសរបស់ព្រះពោធិសត្វនោះ ថ្វាយបង្គំព្រះជនក សូមអនុញ្ញាតបួសតាមព្រះពោធិសត្វ ក្សត្រទាំងពីរអង្គចេញអំពីព្រះនគរ ប្រាប់ឲ្យមហាជនត្រឡប់យាងចូលកាន់ព្រៃហិមពាន្ត សាងអាស្រមបទក្នុងទីដែលគួរពេញចិត្ត បួសជាឥសី ញុំាងឈាន និងអភិញ្ញាឲ្យកើត ទ្រង់ចិញ្ចឹមជីវិតដោយឫសឈើនិងផ្លែឈើក្នុងព្រៃជាដើមដរាបដល់អស់ជីវិត ហើយទៅកាន់ព្រហ្មលោកដូចព្រះមានព្រះភាគត្រាស់ថា

> កុមារទាំងពីរអង្គ គឺយុធញ្ជ័យ ១ យុធិដ្ឋិលៈ ១ លះបង់នូវ
> ព្រះមាតា និងព្រះបិតា ផ្តាច់បោលនូវគ្រឿងជាប់ជំពាក់របស់
> មច្ចុមារ បួសហើយ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ផ្តាច់បោលនូវគ្រឿងជាប់ជំពាក់របស់មច្ចុមារ សេចក្តីថា ព្រះរាជកុមារទាំងពីរកាត់នូវការជាប់ជំពាក់ គឺរាគៈ ទោសៈ

មោហៈ ដែលជារបស់មាន ព្រោះជាហេតុធ្វើរមត្ថជាមួយមច្ចុមារ ដោយការសង្កត់ចិត្ត ហើយបួស ។

ព្រះមាតាព្រះបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ យុធិដ្ឋិលកុមារ ក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ យុធញ្ជយ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ការបរិច្ចាគមហាទានក្នុងកាលមុនបួស និងការលះរាជសម្បត្តិជាដើមរបស់ព្រះមហាសត្វនោះ ជាទានបារមី ។ ការសង្រួមកាយវាចា ជាសីលបារមី ការបួស និងការបានឈាន ជានេក្ខម្មបារមី បញ្ញាផ្តើមធ្វើដោយមនសិការថាជារបស់មិនទៀង រហូតសម្រេចអភិញ្ញាជាទីបំផុត និងបញ្ញាកំណត់ធម៌ជាឧបការៈ និងមិនឧបការៈនៃទានជាដើម ជាបញ្ញាបារមី ។ សេចក្តីព្យាយាមញុំាងប្រយោជន៍នោះឲ្យសម្រេចក្នុងទីទាំងពួង ជាវីរិយបារមី ញាណខន្តិ និងអធិវាសនខន្តី ជាខន្តិបារមី ការមិនពោលខុសអំពីពាក្យប្តេជ្ញា ឈ្មោះជាសច្ចបារមី ការតាំងចិត្តសមាទានដែលមិនញាប់ញ័រក្នុងទីទាំងពួង ជាអធិដ្ឋាន-បារមី ព្រោះចិត្តគិតតែប្រយោជន៍ក្នុងសព្វសត្វទាំងឡាយ ដោយអំណាចនៃ

មេត្តាព្រហ្មវិហារ ឈ្មោះថា មេត្តាបារមី ដោយការព្រងើយកន្តើយក្នុងការ ខុសប្រក្រតី ដែលធ្វើហើយក្នុងសត្វ និងសង្ខារ និងដោយឧបេក្ខាព្រហ្មវិហារ ឈ្មោះថា ឧបេក្ខាបារមី ជាការដែលបានបារមី ១០ ដោយប្រការដូច្នេះ ។ តែគប្បីជ្រាបដោយភាពវិសេសថា ជានេក្ខម្មបារមី ។ ម្យ៉ាងទៀត ក្នុងចរិយា នេះ គប្បីពោលចំពោះដល់អច្ឆរិយគុណរបស់មហាបុរស តាមសមគួរ ដូច ក្នុងអកិត្តិចរិយា សមដូចលោកពោលថា

គួរអស្ចារ្យ មិនធ្លាប់មានមកហើយ ព្រះមហាសត្វទាំងឡាយ ជា អ្នកស្វែងរកគុណធំ ។បេ។ នឹងពោលទៅថ្វី ដល់ការធ្វើតាមព្រះ ពោធិសត្វទាំងនោះ ដោយធម៌សមគួរដល់ធម៌ ដូច្នេះ ។

## អដ្ឋកថាយុធញ្ជយចរិយា ចប់

# សុត្តន្តបិដក

## សោមនស្សចរិយាទី ២

[ ២២ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជារាជបុត្រ ( នៃស្តេចកុរុរាជ ) ក្នុងឥន្ទបត្តបុរីដ៏ឧត្តម មានឈ្មោះប្រាកដថា សោមនស្សកុមារ ជារាជបុត្រដែលជនទាំងឡាយ មានមាតាបិតាជាដើម ស្រឡាញ់ពេញចិត្តក្រៃលែង ជាអ្នកមានសីល ប្រកបដោយគុណ មានសម្តីពីរោះ គោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ មានហិរិ ទាំងមានសេចក្តីឈ្លាសវៃ ក្នុងសង្គហធម៌ ( ៤ យ៉ាង ) ។ មានតាបសកុហកម្នាក់ ជាអ្នកស្និទ្ធស្នាលនៃស្តេចកុរុនោះ ដាំសួនច្បារ និងគុម្ពផ្កាចិញ្ចឹមជីវិត ។ តថាគតឃើញកុហកតាបសនោះ ដូចគំនរអង្កាមមិនមានគ្រាប់អង្ករ ដូចឈើមានប្រហោងក្នុង ឬដូចដើមចេកមិនមានខ្លឹម ក៏ត្រិះរិះថា សប្បុរិសធម៌ មានឈានជាដើម នៃតាបសនេះ មិនមានទេ តាបសនេះ ជាបុគ្គលប្រាសចាកភាពជាសមណៈ លះបង់សុក្កធម៌ គឺហិរិ និងឱត្តប្បៈ ព្រោះហេតុតែការចិញ្ចឹមជីវិត ។ ក្នុងបច្ចន្តប្រទេស មានពួកចោរនៅក្នុងព្រៃធំបះបោរ បិតារបស់តថាគត ទៅបង្ក្រាបបច្ចន្តប្រទេសនោះ បានផ្តាំ ( តថាគតថា ) ម្នាលកូន ចូរបាកុំធ្វេសប្រហែស ចំពោះជដិលដែលមានតបៈដ៏ខ្ពង់ខ្ពស់ ចូរបាញ៉ាំងជដិលនេះ ឲ្យប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នាចុះ ព្រោះតាបសនោះ ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ តថាគតទៅកាន់ទីបម្រើតាបសនោះ បានពោលនូវ

ពាក្យនេះថា ម្នាលគហបតី អ្នកសុខសប្បាយទេឬ ពួកអ្នកជំនួញនាំ ( មាស និងប្រាក់ ) មកឲ្យអ្នកដែរឬ ។ ព្រោះពាក្យដែលតថាគតពោលថា គហបតីកុហកតាបសនោះ អាស្រ័យនូវមានះក៏ខឹង ( និយាយថា ) ក្នុងថ្ងៃនេះ អាត្មាភាពនឹងឲ្យស្ដេចសម្លាប់ទ្រង់ ឬឲ្យបំបរបង់ទ្រង់ចាកដែន ។ លុះព្រះរាជាបង្ក្រាបបច្ចន្តប្រទេសរួចហើយ ( ត្រឡប់មកនគរវិញ ស្ដេចចូលទៅកាន់ឧទ្យាន ) ទ្រង់ត្រាស់សួរកុហកតាបសថា ( បពិត្រលោកម្ចាស់ដ៏ចម្រើន ) ចុះលោកល្មមអត់ទ្រាំបានទេឬ រាជកុមាររាប់អានលោកស្រួលបួលទេឬ ។ តាបសបាបនោះ បានទូលព្រះរាជានោះ តាមដែលខ្លួនអាចឲ្យព្រះរាជកុមារវិនាស ព្រះរាជាជាម្ចាស់ផែនដី ទ្រង់ព្រះសណ្ដាប់ពាក្យនេះរបស់តាបសនោះហើយ ត្រាស់បង្គាប់ពួកពេជ្ឈឃាតថា អ្នកទាំងឡាយ ( បើឃើញកុមារក្នុងទីណា ) ចូរកាត់ក្បាលចិញ្ច្រាំជា ៤ កំណាត់ ហើយកប់ក្នុងផ្លូវបែក បង្ហាញជនដទៃឲ្យដឹងថា នេះជាគតិដែលបៀតបៀនជដិល ។ ពួកពេជ្ឈឃាតទាំងនោះកាចអាក្រក់ មិនមានសេចក្ដីអាណិត ទៅក្នុងទីនោះហើយទាញតថាគតដែលអង្គុយលើចង្កេះមាតា នាំយកទៅ ។ តថាគតនិយាយនឹងជនទាំងនោះ ដែលកំពុងចងតថាគត ដោយចំណងដ៏មាំថា រាជកិច្ចមានដល់ខ្ញុំ សូមអ្នកទាំងឡាយនាំខ្ញុំ ទៅជួបនឹងស្ដេចមួយរំពេចសិន ។ ពួកពេជ្ឈឃាតទាំងនោះ នាំតថាគតទៅជួបនឹង

ស្តេច ដែលសេពគប់នឹងតាបសលាមក លុះតថាគតបានជួប ក៏ញុំាងស្តេចឲ្យដឹងច្បាស់ នូវការប្រព្រឹត្តនៃតាបសនោះ ព្រមទាំង ញុំាងស្តេច ឲ្យលុះក្នុងអំណាចតថាគត ។ ព្រះរាជាជាបិតារបស់ តថាគតនោះ សូមទោសតថាគតក្នុងទីនោះ ហើយប្រទាននូវភាព ជាស្តេចធំដល់តថាគត តែតថាគតនោះឯង ទម្លាយនូវងងឹត ចូល ទៅកាន់ផ្នួសវិញ ។ ភាពនៃខ្លួនជាស្តេចធំ មិនមែនជាទីស្អប់របស់ តថាគតទេ ទាំងការបរិភោគកាម ក៏មិនមែនជាទីស្អប់នៃតថាគត ដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត បានជា តថាគតលះបង់រាជ្យ ( ចូលទៅកាន់ផ្នួស ) ។

## សោមនស្សចរិយាទី ២ ចប់

# អដ្ឋកថា

## សោមនស្សចរិយា

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោមនស្សចរិយាទី ២ ដូចតទៅ បទថា **ឥន្ទបត្ថេ បុរុត្តមេ** បានដល់ ក្នុងនគរដ៏ប្រសើរ មានឈ្មោះយ៉ាងនេះ ។ បទថា **កាមិតោ** សេចក្តីថា ជាបុគ្គលដែលព្រះជនក ព្រះជននីប្រាថ្នា ក្នុងកាលយូរយ៉ាងនេះថា ធ្វើម្តេចហ្ន៎ បុត្រគប្បីកើតម្នាក់ ។ បទថា **ទយិតោ** បានដល់ ជាទីស្រឡាញ់ ។ បទថា **សោមនស្សោតិ វិស្សុតោ** បានដល់ មានឈ្មោះប្រាកដយ៉ាងនេះថា សោមនស្ស ។

បទថា **សីលវា** សេចក្តីថា ប្រកបដោយសីល គឺកុសលកម្មបថ ១០ និងសីល គឺអាចារៈ ។ បទថា **គុណសម្បន្នោ** សេចក្តីថា ចូលដល់ ឬបរិបូណ៌ដោយគុណ មានសទ្ធា និងពហុសច្ចៈជាដើម ។ បទថា **កល្យាណ-បដិភាណវា** សេចក្តីថា ប្រកបដោយបដិភាណ ពោល គឺភាពជាអ្នកឈ្លាសក្នុងឧបាយដែលញ៉ាំងកិច្ចដែលគួរធ្វើនោះៗ ឲ្យសម្រេច ។ បទថា **វុឌ្ឍា-បចាយី** សេចក្តីថា មានប្រក្រតីឱនលំទោនចំពោះបុគ្គលដែលចម្រើនដោយជាតិយ៉ាងនេះ គឺមាតា បិតា ត្រកូលរាមច្បង និងចំពោះបុគ្គលដែលចម្រើនដោយគុណ មានសីលជាដើម ។ បទថា **ហិរីមា** បានដល់ ប្រកបដោយហិរិ មានការខ្មាសបាបជាលក្ខណៈ ។ បទថា **សង្គហេសុ ច កោវិទោ** សេចក្តីថា ឈ្លាសក្នុងការសង្គ្រោះសត្វទាំងឡាយតាមសមគួរ ដោយសង្គហវត្ថុ ៤ មានទាន គឺការឲ្យ បិយវាចា គឺការនិយាយពាក្យគួរជាទីស្រឡាញ់ អត្ថចរិយា

គឺប្រព្រឹត្តវត្តដែលជាប្រយោជន៍ សមានត្តតា គឺមានខ្លួនស្មើ មិនប្រកាន់ខ្លួន ។ គប្បីជ្រាបការភ្ជាប់សេចក្តីថា ក្នុងកាលតថាគតប្រាកដឈ្មោះថា សោមនស្ស ជាឱរសរបស់ព្រះបាទកុរុ ព្រះនាមថា រេណុ បែបនេះ ។ បទថា **តស្ស រញ្ញោ បតិករោ** សេចក្តីថា ជាទីប្រោសប្រាណ គឺជាទីពេញព្រះហឫទ័យ ព្រោះព្រះបាទកុរុ ចូលទៅបម្រើជានិច្ច ។ បទថា **កុហកតាបសោ** សេចក្តីថា តាបសមួយរូប សម្រេចជីវិតដោយការបោកបញ្ឆោត មានលក្ខណៈ សរសើរគុណរបស់អសប្បុរស ជាបុគ្គលដែលព្រះរាជាទ្រង់រាប់អាន ។ បទថា **អារាមំ** បានដល់ សួនផ្លែឈើ តាបសដាំផ្លែឈើដែលជាវល្លិ មានល្ពៅ ឃ្លោក ត្រឡាច ត្រសក់ជាដើម និងបន្លែ មានម្រះព្រៅជាដើម ។ បទថា **មាលាវច្ចំ** សេចក្តីថា ផ្កាមានផ្កាម្លិះ និងផ្កាវំដួលជាដើម ។ ដោយពាក្យនេះ ទើបលោកសម្តែងថាជាសួនផ្កា ។ គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនេះថា តាបសធ្វើសួនដាំផ្កា និងឈើផ្លែ ដូចពោលហើយក្នុងសួននោះ ប្រមូលទ្រព្យដែលបានអំពីការលក់ផ្កា និងផ្លែឈើនោះ ចិញ្ចឹមជីវិត ។

ក្នុងរឿងនោះ គប្បីជ្រាបដូចតទៅនេះ

ក្នុងកាលនោះ មានតាបសម្នាក់ ឈ្មោះមហារក្ខិតៈ មានតាបស ៥០០ ជាបរិវារ នៅក្នុងហិមវន្តប្បទេស ត្រាច់ចារិកទៅកាន់ជនបទដើម្បីសេពរស ជូរ ប្រៃ មកដល់នគរឥន្ទបត្ត ស្នាក់នៅក្នុងព្រះរាជឧទ្យាន មួយអន្លើដោយ បរិវារត្រាច់ទៅបិណ្ឌបាត ដល់ទ្វារព្រះរាជវាំង ។ ព្រះរាជាទតឃើញពួកឥសី ទ្រង់ជ្រះថ្លា ក្នុងឥរិយាបថ អារាធនាឲ្យគង់ត្រង់មហាប្រាសាទ ដែលតាក់

តែងហើយ ទ្រង់អង្គាសដោយអាហារដ៏ប្រណីត ហើយត្រាស់ថា សូមលោកម្ចាស់នៅក្នុងរាជឧទ្យានរបស់ខ្ញុំអស់រដូវវស្សានេះចុះ ហើយយាងទៅព្រះរាជឧទ្យាន ជាមួយតាបសទាំងនោះ ទ្រង់ឲ្យគេធ្វើទីលំនៅ ទ្រង់ថ្វាយបរិក្ខាររបស់បព្វជិត ហើយយាងចេញទៅ ។ តាំងពីនោះមក តាបសទាំងពួងនោះ ក៏បរិភោគក្នុងព្រះរាជនិវេសន៍ ។

ចំណែកព្រះរាជាមិនមានបុត្រ ទ្រង់ប្រាថ្នាបុត្រ បុត្រក៏មិនទាន់កើត ។ កាលចេញវស្សា មហារក្ខិតតាបសគិតថា អញត្រូវត្រឡប់ទៅកាន់ព្រៃហិមពាន្ត ទើបលាព្រះរាជាៗ ទ្រង់ធ្វើសក្ការៈរាប់អានហើយ ចេញទៅក្នុងវាំងផ្លូវ លុះថ្ងៃត្រង់ ក៏គេចចេញអំពីផ្លូវ មួយអន្ទើដោយបរិវារ ចូលទៅអង្គុយក្រោមដើមឈើដែលមានម្លប់មួយដើម ។ តាបសទាំងឡាយសន្ទនាគ្នាថា ព្រះរាជាមិនមានបុត្រ បើព្រះរាជាបានបុត្រជាការល្អ ។ មហារក្ខិត-តាបសបានស្តាប់ការសន្ទនានោះ ក៏ពិចារណាមើលថា ឱរសរបស់ព្រះរាជាមានដែរឬហ្ន៎ ដឹងថា នឹងមាន ទើបពោលថា ពួកអ្នកកុំគិតថ្វីឡើយ ថ្ងៃនេះពេលទៀបភ្លឺ ទេវបុត្រមួយអង្គចុតិមកកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះរាជា ។

ជដិលកោងមួយអង្គបានស្តាប់ដូច្នោះ គិតថា ឥឡូវនេះ អញនឹងបានជារាជកុលុបកៈ គឺជាអ្នកស្និទ្ធស្នាលក្នុងរាជត្រកូល កាលតាបសទាំងឡាយចេញដំណើរទៅ ពុតធ្វើជាឈឺ ហើយដេក កាលតាបសពោលថា មកយើងទៅ ក៏ពោលថា ខ្ញុំទៅមិនរួចឡើយ ។ មហារក្ខិតតាបសដឹងហេតុដែល

តាបសនោះដេក ទើបពោលថា បើលោកទៅបានថ្ងៃណា សូមទៅតាមក្រោយចុះ ហើយនាំពួកឥសីទៅកាន់ហិមវន្តប្បទេស ។ កុហកតាបសប្រញាប់ត្រឡប់ទៅឈរត្រង់ទ្វារនគរ ឲ្យមនុស្សទៅទូលព្រះរាជាថា តាបសដែលជាឧបដ្ឋាករបស់មហារក្ខិតតាបសត្រឡប់មក ព្រះរាជាត្រាស់ឲ្យរាជបុរសប្រញាប់ទៅនិមន្តមក ទើបឡើងប្រាសាទ អង្គុយលើអាសនៈដែលគេក្រាល ។ ព្រះរាជាទ្រង់ថ្វាយបង្គំតាបសនោះ ហើយប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់សួរដល់ការមិនមានរោគរបស់ឥសីទាំងឡាយ ហើយត្រាស់ថា លោកម្ចាស់ត្រឡប់មកដោយរហ័ស ត្រូវការអ្វីឬ ។

តាបសកោងពោលថា បពិត្រមហារាជ ឥសីទាំងឡាយសុខទេ ឥសីទាំងឡាយសន្ទនាគ្នាថា បើព្រះរាជាមានរាជបុត្រ តាំងវង្សត្រកូលជាការល្អ អាត្មាបានស្តាប់ការសន្ទនា ទើបប្រមើលមើលដោយទិព្វចក្ខុថា ព្រះរាជឱរសរបស់ព្រះរាជានឹងមានឬហ្ន៎ ក៏ឃើញថា ទេវបុត្រមានឫទ្ធិច្រើន នឹងចុតិមកកើតក្នុងព្រះឧទររបស់ព្រះនាងសុធម្មាអគ្គមហេសី ហើយទូលបន្តថា អាត្មាមក ក៏ដើម្បីទូលព្រះអង្គថា ជនទាំងឡាយ កាលមិនដឹង គប្បីញុំាងគភ៌ឲ្យវិនាស អាត្មាទូលសេចក្តីនោះមុន អាត្មាទូលដល់ព្រះអង្គហើយ អាត្មានឹងត្រឡប់ទៅ ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់កុំទៅឡើយ ទ្រង់ត្រេកអរ ទ្រង់មានព្រះហឫទ័យជ្រះថ្លា ទើបនាំតាបសកោងទៅកាន់ព្រះរាជឧទ្យាន ចាត់ចែងលំនៅប្រគេន ។ តាំងអំពីនោះមក តាបសកោងនោះ ក៏បរិភោគក្នុងរាជត្រកូលអាស្រ័យនៅ ។ តាបសកោងនោះ ក៏មានឈ្មោះថា ទិព្វចក្ខុកៈ ។

ក្នុងកាលនោះ ព្រះពោធិសត្វចុតិអំពីតាវត្តិង្សភព បដិសន្ធិក្នុងឥន្ទបត្ត-នគរនោះ ។ ក្នុងថ្ងៃថ្វាយព្រះនាម ព្រះមាតាបិតា ក៏ថ្វាយនាមព្រះរាជបុត្រដែលប្រសូតមកថា សោមនស្ស ។ សោមនស្សកុមារទ្រង់ចម្រើនដោយការចិញ្ចឹមបែបព្រះរាជកុមារ ។ តាបសកោងក៏ដាំបន្លែសម្រាប់ស្ល និងផ្លែល្ពៅជាដើមច្រើនប្រភេទ ត្រង់ចំណែកម្ខាងនៃឧទ្យាន យកទៅលក់ក្នុងផ្សារ សន្សំនូវទ្រព្យ ។

ក្នុងកាលនោះ ក្នុងខណៈដែលព្រះពោធិសត្វមានព្រះជន្ម ៧ ឆ្នាំ ជាយដែនរបស់ព្រះរាជាបះបោរ ទ្រង់ត្រាស់នឹងព្រះរាជកុមារថា កូនកុំប្រមាទក្នុងទិព្វចក្ខុតាបស ហើយទ្រង់យាងទៅធ្វើជាយដែនឲ្យមានសន្តិភាព ។

ថ្ងៃមួយ ព្រះរាជកុមារយាងទៅព្រះរាជឧទ្យានដោយទ្រង់ត្រិះរិះថា នឹងសួរសុខទុក្ខជដិល ទ្រង់ឃើញជដិលកោង ស្លៀកសំពត់កាសាវៈមានក្លិនមួយផ្ទាំង ដណ្តប់មួយផ្ទាំង កាន់ពីរថ្នាំងដោយដៃទាំងពីរ ស្រោចទឹកក្នុងទីដែលដាំបន្លែ ទ្រង់ដឹងថា ជដិលកោងនេះ មិនប្រកបសមណធម៌របស់ខ្លួន ធ្វើការលក់ដូរក្នុងផ្សារ ទើបត្រាស់សួរថា នែគហបតីបន្លែ តើលោកធ្វើអ្វី ធ្វើតាបសកោងឲ្យខ្មាស មិនថ្វាយបង្គំ ហើយយាងចេញទៅ ។

ជដិលកោងគិតថា ឥឡូវនេះ កុមារនេះ មានសភាពបែបនេះ ខាងក្រោយ អ្នកណានឹងដឹង អ្នកណានឹងធ្វើអ្វីបាន អញគួរចាត់ការកុមារនេះ ឲ្យវិនាសក្នុងពេលនេះឯង ។ ក្នុងកាលព្រះរាជាត្រឡប់មក ទើបបោះដុំថ្មទៅកាន់ចំណែកម្ខាង ហើយបំបែកក្អមទឹក បោចស្មៅត្រង់ដំបូលបណ្ណសាលា យក

ប្រេងលាបរាងកាយ ចូលទៅកាន់បណ្ណសាលា ដេកទទូរក្បាលលើគ្រែ ដូចមានទុក្ខធ្ងន់ ។ ព្រះរាជាយាងត្រឡប់មក ទ្រង់ធ្វើប្រទក្សិណនគរ មិនទាន់ចូលទៅកាន់ព្រះរាជវាំង ទ្រង់ត្រិះរិះថា អញនឹងសួរសុខទុក្ខទិព្វចក្ខុតាបសជាម្ចាស់របស់អញមុន ហើយយាងចូលទៅកាន់បណ្ណសាលា ទតឃើញការខុសប្រក្រតីនោះ ទ្រង់ព្រះតម្រិះថា នុ៎ះជាអ្វី ទើបយាងទៅខាងក្នុង ទ្រង់ឃើញតាបសកោងនោះដេក ទើបទ្រង់ស្ទាបត្រង់ជើង ត្រាស់សួរថា អ្នកណាបៀតបៀនលោកម្ចាស់យ៉ាងនេះ ខ្ញុំនឹងបញ្ជូនទៅកាន់យមលោក ក្នុងថ្ងៃនេះឯងសូមលោកម្ចាស់ប្រញាប់ប្រាប់មកចុះ ។

ជដិលកោងស្តាប់ដូច្នោះ ដកដង្ហើម ក្រោកឡើងទូលថា បពិត្រមហារាជអាត្មាមកគាល់ព្រះអង្គ ព្រោះការមកគាល់ព្រះអង្គនោះឯង ទើបអាត្មាបានទទួលការក្តៅក្រហាយនេះ ព្រោះការស្និទ្ធស្នាលក្នុងព្រះអង្គ ព្រះរាជឱរសរបស់ព្រះអង្គនោះឯងបៀតបៀនអាត្មា ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបបញ្ជាពេជ្ឈឃាតថា ចូរពួកអ្នកទៅកាត់ក្បាលព្រះរាជកុមារ ចិញ្ច្រាំព្រះរាជកុមារនោះឲ្យជាកំណាត់តូចធំ ហើយយកទៅបោលត្រង់កណ្តាលផ្លូវ ។ ពួកពេជ្ឈឃាត ក៏ទៅអូសព្រះរាជាកុមារ ដែលព្រះមាតាតាក់តែងហើយ ឲ្យប្រថាប់ផ្ទំលើភ្លៅរបស់ព្រះនាង ទូលថា ព្រះរាជាមានបញ្ជាឲ្យសម្លាប់ព្រះរាជកុមារ ។

ព្រះរាជកុមារទ្រង់ខ្លាចសេចក្តីស្លាប់ ទ្រង់ក្រោកអំពីភ្លៅព្រះមាតាហើយត្រាស់ថា ចូរពួកលោកនាំខ្ញុំទៅគាល់ព្រះរាជា ខ្ញុំមានរាជកិច្ចដែលត្រូវក្រាបទូល ។ ពួកពេជ្ឈឃាតស្តាប់ព្រះតម្រាស់របស់ព្រះរាជកុមារហើយ ក៏មិនអាច

សម្លាប់បាន ទើបយកខ្សែចងដូចចងគោ នាំទៅគាល់ព្រះរាជា ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតឃើញកុហកតាបសនោះ ដូចគំនរអង្កាមមិនមានគ្រាប់អង្ករ ដូចឈើមានប្រហោងក្នុង ឬដូចដើមចេកមិនមានខ្លឹម ក៏ត្រិះរិះថា សប្បុរិសធម៌ មានឈានជាដើម នៃតាបសនេះ មិនមានទេ តាបសនេះ ជាបុគ្គលប្រាសចាកភាពជាសមណៈ លះបង់សុក្កធម៌ គឺហិរិ និងឱត្តប្បៈ ព្រោះហេតុតែការចិញ្ចឹមជីវិត ។ ក្នុងបច្ចន្តប្រទេស មានពួកចោរនៅក្នុងព្រៃធំបះបោរ បិតារបស់តថាគត ទៅបង្ក្រាបបច្ចន្តប្រទេសនោះ បានផ្តាំ ( តថាគតថា ) ម្នាលកូន ចូរបាកុំធ្វេសប្រហែសចំពោះជដិល ដែលមានតបៈដ៏ខ្ពង់ខ្ពស់ ចូរបាញុំាងជដិលនេះ ឲ្យប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នាចុះ ព្រោះតាបសនោះ ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ថុសរាសឹវ អតណ្ឌុលំ** សេចក្តីថា ដូចគំនរអង្កាមដែលប្រាសចាកអង្ករ និងកុណ្ឌក ដូចដើមឈើប្រហោងខាងក្នុង តថាគតឃើញតាបសប្រាសចាកសីលសារៈជាដើម ដូចដើមចេកមិនមានខ្លឹម ធម៌មានឈានជាដើមរបស់សប្បុរសទាំងឡាយ មិនមានដល់តាបសនេះឡើយ ព្រោះហេតុអ្វី ព្រោះតាបសនេះប្រាសចាក គឺវិនាសចាកភាពជាសមណៈសូម្បីត្រឹមតែសីល ។ ជាការពិត តាបសនេះប្រាសចាកធម៌ស គឺហិរិ គឺជា

អ្នកលះបង់ធម៌ស ដែលបានដល់ហិរិ ព្រោះហេតុនៃការចិញ្ចឹមជីវិត ។ បទថា **ជីវិតវុត្តិការណា** លោកសម្តែងថា តថាគតគិតថា តាបសនេះ ត្រាច់ទៅដោយភេទរបស់តាបស ព្រោះហេតុនៃជីវិតតែម្យ៉ាងប៉ុណ្ណោះ ។ បទថា **បរន្តិហិ** លោកសម្តែងថា ឈ្មោះថា **បរន្តិនោ** ព្រោះមានជាយដែនដែលជាចំណែកដទៃ ជាលំនៅ គឺនៅក្នុងរវាងព្រំដែន ។ ជាយដែនបះបោរដោយចោរដែលនៅក្នុងព្រៃជាយដែន ។ ព្រះបាទកុរុ ព្រះជនករបស់តថាគត កាលយាងទៅបង្ក្រាបការបះបោរក្នុងជាយដែននោះឲ្យស្ងប់ ក្នុងកាលនោះ បានទូន្មានតថាគតថា បាសោមនស្ស បាកុំប្រមាទក្នុងជដិលដែលជាម្ចាស់របស់បា ជាអ្នកមានព្យាយាមខ្ពង់ខ្ពស់ មានតបៈក្លៀវក្លា មានឥន្ទ្រិយស្ងប់ក្រៃលែង ។ ជដិលនោះ បានឲ្យនូវការសម្រេចដែលប្រាថ្នាគ្រប់យ៉ាង ដល់ពួកយើង ព្រោះហេតុនោះ ចូរបាអនុវត្តតាមការប្រាថ្នា តាមការពេញចិត្ត អនុគ្រោះជដិលនោះ ដូចព្រះមានព្រះភាគត្រាស់ថា

> តថាគតទៅកាន់ទីបម្រើតាបសនោះ បានពោលនូវពាក្យនេះថា ម្នាលគហបតី អ្នកសុខសប្បាយទេឬ ពួកអ្នកជំនួញ នាំ ( មាស និងប្រាក់ ) មកឲ្យអ្នកដែរឬ ។ ព្រោះពាក្យដែលតថាគតពោលថា គហបតី កុហកតាបសនោះ អាស្រ័យនូវមានះ ក៏ខឹង ( និយាយថា ) ក្នុងថ្ងៃនេះ អាត្មាភាព នឹងឲ្យស្តេចសម្លាប់ទ្រង់ ឬឲ្យបំបរបង់ទ្រង់ចាកដែន ។ លុះព្រះរាជាបង្ក្រាបបច្ចន្តប្រទេសរួចហើយ ( ត្រឡប់មកនគរវិញ ស្តេចចូលទៅកាន់ឧទ្យាន ) ទ្រង់ត្រាស់សួរ

កុហកតាបសថា ( បពិត្រលោកម្ចាស់ដ៏ចម្រើន ) ចុះលោក ល្មមអត់ទ្រាំបានទេឬ រាជកុមារពប់អានលោកស្រួលបួលទេឬ ។ តាបសបាបនោះ បានទូលព្រះរាជានោះ តាមដែលខ្លួនអាចឲ្យព្រះរាជកុមារវិនាស ព្រះរាជាជាម្ចាស់ផែនដី ទ្រង់ព្រះសណ្ដាប់ពាក្យនេះ របស់តាបសនោះហើយ ត្រាស់បង្គាប់ពួកពេជ្ឈឃាតថា អ្នកទាំងឡាយ ( បើឃើញកុមារក្នុងទីណា ) ចូរកាត់ក្បាលចិញ្ច្រាំជា ៤ កំណាត់ ហើយកប់ក្នុងផ្លូវប្រែក បង្ហាញជនដទៃឲ្យដឹងថា នេះជាគតិដែលបៀតបៀនជដិល ។ ពួកពេជ្ឈឃាតទាំងនោះ កាចអាក្រក់ មិនមានសេចក្ដីអាណិត ទៅក្នុងទីនោះហើយ ទាញតថាគតដែលអង្គុយលើចង្កេះមាតា នាំយកទៅ ដូច្នេះ ។

បទថា **តមហំ គន្ត្វានុបដ្ឋានំ** សេចក្ដីថា តថាគតមិនលះព្រះតម្រាស់របស់ព្រះជនក បានទៅដើម្បីបម្រើតាបសកោងនោះ បានឃើញតាបសកោងនោះកំពុងស្រោចទឹកក្នុងទីដែលដាំបន្លែ ដឹងថា តាបសនេះ ជាអ្នកលក់បន្លែ ទើបពោលពាក្យនេះថា បពិត្រគហបតី លោកសុខសប្បាយដែរឬ បពិត្រគហបតី រាងកាយរបស់លោកប្រក្រតីទេឬ ម្យ៉ាងទៀត លោកស្រោចទឹកក្នុងទីដែលដាំបន្លែ លោកបានទទួលប្រាក់ឬ លោកបានទទួលមាសឬ ម្យ៉ាងទៀត លោកប្រព្រឹត្តស្រដៀងនឹងអ្នកលក់បន្លែ ។

បទថា **តេន សោ កុបិតោ អាសិ** សេចក្ដីថា ដោយពាក្យដែលតថាគតហៅថា គហបតីនោះ តាបសកោងអាស្រ័យមានះ ជាប់ក្នុងមានះ

ក្រោធនឹងតថាគតច្រើន ទើបពោលថា ក្នុងថ្ងៃនេះ អាត្មាភាពនឹងឲ្យស្តេចសម្លាប់ទ្រង់ ឬឲ្យបំបរបង់ទ្រង់ចាកដែន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តុវំ** ក្នុងបទថា **តុវំ អជ្ជ** ស្មើគ្នានឹង **ត្វំ** អធិប្បាយថា ក្នុងពេលដែលព្រះរាជាយាងមកក្នុងកាលឥឡូវនេះឯង ។ បទថា **និសេធយិត្វា បច្ចន្តំ** សេចក្តីថា ព្រះរាជាទ្រង់បង្ក្រាបជាយដែនស្ងប់ហើយ មិនទាន់យាងចូលព្រះនគរ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ក្នុងខណៈនោះឯង ត្រាស់សួរតាបសកោងនោះថា បពិត្រលោកម្ចាស់ៗ សុខទេឬសក្ការៈ និងការរាប់អាន នៅប្រព្រឹត្តទៅដល់លោកម្ចាស់ទេឬ កុមារបានមកសម្តែងនូវការរាប់អានលោកម្ចាស់ដែរឬ ។

បទថា **កុមារោ យថា នាសិយោ** សេចក្តីថា តាបសកោងនោះបានទូលដល់ព្រះរាជានោះ ដោយប្រការដែលធ្វើព្រះរាជកុមារឲ្យវិនាស គឺឲ្យត្រូវសម្លាប់ ។ បទថា **អាណាបេសិ** សេចក្តីថា ព្រះរាជាទ្រង់ព្រះតម្រិះថា កាលនៅមានទិព្វចក្ខុ តាបសនេះជាម្ចាស់របស់យើង អ្វីដែលមិនសម្រេចដល់យើង ព្រោះហេតុនោះ យើងមិនត្រូវការបុត្រ តាបសនេះប្រសើរជាងបុត្រ ដូច្នោះហើយ ទើបមានព្រះរាជបញ្ជា ។

សួរថា ទ្រង់បញ្ជាដូចម្តេច ឆ្លើយថា ទ្រង់បញ្ជាថា ចូរកាត់ក្បាលក្នុងទីនោះឯង អធិប្បាយថា ចូរពួកអ្នកកាត់ក្បាលរបស់កុមារនោះ ក្នុងទីដែលពួកអ្នកឃើញហើយ ចូរកាត់រាងកាយរបស់កុមារនោះ ជា ៤ កំណាត់ យកទៅដាក់កណ្តាលផ្លូវវាយឲ្យពេញផ្លូវឲ្យមនុស្សឃើញ ។ ព្រោះហេតុអ្វី ព្រោះទុំះ

ជាផលរបស់ជនដែលបៀតបៀនជដិល គឺនុ៎ះជាគតិ នុ៎ះជាការសម្រេច នុ៎ះជាផលរបស់បុគ្គលដែលបៀតបៀនជដិល ។ មួយាងទៀត បទថា **ជដិលហីឡិតា** សេចក្ដីថា នុ៎ះជាការសម្រេចទោសរបស់ព្រះរាជកុមារ ព្រោះការបៀតបៀនជដិល ។ គប្បីជ្រាបអត្ថក្នុងបទនេះ ដោយប្រការដូច្នេះ ។

បទថា **តត្ថ** បានដល់ ព្រោះព្រះរាជបញ្ជារបស់ព្រះរាជានោះ ឬព្រោះការញុះញង់របស់តាបសនោះ ។ បទថា **ការណិកា** បានដល់ ពេជ្ឈឃាត គឺអ្នកសម្លាប់ចោរ ។ បទថា **ចណ្ឌា** បានដល់ មានចិត្តកាច ។ បទថា **លុទ្ទា** បានដល់ គ្រោតគ្រាតមិនមានសេចក្ដីល្អ ។ បទថា **អការុណា** ជាវេវចនៈរបស់បទថា **លុទ្ទា** នោះឯង ។ បាលីថា **អករុណា** ដូច្នេះក៏មាន អធិប្បាយថា មិនមានករុណា ។ បទថា **មាតុ អង្កេ និសិន្នស្ស** បានដល់ អង្គុយលើភ្លៅរបស់ព្រះនាងសុធម្មាទេវី ព្រះជននីរបស់តថាគត ។ បទថា **និសិន្នស្ស** ជាឆដ្ឋីវិភត្តិ ចុះក្នុងអនាទរៈ គឺប្រែថា កាលបើ ។ បទថា **អាកឌ្ឍិត្វា នយន្តិ មំ** សេចក្ដីថា ពួកពេជ្ឈឃាតទាំងនោះ យកខ្សែអូសតថាគតដូចគោ ដែលព្រះជននីតាក់តែងហើយ ឲ្យអង្គុយលើភ្លៅរបស់ព្រះនាង នាំយកទៅសម្លាប់តាមរាជបញ្ជា ។ កាលព្រះរាជកុមារត្រូវពេជ្ឈឃាតនាំទៅ ព្រះនាងសុធម្មាទេវី ចោមរោមដោយពួកទាសី មួយអន្លើដោយពួកស្នំ និងអ្នកនគរ ក៏នាំគ្នាទៅជាមួយព្រះរាជកុមារនោះ ដោយគិតថា ពួកយើងមិនឲ្យសម្លាប់ព្រះរាជកុមារ ដែលមិនមានកំហុស ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតនិយាយនឹងជនទាំងនោះ ដែលកំពុងចងតថាគត ដោយ

ចំណងដ៏មាំថា រាជកិច្ចមានដល់ខ្ញុំ សូមអ្នកទាំងឡាយនាំខ្ញុំទៅជួបនឹងស្តេចមួយរំពេចសិន ។ ពួកពេជ្ឈឃាតទាំងនោះ នាំតថាគតទៅជួបនឹងស្តេច ដែលសេពគប់នឹងតាបសលាមក លុះតថាគតបានជួប ក៏ញុំាំងស្តេចឲ្យដឹងច្បាស់ នូវការប្រព្រឹត្តនៃតាបសនោះ ព្រមទាំងញុំាំងស្តេចឲ្យលុះក្នុងអំណាចតថាគត ដូច្នេះ ។

បទថា **ពន្ធតំ គាឡ្ហពន្ធនំ** បានដល់ ពួកពេជ្ឈឃាតទាំងនោះ ត្រូវចងយ៉ាងមាំ ។ បទថា **រាជកិរិយានិ អត្ថិ មេ** សេចក្តីថា ខ្ញុំមានរាជកិច្ចដែលត្រូវក្រាបទូលដល់ព្រះរាជា ព្រោះហេតុនោះ តថាគតបានពោលពាក្យយ៉ាងនេះដល់ពួកពេជ្ឈឃាតទាំងនោះថា ចូរពួកលោកនាំខ្ញុំទៅគាល់ព្រះរាជាឲ្យឆាប់ ។

បទថា **រញ្ញោ ឧបស្សយឹសុ ចាបស្ស ចាបសេវិនោ** សេចក្តីថា ពួកពេជ្ឈឃាតនាំតថាគតទៅគាល់ព្រះរាជាដែលសេពគប់បុគ្គលលាមក ព្រោះសេពបគប់នឹងតាបសកោង ដែលមានសីលដ៏លាមក មានអាចារៈលាមក ។ បទថា **និស្វាន តំ សញ្ញាបេសឹ** សេចក្តីថា តថាគតទៅគាល់ព្រះរាជាកុរុដែលជាព្រះជនករបស់តថាគត ហើយទូលសួរថា ព្រោះហេតុអ្វី ទើបបិតាឲ្យសម្លាប់បុត្រ ។ កាលព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបបាហៅទិព្វចក្ខុ-តាបស ដែលជាម្ចាស់របស់បិតាដោយពាក្យថា គហបតីទៅវិញ បាធ្វើខុសច្រើន ។ កុមារទូលថា បពិត្របិតា កាលទូលបង្គំពោលនឹងបុគ្គលជាគហបតីថា គហបតីដូច្នេះ តើខុសដូចម្តេច ហើយទូលបន្តថា សូមព្រះបិតាទ្រង់ជឿថា តាបសនោះ ដាំដើមឈើមានផ្លែច្រើនប្រភេទ ហើយលក់ផ្កា ស្លឹក និង

ផលាផលជាដើម ពួកអ្នកលក់កម្រងផ្កា លក់បន្លែ ទិញរបស់ទាំងនោះ អំពីដៃតាបសនេះរាល់ថ្ងៃ ហើយសូមទ្រង់ពិចារណា ទីដាំដើមឈើដែលមានផ្កា និងទីដែលដាំបន្លែចុះ ។ ហើយតថាគតចូលទៅកាន់បណ្ណសាលារបស់តាបសនោះ ឲ្យពួករាជបុរសនាំកហាបណៈ និងកណ្ឌៈ ដែលតាបសបានអំពីលក់ផ្កាជាដើម ឲ្យព្រះរាជាទ្រង់ឃើញ ។ តថាគតឲ្យព្រះរាជាទ្រង់ជ្រាបថា តាបសនោះ ជាតាបសកោង ។ បទថា **មមញ្ច វសមានយិ** សេចក្តីថា ដោយការឲ្យទ្រង់យល់នោះ ព្រះរាជាទ្រង់ជ្រាបល្អថា កុមារពោលពិត តាបសកោងនេះ កាលមុនធ្វើជាអ្នកប្រាថ្នាតិច ឥឡូវនេះ ក្លាយជាបុគ្គលប្រាថ្នាច្រើន ព្រោះហេតុនោះ ទើបតថាគតនាំព្រះរាជាមកកាន់អំណាចរបស់តថាគត ដោយព្រះអង្គទ្រង់នឿយណាយក្នុងតាបសនោះ ហើយធ្លាក់ក្នុងអំណាចរបស់តថាគត ។

លំដាប់នោះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា អាត្មាអញគួរចូលព្រៃបួស ល្អជាងការនៅក្នុងសម្នាក់របស់ព្រះរាជាល្ងង់ខ្លៅបែបនេះ ហើយទូលលាព្រះរាជាថា បពិត្រមហារាជ ទូលបង្គំមិនត្រូវការនៅក្នុងទីនេះ សូមទ្រង់អនុញ្ញាត ទូលបង្គំនឹងបួស ព្រះរាជាត្រាស់ថា បុត្រសម្លាញ់ បិតាមិនបានពិចារណា បញ្ជាឲ្យសម្លាប់បុត្រ សូមបុត្រអត់ទោសឲ្យបិតាចុះ ហើយឲ្យព្រះមហាសត្វអត់ទោសឲ្យ ត្រាស់ថា ចូរកូនគ្រងរាជសម្បត្តិក្នុងថ្ងៃនេះចុះ ។ ព្រះរាជកុមារទូលថា បពិត្របិតា ក្នុងភោគសម្បត្តិដែលជារបស់មនុស្ស នឹងមានអ្វី បុត្រធ្លាប់សោយភោគសម្បត្តិដែលជាទិព្វអស់កាលយូរ ក្នុងកាលមុនបុត្រមិនជាប់ក្នុងសម្បត្តិនោះឡើយ បុត្រនឹងបួស បុត្រមិននៅក្នុងសម្នាក់នៃ

បុគ្គលដែលមានបញ្ញាដោយត្រូវជនដទៃនាំទៅ ជាបុគ្គលល្ងង់ខ្លៅបែបនោះឡើយ កាលទ្រង់ទូន្មានព្រះរាជា ទើបទ្រង់សម្តែងធម៌ដោយគាថាទាំងនេះថា

ការងារដែលបុគ្គលមិនបានពិចារណាហើយ ធ្វើគំនិតដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការផ្សំថ្នាំខុសដូច្នោះ ។ ឯការងារដែលបុគ្គលពិចារណាហើយទើបធ្វើ គំនិតដែលបុគ្គលកំណត់ត្រឹមត្រូវហើយ ទើបគិត រមែងមានផលដ៏ចម្រើន ដូចជាការផ្សំថ្នាំត្រូវ ដូច្នោះឯង ។

គ្រហស្ថអ្នកបរិភោគកាម ខ្ជិល មិនល្អ អ្នកបួសមិនសង្រួម មិនល្អ ព្រះរាជាអ្នកមិនពិចារណាហើយធ្វើ មិនល្អ បណ្ឌិតដែលមានសេចក្តីក្រោធ ការក្រោធនោះ ក៏មិនល្អឡើយ ។

បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយ សឹមធ្វើ មិនត្រូវធ្វើទាំងមិនពិចារណាទេ បពិត្រព្រះរាជា ដ្បិតថា យស និងសេចក្តីសរសើរ រមែងចម្រើនដល់បុគ្គលអ្នកពិចារណាហើយទើបធ្វើ ។

បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយ សឹមដាក់អាជ្ញា ការដែលបុគ្គលធ្វើដោយរួសរាន់ រមែងក្តៅក្រហាយម្យ៉ាងទៀត ប្រយោជន៍ទាំងឡាយ ដែលនរជនផ្តងឡើងត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្តៅក្រហាយខាងក្រោយ ។ ជនទាំងឡាយ បែងចែកហើយ ទើបធ្វើការងារទាំងឡាយ ដែលមិន

មានសេចក្តីក្តៅក្រហាយក្នុងលោក ការងារទាំងនោះ ជាអំពើដែលអ្នកប្រាជ្ញសរសើរហើយថា មានសេចក្តីសុខជាកម្រៃ ជាអំពើដែលអ្នកប្រាជ្ញចុះអនុមតិហើយ ។ បពិត្រព្រះអគ្គ ជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាត មកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះឧរូនៃមាតា ត្រូវពួកទូតទាំងនោះ ទង់ទាញមកដោយរហ័ស ទូលព្រះបង្គំជាខ្ញុំ បានដល់នូវមរណភ័យ ដ៏ក្តៅក្រហាយយ៉ាងចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទីស្រឡាញ់ដូចមធុរស ទូលព្រះបង្គំជាខ្ញុំបានហើយ ថ្ងៃនេះ ទូលព្រះបង្គំជាខ្ញុំ បានរួចចាកការសម្លាប់ដោយលំបាក ទូលព្រះបង្គំជាខ្ញុំ មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជាតែម្យ៉ាង ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មិនបានពិចារណាហើយ បានដល់ មិនស្ទាបស្ទង់ហើយ ។ ពាក្យថា មិនកំណត់ បានដល់ មិនកំណត់ហើយ ។ ពាក្យថា ខុស បានដល់ វិបត្តិ ( មិនមានគុណភាព ) ។ ពាក្យថា ផល បានដល់ សេចក្តីសម្រេច ។ ពាក្យថា មិនសង្រួម បានដល់ ខ្វះនូវការសង្រួម គឺជាមនុស្សទ្រុស្តសីល ។ ពាក្យថា សឹមដាក់អាជ្ញា បានដល់ គប្បីដាក់អាជ្ញា ។ ពាក្យថា ដោយរួសរាន់ បានដល់ ដោយឆាប់ គឺដោយរហ័ស ។ ពាក្យថា ផ្គងឡើងត្រឹមត្រូវ បានដល់ ដោយការតាំងចិត្តទុកដោយប្រពៃ អធិប្បាយថា ប្រយោជន៍ទាំងឡាយរបស់បុគ្គលដែលធ្វើ ដោយការតាំងចិត្ត

ទុកដោយប្រពៃ គឺដោយចិត្តដែលតម្កល់ទុកដោយឧបាយ រមែងមិនក្តៅក្រហាយក្នុងកាលឯក្រោយ ។ ពាក្យថា បែងចែក បានដល់ ចែកដោយបញ្ញាយ៉ាងនេះថា កម្មនេះគួរធ្វើ កម្មនេះមិនគួរធ្វើ ដូច្នេះ ។ ពាក្យថា ការងារទាំងឡាយ បានដល់ កម្មទាំងឡាយ ។ ពាក្យថា ដែលអ្នកប្រាជ្ញចុះអនុមតិហើយ បានដល់ ដែលបណ្ឌិតទាំងឡាយឃើញប្រពៃ គឺមិនមានទោស ។ ពាក្យថា ដ៏ក្តៅក្រហាយ សេចក្តីថា ខ្ញុំដល់នូវមរណភ័យ ជាទុក្ខ មិនគួរត្រេកអរ ចង្អៀតចង្អល់ជាពន្លឹក ។ ពាក្យថា បាន បានដល់ បានជីវិតដោយកម្លាំងប្រាជ្ញារបស់ខ្លួន ។ ពាក្យថា មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជា បានដល់ ខ្ញុំមានចិត្តប្រាថ្នាចំពោះបព្វជ្ជា ។

កាលព្រះមហាសត្វទ្រង់សម្តែងធម៌យ៉ាងនេះ ព្រះរាជាត្រាស់នឹងព្រះទេវីថា នែទេវី ចូរនាងឃាត់ឱរស ។ ព្រះទេវីក៏ទ្រង់ពេញព្រះហឫទ័យក្នុងការបួសរបស់ព្រះរាជកុមារដូចគ្នា ។ ព្រះមហាសត្វថ្វាយបង្គំព្រះជនក ព្រះជននីហើយ ទ្រង់សូមខមាទោសថា បើទោសមានដល់ទូលបង្គំ សូមទ្រង់អត់ទោសឲ្យដល់ទូលបង្គំចុះ ហើយទ្រង់លាមហាជន បែរមុខទៅកាន់ហិមវន្តប្បទេស ។ កាលព្រះមហាសត្វយាងទៅហើយ មហាជនក៏នាំគ្នាវាយតប់ជដិលកោងរហូតដល់អស់ជីវិត ។ ព្រះពោធិសត្វឲ្យរាជបុរស មានអមាត្យរាជបរិស័ទ មួយអន្លើដោយអ្នកនគរ ដែលមានមុខជោកដោយទឹកភ្នែកដែលជាប់តាមទៅត្រឡប់ ។ កាលមនុស្សទាំងឡាយនាំគ្នាត្រឡប់ ពួកទេវតាមកក្នុងភេទរបស់មនុស្ស នាំព្រះពោធិសត្វឆ្លងភ្នំ ៧ ព្រះពោធិសត្វបួសជា

ឥសី ក្នុងបណ្ណសាលាដែលវិស្សុកម្មនិម្មិតក្នុងហិមវន្តប្បទេស ដូចព្រះមានព្រះភាគត្រាស់ថា

ព្រះរាជាជាបិតារបស់តថាគតនោះ សូមទោសតថាគតក្នុងទីនោះ ហើយប្រទាននូវភាពជាស្តេចធំ ដល់តថាគត តែតថាគតនោះឯងទម្លាយនូវងងឹត ចូលទៅកាន់ផ្នួសវិញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តមំ ផាលយិត្វា** បានដល់ កម្ចាត់ងងឹត គឺមោហៈ ដែលជាបដិបក្ខចំពោះការឃើញទោសក្នុងកាម ។ បទថា **បព្វជឹ** បានដល់ ចូលដល់ហើយ ។ បទថា **អនគារិយំ** បានដល់ ជាអ្នកបួស ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ប្រយោជន៍ ដែលព្រះអង្គទ្រង់លះរាជឥស្សរិយយសនោះ ក្នុងកាលនោះ ទើបត្រាស់គាថាចុងក្រោយថា **ន មេ ទេស្សំ** ដូច្នេះជាដើម សេចក្តីនៃគាថានោះ មានន័យដូចពោលហើយ ។

កាលព្រះមហាសត្វបួសហើយយ៉ាងនេះ ទេវតាមកដោយភេទ ជាអ្នកបម្រើក្នុងរាជត្រកូល ទំនុកបម្រុងព្រះមហាសត្វអស់កាល ១៦ ឆ្នាំ ។ ព្រះមហាសត្វញុំាងឈាន និងអភិញ្ញាឲ្យកើតក្នុងទីនោះ ហើយបានចូលដល់ព្រហ្មលោក ។

តាបសកោង ក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះជននី ក្នុងកាលនោះ បានមកជាព្រះមហាមាយា ក្នុងកាលឥឡូវនេះ មហារក្ខិតតាបស ក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរ ក្នុងកាលឥឡូវ

នេះ សោមនស្សកុមារ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីពោលចំពោះដល់បារមី ១០ ដោយន័យដូចពោលហើយ ក្នុងយុធញ្ជយចរិយានោះ ។

ក្នុងចរិយានេះ លោកលើកនេក្ខម្មបារមីឡើងកាន់ទេសនា ថាជាបារមីកំពូលក្រៃលែង ម្យ៉ាងទៀត គប្បីជ្រាបគុណានុភាពរបស់ព្រះមហាសត្វយ៉ាងនេះ គឺភាពដែលព្រះអង្គទ្រង់អាចក្នុងរាជកិច្ចទាំងឡាយ ក្នុងខណៈមានព្រះជន្មបាន ៧ វស្សា ការចាប់តាបសនោះថាជាជដិលកោងបាន ការមិនតក់ស្លុតកាលព្រះរាជាខ្វល់ខ្វាយ មានបញ្ជាឲ្យសម្លាប់ ការដែលព្រះពោធិសត្វយាងទៅគាល់ព្រះរាជា ហើយប្រកាសថា ជដិលនោះខុសដោយន័យផ្សេងៗ និងប្រកាសថា ព្រះអង្គមិនមានកំហុសក្នុងកណ្តាលមហាជន ហើយគិតបានថាព្រះរាជាជឿបុគ្គលដទៃទូន្មាន និងជាបុគ្គលល្ងង់ខ្លៅ កាលព្រះរាជាទ្រង់សូមខមាទោសហើយ ក៏នៅតែដល់នូវសេចក្តីសង្វេគចាកការនៅក្នុងរាជសម្នាក់ និងចាកភាពជាធំក្នុងរាជសម្បត្តិ សូម្បីព្រះរាជាទ្រង់អង្វរ មានប្រការផ្សេងៗ ក៏ទ្រង់លះសិរីរាជសម្បត្តិ ដែលនៅក្នុងកណ្តាប់ដៃ ដូចស្តោះដុំទឹកមាត់ចោល ជាអ្នកមិនមានចិត្តជាប់ក្នុងទីណាៗ ចេញបួស កាលបួសហើយ ត្រេកអរក្នុងការស្ងាត់ មិនយូរប៉ុន្មាន ក៏ញុំាងឈាន និងអភិញ្ញាឲ្យកើតដោយមិនលំបាកដោយប្រការដូច្នេះ ៕៚

**អដ្ឋកថាសោមនស្សចរិយា ចប់**

# សុត្តន្តបិដក

## អយោឃរចរិយាទី ៣

[ ២៣ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជារាជកុមារឈ្មោះអយោឃរៈ ជាឱរសនៃព្រះបាទកាសិករាជ ចម្រើនវ័យវឌ្ឍនាការ ក្នុងផ្ទះជាវិការនៃដែក ។ ព្រះរាជបិតារបស់តថាគតទ្រង់ត្រាស់នឹងតថាគតថា ម្នាលកូន ជីវិត ( របស់កូន ) រស់នៅបានដោយលំបាក បិតាចិញ្ចឹមថែរក្សាកូន ក្នុងផ្ទះជាវិការនៃដែកដ៏ចង្អៀត ចូរកូនគ្រប់គ្រងមហាប្រឹថពីទាំងមូលនេះ ព្រមទាំងដែននិគម និងពួកជនក្នុងថ្ងៃនេះ ។ តថាគតថ្វាយបង្គំ ប្រណម្យអញ្ជលីនូវព្រះមហាក្សត្រ ហើយពោលនូវពាក្យនេះថា ពពួកសត្វណាមួយលើផែនដី ជាសត្វថោកទាប ឬខ្ពង់ខ្ពស់ និងកណ្តាល សត្វទាំងនោះ ពុំមានការរក្សាឡើយ តែងចម្រើនឡើងក្នុងផ្ទះរបស់ខ្លួនជាមួយនឹងពួកញាតិរបស់ខ្លួន ចម្លែកតែខ្ញុំព្រះអង្គ មានការចិញ្ចឹមជីវិត ក្នុងផ្ទះជាវិការនៃដែក ដ៏ចង្អៀតនេះ ចាត់ទុកជាការខ្ពង់ខ្ពស់ក្នុងលោក ខ្ញុំចម្រើនវ័យក្នុងផ្ទះជាវិការនៃដែក ដែលពុំមានពន្លឺព្រះចន្ទ និងព្រះអាទិត្យ ។ ខ្ញុំប្រសូតចេញចាកផ្ទៃនៃមាតា ដែល

ពេញដោយសាកសព មានក្លិនស្អុយ ហើយត្រូវគេដាក់ក្នុងផ្ទះ ជាវិការនៃដែកទៀត បានសេចក្តីទុក្ខយ៉ាងខ្លាំង ជាងកាលដែលនៅក្នុងផ្ទៃ នៃមាតានោះទៅទៀត ។ ខ្ញុំបានសេចក្តីទុក្ខ អាក្រក់ក្រៃលែង ប្រាកដដូច្នោះ បើខ្ញុំនៅត្រេកអរនឹងរាជ្យ ខ្ញុំជាបុគ្គលថោកទាបបំផុត ជាងបុរសដ៏លាមកទៅទៀត ។ ខ្ញុំជាបុគ្គលនឿយណាយ នឹងកាយស្អុយ ពុំត្រូវការដោយរាជ្យឡើយ ខ្ញុំស្វែងរកនូវទី ដែលមច្ចុរាជញាំញីមិនបាននោះ ដែលជាទីរម្ងាត់នូវទុក្ខ ។ តថាគតលុះគិតយ៉ាងនេះហើយ ពួកមហាជនក៏យំស្រែក តថាគតកាត់នូវចំណង ( គឺតណ្ហា ) ហើយចូលកាន់ព្រៃធំ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ មាតាបិតាមិនមែនជាទីស្អប់ របស់តថាគតទេ ទាំងយសដ៏ធំក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់នៃតថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ។

**អយោឃរចរិយាទី ៣ ចប់**

# អដ្ឋកថា

## អយោឃរចរិយា

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអយោឃរចរិយាទី ៣ ដូចតទៅ បទថា **អយោឃរម្ហិ សំវឌ្ឍោ** បានដល់ ចម្រើនហើយក្នុងផ្ទះធំ ដែលធ្វើដោយដែក រាង ៤ ជ្រុង ដើម្បីការពារភ័យដែលកើតអំពីអមនុស្ស និងអន្តរាយ ។ បទថា **នាមេនាសិ អយោឃរោ** បានដល់ ព្រោះភាពជាអ្នកកើត និងចម្រើនក្នុងផ្ទះដែក ទើបប្រាកដឈ្មោះថា អយោឃរកុមារ ។

សេចក្តីសង្ខេបមានដូច្នេះថា ក្នុងកាលនោះ ក្នុងអត្តភាពមុន អគ្គមហេសីរបស់ព្រះបាទកាសី ស្រីរូមប្តី តាំងសេចក្តីប្រាថ្នាថា អញគប្បីស៊ីបុត្រដែលកើតហើយរបស់នាង ហើយកើតក្នុងកំណើតយក្ខិនី កាលបានឱកាស ក្នុងកាលដែលអគ្គមហេសីនោះប្រសូត ក៏ស៊ីឱរសអស់ ២ ដង ក្នុងលើកទី ៣ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសីនោះ ព្រះរាជាទ្រង់ប្រឹក្សាជាមួយពួកមនុស្សថា យក្ខិនីមួយស៊ីឱរសដែលកើតហើយរបស់ព្រះទេវី យើងគួរធ្វើដូចម្តេចល្អ កាលពួកមនុស្សទូលថា ធម្មតាអមនុស្ស រមែងខ្លាចផ្ទះដែក គួរសាងផ្ទះ ទើបឲ្យជាងដែកសាងផ្ទះដែកធំជារាង ៤ ជ្រុង ដោយគ្រឿងតាក់តែងផ្ទះទាំងអស់ សម្រេចដោយដែក តាំងពីសសរជាដើមឲ្យសម្រេច ហើយឲ្យព្រះទេវីដែលមានគភ៌ចាស់ គង់នៅក្នុងផ្ទះដែកនោះ ។ ព្រះទេវីប្រសូតព្រះរាជឱរស មានបុញ្ញលក្ខណៈល្អក្នុងផ្ទះដែកនោះ បានថ្វាយព្រះនាមថា អយោឃរកុមារ ។ ព្រះរាជាទ្រង់ឲ្យព្រះរាជកុមារនោះ ដល់ពួកមេដោះធ្វើការរក្សាយ៉ាងធំ ទ្រង់នាំព្រះទេវីទៅគង់ខាងក្នុង ។ យក្ខិនីដល់វារៈដងទឹក

ក៏នាំទឹកទៅថ្វាយព្រះបាទវេស្សវ័ណ ហើយក៏អស់ជីវិត ។

ព្រះមហាសត្វទ្រង់ចម្រើនក្នុងផ្ទះដែកនោះឯង ដល់នូវភាពជាអ្នកដឹងក្តី រៀនសិប្បៈទាំងពួងក្នុងផ្ទះដែកនោះ ព្រះរាជាទ្រង់ជ្រាបថា ព្រះរាជឱរសមានព្រះជន្ម ១៦ វស្សា ទើបមានព្រះតម្រាស់នឹងពួកអមាត្យថា យើងនឹងប្រគល់រាជសម្បត្តិឲ្យ ចូរពួកលោកនាំព្រះរាជឱរសរបស់យើងមក ពួកអមាត្យទទួលព្រះរាជបញ្ជាហើយ ទ្រង់ឲ្យតាក់តែងព្រះនគរ នាំមង្គលហត្ថី ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាងទៅក្នុងទីនោះ តាក់តែងព្រះរាជកុមារ ឲ្យប្រថាប់គង់លើ-កដីរមង្គល ធ្វើប្រទក្សិណព្រះនគរ ហើយនាំមកគាល់ព្រះរាជា ។ ព្រះរាជាទតឃើញព្រះវរកាយរបស់ព្រះរាជឱរសស្អាត ទើបទ្រង់ឱបព្រះរាជឱរសនោះ ដោយសេចក្តីស្នេហាដ៏មានកម្លាំង ត្រាស់នឹងពួកអមាត្យថា ចូរពួកអ្នកអភិសេកឱរសរបស់យើងក្នុងថ្ងៃនេះឯង ព្រះមហាសត្វថ្វាយបង្គំព្រះជនកហើយទូលថា ខ្ញុំមិនត្រូវការសម្បត្តិ ខ្ញុំនឹងបួស សូមទ្រង់អនុញ្ញាតឲ្យខ្ញុំបួសចុះ ដូចព្រះមានព្រះភាគត្រាស់ថា

ព្រះរាជបិតារបស់តថាគត ទ្រង់ត្រាស់នឹងតថាគតថា ម្នាលកូន
ជីវិត ( របស់កូន ) រស់នៅបានដោយលំបាក បិតាចិញ្ចឹម ថែ
រក្សាកូន ក្នុងផ្ទះជាវិការនៃដែកដ៏ចង្អៀត ចូរកូនគ្រប់គ្រងមហា
ប្រឹថពីទាំងមូលនេះ ព្រមទាំងដែន និគម និងពួកជនក្នុងថ្ងៃនេះ ។
តថាគតថ្វាយបង្គំ ប្រណម្យអញ្ជលីនូវព្រះមហាក្សត្រ ហើយ
ពោលនូវពាក្យនេះថា ពពួកសត្វណាមួយ លើផែនដី ជាសត្វ

ថោកទាប ឬខ្ពង់ខ្ពស់ និងកណ្តាល សត្វទាំងនោះ ពុំមានការរក្សាឡើយ តែងចម្រើនឡើងក្នុងផ្ទះរបស់ខ្លួន ជាមួយនឹងពួកញាតិរបស់ខ្លួន ចម្លែកតែខ្ញុំព្រះអង្គ មានការចិញ្ចឹមជីវិតក្នុងផ្ទះ ជាវិការនៃដែកដ៏ចង្អៀតនេះ ចាត់ទុកជាការខ្ពង់ខ្ពស់ក្នុងលោក ខ្ញុំចម្រើនវ័យក្នុងផ្ទះជាវិការនៃដែក ដែលពុំមានពន្លឺព្រះចន្ទ និងព្រះអាទិត្យ ។ ខ្ញុំប្រសូតចេញចាកផ្ទៃនៃមាតា ដែលពេញដោយសាកសព មានក្លិនស្អុយ ហើយត្រូវគេដាក់ក្នុងផ្ទះជាវិការនៃដែកទៀត បានសេចក្តីទុក្ខយ៉ាងខ្លាំង ជាងកាលដែលនៅក្នុងផ្ទៃនៃមាតានោះទៅទៀត ។ ខ្ញុំបានសេចក្តីទុក្ខអាក្រក់ ក្រៃលែងប្រាកដដូច្នោះ បើខ្ញុំនៅត្រេកអរនឹងរាជ្យ ខ្ញុំជាបុគ្គលថោកទាបបំផុត ជាងបុរសដ៏លាមកទៅទៀត ។ ខ្ញុំជាបុគ្គលនឿយណាយ នឹងកាយស្អុយ ពុំត្រូវការដោយរាជ្យឡើយ ខ្ញុំស្វែងរកនូវទីដែលមច្ចុរាជញាំញីមិនបាននោះ ដែលជាទីរម្ងាប់នូវទុក្ខ ។ តថាគតលុះគិតយ៉ាងនេះហើយ ពួកមហាជនក៏យំស្រែក តថាគតកាត់នូវចំណង ( គឺតណ្ហា ) ហើយចូលកាន់ព្រៃធំ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់នៃតថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឱរកេ្ខណ** សេចក្ដីថា ព្រះបិតាត្រាស់ថា នៃកូន បងប្រុសរបស់កូនពីរនាក់ ត្រូវយក្ខិនីម្នាក់បរិភោគ កូនបានទទួលសេចក្ដីទុក្ខ លំបាក ដែលធ្វើដើម្បីការពារកូនចាកភ័យរបស់អមនុស្សនោះ ។ បទថា **សម្បីឡេ បតិចោសិតោ** សេចក្ដីថា កូនចម្រើនធំធាត់មកក្នុងទីដែលចង្អៀត តាំងអំពីប្រសូតក្នុងផ្ទះដែកដែលជាទីចង្អៀត ដើម្បីការពារអមនុស្សច្រើនយ៉ាង រហូតដល់អាយុ ១៦ ឆ្នាំ ។ បទថា **អជ្ជេវ បុត្ត បដិបជ្ជ កោវលំ វសុធំ ឥមំ** សេចក្ដីថា កូនបានអភិសេកដោយស័ង្ខទាំងបី ដាក់នៅលើគំនររតនៈខាងក្រោម ស្វេតច្ឆត្រដែលប្រដាប់ដោយកម្រងមាស ថ្ងៃនេះ ចូរគ្រប់គ្រងផែនដី គឺមហា-ប្រឹថពីនេះ មួយអន្លើដោយដែន ដែលមានមហាសមុទ្រជាទីបំផុតតែម្យ៉ាង ដែលជារបស់ត្រកូលនេះ មួយអន្លើដោយអ្នកនិគមដែលជាស្រុកធំ ព្រមទាំង បរិវារជនជាច្រើន ។ អធិប្បាយថា ចូរកូនសោយរាជសម្បត្តិចុះ ។ បទថា **វន្ទិត្វា ខត្តិយំ អញ្ជលី បគ្គហេត្វាន ឥធំ វចនមព្រវី** សេចក្ដីថា តថាគត ថ្វាយបង្គំក្សត្រ ព្រះជនករបស់តថាគតដែលជារាជានៃដែនកាសី ផ្គងអញ្ជលី ដល់ព្រះអង្គ ហើយបានពោលពាក្យនេះ ។

បទថា **យេ កេចិ មហិយា សត្តា** បានដល់ សត្វទាំងឡាយពួកខ្លះ ក្នុងមហាប្រឹថពីនេះ ។ បទថា **ហីនមុក្កដ្ឋមជ្ឈិមា** សេចក្ដីថា ថោកទាប ឧក្រិដ្ឋ និងកណ្ដាល ព្រោះរស់នៅក្នុងកណ្ដាលរបស់សត្វទាំងពីរ ។ បទថា **សកេ គេហេ** បានដល់ សត្វទាំងឡាយនោះ ចម្រើនក្នុងផ្ទះរបស់ខ្លួន ។ បទថា **សកញាតិភិ** បានដល់ សត្វទាំងឡាយ ត្រេកអរ រីករាយ មិន

លំបាក រមែងចម្រើនតាមសម្បត្តិជាមួយញាតិរបស់ខ្លួន ។

បទថា **ឥធំ លោកេ ឧត្តរិយំ** សេចក្តីថា ការបិញ្ចឹមនេះ មិនមានអ្នកណាដូចក្នុងលោកនេះ ជាពិសេសចំពោះខ្ញុំ ។ ការចិញ្ចឹមខ្ញុំក្នុងទីចង្អៀតគឺការចម្រើនធំធាត់របស់ខ្ញុំក្នុងទីចង្អៀតនោះដូចម្តេច ជាការចម្រើនធំធាត់ក្នុងផ្ទះដែក ប្រាសចាកពន្លឺព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **សំវឌ្ឍោម្ហិ** បានដល់ ខ្ញុំចម្រើនធំធាត់ ។ បទថា **បូតិកុណបសម្បុណ្ណា** សេចក្តីថា កាលការសង្ស័យក្នុងជីវិតប្រព្រឹត្តទៅ ខ្ញុំប្រសូតចាកឧទររបស់ព្រះជននី ពេញទៅដោយសាកសពច្រើនប្រការ មានក្លិនស្អុយដូចគ្នានឹងគូថនរកបានដូចម្តេច ។ បទថា **តតោ ឃោរតរេ** សេចក្តីថា ទារុណក្រៃលែងជាងនៅក្នុងគភ៌ជាទុក្ខព្រោះនៅមិនល្អ ។ បទថា **បក្ខិត្តោយោឃរេ** ព្រះមហាក្សត្រសម្តែថា ទុកក្នុងផ្ទះដែក ដូចជាឃុំឃាំងក្នុងគុក ។

បទថា **យទិ** ក្នុងបទថា **យទិហំ** នេះ ត្រឹមតែជានិបាត ។ បទថា **តាទិសំ** សេចក្តីថា ខ្ញុំបានទទួលទុក្ខទារុណក្រៃលែង ដូចដែលពោលហើយក្នុងកាលមុន បើនៅត្រេកអរក្នុងរាជសម្បត្តិ កាលបើយ៉ាងនោះ ខ្ញុំនឹងអាក្រក់ក្រៃលែងជាងបុគ្គលអាក្រក់ទៅទៀត ។ បទថា **ឧក្កណ្ឋិតោម្ហិ កាយេន** បានដល់ ខ្ញុំតានតឹង គឺនឿយណាយដោយកាយស្អុយ មានការមិនទាន់ផុតចាកការនៅក្នុងគភ៌ជាដើម ។ បទថា **រជ្ជេនម្ហិ អនត្ថិកោ** សេចក្តីថា ខ្ញុំមិនត្រូវការសូម្បីរាជសម្បត្តិ ។ ទោះបីខ្ញុំផុតចាកកណ្តាប់ដៃរបស់យក្ខិនី ក៏មិនផុតចាកជរា និងមរណៈបានឡើយ ប្រយោជន៍អ្វីដោយរាជសម្បត្តិរបស់ខ្ញុំ

ព្រោះធម្មតារាជសម្បត្តិ ជាប្រភពកើតនៃការវិនាសទាំងពួង ។ តាំងពីកាលដែលតាំងនៅក្នុងរាជសម្បត្តិនោះ ឈ្មោះថា ចេញទៅបានលំបាក ព្រោះហេតុនោះ ខ្ញុំមិនគ្រប់គ្រងរាជសម្បត្តិ នឹងស្វែងរកការរម្ងត់ ។ បទថា **យត្ថ មំ មច្ចុ ន មទ្ទិយេ** សេចក្តីថា ខ្ញុំនឹងស្វែងរកធម៌ជាគ្រឿងរម្ងត់ គឺអមតមហានិព្វាន ជាទីដែលមច្ចុរាជ មានសេនាធំគប្បីញាំញី គប្បីគ្របសង្កត់ខ្ញុំដែលតាំងនៅមិនបាន ។ បទថា **ឃាយាហំ ចិន្តយិត្វាន** សេចក្តីថា តថាគតគិតដោយឧបាយ ដោយការពិចារណាដល់ទោសក្នុងសង្សារ មានប្រការផ្សេងៗដូចពោលហើយនេះយ៉ាងនេះ និងព្រោះការឃើញអានិសង្សក្នុងនិព្វាន ។ បទថា **វិរវន្តេ មហាជនេ** សេចក្តីថា កាលមហាជនមានព្រះជនក ព្រះជននីជាប្រធាន កំពុងយំខ្សឹកខ្សួល ដោយអត់ធ្មត់ដល់សេចក្តីទុក្ខ ដែលព្រាត់ប្រាសចាកតថាគតមិនបាន ។ បទថា **ឆេត្វាន ពន្ធនំ ជេត្វា** សេចក្តីថា តថាគតបានកាត់នូវចំណង ដោយការកាត់នូវគ្រឿងចង គឺតណ្ហាក្នុងជននោះមានការជាប់ជំពាក់ដោយញាតិជាដើម ហើយចូលកាន់ព្រៃធំ ដោយការចូលដល់បព្វជ្ជា ដូចគជសារមានកម្លាំងច្រើន កាត់នូវចំណង គឺខ្សែដែលមិនរឹងមាំបានដោយងាយ ដូច្នោះ ។ គាថាចុងក្រោយ មានអត្ថដូចពោលហើយនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងរឿងនោះដូចតទៅ ព្រះមហាសត្វទ្រង់កាត់ព្រះហឫទ័យក្នុងការបួសរបស់ព្រះអង្គហើយ កាលព្រះរាជាត្រាស់ថា បុត្រសម្លាញ់ បុត្របួសធ្វើអ្វី ទើបទូលថា បពិត្រព្រះជនក បុត្រនៅក្នុង

ព្រះឧទររបស់ព្រះជននីអស់ ១០ ខែ ដូចនៅក្នុងគូថនរក កាលចេញចាក ព្រះឧទររបស់ព្រះជននីហើយ ក៏ត្រូវនៅក្នុងគុកអស់ ១៦ ឆ្នាំ ព្រោះខ្លាច យក្ខិនី មិនបានឃើញសូម្បីតែខាងក្រៅ ដូចធ្លាក់នៅក្នុងឧស្សទនរក ទោះបី កូនផុតអំពីយក្ខិនី ក៏មិនផុតការចាស់ ការស្លាប់បានឡើយ ។ ឈ្មោះថា មច្ចុនេះ ដែលបុគ្គលណាមួយ មិនអាចឈ្នះបាន កូនទៀយណាយក្នុងភព កូននឹងបួសប្រព្រឹត្តធម៌ ទម្រាំព្យាធិ ជរា និងមរណៈមកដល់ សម្រាប់រាជ-សម្បត្តិរបស់កូន បពិត្រព្រះជនក សូមទ្រង់អនុញ្ញាតឲ្យកូនបួសចុះ ហើយ ទ្រង់សម្តែងធម៌ដល់ព្រះជនក ២៤ គាថា មានគាថាជាដើមថា

សត្វនៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅ ដូចជាពពកដែលតាំងឡើង សត្វនោះ កាលទៅ រមែងមិន ត្រឡប់វិញទេ ដូច្នេះ ។

ហើយទូលថា បពិត្រព្រះបិតា រាជសម្បត្តិរបស់ព្រះបិតា សូមជា របស់ព្រះបិតានោះចុះ បុត្រមិនត្រូវការរាជសម្បត្តិនេះឡើយ កាលបុត្រ ពោលនឹងបិតានេះឯង ព្យាធិ ជរា និងមរណៈក៏គប្បីមកដល់ សូមទ្រង់ឈប់ ចុះ ហើយទ្រង់លះកាមទាំងឡាយ ដូចដំរីចុះប្រេងកាត់នូវប្រវាក់ដែក ដូចកូន សីហៈទម្លាយនូវទ្រុងមាស ដូច្នោះហើយ ទ្រង់ថ្វាយបង្គំព្រះជនក ព្រះជននី ចេញបព្វជ្ជា ។

លំដាប់នោះ ព្រះបិតារបស់ព្រះមហាសត្វទ្រង់ព្រះតម្រិះថា កុមារនេះ ប្រាថ្នានឹងបួស តើអញនៅធ្វើអ្វី អញក៏មិនត្រូវការរាជសម្បត្តិ ទើបទ្រង់លះ

រាជសម្បត្តិចេញបួសមួយអន្លើយដោយព្រះរាជឱរសនោះឯង កាលព្រះរាជាចេញបួស អ្នកនគរទាំងអស់ មានព្រះទេវី អមាត្យ ព្រាហ្មណ៍ គហបតីជាដើម ក៏លះបង់ភោគសម្បត្តិចេញបួស បានជាមហាសមាគម មានបរិស័ទប្រមាណ ១២ យោជន៍ ព្រះមហាសត្វទ្រង់នាំមហាជនទាំងនោះ ចូលកាន់ហិមវន្តប្បទេស ។

សក្កទេវរាជទ្រង់ជ្រាបថា ព្រះមហាសត្វចេញបួស ទើបទ្រង់បញ្ជូនវិស្សុកម្មទេវបុត្រ ឲ្យសាងអាស្រមបទ បណ្តាយ ១២ យោជន៍ ទទឹង ៧ យោជន៍ ។ រៀបចំបរិក្ខារបព្វជិតទុកគ្រប់គ្រាន់ ។ ក្នុងចរិយានេះ ការបួសរបស់ព្រះមហាសត្វ ការឲ្យឱវាទ ការទៅកាន់ព្រហ្មលោក និងកិច្ចបដិបត្តិដោយប្រពៃរបស់បរិស័ទទាំងអស់ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងមហាគោវិន្ទចរិយានោះឯង ។

ព្រះជនក ព្រះជននី ក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ បរិស័ទទាំងឡាយ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ អយោឃរបណ្ឌិត ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។ ការពោលចំពោះដល់បារមីដ៏សេស និងការប្រកាសដល់អានុភាពរបស់ព្រះពោធិសត្វនោះ គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ។៚

## អដ្ឋកថាអយោឃរចរិយា ចប់

# សុត្តន្តបិដក

## ភីសចរិយាទី ៤

[ ២៤ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងពារាណសី ដែនកាសី មានបងប្អូនស្រី និងបងប្អូនប្រុស ៧ នាក់ ។ តថាគតជាច្បងនៃជនទាំង ៧ នាក់នុ៎ះ ប្រកបដោយសុក្កធម៌ គឺហិរិ និងឱត្តប្បៈ ឃើញនូវភព ( មានកាមភពជាដើម ) ថាគួរខ្លាច ហើយត្រេកអរក្នុងនេក្ខម្មៈ ។ ពួកសម្លាញ់មានអធ្យាស្រ័យត្រូវគ្នា ដែលមាតាបិតាប្រើឲ្យទៅអញ្ជើញតថាគត ដោយកាមទាំងឡាយថា អ្នកចូរទ្រទ្រង់វង្សត្រកូលចុះ ។ ពាក្យណាដែលពួកសម្លាញ់ទាំងនុ៎ះ បានពោលហើយ ជាពាក្យនាំមកនូវសេចក្ដីសុខ ក្នុងគិហិភាព ពាក្យនោះ ជាពាក្យអាក្រក់សម្រាប់ខ្ញុំ ដូចជាភាជន៍ដ៏ក្ដៅ ។ កាលនោះ ពួកសម្លាញ់ទាំងនោះសួរសេចក្ដីប្រាថ្នារបស់តថាគត នឹងតថាគត ដែលជាអ្នកបោះបង់នូវកាមថា ម្នាលសម្លាញ់ បើអ្នកមិនបរិភោគកាមទេ អ្នកចង់បានអ្វីទៅវិញ ។ តថាគតជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន បានពោលពាក្យនេះ ប្រាប់ពួកសម្លាញ់ទាំងនោះ ដែលស្វែងរកប្រយោជន៍ ( ដល់

តថាគត ) ថា ខ្ញុំត្រេកអរក្នុងនេក្ខម្មៈ ខ្ញុំមិនប្រាថ្នានូវគិហិភាពទេ ។ សម្លាញ់ទាំងនោះ ស្តាប់ពាក្យរបស់តថាគតបានហើយ ទៅជម្រាបមាតាបិតា ( នៃតថាគត ) ឯមាតាបិតាបាននិយាយនឹងតថាគតយ៉ាងនេះថា ម្នាលព្រាហ្មណ៍ដ៏ចម្រើន យើងទាំងអស់គ្នានឹងបួសដែរ ។ មាតាបិតាទាំងគូ និងបងប្អូនប្រុសស្រីទាំង ៧ នាក់របស់តថាគត លះបង់ទ្រព្យរាប់មិនអស់ ចូលទៅកាន់ព្រៃធំ ( ជាមួយនឹងតថាគត ) ។

## ភិសចរិយាទី ៤ ចប់

# អដ្ឋកថា

## ភឹសចរិយា

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភឹសចរិយាទី ៤ ដូចតទៅនេះ បទថា **យទា ហោមិ កាសីនំ បុរវរុត្តមេ** អធិប្បាយថា តថាគតចម្រើនធំធាត់ក្នុងក្រុងពារាណសី ដែលជានគរដ៏ប្រសើររបស់ដែន ដែលបានឈ្មោះថា កាសី ។ បទថា **ភគិនី ច ភាតរោ សត្ត និព្វត្តា សោត្ថិយេ កុលេ** សេចក្ដីថា ពួកយើងទាំងអស់ ៨ នាក់ គឺបងប្រុស ប្អូនប្រុស ៧ នាក់ គឺ ៦ នាក់ មានឧបកញ្ចនៈជាដើម និងតថាគត ជាមួយនឹងប្អូនស្រីពៅ ឈ្មោះកញ្ចនទេវី ។ ក្នុងកាលនោះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ជាព្រាហ្មណ៍ជាន់ខ្ពស់ មាំទាំក្នុងការរៀនសូត្រ ព្រោះមិនត្រេកអរក្នុងការអញ្ជើញដោយមន្ត្រ ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វកើតជាបុត្រព្រាហ្មណមហាសាលមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី ញាតិទាំងឡាយដាក់ឈ្មោះថា កញ្ចនកុមារ កាលកញ្ចនកុមារដើរបាន មានបុត្រដទៃកើតឡើងទៀត ញាតិទាំងឡាយដាក់ឈ្មោះថា ឧបកញ្ចនកុមារ ។ តាំងអំពីនោះមក ជនទាំងឡាយនាំគ្នាហៅព្រះមហាសត្វថា មហាកញ្ចនកុមារ ។ ដោយលំដាប់យ៉ាងនេះ មានកូនប្រុស ៧ នាក់ ។ ចំណែកប្អូនពៅជាធីតាតែម្នាក់ ឈ្មោះកញ្ចនទេវី ។ ព្រះមហាសត្វកាលចម្រើនវ័យ បានទៅកាន់នគរតក្កសិលា រៀនសិប្បៈសព្វយ៉ាង សម្រេចហើយក៏ត្រឡប់ ។

លំដាប់នោះ មាតាបិតា បំណងនឹងចងមហាសត្វឲ្យនៅគ្រប់គ្រងផ្ទះ ទើបពោលថា ពុក និងម៉ែ នឹងនាំទារិកាអំពីត្រកូលដែលមានជាតិស្មើនឹងខ្លួនមកឲ្យកូន ព្រះមហាសត្វពោលថា លោកឪពុក អ្នកម្ដាយ កូនមិនត្រូវការគ្រប់គ្រងផ្ទះ ព្រោះលោកសន្និវាសទាំងអស់ មានភ័យចំពោះមុខសម្រាប់កូនដូចត្រូវភ្លើងឆេះ ត្រូវឃុំឃាំងដូចគុក ប្រាកដជារបស់គួរខ្ពើម ដូចទីចាក់សំរាម ចិត្តរបស់កូនមិនមានតម្រេកក្នុងកាមទាំងឡាយ ពុក និងម៉ែ នៅមានកូនដទៃទៀត សូមឲ្យកូនទាំងនោះគ្រប់គ្រងផ្ទះចុះ ។ មាតាបិតា និងសម្លាញ់ទាំងឡាយអង្វរក៏មិនប្រាថ្នា ។ គ្រានោះ ពួកសម្លាញ់សួរព្រះពោធិសត្វថា នែសម្លាញ់ អ្នកប្រាថ្នាអ្វី ទើបមិនចង់បរិភោគកាម ព្រះពោធិសត្វក៏ប្រាប់ដល់អធ្យាស្រ័យក្នុងការចេញបួសរបស់ខ្លួន ដល់សម្លាញ់ទាំងនោះ ដូចព្រះមានព្រះភាគត្រាស់ថា

> តថាគតជាច្បងនៃជនទាំង ៧ នាក់នុ៎ះ ប្រកបដោយសុក្កធម៌ គឺហិរិ និងឱត្តប្បៈ ឃើញនូវភព ( មានកាមភពជាដើម ) ថាគួរខ្លាច ហើយត្រេកអរក្នុងនេក្ខម្មៈ ។ ពួកសម្លាញ់មានអធ្យាស្រ័យត្រូវគ្នា ដែលមាតាបិតាប្រើឲ្យទៅអញ្ជើញតថាគត ដោយកាមទាំងឡាយថា អ្នកចូរទ្រទ្រង់វង្សត្រកូលចុះ ។ ពាក្យណា ដែលពួកសម្លាញ់ទាំងនុ៎ះ បានពោលហើយ ជាពាក្យនាំមកនូវសេចក្ដីសុខក្នុងគិហិភាព ពាក្យនោះ ជាពាក្យអាក្រក់សម្រាប់ខ្ញុំ ដូចជាភាជន៍ដ៏ក្ដៅ ។ កាលនោះ ពួកសម្លាញ់ទាំងនោះ សួរសេចក្ដី

ប្រាថ្នារបស់តថាគត នឹងតថាគត ដែលជាអ្នកបោះបង់ នូវកាមថា ម្នាលសម្លាញ់ បើអ្នកមិនបរិភោគកាមទេ អ្នកចង់បានអ្វីទៅវិញ ។ តថាគតជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន បានពោលពាក្យនេះ ប្រាប់ពួកសម្លាញ់ទាំងនោះ ដែលស្វែងរកប្រយោជន៍ ( ដល់តថាគត ) ថា ខ្ញុំត្រេកអរក្នុងនេក្ខម្មៈ ខ្ញុំមិនប្រាថ្នានូវគិហិភាពទេ ។ សម្លាញ់ទាំងនោះ ស្តាប់ពាក្យរបស់តថាគតបានហើយ ទៅជម្រាបមាតាបិតា ( នៃតថាគត ) ឯមាតាបិតាបាននិយាយនឹងតថាគតយ៉ាងនេះថា ម្នាលព្រាហ្មណ៍ដ៏ចម្រើន យើងទាំងអស់គ្នានឹងបួសដែរ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឃតេសំ បុត្តោ អាសឹ** សេចក្តីថា ក្នុងកាលនោះ តថាគតជារៀមច្បងរបស់ប្អូនប្រុសស្រី ៧ នាក់ មានឧបកញ្ញៈជាដើមនោះ ។ បទថា **ហិរីសុក្កមុបាគតោ** អធិប្បាយថា តថាគតមានធម៌ស្អាត គឺហិរិ មានការខ្ពើមបាបជាលក្ខណៈ ឈ្មោះថា ជាធម៌ស ព្រោះមានធម៌សជាវិបាក និងព្រោះជម្រះសន្តានឲ្យបរិសុទ្ធ ។ តថាគតខ្ពើមបាបយ៉ាងក្រៃលែង ។ បទថា **ភវំ ទិស្វាន ភយតោ នេក្ខម្មាភិរតោ អហំ** អធិប្បាយថា តថាគតឃើញភពទាំងអស់ មានកាមភពជាដើម មានភ័យចំពោះមុខ ដោយភាពជារបស់គួរខ្លាច ដូចឃើញដំរីកាចស្ទុះមក ដូចឃើញពេជ្ឈឃាតងាជាវមកដើម្បីប្រហារ ដូចឃើញសីហៈ យក្ស អារក្ស សត្វមានពិស អាសិរពិស និងរងើកភ្លើងដែលក្តៅ ហើយត្រេកអរក្នុងបព្វជ្ជាដើម្បីផុតអំពីនោះ ចេញបួសគិតថា អញគប្បីបំពេញសម្មាបដិបត្តិ ដែលជាធម្មចរិយា និងគប្បីញុំាងឈានសមាបត្តិ

ឲ្យកើតឡើងបានដូចម្តេចហ្ន៎ ដូច្នេះ ទើបត្រេកអរក្នុងបព្វជ្ជា កុសលធម៌ និងបឋមជ្ឈានជាដើម ក្នុងកាលនោះ ។ បទថា **បហិតា** បានដល់ ដែលមាតាបិតាបញ្ជូនមក ។ បទថា **ឯកមានសា** សេចក្តីថា ពួកសម្លាញ់ដែលមានអធ្យាស្រ័យស្មើគ្នា មានឆន្ទៈតែមួយ មានការប្រព្រឹត្តជាទីពេញចិត្តនឹងតថាគតមកអំពីមុន ពោលពាក្យគួរស្អប់ មិនជាទីពេញចិត្តរបស់តថាគត ព្រោះមាតាបិតាបញ្ជូនមក ។ បទថា **កាមេហិ មំ និមន្តេន្តិ** សេចក្តីថា មានចិត្តរួមគ្នាជាមួយមាតាបិតា អញ្ជើញតថាគតដោយកាមទាំងឡាយ ។ បទថា **កុលវំសំ ធារេហិ** អធិប្បាយថា ពួកជនទាំងនោះ អញ្ជើញតថាគតថា សូមអ្នកនៅគ្រប់គ្រងផ្ទះ តាំងវង្សត្រកូលរបស់ខ្លួនចុះ ។

បទថា **យំ តេសំ វចនំ វុត្តំ** បានដល់ ពាក្យណាដែលសម្លាញ់ជាទីស្រឡាញ់របស់តថាគតទាំងនោះពោលហើយ ។ បទថា **គិហិធម្មេ សុខាវហំ** សេចក្តីថា ជាគ្រឿងនាំសុខមកឲ្យក្នុងធម៌របស់គ្រហស្ថ គឺកាលភាពជាគ្រហស្ថមាន ឈ្មោះថា នាំសុខមកឲ្យ ព្រោះនាំសេចក្តីសុខដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងភពខាងមុខមកឲ្យ ព្រោះបុរសដែលតាំងនៅក្នុងភាពជាគ្រហស្ថ ជាអ្នកបដិបត្តិតាមរបៀបដ៏ត្រឹមត្រូវ ។ បទថា **តំ មេ អហោសិ កឋិនំ** សេចក្តីថា ពាក្យរបស់ពួកសម្លាញ់របស់តថាគតទាំងនោះ និងរបស់មាតាបិតា ហាក់ដូចជាពាក្យគ្រោតគ្រាត ដូចដុតគ្រង់ត្រចៀកទាំងសងខាងដូចគ្នា ដូចគ្នានឹងផាលដែលក្តៅអស់មួយថ្ងៃ ព្រោះមិនជាទីពេញចិត្តរបស់តថាគត ព្រោះតថាគតត្រេកអរក្រៃលែងហើយ ក្នុងការបួសដោយចំណែក

មួយប៉ុណ្ណោះ ។ បទថា **តេ មំ តទា ឧក្កិបន្តំ** សេចក្តីថា សម្លាញ់របស់តថាគតទាំងនោះ បានសួរតថាគតដែលបន្សាត់ទៅ បោលទៅ ហាមទៅនូវកាមទាំងឡាយ ដែលមាតាបិតានាំចូលទៅច្រើនជង ដោយការអញ្ជើញខ្លួន ។ បទថា **បត្ថិតំ មម** សេចក្តីថា សេចក្តីប្រាថ្នាដោយកាមនេះ ឬនឹងបរិសុទ្ធជាងការបួសនេះ ដោយហេតុនោះ ទើបពួកសម្លាញ់សួរដល់សេចក្តីប្រាថ្នានោះរបស់តថាគត ដែលតថាគតប្រាថ្នាហើយថា អ្នកប្រាថ្នាអ្វីសម្លាញ់ បើអ្នកមិនបរិភោគកាម ។

បទថា **អត្ថកាមោ** បានដល់ ដែលប្រាថ្នាប្រយោជន៍ខ្លួន អធិប្បាយថា ខ្លាចបាប ។ បាលីថា **អត្ថកាមោ** ដូច្នេះក៏មាន ។ បទថា **ហិតេសិនំ** សេចក្តីថា សម្លាញ់ជាទីស្រឡាញ់ដែលស្វែងរកប្រយោជន៍ឲ្យដល់តថាគត ។ អាចារ្យពួកខ្លះពោលថា **អត្ថកាមហិតេសិនំ** គឺបុគ្គលប្រាថ្នាប្រយោជន៍ និងស្វែងរកប្រយោជន៍ បទនោះមិនល្អ ។ បទថា **បិតុ មាតុ ច សាវយុំ** សេចក្តីថា សម្លាញ់របស់តថាគតទាំងនោះ ដឹងនូវការពេញចិត្តក្នុងបព្វជ្ជារបស់តថាគត មិនប្រែប្រួល ទើបប្រាប់ពាក្យរបស់តថាគត ដែលសម្តែងដល់សេចក្តីប្រាថ្នានឹងបួសដល់បិតា និងមាតា បានពោលថា ពុក និងម៉ែ សូមលោកដឹងចុះ មហាកញ្ចនកុមារ នឹងបួសដោយចំណែកមួយប៉ុណ្ណោះ មហាកញ្ចនកុមារនោះ បុគ្គលណាម្នាក់ មិនអាចនាំចូលទៅក្នុងកាមទាំងឡាយដោយឧបាយណាមួយបានឡើយ ។ បទថា **មាតាបិតា ឯវមាហុ** សេចក្តីថា ក្នុងកាលនោះ មាតាបិតារបស់តថាគត ស្តាប់ពាក្យរបស់តថាគតដែល

ពួកសម្លាញ់របស់តថាគតប្រាប់ ទើបពោលយ៉ាងនេះថា លោកដ៏ចម្រើន ពួកយើងទាំងអស់នឹងបួសដែរ បើមហាកញ្ចនកុមារ ពេញចិត្តក្នុងការបួស ពួកខ្ញុំក៏ពេញចិត្តក្នុងវត្ថុដែលកូនខ្ញុំពេញចិត្ត ព្រោះហេតុនោះ យើងទាំងអស់ក៏នឹងបួស ។ បទថា **ភោ** ជាពាក្យហៅព្រាហ្មណ៍ទាំងនោះ ។ បាឋៈថា **បព្វជាម ភោ** ដូច្នេះក៏មាន សេចក្តីថា យើងនឹងបួសដូចគ្នា ប្អូនប្រុស ៦ នាក់ មានឧបកញ្ចនៈជាដើម និងប្អូនស្រីកញ្ចនទេវី ដឹងការពេញចិត្តក្នុងបព្វជ្ជារបស់ព្រះមហាសត្វ បំណងនឹងបួសដូចគ្នា ។ ដោយហេតុនោះ សូម្បីជនទាំងនោះ ដែលមាតាបិតាអញ្ជើញឲ្យនៅគ្រប់គ្រងផ្ទះ ក៏មិនប្រាថ្នា ។ ព្រោះហេតុនោះ ទើបពោលយ៉ាងនេះថា ម្នាលព្រាហ្មណ៍ដ៏ចម្រើន យើងទាំងអស់នឹងបួសដែរ ដូច្នេះ ។

កាលសម្លាញ់ទាំងឡាយ ពោលយ៉ាងនេះហើយ មាតាបិតាក៏ហៅព្រះមហាសត្វ ប្រាប់បំណងរៀងៗ ខ្លួន ដល់ព្រះមហាសត្វ ហើយពោលថា កូនសម្លាញ់ បើកូនបំណងបួសឲ្យខាងតែបាន ចូរកូនលះទ្រព្យ ៨០ កោដិ ដែលជារបស់កូនតាមសប្បាយចុះ ។ លំដាប់នោះ ព្រះមហាបុរសបរិច្ចាគទ្រព្យនោះដល់អ្នកក្រីក្រ និងអ្នកដំណើរជាដើមហើយចេញបួស ចូលទៅកាន់ហិមវន្តប្បទេស ។ មាតាបិតា ប្អូនប្រុស ៦ ប្អូនស្រី ១ អ្នកបម្រើប្រុស ១ អ្នកបម្រើស្រី ១ និងសម្លាញ់ ១ លះឃរាវាស បានទៅជាមួយនឹងព្រះមហាសត្វ ដូចព្រះមានព្រះភាគត្រាស់ថា

មាតាបិតាទាំងគូ និងបងប្អូនប្រុសស្រីទាំង ៧ នាក់របស់តថាគត លះបង់ទ្រព្យរាប់មិនអស់ ចូលទៅកាន់ព្រៃធំ ( ជាមួយនឹងតថាគត ) ដូច្នេះ ។

តែក្នុងអដ្ឋកថាជាតកពោលថា កាលមាតាបិតាអនិច្ចកម្ម ព្រះមហាសត្វធ្វើកិច្ចដែលគួរធ្វើដល់មាតាបិតាទាំងនោះហើយ ទើបចេញបួស ។

កាលជនទាំងនោះ មានព្រះពោធិសត្វជាប្រធាន ចូលទៅកាន់ហិមវន្តប្បទេសយ៉ាងនោះហើយ ទើបអាស្រ័យស្រះឈូកមួយ សាងអាស្រមក្នុងភូមិភាគដែលគួរជាទីត្រេកអរ បួសហើយ ញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយអាហារដែលជាឫសឈើ និងផ្លែឈើក្នុងព្រៃ ។ បណ្តាអ្នកបួសទាំងនោះ ជន ៨ នាក់ មានឧបកញ្ចនៈជាដើម ប្តូរវេនគ្នារកផ្លែឈើ ចែកចំណែករបស់ខ្លួន និងរបស់បុគ្គលក្រៅពីនោះដាក់លើផ្ទាំងថ្មមួយកន្លែង ឲ្យសញ្ញាដោយជួង កាន់យកចំណែករៀងៗ ខ្លួន ចូលទៅកាន់លំនៅ ។ ជនដ៏សេស ក៏ចេញពីបណ្ណសាលា ដោយសញ្ញាជួង កាន់យកចំណែករៀងៗ ខ្លួន ទៅកាន់លំនៅបរិភោគហើយ បំពេញសមណធម៌ ។

ក្នុងកាលតមក បាននាំយកក្រអៅឈូកមកបរិភោគដូចសព្វដង ។ ឥសីទាំងនោះមានសេចក្តីព្យាយាមក្លៀវក្លា មានឥន្ទ្រិយមាំទាំក្រៃលែង ធ្វើកសិណបរិកម្មក្នុងទីនោះ ។ លំដាប់នោះ ដោយតេជះនៃសីលរបស់ឥសីទាំងនោះ កពរបស់សក្កទេវរាជក៏ញាប់ញ័រ សក្កទេវរាជដឹងហេតុនោះ ទ្រង់ព្រះតម្រិះថា អញនឹងសាកល្បងឥសីទាំងនេះ ទើបធ្វើឲ្យចំណែករបស់ព្រះមហាសត្វអន្តរធាន

ទៅ ដោយអានុភាពរបស់ខ្លួន អស់កាល ៣ ថ្ងៃ ។ ក្នុងថ្ងៃដំបូង ព្រះមហាសត្វមិនឃើញចំណែករបស់ខ្លួន គិតថា ប្រហែលជាភ្លេចចំណែករបស់អញ ។ ក្នុងថ្ងៃទី ២ គិតថា អញមានកំហុសអ្វីទេដឹង ទើបមិនតាំងចំណែករបស់អញ ប្រហែលជាចង់បណ្តេញអញទេដឹង ។ ក្នុងថ្ងៃទី ៣ គិតថា អញនឹងស្តាប់ហេតុការណ៍នោះហើយ នឹងឲ្យអ្នកធ្វើពៀរសូមខមាទោស ទើបឲ្យសញ្ញាដោយជួងក្នុងពេលល្ងាច កាលឥសីទាំងអស់ប្រជុំគ្នាដោយសញ្ញានោះ ទើបប្រាប់រឿងនោះឲ្យជ្រាប កាលស្តាប់ថា ឥសីទាំងនោះ បានបែងចែកចំណែកសម្រាប់ខ្លួនទាំង ៣ ថ្ងៃ ទើបពោលថា ពួកលោកទុកចំណែកឲ្យខ្ញុំ តែខ្ញុំមិនបាន តើមានរឿងអ្វីហ្ន៎ ឥសីទាំងអស់ស្តាប់រឿងនោះ ក៏បានដល់នូវសេចក្តីសង្វេគ ។

ក្នុងអាស្រមនោះ សូម្បីរុក្ខទេវតាក៏ចុះមកអំពីភពរបស់ខ្លួន អង្គុយក្នុងសម្នាក់របស់ឥសីទាំងនោះ ។ ដំរីមួយគេចអំពីកណ្តាប់ដៃរបស់ពួកមនុស្សចូលព្រៃ ពានរមួយគេចអំពីកណ្តាប់ដៃរបស់គ្រូពស់ផុតហើយ ព្រោះឲ្យលេងជាមួយពស់ បានធ្វើសេចក្តីស្និទ្ធស្នាលជាមួយឥសីទាំងនោះ ក្នុងកាលនោះ ក៏បានទៅរកឥសីទាំងនោះ បានឈរក្នុងចំណែកម្ខាង ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា អញនឹងសាកល្បងពួកឥសី ឈរមិនប្រាកដខ្លួនក្នុងទីនោះដូចគ្នា ។ ក្នុងខណៈនោះ ឧបកញ្ចនតាបស ប្អូនរបស់ព្រះពោធិសត្វក្រោកឡើងថ្វាយបង្គំព្រះពោធិសត្វ ហើយសម្តែងសេចក្តីគោរពដល់ជនដ៏សេសសួរឡើងថា ខ្ញុំតាំងសញ្ញាហើយ នឹងធ្វើខ្លួនឲ្យបរិសុទ្ធបានឬ កាលឥសីទាំង

នោះពោលថា បាន ទើបឈរក្នុងកណ្តាលពួកឥសី កាលនឹងធ្វើនូវការស្បថ ទើបពោលគាថានេះថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរបាននូវសេះផង គោផង ប្រាក់ផង មាសផង ប្រពន្ធជាទីគាប់ចិត្ត ក្នុងលោកនេះផង ចូរនៅមូលមិត្តគ្នា ដោយកូន និងប្រពន្ធទាំងឡាយចុះ ដូច្នេះ ។

ព្រោះឧបកញ្ចនតាបសនោះ តិះដៀលវត្ថុកាមថា សេចក្តីទុក្ខទាំងឡាយរមែងកើតឡើងព្រោះការព្រាត់ប្រាសចាកវត្ថុដែលជាទីស្រឡាញ់ ទើបពោលគាថានេះ ។

ពួកឥសីបានស្តាប់ដូច្នោះ ក៏បិទត្រចៀកពោលថា លោកនិរទុក្ខ លោកកុំពោលយ៉ាងនោះ ពាក្យសម្បថរបស់លោកធ្ងន់ពេក ព្រះពោធិសត្វពោលថា ពាក្យសម្បថរបស់លោកធ្ងន់ពេកណាស់ លោកមិនបានកាន់យកទេ ចូរអង្គុយលើអាសនៈរបស់ខ្លួន ។ ឥសីដ៏សេស កាលធ្វើការស្បថ បានពោលគាថាទាំងនេះ តាមលំដាប់ថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរទ្រទ្រង់នូវផ្កាកម្រងផង នូវសំពត់ដែលគេនាំមកអំពីដែនកាសី និងខ្លឹមចន្ទន៍ផង ចូរឲ្យបុគ្គលនោះ មានកូនច្រើនផង ចូរឲ្យ ( បុគ្គលនោះ ) ធ្វើនូវសេចក្តីអាឡោះអាល័យ ដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយផង ។

តាបសទី ៣ សួរថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយរបស់លោក ( បុគ្គលនោះ ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស ( បាន ) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យចូរ ( បាន ) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ ( របស់ខ្លួន ) នៅគ្រប់គ្រងផ្ទះចុះ ។

តាបសទី ៤ សួរថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុតចុះ ។

តាបសទី ៥ សួរថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរជាព្រាហ្មណ៍ មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្លងក្បួនយាម និងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន ( ស្ដេច ) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។

តាបសទី ៦ សួរថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក លោកទាំងអស់ ចូរសម្គាល់ ( នូវបុគ្គលនោះ ) ថាជា

អ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទចូរឃើញ ហើយបូជានូវបុគ្គលនោះចុះ ។

តាបសជាសម្លាញ់ស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏ស្តុកស្តម្ភ ដែលកុះករដោយវត្ថុ ៤ យ៉ាង ហាក់ដូចស្តេចវាសវៈប្រទានឲ្យ ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាករាគៈចុះ ។

តាបសជាខ្ញុំប្រុសស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក បុគ្គលនោះ ចូរបានជាធំក្នុងស្រុក ចូររីករាយដោយការរាំនិងច្រៀងទាំងឡាយ ក្នុងកណ្តាលនៃសម្លាញ់ កុំឲ្យបាននូវសេចក្តីវិនាស តិចតួចអំពីស្តេចឡើយ ។

នាងកាញ្ចនទេវីស្បថថា

បពិត្រព្រាហ្មណ៍ ស្រីណា លួចក្រអៅឈូកទាំងឡាយ របស់លោក សូមឲ្យស្តេចឯករាជ ដែលទ្រង់ឈ្នះនូវផែនដី លើកតម្កើង ( ស្រីនោះ ) ឲ្យប្រសើរ លើសជាងស្រីទាំងមួយពាន់ សូមឲ្យ ( ស្រីនោះ ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។

នាងទាសីស្បថថា

បពិត្រព្រាហ្មណ៍ ទាសីណា លួចក្រអៅឈូកទាំងឡាយ របស់លោក ក៏បណ្តាទាសីទាំងឡាយ ទាសីនោះ ចូរកុំញាប់ញ័រ ( ក្នុងកណ្តាល ) នៃម្ចាស់ទាំងឡាយ ដែលជួបជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ ( ទាសីនោះ ) ចូរប្រព្រឹត្ត និយាយកុហក ព្រោះហេតុតែលាភចុះ ។

ទេវតាស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយ របស់លោក ( បុគ្គលនោះ ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្មក្នុងនគរ ឈ្មោះគជង្គលៈចុះ ចូរធ្វើនូវបង្អួចឲ្យហើយ តែមួយថ្ងៃចុះ ។

ដំរីស្បថថា

បពិត្រព្រាហ្មណ៍ ដំរីណា លួចក្រអៅឈូកទាំងឡាយ របស់លោក ដំរីនោះ ចូរជាប់ដោយអន្ទាក់ច្រើន ត្រង់កន្លែងទាំង ៦ ( គឺជើងទាំង ៤ ក និងចង្កេះ ) ចូរឲ្យគេនាំអំពីព្រៃ ជាទីរីករាយ ទៅកាន់រាជធានីចុះ ដំរីនោះ ចូរឲ្យគេចាក់ដោយកង្វេរទាំងឡាយ ដែលមានដងវែង មានបន្ទាពីរចុះ ។

ស្វាស្បថថា

បពិត្រព្រាហ្មណ៍ ស្វាណា លួចក្រអៅឈូកទាំងឡាយ របស់លោក ( ស្វានោះ ) ចូរមានប្រឡៀក ហើយគេចោះត្រចៀក

បំពាក់សំណាចុះ ឲ្យហ្លួតពស់វាយដោយរំពាត់ ហើយចូរទៅរកមាត់ពស់ចុះ ឲ្យគេចងយ៉ាងមាំ ហើយដើរទៅកាន់ប្រកល្បកចុះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ដ៏ក្លៀវក្លា សេចក្តីថា ចូរធ្វើការសម្ងំយ៉ាងធ្ងន់ ក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយ ។ ពាក្យថា មានកសិកម្មបានដល់ បរិបូរដោយកសិកម្ម ។ ពាក្យថា ( បាន ) នូវកូនទាំងឡាយជាគ្រហស្ថ មានទ្រព្យ ចូរ ( បាន ) នូវកាមគ្រប់យ៉ាង សេចក្តីថា ចូរបានបុត្រចូរជាគ្រហស្ថ ចូរមានទ្រព្យដោយទ្រព្យ ៧ យ៉ាង ចូរបាននូវសេចក្តីប្រាថ្នាទាំងពួង មានរូបជាដើម ។ ពាក្យថា ចូរកុំឲ្យឃើញនូវវ័យ សេចក្តីថា ក្នុងកាលចាស់ កុំបីបានបួស មិនឃើញការវិនាសរបស់ខ្លួន ចូរគ្រប់គ្រងផ្ទះដែលសម្រេចដោយកាមគុណ ៥ ។ ពាក្យថា រាជាធិរាជ សេចក្តីថា ជាព្រះរាជាក្រៃលែងក្នុងព្រះរាជាទាំងឡាយ ។ ពាក្យថា មិនប្រាសចាករាគៈ បានដល់ មានការចង់បានក្នុងតំណែងបុរោហិត ។ ពាក្យថា ជាអ្នកមានតបៈ បានដល់ តបៈ គឺសីល ។ ចូរសម្គាល់បុគ្គលនោះថា ជាអ្នកមានសីល ។ ពាក្យថា ដែលកុះករដោយវត្ថុ ៤ យ៉ាង គឺដោយមនុស្សទាំងឡាយ ព្រោះមានមនុស្សកុះករ ១ ដោយស្រូវ ព្រោះមានស្រូវច្រើន ១ ដោយឈើ ព្រោះមានឈើរកបានងាយ ១ ដោយទឹក ព្រោះមានទឹកបរិបូណ៌ ១ ។ ពាក្យថា ហាក់ដូចស្តេចវាសវៈ សេចក្តីថា មិនញាប់ញ័រ ដូចស្តេចវាសវៈប្រទាន អធិប្បាយថា ញុំាងព្រះរាជាឲ្យប្រោសប្រាណ ដោយអានុភាពនៃពរដែលបានអំពីស្តេចវាសវៈ ដែលស្តេចវាសវៈនោះប្រទាន ។ ពាក្យថា មិន

ទាន់បានប្រាសចាកកាគ: សេចក្ដីថា មិនទាន់ប្រាសចាកកាគ: ចូរជាអ្នកលិច ចុះក្នុងភក់ គឺកាម ដូចជ្រូកលិចចុះក្នុងភក់ ដូច្នោះ ។

ពាក្យថា ជាធំក្នុងស្រុក បានដល់ មេស្រុក ។ ពាក្យថា ស្រីនោះ បានដល់ ស្ត្រីនោះ ។ ពាក្យថា ឯករាជ បានដល់ ព្រះរាជាដ៏ប្រសើរ ។ ពាក្យថា លើសជាងស្រីទាំងមួយពាន់ លោកពោលជាមេបទ អធិប្បាយថា ចូរតាំងនៅក្នុងឋានៈដែលក្រៃលែងជាងស្រី ១ ម៉ឺន ៦ ពាន់ ។ ពាក្យថា ស្រីទាំងឡាយ បានដល់ ស្រីទាំងឡាយក្នុងដែន ។ ពាក្យថា ដែលជួបជុំគ្នាទាំងអស់ បានដល់ អគ្គយត្រង់កណ្ដាលឥសីទាំងឡាយ ដែលមកប្រជុំគ្នាទាំងអស់ ។ ពាក្យថា កុំញាប់ញ័រ បានដល់ កុំយឺតយូរ ចូរបរិភោគអាហារមានរសឆ្ងាញ់ ។ ពាក្យថា ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលាភចុះ សេចក្ដីថា តែងខ្លួនគួរស្រឡាញ់ ព្រោះលាភជាហេតុ ចូរត្រាច់ទៅដើម្បីឲ្យកើតលាភ ។ ពាក្យថា ចៅអាវាស បានដល់ ជាអ្នកមើលថែវត្ត ។ ពាក្យថា ឈ្មោះគជង្គល: សេចក្ដីថា ក្នុងនគរមានឈ្មោះយ៉ាងនេះ បានឮថា ក្នុងនគរនោះ មានទព្វសម្ភារៈរកបានងាយ ។ ពាក្យថា ចូរធ្វើនូវបន្ទះឲ្យហើយតែមួយថ្ងៃចុះ បានដល់ ចូរធ្វើបន្ទះមួយបន្ទះអស់ ១ ថ្ងៃ ។ បានឮថា ទេវបុត្រនោះ កាលសាសនារបស់ព្រះកស្សបសម្ពុទ្ធ អាស្រ័យគជង្គលនគរជាព្រះសង្ឃត្ថេរ ជាអ្នកមើលថែវត្តក្នុងមហាវិហារប្រមាណ ១ យោជន៍ ធ្វើការកសាងក្នុងវិហារចាស់ បានទទួលទុក្ខយ៉ាងច្រើន រុក្ខទេវតាពោលសំដៅដល់ព្រះសង្ឃត្ថេរនោះ ។

ពាក្យថា ដោយអន្ទាក់ច្រើន បានដល់ អន្ទាក់ជាច្រើន ។ ពាក្យថា ត្រង់កន្លែងទាំង ៦ បានដល់ ក្នុងទី ៦ កន្លែង គឺត្រង់ជើង ៤ ត្រង់ក ១ ត្រង់ចង្កេះ ១ ។ ពាក្យថា មានជន្លវែង បានដល់ ឈើវែង មានបន្ទាសងខាង ។ ពាក្យថា ដោយកន្ទេរ បានដល់ ជន្ទញ្ជី ឬលំពែង ។ ពាក្យថា ប្រឡៀក បានដល់ ផ្ការាក់ គឺប្រកបដោយកម្រងផ្ការាក់ ដែលគ្រូពស់បំពាក់ត្រង់ក ។ ពាក្យថា ចោះត្រចៀកបំពាក់សំណ បានដល់ ចោះត្រចៀកពាក់ដោយគ្រឿងប្រដាប់ គឺសំណ ។ ពាក្យថា វាយដោយរំពាត់ បានដល់ គ្រូពស់បង្រៀនស្វាឲ្យលេងជាមួយពស់ ត្រូវវាយដោយរំពាត់ ។ ឥសីទាំងនោះ ខ្ពើមការបរិភោគកាម ការនៅគ្រប់គ្រងផ្ទះ និងទុក្ខដែលខ្លួនបានទទួលទាំងអស់ ទើបពោលសច្ចៈយ៉ាងនោះៗ ។

លំដាប់នោះ ព្រះពោធិសត្វត្រិះរិះថា កាលតាបសទាំងនេះធ្វើនូវការស្បថ សូម្បីអញក៏គួរធ្វើការស្បថដែរ កាលធ្វើនូវសម្បថ ទើបពោលគាថានេះថា

នែអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលណា ពោលនូវចំណែកដែលមិនបាត់ ថាបាត់ ម្យ៉ាងទៀត បុគ្គលណា រង្កៀសបន្តិចបន្តួច ( ចំពោះអ្នកទាំងឡាយ ) បុគ្គលនោះ ចូរបាន និងចូរបរិភោគនូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្តាលនៃផ្ទះចុះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា នែអ្នកដ៏ចម្រើនទាំងឡាយ បានដល់ បុគ្គលចម្រើនទាំងឡាយ ។ ពាក្យថា រង្កៀសបន្តិចបន្តួច បានដល់ សង្ស័យ ។

ពាក្យថា បុគ្គលណា បានដល់ បុគ្គលដទៃ ។

លំដាប់នោះ សក្កទេវរាជទ្រង់ជ្រាបថា ឥសីទាំងនេះមិនមានការសម្លឹងក្នុងកាមទាំងឡាយ ទើបទ្រង់សង្វេគ កាលទ្រង់សម្តែងថា បណ្តាឥសីទាំងនេះអង្គណាមួយ ក៏មិនបាននាំយកក្រអៅឈូកទៅ លោកក៏មិនបានពោលដល់វត្ថុដែលមិនបាត់ ថាបាត់ ដែលពិត ខ្ញុំបំណងនឹងសាកល្បងពួកលោក ទើបធ្វើឲ្យបាត់ទៅ ទើបព្រះឥន្ទពោលគាថាចុងក្រោយថា

ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសី ក្បែរច្រាំងទៅកប់ទុកលើគោក ( ឥឡូវនេះ ខ្ញុំដឹងហើយថា ) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោក ជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ដូច្នេះ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ ទើបពោលនឹងសក្កៈថា

ម្នាលទេវរាជ ជាសហស្សនេត្រ ( ពួកយើង ) មិនមែនជាអ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាបុគ្គល គួរអ្នកលេងទេ មិនមែនជាផៅពង្ស ទាំងមិនមែនជាសម្លាញ់របស់អ្នកទេ ហេតុអ្វី ក៏អ្នក ( ធ្វើ ) នូវសេចក្តីមើលងាយចំពោះបុគ្គលដទៃ ហើយលេងជាមួយនឹងពួកឥសី ដូច្នេះ ។

លំដាប់នោះ សក្កទេវរាជ ទ្រង់ឲ្យឥសីទាំងនោះអត់ទោស ដោយព្រះតម្រាស់ថា

បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ជាអាចារ្យរបស់ខ្ញុំផង ជា

បិតារបស់ខ្ញុំផង មួប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទីពឹង ( របស់ខ្ញុំ ) ដែលមានសេចក្តីក្តាំងក្តាត់ហើយ បពិត្រតាបស មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្តង បណ្ឌិតទាំងឡាយ មិនមានសេចក្តីក្រោធជាកម្លាំងទេ ដូច្នេះ ។

ព្រះមហាសត្វ បានអត់ទោសឲ្យដល់សក្កទេវរាជហើយ ខ្លួនឯង កាលនឹងឲ្យពួកឥសីអត់ទោស ទើបពោលថា

កាលដែលពួកឥសី ( នៅក្នុងព្រៃ ) សូម្បីតែមួយយប់ ក៏ឈ្មោះថា បាននៅល្អហើយ ព្រោះថា យើងទាំងឡាយ បានជួបនឹងព្រះវាសវៈ ជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចម្រើនទាំងអស់គ្នា ចូរតាំងចិត្តឲ្យល្អចុះ ដ្បិតព្រាហ្មណ៍ ( ជាអាចារ្យរបស់អ្នកទាំងឡាយ ) បាននូវក្រអៅឈូកវិញហើយ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មិនមែនជាអ្នកបម្រើរបស់អ្នកទេ សេចក្តីថា បពិត្រទេវរាជ ពួកអាត្មាមិនមែនអ្នកបម្រើរបស់អ្នក ឬមិនមែនបុគ្គលណាមួយ ដែលគប្បីលេងសើច មិនមែនញាតិរបស់អ្នក មិនមែនសម្លាញ់របស់អ្នក ដែលគួរធ្វើការរីករាយ ។ កាលបើដូច្នោះ អ្នកអាស្រ័យហេតុអ្វី ក៏អ្នកគឺអ្នកអាងអ្វី អធិប្បាយថា អ្នកលេងសើចជាមួយពួកឥសី ព្រោះអាស្រ័យអ្វី ។ ពាក្យថា មួប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទីពឹង សេចក្តីថា មួង់ជើងរបស់លោកម្ចាស់នេះ ចូរជាទីពឹងនៃការខុសរបស់ខ្ញុំក្នុងថ្ងៃនេះចុះ ។ ពាក្យថា នៅល្អហើយ សេចក្តីថា ការនៅក្នុងព្រៃនេះ ត្រឹមតែមួយយប់របស់ពួកឥសី

ជាការនៅល្អហើយ ព្រោះហេតុអ្វី ព្រោះពួកយើងបានឃើញស្ដេចវាសវៈជាធំជាងពួកកូត បើពួកយើងនៅក្នុងនគរ ពួកយើងក៏នឹងមិនឃើញស្ដេចវាសវៈនេះ ។ ពាក្យថា ពួកអ្នកដ៏ចម្រើនទាំងអស់គ្នា បានដល់ លោកដ៏ចម្រើនទាំងឡាយទាំងអស់ ចូរត្រេកអរ គឺចូររីករាយ ចូរអត់ទោសឲ្យដល់សក្កទេវរាជចុះ ព្រោះហេតុអ្វី ព្រោះព្រាហ្មណ៍ណាបានក្រអៅឈូកវិញហើយ គឺព្រោះអាចារ្យរបស់យើង បានក្រអៅឈូកហើយ ។ សក្កទេវរាជទ្រង់ថ្វាយបង្គំពួកឥសីហើយ ត្រឡប់ទៅកាន់ទេវលោក ពួកឥសីញុំាងឈាន និងអភិញ្ញាឲ្យកើតហើយ បានទៅកាន់ព្រហ្មលោក ។

ប្អូនប្រុសទាំង ៦ មានឧបកញ្ចនៈជាដើមក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ ព្រះមហាកស្សបៈ ១ ព្រះអនុរុទ្ធ ១ ព្រះបុណ្ណៈ ១ ព្រះអានន្ទត្ថេរ ១ ក្នុងកាលឥឡូវនេះ ប្អូនស្រីក្នុងកាលនោះ បានមកជាឧប្បលវណ្ណាក្នុងកាលឥឡូវនេះ ទាសីក្នុងកាលនោះ បានមកជានាងខុជ្ជុត្តរាក្នុងកាលឥឡូវនេះ ទាសៈក្នុងកាលនោះ បានមកជាចិត្តគហបតីក្នុងកាលឥឡូវនេះ រុក្ខទេវតាក្នុងកាលនោះ បានមកជាសាតាគិរៈក្នុងកាលឥឡូវនេះ ។ ដំរីក្នុងកាលនោះ បានមកជាដំរីបាលិលេយ្យក្នុងកាលឥឡូវនេះ ពានរ

ក្នុងកាលនោះ បានមកជាមធុរាសិដ្ឋៈក្នុងកាលឥឡូវនេះ សក្កទេវរាជក្នុងកាលនោះ បានមកជាកាឡុទាយីក្នុងកាលឥឡូវនេះ មហាកញ្ចនតាបសក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងចរិយានេះ គប្បីពោលចំពោះដល់បារមី ១០ របស់ព្រះពោធិសត្វ ដោយន័យដូចពោលហើយខាងដើមនោះឯង ។ មា៉ងទៀត គប្បីប្រកាសគុណានុភាព មានការមិនត្រិះរិះក្នុងកាមទាំងឡាយជាដើម ដោយចំណែកមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

## អដ្ឋកថាភិសចរិយា ចប់

# សុត្តន្តបិដក

## សោណនន្ទបណ្ឌិតចរិយាទី ៩

[ ២៥ ] មានចរិយាដទៃទៀត កាលតថាគតកើតក្នុងត្រកូលព្រាហ្មណមហាសាល ដ៏ប្រសើរថ្លៃថ្លា ក្នុងនគរព្រហ្មវឌ្ឍនៈ ។ កាលនោះឯង តថាគតបានឃើញសត្វលោក ដែលដល់នូវអន្ធកាតត្រូវងងឹត គឺអវិជ្ជាគ្របសង្កត់ ចិត្តរបស់តថាគត ក៏ខ្វល់ខ្វាយចាកភពដូចជាហត្ថាជានេយ្យ ដែលគេចាក់នឹងជន្លួញដោយកម្លាំង ។ កាលនោះ តថាគតឃើញបាបផ្សេងៗ ក៏គិតយ៉ាងនេះថា កាលណាហ្ន៎អញនឹងបានចេញចាកផ្ទះ ចូលទៅកាន់ព្រៃ ។ គ្រានោះ ពួកញាតិអញ្ជើញតថាគតដោយភោគៈ គឺកាមទាំងឡាយ តថាគតប្រាប់នូវធនៈ ( របស់ខ្លួន ) ដល់ពួកញាតិទាំងនោះថា សូមអ្នកទាំងឡាយកុំអញ្ជើញខ្ញុំដោយកាមទាំងនោះឡើយ ។ ប្អូនប្រុសណា របស់តថាគត ឈ្មោះនន្ទបណ្ឌិត ប្អូនប្រុសនោះ ក៏សិក្សាតាមតថាគតពេញចិត្តនឹងបព្វជ្ជា ។ កាលនោះ តថាគតឈ្មោះសោណៈ ប្អូននៃតថាគតឈ្មោះនន្ទៈ និងមាតាបិតានៃតថាគតទាំងពីរ លះបង់ភោគៈទាំងឡាយ ហើយចូលទៅកាន់ព្រៃធំ ក្នុងកាលនោះ ។

សោណនន្ទបណ្ឌិតចរិយាទី ៩ ចប់

# អដ្ឋកថា

## សោណបណ្ឌិតចរិយា

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោណនន្ទបណ្ឌិតចរិយាទី ៥ ដូចតទៅ បទថា **នគរេ ព្រហ្មវឌ្ឍនេ** បានដល់ ក្នុងនគរឈ្មោះព្រហ្មវឌ្ឍនៈ ។ បទថា **កុលវរេ** បានដល់ ក្នុងត្រកូលដ៏ប្រសើរ ។ បទថា **សេដ្ឋេ** បានដល់ គួរសរសើរបំផុត ។ បទថា **មហាសាលេ** បានដល់ ដែលមានវត្ថុជាសារៈច្រើន ។ បទថា **អជាយហំ** បានដល់ តថាគតបានកើតហើយ លោកអធិប្បាយថា ក្នុងកាលនោះ តថាគតបានកើត និងអាស្រ័យនៅក្នុងក្រុងពារាណសី ដែលបានឈ្មោះថា ព្រហ្មវឌ្ឍនៈ ។ បានកើតក្នុងត្រកូលព្រាហ្មណមហាសាល ព្រោះមានសម្បត្តិ ៨០ កោដិ ជាបុគ្គលប្រសើរដោយភាពជាបុគ្គលឧត្តម ព្រោះជាអភិជាតបុត្រ ជាបុគ្គលប្រសើរ ដោយភាពជាបុគ្គលដល់ព្រមដោយវិជ្ជា ។

បានឮថា ក្នុងកាលនោះ ព្រះមហាសត្វចុតិអំពីព្រហ្មលោក កើតជាបុត្ររបស់ព្រាហ្មណមហាសាលម្នាក់ មានសម្បត្តិ ៨០ កោដិ ក្នុងព្រហ្មវឌ្ឍននគរ ។ ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ មាតាបិតាបានដាក់ឈ្មោះថា សោណកុមារ ។ កាលសោណកុមារនោះដើរបាន សត្វដទៃចុតិអំពីព្រហ្មលោក បានបដិសន្ធិក្នុងផ្ទៃរបស់មាតាព្រះពោធិសត្វ មាតាបិតាដាក់ឈ្មោះថា នន្ទកុមារ ។ មាតាបិតាឃើញរូបសម្បត្តិរបស់បុត្រទាំងពីរ ដែលចម្រើនវ័យរៀនចប់ត្រៃវេទ សម្រេចសិប្បៈសព្វយ៉ាង ត្រេកអរ គិតថា នឹងចងឲ្យនៅ

គ្រប់គ្រងផ្ទះ បានពោលនឹងសោណកុមារថា កូនសម្លាញ់ ពុកម៉ែនឹងនាំទារិកាអំពីត្រកូលដែលសមគួរមកឲ្យកូន ចូរកូនគ្រប់គ្រងសម្បត្តិចុះ ។

ព្រះមហាសត្វពោលថា ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះ ខ្ញុំនឹងបដិបត្តិពុកម៉ែដរាបដល់អស់ជីវិត កាលពុកម៉ែអនិច្ចកម្មហើយ ខ្ញុំនឹងបួស ។ ព្រោះក្នុងកាលនោះភពទាំង ៣ បានប្រាកដដល់ព្រះមហាសត្វ ដូចផ្ទះដែលត្រូវភ្លើងឆេះ និងដូចនៅក្នុងរណ្តៅរងើកភ្លើង ។ ម្យ៉ាងទៀត ដោយសេចក្តីវិសេសយ៉ាងក្រៃលែង ព្រះមហាសត្វមានអជ្ឈាស្រ័យក្នុងនេក្ខម្មៈ បានបង្អោនចិត្តទៅក្នុងការបួស ។

មាតាបិតាមិនជ្រាបបំណងរបស់មហាសត្វ សូម្បីពោលរឿយៗ ក៏មិនបានទឹកចិត្តរបស់ព្រះពោធិសត្វនោះ ទើបហៅនន្ទកុមារមកពោលថា កូនសម្លាញ់ បើដូច្នោះ ចូរកូនគ្រប់គ្រងទ្រព្យសម្បត្តិចុះ សូម្បីនន្ទកុមារក៏ពោលថា ខ្ញុំមិនយកក្បាលទទួលទឹកមាត់ ដែលបងប្រុសរបស់ខ្ញុំស្តោះចោលឡើយ សូម្បីខ្ញុំក៏នឹងបួសជាមួយបងប្រុស កាលពុកម៉ែអនិច្ចកម្មទៅ ។ មាតាបិតាក៏គិតថា ក្មេងៗ ទាំងនេះ លះកាមទាំងឡាយយ៉ាងនេះបាន ឯអញ ហេតុអ្វីលះមិនបាន ដោយហេតុនោះ យើងទាំងអស់នឹងបួស ទើបពោលថា នែកូនប្រយោជន៍អ្វីរបស់ពួកកូនដែលបួសក្នុងកាលពុក និងម៉ែស្លាប់ទៅ ពួកយើងនឹងបួសជាមួយកូនដែរ ហើយឲ្យវត្ថុដែលគួរឲ្យដល់ពួកញាតិ ធ្វើទាសៈឲ្យជាអ្នកជា ទូលដល់ព្រះរាជា លះបង់ទ្រព្យទាំងអស់បរិច្ចាគមហាទាន ជនទាំង ៤ ចេញអំពីព្រហ្មវឌ្ឍនគរ អាស្រ័យស្រះធំដេរដាសដោយផ្កាឈូកក្រហម

ឈូក-ស ក្នុងហិមវន្តប្បទេស សាងអាស្រមក្នុងដងព្រៃគួរជាទីត្រេកអរ នាំគ្នាបួសក្នុងទីនោះ ដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះឯង តថាគតបានឃើញសត្វលោក ដែលដល់នូវអន្ធភាព ត្រូវងងឹត គឺអវិជ្ជាគ្របសង្កត់ ចិត្តរបស់តថាគត ក៏ខ្វល់ខ្វាយចាកភព ដូចជាហត្ថាជានេយ្យ ដែលគេចាក់នឹងជន្ទញ់ដោយកម្លាំង ។ កាលនោះ តថាគតឃើញបាបផ្សេងៗ ក៏គិតយ៉ាងនេះថា កាលណាហ្ន៎ អញនឹងបានចេញចាកផ្ទះ ចូលទៅកាន់ព្រៃ ។ គ្រានោះ ពួកញាតិអញ្ជើញតថាគតដោយភោគៈ គឺកាមទាំងឡាយ តថាគតប្រាប់នូវឆន្ទៈ ( របស់ខ្លួន ) ដល់ពួកញាតិទាំងនោះថា សូមអ្នកទាំងឡាយ កុំអញ្ជើញខ្ញុំដោយកាមទាំងនោះឡើយ ។ ប្អូនប្រុសណារបស់តថាគត ឈ្មោះនន្ទបណ្ឌិត ប្អូនប្រុសនោះ ក៏សិក្សាតាមតថាគត ពេញចិត្តនឹងបព្វជ្ជា ។ កាលនោះ តថាគតឈ្មោះសោណៈ ប្អូននៃតថាគតឈ្មោះនន្ទៈ និងមាតាបិតានៃតថាគតទាំងពីរ លះបង់ភោគៈទាំងឡាយ ហើយចូលទៅកាន់ព្រៃធំ ក្នុងកាលនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តទាបិ** សេចក្តីថា ក្នុងកាលដែលតថាគតជាព្រាហ្មណកុមារ ឈ្មោះសោណៈ ក្នុងព្រហ្មវឌ្ឍនគរ ។ បទថា **លោកំ ទិស្វាន** បានដល់ ឃើញសត្វលោកទាំងមូលដោយបញ្ញាចក្ខុ ។ បទថា **អន្ធីភូតំ** សេចក្តីថា ដល់នូវការងងឹត គឺភាពជាអ្នកខ្វាក់ ព្រោះប្រាសចាកបញ្ញាចក្ខុ ។

បទថា **តមោត្ថដំ** បានដល់ ត្រូវងងឹត គឺអវិជ្ជាគ្របសង្កត់ ។ បទថា **ចិត្តំ ភវតោ បតិកុដតិ** សេចក្តីថា ចិត្តរបស់តថាគត ងៀយណាយ រួញរាចាក ភព មានកាមភពជាដើមដោយពិចារណាវត្ថុឲ្យកើតសង្វេគ មានជាតិជាដើម ។ បទថា **តុត្តវេគហតំ វិយ** បានដល់ កង្វេរមានបន្លាដែក ហៅថា **តុត្ត** ឈើវែងហៅថា **បតោទ**។ ព្រះពោធិសត្វសម្តែងថា ដំរីអាជានេយ្យ ត្រូវ គាប់ដោយកង្វេរនោះយ៉ាងកម្លាំង ជាសត្វដល់នូវសេចក្តីសង្វេគ យ៉ាងណា ចិត្តរបស់តថាគតដល់នូវការសង្វេគ ដោយការពិចារណាទោសរបស់កាម ក្នុងកាលនោះ ក៏យ៉ាងនោះ ។

បទថា **ឱស្សាន វិវិធំ ចាបំ** សេចក្តីថា តថាគតឃើញនូវកម្មលាមក មានបាណាតិបាតជាដើម ដែលមានច្រើនយ៉ាង ដែលអ្នកគ្រប់គ្រងផ្ទះទាំង ឡាយធ្វើដោយអំណាចអគតិ មានឆន្ទាគតិ និងទោសាគតិជាដើម ព្រោះ ការគ្រប់គ្រងផ្ទះជាហេតុ និងឃើញថា សត្វទាំងនោះ ជាសត្វគ្រោតគ្រាត ព្រោះកម្មលាមក មានបាណាតិបាតជាដើម ជាហេតុ ។ បទថា **ឃរំ ចិន្តេសហំ តទា** សេចក្តីថា ទើបតថាគតគិតក្នុងខណៈដែលជាសោណកុមារក្នុងកាល នោះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញគប្បីកាត់នូវការជាប់ជំពាក់ក្នុងផ្ទះ ដូចដំរីធំកាត់ចំណងដែកបាន ដូច្នោះហើយ ចូលកាន់ព្រៃ ដោយការចេញ ចាកផ្ទះ ។ បទថា **តទាបិ មំ និមន្តីសុ** សេចក្តីថា មិនមែនក្នុងខណៈដែល តថាគតជាអយោឃរបណ្ឌិតតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិតនោះ ក្នុងកាលនោះ គឺក្នុងខណៈដែលតថាគតជាសោណកុមារនោះ ញាតិទាំងឡាយមានមាតាបិតា

ជាដើម ជាអ្នកបរិភោគកាម ជាអ្នកមានអធ្យាស្រ័យក្នុងកាម អញ្ជើញតថាគត ដោយភោគៈដ៏ច្រើនថា នែកូន ចូរកូនគ្រប់គ្រងទ្រព្យសម្បត្តិ ៨០ កោដិនេះចុះ ចូរតម្កល់វង្សត្រកូលចុះ ។ បទថា **តេសម្បិ ឆន្ទមាចិក្ខី** សេចក្តីថា តថាគត បានប្រាប់នូវការពេញចិត្តរបស់ខ្លួន ដល់ញាតិរបស់តថាគតទាំងនោះថា អ្នកទាំងឡាយ កុំអញ្ជើញខ្ញុំដោយកាមភោគៈទាំងនោះឡើយ អធិប្បាយថា តថាគត បានប្រាប់ដល់អធ្យាស្រ័យដែលបង្អោនទៅក្នុងបព្វជ្ជាថា សូមពួកលោកគ្រប់គ្រងតាមអធ្យាស្រ័យចុះ ។ បទថា **សោបិ មំ អនុសិក្ខន្តោ** សេចក្តីថា តថាគត ពិចារណាដល់ទោសក្នុងកាមទាំងឡាយ មានច្រើនប្រការ ដោយន័យជាដើមថា ឈ្មោះថា កាមទាំងឡាយនេះ មានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន ហើយសិក្សាសីលជាដើម ពេញចិត្តក្នុងការបួស យ៉ាងណា នន្ទបណ្ឌិតនោះ ក៏សិក្សាតាមតថាគត ដោយការចេញបួសរបស់គេយ៉ាងនោះ រមែងពេញចិត្តក្នុងការបួស យ៉ាងនោះដូចគ្នា ។ បទថា **អហំ សោណោ ច នន្ទោ ច** បានដល់ ក្នុងកាលនោះ តថាគត ឈ្មោះសោណៈ និងនន្ទៈប្អូនប្រុសរបស់តថាគត ។ បទថា **ឧភោ មាតាបិតា មម** សេចក្តីថា មាតា និងបិតារបស់តថាគត កើតនូវសេចក្តីសង្វេគថា បុត្រទាំងនេះគង់លះកាមទាំងឡាយបាន សូម្បីក្នុងពេលនៅជាកំលោះយ៉ាងនេះ ហេតុអ្វី អញលះមិនបាននោះ ។ បទថា **ភោគេ ឆឌ្ឌេត្វា** សេចក្តីថា យើងទាំង ៤ នាក់ មិនគិតដល់មហាភោគសម្បត្តិ ៨០ កោដិ លះបង់បាន ដូចដុំទឹកមាត់ ចូលព្រៃធំ ក្នុងហិមវន្តប្បទេស ដោយអធ្យាស្រ័យប្រាថ្នាចំពោះ

បព្វជ្ជា ។

ជនទាំងនោះ កាលចូលទៅហើយ បានសាងអាស្រមត្រង់ភូមិភាគដែលគួរជាទីត្រេកអរនោះ បួសជាតាបសក្នុងទីនោះ បងប្អូនទាំងពីរនោះបម្រើមាតាបិតា ។ ក្នុងបងប្អូនទាំងពីរនោះ នន្ទបណ្ឌិតគិតថា អញនឹងឲ្យមាតាបិតា បរិភោគផលាផលដែលអញនាំមកប៉ុណ្ណោះ ទើបនាំផ្លែឈើ ដែលសល់កាលពីម្សិលមិញ និងក្នុងទីដែលខ្លួនរកអាហារក្នុងថ្ងៃមុនៗ មកអំពីព្រលឹមឲ្យមាតាបិតាបរិភោគ ។ មាតាបិតាបរិភោគផលាផលទាំងនោះហើយខ្ពុរមាត់រក្សាឧបោសថ ។ ចំណែកសោណបណ្ឌិតទៅឆ្ងាយបន្តិច នាំផលាផលដែលទុំល្អ មានរសឆ្ងាញ់ បង្អោនចូលទៅឲ្យមាតាបិតា ។

លំដាប់នោះ មាតាបិតាពោលនឹងសោណបណ្ឌិតថា នែកូន អញបរិភោគផ្លែឈើដែលប្អូនឯងនាំមកហើយ ក៏រក្សាឧបោសថ ឥឡូវនេះ អញមិនត្រូវការទេ ។ ផ្លែឈើរបស់សោណបណ្ឌិតនោះ កាលមិនបានបរិភោគក៏ខូច ។ ក្នុងថ្ងៃស្អែកជាដើមក៏យ៉ាងនោះដូចគ្នា ។ ដោយប្រការយ៉ាងនេះសោណបណ្ឌិតនោះ បានទៅក្នុងទីឆ្ងាយជាង ហើយនាំផលាផលមក ព្រោះបានអភិញ្ញា ៥ តែមាតាបិតា ក៏មិនបានបរិភោគ ។

លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា មាតាបិតាជាសុមាលជាតិ នន្ទៈនាំផលាផលខ្ចីខ្លះ ទុំមិនល្អខ្លះ មកឲ្យមាតាបិតាបរិភោគ កាលបើយ៉ាងនោះមាតាបិតានឹងនៅបានមិនយូរ អញនឹងហាមនន្ទៈនោះ ទើបហៅនន្ទៈមកពោលថា នែនន្ទៈ ចាប់អំពីនេះទៅ បើឯងនាំផ្លែឈើមក ចូរបង្អង់ ចាំអញត្រឡប់

មកសិន អញនឹងឲ្យមាតាបិតាបរិភោគរួមគ្នា ។ កាលសោណបណ្ឌិតពោលយ៉ាងនេះហើយ នន្ទបណ្ឌិតប្រាថ្នាបុណ្យ ទើបមិនធ្វើតាម ។ ព្រះមហាសត្វផ្ទាត់ម្រាមដៃដេញនន្ទបណ្ឌិតដែលមកបម្រើមាតាបិតា ពោលថា ប្អូនមិនធ្វើតាមពាក្យរបស់បណ្ឌិត អញជាបង មាតាបិតាជាភារៈរបស់បង អញនឹងទំនុកបម្រុងមាតាបិតាឯង ចូរប្អូនទៅអំពីទីនេះ ទៅកាន់ទីដទៃចុះ ។

នន្ទបណ្ឌិតត្រូវបងប្រុសបណ្តេញ មិនអាចនៅក្នុងទីនោះបាន ទើបថ្វាយបង្គំព្រះពោធិសត្វ ហើយប្រាប់រឿងដល់មាតាបិតា ចូលទៅកាន់បណ្ណសាលារបស់ខ្លួន សម្លឹងកសិណ ក្នុងថ្ងៃនោះឯង ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ គិតថា អញនឹងនាំខ្សាច់រតនៈមកអំពីជើងភ្នំសិនេរុ ក្រាលបរិវេណបណ្ណសាលាបងប្រុសរបស់អញ ហើយសូមខមាទោស ឬថា នាំទឹកមកអំពីអនោតត្តស្រះ ហើយសូមខមាទោស ឬម្យ៉ាងទៀត បងប្រុសរបស់អញគប្បីអត់ទោសឲ្យ ដោយអំណាចនៃទេវតា អញនឹងនាំមហារាជទាំង ៤ និងសក្កទេវរាជមកហើយ សឹមសូមខមាទោសយ៉ាងនេះក៏មិនល្អ ។ ព្រះរាជានគរព្រហ្មវឌ្ឍនៈ ព្រះនាមមនោជៈនេះ ជាអគ្គរាជាក្នុងជម្ពូទ្វីប អញនឹងនាំព្រះរាជាទាំងអស់តាំងអំពីព្រះបាទមនោជៈនោះមកហើយ សូមខមាទោស កាលបើយ៉ាងនេះ គុណបងប្រុសរបស់អញនឹងខ្ចរខ្ចាយទៅ គ្របសង្កត់ពេញជម្ពូទ្វីប និងប្រាកដដូចព្រះចន្ទ និងព្រះអាទិត្យ ។

កាលនោះ នន្ទបណ្ឌិតបានទៅដោយឫទ្ធិ ចុះត្រង់ទ្វារព្រះរាជនិវេសន៍របស់ព្រះរាជានោះ ក្នុងព្រហ្មវឌ្ឍននគរ ឲ្យមនុស្សទៅទូលដល់ព្រះរាជាថា

មានតាបសមួយអង្គបំណាំងនឹងចូលគាល់ ។ កាលព្រះរាជាប្រទានឱកាស ទើបចូលទៅគាល់ ទូលថា អាត្មានឹងដណ្តើមរាជសម្បត្តិក្នុងជម្ពូទ្វីប ដោយកម្លាំងរបស់ខ្លួន នាំមកថ្វាយដល់ព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា លោកម្ចាស់ ដណ្តើមរាជសម្បត្តិក្នុងជម្ពូទ្វីបមកឲ្យបានដូចម្តេច តាបសទូលថា អាត្មាមិនសម្លាប់បុគ្គលណាម្នាក់ ដណ្តើមដោយឫទ្ធិរបស់ខ្លួនប៉ុណ្ណោះ ហើយនាំមកថ្វាយ ហើយនាំព្រះរាជា មួយអន្លើដោយមហាសេនាទៅដល់ដែនកោសល បោះបន្ទាយមិនឆ្ងាយអំពីនគរ បញ្ជូនទូតដល់ព្រះបាទកោសលថា នឹងច្បាំង ឬព្រមនៅក្នុងអំណាច ។ កាលការច្បាំងជាមួយព្រះបាទកោសលដែលទ្រង់ពិរោធ ត្រៀមការច្បាំងយាងចេញមក ផ្តើមឡើងហើយ នន្ទបណ្ឌិតប្រើឥទ្ធានុភាពរបស់ខ្លួន បណ្តាលឲ្យសេនាមិនមានការប៉ះទង្គិចគ្នា និងឲ្យព្រះបាទកោសលឲ្យនូវពាក្យឆ្លើយថា ខ្ញុំនឹងនៅក្រោមអំណាច ។ ដោយឧបាយនេះ នន្ទបណ្ឌិត ញ៉ាំងព្រះរាជាពេញជម្ពូទ្វីប ឲ្យធ្លាក់នៅក្នុងអំណាចរបស់ព្រះរាជាអង្គនោះទាំងអស់ ។

ព្រះរាជានោះទ្រង់ត្រេកអរនឹងនន្ទបណ្ឌិត ត្រាស់នឹងនន្ទបណ្ឌិតថា បពិត្រលោកម្ចាស់ៗ បានធ្វើដូចដែលបានប្តេជ្ញាហើយ ។ លោកម្ចាស់ជាអ្នកមានឧបការៈច្រើនដល់ខ្ញុំ ខ្ញុំនឹងធ្វើអ្វីតបស្នងលោកម្ចាស់បាន ខ្ញុំប្រាថ្នានឹងឲ្យរាជសម្បត្តិពាក់កណ្តាលក្នុងជម្ពូទ្វីបដល់លោកម្ចាស់ មិនចាំបាច់ពោលដល់ចំនួនដំរី សេះ រថ កែវមណី កែវមុក្តា កែវប្រពាល ប្រាក់ មាស ទាសី ទាសា និងបរិវារជន ។ នន្ទបណ្ឌិតបានស្តាប់ដូច្នោះ ក៏ទូលថា បពិត្រមហារាជ អាត្មា

មិនត្រូវការរាជសម្បត្តិ ពាហនៈ ដំរីជាដើមក៏មិនត្រូវការ តែមាតាបិតារបស់អាត្មាបួសក្នុងអាស្រមនោះ ក្នុងដែនរបស់ព្រះអង្គ ។ អាត្មាបម្រើមាតាបិតាទាំងនោះ ត្រូវសោណបណ្ឌិតបងប្រុសរបស់អាត្មា អ្នកស្វែងរកគុណធំបណ្តេញ ព្រោះកំហុសណាមួយ អាត្មានឹងនាំព្រះអង្គទៅរកបងប្រុស ហើយសូមខមាទោស សូមទ្រង់ជាសម្លាញ់ ក្នុងការឲ្យបងប្រុសរបស់អាត្មាអត់ទោសផងចុះ ។ ព្រះរាជាទ្រង់ទទួលថា សាធុ ហើយចោមរោមដោយអ្នកចម្បាំងមានប្រមាណ ២៤ អក្ខោភិនី[1] មួយអន្លើដោយព្រះរាជា ១០១ នន្ទបណ្ឌិតជាអ្នកនាំមុខ កាលដល់អាស្រមបទនោះ នាំទឹកមកអំពីអនោតត្តស្រះដោយដងរែក ដែលអណ្តែតផុតអំពីស្ថាបិតនៅក្នុងអាកាស ៤ ធ្នាប់ ត្រៀមទឹកផឹកបោសបរិវេណ ហើយចូលទៅរកព្រះមហាសត្វ ដែលឆ្អែតដោយការត្រេកអរក្នុងឈាន អង្គុយនៅក្បែរមាតាបិតា ហើយសូមខមាទោស ។

១- មួយអក្ខោភិនី សរសេរលេខ ១ និងលេខសូន្យ ៤២ ។

ព្រះមហាសត្វឲ្យនន្ទបណ្ឌិត មើលថែមាតា ខ្លួនឯងមើលថែបិតាជរាបដល់អស់ជីវិត ។ ព្រះមហាសត្វសម្តែងធម៌ដល់ព្រះរាជាទាំងនោះ ដោយពុទ្ធលីលាថា

បណ្ឌិតបម្រើមាតា គប្បីបាននូវសុខទុ៎ះ គឺសេចក្តីត្រេកអរីកកាយ
ការសើចលេងសព្វៗ កាល ។ បណ្ឌិតបម្រើបិតា គប្បីបាននូវ
សុខទុ៎ះ គឺសេចក្តីត្រេកអរីកកាយ ការសើចលេងសព្វៗ កាល ។
ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តជាប្រយោជន៍ក្នុង

លោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ ។ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាផ្ទៃនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាន និងការបូជា ព្រោះហេតុនៃកូន ទាំងបិតា ក៏មិនត្រូវបាននូវសេចក្តីរាប់អាន និងការបូជា ព្រោះហេតុនៃកូន ពួកបណ្ឌិតរមែងឃើញដោយល្អ នូវសង្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះបណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថាព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតទឹក ការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះលះលោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

ព្រះរាជាទាំងអស់នោះ មួយអន្លើដោយសេនា កាលបានស្តាប់ដូច្នោះហើយ ទ្រង់ជ្រះថ្លា ។ លំដាប់នោះ ព្រះពោធិសត្វញ៉ាំងព្រះរាជាទាំងនោះឲ្យតាំងនៅក្នុងសីល ៥ ហើយទូន្មានថា សូមទ្រង់ទាំងឡាយ កុំប្រមាទក្នុងទានជាដើមចុះ ហើយបញ្ជូនព្រះរាជាទាំងនោះទៅ ។ ព្រះរាជាទាំងអស់ គ្រងរាជសម្បត្តិដោយធម៌ កាលសោយទិវង្គត ក៏ទៅកើតក្នុងស្ថានសួគ៌ ។ ព្រះពោធិសត្វ ឲ្យនន្ទបណ្ឌិតមើលថែមាតាដោយពោលថា តាំងអំពីនេះទៅ ចូរប្អូនបម្រើមាតា ហើយខ្លួនឯង បម្រើបិតាដរាបដល់អស់ជីវិត ។ ជនពីរនាក់បងប្អូន កាលអស់អាយុ ក៏ទៅកើតក្នុងព្រហ្មលោក ។

មាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ នន្ទបណ្ឌិតក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរក្នុងកាលឥឡូវនេះ ព្រះរាជាព្រះនាមមនោជៈក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរក្នុងកាលឥឡូវនេះ ព្រះរាជា ១០១ អង្គ ក្នុងកាលនោះ បានមកជាអសីតិមហាថេរៈនិងព្រះថេរៈដទៃៗ ក្នុងកាលឥឡូវនេះ បរិស័ទ ២៤ អក្ខោភិនី ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ សោណបណ្ឌិតក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

នេក្ខម្មបារមីជាកំពូលរបស់សោណបណ្ឌិតក៏ពិត តែគប្បីពោលចំពោះដល់បារមីដ៏សេសដោយន័យដូចពោលហើយខាងដើមនោះឯង ម្យ៉ាងទៀតគប្បីប្រកាសគុណានុភាពរបស់ព្រះមហាសត្វយ៉ាងនេះ គឺភាពជាបុគ្គលមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ ភាពជាអ្នកមានការគោរពកោតក្រែងយ៉ាងខ្លាំងក្លា ក្នុងមាតាបិតាទាំងឡាយ ភាពជាអ្នកមិនឆ្អែតដោយការបម្រើមាតាបិតា កាលមានការបម្រើមាតាបិតាទាំងនោះ ក៏ញុំាងកាលវេលាឲ្យអស់ ឲ្យបង្ហោនទៅដោយសមាបត្តិវិហារធម៌ ដោយប្រការដូច្នេះ ។

**អដ្ឋកថាសោណបណ្ឌិតចរិយា ចប់**

**នេក្ខម្មបារមី ចប់**

# សុត្តន្តបិដក

## មូគជក្ខចរិយាទី ៦

[ ២៦ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជារាជឱរស នៃព្រះបាទកាសិករាជ ជនទាំងឡាយ មានមាតាបិតាជាដើម តែង ហៅតថាគត ថាមូគផក្ខៈផង ថាតេមិយៈផង ។ កាលនោះ ពួក ស្រីស្នំ ( របស់ព្រះបាទកាសិករាជ ) ចំនួន ១៦០០០ មិនមាន កូនប្រុស អស់កាលកន្លងទៅនៃថ្ងៃ និងយប់ជាច្រើន គឺអស់ច្រើន ឆ្នាំ កើតបានតែរាជបុត្រមួយ គឺតថាគត ។ ដោយបិតារបស់ តថាគត បានដោយកម្រនូវតថាគត ជាកូនជាទីស្រឡាញ់ ជាកូន មានជាតិខ្ពស់ ទ្រទ្រង់សេចក្ដីរុងរឿង ព្រះរាជាក៏យកនូវស្វេតច្ឆត្រ បាំងតថាគត ចិញ្ចឹមឲ្យផ្ទំលើសិរីសេយនា ។ កាលនោះ តថាគត ដេកលក់លើវរសេយនា ហើយភ្ញាក់ឡើង បានឃើញស្វេតច្ឆត្រ គិតថា អញទៅនរក ព្រោះតែស្វេតច្ឆត្រណា ។ សេចក្ដីភ័យ តក់ស្លុតកើតឡើងដល់តថាគត ជាមួយនឹងការឃើញនូវស្វេតច្ឆត្រ នោះ ពេលនោះ តថាគតពិចារណាមើលថា ក្នុងកាលណាហ្ន៎ អញនឹងដោះខ្លួនឲ្យរួចពីស្វេតច្ឆត្រនេះ ។ ទេវតាជាសាលោហិត ក្នុងកាលមុន ជាអ្នកប្រាថ្នាប្រយោជន៍ដល់តថាគត ទេវតានោះ ឃើញតថាគតបានទុក្ខ ក៏ឲ្យតថាគតប្រកបក្នុងហេតុ ៣ ប្រការ ដូច្នេះថា ចូរអ្នកកុំសម្ដែងនូវភាពរបស់ខ្លួនជាបណ្ឌិត ១ ចូរឲ្យសព្វ សត្វទាំងឡាយដឹងថាជាពាលវិញ ១ ឲ្យពួកជនទាំងពួង មើល

ងាយអ្នកវិញ ១ ប្រយោជន៍នឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ។ កាលទេវតានោះ ពោលយ៉ាងនេះហើយ តថាគតពោលនូវពាក្យនេះថា ម្នាលទេវតា អ្នកពោលនូវពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យនៃអ្នកនោះ ម្នាលទេវតាជាម៉ែ អ្នកឈ្មោះថាប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ។ លុះតថាគតស្តាប់ពាក្យទេវតានោះហើយ ក៏បាននូវទួល គឺទីពឹង ដូចជាបុរស កាលលិចក្នុងសាគរហើយ បាននូវទីទួល ។ តថាគតមានចិត្តត្រេកអរ មានចិត្តសង្វេគ បានអធិដ្ឋាននូវអង្គ ៣ យ៉ាង គឺអធិដ្ឋានជា-គ ថ្លង់ និងខ្វិន វៀរចាកដំណើរធម្មតា ។ តថាគតអធិដ្ឋាននូវអង្គទាំង ៣ ទុំះហើយ នៅអស់ ១៦ ឆ្នាំ លំដាប់ពីនោះមក ជនទាំងឡាយប្របាច់ដៃជើង អណ្តាត និងត្រចៀករបស់តថាគតមើល ឃើញថា អវយវៈតថាគតមិនខ្វះខាត ហើយតិះដៀលតថាគត ថាជាបុរសកាឡកិណី ។ លំដាប់នោះ ពួកអ្នកជនបទទាំងអស់ មានសេនាបតី និងបុរោហិតជាប្រធាន ពួកជនទាំងអស់នោះ ស្រុះចិត្តគ្នា ត្រេកអរក្នុងការលះបង់បោលតថាគត ។ លុះតថាគតស្តាប់នូវសេចក្តីយល់ឃើញរបស់ពួកជនទាំងនោះ ក៏មានចិត្តត្រេកអរ មានចិត្តសង្វេគ តបៈដែលតថាគតប្រព្រឹត្តហើយ ដើម្បីជាប្រយោជន៍ណា ប្រយោជន៍នោះ នឹងសម្រេចដល់តថាគតមិនខាន ។ ជនទាំងឡាយមានមាតាបិតាជាដើម ផ្ងូតទឹកក្រអូប លាបគ្រឿងក្រអូប ហើយ

ឲ្យពាក់រាជមកុដ អភិសេកដោយស្វេតច្ឆត្រ ធ្វើប្រទក្សិណបុរី ឲ្យតថាគតគ្រងរាជ្យអស់ ៧ ថ្ងៃ លុះមណ្ឌលព្រះអាទិត្យរះឡើង សារថីនាំតថាគតដោយរថ ចេញអំពីនគរ ចូលទៅកាន់ព្រៃ ។ សារថីបានទុករថក្នុងទីឱកាសមួយ ចងសេះផុតពីដៃតថាគត ហើយជីករណ្តៅដើម្បីកប់តថាគតក្នុងផែនដី ។ តថាគតគ្រាន់តែគំរាមនូវអធិដ្ឋាន ដែលខ្លួនអធិដ្ឋានហើយ ដោយហេតុផ្សេងៗ តែមិនទម្លាយនូវអធិដ្ឋាននោះទេ ព្រោះហេតុនៃពោធិញ្ញាណ ។ មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួន ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ។ តថាគតអធិដ្ឋាននូវអង្គទាំង ៣ នុ៎ះ ហើយនៅអស់ ១៦ ឆ្នាំ អធិដ្ឋានដទៃស្មើដោយអធិដ្ឋាននេះ មិនមានឡើយ នេះជាអធិដ្ឋានបារមីរបស់តថាគត ។

### មូគផក្ខចរិយាទី ៦ ចប់

# អដ្ឋកថា

## មូគជក្ខចរិយា

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមូគផក្ខចរិយាទី ៦ ដូចតទៅនេះ បទថា **កាសិរាជស្ស អត្រជោ** សេចក្ដីថា ក្នុងកាលតថាគតជាឱរសរបស់ព្រះបាទកាសី ។ ក្នុងកាលនោះ តថាគតឈ្មោះ មូគផក្ខៈ តែជនទាំងឡាយហៅថាតថាគតថា តេមិយៈ ។ គួរក្រាប់សេចក្ដីថា តថាគត ឈ្មោះថា តេមិយៈ តែជនទាំងឡាយ តាំងអំពីព្រះរាជមាតាព្រះរាជបិតាជាដើម ហៅតថាគតថា មូគផក្ខៈ ព្រោះអធិដ្ឋានជាមនុស្ស-គ និងជាមនុស្សខ្វិន ម្យ៉ាងទៀត ក្នុងថ្ងៃដែលព្រះមហាសត្វកើត ភ្លៀងបានធ្លាក់ក្នុងដែនកាសីទាំងមូល ម្យ៉ាងទៀត ព្រោះមហាសត្វនោះ ញុំាងហទយៈរបស់ព្រះរាជា និងរបស់អមាត្យជាដើមឲ្យសើម ដែលកើតដោយបីតិ និងសេចក្ដីស្នេហាដ៏ក្រៃលែង ហេតុនោះ ទើបបានព្រះនាមថា តេមិយកុមារ ។

បទថា **សោឡសិត្ថិសហស្សានំ** បានដល់ ស្រីស្នំរបស់ព្រះបាទកាសី ១ ម៉ឺន ៦ ពាន់ ។ បទថា **ន វិជ្ជតិ បុមោ** សេចក្ដីថា មិនមានព្រះរាជឱរស មិនមែនតែមិនមានព្រះរាជឱរសតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីព្រះរាជធីតារបស់ព្រះអង្គ ក៏មិនមាន ។ បទថា **អហោរត្តានំ អច្ចយេន និព្វត្តោ អហាមេ-កកោ** ព្រះសាស្ដាទ្រង់ត្រាស់ថា ដោយថ្ងៃ និងយប់កន្លងទៅ មិនមែនតិច ព្រោះកន្លងទៅច្រើនឆ្នាំ តថាគតតែម្នាក់ប៉ុណ្ណោះ ដែលសក្កទេវរាជប្រទានឲ្យដល់ព្រះរាជាអង្គនោះ ដែលមិនមានព្រះរាជឱរស តថាគតត្រាច់ស្វែងរក

ពោធិញ្ញាណក្នុងកាលនោះ បានកើតជាឱរសរបស់ព្រះរាជា ។

ក្នុងចរិយានោះ មានរឿងជាលំដាប់ដូចតទៅ ក្នុងអតីតកាល សម័យព្រះបាទកាសីគ្រងរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់មានស្នំ ១ ម៉ឺន ៦ ពាន់នាក់ ក្នុងស្នំទាំងនោះ មិនបានបុត្រ ឬធីតាសូម្បីតែមួយអង្គ ។ អ្នកនគរកើតការក្តៅក្រហាយថា ព្រះរាជឱរសសូម្បីតែមួយអង្គ ដែលនឹងរក្សារាជវង្សរបស់ពួកយើង មិនមានឡើយ ទើបប្រជុំគ្នាទូលព្រះរាជាថា សូមទ្រង់ប្រាថ្នាព្រះរាជឱរសចុះ ព្រះរាជាទ្រង់ត្រាស់នឹងស្នំទាំង ១ ម៉ឺន ៦ ពាន់ថា ពួកនាងចូរប្រាថ្នាបុត្រចុះ ។ ពួកស្នំទាំងនោះ ធ្វើនូវការបួងសួងព្រះចន្ទជាដើម សូម្បីប្រាថ្នាក៏មិនបានបុត្រ ចំណែកព្រះនាងចន្ទាទេវី ព្រះរាជធីតារបស់ព្រះបាទមទ្ទរាជ ដែលជាអគ្គមហេសីរបស់ព្រះរាជានោះ ព្រះនាងសម្បូរដោយសីល ។ ព្រះរាជាត្រាស់ថា សូម្បីនាងក៏ចូរប្រាថ្នាព្រះរាជឱរសចុះ ។ ក្នុងថ្ងៃពេញបូណ៌មី នាងរក្សាឧបោសថ រឭកដល់សីលរបស់ខ្លួន ព្រះនាងតាំងសច្ចកិរិយាថា បើអាត្មាអញមានសីលមិនដាច់ ដោយសច្ចៈរបស់អញនេះ សូមឲ្យព្រះរាជឱរសកើតចុះ ។ ដោយតេជះនៃសីលរបស់ព្រះនាងនោះ អាសនៈរបស់សក្កទេវរាជ ក៏សម្តែងអាការក្តៅ សក្កទេវរាជពិចារណាក៏ជ្រាបហេតុនោះ ទើបត្រាស់ថា អញនឹងអនុគ្រោះព្រះនាងចន្ទាទេវីឲ្យបានព្រះរាជឱរស ទ្រង់ពិចារណាដល់ព្រះរាជឱរសដែលសមគួរដល់ព្រះទេវីនោះ ទ្រង់ឃើញព្រះពោធិសត្វ ជិតនឹងចុតិក្នុងស្ថានតាវត្តិង្ស តាំងនៅលើស្ថានតាវត្តិង្សនោះជរាបដល់អស់អាយុ ចុតិអំពីភពនោះហើយ បំណងនឹងទៅកើត

ក្នុងទេវលោកខាងលើ ទើបចូលទៅរកព្រះពោធិសត្វត្រាស់ថា នែសម្លាញ់ កាលអ្នកកើតក្នុងមនុស្សលោក បារមីទាំងនោះនឹងបរិបូណ៌ សេចក្ដីចម្រើននឹងមានដល់មហាជន ព្រះនាងចន្ទាអគ្គមហេសីរបស់ព្រះបាទកាសី ប្រាថ្នាព្រះរាជឱរស សូមអ្នកទៅកើតក្នុងផ្ទៃរបស់ព្រះនាងនោះចុះ ។ ព្រះពោធិសត្វទទួលទេវតម្រាស់ ហើយបដិសន្ធិក្នុងផ្ទៃនៃព្រះនាងចន្ទាទេវីនោះ ។ ទេវបុត្រ ៥០០ សម្លាញ់របស់ព្រះពោធិសត្វក៏អស់អាយុ ចុតិអំពីទេវលោក បដិសន្ធិក្នុងផ្ទៃរបស់ភរិយាអមាត្យទាំងឡាយរបស់ព្រះរាជានោះ ។ ព្រះទេវីជ្រាបថាព្រះនាងមានគភ៌ហើយ ទើបក្រាបទូលឲ្យព្រះរាជាជ្រាប ។ ព្រះរាជាត្រាស់ឲ្យមើលថែព្រះគភ៌ ។ ព្រះទេវីទ្រង់គភ៌គ្រប់កំណត់ ទើបប្រសូតព្រះរាជបុត្រដែលសម្បូរដោយបុញ្ញលក្ខណៈគ្រប់ប្រការ ។ ថ្ងៃនោះឯង ក្នុងផ្ទះរបស់ពួកអមាត្យទាំងឡាយ កុមារ ៥០០ ក៏កើត ព្រះរាជាទ្រង់ស្ដាប់ហេតុទាំងពីរប្រការ ទ្រង់ត្រិះរិះថា កុមារទាំងនេះ ចូរជាបរិវារព្រះរាជឱរសរបស់យើង ទើបទ្រង់បញ្ជូនមេដោះ ៥០០ និងគ្រឿងប្រដាប់របស់កុមារ ឲ្យដល់កុមារ ៥០០ ។ម្យ៉ាងទៀត ព្រះរាជាទ្រង់ឲ្យមេដោះ ៦៤ នាក់ ដែលមានទឹកដោះឆ្ងាញ់ មានដោះមិនសណ្ដាយ វៀរចាកទោស មានខ្ពស់ពេកជាដើម ហើយទ្រង់ធ្វើសក្ការៈធំដល់ព្រះពោធិសត្វ ទ្រង់បានប្រទានពរដល់ព្រះនាងចន្ទាទេវី ព្រះនាងចន្ទាទេវីទទួលពរហើយ ។ ព្រះរាជកុមារទ្រង់ចម្រើនដោយបរិវារធំ ។ លំដាប់នោះ ពួកមេដោះតាក់តែងព្រះរាជកុមារ ដែលមានព្រះជន្មបាន ១ ខែ នាំមកគាល់ព្រះរាជា ។ ព្រះរាជាទ្រង់សម្លឹងមើលព្រះរាជឱរសគួរស្រឡាញ់

ទ្រង់ឱបក្រសោប ឲ្យព្រះរាជកុមារផ្ទំលើភ្លៅ ទ្រង់ប្រថាប់គន់ ទ្រង់ត្រេកអរជាមួយព្រះរាជឱរស ។ ក្នុងខណៈនោះ ពួករាជបុរសនាំចោរ ៤ នាក់ មកឲ្យកាត់ទោស ។ ក្នុងចោរ ៤ នាក់នោះ ចោរម្នាក់ ព្រះរាជាកាត់ទោសឲ្យវាយដោយផ្តៅមានបន្ទា ១ ពាន់រំពាត់ ។ ចោរម្នាក់ ឲ្យដាក់ច្រវាក់បញ្ចូលក្នុងគុក ។ ចោរម្នាក់ ឲ្យយកលំពែងចាក់លើរាងកាយ ។ ចោរម្នាក់ឲ្យដោតដោយឈើអណ្តោត ។ ព្រះមហាសត្វស្តាប់ពាក្យកាត់ក្តីរបស់ព្រះបិតា ក៏កើតសេចក្តីសង្វេគ ទ្រង់ព្រះតម្រិះថា ឱ បិតារបស់អញ អាស្រ័យភាពជាព្រះរាជា ធ្វើកម្មធ្ងន់ដែលនាំទៅកាន់នរក ។ ស្អែកឡើង ពួកមេដោះឲ្យព្រះមហាសត្វផ្ទំលើសិរិសេយ្យាសនៈ ដែលតាក់តែងក្រោមស្វេតច្ឆត្រ ។

ព្រះមហាសត្វផ្ទំលក់ទៅបានបន្តិច ហើយទ្រង់តើនឡើងបើកព្រះនេត្រសម្លឹងមើលស្វេតច្ឆត្រ ទ្រង់ឃើញសិរីសម្បត្តិធំ ។ ពេលនោះ ព្រះមហាសត្វតាមប្រក្រតីទ្រង់សង្វេគស្រាប់ហើយ រឹងរឹតតែកើតការភ័យខ្លាចខ្លាំងឡើង ។ ព្រះមហាសត្វទ្រង់ពិចារណាថា អញមកកាន់ព្រះរាជនិវេសន៍នេះ អំពីទីណាហ្ន៎ ទ្រង់ក៏ជ្រាបថា មកអំពីទេវលោក ដោយទ្រង់រឭកជាតិបាន ទើបទ្រង់រឭកបន្តទៅអំពីនោះទៀត ទ្រង់ឃើញថា ទ្រង់ធ្លាប់ឆេះក្នុងឧស្សទនរក ។ ទ្រង់ប្រមើលមើលបន្តទៅទៀត ទ្រង់ឃើញភាពដែលព្រះអង្គជាព្រះរាជា ក្នុងនគរនេះឯង ។ លំដាប់នោះ ព្រះពោធិសត្វទ្រង់ផ្ទំត្រិះរិះថា អញសោយរាជសម្បត្តិ ២០ ឆ្នាំ ឆេះក្នុងឧស្សទនរក ៨ ម៉ឺនឆ្នាំ ឥឡូវនេះ អញកើតក្នុងផ្ទះចោរនេះឯង សូម្បីព្រះបិតារបស់អញ កាលពីម្សិលមិញនេះ កាលគេ

នាំចោរ ៤ នាក់មក ក៏ត្រាស់ព្រះតម្រាស់ដ៏ទារុណបែបនោះ ដែលជាហេតុធ្វើឲ្យធ្លាក់នរក អញមិនត្រូវការរាជសម្បត្តិដែលនាំទូវសេចក្ដីវិនាសធំ ដែលមិនប្រាកដនេះមក អញគប្បីផុតអំពីផ្ទះចោរនេះ បានដូចម្ដេចហ្ន៎ ។ គ្រានោះទេពធីតាមួយអង្គ បានលួងលោមព្រះពោធិសត្វនោះថា នែតេមិយកុមារ បាកុំភ័យខ្លាច ការផុតភ័យនឹងមានដល់បា ព្រោះអធិដ្ឋានអង្គ ៣ ។ ព្រះមហាសត្វស្ដាប់ដូច្នោះ មានបំណងនឹងផុតចាកសេចក្ដីវិនាស គឺរាជសម្បត្តិ ទើបទ្រង់អធិដ្ឋានអង្គ ៣ អស់ ១៦ ឆ្នាំ ដោយអធិដ្ឋានមិនញាប់ញ័រ ដូចព្រះមានព្រះភាគត្រាស់ថា

កាលដែលតថាគតកើតជារាជឱរស នៃព្រះបាទកាសិករាជ ជនទាំងឡាយ មានមាតាបិតាជាដើម តែងហៅតថាគត ថាមូគផក្ខៈផង ថាតេមិយៈផង ។ កាលនោះ ពួកស្រីស្នំ ( របស់ព្រះបាទកាសិករាជ ) ចំនួន ១៦០០០ មិនមានកូនប្រុស អស់កាលកន្លងទៅនៃថ្ងៃ និងយប់ជាច្រើន គឺអស់ច្រើនឆ្នាំ កើតបានតែរាជបុត្រមួយ គឺតថាគត ។ ដោយបិតារបស់តថាគត បានដោយកម្រនូវតថាគតជាកូន ជាទីស្រឡាញ់ ជាកូនមានជាតិខ្ពស់ទ្រទ្រង់សេចក្ដីរុងរឿង ព្រះរាជាក៏យកនូវស្វេតច្ឆត្របាំងតថាគតចិញ្ចឹមឲ្យផ្ទំលើសិរីសយនា ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កិច្ឆាលទ្ធំ** សេចក្ដីថា បានដោយក្រ គឺដោយលំបាក ដោយការប្រាថ្នាមកអស់កាលយូរ ។ បទថា **អភិជាតំ** បានដល់

សម្បូរដោយជាតិ ។ ឈ្មោះថា **ផុតិង្គំ** ព្រោះប្រកបដោយការរុងរឿងផ្លូវកាយ និងការរុងរឿងដោយញាណ ។ បទថា **សេតច្ឆត្តំ ធារយិត្វាន សយនេ ចោសេតិ មំ បិតា** សេចក្តីថា ព្រះបាទកាសីជាបិតារបស់តថាគតឲ្យតថាគតដេកលើសិរិសេយ្យាសនៈខាងក្រោមស្វេតច្ឆត្រ តាំងអំពីតថាគតកើត ឲ្យបិញ្ចឹមតថាគតដោយបរិវារធំ ដោយបំណងថា ធូលី ឬទឹកសន្សើមចូរកុំពាល់ត្រូវកុមារនោះ ។ តថាគតដេកលើទីដេកដ៏ប្រសើរ ភ្ញាក់ឡើងហើយសម្លឹងមើលឃើញឆត្រពណ៌ស ។ បទថា **យេនាហំ និរយំ គតោ** សេចក្តីថា ដែលជាហេតុឲ្យតថាគតទៅកាន់នរកក្នុងអត្តភាពទី ៣ បន្ទាប់អំពីអត្តភាពនេះដោយស្វេតច្ឆត្រណា លោកពោលដល់រាជសម្បត្តិ ដោយមាតិកាថា ស្វេតច្ឆត្រ ។ បទថា **សហ ទិដ្ឋស្ស មេ ឆត្តំ** សេចក្តីថា ការតក់ស្លុតកើតឡើងហើយដល់តថាគត ដែលឃើញស្វេតច្ឆត្រនោះ ដំណាលគ្នានឹងការឃើញនោះ អធិប្បាយថា សព្វកាលដែលឃើញនោះឯង ។ បទថា **តាសោ ឧប្បជ្ជិ ភេរវោ** សេចក្តីថា កើតនូវការតក់ស្លុតគួរខ្លាច ព្រោះជាទោសដែលប្រាកដជាក់ច្បាស់ហើយ ។ បទថា **វិនិច្ឆយំ សមាបន្នោ កថាហំ ឥមំ មុញ្ចិស្សំ** សេចក្តីថា តថាគតត្រិះរិះយ៉ាងនេះថា តថាគតនឹងដោះខ្លួនអំពីរាជសម្បត្តិដែលជារបស់កាឡកិណីនេះបានដូចម្តេចហ្ន៎ ។ បទថា **បុព្វសាលោហិតា មយ្ហំ** សេចក្តីថា ទេពធីតាជាមាតារបស់តថាគតក្នុងអត្តភាពមួយដែលស្ថិតនៅក្នុងស្វេតច្ឆត្រនោះ ជាអ្នកប្រាថ្នាប្រយោជន៍ ស្វែងរកប្រយោជន៍ដល់តថាគត ។ បទថា **សា មំ ទិស្វាន ទុក្ខិតំ តីសុ ឋានេសុ យោជយិ**

សេចក្តីថា ទេពធីតានោះ ឃើញតថាគតប្រកបដោយទុក្ខ ព្រោះសេចក្តីទុក្ខយ៉ាងនោះ ទើបណែនាំឲ្យតថាគតប្រកបក្នុងហេតុដែលនឹងចេញចាកទុក្ខ ក្នុងរាជសម្បត្តិ ៣ ប្រការ គឺគ ខ្ទិន និងថ្ងង់ ។ បទថា **បណ្ឌិច្ចយំ** បានដល់ភាពជាអ្នកឈ្លាស ។ ម្យ៉ាងទៀត បាលីថា **បណ្ឌិច្ចំ** ដូច្នេះក៏មាន ។ បទថា **មា វិភាវយ** បានដល់ ចូរអ្នកកុំប្រកាសភាពជាបណ្ឌិត ។ បទថា **ពាលមតោ** បានដល់ ឲ្យគេដឹងថាជាមនុស្សល្ងង់ ។ បទថា **សព្វោ** បានដល់ ជនខាងក្នុង និងជនខាងក្រៅទាំងអស់ ។ បទថា **ឱចិនាយតុ** សេចក្តីថា មនុស្សទាំងពួង រមែងមើលងាយថា ចូរពួកអ្នកនាំមនុស្សកាឡកិណីនេះចេញទៅ ។ បទថា **ឯវំ តវ អត្ថោ ភវិស្សតិ** សេចក្តីថា កាលអ្នកត្រូវមើលងាយដោយន័យដូចពោលហើយយ៉ាងនោះ ប្រយោជន៍ គឺការញ៉ាំងបារមីឲ្យបរិបូណ៌ ដោយការចេញចាកផ្ទះ នឹងមានដល់អ្នក ។

បទថា **តេតំ វចនំ** សេចក្តីថា ខ្ញុំធ្វើតាមពាក្យរបស់នាងដែលពោលថា ចូរអ្នកអធិដ្ឋានអង្គ ៣ ដូច្នេះ ។ បទថា **អត្ថកាមាសិ មេ អម្ម** សេចក្តីថា ទេពធីតា នាងប្រាថ្នាប្រយោជន៍ដល់ខ្ញុំ ។ បទថា **ហិតកាមា** ជាពាក្យពោលដោយបរិយាយរបស់ពាក្យថា **អត្ថកាមា** នុ៎ះឯង ។ បទថា **អត្ថ** នេះគប្បីជ្រាបថា ជាសេចក្តីសុខ ។ បទថា **ហិត** បានដល់ បុណ្យដែលជាហេតុនៃសេចក្តីសុខនោះ ។

បទថា **សាគរេវ ថលំ លភឹ** សេចក្តីថា តថាគតគិតថា តថាគតកើតក្នុងផ្ទះចោរ សេចក្តីវិនាសធំមានដល់តថាគតៗ លិចចុះក្នុងសាគរ គឺ

សេចក្តីសោក បានស្តាប់ពាក្យរបស់ទេពធីតានោះ ក៏បានឃើញនូវទីពឹង ដូចបុគ្គលលិចក្នុងសាគរ បានឃើញត្រើយ អធិប្បាយថា តថាគតបាន ឧបាយចេញចាករាជត្រកូលហើយ ។ បទថា **តយោ អង្គេ អធិដ្ឋហឹ** សេចក្តីថា តថាគតបានអធិដ្ឋានអង្គ ៣ ប្រការ ទម្រាំតថាគតបានចេញអំពីផ្ទះ ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងអង្គ ៣ នោះដោយសរុប ទើបត្រាស់ព្រះគាថាថា **មូគោអហោសឹ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បក្ខោ**[១] បានដល់ ជាមនុស្សខ្វិន ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។

កាលព្រះមហាសត្វ ទ្រង់តាំងនៅក្នុងន័យដែលទេពធីតាឲ្យ ហើយទ្រង់សម្តែងខ្លួនដោយភាពជាមនុស្ស-គជាដើម តាំងអំពីឆ្នាំដែលទ្រង់ប្រសូត ព្រះមាតាព្រះបិតា និងពួកស្នំជាដើមគិតថា ធម្មតាបុងចង្ការបស់មនុស្ស-គ រន្ធត្រចៀករបស់មនុស្សថ្លង់ ដៃជើងរបស់មនុស្សខ្វិន មិនមានសភាពយ៉ាងនេះ ក្នុងរឿងនេះគប្បីមានហេតុ អញនឹងពិសោធកុមារនេះមើល ហើយគិតបន្តថា យើងនឹងពិសោធដោយទឹកដោះជាមុន ទើបមិនឲ្យទឹកដោះអស់ ១ ថ្ងៃ ។ កុមារនោះ ទោះបីស្រេកឃ្លាន ក៏មិនស្រែកយំដើម្បីទឹកដោះ ។

លំដាប់នោះ ព្រះមាតារបស់កុមារព្រះតម្រិះថា កូនរបស់អញពិតជាស្រេកឃ្លាន ចូរពួកនាងឲ្យទឹកដោះដល់កូនយើងចុះ ហើយឲ្យពួកស្នំឲ្យបៅ ។ ពួកមេដោះឲ្យទឹកដោះជារយៈៗ យ៉ាងនេះ សូម្បីពិសោធអស់ ១ ឆ្នាំ ក៏នៅ

---

១- បិដកជា ផក្ខោ ។

តែមិនឃើញឱកាស ។ បន្ទាប់អំពីនោះ ពួកមេដោះគិតថា ធម្មតាកុមារ រមែងចូលចិត្តនំ និងរបស់ទំពា ចូលចិត្តផ្លែឈើ ចូលចិត្តរបស់លេង ចូលចិត្តអាហារ ទើបនាំរបស់ដែលគួរជាទីត្រេកអរនោះៗ ចូលទៅឲ្យ លួងលោមដោយការពិសោធ ក៏មិនឃើញឱកាសអស់ ៥ ឆ្នាំ ។ លំដាប់នោះ ពួកមេដោះគិតថា ធម្មតាកុមារ រមែងខ្លាចភ្លើង ខ្លាចដីរំពុះប្រេង ខ្លាចពស់ ខ្លាចមនុស្សស្រាដាវ យើងនឹងពិសោធដោយហេតុទាំងនោះ ទើបត្រៀមរបស់ដូចពោលហើយ ដោយមិនឲ្យកើតអន្តរាយដល់កុមារដោយអាការទាំងនោះបាន ហើយឲ្យបន្ថែមការសម្តែងដោយអាការដែលគួរខ្លាចក្រៃលែង ។

ព្រះមហាសត្វទ្រង់ពិចារណាដល់ភ័យក្នុងនរក ទើបមិនញាប់ញ័រ ដោយទ្រង់ឃើញថា នរកគួរខ្លាចក្រៃលែងជាងនេះរាប់រយ រាប់ពាន់ រាប់សែនដង ។ ពួកមេដោះពិសោធយ៉ាងនេះក៏មិនឃើញឱកាស ទើបគិតថា ធម្មតាកុមារត្រូវការមើលមហោស្រព ទើបឲ្យសាងមហោស្រព យករាំងននបាំងព្រះមហាសត្វ ហើយឲ្យប្រគំដោយសំឡេងស័ង្ខ និងសំឡេងស្គរ ឲ្យលាន់ឮរងំដូចគ្នាក្នុងខាងទាំង ៤ របស់ព្រះរាជកុមារដែលមិនដឹងរឿង អុជចង្កៀងធ្លលក្នុងទីងងឹត ឲ្យពន្លឺភ្លឺ ចូលទៅយកស្ករអំពៅលាបពេញខ្លួនឲ្យ ដេកក្នុងទីដែលមានរុយ មិនឲ្យងូតទឹកជាដើម ចូលទៅរង់ចាំមើលកុមារដេកលើឧច្ចារបស្សាវៈ បៀតបៀនដោយការសើចចំអក និងជេរថា កុមារដេកលើមូត្រ និងលាមក ដាក់អំបែងរងើកភ្លើងក្រោមគ្រែ ធ្វើឲ្យក្តៅក៏មាន សូម្បីសាកល្បងដោយឧបាយច្រើនយ៉ាង ក៏មិនឃើញឱកាសរបស់កុមារនោះ ។

ព្រះមហាសត្វទ្រង់ពិចារណាដល់ភ័យក្នុងនរកប៉ុណ្ណោះ ក្នុងទីទាំងពួង ទ្រង់មិនទម្លាយការតាំងចិត្ត មិនកម្រើកញាប់ញ័រ ។ ពួកមេដោះសាកល្បងយ៉ាងនេះអស់ ១៥ ឆ្នាំ លុះព្រះជន្មបាន ១៦ វស្សា ពួកមេដោះគិតថា មនុស្សខ្វិនក្តី គក្តី ថ្លង់ក្តី មិនតម្រេកក្នុងវត្ថុដែលគួរតម្រេក មិនចង់ឃើញវត្ថុដែលគួរឃើញ រមែងមិនមាន ព្រោះហេតុនោះ យើងនឹងរកអ្នករបាំមកពិសោធរាជកុមារ ទើបយកគ្រឿងក្រអូបលាបព្រះរាជកុមារ ប្រដាប់ដោយគ្រឿងអលង្ការដូចទេវបុត្រ យាងឡើងលើប្រាសាទដែលមានតែការសប្បាយតែម្យ៉ាង ជាប្រាសាទដែលប្រកបដោយផ្កា គ្រឿងក្រអូប និងកម្រងមាល័យជាដើម ដូចទេវវិមាន ទើបឲ្យស្ត្រីដែលសុទ្ធតែមានរូបស្អាត ឈ្លាសដោយមាយា ប្រៀបដូចទេពអប្សរ ចាំបម្រើថា ពួកនាងចូរឲ្យព្រះរាជកុមារត្រេកអរក្រៃលែង ដោយភាពជារបស់ទៀងជាដើម ស្ត្រីទាំងនោះ ក៏ព្យាយាមដើម្បីចូលទៅធ្វើតាមនោះ ។ ព្រោះព្រះរាជកុមារទ្រង់សម្បូរដោយបញ្ញា ទើបទ្រង់អត់សង្កត់នូវខ្យល់អស្សាសបស្សាសៈ ដោយបំណងថា ស្ត្រីទាំងនេះ កុំប៉ះពាល់រាងកាយរបស់អាត្មាអញឡើយ ។ ស្ត្រីទាំងនោះ កាលមិនបានប៉ះពាល់រាងកាយរបស់ព្រះរាជកុមារ ទើបគិតថា ព្រះរាជកុមារនេះ មានរាងកាយរឹងប្រហែលជាមិនមែនមនុស្ស ពិតជាយក្ខ ទើបនាំគ្នាត្រឡប់ទៅ ។

ព្រះមាតាព្រះបិតា ទ្រង់មិនអាចចាប់កំហុសបានដោយការពិសោធធំៗ អស់ ១៦ ដង និងដោយការពិសោធតូចៗ ជាច្រើនដង ដរាបអស់ ១៦ ឆ្នាំ យ៉ាងនេះ ទើបទ្រង់អង្វរច្រើនដងថា តេមិយៈកូនសម្លាញ់ មាតា និងបិតា

ដឹងថា កូនមិនមែន-គ ព្រោះមាត់ត្រចៀក និងជើងយ៉ាងនេះ មិនមែនរបស់មនុស្ស-គ មនុស្សថ្ងង់ និងមនុស្សខ្វិនឡើយ កូនជាបុត្រដែលមាតាបិតាប្រាថ្នា ទើបបានមក កូនកុំឲ្យមាតាបិតាវិនាសឡើយ ចូរដោះពាក្យនិន្ទាអំពីរាជសម្នាក់ក្នុងជម្ពូទ្វីបទាំងមូលចុះ ។ ព្រះរាជកុមារនោះ សូម្បីព្រះមាតាបិតាអង្វរយ៉ាងនេះ ក៏ធ្វើជាមិនបានឮ ។

លំដាប់នោះ ព្រះរាជាត្រាស់ឲ្យបុរសអ្នកឈ្លាសវៃ ពិនិត្យមើលបាទាទាំងពីរ មើលរន្ធត្រចៀកទាំងពីរ មើលព្រះជិវ្ហា និងព្រះហស្តទាំងទ្វេរបស់ព្រះមហាសត្វហើយ ទ្រង់ស្តាប់ពាក្យដែលអមាត្យក្រាបទូលថា ឥឡូវនេះអ្នកជំនាញទាយលក្ខណៈពោលថា បើព្រះបាទាជាដើមរបស់កុមារនេះ ដូចជើងរបស់អ្នកមិនខ្វិនជាដើម កុមារនេះ មិនមែនជាមនុស្សខ្វិន គ និងថ្លង់ពិតប្រហែលជាមនុស្សកាឡកិណី កាលបើមនុស្សកាឡកិណីបែបនេះ នៅក្នុងព្រះរាជវាំង នឹងប្រាកដអន្តរាយ ៣ យ៉ាង គឺអន្តរាយនៃជីវិត ១ អន្តរាយនៃស្វេតច្ឆត្រ ១ អន្តរាយនៃព្រះមហេសី ១ ។ តែក្នុងថ្ងៃប្រសូត ដើម្បីកុំឲ្យព្រះអង្គទោមនស្ស ទើបពោលថា កុមារនេះមានបុញ្ញលក្ខណៈបរិបូណ៌ ។ ព្រះរាជាទ្រង់ភ័យខ្លាចអន្តរាយ ទើបត្រាស់ថា ចូរពួកអ្នកឲ្យកុមារនេះផ្ទុំក្នុងរថអពមង្គល នាំចេញតាមទ្វារក្រោយ ហើយកប់ក្នុងព្រៃស្មសាន ។ ព្រះមហាសត្វទ្រង់ឮដូច្នោះ ទ្រង់ត្រេកអរក្រៃលែងថា ការប្រាថ្នារបស់អញអស់កាលយូរ នឹងដល់នូវការសម្រេច ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតអធិដ្ឋាននូវអង្គទាំង ៣ នុ៎ះហើយ នៅអស់ ១៦ ឆ្នាំ លំដាប់ពីនោះមក ជនទាំងឡាយ ប្រចាប់ដៃជើង អណ្តាត និងត្រចៀករបស់តថាគតមើល ឃើញថា អវយវៈតថាគតមិនខ្វះខាត ហើយតិះដៀលតថាគតថា ជាបុរសកាឡកិណី ។ លំដាប់នោះ ពួកអ្នកជនបទទាំងអស់ មានសេនាបតី និងបុរោហិតជាប្រធាន ពួកជនទាំងអស់នោះ ស្រុះចិត្តគ្នា ត្រេកអរក្នុងការលះបង់ចោលតថាគត ។ លុះតថាគតស្តាប់នូវសេចក្តីយល់ឃើញរបស់ពួកជនទាំងនោះ ក៏មានចិត្តត្រេកអរ មានចិត្តសង្វេគ តបៈដែលតថាគតប្រព្រឹត្តហើយ ដើម្បីជាប្រយោជន៍ណា ប្រយោជន៍នោះ នឹងសម្រេចដល់តថាគតមិនខាន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មទ្ទិយ** បានដល់ ពិនិត្យមើលដោយការស្ទាបអង្អែល ។ បទថា **អន្ធនត៌** បានដល់ ដៃជាដើមមិនខ្វះខាត ។ បទថា **និន្ទិសុំ** សេចក្តីថា តិះដៀលថា ទោះបីមានអវយវៈមិនខ្វះខាតយ៉ាងនេះ តែស្ងៀមធ្មឹងដូចមនុស្ស-គជាដើម ក៏មិនគួរគ្រងរាជសម្បត្តិ កុមារនេះគឺជាមនុស្សកាឡកិណី ។ បាឋៈថា **និន្ទិសុ** ដូច្នេះក៏មាន អធិប្បាយថា ពោលហើយ ។ បទថា **ជនទំ អនុមោទិសុំ** សេចក្តីថា អ្នកជនបទទាំងពួង ពួករាជបុរស មានសេនាបតី និងបុរោហិតជាប្រធាន មកដើម្បីគាល់ព្រះរាជា រួមចិត្តគ្នាទាំងអស់ មិនសម្តែងអាការចង់ចិញ្ចឹម ដែលព្រះរាជាត្រាស់ឲ្យនាំតថាគតទៅចោល ដោយកប់ក្នុងផែនដី ដើម្បីច្រងផុតអន្តរាយ បែរជានាំគ្នា

ត្រេកអរដោយមានមុខរីករាយថា សាធុ គួរធ្វើហើយ ។

បទថា **សោ មេ អត្ថោ សមិជ្ឈថ** សេចក្តីថា តថាគតប្រព្រឹត្តសន្សំ ប្រព្រឹត្តដោយកម្រ ដោយអធិដ្ឋានភាពជាមនុស្ស-គជាដើម ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ សម្រេចដល់តថាគត ។ គប្បីជ្រាបសម្ពន្ធដោយពាក្យដ៏សេសថា តថាគតនោះបានស្តាប់បំណងរបស់ព្រះរាជមាតាបិតាជាដើម របស់តថាគតនោះហើយ ត្រេកអរដោយការសម្រេចបំណងរបស់តថាគត សង្វេគដោយការមិនពិចារណា ហើយអនុញ្ញាតឲ្យកប់ក្នុងផែនដី ។

កាលព្រះរាជា មានព្រះតម្រាស់ឲ្យកប់កុមារក្នុងផែនដីយ៉ាងនេះហើយ ព្រះនាងចន្ទាទេវីស្តាប់រឿងនោះ ទើបចូលទៅគាល់ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់ប្រទានពរឲ្យដល់ខ្ញុំម្ចាស់ៗ នឹងកាន់យកពរនោះ ឥឡូវនេះសូមទ្រង់ប្រទានពរនោះដល់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាត្រាស់ថា សូមទទួលពរចុះ ។ ព្រះទេវីទូលថា សូមទ្រង់ប្រទានរាជសម្បត្តិដល់ឱរសរបស់ខ្ញុំម្ចាស់ចុះ ព្រះរាជាត្រាស់ថា ឱរសរបស់នាងជាមនុស្សកាឡកិណី យើងមិនអាចឲ្យបានទេ ព្រះនាងទូលថា បពិត្រព្រះអង្គ កាលទ្រង់មិនឲ្យដរាបដល់អស់ជីវិតក៏សូមឲ្យត្រឹម ៧ ឆ្នាំចុះ ព្រះរាជាត្រាស់ថា យើងមិនអាចឲ្យបានឡើយ ព្រះនាងទូលថា សូមទ្រង់ឲ្យ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ ព្រះរាជាត្រាស់ថា មិនអាចឲ្យបាន ព្រះនាងទូលថា សូមឲ្យ ៧ ថ្ងៃចុះ ព្រះរាជាត្រាស់ថា សាធុ យើងឲ្យបាន ។

ព្រះទេវីឲ្យតាក់តែងព្រះរាជឱរស ឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា នេះជារាជសម្បត្តិរបស់តេមិយកុមារ ហើយឲ្យតាក់តែងព្រះនគរ ឲ្យព្រះរាជ-ឱរសគង់លើ-កដំរី លើកស្វេតច្ឆត្រឲ្យព្រះរាជឱរស ធ្វើប្រទក្សិណព្រះនគរ ហើយត្រឡប់មក ឲ្យព្រះពោធិសត្វផ្ទំលើសិរិសេយ្យាសនៈ ដែលតាក់តែងហើយ ព្រះនាងទ្រង់លួងលោមអស់មួយរាត្រីថា តេមិយៈ មាតាដេកមិនលក់អស់ ១៦ ឆ្នាំហើយ ព្រោះអាស្រ័យកូន មាតាយំរហូតនេត្រាហើម ហទយៈរបស់មាតាស្ទើរបែកសញ្ជែកព្រោះសេចក្តីសោក មាតាដឹងថា កូនមិនខ្វិនជាដើម កូនកុំធ្វើឲ្យមាតាអស់ទីពឹងឡើយ ។ ព្រះទេវីទ្រង់ព្រះកន្សែងដោយទំនងនេះអស់ ៦ ថ្ងៃ ។ ក្នុងថ្ងៃទី ៦ ព្រះរាជាត្រាស់ហៅសុនន្ទសារថីមកហើយ ត្រាស់ថា ស្អែកនេះ ចូរបានាំព្រះរាជកុមារដោយរថអពមង្គលចេញទៅអំពីព្រលឹម កប់ក្នុងផែនដីត្រង់ព្រៃខ្មោច លុបដីឲ្យរាបស្មើហើយ ចូរត្រឡប់ ។ ព្រះទេវីស្តាប់ដូច្នោះ ត្រាស់ថា នែកូន ព្រះបាទកាសីមានបញ្ជាឲ្យកប់កូនក្នុងព្រៃខ្មោចក្នុងថ្ងៃស្អែកនេះ ព្រឹកនេះ កូននឹងដល់នូវសេចក្តីស្លាប់ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ ទើបត្រេកអរក្រៃលែងថា នែតេមិយៈ អ្នកព្យាយាមអស់ ១៦ ឆ្នាំ ជិតដល់ទីបំផុតហើយ តែហទយៈរបស់ព្រះមាតាពោធិសត្វ ហាក់ដូចបែកធ្លាយទៅ ។ កាលរាត្រីអស់ទៅ សារថីនាំរថមកអំពីព្រលឹម បញ្ឈរត្រង់ទ្វារ ចូលទៅកាន់បន្ទប់ដ៏មានសិរីទូលថា បពិត្រព្រះទេវី ព្រះនាងកុំខ្វាល់នឹងទូលបង្គំឡើយ ទូលបង្គំធ្វើតាមព្រះរាជបញ្ជា ហើយច្រានព្រះទេវីដោយខ្នងដៃ ដែលឱបព្រះរាជឱរសក្នុងទ្រូង ហើយលើកព្រះរាជ-

កុមារចុះអំពីប្រាសាទ ព្រះទេវីទ្រង់គក់ទ្រូង ព្រះកន្សែងរៀបរាប់ ដោយព្រះសូរសៀងដ៏ខ្លាំង ព្រះនាងដួលចុះលើផ្ទៃប្រាសាទ ។

លំដាប់នោះ ព្រះមហាសត្វទ្រង់សម្លឹងមើលព្រះមាតា ហើយព្រះតម្រិះថា បើអញមិននិយាយ ព្រះមាតានឹងសោយសោកមិនមានទីបំផុត ទោះបីចង់និយាយ ក៏ទ្រង់អត់សង្កត់ដោយព្រះតម្រិះថា បើអញនិយាយ សេចក្ដីព្យាយាមដែលអញធ្វើអស់ ១៦ ឆ្នាំនឹងជាមោឃ តែបើអញមិននិយាយ នឹងបានជាបច្ច័យដល់ខ្លួនអញផង ដល់ព្រះមាតាព្រះបិតាផង ។ សារថីគិតថា អញនឹងនាំព្រះមហាសត្វឡើងរថ ហើយបររថបំណាងទៅកាន់ទ្វារទិសខាងលិច បែរជាបែរមុខទៅទិសខាងកើត រថចេញអំពីព្រះនគរ ដោយអានុភាពរបស់ទេវតាទៅកាន់ទីប្រមាណ ៣ យោជន៍ ព្រះមហាសត្វទ្រង់ត្រេកអរក្រៃលែង ។ ដងព្រៃក្នុងទីនោះ ប្រាកដដល់សារថីដូចព្រៃស្មសាន ។ សារថីគិតថា ទីនេះល្អហើយ ទើបបញ្ឈប់រទេះក្បែរផ្លូវហើយចុះអំពីរថ ដោះគ្រឿងអលង្ការរបស់ព្រះមហាសត្វចេញ ហើយខ្ចប់ កាន់យកចប ផ្ដើមជីករណ្ដៅក្នុងទីមិនឆ្ងាយ ដូចព្រះមានព្រះភាគត្រាស់ថា

> ជនទាំងឡាយ មានមាតាបិតាជាដើម ផ្ងូតទឹកក្រអូប លាបគ្រឿងក្រអូប ហើយឲ្យពាក់រាជមកុដ អភិសេកដោយស្វេតច្ឆត្រ ធ្វើប្រទក្សិណបុរី ឲ្យតថាគតគ្រងរាជ្យអស់ ៧ ថ្ងៃ លុះមណ្ឌលព្រះអាទិត្យរះឡើង សារថីនាំតថាគតដោយរថ ចេញអំពីនគរចូលទៅកាន់ព្រៃ ។ សារថីបានទុករថក្នុងទីឱកាសមួយ ចងសេះ

ផុតពីដៃតថាគត ហើយជីករណ្តៅ ដើម្បីកប់តថាគតក្នុងផែនដី ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន្ហាបេត្វា** បានដល់ ឲ្យងូតដោយក្អមទឹកក្រអូប ១៦ ក្អម ។ បទថា **អនុលិម្បិត្វា** បានដល់ លាបដោយគ្រឿងក្រអូប ។ បទថា **វេឋេត្វា រាជវេឋនំ** បានដល់ ពាក់រាជមកុដត្រង់សិរសា ដែលប្រព្រឹត្តទៅតាមបវេណីរបស់ស្តេចកាសីទាំងឡាយ ។ បទថា **អភិសិញ្ចិត្វា** បានដល់ អភិសេកដោយបែបផែនជារាជាភិសេកក្នុងរាជត្រកូលនោះ ។ បទថា **ឆត្តេន ការេសុំ បុរំ បទក្ខិណំ** បានដល់ មានស្វេតច្ឆត្របាំងឲ្យតថាគតធ្វើប្រទក្សិណព្រះនគរ ។

បទថា **សត្តាហំ ធារយិត្វាន** សេចក្តីថា តាំងស្វេតច្ឆត្ររបស់តថាគត ដែលព្រះនាងចន្ទាទេវី ព្រះមាតារបស់តថាគតបានទទួលហើយ ដោយអំណាចនៃការទទួលពរ ៧ ថ្ងៃ ។ បទថា **ឧគ្គតេ រវិមណ្ឌលេ** សេចក្តីថា បន្ទាប់អំពីនោះ ក្នុងថ្ងៃស្អែក លុះព្រះអាទិត្យរះ សុនន្ទសារថីនាំតថាគតចេញអំពីព្រះនគរដោយរថអពមង្គល ចូលព្រៃដើម្បីកប់តថាគតក្នុងផែនដី ។

បទថា **សជ្ជស្សំ** សេចក្តីថា សារថីបញ្ឈប់រថរបស់តថាគត ដែលទឹមដោយសេះត្រង់ទីមទុកក្នុងឱកាសមួយ ដោយចៀសចេញអំពីផ្លូវ ។ បទថា **ហត្ថមុច្ចិតោ** បានដល់ ផុតអំពីដៃ អធិប្បាយថា មានដៃផុតអំពីរថ ។ ម្យ៉ាងទៀត បទថា **ហត្ថមុច្ចិតោ** បានដល់ ផុតចាកដៃ អធិប្បាយថា លែង ។ បទថា **កាសុំ** បានដល់ រណ្តៅ ។ បទថា **និខាតុំ** បានដល់ ដើម្បីកប់ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងដល់ប្រយោជន៍ដែលទ្រង់អធិដ្ឋាន ប្រព្រឹត្តវត្តដែលធ្វើបានដោយក្រអស់ ១៦ ឆ្នាំ ដោយអធិដ្ឋានធ្វើជាគជាដើម ទើបត្រាស់ ២ គាថាថា

តថាគតគ្រាន់តែគំរាមនូវអធិដ្ឋាន ដែលខ្ញុំនអធិដ្ឋានហើយ ដោយហេតុផ្សេងៗ តែមិនទម្លាយនូវអធិដ្ឋាននោះទេ ព្រោះហេតុនៃពោធិញ្ញាណ ។ មាតា បិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តជ្ជេន្តោ វិវិធការណា** សេចក្តីថា ព្រះរាជាទ្រង់គំរាមដោយហេតុច្រើនប្រការ មានការមិនឲ្យទឹកដោះជាដើម តាំងអំពីតថាគតមានអាយុ ២ ខែ រហូតដល់មានអាយុ ១៦ ឆ្នាំ គឺឲ្យលំបាកដោយការធ្វើឲ្យភ័យ និងការបៀតបៀន ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។

លំដាប់នោះ កាលសុនន្ទសារថីកំពុងជីករណ្តៅ ព្រះមហាសត្វគិតថា នេះជាកាលនៃការព្យាយាមរបស់អញ ទើបក្រោកឡើង ហើយច្របាច់ព្រះហស្ត និងព្រះបាទ ទ្រង់ជ្រាបថា អាត្មាអញមានកម្លាំង ទើបគិតចុះអំពីរថ ។ រំពេចនោះឯង ទីដាក់ព្រះបាទរបស់ព្រះមហាសត្វក៏ប៉ោងឡើង ដូចថង់ស្បែកពេញដោយខ្យល់ តាំងឡើងទល់គ្នានឹងព្រែករថ ។ ព្រះមហាសត្វទ្រង់ចុះ ទ្រង់យាងទៅមកបន្តិចបន្តួច ទ្រង់ជ្រាបថា អាត្មាអញមានកម្លាំង

ល្មមដើរទៅបានក្នុងទី ១០០ យោជន៍ ទើបទ្រង់ចាប់ចុងរថហើយលើកឡើង ដូចយានតូចសម្រាប់ក្មេងលេង ទ្រង់សង្កេតថា បើសារថីប្រទូស្តអញ អញក៏មានកម្លាំងល្មមការពារនូវការប្រទូស្តបាន ។ ព្រះពោធិសត្វគិតនឹងប្រដាប់តាក់តែងខ្លួន ។

ខណៈនោះឯង ភពរបស់សក្កៈក៏សម្តែងនូវអាការក្តៅ សក្កទេវរាជទ្រង់ជ្រាបហេតុនោះ ទើបត្រាស់ឲ្យវិស្សុកម្មទេវបុត្រថា ចូរអ្នកតាក់តែងរាងកាយឲ្យឱរសរបស់ព្រះបាទកាសី ។ វិស្សុកម្មទេវបុត្រទទួលទេវបញ្ជាហើយ ទើបតាក់តែងព្រះមហាសត្វ ដោយគ្រឿងអលង្ការដែលជាទិព្វ និងជារបស់មនុស្ស ដូចសក្កទេវរាជ ។ ព្រះមហាសត្វយាងទៅកាន់ទីដែលសារថីកំពុងជីករណ្តៅដោយទេវលីលា ប្រថាប់ឈរត្រង់មាត់រណ្តៅ ត្រាស់ថា

នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើព្រោះហេតុអ្វី ម្នាលសម្លាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ ។

សារថីមិនបានងើយមើល ពោលថា

ព្រះរាជបុត្តកើតមកហើយ គផង ខ្វិនផង ដូចជាឥតចិត្ត ឯខ្ញុំនោះ ព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុងព្រៃចុះ ។

ព្រះមហាសត្វត្រាស់ថា

ខ្ញុំមិនថ្លង់ មិន-គ មិនខ្វិនទេ មិនមែនវិកលវិការទេ នែនាយសារថី

បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ អ្នកចូរមើលភ្លៅ និងដើមដៃខ្ញុំ ទាំងចូរស្តាប់សម្តីខ្ញុំ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ ។

សារថីនោះឈប់ជីករណ្តៅ ហើយងើយមើល ឃើញរូបសម្បត្តិរបស់ព្រះមហាសត្វ មិនដឹងថាជាមនុស្ស ឬទេវតា ទើបសួរថា

អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ អ្នកជាអ្វី ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបាន ដោយប្រការដូចម្តេច ។

ព្រះមហាសត្វទ្រង់ក៏សម្តែងធម៌ ដោយន័យជាដើមថា

ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្ក-ទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្តៅ បុគ្គលនោះ គឺខ្ញុំ ជាកូនរបស់ព្រះបាទកាសិក អ្នករស់នៅដោយស្រួល ( ព្រោះអាស្រ័យ ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ នែនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថា អ្នកទ្រុស្តមិត្ត ជាមនុស្សលាមក នែនាយសារថីព្រះរាជា ទុកដូចជាដើមឈើ ខ្លួនខ្ញុំ ទុកដូចជាមែកឈើដែរ អ្នកឯង ទុកដូចបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើ ដូច្នោះ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ ដូច្នេះ។

សារថីក៏ទូលអង្វរដើម្បីឲ្យព្រះពោធិសត្វយាងត្រឡប់ ទើបត្រាស់ដល់

ហេតុដែលមិនត្រឡប់ និងការពេញចិត្តក្នុងបព្វជ្ជា និងរឿងរបស់ព្រះអង្គ ក្នុងភពដែលកន្លងទៅហើយ មានភ័យក្នុងនរកជាដើម ព្រោះហេតុនៃការពេញ ចិត្តក្នុងបព្វជ្ជានោះដោយពិស្តារ ។ កាលសារថីនោះបំណាងនឹងបួស ព្រោះ ធម្មកថានោះ និងព្រោះកិច្ចបដិបត្តិនោះ ទើបត្រាស់គាថានេះថា

នែនាយសារថី អ្នកចូរប្រគល់នូវរថ ហើយជាអ្នកមិនមានបំណុល

សឹមមកចុះ ព្រោះថា បព្វជ្ជា ( រមែងសម្រេច ) ដល់បុគ្គលមិន

មានបំណុល បព្វជ្ជាកម្មនេះ ពួកឥសីសរសើរហើយ ដូច្នេះ ។

ព្រះពោធិសត្វបញ្ជូនសារថីត្រឡប់ទៅដើម្បីទូលដល់ព្រះរាជា ។ សារថី នាំរថ និងគ្រឿងអាភរណៈទៅគាល់ព្រះរាជា ទូលសេចក្ដីនោះឲ្យទ្រង់ជ្រាប ។ រំពេចនោះឯង ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងទៅសម្នាក់មហាសត្វ ទើប យាងចេញអំពីព្រះនគរ មួយអន្លើដោយចតុរង្គសេនា ស្នំ អ្នកនគរ និងអ្នក ជនបទ ។ ព្រះមហាសត្វកាលទ្រង់បញ្ជូនសារថីត្រឡប់ទៅហើយ ក៏មាន បំណាងនឹងបួស ។ សក្កទេវរាជទ្រង់ជ្រាបចិត្តរបស់ព្រះពោធិសត្វ ទើបមាន ទេវបញ្ជានឹងវិស្សុកម្មថា តេមិយបណ្ឌិតបំណាងនឹងបួស ចូរអ្នកនិម្មិតអាស្រម បទ និងគ្រឿងបរិក្ខាររបស់បព្វជិតឲ្យដល់ព្រះមហាសត្វនោះ ។ វិស្សុកម្ម ក៏ទៅនិម្មិតអាស្រមក្នុងដងព្រៃប្រមាណ ៣ យោជន៍ ធ្វើឲ្យសម្បូរដោយទី សម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ទីចង្ក្រម ស្រះបោក្ខរណី ផ្លែឈើ និងដើមឈើ និងនិម្មិតគ្រឿងបរិក្ខាររបស់បព្វជិតទាំងពួងស្រេចហើយ ត្រឡប់ ទៅកាន់លំនៅរបស់ខ្លួន ។ ព្រះពោធិសត្វទតឃើញដូច្នោះ ទ្រង់ជ្រាបថា

សក្កទេវរាជប្រទានឲ្យ ទើបយានចូលកាន់បណ្ណសាលា ដោះសំពត់ចេញ កាន់យកភេទជាតាបស អង្គុយលើកម្រាលដែលធ្វើដោយឈើ ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើត ប្រថាប់គង់ក្នុងអាស្រម ដោយសេចក្ដីសុខក្នុងបព្វជ្ជា ។

ព្រះបាទកាសី ក៏យាងទៅតាមផ្លូវដែលសារថីបាទទូល ហើយទ្រង់ចូលកាន់អាស្រម ព្រះមហាសត្វធ្វើបដិសណ្ឋារៈ ព្រះរាជាទ្រង់យាងឲ្យគ្រប់គ្រងរាជសម្បត្តិ ។ តេមិយបណ្ឌិតបដិសេធ ហើយទូលឲ្យព្រះរាជាសង្វេគដោយធម្មីកថាបដិសំយុត្តដោយភាពជារបស់មិនទៀងជាដើម និងបដិសំយុត្តដោយទោសរបស់កាម ដែលជារបស់ថោកទាប ដោយអាការច្រើនយ៉ាង ។ ព្រះរាជាទ្រង់សង្វេគ ទ្រង់នឿយណាយក្នុងការគ្រប់គ្រងផ្ទះ មានព្រះបំណងនឹងបួស ទើបត្រាស់សួរអមាត្យ និងស្នំទាំងឡាយ ។ ជនទាំងអស់ ក៏បំណងនឹងបួស ។ លំដាប់នោះ ព្រះរាជាទ្រង់ជ្រាបថា ស្នំទាំង ១ ម៉ឺន ៦ ពាន់នាក់ មានព្រះនាងចន្ទាទេវីជាដើម មួយអន្លើដោយពួកអមាត្យ បំណងនឹងបួស ទើបទ្រង់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា បុគ្គលណា បំណងនឹងបួសក្នុងសម្នាក់ឱរសរបស់យើង បុគ្គលនោះ ចូរបួសចុះ ទ្រង់ឲ្យបើកទ្វារឃ្លាំងមាសជាដើម ហើយទ្រង់បរិច្ចាគ ។ ម្យ៉ាងទៀត ពួកអ្នកនគរទាំងមូលលះបង់ផ្សារ បិទទ្វារផ្ទះចូលគាល់ព្រះរាជា ។ ព្រះរាជាទ្រង់បួសក្នុងសម្នាក់ព្រះពោធិសត្វ មួយអន្លើដោយមហាជន ។ អាស្រមបទប្រមាណ ៣ យោជន៍ ដែលសក្កៈប្រទាន ក៏ពេញគ្រប់គ្រាន់ ។

ស្ដេចសាមន្តរាជទាំងឡាយបានដំណឹងថា ព្រះបាទកាសីទ្រង់ចេញបួស ទើបព្រះតម្រិះថា អញនឹងដណ្ដើមរាជសម្បត្តិក្នុងក្រុងពារាណសី ទើបយាង ចូលព្រះនគរ ទ្រង់ឃើញព្រះនគរដូចគ្នានឹងទេវនគរ និងព្រះរាជនិវេសន៍ ដូចគ្នានឹងទេវវិមាន ពេញដោយរតនៈ ៧ ប្រការ គិតថា នឹងមានភ័យព្រោះ អាស្រ័យទ្រព្យនេះ ទើបយាងត្រឡប់ក្នុងវេលានោះឯង ។ ព្រះមហាសត្វ ស្ដាប់ការមករបស់ព្រះរាជាទាំងនោះ ទើបយាងទៅកាន់ជាយព្រៃ ប្រថាប់គង់ សម្ដែងធម៌លើអាកាស ព្រះរាជាទាំងអស់ មួយអន្លើដោយបរិវារ ក៏នាំគ្នា បួសក្នុងសម្នាក់របស់ព្រះពោធិសត្វនោះ ដោយប្រការដូច្នេះ បានជាសមាគម ដ៏សន្ធឹកសន្ធាប់ ។ ឥសីទាំងអស់ បរិភោគផ្លែឈើតូចធំ ហើយបំពេញ សមណធម៌ ។ បុគ្គលណា គិតដល់កាមវិតក្កជាដើម ព្រះពោធិសត្វទ្រង់ ជ្រាបចិត្តរបស់បុគ្គលនោះ ហើយយាងទៅក្នុងទីនោះ ប្រថាប់គង់សម្ដែងធម៌ លើអាកាស ។

ព្រះរាជានោះទ្រង់បាននូវសប្បាយក្នុងការស្ដាប់ធម៌ ទើបញ៉ាំងសមាបត្តិ និងអភិញ្ញាឲ្យកើត បុគ្គលដទៃៗ ក៏យ៉ាងនោះ ដោយប្រការដូច្នេះ ជនទាំង អស់ កាលអស់ជីវិត ក៏ទៅកើតក្នុងព្រហ្មលោក ។ សូម្បីសត្វតិរច្ឆានទាំង ឡាយ ដែលមានចិត្តជ្រះថ្លាក្នុងព្រះមហាសត្វ និងក្នុងពួកឥសី ក៏ទៅកាន់កើត ក្នុងស្ថានសួគ៌ ៦ ជាន់ ។ ព្រហ្មចរិយៈរបស់ព្រះមហាសត្វ ប្រព្រឹត្តទៅ អស់កាលយូរ ។

ទេវធីតា អាស្រ័យនៅត្រង់ស្វេតច្ឆត្រក្នុងកាលនោះ បានមកជាព្រះនាងឧប្បលវណ្ណាក្នុងកាលឥឡូវនេះ សារថីក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរក្នុងកាលឥឡូវនេះ ព្រះមាតាព្រះបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ បរិស័ទទាំងឡាយក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ តេមិយបណ្ឌិតក្នុងកាលនោះ បានមកជាព្រះលោកនាថក្នុងកាលឥឡូវនេះ ។

អធិដ្ឋានបារមីរបស់ព្រះមហាសត្វនោះ ដល់ទីបំផុតក្នុងចរិយានេះ ។ បារមីដ៏សេស ក៏គប្បីពោលចំពោះតាមសមគួរ ។ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពយ៉ាងនេះ គឺការខ្លាចនរក តាំងពីប្រសូតបាន ១ ខែ ការខ្លាចបាប ការវៀរសក្នុងរាជសម្បត្តិ ការអធិដ្ឋានជាមនុស្ស-គជាដើម ដែលមាននេក្ខម្មៈជាហេតុ និងការមិនញាប់ញ័រក្នុងការប្រជុំវិរោធិប្បច្ច័យ ក្នុងអធិដ្ឋាននោះ ៕ល៚

**អដ្ឋកថាមូគជក្ខចរិយា ចប់**

**អធិដ្ឋានបារមី ចប់**

# សុត្តន្តបិដក

## កបិលរាជចរិយាទី ៧

[ ២៧ ] កាលដែលតថាគតកើតជាស្តេចស្វា សម្រេចទីលំនៅជិតច្រាំងនៃស្ទឹងមួយ កាលនោះ តថាគតត្រូវក្រពើបៀតបៀន ហើយមិនបាននូវដំណើរចេញទៅ ។ តថាគតស្ថិតនៅលើខ្នងថ្មណា ដែលតាំងនៅក្នុងស្ទឹង ក៏បានលោតអំពីត្រើយអាយ ទៅកាន់ត្រើយនាយ ហើយទំលើខ្នងថ្មនោះ ដែលមានក្រពើនៅ ជាសត្រូវ ឃើញគួរខ្លាច ។ ក្រពើនោះ និយាយនឹងតថាគតថា អ្នកចូរមកវិញ តថាគតនិយាយតបនឹងក្រពើនោះថា អើ ខ្ញុំនឹងមកវិញ ហើយតថាគតលោតជាន់លើក្បាលក្រពើនោះ ទៅស្ថិតនៅលើត្រើយនាយវិញ ។ តថាគតពោលនូវពាក្យសត្យ មិនពោលពាក្យមុសាវាទដល់ក្រពើនោះ កុសលធម៌ដទៃស្មើនឹងសច្ចៈរបស់តថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។

**កបិលរាជចរិយាទី ៧ ចប់**

# អដ្ឋកថា

## កបិលរាជចរិយា

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកបិរាជចរិយាទី ៧ ដូចតទៅនេះ បទថា **យទា អហំ កបិ អាសិ** សេចក្តីថា ក្នុងកាលតថាគតកើតក្នុងកំណើតពានរ ចម្រើនធំធាត់ហើយ បានជាស្តេចពានរ ដែលមានកម្លាំងដូចដំរីសារ សម្បូរដោយថាមពល មានរាងកាយធំប្រមាណប៉ុនកូនសេះ ។ បទថា **នទីកូលេ ទរីសយេ** សេចក្តីថា តថាគតនៅត្រង់ញកភ្នំមួយ ក្បែរឆ្នេរស្ទឹងមួយកន្លែង ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វមិនបានថែរក្សាហ្វូង ត្រាច់ទៅតែម្នាក់ឯង ។ ក្នុងកណ្តាលស្ទឹងនោះ មានកោះមួយ សម្បូរដោយផ្លែឈើមានខ្នុរ និងស្វាយជាដើមច្រើនយ៉ាង ។ ព្រះពោធិសត្វ ព្រោះសម្បូរដោយកម្លាំង លោតអំពីត្រើយអាយរបស់ស្ទឹងទៅដល់ផ្ទាំងថ្មមួយដុំ ដែលមានត្រង់កណ្តាលកោះ និងស្ទឹង លោតអំពីផ្ទាំងថ្មនោះ ក៏ទៅដល់កោះនោះ ។ ស្តេចពានរទំពាស៊ីផ្លែឈើច្រើនយ៉ាងក្នុងកោះនោះ ពេលល្ងាច ក៏ត្រឡប់ដោយវិធីនោះឯង មកដល់លំនៅរបស់ខ្លួន ស្អែកឡើង ក៏ធ្វើយ៉ាងនោះទៀត សម្រេចការរស់នៅដោយទំនងនេះ ។

ក្នុងកាលនោះ មានក្រពើ ១ មួយអន្ទើដោយក្រពើញី អាស្រ័យនៅក្បែរស្ទឹងនោះ ក្រពើមេរបស់ក្រពើនោះឃើញព្រះពោធិសត្វទៅមកៗ កើតនូវការចាញ់ផ្ទៃ ចង់បរិភោគបេះដូងព្រះពោធិសត្វ ទើបប្រាប់ក្រពើជាប្តីថា ខ្ញុំចាញ់គភ៌ចង់ស៊ីសាច់បេះដូងស្វានោះ ។ ក្រពើពោលថា បាន ហើយក៏ទៅដោយបំណងថា ថ្ងៃនេះ នឹងចាប់ស្តេចស្វានោះ ដែលត្រឡប់អំពីកោះក្នុង

ពេលល្ងាច ទើបដេកលើផ្ទាំងថ្ម ។ ព្រះពោធិសត្វស្វែងរកអាហារពេញមួយថ្ងៃ ក្នុងពេលល្ងាច បានឈរលើកោះនោះឯង សម្លឹងមើលផ្ទាំងថ្ម គិតថា ថ្មនេះ ឥឡូវនេះ ខ្ពស់ជាងមុន នឹងមានហេតុអ្វីហ្ន៎ ព្រោះព្រះពោធិសត្វសង្កេតប្រមាណរបស់ទឹក និងប្រមាណរបស់ផ្ទាំងថ្ម បានយ៉ាងល្អ ដោយហេតុនោះ ទើបព្រះពោធិសត្វត្រិះរិះថា ថ្ងៃនេះ ទឹកស្ទឹងនេះ មិនស្រក ហេតុអ្វីដុំថ្មនេះ បែរជាធំ ប្រហែលជាមានក្រពើដេកចាំចាប់អញក្នុងទីនោះពិត ។

ស្តេចស្វាគិតថា អញនឹងពិសោធក្រពើនោះសិន ទើបឈរយ៉ាងនោះធ្វើជានិយាយនឹងថ្មថា នែថ្ម ទោះហៅយ៉ាងនេះក៏មិនមានចម្លើយ ក៏ហៅទៀតថា នែថ្ម អស់វារៈ ៣ ដង ថ្មក៏មិនឆ្លើយ ។ ព្រះពោធិសត្វក៏ពោលទៀតថា នែថ្ម ហេតុអ្វីថ្ងៃនេះមិនឆ្លើយនឹងខ្ញុំ ក្រពើគិតថា ថ្មនេះ ក្នុងថ្ងៃដទៃៗ ប្រហែលជាឆ្លើយជាមួយស្តេចពានរពិត តែថ្ងៃនេះថ្មមិនឆ្លើយព្រោះអញនៅពីលើ ណ្ហើយចុះ អញនឹងឆ្លើយដល់ស្តេចពានរ ទើបពោលថា មានរឿងអ្វីស្តេចពានរ ។ ព្រះពោធិសត្វសួរថា អ្នកជានរណា ក្រពើឆ្លើយថា ខ្ញុំជាក្រពើ ព្រះពោធិសត្វសួរថា អ្នកមកដេកទីនេះដើម្បីអ្វី ក្រពើឆ្លើយថា ខ្ញុំត្រូវការបេះដូងរបស់អ្នក ព្រះពោធិសត្វគិតថា អញមិនមានផ្លូវដទៃសម្រាប់ទៅ ផ្លូវរបស់អញត្រូវបិទហើយ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតត្រូវក្រពើបៀតបៀន ហើយមិនបានទូវដំណើរចេញទៅ ។
តថាគតស្ថិតនៅលើខ្នងថ្មណា ដែលតាំងនៅក្នុងស្ទឹង ក៏បានលោត
អំពីត្រើយអាយ ទៅកាន់ត្រើយនាយ ហើយទំលើខ្នងថ្មនោះ

ដែលមានក្រពើនៅ ជាសត្រូវ ឃើញគួរខ្លាច ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បីឡិតោ សុសុមារេន** ឲ្យប្រកដក្នុងគាថាថា **យម្ហោកាសេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **យម្ហោកាសេ** បានដល់ ឈរត្រង់ឱកាសដែលបានដល់ផ្ទាំងថ្ម ដែលតាំងនៅកណ្តាលស្ទឹងណា ។ បទថា **ឱរា** បានដល់ ត្រើយអាយ ពោល គឺកោះ ។ បទថា **ចារំ** បានដល់ ត្រើយនាយនៃស្ទឹងដែលជាលំនៅរបស់តថាគត ក្នុងកាលនោះ ។ បទថា **បតាមហំ** បានដល់ តថាគតលោតទៅដល់ ។ បទថា **តត្ថប្ចិ** សេចក្តីថា ក្រពើជាសត្វកាច ជាឃាតក ជាសត្រូវ សម្តែងនូវការគ្រោតគ្រាត ជាសត្វ កាច ឃើញហើយ គួរខ្លាច ក្រពើនោះ នៅលើផ្ទាំងថ្មនោះ ។

លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា អញមិនមានផ្លូវដទៃទៀត ថ្ងៃនេះ អញនឹងកន្ទងបង់ក្រពើនេះ អញនឹងដោះក្រពើឲ្យផុតអំពីបាប ដោយអាការ យ៉ាងនេះផង អញនឹងបានជីវិតផង ទើបមហាសត្វពោលនឹងក្រពើថា នែ សម្លាញ់ ខ្ញុំនឹងលោតលើខ្លួនរបស់អ្នក ក្រពើពោលថា នែស្តេចពានរ ចូរ អ្នកកុំបង្អង់ លោតមកចុះ ។ ព្រះមហាសត្វបានពោលថា ខ្ញុំកំពុងមក តែអ្នក ចូរហាមាត់របស់អ្នក ហើយចាំខ្ញុំពេលដែលខ្ញុំមករកអ្នក ។ ធម្មតាកាលក្រពើ ហាមាត់ ភ្នែកទាំងពីរក៏បិទ ក្រពើនោះ មិនបានកំណត់ហេតុការណ៍នោះ ទើបហាមាត់ ភ្នែករបស់ក្រពើក៏បិទ ក្រពើហាមាត់ដេកមិនបើកភ្នែកឡើយ ។ ព្រះមហាសត្វ ដឹងសេចក្តីពិតរបស់ក្រពើនោះ ទើបលោតអំពីកោះ ជាន់ក្បាល ក្រពើ ហើយលោតអំពីនោះទៅឈរត្រង់ត្រើយនាយ ដូចផ្លេកបន្ទោរ ដូច

ព្រះមានព្រះភាគត្រាស់ថា

ក្រពើនោះ និយាយនឹងតថាគតថា អ្នកចូរមកវិញ តថាគត និយាយតបនឹងក្រពើនោះថា អើ ខ្ញុំនឹងមកវិញ ហើយតថាគត លោតជាន់លើក្បាលក្រពើនោះ ទៅស្ថិតនៅលើត្រើយនាយវិញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អសំសិ** ស្មើគ្នានឹង **អភាសិ** ( ពោល ) ។ បទថា **អហាមេស្សមិ** បានដល់ តថាគតក៏ពោលនឹងក្រពើនោះថា ខ្ញុំនឹងមក ។

ម្យ៉ាងទៀត កោះនោះ គួរជាទីត្រេកអរ ប្រដាប់ដោយជួរនៃដើមឈើមានស្វាយ ព្រីង ខ្នុរជាដើម សមគួរជាទីលំនៅ ។ ព្រះមហាសត្វរក្សាពាក្យសច្ចៈ ព្រោះបានប្តេជ្ញាថា ខ្ញុំនឹងមក ក៏បានធ្វើយ៉ាងនោះថា ខ្ញុំនឹងមកពិតប្រាកដ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតពោលនូវពាក្យសត្យ មិនពោលពាក្យមុសាវាទដល់ក្រពើនោះ ដូច្នេះ ។

ព្រោះរក្សាពាក្យសច្ចៈនេះ បានលះបង់ជីវិតរបស់ខ្លួនធ្វើហើយ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កុសលធម៌ដទៃស្មើនឹងសច្ចៈរបស់តថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ក្រពើឃើញភាពអស្ចារ្យដូច្នោះ គិតថា ស្តេចពានរនេះ ធ្វើនូវការអស្ចារ្យក្រៃលែង ទើបពោលថា ស្តេចពានរដ៏ចម្រើន បុគ្គលប្រកបដោយធម៌ ៤ ក្នុង

លោកនេះ រមែងគ្របសង្កត់សត្រូវបាន ធម៌ទាំងអស់នោះ គង់មាននៅក្នុងខ្លួនរបស់អ្នក ដូច្នេះហើយ ទើបពោលថា

បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្ដីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា បុគ្គលណា បានដល់ បុគ្គលណាម្នាក់ ។ ពាក្យថា ទាំងនេះ ( ឃតេ ) លោកសម្ដែងដល់សេចក្ដីដែលពោលក្នុងកាលឥឡូវនេះដោយប្រចក្ស ។ ពាក្យថា ធម៌ ៤ បានដល់ គុណធម៌ ៤ ប្រការ ។ ពាក្យថា សេចក្ដីទៀងទាត់ បានដល់ វចីសច្ចៈ ដែលលោកពោលថា ខ្ញុំនឹងមកកាន់សម្នាក់របស់អ្នក ហើយមិនកុហក មកខាងតែបាន នេះជាវចីសច្ចៈរបស់អ្នក ។ ពាក្យថា ធម៌ បានដល់ វិចារណប្បញ្ញា ។ បញ្ញាដែលប្រព្រឹត្តទៅថា កាលខ្ញុំធ្វើយ៉ាងនេះ នឹងបានផលយ៉ាងនេះ ឈ្មោះថា វិចារណប្បញ្ញារបស់អ្នក ។ ពាក្យថា ព្យាយាមមិនដាច់ បានដល់ សេចក្ដីព្យាយាមដែលមិនដាច់ សេចក្ដីព្យាយាមនេះក៏មានដល់អ្នក ។ ពាក្យថា ការលះ សេចក្ដីថាការបរិច្ចាគខ្លួន អ្នកលះបង់ខ្លួនមករកខ្ញុំ ខ្ញុំមិនអាចចាប់អ្នកបាន នេះជាកំហុសរបស់ខ្ញុំ ។ ពាក្យថា សត្រូវ បានដល់ បច្ចាមិត្ត ។ ពាក្យថា បុគ្គលនោះរមែងកន្លងបង់ សេចក្ដីថា ធម៌ ៤ យ៉ាងនេះ មានដល់បុគ្គលណា ដូចជាមានដល់អ្នក បុគ្គលនោះ រមែងឈានកន្លង គឺគ្របសង្កត់នូវសត្រូវរបស់ខ្លួនដូចអ្នកកន្លងផុតខ្ញុំក្នុងថ្ងៃនេះ ។

ក្រពើសរសើរព្រះពោធិសត្វយ៉ាងនេះហើយ ក៏ទៅកាន់លំនៅនៃខ្លួន ។ ក្រពើក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ក្រពើញីក្នុងកាលនោះ បានមកជានាងចិញ្ចមាណវិកា ក្នុងកាលឥឡូវនេះ ឯស្តេចពានរក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះពោធិសត្វនោះ ដោយន័យដូចពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពយ៉ាងនេះ គឺការដឹងថា ក្រពើដេកលើថ្ម ដោយសង្កេតប្រមាណរបស់ទឹក និងរបស់ថ្ម ដោយកំណត់ថា ឥឡូវនេះ ថ្មប្រាកដមានសភាពខ្ពស់ ។ ការសម្រេចសេចក្តីនោះ ដោយអាងថា ធ្លាប់ពោលនឹងថ្ម ។ ការដោះក្រពើឲ្យផុតចាកបាបធំ ព្រោះប្រញាប់ធ្វើដោយការជាន់ក្បាលក្រពើ ហើយទៅឈរត្រង់ត្រើយនាយមួយរំពេច ការរក្សាជីវិតរបស់ខ្លួន និងការតាមរក្សាសច្ចវាចា ។ល។

## អដ្ឋកថាកបិរាជចរិយា ចប់

# សុត្តន្តបិដក

## សច្ចសវ្ហយបណ្ឌិតចរិយាទី ៨

[ ២៨ ] មានចរិយាដទៃទៀត កាលដែលតថាគតជាតាបស ឈ្មោះសច្ចៈ តថាគត បានរក្សាសត្វលោកដោយសច្ចៈ ធ្វើមហាជន ឲ្យព្រមព្រៀងគ្នា ។

សច្ចសវ្ហយបណ្ឌិតចរិយាទី ៨ ចប់

# អដ្ឋកថា

## សច្ចសវ្ហយបណ្ឌិតចរិយា

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចសវ្ហយបណ្ឌិតចរិយាទី៨ ដូចតទៅនេះ បទថា **តាបសោ សច្ចសវ្ហយោ** សេចក្ដីថា ក្នុងកាលតថាគតជាតាបសឈ្មោះសច្ចៈ ដែលគេហៅដោយ **សច្ច** សព្ទ ។ បទថា **សច្ចេន លោកំ ចាលេសឹ** សេចក្ដីថា តថាគតរក្សាសត្វលោក គឺពួកសត្វក្នុងទីនោះៗ ក្នុងជម្ពូទ្វីប ចាកបាប និងចាកសេចក្ដីវិនាសច្រើនយ៉ាង ដោយការមិននិយាយកុហករបស់ខ្លួន ។ បទថា **សមគ្គំ ជនមកាសហំ** សេចក្ដីថា តថាគតបានធ្វើឲ្យមហាជនដែលឈ្លោះគ្នា ប្រកែកគ្នា វិវាទគ្នាក្នុងទីនោះៗ ឲ្យសាមគ្គីគ្នា មិនវិវាទគ្នា ត្រេកអរគ្នា ដោយសម្ដែងដល់ទោសក្នុងការឈ្លោះគ្នា ពោលដល់អានិសង្សក្នុងសាមគ្គី ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ក្នុងក្រុងពារាណសី ញាតិទាំងឡាយដាក់ឈ្មោះថា សច្ចៈ ។ ព្រះពោធិសត្វកាលចម្រើនវ័យ បានទៅកាន់នគរតក្កសិលា រៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ មិនយូរប៉ុន្មានក៏សម្រេចសិប្បៈសព្វយ៉ាង អាចារ្យអនុញ្ញាតក៏ត្រឡប់ទៅកាន់ក្រុងពារាណសី ថ្វាយបង្គំមាតាបិតា មាតាបិតាសរសើរ ត្រេកអរ ដើម្បីរក្សាទឹកចិត្តរបស់មាតាបិតា ក៏នៅជាមួយមាតាបិតាអស់ ២-៣ ថ្ងៃ ។ លំដាប់នោះ មាតាបិតាបំណងនឹងរកកិរិយា ដែលសមគួរឲ្យ ទើបប្រគល់សម្បត្តិទាំងអស់ឲ្យ ហើយដឹកនាំព្រះពោធិសត្វនោះឲ្យនៅគ្រប់គ្រងផ្ទះ ។

ព្រះមហាសត្វ មានអធ្យាស្រ័យក្នុងការចេញបួស បំណងនឹងសន្សំនេក្ខម្មបារមីរបស់ខ្លួន ទើបពោលដល់ទោសក្នុងការគ្រប់គ្រងផ្ទះ និងអានិសង្សក្នុងបព្វជ្ជា ដោយប្រការផ្សេងៗ កាលមាតាបិតាមានមុខជោកដោយទឹកភ្នែក ទ្រហោយំ បានលះនូវគំនរសម្បត្តិប្រមាណមិនបានផង យសដ៏ប្រសើរផង វង្សត្រកូលដ៏ធំផង កាត់ចំណងក្នុងផ្ទះ ដូចដំរីធំកាត់ផ្តាច់នូវចំណងដែកចេញហើយ ទៅកាន់ហិមវន្តប្បទេស បួសជាឥសី ចិញ្ចឹមជីវិតដោយឫសឈើ និងផ្លែឈើក្នុងព្រៃ មិនយូរប៉ុន្មាន ក៏ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើត ត្រេកអរក្នុងការលេងឈាន នៅដោយវិហារសមាបត្តិ ។

ថ្ងៃមួយ ព្រះពោធិសត្វសម្លឹងមើលលោកដោយទិព្វចក្ខុ បានឃើញពួកមនុស្សក្នុងជម្ពូទ្វីបទាំងមូលដោយច្រើន ខ្វល់ខ្វាយក្នុងអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម ឈ្លោះគ្នានិងគ្នា មានកាមជានិទាន គឺមានកាមជាហេតុ លុះឃើញហើយ ទើបគិតយ៉ាងនេះថា ការដែលឃើញសត្វទាំងនេះខ្វល់ខ្វាយក្នុងបាប និងឈ្លោះគ្នាហើយ ធ្វើព្រងើយកន្តើយ មិនជាការសមគួរដល់អញឡើយ ព្រោះអញបដិបត្តិមហាសម្ពោធិញ្ញាណ ដោយបំណងថា នឹងចម្លងសត្វទាំងឡាយឲ្យឆ្លងចាកភក់ គឺសង្សារ ហើយឲ្យតាំងនៅលើគោក គឺព្រះនិព្វាន ព្រោះហេតុនោះ ដើម្បីកុំឲ្យខុសបដិជ្ញានោះ ផ្លូវដែលល្អ អាត្មាអញគួរទៅកាន់លំនៅរបស់មនុស្ស ទូន្មានសត្វទាំងនោះឲ្យវៀរចាកបាប និងឲ្យវិវាទរបស់មនុស្សទាំងនោះស្ងប់ ។

ព្រះមហាសត្វកាលត្រិះរិះយ៉ាងនេះហើយ កាលមហាករុណាជាស់តឿន

ហើយ ក៏លះសុខដែលកើតអំពីសមាបត្តិ ដែលមានក្នុងទីនោះៗ ដោយឫទ្ធិ សម្តែងធម៌ដែលសមគួរដល់ចិត្តនៃមនុស្សទាំងនោះ សម្តែងដល់ទោស ក្នុងការអាក់អន់ចិត្តដល់គ្នានិងគ្នា ដែលបានទទួលក្នុងបច្ចុប្បន្ន និងក្នុងភពខាងមុខ ញុំាងសត្វទាំងឡាយដែលឈ្លោះប្រកែកគ្នា ដែលវិវាទគ្នា ឲ្យសាមគ្គីគ្នា ប្រកបប្រយោជន៍ឲ្យដល់គ្នានិងគ្នា ចង្អុលបង្ហាញដល់អំពើគ្រោតគ្រាត មានអាការផ្សេងៗ និងទោសក្នុងបាបឲ្យសត្វទាំងឡាយ វៀរចាកបាបនោះហើយ ញុំាងជនពួកខ្លះ ឲ្យតាំងនៅក្នុងកុសលកម្មបថ ១០ ពួកខ្លះ ឲ្យតាំងនៅក្នុងសីលសំវរៈ ក្នុងការឃុំគ្រងឥន្ទ្រិយ ក្នុងសតិសម្បជញ្ញៈ ក្នុងវិវេក ក្នុងឈាន និងអភិញ្ញាតាមសមគួរ ។ ដូចព្រះមានព្រះភាគត្រាស់ថា

មានចរិយាដទៃទៀត កាលដែលតថាគតជាតាបស ឈ្មោះសច្ចៈ តថាគតបានរក្សាសត្វលោកដោយសច្ចៈ ធ្វើមហាជន ឲ្យព្រមព្រៀងគ្នា ដូច្នេះ ។

ក្នុងចរិយានេះ គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះមហាបុរស ដោយន័យដូចពោលខាងដើមហើយនោះឯង ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពយ៉ាងនោះ ដោយប្រការដូច្នេះ ។៚

## អដ្ឋកថា សច្ចសវ្ហយបណ្ឌិតចរិយា
## ចប់

# សុត្តន្តបិដក

## វដ្ដកាបោតកចរិយាទី ៩

[ ២៩ ] ចរិយាដទៃទៀត កាលដែលតថាគតកើតជាកូនសត្វក្រួច ក្នុងអរញ្ញប្រទេសមួយ ទៀបដែនមគធៈ ជាសត្វតូចដូចជាដុំសាច់ មិនទាន់ដុះស្លាប នៅក្នុងសម្បុក ។ កាលនោះ មាតា ( របស់តថាគត ) នាំយក ( ចំណី ) ដោយចំពុះមកចិញ្ចឹមតថាគត តថាគតរស់នៅ ដោយសារសម្ផស្សរបស់មាតានោះ តថាគតមិនទាន់មានកម្លាំងកាយនៅឡើយ ។ ភ្លើងព្រៃឆេះព្រៃ ក្នុងគិម្ហសម័យរាល់ៗ ឆ្នាំ អណ្ដាតភ្លើង ក៏រាលចូលមកជិតលំនៅនៃតថាគត ។ អណ្ដាតភ្លើងដ៏ធំ កាលធ្វើសំឡេងថា ធុំ ធុំ យ៉ាងនេះ ភ្លើងនោះឆេះរាលចូលមករកតថាគតជាលំដាប់ ។ មាតាបិតាតថាគត ភ័យតក់ស្លុត ព្រោះខ្លាចសម្ទុះភ្លើង ក៏លះបង់ចោលតថាគតក្នុងសម្បុក ហើយដោះខ្លួន ចេញរួចទៅ ។ តថាគតលះបង់នូវជើង និងស្លាប តថាគតមិនមានកម្លាំងកាយ តថាគតជាសត្វមិនមានដំណើរទៅក្នុងទីនោះ កាលនោះ គិតយ៉ាងនេះថា អញភ័យតក់ស្លុតញាប់ញ័រ ស្ទុះទៅរកមាតាបិតាណា បើមាតាបិតាទាំងនោះ លះបង់អញចេញទៅហើយ តើក្នុងថ្ងៃនេះ អញត្រូវធ្វើដូចម្ដេច ។ ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ ( សេចក្ដីស្អាត ) និងសេចក្ដីអាណិត សឹងមានក្នុងលោក ( បើដូច្នោះ ) អញនឹងធ្វើនូវសច្ចកិរិយាដ៏ឧត្ដម ដោយសច្ចៈនោះ ។ តថាគតពិចារណាកម្លាំង

ធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ ( នោះ ) ថា ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនរួច ជើងទាំងឡាយរបស់ខ្ញុំមាន តែដើរមិនបាន មាតាបិតា ( របស់ខ្ញុំចេញ ) បាត់ទៅហើយ ម្នាលភ្លើងព្រៃ អ្នកចូរចៀសចេញទៅ ។ ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីស ( ហើយរលត់ក្នុងទីនោះ ) ដូចជាគប់ភ្លើង ដែលបុគ្គលជ្រលក់ទៅក្នុងទឹក កុសលធម៌ដទៃ ស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។

## វដ្តកបោតកចរិយាទី ៩ ចប់

# អដ្ឋកថា

## វដ្ដកាបោតកចរិយា

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវដ្ដកបោតកចរិយាទី៩ ដូចតទៅនេះ ក្នុងបទថា **មគធេ វដ្ដបោតកោ** ជាដើម មានសេចក្ដីសង្ខេបដូចតទៅ ក្នុងកាលតថាគតកើតក្នុងកំណើតក្រួច ក្នុងព្រៃមួយកន្លែង នាដែនមគធៈ ទម្លាយសម្បកស៊ុតចេញមកមិនយូរ មានខ្លួនទន់ នៅជាដុំសាច់ រោមមិនទាន់ដុះ ជាកូនក្រួច នៅក្នុងសម្បុកនោះឯង ។ បទថា **មុខតុណ្ឌកេនាហរិត្វា** សេចក្ដីថា មាតារបស់តថាគតយកចំពុះរបស់ខ្លួន ពាំចំណីមកចិញ្ចឹមតថាគតសព្វកាល ។ បទថា **តស្សា ផស្សេន ជីវាមិ** សេចក្ដីថា តថាគតមានជីវិតរស់នៅ គឺញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយសម្ផស្សខ្លួនរបស់មេរបស់តថាគតនោះ ដែលឲ្យកម្ដៅដ៏ប្រពៃដល់តថាគតសព្វកាល ដោយការក្រាបដើម្បីឲ្យកម្ដៅ និងដើម្បីឲ្យរឹងប៉ឹង ។ បទថា **នត្ថិ មេ កាយិកំ ពលំ** បានដល់ កម្លាំងដែលអាស្រ័យកាយរបស់តថាគតមិនមាន ព្រោះនៅតូច ។

បទថា **សំវច្ឆរេ** បានដល់ រៀងរាល់ឆ្នាំ ។ បទថា **គិម្ហសមយេ** បានដល់ ក្នុងរដូវក្ដៅ ។ ភ្លើងឆេះព្រៃក្នុងទីនោះ កើតឡើងព្រោះមែកឈើឆាប់សង្កៀតគ្នា ភ្លើងឆេះព្រៃដោយហេតុនោះ ។ បទថា **ឧបគច្ឆតិ អម្ហាកំ** បានដល់ ភ្លើង ឈ្មោះថា **ធាវក** ព្រោះជម្រះទីកន្លែងដែលជាលំនៅរបស់ពួកយើង គឺរបស់តថាគត និងមេបាឲ្យស្អាត ដោយធ្វើទីមិនស្អាតដែលជាទីតាំងរបស់ខ្លួនឲ្យស្អាត ឈ្មោះថា **កណ្ហវត្តនិ** ព្រោះធ្វើកំញមឲ្យមកជាផេះ

ឆេះត្រង់គុម្ពឈើក្នុងព្រៃចូលមកជិតសព្វកាល ។

បទថា **សទ្ទាយន្តោ** បានដល់ ធ្វើសំឡេងផុំផុំក្នុងកាលនោះ ព្រោះចូលមកជិតយ៉ាងនេះ ។ ពាក្យនេះ សម្តែងដល់សំឡេងខ្លាំងរបស់ ភ្លើងព្រៃ ។ បទថា **មហាសិខី** ឈ្មោះថា **មហាសិខី** ព្រោះមានអណ្តាតភ្លើងធំ ដោយអំណាចនៃកំញម ដូចគ្នានឹងកំពូលភ្នំ ។ ភ្លើងឆេះ គឺផុតផងព្រៃនោះ មកតាមលំដាប់ គឺដោយលំដាប់ ចូលមកជិតដល់តថាគត ។ បទថា **អគ្គិវេគភយា** សេចក្តីថា មេបារបស់តថាគតតក់ស្លុតព្រោះខ្លាចភ្លើង ដែលឆេះរាលមកដោយរហ័ស ។ បទថា **តសិតា** សេចក្តីថា តក់ស្លុត ដោយកិតភ័យផ្លូវចិត្ត និងដោយស្រៀវស្រើបផ្លូវកាយ ។ បទថា **មាតាបិតា** បានដល់ មេ និងបា ទាំងឡាយ ។ បទថា **អត្តានំ បរិមោចយុំ** សេចក្តីថា បានធ្វើនូវសួស្តីឲ្យដល់ខ្លួន ដោយទៅក្នុងទីដែលភ្លើងមិនបៀតបៀន ។ ពិតហើយ ក្នុងកាលនោះ ព្រះមហាសត្វមានរាងកាយធំប្រមាណប៉ុនសីដក់ ។ មេ និងបា មិនអាចនាំកូនក្រួចនោះទៅបាន ដោយឧបាយណាមួយឡើយ ព្រោះសេចក្តីស្រឡាញ់ខ្លួនគ្របសង្កត់ ទើបបោលកូនជាទីស្រឡាញ់ ហើយគេចទៅ ។ បទថា **ចាលេ បក្ខេ បជហាមិ** សេចក្តីថា តថាគតគិតនឹងដើរទៅលើផែនដី និងហើរទៅលើអាកាស ទើបឈានជើងទាំងពីរ និងព្យាយាមទទះស្លាបទាំងពីររបស់ខ្លួន ។ បាឋៈថា **បជីហាមិ** ដូច្នេះក៏មាន សេចក្តីថា តថាគតព្យាយាមដើម្បីហើរទៅលើអាកាស អាចារ្យពួកខ្លះពោលថា **បតីហាមិ** ដូច្នេះក៏មាន ។ អត្ថនៃបទនោះ មានសេចក្តីដូច្នេះថា តថាគតព្យាយាមឈានជើង និងទទះស្លាប គឺ

*ព្យាយាមនឹងហើរទៅ ព្រោះហេតុអ្វី ទើបព្យាយាមដូច្នោះ ព្រោះកម្លាំងកាយរបស់តថាគតមិនមាន ។ បទថា* **សោហំ អគតិកោ តត្ថ** *សេចក្ដីថា តថាគតគេចទៅមិនបាន ព្រោះខ្វះខាតជើងទាំងពីរ និងស្លាប មាតា បិតា ក៏មិនបានជាទីពឹង ព្រោះលោកគេចទៅ ។ តថាគតនៅក្នុងព្រៃដែលត្រូវភ្លើងបៀតបៀន ឬនៅក្នុងសម្បុកនោះ ក្នុងកាលនោះ ទើបគិតដោយអាការដែលគប្បីពោលក្នុងឥឡូវនេះ យ៉ាងនេះ ។ ម្យ៉ាងទៀត បទថា* **អហំ** *បទទីពីរ គប្បីឃើញថា ត្រឹមតែជានិបាត ។*

*ឥឡូវនេះ ដើម្បីសម្ដែងដល់អាការដែលទ្រង់គិតក្នុងកាលនោះ ទើបព្រះមានព្រះភាគត្រាស់ព្រះតម្រាស់ថា* **យេសាហំ** *ដូច្នេះជាដើម ។*

*ក្នុងបទទាំងនោះ បទថា* **យេសាហំ ឧបធាវេយ្យំ ភីតោ តសិត-វេធិតោ** *សេចក្ដីថា តថាគតខ្លាចព្រោះមរណភ័យ តក់ស្លុតព្រោះចិត្តខ្លាចចំពោះមរណភ័យនោះ ញាប់ញ័រព្រោះរាងកាយរន្ធត់ ឥឡូវនេះ ត្រូវភ្លើងព្រៃបៀតបៀន សម្គាល់ដូចរណ្ដៅទឹក ទើបរត់ទៅលាក់ខ្លួនក្នុងរវាងស្លាបមេ និងបា ។ មេបារបស់តថាគតទាំងនោះ ក៏បោះបង់តថាគតឲ្យនៅតែម្នាក់ឯងគេចទៅហើយ ។ បទថា* **ការំ មេ អជ្ជ កាតវេ** *សេចក្ដីថា ថ្ងៃនេះ អញគួរធ្វើ គួរបដិបត្តិដូចម្ដេច ។ ព្រះមហាសត្វមិនភ្លេចរបស់ដែលគួរធ្វើ ឈរគិតយ៉ាងនេះថា ក្នុងលោកនេះ គុណរបស់សីលគង់មាន គុណរបស់សច្ចៈគង់មាន ធម្មតាសព្វញ្ញុពុទ្ធទាំងឡាយក្នុងអតីត បំពេញបារមី គង់ត្រង់ពោធិមណ្ឌល ត្រាស់ដឹងហើយ ដល់ព្រមហើយដោយសីល សមាធិ បញ្ញា*

វិមុត្តិ និងវិមុត្តិញាណទស្សនៈ ប្រកបដោយសច្ចៈ មេត្តា ករុណា និងខន្តី បំពេញមេត្តាក្នុងសព្វសត្វ គង់មាន ព្រះធម៌ដែលព្រះសព្វញ្ញុពុទ្ធទាំងនោះចាក់ធ្លុះហើយ ជាគុណដ៏ប្រសើរ ដោយចំណែកមួយ គង់មាន ។ មួយវិញទៀត សច្ចៈយ៉ាងនេះ ក្នុងអាត្មាអញ ក៏គង់មាន ។ សភាវធម៌ណាមួយដែលមានរមែងប្រាកដ ព្រោះហេតុនោះ អញគួររឭកដល់ព្រះពុទ្ធក្នុងអតីត និងគុណធម៌ដែលព្រះពុទ្ធទាំងនោះចាក់ធ្លុះហើយ កាន់យកសភាវធម៌ដែលជាសច្ចៈដែលមាននៅក្នុងខ្លួន ហើយធ្វើសច្ចកិរិយា ឲ្យភ្លើងត្រឡប់ទៅ ហើយធ្វើសួស្តីដល់ខ្លួនឯង និងសត្វដ៏សេសក្នុងទីនេះ ក្នុងថ្ងៃនេះ ។ ព្រះមហាសត្វគិតយ៉ាងនេះហើយ តាំងនៅក្នុងអានុភាពរបស់ខ្លួន បដិបត្តិតាមដែលគិត ដូចព្រះព្រះភាគត្រាស់ថា

ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ ( សេចក្តីស្អាត ) និងសេចក្តីអាណិត សឹងមានក្នុងលោក ( បើដូច្នោះ ) អញនឹងធ្វើនូវសច្ចកិរិយាដ៏ឧត្តម ដោយសច្ចៈនោះ ។ តថាគតពិចារណាកម្លាំងធម៌ ហើយរឭកព្រះជិនស្រី ក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ ( នោះ ) ដូច្នេះ ។

ក្នុងបទនោះ មានសេចក្តីថា ព្រះមហាសត្វរឭកដល់គុណរបស់ព្រះពុទ្ធទាំងឡាយ ដែលបរិនិព្វានហើយក្នុងអតីត ប្រារព្ធសភាវៈរបស់សច្ចៈ ដែលមានក្នុងខ្លួន ហើយពោលគាថាណា ធ្វើសច្ចកិរិយាក្នុងកាលនោះ ដើម្បី

សម្តែងគាថានោះ ទើបពោលគាថាជាដើមថា

ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនរួច ជើងទាំងឡាយ
របស់ខ្ញុំមាន តែដើរមិនបាន មាតាបិតា ( របស់ខ្ញុំ ចេញ )
បាត់ទៅហើយ ម្នាលភ្លើងព្រៃ អ្នកចូរចៀសចេញទៅ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សន្តិ បក្ខា អបតនា** ឈ្មោះថា **អបតនា** ព្រោះស្លាបរបស់ខ្ញុំមាន តែហើរមិនទាន់បាន ព្រោះមិនអាចបោះពួយទៅក្នុងអាកាសដោយស្លាបនោះបាន ។ បទថា **សន្តិ បាទា អវញ្ចនា** ឈ្មោះថា **អវញ្ចនា** ព្រោះជើងរបស់ខ្ញុំមាន តែដើរមិនបាន ព្រោះមិនអាចឈានទៅដោយជើងនោះបាន ។ បទថា **មាតាបិតា ច និក្ខន្តា** សេចក្តីថា មាតាបិតារបស់ខ្ញុំ ដែលគួរនាំខ្ញុំទៅក្នុងទីដទៃ ក៏ហើរទៅហើយ ព្រោះខ្លាចស្លាប់ ។ បទថា **ជាតវេទ** ជាឈ្មោះរបស់ភ្លើង ព្រោះថា ភ្លើងនោះ កើតហើយដឹងបានឯង ប្រាកដដោយអណ្តាតភ្លើង និងផ្សែងហុយឡើង ព្រោះហេតុនោះ ទើបលោកហៅថា **ជាតវេទ ។** បទថា **បដិក្កម** សេចក្តីថា សូមភ្លើងថា ចូរអ្នកទៅ គឺចូរត្រឡប់ទៅ ។

ព្រះមហាសត្វ បានដេកធ្វើសច្ចកិរិយាក្នុងសម្បុកថា បើអញមានស្លាបដែលហើរទៅក្នុងអាកាសមិនបាន ភាពដែលអញមានជើង ភាពដែលអញលើកជើងដើរទៅមិនបាន និងភាពដែលមាតាបិតា បោះបង់អាត្មាអញចោលក្នុងសម្បុក ហើយហើរទៅជាពាក្យពិតសោត នៃភ្លើង ដោយពាក្យសច្ចៈនេះ ចូរអ្នកចៀសចេញទៅអំពីទីនេះ ។ ដំណាលគ្នានឹងសច្ចកិរិយា របស់ព្រះ

មហាសត្វនោះ ភ្លើងបានចៀសចេញទៅ ក្នុងទីប្រមាណ ១៦ករីស កាល ភ្លើងចៀសចេញទៅ ក៏មិនបានឆេះ ត្រឡប់ចូលទៅកាន់ព្រៃ រលត់ក្នុងទីនោះ ដូចគប់ភ្លើងជ្រលក់ទឹក ដូច្នោះ ដូចព្រះមានព្រះភាគត្រាស់ថា

ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះ សន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីស ( ហើយរលត់ក្នុងទី នោះ ) ដូចជាគប់ភ្លើង ដែលបុគ្គលជ្រលក់ទៅក្នុងទឹក ដូច្នេះ ។

សច្ចកិរិយារបស់ព្រះពោធិសត្វនោះ ជាខាងដើម នៃការរឭកដល់ ពុទ្ធគុណ ក្នុងសម័យនោះ ក្នុងកំណើតក្រួច មិនទូទៅដល់អ្នកដទៃ ព្រោះ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កុសលធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ដោយហេតុ នោះឯង ទីនោះ ទើបជាបាដិហារ្យតាំងនៅអស់ ១ កប្ប ព្រោះភ្លើងមិនឆេះ ក្នុង ១ កប្បនេះ ។

ដោយអំណាចសច្ចកិរិយាយ៉ាងនេះ ទើបព្រះមហាសត្វធ្វើនូវសួស្តីដល់ ខ្លួន និងដល់សត្វទាំងឡាយក្នុងទីនោះ កាលអស់អាយុក៏ទៅតាមយថាកម្ម ។

មាតាបិតា ក្នុងកាលនោះ បានមកជាមាតាបិតាក្នុងកាលឥឡូវនេះ ឯ ស្តេចក្រួចក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។ បារមីដ៏សេសរបស់ព្រះពោធិសត្វ គប្បីពោលចំពោះតាមសមគួរ ដោយ ន័យដូចពោលខាងដើមហើយនោះឯង ។

ម្យ៉ាងទៀត កាលភ្លើងឆេះរាលមកគួរខ្លាចយ៉ាងនោះ ព្រះពោធិសត្វទោះបីនៅតែឯងក្នុងវ័យនោះ ក៏គង់មិនខ្លាច គប្បីប្រកាសអានុភាពដែលព្រះមហាសត្វរឭកដល់ធម្មគុណ មានសច្ចៈជាដើម និងពុទ្ធគុណ ហើយធ្វើសត្វទាំងឡាយដែលនៅក្នុងទីនោះ ឲ្យដល់នូវសួស្តីដោយសច្ចកិរិយា ព្រោះអាស្រ័យអានុភាពរបស់ខ្លួននោះឯង ។ល។

## អដ្ឋកថាវដ្តពោតកចរិយា ចប់

# សុត្តន្តបិដក

## មច្ឆរាជចរិយាទី ១០

[ ៣០ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចត្រីនៅក្នុងមហាស្រះ លុះដល់គិម្ហសម័យ ដែលមានកម្តៅព្រះអាទិត្យយ៉ាងខ្លាំង ទឹកក្នុងស្រះក៏រីងហួតអស់ ។ លំដាប់នោះ ក្អែក ត្មាត ខ្វែងក្រហម ខ្វែងខ្មៅ និងខ្វែងធំ ចុះទៅទំ ( លើកក់ ) ស៊ីនូវត្រីទាំងឡាយ ទាំងយប់ ទាំងថ្ងៃ ។ តថាគត ព្រមទាំងពួកញាតិ ត្រូវពួកសត្វមានក្អែកជាដើម បៀតបៀនក្នុងទីនោះហើយ ក៏គិតយ៉ាងនេះថា ញាតិទាំងឡាយ ( របស់អញ ) នឹងរួចចាកទុក្ខដោយឧបាយដូចម្តេចហ្ន៎ ។ តថាគតគិតនូវធម៌ និងអត្ថហើយ បានឃើញសច្ចៈ កាលឃើញសច្ចៈហើយ ស្ថិតនៅក្នុងសច្ចៈនោះ ដោះញាតិឲ្យរួចចាកសេចក្តីវិនាសធំទៅបាន ។ តថាគតរឭកនូវធម៌របស់សប្បុរសទាំងឡាយ ហើយពិចារណានូវបរមត្ថសច្ចៈ ធ្វើនូវសច្ច-កិរិយា ដែលជាធម្មជាតទៀងទាត់ក្នុងលោកថា តថាគតរឭកឃើញនូវខ្លួនក្នុងកាលណា តថាគតបានដល់នូវភាពជាអ្នកដឹងក្តីក្នុងកាលណា ក្នុងកាលនោះ តថាគតមិនដែលក្លែងបៀតបៀន សូម្បីនូវសត្វណាមួយឡើយ ។ ដោយពាក្យសច្ចៈនេះ សូមឲ្យមេឃបង្អុរភ្លៀងចុះ ម្នាលមេឃ ចូរអ្នកបង្អុរភ្លៀងចុះមក ចូរអ្នកញុំាងកំណប់ទ្រព្យរបស់ក្អែកឲ្យវិនាសអស់ទៅ ។ ចូរអ្នកញុំាងពួកក្អែក ឲ្យសោយសោក ចូរអ្នកញុំាងពួកត្រី ឲ្យរួចចាកសោក ។ មេឃក៏បង្អុរ

ភ្លៀងចុះមក ដំណាលនឹងពាក្យសច្ចៈដ៏ប្រសើរ ដែលតថាគតធ្វើហើយ ។ តថាគតធ្វើនូវសច្ចៈដ៏ប្រសើរ មានសភាពយ៉ាងនេះ ឲ្យជាព្យាយាមដ៏ឧត្តម ភ្លៀងក៏ធ្លាក់ចុះមកបំពេញនូវទីទួល ទីទាបមួយរំពេច ។ តថាគតអាស្រ័យកម្លាំងតេជះនៃសច្ចៈ បានញុំាងមហាមេឃឲ្យបង្អុរភ្លៀង គុណធម៌ដទៃស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។

## មច្ឆរាជចរិយាទី ១០ ចប់

# អដ្ឋកថា

## មច្ឆរាជចរិយា

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមច្ឆរាជចរិយាទី ១០ ដូចតទៅ បទថា **យទា ហោមិ មច្ឆរាជា មហាសរេ** សេចក្ដីថា ក្នុងអតីតកាល តថាគតកើតក្នុងកំណើតត្រី ត្រូវគេហែរដោយសន្ដានត្រី ៤ របស់ត្រីទាំងឡាយ ក្នុងស្រះធំមួយកន្លែង ដែលគ្របដណ្ដប់ដោយលតាវល្លិ ដែលជាស្រះបោក្ខរណីក្បែរវត្តជេតពន ក្រុងសាវត្ថី ដែនកោសល ។ កាលនោះ តថាគតជាស្ដេចត្រី ហោមរោមដោយពួកត្រី អាស្រ័យនៅក្នុងទីនោះ ។ បទថា **ឧណ្ហេ** បានដល់ ក្នុងរដូវក្ដៅ គឺក្នុងសម័យដែលក្ដៅ ។ បទថា **សូរិយសន្តាបេ** បានដល់ ព្រោះកម្ដៅអំពីព្រះអាទិត្យ ។ បទថា **សរេ ឧទក ខីយថ** សេចក្ដីថា ទឹកក្នុងស្រះនោះរីងស្ងួត គឺហួតហែងអស់ទៅ ។ ក្នុងដែននោះ សម័យនោះភ្លៀងមិនធ្លាក់ឡើយ សម្ទូងក៏ក្រៀមស្វិត ទឹកក្នុងបឹងជាដើមក៏ខះ ត្រីនិងអណ្ដើក នាំគ្នាចូលទៅអាស្រ័យភក់ ។ ក្នុងស្រះនោះ ត្រីទាំងឡាយ ក៏ចូលទៅពួនក្នុងភក់ លាក់ខ្លួនពួនអាត្មាក្នុងទីនោះៗ ។ បទថា **តតោ** បានដល់ខាងក្រោយអំពីទឹករីងនោះ ។ បទថា **កុលលសេនកា** បានដល់ ត្រដក់ និងក្អែងទាំងឡាយ ។ បទថា **ភក្ខយន្តិ ទិវារត្តឹ មច្ឆេ ឧបនិសីទិយ** សេចក្ដីថា ក្អែក និងបក្សីក្រៅអំពីនោះ ត្រាច់រកស៊ីលើភក់នោះៗ យកចំពុះដួចគ្នានឹងចុងស្ន ចឹកត្រីស៊ី ដែលចូលទៅសម្ងំក្នុងភក់ ទាំងដែលបម្រះនទៀល ។

លំដាប់នោះ ព្រះមហាសត្វឃើញសេចក្ដីវិនាសរបស់ត្រីទាំងឡាយ កើតករុណា គិតថា ក្រៅអំពីអញ មិនមានអ្នកដទៃដែលអាចដោះញាតិទាំងឡាយ

របស់អញឲ្យផុតទុក្ខនេះបាន អញដោះត្រីទាំងនេះអំពីទុក្ខនេះដោយឧបាយដូចម្តេចហ្ន៎ ទើបសម្រេចចិត្តថា បើដូច្នោះ អញគប្បីធ្វើសច្ចកិរិយា អាស្រ័យសច្ចធម៌ ដែលអ្នកស្វែងរកគុណជាំក្នុងកាលមុនប្រព្រឹត្ត និងសន្សំមក និងដែលមាននៅក្នុងខ្លួនរបស់អញ ញ៉ាំងភ្លៀងឲ្យធ្លាក់ និងលះបង់ជីវិតជាទាន ដើម្បីពួកញាតិរបស់អញ ដោយហេតុនោះ ឈ្មោះថា អញញ៉ាំងមហាឧបការៈឲ្យកើតដល់សត្វលោក ដែលអាស្រ័យអាហារចិញ្ចឹមជីវិតទាំងអស់ ដូច្នេះហើយទើបធ្វើសច្ចកិរិយាដើម្បីឲ្យភ្លៀងធ្លាក់ ដូចព្រះមានព្រះភាគត្រាស់ថា

តថាគត ព្រមទាំងពួកញាតិ ត្រូវពួកសត្វ មានក្អែកជាដើម បៀតបៀនក្នុងទីនោះហើយ ក៏គិតយ៉ាងនេះថា ញាតិទាំងឡាយ ( របស់អញ ) នឹងរួចចាកទុក្ខដោយឧបាយដូចម្តេចហ្ន៎ ។ តថាគតគិតនូវធម៌ និងអត្ថហើយ បានឃើញសច្ចៈ កាលឃើញសច្ចៈហើយ ស្ថិតនៅក្នុងសច្ចៈនោះ ដោះញាតិឲ្យរួចចាកសេចក្តីវិនាសធំទៅបាន ។ តថាគតរឭកនូវធម៌របស់សប្បុរសទាំងឡាយ ហើយពិចារណានូវបរមត្ថសច្ចៈ ធ្វើនូវសច្ចកិរិយា ដែលជាធម្មជាតទៀងទាត់ក្នុងលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សហ ញាតីហិ បីឡិតោ** សេចក្តីថា តថាគត និងញាតិរបស់តថាគត ត្រូវបៀតបៀនដោយទឹករីងនោះ ។ ម្យ៉ាងទៀត បទថា **សហ** ត្រឹមតែជានិបាត គឺញាតិទាំងឡាយដែលមានទុក្ខជាហេតុ ត្រូវបៀតបៀនដោយសេចក្តីវិនាសនោះ ព្រោះមានមហាករុណា

ទើបគិតដោះ អធិប្បាយថា ពួកញាតិបានទទួលទុក្ខធ្ងន់ ។ បទថា **ធម្មត្ថំ** សេចក្តីថា ប្រយោជន៍ដែលជាធម៌ ឬមានមិនប្រាសចាកធម៌ បានដល់អ្វី បានដល់ សច្ចៈ ។ បទថា **អនុស្សរមស្សយំ** បានដល់ បានឃើញទីពឹង របស់តថាគត និងរបស់ញាតិទាំងឡាយ ។ បទថា **អតិក្កយំ** បានដល់ មហាវិនាស ។

បទថា **សទ្ធម្មំ** សេចក្តីថា ព្រកដល់ធម៌ គឺការមិនបៀតបៀនសត្វ សូម្បីតែមួយ របស់សប្បុរស គឺបុគ្គលល្អទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទថា **បរមត្ថំ វិចិន្តយំ** បានដល់ តថាគតគិតដល់សច្ចៈ ដែលជាប្រយោជន៍ក្រៃលែងនោះ ដែលមានសភាពមិនវិបរិត ។ បទថា **យំ លោកេ ធុវសស្សតំ** គប្បីជ្រាបការភ្ជាប់សេចក្តីថា ការមិនបៀតបៀនសត្វសូម្បីតែមួយរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធ អស់កាលណា តថាគតបានគិតដល់ការមិនបៀតបៀនសត្វដែលស្ថិតស្ថេរ ទៀតទាត់ដោយសេចក្តីពិត អស់កាលទាំងពួងនោះ បានធ្វើសច្ចកិរិយា ។

ឥឡូវនេះ ព្រះមហាសត្វដែលមានរាងកាយ ដូចគ្នានឹងដុំនៃខ្លឹមឈើអញ្ជន បំណងនឹងទទួលយកធម៌នោះ ដែលមាននៅក្នុងខ្លួន ហើយប្រកបវាចាដែលជាសច្ចៈ ទើបកាយកក់ដែលមានពណ៌ខ្មៅ ឲ្យបែកជាពីរ បើកភ្នែកទាំងពីរដែលដូចគ្នានឹងកែវទទឹមដែលគេច្នៃហើយ សម្លឹងមើលទៅអាកាស ពោលគាថាដូច្នេះថា

តថាគតរឭកឃើញនូវខ្លួន ក្នុងកាលណា តថាគតបានដល់នូវភាព ជាអ្នកដឹងក្តី ក្នុងកាលណា ក្នុងកាលនោះ តថាគតមិនដែលក្លែងបៀតបៀន សូម្បីនូវសត្វណាមួយឡើយ ។ ដោយពាក្យសច្ចៈនេះ សូមឲ្យមេឃបង្អុរភ្លៀងចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យតោ សរាមិ អត្តានំ** សេចក្តីថា តាំងអំពីខ្ញុំរឭក គឺព្យាយាមរឭកខ្លួនដែលបានដល់អត្តភាព ។ បទថា **យតោ បត្តោស្មិ វិញ្ញុតំ** សេចក្តីថា តាំងអំពីខ្ញុំដឹងភាពដែលវិញ្ញូជនដឹងហើយ ក្នុងវត្ថុដែលគួរធ្វើនោះៗ ឈ្មោះថា ដឹងនូវភាពដែលវិញ្ញូជនដឹងហើយ ព្រោះអាចរឭកដល់កាយកម្ម វចីកម្មរបស់ខ្ញុំអំពីនេះទៅបានដោយការងើយឡើងទៅខាងលើ ក្នុងរវាងនេះ សូម្បីកើតក្នុងទីដែលត្រូវស៊ីសត្វដែលមានជាតិស្មើគ្នា ខ្ញុំក៏មិនធ្លាប់ស៊ីត្រី មានប្រមាណប៉ុនចុងអង្ករ ខ្ញុំមិនដែលក្លែងបៀតបៀនសត្វដទៃឡើយ មិនចាំបាច់ពោលដល់ការសម្លាប់ ។ បទថា **ឯតេន សច្ចវជ្ជេន** ស្តេចត្រីពោលថា ខ្ញុំពោលដល់ការមិនបៀតបៀនសត្វណាមួយ យ៉ាងណា បើការមិនបៀតបៀននោះ ជាការពិត មិនវិបរិត ដោយសច្ចវាចានេះ សូមមេឃញុំាងភ្លៀងឲ្យធ្លាក់ចុះ ចូរដោះពួកញាតិរបស់ខ្ញុំចាកទុក្ខចុះ ហើយហៅបជ្ជុន្នទេវរាជ ដូចបញ្ជូនអ្នកបម្រើរបស់ខ្លួនទៀតដោយគាថាថា

ម្នាលមេឃ ចូរអ្នកបង្អុរភ្លៀងចុះមក ចូរអ្នកញុំាងកំណប់ទ្រព្យរបស់ក្អែកឲ្យវិនាសអស់ទៅ ។ ចូរអ្នកញុំាងពួកក្អែក ឲ្យសោយសោក ចូរអ្នកញុំាងពួកត្រី ឲ្យរួចចាកសោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អភិត្ថនយ បជ្ជុន្ន** សេចក្តីថា មេឃ លោកហៅថា **បជ្ជុន្ន** ។ ស្តេចត្រីនេះ ហៅវស្សវលាហកទេវរាជ ដែលបានឈ្មោះដោយអំណាចនៃមេឃ ។

បទនោះ មានអធិប្បាយដូចតទៅនេះ ធម្មតាភ្លៀង មិនផ្គរ មិនបញ្ចេញផ្លេកបន្ទោរ ទោះបីភ្លៀងក៏មិនស្អាត ព្រោះហេតុនោះ ចូរអ្នកផ្គរ ហើយបញ្ចេញផ្លេកបន្ទោរឲ្យភ្លៀងធ្លាក់ចុះ ។ បទថា **និធឹ កាកស្ស នាសយ** សេចក្តីថា ក្អែកទាំងឡាយ យកចំពុះចឹកត្រីដែលចូលទៅកាន់ភក់ នាំចេញមកស៊ី ព្រោះហេតុនោះ ត្រីទាំងឡាយក្នុងភក់ លោកហៅថា **និធិ** គឺកំណប់របស់ក្អែកទាំងនោះ ។ អ្នកញ៉ាំងភ្លៀងឲ្យធ្លាក់ ធ្វើទឹកឲ្យលិចកំណប់របស់ក្អែកទាំងនោះ បិទបាំងដោយទឹក ហើយធ្វើកំណប់របស់ក្អែកទាំងនោះឲ្យវិនាសទៅ ។ បទថា **កាកំ សោកាយ រន្ធេហិ** គឺចូរអ្នកញ៉ាំងក្អែកឲ្យក្តៅក្រហាយដោយសេចក្តីសោក សេចក្តីថា ហ្វូងក្អែកកាលមិនបានត្រីក្នុងស្រះធំនេះ ដែលមានទឹកពេញនឹងសុបសៅ អ្នកញ៉ាំងភក់នេះឲ្យពេញ ញ៉ាំងហ្វូងក្អែកនោះ ឲ្យក្តៅក្រហាយដោយសេចក្តីសោក ចូរអ្នកញ៉ាំងភ្លៀងឲ្យធ្លាក់ ដើម្បីឲ្យក្អែកសុបសៅ អធិប្បាយថា ចូរអ្នកធ្វើដោយអាការដែលហ្វូងក្អែក ដល់នូវសេចក្តីសោក ដែលមានលក្ខណៈក្រៀមក្រំខាងក្នុង ។ បទថា **មច្ឆេ សោកា បមោចយ** សេចក្តីថា ចូរអ្នកដោះហ្វូងត្រីទាំងអស់ ដែលជាញាតិរបស់ខ្ញុំ ឲ្យផុតចាកសេចក្តីសោកសៅ គឺការស្លាប់នេះចុះ ។ អាចារ្យពួកខ្លះពោលក្នុងជាតកថា ចូរអ្នកដោះខ្ញុំអំពីសេចក្តីសោក ។ ច អក្ខរៈ ក្នុងបទនោះ ជា **សម្បិណ្ឌនត្ថ**

សេចក្តីថា ចូរអ្នកដោះសត្វទាំងពួង គឺខ្ញុំ និងញាតិរបស់ខ្ញុំ ឲ្យផុតចាកសេចក្តីសោក គឺការស្លាប់ចុះ ។ ពិតហើយ ត្រីទាំងឡាយមានសេចក្តីសោក ព្រោះការស្លាប់យ៉ាងធំកន្លងថា គប្បីដល់នូវភាពជាអាហាររបស់សត្រូវ ព្រោះមិនមានទឹក គប្បីជ្រាបថាសេចក្តីសោកកើតឡើងដល់មហាសត្វ ដែលពោរពេញដោយសេចក្តីករុណា ព្រោះអាស្រ័យការវិនាសអន្តរាយរបស់ត្រីទាំងនោះដោយករុណាធំ ។

ព្រះពោធិសត្វហៅបជ្ជុន្នទេវបុត្រ ដូចបញ្ជាអ្នកបម្រើរបស់ខ្លួន ឲ្យភ្លៀងធំធ្លាក់ពេញដែនកោសល ។ ដោយតេជះនៃសីលរបស់ព្រះមហាសត្វ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជ សម្តែងអាការក្តៅគ្រប់កាល ដោយសច្ចកិរិយានោះឯង ។ សក្កទេវរាជទ្រង់អាវជ្ជនៈថា មានរឿងអ្វីហ្ន៎ កាលទ្រង់ជ្រាបហេតុនោះហើយ ទើបត្រាស់ឲ្យហៅវស្សវលាហកទេវរាជមក មានទេវបញ្ជាថា នែបា ស្តេចត្រីដែលជាមហាបុរសប្រាថ្នា ឲ្យភ្លៀងធ្លាក់ ព្រោះសេចក្តីសោក គឺការស្លាប់របស់ញាតិទាំងឡាយ ចូរអ្នកធ្វើពពកឲ្យជាដុំតែមួយ ហើយឲ្យភ្លៀងធ្លាក់ពេញដែនកោសលចុះ ។ វស្សវលាហកទេវរាជទទួលទេវបញ្ជាហើយ ស្លៀកវលាហកៈមួយដុំ ដណ្តប់វលាហកៈមួយដុំ ច្រៀងចម្រៀងភ្លៀង បែរមុខទៅកាន់ទ្វីបលោកទិសខាងកើត តាមផ្លូវទិសខាងកើត ពពកមួយដុំប្រមាណប៉ុនលានស្រូវ បានតាំងឡើងមួយរយជាន់ មួយពាន់ជាន់ ផ្គរ និងផ្លេកបន្ទោរ ហើយធ្លាក់ចុះមក ដូចគេផ្កាប់ក្អមទឹក ភ្លៀងធំពេញដែនកោសលទាំងមូល ភ្លៀងធ្លាក់ចុះមិនដាច់ខ្សែ មួយសន្ទុះប៉ុណ្ណោះ ស្រះធំ

នោះក៏ពេញ ត្រីទាំងឡាយក៏ផុតចាកមរណភ័យ ក្អែកទាំងឡាយក៏អស់ទីពឹង មិនចំពោះតែត្រីប៉ុណ្ណោះទេ សូម្បីមនុស្សទាំងឡាយ ក៏ញុំាងសម្ទួនទាំងឡាយឲ្យដុះដាល សត្វជើងពីរជាដើម ដែលអាស្រ័យទឹកភ្លៀងចិញ្ចឹមជីវិត ក៏ផុតចាកទុក្ខកាយ និងទុក្ខចិត្ត ដូចព្រះមានព្រះភាគត្រាស់ថា

មេឃក៏បង្អុរភ្លៀងចុះមក ដំណាលនឹងពាក្យសច្ចៈដ៏ប្រសើរ ដែលតថាគតធ្វើហើយ ។ តថាគតធ្វើនូវសច្ចៈដ៏ប្រសើរ មានសភាពយ៉ាងនេះ ឲ្យជាព្យាយាមដ៏ឧត្តម ភ្លៀងក៏ធ្លាក់ចុះមកបំពេញនូវទីទួល ទីទាបមួយរំពេច ។ តថាគតអាស្រ័យកម្លាំងតេជៈនៃសច្ចៈបានញុំាងមហាមេឃឲ្យបង្អុរភ្លៀង គុណធម៌ដទៃស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **១ឈោង អភិវស្សថ** សេចក្តីថា មិនយឺតយូរ ភ្លៀងក៏ធ្លាក់ដោយខណៈដែលធ្វើសច្ចកិរិយានោះឯង ។ បទថា **កត្វា វីរយ-មុត្តមំ** សេចក្តីថា កាលភ្លៀងមិនធ្លាក់ តថាគតក៏មិនខ្ជិលប្រអូស គិតថា គួរធ្វើដូចម្តេច ហើយធ្វើសេចក្តីព្យាយាមដ៏ឧត្តម ញុំាងប្រយោជន៍ និងសេចក្តីសុខ ឲ្យសម្រេចដល់ពួកសត្វទាំងឡាយ ដោយការបំពេញញាតត្ថចរិយា ។ បទថា **សច្ចតេជពលស្សិតោ** សេចកីថា អាស្រ័យកម្លាំងអានុភាពសច្ចៈរបស់តថាគត ញុំាងភ្លៀងធំឲ្យធ្លាក់ក្នុងកាលនោះ ព្រោះហេតុការណ៍យ៉ាងនោះដូច្នោះ ទើបព្រះធម្មរាជា ទ្រង់សម្តែងដល់ភាពដែលសច្ចបារមីរបស់ព្រះអង្គមិនទូទៅដល់អ្នកដទៃ កាលជាស្តេចត្រីធំថា គុណធម៌ដទៃ ស្មើនឹងសច្ចៈនៃ

តថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ព្រះមហាសត្វ មានចិត្តដែលមហាករុណាដាស់តឿនហើយយ៉ាងនេះ ទើបដោះមហាជនចាកមរណទុក្ខ ដោយញុំាងភ្លៀងធំឲ្យធ្លាក់ពេញដែន កាលអស់អាយុ ក៏ទៅតាមយថាកម្ម ។

បជ្ជុន្នទេវរាជ ក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ ហ្វូងត្រី ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ស្ដេចត្រី ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះមហាសត្វនោះ ដោយន័យដូចបានពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពយ៉ាងនេះ គឺការកើតក្នុងកំណើតត្រី ក្នុងទីដែលស៊ីសត្វ មានជាតិស្មើជាមួយខ្លួនជាអាហារ តែមិនស៊ីសត្វណាមួយ ដូចជាត្រីជាដើម សូម្បីប៉ុនចុងអង្ករ កុំថាតែស៊ីឡើយ សត្វសូម្បីតែមួយក៏មិនធ្លាប់បៀតបៀន ការញុំាងភ្លៀងឲ្យធ្លាក់ដោយធ្វើសច្ចៈយ៉ាងនោះ កាលទឹករីង ដោយសេចក្ដីក្លាហាន មិនគិតដល់ទុក្ខដែលខ្លួនបានទទួល ដោយការត្បុលចូលទៅក្នុងភក់ កាលពួកញាតិអត់ធន់មិនបាន ទើបធ្វើទុក្ខនោះទុកក្នុងចិត្ត ជួយស្រោចស្រង់គ្រប់វិធី និងកិច្ចបដិបត្តិដោយប្រការនោះ ។៚

## អដ្ឋកថាមច្ឆរាជចរិយា ចប់

# សុត្តន្តបិដក

## កណ្ហទីបាយនចរិយាទី ១១

[ ៣១ ] មានចរិយាដទៃទៀត កាលតថាគតជាឥសី ឈ្មោះកណ្ហទីបាយនៈ អផ្សុកហើយ នៅតែប្រព្រឹត្តព្រហ្មចរិយៈអស់ ៥០ ឆ្នាំប្លាយ ។ អ្នកណាមួយ មិនដឹងនូវសេចក្តីអផ្សុកក្នុងចិត្ត របស់តថាគតទុំះទេ ទាំងតថាគតសោត ក៏មិនប្រាប់នូវសេចក្តីមិនត្រេកអរ និងសេចក្តីត្រេកអរ ក្នុងចិត្តដល់អ្នកណាមួយឡើយ ។ មហាឥសីឈ្មោះមណ្ឌព្យៈ អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា ជាសម្លាញ់របស់តថាគត ប្រកបដោយបុព្វកម្ម ហើយបាននូវការឡើងកាន់ដែកស្រួច ។ តថាគតថែទាំមណ្ឌព្យតាបសនោះ រហូតបានដល់នូវភាពជាបុគ្គលជារោគហើយ លាមកកាន់អាស្រមនៃខ្លួន របស់តថាគតវិញ ។ ព្រាហ្មណ៍ជាសម្លាញ់ នាំប្រពន្ធ និងកូនមក ជនទាំង ៣ នាក់ជួបជុំគ្នា ចូលទៅកាន់ទីដែលភ្ញៀវមកហើយ ។ តថាគតអង្គុយក្នុងអាស្រមរបស់ខ្លួន សំណេះសំណាលជាមួយជនទាំងនោះ ឯទារកបោះកូនឃ្លីលេង បានញ៉ាំងអាសិរពិសឲ្យខឹង ។ លំដាប់នោះ កុមារនោះ ស្វែងរកផ្លូវដែលកូនឃ្លីនោះរមៀល ក៏យកដៃស្ទាបត្រូវក្បាលអាសិរពិស ។ ឯពស់ក៏ខឹងនឹងការស្ទាបត្រូវនៃទារកនោះ អាស្រ័យកម្លាំងនៃពិសកម្រើក ក៏ចឹកទារកក្នុងខណៈនោះ ដោយសេចក្តីក្រោធយ៉ាងខ្លាំង ។ ទារកដែលត្រូវពស់ចឹកហើយ ក៏ដួលលើផែនដីដោយពិសដ៏ខ្លាំងមួយរំពេច ព្រោះហេតុនោះ បានជាតថាគតមាន

ទុក្ខ ទុក្ខនោះ ផ្សាយមកដល់តថាគត ។ តថាគតលួងលោមជន ទាំងនោះ ដែលដល់នូវសេចក្ដីទុក្ខ មានសរ គឺសេចក្ដីសោក បាន ធ្វើសច្ចកិរិយាដ៏ថ្លៃថ្លាប្រសើរ ឧត្ដមជាដំបូងថា

តថាគតមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្ម- ចរិយៈ អស់ ៧ ថ្ងៃ លំដាប់តទៅ តថាគតប្រព្រឹត្តព្រហ្មចរិយៈ ណា អស់ ៥០ ឆ្នាំប្លាយ ។ តថាគតប្រព្រឹត្តព្រហ្មចរិយៈនោះ ទាំងអផ្សុក ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន ( ដល់ យញ្ញទត្តកុមារ ) ពិស ចូរសាបសូន្យទៅ យញ្ញទត្តកុមារ ចូរ រស់ឡើង ។

យញ្ញទត្តមាណព ដែលញាប់ញ័រដោយកម្លាំងនៃពិស មិនដឹងខ្លួន សោះ ស្រាប់តែក្រោកឡើងរួច ទាំងជាបុគ្គលសះស្បើយរោគ ដំណាលនឹងពាក្យសច្ចៈ ដែលតថាគតធ្វើហើយ គុណធម៌ដទៃស្មើ នឹងសច្ចៈនៃតថាគតពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។

**កណ្ហទីបាយនចរិយាទី ១១ ចប់**

# អដ្ឋកថា

## កណ្ហទីបាយនចរិយា

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកណ្ហទីបាយនចរិយាទី ១១ ដូចតទៅនេះ បទថា **កណ្ហទីបាយនោ ឥសិ** បានដល់ តាបសមានឈ្មោះយ៉ាងនោះ បានឮថា ព្រះពោធិសត្វក្នុងកាលនោះ ឈ្មោះថា ទីបាយនៈ ចូលទៅរកតាបសមណ្ឌព្យៈ ដែលជាសម្លាញ់របស់ខ្លួន ដែលត្រូវដោតដោយឈើអណ្ដោតមិនបោះបង់តាបសនោះ ដោយសីលគុណរបស់តាបស បានឈរផ្អែកឈើអណ្ដោតអស់ ៣ យាម ទើបប្រាកដឈ្មោះថា កណ្ហទីបាយនៈ ព្រោះមានរាងកាយពណ៌ខ្មៅ ដោយតំណក់ឈាមដែលហូរចេញអំពីរាងកាយរបស់តាបសនោះ ស្រក់មកត្រូវហើយស្ងួត ។ បទថា **បរោបញ្ញាសវស្សានិ** គឺក្រៃលែងជាង ៥០ ឆ្នាំ ។ បទថា **អនភិរតោ ចរឹ អហំ** បានដល់ ជាង ៥០ ឆ្នាំ ។ ពាក្យនោះជាទុតិយាវិភត្តិ ចុះក្នុងអច្ចន្តសំយោគ ។ បទថា **អនភិរតោ ចរឹ អហំ** សេចក្ដីថា តថាគតនៅប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រេកអរក្នុងសេនាសនៈស្ងាត់ និងក្នុងធម៌ដែលជាអធិកុសល កាលបួសហើយ ព្រះមហាសត្វត្រេកអរ ប្រព្រឹត្តព្រហ្មចរិយៈ ៧ ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីនោះ ក៏នៅដោយមិនត្រេកអរ ។

ព្រោះហេតុអ្វី ព្រះមហាបុរសក្នុងអត្តភាពច្រើនសែន មានអធ្យាស្រ័យក្នុងនេក្ខម្មៈ ត្រេកអរក្នុងព្រហ្មចរិយៈ តែក្នុងចរិយានេះ មិនត្រេកអរក្នុងព្រហ្មចរិយៈនោះ ព្រោះកាលញាប់ញ័រនៃភាពជាបុថុជ្ជន សួរថា ព្រោះហេតុ

អ្វី ទើបមិនគ្រប់គ្រងផ្ទះជាថ្មី ព្រោះដំបូង ឃើញទោសក្នុងកាមទាំងឡាយ ដោយមានអធ្យាស្រ័យក្នុងនេក្ខម្ម: ទើបបួស តមក ទើបព្រះមហាបុរសកើតការមិនត្រេកអរ ដោយមិនដាក់ចិត្តដោយយោនិសោមនសិការ ។ ព្រះមហា-បុរស កាលមិនអាចបន្ទោបង់នូវការត្រេកអរនោះបាន តែរង្កៀសដោយពាក្យចំអកថា កណ្ហទីបាយនតាបសនេះ ជឿកម្ម និងផលនៃកម្ម លះសម្បត្តិធំចេញអំពីផ្ទះ លះបង់សម្បត្តិណា ក៏ត្រឡប់ទៅដើម្បីសម្បត្តិនោះវិញ ។ កណ្ហទីបាយនៈនេះ ធ្លុតជ្រុក ត្រឡប់សតិហ្ន៎ និងព្រោះខ្លាចហិរិឱត្តប្ប: របស់ខ្លួនបែកធ្លាយ ទើបមិនត្រឡប់ទៅគ្រប់គ្រងផ្ទះ ម្យ៉ាងទៀត ឈ្មោះថាបុណ្យក្នុងបព្វជ្ជានេះ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម សរសើរហើយនឹងធ្លាប់ប្រព្រឹត្តហើយ ព្រោះហេតុនោះ ព្រះមហាបុរស ទោះមានទឹកភ្នែកដោកមុខ ដោយទុក្ខទោមនស្ស ក៏នៅតែប្រព្រឹត្តព្រហ្មចរិយ: មិនលះបង់ព្រហ្មចរិយ:នោះ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា

បុគ្គលណាចេញ ( ចាកផ្ទះបួស ) ដោយសទ្ធាហើយ ត្រឡប់មក ( កាន់ផ្ទះ ) វិញ បុគ្គលនោះឯង ឈ្មោះថា ជាមនុស្សល្ងីល្ងើ មិននឹងនួន យើងស្អប់ខ្ពើមវាទ:នេះ ( សូម្បី ) ជាអ្នកមិនប្រាថ្នា ( បួស ) ក៏ទ្រាំប្រព្រឹត្តព្រហ្មចារ្យ ដែលវិញ្ញូជនសរសើរផង ជាឋាន:របស់ពួកសប្បុរសផង យើងជាអ្នកធ្វើនូវបុណ្យយ៉ាងនេះដូច្នេះ ។

បទថា **ឆ កោចិ ឯតំ ជានាតិ** សេចក្តីថា បុគ្គលណាមួយ គឺតថាគត

មិនប្រាប់ដល់បុគ្គលណាម្នាក់ដែលជាមនុស្ស រមែងមិនដឹងចិត្តដែលមិនត្រេកអរ របស់តថាគតនោះ គឺចិត្តដែលប្រាសចាកសេចក្តីត្រេកអរ ក្នុងការប្រព្រឹត្ត ព្រហ្មចរិយៈ ព្រោះហេតុអ្វី ព្រោះតថាគតមិនប្រាប់ដល់បុគ្គលណាម្នាក់ គឺ មិនបានពោលដល់បុគ្គលណាម្នាក់ថា ការមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត របស់ខ្ញុំ ហេតុនោះ ទើបបុគ្គលណាម្នាក់ដែលជាមនុស្ស មិនដឹងចិត្តនោះ ។

បទថា **សព្រហ្មចារី** ឈ្មោះថា ព្រហ្មចារី ព្រោះជាអ្នកមានសិក្ខា ស្មើ គ្នាដោយបព្វជ្ជាបែបតាបស ។ បទថា **មណ្ឌព្យោ** បានដល់ មានឈ្មោះយ៉ាងនោះ ។ បទថា **សហាយោ** បានដល់ ជាសម្លាញ់ ជាទីស្រឡាញ់ ព្រោះជា មិត្តកាលនៅជាគ្រហស្ថផង និងកាលជាបព្វជិតផង ។ បទថា **មហាឥសិ** បានដល់ ជាឥសីមានអានុភាពច្រើន ។ បទថា **បុព្វកម្មសមាយុត្តោ សូល-មារោបនំ លភិ** សេចក្តីថា ប្រកបដោយបុព្វកម្មរបស់ខ្លួនដែលបានធ្វើ តាមឱកាស ត្រូវដោតដោយឈើអណ្តោតទាំងរស់ គឺត្រូវដោតដោយឈើ អណ្តោត ។

ក្នុងសេចក្តីនេះ មានរឿងជាលំដាប់ដូចតទៅនេះ ក្នុងអតីតកាល ព្រះ រាជាព្រះនាមកោសម្ពិកៈ គ្រងរាជសម្បត្តិក្នុងក្រុងកោសម្ពី ដែនវង្សៈ ។ ក្នុង កាលនោះ ព្រះពោធិសត្វកើតជាបុត្ររបស់ព្រាហ្មណមហាសាល មានសម្បត្តិ ៨០ កោដិ ក្នុងនិគមមួយកន្លែង ។ ព្រាហ្មណកុមារឈ្មោះមណ្ឌព្យៈ បានជា សម្លាញ់ ជាទីស្រឡាញ់របស់ព្រះពោធិសត្វ ។ តមក កាលមាតាបិតាធ្វើ កាលកិរិយា ជនទាំងពីរឃើញទោសក្នុងកាម ទើបរិច្ចាគមហាទាន លះកាម

កាលញាតិមិត្ត និងបរិវារជនកំពុងយំ បានចេញទៅសាងអាស្រម ក្នុងហិមវន្តប្បទេស ហើយបួសចិញ្ចឹមជីវិត ដោយអាហារដែលជាឫសឈើ និងផ្លែឈើក្នុងព្រៃ ដោយការត្រាច់សូម រស់នៅជាង ៥០ ឆ្នាំ ។ ជនទាំងពីរមិនអាចសង្កត់កាមឆន្ទៈបាន សូម្បីត្រឹមតែឈាន ក៏កើតឡើងមិនបាន ។

តាបសទាំងពីរ ត្រាច់ចារិកទៅកាន់ជនបទដើម្បីអាហារ ដែលមានរសជូរប្រៃដល់ដែនកាសី ។ ក្នុងដែនកាសីនោះ សម្លាញ់ (ម្នាក់ទៀត) កាលនៅជាគ្រហស្ថរបស់ទីបាយនៈ ឈ្មោះថា មណ្ឌព្យៈ អាស្រ័យនៅក្នុងនិគមមួយ ទើបឥសីទាំងពីរចូលទៅរកមណ្ឌព្យៈដែលជាសម្លាញ់នោះ ។ មណ្ឌព្យៈឃើញតាបសទាំងពីរ មានចិត្តត្រេកអរ ក៏ធ្វើបណ្ណសាលា ផ្គត់ផ្គង់ដោយបច្ច័យ ៤ តាបសទាំងពីរនៅក្នុងទីនោះបាន ៣-៤ ឆ្នាំ ក៏លាមណ្ឌព្យៈនោះ ចារិកទៅអាស្រ័យនៅត្រង់ព្រៃខ្មោច ដែលពេញទៅដោយដើមរលួសផ្អុង ក្បែរក្រុងពារាណសី ។ ទីបាយនៈនៅតាមគាប់ចិត្ត ហើយទៅរកមណ្ឌព្យៈជាសម្លាញ់របស់ខ្លួន ក្នុងនិគមនោះទៀត ។ មណ្ឌព្យតាបសនៅក្នុងទីនោះឯង ។

ថ្ងៃមួយ ចោរម្នាក់ ធ្វើចោរកម្មខាងក្នុងនគរ លួចទ្រព្យមានតម្លៃ ហើយគេចទៅ ត្រូវពួកម្ចាស់ផ្ទះភ្ញាក់ឡើង និងពួកមនុស្សអ្នករក្សានគរដេញតាម ក៏ចេញទៅតាមលូទឹក ប្រញាប់ចូលទៅកាន់ព្រៃខ្មោច បោះបង្វេចទ្រព្យត្រង់ទ្វារបណ្ណសាលារបស់តាបស ហើយគេចទៅ ។ ពួកមនុស្សឃើញបង្វេចទ្រព្យ ទើបគំរាមថា នែជដិលអាក្រក់ លោកធ្វើចោរកម្មក្នុងពេលយប់ពេលថ្ងៃត្រាច់ទៅដោយភេទជាតាបស ហើយនាំគ្នាវាយ នាំតាបសនោះទៅ

បង្ហាញដល់ព្រះរាជាៗ មិនបានពិចារណា ត្រាស់បញ្ជាថា ចូរដោតត្រង់ឈើអណ្តាត ។ ពួកមនុស្សនាំតាបសនោះទៅកាន់ព្រៃខ្មោច ដោតដោយដើមគគីរ ។ ឈើអណ្តាតមិនបានចូលទៅកាន់រាងកាយរបស់តាបស បន្ទាប់អំពីនោះ ទើបនាំយកដើមស្តៅមក សូម្បីដើមស្តៅនោះ ក៏មិនបានចូល ទើបនាំយកដែកស្រួចមក ដែកស្រួចក៏មិនចូល តាបសគិតថា ជាកម្មចាស់របស់អញទេដឹងហ្ន៎ តាបសរឭកជាតិបាន ឃើញកម្មចាស់ ដោយហេតុនោះ ។ បានឮថា តាបសនោះ ក្នុងអត្តភាពមុន ជាបុត្ររបស់មេជាង ទៅកាន់ទីដែលបិតាចាំងឈើ ចាប់រុយមួយ យកចម្រៀកដើមរលួសផ្អុងដោតរុយនោះ ដូចដោតដោយឈើអណ្តាត ។ បាបរបស់តាបសបានឱកាសក្នុងពេលនេះ តាបសដឹងថា មិនអាចផុតបាបកម្មនេះបាន ទើបពោលនឹងពួករាជបុរសថា បើពួកអ្នកបំណងនឹងដោតអាត្មាត្រង់ឈើអណ្តាត ចូរពួកអ្នកនាំយកដើមរលួសផ្អុងមកចុះ ពួករាជបុរសបានធ្វើតាមនោះហើយ ទើបដោតតាបសត្រង់ឈើអណ្តាត ឲ្យមនុស្សនៅយាម ហើយចៀសចេញទៅ ។

ក្នុងកាលនោះ កណ្ហទីបាយនៈគិតថា អញមិនបានឃើញសម្លាញ់អស់កាលយូរហើយ ទើបមករកមណ្ឌព្យតាបស ស្តាប់រឿងនោះហើយ ទើបចូលទៅកាន់ទីនោះ ឈរក្នុងចំណែកម្ខាងសួរថា នែសម្លាញ់ តើលោកធ្វើអ្វី កាលតាបសប្រាប់ថា ខ្ញុំមិនធ្វើអ្វីឡើយ កណ្ហទីបាយនៈសួរថា លោកអាចរក្សាការប្រទូស្តក្នុងចិត្តបានដែរឬទេ មណ្ឌព្យតាបសឆ្លើយថា ខ្ញុំមិនមានការប្រទូស្តផ្លូវចិត្តចំពោះរាជបុរស និងព្រះរាជាដែលចាប់ខ្ញុំឡើយ កណ្ហទីបាយនតាបស

ពោលថា បើយ៉ាងនោះ មួប់របស់អ្នកមានសីលដូចលោក ជាមួប់ត្រជាក់សម្រាប់ខ្ញុំ ហើយក៏អង្គុយផ្អែកឈើអណ្តោត ពួករាជបុរសដែលនៅយាម ក៏ក្រាបទូលរឿងនោះដល់ព្រះរាជាៗ ទ្រង់ត្រិះរិះថា យើងមិនបានពិចារណាហើយធ្វើ ទើបប្រញាប់យាងទៅក្នុងទីនោះ ត្រាស់សួរទីបាយនតាបសថា ព្រោះហេតុអ្វី ទើបលោកម្ចាស់អង្គុយផ្អែកឈើអណ្តោត តាបសទូលថា អាត្មាអង្គុយរក្សាតាបសនេះ ព្រះរាជាត្រាស់សួរថា លោកម្ចាស់ជ្រាបកាពដែលតាបសនេះធ្វើហើយឬ ទើបធ្វើយ៉ាងនេះ ទីបាយនតាបសទូលថា វត្ថុដែលធ្វើនោះ មិនបានទទួលការពិចារណា ។ លំដាប់នោះ ទីបាយនតាបសពោលពាក្យជាដើមថា ធម្មតាព្រះរាជា គួរជាអ្នកពិចារណាហើយ សឹមធ្វើ ។

គ្រហស្ថ អ្នកបរិភោគកាម ជាអ្នកខ្ជិលប្រអូស មិនល្អ បព្វជិត
មិនសង្រួម មិនល្អ ព្រះរាជា មិនបានពិចារណាមុនហើយ ធ្វើ
មិនល្អ បណ្ឌិតអ្នកច្រើនក្រោធមិនល្អទេ ដូច្នេះ ។

ហើយសម្តែងធម៌ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ជ្រាបថា មណ្ឌព្យតាបសមិនមានកំហុស ទើបត្រាស់ថា ចូរពួកអ្នកដកឈើអណ្តោតចេញ ពួករាជ-បុរសទាញចេញ តែមិនអាចទាញចេញបាន ។ មណ្ឌព្យៈពោលថា បពិត្រមហារាជ អាត្មាបានទទួលទោសបែបនេះ ព្រោះទោសនៃកម្មដែលធ្វើក្នុងជាតិមុន បុគ្គលណាម្នាក់ ក៏មិនអាចទាញឈើចេញអំពីរាងកាយរបស់អាត្មាបានដែរ បើទ្រង់មានបំណងនឹងឲ្យជីវិតដល់អាត្មា ក៏សូមទ្រង់ឲ្យយករណារអារឈើអណ្តោតត្រឹមស្បែកចុះ ។ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះ ។ ឈើអណ្តោត

បានទៅក្នុងរាងកាយរបស់តាបសនោះឯង តែលោកមិនមានការក្តៅក្រហាយ ។ បានឮថា ក្នុងកាលនោះ មណ្ឌព្យតាបស យកចម្រៀកឈើដ៏តូចដោតក្នុងរុយ ចម្រៀកឈើនោះ នៅក្នុងរាងកាយរបស់រុយនោះឯង រុយមិនស្លាប់ដោយហេតុនោះ តែស្លាប់ដោយអស់អាយុរបស់រុយនោះឯង ព្រោះហេតុនោះទើបមណ្ឌព្យតាបសមិនស្លាប់ ។ ព្រះរាជាទ្រង់ថ្វាយបង្គំតាបសហើយ ទ្រង់សូមខមាទោស ទ្រង់ឲ្យតាបសទាំងពីរនៅក្នុងព្រះរាជឧទ្យាននោះឯង ហើយទ្រង់ទំនុកបម្រុង ។ តាំងអំពីនោះមក តាបសនោះ ក៏មានឈ្មោះថា អាណិមណ្ឌព្យៈ ។ តាបសនោះអាស្រ័យព្រះរាជា នៅក្នុងព្រះរាជឧទ្យាននោះឯង ។ ចំណែកទីបាយនតាបស លាងមុខដំបៅរបស់មណ្ឌព្យតាបស របួតជាសះស្បើយហើយ ទើបទៅកាន់បណ្ណសាលា ដែលមណ្ឌព្យព្រាហ្មណ៍ជាសម្លាញ់របស់ខ្លួនកាលនៅជាគ្រហស្ថធ្វើឲ្យ ដូចព្រះមានព្រះភាគត្រាស់ថា

មហាឥសីឈ្មោះមណ្ឌព្យៈ អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា ជាសម្លាញ់របស់តថាគត ប្រកបដោយបុញ្ញកម្ម ហើយបានទូវការឡើងកាន់ដែកស្រួច ។ តថាគតថែទាំមណ្ឌព្យតាបសនោះ របួតបានដល់នូវភាពជាបុគ្គលជារោគហើយ លាមកកាន់អាស្រមនៃខ្លួនរបស់តថាគតវិញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាបុច្ឆិត្វាន** បានដល់ លាមណ្ឌព្យតាបសដែលជាសម្លាញ់របស់តថាគត ។ បទថា **យំ មយ្ហំ សកមស្សមំ** សេចក្តីថា ចូលទៅកាន់បណ្ណសាលា ដែលជាអាស្រមរបស់តថាគត ដែលមណ្ឌព្យ-

ព្រាហ្មណ៍ ជាសម្លាញ់របស់តថាគត កាលនៅជាគ្រហស្ថធ្វើឲ្យ ។

ពួកព្រាហ្មណ៍ឃើញទីបាយនតាបសនោះ ចូលទៅកាន់បណ្ណសាលា ទើបប្រាប់ដល់សម្លាញ់ ។ សម្លាញ់នោះស្តាប់ហើយត្រេកអរ មួយអន្លើដោយបុត្រ ភរិយា កាន់យកគ្រឿងក្រអូប ផ្កាកម្រង និងស្ករអំពៅជាដើមជាច្រើន ទៅកាន់បណ្ណសាលា ថ្វាយបង្គំទីបាយនតាបស លាងជើង ប្រគេនទឹក អង្គុយស្តាប់រឿងរបស់អាណិមណ្ឌព្យតាបស ។ គ្រានោះ បុត្ររបស់មណ្ឌព្យព្រាហ្មណ៍ឈ្មោះយញ្ញទត្តកុមារ លេងវ្លូត្រង់ខាងចុងទីចង្ក្រម ។ ក្នុងទីនោះ ពស់វែកអាស្រ័យក្នុងដំបូកមួយកន្លែង វ្លូដែលកុមារបង្វិលទៅលើផែនដី បានរមៀលធ្លាក់ទៅលើក្បាលពស់វែកក្នុងរន្ធត្រង់ដំបូក កុមារមិនដឹង ក៏លូកដៃចូលទៅក្នុងរន្ធ ពស់វែកខឹងក្រោធ ទើបចឹកដៃរបស់កុមារនោះ កុមារក៏ដួលក្នុងទីនោះដោយកម្លាំងពិស ។ លំដាប់នោះ មាតាបិតាដឹងថា កុមារត្រូវពស់ចឹក ទើបបីកុមារទៅដាក់ឲ្យដេកទៀបបាតជើងរបស់តាបស ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យថ្នាំ ឬមន្ត ធ្វើបុត្ររបស់ខ្ញុំឲ្យជាសះស្បើយចុះ ទីបាយនតាបសពោលថា អាត្មាមិនចេះថ្នាំ អាត្មាមិនមែនគ្រូ អាត្មាជាអ្នកបួស ។ មាតាបិតារបស់កុមារពោលថា បើដូច្នោះ សូមលោកម្ចាស់ផ្សាយមេត្តាក្នុងកុមារនេះហើយ ធ្វើសច្ចកិរិយាចុះ តាបសពោលថា សាធុ អាត្មានឹងធ្វើសច្ចកិរិយា ទើបដាក់ដៃលើក្បាលរបស់យញ្ញទត្ត ធ្វើសច្ចកិរិយា ដូចព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ជាសម្លាញ់ នាំប្រពន្ធ និងកូនមក ជនទាំង ៣ នាក់

ជួបជុំគ្នា ចូលទៅកាន់ទីដែលភ្ញៀវមកហើយ ។ តថាគតអង្គុយក្នុងអាស្រមរបស់ខ្លួន សំណេះសំណាលជានឹងជនទាំងនោះ ឯទារកបោះកូនឃ្លីលេង បានញ៉ាំងអាសិរពិសឲ្យខឹង ។ លំដាប់នោះ កុមារនោះ ស្វែងរកផ្លូវដែលកូនឃ្លីនោះរមៀល ក៏យកដៃស្ទាបត្រូវក្បាលអាសិរពិស ។ ឯពស់ ក៏ខឹងនឹងការស្ទាបត្រូវនៃទារកនោះ អាស្រ័យកម្លាំងនៃពិសកម្រើក ក៏ចឹកទារកក្នុងខណៈនោះ ដោយសេចក្ដីក្រោធយ៉ាងខ្លាំង ។ ទារកដែលត្រូវពស់ចឹកហើយ ក៏ដួលលើផែនដី ដោយពិសដ៏ខ្លាំងមួយរំពេច ព្រោះហេតុនោះ បានជាតថាគតមានទុក្ខ ទុក្ខនោះ ផ្សាយមកដល់តថាគត ។ តថាគតលួងលោមជនទាំងនោះ ដែលដល់នូវសេចក្ដីទុក្ខ មានសរគឺសេចក្ដីសោក បានធ្វើសច្ចកិរិយាដ៏ថ្លៃថ្លាប្រសើរឧត្តម ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាគតញ្ចុំ ចាហុណាគតំ** បានដល់ ចូលទៅរកព្រមដោយសក្ការៈទទួលភ្ញៀវ ។ បទថា **វដ្ដមនុក្ខិបំ** បានដល់ បោះវូដែលមានឈ្មោះថា វដ្ដៈ ព្រោះវិលក្នុងទីដែលបោះទៅ អធិប្បាយថា លេងវូ ។ បទថា **អាសិវិសមកោបយិ** សេចក្ដីថា កុមារបោះវូទៅលើផែនដី វូចូលទៅក្នុងរន្ធដំបូក ត្រូវក្បាលពស់ដែលនៅក្នុងដំបូកនោះ ធ្វើឲ្យពស់ក្រោធ ។ បទថា **វដ្ដគតំ មគ្គំ អន្វេសន្តោ** បានដល់ ស្វែងរកផ្លូវដែលវូនោះទៅ ។ បទថា **អាសិវិសស្ស ហត្ថេន ឧត្តមង្គំ បរាមសិ** សេចក្ដីថា កុមារយកដៃរបស់ខ្លួនលូកចូលទៅកាន់រន្ធក្នុងដំបូក ត្រូវក្បាលពស់វែក ។ បទថា **វិសពលស្សិតោ**

បានដល់ អាស្រ័យកម្លាំងពិស គឺពស់អាស្រ័យកម្លាំងពិសរបស់ខ្លួន ។ បទថា **អឌំសិ ទារកំ ខណោ** បានដល់ ពស់បានចឹកព្រាហ្មណកុមារនោះ ក្នុងខណៈដែលប៉ះនោះឯង ។ បទថា **សហាឧដ្ឋោ** បានដល់ ដំណាលគ្នានឹងពស់ចឹកនោះឯង ។ បទថា **អាសិវិសេឌ** បានដល់ ពិសដ៏ពន្លឹក ។ បទថា **តេឌ** សេចក្តីថា តថាគតជាអ្នកបានទទួលសេចក្តីទុក្ខ ព្រោះកុមារដួលចុះលើផែនដីដោយកម្លាំងពិស ។ បទថា **មម វាហាសិ តំ ឌុក្ខំ** សេចក្តីថា ទុក្ខរបស់កុមារនិងរបស់មាតាបិតារបស់កុមារពាល់ត្រូវតថាគត គឺសេចក្តីទុក្ខនោះ ធ្វើឲ្យតថាគតកើតនូវករុណា ដូចកើតក្នុងសរីរៈរបស់តថាគត ។ បទថា **ត្យាហំ** សេចក្តីថា តថាគតលួងលោមមាតាបិតារបស់ក្មេងនោះដោយន័យជាដើមថា កុំសោយសោកឡើយ ។ បទថា **លោកសល្លិតេ** បានដល់ មានសរ គឺសេចក្តីសោក ។ បទថា **អគ្គំ** បានដល់ តាំងអំពីនោះ តថាគតបានធ្វើសច្ចកិរិយាដែលប្រសើរបំផុត ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងសច្ចកិរិយាដោយសរុប ទើបត្រាស់គាថាថា

តថាគតមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្មចរិយៈអស់ ៧ ថ្ងៃ លំដាប់តទៅ តថាគតប្រព្រឹត្តព្រហ្មចរិយៈណា អស់ ៥០ ឆ្នាំប្លាយ ។ តថាគត ប្រព្រឹត្តព្រហ្មចរិយៈនោះទាំងអផ្សុក ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ ) ពិស ចូរសាបសូន្យទៅ យញ្ញទត្តកុមារ ចូរ

រស់ឡើង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សត្តាហមេវ** បានដល់ ៧ ថ្ងៃ តាំងអំពីថ្ងៃដែលតថាគតបួស ។ បទថា **បសន្នចិត្តោ** បានដល់ មានចិត្តជ្រះថ្លា ព្រោះជឿកម្ម និងផលនៃកម្ម ។ បទថា **បុញ្ញត្ថិកោ** គឺជាអ្នកត្រូវការបុណ្យ បានដល់ ប្រកបហើយដោយការពេញចិត្តក្នុងធម៌ ។ បទថា **អថាបរំ យំ ចរិតំ** សេចក្តីថា កាលនោះ ការប្រព្រឹត្តព្រហ្មចរិយៈរបស់តថាគតលើស ៧ ថ្ងៃ ។ បទថា **អកាមកោវាហិ** បានដល់ តថាគតមិនប្រាថ្នាបព្វជ្ជាឡើយ ។ បទថា **ឯតេន សច្ចេន សុវត្ថិ ហោតុ** សេចក្តីថា បើកាលដែលតថាគតនៅដោយមិនត្រេកអរអស់ ៥០ ឆ្នាំថ្វាយ មិនមានអ្នកណាដឹង ជាពាក្យសច្ចៈ ដោយសច្ចៈនោះ ចូរសួស្តីមានដល់យញ្ញទត្តកុមារចុះ សូមយញ្ញទត្តកុមារ មានជីវិតចុះ ។

កាលព្រះមហាសត្វ ធ្វើសច្ចកិរិយាយ៉ាងនេះហើយ ពិសក៏ហូរចេញអំពីសរីរៈរបស់យញ្ញទត្ត ចូលកាន់ផែនដី កុមារបើកភ្នែកមើលមាតាបិតា ហើយក្រោកឡើង ហៅម៉ែ ពុក ។ ដូចព្រះមានព្រះភាគត្រាស់ថា

យញ្ញទត្តមាណព ដែលញាប់ញ័រដោយកម្លាំងនៃពិស មិនដឹងខ្លួន
សោះ ស្រាប់តែក្រោកឡើងរួច ទាំងជាបុគ្គលសះស្បើយរោគ
ដំណាលនឹងពាក្យសច្ចៈ ដែលតថាគតធ្វើហើយ ដូច្នេះ ។

គាថានេះមានអត្ថដូចតទៅ ដំណាលគ្នានឹងការធ្វើសច្ចៈរបស់តថាគត បន្ទាប់អំពីនោះ កុមារដែលញាប់ញ័រដោយកម្លាំងពិសក្នុងកាលមុន មិនដឹងខ្លួន

ព្រោះសន្ទប់ បានភ្ញាក់ខ្លួន ព្រោះប្រាសចាកពិស ក្រោកឡើងមួយរំពេច កុមារនោះ បានស្បើយរោគ ព្រោះមិនមានកម្លាំងពិស ។

ព្រះសាស្តា កាលទ្រង់សម្តែងដល់ភាពដែលសច្ចកិរិយារបស់ព្រះអង្គនោះជាបរមត្ថបារមី ទើបត្រាស់ថា គុណធម៌ដទៃស្មើ នឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។ ពាក្យនោះ មានអត្ថដឹងបានងាយហើយ តែក្នុងអដ្ឋកថាជាតកពោលថា ដោយសច្ចកិរិយារបស់ព្រះមហាសត្វ ពិសបានស្រកចុះត្រឹមដោះឡើងទៅលើរបស់កុមារ ហើយហូរទៅ ដោយសច្ចកិរិយារបស់បិតា ពិសបានស្រកចុះដល់ចង្កេះរបស់កុមារ ដោយសច្ចកិរិយារបស់មាតា ពិសបានស្រកអំពីរាងកាយដ៏សេសរបស់កុមារ ហើយហូរទៅ សមដូចព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលខ្លះ ខ្ញុំឃើញភ្ញៀវក្នុងវេលា ដែលមកដល់លំនៅ ក៏មិនត្រេកអរ នឹងឲ្យទានទេ តែខ្ញុំមិនឲ្យពួកសមណព្រាហ្មណ៍ ទោះជាពហុស្សូត បានដឹងថា ខ្ញុំមិនស្រឡាញ់ទេ មួយទៀត ខ្ញុំ ទោះបីមិនប្រាថ្នា ( ក្នុងទាន ) ក៏នៅតែឲ្យ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ ) ពិស ចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមារ រស់ឡើង ។

ម្នាលកូន អាសិរពិសណា មានតេជៈច្រើន បានលូនចេញពីរន្ធមកចឹកអ្នក ក្នុងថ្ងៃនេះ ខ្ញុំ និងបិតាអ្នក មិនមានសេចក្តីប្លែកគ្នាណាមួយ ក្នុងអាសិរពិសនោះទេ ( ព្រោះជាអ្នកមិនស្រឡាញ់

អាសិរពិសដូចគ្នា ) ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ពិស ចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមារ រស់ឡើង ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មកដល់លំនៅ បានដល់ ក្នុងវេលាមកផ្ទះ ដើម្បីនៅ ។ ពាក្យថា ខ្ញុំមិនស្រឡាញ់ទេ សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយ សូម្បីជាពហូសូត ក៏មិនដឹងភាពដែលខ្ញុំមិនស្រឡាញ់ថា ព្រាហ្មណ៍នេះ មិនត្រេកអរក្នុងការឲ្យ មិនត្រេកអរចំពោះពួកយើង ។ លោកសម្តែងថា ព្រោះខ្ញុំសម្លឹងមើលសមណព្រាហ្មណ៍ទាំងនោះ ដោយភ្នែកដែលជាទីស្រឡាញ់ប៉ុណ្ណោះ ។ ពាក្យថា ដោយពាក្យសច្ចៈនេះ សេចក្តីថា ទោះបីខ្ញុំឲ្យ ក៏មិនជឿផល ឲ្យព្រោះការមិនប្រាថ្នារបស់ខ្លួន ។ ម្យ៉ាងទៀត ជនដទៃមិនដឹងភាពដែលខ្ញុំមិនប្រាថ្នា ដោយពាក្យសច្ចៈនេះ ចូរសួស្តីមានចុះ ។ ព្រាហ្មណីហៅបុត្រថា ម្នាលកូន ដោយគាថាក្រៅអំពីនេះ ។ ពាក្យថា មានតេជះច្រើន បានដល់ មានពិសខ្លាំងក្លា ។ ពាក្យថា ពីរន្ធ បានដល់ ពីក្រហែងដី ។ បាលីក៏យ៉ាងនេះដូចគ្នា ។ ពាក្យថា ចេញ បានដល់ ផុសឡើង អធិប្បាយថា ចេញអំពីរន្ធក្នុងជំបូក លោកអធិប្បាយថា នៃបាយញ្ញទត្ត សេចក្តីប្លែកណាមួយ មិនមានដល់មាតា ព្រោះការមិនស្រឡាញ់ក្នុងអាសិរពិសនោះ និងក្នុងបិតារបស់អ្នក ។ តែបុគ្គលណាម្នាក់ ក៏មាតាមិនឲ្យដឹងនូវការមិនទីស្រឡាញ់ឪពុករបស់បានោះ រឿរតែថ្ងៃនេះ បើសេចក្តីនេះជាសេចក្តីពិត ដោយពាក្យសច្ចៈនោះ ចូរសួស្តីមានដល់អ្នកចុះ ។

ព្រះពោធិសត្វកាលកុមារប្រាសចាករោគហើយ ក៏ឲ្យបិតារបស់កុមារនោះតាំងនៅក្នុងការជឿកម្ម និងផលរបស់កម្មថា ឈ្មោះថា អ្នកឲ្យទាន គួរជឿកម្ម និងផលនៃកម្ម ហើយគប្បីឲ្យ ដូច្នេះ ខ្លួនឯងបន្ទោបង់នូវការមិនត្រេកអរ ហើយញ៉ាំងឈាន និងអភិញ្ញាឲ្យកើតឡើង លុះអស់អាយុ ក៏ទៅកើតក្នុងព្រហ្មលោក ។

មណ្ឌព្យព្រាហ្មណ៍ ក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ ភរិយារបស់មណ្ឌព្យព្រាហ្មណ៍ ក្នុងកាលនោះ បានមកជានាងវិសាខា ក្នុងកាលឥឡូវនេះ បុត្រ ក្នុងកាលនោះ បានមកជាព្រះរាហុលត្ថេរ ក្នុងកាលឥឡូវនេះ អាណិមណ្ឌព្យតាបស ក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរ ក្នុងកាលឥឡូវនេះ កណ្ហទីបាយនតាបស ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

ក្នុងចរិយានេះ គប្បីពោលចំពោះដល់សច្ចបារមី និងបារមីដ៏សេសរបស់ព្រះមហាសត្វ ដែលលោកលើកឡើងក្នុងបាលី ដោយន័យដូចពោលហើយខាងដើមនោះឯង ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាព មានការបរិច្ចាគមហាភោគសម្បត្តិរហូតដល់អស់ ដោយប្រការដូច្នេះ ។

**អដ្ឋកថាកណ្ហទីបាយនចរិយា ចប់**

# សុត្តន្តបិដក

## សុតសោមចរិយាទី ១២

[ ៣២ ] មានចរិយាដទៃទៀត កាលដែលតថាគតឈ្មោះ សុតសោម ជាម្ចាស់ផែនដី ត្រូវស្តេចបោរិសាទចាប់តថាគត ក៏បាន នឹកឃើញនូវពាក្យប្ដេជ្ញា ដែលខ្លួនបានធ្វើចំពោះនន្ទព្រាហ្មណ៍ ។ ស្តេចបោរិសាទ ដោតក្សត្រ ១០១ អង្គត្រង់បាតដៃ ហើយញុំាង ស្តេចទាំងនោះឲ្យស្វិតស្រពោនហើយ ចូលទៅនាំយកតថាគត ក្នុង ពេលសម្រេចយញ្ញ ។ ស្តេចបោរិសាទសួរតថាគតថា អ្នកឯងចង់ រួចខ្លួន ( អំពីដៃយើង ) ឬទេ បើអ្នកអាចត្រឡប់មក ( កាន់ សម្នាក់ ) យើងវិញ យើងនឹងព្រមធ្វើតាមសេចក្តីពេញចិត្តរបស់ អ្នក ។ កាលនោះ តថាគតទទួល ( ពាក្យ ) ស្តេចបោរិសាទ នោះហើយ ចូលទៅកាន់បុរីជាទីរីករាយ ប្រគល់រាជ្យ ( ដល់មាតា បិតា ) នឹងបាច់និយាយថ្វីដល់ការត្រឡប់មកនៃតថាគតវិញ ។ តថាគតរឭកនូវធម៌របស់សប្បុរសទាំងឡាយ ដែលព្រះជិនស្រី ទាំងឡាយ ធ្លាប់សេពក្នុងកាលមុន ឲ្យទ្រព្យដល់ព្រាហ្មណ៍ ហើយ ចូលទៅកាន់ស្តេចបោរិសាទ ។ តថាគតមិនមានសេចក្តីសង្ស័យថា ស្តេចបោរិសាទនេះ នឹងសម្លាប់ ឬមិនសម្លាប់នូវអញក្នុងទីនោះ ឡើយ តថាគតរក្សាពាក្យសច្ចៈ ចូលទៅ ( កាន់សម្នាក់ស្តេច បោរិសាទ ) ដើម្បីលះបង់នូវជីវិត គុណធម៌ដទៃ ស្មើនឹងសច្ចៈនៃ តថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ។

# អដ្ឋកថា

## មហាសុតសោមចរិយា

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាសុតសោមចរិយាទី ១២ ដូចតទៅនេះ បទថា **សុតសោមោ មហីបតិ** បានដល់ ជាក្សត្រព្រះនាមថា សុតសោម ។

បានឮថា ក្នុងកាលនោះ ព្រះមហាសត្វកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទកោរព្យៈ ក្នុងនគរឥន្ទបត្ថៈ ដែនកុរុ ។ ព្រះមាតាបិតាថ្វាយព្រះនាមព្រះរាជកុមារថា សុតសោម ព្រោះជាអ្នកត្រេកអរដោយការស្តាប់ និងព្រោះមានសម្បុរល្អដូចព្រះចន្ទ ។ កាលសុតសោមរាជកុមារ ទ្រង់ចម្រើនវ័យ សម្រេចសិប្បៈគ្រប់យ៉ាង មាតាបិតាទ្រង់អភិសេកក្នុងរាជសម្បត្តិ ។ បទថា **គហិតោ ចោរិសាទេន** សេចក្តីថា ត្រូវព្រះរាជាក្រុងពារាណសីព្រះនាមបោរិសាទ ព្រោះទំពាស៊ីពួកមនុស្ស ចាប់ទៅដើម្បីពលីកម្មដល់ទេវតា ។

សេចក្តីនេះ នឹងពោលដោយសង្ខេបដូចតទៅ ព្រះបាទពារាណសីវៀរសាច់ហើយ សោយមិនចូល អ្នកគ្រួកាលមិនបានសាច់ដទៃ ក៏ចម្អិនសាច់មនុស្សថ្វាយ ទ្រង់ជាប់ចិត្តក្នុងរស ទ្រង់ឲ្យសម្លាប់មនុស្ស ហើយសោយសាច់មនុស្ស ទើបមានព្រះនាមថា បោរិសាទ ។ ពួកអ្នកនគរ អ្នកនិគម អ្នកជនបទ មានអមាត្យរាជបរិស័ទជាប្រធាន និងកាឡហត្ថិសេនាបតីរបស់ព្រះអង្គ នាំគ្នាទូលថា បពិត្រទេវៈ បើទ្រង់ត្រូវការរាជសម្បត្តិ សូមទ្រង់វៀរចាកការសោយសាច់មនុស្សចុះ ព្រះរាជាត្រាស់ថា ទោះបីយើងលះបង់រាជសម្បត្តិ ក៏មិនវៀរចាកការបរិភោគសាច់មនុស្ស ទើបត្រូវជនទាំង

នោះនិរទេសចេញចាកដែន ចូលព្រៃ អាស្រ័យត្រង់គល់ជ្រៃមួយដើម ដើម្បីរក្សាមុខដំបៅត្រង់ជើង ព្រោះត្រូវជន្លត់ដង់ ទើបធ្វើការបន់ស្រន់ទេវតាថា ខ្ញុំនឹងយកឈាមបំពង់ករបស់ស្តេច ១០១ ក្នុងជម្ពូទ្វីប ធ្វើពលីកម្ម ។ កាលមុខរបួសសះស្បើយជាប្រក្រតី ព្រោះអត់អាហារអស់ ៧ ថ្ងៃ ក៏សម្គាល់ថាជាអានុភាពរបស់ទេវតា ទើបអញបានទូវសួស្តី គិតថា អញនឹងនាំព្រះរាជាមកដើម្បីធ្វើពលីកម្មដល់ទេវតា ហើយសេពគប់ជាមួយយក្ខដែលធ្លាប់ជាសម្លាញ់ក្នុងអតីតជាតិ ដោយកម្លាំងមន្តដែលយក្ខនោះឲ្យ ទើបមានកម្លាំងខ្លាំង និងរហ័សក្រៃលែង ចាប់ព្រះរាជា ១០០ អង្គមក ក្នុងរយៈកាល ៧ ថ្ងៃប៉ុណ្ណោះ ដោតដៃព្រះរាជាទាំងនោះដោយវល្លិ ព្យួរត្រង់ដើមជ្រៃដែលជាលំនៅរបស់ខ្លួន ត្រៀមធ្វើពលីកម្ម ។

លំដាប់នោះ ទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃនោះ មិនប្រាថ្នាពលីកម្មនោះ គិតថា អញនឹងរកឧបាយឃាត់ស្តេចបោរិសាទនោះ ទើបមកក្នុងរូបជាអ្នកបួស សម្តែងខ្លួនឲ្យឃើញ ស្តេចបោរិសាទដេញតាមអស់ចម្ងាយផ្លូវ ៣ យោជន៍ ហើយទើបសម្តែងរូបទិព្វរបស់ខ្លួនឲ្យប្រាកដ ពោលថា អ្នកនិយាយកុហក អ្នកបន់ថា ខ្ញុំនឹងនាំស្តេចក្នុងសកលជម្ពូទ្វីបមកធ្វើពលីកម្ម ឥឡូវនេះអ្នកនាំព្រះរាជាអន់ៗ តាមដែលរកបានមក បើអ្នកមិននាំព្រះបាទសុតសោមដែលធំក្រៃលែងក្នុងជម្ពូទ្វីបមក យើងមិនត្រូវការពលីកម្មរបស់អ្នកឡើយ ។

ស្តេចបោរិសាទត្រេកអរថា អញបានឃើញទេវតារបស់ខ្លួនហើយ ក៏ពោលថា បពិត្រទេវៈ ទ្រង់កុំវិតក្កឡើយ ខ្ញុំនឹងនាំព្រះបាទសុតសោមមក

ក្នុងថ្ងៃនេះឯង ទើបប្រញាប់ទៅកាន់ឧទ្យានដែលសម្បូរដោយម្រឹគ និងខ្លាដំបង កាលគេមិនទាន់ត្រៀមការរក្សា ក៏ចុះកាន់ស្រះបោក្ខរណី ឈរយកស្លឹកឈូកដាក់លើក្បាល កាលស្ដេចបោរិសាទទៅក្នុងរាជឧទ្យាននោះឯង ពេលទៀបភ្លឺ ពួករាជបុរសរៀបចំការរក្សាអស់ ៣ យោជន៍ ដោយជុំវិញ ។ ព្រះមហាសត្វយាងប្រថាប់លើ-កដីរដែលតាក់តែងហើយ ចេញចាកព្រះនគរមួយអន្លើដោយចតុរង្គសេនាអំពីព្រលឹម ក្នុងកាលនោះ នន្ទព្រាហ្មណ៍មកអំពីតក្កសិលានគរ នាំយកសតារហគាថា ៤ បទ ធ្វើដំណើរមកប្រមាណ ១២០ យោជន៍ ដល់នគរនោះ ឃើញព្រះរាជាយាងចេញតាមទ្វារទិសខាងកើត ទើបលើកដៃទូលថា បពិត្រមហារាជ សូមទ្រង់ចម្រើន ហើយថ្វាយព្រះពរ ។ ព្រះរាជាទ្រង់បញ្ជាដំរីឲ្យចូលទៅរកព្រាហ្មណ៍នោះ ត្រាស់ថា នែព្រាហ្មណ៍អ្នកមកអំពីណា ប្រាថ្នាអ្វី ខ្ញុំគួរឲ្យអ្វីដល់អ្នក ព្រាហ្មណ៍បានឮថា ព្រះរាជាជាអ្នកត្រេកអរក្នុងការស្ដាប់ ទើបក្រាបទូលថា ទូលបង្គំនាំសតារហគាថា ៤ បទ មកដើម្បីសម្ដែងថ្វាយទ្រង់ ព្រះមហាសត្វទ្រង់ត្រេកអរ ត្រាស់ថា យើងទៅកាន់ឧទ្យានងូតទឹក ហើយនឹងមកស្ដាប់ អ្នកកុំទើសទាល់ឡើយ ហើយត្រាស់ថា ចូរពួកអ្នករៀបចំលំនៅក្នុងផ្ទះនោះ និងអាហារ គ្រឿងស្លៀកដណ្ដប់ឲ្យដល់ព្រាហ្មណ៍ ហើយយាងទៅកាន់ព្រះរាជឧទ្យាន ដែលមានការយាមយ៉ាងតឹងរ៉ឹង ទ្រង់ដោះគ្រឿងអាភរណៈដ៏ប្រសើរ ទ្រង់ដាក់ព្រះមស្សុ ទ្រង់កក់ព្រះវរកាយ ទ្រង់ចុះស្រង់ក្នុងស្រះបោក្ខរណី ហើយយាងឡើង ទ្រង់ឈរផ្លាស់សំពត់សាដកដែលសើមដោយទឹក ។

លំដាប់នោះ ពួកអ្នកកាន់គ្រឿងប្រដាប់ និងគ្រឿងក្រអូប ក៏នាំរបស់ទាំងនោះមកថ្វាយព្រះរាជា ស្តេចបោរិសាទគិតថា ក្នុងវេលាតាក់តែងព្រះកាយរបស់ព្រះរាជាហើយ ព្រះរាជានឹងធូរពេក អញចាប់ទាន់នៅស្រោលនេះឯង ទើបបន្លឺសំឡេងគ្រវីដាវ ប្រកាសឈ្មោះថា យើង ! បោរិសាទហើយផុសពីក្នុងទឹក ។ ហត្ថាចារ្យជាដើមបានឮសំឡេងរបស់ស្តេចបោរិសាទនោះ ក៏ធ្លាក់ពីលើដំរីជាដើម ។ ពួកទាហានដែលឈរឆ្ងាយ ក៏រត់ទៅអំពីទីនោះ ទាហានដែលនៅជិត ក៏ធ្លាក់អាវុធពីដៃ ដេកផ្កាប់មុខ ។ ស្តេចបោរិសាទបញ្ជិះព្រះរាជាត្រង់ក លោតឆ្លងកំពែងកម្ពស់ ១៨ ហត្ថ ជាន់លើក្បាលដំរីដូចជាន់លើកំពូលភ្នំ និងជាន់លើខ្នងសេះជាដើម រត់ទៅ រហ័សដូចខ្យល់ជាន់លើចន្ទោលរថឲ្យធ្លាក់ចុះ ដូចបន្និលវូ ដូចញាំញីស្លឹកជ្រៃពណ៌ខៀវ ទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ ដោយសម្ទុះដ៏រហ័ស មិនឃើញនរណាដេញតាម ទើបដើរទៅសន្សឹមៗ តំណក់ទឹកដែលជាប់នឹងព្រះកេសារបស់ព្រះបាទសុតសោមក៏ស្រក់លើខ្លួន ព្រះបាទបោរិសាទសម្គាល់ថា ជាតំណក់ទឹកភ្នែកទើបពោលថា សូម្បីព្រះបាទសុតសោម ក៏គង់ស្រក់ទឹកភ្នែក ព្រោះខ្លាចស្លាប់ ។

ព្រះមហាសត្វត្រាស់ថា យើងមិនសោកដល់សេចក្តីស្លាប់ឡើយ តើយំដូចម្តេចកើត តែយើងសោយសោកថា ធម្មតាការធ្វើតាមសន្យា បដិបទារបស់បណ្ឌិតទាំងឡាយ សេចក្តីនោះមិនទាន់សម្រេច យើងឲ្យមនុស្សធ្វើអាគន្តុកវត្តដល់ព្រាហ្មណ៍ដែលនាំសតារហគាថា ៤ បទ ដែលព្រះទសពលព្រះនាមកស្សបៈ ទ្រង់បន្សល់ ហើយណាត់គ្នាថា ងូតទឹកហើយ យើងនឹង

មកស្តាប់ ចូរអ្នករង់ចាំ ទម្រាំយើងមក ហើយទៅកាន់ឧទ្យាន អ្នកមិនទាន់ឲ្យយើងស្តាប់គាថានោះ ចាប់យើងមក ដូចព្រះមានព្រះភាគត្រាស់ថា

កាលដែលតថាគតឈ្មោះសុតសោម ជាម្ចាស់ផែនដី ត្រូវស្តេចបោរិសាទចាប់ តថាគតក៏បាននឹកឃើញនូវពាក្យប្តេជ្ញា ដែលខ្លួនបានធ្វើចំពោះនន្ទព្រាហ្មណ៍ ។ ស្តេចបោរិសាទដោតក្សត្រ ១០១ អង្គត្រង់បាតដៃ ហើយញ៉ាំងស្តេចទាំងនោះ ឲ្យស្វិតស្រពោន ហើយចូលទៅនាំយកតថាគត ក្នុងពេលសម្រេចយញ្ញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ព្រាហ្មណោ សង្គរំ សរឹ** បានដល់ រឭកដល់ពាក្យប្តេជ្ញា ដែលខ្លួនឲ្យដល់នន្ទព្រាហ្មណ៍ ។ បទថា **អាវុណិត្វា ករត្តលេ** សេចក្តីថា ស្តេចបោរិសាទចោះបាតដៃរបស់ស្តេច ១០១ ដែលទៅក្នុងព្រះរាជឧទ្យានជាដើមនោះៗ ហើយនាំមកដោយកម្លាំងរបស់ខ្លួន ហើយដោតខ្សែ ដើម្បីព្យួរត្រង់ដើមឈើ ។ បទថា **ឯតេសំ បមិលាបេត្វា** សេចក្តីថា ស្តេចបោរិសាទចាប់ក្សត្រទាំង ១០១ នោះ យកព្រះបាទឡើងលើ ព្រះសីសៈចុះក្រោម ប្រហារសីសៈដោយកែងជើង យកខ្សែដោតបាតដៃ ឲ្យបានទទួលសេចក្តីលំបាក ឲ្យស្គាំងស្គម ឲ្យក្តៅក្រហាយ ដោយប្រការទាំងពួង ដោយការព្យួរត្រង់ដើមឈើ និងដោយការបង្អត់អាហារគ្រប់យ៉ាង ។ បទថា **យញ្ញត្ថេ** បានដល់ ដើម្បីធ្វើពលីកម្ម គឺឲ្យកើតផលសម្រេច ។ បទថា **ឧបនយី មមំ** បានដល់ នាំតថាគតទៅដែរ ។

ព្រះមហាសត្វត្រូវនាំទៅយ៉ាងនោះ កាលស្តេចបោរិសាទសួរថា ទ្រង់

ខ្លាចសេចក្តីស្លាប់ឬ ព្រះមហាសត្វត្រាស់ថា យើងមិនខ្លាចស្លាប់ឡើយ តែយើងសោក ដ្បិតថា យើងបានសន្យាជាមួយព្រាហ្មណ៍នោះ មិនទាន់បានដោះពាក្យប្តេជ្ញាឡើយ បើទ្រង់លែងយើង យើងស្តាប់ធម៌នោះ ធ្វើសក្ការៈរបស់អានដល់ព្រាហ្មណ៍នោះហើយ នឹងត្រឡប់មកវិញ ។ ស្តេចបោរិសាទពោលថា ខ្ញុំមិនជឿថា កាលខ្ញុំលែងទ្រង់ទៅហើយ ទ្រង់នឹងត្រឡប់មកកាន់កណ្តាប់ដៃខ្ញុំវិញ ព្រះមហាសត្វពោលថា នែបោរិសាទសម្លាញ់ ទ្រង់ និងយើងជាសម្លាញ់ សិក្សាក្នុងសម្នាក់អាចារ្យតែមួយ ទ្រង់មិនជឿឬថា យើងមិនពោលកុហក សូម្បីព្រោះហេតុនៃជីវិត ទើបព្រះមហាសត្វត្រាស់គាថានេះថា

ខ្ញុំចាប់ដាវ និងលំពែង បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំនឹងធ្វើនូវសម្បថចំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមានបំណុល រក្សានូវសច្ចៈ នឹងត្រឡប់មកវិញ ដូច្នេះ ។

បោរិសាទគិតថា សុតសោមនេះពោលថា យើងសូមស្បថ ក្សត្រមិនគួរធ្វើ ណ្ហើយចុះ សុតសោមទៅហើយមិនត្រឡប់ ក៏មិនរួចផុតអំពីដៃរបស់អញបាន ទើបលែងទៅដោយពោលថា

ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ដែលព្រះអង្គស្ថិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ សូមព្រះអង្គ ជាអ្នករក្សានូវសច្ចៈ ដោះនូវការប្តេជ្ញានោះ នឹងព្រាហ្មណ៍ហើយ ចូរត្រឡប់មកវិញ ដូច្នេះ ។

ព្រះមហាសត្វមានកម្លាំងដូចដំរីសារ សម្បូរដោយថាមពល ទ្រង់ដល់

នគរនោះដោយរហ័ស ដូចព្រះចន្ទផុតចាកមាត់រាហុ ដូច្នោះ ។ សេនារបស់ព្រះអង្គគិតថា ព្រះបាទសុតសោមជាបណ្ឌិត នឹងទូន្មានស្តេចបោរិសាទ រួចឆាប់ត្រឡប់មកដូចដំរីចុះប្រេង ទើបបោះជំរំខាងក្រៅព្រះនគរ ព្រោះក្រែងមានពាក្យនិន្ទាថា ពួកអមាត្យឲ្យព្រះរាជាដល់បោរិសាទ ហើយនាំគ្នាត្រឡប់ កាលឃើញព្រះមហាសត្វយាងមកអំពីចម្ងាយ ទើបក្រោកឡើងទទួល ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈថា បពិត្រមហារាជ ស្តេចបោរិសាទធ្វើទ្រង់ឲ្យលំបាកដែរឬ កាលព្រះមហាសត្វត្រាស់ថា កម្មដែលព្រះមាតា ព្រះបិតារបស់ខ្ញុំធ្វើបានលំបាក ស្តេចបោរិសាទក៏បានធ្វើហើយ ស្តេចបោរិសាទអាក្រក់គ្រោតគ្រាតដល់ម្ល៉ោះ គង់ជឿយើង ហើយដោះលែងយើង ទើបតាក់តែងព្រះរាជាឲ្យប្រថាប់លើ-កដំរី ហែហមចូលព្រះនគរ ។ អ្នកនគរទាំងអស់ឃើញព្រះមហាសត្វហើយ នាំគ្នាត្រេកអរ ។

សូម្បីព្រះមហាសត្វ ព្រោះទ្រង់ធ្ងន់ព្រះហឫទ័យក្នុងធម៌ ទើបមិនចូលគាល់ព្រះមាតាបិតា ចូលទៅកាន់ព្រះដំណាក់ ត្រាស់ហៅព្រាហ្មណ៍ ទ្រង់ធ្វើសក្ការៈ និងការរាប់អានធំដល់ព្រាហ្មណ៍នោះ ព្រោះទ្រង់ធ្ងន់ក្នុងធម៌ ទ្រង់គង់លើអាសនៈទាប ហើយត្រាស់ថា លោកអាចារ្យ ខ្ញុំនឹងស្តាប់សតារហ-គាថា ដែលលោកនាំមកដើម្បីខ្ញុំ ក្នុងកាលដែលព្រះមហាសត្វអារាធនាព្រាហ្មណ៍យកទឹកក្រអូបលាងដៃ ហើយនាំគម្ពីរដែលជាទីពេញចិត្តចេញអំពីថង់ ចាប់ដោយដៃទាំង ២ ទូលថា បពិត្រមហារាជ សូមទ្រង់ស្តាប់ចុះ កាលអានគម្ពីរ ទើបពោលគាថាទាំងឡាយថា

បពិត្រព្រះបាទសុតសោម ការជួបប្រទះដោយសប្បុរសទាំងឡាយ អស់វារៈតែម្ដង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ឯការជួបជុំដោយពួកអសប្បុរសជាច្រើនដង រមែងមិនរក្សានូវបុគ្គលនោះបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកឡើយ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ ( នៃពួកសត្វ ) ក៏រមែងដល់នូវសេចក្ដីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្ដីគ្រាំគ្រាទេ ពួកសប្បុរស រមែងចរចាដោយពួកសប្បុរស ។ អាកាស និងដី ស្ថិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវច្រាំងសមុទ្រថា ឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវធម៌របស់ពួកសប្បុរស និងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត ដូច្នេះ ។

ព្រះមហាសត្វទ្រង់ស្ដាប់ដូច្នោះហើយ មានព្រះហឫទ័យត្រេកអរថា ការមករបស់អញមានផល ទ្រង់ព្រះតម្រិះថា គាថាទាំងនេះ មិនមែនសាវកពោល មិនមែនឥសីពោល មិនមែនកវីពោល មិនមែនទេវតាពោល តែព្រះសព្វញ្ញូនោះឯងពោល តើមានតម្លៃដូចម្ដេចហ្ន៎ ទ្រង់ព្រះតម្រិះថា ទោះអញធ្វើចក្រវាលទាំងមូល រហូតដល់ព្រហ្មលោក ឲ្យពេញដោយរតនៈ ៧ ប្រការ

ហើយឲ្យ ក៏នៅតែជាការមិនសមគួរ តែអញល្មមបូជារាជសម្បត្តិ ក្នុងដែនកុរុ ប្រមាណ ៣០០ យោជន៍ ក្នុងឥន្ទបត្តនគរប្រមាណ ៧ យោជន៍ ដល់ព្រាហ្មណ៍នេះ តែព្រាហ្មណ៍នេះមិនមានបុណ្យដែលអាចគ្រប់គ្រងរាជ-សម្បត្តិបាន សេចក្ដីពិត ភាពជាអ្នកមានអានុភាពតិចប្រាកដដល់ព្រាហ្មណ៍នោះ ដោយទ្រង់មើលលក្ខណៈនៃអវយវៈ ព្រោះហេតុនោះ សូម្បីរាជ-សម្បត្តិដែលឲ្យទៅ ក៏តាំងនៅមិនបានក្នុងព្រាហ្មណ៍នេះ ទើបត្រាស់សួរថា លោកអាចារ្យ លោកសម្ដែងគាថាទាំងនេះដល់ក្សត្រដទៃហើយ តើបានអ្វី ព្រាហ្មណ៍ទូលថា បពិត្រមហារាជ បានមួយគាថា ១០០ កហាបណៈ ដោយហេតុនោះ ទើបហៅថា **សតារហាគាថា។** លំដាប់នោះ ព្រះមហាសត្វត្រាស់ដល់ព្រាហ្មណ៍នោះថា លោកអាចារ្យ លោកមិនដឹងតម្លៃគាថាដែលខ្លួនឯងទ្រទ្រង់ត្រាច់ទៅ ទើបព្រះមហាសត្វត្រាស់ថា

គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ
មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍ លោក
ចូរទទួលយកកហាបណៈ ៤ ពាន់ ជាប្រញាប់ចុះ ដូច្នេះ ។

ព្រះមហាសត្វទ្រង់ឲ្យទ្រព្យ ៤០០០ កហាបណៈ និងយានតូចដែលជាសុខ ១ បញ្ជូនព្រាហ្មណ៍នោះទៅ ដោយសក្ការៈ និងការរាប់អានធំ ថ្វាយបង្គំមាតាបិតាទូលថា ទូលបង្គំបានឲ្យបេដ្ឋាដល់បោរិសាទថា ខ្ញុំបូជាព្រះធម្ម-រតនៈ ដែលព្រាហ្មណ៍នាំមកហើយ នឹងធ្វើសក្ការៈរាប់អានដល់ព្រាហ្មណ៍នោះហើយ នឹងត្រឡប់មក ទើបទូលបង្គំមក ។ វត្ថុដែលគួរធ្វើ គួរបដិបត្តិដល់

ព្រាហ្មណ៍ ក្នុងសេចក្ដីនោះ បានធ្វើស្រេចហើយ ឥឡូវនេះ ទូលបង្គំនឹងទៅរកបោរិសាទ ។ ព្រះមាតាបិតាទ្រង់សំណូមពរថា បាសុតសោម កូននិយាយអ្វីយ៉ាងនេះ យើងនឹងចាប់ចោរដោយចតុរង្គសេនា កូនកុំទៅរកចោរឡើយ ។ ស្រីរបាំ ១៦០០០ នាក់ និងបរិវារជនដ៏សេស ក៏នាំគ្នាខ្សឹកខ្សួលថា បពិត្រទេវៈ ទ្រង់ធ្វើឲ្យពួកខ្ញុំម្ចាស់ឥតទីពឹង ហើយយាងទៅណា ។ កោលាហលកើតឡើងម្ដងទៀតថា បានឮថា ព្រះរាជាយាងទៅរកចោរវិញ ។

ព្រះមហាសត្វត្រាស់ថា ធម្មតាការធ្វើតាមពាក្យសច្ចៈ ដែលបានប្ដេជ្ញាជាបដិបទារបស់សាធុសប្បុរសទាំងឡាយ សូម្បីបោរិសាទនោះ ក៏គង់ជឿខ្ញុំហើយលែងខ្ញុំមក ព្រោះហេតុនោះ ខ្ញុំនឹងទៅ ថ្វាយបង្គំមាតាបិតាហើយទ្រង់ទូន្មានជនដ៏សេស មានស្រីស្នំជាដើម ដែលមានទឹកភ្នែកជោកមុខ យំរៀបរាប់មានប្រការផ្សេងៗ តាមជូនដំណើរព្រះរាជាចេញអំពីព្រះនគរ ទ្រង់យកឈើប្រត់ គូសទទឹងផ្លូវ ដើម្បីឲ្យមហាជននាំគ្នាត្រឡប់ ត្រាស់ថា អ្នកទាំងឡាយកុំបីកន្លងគំនូសរបស់យើង ហើយយាងទៅ ។ មហាជនមិនអាចបំពានព្រះតម្រាស់របស់ព្រះមហាសត្វដែលទ្រទ្រង់នូវតេជះបាន ទើបយំដោយសំឡេងខ្លាំង ហើយនាំគ្នាត្រឡប់ ។ ព្រះពោធិសត្វបានប្រារព្ធស្ដេចបោរិសាទ តាមផ្លូវដែលមកនោះឯង ដូចព្រះមានព្រះភាគត្រាស់ថា

ស្ដេចបោរិសាទ សួរតថាគតថា អ្នកឯងចង់រួចខ្លួន ( អំពីដៃយើង )
ឬទេ បើអ្នកអាចត្រឡប់មក ( កាន់សម្នាក់ ) យើងវិញ យើង
នឹងព្រមធ្វើតាមសេចក្ដីពេញចិត្តរបស់អ្នក ។ កាលនោះ តថាគត

ទទួល ( ពាក្យ ) ស្តេចបោរិសាទនោះហើយ ចូលទៅកាន់បុរីជាទីរីករាយ ប្រគល់រាជ្យ ( ដល់មាតាបិតា ) នឹងបាច់និយាយថ្វីដល់ការត្រឡប់មកនៃតថាគតវិញ ។ តថាគត ព្រោកនូវធម៌របស់សប្បុរសទាំងឡាយ ដែលព្រះជិនស្រីទាំងឡាយធ្លាប់សេព ក្នុងកាលមុន ឲ្យទ្រព្យដល់ព្រាហ្មណ៍ហើយ ចូលទៅកាន់ស្តេចបោរិសាទ ។ តថាគតមិនមានសេចក្តីសង្ស័យថា ស្តេចបោរិសាទនេះនឹងសម្លាប់ ឬមិនសម្លាប់នូវអញ ក្នុងទីនោះឡើយ តថាគតរក្សាពាក្យសច្ចៈ ចូលទៅ ( កាន់សម្នាក់ស្តេចបោរិសាទ ) ដើម្បីលះបង់នូវជីវិត គុណធម៌ដទៃ ស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កឹ ត្វំ ឥច្ឆសិ និសជ្ជ** សេចក្តីថា ទ្រង់ប្រាថ្នានឹងឲ្យផុតអំពីកណ្តាប់ដៃខ្ញុំ ទៅនគររបស់ខ្លួនឬ ទ្រង់ពោលថា ការពោលពាក្យសច្ចៈ ដែលខ្ញុំសន្យាមកយូរហើយ ក្នុងនគរតក្កសិលាជាដើម ព្រោះហេតុនោះ ខ្ញុំនឹងធ្វើតាមចិត្តរបស់ទ្រង់ គឺធ្វើតាមគាប់ចិត្តរបស់ទ្រង់ ។ បទថា **យទិ មេ ត្វំ បុនេហិសិ** សេចក្តីថា បើទ្រង់ត្រឡប់មករកខ្ញុំដោយពិតប្រាកដនោះ ។ បទថា **បណ្ហោ អាគមនំ មម** សេចក្តីថា នឹងពោលទៅថ្វីដល់ការមករបស់តថាគតៗ អះអាងការមករបស់តថាគត ដល់ស្តេចបោរិសាទនោះហើយធ្វើសន្យាថា នឹងមកអំពីព្រលឹមនោះឯង ។ បទថា **រជ្ជំ និយ្យាទយិត្វា** សេចក្តីថា ក្នុងកាលនោះ តថាគតបំណងនឹងទៅរកបោរិសាទ ទើប

*ប្រគល់រាជសម្បត្តិប្រមាណ ៣០០ យោជន៍ ដល់មាតាបិតាថា សូមទ្រង់គ្រប់គ្រងរាជសម្បត្តិរបស់ទ្រង់ចុះ ។*

*សួរថា ព្រោះហេតុអ្វី ទើបតថាគតប្រគល់រាជសម្បត្តិ ព្រោះរឭកដល់ធម៌របស់សប្បុរស ព្រោះធម្មតាការធ្វើតាមពាក្យសច្ចៈ ប្បញ្ញាជាបវេណី ជាវង្សរបស់មហាសត្វដែលជាសប្បុរស គឺមនុស្សល្អ ហេតុនោះ ទើបតថាគតរឭកដល់ធម៌ គឺសច្ចបារមីនោះ ដែលជារបស់បុរាណ ដែលព្រះជិនស្រីសម្ពុទ្ធទាំងឡាយទ្រង់ប្រព្រឹត្តមកហើយ កាលនឹងតាមរក្សាសច្ចៈ ក៏ឲ្យទ្រព្យដល់ព្រាហ្មណ៍នោះ លះបង់ជីវិតរបស់ខ្លួន ចូលទៅរកបោរិសាទ ។ បទថា* **ឆត្ថិ មេ សំសយោ តត្ថ** *សេចក្តីថា ក្នុងការទៅរកបោរិសាទនោះ តថាគតមិនមានសេចក្តីសង្ស័យថា បោរិសាទនេះនឹងសម្លាប់អាត្មាអញឬហ្ន៎ តថាគតដឹងថា បោរិសាទនោះកាចឃោរឃៅ ត្រៀមសម្លាប់ស្តេច ១០០ មួយអន្លើដោយតថាគត ធ្វើពលីកម្មដល់ទេវតា នឹងសម្លាប់ដោយពិត ទើបតាមរក្សាសច្ចវាចាតែម្យ៉ាង លះបង់ជីវិតរបស់ខ្លួន ចូលទៅរកស្តេចបោរិសាទនោះព្រោះរឿងដូច្នេះឯង ហេតុនោះ បុគ្គលស្មើដោយសច្ចៈរបស់តថាគតមិនមាន នេះជាសច្ចបារមី ដែលដល់នូវភាពជាបរមត្ថបារមីរបស់តថាគត ដោយប្រការដូច្នេះ ។*

*ម្យ៉ាងទៀត កាលព្រះមហាសត្វចូលទៅរកស្តេចបោរិសាទហើយ ស្តេចបោរិសាទឃើញព្រះភក្ត្ររបស់ព្រះមហាសត្វ ដូចត្របកឈូក ផ្កាឈូករីក គិតថា ព្រះបាទសុតសោមនេះមិនខ្លាចស្លាប់ ទើបមក នេះជាអានុភាពនៃ*

អ៊ីហ្ន៎ ទើបសន្និដ្ឋានថា ព្រះបាទសុតសោមនេះ ជាអ្នកមានតេជះ មិនខ្លាចស្លាប់យ៉ាងនេះ ប្រហែលជាព្រោះស្តាប់ធម៌នោះទេដឹង អញស្តាប់ធម៌នោះហើយ មុខជាមានតេជះ មិនខ្លាចស្លាប់ដូចគ្នា ទើបពោលនឹងព្រះមហាសត្វថា ខ្ញុំសូមស្តាប់សតារហគាថា ដែលទ្រង់ទៅព្រះនគររបស់ខ្លួន ដើម្បីស្តាប់បានដែរឬទេ ។

ព្រះពោធិសត្វទ្រង់ស្តាប់ដូច្នោះ ទ្រង់ព្រះតម្រិះថា បោរិសាទនេះ មានធម៌ដ៏លាមក អញនឹងសង្កត់សង្កិនឲ្យខ្លាសបន្តិចសិន ហើយសឹមពោល ទើបត្រាស់ថា

ព្រះអង្គជាអធម្មិករាជ ព្រះហស្តប្រឡាក់ឈាមជានិច្ច មិនមានសច្ចៈ ធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយការស្តាប់ដូច្នេះ ។

កាលស្តេចបោរិសាទនោះកើតនូវការតាំងចិត្ត នឹងស្តាប់ធម៌ដោយល្អពោលថា

ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវបុណ្យនិងបាប ប៉ុនអម្បាលចិត្តរបស់ខ្ញុំ គង់ត្រេកអរក្នុងធម៌ ព្រោះបានស្តាប់នូវគាថាទាំងឡាយ ដូច្នេះ ។

ព្រះមហាសត្វទ្រង់ព្រះតម្រិះថា បោរិសាទនេះ ដាក់ចិត្តប្រាថ្នានឹងស្តាប់យ៉ាងក្រៃលែង ណ្ហើយចុះ អញនឹងពោលគាថាដល់គេ ទើបត្រាស់ថា នែសម្លាញ់ បើដូច្នោះ ចូរអ្នកស្តាប់ឲ្យល្អ ចូរធ្វើទុកក្នុងចិត្ត ហើយទ្រង់បន្ទឹគាថា

ទាំងឡាយ ដូចកាលនន្ទព្រាហ្មណ៍ពោលដោយគោរព កោលាហលបានកើតឡើងតែមួយ ពេញកាមាវចរ ៦ ជាន់ កាលទេវតាទាំងឡាយឲ្យសាធុការ ទើបព្រះមហាសត្វសម្តែងនូវធម៌ដល់បោរិសាទថា

បពិត្រមហារាជ ការជួបប្រទះដោយសប្បុរសទាំងឡាយ អស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ការជួបជុំដោយពួកអសប្បុរសច្រើនដង រមែងមិនរក្សាបុគ្គលបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកទេ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រា សូម្បីសរីរៈ ( របស់ពួកសត្វ ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រាទេ សប្បុរសទាំងឡាយ រមែងចរចានូវពួកសប្បុរសបាន ។ អាកាសនិងដី ស្ថិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបានពោលនូវប្រាំងសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយរមែងពោលថា ធម៌របស់ពួកសប្បុរស និងពួកអសប្បុរសឆ្ងាយជាងនេះទៅទៀត ដូច្នេះ ។

កាលស្តេចបោរិសាទនោះស្តាប់គាថាទាំងឡាយ ដែលព្រះមហាសត្វត្រាស់ល្អហើយ និងព្រោះបុញ្ញានុភាពរបស់ខ្លួន ទើបសកលកាយពេញដោយ

បីតិ ៥ ប្រការ ។ ស្ដេចបោរិសាទមានចិត្តទន់ក្នុងព្រះពោធិសត្វ ពោលថា សុតសោមសម្លាញ់ ខ្ញុំមិនឃើញប្រាក់ជាដើមដែលជារបស់គួរឲ្យ ខ្ញុំនឹងឲ្យពរមួយ ក្នុងគាថានីមួយៗ ( គឺឲ្យពរ ៤ ) ។

លំដាប់នោះ ព្រះមហាសត្វសង្កត់សង្កិនស្ដេចបោរិសាទថា អ្នកមិនស្គាល់នូវប្រយោជន៍របស់ខ្លួន តើនឹងឲ្យពរដល់អ្នកដទៃបានដូចម្ដេច កាលស្ដេចបោរិសាទអង្វរទៀតថា សូមទ្រង់ទទួលពរចុះ ព្រះមហាសត្វក៏សូមពរទី ១ ថា ខ្ញុំគប្បីឃើញស្ដេចបោរិសាទមិនមានរោគអស់កាលយូរ ។ ស្ដេចបោរិសាទត្រេកអរ គិតថា សុតសោមនេះ កាលអញបំណងនឹងសម្លាប់ស៊ីសាច់ក្នុងកាលឥឡូវនេះ នៅប្រាថ្នាជីវិតរបស់អញដែលធ្វើសេចក្ដីវិនាសឲ្យទៀត មិនដឹងថា ត្រូវ ( អញ ) បញ្ឆោតឲ្យទទួលពរដែលបានឲ្យ ។ ពិតហើយ ព្រះមហាសត្វ ព្រោះទ្រង់ជាអ្នកឈ្លាសក្នុងឧបាយ ទ្រង់សូមជីវិតរបស់ព្រះអង្គ ដោយអាងការស្រឡាញ់ សូមឲ្យស្ដេចបោរិសាទមានជីវិតអស់កាលយូរ ។ បន្ទាប់មកក៏សូមពរទី ២ ថា សូមទ្រង់ឲ្យជីវិតដល់ក្សត្រទាំងឡាយ ១០១ អង្គ សូមដោះលែងក្សត្រទាំងនោះ ឲ្យត្រឡប់ទៅកាន់ដែនរបស់ខ្លួនជាពរទី ៣ សូមឲ្យស្ដេចបោរិសាទវៀរចាកការបរិភោគសាច់មនុស្សជាពរទី ៤ ស្ដេចបោរិសាទឲ្យពរ ៣ តែមិនឲ្យពរទី ៤ ពោលថា សូមទ្រង់សូមពរដទៃចុះ តែត្រូវព្រះមហាសត្វទ្រង់រំអុក ទើបឲ្យពរទី ៤ នោះ ។

លំដាប់នោះ ព្រះពោធិសត្វទ្រង់ឲ្យស្ដេចបោរិសាទអស់ព្យសន៍ ទើបឲ្យស្ដេចបោរិសាទលែងព្រះរាជាទាំងឡាយ ហើយឲ្យព្រះរាជទាំងនោះ ផ្ទំលើផែនដី

ហូតខ្សែចេញពីដៃសន្ទើមៗ ដូចទាញអំបោះចេញអំពីត្រចៀករបស់កុមារ ឲ្យស្តេចបោរិសាទនាំបន្ទះស្បែកមួយបន្ទះដុសនឹងថ្ម ហើយធ្វើសច្ចកិរិយា លាបត្រង់បាតព្រះហស្តនៃស្តេចទាំងនោះ ផាសុកក៏មានក្នុងខណៈនោះឯង ។ ព្រះពោធិសត្វប្រថាប់នៅទីនោះអស់ ២-៣ ថ្ងៃ ទ្រង់ឲ្យបោរិសាទព្យាបាលស្តេចទាំងនោះឲ្យប្រាសចាករោគ ហើយឲ្យធ្វើសេចក្តីស្និទ្ធស្នាលជាមិត្រ មានការមិនបៀតបៀនគ្នានិងគ្នាក្នុងក្សត្រទាំងនោះ ហើយទ្រង់នាំស្តេចបោរិសាទនោះទៅកាន់នគរពារាណសី មួយអន្លើដោយក្សត្រទាំងនោះ ឲ្យតាំងនៅក្នុងរាជ-សម្បត្តិ ទ្រង់ប្រទានឱវាទថា សូមទ្រង់ទាំងឡាយកុំប្រមាទ ហើយបញ្ជូនព្រះរាជាទាំងនោះ ទៅកាន់នគររបស់ខ្លួន ទ្រង់ចោមរោមដោយពួកចតុរង្គសេនារបស់ព្រះអង្គ ដែលមកអំពីឥន្ទបត្តនគរ រំលចូលនគររបស់ព្រះអង្គ អ្នកនគរត្រេកអររីករាយចោមរោមព្រះមហាសត្វ ចូលទៅខាងក្នុងនគរ ថ្វាយបង្គំមាតាបិតាហើយ ឡើងកាន់មហាប្រាសាទ ។

លំដាប់នោះ ព្រះមហាសត្វទ្រង់ឲ្យសាងសាលា ៦ ខ្នង ទ្រង់បរិច្ចាគមហាទានរាល់ថ្ងៃ ទ្រង់បំពេញសីល រក្សាឧបោសថ ចម្រើនបារមីទាំងឡាយសូម្បីព្រះរាជាទាំងនោះ ក៏តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់បំពេញបុណ្យ មានទានជាដើម កាលសោយទិវង្គត ក៏ទៅកាន់ស្ថានសួគ៌ ។

ស្តេចបោរិសាទ ក្នុងកាលនោះ បានមកជាព្រះអង្គុលិមាលត្ថេរ ក្នុងកាលឥឡូវនេះ កាឡហត្ថិអមាត្យ ក្នុងកាលនោះ បានមកជាព្រះសារីបុត្តត្ថេរ ក្នុងកាលឥឡូវនេះ នន្ទព្រាហ្មណ៍ ក្នុងកាលនោះ បានមកជាព្រះអានន្ទ ក្នុង

កាលឥឡូវនេះ រុក្ខទេវតា ក្នុងកាលនោះ បានមកជាព្រះមហាកស្សបត្ថេរ ក្នុងកាលឥឡូវនេះ ព្រះរាជាទាំងឡាយ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ មាតាបិតា ក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ សុតសោមមហារាជ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីពោលចំពោះដល់បារមីដ៏សេសរបស់ព្រះមហាសត្វ ដោយន័យដូចបានពោលហើយខាងដើមនោះឯង ។ ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពនៃព្រះមហាសត្វ ដូចក្នុងអដ្ឋកថាអលីនសត្តុចរិយា ដោយប្រការដូច្នេះ ។*

**អដ្ឋកថា មហាសុតសោមចរិយា ចប់**

**សច្ចបារមី ចប់**

# សុត្តន្តបិដក

## សុវណ្ណសាមចរិយាទី ១៣

[ ៣៣ ] កាលដែលតថាគតជាតាបស ឈ្មោះសាមៈ នៅក្នុងអាស្រមដែលព្រះឥន្ទនិម្មិតឲ្យក្នុងព្រៃ តថាគតញ៉ាំងសីហៈ និងខ្លាធំទាំងឡាយក្នុងព្រៃ ឲ្យចូលមកជិតដោយមេត្តាបាន ។ សត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ក្របី ក្តាន់ និងជ្រូកព្រៃ មកចោមរោមតថាគតដែលនៅក្នុងព្រៃ ។ សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគតក៏មិនខ្លាចសត្វណាមួយឡើយ កាលនោះកម្លាំងមេត្តាឧបត្ថម្ភតថាគត ឲ្យតថាគតនៅក្នុងព្រៃដោយសួស្តី ។

សុវណ្ណសាមចរិយាទី ១៣ ចប់

# អដ្ឋកថា

## សុវណ្ណសាមចរិយា

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុវណ្ណសាមចរិយាទី ១៣ ដូចតទៅ នេះ បទថា **សាមោ យថា វនេ អាសឹ** សេចក្តីថា ក្នុងកាលតថាគតជាតាបសកុមារឈ្មោះសាមៈ នៅក្នុងព្រៃជំក្បែរឆ្នេរស្ទឹងឈ្មោះមិគសម្មតា ក្នុងហិមវន្តប្បទេស ។ បទថា **សក្កេន អភិនិម្មិតោ** សេចក្តីថា ដែលសក្កៈទ្រង់ឲ្យកើត គឺឲ្យមកកើត ព្រោះកើតមកដោយការសម្រេច នៃការណែនាំរបស់សក្កទេវរាជ ។

ក្នុងសុវណ្ណសាមចរិយានោះ មានរឿងជាលំដាប់ដូចតទៅនេះថា ក្នុងអតីត មានស្រុកព្រានមួយក្បែរមាត់ស្ទឹង មិនឆ្ងាយអំពីក្រុងពារាណសី ក្នុងស្រុកនោះ មានបុត្ររបស់ព្រានដែលជាប្រធាននៃព្រាន ឈ្មោះទុកូលៈ ។ មិនឆ្ងាយអំពីស្ទឹងនោះ ក៏មានស្រុកព្រានមួយទៀត ក្នុងស្រុកព្រាននោះ មានកូនស្រីរបស់ព្រានដែលជាប្រធាននៃព្រាន ឈ្មោះបារិកា ជនទាំងពីរនោះ ជាសត្វបរិសុទ្ធ មកអំពីព្រហ្មលោក កាលជនទាំងពីរចម្រើនវ័យ ទាំងដែលមិនប្រាថ្នានោះឯង មាតាបិតាក៏រៀបចំផ្សំផ្គុំឲ្យទាល់តែបាន ។ ជនទាំងពីរ មិនបានឈានចុះកាន់សមុទ្រ គឺកិលេស គឺមិនរួមបវេណី នៅរួមគ្នា ដូចពួកព្រហ្មដូច្នោះ មិនធ្វើកម្មណាមួយរបស់ព្រានផងដែរ ។

កាលនោះ មាតាបិតាពោលនឹងទុកូលថា កូនជាទីស្រឡាញ់ កូនមិនធ្វើកម្មរបស់ព្រាន កូនមិនប្រាថ្នាគ្រប់គ្រងផ្ទះ តើកូនធ្វើអ្វី ទុកូលពោលថា កាលពុកម៉ែអនុញ្ញាត កូននឹងបួស មាតាបិតាពោលថា បើដូច្នោះ ចូរកូនបួស

ចុះ ។ ជនទាំងពីរ ក៏ចូលកាន់ហិមវន្តប្បទេស ទៅដល់ទីដែលស្ទឹងមិគ-សម្មតា ហូរចុះអំពីហិមវន្តប្បទេសប្រសព្វគ្នានឹងស្ទឹងគង្គា ធ្វងស្ទឹងគង្គា បែរមុខទៅកាន់ស្ទឹងមិគសម្មតា ។ ក្នុងកាលនោះ ភពរបស់សក្កៈសម្តែងអាការក្តៅ សក្កទេវរាជទ្រង់ជ្រាបហេតុនោះ ទើបមានទេវបញ្ជាឲ្យវិស្សុកម្មទេវបុត្រមកសាងអាស្រមក្នុងទីនោះ ។ ជនទាំងពីរ ទៅដល់អាស្រមនោះហើយបួស ចម្រើនមេត្តាដែលជាកាមាវចរអាស្រ័យនៅ ក្នុងអាស្រមដែលសក្កទេវរាជទ្រង់ប្រទាន សូម្បីសក្កទេវរាជ ក៏យាងមកបម្រើជនទាំងពីរគឺស្វាមី និងភរិយានោះ ។

ថ្ងៃមួយ សក្កទេវរាជទ្រង់ជ្រាបថា ភ្នែករបស់ស្វាមីភរិយានោះនឹងវិនាស ទើបយាងទៅរក ហើយត្រាស់ថា លោកដ៏ចម្រើន ចក្ខុរបស់លោកទាំងពីរនឹងទទួលអន្តរាយ លោកគួរបានបុត្រមើលថែ ខ្ញុំដឹងថា លោកទាំងពីរ មានចិត្តបរិសុទ្ធ ព្រោះហេតុនោះ ក្នុងខណៈដែលនាងបារិកាមានរដូវ សូមលោកម្ចាស់យកដៃស្ទាបផ្ចិត ដោយអាការយ៉ាងនេះ បុត្ររបស់លោកម្ចាស់នឹងកើត បុត្រនោះនឹងបម្រើលោកម្ចាស់ទាំងពីរ ដូច្នេះហើយ ទ្រង់ក៏ត្រឡប់ ។ ទុកូលបណ្ឌិត ប្រាប់ហេតុនោះដល់នាងបារិកា ក្នុងខណៈដែលនាងបារិកាមានរដូវ ក៏ស្ទាបអង្អែលផ្ចិត ។ ក្នុងកាលនោះ ព្រះពោធិសត្វចុតិចាកទេវលោកបដិសន្ធិក្នុងគភ៌របស់នាងបារិកា ។ លុះកន្លងទៅ ១០ ខែ នាងបារិកាក៏ប្រសូតបុត្រ មានពណ៌ដូចមាស ទើបដាក់ឈ្មោះថា សុវណ្ណសាម ។ មាតាបិតាចិញ្ចឹមសុវណ្ណសាមនោះ រហូតមានអាយុ ១៦ ឆ្នាំ ឲ្យសុវណ្ណសាមអង្គុយ

ក្នុងអាស្រម ខ្លួនឯងទៅរកឫសឈើ និងផ្លែឈើក្នុងព្រៃ ។

ថ្ងៃមួយ កាលភ្លៀងធ្លាក់មិនឆ្ងាយអំពីអាស្រមបទ ទឹកលាយក្លិនញើស ដែលចេញអំពីរាងកាយរបស់មាតាបិតា ដែលកាន់យកផ្លែឈើក្នុងព្រៃហើយ ត្រឡប់ចូលទៅកាន់គល់ឈើ ឈរលើកំពូលដំបូក ក៏ស្រក់ចុះ ចូលប្រមុះ របស់អាសិរពិស ដែលនៅក្នុងរន្ធត្រង់ដំបូកនោះ អាសិរពិសក្រោធ ទើបព្រួសពិសចេញមក ជនទាំងពីរខ្វាក់ភ្នែក ក៏ស្រែកយំកន្ទក់កន្ទេញ ។ លំដាប់នោះ ព្រះពោធិសត្វគិតថា មាតាបិតារបស់អញយឺតយូរពន់ពេក មាតាបិតារបស់អញមានរឿងអ្វីហ្ន៎ ទើបធ្វើដំណើរបញ្ច្រាសផ្លូវមក ធ្វើនូវសំឡេង មាតាបិតាចាំសំឡេងសុវណ្ណសាមបាន ទើបធ្វើសំឡេងតប ដោយសេចក្តីស្រឡាញ់ក្នុងបុត្រ ទើបឃាត់ថា នែបាសុវណ្ណសាម ត្រង់នេះមានអន្តរាយ ចូរកុំមកឡើយ ហើយខ្លួនឯង ក៏ធ្វើដំណើរតាមក្រសែសំឡេង ។ សុវណ្ណ-សាមសួរថា ព្រោះហេតុអ្វី ទើបចក្ខុទាំងពីររបស់លោកខ្វាក់ លុះមាតាបិតាពោលថា មិនដឹង កាលភ្លៀងធ្លាក់ ពុក និងម៉ែឈរលើដំបូក ក្បែរដើមឈើបន្ទាប់អំពីនោះ ក៏មើលមិនឃើញឡើយ សុវណ្ណសាមគ្រាន់តែបានស្តាប់ប៉ុណ្ណោះ ក៏ដឹងថា ត្រង់ដំបូកនោះ មានអាសិរពិសៗ នោះក្រោធ ទើបព្រួសពិស ។

លំដាប់នោះ សុវណ្ណសាមពោលថា សូមពុក និងម៉ែកុំគិតថ្វីឡើយ កូននឹងបម្រើលោកទាំងពីរ ហើយនាំមាតាបិតាមកកាន់អាស្រម ចងខ្សែក្នុងទីដែលមាតាបិតាដើរទៅមក មានទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់

ជាដើម ។ បន្ទាប់អំពីនោះ សុវណ្ណសាមក៏ឲ្យមាតាបិតានៅក្នុងអាស្រម នាំឫសឈើ និងផ្លែឈើក្នុងព្រៃមកចិញ្ចឹមមាតាបិតា ។ ក្នុងពេលព្រឹកក៏បោសលំនៅ នាំទឹកផឹកមកជូន តម្កល់គ្រឿងបរិភោគ មានឈើស្ទន់ និងទឹកលុបមុខ ( ជាដើម ) ហើយឲ្យផ្លែឈើមានរសឆ្ងាញ់ ។ កាលមាតាបិតាខ្ពុរមាត់ហើយ ខ្លួនឯងក៏បរិភោគ ថ្វាយបង្គំមាតាបិតាហើយ ក៏អង្គុយនៅក្បែរមាតាបិតានោះឯង ដោយគិតថា មាតាបិតាប្រើអ្វីខ្លះ និងដោយចំពោះ បានផ្សាយមេត្តាដោយច្រើន ដោយហេតុនោះ សត្វទាំងឡាយក៏មិនបៀតបៀនសុវណ្ណ-សាម ។ ព្រះពោធិសត្វមិនបៀតបៀនសត្វទាំងឡាយ ដូចដែលសត្វទាំងឡាយមិនបៀតបៀនព្រះពោធិសត្វៗ ទៅក្តី មកក្តីអំពីព្រៃ ដើម្បីរកផលាផលរាល់ៗ ថ្ងៃយ៉ាងនេះ ក៏បានចោមរោមទៅដោយហ្វូងម្រឹគ ។ សត្វដែលជាសត្រូវ មានសីហៈ និងខ្លាធំជាដើម ក៏ស្និទ្ធស្នាលយ៉ាងក្រៃលែងជាមួយព្រះពោធិសត្វ ដោយអានុភាពនៃមេត្តា សត្វតិរច្ឆានទាំងឡាយ បានជាសត្វមានចិត្តទន់ចំពោះគ្នានិងគ្នា ត្រង់លំនៅរបស់ព្រះពោធិសត្វនោះ ដោយអាការដូច្នេះ ។ ព្រះពោធិសត្វនោះ ដោយអានុភាពនៃមេត្តាក្នុងទីទាំងពួង ទើបជាអ្នកមិនខ្លាច មិនតក់ស្លុត មិនមានពៀរ ដូចព្រហ្ម ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតញ៉ាំងសីហៈ និងខ្លាធំទាំងឡាយក្នុងព្រៃ ឲ្យចូលមកជិតដោយមេត្តាបាន ។ សត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ក្របី ក្តាន់ និងជ្រូកព្រៃ មកចោមរោមតថាគតដែលនៅក្នុងព្រៃ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មេត្តាយមុបដាមយឹ** ម អក្សរ ជាបទសន្ធិ អធិប្បាយថា ផ្សាយមេត្តាភាវនាទៅក្នុងរាជសីហ៍ និងខ្លាធំ ដែលជាសត្វកាច នឹងពោលថ្វីដល់សត្វដ៏សេស ។ ម្យ៉ាងទៀត ឈ្មោះថា មេត្តា ព្រោះជាហេតុប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅនៃមេត្តា បានដល់ មេត្តាភាវនា ។ តថាគតបង្អោនមេត្តារកគ្នា គឺបង្អោនដោយមិនចំពោះក្នុងសត្វទាំងឡាយ ។ ក្នុងគាថានោះ បាឋៈថា **សីហាព្យគ្ឃេហិ** ដូច្នេះក៏មាន ។ អត្ថនៃគាថានោះថា មិនមែនតែតថាគតប៉ុណ្ណោះទេ ដែលពិត ក្នុងកាលនោះ តថាគតនៅក្នុងព្រៃណា ជាមួយរាជសីហ៍ និងខ្លាធំ តថាគតបង្អោនមេត្តាទៅក្នុងសត្វទាំងឡាយ មួយអន្លើដោយរាជសីហ៍ និងខ្លាធំក្នុងព្រៃនោះ ។ លោកសម្តែងថា រាជសីហ៍ និងខ្លាធំក្នុងកាលនោះ ក៏មានចិត្តមេត្តាក្នុងសត្វទាំងឡាយ ដោយអានុភាពដ៏ធំ នឹងពោលទៅថ្វីដល់សត្វក្រៅអំពីនោះ ។

បទថា **បសទមិគវរាហេហិ** បានដល់ ក្តាន់ និងជ្រូកព្រៃ ។ បទថា **បរិវារេត្វា** បានដល់ តថាគតនៅក្នុងព្រៃនោះ ធ្វើឲ្យសត្វទាំងនោះចោមរោមខ្លួន ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងអានិសង្ស និងការសម្រេចផលទីបំផុត ដែលបានហើយដោយមេត្តាភាវនារបស់ព្រះអង្គក្នុងកាលនោះ ទើបត្រាស់គាថាចុងក្រោយថា

សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគតក៏មិន
ខ្លាចសត្វណាមួយឡើយ កាលនោះ កម្លាំងមេត្តាឧបត្ថម្ភតថាគត

ឲ្យតថាគត នៅក្នុងព្រៃដោយសួស្តី ដូច្នេះ ។

គាថានោះ មានអត្ថដូចតទៅនេះ សត្វណាមួយ ទោះបីជាសត្វមានជាតិជាសត្វខាច មានទទន្សាយ និងឆ្មាជាដើម ក៏មិនតក់ស្លុត មិនភិតភ័យខ្លាចតថាគត សូម្បីតថាគត ក៏មិនចខ្លាចសត្វណាមួយ គឺអំពីសត្វតិរច្ឆានមានរាជសីហ៍ និងខ្លាធំជាដើម អំពីអមនុស្ស មានយក្ខជាដើម អំពីមនុស្សមានព្រានព្រៃដែលមានដៃប្រឡាក់ដោយឈាម ព្រោះហេតុអ្វី ព្រោះតថាគតដែលកម្លាំងមេត្តាឧបការៈ គឺដែលអានុភាពនៃមេត្តាបារមី ដែលតថាគតបំពេញមកអស់កាលយូរឧបត្ថម្ភ ទើបត្រេកអរនៅក្នុងព្រៃ គឺព្រៃធំនោះ ក្នុងកាលនោះ បទដ៏សេស មានអត្ថងាយយល់ហើយ ។

ម្យ៉ាងទៀត ព្រះមហាសត្វផ្សាយមេត្តាទៅក្នុងសព្វសត្វយ៉ាងនេះ ចិញ្ចឹមមាតាបិតាយ៉ាងល្អ ថ្ងៃមួយ នាំផ្លែឈើមានរសឆ្ងាញ់មកអំពីព្រៃ ថ្វាយបង្គំមាតាបិតាដែលសម្រាកក្នុងអាស្រម គិតថា អញនឹងទៅដងទឹកមក ចោមរោមដោយពួកម្រឹគ ឲ្យម្រឹគពីរមកជិតគ្នា ហើយដាក់ក្អមទឹកលើខ្នងម្រឹគទាំងពីរ យកដៃចាប់មាត់ក្អម ហើយទៅកាន់កំពង់ទឹក ។

ក្នុងសម័យនោះ ព្រះរាជាព្រះនាមបីឡិយក្ខ[១] សោយរាជសម្បត្តិក្រុងនគរពារាណសី ។ ព្រះអង្គចង់សោយសាច់ម្រឹគ ទើបប្រគល់រាជសម្បត្តិដល់មាតា សៀតអាវុធទាំង ៥ ចូលទៅកាន់ព្រៃហិមពាន្ត បាញ់ម្រឹគហើយសោយសាច់ ទ្រង់យាងទៅដល់ស្ទឹងមិគសម្មតា ដល់កំពង់ដែលសុវណ្ណសាម

---

១- បិដកខ្មែរជា បិលយក្ខ ។

ទៅដងទឹកដោយលំដាប់ ទ្រង់ឃើញស្នាមជើងម្រឹគ ទើបយាងតាមស្នាមជើង ទ្រង់ឃើញសុវណ្ណសាមដើរទៅ គិតថា អស់កាលមានប្រមាណប៉ុណ្ណោះ អញមិនធ្លាប់ឃើញមនុស្សត្រាច់ទៅយ៉ាងនេះឡើយ មនុស្សនេះ ជាទេវតា ឬជានាគហ្ន៎ បើអញចូលទៅសួរ ក្រែងគេចទៅបាត់ យកល្អ អញបាញ់ បុគ្គលនោះ ធ្វើឲ្យខ្សោយកម្លាំង ហើយសឹមសួរ ក្នុងខណៈដែលព្រះ មហាសត្វងូតទឹក ស្លៀកសំពត់សម្បកឈើ ធ្វើស្បែកខ្លាធៀងស្មា ដងទឹក ពេញក្អមហើយ លើកដាក់លើចង្កេះស្មាខាងឆ្វេង ព្រះរាជាទ្រង់ព្រះតម្រិះថា ឥឡូវនេះ បានឱកាសបាញ់ហើយ ទើបបាញ់ព្រះមហាសត្វខាងស្តាំ ដោយ ព្រួញដែលលាបដោយថ្នាំពិស ព្រួញធ្លុះចេញទៅខាងឆ្វេង ហ្វូងម្រឹគដឹងថា ព្រះពោធិសត្វត្រូវបាញ់ មានការភ័យខ្លាច នាំគ្នារត់ទៅ ។

ចំណែកសាមបណ្ឌិត ទោះបីត្រូវព្រួញហើយ ក៏មិនបានភិតភ័យ នៅឱប ក្អមទឹកយ៉ាងនោះ តាំងស្មារតីសន្សឹមៗ ប្រមូលខ្សាច់ ដាក់ក្អម កំណត់ទិស ដេកបែរក្បាលទៅកាន់លំនៅរបស់មាតាបិតា ខ្ជាក់លោហិតតាមមាត់ពោលថា ខ្ញុំមិនមានពៀរជាមួយបុគ្គលណាឡើយ ឈ្មោះថា ពៀរក្នុងទីណាមួយ ក៏មិន មានដល់ខ្ញុំ ហើយពោលគាថានេះថា

> នរណាហ្ន៎ បាញ់ខ្ញុំជាអ្នកដងទឹក ភ្លេចស្មារតីដោយព្រួញ ជន
> ណាជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំ ហើយពួន
> ដូច្នេះ ។

ព្រះរាជាកាលស្តាប់ដូច្នោះ ទ្រង់ព្រះតម្រិះថា មនុស្សនេះ ទោះបីត្រូវ

អញបាញ់ឲ្យដួលលើផែនដី មិនជេរ មិនបរិភាសអញ នៅហៅរកអញដោយវាចាផ្អែមល្ហែម ហាក់ដូចអង្រួនហទយៈអញ អញនឹងទៅរកបុរសនេះ ទើបយាងចូលទៅបង្ហាញខ្លួន និងទទួលថា ព្រះអង្គជាអ្នកបាញ់ ហើយត្រាស់សួរព្រះមហាសត្វថា អ្នកជានរណា ជាបុត្រអ្នកណា សាមបណ្ឌិតពោលថា ខ្ញុំឈ្មោះសាម ជាបុត្ររបស់ឥសីនេសាទ ឈ្មោះទុកូលបណ្ឌិត ទ្រង់បាញ់ខ្ញុំធ្វើអ្វី ព្រះរាជាត្រាស់កុហកថា ខ្ញុំសម្គាល់ថា ម្រឹគ ទ្រង់សោយសោកថា អញបាញ់សាមនេះដែលមិនមានកំហុស ដោយមិនមែនជាហេតុ ហើយទ្រង់ប្រាប់តាមសេចក្ដីពិត ត្រាស់សួរដល់លំនៅមាតាបិតារបស់សាមបណ្ឌិត រួចយាងទៅក្នុងទីនោះ ហើយទ្រង់ប្រាប់ព្រះអង្គដល់តាបស និងតបស្វិនី ។ កាលមាតាបិតារបស់សាមបណ្ឌិត បានធ្វើបដិសណ្ឋារៈ ព្រះរាជាត្រាស់ថា ខ្ញុំបាញ់សាមហើយ ទ្រង់លួងលោមតាបស និងតបស្វិនី ដែលកំពុងយំថា ខ្ញុំនឹងចិញ្ចឹមលោកទាំងពីរ ដូចដែលសាមចិញ្ចឹមលោកគ្រប់យ៉ាង ហើយទ្រង់នាំទៅរកសាម ។ មាតាបិតាទៅក្នុងទីនោះហើយ យំរៀបរាប់ដោយប្រការផ្សេងៗ ហើយដាក់ដៃត្រង់ទ្រូងរបស់សាមពោលថា នៅលើកាយបុត្ររបស់ខ្ញុំ មានកម្ដៅនៅឡើយ ប្រហែលជាសន្ទប់ព្រោះកម្លាំងពិស គិតថា ពួកយើងនឹងធ្វើសច្ចកិរិយាដើម្បីឲ្យពិសចេញទៅ ទើបមាតាតាំងសច្ចាធិដ្ឋានថា

បុណ្យណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើ
ហើយដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ
សាបរលាបទៅ ដូច្នេះ ។

កាលបិតាតាំងសច្ចាធិដ្ឋានថា

បុណ្យណាទីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដូច្នេះ ។

កាលទេពធីតាធ្វើសច្ចកិរិយាថា

ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃ ដែលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំ ជាងសាមៈទេ ដោយការពោលសច្ចៈនុ៎ះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដូច្នេះ ។

ព្រះមហាសត្វក៏ក្រោកឡើងមួយរំពេច ការឈឺចាប់ក៏បាត់ទៅ ដូចតំណក់ទឹកលើស្លឹកឈូកធ្លាក់ទៅ ដូច្នោះ អវយវៈដែលព្រួញត្រូវ ក៏ជាសះស្បើយជាប្រក្រតី ភ្នែកទាំងពីររបស់មាតាបិតា ក៏ប្រាកដដូចប្រក្រតី រំពេចនោះ ក៏កើតអស្ចារ្យឡើងក្នុងខណៈតែមួយ គឺព្រះមហាសត្វប្រាសចាករោគ ១ មាតាបិតាបានចក្ខុ ១ អរុណរះ ១ មនុស្សទាំង ៤ ប្រាកដក្នុងអាស្រម ១ ។

លំដាប់នោះ ព្រះមហាសត្វក៏ធ្វើបដិសណ្ឋារៈជាមួយព្រះរាជា ហើយសម្តែងធម៌ថ្វាយ ដោយន័យជាដើមថា បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ហើយថ្វាយឱវាទឲ្យក្រៃលែង ឲ្យបាននូវសីល ៥ ។ ព្រះរាជាទ្រង់ទទួលឱវាទរបស់ព្រះមហាសត្វដោយសិរសា ទ្រង់ថ្វាយបង្គំហើយ យាងត្រឡប់ទៅកាន់

នគរពារាណសី ទ្រង់ធ្វើបុណ្យ មានទានជាដើម ហើយបានទៅកាន់ស្ថានសួគ៌ ព្រះពោធិសត្វ និងមាតាបិតា ញុំាងអភិញ្ញាសមាបត្តិឲ្យកើត លុះអស់ជីវិត ក៏ទៅកើតក្នុងព្រហ្មលោក ។

ព្រះរាជាក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ ទេពធីតា ក្នុងកាលនោះ បានមកជាឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ សក្កទេវរាជ ក្នុងកាលនោះ បានមកជាព្រះអនុរុទ្ធ ក្នុងកាលឥឡូវនេះ បិតា ក្នុងកាលនោះ បានមកជាព្រះមហាកស្សបត្ថេរ ក្នុងកាលឥឡូវនេះ មាតា ក្នុងកាលនោះ បានមកជានាងភទ្ទាកាបិលានី ក្នុងកាលឥឡូវនេះ សាម-បណ្ឌិត ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីពោលចំពោះដល់បារមីដ៏សេស របស់ព្រះពោធិសត្វនោះ ដោយន័យដូចបានពោលហើយខាងដើមនោះឯង ។

ម្យ៉ាងទៀត គប្បីប្រកាសគុណានុភាពយ៉ាងនេះ គឺការដែលព្រះពោធិសត្វសូម្បីត្រូវបាញ់ដោយព្រួញ ដែលលាបដោយថ្នាំពិស ដោយចូលពីខាងស្តាំ ហើយធ្លុះទៅខាងឆ្វេង មិនសម្តែងអាការឈឺចាប់ណាមួយ ហើយដាក់ក្អមទឹកចុះសន្សឹមៗ លើផែនដី ការមិនមានវិការផ្លូវចិត្តក្នុងបុគ្គលអ្នកសម្លាប់ ទោះបីមិនស្គាល់ ក៏ដូចស្គាល់ ការបញ្ចេញវាចាដោយពាក្យគួរស្រឡាញ់ ការសោយសោកដោយត្រឹមតែពោលថា ខ្ញុំវិនាសចាកបុណ្យ គឺការបម្រើមាតាបិតា កាលរោគជាសះស្បើយ តាំងនៅក្នុងសេចក្តីករុណា និងមេត្តា ហើយសម្តែងធម៌ថ្វាយព្រះរាជា និងការឲ្យឱវាទ ។៙

# សុត្តន្តបិដក

## ឯករាជចរិយាទី ១៤

[ ៣៤ ] មានចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចឈ្មោះឯករាជ បានអធិដ្ឋានសីលដ៏ក្រៃលែង ហើយគ្រប់គ្រងមហាប្រឹថពី ក្នុងកាសិករដ្ឋ ។ តថាគតបានប្រព្រឹត្តកុសលកម្មបថ ១០ ឥតមានសេសសល់ សង្គ្រោះមហាជនដោយសង្គហវត្ថុទាំង ៤ ។ តថាគត មិនប្រមាទក្នុងលោកនេះ និងបរលោកយ៉ាងនេះ វេលានោះ ស្តេចក្នុងដែនកោសល ឈ្មោះទព្វសេន ចូលមកដណ្តើមរាជបុរីរបស់តថាគត ។ ស្តេចទព្វសេន ធ្វើនូវអ្នកនិគមព្រមទាំងពួកពល និងអ្នកជនបទ ដែលរស់នៅព្រោះអាស្រ័យស្តេចទាំងអស់ឲ្យតាំងនៅក្នុងដៃ ហើយជីកកប់តថាគតក្នុងរណ្តៅ ។ តថាគតបានឃើញនូវមណ្ឌលនៃអាមាត្យ រាជ្យ និងវាំងដ៏ស្តុកស្តម្ភរបស់តថាគត ដូចកូនជាទីស្រឡាញ់ ដែលត្រូវស្តេចទព្វសេនដណ្តើមយកហើយ ( ក៏ផ្សាយមេត្តាចំពោះស្តេចទព្វសេននោះ ) គុណធម៌ដទៃ ស្មើនឹងមេត្តានៃតថាគត ពុំមានឡើយ នេះជាមេត្តាបារមីរបស់តថាគត ។

ឯករាជចរិយាទី ១៤ ចប់

# អដ្ឋកថា

## ឯករាជចរិយា

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឯករាជចរិយាទី ១៤ ដូចតទៅ បទថា **ឯករាជាតិ វិស្សុតោ** បានដល់ ប្រាកដក្នុងជម្ពូទ្វីប ដោយនាមដែលកំណត់ថា ឯករាជ ។

ក្នុងកាលនោះ ព្រះមហាសត្វទ្រង់ជាឱរសព្រះបាទក្រុងពារាណសី ទ្រង់ចម្រើនវ័យ ដល់នូវការសម្រេចសិប្បៈគ្រប់យ៉ាង កាលព្រះបិតាសោយទិវង្គត បានគ្រងរាជសម្បត្តិ មានព្រះនាមប្រកាសថា ឯករាជ ព្រោះទ្រង់បំពេញបារមី ដោយការប្រកបគុណវិសេស ដែលមិនទូទៅដល់អ្នកដទៃ មានសីលអាចារៈ សទ្ធា និងសុតៈ ដែលជាកុសលជាដើម និងដោយភាពជាប្រធាន ព្រោះមិនមានបុគ្គលជាគម្រប់ពីរ ក្នុងផ្ទៃជម្ពូទ្វីប ។ បទថា **បរមំ សីលំ អធិដ្ឋាយ** សេចក្ដីថា អធិដ្ឋានសីលដែលបានដល់កុសលកម្មបថ ១០ ប្រការ ដែលបរិសុទ្ធឧត្ដម ពោល គឺសង្រួមកាយ វាចា បរិសុទ្ធដោយល្អ និងប្រព្រឹត្តប្រពៃផ្លូវចិត្ត បរិសុទ្ធដោយល្អ ដោយការសមាទាន និងដោយការមិនឈានកន្លង ។ បទថា **បសាសាមិ មហាមហឹ** សេចក្ដីថា គ្រប់គ្រងផែនដីធំ គឺគ្រប់គ្រងរាជសម្បត្តិក្នុងដែនកាសី ប្រមាណ ៣០០ យោជន៍ ។

បទថា **ទសកុសលកម្មបថេ** សេចក្ដីថា សមាទានកុសលកម្មបថ ១០ ប្រការ មានការវៀរចាកការសម្លាប់សត្វ រហូតដល់សម្មាទិដ្ឋិ ឬប្រព្រឹត្តកុសលកម្មទាំងនោះ មិនមានចំណែកសេសសល់ ។ បទថា **ចតូហិ សង្គហ–**

**វត្ថូហិ** គប្បីជ្រាបការភ្ជាប់សេចក្តីថា ក្នុងកាលតថាគតប្រាកដ ឈ្មោះថា ឯករាជ សង្គ្រោះមហាជនដោយធម៌ ជាហេតុនៃការសង្គ្រោះ គឺសង្គហវត្ថុ ៤ បានដល់ ទាន បិយវាចា អត្ថចរិយា និងសមានត្តតា តាមសមគួរ ។

បទថា **ឯវំ** សេចក្តីថា កាលតថាគតជាបុគ្គលមិនប្រមាទ ដោយអាការនេះ តាមដែលពោលហើយ គឺការបំពេញសីល គឺកុសលកម្មបថ ១០ ឲ្យបរិបូណ៌ ការសង្គ្រោះមហាជនដោយសង្គហវត្ថុ ៤ ។ បទថា **ឥធ លោកេ បរត្ថ ច** សេចក្តីថា កាលតថាគតជាអ្នកមិនប្រមាទ ក្នុងប្រយោជន៍បច្ចុប្បន្ន គឺការមិនប្រមាទក្នុងលោកនេះ និងកាលតថាគតជាអ្នកមិនប្រមាទ ក្នុងប្រយោជន៍លោកខាងមុខ គឺការមិនប្រមាទ ក្នុងលោកដទៃ ។ បទថា **ឧគ្គសេនោ** បានដល់ ព្រះបាទកោសល ព្រះនាមទព្វសេន ។ បទថា **ឧបគន្ត្វា** សេចក្តីថា ព្រះបាទកោសល ចូលទៅដណ្តើមរាជសម្បត្តិរបស់តថាគត ដោយការលើកចតុរង្គសេនាមកគ្រប់គ្រង ។ បទថា **អច្ឆិន្នន្តោ បុរំ មម** បានដល់ ដណ្តើមនគរពារាណសីរបស់តថាគតដោយកម្លាំង ។

ក្នុងគាថានោះ មានរឿងជាលំដាប់លំដោយដូចតទៅ បានឮថា កាលនោះ ព្រះមហាសត្វឲ្យសាងរោងទាន ៦ ខ្នង គឺត្រង់ទ្វារនគរ ៤ កណ្តាលព្រះនគរ ១ ត្រង់ទ្វារនិវេសន៍ ១ ទ្រង់ឲ្យទានដល់យាចក រហូតដល់អ្នកដំណើរជាដើម ទ្រង់រក្សាសីល និងឧបោសថ ទ្រង់ដល់ព្រមដោយខន្តី មេត្តា និងករុណា ទ្រង់ត្រេកអរក្នុងសព្វសត្វ ដូចមាតាបិតាត្រេកអរនឹងបុត្រដែលអង្គុយលើភ្លៅ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ។ អមាត្យរបស់ព្រះអង្គម្នាក់ ប្រទូស្ត

ស្រីស្នំ តមក មានមនុស្សដើរក្នុងខាងក្រោយ ។ អមាត្យទាំងឡាយ ក្រាបទូលដល់ព្រះរាជា។ ទ្រង់ឃ្លាំសង្កេតមើល ដឹងច្បាស់ដោយព្រះអង្គ ទើបត្រាស់ហៅអមាត្យនោះមកប្រាប់ថា នែអន្ធពាល អ្នកធ្វើកម្មមិនសមគួរ អ្នកមិនគួរនៅក្នុងដែនរបស់យើង ចូរអ្នកកាន់យកទ្រព្យ ហើយនាំកូនប្រពន្ធទៅកាន់ទីដទៃ ហើយទ្រង់និរទេសចេញចាកដែន ។

អមាត្យនោះ ទៅកាន់កោសលជនបទ ចូលទទួលរាជការជាមួយព្រះបាទកោសល ព្រះនាមទព្វសេន បានធ្វើនូវការស្និទ្ធស្នាលជាមួយព្រះរាជានោះដោយលំដាប់ ថ្ងៃមួយ ទូលព្រះរាជាថា បពិត្រព្រះអង្គ នគរពារាណសីដូចគ្នានឹងសម្បុកឃ្មុំមិនមានមេ ព្រះរាជាក៏ទន់ខ្សោយ ព្រះអង្គអាចដណ្តើមរាជសម្បត្តិនោះបានដោយងាយ ។ ព្រះរាជាទព្វសេន ទ្រង់មិនជឿពាក្យរបស់អមាត្យនោះ ព្រោះព្រះបាទពារាណសី ទ្រទ្រង់នូវអានុភាពច្រើន ទើបទ្រង់បញ្ជូនពួកមនុស្សទៅឲ្យធ្វើការសម្លាប់អ្នកស្រុកជាដើម ក្នុងដែនកាសី ទ្រង់ស្តាប់ថា ព្រះពោធិសត្វឲ្យទ្រព្យដល់ចោរទាំងនោះហើយ ដោះលែងទៅ កាលទ្រង់ជ្រាបថា ព្រះរាជាប្រកបដោយធម៌យ៉ាងក្រៃលែង ទើបទ្រង់ព្រះតម្រិះថា អញនឹងដណ្តើមរាជសម្បត្តិក្នុងនគរពារាណសី ទើបលើកកងទ័ពចេញទៅ ។ លំដាប់នោះ ទាហានរបស់ព្រះបាទពារាណសី បានដំណឹងថា ព្រះបាទកោសលលើកកងទ័ពមក ទើបក្រាបទូលដល់ព្រះរាជារបស់ខ្លួនថា ពួកទូលបង្គំនឹងចាប់ព្រះរាជានោះ មិនឲ្យកន្លងវដ្ឋសីមារបស់យើងមក ។

ព្រះពោធិសត្វឃាត់ថា អ្នកទាំងឡាយ ការធ្វើអ្នកដទៃឲ្យលំបាកព្រោះ

អាស្រ័យយើងមិនមាន បុគ្គលត្រូវការរាជសម្បត្តិ ចូរកាន់យករាជសម្បត្តិចុះ ពួកអ្នកកុំទៅឡើយ ។ ព្រះបាទកោសលចូលទៅដល់កណ្តាលជនបទ ពួកទាហានទូលដល់ព្រះរាជាយ៉ាងនោះទៀត ព្រះរាជាក៏ឃាត់ដោយន័យមុន ។ ព្រះបាទទព្វសេន បញ្ឈប់សេនាខាងក្រៅព្រះនគរ ទ្រង់បញ្ជូនសាសន៍ដល់ព្រះបាទឯករាជថា ប្រគល់រាជសម្បត្តិ ឬច្បាំង ព្រះបាទឯករាជទ្រង់បញ្ជូនសាសន៍តបទៅថា ខ្ញុំមិនច្បាំង សូមយករាជសម្បត្តិចុះ ។ ពួកទាហានទូលទៀតថា បពិត្រព្រះអង្គ ពួកទូលបង្គំមិនឲ្យព្រះបាទកោសលចូលនគរបាន នឹងនាំគ្នាច្បាំងព្រះបាទកោសលនោះខាងក្រៅព្រះនគរ ហើយចាប់មកថ្វាយព្រះរាជាទ្រង់ឃាត់ដូចមុន ទ្រង់ត្រាស់ឲ្យបិទទ្វារនគរ ប្រថាប់គង់លើបល្ល័ង្កត្រង់មហាប្រាសាទ ។ ព្រះបាទទព្វសេនចូលទៅកាន់នគរដោយកងទ័ពធំ ទ្រង់មិនឃើញសត្រូវតតាំង សូម្បីតែម្នាក់ ទ្រង់ចូលទៅកាន់ព្រះរាជនិវេសន៍ ដណ្តើមរាជសម្បត្តិឲ្យនៅក្នុងកណ្តាប់ដៃ ឡើងកាន់ប្រាសាទធំ ត្រាស់ឲ្យចាប់ព្រះពោធិសត្វដែលមិនមានកំហុសកប់ក្នុងរណ្តៅ ដូចព្រះមានព្រះភាគត្រាស់ថា

> វេលានោះ ស្តេចក្នុងដែនកោសល ឈ្មោះទព្វសេន ចូលមកដណ្តើមរាជបុរីរបស់តថាគត ។ ស្តេចទព្វសេន ធ្វើនូវអ្នកនិគមព្រមទាំងពួកពល និងអ្នកជនបទ ដែលរស់នៅព្រោះអាស្រ័យស្តេចទាំងអស់ឲ្យតាំងនៅក្នុងដៃ ហើយជីកកប់តថាគតក្នុងរណ្តៅដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **រាជូបជីវេ** បានដល់ អមាត្យរាជបរិស័ទ

ព្រាហ្មណគហបតីជាដើម អាស្រ័យព្រះរាជាចិញ្ចឹមជីវិត ។ បទថា **ឆិគមេ** កែជា **នេគមេ** ។ បទថា **សពលដ្ឋេ** សេចក្តីថា ឈ្មោះថា **សពលដ្ឋ** ព្រោះតាំងកងពលទាក់ទងដោយពួកទាហាន ឈ្មោះថា **សពលដ្ឋ** ព្រោះប្រកបដោយទាហាន មានពួកទាហានដ៏វីរជាដើម ។ បទថា **សរដ្ឋកេ** បានដល់ ព្រមដោយអ្នកជនបទ អធិប្បាយថា ព្រះបាទទព្វសេនទ្រង់ធ្វើអ្នករាជការ និងអ្នកនិគមជទៃៗ ឲ្យនៅក្នុងកណ្តាប់ដៃទាំងអស់ហើយ ។ បទថា **កាសុយា ឆិខណី មមំ** សេចក្តីថា ព្រះបាទទព្វសេន ដណ្តើមរាជសម្បត្តិរបស់តថាគត មួយអន្លើដោយពលពាហនៈទាំងអស់ហើយ ទ្រង់ឲ្យកប់តថាគតក្នុងរណ្តៅត្រឹម-កក្នុងជាតកក៏ពោលថា កប់ក្នុងរណ្តៅ ដោយសេចក្តីថា

បពិត្រព្រះអង្គជាឯករាជ កាលពីដើម ព្រះអង្គនៅសោយកាមគុណទាំងឡាយ ជារបស់ស្តុកស្តម្ភ រកអ្វីប្រសើរជាងគ្មាន ឥឡូវនេះព្រះអង្គនោះ គេបោះទៅក្នុងរណ្តៅ ក្រហេងក្រហូង ហើយនៅតែមិនលះបង់នូវពណ៌សម្បុរ និងកម្លាំងពីដើម ដូច្នេះ ។

តែក្នុងអដ្ឋកថាជាតកពោលថា ព្រះបាទទព្វសេនបញ្ជាឲ្យដាក់សម្រែកព្យួរព្រះពោធិសត្វ យកសីសៈចុះក្រោម ខាងលើធរណីទ្វារ ។

ព្រះមហាសត្វចម្រើនមេត្តា ប្រារព្ធព្រះរាជាដែលជាចោរហើយ ទ្រង់ធ្វើកសិណបរិកម្ម ញុំាងឈាន និងអភិញ្ញាឲ្យកើត ទ្រង់ក្រោកឡើងអំពីរណ្តៅប្រថាប់គង់ពត់ភ្នែនលើអាកាស ដូចព្រះមានព្រះភាគត្រាស់ថា

តថាគត បានឃើញនូវមណ្ឌលនៃអាមាត្យ រាជ្យ និងរាំងដ៏ស្តុក ស្តម្ភរបស់តថាគត ដូចកូនជាទីស្រឡាញ់ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អមច្ចមណ្ឌលំ** សេចក្តីថា ពួកដែលបដិបត្តិរួមជាមួយព្រះរាជា ក្នុងរាជកិច្ចនោះៗ ឈ្មោះថា អមាត្យ ឬមួយអន្ទើដោយពួកអមាត្យទាំងនោះ ។ បទថា **ដីឆំ** បានដល់ រាជសម្បត្តិដែលស្តុកស្តម្ភដោយពលពាហនៈ ដោយអ្នកនគរ និងអ្នកជនបទជាដើម អធិប្បាយថា តថាគតឃើញព្រះរាជាដែលជាសត្រូវ ដណ្តើមយករាជសម្បត្តិដ៏ស្តុកស្តម្ភមួយអន្ទើដោយស្រីស្នំ ទាសី ទាសៈ និងបរិវារ និងរបស់ប្រើប្រាស់ មានសំពត់ និងគ្រឿងប្រដាប់ជាដើម ខាងក្នុងព្រះនគររបស់តថាគត ដូចឃើញបុត្រជាទីស្រឡាញ់របស់ខ្លួនដោយមេត្តាណា បុគ្គលស្មើដោយមេត្តានោះរបស់តថាគតមិនមានក្នុងសាកលលោក ព្រោះហេតុនោះ សភាវៈយ៉ាងនេះ ជាមេត្តាបារមីរបស់តថាគត ដល់នូវភាពជាបរមត្ថបារមី ។

កាលព្រះមហាសត្វទ្រង់ផ្សាយមេត្តា ប្រារព្ធចោររាជនោះ ប្រថាប់គង់ពត់ភ្នែនលើអាកាស ព្រះបាទទព្វសេន ក៏កើតនូវការក្តៅក្រហាយក្នុងព្រះកាយ ទ្រង់ស្រែកថា ក្តៅណាស់ ក្តៅណាស់ ដូច្នេះហើយ ទ្រង់បម្រះនទៀលទៅមកលើផែនដី ត្រាស់ថា នេះមានរឿងអ្វី ពួករាជបុរសទូលថា បពិត្រមហារាជ ទ្រង់ត្រាស់ឲ្យកប់ព្រះរាជាដែលទ្រទ្រង់នូវធម៌ មិនមានកំហុសក្នុងរណ្តៅ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកប្រញាប់នាំព្រះរាជាឡើងមក ។ ពួករាជបុរសទៅឃើញព្រះរាជានោះ គង់ពត់ភ្នែនលើអាកាស ទើបត្រឡប់មក

ទូលដល់ព្រះបាទទព្វសេន ព្រះបាទទព្វសេន ប្រញាប់យាងទៅថ្វាយបង្គំ សូមខមាទោសហើយត្រាស់ថា សូមទ្រង់គ្រងរាជសម្បត្តិរបស់ព្រះអង្គចុះ ។ ទូលបង្គំនឹងការពារពួកចោរដល់ព្រះអង្គ ហើយត្រាស់ឲ្យដាក់អាជ្ញាដល់អមាត្យអាក្រក់ យាងត្រឡប់ទៅកាន់ព្រះនគរវិញ ។ ព្រះពោធិសត្វ ក៏ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ពួកអមាត្យ ហើយទ្រង់បួសជាឥសី ញុំាងមហាជនឲ្យតាំងនៅក្នុងគុណ មានសីលជាដើម កាលអស់អាយុហើយ ក៏ទៅកាន់ព្រហ្មលោក ។ ព្រះបាទទព្វសេន ក្នុងកាលនោះ បានមកជាព្រះអានន្ទត្ថេរ ក្នុងកាលឥឡូវនេះ ព្រះបាទឯករាជ ក្នុងកាលនោះ បានមកជាព្រះលោកនាថ ក្នុងកាលឥឡូវនេះ ។

គប្បីជ្រាបទានបារមី ដោយការលះទ្រព្យ ៦ សែន ក្នុងរោងទាន ៦ កន្លែង រាល់ៗ ថ្ងៃ របស់ព្រះពោធិសត្វនោះ និងដោយការបរិច្ចាគរាជ-សម្បត្តិទាំងអស់ ដល់ព្រះរាជាជាសត្រូវ គប្បីជ្រាបសីលបារមីដោយការរក្សាសីល និងឧបោសថសីលជានិច្ច និងដោយការសង្រួមសីលគ្រប់គ្រាន់របស់អ្នកបួស គប្បីជ្រាបនេក្ខម្មបារមី ដោយការចេញបួស និងដោយការបានសម្រេចឈាន គប្បីជ្រាបបញ្ញាបារមី ដោយការពិចារណាដល់ប្រយោជន៍ និងរបស់មិនជាប្រយោជន៍នៃសត្វទាំងឡាយ និងដោយការចាត់ចែងទាន និងសីលជាដើម គប្បីជ្រាបវីរិយបារមី ដោយការខ្នះខ្នែងសន្សំបុណ្យ មានទានជាដើម និងដោយការបន្ទោបង់កាមវិតក្កជាដើម គប្បីជ្រាបខន្តិបារមី ដោយការអត់ធ្មត់ក្នុងកំហុសរបស់អមាត្យអាក្រក់ និងរបស់ព្រះបាទទព្វសេន គប្បី

ជ្រាបសច្ចបារមីដោយការមិនគេចកែ ដោយការឲ្យជាដើមតាមប្តេជ្ញា គប្បីជ្រាបអធិដ្ឋានបារមី ដោយអធិដ្ឋានការសមាទានមិនញាប់ញ័រ ចំពោះការឲ្យជាដើម គប្បីជ្រាបមេត្តាបារមី ដោយការធ្វើវត្ថុដែលជាប្រយោជន៍ដល់សត្រូវដោយចំណែកមួយ និងដោយការញ៉ាំងមេត្តាឈានឲ្យកើត និងគប្បីជ្រាបឧបេក្ខាបារមី ព្រោះមានព្រះហឫទ័យស្មើ ក្នុងកំហុសដែលអមាត្យលាមកធ្វើ និងព្រះបាទទព្វសេនធ្វើ ក្នុងឧបការៈដែលពួកអ្នកស្វែងរកប្រយោជន៍ មានអមាត្យរបស់ព្រះអង្គជាដើមឲ្យកើតឡើង ទ្រង់ព្រងើយកន្តើយក្នុងការដែលដល់នូវសេចក្តីសុខក្នុងរាជសម្បត្តិ ក្នុងគ្រាដែលត្រូវព្រះរាជាជាសត្រូវកប់ក្នុងរណ្តៅ សមដូចលោកពោលថា

បពិត្រព្រះជនិន្ទ្រ ពួកសប្បុរស បន្ទោបង់នូវជួសុខដោយទុក្ខ
បន្ទោបង់នូវសេចក្តីទុក្ខ ដែលបុគ្គលគ្របសង្កត់មិនបាននោះ
ដោយសារឈានសុខ ជាអ្នកមានចិត្តត្រជាក់ ស្មើក្នុងសេចក្តីសុខ
និងទុក្ខទាំង ២ យ៉ាង ដូច្នេះ ។

ក្នុងចរិយានេះ មេត្តាបារមីជាកំពូលក្រៃលែង ហេតុនោះ ដើម្បីសម្តែងសេចក្តីនោះ ទើបលោកលើកមេត្តាបារមីប៉ុណ្ណោះឡើងកាន់បាលី ម្យ៉ាងទៀតក្នុងចរិយានេះ គប្បីពោលចំពោះដល់គុណវិសេស មានភាពជាអ្នកអនុគ្រោះស្មើគ្នាជាដើម ក្នុងសព្វសត្វរបស់ព្រះមហាសត្វ ដូចបុត្រកើតអំពីទ្រូងដូច្នោះ ដោយប្រការយ៉ាងនេះ ។ល។

# សុត្តន្តបិដក

## មហាលោមហំសចរិយាទី ១៥

[ ៣៥ ] តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយសម្ដែងនូវប្រការដ៏ប្លែកច្រើនយ៉ាង ។ ពួកក្មេងដទៃជាអ្នកជីងការណ៍ ( ឃើញទារកទាំងឡាយ ) ក៏សប្បាយរីករាយ មានចិត្តសង្វេគ ទៅនាំយកគ្រឿងក្រអូប ផ្កាកម្រង ភោជនផ្សេងៗ ដ៏ច្រើន និងគ្រឿងបណ្ណាការ មកឲ្យតថាគត ។ ពួកក្មេងអ្នកស្រុកណា នាំយកសេចក្ដីទុក្ខមកឲ្យតថាគត ពួកក្មេងអ្នកស្រុកណា ឲ្យសេចក្ដីសុខដល់តថាគត តថាគតមានចិត្តស្មើ ចំពោះទារកទាំងអស់នោះ មិនអាណិត មិនក្រោធ ។ តថាគតមានចិត្តជាកណ្ដាល ក្នុងសុខ និងទុក្ខ ក្នុងយស និងអយស តថាគតមានចិត្តស្មើ ក្នុងលោកធម៌ទាំងពួង នេះជាឧបេក្ខាបារមីរបស់តថាគត ។

**មហាលោមហំសចរិយាទី ១៥ ចប់**

# ឧទ្ទាននៃចរិយានោះ

យុធញ្ជយចរិយា ១ សោមនស្សចរិយា ១ អយោឃរចរិយា ១ ភិសចរិយា ១ សោណនន្ទបណ្ឌិតចរិយា ១ មូគផក្ខចរិយា ១ កបិលរាជចរិយា ១ សច្ចសវ្ហយបណ្ឌិតចរិយា ១ វដ្តកបោតក-ចរិយា ១ មច្ឆរាជចរិយា ១ កណ្ហទីបាយនចរិយា ១ សុត-សោមចរិយា ១ សុវណ្ណសាមចរិយា ១ ឯករាជចរិយា ១ លោមហំសចរិយា ១ ព្រះមហេសីសម្ពុទ្ធ ទ្រង់សម្តែងហើយដោយប្រការដូច្នេះ ។

តថាគតរងទុក្ខច្រើនប្រការ សោយសម្បត្តិច្រើនប្រការ ក្នុងភពតូចភពធំ ដូចបានរៀបរាប់មកយ៉ាងនេះ ហើយបានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតបានឲ្យទានដែលព្រះពោធិសត្វគប្បីឲ្យ ទាំងបំពេញសីលមិនមានសេសសល់ ហើយចេញទៅកាន់មហាភិនិស្រ្កមណ៍ បានដល់ បារមីសម្រេចនូវសម្ពោធិញ្ញាណ ជាញាណដ៏ឧត្តម ។ តថាគតបានសាកសួរបណ្ឌិតទាំងឡាយ បានធ្វើព្យាយាមដ៏ឧត្តម បានដល់ ខន្តិបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតបានធ្វើអធិដ្ឋានយ៉ាងមាំ បានរក្សាសច្ចៈ បានដល់ មេត្តាបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតមានចិត្តស្មើ ក្នុងលោកធម៌ទាំងពួង គឺលាភ អលាភ យស អយស សេចក្តីរាប់អាន និងសេចក្តីមើលងាយ ហើយបានសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។

អ្នកទាំងឡាយ គួរឃើញនូវកោសជ្ជៈ ថាជាភ័យ គួរឃើញនូវការប្រារព្ធព្យាយាម ថាជាសេចក្តីក្សេម ហើយប្រឹងប្រែងព្យាយាមចុះ នេះជា

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយគួរឃើញនូវការទាស់ទែង ជាជាភ័យ គួរឃើញនូវការមិនទាស់ទែង ជាជាសេចក្តីក្សេម ហើយចូរព្រមព្រៀងគ្នា ទាំងជាបុគ្គលមានពាក្យពីរោះរកគ្នាចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ មួយទៀត អ្នកទាំងឡាយគួរឃើញនូវសេចក្តីប្រមាទ ជាជាភ័យ គួរឃើញនូវសេចក្តីមិនប្រមាទ ជាជាសេចក្តីក្សេម ហើយចូរចម្រើនមគ្គប្រកបដោយអង្គ ៨ ចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

បានឮថា ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរ នូវបុព្វចរិយារបស់ព្រះអង្គ ហើយសម្តែងនូវធម្មបរិយាយ ឈ្មោះពុទ្ធាបទាន ដោយប្រការដូច្នេះ ។

## ចរិយាបិដក ចប់

# អដ្ឋកថា

## មហាលោមហំសចរិយា

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាលោមហំសចរិយាទី ១៥ ដូចតទៅ បទថា **សុសានេ សេយ្យំ កប្បេមិ** នេះ មានរឿងដូច្នេះ បានឮថា ក្នុងកាលនោះ ព្រះមហាសត្វកើតក្នុងត្រកូលមានភោគៈច្រើន ធំដឹងក្តីហើយ នៅជាមួយគ្រូក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ សម្រេចសិប្បៈគ្រប់យ៉ាង ត្រឡប់មកកាន់ផ្ទះរបស់ត្រកូល កាលមាតាបិតាអនិច្ចកម្មទៅហើយ សូម្បីពួកញាតិអង្វរថា សូមលោកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអ្នកកើតសង្វេគក្នុងភាវៈទាំងពួង ដោយមនសិការដល់ភាពជារបស់មិនទៀង បាននូវអសុភសញ្ញាក្នុងកាយ មិនប្រកាន់ក្នុងកិលេសដែលធ្វើឲ្យមានកង្វល់ ក្នុងការគ្រប់គ្រងផ្ទះ ចម្រើននូវអធ្យាស្រ័យក្នុងនេក្ខម្មៈ ដែលសន្សំមកអស់កាលយូរ បំណងនឹងលះភោគៈធំចេញបួស ទើបគិតថា បើអញបួស នឹងជាអ្នកមិនប្រាកដដោយការលើកតម្កើងខាងគុណធម៌ ។

ព្រះមហាសត្វ វៀរសក្នុងលាភ និងសក្ការៈ មិនចូលទៅបួស ត្រិះរិះដល់ខ្លួនថា អាត្មាអញគ្រប់គ្រាន់ដើម្បីភាពជាអ្នកមិនខុសប្រក្រតី ក្នុងលាភ និងការវិនាសលាភជាដើម ទើបគិតថា អាត្មាអញបំពេញបដិបទា មានការអត់ធន់នឹងពាក្យចំអករបស់អ្នកដទៃជាដើម យ៉ាងពិសេស នឹងញុំាងឧបេក្ខាបារមីឲ្យដល់ទីបំផុត ទើបចេញអំពីផ្ទះដោយសំពត់មួយផ្ទាំង ដែលស្លៀកនោះឯង ជាអ្នកប្រព្រឹត្តសល្លេខធម៌យ៉ាងក្រៃលែង មានកម្លាំង ក៏ធ្វើជាអ្នកអស់កម្លាំង មិនល្ងង់ ក៏ធ្វើជាល្ងង់ ត្រូវអ្នកដទៃចំអកដោយរូបរាងដែលមិនមាន

ចិត្ត ត្រាច់ទៅក្នុងស្រុក និគម និងរាជធានី ដោយនៅត្រឹមតែម្នាក់ឯងប៉ុណ្ណោះ ។ ក្នុងទីណា បានទទួលការបំរអកច្រើន ក៏នៅក្នុងទីនោះយូរ កាលសំពត់ស្លៀកចាស់ សំពត់នោះ នឹងចាស់រហូតជាកន្ទប ក៏មិនទទួលសំពត់ដែលអ្នកដទៃឲ្យ ត្រាច់ទៅដោយសំពត់ត្រឹមតែបិទបាំងអវយវៈ ញុំាងហិរិមិនឲ្យកម្រើកប៉ុណ្ណោះ កាលពេលវេលាកន្លងទៅយ៉ាងនេះ បានដល់ និគមមួយ ។

ក្នុងទីនោះ ក្មេងអ្នកស្រុក និស្ស័យអ្នកលេង ចូលចិត្តវាយតប់ ក្មេងខ្លះ ជាបុត្រ ជាចៅ និងទាសៈជាដើមរបស់ពួករាជវល្លភៈ ជាមនុស្សរឹងត្អឹងគ្រោតគ្រាត ឡេះឡោះ មាត់រឹង ពោលចាក់ដោត ដើរលេងសព្វកាល ។ ក្មេងអ្នកស្រុកទាំងនោះ ឃើញបុរស និងស្ត្រីដែលជាមនុស្សចាស់ ក្រីក្រ ក៏បាចធូលីលើខ្នង សំយុងស្លឹករំពេចទុកក្នុងចន្លោះក្លៀក សម្តែងអាការលេងដោយអកប្បកិរិយាមិនសមគួរ គួរតិះដៀល ហើយសើចលេង ។ ព្រះមហាបុរសឃើញក្មេងអ្នកលេងទាំងនោះ ត្រាច់ទៅក្នុងនិគមនោះ ទើបគិតថា ឥឡូវនេះ អញបានឧបាយជាគ្រឿងបំពេញឧបេក្ខាបារមីហើយ ទើបនៅក្នុងទីនោះ ។ ពួកក្មេងអ្នកលេង ឃើញមហាបុរសនោះ ទើបផ្តើមនូវអំពើមិនសមរម្យ ។

ព្រះមហាសត្វក្រោកឡើង ដើរទៅធ្វើហាក់ដូចជាអត់ធន់មិនបាន និងធ្វើហាក់ដូចជាខ្លាចក្មេងទាំងនោះ ពួកក្មេងទាំងនោះ ក៏តាមព្រះពោធិសត្វទៅ ។ ព្រះពោធិសត្វ កាលត្រូវក្មេងទាំងនោះតាមទៅ ក៏ទៅដល់ព្រៃស្មសាន ដោយយល់ឃើញថា ព្រៃខ្មោចនេះ គង់មិនមានអ្នករំខាន យកគ្រោងឆ្អឹងធ្វើជាខ្នើយ

កើយ ហើយដេក ។ ពួកក្មេងអ្នកលេងក៏នាំគ្នាទៅដល់ក្នុងព្រៃខ្មោចនោះ ធ្វើនូវអំពើមិនសមគួរច្រើនយ៉ាង មានការស្តោះទឹកមាត់ជាដើម ហើយក៏ត្រឡប់ទៅ ពួកក្មេងអ្នកលេងធ្វើយ៉ាងនេះរាល់ថ្ងៃ ។ មនុស្សដែលជាវិញ្ញូជន ឃើញក្មេងធ្វើយ៉ាងនោះក៏ឃាត់ ដឹងថា បុគ្គលនេះ មានអានុភាពច្រើន មានតបៈជាមហាយោគី ទើបនាំគ្នាធ្វើសក្ការៈគោរពរាប់អានយ៉ាងច្រើន ។ ចំណែកព្រះមហាសត្វក៏ញុំាងចិត្តឲ្យនៅជាកណ្តាលគ្រប់យ៉ាង ដូចព្រះមានព្រះភាគត្រាស់ថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសព
ក្នុងព្រៃស្មសាន ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សុសានេ សេយ្យំ កប្បេមិ ឆវដ្ឋិកំ ឧបនិធាយ** សេចក្តីថា តថាគតដេកក្នុងព្រៃខ្មោចនោះ ព្រោះតថាគតមានចិត្តស្មើ ក្នុងវត្ថុដែលស្អាត និងមិនស្អាត ទើបយកឆ្អឹងដែលខ្ចាត់ខ្ចាយក្នុងទីនោះៗ អំពីសាកសពដែលគេចោលក្នុងព្រៃខ្មោច ដែលឆ្កែស្រុក និងឆ្កែចចកជាដើមកកេរ ធ្វើឆ្អឹងមួយកំណាត់ជាខ្នើយកើយ ។ បទថា **គាមមណ្ឌលា** បានដល់ក្មេងអ្នកស្រុក ។ បទថា **រូបំ ឧស្សេន្តិនប្បកំ** សេចក្តីថា ក្មេងអ្នកស្រុកទាំងនោះ ធ្វើនូវការមិនសមគួរ ធ្វើនូវការគ្រោតគ្រាតច្រើនយ៉ាង ដោយការស្តោះទឹកមាត់ សើចចំអក និងបន្ទោបង់បស្សាវៈជាដើម និងដោយការដណ្តើមគ្នាយកស្មៅជាដើម រុកចូលក្នុងត្រចៀករបស់ព្រះពោធិសត្វ លេងតាមគាប់ចិត្ត ។

បទថា **អបរេ** បានដល់ ក្មេងអ្នកស្រុកទាំងនោះ ពួកខ្លះ ។ បទថា

**ឧចាយនាន្ធបនេន្តិ** សេចក្តីថា ក្មេងអ្នកស្រុកទាំងនោះ សង្កេតមើលថា បុរសនេះ កាលក្មេងទាំងនេះធ្វើមិនសមគួរបែបនេះ ដោយការចំអក មិនសម្តែងការខុសប្រក្រតីណាមួយឡើយ បើបានទទួលការរាប់អាន តើដូចម្តេចហ្ន៎ ទើបនាំគ្នាយកគ្រឿងក្រអូប ផ្កា អាហារច្រើនយ៉ាង និងគ្រឿងបណ្ណាការដទៃមកឲ្យ ។ ឬថា មនុស្សដែលជាវិញ្ញូជនដទៃ ក្រៅអំពីក្មេងអ្នកស្រុកដែលឥតមារយាទទាំងនោះ ត្រេកអរថា បុរសនេះ កាលក្មេងទាំងនេះធ្វើអំពើមិនសមគួរច្រើនយ៉ាង យ៉ាងនេះ ក៏មិនក្រោធ ត្រឡប់ចូលទៅតាំងខន្តី មេត្តា និងការអាណិតអាសូរក្នុងក្មេងទាំងនោះ ឱ អច្ឆរិយបុរស មានចិត្តសង្វេគថា កុមារទាំងនេះ បដិបត្តិខុសក្នុងបុរសបែបនេះ ដែលជាអ្នកខ្វល់ខ្វាយ នឹងមានបាបច្រើនហ្ន៎ ទើបនាំគ្រឿងក្រអូប ផ្កាកម្រងជាច្រើន អាហារច្រើនយ៉ាង និងគ្រឿងសក្ការៈដទៃចូលមកឲ្យ ។

បទថា **យេ មេ ទុក្ខំ ឧបហរន្តិ** សេចក្តីថា ក្មេងអ្នកស្រុកពួកណា នាំទុក្ខក្នុងរាងកាយមកឲ្យតថាគត ។ បាឋៈថា **ឧបទហន្តិ** ដូច្នេះក៏មាន ប្រែថា ឲ្យកើត ។ បទថា **យេ ច ទេន្តិ សុខំ មម** សេចក្តីថា មនុស្សដែលជាវិញ្ញូជនពួកណា ឲ្យសេចក្តីសុខដល់តថាគត នាំសេចក្តីសុខមកឲ្យតថាគត ដោយគ្រឿងដែលនាំឲ្យមានសេចក្តីសុខ មានផ្កាកម្រង គ្រឿងក្រអូប និងអាហារជាដើម ។ បទថា **សព្វេសំ សមកោ ហោមិ** សេចក្តីថា តថាគតជាអ្នកមានចិត្តស្មើ គឺដូចគ្នាតែមួយ ដល់ជនទាំងនោះគ្រប់យ៉ាង ព្រោះតថាគតមានចិត្តស្មើ ដោយមិនខុសប្រក្រតីក្នុងទីណាមួយ ។ បទថា **ទយា កោបោ ន វិជ្ជតិ**

សេចក្ដីថា លោកសម្ដែងថា ព្រោះករុណា ពោល គឺមានចិត្តមេត្តាក្នុងបុគ្គល ដែលធ្វើឧបការៈមិនមានដល់តថាគត សូម្បីសេចក្ដីក្រោធ ពោល គឺការប្រទូស្ត ផ្លូវចិត្ត ក្នុងបុគ្គលមិនធ្វើឧបការៈ ក៏មិនមាន ហេតុនោះ ទើបតថាគត ជាអ្នក មានចិត្តស្មើ ដល់ជនទាំងពួង ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្ដែងដល់ការមិនខុសប្រក្រតី និង ការមិនជាប់ក្នុងលោកធម៌ទាំងឡាយ ព្រោះទ្រង់សន្សំញាណសម្ភារ ទើបមាន ហទយៈស្មើក្នុងសត្វទាំងឡាយ ទាំងមានឧបការៈ និងមិនមានឧបការៈ ក្នុង កាលនោះ ទើបត្រាស់គាថាចុងក្រោយថា

តថាគត មានចិត្តជាកណ្ដាល ក្នុងសុខ និងទុក្ខ ក្នុងយស និង
អយស តថាគត មានចិត្តស្មើក្នុងលោកធម៌ទាំងពួង នេះជា
ឧបេក្ខាបារមីរបស់តថាគត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សុខទុក្ខេ** បានដល់ ក្នុងសុខ និងក្នុងទុក្ខ ។ បទថា **តុលាភូតោ** បានដល់ ជាអ្នកដាក់ខ្លួនជាកណ្ដាល វៀរការត្រេកអរ និងការមិនត្រេកអរ គឺមិនសោមនស្ស មិនទោមនស្ស ដូចជញ្ជីងដែលថ្លឹង ស្មើគ្នា ម្យ៉ាងទៀត សព្ទថា **សុខទុក្ខ** ក្នុងបទ **សុខទុក្ខេ** នេះ គប្បីជ្រាបថា សំដៅដល់លាភ និងការវិនាសលាភ ព្រោះមានសុខទុក្ខនោះជាហេតុ ។ បទ ថា **យសេសុ** បានដល់ ក្នុងកិត្តិយស ។ បទថា **អយសេសុ** បានដល់ ក្នុង និន្ទា ។ បទថា **សព្វត្ថ** សេចក្ដីថា ក្នុងលោកធម៌ទាំងអស់ មានសុខជាដើម ដោយប្រការដូច្នេះ ។ ក្នុងកាលនោះ ព្រះមានព្រះភាគ កាលសម្ដែងភាព

ដែលព្រះអង្គមានខ្លួនជាកណ្តាលក្នុងសព្វសត្វ និងក្នុងលោកធម៌ទាំងពួង មិនទូទៅដល់អ្នកដទៃ កាលទ្រង់ប្រកាសភាពដែលព្រះអង្គដល់កំពូលនៃឧបេក្ខា-បារមី ក្នុងអត្តភាពនោះ ដោយបទនោះ ទើបទ្រង់បញ្ចប់ទេសនាដោយបទថា នេះជាឧបេក្ខាបារមីរបស់តថាគត ដូច្នេះ ។

ក្នុងចរិយានេះ ព្រះមហាសត្វរមែងបានបារមី ១០ គ្រប់គ្រាន់ដោយចំពោះ គឺទានបារមី ការបរិច្ចាគសម្បត្តិទាំងពួង និងការបរិច្ចាគអត្តភាពរបស់ខ្លួន ដោយមិនពិចារណាថា បុគ្គលណាមួយកាន់យកសរីរៈនេះ ហើយចូរធ្វើយ៉ាងណាមួយតាមដែលខ្លួនប្រាថ្នា នេះជាទានបារមី ការមិនធ្វើវត្ថុដែលមិនគួរធ្វើទាំងពួង មានអំពើអាក្រក់ជាដើម ជាសីលបារមី ។ ការចម្រើនអសុភសញ្ញា ក្នុងកាយរបស់ព្រះពោធិសត្វ ដែលបែរខ្នងអំពីសេចក្តីត្រេកអរក្នុងកាម ចេញចាកផ្ទះ ជានេក្ខម្មបារមី ភាពជាអ្នកឈ្លាសក្នុងការកំណត់ធម៌ជាឧបការៈដល់ពោធិសម្ភារ និងក្នុងការលះធម៌ ដែលជាបដិបក្ខចំពោះឧបការធម៌នោះ និងការគិតដល់សភាវធម៌ ចាកធម៌ដែលមិនវិបរិត ជាបញ្ញា-បារមី ។ ការបន្ទោបង់កាមវិតក្កជាដើម និងការព្យាយាមអត់ធន់ចំពោះសេចក្តីទុក្ខ ជាវីរិយបារមី ការអត់ធ្មត់ ដោយការអត់ធន់ទាំងអស់ ជាខន្តិបារមី វាចាពិត និងពិតដោយការវៀរ ដោយមិនខុសអំពីការសមាទាន ជាសច្ច-បារមី ការតាំងចិត្តសមាទានមិនញាប់ញ័រ ក្នុងធម៌ដែលមិនមានទោស ជាអធិដ្ឋានបារមី ភាពជាអ្នកមានមេត្តា និងការអាណិតអាសូរក្នុងសព្វសត្វដោយមិនចំពោះ ជាមេត្តាបារមី ចំណែកឧបេក្ខាបារមីរបស់ព្រះពោធិសត្វនោះគប្បីជ្រាបតាមដែលពោលហើយនោះឯង ។ម្យ៉ាងទៀត ក្នុងចរិយានេះ

លោកធ្វើឧបេក្ខាបារមី ឲ្យជាបារមីកំពូល ទើបលើកឧបេក្ខាបារមីនោះឡើងកាន់ទេសនា ។

ម្យ៉ាងទៀត ក្នុងចរិយានេះ គប្បីប្រកាសគុណានុភាពរបស់ព្រះមហាសត្វយ៉ាងនេះ គឺការលះបង់គំនរភោគសម្បត្តិធំ និងវង្សញាតិធំ ហើយចេញអំពីផ្ទះ ដូចការចេញមហាភិនេស្រ្កមណ៍ ការចេញហើយវៀរសន្ទូវលោកនិងសក្ការៈ ដើម្បីចៀសវាងការរាប់អានរបស់អ្នកដទៃ ទើបមិនកាន់យកភេទបព្វជា អធិដ្ឋានបព្វជាគុណទាំងអស់ដោយចិត្តប៉ុណ្ណោះ នៅជាសុខក្រៃលែងដោយភាពជាអ្នកប្រាថ្នាតិចក្រៃលែង ត្រេកអរក្រៃលែងក្នុងការស្ងាត់ មិនអាឡោះអាល័យដល់កាយ និងជីវិតរបស់ខ្លួន ដោយបំណងនឹងព្រងើយកន្តើយ ការអត់ធន់ចំពោះបុគ្គលដែលធ្វើវត្ថុខុសប្រក្រតីដល់ខ្លួន ការប្រព្រឹត្តផុសខាត់កិលេសដ៏ឧក្រិដ្ឋ ការញ៉ាំងខ្លួនឲ្យតាំងមាំដោយភាពជាកណ្ដាលក្នុងទីទាំងពួង ដោយធ្វើឲ្យស្រោលនូវកិលេស ដែលជាបក្ខដិបក្ខចំពោះពោធិសម្ភារ ដែលជាហេតុនៃការមិនខុសប្រក្រតី ក្នុងការធ្វើឧបការៈ និងមិនមានឧបការៈរបស់អ្នកដទៃ ដូចព្រះវីណាស្រេពដូច្នោះ ការមិនប្រឡាក់ប្រឡូសដោយលោកធម៌ទាំងឡាយ ការដល់កំពូលនៃឧបេក្ខាបារមី ដែលជាពុទ្ធបារមីនៃបារមីទាំងពួង ដូច្នេះ ។៚

**អដ្ឋកថាមហាលោមហំសចរិយា ចប់**

**ឧបេក្ខាបារមី ចប់**

**យុគន្ធរវគ្គទី ៣ ចប់**

# អដ្ឋកថា

## ឧទានគាថា

គប្បីជ្រាបវិនិច្ឆ័យក្នុងឧទានគាថាដូចតទៅនេះ ឧទានគាថាមានពាក្យថា **យុធញ្ជយោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កិសេន** លោកសម្តែងមហាកញ្ហចរិយា ដោយឈ្មោះរឿងថា **កិសចរិយា** ។ លោកសម្តែងសោណបណ្ឌិតចរិយា ដោយបទថា **សោណានន្ទោ** នេះ ។ ម្យ៉ាងទៀត បទថា **មូគជក្ខោ** លោកសម្តែងតេមិយបណ្ឌិតចរិយា ដោយឈ្មោះរឿងថា **មូគបក្ខោ** ។ លោកសម្តែងតេមិយបណ្ឌិតចរិយា ដោយឈ្មោះថា **មូគបក្ខ** ។ លោកសម្តែងមហាលោមហំសចរិយា ដោយមាតិកាធម៌ គឺឧបេក្ខាបារមី ។ បទថា **អាសិ ឥតិ វុដ្ឋំ មហេសិនា** អធិប្បាយថា ម្នាលសារីបុត្រ ក្នុងកាលនោះ តថាគតជាព្រះពោធិសត្វឈ្មោះថា **មហេសិនា** ព្រោះស្វែងរកពោធិសម្ភារ មានទានបារមីជាដើម ធំដោយវិធីនេះ បានប្រព្រឹត្តបដិបត្តិមកហើយ ដូចសម្តែងដល់អ្នកក្នុងកាលឥឡូវនេះឯង ។ ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្តែងដល់ប្រយោជន៍ដែលទ្រង់បំពេញបារមី ទ្រង់ធ្វើទុក្ករកិរិយា របស់ព្រះអង្គដែលពោលហើយ និងមិនទាន់បានពោលក្នុងទីនេះ ដែលប្រព្រឹត្តទៅអស់កាលយូរ ដោយការបំពេញបារមីឲ្យបរិបូណ៌រួមគ្នាតែមួយ ដោយសង្ខេបប៉ុណ្ណោះ ទើបត្រាស់គាថានេះថា **ឯវំ ពហុព្វិធំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឯវំ** បានដល់ ដោយន័យដូចពោលហើយនេះ ។ បទថា **ពហុព្វិធំ ទុក្ខំ** សេចក្តីថា ទុក្ខច្រើនយ៉ាង ច្រើនប្រការ ព្រោះអាហារ

មានស្លឹកដង្កៀបក្តាមជាដើម កាលនៅជាអកិត្តិបណ្ឌិតជាដើម និងដោយការអត់អាហារជាដើម ព្រោះឲ្យស្លឹកដង្កៀបក្តាមនោះដល់យាចក ។ មួយវិញទៀត កាលជាព្រះបាទកុរុជាដើម សម្បត្តិមានច្រើន ដែលដូចគ្នានឹងសម្បត្តិនៃសក្កទេវរាជ ។ បទថា **ភវាភវេ** បានដល់ ភពតូចភពធំ ឬសោយសេចក្តីចម្រើន និងសេចក្តីវិនាស ក្នុងភពតូចភពធំ មិនក្តៅក្រហាយដោយទុក្ខច្រើនយ៉ាង មិនត្រូវអួសទាញដោយសម្បត្តិច្រើនយ៉ាង ជាអ្នកខ្វល់ខ្វាយក្នុងការបំពេញបារមី បដិបត្តិបដិបទាដែលសមគួរដល់បារមីនោះ សម្រេចអនុត្តរសម្មាសម្ពោធិញាណដ៏ឧត្តម គឺសព្វញ្ញុតញ្ញាណ ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីសម្តែងដល់បារមីដែលព្រះអង្គបំពេញទុក្ករកិរិយាអស់កាលយូរ ដើម្បីឲ្យបរិបូណ៌ ឲ្យពេញ ដោយមិនសេសសល់ និងសមិទ្ធិផលដែលទ្រង់បានសម្រេចហើយ ទើបត្រាស់គាថាថា **ឧត្វា ធាតព្វកំ ធានំ សីលំ បូរេត្វា អសេសតោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧត្វា ធាតព្វកំ ធានំ** សេចក្តីថា ក្នុងកាលនោះ តថាគតបានលះទេយ្យធម៌ មានរាជសម្បត្តិជាដើម ខាងក្រៅអវយវៈ និងភ្នែកជាដើមខាងក្នុង ដែលគួរឲ្យ ដែលព្រះមហាពោធិសត្វបដិបត្តិមក ដែលជាយានដ៏ប្រសើរ ដើម្បីសម្រេចអនុត្តរសម្មាសម្ពោធិញាណ បន្ទាប់អំពីនោះ បានបរិច្ចាគទាន ដែលចែកជាទានបារមី ទានឧបបារមី ទានបរមត្ថបារមី មានមហាបរិច្ចាគ ៥ ជាទីបំផុត គឺបរិច្ចាគរាជសម្បត្តិ ១ បរិច្ចាគអវយវៈ ១ បរិច្ចាគភ្នែក ១ បរិច្ចាគបុត្រភរិយា ១ បរិច្ចាគខ្លួន ១ ដោយ

មិនសេសសល់ ។ មិនមានប្រមាណនៃអត្តភាព ដែលមហាបុរសបំពេញទានបារមី ក្នុងកាលដែលកន្លងមក ក្នុងចរិយាជាដើមយ៉ាងនេះ គឺក្នុងកាលជាអកិត្តិព្រាហ្មណ៍ ក្នុងកាលជាសង្ខព្រាហ្មណ៍ ក្នុងកាលដែលមិនបានមកក្នុងចរិយានេះ គឺក្នុងកាលជាវិសយ្ហសេដ្ឋី ក្នុងកាលជាវេលាមព្រាហ្មណ៍ជាដើម ។ ទានបារមីរបស់ព្រះពោធិសត្វ កាលជាសសបណ្ឌិត លះបង់ខ្លួនយ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន ជារបស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទានរបស់តថាគត មិនមានឡើយ នេះជាទានបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ឯក្នុងបារមីក្រៅអំពីនោះគប្បីជ្រាបថា ជាបារមី និងឧបបារមីតាមសមគួរ ។

បទថា **សីលំ បូរេត្វា អសេសតោ** សេចក្ដីថា ដែលបុគ្គលបំពេញសីលរបស់ព្រះពោធិសត្វ មានកាយសំវរៈ វចីសំវរៈ និងសង្រួមទាំងកាយទាំងវាចា សង្រួមឥន្រ្ទិយ ស្គាល់ប្រមាណក្នុងការបរិភោគ មានអាជីវៈបរិសុទ្ធគួរបំពេញបារមី ដែលមានប្រភេទជាសីលបារមី សីលឧបបារមី សីល-បរមត្ថបារមី ញ៉ាំងសីលទាំងពួងឲ្យបរិបូណ៌ គឺឲ្យដល់ព្រមដោយប្រពៃដោយមិនមានសេសសល់ ។ ក្នុងទីនេះ ក៏មិនមានប្រមាណនៃអត្តភាពដែលព្រះមហាសត្វបំពេញសីលបារមី ក្នុងការដែលមកហើយ ក្នុងចរិយានេះមានក្នុងកាលជាសីលវនាគរាជ ( ដំរីអ្នកមានសីល ) ក្នុងកាលចម្បេយ្យ-នាគរាជ និងក្នុងកាលដែលមិនបានមក ( ក្នុងចរិយា ) គឺក្នុងកាលជា

មហាពានរ ក្នុងកាលជាដំរីឆទ្ទន្តជាដើម ។ សីលបារមីនៃព្រះពោធិសត្វ កាលជាសង្ខបាល ដែលលះបង់ខ្លួនយ៉ាងនេះថា

តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច នឹងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។ ឯបារមីក្រៅអំពីនេះ គប្បីជ្រាបថា ជាបារមី និងឧបបារមីតាមសមគួរ ។

បទថា **នេក្ខម្មេ ចារមី គន្ត្វា** សេចក្តីថា ដល់នូវបារមីក្នុងការចេញបួសដ៏ធំ ៣ យ៉ាង ឧក្រិដ្ឋក្រៃលែង ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាពដែលព្រះមហាសត្វលះរាជសម្បត្តិធំ ហើយបំពេញនេក្ខម្មបារមី ក្នុងកាលកន្លងមកហើយ ក្នុងចរិយានេះយ៉ាងនេះ គឺក្នុងកាលជាយុធញ្ជយបណ្ឌិត ក្នុងកាលជាសោមនស្សកុមារ និងកាលដែលមិនបានលើកមកពោល គឺក្នុងកាលជាហត្ថិបាលកុមារ ក្នុងកាលជាមឃទេវៈជាដើម ។ មួយវិញទៀត នេក្ខម្មបារមីរបស់ព្រះមហាសត្វនោះ ដែលលះរាជសម្បត្តិ ចេញបួស កាលជាចូឡសុតសោម ព្រោះមិនជាប់ជំពាក់យ៉ាងនេះថា

តថាគតលះរាជសម្បត្តិធំ ដែលនៅក្នុងកណ្តាប់ដៃ ដូចដុំទឹកមាត់ កាលតថាគតលះបង់ ក៏មិនជាប់ជំពាក់ នេះជានេក្ខម្មបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។ ឯបារមីក្រៅអំពីនេះ គប្បី

ជ្រាបថា ជាបារមី និងឧបបារមីតាមសមគួរ ។

បទថា **បណ្ឌិតេ បរិបុច្ឆិត្វា** សេចក្តីថា តថាគតសាកសួរដល់ការវែកធម៌ មានកុសលជាដើម ការវែកកម្ម និងផលនៃកម្ម កម្ម សិប្បៈ វិជ្ជា ដែលមិនមានទោស ដែលនាំមកនូវឧបការៈដល់សត្វទាំងឡាយ ជាមួយនឹងបណ្ឌិតអ្នកមានបញ្ញា ដោយន័យថា អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីមិនមានទោស ដូច្នេះជាដើម ។ ដោយបទនេះ លោកសម្តែងដល់បញ្ញាបារមី ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាព ដែលព្រះមហាសត្វបំពេញបញ្ញាបារមី ក្នុងកាលជាវិធុរបណ្ឌិត ក្នុងកាលជាមហាគោវិន្ទបណ្ឌិត ក្នុងកាលជាកុទ្ទាលបណ្ឌិត ក្នុងកាលជាអរកបណ្ឌិត ក្នុងកាលជាពោធិ-បរិព្វាជក ក្នុងកាលជាមហោសថបណ្ឌិតជាដើម ។ ម្យ៉ាងទៀត បញ្ញាបារមីរបស់ព្រះពោធិសត្វនោះ ក្នុងកាលជាសេនកបណ្ឌិត ដែលបង្ហាញពស់ក្នុងស្បោងថា

> តថាគតឈ្វេងយល់ដោយបញ្ញា ដោះព្រាហ្មណ៍អំពីទុក្ខ បុគ្គលស្មើដោយបញ្ញារបស់តថាគតមិនមាន នេះជាបញ្ញាបារមីរបស់តថាគត ដូច្នេះ ។

នេះ ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **វីរិយំ កត្វាន ឧត្តមំ** សេចក្តីថា ធ្វើវីរិយបារមីតែម្យ៉ាងឲ្យកើត គឺបានវីរិយៈដ៏ឧត្តម ព្រោះអាចឲ្យដល់សម្មាសម្ពោធិញ្ញាណបាន ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាព ដែលព្រះមហាសត្វបំពេញវីរិយបារមីក្នុង

កាលជាមហាសីលវរាជ ក្នុងកាលជាបញ្ចាវុធកុមារ ក្នុងកាលជាមហាពានរជាដើម ។ ម្យ៉ាងទៀត វីរិយបារមីរបស់ព្រះពោធិសត្វនោះ ក្នុងកាលជាព្រះមហាជនក ហែលឆ្លងមហាសមុទ្រ យ៉ាងនេះថា

តថាគតនៅកណ្ដាលមហាសមុទ្រ មើលមិនឃើញត្រើយ ពួកមនុស្សទាំងឡាយ ស្លាប់អស់ហើយ តថាគតមិនមានចិត្តដទៃ នេះជាវីរិយបារមីរបស់តថាគត ដូច្នេះ ។

នេះ ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **ខន្តិយា ចារមី គន្ត្វា** សេចក្ដីថា តថាគតសម្រេចអធិវាសនខន្តីជាដើម ដែលមានសភាពជាខន្តីដ៏ឧក្រិដ្ឋ ដល់នូវខន្តិបារមីដ៏កំពូល អធិប្បាយថា ញ៉ាំងខន្តិបារមីឲ្យបរិបូណ៌ ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាព ដែលព្រះមហាសត្វបំពេញខន្តិបារមី ក្នុងកាលជាស្ដេចពានរ ជាស្ដេចក្របី ជារុរុមិគរាជ ជាធម្មទេវបុត្រជាដើម ។ ម្យ៉ាងទៀត ខន្តិបារមីនៃព្រះមហាសត្វនោះ កាលជាខន្តិវាទីតាបស សោយទុក្ខជាពន្លឹក ដូចមិនមានចិត្តយ៉ាងនេះថា

តថាគតមិនក្រោធនឹងព្រះរាជាកាសី ដែលកាប់តថាគតដោយពូថៅដ៏មុត ដូចតថាគតមិនមានចិត្ត នេះជាខន្តិបារមីរបស់តថាគត ដូច្នេះ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **កត្វា ឧឡារមធិដ្ឋានំ** សេចក្ដីថា តថាគតធ្វើអធិដ្ឋានសមាទានកុសល អធិដ្ឋានសមាទានបារមីនោះៗ និងសមាទានធម៌ដែលជាឧបការៈដល់

បារមីនោះ ឲ្យមាំទាំ មិនឲ្យធូរថយ អធិប្បាយថា អធិដ្ឋានសមាទានបដិបទានោះៗ ដោយមិនមានការប្រែប្រួល ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាពនៃព្រះមហាសត្វដែលបំពេញអធិដ្ឋានបារមី ក្នុងកាលយ៉ាងនេះ គឺក្នុងកាលជាជោតិបាល ក្នុងកាលជាសរភង្គ ក្នុងកាលជាព្រះបាទនេមិ ។ម្យ៉ាងទៀត អធិដ្ឋានបារមីរបស់ព្រះពោធិសត្វនោះ កាលជាតេមិយកុមារ អធិដ្ឋានវត្ត លះបង់ជីវិតយ៉ាងនេះថា

មាតាបិតាមិនជាទីស្អប់របស់តថាគតទេ ទាំងខ្លួន ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **សច្ចវាចានុរក្ខិយ** សេចក្តីថា តថាគតតាមរក្សាសច្ចវាចា វៀរវោហារដែលមិនមែនជាអរិយៈ ដូចគ្នានឹងលាមក ក្នុងកាលមានអន្តរាយដល់ជីវិតក៏នៅតែរក្សា គឺរក្សាវាចាដែលមិនខុសប្រក្រតី ដោយប្រការទាំងពួង ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាពរបស់ព្រះមហាសត្វដែលបំពេញសច្ចបារមីក្នុងកាលយ៉ាងនេះ គឺក្នុងកាលជាជាស្តេចពានរ ក្នុងកាលជាសច្ចតាបស ក្នុងកាលជាស្តេចត្រី ។ ម្យ៉ាងទៀត សច្ចបារមីនៃព្រះពោធិសត្វនោះ ក្នុងកាលជាមហាសុតសោម លះបង់ជីវិត តាមរក្សាពាក្យសច្ចៈយ៉ាងនេះថា

តថាគត តាមរក្សាសច្ចវាចា លះបង់ជីវិតរបស់តថាគត ឲ្យបោរិសាទ ដោះលែងក្សត្រ ១០១ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **មេត្តាយ បារមី គតោ** សេចក្តីថា តថាគតដល់នូវមេត្តាបារមី ដែលមានលក្ខណៈនាំមកនូវវត្ថុជាប្រយោជន៍ដល់សព្វសត្វ ដោយមិនចំពោះដែលជាបារមីដ៏ឧក្រិដ្ឋក្រៃលែង ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាពរបស់ព្រះពោធិសត្វ ដែលបំពេញមេត្តាបារមី ក្នុងអត្តភាពយ៉ាងនេះ គឺក្នុងកាលជាចូឡធម្មបាល ក្នុងកាលជាមហាសីលវរាជ ក្នុងកាលជាសាមបណ្ឌិត ។ ម្យ៉ាងទៀត មេត្តាបារមីរបស់ព្រះពោធិសត្វនោះ ក្នុងកាលជាសុវណ្ណសាម ផ្សាយមេត្តាដោយមិនសម្លឹងមើលសូម្បីតែជីវិត យ៉ាងនេះថា

សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគតក៏មិនខ្លាចសត្វណាមួយឡើយ កាលនោះ កម្លាំងមេត្តាឧបត្ថម្ភតថាគតឲ្យតថាគតនៅក្នុងព្រៃដោយសួស្តី ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

បទថា **សម្មាននាវមានេ** សេចក្តីថា តថាគតមានចិត្តស្មើ មិនខុសប្រក្រតី ក្នុងការរាប់អាន ដោយការបូជាសក្ការៈជាដើមដោយគោរព ក្នុងការមើលងាយ ដោយការស្តោះទឹកមាត់ជាដើម និងក្នុងលោកធម៌ទាំងពួង បានសម្រេចសព្វញ្ញុតញ្ញាណដ៏ឧត្តម ។ ក្នុងបទនោះ មិនមានប្រមាណនៃអត្តភាព

ដែលព្រះមហាសត្វបំពេញឧបេក្ខាបារមី ក្នុងកាលជាមហាពានរ ក្នុងកាលជាព្រះបាទកាសី ក្នុងកាលជាខេមព្រាហ្មណ៍ ក្នុងកាលជាអង្គិសេនបរិញ្វជកជាដើម ។ ម្យ៉ាងទៀត ឧបេក្ខាបារមីរបស់ព្រះពោធិសត្វនោះ ក្នុងកាលជាមហាលោមហំស: ទោះបីក្មេងអ្នកស្រុកធ្វើឲ្យកើតសុខ និងទុក្ខ ដោយការស្តោះទឹកមាត់ជាដើម និងដោយការនាំផ្កា គ្រឿងក្រអូបជាដើម ចូលមកបូជា ក៏មិនលះឧបេក្ខាយ៉ាងនេះថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃស្មសាន

ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយ សម្តែងនូវ

ប្រការដ៏ប្លែកច្រើនយ៉ាង ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ដល់ការបំពេញទុក្ករកិរិយាដែលព្រះអង្គទ្រង់ធ្វើហើយ ក្នុងកទុកប្បនេះ ដើម្បីសម្រេចសម្មាសម្ពោធិញ្ញាណ ដោយសង្ខេបថា

តថាគតរងទុក្ខច្រើនប្រការ សោយសម្បត្តិច្រើនប្រការក្នុងភពតូច

ភពធំ ដូចបានរៀបរាប់មកយ៉ាងនេះ ហើយបានសម្រេចនូវ

សម្ពោធិញ្ញាណដ៏ឧត្តម ដូច្នេះ ។

ហើយទ្រង់សម្តែងបារមី ១០ ដែលព្រះអង្គទ្រង់បំពេញដោយប្រពៃទៀតថា

តថាគតបានឲ្យទាន ដែលព្រះពោធិសត្វគប្បីឲ្យ ទាំងបំពេញសីលមិនមានសេសសល់ ហើយចេញទៅកាន់មហាភិនិក្ខមណ៍ បានដល់ បារមី សម្រេចនូវសម្ពោធិញ្ញាណ ជាញាណដ៏ឧត្តម ។ តថាគតបានសាកសួរបណ្ឌិតទាំងឡាយ បានធ្វើព្យាយាមដ៏ឧត្តម បានដល់ ខន្តិបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតបានធ្វើអធិដ្ឋានយ៉ាងមាំ បានរក្សាសច្ចៈ បានដល់ មេត្តាបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតមានចិត្តស្មើក្នុងលោកធម៌ទាំងពួង គឺលាភ អលាភ យស អយស សេចក្តីរាប់អាន និងសេចក្តីមើលងាយ ហើយបានសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ដូច្នេះ ។៙

**អដ្ឋកថាឧទ្ទានគាថា ចប់**

# សមោធានកថា

[ ៣៦ ] បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ បារមីទាំងនេះ ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យបានសម្រេច គឺព្រះបាទសិវិរាជដ៏ប្រសើរ បានបំពេញទានបារមី ព្រះបាទវេស្សន្តរ និងវេលាមព្រាហ្មណ៍ បានបំពេញទានឧបបារមី អកិត្តិតាបស បានបំពេញទានដ៏មានកម្លាំង ហៅថា ទានឧបបារមី កាលតថាគតកើតជាមាន់និងទន្សាយដ៏ប្រសើរ បានបំពេញទានបរមត្ថបារមី ។ កាលតថាគតកើតជាស្តេចស្វាក្តី ជាដំរីឆទ្ទន្តក្តី ជាដំរីចិញ្ចឹមមាតាក្តី បានបំពេញសីលបារមី ពាក្យដូច្នេះនេះ ព្រះមហេសី ទ្រង់សម្តែងហើយ ។ កាលតថាគតកើតជាស្តេចឈ្មោះចម្បេយ្យៈ និងជាស្តេចនាគឈ្មោះភូរទត្ត បានបំពេញសីលឧបបារមី កាលតថាគតកើតជាសង្ខបាលនាគរាជ ជាអ្នកប្រាជ្ញបានបំពេញសីលបរមត្ថបារមី ។ កាលតថាគតកើតជារាជបុត្រ ឈ្មោះយុធញ្ជយក្តី ជាមហាគោវិន្ទក្តី ជាហត្ថិបាលក្តី ជាកូនព្រាហ្មណមហាសាលឈ្មោះអយោឃរៈក្តី ជាកល្លាតិយៈក្តី ជាសុវណ្ណសាមក្តី ជាមឃវទេវបុត្រក្តី ជានេមិរាជក្តី បានបំពេញទានឧបបារមី ។ កាលតថាគតកើតជាមហោសថបណ្ឌិតក្តី ធនវន្តបណ្ឌិតក្តី កុណ្ឌលបណ្ឌិតក្តី តណ្ឌិលបណ្ឌិតក្តី តិត្តិរៈក្តីសកុណៈក្តីទុំះ បានបំពេញបញ្ញាឧបបារមី ។ កាលតថាគតកើតជាវិធុរបណ្ឌិត ជាសម្ភវកុមារក្តី ទាំងពីរទុំះ បានបំពេញបញ្ញាបារមី កាលតថាគតកើតជាសុរិយព្រាហ្មណ៍ក្តី ជាមាតង្គបណ្ឌិតក្តី ដែល

ជាសិស្សអាស្រ័យនូវអាចារ្យក្នុងកាលមុន ក៏បានបំពេញនូវបញ្ញា-បារមីដែរ ។ ឯបញ្ញាបរមត្ថបារមីនុ៎ះឯង ( តថាគតបានបំពេញក្នុងកាលយោនយកកំណើតកើត ) ជាសេនកបណ្ឌិត កាលតថាគតកើតប្រាកដជាស្តេចជនកមានសីល មានព្យាយាម មានការប្រឹងប្រែងយ៉ាងមាំ បានបំពេញវីរិយបរមត្ថបារមី កាលតថាគតកើតជាស្តេចស្វា ជាអ្នកគោរពធម៌ ៥ ប្រការ បានបំពេញវីរិយបារមី ។ កាលតថាគតកើតជាធម្មបាលកុមារ បានបំពេញខន្តិបារមី ជាគ្រឿងញ៉ាំញីដោយធម៌ នូវបុគ្គលមិនប្រកបដោយធម៌ ហៅថា ខន្តិឧប-បារមី ។ កាលតថាគតកើតជាខន្តិវាទីតាបស ស្វែងរកពុទ្ធភូមិ តថាគតបានធ្វើនូវអំពើដ៏កម្រជាច្រើនយ៉ាង ដើម្បីបំពេញនូវខន្តិ-បរមត្ថបារមី ដោយខន្តិវាទ ។ កាលតថាគតកើតជាទន្សាយ និងជាសត្វក្រួច អាស្រ័យនូវគុណ គឺសច្ចៈ ដូចមានខាងលើនោះ បានញ៉ាំងភ្លើងឲ្យរលត់ដោយសច្ចៈ នេះក៏ជាសច្ចបារមី ។ កាលតថាគតកើតជាត្រីនៅក្នុងទឹក បានធ្វើនូវសច្ចៈដ៏ឧត្តម ញ៉ាំងមហាមេឃឲ្យបង្អុរចុះ នេះជាសច្ចបារមីរបស់តថាគត ។ កាលតថាគតកើតជាសុបារបណ្ឌិត ជាអ្នកប្រាជ្ញ បានញ៉ាំងទូកឲ្យឆ្លងដោយសច្ចៈ កាលកើតជាឥសីឈ្មោះកណ្ហទីបាយនៈ បានញ៉ាំងពិសឲ្យសាបរលាបដោយសច្ចៈ កាលកើតជាស្វា បានឆ្លងខ្សែទឹកគង្គា ដោយសច្ចៈ នេះជាបារមីរបស់តថាគត ជាសាស្តាក្នុងកាលនោះ បារមីនោះ

ជាសច្ចឧបបារមី ។ កាលតថាគតកើតជាស្តេចសុតសោម រក្សាសច្ចៈដ៏ឧត្តម ដោះក្សត្រ ១០១ អង្គឲ្យរួច ( នេះ ) ជាសច្ចបរមត្ថបារមី ។ កាលតថាគតកើតជាកឹធនូៈ កាលនោះ មានបារមីដោយការអធិដ្ឋាន កាលកើតជាទុកៈ និងមាតង្គយៈ បានបំពេញអធិដ្ឋានឧបបារមី ។ កាលតថាគតកើតជាមូគផក្ខពោធិសត្វ បានបំពេញអធិដ្ឋានបរមត្ថបារមី កាលកើតជាមហាកណ្ហៈ ប្រព្រឹត្តទៅដោយមេត្តា កាលកើតជារាជសោធនៈ ( ក៏ប្រព្រឹត្តទៅ ) ដោយមេត្តានោះដែរ បារមីទាំងពីរនេះ ហៅថា មេត្តាបារមី កាលតថាគតកើតជាស្តេចព្រហ្មទត្ត ( ប្រព្រឹត្តទៅ ) ដោយសីល កាលកើតជាគណ្ឋិតិណ្ឌកៈនេះ ( ក៏បានប្រព្រឹត្តទៅ ) ដោយសីលដែរ ។ កាលតថាគតកើតជានន្ទៈ បានធ្វើនូវសេចក្តីស្រឡាញ់ ( ក្នុងសព្វញ្ញុតញ្ញាណ ) បារមីទាំងនោះ ជាឧបបារមី ឯបរមត្ថបារមី បានបំពេញហើយ ក្នុងកាលតថាគតកើតជាស្តេចឯករាជ បារមីដទៃប្រាកដស្មើដោយមេត្តាបារមីនេះ ពុំមានឡើយ ។ កាលតថាគតកើតជាសេកទាំងពីរ បានបំពេញឧបបារមី កាលកើតជាលោមហំសនៈ បានបំពេញបរមត្ថបារមី ឯបារមី ១០ របស់តថាគតនេះ ជាចំណែកនៃពោធិញ្ញាណដ៏ប្រសើរ ។ បារមីទាំងឡាយ មិនលើសអំពី ១០ មិនខ្វះអំពី ១០ បារមីទាំងអស់ ពេញត្រឹម ១០ មិនខ្វះមិនលើស ។

សមោធានកថា ចប់

ចរិយាបិដក ចប់

# អដ្ឋកថា

## បកិណ្ណកកថា

[ ៣៦ ] ដើម្បីភាពឈ្លាសច្រើនប្រការក្នុងពោធិសម្ភារនៃកុលបុត្រទាំងឡាយ ដែលកើតឧស្សាហៈក្នុងកិច្ចបដិបត្តិ ដើម្បីទៅកាន់មហាពោធិញ្ញាណ ទើបគួរពោលបកិណ្ណកកថាក្នុងបារមីទាំងពួង ។

ក្នុងបារមីនោះ មានមាតិកាដូចតទៅនេះ បារមីទាំងនោះ គឺអ្វី ឈ្មោះថាបារមី ព្រោះអត្ថដូចម្ដេច បារមីមានប៉ុន្មានយ៉ាង លំដាប់របស់បារមីដូចម្ដេច អ្វីជាលក្ខណៈ កិច្ច បច្ចុប្បដ្ឋាន និងបទដ្ឋាន អ្វីជាបច្ច័យ អ្វីជាការសៅហ្មង អ្វីជាការផូរផង់ អ្វីជាបដិបក្ខ អ្វីជាបដិបទា អ្វីជាការចែក អ្វីជាការសង្គ្រោះ អ្វីជាឧបាយឲ្យសម្រេច ឲ្យសម្រេចក្នុងកាលណា អ្វីជាអានិសង្ស និងអ្វីជាផលរបស់បារមីទាំងនោះ ។

ក្នុងសេចក្ដីនោះ មានវិសជ្ជនាដូចតទៅ បញ្ហាថា បារមីទាំងនោះ គឺអ្វី ។ បារមី គឺគុណធម៌ទាំងឡាយ មានទានជាដើម កំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយ គឺករុណា ដែលតណ្ហា មានះ និងទិដ្ឋិ មិនចូលទៅកម្ចាត់ ។

បញ្ហាថា បារមីព្រោះអត្ថដូចម្ដេច ព្រះមហាសត្វ ព្រះពោធិសត្វ ជាបុគ្គលកំពូល ខ្ពង់ខ្ពស់ជាងសត្វ ព្រោះប្រកបគុណវិសេស មានទាន និងសីលជាដើម ការកើត ឬការធ្វើរបស់ព្រះពោធិសត្វទាំងនោះ ឈ្មោះថាបារមី បានដល់ ការធ្វើទានជាដើម ក៏ជាបារមី ។

ម្យ៉ាងទៀត ឈ្មោះថា **បរម** ព្រោះអត្ថថា បំពេញ ឈ្មោះថា **ពោធិ-សត្វ** ព្រោះអត្ថថា ជាអ្នកបំពេញ និងជាអ្នករក្សាគុណទាំងឡាយ មានទាន

ជាដើម ។ ភាវៈក្តី កម្មក្តី របស់បារមី ឬរបស់ព្រះពោធិសត្វដែលប្រសើរឧត្តម នេះឈ្មោះថា បារមី បានដល់ ការធ្វើទានជាដើមនោះឯង ។

ម្យ៉ាងទៀត បារមី រមែងចងសត្វដទៃទុកក្នុងខ្លួន ដោយការប្រកបគុណវិសេស ឬបារមី រមែងជុសខាត់សត្វដទៃឲ្យបរិសុទ្ធចាកមន្ទិល គឺកិលេស ឬបារមី រមែងទៅកាន់ត្រើយនាយ គឺនិព្វានដ៏ប្រសើរ ដោយគុណវិសេស ឬបារមី រមែងកំណត់ដឹងលោកដទៃ ដូចដឹងលោកនេះដោយគុណវិសេស គឺញាណដែលកំណត់ហើយ ឬបារមី រមែងថ្លឹងថ្លៃងនូវគុណ មានសីលជាដើមក្នុងសន្តានរបស់ខ្លួនយ៉ាងក្រៃលែង ឬបារមី រមែងទម្លាយបដិបក្ខដទៃចាកធម្មកាយដែលជាអត្តា ឬពួកចោរ គឺកិលេសដែលធ្វើសេចក្តីវិនាសដល់ខ្លួននោះ ព្រោះហេតុនោះ ទើបឈ្មោះថា **បរម** ( បារមី ) ។ សត្វណាប្រកបដោយបរមដូចពោលមកនេះ សត្វនោះ ឈ្មោះថា **មហាសត្វ** ពាក្យជាដើមថា ភាវៈក្តី កម្មក្តី នៃបារមី ក៏គប្បីប្រកបតាមន័យដូចពោលមកហើយ ។

ម្យ៉ាងទៀត បារមី រមែងជុសខាត់ គឺរមែងបរិសុទ្ធ និងញុំាងសត្វទាំងឡាយឲ្យបរិសុទ្ធក្នុងត្រើយនាយ គឺព្រះនិព្វាន ឬបារមី រមែងចង រមែងប្រកបសត្វទាំងឡាយទុកក្នុងព្រះនិព្វាននោះ ឬបារមី រមែងទៅ រមែងដល់ រមែងសម្រេចដល់ព្រះនិព្វាននោះ ឬបារមី រមែងកំណត់ដឹងនូវព្រះនិព្វាននោះតាមសេចក្តីពិត ឬបារមី រមែងធ្វើសត្វឲ្យឈមចុះក្នុងព្រះនិព្វាននោះ ឬបារមី រមែងកម្ចាត់សត្រូវ គឺកិលេសនៃសត្វទាំងឡាយបានក្នុងព្រះនិព្វាននោះ ហេតុនោះ ទើបឈ្មោះថា បារមី ។ បុរសណា បំពេញបារមីដូចពោលមកនេះ

បុរសនោះ ឈ្មោះថា មហាបុរស ។ ភាវៈក្តី កម្មក្តី របស់មហាបុរសនោះ ឈ្មោះថា ភាពជាអ្នកមានបារមី បានដល់ ការធ្វើទានជាដើមនោះឯង គប្បីជ្រាបអត្ថនៃសព្ទថា **បារមី** ដោយន័យដូចពោលនេះឯង ។

បញ្ហាថា បារមីមានប៉ុន្មានយ៉ាង ដោយសង្ខេបមាន ១០ យ៉ាង បារមីទាំងនោះ ប្រាកដដោយសរុបហើយក្នុងបាលី សមដូចព្រះមានព្រះភាគត្រាស់ថា

កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមី ជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សន្សំមក ដូច្នេះ ។

ដូចព្រះសារីបុត្រទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គ ពុទ្ធ-ការកធម៌មានប៉ុន្មាន ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ពុទ្ធការកធម៌មាន ១០ ប្រការ ធម៌ ១០ ប្រការ គឺអ្វីខ្លះ ម្នាលសារីបុត្រ ទាន សីល នេក្ខម្មៈ បញ្ញា វិរិយៈ ខន្តី សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា ជាធម៌ធ្វើឲ្យបានជាព្រះពុទ្ធ ម្នាលសារីបុត្រ ធម៌ ១០ ប្រការនេះឯង ជាពុទ្ធការកធម៌ ។ ព្រះមានព្រះភាគត្រាស់ដូច្នោះហើយ ព្រះសុគតសាស្តា ត្រាស់គាថាប្រព័ន្ធដូចតទៅនេះ

ទាន សីល នេក្ខម្មៈ បញ្ញា វិរិយៈ ជាគម្រប់ ៥ ខន្តី សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា ជាគម្រប់ ១០ ដូច្នេះ ។

តែអាចារ្យពួកខ្លះ ពោលថា មាន ៦ យ៉ាង លោកពោលដូច្នោះ ដោយការសង្គ្រោះបារមីទាំងនោះ ការសង្គ្រោះនោះ នឹងមានជាក់ច្បាស់

ខាងមុខ ។

ពាក្យថា លំដាប់ ក្នុងបញ្ហាថា លំដាប់នៃបារមីទាំងនោះ តើដូចម្តេច នេះជាលំដាប់នៃទេសនា ។ ម្យ៉ាងទៀត លំដាប់នោះ ជាហេតុនៃការសមាទាន គ្រាដំបូង ។ ការសមាទាន ជាហេតុនៃការពិចារណា ដោយប្រការដូច្នេះ ទេសនា ទើបចាត់យកការជ្រើសរើស និងការសមាទានទុកក្នុងខាងដើម ។ ក្នុងបារមីទាំងនោះ ទាន មានឧបការៈច្រើនដល់សីល និងធ្វើបានងាយ ព្រោះហេតុនោះ ទើបលោកពោលទាននោះខាងដើម ។ ទាន ដែលសីលឃុំគ្រង ទើបមានផលច្រើន មានអានិសង្សច្រើន ព្រោះហេតុនោះ ទើបលោកពោលសីលក្នុងលំដាប់នៃទាន ។ សីលដែលនេក្ខម្មៈឃុំគ្រង នេក្ខម្មៈដែលបញ្ញាឃុំគ្រង បញ្ញាដែលវិរិយៈឃុំគ្រង វិរិយៈដែលខន្តីឃុំគ្រង ខន្តីដែលសច្ចៈឃុំគ្រង សច្ចៈដែលអធិដ្ឋានឃុំគ្រង អធិដ្ឋានដែលមេត្តាឃុំគ្រង មេត្តាដែលឧបេក្ខាឃុំគ្រង ទើបមានផលច្រើន មានអានិសង្សច្រើន ព្រោះហេតុនោះ ទើបលោកពោលឧបេក្ខាក្នុងលំដាប់នៃមេត្តា តែគប្បីជ្រាបថា ឧបេក្ខាដែលករុណាឃុំគ្រង និងករុណាដែលឧបេក្ខាឃុំគ្រង ។ ព្រះពោធិសត្វទាំងឡាយមានមហាករុណា មានឧបេក្ខាក្នុងសត្វទាំងឡាយដូចម្តេច អាចារ្យពួកខ្លះពោលថា ព្រះពោធិសត្វទាំងឡាយ ជាអ្នកព្រងើយក្នុងកាលខ្លះ ក្នុងសត្វដែលគួរព្រងើយ តែមិនព្រងើយក្នុងទីទាំងពួង និងដោយប្រការទាំងពួង ។ ឯអាចារ្យពួកដទៃពោលថា ព្រះពោធិសត្វទាំងឡាយ មិនព្រងើយក្នុងសត្វទាំងឡាយ តែព្រងើយក្នុងការមិនសមគួរដែលសត្វធ្វើ ។

ន័យម្យ៉ាងទៀត លោកពោលទានក្នុងលំដាប់ខាងដើម ព្រោះជាវត្ថុទូទៅដល់សព្វសត្វ ដោយប្រព្រឹត្តទៅក្នុងជនច្រើន ព្រោះមានផលតិច និងព្រោះធ្វើបានងាយ ។ លោកពោលសីលក្នុងលំដាប់បន្ទាប់ពីទាន ព្រោះពោលដល់សេចក្តីបរិសុទ្ធរបស់បុគ្គលអ្នកឲ្យ និងអ្នកទទួលដោយសីលមុនហើយទើបពោលដល់ការអនុគ្រោះអ្នកដទៃ ហើយពោលដល់ការមិនបៀតបៀនអ្នកដទៃ ព្រោះពោលដល់ធម៌ដែលគួរធ្វើ ហើយពោលដល់ធម៌ ដែលមិនគួរធ្វើ និងព្រោះពោលដល់ហេតុនៃភោគសម្បត្តិហើយ ទើបពោលដល់ហេតុនៃភវ-សម្បត្តិ ។ លោកពោលនេក្ខម្មៈក្នុងលំដាប់បន្ទាប់ពីសីល ព្រោះការសម្រេចនៃសីលសម្បត្តិមានជម្រិតនេក្ខម្មៈ ព្រោះពោលដល់កាយសុចរិត និងវចី-សុចរិតហើយ ទើបពោលដល់មនោសុចរិត ព្រោះសីលបរិសុទ្ធ ធ្វើឲ្យសម្រេចឈានដោយងាយ ព្រោះពោលដល់បយោគសុទ្ធិ ( សេចក្តីព្យាយាមបរិសុទ្ធ ) ដោយការលះទោស គឺកម្មហើយ ទើបពោលដល់អាសយសុទ្ធិ ( អធ្យាស្រ័យបរិសុទ្ធ ) ដោយការលះទោស គឺកិលេស និងព្រោះពោលដល់កិលេសគ្របសង្កត់ចិត្ត ដោយការលះវីតិក្កមទោស ( ការកន្លងល្មើស ) ។

លោកពោលបញ្ញាក្នុងលំដាប់បន្ទាប់ពីនេក្ខម្មៈ ព្រោះការសម្រេច និងភាពបរិសុទ្ធនៃនេក្ខម្មៈមានជម្រិតបញ្ញា និងពោលថា បើមិនមានឈាន ក៏បញ្ញាមិនមាន ព្រោះបញ្ញាមានសមាធិជាបទដ្ឋាន ឯសមាធិមានបញ្ញាជាបច្ចុប្បដ្ឋាន ព្រោះពោលដល់សមថនិមិត្តហើយ ទើបពោលដល់ឧបេក្ខានិមិត្ត

និងព្រោះពោលដល់ការឈ្លាស ក្នុងឧបាយដែលធ្វើប្រយោជន៍ដល់អ្នកដទៃ ដោយការតាំងចិត្តធ្វើប្រយោជន៍ដើម្បីអ្នកដទៃ ។ លោកពោលវិរិយៈ ក្នុងលំដាប់បន្ទាប់អំពីបញ្ញា ព្រោះកិច្ចនៃបញ្ញាសម្រេចបាន ដោយប្រារព្ធសេចក្ដីព្យាយាម ព្រោះពោលដល់ការអត់ធន់ ចំពោះការសម្លឹងធម៌ គឺការសូន្យរបស់សត្វ ហើយពោលការប្រារព្ធដើម្បីប្រយោជន៍ដល់សត្វជាការអស្ចារ្យ ព្រោះពោលដល់ឧបេក្ខានិមិត្តហើយ ទើបពោលដល់បគ្គហនិមិត្ត ( និមិត្តក្នុងការផ្គងចិត្ត ) និងព្រោះពោលដល់ការពិចារណាមុនហើយទើបធ្វើ ហើយទើបពោលដល់សេចក្ដីព្យាយាម ដែលលោកពោលថា សេចក្ដីព្យាយាមរបស់បុគ្គលអ្នកពិចារណាហើយធ្វើ រមែងនាំមកនូវផលវិសេស ដូច្នេះ ។

លោកពោលខន្តី ក្នុងលំដាប់បន្ទាប់អំពីវិរិយៈ ព្រោះការសម្រេចនៃការអត់ធន់មានជ្រិតសេចក្ដីព្យាយាម ពិតហើយ បុគ្គលមានសេចក្ដីព្យាយាមអាចយកឈ្នះសេចក្ដីទុក្ខ ដែលសត្វ និងសង្ខារនាំមកបាន ព្រោះប្រារព្ធសេចក្ដីព្យាយាម ។ ពិតហើយ ព្រោះសេចក្ដីព្យាយាមជាអលង្ការរបស់អ្នកអត់ធន់ ការអត់ធន់ជារបស់បុគ្គលអ្នកមានសេចក្ដីព្យាយាមល្អ ។ ព្រោះពោលដល់បគ្គហនិមិត្តហើយ ទើបពោលដល់សមថនិមិត្ត និងព្រោះពោលដល់ការលះទោស គឺឧទ្ធច្ចៈមានជ្រិតសេចក្ដីព្យាយាមក្រៃលែង ពិតហើយ ទោស គឺឧទ្ធច្ចៈ រមែងលះបានដោយការអត់ធន់ ក្នុងការសម្លឹងធម៌ ។ ព្រោះពោលថា បុគ្គលមានសេចក្ដីព្យាយាម រមែងមានការធ្វើជាប់តគ្នា ពិតហើយ បុគ្គលដែលធ្ងន់ដោយខន្តី ជាអ្នកមិនរាយមាយ រមែងជាអ្នកធ្វើនូវការជាប់ត ព្រោះពោលថា

បុគ្គលមិនប្រមាទ មិនមានតណ្ហាដើម្បីធ្វើតក្នុងការប្រារព្ធ ធ្វើប្រយោជន៍ដើម្បីអ្នកដទៃ ពិតហើយ កាលការសម្លឹងធម៌តាមសេចក្ដីពិតមាន តណ្ហា រមែងមិនមាន ។ និងព្រោះពោលថា កាលមានការពិចារណាដល់ប្រយោជន៍របស់អ្នកដទៃដ៏កំពូល រមែងអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលអ្នកដទៃធ្វើបាន ។

លោកពោលសច្ចៈ ក្នុងលំដាប់បន្ទអំពីខន្តី ព្រោះខន្តីតាំងនៅបានយូរដោយសច្ចៈ ព្រោះពោលដល់ការអត់ធន់ចំពោះសេចក្ដីវិនាសរបស់អ្នកធ្វើនូវសេចក្ដីវិនាសហើយ ទើបពោលដល់ការមិនក្លែងនិយាយឲ្យភ្លាំងភ្លាត់ ក្នុងការធ្វើឧបការៈនោះ និងព្រោះពោលដល់ការអត់ធន់ក្នុងការសម្លឹងធម៌ គឺការសូន្យរបស់សត្វ ហើយពោលដល់សច្ចៈ ដែលជាញាណឧបត្ថមខន្តីនោះ ។

លោកពោលអធិដ្ឋាន ក្នុងលំដាប់បន្ទអំពីសច្ចៈ ព្រោះការសម្រេចនៃសច្ចៈមានជ្បិតអធិដ្ឋាន ពិតហើយ ការវៀរ រមែងសម្រេចដល់អ្នកតាំងចិត្តមិនញាប់ញ័រ ។ ព្រោះពោលពាក្យមិនខុសការពិត ហើយពោលដល់ភាពជាអ្នកមិនញាប់ញ័រក្នុងការពោលពាក្យ មិនខុសការពិតនោះ ពិតហើយ បុគ្គលទប់ចិត្តបាន មិនញាប់ញ័រ ប្រព្រឹត្តតាមសមគួរដល់ប្តេជ្ញាក្នុងទានជាដើម ព្រោះពោលញាណសច្ចៈហើយ ទើបពោលដល់ការសម្លឹង ការប្រព្រឹត្តទៅក្នុងសម្ភារទាំងឡាយ ពិតហើយ បុគ្គលមានញាណតាមសេចក្ដីពិត រមែងអធិដ្ឋានពោធិសម្ភារទាំងឡាយ និងញុំាងពោធិសម្ភារនោះឲ្យសម្រេច ព្រោះមិនញាប់ញ័រដោយបដិបក្ខទាំងឡាយ ។

លោកពោលមេត្តាបន្ទអំពីអធិដ្ឋាន ព្រោះការសម្រេចនៃអធិដ្ឋានមាន

ដ្បិតការសមាទាន ធ្វើប្រយោជន៍ដើម្បីអ្នកដទៃដោយមេត្តា ព្រោះពោលដល់អធិដ្ឋានហើយ ទើបពោលដល់ការនាំប្រយោជន៍ចូលទៅ ពិតហើយ បុគ្គលតាំងមាំក្នុងពោធិសម្ភារ ជាអ្នកមានប្រក្រតីនៅដោយមេត្តា និងព្រោះជាអ្នកមានអធិដ្ឋានមិនញាប់ញ័រ រមែងមានការសមាទាន ដោយមិនទម្លាយការសមាទាន ។

លោកពោលឧបេក្ខាក្នុងលំដាប់នៃមេត្តា ព្រោះការបរិសុទ្ធនៃមេត្តាមានដ្បិតឧបេក្ខា ព្រោះពោលដល់ការនាំប្រយោជន៍ក្នុងសត្វទាំងឡាយហើយ ទើបពោលដល់ការមិនដាក់ចិត្តក្នុងទោសកំហុសរបស់បុគ្គលនោះ ព្រោះពោលដល់មេត្តាភាវនា ហើយពោលដល់ការចម្រើនផលរបស់មេត្តាភាវនានោះ និងព្រោះពោលដល់ភាពជាគុណគួរអស្ចារ្យថា បុគ្គលព្រងើយក្នុងសត្វដែលប្រាថ្នាប្រយោជន៍ គប្បីជ្រាបលំដាប់នៃបារមីទាំងឡាយនោះ ដោយប្រការដូច្នេះឯង ។

ក្នុងបញ្ហាថា អ្វីជាលក្ខណៈ កិច្ច បច្ចុប្បដ្ឋាន និងបទដ្ឋាននេះ គប្បីជ្រាបសេចក្តីដូចតទៅ ដោយការមិនផ្សេងគ្នា បារមីទាំងអស់ **បរានុគ្គហលក្ខណា** មានការអនុគ្រោះអ្នកដទៃជាលក្ខណៈ **បរេសំ ឧបការករណរសា** មានការធ្វើឧបការៈដល់អ្នកដទៃជាកិច្ច **អវិកម្បនរសា វា** ឬមានការមិនញាប់ញ័រជាកិច្ច **ហិតេសិតាបច្ចុប្បដ្ឋានា** មានការស្វែងរកប្រយោជន៍ដល់សត្វជាបច្ចុប្បដ្ឋាន **ពុទ្ធត្តបច្ចុប្បដ្ឋានា វា** ឬមានភាពជាព្រះពុទ្ធជាបច្ចុប្បដ្ឋាន **មហាករុណាបទដ្ឋានា** មានមហាករុណាជាបទដ្ឋាន **ករុណូបាយ**

**កោសល្លបទដ្ឋានា វា** ឬមានភាពឈ្លាសក្នុងឧបាយនៃករុណាជាបទដ្ឋាន ។

តែពោលដោយការផ្សេងគ្នា ព្រោះចេតនាបរិច្ចាគគ្រឿងឧបភោគបរិភោគនៃខ្លួន ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ជាទានបារមី ។ កាយសុចរិត វចីសុចរិត កំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា និងដោយអត្ថ ចេតនាវៀរវត្ថុមិនគួរធ្វើ និងធ្វើវត្ថុដែលគួរធ្វើជាដើម ជាសីលបារមី ។ ចិត្តកើតឡើងដើម្បីនឹងចេញចាកកាមភព មានការឃើញទោសជាលំដាប់ដំបូង ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ជានេក្ខម្មបារមី ។ ការចាក់ធ្លុះនូវសាមញ្ញលក្ខណៈ និងវិសេសលក្ខណៈនៃធម៌ទាំងឡាយ ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ជាបញ្ញាបារមី ការប្រារព្ធដល់ប្រយោជន៍របស់អ្នកដទៃដោយកាយ និងចិត្ត ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ជាវីរិយបារមី ការអត់ធ្មត់ក្នុងទោសរបស់សត្វ និងសង្ខារ ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា និងការតាំងនៅក្នុងអទោសៈ ចិត្តកើតឡើងប្រព្រឹត្តទៅក្នុងអាការរបស់អទោសៈនោះ ជាខន្តិបារមី ការមិនពោលឃៀងឃ្លាត មានវិរតិចេតនាជាដើម ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ជាសច្ចបារមី ការតាំងចិត្តសមាទានមិនញាប់ញ័រ ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា និងចិត្តកើតឡើង ប្រព្រឹត្តទៅក្នុងអាការនៃការតាំងចិត្តសមាទានមិនញាប់ញ័រនោះ ជាអធិដ្ឋានបារមី ការនាំប្រយោជន៍ និងសេចក្ដីសុខ មកឲ្យដល់សត្វលោក

ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ដោយអត្ថ បានដល់ ការមិនព្យាបាទ ជាមេត្តាបារមី ការកម្ចាត់នូវការត្រេកអរ និងការមិនត្រេកអរ ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា និងការប្រព្រឹត្តទៅស្មើក្នុងសត្វ និងសង្ខារទាំងឡាយ ទាំងដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ជាឧបេក្ខាបារមី ។

ហេតុនោះ ទានបារមី **បរិច្ចាគលក្ខណា** មានការបរិច្ចាគជាលក្ខណៈ **ទេយ្យធម្ម លោភវិទ្ធំសនរសា** មានការកម្ចាត់លោភៈក្នុងទេយ្យធម៌ជាកិច្ច **អនាសត្តិបច្ចុប្បដ្ឋានា** មានការមិនជាប់ជំពាក់ជាបច្ចុប្បដ្ឋាន **ភវវិភវ-សម្បត្តិបច្ចុប្បដ្ឋានា វា** ឬមានសម្បត្តិក្នុងភពតូចភពធំជាបច្ចុប្បដ្ឋាន **បរិច្ច-ជិតព្វវត្ថុបទដ្ឋានា** មានវត្ថុដែលគួរបរិច្ចាគជាបទដ្ឋាន ។ សីលបារមី **សីល-នលក្ខណា** មានការត្រជាក់ជាលក្ខណៈ លោកអធិប្បាយថា មានការសមាទានជាលក្ខណៈ ឬមានការតាំងមាំជាលក្ខណៈ **ទុស្សីល្យវិទ្ធំសនរសា** មានការកម្ចាត់ភាពជាអ្នកទ្រុស្តសីលជាកិច្ច **អនវជ្ជរសា វា** ឬមានការមិនមានទោសជាកិច្ច **សោចេយ្យបច្ចុប្បដ្ឋានា** មានភាពស្អាត ( សុចរិត ) ជាបច្ចុប្បដ្ឋាន **ហិរោត្តប្បបទដ្ឋានា** មានហិរិឱត្តប្បៈជាបទដ្ឋាន ។ នេក្ខម្ម-បារមី **កាមតោ ច ភវតោ ច និក្ខមនលក្ខណា** មានការចេញចាកកាម និងចាកភពជាលក្ខណៈ **តទាទីនវវិភាវនរសា** មានការយល់ជាក់ច្បាស់ក្នុងទោសនៃកាម និងភពនោះជាកិច្ច **តតោ ឯវ វិមុខភាវបច្ចុប្បដ្ឋានា** មានការបែរមុខចេញចាកកាម និងភពនោះជាបច្ចុប្បដ្ឋាន **សំវេគបទដ្ឋានា** មាន

សេចក្តីសង្វេគជាបទដ្ឋាន ។ បញ្ញាបារមី **យថាសភាវបដិវេធលក្ខណា** មានការចាក់ធ្លុះតាមសេចក្តីពិតជាលក្ខណៈ **អក្ខលិតបដិវេធលក្ខណា** វា ឬមានការចាក់ធ្លុះមិនខុសជាលក្ខណៈ ដូចការបាញ់ព្រួញរបស់ខ្មាន់ធ្នូអ្នកឈ្លាស **វិសយោភាសនរសា** មានការបំភ្លឺក្នុងអារម្មណ៍ជាកិច្ច ដូចប្រទីប **អសម្មោហបច្ចុប្បដ្ឋានា** មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចមនុស្សនាំផ្លូវទៅក្នុងព្រៃ **សមាធិបទដ្ឋានា** មានសមាធិជាបទដ្ឋាន **ចតុសច្ចបទដ្ឋានា** វា ឬមានអរិយសច្ច ៤ ជាបទដ្ឋាន ។ វីរិយបារមី **ឧស្សាហលក្ខណា** មានការខ្មីឃ្មាតជាលក្ខណៈ **ឧបត្ថម្ភនរសា** មានការឧបត្ថម្ភជាកិច្ច **អសំសីទនបច្ចុប្បដ្ឋានា** មានការមិនលិចចុះជាបច្ចុប្បដ្ឋាន **វីរិយារម្ភវត្ថុបទដ្ឋានា** មានវត្ថុដែលនាំឲ្យប្រារព្ធព្យាយាមជាបទដ្ឋាន **សំវេគបទដ្ឋានា** វា ឬមានសេចក្តីសង្វេគជាបទដ្ឋាន ។ ខន្តិបារមី **ខមនលក្ខណា** មានការអត់ធន់ជាលក្ខណៈ **ឥដ្ឋានិដ្ឋសហនរសា** មានការអត់ធ្មត់ក្នុងអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាកិច្ច **អធិវាសនបច្ចុប្បដ្ឋានា** មានសេចក្តីអំណត់ជាបច្ចុប្បដ្ឋាន **អវិរោធបច្ចុប្បដ្ឋានា** វា ឬមានការមិនក្រោធជាបច្ចុប្បដ្ឋាន **យថាភូតទស្សនបទដ្ឋានា** មានការឃើញតាមសេចក្តីពិតជាបទដ្ឋាន ។ សច្ចបារមី **អវិសំវាទនលក្ខណា** មានការមិនពោលខុសជាលក្ខណៈ **យថាសភាវវិភាវនរសា** មានការប្រកាសតាមសេចក្តីពិតជាកិច្ច **សាធុតាបច្ចុប្បដ្ឋានា** មានការត្រេកអរជាបច្ចុប្បដ្ឋាន **សោរច្ចបទដ្ឋាន** មានការស្ងប់ស្ងៀមជាបទដ្ឋាន ។ អធិដ្ឋានបារមី **ពោធិសម្ភារេសុ អធិដ្ឋានលក្ខណា** មានការតាំង

ចិត្តក្នុងពោធិសម្ភារជាលក្ខណៈ **តេសំ បដិបក្ខាភិភវនរសា** មានការគ្របសង្កត់វត្ថុដែលជាបដិបក្ខរបស់ពោធិសម្ភារទាំងនោះជាកិច្ច **តត្ថ អចលតា-បច្ចុប្បដ្ឋានា** មានការមិនកម្រើកក្នុងការគ្របសង្កត់វត្ថុដែលជាបដិបក្ខជាបច្ចុប្បដ្ឋាន **ពោធិសម្ភារបទដ្ឋានា** មានពោធិសម្ភារជាបទដ្ឋាន ។ មេត្តា-បារមី **ហិតាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តទៅនៃអាការជាប្រយោជន៍ជាលក្ខណៈ **ហិតូបសំហាររសា** មានការនាំប្រយោជន៍ចូលទៅជាកិច្ច **អាឃាតវិនយរសា វា** ឬមានការកម្ចាត់អាឃាតជាកិច្ច **សោម្មភាវ-បច្ចុប្បដ្ឋានា** មានសេចក្តីត្រជាក់ជាបច្ចុប្បដ្ឋាន **សត្តានំ មនាបភាវ-ទស្សនបទដ្ឋានា** មានការឃើញសត្វទាំងឡាយជាទីគួរពេញចិត្តជាបទដ្ឋាន ។ ឧបេក្ខាបារមី **មជ្ឈត្តាការប្បវត្តិលក្ខណា** មានការប្រព្រឹត្តទៅដោយអាការជាកណ្តាលជាលក្ខណៈ **សមភាវទស្សនរសា** មានការឃើញស្មើជាកិច្ច **បដិឃានុនយវូបសមបច្ចុប្បដ្ឋានា** មានការស្ងប់នូវការត្រេកអរ និងការអាក់អន់ជាបច្ចុប្បដ្ឋាន **កម្មស្សកតាបច្ចវេក្ខណាបទដ្ឋានា** មានការពិចារណាភាពដែលសត្វមានកម្មជារបស់ខ្លួនជាបទដ្ឋាន ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គួរពោលដល់ការកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណាដោយការផ្សេងគ្នានៃលក្ខណៈ មានការបរិច្ចាគជាដើមរបស់ទានជាដើម ។ ពិតហើយ ទានជាដើម ដែលកំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយនៃករុណា ប្រព្រឹត្តទៅហើយ ក្នុងសន្តានរបស់ព្រះពោធិសត្វ ឈ្មោះថា បារមី មានទានបារមីជាដើម ។

បញ្ហាថា អ្វីជាបច្ច័យ លំដាប់ដំបូង អភិនីហារជាបច្ច័យនៃបារមីទាំងឡាយ ។ ពិតហើយ អភិនីហារណា ធ្វើធម្មសមោធាន ៨ ឲ្យដល់ព្រម ដូចព្រះមានព្រះភាគត្រាស់យ៉ាងនេះថា

អភិនីហារ រមែងសម្រេចព្រោះធម្មសមោធាន ៨ ប្រការ គឺភាពជាមនុស្ស ១ ដល់ព្រមដោយភេទ ១ ហេតុ ១ ឃើញព្រះសាស្តា ១ បព្វជ្ជា ១ គុណសម្បត្តិ ១ អធិការៈ ១ ឆន្ទៈ ១ ដូច្នេះ ។

ដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា អាត្មាអញឆ្លងហើយ គប្បីឲ្យសត្វឆ្លង អាត្មាអញផុតហើយ គប្បីឲ្យសត្វផុត អាត្មាអញទូន្មានហើយ គប្បីឲ្យសត្វទូន្មាន អាត្មាអញស្ងប់ហើយ គប្បីឲ្យសត្វស្ងប់ អាត្មាអញស្រាកស្រាន្តហើយ គប្បីឲ្យសត្វស្រាកស្រាន្ត អាត្មាអញរម្ងត់កិលេសហើយ គប្បីឲ្យសត្វរម្ងត់កិលេស អាត្មាអញបរិសុទ្ធហើយ គប្បីឲ្យសត្វបរិសុទ្ធ អាត្មាអញត្រាស់ដឹងហើយ គប្បីឲ្យសត្វត្រាស់ដឹងដូច្នេះ ។ អភិនីហារនោះ ជាបច្ច័យនៃបារមីទាំងពួង ដោយមិនផ្សេងគ្នា ។ ការសម្រេចនៃការស្រាវជ្រាវ ការតាំងមាំ ការតាំងចិត្តសមាទានបារមីជាកយ្យោភាពឡើង ព្រោះការប្រព្រឹត្តទៅនៃបច្ច័យនោះ រមែងមានដល់មហាបុរសទាំងឡាយ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ភាពជាមនុស្ស បានដល់ អត្តភាពរបស់មនុស្ស ព្រោះសេចក្តីប្រាថ្នា រមែងសម្រេចដល់បុគ្គលដែលតាំងនៅក្នុងអត្តភាពជាមនុស្សប៉ុណ្ណោះ ហើយប្រាថ្នាភាពជាព្រះពុទ្ធ មិនសម្រេចដល់បុគ្គលដែល

តាំងនៅក្នុងជាតិ មាននាគ និងគ្រុឌជាដើម បើសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនសមគួរដល់ភាពជាព្រះពុទ្ធ ។

ពាក្យថា ដល់ព្រមដោយភេទ សេចក្តីថា សូម្បីតាំងនៅក្នុងអត្តភាពរបស់មនុស្ស សេចក្តីប្រាថ្នារមែងសម្រេចដល់បុរសប៉ុណ្ណោះ មិនសម្រេចដល់ស្ត្រី បណ្ឌក នបុំសក និងឧភតោព្យញ្ជនកៈឡើយ ។ បើសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះហេតុតាមដែលពោលហើយ និងព្រោះមិនមានសេចក្តីបរិបូណ៌នៃលក្ខណៈ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរ-និកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ស្ត្រីបានជាព្រះអរហន្តសម្មា-សម្ពុទ្ធ ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ដូច្នេះ ។ គប្បីពង្រីកឲ្យពិស្តារ ។ ព្រោះហេតុនោះ ទើបការប្រាថ្នាមិនសម្រេចដល់មនុស្សដែលតាំងនៅក្នុងភេទស្ត្រី ឬដល់បណ្ឌកជាដើម ។

ពាក្យថា ហេតុ បានដល់ ការដល់ព្រមដោយឧបនិស្ស័យ ។ មែនពិតទោះបីជាមនុស្ស ជាបុរស ការប្រាថ្នារមែងសម្រេចព្រោះហេតុសម្បត្តិ ( អាចបានជាព្រះអរហន្តក្នុងជាតិនោះ ) មិនសម្រេចដល់បុគ្គលដទៃឡើយ ។

ពាក្យថា ឃើញព្រះសាស្តា សេចក្តីថា មានព្រះសាស្តានៅចំពោះមុខ ព្រោះការប្រាថ្នារមែងសម្រេចដល់អ្នកប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ ដែលគង់ព្រះជន្មនៅប៉ុណ្ណោះ កាលព្រះមានព្រះភាគបរិនិព្វានហើយ សេចក្តីប្រាថ្នាក្នុងចេតិយក្តី ពោធិព្រឹក្សក្តី ត្រង់ព្រះបដិមាក្តី ឬត្រង់សម្នាក់ព្រះបច្ចេកពុទ្ធក្តី

សាវកពុទ្ធក្តី រមែងមិនសម្រេច ព្រោះហេតុអ្វី ព្រោះអធិការមិនមានកម្លាំងគ្រប់គ្រាន់ ។ ការប្រាថ្នា រមែងសម្រេចក្នុងសម្នាក់របស់ព្រះពុទ្ធប៉ុណ្ណោះ ព្រោះអធិការនោះ ត្រូវមានកម្លាំង ដោយភាពជាអធ្យាស្រ័យដ៏ក្រៃលែង ។

ពាក្យថា បព្វជ្ជា សេចក្តីថា ការប្រាថ្នា រមែងសម្រេចដល់បុគ្គលប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធមានព្រះភាគ បុគ្គលបួសក្នុងសម្នាក់តាបសក្តី ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយដែលជាកម្មកិរិយវាទី មិនសម្រេចដល់បុគ្គលដែលតាំងនៅក្នុងភេទជាគ្រហស្ថ ព្រោះហេតុអ្វី ព្រោះមិនសមគួរជាព្រះពុទ្ធ ។ ព្រោះមហាពោធិសត្វបួសហើយប៉ុណ្ណោះ ទើបសម្រេចសម្មាសម្ពោធិញ្ញាណបាន បុគ្គលជាគ្រហស្ថ សម្រេចមិនបាន ព្រោះហេតុនោះ ក្នុងពេលតាំងបណិធាន ត្រូវជាភេទរបស់បព្វជិតប៉ុណ្ណោះ ព្រោះជាទីតាំងនៃគុណសម្បត្តិដោយពិត ។

ពាក្យថា គុណសម្បត្តិ សេចក្តីថា ដល់ព្រមដោយគុណ មានអភិញ្ញាជាដើម ។ ព្រោះសេចក្តីប្រាថ្នា រមែងសម្រេចដល់បព្វជិតដែលបានសមាបត្តិ ៨ មានអភិញ្ញា ៥ ប៉ុណ្ណោះ មិនសម្រេចដល់បុគ្គលដែលប្រាសចាកគុណសម្បត្តិតាមដែលពោលហើយឡើយ ព្រោះហេតុអ្វី ព្រោះមិនអាចពិចារណាជ្រើសរើសនូវបារមីបាន ព្រះមហាបុរសបំពេញអភិនីហារ ជាអ្នកអាចពិចារណា ស្រាវជ្រាវនូវបារមីបានដោយខ្លួនឯង ព្រោះប្រកបដោយឧបនិស្សយសម្បត្តិ និងអភិញ្ញាសម្បត្តិ ។

ពាក្យថា អធិការៈ បានដល់ មានឧបការៈក្រៃលែង ។ ពិតហើយ

បុគ្គលណា ដល់ព្រមដោយគុណសម្បត្តិតាមដែលពោលហើយ សូម្បីជីវិតរបស់ខ្លួន ក៏លះបង់ដល់ព្រះពុទ្ធបាន រមែងធ្វើឧបការៈដ៏ក្រៃលែង ក្នុងកាលនោះ ។ អភិនីហារ រមែងសម្រេចដល់បុគ្គលនោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ។

ពាក្យថា ឆន្ទៈ សេចក្តីថា ពេញចិត្តក្នុងកុសល ដោយការប្រាថ្នានឹងធ្វើ ។ ពិតហើយ ការប្រាថ្នា រមែងសម្រេចដល់បុគ្គលប្រកបដោយធម៌តាមដែលពោលហើយ មានឆន្ទៈខ្លាំង មានការប្រាថ្នាខ្លាំង មានការប្រាថ្នានឹងធ្វើខ្លាំងដើម្បីប្រយោជន៍ដល់ធម៌ ដែលធ្វើឲ្យជាព្រះពុទ្ធប៉ុណ្ណោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ។

បន្ទាប់អំពីនេះ ជាការប្រៀបធៀបក្នុងភាពជាអ្នកមានឆន្ទៈច្រើន ។ គប្បីជ្រាបភាពជាអ្នកមានឆន្ទៈច្រើន ក្នុងពាក្យថា មានឆន្ទៈច្រើននេះដោយន័យជាដើមយ៉ាងនេះថា បុគ្គលបានស្តាប់ថា អ្នកណាអាចឆ្លងល្វែងចក្កវាឡទាំងមូល ដែលជោរជន់ដោយទឹក ដោយកម្លាំងដើមដៃរបស់ខ្លួននោះឯង ហើយដល់ត្រើយ ( កណ្តាប់ចក្រវាល ) បាន បុគ្គលនោះ នឹងដល់នូវភាពជាព្រះពុទ្ធ ដូច្នេះហើយ មិនរារែក ព្រោះធ្វើបានលំបាក បែរជាមានឆន្ទៈថា ខ្ញុំនឹងឆ្លងដល់ត្រើយបាន មិនសម្តែងអាការមុខក្រញូវក្នុងកាលនោះឡើយ ។ ម្យ៉ាងទៀត បុគ្គលបានស្តាប់ថា បុគ្គលណាជាន់ល្វែងចក្កវាឡទាំងមូល ដែលពេញដោយរងើកភ្លើងប្រាសចាកអណ្តាត ប្រាសចាកផ្សែង ដោយជើងទាំងពីរ អាចដល់ត្រើយបាន បុគ្គលនោះ រមែងដល់នូវភាពជាព្រះពុទ្ធ ហើយមិន

វួញវ ព្រោះធ្វើបានលំបាក បែរជាមានឆន្ទៈថា ខ្ញុំនឹងឈានដើរឆ្លងឲ្យដល់ត្រើយបាន មិនសម្ដែងអាការបងចិញ្ចើមក្នុងកាលនោះឡើយ ។ មួយាងទៀត បុគ្គលបានស្ដាប់ថា បុគ្គលណា អាចជាន់ចក្កវាឡទាំងមូលដែលពេញដោយលំពែង និងចម្រូង ដែលបោះតម្រៀបគ្នាដោយជើងទាំងពីរឆ្លងដល់ត្រើយបាន ។បេ។ មិនសម្ដែងអាការបងចិញ្ចើមក្នុងការនោះឡើយ ។ មួយាងទៀត បុគ្គលបានស្ដាប់ថា បុគ្គលណា ដែលអាចដើរឆ្លងចក្កវាឡទាំងមូល ដែលពេញដោយគុម្ពឫស្សី មានបន្លាស្អេកស្កះទៅដោយព្រៃបន្លា និងវល្លិ ហើយឆ្លងចក្កវាឡដល់ត្រើយបាន ។បេ។ មិនសម្ដែងអាការបងចិញ្ចើម ក្នុងការនោះឡើយ ។ មួយាងទៀត បុគ្គលបានស្ដាប់ថា បុគ្គលណា ឆេះក្នុងនរកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប គប្បីសម្រេចភាពជាព្រះពុទ្ធបាន ដូច្នេះហើយមិនរារែក ព្រោះធ្វើបានលំបាក បែរជាមានឆន្ទៈថា ខ្ញុំនឹងឆេះក្នុងនរកនោះហើយសម្រេចភាពជាព្រះពុទ្ធ មិនសម្ដែងអាការបងចិញ្ចើម ក្នុងការនោះឡើយ ។

អភិនីហារប្រកបដោយអង្គ ៨ យ៉ាងនេះ ដោយអត្ថ គប្បីជ្រាបថា ចិត្តុប្បាទដែលប្រព្រឹត្តទៅយ៉ាងនោះ ព្រោះប្រជុំអង្គ ៨ នេះ ចិត្តុប្បាទនោះមានការតាំងចិត្តទៀងទាត់ ដើម្បីសម្មាសម្ពោធិញ្ញាណដោយប្រពៃនោះឯង ជាលក្ខណៈ មានការប្រាថ្នាជាដើមយ៉ាងនេះថា ឱ អញគប្បីត្រាស់ដឹងសម្មាសម្ពោ-ធិញ្ញាណជាលំដាប់ អញគប្បីញ៉ាំងប្រយោជន៍ និងសេចក្ដីសុខឲ្យសម្រេចដល់សត្វទាំងពួងជាកិច្ច មានភាពជាហេតុនៃពោធិសម្ភារជាបច្ចុប្បដ្ឋាន ។ មាន

មហាករុណាជាបទដ្ឋាន ឬមានឧបនិស្ស័យសម្បត្តិជាបទដ្ឋាន ។

គប្បីឃើញថា បុញ្ញវិសេស ដែលជាមូលនៃធម៌ ដែលធ្វើឲ្យជាព្រះពុទ្ធទាំងពួង ក៏ជាសេចក្តីចម្រើនក្រៃលែង ជាលម្អក្រៃលែង ជាការស្អាតមិនមានប្រមាណ ដោយការប្រព្រឹត្តទៅប្រារព្ធពុទ្ធភូមិដែលជាអចិន្តេយ្យ និងប្រយោជន៍ដល់សត្វលោកប្រមាណមិនបាន ។

ម្យ៉ាងទៀត មហាបុរស មួយអន្លើដោយការសម្រេចនោះឯង ជាបុគ្គលឈ្មោះថា ឈមចុះកាន់កិច្ចបដិបត្តិ ដើម្បីសម្រេចមហាពោធិញ្ញាណ រមែងបាននូវសន្មតថា ព្រះពោធិសត្វ ព្រោះមានសការៈមិនត្រឡប់ ព្រោះសម្រេចដល់ភាពជានិយតបុគ្គល ភាពជាបុគ្គលយកចិត្តទុកដាក់ជានិច្ច ក្នុងសម្មាសម្ពោធិញ្ញាណដោយភាវៈទាំងពួង និងភាពជាអ្នកអាចសិក្សាពោធិសម្ភារ រមែងតាំងនៅព្រមដល់មហាបុរសនោះ ។ ពិតហើយ ព្រះមហាបុរសទាំងឡាយ ស្រាវជ្រាវបារមីទាំងពួងដោយប្រពៃ ដោយញ៉ាំងអភិនីហារតាមដែលពោលហើយ ឲ្យសម្រេចដោយសយម្ភូញាណ ដែលមានភេទជាខាងដើម នៃការសម្រេចសព្វញ្ញុតញ្ញាណ ហើយសមាទាន បំពេញឲ្យបរិបូណ៌ដោយលំដាប់ ។ ដូចសុមេធបណ្ឌិតដែលបំពេញអភិនីហារច្រើន បដិបត្តិហើយ ដូចព្រះតម្រាស់ថា

បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងជ្រើសរើស ក៏បាន

ឃើញទានបារមីជាដំបូង ដូច្នេះ ។

គប្បីពង្រីកសេចក្ដីឲ្យពិស្ដារ ( សូមមើលពុទ្ធវំស: ) ។ គប្បីជ្រាប បច្ច័យ ៤ ហេតុ ៤ និងពល ៤ នៃអភិនីហារនោះ ។

ក្នុងអភិនីហារនោះ បច្ច័យ ៤ តើដូចម្ដេច ព្រះមហាបុរសក្នុងលោក នេះ ឃើញព្រះតថាគត ទ្រង់ធ្វើបាដិហារ្យគួរអស្ចារ្យមិនធ្លាប់មាន ដោយ ពុទ្ធានុភាពធំ ចិត្តរបស់មហាបុរសនោះ រមែងតាំងនៅក្នុងមហាពោធិញ្ញាណ ធ្វើនូវបាដិហារ្យនោះឲ្យជាអារម្មណ៍ ព្រោះអាស្រ័យព្រះតថាគតនោះថា ព្រះ មានព្រះភាគមានធម៌គួរអស្ចារ្យ មិនធ្លាប់មាន និងអានុភាពជាអចិន្តេយ្យយ៉ាង នេះ ព្រោះដឹងច្បាស់ ចាក់ធ្លុះនូវធម្មធាតុ ដែលមានអានុភាពច្រើនហ្ន៎ ។ ព្រះ មហាបុរសនោះ បង្អោនទៅក្នុងសម្ពោធិញ្ញាណនោះ ធ្វើធម្មធាតុនោះឲ្យជា បច្ច័យ អាស្រ័យការឃើញអានុភាពធំនោះឯង រមែងតាំងចិត្តទុកក្នុង អភិនីហារនោះ នេះជាបច្ច័យទី ១ នៃមហាភិនីហារ ។

មហាបុរសមិនឃើញភាពដែលព្រះតថាគត មានអានុភាពធំ តាម ដែលពោលហើយ តែស្ដាប់ថា ព្រះមានព្រះភាគមានសភាពដូច្នេះ និងដូច្នេះ មហាបុរសនោះ បង្អោនទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឲ្យជាបច្ច័យ អាស្រ័យព្រះមានព្រះភាគនោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ នេះជាបច្ច័យ ទី ២ នៃមហាភិនីហារ ។

មហាបុរស មិនឃើញភាពដែលព្រះតថាគតនោះ មានអានុភាពធំ តាមដែលពោលហើយ ទាំងមិនបានស្ដាប់អានុភាពធំនោះ អំពីអ្នកដទៃ តែ

កាលព្រះតថាគតទ្រង់សម្តែងធម៌ មហាបុរសរមែងស្តាប់ធម៌ បដិសំយុត្ត ដោយពុទ្ធានុភាព ដោយន័យ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាល ភិក្ខុទាំងឡាយ ព្រះតថាគតប្រកបដោយកម្លាំង ១០ ដូច្នេះជាដើម ។ មហា បុរសនោះ បង្អោនទៅក្នុងសម្ពោធិញាណ ធ្វើធម្មធាតុនោះឲ្យជាបច្ច័យ អាស្រ័យពុទ្ធានុភាពនោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ នេះជាបច្ច័យទី ៣ នៃមហាភិនីហារ ។

មហាបុរសមិនឃើញភាពដែលព្រះតថាគតនោះ មានអានុភាពធំតាម ដែលពោលហើយ ទាំងមិនបានស្តាប់អានុភាពធំនោះអំពីអ្នកដទៃ ទាំងមិន បានស្តាប់ធម៌របស់ព្រះតថាគត តែជាអ្នកមានអធ្យាស្រ័យទូលាយ មានការ តាំងចិត្តល្អ គិតថា អញនឹងរក្សាវង្សរបស់ព្រះពុទ្ធ បែបផែនរបស់ព្រះពុទ្ធ បវេណីរបស់ព្រះពុទ្ធ ភាពជាធម៌របស់ព្រះពុទ្ធ ហើយធ្វើសក្ការៈ គោរពរាប់ អាន បូជាធម៌ប៉ុណ្ណោះ ប្រព្រឹត្តធម៌ បង្អោនទៅក្នុងសម្ពោធិញាណ ធ្វើធម្មធាតុ នោះឲ្យជាបច្ច័យ អាស្រ័យធម៌នោះ រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ នេះ ជាបច្ច័យទី ៤ នៃមហាភិនីហារ ។

ក្នុងអភិនីហារនោះ ហេតុ ៤ នៃអភិនីហារ តើដូចម្តេច មហាបុរសក្នុង លោកនេះ តាមប្រក្រតី ជាអ្នកសម្បូរដោយឧបនិស្ស័យ សាងសមអធិការ ក្នុងពុទ្ធព្រះទាំងឡាយនាកាលមុន នេះជាហេតុទី ១ នៃអភិនីហារ ។ នៅមាន ប្រការដទៃទៀត មហាបុរសតាមប្រក្រតី ជាអ្នកមានអធ្យាស្រ័យករុណា បង្អោនទៅក្នុងករុណា បំណងនាំទុក្ខរបស់សត្វទាំងឡាយចេញទៅ លះកាយ

និងជីវិតរបស់ខ្លួន នេះជាហេតុទី ២ នៃមហាភិនីហារ ។ នៅមានតទៅទៀត មហាបុរស មានព្យាយាម មិនទៀយណាយ ដើម្បីចេញចាកវដ្តទុក្ខទាំងមូល និងការប្រព្រឹត្តកិច្ចដែលធ្វើបានកម្រ ដើម្បីប្រយោជន៍ដល់សត្វអស់កាលយូរ មិនតក់ស្លុត ដរាបដល់សម្រេចនូវប្រយោជន៍ដែលប្រាថ្នា នេះជាហេតុទី ៣ នៃមហាភិនីហារ ។ នៅមានតទៅទៀត មហាបុរស ជាអ្នកអាស្រ័យកល្យាណមិត្ត ដែលហាមចាកវត្ថុមិនជាប្រយោជន៍ ឲ្យតាំងនៅក្នុងវត្ថុជាប្រយោជន៍ នេះជាហេតុទី ៤ នៃមហាភិនីហារ ។

គប្បីជ្រាបឧបនិស្ស័យសម្បទារបស់មហាបុរសដូច្នេះ អធ្យាស្រ័យនៃមហាបុរសនោះ បង្អោនទៅ ទោរទន់ទៅ ឈមទៅក្នុងសម្ពោធិញ្ញាណ ដោយចំណែកមួយប៉ុណ្ណោះ យ៉ាងណា ការប្រព្រឹត្តប្រយោជន៍ដល់សត្វទាំងឡាយក៏យ៉ាងនោះ ព្រោះមហាបុរសនោះ ធ្វើនូវការតាំងចិត្តពិត ដើម្បីសម្ពោធិញ្ញាណ ក្នុងសម្នាក់នៃព្រះពុទ្ធក្នុងកាលមុន ដោយចិត្ត និងវាចាថា អាត្មាអញនឹងដូចព្រះសម្មាសម្ពុទ្ធអង្គនេះ គប្បីញុំាងប្រយោជន៍ និងសេចក្ដីសុខឲ្យសម្រេចដល់សត្វទាំងឡាយ ដោយប្រពៃដូចគ្នា ។ មហាបុរស មានឧបនិស្ស័យសម្បូរយ៉ាងនេះ ទើបមានភេទដែលធ្វើឲ្យធំពិសេសក្រៃលែង មានការធ្វើដ៏ធំផ្សេងអំពីសាវកពោធិសត្វ និងបច្ចេកពោធិសត្វ ទាំងខាងឥន្ទ្រិយ ខាងកិច្ចបដិបត្តិ និងខាងភាពឈ្លាសវៃ ។ បុគ្គលដទៃ ក្នុងលោកនេះ បដិបត្តិមិនបានដូចមហាបុរសដែលដល់ព្រមដោយឧបនិស្ស័យ មានឥន្ទ្រិយបរិសុទ្ធ មានញាណបរិសុទ្ធ មហាបុរសជាអ្នកបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិន

មែនដើម្បីប្រយោជន៍ខ្លួន ។ ជាការពិត បុគ្គលក្រៅអំពីនេះ មិនបានបដិបត្តិ ដូចមហាបុរសនោះ ដែលបដិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់មហាជន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្យ៉ាងទៀត មហាបុរស រមែងនាំមកនូវភាពជាអ្នកឈ្លាសក្នុងប្រយោជន៍ និងសេចក្តីសុខនោះ ព្រោះបដិភាណដែលកើតឡើងតាមឋានៈ និងព្រោះភាពជាអ្នកឈ្លាសក្នុងឋានៈ និងអឋានៈ ។

ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈនៃទានបារមីរបស់មហាបុរស ដែលមានអធ្យាស្រ័យក្នុងទាន មានជាដើមថា មហាបុរសតាមប្រក្រតី ជាអ្នកមានអធ្យាស្រ័យក្នុងទាន ត្រេកអរក្នុងទាន កាលមានទេយ្យធម៌ រមែងឲ្យនោះឯងមិននឿយណាយចាកការឲ្យទាន ជាអ្នកមានប្រក្រតីចែករំលែករឿយៗ ជាអ្នកមានចិត្តរីក អើពើក្នុងការឲ្យ មានការជាក់ចិត្តក្នុងការឲ្យ កាលឲ្យទានសូម្បីច្រើន ក៏មិនគ្រប់គ្រាន់ក្នុងការឲ្យ ចាំបាច់ពោលថ្វីដល់ការឲ្យតិច ម្យ៉ាងទៀត កាលនឹងញុំាងឧស្សាហៈឲ្យកើតដល់អ្នកដទៃ រមែងពោលដល់គុណក្នុងការឲ្យ សម្តែងធម៌ បដិសំយុត្តដោយការឲ្យ ម្យ៉ាងទៀត ឃើញអ្នកដទៃឲ្យដល់អ្នកដទៃ ក៏ពេញចិត្ត ឲ្យអភ័យដល់អ្នកដទៃ ក្នុងឋានៈដែលជាភ័យ ។

ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈនៃសីលបារមីរបស់មហាបុរស ដែលមានអធ្យាស្រ័យក្នុងសីលយ៉ាងនេះថា មហាបុរសរមែងខ្មាស រមែងខ្ពើចំពោះធម៌លាមក មានសម្លាប់សត្វជាដើម ជាអ្នកមិនបៀតបៀនសត្វទាំង

ឡាយ ជាអ្នកត្រេកអរក្នុងធម៌ស្អាត ជាអ្នកមានសីលល្អ មិនអួតអាង មិនមានមាយា ស្មោះត្រង់ ប្រដៅងាយ ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកទន់ភ្លន់ មិនរឹងត្អឹង មិនលុបគុណ មិនកាន់យករបស់អ្នកដទៃដោយហោចស្មៅមួយសរសៃ មិនធ្វើបុគ្គលដែលមកខ្ចីបុលអស់សង្ឃឹម ឬកាលអ្នកដទៃភ្លេចទ្រព្យក្នុងលំនៅរបស់ខ្លួន ក៏ប្រាប់ឲ្យដឹង ហើយប្រគល់ឲ្យមិនគៃបន្លំយកទ្រព្យអ្នកដទៃ (ដែលភ្លេចនោះ) មិនជាអ្នកលោភលន់ សូម្បីតែចិត្តបាបក្នុងការកាន់យករបស់អ្នកដទៃ ក៏មិនឲ្យកើតឡើង វៀរច្ចាយចាកអបាយមុខមានភាពជាអ្នកលេងស្រីជាដើម និយាយតែពាក្យពិត ជាបុគ្គលទុកចិត្តបាន ផ្សះផ្សាបុគ្គលដែលបែកបាក់គ្នា បន្ថែមវត្ថុដែលជាប្រយោជន៍ឲ្យជាអ្នកពោលពាក្យជាទីស្រឡាញ់ ជាអ្នកមានមុខស្រស់ស្រាយ ពោលពាក្យជាអត្ថ ជាធម៌ មិនមានការចង់បាន មិនមានចិត្តព្យាបាទ មានការឃើញមិនវិបរិត ដោយដឹងភាពដែលសត្វមានកម្មជារបស់ខ្លួន ដោយកំណត់ដឹងអរិយ-សច្ច មាននូវកតញ្ញូកតវេទី គោរពក្រែងចំពោះបុគ្គលដែលចម្រើនដោយវ័យមានអាជីវៈបរិសុទ្ធ ប្រាថ្នានូវធម៌ ដឹកនាំអ្នកដទៃក្នុងធម៌ ហាមសត្វទាំងឡាយចាកវត្ថុដែលមិនគួរធ្វើ ដោយប្រការទាំងពួង ឲ្យតាំងនៅក្នុងវត្ថុដែលគួរធ្វើ ប្រកបព្យាយាមក្នុងកិច្ចនោះដោយខ្លួន កាលធ្វើវត្ថុមិនគួរធ្វើដោយខ្លួនឯងប្រញាប់ប្រញាល់វៀរចាកវត្ថុនោះមួយរំពេច ។

ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈនៃនេក្ខម្មបារមីជាដើម ដោយអំណាចនៃអធ្យាស្រ័យក្នុងនេក្ខម្មៈជាដើមរបស់មហាបុរស មានយ៉ាងនេះថា មហាបុរស

ជាអ្នកមានកិលេសស្តើង មាននីវរណៈស្តើង មានអធ្យាស្រ័យក្នុងទីស្ងាត់ ជាអ្នកមិនរាយមាយ វិតក្កដ៏លាមក មិនហូរចូលក្នុងចិត្តរបស់មហាបុរសនោះ ។ ម្យ៉ាងទៀត ចិត្តរបស់មហាបុរសនោះ ដល់នូវការស្ងាត់ តាំងមាំដោយមិនលំបាក ភាពជាអ្នកមានចិត្តមេត្តា រមែងតាំងនៅក្នុងចំណែកដែលជាសត្រូវយ៉ាងរហ័ស មិនចាំបាច់ពោលដល់បុគ្គលដែលជាមិត្ត ជាអ្នកមានស្មារតី រឭកដល់វត្ថុដែលគួរធ្វើ និងពាក្យដែលនិយាយក្នុងកាលយូរហើយបាន ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា មានឱជៈកើតអំពីធម៌ ជាអ្នកឈ្លាសក្នុងកិច្ចដែលគួរធ្វើនោះៗ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ក្នុងការធ្វើប្រយោជន៍ដល់សត្វទាំងឡាយ ជាអ្នកប្រកបដោយកម្លាំងខន្តី អត់ធន់បានទាំងអស់ ជាអ្នកមានការតាំងចិត្តមិនញាប់ញ័រ សមាទានមាំទាំ និងជាអ្នកព្រងើយក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខា ។

កាលមហាបុរសប្រកបដោយលក្ខណៈនៃពោធិសម្ភារទាំងនេះ ដោយប្រការដូច្នេះ ទើបលោកពោលថា ការអាស្រ័យកល្យាណមិត្រ ជាហេតុនៃអភិនីហារដូច្នេះ លក្ខណៈកល្យាណមិត្រក្នុងរឿងនោះ មានសេចក្តីសង្ខេបដូចតទៅ កល្យាណមិត្រក្នុងលោកនេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគៈ វិរិយៈ សតិ សមាធិ បញ្ញា ។ បណ្តាគុណធម៌ទាំងនោះ មហាបុរសជឿការត្រាស់ដឹងរបស់ព្រះតថាគត និងផលនៃកម្ម ដោយសទ្ធាសម្បត្តិ ព្រោះហេតុនោះ ទើបមិនលះបង់នូវការស្វែងរកប្រយោជន៍ដល់សត្វទាំងឡាយ ដែលជាហេតុនៃសម្មាសម្ពោធិញាណ ជាទីស្រឡាញ់ ជាទី

ពេញចិត្ត ជាទីគោរព គួរលើកតម្កើងនៃសត្វទាំងឡាយ ជាអ្នកឃាំងជាស់តឿន តិះដៀលនូវអំពើអាក្រក់ រង់ចាំជាស់តឿន អត់ធន់ចំពោះពាក្យអាក្រក់ ដោយសីលសម្បត្តិ ជាអ្នកពោលធម៌ជ្រាលជ្រៅ នាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់សត្វទាំងឡាយ ដោយសុតសម្បត្តិ ជាអ្នកប្រាថ្នាតិច សន្តោសស្ងាត់ មិនច្រឡូកច្រឡំដោយចាគសម្បត្តិ ជាអ្នកប្រារព្ធសេចក្តីព្យាយាមក្នុងកិច្ចបដិបត្តិ ដើម្បីជាប្រយោជន៍នៃសត្វទាំងឡាយ ដោយវិរិយសម្បត្តិ ជាអ្នកមានសតិតាំងមាំក្នុងធម៌ដែលមិនមានទោស ដោយសតិសម្បត្តិ ជាបុគ្គលមិនរាយមាយ មានចិត្តតាំងមាំ ដោយសមាធិសម្បត្តិ ។ រមែងដឹងនូវការមិនវិបរិត ដោយបញ្ញាសម្បត្តិ ។ មហាបុរសនោះ ស្វែងរកគតិនៃកុសលធម៌ និងអកុសលធម៌ដោយសតិ ដឹងនូវប្រយោជន៍ និងមិនមែនប្រយោជន៍នៃសត្វទាំងឡាយ តាមសេចក្តីពិតដោយបញ្ញា មានចិត្តឯកក្នុងធម៌នោះដោយសមាធិ ហាមឃាត់នូវសត្វទាំងឡាយ ចាកវត្ថុដែលមិនជាប្រយោជន៍ ហើយឲ្យប្រកបក្នុងវត្ថុដែលជាប្រយោជន៍ដោយវិរិយៈ ដូចព្រះមានព្រះភាគត្រាស់ ( អង្គុត្តរនិកាយ សត្តកនិបាត ) ថា

> ភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ដូច្នេះ ។

មហាបុរសអាស្រ័យកល្យាណមិត្រ ប្រកបដោយគុណយ៉ាងនេះហើយ

រមែងញ៉ាំងឧបនិស្សយសម្បត្តិរបស់ខ្លួនឲ្យផូរផង់ ដោយប្រពៃនោះឯង និងជាអ្នកប្រកបដោយអធ្យាស្រ័យបរិសុទ្ធដោយល្អ ជាអ្នកប្រកបដោយពល ៤ ញ៉ាំងអង្គ ៨ ឲ្យប្រជុំគ្នាដោយមិនយឺតយូរ ធ្វើមហាភិនីហារ មានការមិនត្រឡប់ជាធម្មតា ជាបុគ្គលទៀង មានសម្ពោធិញ្ញាណជាទីទៅខាងមុខ រមែងតាំងនៅក្នុងភាពជាព្រះពោធិសត្វ ។

គប្បីជ្រាបពលទាំង ៤ នេះ នៃអភិនីហារនោះ ដូចតទៅនេះថា

អជ្ឈត្តិកពល ( កម្លាំងខាងក្នុង ) បានដល់ ការពេញចិត្តដោយគោរពក្នុងធម៌អាស្រ័យខ្លួន ក្នុងសម្មាសម្ពោធិញ្ញាណ ព្រោះជាអ្នកមានអធ្យាស្រ័យបង្អោនទៅដោយចំណែកមួយ ។ មហាបុរសមានខ្លួនជាធំ មានការខ្មាសដែលជាទីអាស្រ័យ និងដល់ព្រមដោយអភិនីហារ បំពេញបារមី ហើយសម្រេចសម្មាសម្ពោធិញ្ញាណ ។

ពាហិរពល ( កម្លាំងខាងក្រៅ ) បានដល់ ការពេញចិត្តអាស្រ័យអ្នកដទៃ ក្នុងសម្មាសម្ពោធិញ្ញាណ ព្រោះជាអ្នកមានអធ្យាស្រ័យបង្អោនទៅដោយចំណែកមួយ ។ មហាបុរសមានលោកជាធំ មានការរាប់អានជាទីអាស្រ័យ និងដល់ព្រមដោយអភិនីហារ បំពេញបារមី ហើយសម្រេចសម្មាសម្ពោធិញ្ញាណ ។

ឧបនិស្សយពល ( កម្លាំងឧបនិស្ស័យ ) បានដល់ ការពេញចិត្តដោយឧបនិស្សយសម្បត្តិ ក្នុងសម្មាសម្ពោធិញ្ញាណ ព្រោះជាអ្នកមានអធ្យាស្រ័យបង្អោនទៅដោយចំណែកមួយ ។ មហាបុរសមានឥន្ទ្រិយចាស់ក្លា

មានការឈ្លាសវៃ អាស្រ័យសតិ ដល់ព្រមដោយអភិនីហារ បំពេញបារមី ហើយសម្រេចសព្វញ្ញុតញ្ញាណ ។

បយោគពល ( កម្លាំងព្យាយាម ) បានដល់ ការដល់ព្រមដោយសេចក្តីព្យាយាម ភាពជាអ្នកធ្វើដោយគោរព ភាពជាអ្នកធ្វើជាប់តគ្នា ដែលកើតអំពីសេចក្តីព្យាយាមនោះ ក្នុងសម្មាសម្ពោធិញ្ញាណ មហាបុរសមានព្យាយាមបរិសុទ្ធ ធ្វើជានិរន្តរ៍ និងដល់ព្រមដោយអភិនីហារ បំពេញបារមី ហើយសម្រេចសម្មាសម្ពោធិញ្ញាណ ។

អភិនីហារនេះ ដល់ព្រមដោយសមោធានធម៌មានអង្គ ៨ ដល់នូវភាពបរិបូណ៌ដោយបច្ច័យ ៤ ( មានការឃើញព្រះតថាគតទ្រង់ធ្វើបាដិហារ្យជាដើម ) ហេតុ ៤ ពល ៤ យ៉ាងនេះ ជាបច្ច័យនៃបារមីទាំងឡាយ ព្រោះភាពជាហេតុ ។ម្យ៉ាងទៀត ធម៌ទាំងឡាយគួរអស្ចារ្យ មិនធ្លាប់មាន ៤ ប្រការ រមែងតាំងនៅក្នុងមហាបុរស ដោយការប្រព្រឹត្តទៅរបស់បុគ្គលណា រមែងរាប់អានសព្វសត្វ ដោយចិត្តដែលស្រឡាញ់ ដូចបុត្រកើតអំពីទ្រូង ។ ចិត្តរបស់បុគ្គលនោះ មិនសៅហ្មងដោយអំណាចសេចក្តីសៅហ្មងដល់បុត្រ ។ អធ្យាស្រ័យ និងសេចក្តីព្យាយាមរបស់មហាបុរសនោះ រមែងនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់សត្វទាំងឡាយ ។ ធម៌ដែលធ្វើឲ្យជាព្រះពុទ្ធរបស់ខ្លួន រមែងចម្រើន រមែងឲ្យមានផលក្រៃលែងឡើង ។ ម្យ៉ាងទៀត មហាបុរសប្រកបដោយផលនៃបុណ្យកុសលដ៏ឧត្តម ដែលជាបច្ច័យនៃការប្រព្រឹត្តទៅជាអាហារនៃសេចក្តីសុខ ជាបុគ្គលគួរទទួលទក្ខិណា ជាទីតាំងនៃគារវៈដ៏ឧត្តម

និងជាបុញ្ញក្ខេត្តមិនមានបុគ្គលស្មើដល់សត្វទាំងឡាយ ។ មហាភិនីហារមានគុណច្រើន មានអានិសង្សច្រើនយ៉ាងនេះ គប្បីជ្រាបថា ជាបច្ច័យនៃបារមីទាំងឡាយ ។

មហាករុណា និងភាពជាអ្នកឈ្លាសក្នុងឧបាយ ក៏ដូចអភិនីហារនោះឯង ។ ក្នុងមហាករុណា និងភាពជាអ្នកឈ្លាសក្នុងឧបាយនោះ បញ្ញាដែលជានិមិត្តនៃភាពជាពោធិសម្ភាររបស់ទានជាដើម ឈ្មោះថា ភាពជាអ្នកឈ្លាសក្នុងឧបាយ ។ ការមិនពិចារណាដល់សុខរបស់ខ្លួន ការខ្វល់ខ្វាយក្នុងការធ្វើប្រយោជន៍ដើម្បីអ្នកដទៃជាលំដាប់ ការមិនថោកថយដោយការប្រព្រឹត្តរបស់ព្រះមហាសត្វ ធ្វើបានដោយក្រ និងភាពជាហេតុបាននូវប្រយោជន៍និងសេចក្ដីសុខរបស់សត្វទាំងឡាយ ក្នុងពេលជ្រះថ្លា ការដឹង ការឃើញការស្ដាប់ ការរឭកដល់ រមែងសម្រេចដល់មហាបុរសទាំងឡាយ ដោយភាពជាអ្នកឈ្លាសក្នុងឧបាយ ដែលជាមហាករុណា ។ ពិតហើយ មហាបុរសនោះ ដល់នូវការសម្រេចនៃភាពជាព្រះពុទ្ធដោយបញ្ញា ដល់នូវការសម្រេចនៃកម្មដែលធ្វើឲ្យបានជាព្រះពុទ្ធដោយករុណា ឆ្លងឯងបានដោយបញ្ញា ញុំាងអ្នកដទៃឲ្យឆ្លងដោយករុណា កំណត់ដឹងទុក្ខរបស់អ្នកដទៃដោយបញ្ញា ប្រារព្ធជួយស្រោចស្រង់អ្នកដទៃ ដែលមានទុក្ខដោយករុណា នឿយណាយក្នុងទុក្ខដោយបញ្ញា ទទួលទុក្ខដោយករុណា ជាបុគ្គលបែរមុខចំពោះព្រះនិព្វានដោយបញ្ញា ដល់នូវវដ្ដៈដោយករុណា បែរមុខទៅរកសង្សារដោយករុណា មិនត្រេកអរក្នុងសង្សារដោយបញ្ញា នឿយណាយក្នុងទីទាំងពួងដោយបញ្ញា ព្រោះ

អនុលោមតាមករុណា ទើបអនុគ្រោះសត្វទាំងពួងដោយមិនវៀរ អនុគ្រោះសត្វទាំងពួងដោយករុណា ។ ព្រោះអនុលោមតាមបញ្ញា ទើបមានចិត្តនឿយណាយក្នុងទីទាំងពួង មានភាពជាអ្នកមិនមានអហង្ការ មមង្ការដោយបញ្ញា មានការមិនខ្ជិលច្រអូសដោយករុណា ។ ម្យ៉ាងទៀត ដោយបញ្ញា និងករុណា មហាបុរសសម្រេចគុណសម្បត្តិតាមលំដាប់ គឺភាពជាទីពឹងរបស់ខ្លួន និងអ្នកដទៃ ភាពជាអ្នកមានបញ្ញា និងក្លៀវក្លា ភាពជាអ្នកមិនធ្វើខ្លួនឲ្យក្តៅក្រហាយ មិនធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ការសម្រេចប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ភាពជាអ្នកមិនមានភ័យ មិនតក់ស្លុត ភាពជាអ្នកមានធម៌ជាធំ មិនមានលោកជាធំ ភាពជាបុគ្គលដឹងគុណដល់អ្នកធ្វើឧបការៈមុន ការប្រាសចាកមោហៈ និងតណ្ហា ការសម្រេចវិជ្ជា និងចរណៈ ការសម្រេចនៃពល និងវេសារជ្ជៈ ។ ហេតុនោះ បញ្ញា និងករុណា ទើបជាបច្ច័យនៃបារមីទាំងឡាយ ព្រោះភាពជាឧបាយដោយពិសេសនៃផលរបស់បារមីទាំងពួង ដោយប្រការដូច្នេះឯង ។ ទាំង ២ នេះ ជាបច្ច័យនៃបណិធានដូចជាបច្ច័យនៃបារមីទាំងឡាយ ។

ម្យ៉ាងទៀត ឧស្សាហៈ បញ្ញា ការមាំទាំ និងការប្រព្រឹត្តប្រយោជន៍ គប្បីជ្រាបថា ជាបច្ច័យនៃបារមីទាំងឡាយ ។ ដែលហៅថា ពុទ្ធភូមិ ព្រោះជាទីកើតនៃពុទ្ធភាវៈ ។ ក្នុងបច្ច័យទាំងនោះ សេចក្តីព្យាយាមដោយការអត់ធ្មត់ក្រៃលែងនៃពោធិសម្ភារទាំងឡាយ ឈ្មោះថា ឧស្សាហៈ ។ បញ្ញាដែលជាការឈ្លាសក្នុងឧបាយ ក្នុងពោធិសម្ភារទាំងឡាយ ឈ្មោះថា បញ្ញា ។ ការ

តាំងចិត្តមាំ ព្រោះតាំងចិត្តមិនញាប់ញ័រ ឈ្មោះថា មាំទាំ ។ មេត្តាភាវនា និង
ករុណាភាវនា ឈ្មោះថា ការប្រព្រឹត្តប្រយោជន៍ ។

ម្យ៉ាងទៀត អធ្យាស្រ័យ ៦ ចែកចេញជានេក្ខម្មៈ បវិវេក អលោភៈ អទោសៈ អមោហៈ និងនិស្សរណៈ ។ ព្រះពោធិសត្វទាំងឡាយ ជាអ្នកឃើញទោសក្នុងកាម និងក្នុងការគ្រប់គ្រងផ្ទះ ឈ្មោះថា នេក្ខម្មៈ ។ ម្យ៉ាងទៀត ព្រះពោធិសត្វទាំងឡាយ ឃើញទោសក្នុងការប្រឡូកប្រឡំ ឈ្មោះថា មានអធ្យាស្រ័យក្នុងបវិវេក ឃើញទោសក្នុងលោភៈ ឈ្មោះថា អលោភៈ ។ ឃើញទោសក្នុងទោសៈ ឈ្មោះថា អទោសៈ ឃើញទោសក្នុងមោហៈ ឈ្មោះថា អមោហៈ ឃើញទោសគ្រប់សភាវៈ ឈ្មោះថា និស្សរណៈ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ អធ្យាស្រ័យទាំង ៦ នេះ របស់ព្រះពោធិសត្វទាំងឡាយ ជាបច្ច័យនៃបារមីទាំងឡាយ មានទានជាដើម ។ ពិតហើយ បារមីមានទានបារមីជាដើម បើវៀរការឃើញទោសក្នុងលោភៈជាដើម និងភាពប្រសើរនៃអលោភៈជាដើមហើយ ក៏មានមិនបាន ព្រោះភាពជាអ្នកមានចិត្តបង្អោនទៅក្នុងបរិច្ចាគជាដើម ដោយភាពប្រសើររបស់អលោភៈជាដើម គប្បីជ្រាបថា ជាអ្នកមានអធ្យាស្រ័យមិនលោភ ។

ម្យ៉ាងទៀត ភាពជាអ្នកមានអធ្យាស្រ័យក្នុងទានក៏យ៉ាងនោះ ជាបច្ច័យនៃទានបារមីជាដើម របស់ព្រះពោធិសត្វទាំងឡាយ ដែលប្រព្រឹត្តដើម្បីពោធិញ្ញាណ ។ ពិតហើយ ព្រោះភាពជាអ្នកមានអធ្យាស្រ័យក្នុងទាន ព្រះពោធិសត្វទាំងឡាយ ទើបជាអ្នកឃើញទោសក្នុងសេចក្តីកំណាញ់ ដែលជា

បដិបក្ខចំពោះទាននោះ ទើបបំពេញទានបារមីឲ្យបរិបូណ៌ដោយប្រពៃ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសីល ជាអ្នកឃើញទោសក្នុងភាពជាអ្នកទ្រុស្តសីល ទើបបំពេញបារមីឲ្យបរិបូណ៌ដោយប្រពៃ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងនេក្ខម្មៈ ឃើញក្នុងកាម និងក្នុងការគ្រប់គ្រងផ្ទះ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងការដឹងតាមសេចក្ដីពិត ឃើញទោសក្នុងការមិនដឹង និងសេចក្ដីសង្ស័យ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសេចក្ដីព្យាយាម ឃើញទោសក្នុងការខ្ជិលប្រអូស ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងការអត់ធន់ ឃើញទោសក្នុងការមិនអត់ធន់ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសច្ចៈ ឃើញទោសក្នុងការនិយាយខុស ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងការតាំងចិត្តមាំ ឃើញទោសក្នុងការមិនតាំងមាំ ព្រោះជាអ្នកមានអធ្យាស្រ័យមេត្តា ឃើញទោសក្នុងព្យាបាទ ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងឧបេក្ខា ឃើញទោសក្នុងលោកធម៌ ទើបបំពេញបារមី មាននេក្ខម្មបារមីជាដើមឲ្យបរិបូណ៌ដោយប្រពៃ ។ ភាពជាអ្នកមានអធ្យាស្រ័យក្នុងទានជាដើម ទើបចាត់ជាបច្ច័យ ព្រោះជាហេតុឲ្យសម្រេចទានបារមីជាដើម ។

ការពិចារណាឃើញទោស និងអានិសង្សតាមលំដាប់ ក្នុងការមិនបរិច្ចាគ និងការបរិច្ចាគជាដើម ជាបច្ច័យនៃទានបារមីជាដើមដូចគ្នា ។ ក្នុងបទនោះ គប្បីជ្រាបវិធីពិចារណាដូចតទៅនេះ ធម្មតាវត្ថុដែលសត្វទាំងឡាយហួងហែង ជារបស់នាំមកនូវសេចក្ដីវិនាសយ៉ាងធំច្រើនយ៉ាង ដូច្នេះ គឺដល់សត្វទាំងឡាយ ដែលមានចិត្តជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិ មានដី ចម្ការ

ប្រាក់ មាស គោ ក្របី ខ្ញុំស្រី ខ្ញុំប្រុស បុត្រ ភរិយាជាដើម ដូច្នេះគឺ

ជាហេតុនៃសេចក្តីវិនាស ព្រោះសម្បត្តិមានដីជាដើម មានមនុស្សច្រើនបានច្រើន ដោយភាពជាវត្ថុដែលគួរប្រាថ្នា ព្រោះជាសាធារណៈដល់ភ័យមានរាជភ័យ និងចោរភ័យជាដើម ព្រោះជាទីតាំងនៃវិវាទ នាំមកនូវសត្រូវ ព្រោះជាវត្ថុមិនមានខ្លឹមសារ ព្រោះជាហេតុឲ្យបៀតបៀនអ្នកដទៃ ទាំងក្នុងការបាន និងការថែរក្សា ។

ជាហេតុនៃផលដែលទាក់ទងជាមួយទ្រព្យសម្បត្តិនោះ ព្រោះនាំមកនូវការវិនាសច្រើនយ៉ាង មានសេចក្តីសោកជាដើម ដល់សត្វដែលមានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រឹតរុំ ព្រោះភាពជាហេតុឲ្យកើតក្នុងអបាយ ។ ការបរិច្ចាគនូវវត្ថុទាំងនោះ ទើបជាសួស្តី ព្រោះហេតុនោះ ទើបគួរធ្វើសេចក្តីមិនប្រមាទក្នុងការបរិច្ចាគ ។

មួយ៉ាងទៀត គប្បីពិចារណាឃើញថា បុគ្គលអ្នកសូម កាលសូម ជាអ្នកស្និទ្ធស្នាលរបស់យើង ព្រោះប្រាប់អាថ៌កំបាំងរបស់ខ្លួន ជាអ្នកទូន្មានដល់យើងថា ព្រោះហាក់ដូចជាប្រាប់ថា ចូរកាន់យករបស់ដែលជាប់ខ្លួនទៅកាន់បរលោក កាលលោកត្រូវភ្លើង គឺមរណៈដុត ដូចផ្ទះដែលត្រូវភ្លើងឆេះ ជាសម្លាញ់ជួយជញ្ជូនរបស់យើងចេញទៅអំពីលោកនេះ ជាទីទុកដាក់របស់ដែលភ្លើងមិនឆេះ ដែលជញ្ជូនចេញទៅ ជាកល្យាណមិត្តក្រៃលែង ព្រោះជាសម្លាញ់ក្នុងកល្យាណកម្ម គឺទាន និងព្រោះភាពជាហេតុឲ្យដល់ពុទ្ធភូមិដែលបានដោយលំបាកក្រៃលែងជាងសម្បត្តិទាំងពួង ។

ម្យ៉ាងទៀត គប្បីចូលទៅតាំងការបង្អោនក្នុងកិរិយាបរិច្ចាគថា បុគ្គលនេះសរសើរអញក្នុងកម្មដ៏ក្រៃលែង ព្រោះហេតុនោះ គួរធ្វើនូវការសរសើរនោះឲ្យជាការពិត ១ ព្រោះជីវិតមានការបែកធ្លាយទៅ ដោយចំណែកមួយសូម្បីបុគ្គលនោះមិនសូម អញក៏ឲ្យ នឹងពោលថ្វីដល់ការសូម ១ បុគ្គលនោះមកឯងដោយបុណ្យរបស់អញ ព្រោះជាអ្នកមានអធ្យាស្រ័យធំ ជាអ្នកស្វែងរកអ្នកទទួល ទើបឲ្យបុណ្យដល់អញ ១ ការអនុគ្រោះរបស់អញនេះដោយបំណងដល់ការឲ្យដល់យាចក ១ អញគួរអនុគ្រោះសត្វលោកទាំងអស់នេះ ដូចជាខ្លួនរបស់អញ ១ កាលយាចកមិនមាន ទានបារមីរបស់អញនឹងពេញបានដូចម្តេច ១ អញគួររក្សាទ្រព្យទាំងអស់ដើម្បីយាចកប៉ុណ្ណោះ ១ កាលយាចកទាំងឡាយមិនសូមអញ យាចកគប្បីកាន់យកទ្រព្យអញទៅឯងក្នុងកាលណា ១ អញគប្បីជាទីស្រឡាញ់ និងជាទីពេញចិត្តនៃយាចកទាំងឡាយបានដូចម្តេច ១ យាចកទាំងនោះ គប្បីជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អញបានដូចម្តេច ១ អញកាលឲ្យ ក៏ពេញចិត្ត ឲ្យហើយ ក៏ត្រេកអរកើតនូវបីតិសោមនស្សបានដូចម្តេច ១ យាចកទាំងឡាយរបស់អញ គប្បីទៅជាយ៉ាងណា ទើបអញជាអ្នកមានអធ្យាស្រ័យក្នុងទានទូលំទូលាយ ១ យាចកមិនសូម អញដឹងចិត្តយាចកទាំងឡាយបានដូចម្តេច ហើយទើបឲ្យ ១ កាលទ្រព្យមាន យាចកមាន ការមិនបរិច្ចាគ ជាការបោកបញ្ឆោតរបស់អញធំក្រៃលែង ១ អញគប្បីលះអវយវៈ ឬជីវិតរបស់ខ្លួនដល់យាចកទាំងឡាយបានដូចម្តេច ១ ៗ ម្យ៉ាងទៀត គួរធ្វើចិត្តឲ្យកើតឡើង ដោយមិនពិចារណា

ដល់ប្រយោជន៍ថា ឈ្មោះថា ប្រយោជន៍នេះ រមែងជាប់តាមទាយកដែលមិនប្រាថ្នា ដូចសត្វល្អិតជាប់តាមព្រានធ្នូដែលមិនដាក់ចិត្ត ដូច្នោះ ។

ម្យ៉ាងទៀត បើអ្នកសូមជាមនុស្សដែលអញស្រឡាញ់ គប្បីឲ្យកើតសោមនស្សថា បុគ្គលដែលអញស្រឡាញ់ មកសូមជាមួយនឹងអញ ។ សូម្បីបុគ្គលសូមជាមនុស្សព្រងើយៗ គប្បីឲ្យកើតសោមនស្សថា យាចកនេះ សូមអញ រមែងក្លាយជាមិត្រ ដោយការបរិច្ចាគនេះពិត ។ សូម្បីអ្នកឲ្យ ក៏រមែងជាទីស្រឡាញ់នៃអ្នកសូមទាំងឡាយ ។ កាលបុគ្គលអ្នកមានពៀរសូម ក៏គប្បីឲ្យកើតសោមនស្សជាពិសេសថា សត្រូវសូមអញ សត្រូវនេះ កាលសូមជាមួយអញ ទោះជាបុគ្គលមានពៀរ ក៏ក្លាយជាមិត្រ ជាទីស្រឡាញ់ដោយការបរិច្ចាគនេះពិត ។ គប្បីញ៉ាំងករុណា មានមេត្តាជាខាង មុខឲ្យប្រាកដ ហើយគប្បីឲ្យក្នុងបុគ្គលជាកណ្តាល និងបុគ្គលមានពៀរ ដូចក្នុងបុគ្គលដែលជាទីស្រឡាញ់ ដូច្នោះ ។ បើលោភធម៌ ដែលមានទេយ្យធម៌ជាវិស័យ គប្បីកើតឡើងដល់បុគ្គលដែលមានលោភៈ ព្រោះបុគ្គលនោះថ្មីកមកអស់កាលយូរ ដែលបុគ្គលប្តេជ្ញាជាព្រះពោធិសត្វនោះ គប្បីសិក្សាថា នែសប្បុរស អ្នកបំពេញអភិនីហារដើម្បីត្រាស់ដឹង មិនមែនឬ បានលះកាយនេះ ដើម្បីជាឧបការៈដល់សព្វសត្វ បុណ្យសម្រេចដោយការបរិច្ចាគកាយនោះ ការជាប់ជំពាក់ ប្រព្រឹត្តទៅក្នុងវត្ថុ សូម្បីខាងក្រៅរបស់អ្នកនោះ ដូចគ្នានឹងងូតទឹកដំរី ព្រោះហេតុនោះ អ្នកមិនគួរឲ្យការជាប់ជំពាក់កើតក្នុងទីណាមួយឡើយ កាលដើមឈើធំជាឱសថកើតឡើង បុគ្គលត្រូវការឫស រមែងនាំឫសទៅ បុគ្គល

ត្រូវការក្រម៉ា សម្បក ដើម ប្រគាប ខ្ទឹម មែក ស្លឹក ផ្កា រមែងនាំទៅ បុគ្គលត្រូវការផ្លែ រមែងនាំផ្លែទៅ ដើមឈើនោះ មិនប្រព្រឹត្តឡើងព្រមដោយវិតក្កថា ជនទាំងនេះ នាំរបស់អញទៅ យ៉ាងណា កាលកាយមិនស្អាតជានិច្ច មិនដឹងគុណ លិចចុះក្នុងទុក្ខធំ ដែលអញជាអ្នកដល់នូវសេចក្ដីខ្វល់ខ្វាយ ដើម្បីជាប្រយោជន៍ដល់លោកទាំងពួង ធ្វើដើម្បីឧបការៈដល់សត្វដទៃ មិនគួរឲ្យមិច្ឆាវិតក្កសូម្បីតិចតួចកើតឡើងដូច្នោះ ឬថា សេចក្ដីពិសេសក្នុងធម៌ជាគ្រឿងទម្លាយខ្ចាត់ខ្ចាយ និងកម្ចាត់ដោយចំណែកមួយ ដែលជាមហាភូតរូបខាងក្នុង និងខាងក្រៅ យ៉ាងណា តែសេចក្ដីនេះ ជាការវង្វេង និងជាការស្ញុបស្ញៅតែម្យ៉ាង គឺការប្រកាន់ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ព្រោះហេតុនោះ បុគ្គលមិនគិតដល់ដៃ ជើង ភ្នែកជាដើម និងក្នុងសាច់ជាដើមខាងក្នុង ដូចខាងក្រៅ គប្បីមានចិត្តលះបង់ថា បុគ្គលត្រូវការវត្ថុនោះៗ ចូរនាំទៅចុះ ។

ម្យ៉ាងទៀត កាលមហាបុរសសិក្សាយ៉ាងនេះ ប្រកបសេចក្ដីព្យាយាមដើម្បីត្រាស់ដឹង មិនគិតដល់កាយ និងជីវិត ទើបកាយកម្ម វចីកម្ម មនោកម្មបរិសុទ្ធដោយល្អ ដោយមិនលំបាកឡើយ ។ មហាបុរសនោះ មានកាយកម្មវចីកម្ម មនោកម្ម បរិសុទ្ធដោយល្អ មានអាជីវៈបរិសុទ្ធ តាំងនៅក្នុងកិច្ចបដិបត្តិដើម្បីដឹង ជាអ្នកអាចអនុគ្រោះសព្វសត្វ ដោយការដល់ព្រម ដោយភាពជាអ្នកឈ្លាសក្នុងសេចក្ដីវិនាស និងឈ្លាសក្នុងឧបាយ ដោយបរិច្ចាគទេយ្យធម៌ ដោយប្រមាណក្រៃលែង និងដោយការឲ្យអភ័យ ឲ្យនូវព្រះសទ្ធម្ម

នេះជាន័យក្នុងការពិចារណាទានបារមី ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ពិចារណាក្នុងសីលបារមីយាងនេះថា ឈ្មោះថា សីលនេះ ជាទឹកលាងមន្ទិល គឺទោសៈ ដែលមិនអាចជម្រះបានដោយទឹកក្នុងស្ទឹងគង្គាជាដើម ជាការកម្ចាត់អន្តរាយ មានរាគៈជាដើម ដែលមិនអាចកម្ចាត់បានដោយខ្លឹមចន្ទន៍ជាដើម ជាគ្រឿងប្រដាប់យ៉ាងវិសេសរបស់សប្បុរសទាំងឡាយ មិនទូទៅដោយគ្រឿងប្រដាប់របស់មហាជន មានខ្សែ-ក មកុដ និងកុណ្ឌលជាដើម មិនមានបុគ្គលណាសាងឡើង ព្រោះផ្សាយទៅសព្វទិស មានក្លិនក្រអូប និងសក្តិសមគ្រប់កាល មានអំណាចក្រៃលែង ព្រោះនាំមកនូវគុណដែលខត្តិយមហាសាលជាដើម និងទេវតាទាំងឡាយគួរថ្វាយបង្គំ ជាជណ្តើរឡើងទៅកាន់ទេវលោក មានស្ពានសួគ៌ជាន់ចាតុម្មហារាជិកាជាដើម ជាឧបាយសម្រេចឈាន និងអភិញ្ញា ជាផ្លូវឲ្យដល់មហានគរ គឺព្រះនិព្វាន ជាភូមិប្រតិស្ឋានសាវកពោធិ បច្ចេកពោធិ និងសម្មាសម្ពោធិញ្ញាណ ។ ម្យ៉ាងទៀត សីល រមែងនៅក្នុងឋានៈជាកែវចិន្តាមណី ( កែវដែលឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ) និងដើមកប្បព្រឹក្សជាដើម ព្រោះជាឧបាយឲ្យសម្រេចតាមសេចក្តីត្រូវការ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ម្នាលភិក្ខុ[១] ទាំងឡាយ សេចក្តីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្តីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ដូច្នេះ ។ ក្នុងទីដទៃក៏មានព្រះតម្រាស់ ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំង

---

១- បិដកខ្មែរថា ម្នាលអាវុសោ ។

ឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់ពួកសព្រហ្មចារី ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ដូច្នេះ ។ និង ( ត្រាស់ក្នុងអង្គុត្តរនិកាយ ឯកាទសកនិបាត ) ថា ម្នាលអានន្ទ សីលទាំងឡាយ ជាកុសល មានអវិប្បដិសារៈ ( សេចក្តីមិនក្តៅក្រហាយ ) ជាប្រយោជន៍ ដូច្នេះ ។ និង ( ត្រាស់ក្នុងទីឃនិកាយ មហាវគ្គ ) ថា ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទានេះ មាន ៥ ប្រការ ដូច្នេះ ។ គប្បីពិចារណាគុណរបស់សីលដោយអំណាចនៃសូត្រ មានសីលសម្បទាសូត្រជាដើម ។ គប្បីពិចារណាទោសក្នុងការប្រាសចាកសីល ដោយអំណាចនៃសូត្រ មានអគ្គិក្ខន្ធោបមសូត្រជាដើម ។ គប្បីពិចារណាសីលដោយជានិមិត្តនៃបីតិ និងសោមនស្ស ដោយការមិនមានការតិះដៀលខ្លួនឯង ពោលទោសអ្នកដទៃ និងភ័យអំពីអាជ្ញា និងទុគ្គតិ ដោយភាពជាវត្ថុដែលវិញ្ញូជនសរសើរ ដោយជាហេតុនៃការមិនក្តៅក្រហាយ ដោយជាទីតាំងនៃសួស្តី និងដោយជារបស់ដ៏ក្រៃលែងជាងការដល់ព្រមដោយភាពជាជនធំក្រៃលែង ដោយសម្បត្តិ អធិបតី អាយុ រូប ឋានៈ ពួកញាតិ និងមិត្ត ។ ពិតហើយ បីតិ និងសោមនស្សធំ រមែងកើតដល់អ្នកមានសីល ព្រោះហេតុនៃសីលសម្បទារបស់ខ្លួនថា អាត្មាអញធ្វើកុសលហើយ អាត្មាអញបានធ្វើល្អហើយ អាត្មាអញបានធ្វើនូវការការពារសេចក្តីតក់ស្លុតហើយ ។

ម្យ៉ាងទៀត បុគ្គលមានសីល រមែងមិនតិះដៀលខ្លួន វិញ្ញូជនដទៃមិន

ពោលភ័យព្រោះអាជ្ញា និងទុគ្គតិ រមែងមិនមាន វិញ្ញូជនទាំងឡាយ រមែងសរសើរថា ជាបុគ្គលដែលមានសីល មានធម៌ស្អាត ។ ម្យ៉ាងទៀត ការក្តៅក្រហាយណា រមែងកើតដល់បុគ្គលទ្រុស្តសីលថា អញបានធ្វើអំពើអាក្រក់ហើយហ្ន៎ អញបានធ្វើកម្មគ្រោតគ្រាតហើយ ការក្តៅក្រហាយនោះ មិនមានដល់អ្នកមានសីល ។ ម្យ៉ាងទៀត ធម្មតាសីលនេះ ឈ្មោះថា ជាឋានៈនៃសួស្តីដ៏ក្រៃលែង ព្រោះតាំងចិត្តក្នុងការមិនប្រមាទ ព្រោះឲ្យកាន់យកក្នុងសេចក្តីមិនប្រមាទ ព្រោះញ៉ាំងប្រយោជន៍ធំឲ្យសម្រេចដោយការគ្រប់គ្រងអន្តរាយ មានការវិនាសនៃភោគៈជាដើម និងព្រោះភាពជាមង្គល ។ បុគ្គលមានសីល សូម្បីមានជាតិត្រកូលទាប ក៏ជាបូជនីយបុគ្គល របស់ខត្តិយមហាសាលជាដើម ទើបសីលសម្បទាក្រៃលែងជាងកុសលសម្បត្តិ ។ ក្នុងសេចក្តីនេះ មានព្រះសូត្រ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា បពិត្រមហារាជ ចុះព្រះអង្គសម្គាល់នូវហេតុនោះដូចម្តេច ក្នុងលោកនេះ ( បើ ) មហារាជ មានបុរសជាខ្ញុំបម្រើ ដូច្នេះ ។

សីល រមែងក្រៃលែងជាងទ្រព្យខាងក្រៅ ព្រោះមិនទូទៅដល់ចោរជាដើម ព្រោះជាប់តាមទៅកាន់លោកខាងមុខ ព្រោះមានផលច្រើន និងព្រោះជាទីតាំងនៃគុណ មានសមថៈជាដើម ។ សីល រមែងក្រៃលែងជាងភាពជាធំនៃក្សត្រជាដើម ព្រោះជាទីតាំងនៃភាពជាធំដ៏កំពូល ។ ព្រោះភាពជាធំនៃសត្វទាំងឡាយ ក្នុងពួកសត្វនោះៗ មានសីលជាហេតុ ។ សីល ប្រសើរជាងជីវិត ដូចពុទ្ធវចនថា ជីវិតរបស់អ្នកសីល សូម្បីតែមួយថ្ងៃ ក៏ប្រសើរ

ជាងជីវិតដែលរស់នៅអស់រយនៃឆ្នាំ និងថា កាលនៅមានជីវិត បុគ្គលកន្លងសិក្ខាបទ ស្លាប់វិញប្រសើរជាង ។ សីល រមែងក្រៃលែងជាងរូបសម្បត្តិ ព្រោះ ( រូបសម្បត្តិ ) នាំការពេញចិត្តមកសូម្បីដល់សត្រូវ និងព្រោះជរា រោគ និងវិបត្តិគ្របសង្កត់ ( សីល ) មិនបាន ។ សីល រមែងក្រៃលែងជាងភាពវិសេសរបស់ទីកន្លែង មានប្រាសាទ និងប្រាសាទជំបូលត្រងិលជាដើម និងភាពវិសេសដែលមានក្នុងបុគ្គល មានព្រះរាជា ឧបរាជ និងសេនាបតីជាដើម ព្រោះភាពជាទីតាំងនៃសេចក្ដីសុខដ៏វិសេស ។ សីល រមែងក្រៃលែងជាងបុគ្គលដែលជាញាតិមិត្តស្និទ្ធស្នាលតាមប្រក្រតី និងជនដែលរាប់អាន ព្រោះសីលឲ្យសម្រេចប្រយោជន៍ដោយចំណែកមួយ និងព្រោះជាប់តាមទៅក្នុងបរលោក ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ដូច្នេះ ជាឧទាហរណ៍ ក្នុងសេចក្ដីនេះ ។ ម្យ៉ាងទៀត សីលប៉ុណ្ណោះជាគុណជាតប្រសើរ ព្រោះរក្សាខ្លួនបានជាងកងទ័ពដំរី សេះ រថ និងពលថ្មើរជើង និងការប្រកបសួស្ដីដោយមន្ត និងថ្នាំវិសេស ដែលរក្សាខ្លួនបានដោយក្រ ព្រោះអាស្រ័យខ្លួន មិនអាស្រ័យអ្នកដទៃ និងព្រោះមានវិស័យធំក្រៃលែង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ខុទ្ទកនិកាយ ជាតក ) ថា ធម៌ រមែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ដូច្នេះជាដើម ។ កាលមហាបុរសកំពុងពិចារណាថា សីលប្រកបដោយគុណច្រើនយ៉ាងនេះ សីលសម្បទា ដែលមិនទាន់បរិបូណ៌ រមែងដល់នូវភាពបរិបូណ៌ ដែលមិនទាន់បរិសុទ្ធ រមែងដល់នូវភាពបរិសុទ្ធ ។

បើធម៌ទាំងឡាយ មានទោសៈជាដើម ជាបដិបក្ខចំពោះសីល គប្បីកើតឡើងដល់មហាបុរសនោះក្នុងចន្លោះ ដោយការសន្សំមកអស់កាលយូរ ដែលបុគ្គលប្ដេជ្ញាជាព្រះពោធិសត្វនោះ គប្បីពិចារណាយ៉ាងនេះថា អ្នកតាំងចិត្តពិតប្រាកដដើម្បីត្រាស់ដឹង មិនមែនឬ ការខុសក្នុងសីលមិនអាចឲ្យដល់សូម្បីតែលោកិយសម្បត្តិ នឹងពោលថ្វីដល់លោកុត្តរសម្បត្តិ សីលជាទីតាំងនៃសម្មាសម្ពោធិញ្ញាណដ៏ប្រសើរជាងសម្បត្តិទាំងពួង គួរឲ្យដល់ភាពឧក្រិដ្ឋក្រៃលែង ព្រោះហេតុនោះ អ្នកកាលរក្សាសីលដោយប្រពៃ គួរជាអ្នកមានសីលជាទីស្រឡាញ់ដោយល្អក្រៃលែង តាមន័យដូចពោលហើយថា ដូចសត្វត្រដេវវិចរក្សាស៊ុតដូច្នោះជាដើម ។

ម្យ៉ាងទៀត អ្នកគួរធ្វើការជញ្ជូន និងការអប់រំសត្វទាំងឡាយ ដាក់ក្នុងយាន ៣ ដោយធម្មទេសនា កុំដាក់ចិត្តក្នុងពាក្យសម្ដីរបស់បុគ្គលដែលមានសីលវិបត្តិ ដូចការព្យាបាលរបស់គ្រូពេទ្យ ដែលឃាត់នូវអាហារស្អែង ព្រោះហេតុនោះ គួរជាអ្នកមានសីលបរិសុទ្ធតាមសភាវៈ ព្រោះអាត្មាអញមានតែសទ្ធា នឹងធ្វើការជញ្ជូន និងអប់រំសត្វទាំងឡាយបានដូចម្ដេច ភាពជាអ្នកអាចក្នុងការធ្វើឧបការៈដល់សត្វទាំងឡាយ ការបំពេញបញ្ញាបារមីជាដើម និងគុណវិសេសមានឈានជាដើម របស់អាត្មាអញមាន ព្រោះប្រកបគុណវិសេសមានឈានជាដើមដោយពិត វៀរការបរិសុទ្ធនៃសីល រមែងប្រព្រឹត្តទៅមិនបាន ព្រោះហេតុនោះ គួរញ៉ាំងសីលឲ្យបរិសុទ្ធដោយប្រពៃនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបការពិចារណា ដែលមានការឃើញទោសក្នុង

ការគ្រប់គ្រងផ្ទះ ដោយន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា ការនៅគ្រប់គ្រងផ្ទះ ចង្អៀត ( ពេកណាស់ ) ជាផ្លូវនៃធូលី ដូច្នេះជាដើម ។ ក្នុងកាមទាំងឡាយ ដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា កាមទាំងឡាយ មានឧបមាដូចរាងឆ្អឹង ដូច្នេះជាដើម ។ និងដោយន័យ ( ក្នុងចូឡទុក្ខក្ខន្ធសូត្រ ) ថា មាតាទាស់ទែងគ្នានឹងបុត្តខ្លះ ដូច្នេះជាដើម ។ កាមច្ឆន្ទៈជាដើម ដោយន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ដូចជាបុរសដែលយកទ្រព្យជាបំណុលទៅប្រកបការងារទាំងឡាយ ដូច្នេះជាដើម ។ ជាខាងដើមក្នុងនេក្ខម្មបារមី ដោយការពិចារណាអានិសង្សក្នុងបព្វជ្ជាជាដើម ដោយន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា បព្វជ្ជា ទើបមានពេលទំនេរច្រើន ដូច្នេះជាដើម ដោយផ្ទុយគ្នាតាមដែលពោលហើយ ។ នេះជាសេចក្ដីសង្ខេបក្នុងទីនេះ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបក្នុងទុក្ខក្ខន្ធសូត្រ និងអាសិវិសោបមសូត្រ ( អាសីវិសសូត្រ ) ជាដើម ។

ម្យ៉ាងទៀត គប្បីមនសិការដល់បញ្ញាគុណថា ធម៌ទាំងឡាយ មានទានជាដើម វៀរចាកបញ្ញា បរិសុទ្ធមិនបាន រមែងមិនអាចខ្វល់ខ្វាយតាមសភាវៈរបស់ខ្លួនបាន ដូចសរីរយន្ត វៀរជីវិត រមែងមិនស្អាត ។ ម្យ៉ាងទៀត មិនអាចបដិបត្តិក្នុងកិរិយាទាំងឡាយរបស់ខ្លួនបាន យ៉ាងណា ឥន្ទ្រិយទាំងឡាយមានចក្ខុជាដើម វៀរវិញ្ញាណហើយ ក៏មិនគ្រប់គ្រាន់ដែលនឹងធ្វើកិច្ចក្នុងវិស័យរបស់ខ្លួនបាន ។ ឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមក៏យ៉ាងនោះ វៀរបញ្ញាហើយ ក៏មិនអាចក្នុងកិច្ចបដិបត្តិរបស់ខ្លួនបាន ព្រោះហេតុនោះ ទើបបញ្ញាជា

ជំក្នុងកិច្ចបដិបត្តិ មានការបរិច្ចាគជាដើម ។ ពិតហើយ មហាពោធិសត្វទាំងឡាយ ជាអ្នកមានបញ្ញាចក្ខុបើកហើយ សូម្បីឲ្យអវយវៈតូចធំរបស់ខ្លួន ក៏មិនលើកខ្លួនសង្កត់សង្កិនអ្នកដទៃ ប្រាសចាកការជ្រើសរើសបុគ្គលជាទីស្រឡាញ់ និងបុគ្គលជាទីស្អប់ ដូចដើមឈើដែលជាឱសថ ជាអ្នកកើតនូវសោមនស្សក្នុងកាលទាំង ៣ ។ ពិតហើយ កិរិយាបរិច្ចាគប្រកបដោយការឈ្លាសក្នុងឧបាយដោយបញ្ញា រមែងចូលដល់ភាពជាទានបារមី ព្រោះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ព្រោះថា ទាន ជាប្រយោជន៍របស់ខ្លួន ដូចគ្មានឹងផលចំណេញ ។

ម្យ៉ាងទៀត សេចក្តីបរិសុទ្ធនៃសីល ដោយមិនប្រាសចាកការសៅហ្មងមានតណ្ហាជាដើម រមែងកើតមិនបាន ព្រោះមិនមានបញ្ញា ។ ការអធិដ្ឋានគុណនៃភាពជាព្រះសព្វញ្ញូ នឹងមានអំពីណា បុគ្គលមានបញ្ញាប៉ុណ្ណោះ ពិចារណាឃើញទោសក្នុងការគ្រប់គ្រងផ្ទះ ក្នុងកាមគុណ និងក្នុងសង្សារ និងឃើញអានិសង្សក្នុងបព្វជ្ជា ក្នុងឈានសមាបត្តិ និងក្នុងនិព្វានដោយល្អ កាលបួសហើយ ញុំាងឈានសមាបត្តិឲ្យកើត បែរមុខចំពោះនិព្វាន និងញុំាងអ្នកដទៃឲ្យតាំងនៅក្នុងសមាបត្តិនោះ ។ ការព្យាយាមប្រាសចាកបញ្ញា មិនញុំាងសេចក្តីប្រាថ្នាឲ្យសម្រេចបានទេ ព្រោះការផ្តើមធ្វើមិនល្អ ។ ការមិនផ្តើមធ្វើគង់ប្រសើរជាងការផ្តើមធ្វើមិនល្អ ។ ការសម្រេចលំបាកណាមួយ ដោយសេចក្តីព្យាយាមប្រកបដោយបញ្ញា រមែងមិនមានព្រោះកិច្ចបដិបត្តិដោយឧបាយម្យ៉ាងទៀត បុគ្គលអ្នកមានបញ្ញាប៉ុណ្ណោះ ជាអ្នកមានការអត់សង្កត់ចំពោះ

សេចក្ដីវិនាសរបស់អ្នកដទៃជាដើម ។ បុគ្គលមានបញ្ញាថោកថយ មិនជាអ្នកអត់ធន់ ។ ការវិនាសដែលអ្នកដទៃនាំទៅឲ្យដល់បុគ្គលដែលប្រាសចាកបញ្ញា រមែងចម្រើននូវភាពជាបដិបក្ខនៃការអត់ធន់ តែសេចក្ដីវិនាសទាំងនោះរបស់បុគ្គលអ្នកមានបញ្ញា រមែងប្រព្រឹត្តទៅដើម្បីការមាំទាំនៃខន្តីនោះ ដោយចម្រើនការសម្បូរនៃខន្តី ។ បុគ្គលមានបញ្ញាប៉ុណ្ណោះ ដឹងសច្ចៈ ៣ យ៉ាង ហេតុនៃសច្ចៈទាំងនោះ និងបដិបក្ខតាមសេចក្ដីពិត ជាអ្នកមិនពោលខុសដល់អ្នកដទៃ ។

ម្យ៉ាងទៀត បុគ្គលឧបត្ថម្ភខ្លួនដោយកម្លាំងបញ្ញា ជាអ្នកមានអធិដ្ឋានធម៌មាំទាំ មិនញាប់ញ័រក្នុងបារមីទាំងពួង ដោយការដល់ព្រមដោយបញ្ញា ។ បុគ្គលមានបញ្ញាប៉ុណ្ណោះ មិនធ្វើការបែងចែកថា បុគ្គលដែលជាទីស្រឡាញ់ បុគ្គលជាកណ្ដាល និងបុគ្គលជាសត្រូវ ជាអ្នកឈ្លាសក្នុងការនាំប្រយោជន៍ចូលទៅក្នុងទីទាំងពួង ។ ម្យ៉ាងទៀត ជាបុគ្គលមានភាពជាកណ្ដាល ព្រោះមិនមានការខុសប្រក្រតីក្នុងការជួបលោកធម៌ មានលាភ មិនមានលាភជាដើម ដោយអំណាចនៃបញ្ញា ។ បញ្ញាប៉ុណ្ណោះ ជាហេតុនៃសេចក្ដីបរិសុទ្ធរបស់បារមីទាំងពួងដោយប្រការដូច្នេះ ព្រោះហេតុនោះ គួរពិចារណាគុណរបស់បញ្ញា ។ ម្យ៉ាងទៀត វៀរបញ្ញាហើយ ទស្សនសម្បត្តិ រមែងមិនមាន ។ បន្ទាប់អំពីនោះ វៀរទិដ្ឋិសម្បទា សីលសម្បទា ក៏មានមិនបាន ។ បុគ្គលប្រាសចាកសីលសម្បទា និងទិដ្ឋិសម្បទា សមាធិសម្បទា ក៏មានមិនបាន ។ ម្យ៉ាងទៀត បុគ្គលមានចិត្តមិនតាំងមាំ មិនអាចធ្វើត្រឹមតែប្រយោជន៍ខ្លួនឲ្យសម្រេចបាន ចាំបាច់ពោលថ្វីដល់ប្រយោជន៍អ្នកដទៃ ដែលជាប្រយោជន៍ឧក្រិដ្ឋ ព្រោះ

ហេតុនោះ ព្រះពោធិសត្វដែលបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ គួរទូន្មានខ្លួនថា អ្នកគួរធ្វើសេចក្តីព្យាយាមក្នុងការចម្រើនដោយបញ្ញា ដោយគោរព មិនមែនឬ ។ ពិតហើយ ព្រះមហាសត្វតាំងមាំក្នុងអធិដ្ឋានធម៌ ៤ ដោយបុញ្ញានុភាព អនុគ្រោះសត្វលោកដោយសង្គហវត្ថុ ៤ រមែងញ៉ាំងសត្វទាំងឡាយឲ្យឈមចុះក្នុងមគ្គ ដែលជាការនាំចេញទៅ និងញ៉ាំងឥន្រ្ទិយរបស់សត្វទាំងនោះឲ្យចម្រើនលូតលាស់ ។

ម្យ៉ាងទៀត គប្បីកំណត់គុណរបស់បញ្ញា មានអាការមិនតិចដោយន័យជាដើមថា បុគ្គលច្រើនដោយការពិចារណាក្នុងខន្ធ អាយតនៈជាដើម ដោយកម្លាំងបញ្ញា កំណត់ដឹងនូវការប្រព្រឹត្តទៅ និងការត្រឡប់តាមសេចក្តីពិត នាំគុណមានទានជាដើមទៅកាន់ការឈមចុះ ដឹងគុណវិសេស ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងការសិក្សារបស់ព្រះពោធិសត្វ ហើយគប្បីចម្រើនបញ្ញាបារមី ។

សូម្បីគុណរបស់វិរិយៈ ក៏គប្បីពិចារណាយ៉ាងនោះដូចគ្នាថា កម្មដែលជាលោកិយដែលប្រាកដ មិនអាចសម្រេចបាន ដោយសេចក្តីព្យាយាមថោកថយ តែបុគ្គលប្រារព្ធសេចក្តីព្យាយាម មិនសម្លឹងដល់សេចក្តីសុខរបស់ខ្លួន រមែងសម្រេចបារមីដែលប្រារព្ធ ព្រោះហេតុនោះ គប្បីពិចារណាដល់វិរិយសម្បត្តិ ។ ម្យ៉ាងទៀត គប្បីពិចារណាដល់គុណនៃសេចក្តីព្យាយាម ដោយន័យជាដើមថា ការប្រារព្ធព្យាយាមរបស់ខ្លួនឡើងចាកកក់ គឺសង្សាររបស់បុគ្គលណា ការដល់ទីបំផុតនៃការប្រាថ្នាក្នុងកាលមានសេចក្តីព្យាយាមធូរថយ ដែលបុគ្គលនោះ មិនអាចឲ្យកើតឡើងបាន នឹងពោលថ្វីដល់ការសាងអភិនីហារ

ដើម្បីរលាស់ចោលនូវលោក ព្រមទាំងទេវលោកនោះ ព្រោះពួកនៃកិលេសជាគ្រឿងប្រទូស្ត មានរាគៈជាដើម ហាមបានដោយលំបាក ដូចគជសារធំចុះប្រេង ព្រោះការសមាទានកម្មដែលមានកិលេសជាគ្រឿងប្រទូស្តនោះជាហេតុ ដូចពេជ្ឈឃាតផងាជាវ ព្រោះទុគ្គតិជានិមិត្តនៃកម្មនោះបើកសព្វកាល ព្រោះមិត្តអាក្រក់ដឹកនាំក្នុងកម្មនោះ បានត្រៀមទុកហើយសព្វកាល និងព្រោះធ្វើតាមឱវាទរបស់មិត្តអាក្រក់នោះ ។ ក្នុងការមានសតិរបស់ភាពជាបុថុជ្ជនអន្ធពាល ទើបគួរចេញចាកសង្សារទុក្ខឯងបាន ព្រោះហេតុនោះ មិច្ឆាវិតក្ករមែងនៅឆ្ងាយ ដោយអានុភាពរបស់សេចក្តីព្យាយាម បើអាចសម្រេចសម្មោធិញ្ញាណបាន ដោយសេចក្តីព្យាយាមអាស្រ័យខ្លួន អ្វីធ្វើបានលំបាកក្នុងសេចក្តីនេះ ។

ម្យ៉ាងទៀត គប្បីមនសិការដូច្នេះថា ឈ្មោះថា ខន្តីនេះ ជាអាវុធ មិនបៀតបៀនសប្បុរស ព្រោះសម្បូរដោយគុណសម្បត្តិ ព្រោះកម្ចាត់សេចក្តីក្រោធ ដែលជាបដិបក្ខចំពោះគុណធម៌ មិនមានចំណែកសេសសល់ ជាគ្រឿងប្រដាប់របស់អ្នកអាចគ្របសង្កត់អ្នកដទៃបាន ជាពលសម្បទារបស់សមណព្រាហ្មណ៍ ជាធ្នារទឹកកម្ចាត់ភ្លើង គឺសេចក្តីក្រោធ ជាគ្រឿងចន្លុលបង្ហាញដល់ការកើតនៃកិត្តិសព្ទដ៏ល្អ ជាមន្ត្រ និងថ្នាំពិសេស ឲ្យផាប់នូវពិស គឺវាចាអាក្រក់របស់បុគ្គលអាក្រក់ ជាប្រក្រតីរបស់បុគ្គលអ្នកមានបញ្ញាដ៏កំពូលរបស់បុគ្គលដែលតាំងនៅក្នុងសំវរៈ ជាសាគរ ព្រោះតាំងនៅក្នុងទីជ្រៅ ជាត្រើយនៃមហាសាគរ គឺទោសៈ ជាទ្វារបិទទ្វារអបាយ ជាជណ្តើរឡើងកាន់

ទេវលោក និងព្រហ្មលោក ជាភូមិដែលស្ថិតនៅនៃគុណទាំងពួង ជាសេចក្តីបរិសុទ្ធនៃកាយ វាចា និងចិត្តដ៏ឧត្តម ។

ម្យ៉ាងទៀត គួរចម្រើនខន្តិសម្បទាដោយពិចារណាថា សត្វទាំងឡាយនេះក្តៅក្រហាយក្នុងលោកនេះ ព្រោះមិនមានខន្តិសម្បត្តិ និងក្តៅក្រហាយក្នុងលោកខាងមុខ ព្រោះប្រកបដោយហេតុដែលធ្វើឲ្យក្តៅក្រហាយ ១ បើទុក្ខមានការវិនាសរបស់អ្នកដទៃជាហេតុកើតឡើង អត្តភាពដែលជាដែនកើតរបស់ទុក្ខនោះ និងកម្មដែលជាពូជរបស់ទុក្ខនោះ ដែលអាត្មាអញសាងឡើងឯង ១ នោះជាដើមហេតុនៃភាពជាបំណុលរបស់ទុក្ខនោះ ១ កាលមិនមានបុគ្គលធ្វើឲ្យវិនាស ខន្តិសម្បទារបស់អាត្មាអញនឹងកើតបានដូចម្តេច ១ បើបុគ្គលនេះធ្វើឲ្យវិនាសក្នុងបច្ចុប្បន្ន នេះឯងជាឧបការៈដែលបុគ្គលនេះបានធ្វើដល់អញមុន ១ បុគ្គលធ្វើឲ្យវិនាសនោះឯង ជាអ្នកមានឧបការៈ ព្រោះជាហេតុឲ្យកើតខន្តី ១ សត្វទាំងឡាយទាំងពួងនេះ ដូចគ្នានឹងបុត្ររបស់អញ អ្នកណានឹងក្រោធក្នុងកំហុសដែលបុត្រធ្វើ ១ បុត្រនេះធ្វើខុសដល់អញក្នុងភេទបិសាច គឺសេចក្តីក្រោធណា អញគួរកម្ចាត់ភេទបុគ្គលដែលក្រោធនោះចេញ ១ ទុក្ខនេះកើតដល់អញដោយការវិនាសណា អញនោះឯងជាហេតុនៃការវិនាសនោះ ១ បុគ្គលធ្វើសេចក្តីវិនាសដោយធម៌ណា និងធ្វើក្នុងទីណា ធម៌ទាំងអស់នោះ ក៏រលត់ទៅក្នុងខណៈហើយ ឥឡូវនេះនឹងក្រោធចំពោះបុគ្គលណា ក្រោធធ្វើអ្វី ១ ព្រោះធម៌ទាំងពួងជាអនត្តា អ្នកណាមិនធ្វើខុសដល់គ្នានិងគ្នាខ្លះ ១ ។

ម្យ៉ាងទៀត បើសេចក្តីក្រោធ មានហេតុអំពីកំហុសរបស់អ្នកដទៃ មានការសន្សំយូរគ្របសង្កត់ចិត្ត ក្នុងសេចក្តីនេះ គប្បីពិចារណាដូច្នេះថា ឈ្មោះថា ខន្តីនេះ ជាហេតុនៃការធ្វើតបដែលផ្ទុយគ្នាចំពោះបុគ្គលដទៃដែលធ្វើខុស ១ បុគ្គលធ្វើខុសជាបច្ច័យនៃសទ្ធាដោយឲ្យកើតទុក្ខថា សទ្ធារបស់អញអាស្រ័យទុក្ខ និងជាបច្ច័យនៃអនភិរតិសញ្ញាក្នុងលោកទាំងពួង ១ ភាពប្រក្រតីរបស់ឥន្ទ្រិយនេះ គឺអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា សេចក្តីនោះអញរកបានដូចម្តេចថា ការជួបអារម្មណ៍ដែលមិនគួរប្រាថ្នា មិនគប្បីមានដល់អញ ១ សត្វត្រូវធ្លាក់នៅក្នុងអំណាចរបស់សេចក្តីក្រោធ ជាមនុស្សឆ្កួតដោយសេចក្តីក្រោធ មានចិត្តរាយមាយ ធ្វើខុសតបនឹងបុគ្គលនោះ តើបានប្រយោជន៍អ្វី ១ សត្វទាំងអស់នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ថែរក្សាដូចបុត្រកើតអំពីទ្រូង ព្រោះហេតុនោះ អញមិនគួរធ្វើចិត្តឲ្យក្រោធក្នុងសត្វទាំងនោះ ១ កាលបុគ្គលធ្វើខុសមានគុណ អញមិនគួរធ្វើសេចក្តីក្រោធក្នុងបុគ្គលមានគុណនោះ ១ កាលមិនមានគុណ គួរសម្តែងសេចក្តីករុណាជាពិសេស ១ យសដែលជាគុណរបស់អញ រមែងវិនាសព្រោះសេចក្តីក្រោធ ១ វត្ថុដែលជាសត្រូវទាំងឡាយ មានពណ៌សម្បុរសៅហ្មង និងការនៅជាទុក្ខជាដើម រមែងមកដល់អញដោយសេចក្តីក្រោធ ១ ឈ្មោះថា សេចក្តីក្រោធនេះ ធ្វើនូវវត្ថុមិនជាប្រយោជន៍បានគ្រប់យ៉ាង ញុំាងប្រយោជន៍ទាំងពួងឲ្យវិនាស ជាសត្រូវដែលមានកម្លាំង ១ កាលមានខន្តី សត្រូវណាមួយ ក៏មិនមាន ១ ទុក្ខ មានការធ្វើខុសជាហេតុ ដែលអ្នកធ្វើខុសគប្បីបានទទួលតទៅ កាល

មានខន្តី អញក៏មិនមានទុក្ខនោះ ១ បើអញមានចិត្តក្រោធ ក៏ដូចមានសត្រូវ ជាប់តាមខ្លួន ១ កាលអញគ្របសង្កត់សេចក្តីក្រោធដោយខន្តី សត្រូវក៏ក្លាយ ជាទាសៈ ត្រូវគ្របសង្កត់ដោយប្រពៃ ការលះខន្តិគុណ ដែលមានសេចក្តី ក្រោធជាហេតុ មិនសមគួរដល់អញ ១ កាលមានសេចក្តីក្រោធដែលជា សត្រូវ ទម្លាយនូវគុណធម៌ មានសីលជាដើម គប្បីដល់នូវភាពបរិបូណ៌ ដល់អាត្មាអញបានដូចម្តេច កាលមិនមានធម៌ មានសីលជាដើមទាំងនោះ អញជាអ្នកច្រើនដោយឧបការៈដល់សត្វទាំងឡាយ នឹងដល់នូវសម្បត្តិឧត្តម សមគួរដល់បេ្តជ្ញាបានដូចម្តេច ១ កាលមានការអត់ធន់ សង្ខារទាំងឡាយ ទាំងពួង របស់បុគ្គលមានចិត្តតាំងមាំ ព្រោះមិនមានការវាយមាយខាងក្រៅ រមែងអត់ធន់ចំពោះការសម្លឹង ដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ធម៌ទាំងពួង រមែងអត់ធន់ក្នុងការសម្លឹងដោយភាពជាអនត្តា និងនិព្វាន រមែង អត់ធន់ចំពោះការសម្លឹងដោយភាពជាអសង្ខតៈ អមតៈ សន្តៈ និងបណីត ជាដើម ១ ពុទ្ធធម៌ទាំងឡាយ រមែងប្រាកដដោយភាពជាអចិន្តេយ្យ មិនមាន ប្រមាណ ១ ។

ម្យ៉ាងទៀត បន្ទាប់អំពីនោះ គប្បីជ្រាបការពិចារណាខន្តិបារមីដោយន័យ ជាដើមយ៉ាងនេះថា បុគ្គលតាំងនៅក្នុងខន្តីដ៏សមគួរ រមែងគួរដល់ការសម្លឹង ព្រោះជាបុគ្គលមិនតាំងមាំនៅក្នុងអហង្ការៈ និងមមង្ការៈថា ភាពជារបស់ធម្មតា វៀរចាកការប្រកាន់ខ្លួនទាំងនេះតែម្យ៉ាង រមែងកើត រមែងវិនាសដោយបច្ច័យ ទាំងឡាយរបស់ខ្លួន រមែងមិនមកអំពីទីណា រមែងមិនទៅក្នុងទីណា មិនតាំង

នៅក្នុងទីណា មិនមានសេចក្តីខ្វល់ខ្វាយណាមួយ របស់បុគ្គលណាមួយក្នុងទីនេះ ដូច្នេះ ព្រះពោធិសត្វជាបុគ្គលទៀងចំពោះពោធិញ្ញាណ ជាអ្នកមិនត្រឡប់ជាធម្មតា ដូច្នេះ ។

ម្យ៉ាងទៀត គប្បីពិចារណាការដល់ព្រមនៃសច្ចបារមីដោយន័យជាដើមថា វៀរសច្ចៈហើយ សីលជាដើមក៏មិនមាន កិច្ចបដិបត្តិដែលសមគួរដល់បេ្ញា ក៏មិនមាន ១ ព្រោះឈានកន្លងសច្ចធម៌ ធម៌លាមកក៏ហូរមក បុគ្គលមិនមានសច្ចៈ ជាបុគ្គលជឿមិនបាន ជាអ្នកនាំពាក្យដែលមិនគួរជឿតទៅមកពោល ១ បុគ្គលមានសច្ចៈបរិបូណ៌ ជាអ្នកតាំងមាំក្នុងគុណធម៌ទាំងពួង ជាអ្នកអាចបំពេញពោធិសម្ភារទាំងពួង ឲ្យបរិសុទ្ធិបរិបូណ៌បាន ដោយការមាំទាំក្នុងសច្ចៈ ជាអ្នកធ្វើកិច្ចនៃពោធិសម្ភារទាំងពួង ដោយមិនឲ្យខុសសភាវធម៌ និងជាអ្នកសម្រេចក្នុងកិច្ចបដិបត្តិរបស់ព្រះពោធិសត្វ ១ ។

ម្យ៉ាងទៀត គប្បីពិចារណាគុណក្នុងអធិដ្ឋានបារមីដោយន័យជាដើមថា វៀរការសមាទានមាំក្នុងទានជាដើម ការអធិដ្ឋានមិនញាប់ញ័ររបស់គុណទាំងនោះ ក្នុងកាលជួបនូវបដិបក្ខចំពោះការសមាទានមាំនោះ និងវៀរភាពជាអ្នកមានបញ្ញា និងការបោសក្លាក្នុងអធិដ្ឋាននោះហើយ ការសន្សំទានបារមីជាដើមដែលជាហេតុនៃសម្ពោធិញ្ញាណ រមែងមិនមាន ។

ម្យ៉ាងទៀត គប្បីពិចារណាគុណរបស់មេត្តាដោយន័យជាដើមយ៉ាងនេះថា បុគ្គលតាំងនៅក្នុងគុណត្រឹមតែប្រយោជន៍ខ្លួន វៀរភាពជាអ្នកមានចិត្តប្រាថ្នាប្រយោជន៍ក្នុងសត្វទាំងឡាយហើយ មិនអាចសម្រេចសម្បត្តិក្នុងលោក

នេះ និងក្នុងលោកខាងមុខបាន មិនចាំបាច់ពោលដល់បុគ្គលដែលប្រាជ្ញា ញុំាងសព្វសត្វឲ្យតាំងនៅក្នុងនិព្វានសម្បត្តិនោះឡើយ ១ លោកអ្នកប្រាជ្ញា លោកុត្តរសម្បត្តិដល់សព្វសត្វ ក្នុងខាងក្រោយ ក៏គួរលោកិយសម្បត្តិ ក្នុងបច្ចុប្បន្នមុន ១ ឥឡូវនេះ អញនាំចូលទៅនូវប្រយោជន៍ និងសេចក្តីសុខដល់សត្វដទៃ តាមដែលគិតទុកក៏មិនទាន់បាន កាលណា ទើបញុំាងប្រយោជន៍នោះឲ្យសម្រេចបាន ដោយសេចក្តីព្យាយាម ១ បុគ្គលដែលត្រូវអញឲ្យចម្រើន ដោយការនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ឥឡូវនេះ ខាងក្រោយ នឹងជាសម្លាញ់អ្នកចែកធម៌របស់អញ ១ ការសន្សំពោធិញ្ញាណរបស់វៀរចាកសម្លាញ់ទាំងនោះ រមែងមិនសម្រេច ព្រោះហេតុនោះ គប្បីចូលទៅតាំងភាពជាអ្នកមានអធ្យាស្រ័យបំពេញនូវប្រយោជន៍ ក្នុងសព្វសត្វក្រៃលែងឡើងថា សត្វទាំងនេះ ជាបុញ្ញក្ខេត្តយ៉ាងក្រៃលែង ជាប្រភពកើតនៃកុសលដ៏កំពូល ជាទីតាំងនៃសេចក្តីគោរពដ៏ឧត្តមរបស់អញ ព្រោះជាហេតុឲ្យសម្រេចសេចក្តីចម្រើន ដោយពុទ្ធគុណទាំងពួង ១ ។ គប្បីចម្រើនមេត្តាក្នុងសព្វសត្វដោយការអធិដ្ឋានករុណាទៀតផង ព្រោះភាពជាអ្នកប្រាជ្ញាដើម្បីកម្ចាត់វត្ថុមិនមានប្រយោជន៍ និងទុក្ខរបស់សត្វទាំងនោះ មានកម្លាំង មានឫសគល់មាំទាំ រមែងកើតឡើងដល់បុគ្គលដែលត្រេកអរ នាំប្រយោជន៍ និងសេចក្តីសុខចូលទៅឲ្យក្នុងសត្វទាំងឡាយ ដោយចិត្តដែលមិនមានព្រំដែន ។ ម្យ៉ាងទៀត ករុណាជាខាងដើម ជាចរណៈ ជាគោល ជាមូល ជាប្រធាន ជាប្រមុខនៃពុទ្ធការកធម៌ទាំងឡាយទាំងពួង ។

ម្យ៉ាងទៀត គប្បីពិចារណាឧបេក្ខាបារមី ដោយន័យជាដើមយ៉ាងនេះថា សេចក្ដីវិនាសដែលសត្វទាំងឡាយធ្វើ ព្រោះមិនមានឧបេក្ខា គប្បីឲ្យកើតនូវភាពពិការផ្លូវចិត្ត កាលចិត្តពិការ ក៏មិនមានការសន្សំទានបារមីជាដើម ១ កាលចិត្តនៅពាក់ព័ន្ធដោយមេត្តា វៀរឧបេក្ខាហើយ ការបរិសុទ្ធនៃការសន្សំបារមី ក៏មិនមាន ១ បុគ្គលមិនមានឧបេក្ខា មិនអាចបង្អោនបុញ្ញសម្ភារ និងប្រយោជន៍អនុគ្រោះចំពោះសត្វ ដែលជាផលរបស់បុញ្ញសម្ភារនោះ ចូលទៅក្នុងការសន្សំទាំងឡាយបាន ១ កាលមិនមានឧបេក្ខា បុគ្គលមិនអាចបរិច្ចាគដោយមិនចែកទេយ្យធម៌និងបដិគ្គាហកមុនបាន ១ បុគ្គលប្រាសចាកឧបេក្ខា មិនមនសិការដល់អន្តរាយនៃបច្ច័យជាគ្រឿងនាំមកនូវជីវិត និងជីវិតហើយ មិនអាចធ្វើសីលឲ្យបរិសុទ្ធបាន ១ ។

ម្យ៉ាងទៀត ការសម្រេចនៃការតាំងចិត្តសមាទានពោធិសម្ភារទាំងពួងឲ្យបរិបូណ៌ រមែងសម្រេចដោយអានុភាពនៃឧបេក្ខា គឺដោយការមិនត្រេកអរ និងការត្រេកអរមួយពាន់ សម្រេចដោយកម្លាំងនេក្ខម្មៈ ដោយអំណាចនៃឧបេក្ខាដោយកើតឡើង ដោយអំណាចនៃការពិចារណា ដោយសម្រេចកិច្ចនៃការសន្សំបារមីទាំងពួង ដោយមិនធ្វើកិច្ចធំៗ ព្រោះមិនសម្លឹងដល់សេចក្ដីព្យាយាមដែលផ្ដើមច្រើនហើយ ដោយការព្រងើយ ដោយសម្លឹងដល់ការអត់ធន់ ដោយមិនពោលខុសចំពោះសត្វ និងសង្ខារ ដោយអំណាចនៃឧបេក្ខា ដោយការសម្រេច ការតាំងចិត្តដែលមិនញាប់ញ័រក្នុងធម៌ដែលសមាទានហើយ ដោយការព្រងើយចំពោះលោកធម៌ ដោយការសម្រេចនៃមេត្តាវិហារធម៌ ដោយការ

មិនចងចិត្តក្នុងសេចក្ដីវិនាសរបស់បុគ្គលដទៃជាដើម ។ ការពិចារណាទោស និងអានិសង្សតាមលំដាប់ ក្នុងការមិនបរិច្ចាគ និងការបរិច្ចាគជាដើមយ៉ាងនេះ គប្បីឃើញថា ជាបច្ច័យនៃទានបារមីជាដើម ។

ម្យ៉ាងទៀត គប្បីជ្រាបថា ចរណធម៌ ១៥ និងអភិញ្ញា ៥ ជាគ្រឿងប្រកប គឺឧបការៈដល់បារមី ។ សីលសំវរៈ ១ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ការស្គាល់ប្រមាណក្នុងការបរិភោគ ១ ការប្រកបព្យាយាមរឿយៗ ១ សទ្ធម្ម ៧ និងឈាន ៤ ឈ្មោះថា ចរណធម៌ ។ ក្នុងចរណធម៌ទាំងនោះ ធុតង្គ ១៣ និងការប្រាថ្នាតិចជាដើមជាបរិក្ខារនៃធម៌ ៤ មានសីលជាដើម ។ ក្នុងព្រះសទ្ធម្ម ៧ ភាពដែលចិត្តបង្អោនទៅក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សីល ចាគៈ ការរឭកដល់ទេវតា ការរឭកដល់ការស្ងប់ ការវៀរបុគ្គលសៅហ្មង ការគប់រកបុគ្គលជាទីស្រឡាញ់ ការពិចារណាធម៌ដែលគួរជ្រះថ្លា ជាបរិក្ខាររបស់សទ្ធា ។ ភាពដែលចិត្តបង្អោនទៅក្នុងការពិចារណាទោសនៃអកុសលរបស់អបាយ ការពិចារណានូវការឧបត្ថម្ភរបស់កុសលធម៌ ការវៀរបុគ្គលដែលប្រាសចាកហិរិឱត្តប្បៈ ការគប់រកបុគ្គលដែលដល់ព្រមដោយហិរិឱត្តប្បៈ ជាបរិក្ខាររបស់ហិរិឱត្តប្បៈ ។ ភាពជាបុគ្គលមានឥន្ទ្រិយចាស់ក្លាដោយការសន្សំគុណ មានការសោកស្តូរ ការប្រកបសេចក្ដីព្យាយាមខាងដើម ការតាំងនៅក្នុងព្រះសទ្ធម្ម និងតាំងនៅក្នុងវិជ្ជាដែលមិនមានទោសជាដើម ការនៅឆ្ងាយអំពីកិលេស ការវៀរបុគ្គលដែលមានសុតៈតិច ការគប់បុគ្គលដែលមានសុតៈច្រើន និងការមានចិត្តបង្អោនទៅក្នុងសុតៈ ជាបរិក្ខារ

របស់ពហុសច្ចៈ ការពិចារណាឃើញភ័យក្នុងអបាយ ការពិចារណាឃើញផ្លូវ ការពិចារណាការសម្គាល់របស់ធម៌ ការបន្ទោបង់ថីនមិទ្ធៈ ការវៀរបុគ្គលខ្ជិលច្រអូស ការសេពគប់បុគ្គលប្រារព្ធសេចក្ដីព្យាយាម ការពិចារណា ការព្យាយាមប្រពៃ និងការមានចិត្តបង្ហោនទៅក្នុងវីរិយៈជាបរិវាររបស់វីរិយៈ ។ ការមានសតិសម្បជញ្ញៈ ការវៀរឆ្ងាយអំពីបុគ្គលដែលមិនមានស្មារតី ការគប់រកបុគ្គលដែលមិនមានស្មារតីតាំងមាំ និងការមានចិត្តបង្អោនទៅក្នុងសតិ ជាបរិក្ខាររបស់សតិ ។ ភាពជាអ្នកសាកសួរ ការដឹងទាន់ក្នុងហេតុការណ៍ ការមានអកប្បកិរិយាស្ងប់ ការវៀរបុគ្គលមានបញ្ញាថោកថយ ការគប់រកបុគ្គលមានបញ្ញា ការពិចារណាដល់ញាណដ៏ជ្រាលជ្រៅ និងការមានចិត្តបង្អោនទៅក្នុងបញ្ញាជាបរិក្ខាររបស់បញ្ញា ។ ពួក ៤ នៃគុណ មានសីលជាដើម បុព្វភាគការនាក្នុងអារម្មណ៍ ៣៨ និងការធ្វើវសី មានអាវជ្ជនវសីជាដើម ជាបរិក្ខារនៃឈានទាំង ៤ ។

គប្បីពោលចំពោះតាមសមគួរ ដល់ភាពដែលចរណៈជាដើម ជាបច្ច័យនៃការសន្សំទានបារមីជាដើម ដោយន័យជាដើមថា ក្នុងចរណៈទាំងនោះដោយចរណៈ គឺសីលជាដើម បុគ្គលរមែងជាអ្នកអាចក្នុងការឲ្យអភ័យសត្វទាំងឡាយ ដោយសេចក្ដីបរិសុទ្ធបយោគក្នុងការឲ្យអាមិស ដោយសេចក្ដីបរិសុទ្ធនៃអជ្ឈាស្រ័យ ក្នុងការឲ្យធម៌ដោយសេចក្ដីបរិសុទ្ធទាំងពីរយ៉ាង ។ ខ្ញុំមិនលើកមកពោល ព្រោះក្រែងពិស្ដារពេក ។ ការបានចក្ក ៤ ជាដើម ក៏គប្បីជ្រាបថា ជាបច្ច័យនៃទានជាដើម ដោយប្រការដូច្នេះ ។

បញ្ហាថា អ្វីជាសេចក្តីសៅហ្មង ពោលដោយសរុប ភាពដែលទានជាដើម ត្រូវតណ្ហាជាដើមបៀតបៀនអង្អែល ជាការសៅហ្មងនៃបារមីទាំងឡាយ ។ ពោលដោយការផ្សេងគ្នា ការកំណត់ទេយ្យធម៌ និងបដិគ្គាហក ជាការសៅហ្មងនៃទានបារមី ។ ការកំណត់បុគ្គល និងពេលវេលា ជាការសៅហ្មងនៃសីលបារមី ។ ការកំណត់ការត្រេកអរក្នុងកាម និងភព និងការមិនត្រេកអរក្នុងការស្ងប់រម្ងាប់កាម និងភពនោះ ជាការសៅហ្មងនៃនេក្ខម្មបារមី ។ ការកំណត់ថា អញ របស់អញ ជាការសៅហ្មងនៃបញ្ញាបារមី ។ ការកំណត់ដោយការរួញរា និងការរាយមាយ ជាការសៅហ្មងនៃវីរិយបារមី ។ ការកំណត់ខ្លួន និងអ្នកដទៃ ជាការសៅហ្មងនៃខន្តិបារមី ។ ការកំណត់ ដោយមានការឃើញក្នុងវត្ថុដែលមិនបានឃើញជាដើម ជាការសៅហ្មងនៃសច្ចបារមី ។ ការកំណត់ដោយទោស និងគុណក្នុងពោធិសម្ភារ និងចំណែកផ្ទុយគ្នា ជាមួយពោធិសម្ភារ ជាការសៅហ្មងនៃអធិដ្ឋានបារមី ។ ការកំណត់ដោយប្រយោជន៍ និងមិនមែនប្រយោជន៍ ជាការសៅហ្មងនៃមេត្តាបារមី ។ ការកំណត់វត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ជាការសៅហ្មងនៃឧបេក្ខាបារមី គប្បីឃើញដោយប្រការដូច្នេះ ។

បញ្ហាថា អ្វីជាការផូរផង់ គប្បីជ្រាបថា ការមិនត្រូវតណ្ហាជាដើមទម្លាយ ការប្រាសចាកការកំណត់តាមដែលពោលហើយ ជាការផូរផង់នៃបារមីទាំងនោះ ព្រោះទានបារមីជាដើម ប្រាសចាកការកំណត់ទេយ្យធម៌ និងបដិគ្គាហកជាដើម មិនត្រូវកិលេសទាំងឡាយ មានតណ្ហា មានះ ទិដ្ឋិ កោធៈ ឧបនាហៈ

មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មទៈ បមាទៈជាដើមទម្លាយ រមែងជាបារមីបរិសុទ្ធផូរផង់ ។

បញ្ហាថា អ្វីជាបដិបក្ខ ពោលដោយរួមការសៅហ្មងទាំងអស់ អកុសលធម៌ទាំងអស់ជាបដិបក្ខនៃបារមីទាំងនោះ តែពោលដោយការផ្សេងគ្នា គប្បីជ្រាបថា សេចក្តីកំណាញ់ជាដើម ដែលពោលហើយក្នុងកាលមុន ជាបដិបក្ខនៃបារមីទាំងនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ទាន ជាបដិបក្ខដល់លោភៈ ទោសៈ និងមោហៈ ព្រោះប្រកបដោយគុណ គឺអលោភៈ អទោសៈ អមោហៈ ក្នុងទេយ្យធម៌ បដិគ្គាហក និងផលនៃទានទាំងឡាយ ។ សីលជាបដិបក្ខដល់លោភៈជាដើម ព្រោះប្រាសចាកការវៀច គឺទោសៈ មានវៀចផ្លូវកាយជាដើម ។ នេក្ខម្មៈ ជាបដិបក្ខដល់ទោស ៣ ព្រោះវៀរចាកកាមសុខ ការចូលទៅបៀតបៀនអ្នកដទៃ និងការធ្វើខ្លួនឲ្យលំបាក ។ បញ្ញា ជាបដិបក្ខដល់លោភៈជាដើម ព្រោះធ្វើលោភៈជាដើមឲ្យងងឹត និងព្រោះមិនធ្វើញាណឲ្យងងឹត ។ វីរិយៈ ជាបដិបក្ខដល់លោភៈជាដើម ដោយមិនរួញរា មិនរាយមាយ និងប្រារព្ធដើម្បីការដឹង ។ ខន្តី ជាបដិបក្ខដល់លោភៈជាដើម ព្រោះអត់ធន់ចំពោះការសូន្យនៃវត្ថុដែលគួរប្រាថ្នា និងវត្ថុមិនគួរប្រាថ្នា ។ សច្ចៈ ជាបដិបក្ខដល់លោភៈជាដើម ព្រោះប្រព្រឹត្តទៅតាមសេចក្តីពិត កាលអ្នកដទៃធ្វើឧបការៈ និងធ្វើនូវសេចក្តីវិនាស ។ អធិដ្ឋាន ជាបដិបក្ខដល់លោភៈជាដើម ព្រោះគ្របសង្កត់លោកធម៌ ហើយមិនញាប់ញ័រក្នុងការសន្សំបារមីតាមដែលសមាទាន

ហើយ ។ មេត្តា ជាបដិបក្ខដល់លោភៈជាដើម ព្រោះស្ងប់ចាកនីវរណៈ ។ ឧបេក្ខា ជាបដិបក្ខដល់លោភៈជាដើម ព្រោះកម្ចាត់ការត្រេកអរ និងការមិនត្រេកអរក្នុងវត្ថុដែលគួរប្រាថ្នា និងវត្ថុដែលមិនគួរប្រាថ្នា និងព្រោះប្រព្រឹត្តទៅស្មើ ។

បញ្ហាថា អ្វីជាបដិបទា ការធ្វើសេចក្តីអនុគ្រោះដល់សត្វទាំងឡាយដោយចំណែកច្រើន ដោយការលះគ្រឿងឧបភោគបរិភោគ សេចក្តីសុខ រូបកាយ និងជីវិត ដោយការកម្ចាត់ភ័យ និងការចង្អុលបង្ហាញនូវធម៌ ជាបដិបទារបស់ទានបារមី ។ ក្នុងទានបារមីនោះ ទានមាន ៣ យ៉ាង ដោយជាវត្ថុដែលគួរឲ្យ គឺអាមិសទាន ១ អភយទាន ១ ធម្មទាន ១ ។ ក្នុងទានទាំងនោះ វត្ថុដែលព្រះពោធិសត្វគួរឲ្យ មាន ២ យ៉ាង គឺវត្ថុខាងក្នុង ១ វត្ថុខាងក្រៅ ១ ក្នុង ២ យ៉ាងនោះ វត្ថុខាងក្រៅ មាន ១០ គឺបាយ ១ ទឹក ១ សំពត់ ១ យាន ១ ផ្កាកម្រង ១ គ្រឿងក្រអូប ១ គ្រឿងលាប ១ ទីដេក ១ ទីអាស្រ័យ ១ ប្រទីប ១ ។ បណ្តាវត្ថុមានបាយជាដើម មានវត្ថុច្រើនយ៉ាង ដោយចែករបស់គួរទំពា និងគួរបរិភោគជាដើម ។ម្យ៉ាងទៀត វត្ថុ ៦ យ៉ាង ដោយអារម្មណ៍ គឺរូបារម្មណ៍រហូតដល់ធម្មារម្មណ៍ ។ ម្យ៉ាងទៀត បណ្តាវត្ថុមានរូបារម្មណ៍ជាដើម វត្ថុច្រើនយ៉ាង ដោយការចែកជាពណ៌ខៀវជាដើម ។ ម្យ៉ាងទៀត មានវត្ថុច្រើនយ៉ាងដោយគ្រឿងឧបករណ៍ដែលធ្វើនូវការត្រេកអរច្រើនប្រភេទ មានកែវមណី មាស ប្រាក់ មុក្តា កែវប្រពាល ស្រែ ចម្ការ អារាម ខ្ញុំស្រី ខ្ញុំប្រុស គោ ក្របីជាដើម ។

ក្នុងវត្ថុទាំងនោះ ព្រះមហាបុរស កាលនឹងឲ្យវត្ថុខាងក្រៅ រមែងឲ្យវត្ថុតាមដែលសូមត្រូវការ កាលនឹងឲ្យ ក៏ដឹងដោយខ្លួនឯងថា បុគ្គលដែលត្រូវការ សូម្បីមិនសូមក៏ឲ្យបុគ្គលនោះ ចាំបាច់ពោលថ្វីដល់មានអ្នកសូម ត្រេកអរលះឲ្យ ឲ្យដោយមិនជាប់ជំពាក់ ឲ្យវត្ថុដែលប្រាថ្នា កាលមានទេយ្យធម៌ រមែងឲ្យវត្ថុដែលមិនប្រាថ្នា ។ រមែងឲ្យដោយមិនសង្ឃឹមផលតបស្នង កាលមិនមានទេយ្យធម៌ រមែងបែកចែកវត្ថុដែលប្រាថ្នា ឲ្យសមគួរដល់ការចែកចាយ ។ ម្យ៉ាងទៀត មិនឲ្យសស្ត្រា ថ្នាំពិស និងគ្រឿងស្រវឹងជាដើម ដែលនាំមកនូវការបៀតបៀនអ្នកដទៃ សូម្បីរបស់លេងដែលប្រកបដោយសេចក្តីវិនាស និងនាំមកនូវសេចក្តីប្រមាទ ក៏មិនឲ្យ ។ ម្យ៉ាងទៀត មិនឲ្យរបស់មិនជាទីសប្បាយ មានទឹកផឹក និងរបស់បរិភោគជាដើម ឬរបស់ដែលមិនមានប្រមាណដល់អ្នកសូមដែលមានជំងឺ តែឲ្យរបស់ដែលជាសប្បាយប៉ុណ្ណោះ ដែលសមគួរដល់ប្រមាណ ។

ម្យ៉ាងទៀត គ្រហស្ថសូម ក៏ឲ្យរបស់សមគួរដល់គ្រហស្ថ បព្វជិតសូម ក៏ឲ្យរបស់សមគួរដល់បព្វជិត ឲ្យដោយមិនឲ្យកើតនូវការបៀតបៀន ដល់បុគ្គលណាមួយ ក្នុងបុគ្គលទាំងនេះ គឺមាតាបិតា ញាតិសាលោហិត មិត្តអមាត្យ បុត្ត ភរិយា ទាសៈ និងកម្មករ និងដឹងនូវទេយ្យធម៌ល្អហើយ មិនឲ្យរបស់សៅហ្មង មិនឲ្យដោយសង្ឃឹមលាភសក្ការៈ និងការសរសើរ មិនឲ្យដោយសង្ឃឹមការតបស្នង មិនឲ្យដោយសង្ឃឹមផល វៀរតែសម្មាសម្ពោធិញ្ញាណ មិនឲ្យមើលងាយអ្នកសូម ឬទេយ្យធម៌ មិនឲ្យទានដោយបោះ ឬ

ប្រមៀលដល់យាចកដែលមិនសង្រួម ជេរនិងគ្រោធ ។ ដែលពិត មានចិត្ត ជ្រះថ្លា ឲ្យដោយគោរពតែម្យ៉ាង មិនឲ្យព្រោះជឿមង្គលភ្ញាក់ផ្អើល ឲ្យព្រោះ ជឿកម្ម និងផលនៃកម្មប៉ុណ្ណោះ មិនឲ្យយាចកត្រូវលំបាក ដោយការឲ្យចូល ទៅអង្គុយជិតជាដើម ឲ្យដោយមិនធ្វើឲ្យយាចកលំបាក ម្យ៉ាងទៀត មិនឲ្យ ទាន បំណងនឹងបោកបញ្ឆោត ឬបំណងនឹងទម្លាយអ្នកដទៃ ឲ្យដោយមាន ចិត្តមិនសៅហ្មងតែម្យ៉ាង មិនឲ្យទានដោយប្រើវាចាគ្រោតគ្រាត មុខក្រញូវ ខ្មោះខ្មួរ ឲ្យដោយវាចាជាទីស្រឡាញ់ និយាយមុន និយាយល្មមប្រមាណ ។ លោភៈមានច្រើនក្នុងទេយ្យធម៌ណា ព្រោះការពេញចិត្ត ត្រេកអរក្រៃលែង ព្រោះសន្សំមកអស់កាលយូរក្តី ព្រោះការចង់បានតាមសភាវៈក្តី ព្រះពោធិ- សត្វដឹង រមែងបន្ទោបង់សេចក្តីលោភនោះដោយរហ័ស ហើយស្វែងរក យាចកដើម្បីឲ្យទាន ។ ម្យ៉ាងទៀត ទេយ្យវត្ថុណា មានតិច ឯយាចកក៏ ប្រាកដហើយ មិនគិតដល់ទេយ្យវត្ថុនោះ សុខចិត្តធ្វើខ្លួនឲ្យលំបាក ហើយឲ្យ ដ្បិតរាប់អានយាចកដូចអកិត្តិបណ្ឌិត ដូច្នោះ ។ ម្យ៉ាងទៀត មហាបុរស កាល មានមនុស្សមកសូមបុត្ត ភរិយា ទាសៈ កម្មករ និងបុរសរបស់ខ្លួន ក៏មិនឲ្យ ជនទាំងនោះដែលមិនយល់ព្រម ដែលពេញទៅដោយទោមនស្សដល់អ្នក សូម តែកាលជនទាំងនោះយល់ព្រមដោយល្អ មានសោមនស្ស ទើបឲ្យ ។ ម្យ៉ាងទៀត កាលឲ្យ បើដឹង រមែងមិនឲ្យដល់យក្ខ អារក្ស បិសាចជាដើម ឬដល់មនុស្សដែលធ្វើការងារគ្រោតគ្រាត ។ ម្យ៉ាងទៀត សូម្បីរាជសម្បត្តិ ក៏មិនឲ្យដល់បុគ្គលបែបនោះ និងមិនឲ្យដល់បុគ្គលដែលបដិបត្តិដើម្បីភាពមិន

ជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីវិនាសដល់សត្វលោក តែឲ្យដល់បុគ្គលដែលតាំងនៅក្នុងធម៌ប៉ុណ្ណោះ រក្សាលោកដោយធម៌ ។ គប្បីជ្រាបកិច្ចបដិបត្តិក្នុងទានខាងក្រៅ មានត្រឹមប៉ុណ្ណោះ ។

ចំណែកទានខាងក្នុង គប្បីជ្រាបដោយអាការ ២ យ៉ាង សួរថា ជ្រាបដូចម្តេច ឆ្លើយថា ដូចបុរសណាម្នាក់ លះបង់នូវខ្លួនដល់អ្នកដទៃ ព្រោះហេតុតែអាហារ និងគ្រឿងស្លៀកដណ្តប់ រមែងស្តាប់បង្គាប់ រមែងជាទាសៈយ៉ាងណា ព្រះមហាបុរសក៏យ៉ាងនោះដូចគ្នា មានចិត្តប្រាសចាកអាមិស ព្រោះហេតុសម្ពោធិញ្ញាណ ប្រាថ្នាប្រយោជន៍ និងសេចក្តីសុខដ៏កំពូល ដល់សត្វលោកទាំងឡាយ បំណងនឹងបំពេញទានបារមីរបស់ខ្លួន ទើបលះបង់ខ្លួនដើម្បីអ្នកដទៃ រមែងស្តាប់បង្គាប់ រមែងធ្វើតាមបំណង មិនញាប់ញ័រ មិនរួញរាប្រគល់អវយវៈតូចធំ មានដៃ ជើង និងភ្នែកជាដើម ឲ្យដល់បុគ្គលដែលត្រូវការដោយអវយវៈនោះៗ មិនជាប់ជំពាក់ មិនដល់នូវការចងចិញ្ចើម ក្នុងការប្រគល់ឲ្យនោះ ដូចក្នុងវត្ថុខាងក្រៅ ។ ពិតហើយ ព្រះមហាបុរសញ៉ាំងសេចក្តីប្រាថ្នារបស់យាចកទាំងនោះឲ្យបរិបូណ៌ ដោយការបរិភោគតាមសប្បាយ ឬដោយការជំនាញរបស់ខ្លួន ទើបលះបង់វត្ថុខាងក្រៅ ដោយអាការ ២ យ៉ាង ដោយបំណងថា អញឲ្យទានអស់ហើយ នឹងសម្រេចសម្ពោធិញ្ញាណ ដោយការលះបង់យ៉ាងនេះ ។ គប្បីជ្រាបកិច្ចបដិបត្តិក្នុងវត្ថុខាងក្នុង ដោយប្រការដូច្នេះ ។

ឲ្យការឲ្យទាំងពីរ ២ វត្ថុខាងក្នុង ដែលកំពុងឲ្យឯណាប្រព្រឹត្តទៅ ដើម្បី

ប្រយោជន៍ដល់យាចក ដោយចំណែកមួយប៉ុណ្ណោះ រមែងឲ្យវត្ថុខាងក្នុងនោះ មិនឲ្យវត្ថុខាងក្រៅ ម្យ៉ាងទៀត ព្រះមហាបុរស កាលដឹង រមែងមិនឲ្យ អត្តភាព ឬអវយវៈតូចធំរបស់ខ្លួនដល់មារ ឬដល់ទេវតាដែលជាបក្ខពួករបស់ មារ ដែលបំណងនឹងបៀតបៀន ដោយគិតថា សេចក្ដីវិនាសកុំបីមានដល់ មារជាដើមទាំងនោះ រមែងមិនឲ្យដល់បុគ្គលដែលត្រូវទេវតាចូល ដូចមិនឲ្យ ដល់ទេវតា ដែលទាក់ទងដល់ពួកមារ ដូច្នោះ និងមិនឲ្យដល់មនុស្សឆ្កួត ។ តែកាលត្រូវមនុស្សទាំងនោះសូម ក៏ឲ្យរហូតទៅ ព្រោះការសូមបែបនោះ រក បានដោយកម្រ និងព្រោះការឲ្យបែបនោះ ធ្វើបានលំបាក ។

ចំណែកអភយទាន គប្បីជ្រាបដោយការការពារចាកភ័យ ដែលប្រាកដ ដល់សត្វទាំងឡាយ ចាកព្រះរាជា ចោរ ភ្លើង ទឹក សត្រូវ សត្វកាច មាន សីហៈ និងខ្លាធំជាដើម អមនុស្ស មាននាគ យក្ស អារក្ស និងបិសាច ជាដើម ។

ចំណែកធម្មទាន បានដល់ ការសម្ដែងធម៌មិនវិបរិត ដល់បុគ្គលមាន ចិត្តមិនសៅហ្មង ។ ការចង្អុលប្រាប់ប្រយោជន៍ដែលសមគួរ នាំបុគ្គលដែល មិនចូលទៅដល់សាសនា ឲ្យចូលដល់ ដែលចូលដល់ហើយ ឲ្យចម្រើន ដុះដាលដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថ-ប្រយោជន៍ ។ ក្នុងការសម្ដែងធម៌នោះ គប្បីជ្រាបន័យដោយសង្ខេបដូច្នេះមុន គឺទានកថា សីលកថា សគ្គកថា ទោស និងការសៅហ្មងរបស់កាម និង អានិសង្សក្នុងការចេញចាកកាម ។ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបការ

ប្រតិស្ឋាន និងការធ្វើឲ្យផូរផង់ក្នុងធម៌នោះៗ តាមសមគួរ ដោយអំណាចការប្រកាសគុណរបស់ធម៌ទាំងនោះ ដល់បុគ្គលមានចិត្តបង្អោនទៅហើយ ក្នុងសាវកពោធិញ្ញាណ គឺការចូលដល់សរណៈ ការសង្រួមក្នុងសីល ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការស្គាល់ប្រមាណក្នុងការបរិភោគ ការប្រកបព្យាយាមរឿយៗ ព្រះសទ្ធម្ម ៧ ការប្រកបសមថៈ ដោយការធ្វើកម្មក្នុងអារម្មណ៍ ៣៨ ការប្រកបវិបស្សនាដោយមាតិកា គឺកាន់យកតាមសមគួរក្នុងការកាន់យកមាំក្នុងវិបស្សនាក្នុងរូបកាយជាដើម បដិបទាដើម្បីការបរិសុទ្ធយ៉ាងនោះ ការកាន់យកភាពត្រឹមត្រូវដោយវិជ្ជា ៣ អភិញ្ញា ៦ បដិសម្ភិទា ៤ សាវកពោធិញ្ញាណ ។ម្យ៉ាងទៀត គប្បីជ្រាបការប្រតិស្ឋាន ការធ្វើឲ្យផូរផង់ក្នុងញាណទាំងពីរ ដោយការប្រកាសភាពជាអ្នកមានអានុភាពច្រើនរបស់ព្រះពុទ្ធទាំងនោះ ក្នុងឋានៈ ៣ យ៉ាង ដោយមាតិកា មានសភាវលក្ខណៈនិងកិច្ចជាដើមនៃទានបារមីជាដើម តាមសមគួរដល់សត្វទាំងឡាយ ដែលបង្អោនទៅក្នុងបច្ចេកពោធិញ្ញាណ និងក្នុងសម្មាសម្ពោធិញ្ញាណ ។ ព្រះមហាបុរស រមែងឲ្យធម្មទានដល់សត្វទាំងឡាយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត មហាបុរសកាលឲ្យអាមិសទានដល់សត្វទាំងឡាយ រមែងឲ្យទានបាយដោយតាំងចិត្តថា អាត្មាអញគប្បីញ៉ាំងសម្បត្តិ មានអាយុ វណ្ណៈ សុខៈ ពល បដិភាណជាដើម និងសម្បត្តិ គឺផលដ៏ប្រសើរ គួរជាទីត្រេកអរឲ្យសម្រេចដល់សត្វទាំងឡាយដោយទាននេះ ។ ម្យ៉ាងទៀត ឲ្យទឹកដើម្បីរម្ងាប់នូវការស្រេក គឺកាមក្កិលេសរបស់សត្វទាំងឡាយ ឲ្យនូវសំពត់ ដើម្បីឲ្យនូវ

ពណ៌សម្បុរល្អ និងដើម្បីឲ្យសម្រេចគ្រឿងប្រដាប់ គឺហិរិឱត្តប្បៈ ឲ្យយាន ដើម្បីឲ្យសម្រេចឥទ្ធិវិធៈ គឺការសម្តែងឫទ្ធិបាន និងនិញ្វានសុខ ឲ្យគ្រឿងក្រអូប ដើម្បីឲ្យសម្រេចភាពក្រអូប គឺសីល ឲ្យនូវផ្កា និងគ្រឿងលាប ដើម្បីឲ្យ សម្រេចនូវភាពស្អាតដោយពុទ្ធគុណ ឲ្យនូវអាសនៈ ដើម្បីឲ្យសម្រេចអាសនៈ ត្រង់ពោធិមណ្ឌល ឲ្យនូវទីដេក ដើម្បីឲ្យសម្រេចតថាគតសេយ្យា គឺការដេក បែបព្រះតថាគត ឲ្យទីសម្រាក ដើម្បីឲ្យសម្រេចភាពជាសរណៈ ឲ្យប្រទីប ដើម្បីឲ្យបានចក្ខុ ៥ ឲ្យរូបជាទាន ដើម្បីឲ្យសម្រេចរស្មីដែលចេញអំពីកាយ ១ ព្យាម ឲ្យសំឡេងជាទាន ដើម្បីឲ្យសម្រេចសំឡេងដូចសំឡេងព្រហ្ម ឲ្យ រសជាទាន ដើម្បីឲ្យជាទីស្រឡាញ់របស់សត្វលោកទាំងពួង ឲ្យផោដ្ឋព្វៈ ជាទាន ដើម្បីភាពជាពុទ្ធសុខុមាល ឲ្យភេសជ្ជៈជាទាន ដើម្បីការមិនចាស់ មិនស្លាប់ ឲ្យនូវភាពជាអ្នកជា ជាទានដល់ទាសៈទាំងឡាយ ដើម្បីដោះភាព ជាទាសៈ គឺកិលេស ។ ឲ្យនូវការត្រេកអរក្នុងរបស់លេងដែលមិនមានទោស ជាទានដើម្បីការត្រេកអរក្នុងព្រះសទ្ធម្ម ឲ្យបុត្តជាទាន ដើម្បីនាំសត្វទាំងអស់ ចេញទៅអំពីភាពជាបុត្តរបស់ខ្លួន ក្នុងជាតិជាអរិយៈ ឲ្យកិរិយាជាទាន ដើម្បី ដល់នូវភាពជាធំនៃលោកទាំងពួង ។ ឲ្យមាស និងកែវមណី កែវមុក្តា កែវ ប្រពាលជាដើមជាទាន ដើម្បីភាពសម្បូរដោយលក្ខណៈល្អ ឲ្យគ្រឿងប្រដាប់ ច្រើនប្រភេទជាទាន ដើម្បីការសម្បូរនៃអនុព្យញ្ជនៈ ឲ្យឃ្លាំងសម្បត្តិជាទាន ដើម្បីសម្រេចគំនរនៃព្រះសទ្ធម្ម ឲ្យរាជសម្បត្តិជាទាន ដើម្បីភាពជាធម្មរាជា ឲ្យអារាម ស្រះ ព្រៃជាទាន ដើម្បីការសម្បូរនៃឈានជាដើម ឲ្យជើងជាទាន

ដើម្បីឈានទៅកាន់វេស្មីពោធិមណ្ឌល ដោយព្រះបាទដែលមានរូបចក្ក ឲ្យដៃជាទាន ដើម្បីឲ្យដៃ គឺព្រះសទ្ធម្មដល់សត្វទាំងឡាយ ដើម្បីដកចាកឱឃៈ ៤ ឲ្យត្រចៀក និងច្រមុះជាទាន ដើម្បីបាននូវឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម ឲ្យចក្ខុជាទាន ដើម្បីបានសាមន្តចក្ខុ ឲ្យសាច់ និងឈាមជាទាន ដោយបំណងថា កាយរបស់អញ ចូរនាំប្រយោជន៍ និងសេចក្ដីសុខមកឲ្យដល់សព្វសត្វអស់កាលទាំងពួង ក្នុងការឃើញ ការស្ដាប់ ការរឭកដល់ការបម្រើជាដើម និងគប្បីជាកាយដែលសត្វលោកទាំងពួង គប្បីចូលទៅអាស្រ័យ ឲ្យអវយវៈដ៏ឧត្តម ( ក្បាល ) ជាទាន ដោយបំណងថា អាត្មាអញគប្បីជាបុគ្គលប្រសើរបំផុត ក្នុងលោកទាំងពួង ។

ម្យ៉ាងទៀត មហាបុរសកាលឲ្យយ៉ាងនេះ មិនឲ្យដើម្បីស្វែងរកកំហុស មិនឲ្យដើម្បីបៀតបៀនអ្នកដទៃ មិនឲ្យព្រោះខ្លាច ព្រោះខ្មាស ព្រោះអាក់អន់ក្នុងទក្ខិណេយ្យបុគ្គល ។ កាលមានរបស់ប្រណីត មិនឲ្យរបស់សៅហ្មង មិនឲ្យដោយការលើកខ្លួន មិនឲ្យដោយការសង្កត់សង្កិនអ្នកដទៃ មិនឲ្យដោយសង្ឃឹមផល មិនឲ្យដោយស្អប់ខ្ពើមយាចក មិនឲ្យដោយមិនគោរព ដែលពិតឲ្យដោយគោរព ឲ្យដោយផ្ទាល់ដៃ ឲ្យតាមកាល ធ្វើនូវការគោរព ហើយឲ្យឲ្យដោយមិនបែងចែក ឲ្យដោយមានចិត្តត្រេកអរក្នុងកាលទាំង ៣ កាលឲ្យហើយ មិនក្ដៅក្រហាយក្នុងខាងក្រោយ មិនសរសើរ និងមើលងាយបដិគ្គាហកបន្ទឹវាចាគួរស្រឡាញ់ចំពោះបដិគ្គាហក ជីងនូវវាចាស្នូម ឲ្យព្រមទាំងបរិវារទាន ព្រោះកាលឲ្យបាយជាទាន រមែងឲ្យសំពត់ជាដើម ដោយតាំងចិត្តថា អញនឹង

ធ្វើវត្ថុនោះឲ្យជាបរិវារ ហើយឲ្យ ។ មួយវិញទៀត កាលឲ្យសំពត់ជាទាន រមែង ឲ្យមួយអន្ទើដោយបាយជាដើម ដោយតាំងចិត្តថា អញនឹងធ្វើសំពត់នោះឲ្យ ជាបរិវារ ហើយឲ្យ សូម្បីក្នុងការឲ្យយានជាដើម ក៏ន័យនេះដូចគ្នា ។

មួយវិញទៀត មហាបុរសកាលឲ្យរូបជាទាន រមែងឲ្យដើម្បីធ្វើអារម្មណ៍ ដទៃ ឲ្យជាបរិវាររបស់រូបនោះ ។ ក្នុងអារម្មណ៍ដ៏សេស មានសំឡេងជាដើម ក៏ន័យដូចគ្នា ។ ក្នុងអារម្មណ៍ទាំងនោះ ការឲ្យរូបជាទាន បានដល់ កាលបាន អារម្មណ៍ណាមួយ ក្នុងបណ្ដាផ្កា និងសំពត់ជាដើម ដែលមានពណ៌ខៀវ លឿង ក្រហម និងសជាដើម ហើយអន្ទុយកំណត់ថា ជារូប គិតថា អញ នឹងឲ្យរូបជាទាន រូបជាទានជារបស់អញ ហើយតម្កល់ទាន ក្នុងទក្ខិណេយ្យ-បុគ្គលដែលមិនញាប់ញ័រ នេះ ឈ្មោះថា ឲ្យរូបជាទាន ។

គប្បីជ្រាបការឲ្យសំឡេងជាទាន ដោយសំឡេងស្គរជាដើម ក្នុងការឲ្យ សំឡេងជាទាននោះ មិនអាចឲ្យសំឡេងបាន ដូចដកមើម និងក្រអៅឈូក និងដូចដាក់បាច់ផ្កាឈូកខៀវលើដៃ តែធ្វើឲ្យព្រមជាមួយវត្ថុ ហើយឲ្យ ឈ្មោះ ថា ឲ្យសំឡេងជាទាន ព្រោះហេតុនោះ កាលណាធ្វើឯង ឬប្រើឲ្យធ្វើភ្លេង បូជាព្រះរតនត្រ័យដោយតន្ត្រីណាមួយ មានស្គរ និងសម្ភោរជាដើម ដោយ គិតថា អញនឹងឲ្យសំឡេងជាទាន តាំងទុកឯង និងឲ្យអ្នកដទៃតាំងស្គរជាដើម ដោយតាំងចិត្តថា សំឡេងជាទានរបស់អញ ។ ឲ្យថ្នាំរក្សាសំឡេង មាន ប្រេង និងស្ករអំពៅជាដើមដល់ធម្មកថិកទាំងឡាយ ប្រកាសការស្ដាប់ធម៌ សូធ្យសរភញ្ញ ពោលធម្មកថា ធ្វើឯង និងឲ្យអ្នកដទៃ ធ្វើនូវឧបនិសិន្នកថា

និងអនុមោទនាកថា ក្នុងកាលនោះ ឈ្មោះថា ឲ្យសំឡេងជាទាន ។

ម្យ៉ាងទៀត មហាបុរសបានវត្ថុ មានក្លិនក្រអូបគួរគ្រេកអរណាមួយ មានក្លិនក្រអូបកើតអំពីឫសឈើដែលមានក្លិនជាដើម ឬក្លិនណាមួយដែលអប់ហើយ កំណត់ថាជាក្លិន គិតថា អញនឹងឲ្យក្លិនជាទាន ក្លិនជាទានរបស់អញ ហើយធ្វើឯង និងឲ្យអ្នកដទៃធ្វើការបូជាព្រះពុទ្ធរតនៈជាដើម បរិច្ចាគវត្ថុ មានក្លិនក្រអូប មានក្រស្នា និងចន្ទន៍ជាដើម ដើម្បីបូជាដោយក្លិន នេះ ឈ្មោះថា ឲ្យក្លិនជាទាន ។

ម្យ៉ាងទៀត មហាបុរសបានវត្ថុ មានរសគួរគ្រេកអរណាមួយ មានរសដែលកើតអំពីឫសជាដើម កំណត់ថាជារស គិតថា អញនឹងឲ្យរសជាទាន រសជាទានរបស់អញ ហើយឲ្យដល់ទក្ខិណេយ្យបុគ្គល ឬលះវត្ថុមានរសឆ្ងាញ់ ដូចជាស្រូវ និងគោរសជាដើម នេះ ឈ្មោះថា ឲ្យរសទាន ។

ម្យ៉ាងទៀត ឲ្យផោដ្ឋព្វៈជាទាន គប្បីជ្រាបដោយអំណាចគ្រែ និងតាំងជាដើម និងដោយអំណាចកម្រាល និងសំពត់ដណ្តប់ ( ភួយ ) ជាដើម ។

ក្នុងកាលមហាបុរសបានវត្ថុជាផោដ្ឋព្វៈ មិនមានទោស គួរជាទីគ្រេកអរ មានសម្ផស្សជាសុខ មានគ្រែ តាំង ពូក ខ្នើយជាដើម ឬមានសំពត់ដណ្តប់ជាដើម កំណត់ថាជាផោដ្ឋព្វៈ គិតថា អញនឹងឲ្យផោដ្ឋព្វៈជាទាន ផោដ្ឋព្វៈជាទានរបស់អញ ហើយឲ្យដល់ទក្ខិណេយ្យបុគ្គល បានវត្ថុដែលមានសម្ផស្សល្អ តាមដែលពោលហើយបរិច្ចាគទៅ នេះ ឈ្មោះថា ឲ្យផោដ្ឋព្វៈជាទាន ។

ម្យ៉ាងទៀត គប្បីជ្រាបធម្មទាន ដោយអំណាចនៃជីវិត ដែលប្រកប

ដោយឱជះ ព្រោះបំណងយកធម្មារម្មណ៍ ពិតហើយ មហាបុរសបានវត្ថុគួរត្រេកអរណាមួយ មានឱជាជាដើម ហើយកំណត់ថាជាធម្មតារម្មណ៍ គិតថា អញនឹងឲ្យធម៌ជាទាន ធម៌ជាទានរបស់អញ ហើយឲ្យរបស់មានរសឆ្ងាញ់ មានសប្បិ នវនីតជាដើមជាទាន ។ ឲ្យទឹកបាន ៨ យ៉ាង មានទឹកធ្វើអំពីផ្លែស្វាយជាដើមជាទាន កំណត់គិតថា ឲ្យជីវិតជាទាន ទើបឲ្យសលាកកត្ត និងបក្ខិកកត្តជាដើម រកគ្រូពេទ្យព្យាបាលអ្នកជំងឺ ហែកសំណាញ់ បំផ្លាញលបដាក់ត្រី បើកទ្រុងបក្សី ឲ្យលែងសត្វដែលចងដោយចំណង វាយស្គរប្រកាស មិនឲ្យសម្លាប់សត្វ ធ្វើឯង និងឲ្យអ្នកដទៃធ្វើកម្មដទៃ និងកម្មបែបនេះដើម្បីការពារជីវិតសត្វទាំងឡាយ នេះ ឈ្មោះថា ឲ្យធម៌ជាទាន ។

មហាបុរសបង្អោនទានសម្បទា តាមដែលពោលហើយទាំងអស់នេះ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់សត្វលោកទាំងពួង ។ម្យ៉ាងទៀត បង្អោនទានសម្បទា ដើម្បីសម្មាសម្ពោធិញ្ញាណរបស់ខ្លួន ដើម្បីអកុប្បវិមុត្តិ ដើម្បីឆន្ទះ វីរិយៈ សមាធិ បដិភាណ ញាណ អបរិក្ខយវិមុត្តិ គឺវិមុត្តិដែលមិនអស់ទៅ ។ ព្រះមហាសត្វបដិបត្តិទានបារមីនេះ គប្បីឲ្យអនិច្ចសញ្ញាប្រាកដក្នុងជីវិត ក្នុងភោគៈក៏ដូចគ្នា ។ គប្បីមនសិការដល់ភាពជាសាធារណៈយ៉ាងច្រើនដល់សត្វទាំងនោះ គប្បីឲ្យមហាករុណាប្រាកដ ក្នុងសត្វទាំងឡាយរឿយៗ ជានិច្ច កាន់យកទ្រព្យដែលគួរកាន់យកទៅបាន នាំសម្បត្តិទាំងអស់ និងខ្លួនចេញអំពីផ្ទះទៅខាងក្រៅ ដូចចេញអំពីផ្ទះដែលត្រូវភ្លើងឆេះ មិនឲ្យមានសេសសល់ ។ មិនធ្វើការបែងចែកក្នុងទីណាឡើយ ដោយពិត ជាអ្នក

មិនសម្ងឹង គឺលះទាំងអស់នោះឯង នេះជាលំដាប់នៃកិច្ចបដិបត្តិទានបារមី ។

ម្យ៉ាងទៀត គប្បីជ្រាបលំដាប់នៃកិច្ចបដិបត្តិសីលបារមីដូចតទៅ

មហាបុរសបំណងនឹងតាក់តែងសត្វទាំងឡាយ ដោយគ្រឿងប្រដាប់ គឺសីលរបស់ព្រះសព្វញ្ញូ គួរជម្រះសីលរបស់ខ្លួនជាបឋមសិន ។ ម្យ៉ាងទៀត ក្នុងការជម្រះសីលនោះ សីលរមែងបរិសុទ្ធដោយអាការ ៤ យ៉ាង គឺដោយការបរិសុទ្ធនៃអជ្ឈាស្រ័យ ១ ដោយការសមាទាន ១ ដោយមិនឈានកន្លង ១ និងដោយធ្វើឲ្យជាប្រក្រតី កាលមានការឈានកន្លងហើយ ១ ។ ពិតហើយ បុគ្គលខ្លះមានខ្លួនជាធំ ព្រោះអជ្ឈាស្រ័យបរិសុទ្ធ ខ្ពើមបាប ញ៉ាំងហិរិឲ្យប្រាកដខាងក្នុង ហើយមានសមាចារបរិសុទ្ធដោយល្អ ។ ម្យ៉ាងទៀត បុគ្គលខ្លះកាលមានការសមាទាន កាន់យកលោកជាធំ តក់ស្លុតចំពោះបាប ញ៉ាំងឱត្តប្បៈឲ្យប្រាកដ ជាអ្នកមានសមាចារបរិសុទ្ធដោយល្អ ដោយប្រការដូច្នេះ បុគ្គលទាំងនោះ រមែងតាំងនៅក្នុងសីល ព្រោះមិនកន្លងទាំង ២ យ៉ាង តែជួនកាល ព្រោះមិនមានសតិ សីលក៏ដាច់ជាដើម ធ្វើសីលដែលដាច់ទៅនោះឲ្យជាប្រក្រតីដោយរហ័ស ដោយការនៅកម្ម ( សមាទាន ) ជាដើម ដើម្បីការដល់ព្រមនៃហិរិឱត្តប្បៈ តាមដែលពោលហើយនោះ ។

សីលមាន ២ យ៉ាង គឺវារិត្តសីល ១ ចារិត្តសីល ១ ក្នុងសីល ២ យ៉ាងនោះ គប្បីជ្រាបលំដាប់កិច្ចបដិបត្តិក្នុងវារិត្តសីលរបស់ព្រះពោធិសត្វដូចតទៅ គប្បីជាអ្នកមានចិត្តករុណាក្នុងសព្វសត្វ ដោយហោចសូម្បីយល់សប្តិក៏មិនគប្បីកើតអាឃាត មិនគប្បីប៉ះរបស់អ្នកដទៃដូចពស់ ព្រោះត្រេកអរ

ក្នុងការជួយសង្គ្រោះអ្នកដទៃ បើជាបព្វជិត ជាអ្នកប្រព្រឹត្តឆ្ងាយចាកអព្រហ្ម-ចរិយៈ ប្រាសចាកមេថុនសំយោគ ៧ យ៉ាង មិនចាំបាច់ពោលដល់ការប្រព្រឹត្តកន្លងកិរិយាអ្នកដទៃ ។ បើជាគ្រហស្ថ មិនមែនបព្វជិត សូម្បីចិត្តលាមក ក៏មិនឲ្យកើតឡើងក្នុងកិរិយារបស់អ្នកដទៃសព្វកាល ។ កាលពោលក៏ពោលពាក្យល្មមប្រមាណ ជាពាក្យពិតមានប្រយោជន៍ គួរស្រឡាញ់ និងពោលធម៌តាមកាល មិនលោភ មិនព្យាបាទ មិនយល់ខុស ប្រកបដោយកម្មស្សកតញ្ញាណ មានសទ្ធាមាំទាំ ស្រឡាញ់មាំទាំក្នុងកិរិយា បដិបត្តិប្រពៃដែលប្រព្រឹត្តទៅដោយប្រពៃ ។

កាលមហាបុរសវៀរចាកអកុសលកម្មបថ ដែលជាផ្លូវនៃអបាយ ៤ និងវៀរចាកអកុសលធម៌ ហើយតាំងនៅក្នុងកុសលកម្មបថ ដែលជាផ្លូវនៃស្ថានសួគ៌ និងព្រះនិព្វាន សេចក្តីប្រាថ្នាដែលចូលទៅប្រកបប្រយោជន៍ និងសេចក្តីសុខដល់សត្វទាំងឡាយតាមប្រាថ្នា ព្រោះជាអ្នកប្រកបដោយអជ្ឈាស្រ័យបរិសុទ្ធ រមែងសម្រេចរួសរាន់ ។ បារមីរមែងបរិបូណ៌ មហា-បុរសនេះមានសភាពយ៉ាងនេះ ។ មហាបុរស រមែងឲ្យអភយទានដល់សព្វសត្វ ដោយមិនប្រព្រឹត្តបៀតបៀន ញុំាងមេត្តាភាវនាឲ្យបរិបូណ៌ ដោយមិនលំបាក រមែងសម្រេចអានិសង្សមេត្តា ១១ ប្រការ មានអាពាធតិច មិនមានជំងឺតម្កាត់ មានអាយុវែង មានសេចក្តីសុខច្រើន រមែងដល់នូវលក្ខណៈវិសេស និងកាត់វាសនាដែលជាទោសបាន ។

ម្យ៉ាងទៀត ព្រោះមិនលួចទ្រព្យ ទើបបានភោគសម្បត្តិ ដែលមិនទូទៅ

ដល់ចោរជាដើម បុគ្គលដទៃមិនវៀរវៀស ជាទីស្រឡាញ់ ជាទីពេញចិត្ត គួរគប់រក មានចិត្តមិនជាប់ជំពាក់ក្នុងវិភវសម្បត្តិ គាប់ចិត្តក្នុងបរិច្ចាគ និងកាត់វាសនាដែលជាលោភៈបាន ។

ព្រោះមិនប្រព្រឹត្តខុសក្នុងព្រហ្មចរិយៈ ទើបជាអ្នកមិនឡេះឡោះ មានកាយ និងចិត្តស្ងប់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីវៀរវៀសរបស់សត្វទាំងឡាយ កិត្តិសព្ទដ៏ល្អរមែងផ្សាយទៅ មិនមានចិត្តជាប់ជំពាក់ក្នុងមាតុគ្រាមទាំងឡាយ មានអធ្យាស្រ័យមិនលោភ ច្រើនទៅដោយនេក្ខម្មៈ រមែងបាននូវលក្ខណៈវិសេស និងកាត់វាសនាដែលជាលោភៈបាន ។

ព្រោះមិននិយាយកុហក ទើបជាប្រមាណនៃសត្វទាំងឡាយ ជាទីទុកចិត្តបាន មានពាក្យគួរជឿ ជាទីស្រឡាញ់ ជាទីពេញចិត្តនៃទេវតាទាំងឡាយ មានមាត់ក្រអូប រក្សាកាយសមាចារ វចីសមាចារ រមែងបាននូវលក្ខណៈវិសេស និងកាត់វាសនាដែលជាកិលេសបាន ។

ព្រោះមិននិយាយញុះញង់ ទើបមានពួកមិនបែក មានបរិវារមិនបែក ទោះបីមានការព្យាយាមពីអ្នកដទៃ មានសំឡេងមិនបែកក្នុងព្រះសទ្ធម្ម មានមិត្តមាំទាំ ជាទីស្រឡាញ់របស់សត្វទាំងឡាយដោយចំណែកមួយ ដូចសន្សំទុកក្នុងវាងកព ច្រើនដោយសេចក្តីមិនសៅហ្មង ។

ព្រោះមិនពោលទ្រគោះបោះបោក ទើបជាទីស្រឡាញ់ ជាទីពេញចិត្តនៃសត្វទាំងឡាយ មានប្រក្រតីនៅជាសុខ និយាយពីរោះ គួរសរសើរ សំឡេងប្រកបដោយអង្គ ៨ រមែងកើតឡើង ។

ព្រោះមិនពោលពាក្យឥតប្រយោជន៍ ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត គួរគោរព គួរសរសើររបស់សត្វទាំងឡាយ មានពាក្យសម្ដីគួរជឿ និយាយល្មមប្រមាណ មានសក្តិធំ និងអានុភាពច្រើន ឈ្លាសក្នុងការស្រាយប្រស្នា ដោយបដិភាណដ៏រួសរាន់ ជាអ្នកអាចក្នុងការឆ្លើយបញ្ហាជាច្រើនរបស់សត្វទាំងឡាយ ច្រើនភាសាដោយភាសាតែមួយប៉ុណ្ណោះ ក្នុងពុទ្ធភូមិ ។

ព្រោះជាអ្នកមិនលោភ ទើបមានលាភតាមដែលត្រូវការ បាននូវការពេញចិត្តក្នុងភោគៈជាច្រើន ជាទីទទួលយករបស់ក្សត្រមហាសាលជាដើម សត្រូវគ្រប់សង្កត់មិនបាន មិនដល់នូវភាពជាអ្នកមានឥន្ទ្រិយពិការ និងជាបុគ្គលមិនមានបុគ្គលប្រៀប ។

ព្រោះមិនព្យាបាទ ទើបជាបុគ្គលគួរស្រឡាញ់ ជាទីសរសើរនៃសត្វទាំងឡាយ ឲ្យសត្វជ្រះថ្លាដោយមិនលំបាក ព្រោះជាអ្នកពេញចិត្តក្រៃលែងក្នុងប្រយោជន៍របស់អ្នកដទៃ ។ម្យ៉ាងទៀត ជាអ្នកមានសភាវៈមិនសៅហ្មងនៅដោយមេត្តា ជាទីមានសក្តិធំ មានអានុភាពច្រើន ។

ព្រោះជាអ្នកមិនមានមិច្ឆាទិដ្ឋិ ទើបបាននូវសម្លាញ់ល្អ ទោះបីត្រូវកាត់ក្បាល ក៏មិនធ្វើបាប ជាអ្នកមិនជឿមង្គលភ្ញាក់ផ្អើល ព្រោះឃើញភាពដែលសត្វមានកម្មជារបស់ខ្លួន សទ្ធារបស់លោក ជាឫសគល់តាំងមាំក្នុងព្រះសទ្ធម្ម ជឿនូវការត្រាស់ដឹងរបស់តថាគត មិនត្រេកអរក្នុងលទ្ធិដទៃ ដូចស្តេចហង្ស មិនត្រេកអរក្នុងស្រះដែលគេចាក់សំរាម ដូច្នោះ ។ ជាអ្នកឈ្លាសក្នុងការ

កំណាត់ដឹងលក្ខណៈ ៣ យ៉ាង ជាអ្នកបាននូវអនាវរណញ្ញាណក្នុងទីបំផុត មិនសម្រេចពោធិញ្ញាណដរាបណា នឹងជាអ្នកប្រោកដច្បាស់ក្នុងពួកសត្វនោះៗដរាបនោះ នឹងដល់សម្បត្តិច្រើនសន្ធឹកសន្ធាប់ ។ គប្បីញ៉ាំងការរាប់អានយ៉ាងច្រើនឲ្យកើតឡើងថា ឈ្មោះថា សីលនេះ ជាទីតាំងនៃសម្បត្តិសព្វយ៉ាង ជាដែនកើតនៃពុទ្ធគុណទាំងពួងជាខាងដើម ជាចរណៈ ជាប្រធាន ជាប្រមុខនៃពុទ្ធការកធម៌ទាំងពួង ដូច្នោះហើយ ទើបជាអ្នកមិនប្រមាទ ដោយកម្លាំងនៃសតិសម្បជញ្ញៈ ក្នុងការសង្រួមកាយវាចា ក្នុងការទូន្មានឥន្ទ្រិយ ក្នុងសេចក្តីបរិសុទ្ធរបស់អាជីវៈ និងក្នុងការបរិភោគនូវបច្ច័យទាំងឡាយ កំណាត់លាភសក្ការៈ និងការសរសើរ ដូចសត្រូវចំពោះមុខ ធ្វើជាមិត្តហើយ ឲ្យសីលបរិបូណ៌ដោយគោរព តាមន័យដូចពោលហើយថា **កិកីវ អណ្ឌំ** សត្វត្រដេវវិចរក្សាស៊ុត ដូច្នេះ នេះជាលំដាប់នៃបដិបត្តិក្នុងវារិត្តសីល ។

ឯកិច្ចបដិបត្តិក្នុងចារិត្តសីល គប្បីជ្រាបយ៉ាងនេះថា ព្រះពោធិសត្វធ្វើអភិវាទ ធ្វើការក្រោកទទួល ធ្វើអញ្ជលីកម្ម ធ្វើសាមីចិកម្មដល់កល្យាណមិត្តដែលតាំងនៅក្នុងឋានៈជាគ្រូសព្វកាល ។ម្យ៉ាងទៀត ធ្វើការទំនុកបម្រុងនូវកល្យាណមិត្តទាំងនោះសព្វកាល ធ្វើការជួយសង្គ្រោះអ្នកជំងឺទាំងឡាយ ស្តាប់បទសុភាសិត ហើយធ្វើសាធុការ ពណ៌នាគុណរបស់អ្នកមានគុណធម៌ អត់ធន់ក្នុងការធ្វើនូវវិនាសរបស់អ្នកដទៃ ។ រឭកដល់អ្នកធ្វើឧបការៈ អនុមោទនាបុណ្យ បង្អោនបុណ្យរបស់ខ្លួនដើម្បីសម្មាសម្ពោធិញ្ញាណ នៅដោយសេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយសព្វកាល កាលមានទោសឃើញដោយ

ភាពជាទោសហើយ ប្រាប់ដល់សហធម្មិកនោះតាមសេចក្តីពិត បំពេញសម្មាបដិបត្តិឲ្យក្រៃលែងដោយប្រពៃ ។

ម្យ៉ាងទៀត កាលគួរធ្វើវត្ថុជាប្រយោជន៍ដែលសមគួរដល់ខ្លួនដល់សត្វទាំងឡាយ ជាអ្នកព្យាយាម មិនខ្ជិលច្រអូស ចូលដល់ភាពជាសម្លាញ់ ។ ម្យ៉ាងទៀត កាលទុក្ខ មានជំងឺជាដើមកើតឡើងដល់សត្វទាំងឡាយ ជាអ្នកចាត់ការជួយសង្គ្រោះតាមសមគួរ កាលសត្វទាំងឡាយធ្លាក់នៅក្នុងសេចក្តីវិនាស មានការវិនាសចាកញាតិ និងសម្បត្តិជាដើម ក៏ជួយបន្ទោបង់នូវសេចក្តីសោក ជាអ្នកតាំងនៅក្នុងសភាពដែលនឹងជួយសង្គ្រោះ ជាអ្នកសង្កត់សង្កិនដល់បុគ្គលដែលគួរសង្កត់សង្កិនតាមធម៌ ដើម្បីឲ្យផុតចាកអកុសល ហើយតាំងនៅក្នុងកុសល ជាអ្នកសរសើរបុគ្គលដែលគួរសរសើរដោយធម៌ ។ កម្មណាដែលធ្វើបានលំបាកក្រៃលែង ជាកម្មទូលំទូលាយ មានអានុភាពជាអចិន្តេយ្យ ដែលនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់សត្វទាំងឡាយដោយចំណែកមួយ ដែលព្រះមហាពោធិសត្វក្នុងកាលមុនបានប្រព្រឹត្តហើយពោធិសម្ភាររបស់ព្រះមហាពោធិសត្វទាំងនោះ បានដល់នូវការចាស់ក្លាដោយប្រពៃ ដោយកម្មណា ស្តាប់កម្មទាំងនោះហើយ មិនតក់ស្លុត មហាបុរសទាំងនោះ ក៏ជាមនុស្សដូចគ្នា មានអត្តភាពអប់រំដើម្បីការបរិបូណ៌នៃការសិក្សាតាមលំដាប់ បានសម្រេចដល់បារមីយ៉ាងឧក្រិដ្ឋក្នុងពោធិសម្ភារ ដើម្បីដល់ព្រមដោយអានុភាពដ៏កំពូលបែបនោះ ព្រោះហេតុនោះ សូម្បីអាត្មាអញក៏គប្បីបដិបត្តិយ៉ាងនោះដោយប្រពៃ ក្នុងសិក្ខា មានសីលសិក្ខាជាដើម មិន

លះបង់សេចក្តីព្យាយាម ដែលមានសទ្ធាជាបុរេចរិត ដោយគិតថា អាត្មាអញក៏នឹងបំពេញសិក្ខាឲ្យបរិបូណ៌តាមលំដាប់ ដោយកិច្ចបដិបត្តិ ហើយនឹងសម្រេចតាមដល់បទនោះដោយចំណែកមួយ ដូច្នេះ ឈ្មោះថា ជាអ្នកធ្វើនូវភាពបរិបូណ៌ក្នុងសីលទាំងឡាយ ដោយប្រពៃ ។

ម្យ៉ាងទៀត មហាបុរសជាអ្នកបិទបាំងនូវអំពើល្អ បើកនូវទោស ប្រាថ្នាតិច សន្តោស គាប់ចិត្តក្នុងទីស្ងាត់ មិនច្រឡូកច្រឡំ អត់ធន់ចំពោះទុក្ខ មិនតក់ស្លុត មិនរាយមាយ មិនលើកតម្កើងខ្លួន មិនញាប់ញ័រ មិនមាត់រឹង មិនជាអ្នករករឿងឈ្លោះ ជាអ្នកមានឥន្ទ្រិយស្ងប់ ជាអ្នកមានចិត្តស្ងប់ ប្រាសចាកមិច្ឆាជីព មានការបោកបញ្ឆោតជាដើម ដល់ព្រមដោយអាចារ និងគោចរ ឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទ ប្រារព្ធសេចក្តីព្យាយាម មានខ្លួនមាំទាំ មិនគិតដល់កាយ និងជីវិត មិនព្រមទទួល លះបង់ បន្ទោបង់នូវការសម្ងំកាយ និងជីវិត សូម្បីមានប្រមាណតិច មិនចាំបាច់ពោលដល់មានប្រមាណច្រើន ។ ជាអ្នកលះ ជាអ្នកបន្ទោបង់នូវឧបក្កិលេស មានកោធៈ និងឧបនាហៈជាដើម ដែលជាហេតុនៃការទ្រុស្ត-សីលទាំងពួង ជាអ្នកមិនត្រេកអរក្នុងការសម្រេចធម្មវិសេស ដែលមានប្រមាណតិចតួច មិនរារែកចិត្ត ព្យាយាមដើម្បីសម្រេចធម្មវិសេសដែលក្រៃលែង ។

សម្បត្តិតាមដែលបានមក មិនមានចំណែកនៃសេចក្តីវិនាស ឬតាំងមាំដោយវិធីណា មហាបុរស ជាអ្នកដឹកនាំដោយវិធីនោះ ម្យ៉ាងទៀត មហាបុរស

ជាអ្នកនាំផ្លូវមនុស្សភ្នែកខ្វាក់ បង្ហាញផ្លូវ ជាអ្នកឲ្យសញ្ញាដោយម្រាមដៃដល់មនុស្សថ្លង់ អនុគ្រោះប្រយោជន៍ ក្នុងមនុស្សគក៏ដូចគ្នា ឲ្យតាំង ឲ្យយានដល់ជនពិការ ឬនាំទៅ បុគ្គលមិនមានសទ្ធា ព្យាយាមឲ្យមានសទ្ធា បុគ្គលខ្ជិលច្រអូស ព្យាយាមឲ្យកើតឧស្សាហៈ បុគ្គលវង្វេង ព្យាយាមឲ្យបាននូវសតិ បុគ្គលមានចិត្តរវើរវាយ ព្យាយាមឲ្យបានសមាធិ បុគ្គលមានបញ្ញាថោកថយ ព្យាយាមឲ្យមានបញ្ញាល្អ បុគ្គលលិចក្នុងកាមច្ឆន្ទៈ ព្យាយាមឲ្យបន្ទោបង់កាមច្ឆន្ទៈ បុគ្គលលិចចុះក្នុងព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ និងវិចិកិច្ឆា ព្យាយាមឲ្យបន្ទោបង់វិចិកិច្ឆា ។ បុគ្គលត្រូវកាមវិតក្កជាដើមគ្របសង្កត់ ព្យាយាមបន្ទោបង់មិច្ឆាវិតក្ក មានកាមវិតក្កជាដើម អាស្រ័យភាពជាអ្នកដឹងគុណ ដែលធ្វើហើយរបស់សត្វដែលជាបុព្វការី ទើបហៅមុន ពោលពាក្យគួរជាទីស្រឡាញ់ សង្គ្រោះ រាប់អាន ដោយធ្វើការតបស្នងដូចគ្នា ឬក្រៃលែងជាង ។

មហាបុរស រមែងគិតតាមជួយសង្គ្រោះសម្លាញ់ ក្នុងអន្តរាយទាំងឡាយ ។ មហាបុរស កំណត់ដឹងខ្លួន និងសភាពប្រក្រតីរបស់សម្លាញ់ទាំងនោះហើយ នៅរួមជាមួយសម្លាញ់ដូចដែលធ្លាប់នៅរួមគ្នាមក ម្យ៉ាងទៀតបដិបត្តិក្នុងសម្លាញ់ ដូចដែលធ្លាប់បដិបត្តិមក ដោយឲ្យផុតចាកអកុសល ហើយតាំងនៅក្នុងកុសល មិនមែនឲ្យតាំងនៅដោយប្រការដទៃ ព្រោះការតាមរក្សាចិត្តរបស់អ្នកដទៃនៃព្រះពោធិសត្វទាំងឡាយ ក៏ត្រឹមតែដើម្បីសេចក្តីចម្រើននៃកុសលក្រៃលែងប៉ុណ្ណោះ កាលបើយ៉ាងនោះ ទើបមិនគួរបៀតបៀន

សត្វដទៃ មិនគួរឈ្លោះ មិនគួរឲ្យដល់នូវភាពជាអ្នកខ្មាស ព្រោះអធ្យាស្រ័យនោះ ។ មិនគួរឲ្យកើតសេចក្ដីរង្កៀសក្នុងសត្វដទៃ គួរទាក់ទងក្នុងឋានៈដែលគួរសន្តត់សន្តិន កាលបុគ្គលនោះតូចទាបជាង មិនគួរដាក់ខ្លួនឲ្យខ្ពស់ជាង មិនគួរសេពគប់ក្នុងអ្នកដទៃរហូតដល់អស់ ( ទ្រព្យ ) ក៏មិនមែន មិនគួរសេពគប់ច្រើន មិនគួរសេពគប់មិនស្គាល់កាល ។

ម្យ៉ាងទៀត គប្បីជ្រាបថា មហាបុរស រមែងគប់រកសត្វដែលគួរគប់រកតាមសមគួរដល់កាលៈទេសៈ មិនតិះដៀលបុគ្គលដែលជាទីស្រឡាញ់ ឬសរសើរបុគ្គលដែលមិនជាទីស្រឡាញ់ ចំពោះមុខអ្នកដទៃ មិនស្និទ្ធស្នាលជាមួយបុគ្គលដែលមិនស្និទ្ធស្នាល មិនបដិសេធការអញ្ជើញដែលប្រកបដោយធម៌ មិនសម្ដែងខ្លួនច្រើន មិនទទួលរបស់ច្រើន រមែងត្រេកអរជាមួយអ្នកមានសទ្ធា ដោយការពោលអានិសង្សនៃសទ្ធា រមែងត្រេកអរនឹងមានអ្នកមានសីល មានសុតៈ ចាគៈ និងបញ្ញា ដោយការពោលដល់ភាពបរិបូណ៌នៃបញ្ញា ។ ម្យ៉ាងទៀត បើព្រះពោធិសត្វជាអ្នកដល់កម្លាំងអភិញ្ញា ក៏បង្ហាញនរកជាដើម តាមសមគួរដោយកម្លាំងអភិញ្ញា ញុំាងសត្វដែលដល់សេចក្ដីប្រមាទឲ្យសង្វេគ ហើយញុំាងសត្វដែលមិនមានសទ្ធាជាដើម ឲ្យតាំងនៅក្នុងសទ្ធាជាដើម ឲ្យឈមចុះក្នុងសាសនា ឲ្យលូតលាស់ក្នុងគុណសម្បត្តិ មានសទ្ធាជាដើម ។ សត្វនេះ ជាអ្នកប្រព្រឹត្តតាមចរិតនៃមហាបុរស ដែលជាអ្នកបង្ហូរមកនូវបុណ្យកុសល មិនមានប្រមាណ រមែងចម្រើនក្រៃលែង ។

ម្យ៉ាងទៀត លោកតាំងសំណួរដោយន័យជាដើមថា សីល គឺអ្វី សីល

ដោយអត្ថដូចម្ដេច ហើយពោលសេចក្ដីពិស្ដារនៃសីលក្នុងវិសុទ្ធិមគ្គ ដោយប្រការផ្សេងៗ ដោយន័យជាដើមថា ធម៌ មានចេតនាជាដើម របស់បុគ្គលអ្នកវៀរចាកបាណាតិបាតជាដើម ឬរបស់អ្នកបំពេញវត្តបដិបត្តិ ឈ្មោះថាសីល ។ កថាទាំងអស់នោះ គួរនាំមកពោលក្នុងទីនេះ ផ្សេងគ្នាត្រឹមតែក្នុងវិសុទ្ធិមគ្គនោះ សីលកថា មកដោយអំណាចនៃសាវកពោធិសត្វតែម្យ៉ាង ក្នុងទីនេះ លោកពោលដល់សីលកថា ដោយអំណាចនៃព្រះមហាសត្វ ថាមានការធ្វើនូវភាពជាអ្នកឈ្លាសក្នុងឧបាយ គឺករុណាជាចំណែកខាងដើម មហាបុរស មិនបង្អោនទៅដើម្បីវិជ្ជា ៣ អភិញ្ញា ៦ ដើម្បីសម្រេចបដិសម្ភិទា ៤ សាវកពោធិញ្ញាណ បច្ចេកពោធិញ្ញាណរបស់ខ្លួន ព្រោះសីលនេះ ក្នុងទុគ្គតិ មិនបង្អោនទៅ ដើម្បីផុតកិលេស ដោយឥតសេសសល់សម្រាប់ខ្លួន ក្នុងសុគតិ មិនបង្អោនទៅដើម្បីរាជសម្បត្តិ ដើម្បីចក្កពត្តិសម្បត្តិ ដើម្បីទេវសម្បត្តិ ដើម្បីសក្កសម្បត្តិ ដើម្បីមារសម្បត្តិ ដើម្បីព្រហ្មសម្បត្តិ តែបង្អោនទៅដើម្បីឲ្យសត្វទាំងពួង មានសីលជាគ្រឿងប្រដាប់ដ៏កំពូល ដោយភាពជាព្រះសព្វញ្ញូដូច្នេះឯង នេះគឺលំដាប់នៃកិច្ចបដិបត្តិក្នុងការបំពេញសីលបារមី ។

ម្យ៉ាងទៀត ព្រោះការកើតឡើងនៃកុសលចិត្តដែលប្រព្រឹត្តទៅហើយដោយការចេញចាកកាម និងភពទាំងឡាយ មានការឃើញទោសជាខាងដើម កំណត់ដោយភាពជាអ្នកឈ្លាសក្នុងឧបាយ គឺករុណា ឈ្មោះថា នេក្ខម្មបារមី ហេតុនោះ កាមទាំងឡាយ មានការត្រេកអរតិច មានការពាក់ព័ន្ធដោយវត្ថុមិនជាប្រយោជន៍ជាច្រើន លិទ្ធក្ខន្ធនូវភាពដែលយកវាសមិនមានឱកាស រក

សេចក្តីសុខក្នុងនេក្ខម្មៈបាន ដូចលិទ្ធតំណក់ទឹកឃ្មុំដែលជាប់ត្រង់មុខកាំបិត ព្រោះតាំងនៅជាមួយសេចក្តីសៅហ្មងទាំងមូល ព្រោះចង្អៀតចង្អល់ច្រើន ដោយបុត្ត និងភរិយាជាដើម ព្រោះវឹកវរដោយការតាំងចិត្តធ្វើការងារច្រើនយ៉ាង មានកសិកម្ម និងពាណិជ្ជកម្មជាដើម បានពេលបន្តិចបន្តួច ដូចការរាំដែលប្រើពន្លឺផ្លេកបន្ទោរ សោយដោយសញ្ញាវិបរិត ដូចគ្រឿងប្រដាប់របស់មនុស្សឆ្កួត ជាវត្ថុតបស្នង ដូចសំពត់បិទលាមក មិនឆ្អែត ដូចផឹកទឹកបន្តិចបន្តួចត្រង់ម្រាមដៃដែលសើមដោយទឹក មានការមិនសប្បាយ ដូចបរិភោគអាហារក្នុងពេលឃ្លាន ជាហេតុប្រជុំនូវសេចក្តីវិនាស ដូចនុយត្រង់ផ្លែសន្ទូចជាហេតុកើតទុក្ខក្នុងកាលទាំង ៣ ដូចកម្តៅរបស់ភ្លើង មានការចងជាគ្រឿងសម្គាល់ ដូចជ័រសម្រាប់ដាក់ស្វា មានការបិទបាំងដោយវត្ថុដែលមិនជាប្រយោជន៍ ដូចបិទដោយតក្កៈ ជាទីតាំងនៃភ័យ ដូចស្រុកសត្រូវ ជានុយរបស់កិលេសមារជាដើម ដូចចិញ្ចឹមសត្រូវ មានទុក្ខកើតអំពីការប្រែប្រួល ដូចសម្បត្តិមហោស្រព មានការដុតខាងក្នុង ដូចភ្លើងឆេះក្នុងឈើប្រហោង មានទោសច្រើន ដូចស្មៅយាប្លង សំយុងក្នុងរណ្តៅលាមក ជាហេតុនៃការស្រេក ដូចទឹកប្រៃដែលជនថោកទាបសេព ដូចសុរា និងមេរ័យ ឧបមាដូចរាងឆ្អឹង ព្រោះមានសេចក្តីត្រេកអរតិច ព្រះយោគាវចរកំណត់ទោសដោយន័យនេះជាដើមហើយ ឃើញអានិសង្សក្នុងការបួស ដោយបរិយាយដែលផ្ទុយគ្នាអំពីទោសនោះ មានចិត្តបង្អោនទៅក្នុងគុណ មាននេក្ខម្មៈ វិវេក និងសេចក្តីសុខដ៏ស្ងប់ជាដើម គប្បីបំពេញនេក្ខម្មបារមី ម្យ៉ាងទៀត ព្រោះនេក្ខម្មៈ

ជាហេតុនៃបព្វជ្ជា ហេតុនោះ ទើបមិនលើកបព្វជ្ជាមកមុន កាលព្រះពុទ្ធមិនទាន់កើតឡើង ព្រះមហាសត្វ តាំងនៅក្នុងបព្វជ្ជា ទើបមិនលើកបព្វជ្ជារបស់តាបស បរិព្វជកដែលជាកម្មវាទី កិរិយវាទីមកពោល ។

កាលព្រះសម្មាសម្ពុទ្ធទាំងឡាយកើតហើយ គួរបួសក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធទាំងនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត កាលបួសហើយ ក៏ជាអ្នកតាំងនៅក្នុងសីលតាមដែលពោលហើយ គួរសមាទានធុតង្គគុណ ដើម្បីសេចក្តីផូរផង់នៃសីលបារមីនោះឯង ។ ពិតហើយ មហាបុរសទាំងឡាយ សមាទានធុតង្គធម៌ ហើយរក្សាធុតង្គធម៌នោះដោយប្រពៃ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស មានសមាចារទាំងពួងបរិសុទ្ធដោយគុណនៃសីល មិនមានទោសព្រោះជាអ្នកមានមន្ទិល គឺកិលេសខ្ជាក់ចេញហើយដោយទឹក គឺគុណធម៌ មានការជុសខាតកិលេស ជាអ្នកស្ងាត់ មិនច្រឡូកច្រឡំ ប្រារព្ធសេចក្តីព្យាយាមចិញ្ចឹមងាយជាដើម តាំងនៅក្នុងអរិយវង្ស ៣ ដែលជាបុរាណធម៌ ចូលដល់ឈានដែលមានប្រភេទជាឧបចារជ្ឈាន និងអប្បនាឈាន តាមសមគួរក្នុងអារម្មណ៍ ៤០ ដើម្បីសម្រេចអរិយវង្ស គឺភាពជាអ្នកត្រេកអរក្នុងភាវនាទី ៤ ។ ដោយប្រការដូច្នេះ ឈ្មោះថា មហាបុរសនោះ បំពេញនេក្ខម្មបារមីដោយប្រពៃហើយ ។

ម្យ៉ាងទៀត ក្នុងទីនេះគប្បីពោលកម្មដ្ឋាន និងវិធីភាវនានៃសមាធិភាវនា ៤០ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ អរូបជ្ឈាន ៤ សញ្ញា ១ វវត្ថាន ១ មួយអន្ទើដោយធុតង្គ ១៣ ដោយពិស្តារ ។ ព្រោះ

ទាំងអស់នោះ លោកបានពោលពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ដោយប្រការទាំងពួងហើយ ។ ហេតុនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ព្រោះផ្សេងគ្នាត្រឹមតែក្នុងវិសុទ្ធិមគ្គនោះ លោកពោលដោយអំណាចនៃសាវកពោធិសត្វតែម្យ៉ាង ។ ក្នុងទីនេះ លោកពោលដោយអំណាចមហាពោធិសត្វថា មានការធ្វើភាពជាអ្នកឈ្លាសក្នុងឧបាយ គឺករុណាជាដើម ។ គប្បីជ្រាបលំដាប់នៃនេក្ខម្មបារមីក្នុងទីនេះយ៉ាងនេះឯង ។

ម្យ៉ាងទៀត ព្រោះបញ្ញានៅរួមជាមួយមោហៈមិនបាន ដូចពន្លឺ មិននៅរួមជាមួយងងឹត ហេតុនោះ ព្រះពោធិសត្វដែលបំណងឲ្យបញ្ញាបារមីបរិបូណ៌ ទើបគួរវៀរហេតុនៃមោហៈមុន ។ គប្បីជ្រាបដល់ហេតុនៃមោហៈទាំងនេះដូចតទៅនេះ ការមិនត្រេកអរ ការប្រអូស ការដេកលក់ ការសុបសៅ ការខ្ជិល ការត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ មិនចូលចិត្តធ្វើ មិនដាក់ចិត្តក្នុងញាណ ការប្រកាន់ខុស ការមិនសាកសួរ ការមិនបរិហាររាងកាយឲ្យល្អ ចិត្តមិនតាំងមាំ គប់រកបុគ្គលដែលមានបញ្ញាថោកថយ មិនចូលទៅជិតអ្នកមានបញ្ញា មើលងាយខ្លួន ពិចារណាខុស កាន់យកវិបរិតប្រកាន់មាំក្នុងកាយច្រើន មិនមានសេចក្តីសង្វេគ ប្រកបដោយនីវរណៈ ៥ ពោលដោយសង្ខេប បានដល់ ធម៌ដែលជាហេតុឲ្យបញ្ញា រមែងអ្នកសេពដែលមិនកើតឡើង នឹងមិនកើតឡើង ដែលកើតឡើងហើយ រមែងវិនាស បុគ្គលវៀរហេតុនៃការវង្វេងទាំងនេះ គប្បីធ្វើសេចក្តីព្យាយាមក្នុងពាហុសច្ចៈនិងក្នុងឈានជាដើម ដោយប្រការដូច្នេះ ។

គប្បីជ្រាបការចែកលក្ខណៈរបស់ពាហុសច្ចៈ ក្នុងបញ្ញានោះដូចតទៅ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ អរិយសច្ច ៤ ឥន្ទ្រិយ ២២ បដិច្ចសមុប្បាទ ១២ សតិប្បដ្ឋាន ៤ និងប្រភេទធម៌ មានកុសលជាដើម វិជ្ជាដែលមិនមានទោសក្នុងលោក ការឆ្លើយបញ្ហាដែលល្អ ដែលប្រកបដោយវិធីនាំប្រយោជន៍ និងសេចក្ដីសុខឲ្យដល់សត្វទាំងឡាយ គប្បីធ្វើសុតមយប្បញ្ញាឲ្យកើត ដោយការឈមចុះកាន់សុតវិស័យសព្វយ៉ាងគ្រប់ប្រការ ដោយបញ្ញាដែលជាការឈ្លាសក្នុងឧបាយជាខាងដើម ដោយសតិ ដោយវិរិយៈ ដោយការរៀនសូត្រ ការស្ដាប់ ការទ្រទ្រង់ចាំ ការសន្សំ ការសាកសួរដោយល្អ ហើយឲ្យអ្នកដទៃតាំងនៅក្នុងបញ្ញានោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បញ្ញាដែលជាបដិភាណដែលធ្វើឲ្យសត្វទាំងឡាយដល់គោលដៅក្នុងវត្ថុដែលគួរធ្វើ និងជាអ្នកឈ្លាសក្នុងសេចក្ដីចម្រើន សេចក្ដីវិនាស និងឧបាយ គប្បីឲ្យប្រព្រឹត្តទៅតាមសមគួរក្នុងបញ្ញានោះៗ ព្រោះអាស្រ័យភាពជាអ្នកស្វែងរកប្រយោជន៍ ។ ម្យ៉ាងទៀត បុគ្គលដែលញុំាងសត្វទាំងឡាយ ឲ្យអត់ធន់ចំពោះការសម្លឹងដោយត្រិះរិះដល់អាការនៃសភាវធម៌ មានខន្ធជាដើម គប្បីធ្វើចិន្តាមយប្បញ្ញាឲ្យកើត ។ ម្យ៉ាងទៀត បុគ្គលដែលញុំាងលោកិយប្បញ្ញាឲ្យកើតឡើង ដោយអំណាចនៃការកំណត់លក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈរបស់ខន្ធជាដើម គប្បីធ្វើភាវនាមយប្បញ្ញាដែលជាចំណែកខាងដើមឲ្យបរិបូណ៌ ។ ពិតហើយ នេះត្រឹមតែជានាមរូបរមែងកើតឡើង និងរលត់ទៅដោយបច្ច័យទាំងឡាយតាមសមគួរ ដោយ

ប្រការដូច្នេះ ។ ក្នុងរឿងនេះ មិនមានអ្នកណាធ្វើឯង ឬឲ្យអ្នកដទៃធ្វើ ជាការមិនទៀង ព្រោះអត្ថថា កើតហើយ ត្រឡប់ទៅជាមិនមាន ជាទុក្ខ ព្រោះអត្ថថា កើតឡើងហើយ នឹងវិនាស ជាអនត្តា ព្រោះអត្ថថា មិននៅក្នុងអំណាចរបស់ខ្លួន ដោយហេតុនោះ មហាបុរសកំណត់ដឹងធម៌ខាងក្នុង និងធម៌ខាងក្រៅដោយមិនប្លែកគ្នា លះនូវការជាប់ជំពាក់ក្នុងធម៌នោះ និងឲ្យអ្នកដទៃ លះនូវការជាប់ជំពាក់ក្នុងធម៌នោះ ដោយអំណាចនៃករុណាតែម៉្យាងប៉ុណ្ណោះ ព្រះពុទ្ធគុណគង់មិនមកដល់បាតដៃដរាបណា ញុំាងសត្វទាំងឡាយឲ្យតាំងនៅក្នុងញាណ ៣ ដោយការឈមចុះ និងដោយការអប់រំ ញុំាងឈានវិមោក្ខ-សមាធិ និងសមាបត្តិ អភិញ្ញាដែលជាលោកិយ ឲ្យដល់នូវការជំនាញ ហើយសម្រេចដល់ទីបំផុតនៃបញ្ញា ។

ក្នុងលោកិយអភិញ្ញានោះ ភាវនាបញ្ញា គឺលោកិយអភិញ្ញា ៥ មួយអន្លើដោយវត្ថុជាគ្រឿងនៃញាណ បានដល់ ឥទ្ធិវិធញ្ញាណ ទិព្វសោតធាតុញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ ទិព្វចក្ខុញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ ។ ម៉្យាងទៀត ភាវនាបញ្ញាដែលចែកជាលោកិយ និងលោកុត្តរ ដែលបុគ្គលគប្បីចម្រើន ដោយធ្វើការសន្សំញាណ ដោយការរៀន ការការសាកសួរក្នុងធម៌ដែលជាបាទ មានខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ អរិយសច្ច និងបដិច្ចសមុប្បាទជាដើមហើយ តាំងនៅក្នុងវិសុទ្ធិ ២ ដែលជាបាទ គឺសីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ ហើយធ្វើវិសុទ្ធិទាំង ៥ នេះ ជាសរីរៈឲ្យបរិបូណ៌ បានដល់ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណ-

វិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ១ បដិបទាញាណទស្សនវិសុទ្ធិ ១ ញាណទស្សនវិសុទ្ធិ ១ ។ ព្រោះវិធីឲ្យសម្រេចការនៃបញ្ញាទាំងនោះ លោកពោលហើយដោយពិស្តារ ក្នុងវិសុទ្ធិមគ្គ ដោយប្រការទាំងពួង មួយអន្លើដោយការចែកលក្ខណៈ ដោយន័យជាដើមថា ព្រះយោគីជាអាទិកម្មិក បំណងនឹងធ្វើការសម្តែងឫទ្ធិ មានធ្វើបុគ្គលម្នាក់ ឲ្យទៅជាច្រើននាក់ និងដោយន័យជាដើមថា ឈ្មោះថា ខន្ធ បានដល់ រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ហេតុនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ ក្នុងវិសុទ្ធិមគ្គនោះ បញ្ញាមកហើយ ដោយអំណាចនៃសាវកពោធិសត្វតែម្យ៉ាង ក្នុងទីនេះ ផ្សេងគ្នាត្រឹមតែលោកពោលដោយអំណាចនៃមហាពោធិសត្វថា ធ្វើនូវភាពជាអ្នកឈ្លាសក្នុងឧបាយ គឺករុណាជាខាងដើមចម្រើនវិបស្សនា ក្នុងបដិបទាញាណទស្សនវិសុទ្ធិប៉ុណ្ណោះ ព្រោះមិនទាន់ដល់ញាណទស្សនវិសុទ្ធិ ។ គប្បីជ្រាបលំដាប់នៃកិច្ចបដិបត្តិបញ្ញាបារមីក្នុងទីនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះព្រះមហាសត្វបំពេញបារមីដើម្បីសម្មាសម្ពោធិញ្ញាណ គប្បីជាអ្នកប្រកបសេចក្តីខ្វល់ខ្វាយសព្វកាល ដើម្បីឲ្យបារមីបរិបូណ៌ ដោយបំពេញជាប់តគ្នាទៅសព្វកាល ព្រះមហាសត្វពិចារណារាល់ៗ ថ្ងៃថា ថ្ងៃនេះអាត្មាអញសន្សំបុញ្ញសម្ភារ ឬញាណសម្ភារអ្វីហ្ន៎ ឬថា អញធ្វើប្រយោជន៍ដើម្បីអ្នកដទៃយ៉ាងណាល្អ គប្បីធ្វើឧស្សាហ៍ ដើម្បីប្រយោជន៍ដល់សត្វ ។ ព្រះយោគាវចរមានចិត្តមិនពិចារណាដល់កាយ និងជីវិត គប្បីលះបង់វត្ថុ

ដែលជាទីហួងហែងរបស់ខ្លួន ដើម្បីជួយសត្វទាំងពួង ។ ធ្វើកម្មណាមួយដោយកាយ ឬវាចា គប្បីធ្វើកម្មនោះ ដោយចិត្តបង្អោនទៅក្នុងសព្វញ្ញុតញ្ញាណប៉ុណ្ណោះ គឺគប្បីឲ្យចិត្តបង្អោនទៅដើម្បីពោធិញ្ញាណ គប្បីមានចិត្តផុតចាកកាមទាំងឡាយដែលឧឡារ និងថោកទាប ។ ព្រះមហាសត្វ គប្បីចូលទៅតាំងភាពជាអ្នកឈ្លាសក្នុងឧបាយ ហើយគប្បីបដិបត្តិក្នុងបារមីទាំងពួង ដែលគួរធ្វើ ។

គប្បីប្រារព្ធសេចក្តីព្យាយាមក្នុងប្រយោជន៍របស់សត្វនោះៗ គប្បីអត់ធ្មត់ក្នុងវត្ថុទាំងពួង មានវត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាដើម ។ មិនគប្បីពោលខុសការពិត គប្បីផ្សាយមេត្តា និងករុណាដល់សត្វទាំងពួង ដោយមិនចំពោះ ។ ទុក្ខឯណាមួយដែលកើតឡើងដល់សត្វទាំងឡាយ គប្បីគិតថាទុក្ខនោះកើតឡើងក្នុងខ្លួន ។ម្យ៉ាងទៀត គប្បីអនុមោទនាបុណ្យនៃសត្វទាំងពួង គប្បីពិចារណារឿយៗ ដល់ភាពដែលព្រះពុទ្ធជាធំ មានអានុភាពច្រើន ធ្វើនូវកម្មណាមួយដោយកាយ ឬវាចា គប្បីធ្វើកម្មទាំងអស់នោះ ឲ្យមានចិត្តទោរទន់ទៅដើម្បីពោធិញ្ញាណជាខាងដើម ដោយឧបាយនេះ ព្រះពោធិសត្វជាមហាសត្វ ប្រកបសេចក្តីខ្វល់ខ្វាយក្នុងទានជាដើម មានកម្លាំង មានសេចក្តីព្យាយាមមាំ ចូលទៅសន្សំបុញ្ញសម្ភារ និងញាណសម្ភារ ប្រមាណមិនបានរាល់ៗ ថ្ងៃ ។

ម្យ៉ាងទៀត ដើម្បីឲ្យសត្វបានបរិភោគ និងដើម្បីគ្រប់គ្រងសត្វ គប្បីលះបង់រាងកាយ និងជីវិតរបស់ខ្លួន ស្វែងរក និងគប្បីនាំវត្ថុដែលកម្ចាត់ទុក្ខមានការឃ្លាន ស្រេក រងា ក្តៅ ខ្យល់ និងកម្តៅថ្ងៃជាដើម ។ ព្រះមហាសត្វ

បានទទួលសេចក្តីសុខដែលកើតអំពីការកម្ចាត់ទុក្ខ តាមដែលពោលហើយដោយខ្លួន និងបានទទួលសេចក្តីសុខដោយខ្លួន ព្រោះភាពដែលខ្លួនត្រជាក់ល្អហើយ ព្រោះមិនមានការក្តៅក្រហាយផ្លូវកាយ និងផ្លូវចិត្ត ក្នុងសួន ក្នុងប្រាសាទ ក្នុងស្រះជាដើម និងក្នុងដងព្រៃ ដែលគួរជាទីត្រេកអរ និងបានឮមកថា ព្រះពុទ្ធ ព្រះអនុពុទ្ធ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះមហាពោធិសត្វទាំងឡាយ តាំងនៅក្នុងនេក្ខម្មបដិបត្តិ រមែងសោយសុខក្នុងឈាន និងសមាបត្តិបែបនេះ ដែលជាវិហារធម៌ នៅជាសុខក្នុងបច្ចុប្បន្ន ហើយបង្អោនសេចក្តីសុខទាំងអស់នោះ ទៅក្នុងសត្វទាំងឡាយ ដោយមិនចំពោះ នេះជាន័យរបស់បុគ្គលតាំងនៅក្នុងឋានៈដែលមិនមាំទាំ ។

ឯបុគ្គលតាំងនៅក្នុងឋានៈដែលមាំទាំ កាលបង្អោនបីតិ បស្សទ្ធិ សុខសមាធិ យថាភូតញាណដែលកើតដោយការសម្រេចគុណវិសេស តាមដែលខ្លួនសោយហើយ ចូលទៅក្នុងសត្វទាំងឡាយ រមែងបង្អោននាំសេចក្តីទុក្ខរបស់សត្វចូលមក ។ម្យ៉ាងទៀត ព្រះមហាសត្វឃើញពួកសត្វលិចចុះក្នុងសង្សារទុក្ខធំ និងក្នុងអភិសង្ខារទុក្ខ គឺកិលេសដែលជាហេតុនៃសង្សារទុក្ខនោះ ឃើញសត្វនរកសោយទុក្ខវេទនាដ៏ពន្លឹក មានការក្តៅក្រហាយ ដែលកើតអំពីការកាប់ ចាក់ ពុះ ជំ ដុត ដោយភ្លើងជាដើម ក្នុងនរកផ្សេងៗ សត្វតិរច្ឆាន សោយទុក្ខធ្ងន់ ដោយការខឹងគ្នានិងគ្នា ធ្វើឲ្យក្តៅក្រហាយ បៀតបៀនឲ្យលំបាក និងអាស្រ័យអ្នកដទៃជាដើម សត្វប្រេត មាននិជ្ឈាមតណ្ហិកប្រេតជាដើម ត្រូវសេចក្តីស្រេកឃ្លាន ខ្យល់ កម្តៅថ្ងៃជាដើម ដុតរោលក្នុងរាងកាយ

ដោយកម្រងភ្លើង ស្គាំងស្គម លើកដៃសូមអាហារ មានទឹកមាត់ដែលគេស្តោះចោលជាដើម សោយទុក្ខធំ សត្វនរក ប្រេត តិរច្ឆានដល់នូវការលំបាកធំ មានការស្វែងរកអាហារជាហេតុ ព្រោះត្រូវកម្មដែលមានកម្លាំងគ្របសង្កត់ ដោយការប្រកបហេតុ មានការកាត់ដៃជាដើម ដោយការឲ្យកើតរោគ មានការស្រែកឃ្លានជាដើម ដោយធ្វើឲ្យជាអ្នកមានពណ៌សម្បុរថោកថយ គួរខ្ពើម ជាសត្វក្រីក្រអនាថាជាដើម ព្រោះការនាំទៅរបស់អ្នកដទៃ និងព្រោះអាស្រ័យអ្នកដទៃ និងមនុស្សដែលសោយទុក្ខធ្ងន់ ដែលមិនមានសេសសល់អំពីទុក្ខក្នុងអបាយ និងកាមាវចរទេវតា ដែលត្រូវកម្តៅ មានរាគៈជាដើមដុតរោល ព្រោះមានចិត្តរាយមាយ ក្នុងការបរិភោគរបស់ជាប្រក្រតី និងរបស់ពុល មានការក្តៅក្រហាយមិនស្ងប់ ដូចគំនរភ្នក់ភ្លើងដែលធ្វើដោយឈើស្ងួត ដែលមានអណ្តាតភ្លើងសន្ធោសន្ធៅ ដោយកម្លាំងខ្យល់អាស្រ័យអ្នកដទៃកម្ចាត់នូវការមិនស្ងប់ និងរូបាវចរទេវតា អរូបាវចរទេវតាថា កាលនៅមានការប្រព្រឹត្តទៅបានយូរ ទេវតាទាំងនោះ ក៏ដូចគ្នានឹងបក្សីដែលបោះពួយទៅកាន់អាកាសឆ្ងាយ ដោយសេចក្តីព្យាយាមច្រើន និងដូចព្រួញដែលមនុស្សមានកម្លាំង បាញ់ទៅធ្លាក់ក្នុងទីឆ្ងាយ តែក្នុងទីបំផុតក៏ធ្លាក់ព្រោះមិនទៀងក្នុងទីបំផុត ទើបមិនកន្លងផុតជាតិ ជរា និងមរណៈទៅបានញុំាងសេចក្តីសង្វេគធំឲ្យប្រាកដ ហើយផ្សាយមេត្តា និងករុណាទៅកាន់សត្វទាំងឡាយដោយមិនចំពោះ បុគ្គលសន្សំពោធិសម្ភារដោយកាយ វាចា និងចិត្ត ជាលំដាប់យ៉ាងនេះ បារមី រមែងពេញបរិបូណ៌ យ៉ាងណា បុគ្គលធ្វើ

ដោយគោរព ធ្វើជាប់ត ប្រព្រឹត្តមិនធូរថយ គប្បីញុំាងឧស្សាហៈឲ្យប្រព្រឹត្តទៅ គប្បីបំពេញវីរិយបារមីឲ្យបរិបូណ៌ ដូច្នោះ ។

ម្យ៉ាងទៀត សេចក្តីព្យាយាមដែលជួយឲ្យកើតនូវការត្រេកអរ និងការខ្វល់ខ្វាយចំពោះភាពជាព្រះពុទ្ធ ដែលជាទីតាំងនៃការសន្សំគុណ ដែលប្រមាណមិនបានបរិបូណ៌ឱឡារក្រៃលែង ប្រាសចាកមន្ទិល មិនមានអ្វីប្រៀប មិនមានឧបក្កិលេស មានអានុភាពជាអចិន្តេយ្យ ដែលមនុស្សចំណែកច្រើនស្តាប់មិនបាន មិនចាំបាច់ពោលដល់បដិបត្តិឡើយ ។

ម្យ៉ាងទៀត ការកើតឡើងនៃចិត្ត ដែលមានអភិនីហារ ៣ ពុទ្ធភូមិ ៤ សង្គហវត្ថុ ៤ ការមានករុណាជារសយ៉ាងឯក ការអត់ធន់ចំពោះការសម្លឹងដែលជាបច្ច័យវិសេស ដោយការធ្វើឲ្យជាក់ច្បាស់ក្នុងពុទ្ធធម៌ ការមិនចូលទៅត្រឹមតែលាភក្នុងពុទ្ធធម៌ទាំងពួង ការសម្គាល់ក្នុងសត្វទាំងពួង ថាជាបុត្តជាទីស្រឡាញ់ ការមិនស្រេកក្នុងសង្សារទុក្ខ កិរិយាបរិច្ចាគទេយ្យធម៌ទាំងពួង ការមានចិត្តត្រេកអរដោយការបរិច្ចាគនោះ ការអធិដ្ឋានអធិសីលជាដើម ការមិនញាប់ញ័រក្នុងអធិដ្ឋាននោះ បីតិ និងបាមោជ្ជក្នុងកុសលកិរិយា ភាពដែលចិត្តបង្អោនទៅក្នុងវិវេក ការប្រកបឈានរឿយៗ ការមិនតិះដៀលធម៌ដែលមិនមានទោស សម្តែងធម៌តាមដែលបានស្តាប់មក ដោយអធ្យាស្រ័យអនុគ្រោះដល់អ្នកដទៃ ការធ្វើឲ្យសត្វទាំងឡាយតាំងនៅក្នុងបែបផែន ការមាំទាំក្នុងការចាប់ផ្តើម ភាពជាអ្នកឈ្លាស និងភាពជាអ្នកក្លាហាន មិនមានការវិនាសក្នុងការពោលប្រទូស្តចំពោះអ្នកដទៃ និងធ្វើសេចក្តីវិនាសដល់អ្នកដទៃ

តាំងមាំក្នុងសច្ចៈ ជំនាញក្នុងសមាបត្តិ មានកម្លាំងក្នុងអភិញ្ញា ដឹងលក្ខណៈ ៣ សន្សំបារមីក្នុងលោកុត្តរមគ្គ ដោយការប្រកបសេចក្តីព្យាយាមក្នុងសតិប្បដ្ឋានជាដើម ការឈានចុះកាន់លោកុត្តរធម៌ ៩ កិរិយាបដិបត្តិពោធិសម្ភារទាំងអស់ មានជាដើមយ៉ាងនេះ ដោយប្រការដូច្នេះ រមែងសម្រេចដោយអានុភាពនៃវីរិយៈ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ គួរធ្វើសេចក្តីព្យាយាមឲ្យដល់ព្រម ដោយវិធីដែលសេចក្តីព្យាយាមនោះ នឹងនាំផលវិសេសឧត្តមមកឲ្យមិនដូរថយ ផ្តើមតាំងអំពីអភិនីហារ ( ការតាំងសេចក្តីប្រាថ្នា ) រហូតដល់សម្រេចមហាពោធិញ្ញាណ ។

កាលសេចក្តីព្យាយាមតាមដែលពោលហើយបរិបូណ៌ ពោធិសម្ភារទាំងអស់ មានខន្តី សច្ចៈ អធិដ្ឋានជាដើម និងទាន សីលជាដើម ក៏ឈ្មោះថា បរិបូណ៌ ព្រោះប្រព្រឹត្តទៅទាក់ទងនឹងសេចក្តីព្យាយាមនោះ ហេតុនោះគប្បីជ្រាបបដិបទាក្នុងខន្តិបារមីជាដើម ដោយន័យនោះឯង ។

ការធ្វើសេចក្តីអនុគ្រោះ ដោយបរិច្ចាគគ្រឿងឧបភោគបរិភោគ និងសេចក្តីសុខដល់សត្វទាំងឡាយ ដោយចំណែកច្រើន ឈ្មោះថា បដិបត្តិដោយទានហេតុទាំងឡាយ មានការរក្សាមិនផ្តាច់ជីវិត សម្បត្តិ ភរិយា និងពោលពាក្យគួរជាទីស្រឡាញ់ ពាក្យជាប្រយោជន៍ និងការមិនបៀតបៀនសត្វទាំងឡាយទាំងនោះ ឈ្មោះថា បដិបត្តិដោយសីល ។ ការប្រព្រឹត្តប្រយោជន៍ច្រើនយ៉ាងដោយទទួលអាមិស និងឲ្យធម្មទានជាដើមដល់សត្វទាំងនោះ ឈ្មោះថា បដិបត្តិដោយនេក្ខម្មៈ ភាពជាអ្នកឈ្លាសក្នុងឧបាយ ធ្វើប្រយោជន៍ដល់សត្វ

ទាំងឡាយ ឈ្មោះថា បដិបត្តិដោយបញ្ញា មានឧស្សាហៈ ផ្តើមមិនរួញរាក្នុងការនោះ ឈ្មោះថា បដិបត្តិដោយវីរិយៈ ។ ការអត់ធន់ចំពោះកុហសរបស់សត្វនោះៗ ឈ្មោះថា បដិបត្តិដោយខន្តិ ការមិនបោកបញ្ឆោត ធ្វើឧបការៈសមាទាន និងមិនពោលខុសចាកសេចក្តីពិតជាដើមដល់សត្វទាំងនោះ ឈ្មោះថា បដិបត្តិដោយសច្ចៈ សូម្បីធ្លាក់ក្នុងសេចក្តីវិនាស ក៏មិនបានញាប់ញ័រក្នុងការធ្វើឧបការៈ ឈ្មោះថា បដិបត្តិដោយអធិដ្ឋាន ការគិតដល់តែប្រយោជន៍និងសេចក្តីសុខនៃសត្វទាំងឡាយនោះ ឈ្មោះថា បដិបត្តិដោយមេត្តា ។ ការមិនខុសប្រក្រតី ក្នុងសត្វទាំងនោះ ទាំងដែលធ្វើឧបការៈ ឬសេចក្តីវិនាស ឈ្មោះថា បដិបត្តិដោយឧបេក្ខា ។ ព្រះមហាពោធិសត្វ អនុគ្រោះសព្វសត្វទាំងឡាយ មិនមានប្រមាណដូចពោលមកនេះហើយ ជាអ្នកសន្សំបុញ្ញសម្ភារនិងញាណសម្ភារមិនមានប្រមាណ មិនទូទៅដល់បុថុជ្ជន គប្បីជ្រាបថា ជាកិច្ចបដិបត្តិក្នុងបារមីទាំងនេះ ។ គប្បីញ៉ាំងបច្ច័យនៃបារមីទាំងនោះ ដែលពោលហើយឲ្យដល់ព្រម ដោយគោរពចុះ ។

បញ្ហាថា អ្វីជាការចែក បារមីមាន ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ។ ក្នុងសេចក្តីនេះ អាចារ្យពួកខ្លះពោលថា ធម៌ស ដែលលាយដោយធម៌ខ្មៅរបស់ព្រះពោធិសត្វ ដែលធ្វើអភិនីហារក្នុងបារមី ( តាំងសេចក្តីប្រាថ្នា ) ហើយជាអ្នកប្រកបដោយអធ្យាស្រ័យបង្អោនទៅក្នុងការធ្វើប្រយោជន៍ដើម្បីអ្នកដទៃ ចាត់ជាបារមីដូចគ្នា ធម៌ស មិនលាយដោយធម៌ខ្មៅ ចាត់ជាឧបបារមី ធម៌មិនខ្មៅ មិន-ស ចាត់ជាបរមត្ថបារមី ។ ម្យ៉ាងទៀត

បារមីដែលបំពេញមក ក្នុងកាលផ្តើមជាបារមី ដែលបំពេញក្នុងភូមិរបស់ព្រះពោធិសត្វ ឧបបារមី ដែលបំពេញពេញបរិបូណ៌ ដោយអាការទាំងពួង ក្នុងពុទ្ធភូមិ បរមត្ថបារមី ។ ម្យ៉ាងទៀត ក្នុងភូមិរបស់ព្រះពោធិសត្វ ចាត់ជាបារមី ព្រោះធ្វើប្រយោជន៍ដើម្បីអ្នកដទៃ ចាត់ជាឧបបារមី ព្រោះធ្វើប្រយោជន៍ដើម្បីខ្លួន ក្នុងពុទ្ធភូមិ ចាត់ជាបរមត្ថបារមី ព្រោះបំពេញប្រយោជន៍ទាំងពីរដោយការសម្រេចពលធម៌ និងវេសារជ្ជធម៌ ។

អាចារ្យពួកមួយពោលថា ការចែកបារមីទាំងនោះទៅតាមការតាំងសេចក្តីប្រាថ្នាក្នុងខាងដើម ការផ្តើមបំពេញក្នុងកណ្តាល និងការសម្រេចក្នុងទីបំផុត ។ អាចារ្យពួកដទៃ ចែកបារមីទាំងនោះ ចេញទៅតាមការសន្សំបុណ្យរបស់អ្នកស្ងប់ម្ងាប់ទោសៈ តាំងនៅក្នុងករុណាប្រក្រតីរបស់បុគ្គលសម្រេចភវសុខ របស់បុគ្គលដែលសម្រេចវិមុត្តិសុខ និងបរមសុខ ។ អាចារ្យពួកខ្លះចែកបារមីតាមដែលពោលហើយ ក្នុងពេលកើតរបស់ព្រះពោធិសត្វ គឺបារមី ឧបបារមី បរមត្ថបារមី នៃលោកអ្នកដែលមានការខ្មាស មានសតិ មានការរាប់អាន ជាទីពឹងរបស់លោកអ្នកដែលមានលោកុត្តរធម៌ជាធំ របស់អ្នកធ្ងន់នៅក្នុងសីល សមាធិ បញ្ញា ។ របស់អនុពុទ្ធដែលត្រូវលើកឲ្យធ្ងន់ របស់ព្រះបច្ចេកពុទ្ធ ដែលធ្ងន់ និងព្រះសម្មាសម្ពុទ្ធដែលធ្ងន់ និងលើកអ្នកដទៃឲ្យធ្ងន់ ។ អាចារ្យពួកដទៃពោលថា ការសន្សំបារមី ប្រព្រឹត្តទៅហើយ តាំងពីការតាំងសេចក្តីប្រាថ្នាផ្លូវចិត្ត រហូតដល់ការប្រាថ្នាផ្លូវវាចា ឈ្មោះថា បារមី ការសន្សំបារមី ប្រព្រឹត្តទៅហើយ តាំងអំពីការប្រាថ្នាផ្លូវវាចា រហូតដល់ការប្រាថ្នាផ្លូវ

កាយ ជាឧបបារមី ការសន្សំបារមី តាំងអំពីការប្រាថ្នាផ្លូវកាយទៅ ជាបរមត្ថ-បារមី ។ តែអាចារ្យពួកដទៃពោលថា ការសន្សំបារមី ប្រព្រឹត្តទៅហើយ ដោយអំណាចការអនុមោទនាបុណ្យនៃអ្នកដទៃជាបារមី ការសន្សំបារមី ដែលប្រព្រឹត្តទៅហើយ ដោយអំណាចការឲ្យអ្នកដទៃធ្វើជាឧបបារមី ការសន្សំបារមី ប្រព្រឹត្តទៅហើយ ដោយការធ្វើឯង ជាបរមត្ថបារមី ។

ម្យ៉ាងទៀត អាចារ្យពួកមួយពោលថា បុញ្ញសម្ភារ ញាណសម្ភារដែលនាំកវសុខមកឲ្យជាបារមី ការនាំនិព្វានសុខមកឲ្យដល់ខ្លួន ជាឧបបារមី ការនាំសុខទាំង ២ យ៉ាងនោះមកឲ្យដល់បុគ្គលដទៃ ជាបរមត្ថបារមី ។ ម្យ៉ាងទៀត កិរិយាបរិច្ចាគបុត្តភរិយា និងគ្រឿងឧបករណ៍ មានទ្រព្យជាដើម ជាទានបារមី កិរិយាបរិច្ចាគអវយវៈ ជាទានឧបបារមី កិរិយាបរិច្ចាគជីវិតរបស់ខ្លួន ជាទានបរមត្ថបារមី ។ ម្យ៉ាងទៀត សីលបារមី ៣ យ៉ាង ដោយការមិនឈានកន្លងហេតុទាំង ៣ យ៉ាង មានបុត្ត និងភរិយាជាដើម នេក្ខម្មបារមី ៣ យ៉ាង ដោយការកាត់អាល័យក្នុងវត្ថុ ៣ យ៉ាងនោះ ហើយចេញបួស បញ្ញា-បារមី ៣ យ៉ាង ដោយការប្រមូលតណ្ហាក្នុងគ្រឿងឧបភោគបរិភោគ អវយវៈ ជីវិត ហើយធ្វើការកាត់នូវប្រយោជន៍ មិនមែនប្រយោជន៍របស់សត្វទាំងឡាយ វិរិយបារមី ៣ យ៉ាង ដោយការព្យាយាមបរិច្ចាគប្រភេទតាមដែលពោលហើយ ខន្តិបារមី ៣ យ៉ាង ដោយការអត់ធន់ចំពោះបុគ្គលដែលធ្វើអន្តរាយដល់គ្រឿងឧបភោគបរិភោគ អវយវៈ និងជីវិត សច្ចបារមី ៣ យ៉ាង ដោយការមិនលះសច្ចៈ ព្រោះហេតុតែគ្រឿងឧបភោគបរិភោគ អវយវៈ និង

ជីវិត  អធិដ្ឋានបារមី ៣ យ៉ាង ដោយការអធិដ្ឋានមិនញាប់ញ័រ សូម្បីពេលគ្រឿងឧបភោគបរិភោគជាដើមវិនាសទៅ ដោយឃើញថា ទានបារមីជាដើមរមែងបរិសុទ្ធ ដោយអំណាចអធិដ្ឋានមិនកម្រើក ។ មេត្តាបារមី ៣ យ៉ាង ដោយមិនលះមេត្តាក្នុងសត្វទាំងឡាយ  សូម្បីបុគ្គលចូលទៅបំផ្លាញ់គ្រឿងឧបភោគបរិភោគជាដើម ឧបេក្ខាបារមី ៣ យ៉ាង ដោយបានទូវភាពដែលខ្វនជាកណ្តាលក្នុងសត្វ និងសង្ខារទាំងឡាយ ទាំងដែលមានឧបការៈ និងធ្វើសេចក្តីវិនាសចំពោះវត្ថុ ៣ យ៉ាង តាមដែលពោលហើយ គប្បីជ្រាបការចែកបារមីទាំងនោះ ដោយន័យជាដើមយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

ក្នុងបញ្ហាថា អ្វីជាការសង្គ្រោះ គប្បីជ្រាបបារមី ៦ យ៉ាង ដោយសភាវៈគឺទានបារមី សីលបារមី ខន្តិបារមី វីរិយបារមី ឈានបារមី និងបញ្ញាបារមីដូចបារមី ១០ ចែកចេញជា ៣០ គឺទានបារមីជាដើម ។ ពិតហើយ ក្នុងបារមីទាំងនោះ នេក្ខម្មបារមី សង្គ្រោះក្នុងសីលបារមី ព្រោះសីលបារមីក្នុងបព្វជ្ជាម្យ៉ាងទៀត ( នេក្ខម្មបារមី ) សង្គ្រោះចូលក្នុងឈានបារមី ព្រោះមានការស្ងាត់ចាកនីវរណៈ សង្គ្រោះចូលក្នុងបារមីទាំង ៦ ព្រោះភាពជាកុសលធម៌ ។ សច្ចបារមី  ជាចំណែករបស់សីលបារមី  ព្រោះជាចំណែកនៃវចីវិរតិសច្ចៈ និងសង្គ្រោះចូលក្នុងបញ្ញាបារមី  ព្រោះជាចំណែកនៃញាណសច្ចៈ មេត្តា-បារមី សង្គ្រោះចូលក្នុងឈានបារមីនោះឯង ឧបេក្ខាបារមី ក៏សង្គ្រោះចូលក្នុងឈានបារមី និងបញ្ញាបារមី ។ លោកសង្គ្រោះអធិដ្ឋានបារមី ចូលក្នុងបារមីទាំងអស់ ដោយប្រការដូច្នេះ ។

កាលសម្ព័ន្ធគុណធម៌ គឺបារមី ៦ យ៉ាង មានទានជាដើម ចូលជាមួយគ្នា និងបាន ១៥ គូ ផ្តើមអំពីគូទី ១ ធ្វើឲ្យសម្រេចគូគុណធម៌ ១៥ គូ ផ្តើមអំពីគូទី ១ តើដូចម្តេច ។

គូទាន និងសីល ឲ្យសម្រេចគុណធម៌ គូការធ្វើវត្ថុដែលជាប្រយោជន៍ដើម្បីអ្នកដទៃ និងការមិនធ្វើវត្ថុដែលមិនជាប្រយោជន៍ដើម្បីអ្នកដទៃ ១ គូទាន និងខន្តី គូអលោភៈ និងអទោសៈ ១ គូទាន និងវិរិយៈ គូចាគៈ និងសុតៈ ១ គូទាន និងឈាន គូការលះកាម និងការលះទោសៈ ១ គូទាន និងបញ្ញា គូយានដែលជាអរិយៈ និងទឹមដែលជាអរិយៈ ១ ក្រុមពីរ គឺសីល និងខន្តី ឲ្យសម្រេចគុណធម៌ ២ យ៉ាង គឺបយោគសុទ្ធិ និងអាសយសុទ្ធិ ១ សីល និងវិរិយៈ ការនាពីរ ១ សីល និងឈាន កាលលះនូវភាពជាអ្នកទ្រុស្តសីល និងការលះកិលេសជាគ្រឿងរួបរឹត ១ សីល និងបញ្ញា ទានពីរ ១ គូខន្តី និងវិរិយៈ ឲ្យសម្រេចគុណធម៌ ២ យ៉ាង គឺការអត់ធន់ និងការមានតេជះ ១ គូខន្តី និងឈាន គូការលះវិរោធៈ ( ការខឹងក្រោធ ) និងលះអនុរោធៈ ( សេចក្តីត្រេកអរ ) ១ គូខន្តី និងបញ្ញា គូខន្តី និងដែលជាសុញ្ញតា និងបដិវេធដែលជាសុញ្ញតា ១ គឺការអនុលោមតាមដោយគូ គឺខន្តី និងឈាន ។ ពួក ២ គឺវិរិយៈ និងឈាន ធ្វើឲ្យសម្រេចពួក ២ គឺបគ្គហៈ ( ការផ្គងសេចក្តីព្យាយាម ) និងការអវិក្ខេបៈ ( ការមិនរាយមាយ ) ១ ពួក ២ គឺវិរិយៈ និងបញ្ញា ឲ្យសម្រេចពួកសរណៈពីរ ១ ពួក ២ គឺឈាន និង

បញ្ញា ឲ្យសម្រេចពួកឃានពីរ ១ ( រួមជា ១៥ ដូច្នេះ ) ។

ពួក ៣ គឺទាន សីល ខន្តី ធ្វើឲ្យសម្រេចការលះលោភៈ លះទោសៈ លះមោហៈ ។

ពួក ៣ គឺទាន សីល វីរិយៈ ធ្វើឲ្យសម្រេចការឲ្យនូវវត្ថុដែលជាសារៈ ៣ យ៉ាង គឺឲ្យភោគៈ ឲ្យជីវិត ឲ្យរាងកាយ ។

ពួក ៣ គឺទាន សីល ឈាន ធ្វើឲ្យសម្រេចបុញ្ញកិរិយាវត្ថុ ៣ ។

ពួក ៣ ទាន សីល បញ្ញា ធ្វើឲ្យសម្រេចទាន ៣ យ៉ាង គឺ អមិសទាន អភយទាន ធម្មទាន ។

គប្បីប្រកបពួក ៣ និងពួក ៤ ជាដើម តាមដែលមាន ជាមួយពួក ៣ និងពួក ៤ ជាដើម ដទៃៗ ទៀត យ៉ាងនេះ ។

ម្យ៉ាងទៀត គប្បីជ្រាបការសង្គ្រោះបារមី ៦ យ៉ាង ចូលជាមួយអធិដ្ឋានធម៌ ៤ នៃបារមីទាំងនេះ ដោយប្រការដូច្នេះ ។ ពិតហើយ ដោយរួមបារមីទាំងអស់ចូលជាមួយគ្នា អធិដ្ឋានធម៌ ៤ យ៉ាង គឺសច្ចាធិដ្ឋាន ចាគាធិដ្ឋាន ឧបសមាធិដ្ឋាន បញ្ញាធិដ្ឋាន ក្នុងអធិដ្ឋានធម៌ទាំងនោះ ឈ្មោះថា អធិដ្ឋាន ព្រោះជាហេតុតាំងមាំ ឬជាទីតាំងមាំ ឬត្រឹមតែតាំងមាំ ។ ឈ្មោះថា សច្ចាធិដ្ឋាន ព្រោះជាសច្ចៈផង ជាអធិដ្ឋានផង ឬព្រោះជាទីតាំងនៃសច្ចៈ ឬព្រោះមានសច្ចៈជាទីតាំង ។ ក្នុងអធិដ្ឋានធម៌ដ៏សេស ក៏ដូចគ្នាយ៉ាងនោះ ។ ក្នុងអធិដ្ឋានធម៌នោះដោយមិនផ្សេងគ្នា ឈ្មោះថា សច្ចាធិដ្ឋាន ព្រោះកាន់យកថាជាបារមីទាំងពួង តាមសមគួរដល់បដិញ្ញារបស់ព្រះមហាសត្វ ដែលអនុគ្រោះ

សព្វសត្វ ដែលសន្សំបុញ្ញាភិនីហារ ក្នុងលោកុត្តរគុណ ។ ឈ្មោះថា ចាគាធិដ្ឋាន ព្រោះលះបង់វត្ថុជាបដិបក្ខចំពោះសច្ចៈទាំងនោះ ។ ឈ្មោះថា ឧបសមាធិដ្ឋាន ព្រោះស្ងប់ចាកវត្ថុមិនជាគុណនៃបារមីទាំងពួង ។ ឈ្មោះថា បញ្ញាធិដ្ឋាន ព្រោះជាអ្នកឈ្លាសក្នុងឧបាយ ដែលជាប្រយោជន៍ដល់អ្នកដទៃ ដោយអធិដ្ឋានធម៌ទាំងនោះ ។

តែដោយផ្សេងគ្នា ទានជាបទដ្ឋាននៃអធិដ្ឋានធម៌ ៤ នៃកុសលធម៌ទាំងឡាយ ព្រោះឲ្យដោយមិនឲ្យខុសចាកប្តេជ្ញាថា គប្បីឲ្យដោយមិនឲ្យយាចកខុសបំណង ព្រោះអនុមោទនាទានមិនវិនាស ព្រោះលះបង់នូវវត្ថុជាបដិបក្ខចំពោះមច្ឆរិយៈជាដើម ព្រោះរម្ងាប់នូវការខ្វាច ដោយលោភៈ ទោសៈ និងមោហៈក្នុងទេយ្យធម៌ ក្នុងបដិគ្គាហក ក្នុងទាន និងការអស់ទៅនៃទេយ្យធម៌ ព្រោះឲ្យតាមសមគួរតាមកាល និងតាមវិធី និងព្រោះបញ្ញាក្រៃលែង ។ម្យ៉ាងទៀត សីលជាបទដ្ឋាននៃអធិដ្ឋានធម៌ ៤ ព្រោះមិនកន្លងសំវរសមាទាន ព្រោះលះនូវភាពទ្រុស្តសីល ព្រោះស្ងប់ចាកទុច្ចរិត និងព្រោះបញ្ញាក្រៃលែង ។ខន្តីជាបទដ្ឋាននៃអធិដ្ឋានធម៌ ៤ ព្រោះអត់ធន់បានតាមប្តេជ្ញា ព្រោះលះបង់នូវការប្រកាន់ទោសរបស់អ្នកដទៃ ព្រោះស្ងប់នូវសេចក្តីក្រោធ និងព្រោះវង្វេង និងព្រោះមានបញ្ញាក្រៃលែង ។ វីរិយៈជាបទដ្ឋាននៃអធិដ្ឋានធម៌ ៤ ព្រោះធ្វើដើម្បីប្រយោជន៍អ្នកដទៃ តាមសមគួរដល់ប្តេជ្ញា ព្រោះលះបង់នូវភាពល្អ[១] ព្រោះស្ងប់ចាកអកុសល និងព្រោះមានបញ្ញាក្រៃលែង ។ ឈានជាបទដ្ឋាន

---

១- បាលីថា វិសទបរិច្ចាគតោ ។

នៃអធិដ្ឋានធម៌ ៤ ព្រោះគិតដល់ប្រយោជន៍នៃលោក តាមសមគួរដល់ប្បដ្ឋា ព្រោះលះនូវនីវរណៈ ព្រោះស្ងប់ចិត្ត និងព្រោះមានបញ្ញាក្រៃលែង ។ បញ្ញា ជាបទដ្ឋាននៃអធិដ្ឋានធម៌ ៤ ព្រោះឈ្លាសក្នុងឧបាយ ធ្វើប្រយោជន៍ដើម្បីអ្នកដទៃតាមប្បដ្ឋា ព្រោះលះបង់នូវការធ្វើដែលមិនជាឧបាយ ព្រោះស្ងប់នូវការក្តៅក្រហាយដែលកើតអំពីមោហៈ និងព្រោះបានភាពជាសព្វញ្ញូ ។

ក្នុងអធិដ្ឋានធម៌ទាំងនោះ សច្ចាធិដ្ឋាន ដោយការចាត់តាមប្បដ្ឋា ដើម្បីវត្ថុគួរដឹងជាចាគាធិដ្ឋាន ដោយការលះវត្ថុកាម និងកិលេសកាម ជាឧបសមាធិដ្ឋាន ដោយការស្ងប់ទុក្ខដែលកើតអំពីទោសៈ ជាបញ្ញាធិដ្ឋាន ដោយការត្រាស់ដឹងតាម និងការចាក់ធ្លុះ ។

សច្ចាធិដ្ឋាន មានសត្រូវ គឺទោសៈ ៣ យ៉ាង កំណត់ដោយសច្ចៈ ៣ យ៉ាង ចាគាធិដ្ឋាន មានសត្រូវ គឺទោសៈ ៣ យ៉ាង កំណត់ដោយចាគៈ ៣ យ៉ាង ។ ឧបសមាធិដ្ឋាន មានសត្រូវ គឺទោសៈ ៣ យ៉ាង កំណត់ដោយឧបសមៈ ៣ យ៉ាង ។ បញ្ញាធិដ្ឋាន មានសត្រូវ គឺទោសៈ ៣ យ៉ាង កំណត់ដោយញាណ ៣ យ៉ាង ។

ចាគាធិដ្ឋាន ឧបសមាធិដ្ឋាន និងបញ្ញាធិដ្ឋាន កំណត់ដោយសច្ចាធិដ្ឋាន ព្រោះនិយាយមិនខុសតាមសេចក្តីពិត និងព្រោះចាត់តាមប្បដ្ឋា ។ សច្ចាធិដ្ឋាន ឧបសមាធិដ្ឋាន និងបញ្ញាធិដ្ឋាន កំណត់ដោយចាគាធិដ្ឋាន ព្រោះលះបង់នូវវត្ថុដែលជាបដិបក្ខ និងព្រោះផលនៃការលះទាំងពួង សច្ចាធិដ្ឋាន ចាគាធិដ្ឋាន និងបញ្ញាធិដ្ឋាន កំណត់ដោយឧបសមាធិដ្ឋាន ព្រោះស្ងប់ចាកការក្តៅក្រហាយ

គឺកិលេស ព្រោះស្ងប់ចាកកាម និងព្រោះស្ងប់ចាកការក្តៅក្រហាយ គឺកាម សច្ចាធិដ្ឋាន ចាគាធិដ្ឋាន និងឧបសមាធិដ្ឋាន កំណត់ដោយបញ្ញាធិដ្ឋាន ព្រោះមានញាណដល់មុន និងព្រោះវិលទៅតាមញាណ ។ បារមីទាំងអស់ ប្រកាសសច្ចៈ ធ្វើចាគៈឲ្យប្រាកដ កពូនទូវឧបសមៈ មានបញ្ញាបរិសុទ្ធយ៉ាងនេះដោយប្រការដូច្នេះ ។ ពិតហើយ សច្ចៈជាហេតុកើតបារមីទាំងនោះ ចាគៈជាហេតុកំណត់បារមី ឧបសមៈ ជាហេតុចម្រើនដោយជុំវិញ បញ្ញា ជាហេតុនៃសេចក្តីបរិសុទ្ធ ។ មួយវិញទៀត សច្ចាធិដ្ឋាន មានក្នុងចំណែកខាងដើម ព្រោះសច្ចៈប្បដិញ្ញា ចាគាធិដ្ឋាន មានក្នុងចំណែកកណ្តាល ព្រោះលះបង់ខ្លួន ដើម្បីប្រយោជន៍ដល់អ្នកដទៃ របស់បុគ្គលដែលធ្វើនូវតាំងចិត្តពិត ឧបសមាធិដ្ឋាន មានក្នុងទីបំផុត ព្រោះការស្ងប់ទាំងពួងជាទីបំផុត បញ្ញាធិដ្ឋាន មានក្នុងខាងដើម កណ្តាល និងខាងចុង ព្រោះកាលសច្ចៈ ចាគៈ ឧបសមៈមាន បញ្ញាក៏មាន ព្រោះកាលសច្ចៈ ចាគៈ ឧបសមៈមិនមាន បញ្ញាក៏មិនមាន និងព្រោះមានតាមប្បដិញ្ញា ។

ក្នុងអធិដ្ឋានធម៌នោះ មហាបុរសទាំងឡាយជាគ្រហស្ថ រមែងអនុគ្រោះសត្វដទៃដោយអាមិសទាន ដោយធ្វើប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃរឿយៗ ដោយធ្វើភាពជាបុគ្គលគួរគោរព គួរស្រឡាញ់ និងដោយសច្ចាធិដ្ឋាន និងចាគាធិដ្ឋាន ។ មួយវិញទៀត បព្វជិត រមែងអនុគ្រោះបុគ្គលដទៃដោយធម្មទាន ដោយធ្វើប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ដោយធ្វើនូវភាពជាបុគ្គលគួរគោរព គួរស្រឡាញ់ និងដោយឧបសមាធិដ្ឋាន និងបញ្ញាធិដ្ឋាន ។

ក្នុងភពចុងក្រោយនោះ ព្រះពោធិសត្វបំពេញអធិដ្ឋានធម៌ ៤ ឲ្យបរិបូណ៌ អាចារ្យពួកមួយពោលថា សេចក្តីពិត ព្រះពោធិសត្វមានអធិដ្ឋានធម៌ ៤ បរិបូណ៌ហើយ កើតក្នុងភពចុងក្រោយ ។ ក្នុងកំណើតចុងក្រោយនោះ ព្រះពោធិសត្វ មានសតិសម្បជញ្ញៈ ផ្តើមដោយបញ្ញាធិដ្ឋានក្នុងការឈមចុះកាន់គភ៌ ការតាំងនៅ និងការប្រសូតិ ដើម្បីញុំាងសច្ចាធិដ្ឋានឲ្យបរិបូណ៌ លុះប្រសូតភ្លាម ទ្រង់បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ឈានព្រះបាទ ៧ ជំហាន ទ្រង់ទតទិសទាំងពួង មានព្រះវាចាមាំទាំក្នុងសច្ចៈ ទ្រង់បន្លឺសីហនាទ ៣ ដងថា **អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស** យើងជាកំពូលនៃលោក យើងជាច្បងក្នុងលោក យើងប្រសើរជាងគេក្នុងលោក ។

ការស្ងប់របស់បុគ្គលស្រវឹង ក្នុងភាពជាកំលោះ ក្នុងការមិនមានរោគក្នុងជីវិត និងសម្បត្តិទាំងឡាយរបស់ព្រះពោធិសត្វ ដែលឈ្លាសក្នុងការចន្អុលបង្ហាញធម៌ ៤ ប្រការ ជាអ្នកឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិត មានឡើងដោយផ្តើមអំពីឧបសមាធិដ្ឋាន ។ ការលះបង់ មិនគិតដល់វង្សញាតិដ៏ធំ និងចក្កពត្តិរាជសម្បត្តិ ដែលដល់កណ្តាប់ដៃ ដោយផ្តើមអំពីចាគាធិដ្ឋាន ។

ក្នុងឋានៈទី ២ អាចារ្យពួកខ្លះពោលថា អធិដ្ឋានធម៌ ៤ បរិបូណ៌ហើយក្នុងអភិសម្ពោធិញាណ តែក្នុងអធិដ្ឋាននោះ គប្បីជ្រាបថា មានការត្រាស់ដឹងអរិយសច្ច ៤ ដោយផ្តើមអំពីសច្ចាធិដ្ឋានតាមបដិជ្ញា បន្ទាប់អំពីនោះ ទើប

សច្ចាធិដ្ឋានបរិបូណ៌ មានការលះបង់កិលេស និងឧបក្កិលេសទាំងពួង ដោយផ្តើមអំពីចាគាធិដ្ឋាន ព្រោះបន្ទាប់អំពីនោះ ទើបចាគាធិដ្ឋានបរិបូណ៌ ។ មានការសម្រេចដល់ភាពស្ងប់ក្រៃលែង ដោយផ្តើមអំពីឧបសមាធិដ្ឋាន បន្ទាប់អំពីនោះ ទើបឧបសមាធិដ្ឋានបរិបូណ៌ ។ ការបានអនាវរណញ្ញាណ ដោយផ្តើមអំពីបញ្ញាធិដ្ឋាន បន្ទាប់អំពីនោះ ទើបបញ្ញាធិដ្ឋានបរិបូណ៌ ។ ពាក្យនោះមិនទាន់បរិបូណ៌ប៉ុន្មានឡើយ ព្រោះអភិសម្ពោធិញ្ញាណជាធម៌ដ៏ជ្រាលជ្រៅ ។

ក្នុងឋានៈទី ៣ អាចារ្យពួកដទៃពោលថា អធិដ្ឋានធម៌ ៤ បរិបូណ៌កាលទ្រង់សម្តែងធម្មចក្រ ។ ក្នុងឋានៈនោះ គប្បីជ្រាបថា សច្ចាធិដ្ឋានបរិបូណ៌ដល់អ្នកផ្តើមអំពីការសច្ចាធិដ្ឋាន ដោយការសម្តែងអរិយសច្ច ដោយអាការ ១២ ។ ចាគាធិដ្ឋាន បរិបូណ៌ដល់អ្នកផ្តើមអំពីចាគាធិដ្ឋាន ដោយការធ្វើការបូជាចំពោះព្រះសទ្ធម្ម ។ ឧបសមាធិដ្ឋាន បរិបូណ៌ដោយអ្នកផ្តើមអំពីឧបសមាធិដ្ឋាន ដោយការស្ងប់ឯង និងធ្វើកិលេសរបស់បុគ្គលដទៃឲ្យស្ងប់ ។ បញ្ញាធិដ្ឋាន បរិបូណ៌ដល់អ្នកផ្តើមអំពីបញ្ញាធិដ្ឋាន ដោយការកំណត់អធ្យាស្រ័យជាដើមរបស់វេនេយ្យសត្វ ។ ពាក្យពោលនោះ ក៏មិនទាន់បរិបូណ៌ប៉ុន្មានព្រោះពុទ្ធកិច្ចមិនទាន់ចប់ ។ អាចារ្យមួយពួកទៀតពោលថា អធិដ្ឋានធម៌ ៤ បរិបូណ៌ក្នុងការបរិនិព្វាន ក្នុងឋានៈនោះ គប្បីជ្រាបថា សច្ចាធិដ្ឋានបរិបូរណ៌ដោយការសម្បូរនៃបរមត្ថសច្ច ព្រោះបរិនិព្វានហើយ ។ ចាគាធិដ្ឋាន បរិបូណ៌ដោយការលះឧបធិទាំងពួង ឧបសមាធិដ្ឋាន បរិបូណ៌ដោយការស្ងប់សង្ខារទាំងពួង បញ្ញាធិដ្ឋាន បរិបូណ៌ដោយការសម្រេចប្រយោជន៍ដោយបញ្ញា ។

ក្នុងអធិដ្ឋានធម៌ ៤ នោះ គប្បីជ្រាបថា ការបរិបូណ៌ដោយសច្ចាធិដ្ឋាន ជាការមុតស្រួចរបស់មហាបុរស ផ្តើមដោយសច្ចាធិដ្ឋានក្នុងអភិជាតិ ដែលជាខេត្តនៃមេត្តាដោយពិសេស ។ ការបរិបូណ៌ដោយបញ្ញាធិដ្ឋាន ជាការមុតស្រួចរបស់មហាបុរស ផ្តើមអំពីបញ្ញាធិដ្ឋាន ក្នុងអភិសម្ពោធិញ្ញាណ ដែលជាខេត្តនៃករុណាដោយពិសេស ការបរិបូណ៌ដោយចាគាធិដ្ឋាន ជាការមុតស្រួចរបស់ព្រះមហាបុរស ផ្តើមអំពីចាគាធិដ្ឋាន កាលទ្រង់សម្តែងព្រះធម្មចក្កដែលជាខេត្តនៃមុទិតាដោយពិសេស ។ សេចក្តីបរិបូណ៌ដោយឧបសមាធិដ្ឋាន ជាការមុតស្រួចរបស់ព្រះមហាបុរស ផ្តើមអំពីឧបសមាធិដ្ឋាន ក្នុងការបរិនិព្វាន ដែលជាខេត្តនៃឧបេក្ខាដោយពិសេស ។

ក្នុងអធិដ្ឋានធម៌ ៤ នោះ សីលគប្បីជ្រាបដោយការនៅរួមគ្នារបស់ព្រះមហាបុរស ដែលផ្តើមអំពីសច្ចាធិដ្ឋាន ។ ការស្អាត គប្បីជ្រាបដោយកិច្ចរបស់ព្រះមហាបុរស ដែលផ្តើមអំពីចាគាធិដ្ឋាន ។ កម្លាំង គប្បីជ្រាបក្នុងពេលមានអន្តរាយរបស់ព្រះមហាបុរស ដែលផ្តើមអំពីឧបសមាធិដ្ឋាន ។ បញ្ញាគប្បីជ្រាបដោយការសន្ទនារបស់ព្រះមហាបុរស ដែលផ្តើមអំពីបញ្ញាធិដ្ឋាន ។ គប្បីជ្រាបសេចក្តីបរិសុទ្ធនៃសីល អាជីវៈ ចិត្ត និងទិដ្ឋិដោយអាការយ៉ាងនេះ ។ ម្យ៉ាងទៀត មហាបុរស មិនដល់នូវទោសាគតិ ព្រោះពោលខុស ដោយផ្តើមអំពីសច្ចាធិដ្ឋាន មិនដល់នូវលោភាគតិ ព្រោះមិនទាក់ទងដោយផ្តើមអំពីចាគាធិដ្ឋាន ។ មិនដល់នូវភយាគតិ ព្រោះមិនខុស ដោយផ្តើមអំពីឧបសមាធិដ្ឋាន ។ មិនដល់នូវមោហាគតិ ព្រោះត្រាស់ដឹងតាមសេចក្តីពិត ដោយផ្តើម

ពីបញ្ញាធិដ្ឋាន ។

ម្យ៉ាងទៀត គប្បីជ្រាបថា មិនប្រទូស្ត រមែងអត់ធន់ដោយអធិដ្ឋានធម៌ទី ១ មិនលោភ សេពដោយអធិដ្ឋានធម៌ទី ២ មិនខ្លាច វៀរចោយដោយអធិដ្ឋានធម៌ទី ៣ មិនវង្វេង បន្ទោបង់បានដោយអធិដ្ឋានធម៌ទី ៤ ។ ការសម្រេចនេក្ខម្មសុខ មានដោយអធិដ្ឋានធម៌ទី ១ ការបានទូវបីតិសុខ ដែលកើតអំពីវិវេក ការស្ងប់ និងសម្មាធិ មានបានដោយអធិដ្ឋានធម៌ដ៏សេស ។ ម្យ៉ាងទៀត ការបានបីតិសុខដែលកើតអំពីវិវេក បីតិសុខដែលកើតអំពីសមាធិ សុខផ្លូវកាយដែលមិនកើតអំពីបីតិ និងឧបេក្ខាសុខ ដែលកើតអំពីសតិបរិសុទ្ធ រមែងមានដោយអធិដ្ឋានធម៌ទាំងនេះតាមលំដាប់ ។ គប្បីជ្រាបការប្រមូលបារមីទាំងអស់ចូលគ្នាដោយអធិដ្ឋានធម៌ ៤ ប្រការ ដែលទាក់ទងគ្នាដោយគុណមិនតិច ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត គប្បីឃើញថា ការសមោធានបារមីទាំងអស់ចូលដោយករុណា និងបញ្ញាក៏បាន ដូចការសមោ-ធានបារមីទាំងអស់ ចូលក្នុងអធិដ្ឋានធម៌ ៤ ព្រោះពោធិសម្ភារទាំងអស់លោកសង្គ្រោះដោយករុណា និងបញ្ញា ។ គប្បីជ្រាបការសង្គ្រោះបារមីទាំងនោះយ៉ាងនេះថា គុណ មានទានជាដើម កំណត់ដោយករុណា និងបញ្ញាជាមហាពោធិសម្ភារ មានការសម្រេចភាពជាព្រះពុទ្ធជាទីបំផុត ។

បញ្ហាថា អ្វីជាឧបាយឲ្យសម្រេច ឆ្លើយថា ការសន្សំបុញ្ញាភិសម្ភារទាំងអស់ ឧទ្ទិសសម្មាសម្ពោធិញ្ញាណ ដោយមិនធ្វើឲ្យខ្វះខាត ការធ្វើដោយសេចក្តីគោរពក្នុងសម្មាសម្ពោធិញ្ញាណនោះ ដោយការអើពើ និងដោយការ

រាប់អានច្រើន ការធ្វើនូវសេចក្ដីព្យាយាមជាប់ត ដោយការព្យាយាមជាលំដាប់ទៅ និងការព្យាយាមអស់កាលយូរជាដើម មិនឈប់ក្នុងចន្លោះ ។ ប្រមាណកាលរបស់ឧបាយឲ្យសម្រេចនោះ នឹងមានច្បាស់ខាងមុខ ។ ការប្រកបអង្គ ៤ ជាឧបាយឲ្យបារមីទាំងនោះសម្រេច ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រះមហាសត្វបដិបត្តិដើម្បីត្រាស់ដឹង គួរប្រគល់ខ្លួនដល់ព្រះពុទ្ធទាំងឡាយ ដើម្បីសម្មាសម្ពោធិញ្ញាណជាបឋមនោះឯងថា ខ្ញុំសូមប្រគល់អត្តភាពនេះ ដល់ព្រះពុទ្ធទាំងឡាយ មុននឹងបានវត្ថុដែលហួងហែងនោះៗ គួរលះរបស់នោះក្នុងផ្លូវនៃទានថា វត្ថុណាមួយ ដែលជារបស់ប្រើប្រចាំជីវិតដែលកើតដល់ខ្ញុំ វត្ថុទាំងអស់នោះ កាលមានអ្នកសូម ខ្ញុំនឹងឲ្យ ខ្ញុំនឹងបរិភោគចំណែកដែលសេសសល់អំពីដែលឲ្យដល់យាចកទាំងនោះប៉ុណ្ណោះ ។

កាលមហាបុរសនោះ តាំងចិត្តដើម្បីបរិច្ចាគដោយប្រពៃយ៉ាងនេះ វត្ថុដែលហួងហែង ឬវត្ថុមិនមានវិញ្ញាណឯណាកើតឡើង គ្រឿងហួងហែងរបស់ទាន មាន ៤ យ៉ាង គឺមិនធ្លាប់ឲ្យទានក្នុងកាលមុន ១ របស់មានតិច ១ គិតថាជារបស់ល្អ ១ គិតថានឹងអស់ទៅ ១ ។ ក្នុងគ្រឿងហួងហែងនៃទានទាំងនោះ ក្នុងកាលណា កាលទេយ្យធម៌មានដល់ព្រះមហាពោធិសត្វ និងកាលយាចកប្រាកដ ចិត្តក្នុងការឲ្យ មិនស្ទុះទៅ មិនឈានទៅ ដោយហេតុនោះ គួរប្រាកដចិត្តក្នុងសេចក្ដីនោះបានថា កាលមុន អាត្មាអញមិនបានសន្សំក្នុងការឲ្យពិត ។ ដូច្នោះ ក្នុងឥឡូវនេះ ការប្រាថ្នាដែលនឹងឲ្យរបស់អាត្មាអញ ទើបមិនតាំងនៅក្នុងចិត្ត ។ ទើបព្រះមហាពោធិសត្វនោះកាត់ផ្ដាច់ មានដៃ

ស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងការចែកទាន រមែងឲ្យទានដោយគិតថា ពីពេលនេះទៅ អញនឹងមានចិត្តត្រេកអរក្នុងទានយ៉ាងក្រៃលែង វត្ថុដែលហួងហែងអញលះបង់ដល់ពួកយាចកអំពីដំបូងហើយ មិនមែនឬ ណ្ហើយចុះ អញនឹងឲ្យទានតាំងអំពីថ្ងៃនេះទៅ ។ គ្រឿងហួងហែងទានទី ១ របស់ព្រះមហាសត្វ ត្រូវកម្ចាត់ទៅ កាត់ផ្តាច់ទៅ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមហាសត្វ កាលទេយ្យធម៌មានតិច និងខ្វះខាត រមែងសិក្សាថា កាលមុន ព្រោះអញមិនគាប់ចិត្តក្នុងទាន ឥឡូវនេះ ទើបអញខ្វះខាតបច្ច័យយ៉ាងនេះ ព្រោះហេតុនោះ ឥឡូវនេះ អញនឹងបៀតបៀនខ្លួនឯងដោយទេយ្យធម៌តាមដែលបានបន្តិចបន្តួចក៏ដោយ អាក្រក់ក៏ដោយ អញត្រូវឲ្យទានឲ្យខាងតែបាន អញនឹងសម្រេចទានបារមីតទៅ រហូតដល់ទីបំផុត ។ ព្រះមហាសត្វនោះក៏កាត់ផ្តាច់ មានដៃស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងការចែកទាន ឲ្យទានតាមមានតាមបាន ។ គ្រឿងហួងហែងទានទី ២ របស់ព្រះមហាសត្វ ឈ្មោះថា ត្រូវកម្ចាត់ទៅ កាត់ផ្តាច់ទៅដោយអាការយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះមហាសត្វ កាលចិត្តមិនប្រាថ្នានឹងឲ្យកើតឡើង ព្រោះស្តាយទេយ្យធម៌ រមែងសិក្សាថា សប្បុរស អ្នកប្រាថ្នាសម្មាសម្ពោធិញ្ញាណដ៏ឧត្តម សម្មាសម្ពោធិញ្ញាណប្រសើរជាងវត្ថុទាំងពួង មិនមែនឬ ព្រោះហេតុនោះ អ្នកគួរឲ្យទេយ្យធម៌ ដែលគួរពេញចិត្តក្រៃលែង ដើម្បីសម្មាសម្ពោ-

ធិញ្ញាណប៉ុណ្ណោះ ។ ទើបព្រះមហាសត្វនោះកាត់ផ្តាច់ មានដៃស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងការឲ្យទាន រមែងឲ្យទេយ្យធម៌ដែលគួរពេញចិត្តក្រៃលែង ។ គ្រឿងហួងហែងទានទី ៣ របស់ព្រះមហាសត្វឈ្មោះថា ត្រូវកម្ចាត់ទៅ កាត់ផ្តាច់ទៅ ដោយអាការយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះមហាសត្វ កាលឲ្យទាន ឃើញការអស់របស់ទេយ្យធម៌ក្នុងកាលណា រមែងសិក្សាថា សភាពរបស់ភោគៈទាំងឡាយ យ៉ាងនេះ គឺមានការអស់ទៅ សូន្យទៅជាធម្មតា ម្យ៉ាងទៀត ព្រោះអាត្មាអញមិនធ្វើទានបែបនេះមកអំពីមុន ទើបភោគៈទាំងឡាយប្រាកដការអស់ទៅ ដោយអាការយ៉ាងនេះ ណ្ហើយចុះ អញគប្បីឲ្យទានដោយទេយ្យធម៌ តាមដែលបាន តិចក្តី ច្រើនក្តី អញនឹងដល់ទីបំផុតនៃទានបារមីតទៅ ។ ព្រះមហាសត្វនោះកាត់ផ្តាច់ មានដៃស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងការឲ្យទាន ឲ្យទានតាមរបស់ដែលបាន ។ គ្រឿងហួងហែងទានទី ៤ របស់ព្រះមហាសត្វ ឈ្មោះថា កម្ចាត់ទៅ កាត់ផ្តាច់ទៅ ដោយអាការយ៉ាងនេះ ហេតុនោះ វត្ថុណាមួយ ដែលជាគ្រឿងរារាំង មិនមានប្រយោជន៍ចំពោះទានបារមី ការពិចារណាវត្ថុនោះតាមសមគួរ ទើបជាឧបាយ ដោយប្រការដូច្នេះ ។ គប្បីឃើញក្នុងសីលបារមីជាដើម ដូចគ្នានឹងទានបារមីនេះ ។

ម្យ៉ាងទៀត ការថ្វាយខ្លួនដល់ព្រះពុទ្ធទាំងឡាយរបស់ព្រះមហាសត្វនុ៎ះជាឧបាយឲ្យបារមីទាំងពួងសម្រេចដោយប្រពៃ ។ ពិតហើយ ព្រះមហាបុរសប្រគល់ខ្លួនដល់ព្រះពុទ្ធទាំងឡាយហើយ ព្យាយាមដើម្បីភាពបរិបូណ៌នៃពោធិ-

សម្ភារក្នុងជាតិនោះៗ កាលកាត់វត្ថុដែលធ្វើឲ្យរាងកាយសប្បាយ ធ្វើឲ្យអត់ធន់បានដោយក្រខ្វះ កើតក្នុងទីកន្តារលំបាកខ្វះ កាលមានសេចក្តីវិនាសដែលអូសទាញជីវិត នូវសព្វសត្វ និងសង្ខារកើតឡើង ក៏គិតថា អញបរិច្ចាគអត្តភាពនេះដល់ព្រះពុទ្ធទាំងឡាយហើយ ក្នុងសេចក្តីនេះ យ៉ាងណាក៏ដោយចុះ មិនញាប់ញ័រ មិនដល់នូវអាការដទៃ សូម្បីតិចតួចក្នុងហេតុនោះ ជាអ្នកមានអធិដ្ឋានមាំទាំ ក្នុងការធ្វើកុសលដោយពិត ។ ទើបការប្រគល់ខ្លួនជាឧបាយ ឲ្យនូវបារមីទាំងនោះសម្រេចបានយ៉ាងនេះ ។

ម្យ៉ាងទៀត ពោលដោយសង្ខេប បុគ្គលសន្សំបុញ្ញាភិនីហារ មានការជាប់ជំពាក់ក្នុងខ្លួនឯង មានការជាប់ជំពាក់ច្រើនក្នុងអ្នកដទៃ ជាឧបាយឲ្យបារមីទាំងនោះសម្រេចបាន ។ ពិតហើយ ការជាប់ជំពាក់ក្នុងខ្លួនរបស់ព្រះមហាសត្វ ដែលធ្វើមហាបណិធាន ដើម្បីសម្រេចសម្មាសម្ពោធិញាណ ដែលមិនជាប់ក្នុងធម៌ទាំងពួង ដោយកំណត់ដឹងដោយសេចក្តីពិត រមែងដល់នូវការអស់ទៅសូន្យទៅ ការជាប់ជំពាក់ដោយមេត្តា និងករុណាក្នុងសត្វទាំងនោះរមែងចម្រើនដល់ព្រះមហាបុរស ដែលឃើញសព្វសត្វ ដូចបុត្តជាទីស្រឡាញ់ពោរពេញមហាករុណា បន្ទាប់អំពីនោះ ព្រះមហាបុរសដែលធ្វើវត្ថុដែលជាបដិបក្ខចំពោះពោធិសម្ភារ មានអច្ឆរិយៈជាដើមឲ្យឆ្ងាយ ព្រោះប្រាសចាកលោភៈ ទោសៈ មោហៈ ក្នុងសន្តានរបស់ខ្លួន និងរបស់អ្នកដទៃតាមសមគួរដល់ប្រយោជន៍នោះៗ រមែងធ្វើនូវការជញ្ជូនសត្វដាក់ក្នុងយាន ៣ ខាងលើ និងធ្វើការអប់រំដោយការសង្គ្រោះដល់ជនដោយចំណែកមួយ ដោយសង្គហ-

វត្ថុ ៤ គឺទាន បិយវាចា អត្ថចរិយា និងសមានត្តតា ដែលប្រព្រឹត្តទៅតាមអធិដ្ឋានធម៌ ៤ ។

ពិតហើយ មហាករុណា និងមហាបញ្ញារបស់មហាសត្វទាំងឡាយប្រដាប់ដោយទាន ទានប្រដាប់ដោយបិយវាចាៗ ប្រដាប់ដោយអត្ថចរិយាៗ ប្រដាប់ដោយការនិងសង្គ្រោះដោយសមានត្តតា កាលព្រះមហាសត្វទាំងនោះធ្វើសត្វទាំងពួងមិនឲ្យមានការផ្សេងគ្នាដោយខ្លួន បដិបត្តិក្នុងពោធិសម្ភារ ការសម្រេចរមែងមានដោយភាពមានខ្លួនស្មើគ្នា ព្រោះមានសុខទុក្ខស្មើក្នុងទីទាំងពួង កិច្ចបដិបត្តិដោយការធ្វើសេចក្តីសង្គ្រោះចំណែកមួយ ដល់ជនដោយសង្គហវត្ថុ ៤ នោះ ដែលជាការធ្វើនូវអធិដ្ឋានធម៌ ៤ ឲ្យបរិបូណ៌ និងចម្រើនក្រៃលែង រមែងសម្រេចដល់ព្រះមហាសត្វទាំងឡាយ សូម្បីជាព្រះពុទ្ធហើយ ព្រោះទានជាការបរិបូណ៌ និងចម្រើនក្រៃលែងដោយចាគាធិដ្ឋានរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ បិយវាចាជាការបរិបូណ៌ និងចម្រើនក្រៃលែងដោយសច្ចាធិដ្ឋាន អត្ថចរិយាជាការបរិបូណ៌ និងចម្រើនក្រៃលែងដោយបញ្ញាធិដ្ឋាន សមានត្តតា ជាការបរិបូណ៌ និងចម្រើនក្រៃលែងដោយឧបសមាធិដ្ឋាន ។ ពិតហើយ ព្រះតថាគត ជាអ្នកស្មើដោយព្រះសាវ័ក និងព្រះបច្ចេកពុទ្ធទាំងពួង ក្នុងការបរិនិព្វាន ។ ក្នុងការបរិនិព្វាននោះ លោកទាំងនោះដូចគ្នា ដោយមិនផ្សេងគ្នាឡើយ ដោយហេតុនោះ ទើបលោកពោលថាការផ្សេងគ្នានៃវិមុត្តិ រមែងមិនមាន ។

ម្យ៉ាងទៀត ក្នុងសេចក្តីនោះ មានគាថាដូចតទៅនេះថា

ព្រះសាស្តា ជាអ្នកមានសច្ចៈ មានចាគៈ មានការស្ងប់រម្ងាប់ មានបញ្ញា ជាអ្នកអនុគ្រោះ ជាអ្នកសន្សំបុញ្ញបារមីទាំងពួង មិនធ្វើប្រយោជន៍ឲ្យសម្រេចដូចម្តេចកើត ។

ព្រះសាស្តា មានព្រះមហាករុណា ស្វែងរកគុណ ដែលជាប្រយោជន៍ ព្រងើយ និងមិនពិចារណាក្នុងវត្ថុទាំងពួង ឱ ព្រះជិនស្រី គួរអស្ចារ្យហ្ន៎ ។

ព្រះសាស្តា ទ្រង់នឿយណាយធម៌ទាំងពួង ទ្រង់ព្រងើយក្នុងសត្វទាំងឡាយ ទ្រង់ខ្វល់ខ្វាយក្នុងប្រយោជន៍ដល់សព្វសត្វ សព្វកាល ឱ ព្រះជិនស្រី គួរអស្ចារ្យហ្ន៎ ។

ព្រះសាស្តា ទ្រង់ខ្វល់ខ្វាយ មិនខ្ជិលច្រអូស ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់សព្វសត្វ ក្នុងកាលទាំងពួង ឱ ព្រះជិនស្រី គួរអស្ចារ្យហ្ន៎ ។

បញ្ហាថា ឲ្យសម្រេចដោយកាលណា លោកពោលក្នុងអដ្ឋកថាថា ដោយកំណត់យ៉ាងទាប ៤ អសង្ខេយ្យ និង ១ សែនមហាកប្ប ដោយកំណត់យ៉ាងកណ្តាល ៨ អសង្ខេយ្យ និង ១ សែនមហាកប្ប ដោយកំណត់យ៉ាងខ្ពស់ ១៦ អសង្ខេយ្យ និង ១ សែនមហាកប្ប ។ ការផ្សេងគ្នាទាំងនេះគប្បីជ្រាបដោយអំណាចនៃព្រះពោធិសត្វដែលជាបញ្ញាធិក សទ្ធាធិក និងវីរិយាធិកតាមលំដាប់ ។ ពិតហើយ ព្រះពោធិសត្វដែលជាបញ្ញាធិកទាំង

ឡាយ មានសទ្ធាទន់ខ្សោយ មានបញ្ញាខ្លាំងក្លា ព្រះពោធិសត្វដែលជាសទ្ធាធិក ទាំងឡាយ មានបញ្ញាជាកណ្តាល ព្រះពោធិសត្វដែលជាវីរិយាធិកទាំងឡាយ មានបបញ្ញាទន់ខ្សោយ ឯសម្មាសម្ពោធិញ្ញាណ សម្រេចបានដោយអានុភាព នៃបញ្ញា ។

ម្យ៉ាងទៀត គប្បីសម្រេចសម្មាសម្ពោធិញ្ញាណដោយអានុភាពនៃបញ្ញា ចំណែកអាចារ្យមួយពួកទៀតពោលថា នេះជាការចែកកាលរបស់ព្រះពោធិ-សត្វទាំងឡាយ ទៅតាមសេចក្តីព្យាយាមដែលចាស់ក្លា កណ្តាល និងទន់ខ្សោយ ។ អាចារ្យពួកខ្លះពោលថា តែដោយការមិនផ្សេងគ្នា ពោធិសម្ភារទាំងឡាយ រមែងដល់នូវការបរិបូណ៌ដល់ព្រះពោធិសត្វទាំងនោះ ក្នុងរយៈកាលដែលផ្សេងគ្នាតាមដែលពោលហើយ ដោយការចាស់ក្លា កណ្តាល និងទន់ខ្សោយនៃធម៌ទាំងឡាយ ដែលបន្ទុំបារមីឲ្យចាស់ក្លាដោយវិមុត្តិ ព្រោះហេតុនោះ ការចែកកាលជា ៣ ទើបគួរ ។ ដោយអាការយ៉ាងនេះ ទើបព្រះពោធិសត្វទាំងឡាយ ចែកជា ៣ ប្រភេទ ក្នុងខណៈនៃអភិនីហារ ដោយការចែកជាឧគ្ឃដិតញ្ញូពោធិសត្វ វិបចិតញ្ញូពោធិសត្វ និងនេយ្យពោធិសត្វ ។

ក្នុង ៣ យ៉ាងនោះ ព្រះពោធិសត្វដែលជាឧគ្ឃដិតញ្ញូ ស្តាប់គាថា ៤ បាទ ចំពោះព្រះភក្ត្ររបស់ព្រះសម្មាសម្ពុទ្ធ កាលមិនទាន់ចប់បាទទី ៣ បើបង្អោនចិត្តទៅក្នុងសាវកពោធិញ្ញាណ ក៏ជាអ្នកមានឧបនិស្ស័យអាចសម្រេចអរហត្ត មួយអន្លើដោយអភិញ្ញា ៦ និងបដិសម្ភិទា ។

ព្រះពោធិសត្វប្រភេទទី ២ ស្តាប់គាថា ៤ បាទ ចំពោះព្រះភក្ត្ររបស់

ព្រះដ៏មានព្រះភាគ មិនទាន់ចប់បាទទី ៤ បើបង្អោនទៅក្នុងសាវកពោធិញ្ញាណ ក៏ជាអ្នកមានឧបនិស្ស័យអាចសម្រេចអរហត្ត ដោយអភិញ្ញា ៦ មួយអន្លើ ដោយបដិសម្ភិទា ។

ចំណែកព្រះពោធិសត្វប្រភេទទី ៣ ស្តាប់គាថា ៤ បាទ ចំពោះព្រះភក្ត្រ របស់ព្រះដ៏មានព្រះភាគ កាលចប់គាថាហើយ ជាអ្នកមានឧបនិស្ស័យអាច សម្រេចអរហត្ត ដោយអភិញ្ញា ៦ ។

ព្រះពោធិសត្វទាំង ៣ ពួកនេះ វៀរការប្រើពេលវេលាផ្សេងគ្នាហើយ ជាអ្នកសន្សំបុញ្ញាភិនីហារ និងបានទទួលព្យាករ ក្នុងសម្នាក់របស់ព្រះពុទ្ធ ទាំងឡាយបំពេញបារមីមកដោយលំដាប់ រមែងសម្រេចសម្មាសម្ពោធិញ្ញាណ តាមការផ្សេងគ្នានៃកាលតាមដែលពោលហើយ តាមលំដាប់ ។ កាលមិន ទាន់ដល់ពេលតាមដែលកំណត់ ព្រះមហាសត្វទាំងនោះ ទោះបីឲ្យមហាទាន ដូចគ្នានឹងទានរបស់ព្រះវេស្សន្តររាល់ៗ ថ្ងៃ សន្សំបារមីធម៌ទាំងពួង មានសីល ជាដើមតាមសមគួរ ធ្វើមហាបរិច្ចាគ ៥ ញុំាងញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយាឲ្យដល់ទីបំផុតក្រៃលែង នឹងបានជាព្រះសម្មាសម្ពុទ្ធក្នុងចន្លោះនោះ សេចក្តីនោះ រមែងប្រព្រឹត្តទៅមិនបាន ព្រោះហេតុអ្វី ព្រោះញាណមិនទាន់ ចាស់ក្លា ព្រោះពុទ្ធការកធម៌មិនទាន់សម្រេច ។ ពិតហើយ សូម្បីព្យាយាម ដោយឧស្សាហៈទាំងអស់ក្នុងរវាងនោះ ក៏មិនអាចសម្រេចសម្មាសម្ពោធិញ្ញាណ ដែលកំណត់ដោយកាល តាមដែលពោលហើយ ដូចសម្ទូងសម្រេចតាម កាលដែលកំណត់ប៉ុណ្ណោះ ព្រោះហេតុនោះ គប្បីជ្រាបថា ការបរិបូណ៌នៃ

បារមី រមែងសម្រេចដោយរយៈកាលតាមដែលពោលហើយ ។

បញ្ហាថា អ្វីជាអានិសង្ស ព្រះពោធិសត្វទាំងឡាយ ដែលសន្សំបុញ្ញា-ភិនីហារ ជាអ្នកមានអានិសង្ស ដែលលោកពណ៌នាយ៉ាងនេះថា

នរជនទាំងឡាយ ដែលសម្បូរដោយគុណទាំងពួងយ៉ាងនេះ ជាអ្នកតែងបានចំពោះពោធិញ្ញាណ អន្ទោលទៅអស់កាលវែងឆ្ងាយ រាប់បានត្រាច់ទៅអស់កាលយូរ រាប់រយកោដិកប្ប ។

រមែងមិនកើតក្នុងអវីចី ១ មិនកើតក្នុងលោកន្តរនរក ១ មិនកើតជានិជ្ឈាមតណ្ហិកប្រេត ១ ខុប្បិបាសិកប្រេត ១ កាឡ-កញ្ជិកាប្រេត ១ ។

ទោះបីចូលដល់ទុគ្គតិ ក៏មិនកើតជាសត្វល្អិត ១ នរជនទាំងនោះ កាលកើតក្នុងមនុស្សលោក ក៏មិនកើតជាមនុស្សភ្នែកខ្វាក់ ១ ។

មិនកើតជាមនុស្សត្រចៀកថ្លង់ ១ មនុស្សគ ១ មនុស្សខ្វិន ១ មិនកើតជាឧភតោព្យញ្ជនកៈ ១ ខ្ទើយ ១ ។

មិនដល់នូវភាពជាស្ត្រី ១ នរជនទាំងឡាយ ដែលទៀងចំពោះពោធិញ្ញាណ រមែងមិនជាបុគ្គលដែលទាក់ទងដោយទោសតាមដែលពោលហើយ ជាអ្នកផុតចាកអនន្តរិយកម្ម ១ ជាអ្នកមានគោចរបរិសុទ្ធ ក្នុងទីទាំងពួង ។

ជាអ្នកជឿកម្ម ជឿផលរបស់កម្ម ១ មិនសេពមិច្ឆាទិដ្ឋិ ១

ទោះបីនៅក្នុងឋានសួគ៌ ក៏មិនចូលដល់អសញ្ញីភព ១ ។
រមែងមិនមានហេតុកើតក្នុងទេវលោកជាន់សុទ្ធាវាស ១ បង្អោន
ទៅក្នុងនេក្ខម្ម: ជាសប្បុរស មិនជាប់ជំពាក់ក្នុងភពតូច ភពធំ
រមែងប្រព្រឹត្តលោកត្ថចរិយា បំពេញបារមីទាំងពួង ។

ម្យ៉ាងទៀត ព្រះពោធិសត្វទាំងឡាយ ជាបុគ្គលមានអច្ឆរិយព្ភូតធម៌ ១៦ យ៉ាង ដោយន័យ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ម្នាលអានន្ទ ពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិតចុះមកកាន់ផ្ទៃនៃមាតា តែងមានសតិសម្បជញ្ញ: ដូច្នេះ ។ ម្យ៉ាងទៀត ជាអ្នកមានបុព្វនិម្មិត ៣២ យ៉ាង ដោយន័យ ( ក្នុងពុទ្ធវំស: ) ថា ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ ជាដើម ។ និងដោយន័យមួយទៀតថា ម្នាលសារីបុត្ត កាលព្រះពោធិសត្វប្រសូត លោកធាតុទាំងមួយហ្មឺននេះ ក៏កក្រើករំពើកញាប់ញ័រ ដូច្នេះជាដើម ឬអានិសង្សដទៃណា មានអាការដែលបានសម្តែងក្នុងទីដទៃៗ ដូចជាក្នុងជាតក និងពុទ្ធវង្សជាដើម យ៉ាងនេះថា ភាពជាអ្នកជំនាញក្នុងកម្មជាដើម ជាការសម្រេចបំណងរបស់ព្រះពោធិសត្វទាំងឡាយ ដូច្នេះជាដើម ទាំងអស់នោះ ជាអានិសង្សនៃបារមីទាំងនោះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា គុណធម៌មានអលោភ: និងអទោស:ជាដើម មានប្រភេទតាមដែលបានសម្តែងហើយ ជាអានិសង្ស ។

ម្យ៉ាងទៀត ព្រះពោធិសត្វជាអ្នកស្មើនឹងបិតារបស់សត្វទាំងឡាយ តាំងអំពីសន្សំអភិនីហារដើម្បីស្វែងរកប្រយោជន៍ ជាបុគ្គលគួរដល់ទក្ខិណា គួរគោរព

គួរលើកតម្កើង និងជាបុញ្ញក្ខេត្តយ៉ាងក្រៃលែង ដោយប្រកបគុណវិសេស និងដោយច្រើន ព្រះពោធិសត្វជាទីស្រឡាញ់របស់មនុស្ស របស់អមនុស្ស ទេវតាអ្នកថែរក្សា សត្វសាហាវជាដើម គ្របសង្កត់មិនបាន ព្រោះមានសន្តាន អប់រំដោយមេត្តាករុណា ។ មា៉្យងទៀត ព្រះពោធិសត្វកើតក្នុងសត្តនិកាយណាៗ រមែងគ្របសង្កត់សត្វដទៃក្នុងសត្តនិកាយនោះៗ ដោយពណ៌សម្បុរ យស សុខ ពល អធិបតេយ្យដ៏ក្រៃលែង ព្រោះប្រកបដោយបុញ្ញវិសេស ។

ជាអ្នកមានអាពាធតិច មានរោគតិច ។ សទ្ធារបស់ព្រះពោធិសត្វនោះ បរិសុទ្ធដោយល្អ សេចក្តីព្យាយាមបរិសុទ្ធដោយល្អ សតិ សមាធិ បញ្ញា បរិសុទ្ធដោយល្អ ។ មានកិលេសស្តើង មានការក្រវល់ក្រវាយតិច មានការក្តៅក្រហាយតិច ជាអ្នកប្រដៅងាយ ព្រោះមានកិលេសស្តើង ជាអ្នកមានទូវសេចក្តីគោរព ជាអ្នកអត់ធន់ស្ងប់ស្ងៀម ជាអ្នកទន់ភ្លន់ ឈ្លាសក្នុងបដិសណ្ឋារៈ មិនក្រោធ មិនចងសេចក្តីក្រោធ មិនលុបគុណ មិនវាយឫកស្មើ មិនប្រណែន មិនកំណាញ់ មិនអួតអាង មិនលាក់ពុត មិនរឹងត្អឹង មិនប្រកាន់ខ្លួន មិនលើកខ្លួន មិនប្រមាទ អត់ធន់ចំពោះការក្តៅក្រហាយអំពីអ្នកដទៃ មិនធ្វើអ្នកដទៃឲ្យក្តៅក្រហាយ អន្តរាយ មានភ័យជាដើមដែលមិនទាន់កើត រមែងមិនកើតក្នុងតំបន់ដែលខ្លួនអាស្រ័យនៅ និងដែលកើតហើយ រមែងស្ងប់ទៅ ទុក្ខមានប្រមាណក្រៃលែង រមែងមិនបៀតបៀនព្រះពោធិសត្វ ក្នុងអបាយទុក្ខដែលកើតដូចជនទូទៅ រមែងដល់នូវសេចក្តីសង្វេគដោយប្រមាណក្រៃលែង ព្រោះហេតុនោះ គប្បីជ្រាបថា គុណវិសេសទាំងនោះ មានភាពស្មើដោយបិតា

និងភាពទក្ខិណេយ្យបុគ្គលជាដើម របស់សត្វទាំងឡាយ ជាអានិសង្សដែល ព្រះមហាបុរស បានក្នុងភពនោះៗ តាមសមគួរ ។

ម្យ៉ាងទៀត គុណសម្បត្តិទាំងនេះ គឺអាយុសម្បទា រូបសម្បទា កុលសម្បទា ឥស្សរិយសម្បទា អាទេយ្យវចនតា គឺមានពាក្យគួរជឿ មហានុភាវតា គប្បីជ្រាបថា ជាអានិសង្សនៃបារមីទាំងឡាយរបស់មហាបុរស ។

ក្នុងគុណវិសេសទាំងនោះ ឈ្មោះថា អាយុសម្បទា បានដល់ ភាពជាអ្នកមានអាយុវែង ការតាំងនៅយូរក្នុងកំណើតនោះៗ ញុំាងកុសលសមាទានតាមដែលផ្តើមក្នុងអាយុសម្បទានោះឲ្យដល់ទីបំផុត និងសន្សំកុសលច្រើន ។ ឈ្មោះថា រូបសម្បទា បានដល់ ជាអ្នកមានរូបស្អាត គួរមើល គួរជ្រះថ្លា ជាអ្នកនាំមកនូវការជ្រះថ្លា គួរសរសើររបស់សត្វទាំងឡាយ ដែលកាន់យករូបជាប្រមាណ ដោយរូបសម្បទានោះ ។ ឈ្មោះថា កុលសម្បទា បានដល់ ការកើតក្នុងត្រកូលដ៏ក្រៃលែង គួរចូលទៅរក គួរចូលទៅអង្គុយជិត សូម្បីបុគ្គលស្រវឹង មានស្រវឹងដោយជាតិជាដើម ដោយកុលសម្បទានោះ ធ្វើជនទាំងនោះឲ្យអស់ព្យសន៍ ដោយហេតុនោះ ។ ឈ្មោះថា ឥស្សរិយសម្បទា បានដល់ ភាពជាអ្នកមាននូវសម្បត្តិច្រើន មានសក្តិធំ និងមានបរិវារច្រើន ជាអ្នកអាចសង្រ្គោះបុគ្គលដែលគួរសង្រ្គោះដោយសង្គហវត្ថុ ៤ សង្កត់សង្កិនបុគ្គលដែលគួរសង្កត់សង្កិនដោយធម៌ ដោយឥស្សរិយសម្បទានោះ ។ ឈ្មោះថា អាទេយ្យវចនតា បានដល់ ភាពជាបុគ្គលគួរជឿ គួរកាន់យកជាប្រមាណរបស់សត្វទាំងឡាយ ដោយការកាន់យកនោះ ពាក្យប្រាប់របស់ព្រះពោធិសត្វ

មិនប្រែប្រួល ។ ឈ្មោះថា មហានុភាវតា បានដល់ ព្រោះមានអានុភាពច្រើន អ្នកដទៃគ្របសង្កត់មិនបាន តែខ្លួនឯងគ្របសង្កត់អ្នកដទៃបានដោយពិតដោយធម៌ ដោយស្មើ និងដោយគុណតាមសេចក្តីពិត ដោយភាពជាអ្នកមានអានុភាពធំនោះ ។ គប្បីជ្រាបថា គុណវិសេស មានអាយុសម្បទាជាដើមនេះ ជាអានិសង្សនៃបារមីទាំងឡាយរបស់ព្រះមហាបុរស និងជាហេតុនៃសេចក្តីចម្រើនរបស់បុញ្ញសម្ភារមិនមានប្រមាណ និងជាហេតុនៃការជញ្ជូនសត្វទាំងឡាយ ដាក់ក្នុងយាន ៣ និងការអប់រំសត្វទាំងឡាយ ។

បញ្ហាថា អ្វីជាផល ពោលដោយសង្ខេប ភាពជាព្រះសម្មាសម្ពុទ្ធ ជាផលនៃបារមីទាំងនោះ ពោលដោយពិស្តារ សិរិធម្មកាយដែលល្អទូទៅ តាំងឡើងដោយគុណប្រមាណមិនបាន មិនមានទីបំផុត តាំងអំពីសម្បត្តិរបស់រូបកាយដ៏រុងរឿងដោយពួកគុណមិនតិចជាដើម មហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ រស្មីប្រមាណ ១ ព្យាមជាដើម អធិដ្ឋានធម៌ ទសពលញ្ញាណ វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ ពុទ្ធធម៌ ១៨ ពួក ។ ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ ក៏មិនអាចសរសើរពុទ្ធគុណទាំងឡាយឲ្យដល់ទីបំផុត ដោយកប្បជាច្រើន នេះជាផលនៃបារមីទាំងនោះ សមដូចលោកពោលថា

ទោះបីព្រះពុទ្ធ គប្បីសរសើរគុណរបស់ព្រះពុទ្ធផងគ្នា មិន
ត្រាស់រឿងដទៃ អស់កប្បដ៏វែងឆ្ងាយ នឹងអស់ទៅមុន ការ
សរសើរគុណរបស់ព្រះតថាគត មិនទាន់អស់ទៅឡើយ ។

គប្បីជ្រាបបកិណ្ណកកថាក្នុងបារមីទាំងឡាយក្នុងទីនេះ ដោយប្រការដូច្នេះ តែបទណាក្នុងបាលី លោកសម្តែងបារមីទាំងអស់ រួមគ្នាដោយន័យជាដើមថា តថាគតបានឲ្យទានដែលព្រះពោធិសត្វគប្បីឲ្យ ដូច្នេះហើយ ពោលពីរគាថាចុងក្រោយ ដោយន័យជាដើមថា អ្នកគួរឃើញនូវកោសជ្ជៈថាជាភ័យ ដូច្នេះ បទនោះ លោកពោលដើម្បីឲ្យឱវាទដល់វេនេយ្យសត្វ ក្នុងការអប់រំបន្ទំវិមុត្តិឲ្យចាស់ក្លា ដោយធម៌ ជាគ្រឿងនៅដោយសេចក្តីមិនប្រមាទ ដែលជាគ្រឿងចម្រើនមេត្តាភាវនា ដែលប្រារព្ធសេចក្តីព្យាយាម ជាគ្រឿងជួយឲ្យពុទ្ធ-ការកធម៌ដូចពោលហើយ ដល់នូវការចាស់ក្លា និងគ្រឿងបន្ទំវិមុត្តិ ពោលគឺសម្មាសម្ពោធិញ្ញាណសម្រាប់ខ្លួន ។

ក្នុងបទទាំងនោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអានិសង្សក្នុងការប្រារព្ធសេចក្តីព្យាយាម ដោយលើកវត្ថុ ដែលមានទោសដែលផ្ទុយគ្នាមកសម្តែងដោយព្រះតម្រាស់ថា មាតិកាសម្តែងដល់ទោស ក្នុងចំណែកដែលជាបដិបក្ខដោយបទនេះថា គួរឃើញនូវការប្រារព្ធព្យាយាមថាជាសេចក្តីក្សេមដូច្នេះ ។ ទ្រង់ដឹកនាំក្នុងការប្រារព្ធសេចក្តីព្យាយាម ដោយព្រះតម្រាស់ថា ហើយប្រឹងប្រែងព្យាយាមចុះ ។ម្យ៉ាងទៀត ព្រោះទ្រង់ប្រកាសដោយសេចក្តីសង្ខេបថា

ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញ៉ាំង
ចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់
ព្រះពុទ្ធទាំងឡាយ ដូច្នេះ ។

តែដោយពិស្តារ សម្បត្តិគ្រប់យ៉ាង ដែលប្រកាសដោយពុទ្ធវចនៈ ជាមួយសេចក្តីព្យាយាមទាំងមូល ហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ដឹកនាំក្នុងការប្រារព្ធសេចក្តីព្យាយាម ទើបត្រាស់ថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

ក្នុងគាថានោះ មានសេចក្តីសង្ខេបដូចតទៅ ការប្រារព្ធព្យាយាម ការប្រកបដោយសម្មប្បធាន ដោយការញ៉ាំងអធិសីលសិក្ខាជាដើមឲ្យបរិបូណ៌ ព្រោះឃើញនូវការខ្ជិលច្រអូសដោយភាពជាភ័យថា ការខ្ជិលច្រអូសជាហេតុនៃសេចក្តីវិនាសទាំងពួង ព្រោះជាឫសគល់នៃសេចក្តីសៅហ្មងទាំងពួង ការប្រារព្ធនូវសេចក្តីព្យាយាម ដោយភាពជាបដិបក្ខចំពោះការខ្ជិលច្រអូសនោះ ដោយភាពជាធម៌ក្សេម ព្រោះឲ្យសម្រេចនូវការផ្សេងចាកយោគៈ ៤ ។ ការទូន្មានប្រពៃក្នុងការតាមប្រកបសេចក្តីព្យាយាមនោះថា អ្នកទាំងឡាយ ចូរប្រារព្ធព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅ ពាក្យទូន្មាន និងជាឱវាទរបស់ព្រះពុទ្ធមានព្រះភាគទាំងឡាយ ។ សូម្បីក្នុងគាថាដ៏សេស ក៏គប្បីជ្រាបដោយន័យនេះឯង ។

តែការផ្សេងគ្នា មានដូច្នេះ បទថា **វិវាទំ** បានដល់ ដោយសេចក្តីក្រោធ អធិប្បាយថា ប្រកែកគ្នាដោយវិវាទវត្ថុ ៦ ប្រការ ។ បទថា **អវិវាទំ** សេចក្តីថា មេត្តាវចីកម្ម ឬមេត្តាភាវនា ដែលជាបដិបក្ខចំពោះការទាស់ទែងគ្នា ។ ម្យ៉ាងទៀត បទថា **អវិវាទំ** បានដល់ សារាណិយធម៌ ៦ ដែលជាហេតុមិនទាស់ទែងគ្នា ។ បទថា **សមគ្គា** បានដល់ មិនបែងចែកពួកគណៈ

អធិប្បាយថា រួមគ្នាផ្លូវកាយ និងចិត្ត មិនវៀរ មិនបែកគ្នា ។ បទថា **សខិលា** បានដល់ គួរស្រឡាញ់ ទន់ភ្លន់ អធិប្បាយថា មានចិត្តទន់ដល់គ្នានិងគ្នា ។ ក្នុងបទថា **ឯសា ពុទ្ធានុសាសនី** នេះ បានដល់ មិនអាស្រ័យការមិនវិវាទគ្នាដោយប្រការទាំងពួង ហើយដឹកនាំឲ្យនូវរួមសាមគ្គីគ្នា ដោយបំពេញសារាណិយធម៌ ៦ ។ គប្បីប្រកបបទថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ពិតហើយ ជនទាំងឡាយនៅរួមគ្នាដោយសាមគ្គី មានសីល និងទិដ្ឋិស្មើគ្នា មិនវិវាទគ្នា នឹងញុំាងត្រៃសិក្ខាឲ្យបរិបូណ៌បានដោយងាយនោះឯង ព្រោះហេតុនោះ ទើបព្រះសាស្តាទ្រង់សម្តែងថា ការព្រមព្រៀងគ្នា ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។

បទថា **បមាទំ** បានដល់ សេចក្តីប្រមាទ គឺការវង្វេងកុសលធម៌ និងការបណ្តោយចិត្តឲ្យធ្លាក់ទៅក្នុងអកុសលធម៌ សមដូចលោកពោល ( ក្នុងអភិធម្មវិភង្គ ) ថា បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទំរន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ។បេ។ ការធ្វេសប្រហែសក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះ ហៅថា សេចក្តីប្រមាទ ។

បទថា **អប្បមាទំ** បានដល់ សេចក្តីមិនប្រមាទ គប្បីជ្រាបការមិនប្រមាទនោះ ដោយជាបដិបក្ខចំពោះសេចក្តីប្រមាទ ព្រោះដោយអត្ថ ការមិននៅប្រាសចាកសតិ ឈ្មោះថា ការមិនប្រមាទ ។ ពាក្យថា ការមិននៅប្រាសចាកសតិ នេះជាឈ្មោះរបស់សតិដែលចូលទៅតាំងមាំហើយជានិច្ច តែអាចារ្យពួកមួយទៀតពោលថា អរូបក្ខន្ធ ៤ ប្រព្រឹត្តទៅដោយតាំងសតិសម្បជញ្ញៈ ឈ្មោះថា ការមិនប្រមាទ ។ ព្រោះអប្បមាទភាវនា មិនបានចែកចេញជាភាវនាមួយដោយឡែក និងឡែកចាកគ្នាជាបែបដទៃ ។ បុញ្ញកិរិយាណាដែលជាកុសលកិរិយា គប្បីជ្រាបថា ទាំងអស់ជាអប្បមាទភាវនានោះឯង ។

តែដោយការផ្សេងគ្នា សីលភាវនា សមាធិភាវនា បញ្ញាភាវនា កុសលភាវនា អនវជ្ជភាវនា គឺភាវនាដែលមិនមានទោស អប្បមាទភាវនាទាំងអស់ឡើងកាន់សរណគមន៍ និងការសង្រួមកាយវាចា ដែលចូលទៅអាស្រ័យវិវដ្ត គឺនិព្វាន ។ ពិតហើយ បទថា **អប្បមាទោ** នេះ សម្តែងដល់អត្ថដ៏ធំសង្គ្រោះយកអត្ថដែលធំក្រៃលែង ។ ធម្មកថិកនាំព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងមូល មកពោលពង្រីកអត្ថនៃបទថា អប្បមាទ ទើបគិះដៀលថា និយាយក្រៅការ ព្រោះហេតុអ្វី ព្រោះអត្ថនៃបទអប្បមាទទូលំទូលាយខ្លាំង ។ សេចក្តីពិត ព្រះសម្មាសម្ពុទ្ធផ្ទំក្នុងកាលបរិនិព្វាន ក្នុងរវាងដើមសាលព្រឹក្សទាំងគូ ក្នុងក្រុងកុសិនារា ទ្រង់សម្តែងធម៌ដែលព្រះអង្គត្រាស់មក ៤៥ ព្រះវស្សា តាំងអំពីត្រាស់ដឹង សង្គ្រោះចូលដោយបទមួយប៉ុណ្ណោះ ទ្រង់បានប្រទានឱវាទដល់ភិក្ខុទាំងឡាយថា **អប្បមាទេន សម្បាទេថ** អ្នកទាំងឡាយ ចូរ

ញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ ដូច្នេះ ។ម្យ៉ាង ទៀត ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្នាមជើងទាំងឡាយ ណាមួយ របស់ពួកសត្វដែលនៅលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីប្រាកដជាវិសេសជាងស្នាមជើងនៃ សត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះ ជាស្នាមជើងធំ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយណានីមួយ កុសលធម៌ទាំងអស់ នោះ មានសេចក្ដីមិនប្រមាទជាមូល ឈមចុះកាន់សេចក្ដីមិនប្រមាទ សេចក្ដី មិនប្រមាទ លោកពោលថា ប្រសើរជាងធម៌ទាំងនោះ ។ ព្រះសាស្ដាកាល ទ្រង់សម្ដែងដល់អប្បមាទការនា ដល់នូវភាពជាកំពូល ទើបត្រាស់ថា **ភាវេថដ្ឋង្គិកំ មគ្គំ** ហើយចូលចម្រើនមគ្គប្រកបដោយអង្គ ៨ ចុះ ។

អត្ថនៃគាថានោះ មានដូចតទៅ ចូរពួកអ្នកចម្រើនអរិយមគ្គមានអង្គ ៨ សង្គ្រោះចូលក្នុងខន្ធ ៣ មានសីលក្ខន្ធជាដើម មានសម្មាទិដ្ឋិជាប្រធាន ដោយ អំណាចនៃអង្គ ៨ មានសម្មាទិដ្ឋិជាដើមនោះឯង ចូរញុំាងមគ្គនោះឲ្យកើតក្នុង សន្តានរបស់ខ្លួន ពួកអ្នកមិនតាំងនៅត្រឹមតែមគ្គដែលឃើញ ចូរចម្រើនដោយ ឲ្យមគ្គ ៣ ខាងលើកើតឡើងផង ។ អប្បមាទភាវនារបស់ពួកអ្នក នឹងដល់ កំពូល ដោយប្រការដូច្នេះ ។ បទថា **ឯសា ពុទ្ធានុសាសនី** បានដល់ សេចក្ដី មិនប្រមាទក្នុងកុសលធម៌ទាំងឡាយ និងការខ្វល់ខ្វាយក្នុងសេចក្ដីមិនប្រមាទ នោះ ហើយអប់រំអរិយមគ្គនេះ ជាពាក្យប្រៀនប្រដៅ ជាឱវាទរបស់ព្រះពុទ្ធ មានព្រះភាគទាំងឡាយ ។

ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចប់ទេសនាចរិយាបិដក ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ បទថា **ឥត្ថំ** ក្នុងបទជាដើមថា **ឥត្ថំ សុទំ** បានដល់ ដោយប្រការថា **កាលេ ច សតសហស្សេ** និង ១ សែនកប្ប ជាដើម ។ បទថា **សុទំ** ត្រឹមតែជានិបាត ។ បទថា **ភគវា** ឈ្មោះថា ភគវា ដោយហេតុមានភាពជាអ្នកមានជោគជាដើម ។ បទថា **អត្តនោ បុព្វចរិយំ** សេចក្តីថា ការបំពេញទុក្ករកិរិយាដែលជាបដិបទារបស់ព្រះអង្គ ក្នុងជាតិជា អកិត្តិបណ្ឌិតជាដើមក្នុងកាលមុន ។ បទថា **សម្ភាវយមានោ** បានដល់ ទ្រង់ប្រកាសដោយប្រពៃ ដូចឲ្យមើលផ្លែកន្ទួតព្រៃនៅលើបាតដៃ ដូច្នោះ ។ បទថា **ពុទ្ធាបទានិយំ នាម** សេចក្តីថា ឈ្មោះថា ពុទ្ធាបទាន ព្រោះសម្តែងដល់កម្មចាស់ដែលជាអធិកិច្ច ដែលធ្វើបានលំបាកអំពីមុនរបស់ព្រះពុទ្ធទាំងឡាយ ។ បទថា **ធម្មបរិយាយំ** បានដល់ ការសម្តែងធម៌ ឬហេតុដែលជាធម៌ ។ បទថា **អភាសិត្ថ** បានដល់ បានពោលហើយ ។ម្យ៉ាងទៀត បទណាដែលមិនបានពោលក្នុងទីនេះ គប្បីជ្រាបថា បទនោះ មិនបានពោលទៀត ព្រោះមានន័យដូចពោលហើយខាងដើម ឬបើពុំដូច្នោះ ព្រោះមានអត្ថងាយយល់ហើយ ។៚

**បកិណ្ណកកថា ចប់**

# និគមនកថា

ដោយពាក្យដែលពោលមក មានប្រមាណប៉ុណ្ណេះ ។

ព្រះសាស្តា មានព្រះចរិតបរិសុទ្ធ ទ្រង់ដល់នូវត្រើយនៃពុទ្ធចរិយា ទ្រង់ឈ្លាសក្នុងចរិយាទាំងឡាយ ទ្រង់ជាអាចារ្យនៃសត្វលោកដ៏កំពូល ។

ទ្រង់សម្រេចភាពអស្ចារ្យទាំងពួង នៃអច្ឆរិយធម៌ទាំងឡាយ ទ្រង់ប្រកាសអានុភាពនៃបុព្វចរិយារបស់ព្រះអង្គ ។

ព្រះសាស្តា ជាទីពឹង ទ្រង់សម្តែងចរិយាបិដកនឹងព្រះថេរៈ ជាតាទិ-បុគ្គលដែលសង្គាយនាព្រះធម៌ បានសង្គាយនាចរិយាបិដកយ៉ាងនោះ ។

ដើម្បីប្រកាសអត្ថនៃចរិយាបិដកនោះ ខ្ញុំបានផ្តើមពណ៌នាអត្ថ ដោយអាស្រ័យន័យរបស់អដ្ឋកថាបុរាណ ។

ជ្រើសរើស និងប្រកាសភាពក្រៃលែង ក្នុងចរិយាបិដកនោះតាមសមគួរ ដោយឈ្មោះថា បរមត្ថទីបនី ។

ការវិនិច្ឆ័យមិនសាំញ៉ាំ ដល់នូវភាពសម្រេចដោយភាណវារនៃបាលី ២៨ បរិបូណ៌ ។

ហេតុនោះ ខ្ញុំជាអ្នករចនាបរមត្ថទីបនីនោះ សូមបានសម្រេចនូវបុណ្យដែលជាពាក្យប្រៀនប្រដៅរបស់ព្រះបរមលោកនាថ ដោយអានុភាពនៃបុណ្យនោះចុះ ។

សូមសត្វទាំងពួងឈមចុះ ដើម្បីបដិបត្តិសីលជាដើម ដែលបរិសុទ្ធ ហើយ ចូរមានចំណែកនៃវិមុត្តិរសចុះ ។

សូមសាសនារបស់ព្រះសម្មាសម្ពុទ្ធ ប្រតិស្ឋានក្នុងលោក អស់កាលយូរ សូមសត្វទាំងឡាយ មានសេចក្ដីគោរពក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធនោះជានិច្ចចុះ ។

ទេវតាជាធំក្នុងផែនដី ចូរឲ្យភ្លៀងធ្លាក់តាមរដូវកាល ដោយប្រពៃ ជាអ្នកត្រេកអរក្នុងព្រះសទ្ធម្ម ចូរគ្រប់គ្រងលោក ដោយធម៌ចុះ ដោយប្រការដូច្នេះ ។

អដ្ឋកថានេះ ព្រះធម្មបាលាចារ្យ នៅក្នុងពទរតិត្ថវិហារ គឺវិហារកំពង់ពុទ្រា ( វត្តកំពង់ពុទ្រា ) បានរចនាដូច្នេះឯង ។៚

## អដ្ឋកថាចរិយាបិដក ចប់

# ក្បាលទី ៦៣

# សុត្តន្តបិដក ចាលីប្រែ -៧៧

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
| --- | --- |
| អកិត្តិចរិយាទី ១ | ២ |
| និទានកថា | ៨ |
| កប្បសូត្រ | ១៩ |
| អន្តរសូត្រ | ៣៣ |
| អត្តរបស់សព្វសត្វ | ៣៧ |
| អត្តរបស់ពោធិសត្វ | ៣៨ |
| អដ្ឋកថាអកិត្តិចរិយា | ៤៥ |
| សង្ខព្រាហ្មណចរិយាទី ២ | ៦២ |
| អដ្ឋកថាសង្ខព្រាហ្មណចរិយា | ៦៤ |
| កុរុធម្មចរិយាទី ៣ | ៧៧ |
| អដ្ឋកថាកុរុធម្មចរិយា | ៧៩ |
| មហាសុទស្សនចរិយាទី ៤ | ៨៩ |
| អដ្ឋកថាមហាសុទស្សនចរិយា | ៩១ |
| មហាគោវិន្ទចរិយាទី ៥ | ១០២ |
| អដ្ឋកថាមហាគោវិន្ទចរិយា | ១០៣ |
| នេមិរាជចរិយាទី ៦ | ១១៦ |
| អដ្ឋកថានេមិរាជចរិយា | ១១៧ |
| ចន្ទកុមារចរិយាទី ៧ | ១៣០ |
| អដ្ឋកថាចន្ទកុមារចរិយា | ១៣១ |

សិវិរាជចរិយាទី ៨ ...... ...... ...... ...... ...... ...... ១៤២
អដ្ឋកថាសិវិរាជចរិយា ...... ...... ...... ...... ...... ...... ១៤៤
វេស្សន្តរចរិយាទី ៩ ...... ...... ...... ...... ...... ...... ១៦៧
អដ្ឋកថាវេស្សន្តរចរិយា ...... ...... ...... ...... ...... ...... ១៧៥
សសបណ្ឌិតចរិយាទី ១០ ...... ...... ...... ...... ...... ...... ២៣០
អដ្ឋកថាសសបណ្ឌិតចរិយា ...... ...... ...... ...... ...... ...... ២៣៣

## សីលបារមិតា

សីលវនាគចរិយាទី ១ ...... ...... ...... ...... ...... ...... ២៤៧
អដ្ឋកថាសីលវនាគចរិយា ...... ...... ...... ...... ...... ...... ២៤៩
ភូរិទត្តចរិយាទី ២ ...... ...... ...... ...... ...... ...... ២៦០
អដ្ឋកថាភូរិទត្តចរិយា ...... ...... ...... ...... ...... ...... ២៦២
ចម្បេយ្យចរិយាទី ៣ ...... ...... ...... ...... ...... ...... ២៨០
អដ្ឋកថាចម្បេយ្យនាគចរិយា ...... ...... ...... ...... ...... ...... ២៨១
ចូឡពោធិចរិយាទី ៤ ...... ...... ...... ...... ...... ...... ២៩២
អដ្ឋកថាចូឡពោធិចរិយា ...... ...... ...... ...... ...... ...... ២៩៤
មហិសរាជចរិយាទី ៥ ...... ...... ...... ...... ...... ...... ៣០៨
អដ្ឋកថាមហិសរាជចរិយា ...... ...... ...... ...... ...... ...... ៣១០
រុរុមិគចរិយាទី ៦ ...... ...... ...... ...... ...... ...... ៣១៧
អដ្ឋកថារុរុមិគរាជចរិយា ...... ...... ...... ...... ...... ...... ៣១៩
មាតង្គចរិយាទី ៧ ...... ...... ...... ...... ...... ...... ៣៣៤
អដ្ឋកថាមាតង្គចរិយា ...... ...... ...... ...... ...... ...... ៣៣៥
ធម្មទេវបុត្តចរិយាទី ៨ ...... ...... ...... ...... ...... ...... ៣៥២
អដ្ឋកថាធម្មទេវបុត្តចរិយា ...... ...... ...... ...... ...... ...... ៣៥៤
ជយទិសចរិយាទី ៩ ...... ...... ...... ...... ...... ...... ៣៦៥

អដ្ឋកថាជយទិសចរិយា ...... ...... ...... ...... ...... ...... ៣៦៧
សន្ធិបាលចរិយាទី ១០ ...... ...... ...... ...... ...... ...... ៣៨១
អដ្ឋកថាសន្ធិបាលចរិយា ...... ...... ...... ...... ...... ...... ៣៨៣

## នេក្ខម្មាធិចារមី

យុធញ្ជយចរិយាទី ១ ...... ...... ...... ...... ...... ...... ៣៩៤
អដ្ឋកថាយុធញ្ជយចរិយា ...... ...... ...... ...... ...... ...... ៣៩៦
សោមនស្សចរិយាទី ២ ...... ...... ...... ...... ...... ...... ៤០៥
អដ្ឋកថាសោមនស្សចរិយា ...... ...... ...... ...... ...... ...... ៤០៨
អយោឃរចរិយាទី ៣ ...... ...... ...... ...... ...... ...... ៤២៦
អដ្ឋកថាអយោឃរចរិយា ...... ...... ...... ...... ...... ...... ៤២៨
ភីសចរិយាទី ៤ ...... ...... ...... ...... ...... ...... ៤៣៦
អដ្ឋកថាភីសចរិយា ...... ...... ...... ...... ...... ...... ៤៣៨
សោណនន្ទបណ្ឌិតចរិយាទី ៥ ...... ...... ...... ...... ...... ...... ៤៥៧
អដ្ឋកថាសោណបណ្ឌិតចរិយា ...... ...... ...... ...... ...... ...... ៤៥៨
មូគផក្ខចរិយាទី ៦ ...... ...... ...... ...... ...... ...... ៤៧០
អដ្ឋកថាមូគផក្ខចរិយា ...... ...... ...... ...... ...... ...... ៤៧៣
កបិលរាជចរិយាទី ៧ ...... ...... ...... ...... ...... ...... ៤៩៦
អដ្ឋកថាកបិលរាជចរិយា ...... ...... ...... ...... ...... ...... ៤៩៧
សច្ចសវ្ហយបណ្ឌិតចរិយាទី ៨ ...... ...... ...... ...... ...... ...... ៥០៣
អដ្ឋកថាសច្ចសវ្ហយបណ្ឌិតចរិយា ......... ...... ...... ...... ...... ៥០៤
វដ្ដកបោតកចរិយាទី ៩ ...... ...... ...... ...... ...... ...... ៥០៧
អដ្ឋកថាវដ្ដកបោតកចរិយា ...... ...... ...... ...... ...... ...... ៥០៩
មច្ឆរាជចរិយាទី ១០ ...... ...... ...... ...... ...... ...... ៥១៦
អដ្ឋកថាមច្ឆរាជចរិយា ...... ...... ...... ...... ...... ...... ៥១៨

កណ្ហទីបាយនចរិយាទី ១១ ...... ...... ...... ...... ...... ...... ៥២៦

អដ្ឋកថាកណ្ហទីបាយនចរិយា ...... ...... ...... ...... ...... ...... ៥២៨

សុតសោមចរិយាទី ១២ ...... ...... ...... ...... ...... ...... ៥៤២

អដ្ឋកថាមហាសុតសោមចរិយា ...... ...... ...... ...... ...... ...... ៥៤៣

សុវណ្ណសាមចរិយាទី ១៣ ...... ...... ...... ...... ...... ...... ៥៦០

អដ្ឋកថាសុវណ្ណសាមចរិយា ...... ...... ...... ...... ...... ...... ៥៦១

ឯកករាជចរិយាទី ១៤ ...... ...... ...... ...... ...... ...... ៥៧១

អដ្ឋកថាឯកករាជចរិយា ...... ...... ...... ...... ...... ...... ៥៧២

មហាលោមហំសចរិយាទី ១៥ ...... ...... ...... ...... ...... ...... ៥៨០

អដ្ឋកថាមហាលោមហំសចរិយា ...... ...... ...... ...... ...... ...... ៥៨៣

អដ្ឋកថាឧទានគាថា ...... ...... ............ ...... ...... ...... ៥៩០

សមោធានកថា ...... ...... ............ ...... ...... ...... ៦០០

អដ្ឋកថាបកិណ្ណកកថា ...... ...... ............ ...... ...... ...... ៦០៣